# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៦៤

បាលីប្រែ ៧៨

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# អដ្ឋសាលិនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

# ធម្មសង្គណី

## បឋមភាគ

# ៦៤

## បាលីប្រែ ៧៨



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៦៤

# ធម្មសង្គណី បឋមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## មាតិកា

[ ១ ] ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌ជាអព្យាក្រឹត ពួកធម៌ប្រកបដោយសុខវេទនា ពួកធម៌ប្រកបដោយទុក្ខវេទនា ពួកធម៌ប្រកបដោយវេទនាមិនជាទុក្ខមិនជាសុខ ពួកធម៌ជាវិបាក ពួកធម៌មានវិបាកជាប្រក្រតី ពួកធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពួកធម៌ដែលមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ដែលសៅហ្មង ទាំងគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ដែលមិនសៅហ្មង តែគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ប្រកបដោយវិតក្កទាំងប្រកបដោយវិចារ ពួកធម៌គ្មានវិតក្ក មានត្រឹមតែវិចារ ពួកធម៌គ្មានវិតក្កទាំងគ្មានវិចារ ពួកធម៌ប្រកបដោយបីតិ ពួកធម៌ប្រកបដោយសុខ ពួកធម៌ប្រកបដោយឧបេក្ខា ពួកធម៌ដែលត្រូវលះដោយទស្សនៈ ពួកធម៌ដែលត្រូវលះដោយភាវនា ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះ

ដោយភាវនា ពួកធម៌មានហេតុ ដែលត្រូវលះដោយទស្សនៈ ពួកធម៌មានហេតុដែលត្រូវលះដោយភាវនា ពួកធម៌មានហេតុ ដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ពួកធម៌ដល់នូវការសន្សំកពូនឡើងដោយកម្មកិលេស ពួកធម៌មិនដល់នូវការសន្សំកពូនឡើង ពួកធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង មិនមែនជាមិនដល់នូវការសន្សំកពូនឡើង ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ពួកធម៌មានសភាពតូចច្មារ ពួកធម៌ដល់នូវសភាពធំ ពួកធម៌ប្រមាណមិនបាន ពួកធម៌មានអា-រម្មណ៍តូចច្មារ ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ដ៏ថោកទាប ពួកធម៌យ៉ាងកណ្ដាល ពួកធម៌ដ៏ឧត្ដម ពួកធម៌មានសភាពខុស និងទៀង ពួកធម៌មានសភាពត្រូវ និងទៀង ពួកធម៌មិនទៀង ពួកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌មានមគ្គជាហេតុ ពួកធម៌មានមគ្គជាអធិបតី ពួកធម៌កើតឡើងហើយ ពួកធម៌មិនទាន់កើតឡើង ពួកធម៌ដែលប្រុងនឹងកើតឡើង ពួកធម៌ជាអតីត ( កន្លងទៅហើយ ) ពួកធម៌ជាអនាគត ( មិនទាន់មកដល់ ) ពួកធម៌ជាបច្ចុប្បន្ន ( កើតឡើងចំពោះមុខ ) ពួកធម៌មានអារម្មណ៍ជាអតីត ពួកធម៌មានអារម្មណ៍ជាអនាគត ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ ពួកធម៌ជាខាងក្នុង និងខាងក្រៅ ពួកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌មានអារម្មណ៍ខាងក្រៅ ពួកធម៌មានអារម្មណ៍ខាងក្នុងនិងខាងក្រៅ ពួកធម៌ប្រកបដោយការ

ឃើញ និងប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ។

**តិកមាតិកា ២២ ចប់**

# អដ្ឋសាលិនី

## អដ្ឋកថា ធម្មសង្គណិ

### សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ

## ពាក្យប្រារព្ធ

ព្រះសម្ពុទ្ធអង្គណា អ្នកស្វែងរកគុណដ៏ធំក្រៃលែង ទ្រង់មានបញ្ញាប្រព្រឹត្តទូទៅ ក្នុងញេយ្យធម៌ទាំងពួង តាមពេញព្រះហឫទ័យ ដូចករុណាដែលផ្សាយទៅក្នុងពួកសត្វ មានព្រះហឫទ័យដែលសេចក្ដីករុណា ក្នុងពួកសត្វនោះឲ្យកើតឡើង កាលគង់ចាំវស្សាក្នុងស្ថានតាវត្តិង្សទេវលោក ក្នុងកាលសម្ដែងយមកប្បាដិហារិយ៍ស្រេចហើយ បានគង់លើសិលាអាសនៈ ឈ្មោះបណ្ឌុកម្ពល ត្រង់គល់បារិច្ឆត្តក ដូចព្រះអាទិត្យលើកំពូលភ្នំយុគន្ធរ ដែលពួកទេវតាទាំងមួយម៉ឺនចក្រវាឡ បានមកអង្គុយប្រជុំចោមរោម ទ្រង់បានធ្វើសន្តុសិតទេវបុត្តដែលជាពុទ្ធមាតា ឲ្យជាប្រធាននៃទេវតាទាំងឡាយ ហើយត្រាស់អភិធម្ម ដោយតេជះនៃបញ្ញានោះ ។

ព្រះសម្មាសម្ពុទ្ធជាទេវតានៃទេវតា ជាអ្នកនាំពួកដ៏វិសេស កាលទ្រង់សម្ដែងព្រះអភិធម្មណា ដល់ទេវតាទាំងឡាយ ហើយក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរដែលជាឧបដ្ឋាករបស់ព្រះមហេសី ត្រង់អនោតត្តស្រះ ដោយន័យសង្ខេបម្ដងទៀត ព្រះថេរៈបានស្ដាប់ព្រះអភិធម្មណា ហើយក៏នាំមកកាន់ផ្ទៃផែនដីប្រាប់ដល់ភិក្ខុទាំងឡាយ ។ ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយទ្រទ្រង់ហើយ ដោយប្រការដូច្នេះ ។ ក្នុងគ្រាធ្វើសង្គាយនា ព្រះអានន្ទត្ថេរ

ជាបណ្ឌិត បានចងក្រងម្តងទៀត ។

អដ្ឋកថាណា នៃព្រះអភិធម្មនោះ ដែលវិចិត្រទៅដោយន័យផ្សេងៗ ដែលបុគ្គលពិចារណារឿយៗ ដោយញាណដ៏ជ្រាលជ្រៅ ដែលឈមចុះបាន ដែលព្រះថេរៈទាំងឡាយអ្នកមានវសី មានព្រះមហាកស្សបៈជាដើមចងក្រងហើយក្នុងខាងដើមមុន ព្រះថេរៈទាំងឡាយអ្នកស្វែងរកគុណធំ ចងក្រងតាមហើយក្នុងកាលជាខាងក្រោយទៀត ។ ម្យ៉ាងទៀត អដ្ឋកថាណា ដែលព្រះមហិន្ទត្ថេរនាំមកកាន់កោះដ៏ឧត្តមនេះ រៀបរៀងដោយភាសានៃអ្នកកោះ ។

ខ្ញុំដែលភិក្ខុឈ្មោះពុទ្ធឃោសៈ មានអាចារៈ និងសីលបរិសុទ្ធ មានបញ្ញាមុតស្រួច ប្រាសចាកមន្ទិល អារាធនាដោយគោរពក្រៃលែងហើយ ទើបនមស្ការយុគលបាទរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់មានសិរីអង្គនោះ បូជាព្រះសទ្ធម្មរបស់ព្រះពុទ្ធអង្គនោះ និងធ្វើអញ្ជលីចំពោះព្រះសង្ឃ ធ្វើអន្តរាយឲ្យអស់ទៅដោយមិនសេសសល់ ដោយអានុភាពនៃការនមស្ការក្នុងព្រះរតន-ត្រ័យដែលធ្វើហើយនេះ និងនាំអដ្ឋកថានោះ ចេញចាកភាសានៃអ្នកកោះតម្ពបណ្ណិ ហើយលើកឡើងកាន់ភាសាដែលមិនមានពាក្យតិះដៀល តាមន័យតន្តិភាសា មិនឲ្យលាយឡំដោយលទ្ធិនិកាយដទៃ សម្តែងតាមពាក្យវិនិច្ឆ័យរបស់ភិក្ខុដែលនៅក្នុងមហាវិហារ កាន់យកវត្ថុដែលគួរកាន់យក ធ្វើបុគ្គលដែលមានបញ្ញាឲ្យត្រេកអរ ហើយប្រកាសអត្ថ ក្នុងគម្ពីរអដ្ឋកថាទាំងឡាយក៏ព្រោះហេតុដែលកម្មដ្ឋានទាំងពួង ចរិយា អភិញ្ញា និងវិបស្សនាទាំងអស់នេះ ខ្ញុំប្រកាសទុកក្នុងវិសុទ្ធិមគ្គហើយ ហេតុនោះ មិនកាន់យកកម្មដ្ឋានជា

ដើមតាមបែបទាំងអស់ និងធ្វើការពណ៌នាតាមលំដាប់បទទាំងឡាយប៉ុណ្ណោះ កាលខ្ញុំពោលនូវព្រះអភិធម្មកថានេះ ដោយប្រការដូច្នេះ សូមសាធុជនទាំងឡាយ កុំមានចិត្តរាយមាយ ចូរតាំងចិត្តស្តាប់ ព្រោះថា កថានេះ រកបានដោយក្រនោះឯង ។

## ពាក្យប្រារព្ធ ចប់

# និទានកថា

បណ្តាពាក្យទាំងនោះ ពាក្យថា **អភិធម្ម** សួរថា ឈ្មោះថា **អភិធម្ម** ព្រោះអត្ថដូចម្តេច ។ ឆ្លើយថា ព្រោះអត្ថថា ជាធម៌ដ៏ក្រៃលែង និងវិសេស ។ ពិតហើយ **អភិ** សព្ទ ក្នុងពាក្យថា **អភិធម្ម** នេះ សម្តែងដល់សេចក្តីថា ក្រៃលែង និងវិសេស ដូចក្នុងប្រយោគជាដើមថា **ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ** ទុក្ខវេទនាជាទម្ងន់ ចម្រើនឡើងដល់ខ្ញុំព្រះអង្គ មិនធូរថយទេ ដូច្នេះ និងពុទ្ធដីកាមួយកន្លែងទៀតថា **អភិក្កន្តវណ្ណា** មានរស្មីរុងរឿង ដូច្នេះ ព្រោះហេតុនោះ ទើបពោលថា ប្រៀបដូចកាលឆត្រ និងទង់ជាច្រើនត្រូវលើកឡើងហើយ ឆត្រណាមានប្រមាណក្រៃលែង មានពណ៌សម្បុរ និងសណ្ឋានដែលវិសេសជាងឆត្រដទៃ ឆត្រនោះ ឈ្មោះថា **អតិច្ឆត្ត** ទង់ណាមានប្រមាណក្រៃលែង សម្បុរដោយភាពវិសេសនៃពណ៌ ដែលជ្រលក់ហើយផ្សេងៗ នុ៎ះឯង ទង់នោះ ហៅថា **អតិធជោ** និងប្រៀបដូចកាលពួករាជកុមារ និងពួកទេវតារួមប្រជុំគ្នាហើយ រាជកុមារណាក្រៃលែងជាងដោយសម្បត្តិ មានជាតិ ភោគៈ យស និងភាពជាធំជាដើម និងមានឆវីវណ្ណវិសេសជាង ព្រះរាជកុមារនោះ ហៅថា **អតិរាជកុមារ** ទេវតាណាក្រៃលែងជាងដោយអាយុ វណ្ណៈ ឥស្សរិយៈ យស និងសម្បត្តិជាដើម និងមានឆវីវណ្ណវិសេសជាង ទេវតានោះ គេហៅថា **អតិទេវ** សូម្បីព្រហ្មដែលមានលក្ខណៈដូច្នោះ គេក៏ហៅថា **អតិព្រហ្ម** យ៉ាងណា សូម្បីធម៌នេះ ក៏យ៉ាងនោះដូចគ្នា ហៅថា **អភិធម្ម** ព្រោះអត្ថថា ជាធម៌ដ៏ក្រៃលែង និងវិសេស ។

ពិតហើយ តាមគន្លងព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់ចែកខន្ធ ៥ ដោយឯកទេសប៉ុណ្ណោះ ទ្រង់មិនបានចែកដោយនិប្បទេស ( មិនសេសសល់ ) តែតាមគន្លងព្រះអភិធម្មហើយ ព្រះអង្គទ្រង់ចែកដោយមិនសេសសល់ ដោយអំណាចនៃសុត្តន្តភាជនីយន័យ អភិធម្មភាជនីយន័យ និងបញ្ហាបុច្ឆកន័យ ។ ម្យ៉ាងទៀត អាយតនៈ ១២ ធាតុ ១៨ សច្ចៈ ៤ ឥន្ទ្រិយ ២២ និងបច្ចយាការ ដែលសម្តែងដល់អង្គ ១២ ក៏ត្រាស់ដោយមិនសេសសល់ ដូចគ្នា តាមពិត សុត្តន្តភាជនីយ ក្នុងឥន្ទ្រិយវិភង្គ និងបញ្ហាបុច្ឆកៈ ក្នុងបច្ចយាការ មិនមានឡើយ ពិតយ៉ាងនោះ តាមគន្លងព្រះសូត្រហើយ សតិប្បដ្ឋាន ៤ ព្រះអង្គទ្រង់ចែកដោយឯកទេសប៉ុណ្ណោះ មិនបានចែកដោយមិនសេសសល់ តែតាមគន្លងព្រះអភិធម្មហើយ ទ្រង់ចែកដោយមិនសេសសល់ តាមន័យទាំង ៣ ។ សូម្បីសម្មប្បធាន ៤ ឥទ្ធិបាទ ៤ សម្ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ ឈាន ៤ អប្បមញ្ញា ៤ សិក្ខាបទ ៥ បដិសម្ភិទា ៤ ក៏ទ្រង់ចែកដោយមិនសេសសល់ តាមន័យទាំង ៣ ដូចគ្នា តែក្នុងធម៌ទាំងនេះ សុត្តន្តភាជនីយ ក្នុងសិក្ខាបទវិភង្គតែម្យ៉ាងមិនមាន ។ តាមគន្លងព្រះសូត្រហើយ ញាណ ព្រះអង្គក៏ទ្រង់ចែកដោយឯកទេសប៉ុណ្ណោះ មិនចែកដោយមិនសេសសល់ ។ កិលេសទាំងឡាយ ក៏ដូចគ្នា ។ តែតាមគន្លងព្រះអភិធម្មហើយ ទ្រង់តាំងមាតិកាដោយន័យប្រភេទមួយ មានញាណវត្ថុជាដើម ហើយចែកដោយមិនសេសសល់ ។ កិលេសទាំងឡាយ ក៏ដូចគ្នា ទ្រង់ចែកដោយន័យមិនមែនតិច ចាប់ផ្តើមអំពីធម៌ពួក ១ ។ តែ

តាមគន្លងព្រះសូត្រ ការកំណត់ភូមិដទៃ ក៏ទ្រង់ចែកដោយឯកទេសនុ៎ះឯង មិនចែកដោយមិនសេសសល់ ។ តាមគន្លងព្រះអភិធម្មហើយ ទ្រង់កំណត់ភូមិដទៃដោយន័យទាំង ៣ និងទ្រង់បញ្ញត្តដោយមិនសេសសល់ ។

ឈ្មោះថា **អភិធម្ម** ព្រោះអត្ថថា ជាធម៌ដ៏ក្រៃលែង និងវិសេស ដោយប្រការដូច្នេះ ។

ពោលដោយការកំណត់បករណ៍ព្រះអភិធម្មនេះ ទ្រង់តាំងជា ៧ បករណ៍ គឺធម្មសង្គណិបករណ៍ ១ វិភង្គប្បករណ៍ ១ ធាតុកថាបករណ៍ ១ បុគ្គលប្បញ្ញត្តិប្បករណ៍ ១ កថាវត្ថុប្បករណ៍ ១ យមកប្បករណ៍ ១ បដ្ឋានប្បករណ៍ ១ ។

នេះជាកថាដែលដូចគ្នារបស់អាចារ្យទាំងឡាយ ក្នុងអដ្ឋកថានេះ ។ ចំណែកអាចារ្យវិតណ្ឌវាទី ( អ្នកពោលជំទាស់ ) ពោលថា ព្រោះហេតុអ្វី ទើបកាន់យកកថាវត្ថុផង កថាវត្ថុនោះ ព្រះមោគ្គលិបុត្តតិស្សត្ថេរតាំងទុក កាលព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ ២១៨ ឆ្នាំ មិនមែនឬ ។ ហេតុនោះ សូមឲ្យកាត់កថាវត្ថុនោះចេញ ព្រោះជាសាវកភាសិត ដូច្នេះ ។

**សកវាទី** សួរថា បករណ៍ ៦ នឹងជាព្រះអភិធម្មបានឬ ។

**បរវាទី** ឆ្លើយថា ខ្ញុំមិនបានពោលយ៉ាងនោះ ។

**សកវាទី** សួរថា បើដូច្នោះ លោកពោលដូចម្ដេច ។

**បរវាទី** ឆ្លើយថា ខ្ញុំពោលថា បករណ៍ ៧ ឈ្មោះថា អភិធម្ម ។

**សកវាទី** សួរថា លោកយកបករណ៍ណា មកជាបករណ៍ទី ៧ ។

**បរវាទី** ឆ្លើយថា បករណ៍ឈ្មោះថា មហាធម្មហទយៈ មាន រួមជាមួយ មហាធម្មហទយៈនោះ ទើបជា ៧ បករណ៍ ។

**សកវាទី** ពោលថា ក្នុងមហាធម្មហទយបករណ៍ មិនមានអ្វីដែលមិនធ្លាប់ពោលហើយ ( គឺមិនមានអ្វីថ្មី ) និងបញ្ហាវារៈដ៏សេស ក៏មានតិចតួច ព្រោះហេតុនោះ រួមជាមួយកថាវត្ថុ ទើបជា ៧ បករណ៍ ។

**បរវាទី** ឆ្លើយថា មិនមែន ៧ ទាំងកថាវត្ថុបករណ៍ ឈ្មោះថា មហាធាតុកថា មាន រួមជាមួយមហាធាតុកថានោះ ទើបជា ៧ បករណ៍ ។

**សកវាទី** សួរថា ក្នុងមហាធម្មហទយប្បករណ៍ មាន បញ្ហាវារៈដ៏សេសតិចតួចប៉ុណ្ណោះ ទាំងក្នុងមហាធាតុកថា ក៏មិនមានអ្វីថ្មីឡើយ មានតន្តិ គឺបែបផែននៃពាក្យត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះសល់នៅ រួមជាមួយកថាវត្ថុនោះឯង ទើបជា ៧ បករណ៍ ។

ពិតហើយ ព្រះសម្មាសម្ពុទ្ធ កាលទ្រង់សម្តែងនូវបករណ៍នៃអភិធម្ម ៧ ( សត្តប្បករណ៍ ) លុះដល់កថាវត្ថុ ក៏ទ្រង់តាំងមាតិកានៃបាលី មានប្រមាណមួយភាណវារ ដែលនៅមិនពេញក្នុងកថាមគ្គទាំងពួង ផ្តើមសេចក្តីល្មមសមគួរដល់ការប្រកបវាទៈដែលជាប្រធាន ៨ មាតិកា ដោយអំណាច ២ បញ្ចកៈ គឺអនុលោមបញ្ចកៈ ១ បច្ចនិកបញ្ចកៈ ១ ក្នុងបញ្ហា ៤ ក្នុងបុគ្គលវាទមុន ។

បែបផែននេះ ព្រះសាស្តាទ្រង់អាស្រ័យវាទៈទីមួយ សម្តែងនិគ្គហៈទី ១

ទ្រង់អាស្រ័យវាទៈទី ២ សម្តែងនិគ្គហៈទី ២ ។បេ។ ទ្រង់អាស្រ័យវាទៈទី ៨ សម្តែងនិគ្គហៈទី ៨ គឺទ្រង់តាំងមាតិកាយ៉ាងនេះថា

**សកវាទី** សួរថា បុគ្គលគេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។

**បរវាទី** ឆ្លើយថា អើ ។

**សកវាទី** សួរថា បុគ្គលណាមានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។

**បរវាទី** ឆ្លើយថា អ្នកមិនគួរពោលយ៉ាងនេះទេ ។

**សកវាទី** ពោលថា ចូរអ្នកដឹងនូវកំហុសចុះ ។បេ។

បុគ្គលគេមិនដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អ្នកមិនត្រូវពោលយ៉ាងនេះទេ ។ ចូរអ្នកដឹងនូវកំហុសចុះ ។បេ។ បុគ្គលគេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមក្នុងទីទាំងពួងឬ បុគ្គលគេមិនដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមក្នុងទីទាំងពួងឬ ។ បុគ្គលគេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមក្នុងកាលទាំងពួងឬ បុគ្គលគេមិនដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងឬ ។ បុគ្គលគេមិនដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងឬ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួង ដូច្នេះដែរ[1] ។

---

១-សេចក្តីពិស្តារ សូមមើលក្នុងបិដកខ្មែរលេខ ៨៤ ចាប់ពីឃ្នាបទី ១ ដល់ឃ្នាបទី ១៦ ។

*គប្បីជ្រាបការតាំងមាតិកាក្នុងបាលីទាំងពួង ដោយន័យនេះ កាលទ្រង់តាំងមាតិកានេះ ទ្រង់ឃើញហេតុនេះឯង ទើបទ្រង់តាំងទុក ។*

*ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា កាលតថាគតបរិនិព្វានកន្លងទៅបាន ២១៨ ឆ្នាំ ព្រះថេរៈមានឈ្មោះថា មោគ្គលិបុត្តតិស្សត្ថេរ នឹងអង្គុយក្នុងកណ្ដាលភិក្ខុមួយពាន់ ប្រមូលព្រះសូត្រមកមួយពាន់ គឺព្រះសូត្រ ៥០០ សូត្រ ក្នុងផ្នែកសកវាទី ព្រះសូត្រ ៥០០ សូត្រ ក្នុងផ្នែកបរវាទី ហើយនឹងចែកកថាវត្ថុប្បករណ៍ មានប្រមាណស្មើនឹងទីឃនិកាយ ។*

*សូម្បីព្រះមោគ្គលិបុត្តតិស្សត្ថេរ កាលនឹងសម្ដែងបករណ៍នេះ មិនបានសម្ដែងដោយញាណរបស់ខ្លួន តែសម្ដែងតាមមាតិកាដែលតាំងទុកដោយន័យដែលព្រះសាស្ដាទ្រង់ប្រទាន ។ ហេតុនោះ ទើបបករណ៍នេះទាំងអស់ឈ្មោះថា ជាពុទ្ធភាសិតដូចគ្នា ព្រោះព្រះថេរៈសម្ដែងតាមមាតិកាដែលតាំងទុកដោយន័យដែលព្រះសាស្ដាទ្រង់ប្រទាន ដូចអ្វី ដូចមធុបិណ្ឌិកសូត្រជាដើម ។*

*ពិតហើយ ក្នុងមធុបិណ្ឌិកសូត្រ ព្រះមានព្រះភាគ ទ្រង់តាំងមាតិកា ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ សេចក្ដីដែលបុគ្គលគប្បីត្រេកអរ គប្បីពោល គប្បីប្រកាន់ ( ថាអញ ថាយើង ) បើមិនមានក្នុងសភាវៈនោះទេ សេចក្ដីមិនត្រេកអរជាដើមនោះឯង ហៅថាទីបំផុតនៃរាគានុស័យ ដូច្នេះហើយ ទ្រង់ក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ។*

ភិក្ខុទាំងឡាយ ទទួលព្រះធម្មទេសនា ចូលទៅរក ព្រះមហាកច្ចានត្ថេរ ហើយសាកសួរសេចក្ដីនៃមាតិកាដែលព្រះសាស្ដា ទ្រង់តាំងទុកហើយ ព្រះថេរៈមិនពោលវិសជ្ជនាត្រឹមតែពាក្យត្រូវសួរប៉ុណ្ណោះ ដើម្បីនឹងសម្ដែងភាពឱនលំទោនចំពោះព្រះទសពល ទើបនាំការប្រៀបធៀបដូចខ្លឹមឈើ មកសម្ដែងថា ម្នាលអាវុសោ ដូចបុរសជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើដូច្នេះហើយ សរសើរព្រះសាស្ដាថា ព្រះមានព្រះភាគ ប្រៀបដូចដើមឈើដែលមានខ្លឹម សាវកដូចមែកឈើ និងស្លឹកឈើ ម្នាលអាវុសោ ព្រោះថាព្រះមានព្រះភាគនោះ តែងទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតនោះ មានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌មិនវិបរិតកើតហើយ ព្រះអង្គជាបុរសដ៏ប្រសើរ ព្រះអង្គជាអ្នកពោលនូវធម៌ អ្នកប្រាប់នូវធម៌ អ្នកបង្អោននូវប្រយោជន៍ អ្នកឲ្យនូវសេចក្ដីប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានឈ្មោះអមតៈ ជាម្ចាស់នៃធម៌ កាលនេះ ជាកាលគួរដល់ព្រះតថាគតនុ៎ះហើយ ដូច្នេះ ព្រះថេរៈទាំងឡាយអង្វរហើយរឿយៗ ទើបចែកសេចក្ដីនៃមាតិកា តាមដែលព្រះសាស្ដាទ្រង់តាំងទុក ដោយបំណងនេះថា តែថា បើលោកដ៏មានអាយុទាំងឡាយចង់ដឹង ( សេចក្ដីនេះឲ្យច្បាស់លាស់ ) គប្បីនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ ហើយសាកសួរសេចក្ដីនេះចុះ បើប្រៀបធៀបគ្នាបាននឹងព្រះសព្វញ្ញុតញ្ញាណ ក៏គប្បីកាន់យក បើប្រៀបធៀបគ្នាមិនបានក៏កុំកាន់យក ដូច្នេះហើយ ពោលថា ( បើ ) ព្រះមានព្រះភាគនៃយើង ទ្រង់សម្ដែងយ៉ាងណា យើងទាំង

ទ្បាយគប្បីចាំទុកនូវឧទ្ទេសនោះ ដូច្នោះហើយ បញ្ជូនភិក្ខុទាំងនោះទៅ ។

ពួកភិក្ខុទាំងនោះ ចូលទៅគាល់ព្រះសាស្ដា ហើយទូលសួរសេចក្ដីនោះ ព្រះសាស្ដាមិនត្រាស់ថា កច្ចានៈពោលមិនល្អ ទ្រង់បង្អោនព្រះសូរង៍ទៅ ដូចទ្រង់លើកព្រះសុវណ្ណភិង្ការ ( ផ្តាំងទឹកត្រជាក់ធ្វើពីមាស ) ឡើង កាល ញាំងមុខព្រះថេរៈឲ្យពេញ ធ្វើឲ្យមានមុខធំ ដូចផ្កាឈូកមួយរយស្រទាប់ ដែលរីកល្អហើយ ដ៏មានសិរី ទើបទ្រង់បន្លឺព្រះសូរសៀងដូចសំឡេងព្រហ្ម ប្រទានសាធុការដល់ព្រះថេរៈថា សាធុ សាធុ ហើយត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ មហាកច្ចានៈ ( នេះ ) ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ( នេះ ) ជាអ្នកមានប្រាជ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ទុកជា អ្នកទាំងឡាយ សាកសួរសេចក្ដីនេះនឹងតថាគត តថាគត ក៏គង់តែព្យាករ សេចក្ដីនោះយ៉ាងហ្នឹងដែរ ដូច្នេះ ។

ចាប់តាំងអំពីកាលដែលព្រះសាស្ដាទ្រង់អនុមោទនាហើយយ៉ាងនេះ ព្រះ សូត្រទាំងមូល ឈ្មោះថា ជាពុទ្ធភាសិត ។ សូម្បីព្រះសូត្រ ដែលព្រះ អានន្ទត្ថេរជាដើម ឲ្យពិស្ដារហើយ ក៏ន័យនេះដូចគ្នា ។ ព្រះសម្មាសម្ពុទ្ធ កាលទ្រង់សម្ដែងអភិធម្មប្បករណ៍ ៧ លុះដល់កថាវត្ថុ ទ្រង់ក៏តាំងមាតិកា ដោយន័យដែលពោលហើយ ។ មួយទៀត កាលទ្រង់តាំង ទ្រង់បាន ឃើញហេតុនេះថា កាលតថាគតបរិនិព្វានកន្លងទៅហើយ ២១៨ ឆ្នាំ ភិក្ខុ មានឈ្មោះថា មោគ្គលិបុត្តតិស្សត្ថេរ អង្គុយក្នុងកណ្ដាលជំនុំភិក្ខុមួយពាន់ រូប ហើយនឹងប្រមូលព្រះសូត្រមួយពាន់សូត្រ គឺក្នុងសកវាទីប្រាំរយសូត្រ

ក្នុងបរវាទីប្រាំរយសូត្រ ហើយចែកកថាវត្ថុប្បករណ៍ មានប្រមាណស្មើនឹងទីឃនិកាយ ។ សូម្បីព្រះមោគ្គលិបុត្តតិស្សត្ថេរ កាលនឹងសម្តែងបករណ៍នេះ ក៏មិនសម្តែងដោយចំណេះដឹងរបស់ខ្លួន តែសម្តែងតាមមាតិកា ដែលតាំងទុកដោយន័យដែលព្រះសាស្តាទ្រង់ប្រទាន ព្រោះហេតុនោះ ទើបបករណ៍ទាំងអស់នេះ ឈ្មោះថា ជាពុទ្ធភាសិតដោយពិត ព្រោះព្រះថេរៈសម្តែងតាមមាតិកាដែលតាំងទុកតាមន័យដែលព្រះសាស្តាទ្រង់ប្រទានហើយ ។ បករណ៍ទាំង ៧ រួមទាំងកថាវត្ថុ ទើបឈ្មោះថា អភិធម្ម ដោយប្រការដូច្នេះ ។

បណ្តាបករណ៍ទាំង ៧ នេះ ក្នុងបករណ៍ធម្មសង្គណិ មានវិភត្តិ ៤ គឺ ចិត្តវិភត្តិ ( ការចែកចិត្ត ) ១ រូបវិភត្តិ ( ការចែករូប ) ១ បនិក្ខេបរាសិ ( ការចែកពួកធម៌ដែលតាំងទុក ) ១ អត្ថុទ្ធារ ( ការលើកអត្ថឡើងសម្តែង ) ១ ។

បណ្តាការចែកធម៌ទាំង ៤ នោះ ចិត្ត ៨៩ គឺកាមាវចរកុសលចិត្ត ៨ អកុសលចិត្ត ១២ កុសលវិបាកចិត្ត ១៦ អកុសលវិបាកចិត្ត ៧ កិរិយាចិត្ត ១១ រូបាវចរកុសលចិត្ត ៥ រូបាវចរវិបាកចិត្ត ៥ រូបាវចរកិរិយាចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ អរូបាវចរវិបាកចិត្ត ៤ អរូបាវចរកិរិយាចិត្ត ៤ លោកុត្តរកុសលចិត្ត ៤ លោកុត្តរវិបាកចិត្ត ៤ ឈ្មោះថា **ចិត្តវិភត្តិ** ។ សូម្បីពាក្យថា **ចិត្តុប្បាទកណ្ឌ** ក៏ជាឈ្មោះរបស់ចិត្តវិភត្តិនេះដូចគ្នា ចិត្តនោះពោលដោយផ្លូវនៃពាក្យនិយាយ មាន ៦ ភាណវារជាង តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

ក្នុងលំដាប់តពីចិត្តវិភត្តិនោះ ការចែកដែលព្រះមានព្រះភាគ ទ្រង់តាំងមាតិកាដោយន័យជាដើមថា ធម៌ពួកមួយ ធម៌ពួកពីរ ហើយទ្រង់ចែកសម្តែងដោយពិស្តារ ឈ្មោះថា **រូបវិភត្តិ** សូម្បីពាក្យថា **រូបកណ្ឌ** ក៏ជាឈ្មោះរបស់រូបវិភត្តិនោះឯង រូបកណ្ឌនោះ ពោលដោយផ្លូវនៃពាក្យនិយាយមាន ២ ភាណវារជាង តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

ក្នុងលំដាប់តអំពីរូបវិភត្តិនោះ គំនរធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងសរុបដោយមូលជាដើមយ៉ាងនេះ គឺដោយមូល ដោយខន្ធ ដោយទ្វារ ដោយភូមិ ដោយអត្ថ ដោយធម៌ ដោយនាម ដោយលិង្គ ឈ្មោះថា **និក្ខេបរាសិ** ។

ដែលហៅថា និក្ខេប ព្រោះព្រះអង្គទ្រង់សម្តែងសរុបដោយ
មូលខ្លះ ដោយខន្ធខ្លះ ដោយទ្វារខ្លះ ដោយភូមិខ្លះ ដោយ
អត្ថខ្លះ ដោយធម៌ខ្លះ ដោយនាមខ្លះ ដោយលិង្គខ្លះ ។

សូម្បីពាក្យថា **និក្ខេបកណ្ឌ** ក៏ជាឈ្មោះរបស់និក្ខេបរាសិនុ៎ះឯង និក្ខេបកណ្ឌនោះ ពោលដោយផ្លូវនៃវាចាក៏មានប្រមាណ ៣ ភាណវារ កាលឲ្យពិស្តារ រមែងមិនមានទីបំផុត មិនមានប្រមាណ ។

ក្នុងលំដាប់តពីនិក្ខេបរាសិនោះ កណ្ឌដែលលើកអត្ថនៃពុទ្ធវចនៈ គឺព្រះត្រៃបិដកឡើងសម្តែងសរុបទុក រហូតដល់សរណទុកៈ ក្នុងសម័យដែលពួកភិក្ខុអ្នករៀនមហាបករណ៍ កំណត់ដល់ចំនួនក្នុងមហាបករណ៍មិនបាន រមែង

រួមចំនួនទុក ឈ្មោះថា អដ្ឋកថាកណ្ឌ ។ អដ្ឋកថាកណ្ឌនោះ ពោលដោយគន្ថនៃវាចា មានប្រមាណ ២ ភាណវារ តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

ធម្មសង្គណិបករណ៍ទាំងអស់ រមែងមានដោយប្រការដូច្នេះ ធម្មសង្គណិបករណ៍នោះ ពោលដោយគន្ថនៃវាចា មាន ១៣ ភាណវារជាង តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

ធម្មសង្គណិបករណ៍ គឺចិត្តវិភត្តិ រូបវិភត្តិ និក្ខេបកណ្ឌ និង
អត្ថជោតនា ( អដ្ឋកថាកណ្ឌ ) នេះ មានអត្ថជ្រាលជ្រៅ
ល្អិតសុខុម សូម្បីឋានៈនេះ ព្រះអង្គក៏ទ្រង់សម្តែងហើយ
ដោយប្រការដូច្នេះ ។

ក្នុងលំដាប់តពីធម្មសង្គណិបករណ៍នោះ ជាវិភង្គប្បករណ៍ វិភង្គប្បករណ៍នោះ ព្រះមានព្រះភាគ ទ្រង់ចែកទុក ១៨ យ៉ាង គឺខន្ធវិភង្គ ១ អាយតនវិភង្គ ១ ធាតុវិភង្គ ១ សច្ចវិភង្គ ១ ឥន្ទ្រិយវិភង្គ ១ បច្ចយាការវិភង្គ ១ សតិប្បដ្ឋានវិភង្គ ១ សម្មប្បធានវិភង្គ ១ ឥទ្ធិបាទវិភង្គ ១ ពោជ្ឈង្គវិភង្គ ១ មគ្គវិភង្គ ១ ឈានវិភង្គ ១ អប្បមញ្ញាវិភង្គ ១ សិក្ខាបទវិភង្គ ១ បដិសម្ភិទាវិភង្គ ១ ញាណវិភង្គ ១ ខុទ្ទកវត្ថុវិភង្គ ១ ធម្មហទយវិភង្គ ១ ។

បណ្តាវិភង្គទាំងនោះ ខន្ធវិភង្គចែកចេញជា ៣ យ៉ាង គឺសុត្តន្តភាជនីយ អភិធម្មភាជនីយ និងបញ្ហាបុច្ឆក ខន្ធវិភង្គនោះពោលដោយគន្ថនៃពាក្យមាន

ប្រមាណ ៥ ភាណវារ តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។ ខាងមុខអំពីនេះ អាយតនវិភង្គជាដើម ទ្រង់ក៏ចែកដោយន័យទាំង ៣ នោះដូចគ្នា បណ្តាវិភង្គទាំងនោះ អាយតនវិភង្គ ពោលដោយគន្ធងនៃពាក្យ មាន ១ ភាណវារជាង ធាតុវិភង្គ មានប្រមាណ ២ ភាណវារ សច្ចវិភង្គក៏មានប្រមាណ ២ ភាណវារដូចគ្នា ក្នុងឥន្ទ្រិយវិភង្គ មិនមានសុត្តន្តភាជនីយ ឥន្ទ្រិយវិភង្គនោះ ពោលដោយគន្ធងនៃពាក្យមានប្រមាណ ១ ភាណវារជាង បច្ចយាការវិភង្គ មានប្រមាណ ៦ ភាណវារ តែក្នុងបច្ចយាការវិភង្គនេះ មិនមានបញ្ហាបុច្ឆកៈ ។ សតិប្បដ្ឋានវិភង្គ មានប្រមាណ ១ ភាណវារជាង សម្មប្បធាន ... ឥទ្ធិបាទ ... ពោជ្ឈង្គ ... និងមគ្គវិភង្គមួយវិភង្គៗ មាន ១ ភាណវារជាង ។ ឈានវិភង្គ មានប្រមាណ ២ ភាណវារ អប្បមញ្ញាវិភង្គ មានប្រមាណ ១ ភាណវារជាង ក្នុងសិក្ខា-បទវិភង្គ មិនមានសុត្តន្តភាជនីយ តែសិក្ខាបទវិភង្គនោះ ពោលដោយគន្ធងនៃពាក្យ មាន ១ ភាណវារជាង បដិសម្ភិទាវិភង្គ ក៏មានប្រមាណ ១ ភាណវារជាង ញាណវិភង្គ ចែកចេញ ១០ យ៉ាង តែញាណវិភង្គនោះកាលពោលដោយគន្ធងនៃពាក្យ មានប្រមាណ ៣ ភាណវារ សូម្បីខុទ្ទកវត្ថុវិភង្គ ក៏ចែកទុក ១០ យ៉ាង តែពោលដោយគន្ធងនៃពាក្យ មានប្រមាណ ៣ ភាណវារ ធម្មហទយវិភង្គ ចែកទុក ៣ យ៉ាង ពោលដោយគន្ធងនៃពាក្យមានប្រមាណ ២ ភាណវារជាង វិភង្គសូម្បីទាំងអស់កាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ បករណ៍ ឈ្មោះថា

វិកប្បករណ៍នេះ កាលពោលដោយគន្លងនៃពាក្យ មានប្រមាណ ៣៥ ភាណវារ តែកាលឲ្យពិស្តារ រមែងមិនមានទីបំផុត មិនមានប្រមាណ ដោយប្រការដូច្នេះ ។

ក្នុងលំដាប់តអំពីវិកប្បករណ៍នោះ ជាធាតុកថាបករណ៍ ។ ធាតុកថាបករណ៍នោះ ទ្រង់ចែកទុក ១៤ យ៉ាង គឺធម៌ដែលសង្គ្រោះបាន ធម៌ដែលសង្គ្រោះមិនបាន ១ ធម៌ដែលសង្គ្រោះមិនបាន ដោយធម៌ដែលសង្គ្រោះបាន ១ ធម៌ដែលសង្គ្រោះបាន ដោយធម៌ដែលសង្គ្រោះមិនបាន ១ ធម៌ដែលសង្គ្រោះបានដោយធម៌ដែលសង្គ្រោះបាន ១ ធម៌ដែលសង្គ្រោះមិនបានដោយធម៌ដែលសង្គ្រោះមិនបាន ១ ធម៌ដែលប្រកបបាន ធម៌ដែលមិនប្រកបបាន ១ ធម៌ដែលប្រកបមិនបាន ដោយធម៌ដែលប្រកបបាន ១ ធម៌ដែលប្រកបបានដោយធម៌ដែលប្រកបមិនបាន ១ ធម៌ដែលប្រកបបានដោយធម៌ដែលប្រកបបាន ១ ធម៌ដែលប្រកបមិនបាន ដោយធម៌ដែលប្រកបមិនបាន ១ ធម៌ដែលប្រកបបាន ធម៌ដែលប្រកបមិនបាន ដោយធម៌ដែលសង្គ្រោះបាន ១ ធម៌ដែលសង្គ្រោះបាន ធម៌ដែលសង្គ្រោះមិនបាន ដោយធម៌ដែលប្រកបបាន ១ ធម៌ដែលប្រកបបាន ធម៌ដែលប្រកបមិនបាន ដោយធម៌ដែលសង្គ្រោះមិនបាន ១ ធម៌ដែលសង្គ្រោះបាន ធម៌ដែលសង្គ្រោះមិនបាន ដោយធម៌ដែលប្រកបមិនបាន ១ ។

ធាតុកថាបករណ៍នោះ ពោលដោយគន្លងនៃពាក្យ មានប្រមាណ ៦ ភាណវារជាង តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

ក្នុងលំដាប់តអំពីធាតុកថាបករណ៍នោះ ជាបុគ្គលបញ្ញត្តិ ។ បុគ្គលបញ្ញត្តិនោះ ទ្រង់ចែកទុក ៦ យ៉ាង គឺខន្ធបញ្ញត្តិ ១ អាយតនបញ្ញត្តិ ១ ធាតុបញ្ញត្តិ ១ សច្ចបញ្ញត្តិ ១ ឥន្ទ្រិយបញ្ញត្តិ ១ បុគ្គលបញ្ញត្តិ ១ ។

បុគ្គលបញ្ញត្តិនោះ ពោលដោយគន្ធនៃពាក្យ មាន ៥ ភាណវារជាង តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណដូចគ្នា ។

ក្នុងលំដាប់តអំពីបុគ្គលបញ្ញត្តិប្បករណ៍ ជាកថាវត្ថុប្បករណ៍ ។ កថាវត្ថុប្បករណ៍នោះ ទ្រង់ប្រមូលចែកទុកមួយពាន់សូត្រ គឺក្នុងសកវាទៈ ៥០០ សូត្រ ក្នុងបរវាទៈ ៥០០ សូត្រ កថាវត្ថុប្បករណ៍នោះ ពោលដោយគន្ធនៃពាក្យ មិនកាន់យកពាក្យដែលកត់ត្រាទុកក្នុងកោដ្ឋកៈ ក្នុងឥឡូវនេះ មានប្រមាណស្មើនឹងទីឃនិកាយ ដោយន័យដែលលើកឡើងកាន់សង្គីតិ តែកាលឲ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

ក្នុងលំដាប់តអំពីកថាវត្ថុប្បករណ៍នោះ ជាយមកប្បករណ៍ ។ យមកប្បករណ៍នោះ ទ្រង់ចែកទុក ១០ យ៉ាង គឺមូលយមក ១ ខន្ធយមក ១ អាយតនយមក ១ ធាតុយមក ១ សច្ចយមក ១ សង្ខារយមក ១ អនុសយយមក ១ ចិត្តយមក ១ ធម្មយមក ១ ឥន្ទ្រិយយមក ១ ។

យមកប្បករណ៍នោះ ពោលដោយគន្ធនៃពាក្យ មានប្រមាណ ១២០ ភាណវារ កាលពោលដោយពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

ក្នុងលំដាប់នៃយមកប្បករណ៍នោះ ជាមហាបករណ៍ ។ សូម្បីពាក្យថា បដ្ឋាន ក៏ជាឈ្មោះរបស់មហាបករណ៍នោះឯង ។ មហាបករណ៍នោះ ខាង

ដើមទ្រង់ចែកទុក ២៤ យ៉ាង ដោយអំណាចនៃបច្ច័យ គឺហេតុប្បច្ច័យ ១ អារម្មណប្បច្ច័យ ១ អធិបតិប្បច្ច័យ ១ អនន្តរប្បច្ច័យ ១ សមនន្តរប្បច្ច័យ ១ សហជាតប្បច្ច័យ ១ អញ្ញមញ្ញប្បច្ច័យ ១ និស្សយប្បច្ច័យ ១ ឧបនិស្សយប្បច្ច័យ ១ បុរេជាតប្បច្ច័យ ១ បច្ឆាជាតប្បច្ច័យ ១ អាសេវនប្បច្ច័យ ១ កម្មប្បច្ច័យ ១ វិបាកប្បច្ច័យ ១ អាហារប្បច្ច័យ ១ ឥន្ទ្រិយប្បច្ច័យ ១ ឈានប្បច្ច័យ ១ មគ្គប្បច្ច័យ ១ សម្បយុត្តប្បច្ច័យ ១ វិប្បយុត្តប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ នត្ថិប្បច្ច័យ ១ វិគតប្បច្ច័យ ១ អវិគតប្បច្ច័យ ១ ។

ក្នុងទីនេះ គប្បីប្រមូលបដ្ឋានទុកដូច្នេះ ពិតហើយ តិកៈទាំងឡាយ មានកុសលត្តិកៈជាដើម ឈ្មោះថា តិកៈ ២២ ទុកៈទាំងនេះ គឺ **ហេតូ ធម្មា ន ហេតុ ធម្មា ។បេ។ សរណា ធម្មា អរណា ធម្មា** ឈ្មោះថា ទុកៈ ១០០ ទុកៈសូម្បីដទៃទៀត គឺ **វិជ្ជាភាគិនោ ធម្មា អវិជ្ជាភាគិនោ ធម្មា ។បេ។ ខយេ ញាណំ អនុប្បាទេ ញាណំ** ឈ្មោះថា សុត្តន្តិកទុកៈ ៤២ ។ បណ្ដាតិកៈ និងទុកៈទាំងនោះ មាតិកានេះ គឺតិកៈ ២២ ទុកៈ ១០០ ឈ្មោះថា មាតិកានៃបករណ៍ទាំង ៧ ជាពុទ្ធវចនៈដែលព្រះជិនស្រីទ្រង់ភាសិតទុក គឺជាធម៌ដែលព្រះពុទ្ធមានព្រះសព្វញ្ញុតញ្ញាណសម្ដែងហើយ ។

មានសំណួរសួរថា កាលបើដូច្នោះ ទុកៈ ៤២ ដទៃទៀតមកពីណា ។ នរណាអ្នកតាំងទុក ។ នរណាជាអ្នកសម្ដែង ។

ឆ្លើយថា មកអំពីព្រះធម្មសេនាបតីសារីបុត្ត ព្រះធម្មសេនាបតីនោះតាំង

ទុក ព្រះធម្មសេនាបតីនោះសម្ដែងទុក ។

ព្រះថេរៈកាលតាំងធម៌ទាំងនេះ មិនបានតាំងទុកដោយការលើកឡើងសម្ដែងដោយខ្លួនឯង គឺដោយប្រាជ្ញាញាណរបស់ខ្លួនទេ តែព្រះថេរៈបានប្រមូលបន្ថែមឡើង ចាប់ពីធម៌ពួកមួយ តាមសង្គីតិសូត្រ និងទសុត្តរសូត្រ មានឯកនិបាតជាដើម តាំងទុកដើម្បីព្រះថេរៈអ្នកជំនាញព្រះអភិធម្ម អ្នកដល់ព្រះសូត្រហើយនឹងមិនលំបាក ។ ទុកៈទាំងនោះ ចែកឲ្យដល់ទីបំផុតទុកក្នុងនិក្ខេបកណ្ឌមួយនោះឯង ។ លោកចែកអភិធម្មទុក រហូតដល់សរណទុកៈក្នុងឋានៈដ៏សេស ។

ពិតហើយ ក្នុងអនុលោមបដ្ឋាន ព្រះសម្មាសម្ពុទ្ធ ទ្រង់អាស្រ័យតិកៈ ២២ សម្ដែងធម៌ឈ្មោះតិកបដ្ឋាន ។ ទ្រង់អាស្រ័យទុកៈ ១០០ សម្ដែងធម៌ឈ្មោះទុកបដ្ឋាន ខាងមុខអំពីនេះ ក៏កាន់យកតិកៈ ២២ បញ្ចូលជាមួយទុកៈ ១០០ សម្ដែងធម៌ឈ្មោះទុកតិកបដ្ឋាន បន្ទាប់អំពីនោះ ក៏កាន់យកទុកៈ ១០០ បញ្ចូលជាមួយតិកៈ ២២ សម្ដែងធម៌ឈ្មោះតិកទុកបដ្ឋាន បន្ទាប់អំពីនោះ ទ្រង់បញ្ចូលតិកៈទាំងឡាយ ចូលក្នុងតិកៈទាំងឡាយនុ៎ះឯង សម្ដែងធម៌ឈ្មោះតិកតិកបដ្ឋាន ហើយទ្រង់សង្គ្រោះទុកៈទាំងឡាយ បញ្ចូលក្នុងទុកៈទាំងឡាយនោះឯង សម្ដែងធម៌ឈ្មោះទុកទុកបដ្ឋាន ។

> ន័យទាំង ៦ គឺតិកបដ្ឋានដ៏ប្រសើរ ១ ទុកបដ្ឋានដ៏ឧត្ដម ១
> ទុកត្តិកបដ្ឋាន ១ តិកទុកបដ្ឋាន ១ តិកត្តិកបដ្ឋាន ១
> ទុកទុកបដ្ឋាន ១ ជាន័យដ៏ជ្រៅក្នុងអនុលោម ។

សូម្បីក្នុងបច្ចនីយបដ្ឋាន ក៏ឈ្មោះថា តិកបដ្ឋាន ព្រោះអាស្រ័យតិកៈ ២២ ។ ឈ្មោះថា ទុកបដ្ឋាន ព្រោះអាស្រ័យទុកៈ ១០០ ។ ឈ្មោះថា ទុកតិកបដ្ឋាន ព្រោះសង្គ្រោះតិកៈ ២២ ចូលក្នុងទុកៈ ១០០ ។ ឈ្មោះថា តិកទុកបដ្ឋាន ព្រោះសង្គ្រោះទុកៈ ១០០ ចូលក្នុងតិកៈ ២២ ។ ឈ្មោះថា តិកតិកបដ្ឋាន ព្រោះសង្គ្រោះតិកៈទាំងឡាយ ចូលក្នុងតិកៈទាំងឡាយនុ៎ះឯង ។ ឈ្មោះថា ទុកទុកបដ្ឋាន ព្រោះសង្គ្រោះទុកៈទាំងឡាយ ចូលក្នុងទុកៈទាំងឡាយ ។

សូម្បីក្នុងធម៌បច្ចនីយ ក៏ទ្រង់សម្តែងបដ្ឋានដោយន័យទាំង ៦ ព្រោះហេតុនោះ ទើបព្រះសង្គីតិការកមហាថេរៈពោលថា

ន័យទាំង ៦ គឺតិកបដ្ឋានដ៏ប្រសើរ ១ ទុកបដ្ឋានដ៏ឧត្តម ១ ទុកត្តិកបដ្ឋាន ១ តិកទុ្កបដ្ឋាន ១ តិកត្តិកបដ្ឋាន ១ ទុកទុ្កបដ្ឋាន ១ ជាន័យដ៏ជ្រៅក្នុងបច្ចនីយៈ ។

ខាងមុខអំពីនោះ ក្នុងធម្មអនុលោមបច្ចនីយៈ ក៏ទ្រង់សម្តែងន័យ ៦ ដោយឧបាយនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា

ន័យទាំង ៦ គឺតិកបដ្ឋានដ៏ប្រសើរ ១ ទុកបដ្ឋានដ៏ឧត្តម ១ ទុកត្តិកបដ្ឋាន ១ តិកទុ្កបដ្ឋាន ១ តិកត្តិកបដ្ឋាន ១ ទុកទុ្កបដ្ឋាន ១ ជាន័យដ៏ជ្រៅក្នុងអនុលោមបច្ចនីយៈ ។

ក្នុងលំដាប់បន្ទាប់អំពីនោះ ក្នុងធម្មបច្ចនីយានុលោម ក៏ទ្រង់សម្តែងបដ្ឋានដោយន័យទាំង ៦ នេះដូចគ្នា ព្រោះហេតុនោះ ទើបលោកពោលថា

នយ័ទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជានយ័ដ៏ជ្រៅក្នុងបច្ចនីយានុលោម ។

បដ្ឋានដែលជាទីប្រជុំនៃសមន្តប្បដ្ឋានទាំង ២៤ នេះ គឺបដ្ឋាន ៦ ក្នុងធម្មអនុលោម បដ្ឋាន ៦ ក្នុងធម្មបដិលោម បដ្ឋាន ៦ ក្នុងធម្មអនុលោម-បច្ចនីយៈ បដ្ឋាន ៦ ក្នុងធម្មបច្ចនីយានុលោម ឈ្មោះថា មហាបករណ៍ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ដើម្បីការដឹងច្បាស់ដល់ភាពនៃព្រះអភិធម្មនេះ ជាធម៌ដ៏ជ្រាលជ្រៅ គប្បីជ្រាបសាគរ ( សមុទ្ទ ) ៤ គឺ

**សំសារសាគរ** សាគរ គឺសំសារ ១ **ជលសាគរ** សាគរ គឺទឹកមហាសមុទ្ទ ១ **នយសាគរ** សាគរ គឺនយ័ ១ **ញាណសាគរ** សាគរ គឺញាណ ១ ។

បណ្តាសាគរទាំង ៤ នោះ ឈ្មោះថា សំសារសាគរ គឺសំសារវដ្ត ដែលលោកពោលយ៉ាងនេះថា

លំដាប់នៃខន្ធ ធាតុ និងអាយតនៈ ដែលប្រព្រឹត្តទៅមិនដាច់
ខ្សែ លោកហៅថា សំសារ ដូច្នេះ ។

នេះឈ្មោះថា សំសារសាគរ ។ សំសារសាគរនេះ ព្រោះហេតុថា ខាងដើមនៃការកើតឡើងរបស់សត្វទាំងនេះ រមែងមិនប្រាកដ គឺមិនមានកំណត់ថា សត្វទាំងឡាយកើតឡើងមកហើយ ក្នុងទីបំផុតត្រឹមតែមួយរយឆ្នាំ

ប៉ុណ្ណោះ ត្រឹមតែមួយពាន់ឆ្នាំប៉ុណ្ណោះ ត្រឹមតែមួយសែនឆ្នាំប៉ុណ្ណោះ ត្រឹមតែមួយរយកប្បប៉ុណ្ណោះ ត្រឹមតែមួយពាន់កប្បប៉ុណ្ណោះ ត្រឹមតែមួយសែនកប្បប៉ុណ្ណោះ ក្នុងកាលមុនអំពីនេះ មិនមានឡើយ ដូច្នេះ ឬថា សត្វទាំងឡាយកើតឡើងហើយ ក្នុងកាលនៃព្រះរាជាព្រះនាមឯណោះ ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមឯណោះ ក្នុងកាលមុនអំពីនោះ មិនមានឡើយដូច្នេះ ប៉ុន្តែមានដោយន័យនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជាមិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុនអំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយឡើយ ដូច្នេះ ។ ការកំណត់ខាងដើម និងខាងចុងដែលបុគ្គលដឹងមិនបាននេះ ឈ្មោះថា **សំសារសាគរ** ។

**មហាសមុទ្ទ** គប្បីជ្រាបថា ឈ្មោះថា **ជលសាគរ** មហាសមុទ្ទនោះជម្រៅ ៨៤០០០ យោជន៍ ដែលឈ្មោះថា ការប្រមាណទឹកក្នុងមហាសមុទ្ទនោះ ថាមានប៉ុណ្ណោះ គឺមានទឹកមួយរយអាឡ្ហកៈ មួយពាន់អាឡ្ហកៈ ឬមួយសែនអាឡ្ហកៈមិនបានឡើយ តាមពិត អន្លង់នៃមហាសមុទ្ទនោះ រមែងប្រាកដថា នរណាៗ គប្បីរាប់មិនបាន គប្បីប្រមាណមិនបាន រមែងដល់ការរាប់ថា ជាអន្លង់ទឹកធំ ដោយពិត នេះឈ្មោះថា **ជលសាគរ** ។

**នយសាគរ** តើដូចម្តេច ។ **នយសាគរ** បានដល់ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក បីតិសោមនស្សដែលមិនមានទីបំផុត រមែងកើតដល់កុលបុត្តទាំងឡាយ ដែលពិចារណាតន្តិទាំងពីរ ដែលដល់ព្រមដោយសទ្ធា មានសេចក្តីជ្រះថ្លាច្រើន មានញាណដ៏ក្រៃលែង ។ **តន្តិ** ទាំងពីរ តើដូចម្តេច ។

តន្តិទាំងពីរ គឺព្រះវិន័យ និងព្រះអភិធម្ម ។ បីតិ និងសោមនស្សដែលមិនមានទីបំផុត រមែងកើតដល់ភិក្ខុវិន័យធរទាំងឡាយ អ្នកពិចារណាតន្តិនៃវិន័យថា ការបញ្ញត្តិសិក្ខាបទថា ឈ្មោះថា អាបត្តិនេះ រមែងមាន ព្រោះទោសនេះ ព្រោះការឈានកន្លង ដូច្នេះ ឈ្មោះថា ការបញ្ញត្តិសិក្ខាបទដែលសមគួរដល់ទោស មិនមែនវិស័យរបស់ជនដទៃ ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ដូច្នេះ និងដល់បុគ្គលពិចារណាឧត្តរិមនុស្សធម្មបេយ្យាល ដល់អ្នកពិចារណានីលបេយ្យាល ដល់អ្នកពិចារណាសញ្ចរិត្តបេយ្យាល ។ បីតិ និងសោមនស្សដែលមិនមានទីបំផុត រមែងកើតដល់ភិក្ខុរៀនព្រះអភិធម្ម អ្នកពិចារណានូវតន្តិនៃព្រះអភិធម្មថា ព្រះសាស្តារបស់យើងទាំងឡាយ កាលទ្រង់ចែកសូម្បីសេចក្តីផ្សេងគ្នានៃខន្ធ សូម្បីសេចក្តីផ្សេងគ្នានៃអាយតនៈ សូម្បីសេចក្តីផ្សេងគ្នានៃធាតុ សេចក្តីផ្សេងគ្នានៃឥន្ទ្រិយ ពល ពោជ្ឈង្គ កម្ម វិបាក ការកំណត់រូប និងអរូប ធម៌ដ៏ល្អិតសុខុម ទ្រង់ធ្វើមួយមាតិកាៗ ក្នុងរូបធម៌ និងអរូបធម៌ឲ្យជាចំណែកៗ សម្តែងដូចការរាប់ផ្កាយទាំងឡាយក្នុងលម្ហមេឃ ដូច្នោះ ។ ក៏ក្នុងការកើតឡើងនៃបីតិសោមនស្សនោះ គប្បីជ្រាបសូម្បីរឿងដូចតទៅនេះ

មានតំណាលថា ព្រះថេរៈឈ្មោះថា មហានាគតិមិយតិស្សទត្ត កាលទៅកាន់ត្រើយនាយ ដោយគិតថា អញនឹងថ្វាយបង្គំមហាពោធិ ទើបអង្គុយលើផ្ទៃខាងលើនៃនាវា សម្លឹងមើលមហាសមុទ្រនោះ ក្នុងគ្រានោះ ត្រើយនាយមិនប្រាកដដល់លោកឡើយ ត្រើយអាយក៏មិនប្រាកដ មហាសមុទ្រប្រាស

ចាកពពុះទឹកដែលកើតអំពីកម្លាំងរលក ដូចគ្នានឹងបន្ទះប្រាក់ដែលគេផៃ និង ដូចកម្រាលធ្វើដោយផ្កាម្ជុះ ដូច្នោះ ព្រះថេរៈគិតថា កម្លាំងរលករបស់ មហាសមុទ្ទមានកម្លាំងឬហ្ន៎ ឬថា នយមុខ ( សេចក្ដីដែលព្រះមានព្រះភាគ ទ្រង់ណែនាំ ) ក្នុងសមន្តប្បដ្ឋាន ២៤ ប្រភេទ មានកម្លាំង ដូច្នេះ ។ ខណៈនោះ បីតិដ៏មានកម្លាំង ក៏កើតឡើងដល់ព្រះថេរៈដែលពិចារណាធម៌ដ៏ ល្អិតសុខុមថា ការកំណត់ក្នុងមហាសមុទ្ទរមែងប្រាកដ ព្រោះថា មហាសមុទ្ទ នេះ ខាងក្រោមកំណត់ដោយផែនដី ខាងលើកំណត់ដោយអាកាស ម្ខាង កំណត់ដោយភ្នំចក្កវាឡ ម្ខាងកំណត់ដោយច្រាំង តែការកំណត់សមន្តប្បដ្ឋាន រមែងមិនប្រាកដ ដូច្នេះ ព្រះថេរៈគ្របសង្កត់បីតិ ហើយចម្រើនវិបស្សនា ខណៈអង្គុយនោះឯង ក៏ញុំាងកិលេសទាំងពួងឲ្យអស់ទៅ តាំងនៅក្នុងអរហត្ត ដែលជាអគ្គផល ហើយបន្លឺឧទានថា

> ព្រះយោគាវចរ រមែងឃើញធម៌ដ៏ជ្រាលជ្រៅ ដែលត្រាស់ ដឹងបានដោយកម្រ មានហេតុជាដែនកើត ដែលព្រះមហេសី ទ្រង់ត្រាស់ដឹងក្រៃលែងដោយព្រះអង្គឯង សម្ដែងទុកដោយ លំដាប់ដោយឥតសេសសល់ ក្នុងសមន្តប្បដ្ឋាននេះប៉ុណ្ណោះ ដូចគ្នានឹងការព្រមនៃរូបនោះឯង ។ នេះឈ្មោះថា នយ- សាគរ ។

**ញាណសាគរ** តើដូចម្ដេច ។ សព្វញ្ញុតញ្ញាណ ឈ្មោះថា **ញាណ- សាគរ ។**

ពិតហើយ ញាណដទៃមិនអាចដើម្បីនឹងដឹងសាគរនោះថា នេះឈ្មោះថា សំសារសាគរ នេះឈ្មោះថា ជលសាគរ នេះឈ្មោះថា នយសាគរ តែសព្វញ្ញុតញ្ញាណប៉ុណ្ណោះអាចដឹងបាន ព្រោះហេតុនោះ សព្វញ្ញុតញ្ញាណទើបឈ្មោះថា **ញាណសាគរ** ។

បណ្ដាសាគរទាំង ៤ នេះ នយសាគរ លោកសំដៅយកក្នុងទីនេះ ព្រះពុទ្ធទាំងឡាយ ជាសព្វញ្ញូប៉ុណ្ណោះ រមែងចាក់ធ្លុះក្នុងនយសាគរនេះ ។

ព្រះមានព្រះភាគអង្គនេះ គង់ត្រង់មណ្ឌលពោធិព្រឹក្ស ទ្រង់ចាក់ធ្លុះនយសាគរនេះ គង់ដោយភ្នែនមួយអស់មួយសប្ដាហ៍ ពិចារណាធម៌ដែលទ្រង់ត្រាស់ដឹងហើយថា កាលតថាគតស្វែងរកធម៌នេះ កន្លងទៅ ៤ អសង្ខេយ្យនិង ១ សែនកប្ប ខាងក្រោយមក តថាគតអង្គុយខាងលើបល្ល័ង្កនេះ ទើបញុំាងកិលេស ១៥០០ ឲ្យអស់ទៅ ហើយចាក់ធ្លុះបាន ដូច្នេះ លំដាប់នោះ ទើបទ្រង់ក្រោកចាកបល្ល័ង្កនោះ ប្រថាប់ឈរក្រឡេកមើលបល្ល័ង្ក អស់មួយសប្ដាហ៍ ដោយព្រះនេត្រដែលមិនប៉ប្រិចដោយព្រះតម្រិះថា សព្វញ្ញុ-តញ្ញាណ តថាគតចាក់ធ្លុះហើយ លើបល្ល័ង្កនេះឯងហ្ន៎ ដូច្នេះ ។

លំដាប់នោះ ពួកទេវតាទាំងឡាយមានបរិវិតក្កកើតឡើងថា ក្នុងថ្ងៃនេះព្រះសិទ្ធត្ថៈ គប្បីធ្វើកិច្ចដែលគួរធ្វើពិត ទើបមិនទាន់លះអាល័យក្នុងបល្ល័ង្កដូច្នេះ ។

ព្រះសាស្ដា ទ្រង់ជ្រាបបរិវិតក្ករបស់ទេវតាទាំងឡាយ ដើម្បីនឹងញុំាងវិតក្ករបស់ទេវតាទាំងនោះឲ្យស្ងប់ ទើបហោះឡើងទៅឰដ៏អាកាស សម្ដែង

យមកប្បាដិហារិយ៍ ។

ពិតហើយ បាដិហារិយ៍ដែលព្រះអង្គ ទ្រង់ធ្វើត្រង់មហាពោធិបល្ល័ង្កក្តី ត្រង់សមាគមនៃព្រះញាតិក្តី ត្រង់សមាគមបាដលីបុត្តក្តី បាដិហារិយ៍ទាំងអស់ ដូចគ្នានឹងយមកប្បាដិហារិយ៍ ដែលធ្វើនៅត្រង់មណ្ឌលគណ្ឌាម្ពព្រឹក្ស ( គល់ស្វាយរបស់នាយគណ្ឌ ) នុ៎ះឯង កាលទ្រង់ធ្វើបាដិហារិយ៍យ៉ាងនេះហើយ ទើបយាងចុះអំពីអាកាស ហើយចង្ក្រមអស់មួយសប្តាហ៍ ក្នុងចន្លោះនៃបល្ល័ង្ក និងទីដែលព្រះអង្គទ្រង់ប្រថាប់ឈរ ។ ក្នុង ២១ ថ្ងៃនេះ សូម្បីមួយថ្ងៃ រស្មីទាំងឡាយ មិនបានផ្សាយចេញអំពីសរីរៈរបស់ព្រះសាស្តា តែក្នុងសប្តាហ៍ទី ៤ ទ្រង់គង់ក្នុងផ្ទះកែវ ក្នុងទិសពាយ័ព្យ ។ ឈ្មោះថា ផ្ទះកែវ មិនមែនផ្ទះដែលសម្រេចដោយរតនៈ តែបណ្ឌិតគប្បីជ្រាបស្ថានទីដែលព្រះមានព្រះភាគ ទ្រង់ពិចារណាបករណ៍ទាំង ៧ ថាជាផ្ទះកែវ ។

បណ្តាបករណ៍ទាំង ៧ នោះ កាលទ្រង់ពិចារណាធម្មសង្គណិ រស្មីទាំងឡាយ ក៏មិនផ្សាយចេញអំពីព្រះសរីរៈ កាលពិចារណាវិភង្គប្បករណ៍ ធាតុកថា បុគ្គលប្បញ្ញត្តិ កថាវត្ថុប្បករណ៍ និងយមកប្បករណ៍ រស្មីទាំងឡាយ ក៏មិនបានផ្សាយចេញអំពីព្រះសរីរៈ តែកាលណាទ្រង់ឈមចុះកាន់មហាបករណ៍ ផ្តើមពិចារណាថា **ហេតុប្បច្ចយោ អារម្មណប្បច្ចយោ ។បេ។ អវិគតប្បច្ចយោ** ដូច្នេះ កាលនោះ សព្វញ្ញុតញ្ញាណដោយចំណែកមួយរបស់ព្រះមានព្រះភាគ ដែលពិចារណាសមន្តប្បដ្ឋាន ២៤ ប្រការ រមែងបានឱកាស ( ចន្លោះ ) ក្នុងមហាបករណ៍នុ៎ះឯង ប្រៀបដូចត្រីធំ ឈ្មោះថា

តិមិរបិង្គល រមែងបានឱកាសដោយចំណែកមួយ ក្នុងមហាសមុទ្រដែលមានជម្រៅ ៨៤០០០ យោជន៍នុ៎ះឯង យ៉ាងណា ព្រះសព្វញ្ញុតញ្ញាណក៏យ៉ាងនោះដូចគ្នា រមែងបានឱកាសក្នុងមហាបករណ៍ ដោយចំណែកមួយនុ៎ះឯង ។

កាលព្រះសាស្តា ទ្រង់ពិចារណាធម៌ដ៏ល្អិតសុខុមតាមសប្បាយ ដោយព្រះសព្វញ្ញុតញ្ញាណ ដែលបានឱកាសហើយយ៉ាងនេះ ព្រះឆព្វណ្ណរំសី គឺ នីលៈ ( ខៀវដូចផ្កាអញ្ចន់ ) បីតៈ ( លឿងដូចហរិតាល ) លោហិតៈ ( ក្រហមដូចពណ៌អរុណ ) ឱទាតៈ ( សដូចផ្ទាំងប្រាក់ ) មញ្ជេដ្ឋៈ ( ពណ៌ហង្សបាទដូចផ្កាសិរមាន់ ) បភស្សរៈ ( ភ្លឺផ្លេកដូចកែវផលិក ) ក៏ផ្សាយចេញអំពីព្រះសរីរៈ ។ ផ្ទៃមេឃហាក់ដូចជាពេញទៅដោយផ្កាអញ្ចន់ផ្សាយទូទៅ ដូចដេរដាសដោយផ្កាកប្បាស ឬត្របកឧប្បលខៀវ ដូចកំពីងត្នោតប្រដាប់ដោយកែវមណី ដែលគេរីទៅមក និងដូចរបស់ពណ៌ខៀវចាស់ដែលលាតសន្ធឹងដោយអំណាចនៃរស្មី មានពណ៌ខៀវពួកណា ព្រះរស្មីមានពណ៌ខៀវទាំងនោះ ចេញទៅហើយចាកព្រះកេសា និងព្រះមស្សុទាំងឡាយ និងអំពីទីដែលមានពណ៌ខៀវនៃព្រះនេត្រទាំងគូ ។

ចំណែកនៃទិសទាំងឡាយ រមែងរុងរឿង ដូចស្រោចស្រង់ ( ជម្រះ ) ដោយទឹកមាស ដូចផ្សាយជំបារមាសចេញទៅ ដូចជ្រលក់ដោយលម្អិតនៃចន្ទន៍ក្រហម និងដូចរោយរាយដោយផ្កាកណិការ ដោយអំណាចនៃរស្មីមានពណ៌លឿងទាំងឡាយណា រស្មីមានពណ៌លឿងទាំងឡាយនោះ ផ្សាយចេញហើយអំពីព្រះឆវីវណ្ណ និងអំពីពណ៌លឿងនៃព្រះនេត្រទាំងគូ ។

ចំណែកនៃទិសទាំងឡាយរុងរឿងហើយ ដូចជ្រលក់ដោយលម្អិតនៃល័ក្ត ដូចស្រោចដោយទឹកល័ក្តដែលចម្អិនល្អហើយ ដូចគ្របដណ្តប់ដោយសំពត់កម្ពលពណ៌ក្រហម ដូចរោយរាយដោយផ្កាជយព្រឹក្ស ផ្កាចារ និងផ្កាច្បា ដោយអំណាចនៃរស្មីមានពណ៌ក្រហមទាំងឡាយណា ព្រះរស្មីមានពណ៌ក្រហមទាំងឡាយនោះ ផ្សាយចេញហើយចាកព្រះមំសៈ ព្រះលោហិត និងចាកទីពណ៌ក្រហមនៃព្រះនេត្រទាំងគូ ។

ចំណែកនៃទិសទាំងឡាយរុងរឿងហើយ ដូចពេញទៅដោយធារទឹកដោះស្រស់ដែលចាក់អំពីថ្នាំងប្រាក់ ដូចពិតានដំបារប្រាក់ដែលគេសន្ធឹង ដូចសណ្តង់ត្នោតប្រាក់ដែលយោលទៅមក ដូចដេរដាសដោយផ្ការុន ផ្កាកុមុទ ផ្កាកន្ទុ-ស ផ្កាម្លិះលា ផ្កាម្លិះរួតជាដើម ដោយអំណាចនៃរស្មីមានពណ៌សឯណា រស្មីមានពណ៌សទាំងឡាយនោះ ផ្សាយចេញហើយអំពីព្រះអដ្ឋិទាំងឡាយ អំពីព្រះទន្តទាំងឡាយ និងអំពីទីដែលមានពណ៌សនៃព្រះនេត្រទាំងគូ ។

ចំណែកព្រះរស្មីពណ៌ហង្សបាទ និងភ្លឺផ្លេក ក៏ផ្សាយចេញអំពីចំណែកនៃព្រះសរីរៈនោះៗ ព្រះឆព្វណ្ណរង្សីទាំងនោះ ផ្សាយចេញហើយ ទម្លុះមហាប្រឹថពីដ៏ក្រាស់ ដោយប្រការដូច្នេះ ។

មហាប្រឹថពីកម្រាស់ ២៤០០០០ យោជន៍ ដូចជាដុំមាសដែលគេខាត់មន្ទិលហើយ ។ ពេលនោះ រស្មីទាំងឡាយ ទម្លុះផែនដីចុះទៅដល់ទឹកក្នុងខាងក្រោម ទឹកទ្រផែនដីកម្រាស់ ៤៨០០០០ យោជន៍ ដូចមាសដែល

ហូរអំពីឡមាស ព្រះរស្មីទាំងនោះ ទម្លុះទឹកចុះទៅដល់ខ្យល់ ខ្យល់កម្រាស់ ៩៦០០០០ យោជន៍ ដូចជាដុំមាសដែលគេលើកឡើងហើយ ។ ព្រះរស្មីទាំងឡាយទម្លុះខ្យល់ហើយ ផ្សាយទៅកាន់អជដាកាសខាងក្រោម ។

ពោលដោយចំណែកខាងលើ ព្រះរស្មីទាំងឡាយ ផ្សាយទៅហើយដល់ឋានចាតុម្មហារាជិកា ទម្លុះឋានចាតុម្មហារាជិកា ទៅដល់ឋានតាវត្តិង្ស តពីនោះ ក៏ទៅដល់យាមា តុសិត និម្មានរតី បរនិម្មិតវសវត្តី តអំពីនោះ ក៏ទៅកាន់ព្រហ្មលោក ៩ ជាន់ តអំពីនោះ ក៏ទៅដល់វេហប្ផលា បន្ទាប់មកក៏ទៅដល់បញ្ចសុទ្ធាវាស ទៅដល់អរូបភូមិទាំង ៤ ជាន់ ទម្លុះអរូបភូមិទាំង ៤ ហើយ ផ្សាយទៅកាន់អជដាកាស ។

ដោយចំណែកខាងទទឹងទាំងឡាយ ព្រះរស្មីផ្សាយទៅកាន់លោកធាតុទាំងឡាយដែលមិនមានទីបំផុត ក្នុងទីទាំងឡាយមានប្រមាណប៉ុណ្ណោះ មិនមានរស្មីព្រះចន្ទក្នុងព្រះចន្ទ មិនមានរស្មីព្រះអាទិត្យក្នុងព្រះអាទិត្យ មិនមានរស្មីផ្កាយក្នុងផ្កាយទាំងឡាយ មិនមានរស្មីរបស់ទេវតាទាំងឡាយ ក្នុងទីទាំងពួង គឺទីឧទ្យាន វិមាន ដើមកប្បព្រឹក្សទាំងឡាយ គ្រឿងសរីរៈទាំងឡាយ គ្រឿងអាភរណៈទាំងឡាយ ។ ទោះបីមហាព្រហ្មដែលអាចផ្សាយពន្លឺទៅកាន់តិសហស្សីលោកធាតុ និងមហាសហស្សីលោកធាតុ ក៏ដូចជាពន្លឺអំពិលអំពែកក្នុងវេលាដែលព្រះអាទិត្យរះឡើង ព្រះចន្ទ ព្រះអាទិត្យ ផ្កាយ ឧទ្យាន វិមាន ដើមកប្បព្រឹក្សរបស់ទេវតា ក៏ប្រាកដត្រឹមតែជាការកំណត់ប៉ុណ្ណោះ ។ ពិតហើយ ទីដែលមានប្រមាណប៉ុណ្ណោះ បានជាទីគ្របសង្កត់ហើយដោយ

រស្មីរបស់ព្រះពុទ្ធទាំងនោះ សូម្បីឫទ្ធិបែបនេះ មិនមែនជាឫទ្ធិកើតអំពីការអធិដ្ឋាន មិនមែនឫទ្ធិកើតអំពីការនោរបស់ព្រះពុទ្ធទាំងឡាយ តែកាលព្រះលោកនាថ ទ្រង់ពិចារណាធម៌ដ៏ល្អិតសុខុម ព្រះលោហិតក៏ស្រស់ថ្លា វត្ថុរូបក៏ផូរផង់ ព្រះឆវីវណ្ណក៏ស្រស់ថ្លា ។ វណ្ណធាតុមានចិត្តជាសមុដ្ឋាន តាំងនៅមិនញាប់ញ័រក្នុងប្រទេសប្រមាណ ៨០ ហត្ថ ដោយជុំវិញ ។ ព្រះមានព្រះភាគ ទ្រង់ពិចារណាធម៌ដោយលក្ខណៈនេះ អស់ ៧ ថ្ងៃ ។

មានសំណួរសួរថា ធម៌ដែលព្រះមានព្រះភាគ ទ្រង់ពិចារណាអស់ ៧ យប់ ៧ ថ្ងៃ មានប្រមាណប៉ុនណា ។ ឆ្លើយថា ប្រមាណមិនបាន ។ នេះឈ្មោះថា ទេសនាដោយព្រះហឫទ័យមុន ។ កាលបើយ៉ាងនេះ បុគ្គលណាមួយ ក៏មិនគប្បីពោលថា ព្រះសាស្ដា កាលទ្រង់បន្ទឺព្រះវាចាសម្ដែងធម៌ដែលព្រះអង្គត្រិះរិះដោយព្រះហឫទ័យអស់ ៧ ថ្ងៃយ៉ាងនេះ ដោយកន្លងទៅមួយរយឆ្នាំក្ដី មួយពាន់ឆ្នាំក្ដី មួយសែនឆ្នាំក្ដី ក៏មិនអាចដើម្បីឲ្យដល់ទីបំផុតបាន ។ ពិតហើយ ក្នុងកាលខាងក្រោយមក ព្រះតថាគតប្រថាប់គង់កណ្ដាលពួកទេវតាមួយម៉ឺនចក្កវាឡ ខាងលើបណ្ឌុកម្ពលសិលាសនៈ ត្រង់មណ្ឌលបារិច្ឆត្តកៈ ក្នុងឋានតាវត្តិង្ស កាលទ្រង់សម្ដែងធម៌ ទ្រង់ធ្វើពុទ្ធមាតាឲ្យជាកាយសក្ខី ទ្រង់សង្ខេបហើយសង្ខេបទៀតនូវលំដាប់ធម៌ ចាកចន្លោះធម៌ ហើយសម្ដែងដោយចំណែកនៃរយដោយចំណែកនៃពាន់ ដោយចំណែកនៃសែន ។ ទេសនាដែលព្រះអង្គឲ្យប្រព្រឹត្តទៅជាប់តគ្នាអស់ ៣ ខែ ជាអនន្តទេសនាប្រមាណមិនបាន ដូចអាកាសគង្គាដែលហូរចុះមកយ៉ាងរហ័ស

និងដូចខ្សែទឹកដែលហូរចេញអំពីផ្ទាំងទឹកដែលផ្កាប់ ដូច្នោះ ។

ពិតហើយ ព្រះធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់ពង្រីកចេញបន្តិចបន្តួចអនុមោទនា ក្នុងកាលជាទីអនុមោទនាកត្ត ក៏បានប្រមាណស្មើនឹងទីឃនិកាយ និងមជ្ឈិមនិកាយ ។ មួយទៀត កាលទ្រង់សម្តែងធម៌ដល់បរិស័ទ ដែលប្រជុំគ្នាខាងក្រោយនៃកត្ត ទេសនាក៏មានប្រមាណស្មើនឹងនិកាយធំទាំងពីរ គឺសំយុត្តនិកាយ និងអង្គុត្តរនិកាយ ។ ព្រោះហេតុអ្វី ព្រោះភវង្គ-បរិវាស ( ការនៅអាស្រ័យនឹងភវង្គចិត្ត ) របស់ព្រះពុទ្ធទាំងឡាយលឿនរហ័ស ព្រះឱស្ឋបិទជិត បបូរព្រះឱស្ឋរាបស្មើ ព្រះជិវ្ហាទន់ ព្រះសូរសៀងពីរោះ ព្រះវាចាបន្ទឺបានយ៉ាងរហ័ស ព្រោះហេតុនោះ សូម្បីធម៌ដែលព្រះអង្គសម្តែងហើយត្រឹមមួយខណៈនោះ ទើបមានប្រមាណប៉ុណ្ណោះ ធម៌ដែលព្រះអង្គទ្រង់សម្តែងហើយ អស់ត្រៃមាស ទើបមិនមានទីបំផុត មិនមានប្រមាណ ។

មែនពិត ព្រះអានន្ទត្ថេរជាពហុស្សូត ទ្រទ្រង់ព្រះត្រៃបិដក ឈរដោយឥរិយាបថមួយនោះឯងរមែងរៀន រមែងប្រាប់ រមែងសម្តែងគាថា ១៥០០០ គាថា បទធម៌ ៦០០០០ បទ ដូចជនទាញផ្កាឈើទាំងមែក ធម៌មានប្រមាណប៉ុណ្ណោះ ឈ្មោះថា ជាឧទ្ទេសមគ្គ ១ របស់ព្រះថេរៈ ព្រោះថាបុគ្គលដទៃ កាលឲ្យឧទ្ទេសតាមលំដាប់បទដល់ព្រះថេរៈ រមែងមិនអាចឲ្យគឺប្រាប់មិនទាន់ ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ទើបឲ្យបរិបូណ៌ សាវកដែលមានសតិច្រើនក្រៃលែង មានគតិដ៏ពន្លឹក មានធិតិដ៏ក្រៃលែងយ៉ាងនេះ សូម្បី

រៀនទេសនាដែលព្រះសាស្ដាសម្ដែងហើយ អស់ត្រៃមាស ដោយទំនងនេះ អស់ ១០០០ ឆ្នាំ ក៏មិនអាចឲ្យដល់ទីបំផុតបាន ។

សួរថា ឧបាទិន្នកសរីរៈទាក់ទងដោយកពឡិង្គាហារបស់ព្រះតថាគត ទ្រង់សម្ដែងធម៌ជាប់តគ្នាអស់ ៣ ខែយ៉ាងនេះ ប្រព្រឹត្តទៅបានដូចម្ដេច ។ ឆ្លើយថា ដោយការទំនុកបម្រុងនោះឯង ។ ពិតហើយ កាលនោះ ព្រះពុទ្ធទាំងឡាយ ទ្រង់វិគ្រោះល្អហើយ ទ្រង់កំណត់ល្អហើយ ទ្រង់ពិចារណាល្អហើយ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ ទើបទ្រង់ប្រមើលមើលកាល ក្នុងមនុស្សលោក ព្រះអង្គទ្រង់កំណត់កាលកិច្ចាចារ ហើយនិម្មិតពុទ្ធនិម្មិតហើយអធិដ្ឋានថា ការដណ្ដប់ចីវរ ការកាន់បាត្រ ការបន្លឺសំឡេង កិរិយាអាការរបស់ពុទ្ធនិម្មិតនេះ ចូរមានយ៉ាងនេះ ចូរសម្ដែងធម៌មានប្រមាណប៉ុណ្ណេះ ដូច្នេះហើយ ទ្រង់កាន់បាត្រ និងចីវរយាងទៅកាន់អនោតត្តស្រះ ទេវតាថ្វាយឈើស្ទន់ ឈ្មោះនាគលតា ទ្រង់ទំពាក្នុងអនោតត្តស្រះនោះ បដិបត្តិសរីរៈក្នុងអនោតត្តស្រះ ហើយប្រថាប់ឈរលើផ្ទាំងមនោសិលា ទទ្រង់ស្បង់ពីរជាន់ដែលជ្រលក់ល្អហើយ ទ្រង់ដណ្ដប់ចីវរ ហើយកាន់បាត្រថ្មដែលមហារាជទាំង ៤ ថ្វាយ យាងទៅកាន់ឧត្តរកុរុទ្វីប ទ្រង់នាំបិណ្ឌបាតមកអំពីទីនោះ ប្រថាប់គង់ត្រង់មាត់ស្រះ ឈ្មោះអនោតត្តៈ ទ្រង់សោយហើយ យាងទៅកាន់ព្រៃចន្ទន៍ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។

ព្រះធម្មសេនាបតីសារីបុត្តត្ថេរ ក៏ទៅក្នុងទីនោះ ធ្វើវត្តចំពោះព្រះសម្មា-

សម្ពុទ្ធហើយ អន្ទុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ប្រទាន ន័យដល់ព្រះថេរៈ ទើបត្រាស់ប្រាប់ថា ម្នាលសារីបុត្ត ធម៌ដែលតថាគត សម្តែងហើយ មានប្រមាណប៉ុណ្ណេះ ។ កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទាន ន័យយ៉ាងនេះ ការប្រទានន័យដល់ព្រះអគ្គសាវកដែលដល់ព្រមដោយបដិ-សម្ភិទាហើយ ដូចបុគ្គលដែលឈរក្នុងទីបំផុតនៃច្រាំង ហើយលាដៃចង្អុលឲ្យ មើលមហាសមុទ្រ ដូច្នោះ ។ ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ រមែងប្រាកដច្បាស់ដល់ព្រះថេរៈ ដោយន័យមួយរយ ន័យមួយពាន់ ន័យ មួយសែន ។

សួរថា ព្រះសាស្តាទ្រង់សម្រាកក្នុងវេលាថ្ងៃ ហើយយាងទៅសម្តែង ធម៌នៅពេលណា ។ ឆ្លើយថា ធម្មតាពេលវេលាសម្រាប់សម្តែងធម៌ដល់ អ្នកក្រុងសាវត្ថី ដែលប្រជុំគ្នាហើយមាន ក៏យាងទៅវេលានោះ ។ សួរថា បុគ្គលណារមែងជ្រាប បុគ្គលណាមិនជ្រាបថា ព្រះសាស្តាយាងទៅសម្តែង ធម៌ ឬថា យាងមកសម្តែងធម៌ ។ ឆ្លើយថា ទេវតាដែលមានសក្តិធំ រមែង ដឹង ទេវតាដែលមានសក្តិតូច រមែងមិនដឹង ។ សួរថា ព្រោះហេតុអ្វី ទើប ទេវតាសក្តិតូចមិនដឹង ។ ឆ្លើយថា ព្រះសម្មាសម្ពុទ្ធក្តី ឬពុទ្ធនិម្មិតក្តី មិន មានការផ្សេងពីគ្នាដោយវត្ថុទាំងឡាយ មានព្រះរស្មីជាដើម សេចក្តីពិត ការ ផ្សេងគ្នានៃព្រះពុទ្ធ និងព្រះពុទ្ធនិម្មិតទាំងពីរអង្គនោះ ក្នុងព្រះរស្មីក្តី ព្រះ សូរសៀងក្តី ព្រះតម្រាស់ក្តី មិនមាន ។

ចំណែកព្រះសារីបុត្តត្ថេរ ក៏នាំធម៌ដែលព្រះសាស្តា ទ្រង់សម្តែងហើយ

មកសម្ដែងដល់ភិក្ខុ ៥០០ ដែលជាសទ្ធិវិហារិករបស់ខ្លួន ។ បុព្វកម្មរបស់ភិក្ខុទាំង ៥០០ នោះ មានដូចតទៅ

បានឮថា ក្នុងកាលនៃព្រះទសពល ព្រះនាមកស្សប ភិក្ខុទាំងនោះកើតក្នុងកំណើតជាសត្វប្រចៀវ សំយុងខ្លួននៅត្រង់ញកភ្នំ កាលភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្ម ២ រូប ស្វាធ្យាយព្រះអភិធម្ម ក៏កាន់យកនិមិត្តក្នុងសំឡេង សូម្បីមិនដឹងថា ជាធម៌ចំណែកខ្មៅ និងធម៌ចំណែកស ធ្វើកាលកិរិយាហើយ ក៏កើតក្នុងទេវលោក ដោយហេតុកាន់យកនិមិត្តក្នុងសំឡេងប៉ុណ្ណោះ ពួកជនទាំងនោះ នៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ក្នុងកាលនោះ មកកើតក្នុងមនុស្សលោក ជ្រះថ្លាក្នុងយមកប្បាដិហារិយ៍ ទើបបួសក្នុងសម្នាក់របស់ព្រះថេរៈ ព្រះថេរៈនាំព្រះធម៌ដែលព្រះសាស្ដាទ្រង់សម្ដែង មកសម្ដែងដល់ភិក្ខុទាំងនោះ ។ ការបញ្ចប់នៃការសម្ដែងព្រះអភិធម្មរបស់ព្រះសម្មាសម្ពុទ្ធ និងការរៀនបករណ៍ ៧ របស់ភិក្ខុទាំងនោះ ទើបមានព្រមគ្នានោះឯង ។

ផ្លូវនៃការប្រាប់ព្រះអភិធម្ម មានព្រះសារីបុត្តត្ថេរជាដើមហេតុ សូម្បីវារៈពោលដោយការរាប់ចំនួនក្នុងមហាបករណ៍ ព្រះថេរៈនោះឯងតាំងទុក ។ មែនពិត ព្រះថេរៈមិនលំបាកដល់ជាប់ធម៌ ទើបតាំងវារៈពោលដោយការរាប់ចំនួនដោយវិធីនេះ ដោយគិតថា ការកាន់យក ការទ្រទ្រង់ចាំ ការរៀន និងការប្រាប់ នឹងមានបានដោយងាយ ។ សួរថា កាលបើយ៉ាងនោះ ព្រះថេរៈក៏ជាអ្នកទ្រទ្រង់ព្រះអភិធម្មមុនទេដឹង ឆ្លើយថា មិនមែនឡើយ ព្រះសម្មាសម្ពុទ្ធនោះឯង ទ្រង់ជាអ្នកទ្រទ្រង់ព្រះអភិធម្មមុនគេ ព្រោះថា ព្រះមាន

ព្រះភាគប្រថាប់គង់ត្រង់មហាពោធិបល្ល័ង្ក ទ្រង់ចាក់ធ្លុះហើយនូវអភិធម្មនោះ កាលបានជាព្រះពុទ្ធហើយ ក៏ប្រថាប់ដោយភ្នែនមួយអស់ ៧ ថ្ងៃ ទ្រង់បន្លឺឡើងនូវឧទាននេះថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាម ញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួង របស់ព្រាហ្មណ៍នោះ រមែងអស់ទៅក្នុងកាលនោះ ព្រោះដឹងច្បាស់នូវធម៌ ព្រមទាំងហេតុ ។

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាម ញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់កិលេសក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួង របស់ព្រាហ្មណ៍នោះ រមែងអស់ទៅក្នុងកាលនោះ ព្រោះបានដឹងច្បាស់នូវព្រះនិព្វានជាទីអស់ទៅនៃបច្ច័យទាំងឡាយ ។

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាម ញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា ព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារ ព្រមទាំងសេនាមារ ឋិតនៅក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើងធ្វើអាកាសឲ្យរុងរឿងដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវងងឹតឋិតនៅដូច្នោះឯង ដូច្នេះ ។

នេះឈ្មោះថា បឋមពុទ្ធវចនៈ តែអាចារ្យអ្នកពោលធម្មបទ រមែងពោលថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺ តណ្ហា អ្នកធ្វើផ្ទះ គឺ អត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។

នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ឈ្មោះថា បឋមពុទ្ធវចនៈ ។

ព្រះតម្រាស់ដែលព្រះមានព្រះភាគ ទ្រង់ផ្ទំក្នុងចន្លោះដើមរាំងទាំងគូ ក្នុងសម័យទៀបបរិនិព្វានថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញុំាងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ដូច្នេះ ឈ្មោះថា បច្ឆិមពុទ្ធវចនៈ ។

ព្រះសទ្ធម្មដែលប្រកាសអមតៈ ដែលទ្រង់ត្រាស់ ៤៥ ព្រះវស្សា

ក្នុងចន្លោះនៃព្រះពុទ្ធវចនៈទាំងពីរ ដូចនាយមាលាការក្រងផ្កា និងដូចជាងកែវក្រងកម្រងកែវ ឈ្មោះថា មជ្ឈិមពុទ្ធវចនៈ ។ ព្រះពុទ្ធវចនៈទាំងអស់នោះ កាលប្រមូលរួបរួមគ្នាដោយបិដក ក៏ជាបិដក ៣ ដោយនិកាយ ក៏ជានិកាយ ៥ ដោយអង្គ ក៏មានអង្គ ៩ ដោយធម្មក្ខន្ធ ក៏មាន ៨៤០០០ ព្រះធម្មក្ខន្ធ ។

សេចក្តីនេះ ដូចម្តេច ពិតហើយ ព្រះពុទ្ធវចនៈទាំងអស់ ដោយបិដកមាន ៣ ប្រភេទប៉ុណ្ណោះ គឺវិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។ បណ្តាបិដកទាំង ៣ នោះ ព្រះពុទ្ធវចនៈ គឺបាតិមោក្ខទាំង ២ វិភង្គទាំង ២ ខន្ធកៈ ២២ បរិវារ ១៦ ឈ្មោះថា វិនយបិដក ។

ព្រះពុទ្ធវចនៈ គឺទីឃនិកាយដែលមានសូត្រ ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម មជ្ឈិមនិកាយ ដែលរួមសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម សំយុត្តនិកាយ រួបរួមសូត្រ មាន ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម អង្គុត្តរនិកាយរួបរួមសូត្រ ៩៥៥៧ សូត្រ មានចិត្តបរិយាទានសូត្រជាដើម ខុទ្ទកនិកាយ មាន ១៥ ប្រភេទ គឺខុទ្ទកបាឋៈ ១ ធម្មបទ ១ ឧទាន ១ ឥតិវុត្តកៈ ១ សុត្តនិបាត ១ វិមានវត្ថុ ១ បេតវត្ថុ ១ ថេរគាថា ១ ថេរីគាថា ១ ជាតក ១ និទ្ទេស ១ បដិសម្ភិទា ១ អបទាន ១ ពុទ្ធវង្ស ១ ចរិយាបិដក ១ ឈ្មោះថា សុត្តន្តបិដក ។ បករណ៍ ៧ មានធម្មសង្គណិជាដើម ឈ្មោះថា អភិធម្មបិដក ។

បណ្តាបិដកទាំង ៣ នោះ

ព្រះវិន័យនេះ បណ្ឌិតដែលដឹងអត្ថ នៃព្រះវិន័យទាំងឡាយ
ពោលថា ព្រះវិន័យ ព្រោះមានន័យផ្សេងៗ ព្រោះមានន័យ
ពិសេស និងព្រោះទូន្មាន កាយ វាចា ដូច្នេះ ។

ពិតហើយ ក្នុងវិនយបិដកនេះ ឈ្មោះថា មានន័យផ្សេងៗ គឺមានន័យដែលចែកដោយបាតិមោក្ខុទ្ទេស ៥ យ៉ាង អាបត្តិ ៧ កង មានបារាជិកជាដើម មាតិកា និងវិភង្គជាដើម ដែលឈ្មោះថា មានន័យពិសេស គឺ ន័យនៃអនុប្បញ្ញត្តិ ដែលមានព្រះបំណងធ្វើឲ្យមាំទាំ និងឲ្យធូរថយ ។ វិន័យនេះ ឈ្មោះថា រមែងទូន្មានកាយ វាចា ព្រោះរាំងការប្រព្រឹត្តិខុសតាមផ្លូវកាយ និងវាចា ព្រោះហេតុនោះ វិន័យនេះ បណ្ឌិតគប្បីពោលថា ឈ្មោះថា វិន័យ ព្រោះមានន័យផ្សេងៗ ព្រោះមាននយវិសេស ព្រោះអប់រំកាយវាចា ។ ដោយហេតុនោះឯង ដើម្បីភាពជាអ្នកឈ្លាសក្នុងអត្ថនៃការពោលដល់ព្រះវិន័យនោះ ទើបលោកចងគាថាថា

ព្រះវិន័យនេះ បណ្ឌិតដឹងអត្ថនៃវិន័យទាំងឡាយ ពោលថា
ព្រះវិន័យ ព្រោះមាននយផ្សេងៗ ព្រោះមាននយវិសេស និង
ព្រោះទូន្មានកាយ វាចា ដូច្នេះ ។

ចំណែកព្រះសូត្រ

លោកពោលថា ព្រះសូត្រ ព្រោះសម្ដែងដល់ប្រយោជន៍
ព្រោះមានប្រយោជន៍ដែលព្រះពុទ្ធត្រាស់ល្អហើយ ព្រោះឲ្យ
នូវប្រយោជន៍ ព្រោះបង្ហូរមកនូវប្រយោជន៍ ព្រោះជាទីពួន

យ៉ាងល្អ និងព្រោះមានចំណែកប្រៀបដោយខ្សែបន្ទាត់ ដូច្នេះ ។

ពិតហើយ ព្រះសូត្រនោះរមែងសម្តែងប្រយោជន៍ទាំងឡាយ មានប្រយោជន៍របស់ខ្លួន និងប្រយោជន៍របស់អ្នកដទៃជាដើម ។ ម្យ៉ាងទៀត ក្នុងព្រះសូត្រនេះ មានប្រយោជន៍ដែលត្រាស់យ៉ាងល្អ ព្រោះត្រាស់អនុលោមតាមអធ្យាស្រ័យរបស់វេនេយ្យសត្វ ព្រះសូត្រនេះ រមែងឲ្យនូវប្រយោជន៍ទាំងឡាយ អធិប្បាយថា ឲ្យផលដូចស្រូវឲ្យផល ។ ព្រះសូត្រនេះ រមែងបង្ហូរមកនូវប្រយោជន៍ទាំងឡាយនោះ អធិប្បាយថា រមែងហូរចេញ ដូចមេគោទឹកដោះ បង្ហូរមកនូវធ្លារទឹកដោះ ។ ព្រះសូត្រនេះ រមែងជាទីពួនអធិប្បាយថា រមែងរក្សាប្រយោជន៍ទាំងឡាយនោះយ៉ាងល្អ ។ ព្រះសូត្រនេះ មានចំណែកប្រៀបដោយខ្សែបន្ទាត់ ប្រៀបដូចខ្សែបន្ទាត់ រមែងជាប្រមាណរបស់ជាងឈើទាំងឡាយ យ៉ាងណា ព្រះសូត្រនេះ ក៏ជាប្រមាណរបស់វិញ្ញូជនទាំងឡាយ យ៉ាងនោះដូចគ្នា ។ ម្យ៉ាងទៀត ផ្កាទាំងឡាយដែលគេក្រងដោយអំបោះ រមែងមិនរាត់រាយ មិនខ្ចាត់ខ្ចាយ យ៉ាងណា ប្រយោជន៍ទាំងឡាយ ដែលទ្រង់សង្គ្រោះដោយព្រះសូត្រនេះ ក៏យ៉ាងនោះដូចគ្នា ដោយហេតុនោះ ដើម្បីភាពជាអ្នកឈ្លាសក្នុងអត្ថនៃការពោលដល់ព្រះសូត្រនោះ ទើបលោកចងគាថាថា

លោកពោលថា ព្រះសូត្រ ព្រោះសម្តែងដល់ប្រយោជន៍
ព្រោះមានប្រយោជន៍ដែលព្រះពុទ្ធត្រាស់ល្អហើយ ព្រោះឲ្យ
នូវប្រយោជន៍ ព្រោះបង្ហូរមកនូវប្រយោជន៍ ព្រោះជាទីពួន

យ៉ាងល្អ និងព្រោះមានចំណែកប្រៀបដោយខ្សែបន្ទាត់ ដូច្នេះ ។

ចំណែកព្រះអភិធម្ម

លោកពោលថា ព្រះអភិធម្ម ព្រោះហេតុក្នុងអភិធម្មបិដកនេះ ព្រះមានព្រះភាគ ត្រាស់ធម៌ដែលមានសេចក្ដីចម្រើន ១ ដែលគួរកំណត់ ១ ដែលគួរបូជា ១ ដែលកំណត់ ១ និងដ៏ក្រៃលែង ១ ដូច្នេះ ។

មែនពិត **អភិ** សព្ទនេះ ប្រើក្នុងអត្ថថា ចម្រើន គួរកំណត់ គួរបូជា កំណត់ និងក្រៃលែង ។ ពិតហើយ **អភិ** សព្ទនេះ ប្រើក្នុងអត្ថថា ចម្រើន ដូចក្នុងប្រយោគជាដើមថា **ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ** ទុក្ខវេទនាជាទម្ងន់ ចម្រើនឡើងដល់ខ្ញុំព្រះអង្គ មិនធូរថយទេ ដូច្នេះ ។ ប្រើក្នុងអត្ថថា គួរកំណត់ ដូចក្នុងប្រយោគជាដើមថា **យា តា រត្តិយោ អភិញ្ញាតា អភិលក្ខិតា** រាត្រីទាំងឡាយណា ដែលគេដឹងច្បាស់ ដែលគេកំណត់ដឹង ដូច្នេះ ។ ប្រើក្នុងអត្ថថា គួរបូជា ដូចក្នុងប្រយោគជាដើមថា **រាជាភិរាជា មនុជិន្ទោ** ជាព្រះរាជាធិរាជដ៏ធំជាងមនុស្ស ដូច្នេះ ។ ប្រើក្នុងអត្ថដែលកំណត់ ដូចក្នុងប្រយោគជាដើមថា **សិក្ខាយ**[១] **វិនេតុំ អភិធម្មេ វិនេតុំ អភិវិនយេ** អាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអភិធម្ម ១ អាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអភិវិន័យ ១ ដូច្នេះ អធិប្បាយថា ក្នុងធម៌ និងវិន័យដែលវៀរចាកការលាយឡំគ្នា ។

---

១- អដ្ឋកថា ជាបដិពលោ ។

ប្រើក្នុងអត្ថថា ក្រៃលែង ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តេន វណ្ណេន** មានសម្បុរល្អ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងអភិធម្មនេះ ព្រះមានព្រះភាគត្រាស់ធម៌ទាំងឡាយដែលមានសេចក្ដីចម្រើន ដោយន័យជាដើមថា បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព និងពុទ្ធដីកាថា ភិក្ខុនោះ រមែងមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ដូច្នេះ ក៏មាន ។ ត្រាស់ធម៌ទាំងឡាយ ដែលគួរកំណត់ ព្រោះជាធម៌ដែលគួរកំណត់ដោយអារម្មណ៍ជាដើម ដោយន័យថា មានរូបជាអារម្មណ៍ក្ដី មានសំឡេងជាអារម្មណ៍ក្ដី ដូច្នេះជាដើម ក៏មាន ។ ត្រាស់ធម៌ទាំងឡាយដែលគួរបូជា អធិប្បាយថា សមគួរដល់ការបូជាដោយន័យថា ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌ជាលោកុត្តរ ដូច្នេះជាដើម ក៏មាន ។ ត្រាស់ធម៌ទាំងឡាយ ដែលទ្រង់កំណត់ ព្រោះជាធម៌ដែលកំណត់ដោយសភាវៈ ដោយន័យថា ផស្សៈក៏កើតមាន វេទនាកើតមាន ដូច្នេះជាដើម ក៏មាន និងត្រាស់ធម៌ទាំងឡាយដែលក្រៃលែងដោយន័យថា ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ប្រកបដោយឧត្តរៈ ដូច្នេះជាដើមក៏មាន ។ ដោយហេតុនោះ ដើម្បីភាពជាអ្នកឈ្លាសក្នុងអត្ថនៃការពោលដល់ព្រះអភិធម្មនេះ ទើបលោកចងគាថាថា

ព្រះអភិធម្ម លោកពោលថា អភិធម្ម ព្រោះហេតុដែលក្នុង
អភិធម្មបិដកនេះ ព្រះមានព្រះភាគត្រាស់ធម៌ ដែលមានសេចក្ដី

ចម្រើន ១ ធម៌ដែលគួរកំណត់ ១ ធម៌ដែលគួរបូជា ១ ធម៌ដែលកំណត់ចែក ១ និងធម៌ដ៏ក្រៃលែង ១ ។

ម្យ៉ាងទៀត ក្នុងបិដកទាំង ៣ នេះ បណ្ឌិតដឹងអត្ថនៃបិដកសព្ទ ពោលបិដកដែលមិនផ្សេងគ្នានោះ ដោយអត្ថថា ជាបរិយត្តិ និងជាភាជនៈ ។ ឥឡូវនេះ គប្បីជ្រាបសព្ទទាំង ៣ មានវិន័យជាដើម រួមចូលជាមួយបិដកនោះ ។

ពិតហើយ បរិយត្តិ លោកក៏ហៅថា បិដក ដូចក្នុងប្រយោគជាដើមថា **មា បិដកសម្បទានេន** កុំប្រកាន់ដោយអាងក្បួនតម្រា ដូច្នេះ សូម្បីភាជនៈឯណានីមួយ ក៏ហៅថា បិដក ដូចក្នុងប្រយោគជាដើមថា **អថ បុរិសោ អាគច្ឆេយ្យ កុទាលបិដកំអាទាយ** កាលណោះ មានបុរសកាន់ចប និងកញ្ច្រែដើរមក ដូច្នេះ ។ ព្រោះហេតុនោះ បណ្ឌិតដឹងអត្ថនៃបិដកសព្ទ ទើបបិដកដោយអត្ថថា ជាបរិយត្តិ និងភាជនៈ ( កញ្ច្រែ ) ។

ពាក្យថា ឥឡូវនេះ គប្បីជ្រាបថា សព្ទទាំង ៣ មានវិន័យជាដើម សង្គ្រោះចូលជាមួយបិដកសព្ទនោះ បានដល់ គប្បីធ្វើសមាសជាមួយបិដក-សព្ទនោះ ដែលមានអត្ថ ២ យ៉ាង យ៉ាងនេះហើយ ជ្រាបសព្ទទាំង ៣ មានវិន័យជាដើម យ៉ាងនេះថា ព្រះវិន័យនោះផង ជាបិដកផង ឈ្មោះថា វិនយបិដក ព្រោះជាបរិយត្តិ និងព្រោះជាភាជនៈនៃអត្ថនោះៗ ។ ព្រះសូត្រនោះផង ជាបិដកផង ឈ្មោះថា សុត្តន្តបិដក ព្រះអភិធម្មនោះផង ជាបិដកផង ឈ្មោះថា អភិធម្មបិដក ដោយន័យតាមដែលពោលហើយនោះឯង ។

កាលជ្រាបយ៉ាងនេះហើយ ដើម្បីការឈ្វេងយល់ដោយប្រការផ្សេងៗ ក្នុង

ទាំង ៣ នោះ

បណ្ឌិតគប្បីសម្តែងប្រភេទនៃទេសនា សាសន កថា សិក្ខា បហានៈ និងគម្ភីរភាព ក្នុងបិដកទាំងនោះតាមសមគួរ គឺភិក្ខុ រមែងសម្រេចប្រភេទនៃបរិយត្តិ សម្បត្តិ និងវិបត្តិឯណា ក្នុង បិដកណា ដោយប្រការណា គប្បីអធិប្បាយប្រភេទនៃបរិ-យត្តិ សម្បត្តិ និងវិបត្តិទាំងអស់នោះ ដោយប្រការនោះចុះ ។

ក្នុងសេចក្តីនោះ មានពាក្យបរិយាយ និងអធិប្បាយដូចតទៅនេះ ពិត ហើយ បិដកទាំង ៣ នេះ លោកហៅតាមលំដាប់ថា អាណាទេសនា វោហារទេសនា បរមត្ថទេសនា យថាបរាធសាសន យថានុលោមសាសន យថាធម្មសាសន សំវរាសំវរកថា ទិដ្ឋិវិនិវេឋនកថា និងនាមរូបបរិច្ឆេទកថា ។

មែនពិត បណ្តាបិដកទាំង ៣ នេះ វិនយបិដក ហៅថា អាណាទេសនា ព្រោះព្រះមានព្រះភាគ គួរដល់ការប្រើអាជ្ញា ទ្រង់សម្តែងច្រើនទៅដោយ អាជ្ញា ។ សុត្តន្តបិដក ហៅថា វោហារទេសនា ព្រោះព្រះមានព្រះភាគទ្រង់ ជាអ្នកឈ្លាសក្នុងវោហារ ទ្រង់សម្តែងច្រើនទៅដោយវោហារ អភិធម្មបិដក ហៅថា បរមត្ថទេសនា ព្រោះព្រះមានព្រះភាគព្រះអង្គឈ្លាសក្នុងបរមត្ថធម៌ ទ្រង់សម្តែងច្រើនទៅដោយបរមត្ថធម៌ ។

មែនពិត បិដកទី ១ ហៅថា យថាបរាធសាសន ព្រោះសត្វទាំងឡាយ មានកំហុសច្រើន ព្រះមានព្រះភាគ ទ្រង់ប្រៀនប្រដៅ ក្នុងវិនយបិដកនេះ តាមកំហុស បិដកទី ២ ហៅថា យថានុលោមសាសន ព្រោះពួកសត្វដែល

មានអជ្ឈាស្រ័យ អនុស័យ ចរិយា និងអធិមុត្តិច្រើនយ៉ាង ព្រះមានព្រះភាគ ទ្រង់ទូន្មានក្នុងសុត្តន្តបិដកនេះ តាមលំដាប់ បិដកទី ៣ ហៅថា យថាធម្មសាសនៈ ព្រោះសត្វទាំងឡាយ មានសេចក្តីសម្គាល់ក្នុងសភាវៈ ត្រឹមតែពួកនៃធម៌ថា អញ របស់អញ ព្រះមានព្រះភាគ ទ្រង់ទូន្មានក្នុងព្រះអភិធម្មបិដកនេះ តាមសមគួរដល់ធម៌ ។

ពិតហើយ បិដកទី ១ ហៅថា សំវរាសំវរកថា ព្រោះព្រះមានព្រះភាគ ត្រាស់ការសង្រួមតូចធំដែលជាបដិបក្ខចំពោះការប្រព្រឹត្តិខុស ទុកក្នុងវិនយ-បិដកនេះ ។ ពាក្យថា **សំវរាសំវរ** នេះ បានដល់ ការសង្រួមតូច និងធំ ដូច **កម្មាកម្ម** ( កម្មតូចធំ ) និង **ផលាផល** ( ផ្លែឈើតូចធំ ) បិដកទី ២ ហៅថា ទិដ្ឋិវិនិវេឋនកថា ព្រោះព្រះមានព្រះភាគ ត្រាស់ដល់ការដោះទិដ្ឋិ ដែលជាបដិបក្ខចំពោះទិដ្ឋិ ៦២ ក្នុងសុត្តន្តបិដកនេះ បិដកទី ៣ ហៅថា នាមរូបបរិច្ឆេទកថា ព្រោះត្រាស់ដល់ការកំណត់នាម និងរូប ដែលជាបដិបក្ខចំពោះធម៌ មានរាគៈជាដើម ក្នុងអភិធម្មបិដកនេះ ។

មួយទៀត ក្នុងបិដកទាំង ៣ នេះ បណ្ឌិតគប្បីជ្រាបសិក្ខា ៣ បហានៈ ៣ និងគម្ភីរភាព ៤ ។

ពិតហើយ ពោលដោយន័យវិសេស ព្រះមានព្រះភាគត្រាស់អធិសីល-សិក្ខា ក្នុងវិនយបិដក ត្រាស់អធិចិត្តសិក្ខា ក្នុងសុត្តន្តបិដក និងត្រាស់អធិប្បញ្ញាសិក្ខា ក្នុងអភិធម្មបិដក ។ មួយទៀត ព្រះមានព្រះភាគ ត្រាស់បហានៈ ( ការលះ ) វីតិក្កមកិលេស ក្នុងវិនយបិដក ព្រោះ

សីលជាបដិបក្ខចំពោះកិលេសដែលកន្លងល្មើស ( វីតិក្កមកិលេស ) ។ ត្រាស់ការលះបរិយុដ្ឋានកិលេស ក្នុងសុត្តន្តបិដក ព្រោះសមាធិជាបដិបក្ខចំពោះកិលេសដែលរួបរឹត ( បរិយុដ្ឋានកិលេស ) ។ ត្រាស់ការលះអនុសយកិ្កលេស ក្នុងអភិធម្មបិដក ព្រោះបញ្ញា ជាបដិបក្ខចំពោះអនុ-សយក្កិលេស ។

ម្យ៉ាងវិញទៀត ក្នុងបិដកទី ១ ត្រាស់ការលះបង់កិលេសទាំងឡាយដោយតទង្គប្បហាន ក្នុងបិដកទាំង ២ ក្រៅនេះ ត្រាស់ការលះកិលេសដោយវិក្ខម្ភនប្បហាន និងសមុច្ឆេទប្បហាន មួយទៀត ក្នុងបិដកទី ១ ត្រាស់ការលះបង់សង្កិលេស គឺទុច្ចរិត ក្នុងបិដកទាំង ២ ក្រៅនេះ ត្រាស់ការលះបង់កិលេស គឺតណ្ហា និងទិដ្ឋិ ។

មួយទៀត ក្នុងបិដកទាំង ៣ នេះ បិដកនីមួយៗ គប្បីជ្រាបគម្ភីរភាព ៤ យ៉ាង គឺដោយធម៌ ដោយអត្ថ ដោយទេសនា និងដោយបដិវេធ ។ បណ្តាគម្ភីរភាពទាំងនោះ ព្រះបាលី ( **តន្តិ** ) ឈ្មោះថា **ធម៌** ។ សេចក្តីនៃបាលីនោះ ឈ្មោះថា **អត្ថ** ។ ការសម្តែងបាលីតាមដែលកំណត់យ៉ាងល្អដោយចិត្តនោះ ឈ្មោះថា **ទេសនា** ។ ការត្រាស់ដឹងតាមសេចក្តីពិតនូវធម៌ និងអត្ថនៃបាលីនោះ ឈ្មោះថា **បដិវេធ** ។ ពិតហើយ ធម៌ អត្ថទេសនា និងបដិវេធ ក្នុងបិដកទាំង ៣ នោះ ឈ្មោះថា **ជ្រាលជ្រៅ** ព្រោះសត្វទាំងឡាយដែលមានបញ្ញាតិច ឈមចុះបានដោយកម្រ ជាទីពឹងដែលបុគ្គលអ្នកមានបញ្ញាតិច មិនគប្បីបាន ប្រៀបដូចមហាសមុទ្រដែលសត្វតូចៗ

ទាំងឡាយ មានទទន្សាយជាដើម ឈមចុះបានដោយកម្រ ទាំងជាទីពឹងក៏មិនបាន ។ បណ្ឌិតគប្បីជ្រាបគម្ភីរភាពទាំង ៤ យ៉ាង ក្នុងបិដកទាំង ៣ នេះ ក្នុងបិដកនីមួយៗ ដោយប្រការដូច្នេះ ។

មួយវិញទៀត ហេតុ ឈ្មោះថា **ធម៌** ដូចព្រះតម្រាស់ថា សេចក្តីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា ដូច្នេះ ។ ផលរបស់ហេតុ ឈ្មោះថា **អត្ថ** ដូចព្រះតម្រាស់ថា សេចក្តីដឹងផលនៃហេតុឈ្មោះថា អត្ថប្បដិសម្ភិទា ដូច្នេះ ។ បញ្ញត្តិ សំដៅយកការពោលធម៌តាមសមគួរដល់ធម៌ ឈ្មោះថា **ទេសនា** ឬថា ការពោលធម៌ដោយអំណាចនៃអនុលោម បដិលោម សង្ខេប និងពិស្តារជាដើម ឈ្មោះថា **ទេសនា** ។ ការត្រាស់ដឹង ឈ្មោះថា **បដិវេធ** ។ បដិវេធនោះ ទាំងជាលោកិយ ទាំងជាលោកុត្តរ អធិប្បាយថា ការឈមចុះក្នុងធម៌ទាំងឡាយសមគួរដល់អត្ថ ក្នុងអត្ថទាំងឡាយសមគួរដល់ធម៌ ក្នុងបញ្ញត្តិទាំងឡាយ សមគួរដល់គន្លងនៃបញ្ញត្តិដោយវិស័យ ( អារម្មណ៍ ) ដោយអសម្មោហៈ ( ការមិនវង្វេង ) ឬថា ភាពដែលធម៌ទាំងនោះដែលព្រះមានព្រះភាគត្រាស់ក្នុងទីនោះៗ ជាធម៌មិនវិបរិតពោល គឺកំណត់បានដែលបុគ្គលគប្បីត្រាស់ដឹងបាន ឈ្មោះថា បដិវេធ ។

ឥឡូវនេះ ព្រោះក្នុងបិដកទាំងនេះ ធម៌ ឬអត្ថណាមួយ ឬទេសនាណាដែលជាគ្រឿងធ្វើបញ្ចាំងអត្ថ ដែលបែរមុខចំពោះញាណ របស់អ្នកស្តាប់ដោយប្រការដែលគប្បីឲ្យបុគ្គលនោះដឹងបាន ឬការចាក់ធ្លុះ ពោល គឺការឈមចុះកាន់ធម៌ដែលមិនវិបរិត ក្នុងបិដកទាំង ៣ ទាំងនេះឯណា ឬភាព

ដែលធម៌ទាំងនោះមិនវិបរិត ពោល គឺកំណត់បានដែលគប្បីចាក់ធ្លុះបានឯណា ធម៌ទាំងអស់នោះ បុគ្គលដែលមានបញ្ញាតិច មិនបំពេញកុសលសម្ភារ ឈមចុះបានដោយកម្រ ទាំងនឹងជាទីពឹងក៏មិនបាន ប្រៀបដូចមហាសមុទ្រ សត្វតូចៗ មានទទន្សាយជាដើម ឈមចុះបានដោយក្រ ទាំងនឹងជាទីពឹង មិនបាន ក៏យ៉ាងនោះ ទើបឈ្មោះថា **ជ្រាលជ្រៅ** ។ បណ្ឌិតគប្បីជ្រាបគម្ពីរភាពទាំង ៤ យ៉ាង ក្នុងបិដកទាំង ៣ នេះ បិដកនីមួយៗយ៉ាងនេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ រមែងជាការដែលពោលដល់អត្ថនៃគាថានេះថា

បណ្ឌិតគប្បីសម្ដែងប្រភេទនៃទេសនា សាសនៈ កថា សិក្ខាបហានៈ និងគម្ភីរភាពក្នុងបិដកទាំងនោះតាមសមគួរ ដូច្នេះ ។

តែក្នុងគាថានេះថា

ភិក្ខុរមែងសម្រេចភេទនៃបរិយត្តិ សម្បត្តិ និងវិបត្តិឯណា ក្នុងបិដកណាដោយប្រការណា គប្បីអធិប្បាយប្រភេទនៃបរិយត្តិ សម្បត្តិ និងវិបត្តិទាំងអស់នោះ ដោយប្រការនោះ ។

បណ្ឌិតគប្បីឃើញសេចក្ដីផ្សេងគ្នានៃបរិយត្តិ ៣ ក្នុងព្រះត្រៃបិដកទាំង ៣ ដូចតទៅ

ពិតហើយ បរិយត្តិមាន ៣ ប្រភេទ គឺអលគទ្ទូបមបរិយត្តិ ១ និស្សរណត្ថបរិយត្តិ ១ ភណ្ឌាគារិកបរិយត្តិ ១ ។

បណ្ដាបរិយត្តិទាំងនោះ បរិយត្តិដែលរៀនយកមិនល្អ គឺរៀនដើម្បីហេតុ

នៃការដោះស្រាយវាទៈជាដើម ឈ្មោះថា **អលគទ្ទូបមបរិយត្តិ** ដែលព្រះមានព្រះភាគទ្រង់សំដៅយក ត្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកត្រូវការដោយពស់វែក ស្វែងរកពស់វែក ក៏ត្រាច់ទៅស្វែងរកពស់វែក បុរសនោះ បានឃើញពស់វែក ១ យ៉ាងធំហើយ ក៏ចាប់ពស់វែកនោះត្រង់ខ្លួន ឬកន្ទុយ ពស់វែកនោះ ក៏ងាកមកចឹកបុរសនោះ ត្រង់ដៃ ឬដើមដៃ ឬអវយវៈតូចធំណាមួយ បុរសនោះក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខជិតតែនឹងស្លាប់ មានពស់វែកនោះជាហេតុ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាពស់វែក បុរសនោះ ចាប់មិនស្រួល ម្នាលភិក្ខុទាំងឡាយ មានមោឃ-បុរសពួកខ្លះ ក្នុងសាសនានេះ រៀនធម៌ គឺសុត្តៈ ។បេ។ វេទល្លៈ លុះមោឃបុរសទាំងនោះ រៀនធម៌នោះហើយ មិនបានពិចារណានូវសេចក្តីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងនោះមិនបានពិចារណានូវសេចក្តី ដោយប្រាជ្ញាហើយ ក៏មិនប្រាកដច្បាស់ក្នុងចិត្តមោឃបុរសទាំងនោះ រៀនធម៌ ដោយមានបំណងតែខាងលើកទោសគេផងដោយមានបំណង តែខាងដោះស្រាយនូវវាទៈដូច្នេះ ដូច្នោះផង កុលបុត្តទាំងឡាយ រៀនធម៌ដើម្បីប្រយោជន៍ណា ពួកមោឃបុរសនោះ ក៏មិនបាននូវប្រយោជន៍នោះ របស់ធម៌នោះឡើយ ធម៌ទាំងឡាយនោះ ដែលមោឃ-បុរសទាំងនោះ រៀនមិនល្អហើយ ក៏ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរអង្វែង ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំង

ឡាយ ព្រោះថា ធម៌ទាំងឡាយដែលមោឃបុរស រៀនមិនល្អហើយយ៉ាង នេះឯង ដូច្នេះ ។

ចំណែកបរិយត្តិណា ដែលបុគ្គលរៀនល្អហើយ គឺប្រាថ្នានូវភាពបរិបូណ៌ នៃគុណ មានសីលក្ខន្ធជាដើម រៀនហើយ មិនមែនរៀនព្រោះហេតុនៃការ ដោះស្រាយវាទៈជាដើម បរិយត្តិនេះ ឈ្មោះថា **និស្សរណត្ថបរិយត្តិ** ដែល ព្រះមានព្រះភាគទ្រង់សំដៅយក ត្រាស់ថា ធម៌ទាំងនោះ ដែលកុលបុត្ត ពួកនោះ រៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលយូរអង្វែង ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះ ហេតុតែធម៌ទាំងឡាយដែលកុលបុត្តទាំងនោះ បានរៀនដោយល្អ ដូច្នេះ ។

ចំណែកព្រះខីណាស្រពដែលមានខន្ធកំណត់ដឹងហើយ លះកិលេសបាន ហើយ មានមគ្គចម្រើនហើយ មានធម៌មិនកម្រើកចាក់ធ្លុះហើយ ធ្វើនិរោធ ឲ្យជាក់ច្បាស់ហើយ រមែងរៀនបរិយត្តិណា ដើម្បីរក្សាប្រពៃណី ដើម្បី រក្សាវង្សតែម្យ៉ាង បរិយត្តិនេះ ឈ្មោះថា ភណ្ឌាគារិកបរិយត្តិ ( បរិយត្តិ ប្រៀបដូចជាឃ្លាំង ) ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបប្រភេទនៃបរិយត្តិ ៣ យ៉ាង ក្នុងព្រះត្រៃបិដកទាំងនោះ ដូចដែលពោលមកហើយនេះឯង ។

មួយទៀត ភិក្ខុអ្នកបដិបត្តិល្អហើយ ក្នុងព្រះវិន័យ អាស្រ័យសីល- សម្បទា រមែងសម្រេចវិជ្ជា ៣ ព្រោះត្រាស់ប្រភេទនៃវិជ្ជា ៣ ទាំងនោះឯង ក្នុងព្រះវិន័យនោះ ។ ភិក្ខុអ្នកបដិបត្តិល្អហើយ ក្នុងព្រះសូត្រ អាស្រ័យ សមាធិសម្បទា រមែងសម្រេចអភិញ្ញា ៦ ព្រោះត្រាស់ប្រភេទនៃអភិញ្ញា

ទាំង ៦ នោះឯង ក្នុងព្រះសូត្រនោះ ។ ភិក្ខុអ្នកបដិបត្តិល្អហើយ ក្នុងព្រះអភិធម្ម អាស្រ័យបញ្ញាសម្បទា រមែងសម្រេចបដិសម្ភិទា ៤ ព្រោះត្រាស់ប្រភេទនៃបដិសម្ភិទាទាំង ៤ នោះឯង ក្នុងព្រះអភិធម្មនោះ ។ ភិក្ខុអ្នកបដិបត្តិដោយល្អ ក្នុងព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្មទាំងនេះ រមែងសម្រេចសម្បត្តិ មានវិជ្ជា ៣ អភិញ្ញា ៦ និងបដិសម្ភិទា ៤ នេះ តាមលំដាប់ដោយប្រការដូច្នេះ ។

មួយទៀត ភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះវិន័យ ជាអ្នកមានសេចក្តីសម្គាល់ថា មិនមានទោសក្នុងផស្សៈដែលមានចិត្តគ្រប់គ្រងជាដើម ដែលព្រះមានព្រះភាគទ្រង់ហាមហើយ ដោយភាពស្មើគ្នា ដោយសម្ផស្ស មានកម្រាល និងសំពត់ស្លៀកដណ្តប់ ដែលមានសម្ផស្សជាសុខជាដើម ដែលទ្រង់អនុញ្ញាតហើយ ដូចពាក្យដែលព្រះអរិដ្ឋៈពោលថា ធម៌ទាំងឡាយណា ដែលព្រះដ៏-មានព្រះភាគសម្តែងថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគ សម្តែងហើយ ដោយប្រការដូច្នោះ ។ តអំពីនោះមកលោកក៏ដល់នូវភាពជាអ្នកទ្រុស្តសីល ។

ភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះសូត្រ មិនដឹងពាក្យអធិប្បាយ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ដូច្នេះ រមែងកាន់យកខុស ដែលព្រះមានព្រះភាគទ្រង់សំដៅយកត្រាស់ថា នែមោឃបុរស កាលបើហេតុមានទំនងយ៉ាងនេះ អ្នកឯង

ហៅថា ពោលបន្អាច់យើងផង ជីកគាស់ខ្លួនឯងផង បានបាបជាច្រើនផង ដោយទិដ្ឋិដែលខ្លួនប្រកាន់ខុស ដូច្នេះ តអំពីនោះ លោកក៏ដល់នូវភាពជាមនុស្សមិច្ឆាទិដ្ឋិ ។ ភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះអភិធម្ម កាលពិចារណាធម៌ហួសប្រមាណ រមែងគិតសូម្បីតែវត្ថុដែលមិនគួរគិត តអំពីនោះ ក៏នឹងដល់នូវសេចក្ដីរវើរវាយនៃចិត្ត សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ អចិន្ត្រៃយ៍ ( ហេតុដែលមិនគួរគិត ) នេះ មាន ៤ ប្រការ ដែលបុគ្គលមិនគួរគិតទេ តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួត និងសេចក្ដីលំបាក ដូច្នេះ ។ ភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះត្រៃបិដកនេះ រមែងដល់នូវវិបត្តិ មានភាពជាអ្នកទ្រុស្តសីល ជាមនុស្សមិច្ឆាទិដ្ឋិ និងសេចក្ដីរវើរវាយនៃចិត្តនេះតាមលំដាប់ ដោយប្រការដូច្នេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ អត្ថនៃគាថានេះ ក៏ឈ្មោះថា ខ្ញុំពោលហើយថា

> ភិក្ខុរមែងសម្រេចប្រភេទនៃបរិយត្តិ សម្បត្តិ និងវិបត្តិឯណា
> ក្នុងបិដកណា ដោយប្រការណា គប្បីអធិប្បាយប្រភេទនៃ
> បរិយត្តិ សម្បត្តិ និងវិបត្តិទាំងអស់នោះ ដោយប្រការដូច្នេះ ។

បណ្ឌិតកាលជ្រាបបិដកទាំងឡាយ ដោយប្រការផ្សេងៗ ដោយអាការយ៉ាងនេះហើយ គប្បីជ្រាបពុទ្ធវចនៈទាំងអស់ដែលប្រមូលមកដោយអំណាចនៃបិដកទាំងនោះថា ជាបិដក ៣ ដូច្នេះ ។

ព្រះពុទ្ធវចនៈ ពោលដោយនិកាយ មាន ៥ និកាយ តើដូចម្តេច ។ ពិតហើយ ព្រះពុទ្ធវចនៈទាំងអស់នោះ មាន ៥ ប្រភេទ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ ។

បណ្តានិកាយទាំង ៥ នោះ ទីឃនិកាយ តើដូចម្តេច ព្រះសូត្រ ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម ដែលសង្គ្រោះ ៣ វគ្គ ហៅថា ទីឃនិកាយ ដូចគាថាដែលលោកចងថា

ព្រះសូត្រ ៣៤ សូត្រប៉ុណ្ណោះ មាន ៣ វគ្គ លោកសង្គ្រោះ
ទុកសម្រាប់និកាយណា និកាយនោះ ឈ្មោះថា ទីឃនិកាយ
រាប់តាមលំដាប់ ជានិកាយទីមួយ ។

សួរថា ព្រោះហេតុអ្វី ទើបនិកាយទីមួយនេះ ហៅថា ទីឃនិកាយ ។ ឆ្លើយថា ព្រោះជាទីប្រជុំ និងជាទីអាស្រ័យនៅនៃព្រះសូត្រទាំងឡាយដែលមានខ្នាតវែង ។

ពិតហើយ ទីជាទីប្រជុំ និងទីជាទីអាស្រ័យនៅ ក៏ហៅថា និកាយ ។ ក្នុងសេចក្តីនេះ មានពាក្យសាធកៈទាំងខាងសាសនា និងផ្លូវលោក ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាននេះ ដ៏វិចិត្រយ៉ាងណា ចិត្តណាដែលវិចិត្រយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញ សូម្បីនូវពួកធម៌មួយដទៃអំពីចិត្តនោះឡើយ ដូច្នេះ ។ និងប្រយោគថា លំនៅ ( និកាយ ) របស់បោណិកខត្តិយៈ លំនៅរបស់ចិក្ខល្លិកខត្តិយៈ ។ គប្បីជ្រាបសេចក្តីនៃពាក្យក្នុងនិកាយ ដែលនៅសល់

( ៤ និកាយទៀត ) ដោយប្រការដូចពោលមកហើយ ។

មជ្ឈិមនិកាយ តើដូចម្ដេច ។ ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម ដែលសង្គ្រោះ ១៥ វគ្គ ជាព្រះសូត្រខ្នាតកណ្ដាល ឈ្មោះថា មជ្ឈិមនិកាយ ដូចគាថាដែលលោកចងថា

ព្រះសូត្រ ១៥២ សូត្រ មានក្នុងនិកាយណា និកាយនោះ
ឈ្មោះថា មជ្ឈិមនិកាយ លោកសង្គ្រោះទុកជា ១៥ វគ្គ ។

សំយុត្តនិកាយ តើដូចម្ដេច ។ ព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ដែលតាំងទុកដោយអំណាចនៃទេវតាសំយុត្តជាដើម ហៅថា សំយុត្តនិកាយ ដូចគាថាដែលលោកចងថា

ព្រះសូត្រ ៧៧៦២ សូត្រ មាននៅក្នុងនិកាយណា និកាយ
នោះ លោកសង្គ្រោះទុកជាសំយុត្តនិកាយ ។

អង្គុត្តរនិកាយ តើដូចម្ដេច ។ ព្រះសូត្រ ៩៥៥៧ សូត្រ មានចិត្តបរិយាទានសូត្រជាដើម ដែលតាំងទុកដោយអំណាចការបន្ថែមឡើងមួយនិបាតៗ ដូចគាថាដែលលោកចងថា

ព្រះសូត្រក្នុងអង្គុត្តរនិកាយ ចំនួន ៩៥៥៧ សូត្រ មាននៅ
ក្នុងនិកាយណា និកាយនោះ ឈ្មោះថា អង្គុត្តរនិកាយ ។

ខុទ្ទកនិកាយ តើដូចម្ដេច ។ គឺវិន័យបិដក អភិធម្មបិដកទាំងអស់ និងបាឋៈ ១៥ ប្រភេទ មានធម្មបទ ខុទ្ទកបាឋៈជាដើម ដែលសម្ដែងមុនហើយ វៀរនិកាយ ៤ ( មានទីឃនិកាយជាដើម ) ព្រះពុទ្ធវចនៈដ៏សេស

ឈ្មោះថា ខុទ្ទកនិកាយ ។ ដូចគាថាដែលលោកចងថា

វៀរលែងនិកាយ ៤ មានទីឃនិកាយជាដើមនេះ ព្រះពុទ្ធ-វចនៈដទៃក្រៅអំពីទីឃនិកាយជាដើមនោះ ហៅថា ខុទ្ទក-និកាយ ។

និកាយ ៥ យ៉ាង រមែងមានដោយអំណាចនៃនិកាយយ៉ាងនេះ ។

ព្រះពុទ្ធវចនៈមានអង្គ ៩ តើដូចម្ដេចខ្លះ ។ ពិតហើយ ព្រះពុទ្ធវចនៈទាំងអស់នេះ មាន ៩ ប្រភេទ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ។ បណ្ដាអង្គទាំង ៩ នោះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារ ព្រះសូត្រក្នុងសុត្តនិបាត មានមង្គលសូត្រ រតនសូត្រ នាលកសូត្រ និងតុវដ្ដកសូត្រជាដើម និងព្រះតម្រាស់របស់ព្រះតថាគត សូម្បីដទៃដែលមានឈ្មោះថា សុត្តន្ត គប្បីជ្រាបថា ជា **សុត្ត** ។

ព្រះសូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា ជាគេយ្យៈ ពោលដោយចំពោះ សគាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយជា **គេយ្យៈ** ។ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រ ដែលមិនមានគាថា និងព្រះពុទ្ធវចនៈដទៃដែលមិនប្រកបដោយអង្គ ៨ គប្បីជ្រាបថាជា **វេយ្យាករណៈ** ។ ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះថាសូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថាជា **គាថា** ។ ព្រះសូត្រ ៨២ សូត្រ ដែលបដិសំយុត្តដោយគាថាដែលសម្រេចដោយសោមនស្សញ្ញាណ គប្បីជ្រាបថាជា **ឧទាន** ។

ព្រះសូត្រ ១១០ សូត្រ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **វុត្តញ្ហេតំ ភគវតា** គប្បីជ្រាបថាជា **ឥតិវុត្តកៈ** ។ ជាតក ៥៥០ ជាតក មាន អបណ្ណកជាតកជាដើម គប្បីជ្រាបថាជា **ជាតក** ។ ព្រះសូត្រដែលបដិ-សំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យជាដើម ថា ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភូតធម៌ ( ធម៌ជាអស្ចារ្យចម្លែក ) ទាំង-ឡាយ ៤ យ៉ាងនេះ មាននៅក្នុងអានន្ទ ដូច្នេះ គប្បីជ្រាបថាជា **អព្ភូត-ធម៌** ។ ព្រះសូត្រដែលមានអ្នកទូលសួរហើយ បានហើយបានទៀតនូវការ ដឹង និងការត្រេកអរទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណមសូត្រ ជាដើម គប្បីជ្រាបថាជា **វេទល្លៈ** ។ កាលពោលដោយអង្គ ព្រះពុទ្ធវចនៈ មានអង្គ ៩ ដោយប្រការដូច្នេះ ។

ព្រះពុទ្ធវចនៈ ៨៤០០០ ព្រះធម្មក្ខន្ធដោយធម្មក្ខន្ធ តើដូចម្តេច ។ ពិតហើយ ព្រះពុទ្ធវចនៈទាំងអស់នេះឯង មាន ៨៤០០០ ប្រភេទ ដោយ អំណាចនៃព្រះធម្មក្ខន្ធ ដែលព្រះអានន្ទរបររមសម្តែង ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) យ៉ាងនេះថា

> សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ ( ក្នុងហឫទ័យ )
> របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ម៉ឺន ៤ ពាន់
> ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ម៉ឺន ២ ពាន់ធម្មក្ខន្ធ
> អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ដូច្នេះ ។

បណ្ដាពុទ្ធវចនៈទាំងនោះ ព្រះសូត្រមានអនុសន្ធិមួយ ហៅថា ធម្មក្ខន្ធមួយ ។ ព្រះសូត្រណា មានច្រើនអនុសន្ធិ ក៏រាប់ចំនួនធម្មក្ខន្ធ តាមអនុសន្ធិក្នុងព្រះសូត្រនោះ ។ ក្នុងការចងជាគាថា ការសួរបញ្ហាជាធម្មក្ខន្ធមួយ ការវិស្សជ្ជនា ក៏ជាធម្មក្ខន្ធមួយ ។ ក្នុងព្រះអភិធម្ម ការចែកតិកៈ និងទុកៈមួយពួកៗ និងការចែកវារចិត្តមួយយ៉ាងៗ ក៏ជាធម្មក្ខន្ធមួយ ។ ក្នុងព្រះវិន័យ មានវត្ថុ មាតិកា បទភាជនីយ អាបត្តិ អនាបត្តិ អន្តរាបត្តិ ការកំណត់តិកៈធម៌ដែលជាអតេកិច្ឆ ធម៌ដែលជាសតេកិច្ឆ ក្នុងវត្ថុជាដើមទាំងនេះ មួយចំណែកៗ គប្បីជ្រាបថាជាធម្មក្ខន្ធមួយៗ ។ ពោលដោយធម្មក្ខន្ធ គប្បីជ្រាបថា ជាធម្មក្ខន្ធ ៨៤០០០ ធម្មក្ខន្ធ ដោយអាការយ៉ាងនេះ ។

ព្រះពុទ្ធវចនៈទាំងអស់នោះ តាមដែលពោលហើយនុ៎ះឯង ដែលពួកសង្ឃអ្នកមានវសី មានព្រះមហាកស្សបជាប្រធាន កាលសង្គាយនាក្នុងវេលាធ្វើបញ្ចសតិកសង្គីតិ បានសង្គាយនាកំណត់ប្រភេទយ៉ាងច្បាស់ ដូច្នេះថា នេះជាធម៌ នេះជាវិន័យ នេះជាបឋមពុទ្ធវចនៈ នេះជាមជ្ឈិមពុទ្ធវចនៈ នេះជាបច្ឆិមពុទ្ធវចនៈ នេះជាវិនយបិដក នេះជាសុត្តន្តបិដក នេះជាអភិធម្មបិដក នេះជាទីឃនិកាយ ។បេ។ នេះជាខុទ្ទកនិកាយ ទាំងនេះជានវង្គសត្ថុសាសនៈ ដែលមានសុត្តៈជាដើម ទាំងនេះជាធម្មក្ខន្ធ មាន ៨៤០០០ ធម្មក្ខន្ធ ដូច្នេះ ។ មួយទៀត ព្រះថេរៈទាំងនោះ មិនបានកំណត់ត្រឹមប្រភេទដែលពោលមកនេះប៉ុណ្ណោះ បានកំណត់ប្រភេទសង្គហៈ សូម្បីដទៃទៀតៗ ដែលប្រាកដក្នុងបិដកទាំង ៣ មិនមែនតិច មានដូចជាឧទានសង្គហៈ

វគ្គសង្គហៈ បេយ្យាលសង្គហៈ និបាតសង្គហៈ មានឯកនិបាត ទុកនិបាតជាដើម សំយុត្តសង្គហៈ និងបណ្ណាសកសង្គហៈជាដើម សង្គាយនាហើយយ៉ាងនេះ អស់ ៧ ខែ ។

ក្នុងអវសាននៃការសង្គាយនាព្រះពុទ្ធវចនៈនោះ មហាប្រឹថពីនេះ បានកក្រើកញាប់ញ័រ មានប្រការមិនមែនតិច រហូតទៅដល់ទឹកទ្រផែនដី ជាទីបំផុត ដូចមានបាមោជ្ជកើតឡើងព្រម ហើយឲ្យនូវសាធុការថា ចូរមើលសាសនារបស់ព្រះទសពលនេះ ដែលព្រះមហាកស្សបត្ថេរធ្វើឲ្យអាចប្រព្រឹត្តទៅអស់កាលប្រមាណ ៥០០០ ឆ្នាំ និងបានកើតសេចក្តីអស្ចារ្យទាំងឡាយជាអនេកប្បការ ។

ក្នុងបិដកនេះ កាលព្រះថេរៈទាំងឡាយ សង្គាយនាព្រះពុទ្ធវចនៈហើយយ៉ាងនេះ ព្រះអភិធម្មនេះ កាលពោលដោយបិដកជា **អភិធម្មបិដក** កាលពោលដោយនិកាយជា **ខុទ្ទកនិកាយ** កាលពោលដោយអង្គជា **វេយ្យាករណៈ** កាលពោលដោយធម្មក្ខន្ធជា **ធម្មក្ខន្ធច្រើនពាន់ធម្មក្ខន្ធ** ( ៤២០០០ ធម្មក្ខន្ធ ) ។ បណ្តាភិក្ខុទាំងឡាយ អ្នកទ្រទ្រង់ព្រះអភិធម្មនោះ ក្នុងកាលមុន មានភិក្ខុមួយរូប អង្គុយនៅក្នុងទីប្រជុំបរិស័ទ កាលនឹងនាំសូត្រចាកព្រះអភិធម្មមកពោល បានពោលធម្មកថាថា រូបក្ខន្ធ ជាអព្យាកតៈ ខន្ធ ៤ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន អាយតនៈ ១០ ជាអព្យាកតៈ អាយតនៈ ២ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ធាតុ ១៦ ជាអព្យាកតៈ ធាតុ ២ ជាកុសលក៏មាន ជាអកុ-

សលក៏មាន ជាអព្យាកតៈក៏មាន សមុទយសច្ច ជាអកុសល មគ្គសច្ច ជាកុសល និរោធសច្ច ជាអព្យាកតៈ ទុក្ខសច្ច ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ឥន្ទ្រិយ ១០ ជាអព្យាកតៈ ទោមនស្សិន្ទ្រិយ ជាអកុសល អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ជាកុសល ឥន្ទ្រិយ ៤ ជាកុសលក៏មាន ជាអព្យាកតៈក៏មាន ឥន្ទ្រិយ ៦ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ដូច្នេះ ។

ភិក្ខុមួយរូប ដែលអង្គុយនៅក្នុងទីនោះ បានសួរព្រះធម្មកថិកថា អ្នកមានអាយុធម្មកថិក លោកនាំសូត្រមកវែងដូចយកមករុំព័ទ្ធភ្នំសិនេរុ សូត្រនេះ មានឈ្មោះដូចម្តេច ។ ព្រះធម្មកថិក ឆ្លើយថា ឈ្មោះថា ព្រះអភិធម្មសូត្រ អ្នកដ៏មានអាយុ ។ ភិក្ខុនោះ សួរថា ព្រោះហេតុអ្វី ទើបនាំព្រះអភិធម្មសូត្រមក ការនាំព្រះសូត្រដទៃដែលជាពុទ្ធភាសិតមក មិនសមគួរឬ ។ ព្រះធម្មកថិក សួរថា ព្រះអភិធម្ម អ្នកណាសម្តែង ។ ភិក្ខុនោះ ឆ្លើយថា ព្រះអភិធម្មនេះ មិនមែនជាពុទ្ធភាសិត ។ ព្រះធម្មកថិក សួរថា អ្នកដ៏មានអាយុ លោករៀនវិនយបិដកដែរឬទេ ។ ភិក្ខុនោះឆ្លើយថា ខ្ញុំមិនបានរៀនទេ អាវុសោ ។ ព្រះធម្មកថិកសួរថា ប្រហែលព្រោះតែលោកមិនទ្រទ្រង់ព្រះវិន័យ កាលមិនដឹង ទើបពោលយ៉ាងនេះ ។ ភិក្ខុនោះ ឆ្លើយថា ពោលត្រឹមតែព្រះវិន័យ ខ្ញុំក៏រៀនមកដូចគ្នា ។ ព្រះធម្មកថិក ពោលថា សូម្បីវិន័យនោះ លោកក៏រៀនមកមិនល្អ គង់នឹងអង្គុយរៀនហើយដេកលក់ នៅខាងក្រោយបរិស័ទ ឬថា ព្រះឧបជ្ឈាយ៍អ្នកឲ្យបុគ្គលដូចជា

លោកបព្វជ្ជាឧបសម្បទា គង់នឹងភ្ញាំងភ្ញាត់ទៅ ព្រោះហេតុអ្វី ព្រោះត្រឹមតែវិន័យ លោកក៏រៀនមិនល្អ ពិតហើយ ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះ ក្នុងព្រះវិន័យនោះថា វារៈដែលមិនត្រូវអាបត្តិ ( ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង ) គឺភិក្ខុមិនចង់ពោលបន្ទាប់ ១ ភិក្ខុពោលថា ណ្ហើយចុះ ចូរអ្នករៀនព្រះសូត្រទាំងឡាយក្តី គាថាទាំងឡាយក្តី អភិធម្មក្តី ជាមុនសិន ចាំរៀនវិន័យជាខាងក្រោយវិញ ១ ដូច្នេះ និងពុទ្ធដីកាថា ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងព្រះសូត្រ ហើយបែរទៅសួរវិន័យក្តី អភិធម្មក្តី ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងអភិធម្ម ហើយបែរទៅសួរព្រះសូត្រក្តី វិន័យក្តី ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងវិន័យ ហើយបែរទៅសួរព្រះសូត្រក្តី អភិធម្មក្តី ... ដូច្នេះ ពាក្យមានប្រមាណប៉ុណ្ណេះ លោកក៏មិនដឹង ។

ព្រះធម្មកថិកនោះ ទើបជាអ្នកគ្រប់សង្កត់បរវាទីបាន ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

មហាគោសិង្គសូត្រ ជាសូត្រសំខាន់ជាងសូត្រនេះ ព្រោះជាពុទ្ធភាសិត ។ ពិតហើយ ក្នុងមហាគោសិង្គសូត្រ ( មហាគោសិង្គសាលសូត្រ ) នោះ ព្រះធម្មសេនាបតីសារីបុត្តត្ថេរ ទៅគាល់ព្រះមានព្រះភាគ ដើម្បីក្រាបទូលបញ្ហា ដែលសាកសួរ និងពាក្យវិស្សជ្ជនានូវគ្នានិងគ្នា កាលនឹងប្រាប់ពាក្យវិស្សជ្ជនា របស់ព្រះមហាមោគ្គល្លានត្ថេរ ទើបក្រាបទូលថា ម្នាលអាវុសោសារីបុត្ត ភិក្ខុទាំងឡាយពីររូបក្នុងសាសនានេះ សម្តែងនូវអភិធម្មកថា ភិក្ខុទាំងនោះសួរគ្នានិងគ្នា លុះសួរប្រស្នាហើយ ដោះស្រាយដល់គ្នានិងគ្នា ក៏

មិនបានរុករកពន្លាផង កថារបស់ភិក្ខុទាំងនោះ ប្រព្រឹត្តទៅប្រកបដោយធម៌ផង ម្នាលអាវុសោសារីបុត្ត ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ដូច្នេះ ។

ព្រះសាស្ដាមិនត្រាស់ថា ដែលឈ្មោះថាភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្ម ជាអ្នកស្ថិតនៅខាងក្រៅសាសនារបស់តថាគត ដូច្នេះ តែទ្រង់លើកព្រះសូរង ឡើង ដូចសុវណ្ណភិង្គារ ( កុណ្ឌីមាស ) មានព្រះភក្ត្រដ៏មានសិរី ដូចព្រះចន្ទរះ ទ្រង់បញ្ចេញសូរសៀង ខ្ទរខ្ទារដូចសំឡេងរបស់ព្រហ្ម ប្រទានសាធុការដល់ព្រះមហាមោគ្គល្លានត្ថេរថា ម្នាលសារីបុត្ត ត្រូវល្អហើយ ដូច្នេះហើយ ត្រាស់ថា មោគ្គល្លានព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្ត ព្រោះថា មោគ្គល្លាន ជាធម្មកថិក ដូច្នេះ ។

មែនពិត បានឮថា ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មប៉ុណ្ណោះ ឈ្មោះថា ព្រះធម្មកថិក ក្រៅពីនេះ សូម្បីពោលធម៌ ក៏មិនមែនជាព្រះធម្មកថិក ព្រោះហេតុអ្វី ព្រោះថា ភិក្ខុអ្នកមិនទ្រទ្រង់ព្រះអភិធម្មទាំងនោះ កាលពោលធម៌ រមែងពោលលាំដាប់កម្ម លាំដាប់វិបាក កំណត់រូប និងអរូប លាំដាប់ធម៌ ឲ្យប្រហូកប្រហល់ ចំណែកភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្ម រមែងមិនឲ្យលាំដាប់ធម៌ប្រហូកប្រហល់ ព្រោះហេតុនោះ ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្ម ពោលធម៌ក្ដី មិនបានពោលក្ដី តែក្នុងវេលាដែលលោកត្រូវសាកសួរបញ្ហាហើយ ក៏នឹងពោលដោះស្រាយបញ្ហានោះបាន ។ ព្រះសាស្ដា ទ្រង់សំដៅដល់ពាក្យនេះថា ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មនេះប៉ុណ្ណោះ ឈ្មោះថា ជាព្រះធម្មកថិកដោយពិត

ដូច្នេះ ទើបទ្រង់ប្រទានសាធុការ ហើយត្រាស់ថា មោគ្គល្លានពោលល្អហើយ ដូច្នេះ ។

បុគ្គលកាលជំទាស់នឹងព្រះអភិធម្ម ឈ្មោះថា រមែងឲ្យនូវការប្រហារ ជិនចក្កនេះ រមែងជំទាស់ព្រះសព្វញ្ញុតញ្ញាណ រមែងមើលងាយវេសា-រជ្ជញ្ញាណរបស់ព្រះសាស្តា រមែងរារាំងបរិស័ទអ្នកត្រូវការស្តាប់ រមែងធ្វើនូវគ្រឿងរារាំងអរិយមគ្គ នឹងប្រាកដក្នុងភេទករវត្ថុ ១៨ យ៉ាង ណាមួយ ជាអ្នកគួរដល់ឧក្ខេបនីយកម្ម និយស្សកម្ម តជ្ជនីយកម្ម ព្រោះធ្វើកម្មនោះ ទើបគួរបញ្ជូនលោកទៅថា ចូរលោកទៅ ចូរជាមនុស្សស៊ីដែល ចិញ្ចឹមជីវិតចុះ ដូច្នេះ ។

បើបុគ្គលគប្បីពោលយ៉ាងនេះថា ប្រសិនបើព្រះអភិធម្ម ជាពុទ្ធភាសិតសោត សូម្បីនិទានរបស់ព្រះអភិធម្មនោះ ក៏គួរបាត់ជាព្រះអភិធម្មផង ដូចនិទានដែលលោកចាត់ទុកច្រើនពាន់ព្រះសូត្រ ដោយន័យជាដើមថា សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនគររាជគ្រឹះ ដូច្នេះ ។ គប្បីជំទាស់នឹងអ្នកនោះថា និទានរបស់ជាតក សុត្តនិបាត និងធម្មបទជាដើម បែបនេះ ក៏មិនមាន ធម៌ទាំងនេះ ក៏មិនមែនពុទ្ធភាសិតទេដឹង ហើយគប្បីប្រាប់ឲ្យក្រៃលែងជាងនេះ ដោយអាការយ៉ាងនេះថា នែបណ្ឌិត ធម្មតាព្រះអភិធម្មនេះ ជាវិស័យរបស់ព្រះសព្វញ្ញុពុទ្ធទាំងឡាយប៉ុណ្ណោះ មិនមែនវិស័យរបស់ពួកជនដទៃ មែនពិត ការយាងចុះកាន់ផ្ទៃរបស់ព្រះពុទ្ធទាំងឡាយ ប្រាកដហើយ អភិជាតិក៏ប្រាកដ អភិសម្ពោធិក៏ប្រាកដ ធម្មចក្កប្បវត្តនៈក៏ប្រាកដ

យមកប្បាដិហារិយ៍ក៏ប្រាកដ ការចូលទៅកាន់លំនៅរបស់ទេវតាក៏ប្រាកដ ការសម្តែងធម៌ក្នុងទេវលោកក៏ប្រាកដ ការយាងចុះអំពីទេវលោកក៏ប្រាកដ ដែលឈ្មោះថា ការលួចដីរកែវ ឬសេះកែវរបស់ស្តេចចក្កពត្តិ ហើយទីម រថតូចទៅ នុ៎ះមិនមែនជាឋានៈ មិនមែនជាហេតុ ឬថា ឈ្មោះថា ការលួច ចក្ករតនៈ ហើយព្យួរត្រង់រទេះផ្ទុកចំបើងយកទៅ មិនមែនជាឋានៈ មិន មែនជាហេតុដែលប្រព្រឹត្តទៅបាន ឬឈ្មោះថា ការលួចមណីរតនៈ ដែល អាចបំភ្លឺបានឆ្ងាយប្រមាណមួយយោជន៍ ទុកក្នុងកញ្ច្រែងកប្បាស ហើយប្រើ ប្រាស់ ក៏មិនមែនជាឋានៈ មិនមែនជាហេតុដែលប្រព្រឹត្តទៅបាន ព្រោះ ហេតុអ្វី ព្រោះជាកណ្ឌៈ សមគួរដល់ស្តេចចក្កពត្តិ សេចក្តីនេះយ៉ាងណា ធម្មតាព្រះអភិធម្ម ក៏យ៉ាងនោះដូចគ្នា មិនមែនវិស័យរបស់ពួកជនដទៃ ជា វិស័យរបស់ព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ និងទេសនាក៏ជាទេសនាទ្រង់សម្តែង ដោយអំណាចនៃព្រះសព្វញ្ញុពុទ្ធទាំងនោះ ពិតហើយ ការយាងចុះកាន់ផ្ទៃ របស់ព្រះពុទ្ធទាំងឡាយ ប្រាកដហើយ ។បេ។ ការយាងចុះអំពីទេវលោក ក៏ប្រាកដ នៃបណ្ឌិត ឈ្មោះថា កិច្ចដោយនិទានរបស់ព្រះអភិធម្ម ទើបមិន មាន ។ កាលពោលយ៉ាងនេះហើយ បរវាទីក៏មិនអាចលើកឧទាហរណ៍ ដែលប្រកបដោយធម៌ មកឆ្លើយឆ្លងបាន ។

ចំណែកព្រះតិស្សភូតិត្ថេរ អ្នកនៅក្នុងមណ្ឌលារាមបាននាំបទេសវិហារ-សូត្រនេះមកពោលថា ព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ដឹងជាដំបូង

ដោយធម៌ជាគ្រឿងនៅឯណា តថាគតក៏បានសម្រេចសម្រាន្តនៅ ដោយចំណែកនៃធម៌ជាគ្រឿងនៅនោះ ដូច្នេះ ដើម្បីសម្តែងថា ព្រះអភិធម្មនេះ មានមហាពោធិជានិទាន ដូច្នេះ ។ ពិតហើយ ឈ្មោះថា បទេស ( ក្នុងបទេសវិហារសូត្រ ) មាន ១០ យ៉ាង គឺខន្ធប្បទេស អាយតនប្បទេស ធាតុប្បទេស សច្ចប្បទេស ឥន្ទ្រិយប្បទេស បច្ចយាការប្បទេស សតិប្បដ្ឋានប្បទេស ឈានប្បទេស នាមប្បទេស ធម្មប្បទេស បណ្តាបទេសទាំង ១០ នោះ គប្បីជ្រាបដូចតទៅ

ព្រះសាស្តា ទ្រង់ចាក់ធ្លុះបញ្ចក្ខន្ធដោយឥតសេសសល់ ត្រង់មណ្ឌលមហាពោធិព្រឹក្ស ហើយទ្រង់ប្រថាប់នៅដោយវេទនាខន្ធនោះឯង អស់ត្រៃមាសនេះ ទ្រង់ចាក់ធ្លុះអាយតនៈ ១២ ធាតុ ១៨ ដោយឥតសេសសល់ ហើយប្រថាប់នៅដោយអំណាចវេទនា ក្នុងធម្មាយតនៈ និងដោយអំណាចវេទនាក្នុងធម្មធាតុនុ៎ះឯង អស់ត្រៃមាសនេះ ទ្រង់ចាក់ធ្លុះសច្ចៈ ៤ ដោយឥតសេសសល់ ហើយប្រថាប់នៅដោយអំណាចវេទនា ក្នុងទុក្ខសច្ចនុ៎ះឯង អស់ត្រៃមាសនេះ ទ្រង់ចាក់ធ្លុះឥន្ទ្រិយ ២២ ដោយឥតសេសសល់ ហើយគង់នៅដោយអំណាចនៃឥន្ទ្រិយក្នុងពួក ៥ នៃវេទនាអស់ត្រៃមាសនេះ ទ្រង់ចាក់ធ្លុះបរិវដ្តៈនៃបច្ចយាការ ១២ បទ ដោយឥតសេសសល់ ហើយគង់នៅដោយអំណាចនៃវេទនាដែលមានផស្សៈជាបច្ច័យអស់ត្រៃមាសនេះ ទ្រង់ចាក់ធ្លុះសតិប្បដ្ឋាន ៤ ដោយឥតសេសសល់ហើយ គង់នៅដោយអំណាចនៃវេទនាសតិប្បដ្ឋានអស់ត្រៃមាសនេះ ទ្រង់ចាក់ធ្លុះឈាន ៤ ដោយអំណាច

នៃវេទនាក្នុងអន្តរាយទាំងឯង អស់ត្រៃមាសនេះ ទ្រង់ចាក់ផ្ទះនាមដោយឥត សេសសល់ ហើយគង់នៅដោយអំណាចនៃវេទនាក្នុងនាមនោះឯង អស់ត្រៃ មាសនេះ ទ្រង់ចាក់ផ្ទះធម៌ទាំងឡាយ ដោយឥតសេសសល់ ហើយគង់នៅ ដោយអំណាចនៃវេទនាតិកៈទាំងឯង អស់ត្រៃមាសនេះ ដូច្នេះ ព្រះថេរៈពោល និទាននៃព្រះអភិធម្ម ដោយអំណាចនៃបទេសវិហារសូត្រយ៉ាងនេះ ។

ចំណែកព្រះសុមនទេវត្ថេរ អ្នកនៅក្នុងគាមវាសី កាលសន្ទនាធម៌ខាង ក្រោមលោហប្រាសាទ ពោលថា បរវាទីបុគ្គលនេះ ដូចជាផ្គងដៃទាំងពីរ ទួញសោកនៅក្នុងព្រៃ និងសាងគតិដែលមិនមានសាក្សី ទើបមិនជ្រាបសូម្បី ព្រះអភិធម្មថា មាននិទានហើយពោលយ៉ាងនេះទៀតថា សម័យមួយ ព្រះមាន ព្រះភាគ គង់នៅត្រង់បណ្ឌុកម្ពលសិលាសនៈ ត្រង់មណ្ឌលបារិច្ឆត្តកព្រឹក្ស នាស្ថានតាវត្តិង្ស ក្នុងគ្រានោះឯង ព្រះមានព្រះភាគត្រាស់អភិធម្មកថា ដល់ ទេវតាក្នុងស្ថានតាវត្តិង្សថា **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា** ជាដើម ។ ចំណែកក្នុងព្រះសូត្រដទៃៗក៏មាននិទានដូចគ្នា ទាំងឯង ។

ក្នុងព្រះអភិធម្មមាននិទាន ២ យ៉ាង គឺ **អធិគមនិទាន និងទេសនានិទាន** ។ បណ្តានិទានទាំង ២ នោះ អធិគមនិទាន គប្បីជ្រាបតាំងអំពីព្រះទសពល ទ្រង់ព្រះនាមទីបង្ករ រហូតដល់មហាពោធិបល្ល័ង្ក **ទេសនានិទាន** គប្បី ជ្រាបរហូតដល់ការប្រកាសព្រះធម្មចក្ក ។ បណ្ឌិតគប្បីជ្រាបការតាំងបញ្ហា ដើម្បីភាពជាអ្នកឈ្លាសក្នុងនិទានរបស់ព្រះអភិធម្ម ដែលបរិបូរណ៍ដោយនិទាន ទាំង ២ យ៉ាងនេះ ដូចតទៅនេះមុន ។ សួរថា ព្រះអភិធម្មនេះឲ្យចម្រើន

មកដោយអ្វី ឲ្យដុះដាលក្នុងទីណា សម្រេចហើយក្នុងទីណា សម្រេចហើយក្នុងកាលណា នរណាសម្រេច ពិចារណាហើយក្នុងទីណា ពិចារណាហើយក្នុងកាលណា នរណាពិចារណាហើយ សម្ដែងក្នុងទីណា សម្ដែងហើយដើម្បីប្រយោជន៍ដល់នរណា សម្ដែងហើយដើម្បីអ្វី ពួកជនណា ទទួល ពួកជនណា កំពុងសិក្សា ពួកជនណា សិក្សាហើយ ពួកជនណា ទ្រទ្រង់ជាពាក្យរបស់នរណា នរណានាំមក ដូច្នេះ ។

ក្នុងបញ្ហានោះ មានវិសជ្ជនាដូច្នេះ សំណួរថា ព្រះអភិធម្មនេះឲ្យចម្រើនមកដោយអ្វី ឆ្លើយថា ឲ្យចម្រើនមកដោយសទ្ធា ឆ្ពោះមុខទៅកាន់បញ្ញា ជាគ្រឿងត្រាស់ដឹង ។ សំណួរថា ឲ្យដុះដាលក្នុងទីណា ឆ្លើយថា ឲ្យដុះដាលក្នុងជាតក ៥៥០ ។ សំណួរថា សម្រេចហើយក្នុងទីណា ឆ្លើយថា ត្រង់មណ្ឌលពោធិព្រឹក្ស ។ សំណួរថា សម្រេចក្នុងកាលណា ឆ្លើយថា ក្នុងថ្ងៃ ១៥ កើត ខែវិសាខ ។ សំណួរថា នរណាសម្រេច ឆ្លើយថា ព្រះសព្វញ្ញុ-ពុទ្ធ ។ សំណួរថា ពិចារណាក្នុងទីណា ឆ្លើយថា ទៀបគល់ពោធិព្រឹក្ស ។ សំណួរថា ពិចារណាហើយក្នុងកាលណា ឆ្លើយថា ក្នុងវេលា ៧ ថ្ងៃ ត្រង់ផ្ទះកែវ ។ សំណួរថា នរណាពិចារណា ឆ្លើយថា ព្រះសព្វញ្ញុពុទ្ធ ។ សំណួរថា សម្ដែងក្នុងទីណា ឆ្លើយថា ក្នុងស្ថានតាវត្តិង្ស ។ សំណួរថា សម្ដែងហើយដើម្បីប្រយោជន៍ដល់នរណា ឆ្លើយថា ដល់ទេវតាទាំងឡាយ ។ សំណួរថា សម្ដែងហើយដើម្បីអ្វី ឆ្លើយថា ដើម្បីចេញចាកឱឃៈទាំង ៤ ។ សំណួរថា នរណាទទួល ឆ្លើយថា ពួកទេវតា ។ សំណួរថា នរណា

កំពុងសិក្សា ឆ្លើយថា ព្រះសេក្ខៈ និងកល្យាណបុថុជ្ជន ។ សំណួរថា នរណាសិក្សាហើយ ឆ្លើយថា ព្រះអរហន្តខីណាស្រព ។ សំណួរថា នរណាទ្រទ្រង់ ឆ្លើយថា ប្រព្រឹត្តទៅដល់ពួកជនណា ពួកជននោះ រមែងទ្រទ្រង់ចាំ ។ សំណួរថា ជាពាក្យរបស់នរណា ឆ្លើយថា ជាព្រះតម្រាស់របស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ សំណួរថា នរណាជាអ្នកនាំមក ឆ្លើយថា អាចារ្យនាំតៗ គ្នាមក ។

ពិតហើយ ព្រះអភិធម្មនេះដែលព្រះថេរៈទាំងឡាយ គឺព្រះសារីបុត្តត្ថេរ ព្រះភទ្ទជិ ព្រះសោភិតៈ ព្រះបិយជាលី ព្រះបិយបាល ព្រះបិយទស្សី ព្រះកោសិយបុត្ត ព្រះសិគ្គវៈ ព្រះសន្ទេហៈ ព្រះមោគ្គលីបុត្ត ព្រះតិស្សទត្ត ព្រះធម្មិយ ព្រះទាសក ព្រះសោណក ព្រះរេវតៈជាអ្នកនាំមក រហូតមកដល់កាលនៃតតិយសង្គីតិ តអំពីនោះ សិស្សានុសិស្សរបស់ព្រះថេរៈទាំងនោះឯង នាំមកហើយ ដោយបន្តមកតាមអាចារ្យ ក្នុងជម្ពូទ្វីបយ៉ាងនេះ ដោយអាការយ៉ាងនេះ ។

ចំណែកព្រះថេរៈដ៏ប្រសើរទាំងនេះ គឺ

> ក្នុងកាលនោះ ព្រះថេរៈដ៏ប្រសើរ មានបញ្ញាច្រើនទាំងនេះ គឺ
> ព្រះមហិន្ទត្ថេរ ១ ព្រះឥដ្ឋិយត្ថេរ ១ ព្រះឧត្តិយត្ថេរ ១ ព្រះ
> សម្ពលត្ថេរ ១ ព្រះថេរៈជាបណ្ឌិតឈ្មោះថាភទ្ទ ១ មកក្នុង
> កោះសីហឡនេះ អំពីជម្ពូទ្វីប ។

នាំព្រះអភិធម្មមកហើយកាន់កោះនេះ បន្ទាប់អំពីនោះ ព្រះអភិធម្មនោះ

ដែលអាចារ្យដទៃៗ ពោល គឺសិស្សានុសិស្សរបស់ព្រះថេរៈទាំងនោះឯង នាំបន្តគ្នាមក រហូតដល់បច្ចុប្បន្ននេះ ។

# អធិគមនិទាន

## សុមេធកថា

ពោលដល់អធិគមនិទាន ចាប់តាំងអំពីព្រះទសពលព្រះនាមទីបង្ករ រហូតដល់មហាពោធិបល្ល័ង្ក និងពោលដល់ទេសនានិទាន រហូតដល់ទ្រង់ប្រកាសធម្មចក្ករបស់ព្រះអភិធម្មនោះ ដែលព្រះមហានាគទាំងឡាយ នាំមកហើយយ៉ាងនេះឯណា ដើម្បីការជាក់ច្បាស់នៃអធិគមនិទាន និងទេសនា-និទាននោះ គប្បីជ្រាបអនុបុព្វីកថាដូចតទៅនេះ

បានឮថា ក្នុងទីបំផុតនៃបួនអសង្ខេយ្យ ក្រៃលែងដោយមួយសែនកប្ប រាប់ថយក្រោយអំពីភទ្ទកប្បនេះទៅ មាននគរឈ្មោះថា **អមរវតី** ព្រាហ្មណ៍ឈ្មោះសុមេធ ជាអ្នកកើតល្អហើយទាំងពីរចំណែក គឺជាអ្នកមានកំណើតបរិសុទ្ធល្អហើយ អំពីមាតា និងបិតា អស់ ៧ ជួរត្រកូល ជាបុគ្គលដែលបុគ្គលណាមួយមិនមើលងាយ មិនរង្កៀសដោយការពោលដល់ជាតិ ត្រកូល ជាអ្នកមានរូបល្អ គួរពិតពិលរមិលមើល នាំមកនូវសេចក្តីជ្រះថ្លា ប្រកបដោយវណ្ណៈ និងទ្រង់ទ្រាយល្អ អាស្រ័យនៅក្នុងនគរអមរវតីនោះ ។ សុមេធ-ព្រាហ្មណ៍នោះ មិនបានធ្វើការងារដទៃ ក្រៅពីរៀនសិប្បៈរបស់ព្រាហ្មណ៍ប៉ុណ្ណោះ ។ ក្នុងវេលាដែលគេនៅជាកំលោះនុ៎ះឯង មាតាបិតាបានធ្វើកាល-កិរិយាហើយ ។ គ្រានោះ រាសិវឌ្ឍកអមាត្យ បាននាំបញ្ជីទ្រព្យមក ហើយបើកបន្ទប់ដែលពេញដោយមាសប្រាក់ កែវមណី និងកែវមុក្តាជាដើម ហើយប្រាប់ទ្រព្យរហូតដល់ ៧ តំណនៃត្រកូលថា ម្នាលកុមារ ទ្រព្យដែលជា

របស់នៃមាតារបស់អ្នក មានប្រមាណប៉ុណ្ណេះ ទ្រព្យដែលជារបស់នៃបិតា ជីតា ជីដូនរបស់អ្នក មានប្រមាណប៉ុណ្ណេះជាដើម ហើយពោលថា ចូរអ្នកប្រើប្រាស់ទ្រព្យនោះ ។

សុមេធបណ្ឌិតគិតថា បិយជនទាំងឡាយរបស់អញ មានបិតា និងជីតាជាដើម រួបរួមទ្រព្យនេះហើយ នាំគ្នាទៅកាន់បរលោក មិនបានកាន់យកសូម្បីតែកហាបណៈមួយទៅ ចំណែកអញនឹងធ្វើហេតុដែលអាចឲ្យកាន់យកទៅបាន ទើបសមគួរ ហើយក៏ក្រាបទូលដល់ព្រះរាជា ហើយឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ឲ្យទានដល់មហាជន ហើយបួសជាតាបស ។ បណ្ឌិតគប្បីពោលសុមេធកថាក្នុងទីនេះ ។

ពិតហើយ រឿងសុមេធតាបសនេះ លោកពោលក្នុងពុទ្ធវង្សថា

ក្នុង ៤ អសង្ខេយ្យ និង ១ សែនកប្ប មាននគរឈ្មោះអមរវតី ជានគរគួរពិតពិលរមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូរណ៍ដោយបាយ និងទឹក ទាំងមិនស្ងាត់ ដោយមានសំឡេង ១០ យ៉ាង គឺសំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងស័ង្ខ និងសំឡេងរថជាដើម ។ ទាំងជានគរគឹកកងដោយសំឡេង ដែលប្រកបដោយបាយ និងទឹកថា ចូរស៊ី ចូរផឹក ជានគរសម្បូរដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួងបរិបូរណ៍ដោយការងារគ្រប់យ៉ាង ។ បរិបូរណ៍ដោយកែវ ៧ ប្រការ កុះករដោយជនជាតិផ្សេងៗ សម្រេច ( ដោយគ្រឿង

បរិភោគ និងឧបភោគទាំងពួង ) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ ។ វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្ត ចងចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមីក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ។ កាលនោះ តបាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្ដីទុក្ខ ការបែកធ្លាយសរីរៈក៏នាំមកនូវសេចក្ដីទុក្ខដូចគ្នា ( សេចក្ដីស្លាប់ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ ) អាត្មាអញ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់មិនស្លាប់ ជាទីក្សេមក្សាន្ត ។ បើដូច្នោះ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្ដីត្រូវការ ហើយនឹងចេញទៅ ។ ផ្លូវនោះ នឹងមានពិត ផ្លូវនោះ មិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។ កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន ការប្រាសចាកភពបុគ្គលគួរតែប្រាថ្នា

រក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វាន ដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះដែរ ។ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមាន ព្រះនិព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នា ក៏មានយ៉ាងនោះដែរ ។ បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹកហើយ មិនស្វែងរកស្រះ ទោសនោះ មិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វាន មានហើយ បុគ្គលមិនស្វែងរកស្រះ សម្រាប់លាងនូវកិលេស ជាមន្ទិលចេញទេ ទោសនោះ មិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ។ បុរសដែលត្រូវសត្រូវទាំងឡាយ ចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះ មិនរត់ទៅ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ។ បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះព្យាបាលជំងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គលត្រូវជំងឺ គឺកិលេសទាំងឡាយ

បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះ មិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់ បុគ្គលនោះឯង យ៉ាងនោះដែរ ។ ( បើដូច្នោះ ) គួរតែ អាត្មាអញលះបង់កាយស្អុយនេះ ដែលពេញដោយសាកសព ផ្សេងៗ ចេញ គប្បីជាអ្នកមិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការរូប ហើយចេញទៅ ។ បុរសបាន ស្រាយសាកសពដ៏គួរខ្ពើមរអើម ដែលជាប់ព្ធដ៏ក គប្បីជា អ្នកមានសេចក្តីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញ គួរតែលះបង់កាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗ ចេញ ហើយគប្បី ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ចេញទៅ យ៉ាងនោះដែរ ។ បុរសស្រ្តីទាំងឡាយ ទៅបន្ទោបង់នូវករីសៈ ក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តី ត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញ នឹងលះ បង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញទៅ ដូចបុរសស្រ្តីទាំងឡាយ ដែលបន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។ ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលិចចូលទឹក ឥតមានអាឡោះអាល័យ ឥត ត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយ

នេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកលះចោលនូវទូកចាស់ ដូច្នោះឯង ។ បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យក៏លះបង់ហើយដើរទៅ យ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញ នឹងលះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌យ៉ាងនោះដែរ ។ លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយ ឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ ។ តថាគតនិម្មិតនូវទីចង្ក្រម ដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពល ដែលប្រកបដោយគុណ ៨ ប្រការ ។ លះបង់សំពត់សាដកដែលប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បកឈើដែលប្រកបដោយគុណ ១២ ប្រការវិញ ។ លះបង់បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើ ដែលប្រកបដោយគុណ ១០ យ៉ាង ។ លះបង់ស្រូវដែលគេព្រោះ គេដាំដោយមិនសេសសល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិ-

បូរណ៍ដោយគុណច្រើនប្រការ ។ តថាគតផ្គងព្យាយាម ក្នុង
អាស្រមបទនោះ ( ញុំាំងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទី
អង្គុយ ទីឈរ និងទីចង្ក្រម បានលុះអភិញ្ញាពលក្នុងរវាង ៧
ថ្ងៃ ដូច្នេះ ។

បណ្ដាគាថាទាំងនោះ បាទគាថាពីរថា **តថាគតធ្វើអាស្រម សាង បណ្ណសាលានេះ** សេចក្ដីថា លោកពោលហាក់ដូចអាស្រម បណ្ណសាលា និងទីចង្ក្រមនោះ សុមេធបណ្ឌិតដែលចេញទៅ ដោយគិតថា អញនឹងបួស ដូច្នេះ សាងដោយដៃរបស់ខ្លួនឯង តែក្នុងគាថានោះ គប្បីជ្រាបសេចក្ដីដូច្នេះថា

ព្រះមហាសត្វ កាលទៅដល់ហិមពាន្តហើយគិតថា ថ្ងៃនេះ អញនឹងចូលទៅកាន់ភ្នំឈ្មោះធម្មិក ដូច្នេះ ។ សក្កទេវរាជ ជាស្ដេចនៃទេវតា ទ្រង់ទតឃើញសុមេធបណ្ឌិតចេញទៅ ដោយគិតថា អញនឹងបួស ទើបត្រាស់ហៅវិស្សកម្មទេវបុត្តមកប្រាប់ថា សុមេធបណ្ឌិតនេះ ចេញទៅហើយ ដោយគិតថា អញនឹងបួស នែបា ចូរបាទៅសាងសង់ទីសម្រាប់នៅ ដល់ព្រះមហាសត្វចុះ ។ វិស្សកម្មទេវបុត្តនោះ ទទួលពាក្យរបស់សក្កទេវរាជហើយ ក៏ទៅនិម្មិតអាស្រមបទដែលគួររីករាយ បណ្ណសាលាដែលបិទបាំងល្អហើយ និងទីចង្ក្រម ដែលជាទីគាប់ចិត្ត ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកអាស្រមបទនោះ ដែលសម្រេចដោយបុញ្ញានុភាពរបស់ខ្លួន ក្នុងកាលនោះ ទើបត្រាស់ថា

តថាគតធ្វើអាស្រម សាងបណ្ណសាលា តថាគតនិម្មិតនូវទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា តថាគតធ្វើអាស្រម បានដល់ ដែលតថាគតធ្វើទុកល្អហើយ ។ ពាក្យថា សាងបណ្ណសាលា សេចក្ដីថា សូម្បីសាលាដែលប្រក់ដោយស្លឹកឈើ ក៏ជាសាលាដែលតថាគតសាងល្អហើយ ។

ពាក្យថា ដែលប្រាសចាកទោស ៥ ប្រការ សេចក្ដីថា ឈ្មោះថាទោសនៃទីចង្ក្រមទាំងនេះ មាន ៥ យ៉ាង គឺជាទីរឹង និងពុំរាបស្មើ ១ មានដើមឈើដុះនៅខាងក្នុង ១ បិទបាំងដោយស្មៅ និងវល្លិ ១ ទីដែលចង្អៀតពេក ១ ទីដែលធំទូលាយពេក ១ ។

ពិតហើយ ទីចង្ក្រមដែលមានដីរឹង និងពុំរាបស្មើ ជើងទាំងពីររបស់អ្នកចង្ក្រម រមែងឈឺ រមែងហើម ចិត្តរមែងមិនបាននូវឯកគ្គតា កម្មដ្ឋានរមែងវិបត្តិ ។ តែកម្មដ្ឋាន រមែងបរិបូណ៌បាន ព្រោះអាស្រ័យការនៅដែលជាផាសុក ក្នុងផ្ទៃដីដែលទន់ រាបស្មើ ព្រោះហេតុនោះ គប្បីជ្រាបភូមិភាគដែលរឹង ពុំរាបស្មើ ថាជាទោសទីមួយក្នុងទីចង្ក្រម ។ កាលដើមឈើមាននៅខាងក្នុងទីចង្ក្រម ឬមាននៅក្នុងកណ្ដាល ឬក្នុងទីបំផុតនៃទីចង្ក្រម អ្នកចង្ក្រមអាស្រ័យសេចក្ដីប្រមាទហើយ មែកឈើរមែងប៉ះថ្ងាស ឬក្បាល ព្រោះហេតុនោះ ទីចង្ក្រមដែលមានដើមឈើនៅខាងក្នុង គប្បីជ្រាបថា ជាទោសទីពីរ ។ កាលចង្ក្រមក្នុងទីចង្ក្រមដែលស្កុកដោយព្រៃ មានស្មៅ និងវល្លិជា

ដើម រមែងជាន់សត្វ មានពស់ជាដើម ក្នុងវេលាងងឹតឲ្យស្លាប់ ឬត្រូវសត្វ មានពស់ជាដើមចឹក ឬខាំ រមែងដល់នូវទុក្ខ ព្រោះហេតុនោះ ទីចង្ក្រមដែលស្កុកដោយព្រៃ គប្បីជ្រាបថា ជាទោសទីបី ។ កាលដើរចង្ក្រមក្នុងទីចង្ក្រមដែលចង្អៀតពេក ដោយទទឹងមួយហត្ថ ឬកន្លះហត្ថ ក្រចកក្តី ម្រាមជើងក្តី រមែងបែក ព្រោះរអិលទៅក្នុងទីដែលកំណត់ ព្រោះហេតុនោះ ទីចង្ក្រមដែលចង្អៀតពេក គប្បីជ្រាបថា ជាទោសទីបួន ។ កាលចង្ក្រមក្នុងទីចង្ក្រមដែលធំពេក ចិត្តរមែងប្រឫកប្របល់ រមែងមិនបាននូវឯកគ្គតា ព្រោះហេតុនោះ ទីចង្ក្រមដែលធំទូលាយពេក គប្បីជ្រាបថា ជាទោសទីប្រាំ ។

ទីចង្ក្រមខាតតូច ដោយចំណែកទទឹងមួយហត្ថមួយចំអាម ត្រង់ជាយទាំងពីរប្រមាណមួយហត្ថ បណ្តោយប្រមាណ ៦០ ហត្ថ មានផ្ទៃដីទន់រោយរាយខ្សាច់រាបស្មើ រមែងសមគួរ ព្រោះហេតុនោះ ទីបែបនោះ ដូចទីចង្ក្រមរបស់ព្រះមហាមហិន្ទត្ថេរ ដែលញុំាងសេចក្តីជ្រះថ្លា ឲ្យកើតដល់អ្នកកោះក្នុងចេតិយគិរី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា តថាគតនិម្មិតនូវទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ ដូច្នេះ ។

ពាក្យថា ដែលប្រកបដោយគុណ ៨ ប្រការ បានដល់ ប្រកបដោយសេចក្តីសុខរបស់សមណៈ ៨ យ៉ាង ធម្មតាសេចក្តីសុខ របស់សមណៈមាន ៨ យ៉ាង គឺមិនហួងហែងវត្ថុទាំងឡាយ មានទ្រព្យ និងស្រូវជាដើម ១ ជាអ្នកស្វែងរកបិណ្ឌបាត ប្រាសចាកទោស ១ ជាអ្នកឆាន់បិណ្ឌបាតត្រជាក់

១ កាលរាជត្រកូល កៀបសង្កត់ពួកអ្នកដែនរឹបអូសយកទ្រព្យ ដែលមានសារៈ ឬទាសាទាសី និងកហាបណៈជាដើម ភាពជាអ្នកមិនត្រូវសេចក្ដីសៅហ្មង ព្រោះការគាបសង្កត់ដូចពួកអ្នកដែន ១ មិនមានឆន្ទរាគៈក្នុងគ្រឿងប្រើប្រាស់ទាំងឡាយ ១ ប្រាសចាកភ័យក្នុងការដែលត្រូវពួកចោរប្លន់ ១ មិនប្រឡូកប្រឡំដោយព្រះរាជា និងមហាមាត្យ របស់ព្រះរាជា ១ មិនទើសទាក់ក្នុងទិសទាំងបួន ១ ។

ពាក្យនេះ មានអធិប្បាយថា ជនដែលនៅក្នុងអាស្រមបទនោះ អាចជួបសេចក្ដីសុខរបស់សមណៈទាំង ៨ យ៉ាងនេះ យ៉ាងណា តថាគតសាងអាស្រមនោះ ប្រកបដោយគុណ ៨ ប្រការ ក៏យ៉ាងនោះ ។

ពាក្យថា នាំមកនូវអភិញ្ញាពល សេចក្ដីថា តថាគតនៅក្នុងអាស្រមបទនោះ ធ្វើកសិណបរិកម្ម ផ្ដើមវិបស្សនាដោយភាពមិនទៀង ជាទុក្ខ ដើម្បីត្រូវការឲ្យអភិញ្ញាទាំងឡាយ និងសមាបត្តិទាំងឡាយកើតឡើង ហើយនាំវិបស្សនាពលដែលមានកម្លាំងមក អធិប្បាយថា ខ្ញុំនៅក្នុងទីនោះ រមែងអាចដើម្បីនាំកម្លាំងនោះមកបាន យ៉ាងណា ខ្ញុំសាងអាស្រមបទដ៏សមគួរដល់វិបស្សនាពលនោះ ដើម្បីត្រូវការអភិញ្ញា ក៏យ៉ាងនោះ ។

ក្នុងបាទនៃគាថាថា លះបង់សំពត់សាដក ដែលប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះនៃគាថាថា លះបង់សំពត់សាដក ដែលប្រកបដោយ ។បេ។ ដោយគុណ ១២ ប្រការវិញ ដូច្នេះ គប្បីជ្រាបអនុបុព្វីកថាដូចតទៅនេះ

បានឮថា កាលវិស្សកម្មទេវបុត្តនិម្មិតអាស្រម ដែលប្រដាប់ដោយកុដិ ទីពួនសម្ងំ ទីចង្ក្រមជាដើម ដ៏ដេរដាសទៅដោយដើមឈើមានផ្កា និងផ្លែ ដែលជាទីគួររីករាយចិត្ត មានស្រះទឹកថ្លាស្អាត ប្រាសចាកម្រឹគកាច និងសំឡេងសកុណជាតិដែលគួរខ្លាច សមគួរដល់សេចក្ដីស្ងប់ស្ងាត់ ចាត់ចែងបន្ទះក្ដារសម្រាប់តោងក្នុងទីបំផុតទាំងពីរ នៃទីចង្ក្រមដែលប្រដាប់ហើយ និម្មិតផ្ទាំងថ្ម មានផ្ទៃរាបស្មើ មានពណ៌ដូចសណ្ដែកបាយ ក្នុងពាក់កណ្ដាលនៃទីចង្ក្រម ដើម្បីប្រយោជន៍ដល់ការអង្គុយ និម្មិតវត្ថុទាំងពួងដែលជាគ្រឿងប្រើប្រាស់របស់ពួកបព្វជិតយ៉ាងនេះ គឺបរិក្ខាររបស់តាបស មានជដាមណ្ឌល សំពត់ក្រងដោយសម្បុរឈើ ឈើច្រត់ចម្ពាមបី និងកុណ្ឌីទឹកជាដើម ទុកខាងក្នុងបណ្ណសាលា និម្មិតឆ្នាំងទឹកសម្រាប់ផឹក ស័ង្ខដួសទឹកផឹក និងផ្ដិលដងទឹក ទុកក្នុងមណ្ឌប និម្មិតអំបែងរងើកភ្លើង និងឧសជាដើម ទុកក្នុងរោងភ្លើងហើយ ចារឹកអក្សរទុកត្រង់ជញ្ជាំងបណ្ណសាលាថា នរណាត្រូវការបួស ចូរកាន់យកបរិក្ខារទាំងនេះបួសចុះ ដូច្នេះហើយ ទៅកាន់ទេវលោកវិញ ។ សុមេធបណ្ឌិត រកទីដែលជាផាសុកដ៏សមគួរដល់លំនៅរបស់ខ្លួន តាមជើងភ្នំត្រង់ជាយព្រៃហិមពាន្ត ឃើញអាស្រមដែលវិស្សកម្មទេវបុត្តនិម្មិត ដែលសក្កទេវរាជទ្រង់ប្រទាន ដែលជាទីគួររីករាយ ត្រង់ទីបត់នៃស្ទឹងហើយ ទើបទៅក្នុងទីបំផុតនៃទីចង្ក្រម មិនឃើញស្នាមជើង ទើបគិតថា បព្វជិតដែលនៅប្រចាំទៅស្វែងរកភិក្ខាក្នុងស្រុក ប្រហែលជាហត់នឿយ ត្រឡប់មកហើយចូលទៅកាន់បណ្ណសាលា នឹងអង្គុយសម្រាក ដូច្នេះ រង់ចាំមើលបន្តិច

ទើបបើកទ្វារបណ្ណសាលា ដោយគិតថា បព្វជិតទាំងនោះយឺតយូរ អញនឹង ដឹង ហើយចូលទៅខាងក្នុង ក្រឡេកមើលខាងណេះ ខាងណោះ ហើយអាន អក្សរទាំងឡាយត្រង់ជញ្ជាំងធំហើយគិតថា បរិក្ខារទាំងនេះ សមគួរដល់អាត្មា អញ អញនឹងកាន់យកបរិក្ខារទាំងនេះ បួស ដូច្នេះ ទើបលះបង់គូសំពត់ សាដកដែលខ្លួនស្លៀក និងដណ្ដប់ចេញ ដោយហេតុនោះ ទើបព្រះមានព្រះ ភាគត្រាស់ថា លះបង់សំពត់សាដក ... ក្នុងអាស្រមបទនោះ អធិប្បាយថា ម្នាលសារីបុត្ត តថាគតចូលទៅដោយអាការយ៉ាងនេះហើយ លះសំពត់ សាដកត្រង់បណ្ណសាលានោះ ។

ពាក្យថា ដែលប្រកបដោយទោស ៩ ប្រការ លោកសម្ដែងថា តថាគតកាលលះសំពត់សាដក ឃើញទោស ៩ យ៉ាងហើយ ទើបលះ ។ ពិតហើយ ទោស ៩ យ៉ាង ក្នុងសំពត់សាដក រមែងប្រាកដដល់បព្វជិត ដែលបួសជាតាបស ។ ទោស ៩ យ៉ាង ក្នុងសំពត់សាដកនោះ គឺសំពត់ នោះមានតម្លៃច្រើន ១ កើតឡើងបានទាក់ទងដោយអ្នកដទៃ ១ ប្រើហើយ ប្រឡាក់ឆាយ ប្រឡាក់ហើយត្រូវបោកគក់ ជ្រលក់ ១ ប្រើហើយចាស់ រហែស កាលចាស់ហើយត្រូវដេរប៉ះ ១ ស្វែងរកទៀត បានដោយក្រ ១ មិនសមគួរដល់អ្នកបួសជាឥសី ១ ជារបស់សាធារណៈដល់សត្រូវ ព្រោះ ត្រូវថែរក្សាបានដោយក្រ កុំឲ្យសត្រូវយកទៅបាន ១ ជាគ្រឿងប្រដាប់របស់ អ្នកប្រើប្រាស់ ១ ជាភារៈដល់រាងកាយរបស់អ្នកយកជាប់ខ្លួនធ្វើដំណើរទៅ និងជាហេតុឲ្យប្រាថ្នាច្រើន ១ ។

ពាក្យថា ស្លៀកសំពត់សម្បកឈើ សេចក្តីថា ម្នាលសារីបុត្ត ក្នុងកាលនោះ តថាគតឃើញទោសទាំង ៩ យ៉ាងនេះ ទើបលះបង់សំពត់សាដក ហើយស្លៀកសំពត់ក្រងដោយស្បូវភ្លាំង គឺកាន់យកសំពត់ដែលក្រងដោយស្បូវភ្លាំង ដែលបុគ្គលច្រៀកស្មៅជំណោកទន្សាយជាចម្រៀកៗ ហើយក្រងដើម្បីប្រយោជន៍ដល់ការស្លៀកដណ្តប់ ។ ពាក្យថា ដែលប្រកបដោយគុណ ១២ ប្រការវិញ បានដល់ ប្រកបដោយអានិសង្ស ១២ ប្រការ ។ ពិតហើយ សំពត់ស្បូវភ្លាំង មានអានិសង្ស ១២ ប្រការ គឺជាសំពត់ដែលមានតម្លៃតិចល្អ ជារបស់គួរ នេះជាអានិសង្សទី ១ អាចធ្វើបានដោយដៃរបស់ខ្លួន នេះជាអានិសង្សទី ២ ប្រើប្រាស់ហើយ ប្រឡាក់បានដោយក្រសូម្បីបោកគក់ ក៏មិនយឺតយូរ នេះជាអានិសង្សទី ៣ សូម្បីចាស់ព្រោះការប្រើប្រាស់ ក៏មិនចាំបាច់ដេរ នេះជាអានិសង្សទី ៤ កាលស្វែងរកទៀតក៏ធ្វើបានដោយងាយ នេះជាអានិសង្សទី ៥ សមគួរដល់ការបួសជាតាបស នេះជាអានិសង្សទី ៦ ពួកសត្រូវមិនប្រើប្រាស់ នេះជាអានិសង្សទី ៧ មិនមែនជាគ្រឿងប្រដាប់របស់អ្នកប្រើប្រាស់ នេះជាអានិសង្សទី ៨ ជារបស់ស្រាលក្នុងវេលាស្លៀកដណ្តប់ នេះជាអានិសង្សទី ៩ ជារបស់បុគ្គលដែលមានសេចក្តីប្រាថ្នាតិចក្នុងចីវរជាបច្ច័យ នេះជាអានិសង្សទី ១០ ភាពជាអ្នកមិនមានទោសរបស់អ្នកទ្រទ្រង់ធម៌ ព្រោះកើតអំពីសម្បកឈើ នេះជាអានិសង្សទី ១១ កាលសំពត់ស្បូវភ្លាំងវិនាសទៅ ក៏មិនអាល័យ នេះជាអានិសង្សទី ១២ ។

ក្នុងកន្ទះគាថាថា លះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ នៃគាថាថា

លះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ
ចូលទៅកាន់គល់ឈើ ដែលប្រកបដោយគុណ ១០ ប្រការ
ដូច្នេះ ។

សួរថា សុមេធបណ្ឌិត លះបង់បណ្ណសាលានោះ បានយ៉ាងដូចម្ដេច ។ ឆ្លើយថា បានឮថា សុមេធបណ្ឌិតនោះ កាលដោះសំពត់សាដកទាំងគូនោះ កាន់យកសំពត់ស្បង់ក្លាំងដែលជ្រលក់ហើយ ដូចកម្រងផ្កានៅងដែលពាក់នៅត្រង់ស្បង់ចីវរ ស្លៀកហើយ ក៏ដណ្ដប់សំពត់ស្បង់ក្លាំងមានពណ៌ដូចមាស មួយផ្ទាំងទៀតសង្កត់សំពត់ស្លៀកនោះ ហើយធ្វើស្បែកខ្លាជំបង មានក្រចកជើង ដូចសណ្ឋាននៃផ្កាបុសនាគ ឲ្យជាសំពត់នៅលើស្មាម្ខាង ហើយពាក់ជដាមណ្ឌល សៀតស្នៀតជដាចូលក្នុងផ្នួងសក់ ដើម្បីធ្វើឲ្យមិនញាប់ញ័រហើយ ហើយដាក់ឃ្លោកមានពណ៌ដូចកែវប្រពាលទុកក្នុងសង្រែក ដូចសំណាញ់កែវមុក្តា ហើយកាន់យកដងរែកដែលកោងក្នុងទីទាំង ៣ អន្លើ ហើយព្យួរឃ្លោកទឹក ទុកខាងចុងដងរែកម្ខាង ព្យួរតម្អក់ជាល និងឈើច្រត់ចម្លាមបីជាដើម ទុកនៅខាងចុងដងរែកម្ខាង ហើយរែកគ្រឿងបរិក្ខារលើស្មាកាន់ឈើច្រត់មនុស្សចាស់ដោយដៃខាងស្ដាំ ចេញអំពីបណ្ណសាលា ចង្ក្រមទៅមកក្នុងទីចង្ក្រមធំ មានបណ្ដោយ ៦០ហត្ថ ក្រឡេកមើលភេទរបស់ខ្លួន ហើយកើតឧស្សាហះថា មនោរថរបស់អញដល់ទីបំផុតហើយ បព្វជ្ជារបស់

អញជាការល្អហ្ន៎ ក៏ឈ្មោះថាបព្វជ្ជានេះ វីរបុរសទាំងពួង មានព្រះពុទ្ធ និង ព្រះបច្ចេកពុទ្ធជាដើម សរសើរហើយ លើកតម្កើងហើយ ចំណងរបស់គ្រហស្ថ អញលះបានហើយ អញចេញបួសហើយ អញបានបព្វជ្ជាដ៏ឧត្តមហើយ អញនឹងធ្វើសមណធម៌ អញនឹងបានសេចក្តីសុខ ក្នុងមគ្គ និងផល ដូច្នេះ ដាក់អម្រែកបរិក្ខារចុះ ហើយអង្គុយលើផ្ទាំងថ្មមានពណ៌ដូចសណ្តែកបាយ ត្រង់កណ្តាលទីចង្ក្រម ដូចបដិមាមាស ញុំាងចំណែកនៃថ្ងៃឲ្យកន្លងទៅ ហើយចូលទៅកាន់បណ្ណសាលា ក្នុងវេលាល្ងាច ដេកហើយលើកម្រាលធ្វើដោយស្លឹកឈើ នៅលើគ្រែនាបឫស្សី ឲ្យសរីរៈទទួលអាកាសហើយ ភ្ញាក់ក្នុងវេលាទៀបភ្លឺ រំពឹងដល់ការមករបស់ខ្លួនថា អញឃើញទោសក្នុងឃរាវាស ទើបលះបង់យសដ៏ធំក្រៃលែង មានភោគៈប្រមាណមិនបាន ចូលទៅកាន់ព្រៃ ជាអ្នកស្វែងរកនេក្ខម្មៈ បួសហើយ ចាប់ផ្តើមអំពីនេះទៅ អញមិនគួរប្រមាទ ព្រោះថា រុយ គឺមិច្ឆាវិតក្ក រមែងខាំស៊ីបុគ្គលដែលលះបង់នូវសេចក្តីស្ងប់ស្ងាត់ ត្រាច់ទៅដោយអាការយ៉ាងនេះ ឥឡូវនេះ អញគួរបម្រើនការស្ងប់ស្ងាត់ ដ្បិតថា អញឃើញបលិពោធរបស់ឃរាវាស ទើបចេញមក ម្យ៉ាងទៀត បណ្ណសាលានេះ ជាទីញុំាងចិត្តឲ្យឆ្អែត មានចំណែកនៃផ្ទៃដីជុំវិញដែលតាក់តែងហើយ មានពណ៌ដូចផ្លែព្នៅទុំ ទាំងជញ្ជាំងសោតក៏សស្អាតដូចជំពារប្រាក់ ដំបូលបណ្ណសាលា មានពណ៌ដូចជើងព្រាប គ្រែនាបឫស្សីតូច ក៏មានពណ៌ដូចកម្រាលដ៏វិចិត្រ អញបាននូវលំនៅជាទីសប្បាយ ការដល់ព្រមនៃផ្ទះរបស់អញ ដូចការដល់ព្រមដែលក្រៃលែងជាង

បណ្ណសាលានេះ រមែងមិនប្រាកដ ដូច្នេះ កាលពិនិត្យមើលទោសទាំងឡាយនៃបណ្ណសាលា បានឃើញទោស ៨ យ៉ាង ។

ទោស ៨ យ៉ាង ដែលទាក់ទងដោយការប្រើប្រាស់បណ្ណសាលា គឺ ត្រូវស្វែងរកទព្វសម្ភារទាំងឡាយ ដោយគ្រឿងប្រកបច្រើន មករួបរួមគ្នា ហើយធ្វើ នេះជាទោសទី ១ ត្រូវមើលថែទព្វសម្ភារ មានស្មៅ ស្លឹកឈើ និងដីស្អិតដែលធ្លាក់ទៅទាំងនោះជានិច្ច ដើម្បីឲ្យទព្វសម្ភារទាំងនោះ ស្ថិតនៅបានយូរ ជាទោសទី ២ ដែលឈ្មោះថា សេនាសនៈ រមែងដល់នូវភាពចាស់ ទ្រុឌទ្រោម កាលត្រូវក្រោកឡើងជួសជុលក្នុងកាលដែលមិនសមគួរ ភាពជាឯកគ្គតានៃចិត្ត ក៏រមែងមិនមាន ហេតុនោះ ការដែលត្រូវក្រោកឡើងជួសជុល ទើបជាទោសទី ៣ ភាពដែលរាងកាយទន់ខ្សោយព្រោះប៉ះត្រជាក់និងក្តៅ ជាទោសទី ៤ បុគ្គលអ្នកចូលទៅកាន់ផ្ទះ ហើយអាចធ្វើសេចក្តីអាក្រក់ឯណាមួយក៏បាន ហេតុនោះ ភាពដែលផ្ទះ ជាគ្រឿងបិទបាំងការតិះដៀល ទើបជាទោសទី ៥ សេចក្តីប្រកាន់មាំថា ផ្ទះរបស់អញ ដូច្នេះ ជាទោសទី ៦ ដែលឈ្មោះថា ការមានផ្ទះនោះ ក៏រមែងមានសម្ងាត់ ហេតុនោះ ទើបសេចក្តីនេះ ជាទោសទី ៧ ការដែលត្រូវជារបស់សាធារណៈ ព្រោះជារបស់សាធារណៈដល់សុច សង្កើច ជីងចក់ តុកកែជាដើម ជាទោសទី ៨ ។

ព្រះមហាសត្វឃើញទោសទាំង ៨ ប្រការនេះ ដោយប្រការដូច្នេះ ទើបលះបង់បណ្ណសាលា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

លះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការដូច្នេះ ។

បាទគាថា ២ ថា ចូលទៅកាន់គល់ឈើ ដែលប្រកបដោយគុណ ១០ យ៉ាង ព្រះមហាសត្វ កាលបដិសេធគ្រឿងប្រក់ហើយ ទើបពោលថា ចូលទៅកាន់គល់ឈើ ដែលប្រកបដោយគុណ ១០ យ៉ាង ដូច្នេះ ។

ត្រង់គល់ឈើនោះ មានគុណ ១០ យ៉ាង ទាំងនេះ គឺភាពជាអ្នកមិនចាំបាច់ផ្តួចផ្តើម ( មិនចាំបាច់សាងសង់ដូចផ្ទះ ) ជាគុណទី ១ ត្រង់គល់ឈើនោះ ត្រឹមតែចូលទៅនៅប៉ុណ្ណោះ មិនចាំបាច់សម្អាត នេះជាគុណទី ២ គល់ឈើនោះបោសក្តី មិនបោសក្តី ក៏ប្រើបានយ៉ាងផាសុកនោះឯង ការដែលមិនត្រូវថែរក្សា ជាគុណទី ៣ គល់ឈើនោះ រមែងមិនបិទបាំង ការតិះដៀល ព្រោះថា កាលបុគ្គលធ្វើអំពើអាក្រក់ ត្រង់គល់ឈើនោះ រមែងខ្មាស ហេតុនោះ ទើបការដែលមិនបិទបាំងការតិះដៀលជាគុណទី ៤ រមែងមិនធ្វើឲ្យកាយរឹងប៉ឹង ដូចនៅក្នុងទីវាល ហេតុនោះ ការដែលកាយមិនរឹងប៉ឹងទើបជាគុណទី ៥ ភាពមិនជាហេតុនៃការហួងហែង ជាគុណទី ៦ ការហាមសេចក្តីអាល័យក្នុងផ្ទះ ជាគុណទី ៧ មិនមានការឲ្យចេញទៅ ដោយពាក្យថា ខ្ញុំនឹងធ្វើការសម្អាតទីនេះ ចូរលោកចេញទៅ ដូចក្នុងផ្ទះដែលទូទៅដល់ជនច្រើន ជាគុណទី ៨ អ្នកនៅមានបីតិ ជាគុណទី ៩ ភាពជាអ្នកមិនចាំបាច់ស្វែងរកព្រោះសេនាសនៈ គឺគល់ឈើ ជារបស់រកបានងាយ ក្នុងទីដែលខ្ជួនទៅហើយជាគុណទី ១០ ។ ព្រះមហាសត្វឃើញគុណ ១០ ប្រការទាំងនេះ ដោយប្រការដូច្នេះហើយ ទើបពោលថា ចូលទៅកាន់គល់ឈើ

ដូច្នេះ ។

ព្រះមហាសត្វ កំណត់ហេតុទាំងឡាយនេះ មានប្រមាណប៉ុណ្ណេះហើយ ក្នុងថ្ងៃស្អែកឡើង ទើបចូលទៅកាន់ស្រុកដើម្បីភិក្ខា ។ គ្រានោះ ពួកមនុស្ស ក្នុងស្រុកដែលព្រះមហាសត្វទៅដល់ទីនោះ បានប្រគេនភិក្ខាដោយឧស្សាហៈ ធំ ។ ព្រះមហាសត្វ ធ្វើភត្តកិច្ចស្រេចហើយ ត្រឡប់មកកាន់អាស្រម អង្គុយ ហើយគិតថា អញមិនបានបួសដោយគំនិតថា អញនឹងមិនបានអាហារដែល ឈ្មោះថា អាហារដ៏ល្អនោះ រមែងញុំាងសេចក្ដីស្រវឹងក្នុងការប្រកាន់ខ្លួន និង ស្រវឹងក្នុងភាពជាបុរសឲ្យចម្រើន ការអស់ទុក្ខដែលមានអាហារជាមូល មិន មានទេ បើដូច្នោះ អាត្មាអញគប្បីលះបង់អាហារ ដែលកើតអំពីធញ្ញជាតិ ដែលគេព្រោះ និងដាំដោយដាច់ខាត ហើយកាន់យកផ្លែឈើ តាមដែលស្វែង រកបាន ដែលដល់ព្រមដោយគុណជាច្រើន ព្រោះហេតុនោះ អញនឹងលះបង់ អាហារដែលកើតអំពីធញ្ញជាតិ ដែលគេព្រោះ និងដាំ ហើយបរិភោគផ្លែ ឈើតាមដែលអាចរកបាន ( ផ្លែឈើដែលជ្រុះឯង ) ដូច្នេះ ចាប់តាំងអំពី កាលនោះ ព្រះមហាសត្វក៏ធ្វើយ៉ាងនោះ ហើយបន្តព្យាយាម នៅខាងក្នុង ៧ ថ្ងៃ ក៏ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើងហើយ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

លះបង់ស្រូវដែលគេព្រោះ គេដាំដោយមិនសេសសល់ កាន់
យកផ្លែឈើដែលជ្រុះឯង បរិបូរណ៍ដោយគុណច្រើនប្រការ ។
តបាគតផ្គងព្យាយាម ក្នុងអាស្រមបទនោះ ( ញុំាងយប់ និង

ថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្ក្រម បានលុះអភិញ្ញាពលក្នុងរវាង ៧ ថ្ងៃ ។ កាលតថាគតសម្រេចអភិញ្ញាហើយ ជាអ្នកមានវសីក្នុងសាសនានៃតាបស កាលនោះ ព្រះជិនស្រីព្រះនាមទីបង្ករ ជានាយកនៃលោក ទ្រង់កើតឡើង ។ កាលព្រះពុទ្ធ ចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្តែងធម្មចក្កផង តថាគតជាអ្នកឆ្អែតស្កប់ស្កល់ដោយសេចក្តីត្រេកអរក្នុងឈាន ប៉ុន្តែ មិនបានឃើញនូវនិមិត្តទាំង ៤ ឡើយ ។ ពួកមហាជនក្នុងបច្ចន្តប្រទេសមានចិត្តត្រេកអរ និមន្តព្រះតថាគត បាននាំគ្នាជម្រះផ្លូវជាទីមកនៃព្រះតថាគតនោះ ។ សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះទៅឯអាកាស តថាគតឃើញជនកំពុងតែពេញចិត្ត ត្រេកអរស្រស់ស្រាយ រីករាយ ក៏ចុះអំពីអាកាស ហើយសួរមនុស្សទាំងឡាយក្នុងខណៈនោះថា មហាជនត្រេកអរ ស្រស់ស្រាយរីករាយ ពេញចិត្ត ជម្រះផ្លូវគន្លងប្រឡាយ ដើម្បីអ្នកណា ។ ពួកជនទាំងនោះ ដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថាព្រះពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រី ព្រះនាមទីបង្ករជាលោកនាយក ទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវគន្លងប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ ។ បីតិកើតឡើង

ដល់តថាគត ក្នុងខណៈនោះ ព្រោះតែឮពាក្យថា ព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះហើយ ក៏បានទូវសោមនស្ស ។ តថាគតស្ថិតនៅក្នុងប្រទេសនោះ ត្រេកអរមានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្តុះពូជកុសល ក្នុងបុញ្ញក្ខេត្តនេះ កុំឲ្យខណៈកន្លងទៅទទេឡើយ ។ ( លុះគិតដូច្នេះហើយ ក៏និយាយទៅរកមហាជនថា ) បើអ្នកទាំងឡាយជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវប្រឡាយដែរ ។ កាលនោះ ពួកជនទាំងនោះ ក៏ឲ្យឱកាសមួយដល់តថាគត ដើម្បីជម្រះផ្លូវ តថាគតគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ជម្រះផ្លូវបណ្តើរ ក្នុងឱកាសនោះ ។ កាលដែលឱកាស ( ផ្លូវ ) របស់តថាគតធ្វើមិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះជិនស្រី ជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្តេចយាងមកតាមផ្លូវ ជាមួយនឹងព្រះខីណាស្រព ៤ សែនរូប សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិបុគ្គល ប្រាសចាកមន្ទិល ។ ការក្រោកទទួល ( ព្រះសាស្តា ) ក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយជាច្រើន ក៏លាន់ឮឡើង គគ្រឹកគគ្រេងពួកមនុស្ស និងទេវតាក៏ត្រេកអរ ញុំាងសាធុការ ឲ្យប្រព្រឹត្តទៅ ។ ពួកទេវតាឃើញពួកមនុស្ស ឯពួកមនុស្សក៏ឃើញពួកទេវតា ទេវតា និងមនុស្សទាំងពីរពួកនេះ បានផ្គងអញ្ជលី

ដើរដង្ហែព្រះតថាគត ។ ពួកទេវតា ប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្ស ក៏ប្រគំតូរ្យតន្ត្រីជារបស់មនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតាដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្ស ផ្កាឈូក ផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វឰដ៏អាកាស អំពីទិសតូចទិសធំ ។ ពួកទេវតា ដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយលម្អិតខ្លឹមចន្ទន៍ទិព្វផង គ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូចទិសធំឰដ៏អាកាស ។ ពួកមនុស្សដែលស្ថិតនៅលើផែនដីក៏រោយរាយផ្កា ចម្ប៉ា ផ្កាស្រល់ ផ្កាកូដ្ឋ ផ្កាខ្លឹង ផ្កាបុសនាគ និងផ្កាកាកេស អំពីទិសតូចទិសធំ ។ តថាគត រំសាយសក់ ត្រង់ប្រទេសនោះហើយ ក្រាលចីវរសម្បកឈើ និងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ ( អធិដ្ឋានថា ) សូមព្រះពុទ្ធ ព្រមទាំងពួកសិស្ស ជាន់អាត្មាអញយាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ។ កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះ ដោយចិត្តយ៉ាងនេះថា បើអាត្មាអញប្រាថ្នាដុតកិលេសទាំងឡាយ របស់អញក្នុងថ្ងៃនេះក៏បាន ។ តែថា ប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ដោយភេទ ដែលគេមិនស្គាល់ក្នុងទីនេះ អាត្មាអញគប្បី

ដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាង លោក ព្រមទាំងទេវលោកឲ្យរួចរដោះ ( ចាកសង្សារ ) ។ ប្រយោជន៍អ្វី អាត្មាអញជាបុរស សម្ដែងកម្លាំងឆ្លងទៅម្នាក់ ឯង អាត្មាអញគួរដល់នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញ នឹងបានដល់នូវសព្វញ្ញុ-តញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មា អញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។ តថាគតនឹងកាត់ ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើងជិះលើនាវា គឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ ព្រះពុទ្ធព្រះ នាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿង បូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈរបស់តថាគត ត្រាស់ ពាក្យនេះថា ( ម្នាលភិក្ខុទាំងឡាយ ) អ្នកទាំងឡាយ ចូរ មើលតាបសនេះ ជាជដិលមានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹង បានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបានអំពី កប្បនេះទៅ ។ សត្វនេះ នឹងចេញចាកក្រុង ឈ្មោះកបិលវត្ថុ ជាទីរីករាយ តម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ អង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាស ដែលនាង សុជាតាថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះ ជិនស្រីនោះ បានទទួលបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា

ហើយ នឹងត្រឡប់មកតាមផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ ( អន្វយ ) ទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបានត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជនិកាមាតារបស់តាបសនោះ នឹងមាននាមថាព្រះនាងមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯតាបសនេះ នឹងមានឈ្មោះថាព្រះគោតម អគ្គសាវកទាំងពីររូប គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។ អគ្គសាវិកាពីររូប គឺនាងខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ឈើជាទីត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺចិត្តៈ ១ ហត្ថាឡវកៈ ១ ។ នាងនន្ទមាតា និងនាងឧត្តរា ជាឧបដ្ឋាយិកាដ៏ប្រសើរ ព្រះគោតមមានយសនោះ មានព្រះជន្ម ១០០ វស្សា ។ ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាករណ៍របស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយដោយគិតថា សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។

សំឡេងហៅទាំងឡាយ ក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក ទាំងមួយម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ។ ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថា ឆ្លងស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគតគង់ នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទីបង្ករទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើរបស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ ។ សាវកទាំងឡាយណា ជាបុត្រនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវកទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ ពួកយក្ខក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ ។ កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ កន្លងនូវការឃើញរបស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ។ តថាគតជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខ រីករាយដោយបាមោជ្ជ

ផ្សព្វផ្សាយដោយបីតិ អន្ទ័យពែនក្អែន ក្នុងកាលនោះ ។ តថាគតអន្ទ័យពែនក្អែន គិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ។ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសីស្មើ ដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើ ក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្តីសុខបែបនេះ ។ ក្នុងកាលដែលតថាគតអន្ទ័យពែនក្អែនគិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញុំាងសំឡេងខ្ទាំងឲ្យលាន់ឮថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ក្អែននៃពោធិសត្វទាំងឡាយប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ។ ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេង ឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ខ្យល់ធំទាំងឡាយ ក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាទាំងពួងដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះក៏បញ្ចេញ

ផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ វល្លិទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែក្នុងខណៈនោះ វល្លិ និងឈើទាំងអស់នោះក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ កែវទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្វ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ មហាសមុទ្រ ក៏ស្រុកចុះ លោកធាតុទាំងមួយម៉ឺន ក៏ញាប់ញ័រ ក្នុងខណៈនោះ មហាសមុទ្រ និងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ភ្លើងក្នុងនរក ទាំងមួយម៉ឺន ក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ព្រះអាទិត្យប្រាសចាកមន្ទិល ផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់

ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុល ឡើងលើផែនដី ក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដីក្នុង ថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកផ្កាយ ទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្តឫក្សទាំងឡាយ ប្រកបដោយ ព្រះចន្ទវិសាខ ( ក៏រុងរឿង ) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចំណែកឯពួកសត្វ នៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោល ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ សេចក្តីអផ្សុកមិន មានដល់សត្វទាំងឡាយ សត្វទាំងឡាយ ជាអ្នកត្រេកអរ ក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃ នេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគទាំង-ឡាយដ៏ស្រាលៗ ក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេកឃ្លាន ក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លាន ទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះ ពុទ្ធប្រាកដ ។ រាគក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ ក៏បាត់បង់ទៅក្នុងកាលនោះ រាគ និងកិលេសទាំងអស់នោះក៏ ប្រាសចេញទៅក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ ប្រាកដ ។ ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនុ៎ះ

ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ធូលីក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលីក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្លិនស្អុយក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញ ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរាំងមិនមានឡើយ កំពែង សន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអាកាស ( ប្រាកដ ) ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចុតិ និងឧបបត្តិ មិនមានក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ( និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មោធិញ្ញាណ ) ( ពួក

សត្វពោលថា បពិត្រសុមេធតាបស ) សូមលោក ផ្គង ព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់ កុំថយក្រោយឡើយ ពួក យើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធ ប្រាកដ ។ តថាគត លុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះ ពុទ្ធ និងទេវតាទាំងមួយម៉ឺនចក្កវាឡហើយ ក៏ត្រេកអរ ស្រស់ ស្រាយ រីករាយ គិតក្នុងកាលនោះយ៉ាងនេះថា ធម្មតាព្រះ ពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះ ជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះ ពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញ នឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដីដែលគេ បោលទៅឰដ៏អាកាស ទៀងតែធ្លាក់មកលើផែនដីវិញ យ៉ាង ណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ ប្រាកដយ៉ាងនោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្ដីស្លាប់របស់សព្វសត្វ ទៀងទាត់ ប្រាកដ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធប្រសើរទាំងឡាយ ទៀងទាត់ ប្រាកដ ដូច្នោះដែរ ។ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យ ទៀង តែរះឡើង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំង ឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ សីហៈដែលចេញ

អំពីជំណោក តែងបន្ទឺសំឡេង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។ ការសម្រាលគភ៌នៃស្រីដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។ បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។ កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវទានបារមីជាដំបូងនេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះ ចាក់មិនឲ្យសល់ទឹក ទឹកមិនជក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទានកុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ ដូច្នោះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណ ឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើស

រក ក៏ឃើញសីលបារមីទី ២ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកឯង ចូរសមាទាន ធ្វើសីលបារមីទី ២ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។ សត្វចាមរី ( កាលឃើញ ) រោមកន្ទុយចំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាលឲ្យដូចជាសត្វចាមរីរក្សាកន្ទុយយ៉ាងនោះចុះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណ ឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថាម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់នៅក្នុងគុកអស់កាលយូរត្រូវសេចក្តីទុក្ខ បៀតបៀនហើយ រមែងមិនញុំាងសេចក្តីត្រេកអរ ឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច

( ចាកគុកនោះ ) យ៉ាងណា អ្នកចូរឃើញនូវកពទាំងអស់ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មៈ ដើម្បីរួចចាកភពយ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជនជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញវីរិយ-បារមីទី ៥ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព

ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធ-បណ្ឌិត ) អ្នកចូរសមាទានធ្វើវីរិយបារមីទី ៥ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈ ជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាមឲ្យមាំមួន ក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់វីរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណ មិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវខន្តិបារមីទី ៦ នេះ ឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ ក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយយ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយរបស់ពួកជនទាំងពួង

យ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្មោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើសច្ចបារមីទី ៧ នេះ ឲ្យមាំមួន កុំមានពាក្យបែកជាពីរក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្មោធិញ្ញាណមិនខានឡើយ ។ ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថីក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកវិថីក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្មោធិញ្ញាណ មិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯង

ថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើអធិដ្ឋាន-
បារមីទី ៨ នេះឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមី
នោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ភ្នំថ្ម
ឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា
រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែលយ៉ាងណា អ្នកចូរកុំកម្រើក
ក្នុងអធិដ្ឋានបារមីសព្វកាល យ៉ាងនោះដែរ លុះដល់នូវ
អធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខាន
ឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ
អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌
ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុង
ជ្រើសរើសរក ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វ
ទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយ
ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន
ធ្វើនូវមេត្តាបារមីទី ៩ នេះ ឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គល
ដទៃស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។ ធម្មតា
ទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អទាំងអាក្រក់
រមែងកម្ចាត់បង់នូវធូលី និងមន្ទិលយ៉ាងណា ។ អ្នកចូរចម្រើន
មេត្តាឲ្យស្មើ ចំពោះមិត្ត និងសត្រូវយ៉ាងនោះដែរ លុះដល់នូវ
មេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខាន

ឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើឧបេក្ខាបារមីទី ១០ នេះ ឲ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។ ធម្មតាផែនដី តែងព្រងើយកន្តើយ ចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួន ឲ្យដូចជាជញ្ជីង ចំពោះសុខ និងទុក្ខសព្វកាល យ៉ាងនោះដែរ ។ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណពុំខាន ។ ធម៌ទាំងឡាយណា ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០ នោះឲ្យមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីធម៌ទាំងនេះ ដោយសភាវលក្ខណៈ ផែនដីទាំងមួយម៉ឺនលោកធាតុ

ក៏ញាប់ញ័រ ដោយតេជះនៃធម៌ ។ ផែនដីកម្រើកបន្ទឺឡើង ដូចជាឃ្នាបអំពៅដែលត្រូវគេគាប ឬចក្រយន្តប្រេង ត្រូវគេគាបហើយ ( រមែងវិលញ័រ ) យ៉ាងណា ផែនដីក៏ញាប់ញ័រយ៉ាងនោះដែរ ។ បរិស័ទរបស់ព្រះពុទ្ធ មានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាស បរិស័ទនោះ ក៏ញាប់ញ័រ ដេកជ្រប់លើផែនដីក្នុងទីអង្គាសនោះ ។ ឆ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចគ្នាបែកខ្ទេចខ្ទីអស់ក្នុងទីនោះ ។ ពួកមហាជន មានចិត្តរន្ធត់ តក់ស្លុត ភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នា ហើយចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ដូចម្តេច នឹងមានដល់មនុស្សលោក លោកទាំងមូលត្រូវសេចក្តីអន្តរាយបៀតបៀនហើយ សូមព្រះអង្គ ទ្រង់មេត្តាប្រោស បន្ទោបង់សេចក្តីអន្តរាយនោះចេញ ។ គ្រានោះ ព្រះមហាមុនីទីបង្ករទ្រង់ញុាំងមហាជនទាំងនោះ ឲ្យយល់ច្បាស់ថាអ្នកទាំងឡាយ ចូរកុំមានសេចក្តីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។ ដ្បិតតថាគតបានព្យាករក្នុងថ្ងៃនេះថាសុមេធបណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ( ក្នុងកាលជាអនាគត ) សុមេធបណ្ឌិតនុ៎ះ កំពុងពិចារណាធម៌ដែលព្រះជិនស្រីអំពីបុរាណធ្លាប់សេពមក ។ កាលសុមេធ-

បណ្ឌិតពិចារណាធម៌ គឺពុទ្ធភូមិដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោកព្រមទាំងទេវលោកញាប់ញ័រ ។ ចិត្ត ( នៃមហាជន ) ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះបានស្ដាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នា ក៏ចូលមករកតថាគតហើយក្រាបថ្វាយបង្គំម្ដងទៀត ។ គ្រានោះ តថាគតសមាទាននូវពុទ្ធគុណ ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយបង្គំ ព្រះពុទ្ធទីបង្ករហើយក្រោកចាកអាសនៈ ។ ពួកទេវតា ពួកមនុស្សទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្ស ចំពោះសុមេធបណ្ឌិតដែលក្រោកចាកអាសនៈ ។ ពួកទេវតា និងពួកមនុស្សទាំងពីរពួកនោះបាននូវសួស្ដី ( ពោលថា ) តំណែងដ៏ធំដែលលោកប្រាថ្នាហើយ សូមលោកបាននូវតំណែងនោះសមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួង ចូរបរវៀសចៀសចេញទៅ សេចក្ដីសោក និងរោគ ក៏ចូរចៀសវាងចេញទៅសេចក្ដីអន្តរាយកុំបីមានដល់លោកឡើយ សូមលោកបានលុះនូវសព្វញ្ញុតញ្ញាណដ៏ខ្ពង់ខ្ពស់ឆាប់ៗ ចុះ ។ កាលដល់រដូវផ្កាពួកឈើមានផ្កា រមែងបញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កាដោយពុទ្ធញ្ញាណយ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញ

ហើយនូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបស មាន ព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០ យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀបគល់ពោធិមណ្ឌៈយ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរត្រាស់ដឹងទៀបគល់ពោធិមណ្ឌៈនៃព្រះជិនស្រី យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំងធម្មចក្ក ឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅយ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ ចូររុងរឿងក្នុងលោកធាតុទាំងមួយម៉ឺន យ៉ាងនោះ ។ ព្រះអាទិត្យដែលរួចផុតអំពីរាហុ រមែងរុងរឿងដោយកម្តៅ យ៉ាងណា លោកចូររួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធសិរី យ៉ាងនោះដែរ ។ ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្ទ យ៉ាងណា ពួកលោក ព្រមទេវលោកក៏រមែងប្រជុំក្នុងសម្នាក់របស់លោក យ៉ាងនោះដែរ ។ គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតា និងមនុស្សទាំងនោះ ស្ងើចសរសើរហើយ ក៏សមាទាននូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំ ។

**សុមេធកថា ចប់**

គ្រានោះ ពួកឧបាសកឧបាសិកាទាំងនោះ ញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្ដាទីបង្ករនោះជាទីពឹង ។ ព្រះតថាគត ទ្រង់ញុំាងបុគ្គលខ្លះឲ្យតម្កល់នៅក្នុងសរណគមន៍ ញុំាងបុគ្គលខ្លះឲ្យតាំងនៅក្នុងសីល ៥ ញុំាងបុគ្គលដទៃទៀត ឲ្យតម្កល់នៅក្នុងសីល ១០ ។ ព្រះអង្គទ្រង់ប្រទានមគ្គដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្ដមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ ៨ ដ៏ប្រសើរដល់បុគ្គលខ្លះ ប្រទានវិជ្ជា ៣ ដល់បុគ្គលខ្លះ អភិញ្ញា ៦ ដល់បុគ្គលខ្លះ ។ ព្រះមហាមុនីទ្រង់ទូន្មានពួកជន ដោយន័យជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនានៃព្រះលោកនាថ ជាគុណជាតដ៏ធំទូលាយ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះហនុកា ( ដូចព្រះចន្ទក្នុងថ្ងៃ ១២ កើត ) មានដងខ្លួនមូលក្លំ ដូចគោឧសភ ទ្រង់ចម្លងពួកជនច្រើន ឲ្យរួចចាកទុគ្គតិ ។ ព្រះមហាមុនី ទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ស្ថិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិត ហើយញុំាងពួកជននោះឲ្យត្រាស់ដឹងក្នុងខណៈនោះ ។ ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ញុំាងពួកទេវតា ១០០ កោដិ ឲ្យត្រាស់ដឹង ក្នុង

ការត្រាស់ដឹងទី ២ ព្រះលោកនាថ ទ្រង់ញុំាងពួកទេវតា និងមនុស្ស ៩០ កោដិ ឲ្យត្រាស់ដឹង ។ កាលណា ព្រះពុទ្ធ ទ្រង់សម្តែងធម៌ក្នុងភពនៃទេវតា កាលនោះ ពួកទេវតា ៩០ ពាន់កោដិ ( បានត្រាស់ដឹង ) នេះជាការត្រាស់ដឹងទី ៣ ។ ព្រះសាស្តាទីបង្ករ មានសាវកសន្និបាត ( ការជួបជុំសាវ័ក ) ៣ លើក គឺសន្និបាតលើកទី ១ មានភិក្ខុសង្ឃមួយសែនកោដិ ។ កាលដែលព្រះជិនស្រី ទ្រង់យាងទៅក្នុងទីស្ងាត់លើ កំពូលភ្នំនារទ: ពួកព្រះខីណាស្រពប្រាសចាកមន្ទិល ចំនួន ១០០ កោដិ មកប្រជុំគ្នា ( នោះជាសន្និបាតលើកទី ២ ) ។ កាលព្រះមហាមុនីមានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ ៩០ កោដិ ឰដ៏ភ្នំសុទស្សន: ( នេះជាសន្និបាតលើកទី ៣ ) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅឰដ៏អាកាស ជាអ្នកបានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ។ ពួកសត្វចំនួន ៣ ម៉ឺន បានត្រាស់ដឹងនូវសច្ច: ការត្រាស់ដឹងរបស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់មិនអស់ឡើយ ។ សាសនារបស់ ព្រះទីបង្ករ មានព្រះភាគ ជាគុណជាតធំទូលាយ មានជនច្រើនស្តុកស្តម្ភ សាយភាយ គឺព្រះអង្គទ្រង់ជម្រះល្អហើយ ក្នុងកាលនោះ ។ ពួកព្រះខីណាស្រពចំនួន ៤ សែនរូប

បានលុះអភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករ ដែលទ្រង់ជ្រាបច្បាស់នូវលោកសព្វកាល ។ ក្នុងសម័យនោះ ពួកជនណាមួយ ដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខ-បុគ្គល លះបង់នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។ សាសនា ( របស់ព្រះពុទ្ធទីបង្ករនោះ ) រីកសាយល្អ រុងរឿងដោយពួកព្រះអរហន្តខីណាស្រព ជាតាទិបុគ្គល ប្រាសចាកមន្ទិលសព្វកាល ។ នគររបស់ព្រះសាស្តាព្រះនាមទីបង្ករ ឈ្មោះរម្មាវតី ក្សត្រិយ៍ព្រះនាមសុទេវៈ ( ជាព្រះបិតា ) ព្រះជនិកា ព្រះនាមសុមេធា ។ ព្រះសុមង្គលៈ និងព្រះតិស្សៈ ជាអគ្គសាវក ព្រះសាគតៈជាឧបដ្ឋាករបស់ព្រះសាស្តាទីបង្ករ ។ នាងនន្ទា និងសុនន្ទា ជាអគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា ដើមលៀប ។ ព្រះមហាមុនីទីបង្ករ មានកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើមសាលរាជព្រឹក្ស មានផ្ការីកស្កុសស្កាយ ។ រស្មីរបស់ព្រះអង្គ ផ្សាយទៅចម្ងាយ ១០ យោជន៍[១] ជុំវិញ ព្រះមហេសីនោះ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញ៉ាំងព្រះសទ្ធម្ម ឲ្យ

១-បិដកខ្មែរជាទសយោជនេ តែច្បាប់ឆដ្ឋសង្គាយនា ជាទ្វាទសយោជនេ ប្រែថា ១២ យោជន៍ ។

រុងរឿង ចម្លងមហាជន ញ៉ាំងប្រជុំជនច្រើន ឲ្យឆ្លងចាក សង្សារវដ្ត ។ ព្រះទីបង្ករនោះ ព្រមទាំងសាវកនិព្វានទៅ ដូច គំនរភ្លើង ដែលរុងរឿងរលត់ទៅ ដូច្នោះ ឫទ្ធិនោះក្តី យស នោះក្តី ទាំងចក្ករតនៈឰដ៏ព្រះបាទានោះក្តី ក៏រលត់ទៅ ។ សម្បត្តិទាំងអស់ ក៏អន្តរធានទៅ ឱហ្ន៎ ! សង្ខារទាំងពួង ជា របស់សូន្យទទេ ។

## ទីបង្ករពុទ្ធវង្សទី ១ ចប់

# កោណ្ឌញ្ញកថាទី ២

ក្នុងសម័យខាងក្រោយ កាលព្រះមានព្រះភាគ ព្រះនាមទីបង្ករ ទ្រង់រម្ងត់ខន្ធបរិនិព្វានកន្លងទៅហើយ មួយអសង្ខេយ្យ ព្រះសាស្តាព្រះនាមកោណ្ឌញ្ញៈ ក៏ទ្រង់ឧប្បត្តិកឡើង សូម្បីសាសនារបស់ព្រះមានព្រះភាគនោះក៏មានសាវកសន្និបាត ៣ លើក ការប្រជុំលើកដំបូង មានសាវ័កមកប្រជុំប្រមាណមួយសែនកោដិ លើកទីពីរ មានសាវ័កមកប្រជុំប្រមាណមួយពាន់កោដិ លើកទីបី មានសាវ័កមកប្រជុំ ៩០ កោដិ ។

គ្រានោះ ព្រះពោធិសត្វជាស្តេចចក្កពត្តិ ព្រះនាម **វិជិតាវី** បានថ្វាយមហាទានដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន មានប្រមាណរាប់បានមួយសែនកោដិ ព្រះសាស្តាបានព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ហើយសម្តែងធម៌ ។ ព្រះពោធិសត្វនោះ ទ្រង់ស្តាប់ធម្មកថា របស់ព្រះសាស្តាហើយ ទ្រង់ប្រគល់រាជសម្បត្តិ ចេញសាងផ្នួស ទ្រង់សិក្សាព្រះត្រៃបិដក ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើង មានឈានមិនសាបសូន្យហើយ ទ្រង់ឧប្បត្តិកឡើងក្នុងព្រហ្មលោក ។

នគររបស់ព្រះមានព្រះភាគ ព្រះនាម **កោណ្ឌញ្ញៈ** នោះ ឈ្មោះថា **រម្មវតី** ព្រះមហាក្សត្រិយ៍ ព្រះនាម **សុនន្ទៈ** ជាព្រះរាជបិតា ព្រះទេវីព្រះនាម **សុជាតា** ជាព្រះមាតា ព្រះភទ្ទត្ថេរនិងសុភទ្ទត្ថេរជាអគ្គសាវ័ក

ព្រះថេរៈព្រះនាមអនុរុទ្ធ ជាពុទ្ធុបដ្ឋាក ព្រះនាងតិស្សាថេរី និងព្រះនាងឧបតិស្សាថេរី ជាគូអគ្គសាវិកា មានឈើជាទីត្រាស់ដឹង ឈ្មោះថា **សាលកល្យាណី** ព្រះសរីរៈរបស់ព្រះមហាមុនីនោះ កម្ពស់ ៨៨ ហត្ថ ព្រះអង្គមានព្រះជន្មាយុមួយសែនឆ្នាំ ។

## កោណ្ឌញ្ញកថាទី ២ ចប់ ។

# មង្គលកថាទី ៣

ក្នុងសម័យខាងក្រោយមក កាលព្រះកោណ្ឌញ្ញសម្ពុទ្ធបរិនិព្វានកន្លងទៅហើយ ប្រមាណមួយអសង្ខេយ្យ ក្នុងកប្បតែមួយនុ៎ះឯង មានព្រះពុទ្ធស្តេចឧប្បត្តិកឡើង ៤ ព្រះអង្គ គឺព្រះមង្គលសម្ពុទ្ធ ព្រះសុមនសម្ពុទ្ធ ព្រះរេវតសម្ពុទ្ធ និងព្រះសោភិតសម្ពុទ្ធ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាម **មង្គលៈ** មានសាវកមហាសន្និបាត ៣ លើក ក្នុងមហាសន្និ-បាតលើកទីមួយ មានភិក្ខុមកប្រជុំប្រមាណមួយសែនកោដិ[១] ក្នុងលើកទីពីរប្រមាណមួយពាន់កោដិ[២] ក្នុងលើកទីបី ប្រមាណ ៩០ កោដិ ។

បានឮថា ព្រះអានន្ទកុមារជាព្រះភាតាមាតាផ្សេងគ្នានឹងព្រះមានព្រះភាគអង្គនោះ ព្រមទាំងបរិស័ទ ៩០ កោដិ បានយាងទៅកាន់សម្នាក់របស់ព្រះសាស្តា ដើម្បីស្តាប់ធម៌ ។ ព្រះសាស្តាសម្តែងអនុបុព្វីកថាដល់ទ្រង់ មួយអន្លើដោយបរិស័ទ សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ព្រះសាស្តាទ្រង់ពិនិត្យមើលបុព្វចរិយា របស់កុលបុត្តទាំងនោះ ទ្រង់ឃើញឧបនិស្ស័យនៃការបានបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ទើបទ្រង់លាព្រះហស្តខាងស្តាំ ដោយព្រះតម្រាស់ថា ចូរពួកអ្នកជាភិក្ខុចុះ ដូច្នេះ ខណៈនោះឯងកុលបុត្តទាំងពួងក៏ទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដូចព្រះថេរៈមានវស្សា ៦០ ដល់ព្រមដោយកិរិយាមារយាទ មកចោមរោមថ្វាយបង្គំព្រះសាស្តា ។ សាសនារបស់ព្រះមានព្រះភាគនេះ ក៏មានសាវកសន្និបាត ៣

១-បិដកខ្មែរ ជាមួយកោដិ ។

២-បិដកខ្មែរ ជាមួយសែនកោដិ ។

លើក ។

រស្មីសរីរៈ របស់ព្រះពុទ្ធទាំងឡាយដទៃៗ មានប្រមាណ ៨០ ហត្ថ ដោយជុំវិញ ប៉ុន្តែ រស្មីសរីរៈរបស់ព្រះមានព្រះភាគ ព្រះនាមមង្គលៈនោះ មិនដូចព្រះពុទ្ធអង្គដទៃៗ ទេ គឺមានព្រះរស្មីផ្សាយចេញទៅកាន់មួយម៉ឺនលោកធាតុ តាំងនៅអស់កាលជានិច្ច ដើមឈើ ភ្នំ មហាសមុទ្ទជាដើម ដោយហោចទៅសូម្បីថ្នាំងបាយជាដើម ដូចជាដណ្តប់ដោយដំបារនៃមាស ដូច្នោះ ។ ព្រះជន្មាយុរបស់ព្រះអង្គ មានប្រមាណ ៩ ម៉ឺនឆ្នាំ អស់កាលមានប្រមាណប៉ុណ្ណោះ ព្រះចន្ទ ព្រះអាទិត្យជាដើម មិនអាចដើម្បីបញ្ចេញរស្មីរបស់ខ្លួនបាន ការកំណត់ថា ពេលយប់ និងពេលថ្ងៃមិនប្រាកដ សត្វទាំងឡាយត្រាច់ទៅដោយពន្លឺរបស់ព្រះពុទ្ធជានិច្ច ដូចត្រាច់ទៅដោយពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃ ។ សត្វលោកកំណត់វេលាយប់ និងវេលាថ្ងៃបានដោយផ្ការីក ថាជាវេលាល្ងាច កំណត់សំឡេងបក្សីស្រែក ថាជាវេលាព្រឹក ។

សួរថា អានុភាពនេះ របស់ព្រះពុទ្ធអង្គដទៃមិនមានឬ ។ ឆ្លើយថា មិនមែនមិនមាននោះទេ តាមពិត សូម្បីព្រះពុទ្ធអង្គដទៃនោះ កាលមានបំណងក៏គប្បីផ្សាយព្រះរស្មីទៅមួយម៉ឺនលោកធាតុ ឬក្រៃលែងជាងនោះក៏បាន ប៉ុន្តែព្រះរស្មីសរីរៈរបស់ព្រះមានព្រះភាគ ព្រះនាមមង្គលៈ ផ្សាយទៅកាន់ម៉ឺនលោកធាតុ តាំងនៅជានិច្ចនោះឯង ដោយអំណាចការតាំងសេចក្តីប្រាថ្នាក្នុងបុព្វជាតិ ដូចព្រះរស្មីមួយព្យាមរបស់ព្រះពុទ្ធអង្គដទៃៗ ។

បានឮថា ព្រះមង្គលសម្ពុទ្ធអង្គនោះ ក្នុងខណៈបំពេញបារមីជាព្រះពោធិ-

សត្វ តាំងនៅក្នុងអត្តភាពដូចព្រះវេស្សន្តរ ព្រមទាំងបុត្ត និងភរិយានៅទាក្នុំ ដូចភ្នំវង្កត ។ គ្រានោះ មានយក្សមួយឈ្មោះខរទាឋិកៈ ជ្រាបថា ព្រះមហាបុរសមានព្រះហឫទ័យក្នុងការឲ្យទាន ទើបកាឡាខ្លួនជាព្រាហ្មណ៍ ចូលទៅហើយ ទូលសុំទារកទាំងពីរអង្គនឹងព្រះមហាសត្វ ព្រះមហាសត្វទ្រង់ត្រេកអរ រីករាយហើយ ដោយទ្រង់ព្រះតម្រិះថា អញនឹងឲ្យកូនតូចដល់ព្រាហ្មណ៍ ដូច្នេះ ញុំាងផែនដីឲ្យញាប់ញ័រ រហូតដល់ទឹកទ្រផែនដី ហើយព្រះរាជទានទារកទាំងពីរ ។ យក្សឈរផ្អែកបន្ទះក្តារ ក្នុងទីបំផុតនៃទីចង្ក្រម កាលព្រះមហាសត្វ កំពុងសម្លឹងមើលទុំះឯង ទំពាស៊ីទារកទាំងពីរអង្គ ដូចទំពាស៊ីក្រអៅឈូក មហាបុរសក្រឡេកមើលយក្ស កាលយក្សនេះត្រឹមតែហាមាត់ប៉ុណ្ណោះ ផ្ទារលោហិតក៏ហូរចេញមក ដូចអណ្តាតភ្លើង ព្រះមហា-បុរសនោះ សូម្បីឃើញមាត់របស់យក្សនោះ ក៏មិនមានការអាក់អន់ព្រះហឫទ័យ សូម្បីត្រឹមប៉ុនចុងសក់ ទ្រង់ព្រះតម្រិះថា **សុទិន្នំ វត មេ ទានំ** ទានអញឲ្យល្អហើយហ្ន៎ ហើយញុំាងបីតិសោមនស្សដ៏ធំឲ្យកើតឡើងក្នុងព្រះសរីរៈរបស់ព្រះអង្គ ។

ព្រះមហាបុរសនោះ ទ្រង់តាំងសេចក្តីប្រាថ្នាថា ដោយវិបាកជាគ្រឿងហូរចេញនៃបុណ្យរបស់អញនេះ ក្នុងអនាគតកាល សូមរស្មីទាំងឡាយចេញអំពីសរីរៈ ដោយទំនងនេះ ដូច្នេះ កាលព្រះអង្គអាស្រ័យហេតុនោះត្រាស់ដឹងជាព្រះពុទ្ធហើយ ទើបរស្មីទាំងឡាយចេញអំពីព្រះសរីរៈ ផ្សាយទៅកាន់ទីដែលមានប្រមាណប៉ុណ្ណោះ ។

បុព្វចរិយាម្យ៉ាងទៀតរបស់ព្រះមង្គលសម្ពុទ្ធ បានឮថា ព្រះមង្គលសម្ពុទ្ធអង្គនោះ ក្នុងវេលាដែលព្រះអង្គជាព្រះពោធិសត្វ ឃើញចេតិយរបស់ព្រះពុទ្ធមួយព្រះអង្គ បានគិតថា អញគួរលះបង់ជីវិតបូជាព្រះពុទ្ធអង្គនេះ ទើបរុំសរីរៈទាំងមូលដូចប្រទីបមានជន ហើយយកថាសមាសកម្ពស់ប្រមាណមួយហត្ថ មានតម្លៃមួយសែនកហាបណៈមក ដាក់សប្បិរហូតពេញ ហើយអុជប្រទីបមួយពាន់ដាក់ក្នុងថាសនោះ ឲ្យភ្លឺសន្ធោសន្ធៅ ហើយទូលថាសនោះដោយសីសៈ ដុតសរីរៈទាំងមូលឲ្យឆេះសន្ធោសន្ធៅ ហើយធ្វើប្រទក្សិណចេតិយអស់រាត្រីទាំងមូល ។ កាលព្រះពោធិសត្វព្យាយាមយ៉ាងនេះ អរុណក៏រះឡើង សូម្បីត្រឹមរណ្ដៅរោមមួយក៏មិនឆេះ ហាក់ដូចជាចូលទៅកាន់គុម្ពឈូកដូច្នោះ ពិតហើយ ឈ្មោះថា ធម៌នោះ រមែងរក្សាបុគ្គល ដែលរក្សានូវខ្លួន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

> ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្ដីសុខ នេះជាអានិសង្ស ក្នុងធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ដូច្នេះ ។

ដោយវិបាកជាគ្រឿងហូរចេញនៃកម្មនេះ ទើបរស្មីព្រះវរកាយរបស់ព្រះមានព្រះភាគ ព្រះនាមមង្គលៈនោះ ផ្សាយចេញទៅមួយម៉ឺនលោកធាតុ តាំងនៅហើយ ។

ក្នុងគ្រានោះ ព្រះពោធិសត្វនៃយើងទាំងឡាយ ជាព្រាហ្មណ៍ នាមថា **សុរុចិ** គិតថា អញនឹងអារាធនាព្រះសាស្ដាដូច្នេះ ទើបចូលទៅគាល់ បានស្ដាប់មធុរធម្មកថាហើយ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលភិក្ខារបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកត្រូវការភិក្ខុប៉ុន្មាន ។ ព្រាហ្មណ៍សុរុចិ ទូលថា បពិត្រព្រះអង្គ ភិក្ខុជាបរិវាររបស់ព្រះអង្គមានប្រមាណប៉ុន្មាន ។ គ្រានោះ ជាសាវកសន្និបាតលើកទីមួយរបស់ព្រះសាស្ដា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ប្រមាណមួយសែនកោដិ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ ព្រមទាំងពួកភិក្ខុទាំងអស់ ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ព្រះសាស្ដាទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាពហើយ ។

ព្រាហ្មណ៍កាលនិមន្តដើម្បីទទួលភត្ត ក្នុងថ្ងៃស្អែកហើយ កាលត្រឡប់មកផ្ទះ បានគិតថា យើងអាចនឹងថ្វាយវត្ថុទាំងឡាយ មានបបរ បាយ និងសំពត់ជាដើម ដល់ភិក្ខុមានប្រមាណប៉ុណ្ណោះបាន ប៉ុន្តែទីសម្រាប់អង្គុយ នឹងធ្វើដូចម្ដេច ដូច្នេះ ។ គំនិតរបស់ព្រាហ្មណ៍នោះ បានញុំាងសេចក្ដីក្ដៅក្រហាយកើតឡើង ដល់បណ្ឌុកម្ពលសិលាសនៈរបស់សក្កទេវរាជ ដែលតាំងនៅឆ្ងាយចម្ងាយ ៨ ម៉ឺន ៤ ពាន់យោជន៍ សក្កទេវរាជទ្រង់ព្រះតម្រិះថា នរណាហ្ន៎ ប្រាថ្នានឹងឲ្យយើងឃ្លាតចាកឋានៈនេះ កាលប្រមើលមើលដោយទិព្វចក្ខុ ទ្រង់ឃើញមហាបុរសហើយ ទ្រង់ជ្រាបថា សុរុចិព្រាហ្មណ៍និមន្តពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន បានគិតដល់ការចាត់ចែងទីអង្គុយថ្វាយ

ទាន សូម្បីអញក៏គួរទៅកាន់ទីនោះ ដើម្បីកាន់យកចំណែកបុណ្យ ដូច្នេះហើយ និម្មិតភេទជាជាងឈើ កាន់កាំបិត និងពូថៅ ឈរប្រាកដនៅខាងមុខមហាបុរស សួរថា មាននរណាជួលខ្ញុំឲ្យធ្វើការដែរឬទេ ។ មហាបុរសឃើញជាងឈើនោះ ទើបសួរថា អ្នកធ្វើអ្វីបានខ្លះ ។ ជាងឈើនោះ ឆ្លើយថា ឈ្មោះថា សិល្បៈដែលខ្ញុំមិនចេះមិនមានទេ នរណានឹងឲ្យខ្ញុំធ្វើផ្ទះ ឬមណ្ឌប ឬវត្ថុណា ខ្ញុំធ្វើបានទាំងអស់ មហាបុរសពោលថា បើដូច្នោះ យើងមានការងារ ។ ជាងឈើសួរថា លោកម្ចាស់ មានការងារអ្វី ។ មហាបុរសឆ្លើយថា យើងនិមន្តភិក្ខុមួយសែនកោដិ មកឆាន់កត្តាហារក្នុងថ្ងៃស្អែកនេះទុកហើយ ចូរអ្នកធ្វើមណ្ឌបសម្រាប់ជាទីអង្គុយឲ្យភិក្ខុទាំងនោះ ។ ជាងឈើពោលថា បើអ្នកអាចឲ្យថ្លៃឈ្នួលដល់ខ្ញុំ ខ្ញុំក៏នឹងធ្វើ មហាបុរសពោលថា យើងនឹងឲ្យ ជាងឈើទទួលថា សាធុ ខ្ញុំនឹងធ្វើ ហើយទៅមើលផ្ទៃដីត្រង់ប្រទេសមួយ ។

ផ្ទៃដីត្រង់ប្រទេសនោះ មានប្រមាណ ១២ ឬ ១៣ យោជន៍ មានផ្ទៃរាបស្មើ ដូចមណ្ឌលកសិណ ។ ព្រះឥន្ទជាងឈើ គិតថា សូមមណ្ឌបសម្រេចដោយកែវ ៧ ប្រការ ចូរតាំងឡើងក្នុងទីមានប្រមាណប៉ុណ្ណេះ ដូច្នេះហើយ សម្លឹងមើល រំពេចនោះឯង មណ្ឌបក៏ទម្លាយផែនដីផុសឡើង មណ្ឌបនោះ មានសសរទាំងឡាយសម្រេចដោយមាស មានត្របកឈូកដែលបិទសម្រេចដោយប្រាក់ បណ្ដាសសរដែលសម្រេចដោយប្រាក់ មានត្របកឈូកសម្រេចដោយមាស បណ្ដាសសរដែលសម្រេចដោយកែវមណី មានត្របក

ឈូកសម្រេចដោយកែវប្រពាល បណ្ដាសសរកែវប្រពាល មានត្របកឈូកសម្រេចដោយកែវមណី បណ្ដាសសរ ដែលសម្រេចដោយរតនៈ ៧ ប្រការ មានត្របកឈូកសម្រេចដោយរតនៈ ៧ ប្រការ តអំពីនោះ ក៏សម្លឹងមើល អធិដ្ឋានថា សូមបណ្ដាញកណ្ដឹងសំយុងចុះ ត្រង់ជាយពិតានជុំវិញមណ្ឌប ដូច្នេះ ដំណាលគ្នានឹងការមើលនុ៎ះឯង បណ្ដាញកណ្ដឹង ក៏សំយុងចុះហើយ កណ្ដឹងណាត្រូវខ្យល់បក់តិចៗ កណ្ដឹងនោះ ក៏បន្លឺសំឡេងពីរោះ ដូចសំឡេងដ៏ពីរោះ របស់តន្ត្រីមានអង្គ ៥ នោះឯង វេលានោះបានដូចជាវេលាលេងភ្លេងទិព្វ ហើយអធិដ្ឋានថា សូមកម្រងផ្កាក្រអូប និងកួងមាល័យទាំងឡាយសំយុងចុះខាងក្នុងចន្លោះ កួងមាល័យទាំងនោះក៏សំយុងចុះហើយ តអំពីនោះ ក៏អធិដ្ឋានថា សូមអាសនៈទាំងឡាយ និងទីអង្គុយសម្រាប់ភិក្ខុមួយសែនកោដិ ទម្លាយផែនដីផុសឡើង ក្នុងរំពេចនោះឯង វត្ថុទាំងអស់នោះក៏ប្រាកដឡើង តអំពីនោះក៏អធិដ្ឋានថា សូមពាងទឹកទាំងឡាយតាំងឡើងត្រង់ជ្រុងនីមួយៗ ពាងទឹកទាំងឡាយ ក៏ប្រាកដឡើង សក្កទេវរាជនិម្មិតវត្ថុសព្វយ៉ាងបែបនេះហើយ ទើបទៅកាន់សម្នាក់របស់ព្រាហ្មណ៍ហើយប្រាប់ថា នែព្រាហ្មណ៍ ចូរលោកមកពិនិត្យមើលមណ្ឌបរបស់លោក ហើយចូរឲ្យថ្លៃឈ្នួលដល់ខ្ញុំ ដូច្នេះ ។

មហាបុរសទៅពិនិត្យមើលមណ្ឌបហើយ កាលកំពុងតែសម្លឹងមើលនុ៎ះឯង បីតិ ៥ ប្រការ ក៏ពាល់ត្រូវសរីរៈផ្សាយទៅមិនមានរវាងចន្លោះ លំដាប់នោះ មហាបុរស កាលពិនិត្យមើលមណ្ឌបហើយ មានគំនិតយ៉ាងនេះថា

មណ្ឌបនេះ មិនមែនមនុស្សធ្វើ តែអាស្រ័យអធ្យាស្រ័យ និងគុណរបស់អញ ទើបធ្វើកពរបស់សក្កទេវរាជឲ្យក្តៅ ព្រោះហេតុនោះ មណ្ឌបនេះនឹងជាមណ្ឌបដែលសក្កទេវរាជសាងឲ្យ ការដែលអញឲ្យទានត្រឹមតែមួយថ្ងៃ ក្នុងមណ្ឌបបែបនេះ មិនសមគួរឡើយ អញនឹងឲ្យទានអស់ ៧ ថ្ងៃ ដូច្នេះ ។

ការដែលឲ្យទានដោយវត្ថុដែលជាខាងក្រៅ សូម្បីមានប្រមាណត្រឹមណា ក៏មិនអាចនឹងញ៉ាំងចិត្ត របស់ព្រះពោធិសត្វទាំងឡាយ ឲ្យត្រេកអរ ប៉ុន្តែសេចក្តីត្រេកអរ របស់ព្រះពោធិសត្វនឹងមាន ក៏ព្រោះការបរិច្ចាគក្នុងកាលដែលបានកាត់ក្បាលដែលប្រដាប់តាក់តែងហើយ ឆ្កៀលភ្នែកទាំងគូដែលបន្តក់ថ្នាំហើយ ពុះទ្រូងរូងយកបេះដូងហើយឲ្យ ក្នុងសិវិរាជជាតកពណ៌នាថា កាលព្រះពោធិសត្វនៃយើងទាំងឡាយ លះបង់ទ្រព្យរាល់ៗ ថ្ងៃ មួយថ្ងៃ ប្រមាណ ៥ សែនកហាបណៈ ឲ្យទានត្រង់ទ្វារនគរទាំង ៤ និងត្រង់កណ្តាលនគរ ការបរិច្ចាគទាននោះ ក៏មិនញ៉ាំងចិត្តឲ្យត្រេកអរបាន ប៉ុន្តែកាលណា សក្កទេវរាជកាឡាខ្លួនជាព្រាហ្មណ៍ មកសូមព្រះនេត្រទាំងគូរបស់ព្រះអង្គ កាលទ្រង់ឆ្កៀលព្រះនេត្រឲ្យទុះឯង សេចក្តីត្រេកអរក្នុងព្រះហឫទ័យក៏កើតឡើង ចិត្តរបស់ព្រះអង្គមិនបានប្រែប្រួលសូម្បីប៉ុនចុងសក់ ឈ្មោះថាសេចក្តីត្រេកអរ របស់ព្រះពោធិសត្វទាំងឡាយ ព្រោះអាស្រ័យទានមានសភាពបែបនេះ ទើបមិនមាន ព្រោះហេតុនោះ ទើបមហាបុរសនោះ គិតថាយើងគួរនឹងថ្វាយទាន ដល់ភិក្ខុមួយសែនកោដិ ៧ ថ្ងៃ ដូច្នេះ ទើបនិមន្តពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ក្នុងមណ្ឌបនោះ ហើយបានថ្វាយ

អាហារទាន ឈ្មោះថា គវបាន: អស់ ៧ ថ្ងៃ ។ ពាក្យថា **គវបាន** លោកហៅភោជន ដែលគេយកទឹកដោះចាក់ក្នុងថ្នាំងធំរហូតពេញ ហើយលើកឡើងដាក់លើជើងក្រាន កាលទឹកដោះខាប់ហើយ ចាក់អង្ករចូលទៅបន្តិច ហើយលាយដោយទឹកឃ្មុំ ស្ករក្រាម និងទឹកដោះថ្លា ។

មនុស្សទាំងឡាយ មិនអាចអង្គាសភិក្ខុបានទាំងអស់ ទើបទេវតាទាំងឡាយចូលទៅជួយអង្គាសហើយ ទីមានប្រមាណ ១២-១៣ យោជន៍ ក៏មិនគ្រប់គ្រាន់ឲ្យភិក្ខុគង់ ។ តែភិក្ខុទាំងឡាយគង់បានដោយអានុភាពរបស់ខ្លួន ។ ក្នុងថ្ងៃចុងក្រោយ ព្រះពោធិសត្វឲ្យលាងបាត្រភិក្ខុទាំងអស់ ដាក់ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ដើម្បីឲ្យជាភេសជ្ជៈ ហើយថ្វាយជាមួយនឹងត្រៃចីវរ សំពត់ចីវរដែលភិក្ខុថ្មីក្នុងសង្ឃបាន មានតម្លៃមួយសែនកហាបណៈ ។

ព្រះសាស្ដាកាលធ្វើអនុមោទនា ទ្រង់ពិចារណាថា បុរសនេះបានឲ្យទានដ៏ធំមានសភាពយ៉ាងនេះ នឹងមានហេតុអ្វីហ្ន៎ ទ្រង់ឃើញថា ក្នុងអនាគត-កាល ក្នុងទីបំផុតនៃពីរអសង្ខេយ្យក្រៃលែងដោយមួយសែនកប្ប នឹងបានជាព្រះពុទ្ធ ព្រះនាមថា **គោតម** ដូច្នេះ ទើបត្រាស់ហៅមហាបុរសមក ហើយទ្រង់ព្យាករថា កន្លងកាលមានប្រមាណប៉ុណ្ណេះហើយ អ្នកនឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។

មហាបុរសស្ដាប់ពាក្យព្យាករណ៍ហើយ គិតថា បានឮថា អញនឹងបានត្រាស់ជាព្រះពុទ្ធ ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់អញ អញ

នឹងបួស ដូច្នេះហើយ ទើបលះបង់សម្បត្តិបែបនេះ ដូចស្តោះទឹកមាត់ ហើយបួសក្នុងសម្នាក់ព្រះសាស្តា កាលបួសហើយ ក៏រៀនព្រះពុទ្ធវចនៈ ញ៉ាំងអភិញ្ញាទាំងឡាយ និងសមាបត្តិទាំងឡាយឲ្យកើតហើយ ក្នុងវេលាអស់អាយុ ក៏កើតក្នុងព្រហ្មលោក ។

នគររបស់ព្រះមានព្រះភាគ ព្រះនាមថា **មង្គលៈ** មានឈ្មោះថា **ឧត្តរៈ** ព្រះបិតាជាក្សត្រិយ៍ ព្រះនាមថា **ឧត្តរៈ** ព្រះមាតាព្រះនាមថា **ឧត្តរា** ព្រះសុទេវត្ថេរ និងព្រះធម្មសេនត្ថេរ ជាគូនៃអគ្គសាវក ភិក្ខុជាឧបដ្ឋាកឈ្មោះថា បាលិតៈ ព្រះនាងសីវលីថេរី[១] និងព្រះនាងអសោកាថេរី ជាគូអគ្គសាវិកា ដើមឫឹងជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ។ កាលព្រះមានព្រះភាគ តម្កល់ព្រះជន្មបាន ៩ ម៉ឺនឆ្នាំហើយ ក៏រម្លត់ខន្ធបរិនិព្វាន ម៉ឺនចក្កវាលក៏មានងងឹតព្រមគ្នានោះឯង ។ ការយំស្រែកដ៏ធំ មានដល់មនុស្សទាំងឡាយ ក្នុងចក្កវាលទាំងអស់នុ៎ះឯង ។

## មង្គលកថាទី ៣ ចប់

១-បិដកខ្មែរជា សីវលា ។

# សុមនកថាទី ៤

កាលព្រះមង្គលសម្ពុទ្ធបរិនិព្វាន ធ្វើឲ្យម៉ឺនលោកធាតុងងឹត យ៉ាងនេះហើយ តអំពីនោះមក ព្រះសាស្ដាព្រះនាមថា **សុមនៈ** ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះពុទ្ធអង្គនោះ មាន ៣ លើក សន្និបាតលើកទី ១ មានភិក្ខុមួយសែនកោដិ លើកទី ២ មានភិក្ខុប្រមាណ ៩ ម៉ឺនកោដិ ត្រង់ភ្នំកញ្ចនបព៌ត លើកទី ៣ មានភិក្ខុ ៨ ម៉ឺនកោដិ ។

គ្រានោះ ព្រះពោធិសត្វជានាគរាជ ឈ្មោះថា **អតុលៈ** មានឫទ្ធិច្រើន មានអានុភាពច្រើន បានជ្រាបថា ព្រះពុទ្ធទ្រង់ឧប្បត្តិកឡើងហើយ ទើបនាំពួកញាតិចេញអំពីនាគពិភព មកប្រគំតន្ត្រីទិព្វ បូជាព្រះមានព្រះភាគដែលមានភិក្ខុប្រមាណមួយសែនកោដិជាបរិវារ បានថ្វាយមហាទាន ហើយថ្វាយសំពត់មួយគូមួយអង្គ ហើយតាំងនៅក្នុងសរណៈទាំងឡាយ ព្រះសាស្ដាព្រះនាមសុមនៈនោះ បានព្យាករព្រះពោធិសត្វថា ក្នុងអនាគតកាល អតុលនាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។ នគររបស់ព្រះមានព្រះភាគអង្គនោះឈ្មោះថា **មេខលា** ព្រះបិតាជាព្រះរាជា ព្រះនាមថា **សុទត្ដៈ** ព្រះមាតាព្រះនាម **សិរិមា** ព្រះសរណត្ថេរ និងព្រះភាវិតត្ដត្ថេរ ជាគូអគ្គសាវក ភិក្ខុឧបដ្ឋាក ឈ្មោះថា ឧទេនត្ថេរ ព្រះនាងសោណាថេរី និងព្រះនាងឧបសោណាថេរី ជាគូអគ្គសាវិកា ដើមខ្ទឹងជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៩០ ហត្ថ ព្រះជន្មាយុរបស់ព្រះអង្គប្រមាណ ៩ ម៉ឺនឆ្នាំទុះឯង ។

សុមនកថាទី ៤ ចប់

# រេវតកថាទី ៥

ក្នុងសម័យតអំពីព្រះសុមនសម្ពុទ្ធនោះមក ព្រះសាស្ដាព្រះនាម **រេវតៈ** ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះរេវតសម្ពុទ្ធអង្គនោះ មាន ៣ លើក ក្នុងសន្និបាតលើកទី ១ មានភិក្ខុរាប់ចំនួនមិនអស់ លើកទី ២ មានភិក្ខុមួយសែនកោដិ ក្នុងលើកទី ៣ ក៏ដូចគ្នា ។

គ្រានោះ ព្រះពោធិសត្វជាព្រាហ្មណ៍ មានទាមថា **អតិទេវៈ** ស្ដាប់ព្រះធម៌ទេសនាហើយ តាំងនៅក្នុងសរណៈទាំងឡាយ ប្រណម្យអញ្ជលីលើសិរសា ពោលសរសើរការលះកិលេសរបស់ព្រះសាស្ដាអង្គនោះ ហើយបានបូជាដោយសំពត់ដណ្ដប់ ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគព្រះនាមថា រេវតៈ អង្គនោះ មាននគរឈ្មោះថា **សុធញ្ញវតី**[១] ព្រះបិតាជាក្សត្រិយ៍ ទ្រង់ព្រះនាមថា **វិបុលៈ** ព្រះមាតាព្រះនាម **វិបុលា** ព្រះវរុណត្ថេរ និងព្រះព្រហ្មទេវត្ថេរជាគូអគ្គសាវក ពុទ្ធុបដ្ឋាកឈ្មោះសម្ភវៈ ព្រះនាងភទ្ទាថេរី និងព្រះនាងសុភទ្ទាថេរី ជាគូអគ្គសាវិកា ដើមខ្លឹងជាឈើត្រាស់ដឹង ព្រះអង្គមានកម្ពស់ ៨០ ហត្ថ មានព្រះជន្មាយុ ៦ ម៉ឺនព្រះវស្សា ។

រេវតកថាទី ៥ ចប់

---

១-បិដកខ្មែរជា សុធញ្ញក ។

# **សោភិតកថាទី ៦**

ក្នុងសម័យតអំពីព្រះរេវតសម្ពុទ្ធនោះមក ព្រះសាស្ដា ទ្រង់ព្រះនាមថា **សោភិតៈ** ទ្រង់ឧប្បត្តិកឡើង សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក សន្និបាតលើកទី ១ មានភិក្ខុមួយរយកោដិ លើកទី ២ មានភិក្ខុ ៩០ កោដិ លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

គ្រានោះ ព្រះពោធិសត្វ ជាព្រាហ្មណ៍ មាននាមថា **អជិតៈ** ស្ដាប់ព្រះធម៌ទេសនារបស់ព្រះសាស្ដាហើយ តាំងនៅក្នុងសរណៈទាំងឡាយ បានថ្វាយមហាទានដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន សូម្បីព្រះសោភិតៈ ក៏ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគ ព្រះនាមថា **សោភិតៈ** នោះ មានឈ្មោះថា **សុធម្ម** ព្រះបិតាជាព្រះរាជា ព្រះនាមថា **សុធម្ម** ព្រះមាតាព្រះនាមថា **សុធម្មា** ព្រះអសមត្ថេរ និងព្រះសុនេត្តត្ថេរ ជាគូអគ្គសាវក ពុទ្ធុបដ្ឋាកឈ្មោះថា អនោមៈ ព្រះនាងនកុលាថេរី និងព្រះនាងសុជាតាថេរី ជាគូអគ្គ-សាវិកា ដើមខ្លឹងជាឈើត្រាស់ដឹង ព្រះអង្គមានព្រះសរីរៈកម្ពស់ ៥៨ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនព្រះវស្សា ។

សោភិតកថាទី ៦ ចប់

# អនោមទស្សីកថាទី ៧

ក្នុងសម័យតអំពីព្រះសោភិតសម្ពុទ្ធ កន្លងទៅមួយអសង្ខេយ្យ ក្នុងកប្ប ១ មានព្រះពុទ្ធកើតឡើង ៣ ព្រះអង្គ គឺ**ព្រះអនោមទស្សីសម្ពុទ្ធ ព្រះបទុមសម្ពុទ្ធ ព្រះនារទសម្ពុទ្ធ** សាសនារបស់ព្រះមានព្រះភាគ ព្រះនាមថា អនោមទស្សី មានសាវកសន្និបាត ៣ លើក ក្នុងលើកទី ១ មានភិក្ខុ ៨ សែន លើកទី ២ មានភិក្ខុ ៧ សែន លើកទី ៣ មានភិក្ខុ ៦ សែន ។

ក្នុងកាលនោះ ព្រះពោធិសត្វជាសេនាបតីយក្ស មានឫទ្ធិច្រើន មានអានុភាពច្រើន ជាធំជាងយក្សច្រើនសែនកោដិ ។ សេនាបតីយក្សនោះស្តាប់ថា ព្រះពុទ្ធទ្រង់ឧប្បត្តិកឡើងហើយ បានមកថ្វាយមហាទានដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន សូម្បីព្រះសាស្តាក៏បានព្យាករយក្សនោះថា ក្នុងអនាគតកាល នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **ចន្ទវតី** ព្រះបិតាជាព្រះរាជា ព្រះនាមថា **យសវា** ព្រះមាតាព្រះនាមថា **យសោធរា** ព្រះនិសភត្ថេរ និងព្រះអនោមត្ថេរ ជាគូអគ្គសាវក ពុទ្ធុបដ្ឋាក ឈ្មោះថា វរុណៈ ព្រះនាងសុន្ទរីថេរី[១] និងព្រះនាងសុមនាថេរី ជាគូអគ្គសាវិកា ដើមអជ្ជុនជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះមានព្រះភាគ កម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ។

***អនោមទស្សីកថាទី ៧ ចប់***

---

១- បិដកខ្មែរជា សុន្ទរា ។

# បទុមកថាទី ៨

ក្នុងសម័យតមក ព្រះសាស្តាទ្រង់ព្រះនាមថា **បទុមៈ** ទ្រង់ឧប្បត្តិកឡើង សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក លើកទី ១ មានភិក្ខុមួយសែនកោដិ លើកទី ២ មានភិក្ខុ ៣ សែនរូប លើកទី ៣ មានភិក្ខុអ្នកអាស្រ័យនៅក្នុងព្រៃមហាវ័ន ក្នុងព្រៃស្ងាត់ មកប្រជុំគ្នា ២ សែនរូប ។

គ្រានោះ ព្រះតថាគតគង់នៅក្នុងព្រៃនោះឯង ព្រះពោធិសត្វជាស្តេចសីហៈ បានឃើញព្រះសាស្តា កំពុងចូលនិរោធសមាបត្តិហើយ មានចិត្តជ្រះថ្លា ក៏ក្រាបចុះថ្វាយបង្គំ ធ្វើប្រទក្សិណ មានបីតិសោមនស្សកើត ហើយបន្លឺសីហនាទ ៣ ដង មិនលះបង់បីតិមានព្រះពុទ្ធជាអារម្មណ៍ មិនចេញទៅស្វែងរកអាហារ ព្រោះសេចក្តីសុខដែលកើតអំពីបីតិនុ៎ះឯង បានធ្វើការលះបង់ជីវិត ចូលទៅឈរយាមអស់ ៧ ថ្ងៃ កាលកន្លងទៅបាន ៧ ថ្ងៃ ព្រះសាស្តាទ្រង់ចេញអំពីនិរោធហើយ ទតឃើញស្តេចសីហៈ ទ្រង់ព្រះតម្រិះថា សីហៈនេះ ញ៉ាំងចិត្តឲ្យជ្រះថ្លាសូម្បីក្នុងពួកភិក្ខុ ហើយនឹងថ្វាយបង្គំភិក្ខុសង្ឃ ចូរភិក្ខុសង្ឃមក ដូច្នេះ ភិក្ខុទាំងឡាយមកហើយ ក្នុងខណៈនោះមួយរំពេច ស្តេចសីហៈ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងសង្ឃ ព្រះសាស្តា ទ្រង់ប្រមើលមើលភូមិកធម៌ដែលមាននៅក្នុងចិត្តរបស់ស្តេចសីហៈ ទើបព្យាករថា ក្នុងអនាគតកាល ស្តេចសីហៈនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **ចម្បកៈ** ព្រះបិតាជាព្រះរាជា ព្រះនាមថា **អសមៈ** ព្រះមាតាព្រះនាមថា **អសមា** ព្រះសាលត្ថេរនិងព្រះឧបសាលត្ថេរ ជាគូអគ្គសាវក ពុទ្ធុបដ្ឋាក ឈ្មោះថា វរុណៈ

ព្រះនាងភរមាថេរី និងព្រះនាងសុភមាថេរី[1] ជាគូអគ្គសាវិកា ដើមម្រុមជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះអង្គកម្ពស់ ៥៨ ហត្ថ មានព្រះជន្មាយុមួយសែនឆ្នាំ ។

## បទុមកថាទី ៨ ចប់

១- បិដកខ្មែរជា ព្រះនាងភរជា និងព្រះនាងសុភជា ។

# នារទកថាទី ៩

ក្នុងសម័យខាងក្រោយមក ព្រះសាស្តា ទ្រង់ព្រះនាមថា **នារទៈ** ទ្រង់ឧប្បត្តិកឡើង សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក សន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ មានភិក្ខុ ៩០ ពាន់កោដិ លើកទី ៣ មានភិក្ខុ ៨០ ពាន់កោដិ[១] ។

គ្រានោះ ព្រះពោធិសត្វបួសជាឥសី ជាអ្នកស្ទាត់ជំនាញក្នុងអភិញ្ញា ៥ និងសមាបត្តិ ៨ បានថ្វាយមហាទានដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន ហើយបូជាដោយខ្លឹមចន្ទន៍ក្រហម សូម្បីព្រះមានព្រះភាគអង្គនោះ ក៏ទ្រង់ព្យាករព្រះពោធិសត្វនោះថា ក្នុងអនាគតកាល ឥសីនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **ធញ្ញវតី** ព្រះបិតាជាក្សត្រិយ៍ ព្រះនាមថា **សុទេវៈ** ព្រះមាតាព្រះនាមថា **អនោមា** ព្រះភទ្ទសាលត្ថេរ និងជិតមិត្តត្ថេរ ជាគូអគ្គសាវក ពុទ្ធុបដ្ឋាក ឈ្មោះថា ព្រះវាសិដ្ឋ[២] ព្រះនាងឧត្តរាថេរី និងព្រះនាងផគ្គុនីថេរី ជាគូអគ្គសាវិកា មហាសោណព្រឹក្ស ( ដើមម្រុម ) ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ[៣] ។

**នារទកថាទី ៩ ចប់**

---

១-បិដកខ្មែរជា ៨០ សែន ។

២-បិដកខ្មែរជា វាសេដ្ឋៈ ។

៣- បិដកខ្មែរជាប្រាំបួនសែនឆ្នាំ ធម្មតាព្រះពុទ្ធមិនដែលមានព្រះជន្មវែងជាង ១ សែនឆ្នាំទេ បណ្ឌិតគប្បីពិចារណា ឯបាលីជា ៩ ម៉ឺនឆ្នាំដូចគ្នា ( នវុតិវស្សសហស្សានិ ) ។

# បទុមុត្តរកថាទី ១០

ក្នុងសម័យក្រោយអំពីព្រះពុទ្ធព្រះនាមនារទៈអង្គនោះមក កន្លងទៅមួយអសង្ខេយ្យ រាប់ថយក្រោយអំពីកប្បនេះ ក្នុងទីបំផុតនៃមួយសែនកប្ប ក្នុងកប្បមួយ មានព្រះពុទ្ធទ្រង់ព្រះនាម **បទុមុត្តរៈ** មួយព្រះអង្គប៉ុណ្ណោះ ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះអង្គមាន ៣ លើក ក្នុងលើកទី ១ មានភិក្ខុមួយសែនកោដិ លើកទី ២ មានភិក្ខុមកប្រជុំនៅនាភ្នំវេភារបព៌ត ៩០ ពាន់កោដិ លើកទី ៣ មានភិក្ខុ ៨០ ពាន់កោដិ ។

គ្រានោះ ព្រះពោធិសត្វសោយព្រះជាតិជាអ្នកគ្រប់គ្រងមហារដ្ឋ ឈ្មោះថា **ជដិលៈ** បានថ្វាយទាន ព្រមទាំងចីវរដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន សូម្បីព្រះបទុមុត្តរសម្ពុទ្ធ ព្រះអង្គនោះ ក៏បានព្យាករព្រះពោធិសត្វថា ក្នុងអនាគតកាល ជដិលៈនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ ឈ្មោះថាតិរ្ថិយមិនមាន ។ ទេវតា និងមនុស្សទាំងពួង បានដល់ព្រះពុទ្ធប៉ុណ្ណោះជាសរណៈ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **ហំសវតី** ព្រះបិតាជាក្សត្រិយ៍ ព្រះនាមថា **អានន្ទៈ** ព្រះមាតាព្រះនាមថា **សុជាតា** ព្រះទេវិលត្ថេរ និងព្រះសុជាតត្ថេរជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាកមាននាមថា សុមនៈ ព្រះនាងអមិត្តាថេរី និងព្រះនាងអសមាថេរី ជាគូអគ្គសាវិកា ដើមស្រល់ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ( បិដកខ្មែរជា ៥៨ ហត្ថក្រពុំ ) រស្មីព្រះវរកាយផ្សាយទៅ ១២ យោជន៍ ព្រះជន្មាយុមួយសែនឆ្នាំ ។

បទុមុត្តរកថាទី ១០ ចប់

# សុមេធកថាទី ១១

ក្នុងសម័យខាងក្រោយអំពីព្រះបទុមុត្តរសម្ពុទ្ធអង្គនោះកន្លងទៅបាន ៧០ ពាន់កប្ប រាប់ថយក្រោយអំពីកប្បនេះទៅ ៣ ម៉ឺនកប្ប ក្នុងកប្បមួយ មានព្រះពុទ្ធទ្រង់ឧប្បត្តិកឡើង ២ ព្រះអង្គ គឺ**ព្រះសុមេធសម្ពុទ្ធ** និង**ព្រះសុជាតសម្ពុទ្ធ** សាវកសន្និបាត របស់ព្រះសុមេធសម្ពុទ្ធនោះ ក៏មាន ៣ លើក លើកទីមួយ នៅក្នុងនគរសុទស្សនៈ មានភិក្ខុជាព្រះខីណាស្រព ១០០ កោដិ លើកទីពីរ ៩០ កោដិ លើកទីបី ៨០ កោដិ ។

គ្រានោះ ព្រះពោធិសត្វជាមាណព មានឈ្មោះថា **ឧត្តរៈ** លះបង់ទ្រព្យដែលកប់ទុក ៨០ កោដិ ថ្វាយមហាទានដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន ស្តាប់ធម៌ តាំងនៅក្នុងសរណៈទាំងឡាយហើយចេញបួស ព្រះពុទ្ធអង្គនោះ ក៏បានព្យាករព្រះពោធិសត្វនោះថា ក្នុងអនាគតកាល មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគព្រះនាមថា **សុមេធៈ** ឈ្មោះថា **សុទស្សនៈ** ព្រះបិតាជាព្រះរាជា ព្រះនាមថា **សុទត្តៈ** ព្រះមាតាព្រះនាមថា **សុទត្តា** ព្រះសរណត្ថេរ និងព្រះសព្វកាមត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាក មាននាមថា សាគរត្ថេរ ព្រះនាងរាមាថេរី និងព្រះនាងសុរាមាថេរីជាគូអគ្គសាវិកា ដើមស្តៅជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

**សុមេធកថាទី ១១ ចប់**

# សុជាតកថាទី ១២

ក្នុងសម័យខាងក្រោយអំពីព្រះសម្ពុទ្ធអង្គនោះមក ព្រះសាស្ដាព្រះនាមថា **សុជាតៈ** ទ្រង់ឧប្បត្តិកឡើង សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក លើកទី ១ មានភិក្ខុ ៦០ សែនរូប លើកទី ២ មានភិក្ខុ ៥០ សែនរូប លើកទី ៣ មានភិក្ខុ ៤០ សែនរូប[១] ។

គ្រានោះ ព្រះពោធិសត្វជាស្ដេចចក្កពត្តិ ទ្រង់ស្ដាប់ថា ព្រះពុទ្ធទ្រង់ឧប្បត្តិកឡើងហើយ ទើបចូលទៅគាល់ ទ្រង់ស្ដាប់ធម៌ហើយថ្វាយរាជសម្បត្តិក្នុងមហាទ្វីបទាំង ៤ ព្រមដោយរតនៈ ៧ ប្រការ ដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន ហើយទ្រង់បួសក្នុងសម្នាក់របស់ព្រះមានព្រះភាគព្រះអង្គនោះ អ្នកដែនទាំងអស់ កាន់យកសួយរបស់រដ្ឋមកឲ្យ សម្រេចកិច្ចកម្មរបស់អារាម ថ្វាយមហាទានជានិច្ចដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន សូម្បីព្រះពុទ្ធអង្គនោះ ក៏ទ្រង់ព្យាករស្ដេចចក្កពត្តិនោះហើយ ។

នគររបស់ព្រះសុជាតសម្ពុទ្ធអង្គនោះ ឈ្មោះថា **សុមង្គលៈ** ព្រះបិតាជាព្រះរាជា ព្រះនាមថា **ឧគ្គតៈ** ព្រះមាតាព្រះនាមថា **បភាវតី** ព្រះសុទស្សនៈ និងព្រះសុទេវៈ ជាគូអគ្គសាវក ភិក្ខុឧបដ្ឋាកមាននាមថា នារទៈ ព្រះនាងនាគាថេរី និងព្រះនាងនាគសមាលាថេរី[២] ជាគូអគ្គសាវិកា ដើមឫស្សី

១-បិដកខ្មែរជា ៤ សែន ។

២-បិដកខ្មែរជា នាគសមានា ។

ធំជាឈើត្រាស់ដឹង បានឮថា ដើមឫស្សីនោះតាន់ មិនមានប្រហោង លម្អ ទៅដោយមែកធំឡើងទៅខាងលើ ដូចកន្ទុយក្ងោក ព្រះសរីរៈរបស់ព្រះអង្គ កម្ពស់ ៥០ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

## សុជាតកថាទី ១២ ចប់

# បិយទស្សីជាទី ១៣

ក្នុងសម័យខាងក្រោយអំពីព្រះសុជាតសម្ពុទ្ធអង្គនោះ ក្នុងទីបំផុតនៃ ១៨០០ កប្ប អំពីកប្បនេះ ក្នុងកប្បមួយ មានព្រះពុទ្ធទ្រង់ឧប្បត្តិកឡើង ៣ អង្គ គឺ**ព្រះបិយទស្សីសម្មាសម្ពុទ្ធ ព្រះអត្ថទស្សីសម្មាសម្ពុទ្ធ ព្រះធម្មទស្សីសម្មាសម្ពុទ្ធ** សូម្បីព្រះសម្ពុទ្ធព្រះនាមថា បិយទស្សីអង្គនោះ ក៏មានសាវកសន្និបាត ៣ លើក លើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ មានភិក្ខុ ៩០ កោដិ លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

គ្រានោះ ព្រះពោធិសត្វជាមាណព មាននាមថា **កស្សប** ដល់នូវត្រើយនៃត្រៃវេទ បានស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ បរិច្ចាគទ្រព្យមួយសែនកោដិសាងសង្ឃារាម តាំងនៅក្នុងសរណៈ និងសីលទាំងឡាយ គ្រានោះ ព្រះសាស្តាទ្រង់ព្យាករព្រះពោធិសត្វនោះថា កាលកន្លងទៅ ១៨០០ កប្បហើយ សត្វនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **អនោម**[១] ព្រះបិតាជាព្រះរាជា ព្រះនាមថា **សុទិន្នៈ**[២] ព្រះមាតាព្រះនាមថា **ចន្ទា**[៣] ព្រះបាលិតត្ថេរ និងព្រះសព្វទស្សីថេរៈ ជាគូអគ្គសាវក ភិក្ខុឧបដ្ឋាកមាននាមថា

---

១- បិដកខ្មែរជា សុធញ្ញៈ ។ ២- បិដកខ្មែរជា សុទត្ត ។ ៣- បិដកខ្មែរជា សុចន្ទា ។

សោភិតៈ ព្រះនាងសុជាតាថេរី និងព្រះនាងធម្មទិន្នាថេរី ជាគូអគ្គសាវិកា ដើមប្រយង្គ[១] ជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះអង្គកម្ពស់ ៨០ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

## បរិយទស្សិកថាទី ១៣ ចប់

១- បិដកខ្មែរជា ដើមថ្វាន់ ។

# អត្ថទស្សីកថាទី ១៤

ក្នុងសម័យខាងក្រោយព្រះសម្ពុទ្ធអង្គនោះ ព្រះមានព្រះភាគព្រះនាមថា **អត្ថទស្សី** ទ្រង់ឧប្បត្តិកឡើង សូម្បីសាវកសន្និបាតរបស់ព្រះមានព្រះភាគអង្គនោះ មាន ៣ លើក លើកទី ១ មានភិក្ខុ ៩ លាន ៨ សែន[១] លើកទី ២ មានភិក្ខុ ៨ ម៉ឺន ៨ ពាន់ លើកទី ៣ ក៏មានភិក្ខុ ៨ ម៉ឺន ៨ ពាន់ ដូចគ្នា[២] ។

គ្រានោះ ព្រះពោធិសត្វជាតាបសមានឫទ្ធិច្រើន មាននាមថា **សុសីម**[៣] បាននាំឆត្រផ្កាមន្ទារវៈ អំពីទេវលោកមកបូជាព្រះសាស្តា សូម្បីព្រះសាស្តាក៏បានព្យាករព្រះពោធិសត្វនោះហើយ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **សោភណា** ព្រះបិតាជាព្រះរាជា ព្រះនាមថា **សាគរៈ** ព្រះមាតាព្រះនាមថា **សុទស្សនា** ព្រះសន្តុត្តរ និងព្រះឧបសន្តុត្តរជាគូអគ្គសាវក ព្រះឧបដ្ឋាក មាននាមថា អភ័យ ព្រះនាងធម្មាថេរី និងព្រះនាងសុធម្មាថេរី ជាគូអគ្គសាវិកា ដើមចម្ប៉ាជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨០ ហត្ថ រស្មីព្រះវរកាយ ផ្សាយទៅជុំវិញមួយយោជន៍អស់កាលជានិច្ច ព្រះជន្មាយុ ១ សែនឆ្នាំ ។

**អត្ថទស្សីកថាទី ១៤ ចប់**

១- បិដកខ្មែរជា ៩៨ ពាន់ ។ ២- បិដកខ្មែរជា ៧៨ ពាន់ ។ ៣- បិដកខ្មែរជាសុសិមៈ ។

# ធម្មទស្សីកថាទី ១៥

ក្នុងសម័យខាងក្រោយអំពីព្រះសម្ពុទ្ធអង្គនោះ ព្រះសាស្ដា ព្រះនាមថា **ធម្មទស្សី** ទ្រង់ឧប្បត្តិកឡើង សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក សន្និបាតលើកទី ១ មានភិក្ខុ ១០០ កោដិ[១] លើកទី ២ មានភិក្ខុ ៩០ កោដិ[២] លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

គ្រានោះ ព្រះពោធិសត្វជាសក្កទេវរាជ ទ្រង់ធ្វើការបូជាដោយផ្កាកម្រង គ្រឿងក្រអូបដ៏ជាទិព្វ និងតន្ត្រីដ៏ជាទិព្វ សូម្បីព្រះមានព្រះភាគអង្គនោះ ក៏បានព្យាករព្រះពោធិសត្វហើយ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **សរណៈ** ព្រះបិតាជាព្រះរាជា ព្រះនាមថា **សរណៈ** ព្រះមាតាទ្រង់ព្រះនាមថា **សុនន្ទា** ព្រះបទុមត្ថេរ និងព្រះបុស្សទេវត្ថេរ ជាគូអគ្គសាវក ព្រះឧបដ្ឋាកមាននាមថា សុនេត្តៈ[៣] ព្រះនាងខេមាថេរី និងព្រះនាងសច្ចនាមាថេរី ជាគូអគ្គសាវិកា ដើមទន្ទាប់ជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះមានព្រះភាគអង្គនោះ កម្ពស់ ៨០ ហត្ថ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

ធម្មទស្សីកថាទី ១៥ ចប់

---

១- បិដកខ្មែរជា មួយពាន់កោដិ ។ ២- បិដកខ្មែរជា មួយរយកោដិ ។

៣- បិដកខ្មែរជា ព្រះសុទត្តត្ថេរ ។

# សិទ្ធត្ថកថាទី ១៦

ក្នុងសម័យខាងក្រោយអំពីព្រះសម្ពុទ្ធអង្គនោះមក រាប់ថយក្រោយអំពីកប្បនេះទៅ ៩៤ កប្ប ក្នុងកប្បមួយ មានព្រះពុទ្ធមួយព្រះអង្គ ព្រះនាមថា **សិទ្ធត្ថៈ** ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះមានព្រះភាគអង្គនោះមាន ៣ លើក ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិ[១] ក្នុងលើកទី ២ មានភិក្ខុ ៩០ កោដិ ក្នុងលើកទី ៣ មានភិក្ខុ ៨០ កោដិ ។

គ្រានោះ ព្រះពោធិសត្វ ជាតាបស មាននាមថា **មង្គលៈ** មានតេជះដ៏ខ្លាំងក្លា ដល់ព្រមដោយកម្លាំងនៃអភិញ្ញា បាននាំផ្លែព្រីងធំ ( ព្រីងប្រចាំទ្វីប ) មកថ្វាយព្រះតថាគត ។ ព្រះសាស្តា ទ្រង់សោយផ្លែព្រីងនោះហើយ ទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងទីបំផុតនៃកប្បទី ៩៤ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **វេភារៈ** ព្រះបិតាជាព្រះរាជាមានព្រះនាមថា **ជយសេនៈ**[២] ព្រះមាតាមានព្រះនាមថា **សុជស្សា** ព្រះសម្ពលត្ថេរ និងព្រះសុមិត្តត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាកមាននាមថា រេវតៈ ព្រះនាងសីវលាថេរី និងព្រះនាងសុរាមាថេរី ជាគូអគ្គសាវិកា ដើមកណិការ ជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះអង្គ កម្ពស់ ៦០ ហត្ថ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

*សិទ្ធត្ថកថាទី ១៦ ចប់*

---

១- បិដកខ្មែរជា ១០០ កោដិ ។ ២- បិដកខ្មែរជា ឧទេនៈ ។

# តិស្សកថាទី ១៧

ក្នុងសម័យខាងក្រោយអំពីព្រះសម្ពុទ្ធអង្គនោះមក រាប់ថយក្រោយអំពីភទ្ទកប្បនេះទៅ ៩២ កប្ប ក្នុងកប្បមួយ មានព្រះពុទ្ធ ២ ព្រះអង្គ ទ្រង់ឧប្បត្តិកឡើង គឺ**ព្រះតិស្សសម្មាសម្ពុទ្ធ និងព្រះផុស្សសម្មាសម្ពុទ្ធ**[១] សាវកសន្និបាត របស់ព្រះតិស្សសម្មាសម្ពុទ្ធ ក៏មាន ៣ លើក ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១០០ កោដិ[២] ក្នុងលើកទី ២ មានភិក្ខុ ៩០ កោដិ[៣] ក្នុងលើកទី ៣ មានភិក្ខុ ៨០ កោដិ[៤] ។

គ្រានោះ ព្រះពោធិសត្វ ជាក្សត្រិយ៍ ទ្រង់ព្រះនាមថា **សុជាតៈ** មានព្រះរាជសម្បត្តិច្រើន មានយសធំ ទ្រទ្រង់ផ្នួសជាឥសី ដល់នូវភាពជាអ្នកមានឫទ្ធិច្រើន ទ្រង់ស្តាប់ថា ព្រះពុទ្ធទ្រង់ឧប្បត្តិកឡើងហើយ ទើបកាន់យកផ្កាមន្ទារវៈ ផ្កាបទុម និងផ្កាបារិច្ឆត្តកៈដ៏ជាទិព្វមកបូជាព្រះតថាគត ទ្រង់យាងទៅក្នុងកណ្តាលបរិស័ទទាំង ៤ ផ្កាទាំងនោះ បានក្លាយជាពិតានផ្កា តាំងនៅក្នុងអាកាស សូម្បីព្រះសាស្តាអង្គនោះ ក៏បានព្យាករព្រះពោធិសត្វនោះថា រាប់អំពីកប្បនេះទៅ ក្នុងកប្បទី ៩២ តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **ខេមៈ**[៥] ព្រះរាជបិតាព្រះនាមថា **ជនសន្ធៈ**[៦] ព្រះរាជមាតាព្រះនាមថា **បទុមា** ព្រះព្រហ្មទេវត្ថេរ

---

១- បិដកខ្មែរជា ព្រះបុស្ស ។ ២- បិដកខ្មែរជា ១ សែនអង្គ ។ ៣- បិដកខ្មែរជា ៩០ សែនអង្គ ។ ៤- បិដកខ្មែរជា ៨០ សែនអង្គ ។ ៥- បិដកខ្មែរជា ខេមកៈ ។ ៦-បិដកខ្មែរជា ជនសន្ធៈ ។

និងព្រះឧទយត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាក មានទាមថា សមង្គៈ[1] ព្រះនាងផុស្សាថេរី និងព្រះនាងសុទត្តាថេរី ជាគូអគ្គសាវិកា ដើមធ្ងន់ជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៦០ ហត្ថ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

**តិស្សកថាទី ១៧ ចប់**

១- ច្បាប់របស់ស្យាមជា សុមង្គលៈ បិដកខ្មែរជា សមគៈ ។

# ផុស្សកថាទី ១៨

ក្នុងសម័យខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធអង្គនោះមក ព្រះសាស្ដា ព្រះនាមថា **ផុស្សៈ** ទ្រង់ឧប្បត្តិកឡើង សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក ក្នុងលើកទី ១ មានភិក្ខុ ៦ លាន ក្នុងលើកទី ២ មានភិក្ខុ ៥ លាន ក្នុងលើកទី ៣ មានភិក្ខុ ៣ លាន ២ សែន[១] ។

គ្រានោះ ព្រះពោធិសត្វ ជាក្សត្រិយ៍ ព្រះនាមថា **វិជិតាវី** បានលះបង់រាជសម្បត្តិធំ ចូលបួសក្នុងសម្នាក់ព្រះសាស្ដា រៀនចប់ព្រះត្រៃបិដក បានពោលធម្មកថាដល់មហាជន និងបំពេញសីលបារមី សូម្បីព្រះពុទ្ធអង្គនោះក៏បានព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **កាសី** ព្រះរាជបិតាព្រះនាមថា **ជយសេនៈ** ព្រះរាជមាតា ព្រះនាមថា **សិរិមា** ព្រះសុរក្ខិតត្ថេរ និងព្រះធម្មសេនត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាកមាននាមថា សភិយៈ[២] ព្រះនាងចាលាថេរី និងព្រះនាងឧបចាលាថេរី ជាគូអគ្គសាវិកា ដើមកន្ទួតព្រៃជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ផុស្សកថាទី ១៨ ចប់

---

១- បិដកខ្មែរជា ៤០ សែន ។ ២- បិដកខ្មែរជា សភិយ្យៈ ។

# វិបស្សីកថាទី ១៩

*ក្នុងសម័យខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធអង្គនោះមក រាប់ចាប់អំពីកប្បនេះថយទៅ ក្នុងកប្បទី ៩១ ព្រះមានព្រះភាគ ព្រះនាមថា* **វិបស្សី** *ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះអង្គ មាន ៣ លើក ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ៦ លាន ៨ សែន ក្នុងលើកទី ២ មានភិក្ខុ ១ សែន ក្នុងលើកទី ៣ មានភិក្ខុ ៨ ម៉ឺន ។*

*គ្រានោះ ព្រះពោធិសត្វ ជានាគរាជ មានឈ្មោះថា* **អតុលៈ** *មានឫទ្ធិច្រើន មានអានុភាពច្រើន បានថ្វាយតាំងមាសដែលរំលេចទៅដោយរតនៈ ៧ ប្រការ ដល់ព្រះមានព្រះភាគ សូម្បីព្រះមានព្រះភាគអង្គនោះ ក៏ទ្រង់ព្យាករព្រះពោធិសត្វនោះថា រាប់អំពីកប្បនេះទៅ ក្នុងកប្បទី ៩១ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។*

*នគររបស់ព្រះពុទ្ធអង្គនោះ មានឈ្មោះថា* **ពន្ធុមតី** *ព្រះរាជបិតា ព្រះនាមថា* **ពន្ធុមា** *ព្រះរាជមាតា ព្រះនាមថា* **ពន្ធុមតី** *ព្រះខណ្ឌត្តេរ*[១] *និងព្រះតិស្សត្ថេរជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាកមាននាមថា អសោកៈ ព្រះនាងចន្ទាថេរី និងព្រះនាងចន្ទមិត្តាថេរី ជាគូអគ្គសាវិកា ដើមប្រទៀង ជាឈើត្រាស់ដឹង ព្រះអង្គមានព្រះសរីរៈកម្ពស់ ៨០ ហត្ថ មានព្រះរស្មីផ្សាយទៅ ៧ យោជន៍ដោយជុំវិញ មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ។*

*វិបស្សីកថាទី ១៩ ចប់*

---

*១- បិដកខ្មែរជា ខន្ធៈ ។*

# សិខីកថាទី ២០

ក្នុងសម័យខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធអង្គនោះមក រាប់ថយក្រោយអំពីកប្បនេះ ក្នុងកប្បទី ៣១ មានព្រះពុទ្ធឧប្បត្តិកឡើង ២ ព្រះអង្គ គឺ**ព្រះសិខីសម្ពុទ្ធ និងព្រះវេស្សភូសម្ពុទ្ធ** សាវកសន្និបាតរបស់ព្រះមានព្រះភាគ ព្រះនាមថា សិខី ក៏មាន ៣ លើក ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ សែនរូប ក្នុងលើកទី ២ មានភិក្ខុ ៨ ម៉ឺនរូប ក្នុងលើកទី ៣ មានភិក្ខុ ៧ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វ ជាព្រះរាជា ព្រះនាមថា **អរិន្ទមៈ** បានថ្វាយមហាទាន មួយអន្ទើដោយចីវរដល់ភិក្ខុ មានព្រះពុទ្ធជាប្រធាន បានថ្វាយដំរីកែវប្រដាប់ដោយរតនៈ ៧ ប្រការ បានថ្វាយកប្បិយភណ្ឌ មានតំនរប្រមាណប៉ុនស្តេចដំរី ។ សូម្បីព្រះពុទ្ធអង្គនោះ ទ្រង់បានព្យាករព្រះពោធិសត្វនោះថា រាប់អំពីកប្បនេះទៅ ក្នុងកប្បទី ៣១ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **អរុណាវតី** ព្រះរាជបិតា ព្រះនាមថា **អរុណវា** ( បិដកខ្មែរជា អរុណៈ ) ព្រះរាជមាតា ព្រះនាមថា **បភាវតី** ព្រះអភិភូថេរៈ និងព្រះសម្ភវត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាក មាននាមថា ខេមង្ករ ព្រះនាងសខិលាថេរី និងព្រះនាងបទុមាថេរី ជាគូអគ្គសាវិកា ដើមបុណ្ឌរីកព្រឹក្ស ( ដើមស្វាយ-ស ) ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៧០ ហត្ថ មានព្រះរស្មីផ្សាយទៅ ៣ យោជន៍ដោយជុំវិញ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ។

**សិខីកថាទី ២០ ចប់**

# វេស្សភូកជាទី ២១

ក្នុងសម័យខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធអង្គនោះមក ព្រះសាស្តា ព្រះនាមថា **វេស្សភូ** ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះអង្គ មាន ៣ លើក ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ៨ ម៉ឺន[១] ក្នុងលើកទី ២ មានភិក្ខុ ៧ ម៉ឺន[២] ក្នុងលើកទី ៣ មានភិក្ខុ ៦ ម៉ឺន[៣] ។

គ្រានោះ ព្រះពោធិសត្វ ជាព្រះរាជាព្រះនាមថា **សុទស្សនៈ** បានថ្វាយមហាទាន ព្រមទាំងចីវរដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន ហើយទ្រង់បួសក្នុងសម្នាក់ព្រះសាស្តា ជាអ្នកដល់ព្រមដោយអាចារគុណ ជាអ្នកឱនលំទោន និងច្រើនទៅដោយបីតិក្នុងពុទ្ធរតនៈ ព្រះមានព្រះភាគអង្គនោះ ទ្រង់បានព្យាករព្រះពោធិសត្វនោះថា រាប់អំពីកប្បនេះទៅ ក្នុងកប្បទី ៣១ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **អនោមៈ** ព្រះរាជបិតា ព្រះនាមថា **សុប្បតីតៈ** ព្រះរាជមាតាព្រះនាមថា **យសវតី** ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាក មាននាមថា ឧបសន្តៈ ព្រះនាងទាមាថេរី និងព្រះនាងសមាលាថេរី[៤] ជាគូអគ្គសាវិកា

---

១- បិដកខ្មែរជា ៨០ ពាន់កោដិ ។ ២- បិដកខ្មែរជា ៧០ ពាន់កោដិ ។

៣- បិដកខ្មែរជា ៦០ ពាន់កោដិ ។ ៤- បិដកខ្មែរជា រាមា និងសមានា ។

ដើមសាលព្រឹក្ស ជាឈើត្រាស់ដឹង ព្រះអង្គមានព្រះសរីរៈកម្ពស់ ៦០ ហត្ថ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ។

## វេស្សភូកថាទី ២១ ចប់

# កកុសន្ធកជាតី ២២

ក្នុងសម័យខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធនោះមក ក្នុងកប្បនេះ មានព្រះពុទ្ធ ៤ ព្រះអង្គ ទ្រង់ឧប្បត្តិកឡើង គឺ**ព្រះកកុសន្ធសម្មាសម្ពុទ្ធ ព្រះកោនាគមនសម្មាសម្ពុទ្ធ ព្រះកស្សបសម្មាសម្ពុទ្ធ និងព្រះមានព្រះភាគនៃយើងទាំងឡាយ** សាវកសន្និបាតរបស់ព្រះមានព្រះភាគ ព្រះនាមថា កកុ-សន្ធៈ មានមួយលើក មានភិក្ខុមកប្រជុំ ៤ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វជាព្រះរាជា ព្រះនាមថា **ខេមៈ** បានថ្វាយមហា-ទាន ព្រមទាំងបាត្រចីវរ និងថ្នាំបន្តក់ភ្នែកដល់ពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន បានស្ដាប់ធម៌ទេសនារបស់ព្រះសាស្ដាហើយ ទ្រង់បួស ។ សូម្បីព្រះសាស្ដាអង្គនោះ ក៏ព្យាករព្រះពោធិសត្វហើយ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **ខេមៈ**[១] បិតាជាព្រាហ្មណ៍ មាននាមថា **អគ្គិទត្ត:** មាតាជាព្រាហ្មណី មាននាមថា **វិសាខា** ព្រះវិធុរត្ថេរ និងព្រះសញ្ជីវត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាក មាននាមថា ពុទ្ធិជៈ ព្រះនាងសាមាថេរី និងព្រះនាងចម្បាថេរីជាគូអគ្គសាវិកា ដើមប្រេសធំជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៤០ ហត្ថ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ។

**កកុសន្ធកថាទី ២២ ចប់**

---

១- បិដកខ្មែរជា ខេមវតី ។

# កោណាគមនកជាតិ ២៣

ក្នុងសម័យខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធអង្គនោះមក ព្រះសាស្ដាព្រះនាមថា **កោណាគមនៈ** ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះអង្គមាន ១ លើក ក្នុងសន្និបាតនោះ មានភិក្ខុ ៣ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វជាព្រះរាជា ទ្រង់ព្រះនាមថា **បព្វតៈ** ទ្រង់ចោមរោមដោយពួកអមាត្យ យាងទៅកាន់សម្នាក់ព្រះសាស្ដា ស្ដាប់ធម៌ទេសនា ហើយនិមន្តពួកភិក្ខុ មានព្រះពុទ្ធជាប្រធាន ថ្វាយមហាទាន ហើយថ្វាយសំពត់ថ្មី សំពត់ចិនៈ សំពត់សូត្រ សំពត់កម្ពល និងស្បែកជើងមាស ហើយទ្រង់បួសក្នុងសម្នាក់ព្រះសាស្ដា ព្រះសាស្ដាអង្គនោះ ទ្រង់បានព្យាករព្រះពោធិសត្វ ។

នគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា **សោភវតី** ព្រះបិតាជាព្រាហ្មណ៍ មាននាមថា **យញ្ញទត្តៈ** ព្រះមាតាជាព្រាហ្មណី មាននាមថា **ឧត្តរា** ព្រះភិយ្យោសត្ថេរ និងព្រះឧត្តរត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាកមាននាមថា សោត្ថិជៈ ព្រះនាងសមុទ្ទាថេរី និងព្រះនាងឧត្តរាថេរី ជាគូអគ្គ-សាវិកា ដើមល្វាជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៣០ ហត្ថ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ។

កោនាគមនកជាទី ២៣ ចប់

# កស្សបកថាទី ២៤

ក្នុងសម័យខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធអង្គនោះមក មានព្រះសាស្ដា ព្រះនាមថា **កស្សប** ទ្រង់ឧប្បត្តិកឡើង សាវកសន្និបាតរបស់ព្រះមាន-ព្រះភាគអង្គនោះ មានតែមួយលើក មានភិក្ខុ ២ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វជាមាណព មាននាមថា **ជោតិបាល** ជាអ្នករៀនចប់ត្រៃវេទ មានឈ្មោះបោះសំឡេងប្រាកដខ្ចរខ្ចាយទៅទាំងលើគោក និងឰដ៏អាកាស ជាមិត្តនៃស្មូនឆ្នាំង មាននាមថា ឃដិការ ព្រះពោធិសត្វនោះបានចូលទៅគាល់ព្រះសាស្ដាជាមួយនឹងស្មូនឆ្នាំងនោះ ស្ដាប់ធម្មកថា បួសហើយ ប្រារព្ធសេចក្ដីព្យាយាម រៀនចប់ព្រះត្រៃបិដក ជម្រះព្រះពុទ្ធសាសនាឲ្យបរិសុទ្ធដោយវត្តសម្បត្តិ សូម្បីព្រះសាស្ដាអង្គនោះ ក៏បានព្យាករព្រះពោធិសត្វនោះហើយ ។

នគរដែលព្រះមានព្រះភាគអង្គនោះប្រសូត មានឈ្មោះថា **ពារាណសី** ព្រះបិតាជាព្រាហ្មណ៍ មាននាមថា **ព្រហ្មទត្ត** ព្រះមាតាជាព្រាហ្មណី មាននាមថា **ធនវតី** ព្រះតិស្សត្ថេរ និងព្រះភារទ្វាជត្ថេរ ជាគូអគ្គសាវក ភិក្ខុជាឧបដ្ឋាក មាននាមថា សព្វមិត្ត ព្រះនាងអនុឡាថេរី និងព្រះនាងឧរុវេឡាថេរី ជាគូអគ្គសាវិកា ដើមនិគ្រោធ ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ២០ ហត្ថ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ។

**កស្សបកថាទី ២៤ ចប់**

ចំណែកក្នុងកាលតអំពីព្រះសម្មាសម្ពុទ្ធ ព្រះនាមថា កស្សបនោះមក វៀរព្រះសម្មាសម្ពុទ្ធអង្គនេះនៃយើងទាំងឡាយហើយ មិនមានព្រះពុទ្ធអង្គដទៃឡើយ[១] ។ ព្រះពោធិសត្វបានទទួលព្យាករក្នុងសម្នាក់ព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះទីបង្ករសម្មាសម្ពុទ្ធជាដើម ដែលមានអភិនីហារបានធ្វើទុកហើយ ទៀបបាទមូលរបស់ព្រះពុទ្ធ ព្រះនាមថា ទីបង្ករ ដោយសមោធានធម៌ ៨ ប្រការនេះ គឺអភិនីហារ រមែងសម្រេចបាន ព្រោះសមោធានធម៌ ៨ ប្រការ គឺ

ភាពជាមនុស្ស ១ ការដល់ព្រមដោយភេទ ១ ហេតុ ១
ការបានជួបព្រះសាស្តា ១ បព្វជ្ជា ១ ការដល់ព្រមដោយ
គុណ ១ ការធ្វើដ៏ក្រៃលែង ១ ឆន្ទៈ ១ ។

ហើយធ្វើនូវឧស្សាហៈថា ណ្ហើយចុះ អញនឹងជ្រើសរើស ពុទ្ធការកធម៌ទាំងឡាយ ខាងនោះ និងខាងនេះ ដូច្នេះហើយ ឃើញពុទ្ធការកធម៌ មានការបំពេញទានបារមីជាដើមថា កាលអាត្មាអញកំពុងជ្រើសរើសក្នុងកាលនោះ បានឃើញទានបារមី ដែលជាពុទ្ធការកធម៌ទី ១ ទើបបំពេញពុទ្ធការកធម៌ទាំងនោះ រហូតដល់កំណើតជាព្រះវេស្សន្តរ ។ ព្រះពោធិសត្វ កាលអន្ទោលទៅមក សម្រេចអានិសង្សរបស់ព្រះពោធិសត្វទាំងឡាយ ដែលមានអភិនីហារធ្វើហើយ ដែលលោកពណ៌នាថា

នរជនទាំងឡាយ អ្នកបរិបូរណ៍ដោយអង្គនៃគុណទាំងពួងយ៉ាង

១- មិនមានក្នុងទីនេះ មិនមានសម្រាប់ទូរេនិទាន ឯក្នុងអនាគតមាន ។

នេះ ជាអ្នកទៀងដើម្បីនឹងត្រាស់ដឹង កាលនៅត្រាច់ទៅកាន់សំសារវដ្តអស់កាលយូរ សូម្បីរាប់រយកោដិកប្ប ក៏មិនកើតក្នុងអវិចី និងក្នុងលោកន្តរនរក មិនកើតជានិជ្ឈាមតណ្ហិកប្រេត ខុប្បិបាសិកប្រេត កាលកញ្ចិកប្រេត សូម្បីនឹងកើតក្នុងទុគ្គតិ ក៏មិនកើតជាសត្វតូចៗ កាលកើតក្នុងមនុស្ស រមែងមិនកើតជាមនុស្សខ្វាក់អំពីកំណើត មិនកើតជាមនុស្សថ្លង់ មិនកើតជាមនុស្សគ មិនកើតជាជនពិការ មិនកើតជាស្ត្រី មិនកើតជាឧភតោព្យញ្ជនកៈ មិនកើតជាខ្ទើយ ។ នរជនទាំងឡាយដែលទៀង ដើម្បីត្រាស់ដឹង រមែងមិនជាបុគ្គលដែលទាក់ទងហើយ ( ក្នុងទោសតាមដែលពោលហើយ ) ជាអ្នកផុតហើយចាកអនន្តរិយកម្ម មានគោចរ គឺការចិញ្ចឹមជីវិតបរិសុទ្ធក្នុងទីទាំងពួង មិនសេពមិច្ឆាទិដ្ឋិ មានការឃើញក្នុងការធ្វើថា ជាកម្ម សូម្បីកើតក្នុងស្ថានសួគ៌ ក៏មិនកើតក្នុងអសញ្ញីភព ឈ្មោះថា ហេតុកើតក្នុងសុទ្ធាវាសទាំងឡាយក៏មិនមាន ជាអ្នកបង្អោនទៅក្នុងនេក្ខម្មៈ ជាសប្បុរស មិនជាប់នៅក្នុងភពតូចភពធំ រមែងត្រាច់ទៅ ដើម្បីប្រព្រឹត្តប្រយោជន៍ដល់សត្វលោក រមែងបំពេញបារមីទាំងពួង ដូច្នេះ ។

ម្យ៉ាងទៀត កាលព្រះពោធិសត្វបំពេញបារមីទាំងឡាយ ឈ្មោះថាប្រមាណអត្តភាពដែលបំពេញទានបារមី រាប់មិនបាន គឺក្នុងកាលសោយព្រះ

ជាតិជាអកិត្តិព្រាហ្មណ៍ ក្នុងកាលសោយព្រះជាតិជាសង្ខព្រាហ្មណ៍ ក្នុងកាលសោយព្រះជាតិ ជាព្រះបាទធនញ្ជ័យ ក្នុងកាលសោយព្រះជាតិ ជាព្រះបាទមហាសុទស្សនៈ ក្នុងកាលសោយព្រះជាតិជាមហាគោវិន្ទៈ ក្នុងកាលសោយព្រះជាតិ ជាព្រះបាទនិមិមហារាជ ក្នុងកាលសោយព្រះជាតិជាព្រះចន្ទកុមារ ក្នុងកាលសោយព្រះជាតិជាវិសយ្ហសេដ្ឋី ក្នុងកាលសោយព្រះជាតិជាសសបណ្ឌិត ក្នុងកាលសោយព្រះជាតិ ជាព្រះបាទសិវិរាជ ក្នុងកាលសោយព្រះជាតិ ជាព្រះវេស្សន្តរជាដើម ។

ម្យ៉ាងទៀត ការបំពេញទានរបស់ព្រះពោធិសត្វនោះ ដែលលះបង់អត្តភាព លោកពោលក្នុងសសបណ្ឌិតជាតកយ៉ាងនេះថា

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន
ជារបស់ខ្លួន បុគ្គលអ្នកឲ្យទានស្មើដោយទាន របស់តថាគត
មិនមានឡើយ នេះជាទានបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

មួយទៀត ឈ្មោះថា ប្រមាណអត្តភាពដែលបំពេញសីលបារមីរាប់មិនបាន គឺក្នុងកាលសោយព្រះជាតិជាសីលវនាគរាជ ក្នុងកាលសោយព្រះជាតិជាចម្បេយ្យនាគរាជ ក្នុងកាលសោយព្រះជាតិជាភូរិទត្តនាគរាជ ក្នុងកាលសោយព្រះជាតិជាស្តេចដំរីឆទ្ទន្ត ក្នុងកាលសោយព្រះជាតិជារាជបុត្តរបស់ព្រះបាទជយទិសរាជ ក្នុងកាលសោយព្រះជាតិ ជាអលីនចិត្តកុមារជាដើម ។ ការបំពេញសីលរបស់ព្រះពោធិសត្វនោះ ធ្វើនូវការលះបង់អត្តភាព ដែល

ពោលក្នុងសន្ធបាលជាតកយ៉ាងនេះថា

តថាគតមិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួច នឹងចាក់ដោយលំពែងទាំងឡាយឡើយ នេះជាសីលបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

មួយទៀត ឈ្មោះថា ប្រមាណអត្តភាពដែលលះបង់រាជសម្បត្តិធំបំពេញនេក្ខម្មបារមី មិនអាចរាប់បាន គឺក្នុងកាលដែលសោយព្រះជាតិ ជាសោមនស្សកុមារ ក្នុងកាលសោយព្រះជាតិ ជាហត្ថិបាលកុមារ ក្នុងកាលសោយព្រះជាតិ ជាអយោឃរបណ្ឌិតជាដើម ។ ការបំពេញនេក្ខម្មរបស់ព្រះពោធិសត្វនោះដែលលះបង់រាជសម្បត្តិ ចេញបួសដោយការលះបង់ ដែលលោកពោលក្នុងចូឡសុតសោមជាតកយ៉ាងនេះថា

តថាគតលះបង់រាជសម្បត្តិធំ ដែលនៅក្នុងព្រះហស្ត ដូចលះបង់ដុំទឹកមាត់ កាលតថាគតលះបង់ ក៏មិនមានសេចក្តីស្តាយ នុ៎ះជានេក្ខម្មបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

មួយទៀត ឈ្មោះថា ប្រមាណអត្តភាពដែលបំពេញបញ្ញាបារមីរាប់មិនបាន គឺក្នុងកាលដែលព្រះអង្គសោយព្រះជាតិជាវិធុរបណ្ឌិត ក្នុងកាលដែលសោយព្រះជាតិជាមហាគោវិន្ទបណ្ឌិត ក្នុងកាលសោយព្រះជាតិជាកុទ្ទាលបណ្ឌិត ក្នុងកាលសោយព្រះជាតិជាអរកបណ្ឌិត ក្នុងកាលសោយព្រះជាតិ

ជាពោធិបរិវាជក ក្នុងកាលសោយព្រះជាតិជាមហោសធបណ្ឌិតជាដើម ។ ការបំពេញបញ្ញារបស់ព្រះពោធិសត្វនោះ ដែលបង្ហាញពស់ពិសក្នុងថង់ ក្នុងកាលសោយព្រះជាតិជាសេនកបណ្ឌិត ដែលពោលក្នុងសត្តុភស្តជាតក (សេនកជាតក) សម្តែងនូវពស់ពិសក្នុងថង់ ដែលពោលយ៉ាងនេះថា

តថាគតប្រើបញ្ញាពិចារណា ទើបជួយព្រាហ្មណ៍ឲ្យរួចផុតចាក
ទុក្ខ បញ្ញារបស់តថាគតមិនមាននរណាស្មើ នុ៎ះជាបញ្ញា-
បារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

ឈ្មោះថា ប្រមាណអត្តភាពដែលបំពេញវីរិយបារមីជាដើម ក៏រាប់មិនបានដូចគ្នា ។ ការបំពេញសេចក្តីព្យាយាមរបស់ព្រះពោធិសត្វនោះ ដែលឆ្លងមហាសមុទ្ទ ពោលក្នុងមហាជនកជាតកយ៉ាងនេះថា

មនុស្សទាំងឡាយ មើលមិនឃើញត្រើយ នាំគ្នាស្លាប់នៅក្នុង
កណ្តាលមហាសមុទ្ទ ចិត្តរបស់តថាគត មិនបានប្រែប្រួលជា
ប្រការដទៃ នុ៎ះជាវីរិយបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

ការបំពេញខន្តិបារមីរបស់ព្រះពោធិសត្វ ដែលអត់សង្កត់ក្នុងទុក្ខធំ ដូចមិនមានចិត្ត ដែលពោលក្នុងខន្តិវាទិជាតកយ៉ាងនេះថា

កាលព្រះបាទកាសិរាជ យកពូថៅដ៏មុតកាប់តថាគត ដែល

ដូចជាមនុស្សមិនមានចិត្ត តថាគតក៏មិនខឹងក្រោធ នុ៎ះជាខន្តិបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

ការបំពេញសច្ចបារមីរបស់ព្រះពោធិសត្វ ដែលលះបង់ជីវិតរក្សាសច្ចៈ ដែលពោលក្នុងមហាសុត្តសោមជាតកយ៉ាងនេះថា

តថាគតកាលតាមរក្សានូវសច្ចវាចា លះបង់ជីវិតរបស់តថាគត ឲ្យដោះលែងក្សត្រិយ៍ ១០១ អង្គ នុ៎ះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។

ការបំពេញអធិដ្ឋានបារមីរបស់ព្រះពោធិសត្វ ដែលលះបង់ជីវិតអធិដ្ឋានវត្ត ដែលពោលក្នុងមូគបក្ខជាតក ( តេមិយជាតក ) យ៉ាងនេះថា

មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ យសធំក៏មិនមែនជាទីស្អប់របស់តថាគតដែរ[១] តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាននោះ ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។

ការបំពេញមេត្តាបារមីរបស់ព្រះពោធិសត្វ ដែលមិនបានឃើញសូម្បីតែជីវិតរបស់ខ្លួន ចម្រើនមេត្តា ដែលពោលក្នុងឯករាជជាតកយ៉ាងនេះថា

---

១- ក្នុងអបទានជា ទាំងខ្លួនក៏មិនមែនជាទីស្អប់របស់តថាគតដែរ ។

សត្វណាមួយមិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគតក៏មិនខ្លាចសត្វណាមួយឡើយ កាលណោះ កម្លាំងមេត្តាឧបត្ថម្ភតថាគត ឲ្យតថាគតនៅក្នុងព្រៃដោយសួស្តី ដូច្នេះ[១] ។

ឈ្មោះថា បរមត្ថបារមី ។

ការបំពេញឧបេក្ខាបារមី របស់ព្រះពោធិសត្វដែលមិនលះឧបេក្ខា ក្នុងកាលពួកក្មេងអ្នកស្រុក ដែលញុំាងសេចក្តីទុក្ខ និងសេចក្តីសុខ ឲ្យកើតឡើងដោយការស្តោះទឹកមាត់ជាដើម និងដោយការនាំផ្កាកម្រង គ្រឿងក្រអូបមកឲ្យជាដើម ដែលពោលក្នុងលោមហំសជាតកយ៉ាងនេះថា

តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសពក្នុងព្រៃស្មសាន ពួកក្មេងអ្នកស្រុកចូលមកជិត ( តថាគត ) ហើយសម្តែងនូវប្រការដ៏ប្លែកច្រើនយ៉ាង ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។ សេចក្តីសង្ខេបក្នុងទីនេះមានប្រមាណប៉ុណ្ណេះ ចំណែកសេចក្តីពិស្តារ គប្បីកាន់យកក្នុងចរិយាបិដក ។

ព្រះពោធិសត្វ កាលបំពេញបារមីទាំងឡាយយ៉ាងនេះហើយ តាំងនៅក្នុងអត្តភាពរបស់ព្រះវេស្សន្តរ បានកសាងបុណ្យជាច្រើន ដែលជាហេតុឲ្យផែនដីធំកម្រើកញាប់ញ័រ តាមដែលពោលយ៉ាងនេះថា

ប្រឹថពីមិនមានចេតនាទេ មិនដឹងសុខ និងទុក្ខទេ តែមហាប្រឹថពី

---

១-គាថានេះ មិនប្រទះក្នុងឯករាជចរិយា ឬឯករាជជាតកឡើយ តែប្រទះក្នុងសុវណ្ណសាមចរិយាទៅវិញ ។

នោះ បានកម្រើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះកម្លាំងទាន
របស់តថាគត ដូច្នេះ ។

កាលអស់ព្រះជន្មាយុហើយ ទ្រង់ច្យុតចាកលោកនេះ កើតឡើងក្នុងស្ថានតុសិត ទ្រង់ធំក្រៃលែងជាងទេវតាដទៃក្នុងតុសិតនោះ ដោយឋានៈ ១០ ប្រការ ទ្រង់សោយទិព្វសម្បត្តិអស់ព្រះជន្មាយុ ៥៧ កោដិ ៦ លានឆ្នាំ ដោយការរាប់ឆ្នាំរបស់មនុស្ស ឥឡូវនេះ ៧ ថ្ងៃទៀត នឹងដល់នូវការអស់អាយុ ព្រោះហេតុនោះ កាលកើតបុព្វនិមិត្តទាំង ៥ នេះគឺ

សំពត់ទាំងឡាយសៅហ្មង ១ ទិព្វមាលាស្វិតស្រពោន ១ ញើសហូរចេញអំពីក្លៀក ១ ឆវីវណ្ណក្នុងសរីរៈប្រាសទៅ ១ នឿយណាយក្នុងទិព្វាសនៈ ១ ។

ពួកទេវតាឃើញនិមិត្តទាំងនោះ ក៏នាំគ្នាតក់ស្លុតពោលថា អ្នកដ៏ចម្រើនទាំងឡាយអើយ ស្ថានសួគ៌នឹងស្ងាត់សូន្យ ដូច្នេះ គប្បីជ្រាបថា ព្រះមហាសត្វបំពេញបារមីគ្រប់ហើយ ទើបគិតថា ឥឡូវនេះ ព្រះពោធិសត្វនេះ ទ្រង់នឹងមិនឧប្បត្តិកក្នុងទេវលោកដទៃៗ ទ្រង់បដិសន្ធិក្នុងមនុស្សលោក ហើយដល់នូវភាពជាព្រះពុទ្ធ ពួកមនុស្សនឹងនាំគ្នាធ្វើបុណ្យជាច្រើន ចុតិហើយ ក៏នឹងញុំាងទេវលោកឲ្យពេញ ដូច្នេះ ទើបនាំគ្នាក្រាបទូល ដើម្បីប្រយោជន៍ដល់ភាពជាព្រះពុទ្ធ ដូចដែលត្រាស់យ៉ាងនេះថា

កាលដែលតថាគតនៅជាទេវបុត្ត ឈ្មោះសន្តុសិតៈ ក្នុងពួក
ទេវបុត្តជាន់តុសិត កាលនោះ ទេវតាមួយម៉ឺនលោកធាតុ មក

ប្រជុំគ្នា ធ្វើអញ្ជលីអារាធនាតថាគតថា បពិត្រព្រះអង្គមាន ព្យាយាមធំ កាលនេះគួរដល់ព្រះអង្គហើយ សូមព្រះអង្គទ្រង់ កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្សលោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះអមតៈ ដូច្នេះ ។

ព្រះពោធិសត្វ ពិនិត្យមើលមហាវិលោកនៈ ៥ នេះ គឺកាល ទ្វីប ប្រទេស ត្រកូល និងប្រមាណអាយុព្រះពុទ្ធមាតា សម្រេចព្រះហឫទ័យហើយ ទើបយាងចុះចាកស្ថានតុសិត មកចាប់បដិសន្ធិក្នុងសក្យត្រកូល បានទទួល ការទំនុកបម្រុងដោយសម្បត្តិជាច្រើនក្នុងសក្យត្រកូលនោះ ទ្រង់ដល់នូវភាព ជាកំលោះស្រស់សង្ហាតាមលំដាប់ ។ គប្បីជ្រាបសេចក្តីពិស្តារ ក្នុងរវាងនេះ ដោយអំណាចនៃបទព្រះសូត្រទាំងឡាយ ( អច្ឆរិយព្ភូតធម្មសូត្រ ) ថា ម្នាលអានន្ទ ពោធិសត្វច្យុតចាកពួកទេវតាជាន់តុសិត ចុះមកកាន់ផ្ទៃនៃមាតា តែងមានសតិសម្បជញ្ញៈ ដូច្នេះជាដើម ។ និងគប្បីជ្រាបដោយអំណាចនៃ អដ្ឋកថារបស់បទព្រះសូត្រទាំងនោះចុះ ។

ព្រះពោធិសត្វនោះ សោយសិរីរាជសម្បត្តិដូចទេវលោក ក្នុងប្រាសាទ ទាំង ៣ ដ៏សមគួរដល់រដូវទាំង ៣ ក្នុងសម័យដែលយាងទៅក្រសាល ក្នុងព្រះរាជឧទ្យាន បានទតឃើញទេវទូត ៣ គឺមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់តាមលំដាប់ ទ្រង់តក់ស្លុតព្រះហឫទ័យ ក៏យាងត្រឡប់មកអំពី ឧទ្យាន បានឃើញបព្វជិតក្នុងគ្រាទី ៤ បានញុំាងឆន្ទៈក្នុងបព្វជ្ជា ឲ្យកើត ឡើងថា បព្វជ្ជាប្រពៃហ្ន៎ ហើយយាងទៅកាន់ព្រះរាជឧទ្យាន ញុំាងកាល

វេលា ឲ្យកន្ទួងទៅក្នុងឧទ្យាននោះ ទ្រង់ប្រថាប់គង់ត្រង់ប្រាំងស្រះបោក្ខរណី មង្គល ជាបុគ្គលដែលវិស្សកម្មទេវបុត្តកាឡាខ្លួនជាជាងកោរកាត់ មកប្រដាប់ តាក់តែង ព្រះអង្គទ្រង់សណ្តាប់ដំណឹងថា រាហុលកុមារប្រសូតហើយ ទ្រង់ ជ្រាបដល់សេចក្តីស្នេហាក្នុងបុត្តមានកម្លាំងខ្លាំងក្លា ទើបទ្រង់ព្រះតម្រិះថា អញ នឹងកាត់វាមុនចំណងនេះចម្រើនឡើង ទើបយាងចូលទៅកាន់ព្រះនគរ ក្នុង វេលាល្ងាច បានស្តាប់គាថាព្រះនាងកិសាគោតមី ជីតារបស់ម្ចាស់មាពោលថា

បុរសបែបនេះ ជាបុត្តរបស់មាតាណា មាតានោះ ជាអ្នករលត់ ទុក្ខពិត បុរសបែបនេះ ជាបុត្តរបស់បិតាណា បិតានោះ ជា អ្នករលត់ទុក្ខពិត បុរសបែបនេះ ជាស្វាមីរបស់ភរិយាណា ភរិយានោះ ជាអ្នករលត់ទុក្ខពិត ដូច្នេះ ។

ទ្រង់ព្រះតម្រិះថា ព្រះនាងនេះ ឲ្យយើងស្តាប់និព្វុតបទ ទើបដោះខ្សែក កែវមុក្តាហារ មានតម្លៃប្រមាណមួយសែន អំពីព្រះសូរងប្រទានដល់ព្រះ នាងកិសាគោតមីនោះ ហើយយាងចូលទៅកាន់ទីប្រថាប់របស់ព្រះអង្គ ទ្រង់ ប្រថាប់គង់លើព្រះទែនសិរីសេយ្យាសន៍ ទ្រង់ទតឃើញប្រការដ៏ប្លែក របស់ ស្ត្រីអ្នកបាំទាំងឡាយព្រោះអំណាចនៃការដេកលក់ មានព្រះហឫទ័យនឿយ ណាយ ទ្រង់ដាស់នាយឆន្នៈឲ្យក្រោក់ឡើងហើយ ត្រាស់ឲ្យនាំសេះកណ្ឋកៈ មក ទ្រង់ឡើងផែលសេះកណ្ឋកៈ មានឆន្នៈជាសម្លាញ់ មានពួកទេវតាមួយ ម៉ឺនលោកធាតុចោមរោម ហើយយាងចេញសាងមហាអភិនេស្រ្កមណ៍ដោយ រាត្រីដែលនៅសេសសល់ទុ៎ះឯង ទ្រង់ឆ្លងមហាអាណាចក្រទៅ ៣ ដែន ទ្រង់

បួសជិតប្រាំងនៃស្ទឹងអនោមា ហើយយាងទៅតាមលំដាប់ ដល់ក្រុងរាជគ្រឹះ ទ្រង់ត្រាច់ទៅដើម្បីដុំបាយក្នុងក្រុងរាជគ្រឹះនោះ ប្រថាប់គង់ត្រង់ញកភ្នំបណ្ឌវៈ បានទទួលអារាធនាអំពីព្រះរាជាមគធៈ ឲ្យគ្រងរាជសម្បត្តិ ទ្រង់បដិសេធរាជសម្បត្តិនោះ ទ្រង់ឲ្យបដិញ្ញាដល់ព្រះបាទមគធៈថា នឹងត្រឡប់មកក្នុងដែនរបស់ព្រះអង្គ កាលណាសម្រេចសព្វញ្ញុតញ្ញាណហើយ ។ ហើយយាងចូលទៅរកអាឡារតាបស និងឧទកតាបស នៅមិនទាន់ពេញព្រះហឫទ័យដោយគុណវិសេសដែលបានសម្រេចក្នុងសម្នាក់របស់តាបសទាំងនោះ ទើបទ្រង់តាំងមហាបធាន អស់ ៦ វស្សា កាលដល់ថ្ងៃពេញបូណ៌ ខែវិសាខ វេលាព្រឹក ទ្រង់សោយបាយាសដែលនាងសុជាតា អ្នកស្រុកសេនានិគមថ្វាយ ហើយយាងទៅបណ្តែតថាសមាសក្នុងស្ទឹងនេរញ្ជរា ទ្រង់ឲ្យវេលាថ្ងៃកន្លងទៅដោយសមាបត្តិផ្សេងៗ ជិតព្រៃមហាវ័ន ទៀបឆ្នេរនៃស្ទឹងនេរញ្ជរាក្នុងវេលាល្ងាចទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលសោត្ថិយព្រាហ្មណ៍ថ្វាយ ជាអ្នកមានគុណដែលកាឡនាគរាជសរសើរហើយ ទ្រង់ឡើងកាន់ពោធិមណ្ឌលទ្រង់ក្រាលស្មៅទាំងឡាយ ហើយទ្រង់ធ្វើបដិញ្ញាថា អាត្មាអញនឹងមិនទម្លាយភ្នែននេះ រហូតចិត្តរបស់អាត្មាអញផុតចាកអាសវៈទាំងឡាយ ព្រោះសេចក្តីមិនប្រកាន់មាំ ហើយប្រថាប់គង់លើពោធិបល្ល័ង្ក មានព្រះភក្ត្របែរទៅកាន់ទិសខាងកើត កាលព្រះអាទិត្យនៅមិនទាន់អស្តង្គតនុ៎ះឯង ក៏ទ្រង់កម្ចាត់មារនិងសេនានៃមារហើយ ក្នុងបឋមយាមទ្រង់សម្រេចនូវបុព្វេនិវាសញ្ញាណ ក្នុងមជ្ឈិមយាមទ្រង់សម្រេចនូវចុតូបបាតញ្ញាណ ក្នុងទីបំផុតនៃបច្ឆិមយាម ទ្រង់

ចាក់ធ្លុះសព្វញ្ញុតញ្ញាណដែលប្រដាប់ដោយគុណ របស់ព្រះពុទ្ធទាំងពួង មានទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើមនុ៎ះឯង ឈ្មោះថា ទ្រង់ដល់នូវសាគរ គឺន័យរបស់ព្រះអភិធម្មនេះ គប្បីជ្រាបអធិគមនិទាន របស់ព្រះអភិធម្មនោះ ដោយប្រការដូច្នេះ ។

**អធិគមនិទាន ចប់**

# ទេសនានិទាន

ព្រះមានព្រះភាគ ទ្រង់ដល់នូវព្រះអភិធម្ម ដោយប្រការដូច្នេះហើយ ទ្រង់ប្រថាប់គង់ដោយភ្នែនតែមួយ កន្លងទៅ ១ សប្តាហ៍ ទ្រង់ទតមើលពោធិព្រឹក្ស មិនប៉ប្រិចព្រះនេត្រកន្លងទៅ ១ សប្តាហ៍ ទ្រង់ចង្ក្រមកន្លងទៅ ១ សប្តាហ៍ ក្នុងសប្តាហ៍ទី ៤ ទ្រង់ពិចារណាព្រះអភិធម្មដែលទ្រង់សម្រេចដោយព្រះសយម្ភូញាណ ហើយទ្រង់ឲ្យសប្តាហ៍ទាំង ៣ សូម្បីដទៃទៀតកន្លងទៅ ត្រង់គល់អជបាលនិគ្រោធ គល់មុចលិន្ទ និងទៀបគល់រាជាយតនៈ ក្នុងសប្តាហ៍ទី ៨ ទ្រង់ត្រឡប់ទៅប្រថាប់គង់ទៀបគល់អជបាលនិគ្រោធ ទ្រង់ដល់នូវភាពជាអ្នកខ្វល់ខ្វាយតិច ព្រោះទ្រង់ពិចារណាដល់ធម៌ ជាសភាវៈដ៏ជ្រាលជ្រៅ កាលទ្រង់សម្តែងធម៌ដែលសហម្បតីព្រហ្ម ដែលមានមហាព្រហ្មមួយម៉ឺន ជាបរិវារមកទូលអារាធនាហើយ ទើបទ្រង់ត្រួតមើលលោកដោយពុទ្ធចក្ខុ ទ្រង់ទទួលការអារាធនារបស់មហាព្រហ្មហើយ ទ្រង់ប្រមើលមើលថា តថាគតគប្បីសម្តែងធម៌ដល់នរណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបសធ្វើកាលកិរិយាហើយ ទើបទ្រង់រឭកដល់ភិក្ខុបញ្ចវគ្គិយដែលមានឧបការៈច្រើន ស្តេចក្រោកចាកអាសនៈ យាងទៅកាន់ដែនកាសី ក្នុងរវាងផ្លូវ ទ្រង់សន្ទនាជាមួយនឹងឧបកាជីវក ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ទ្រង់យាងទៅដល់លំនៅនៃបញ្ចវគ្គិយភិក្ខុ ត្រង់ព្រៃឥសិបតនមិគទាយវ័ន ទ្រង់ធ្វើបញ្ចវគ្គិយដែលហៅព្រះអង្គ ដោយពាក្យដែលមិនសមគួរ ឲ្យជឿស្តាប់ហើយ ទ្រង់ប្រកាសព្រះធម្មចក្កប្រោសបញ្ចវគ្គិយ មានព្រះអញ្ញាកោណ្ឌញ្ញត្ថេរជាប្រធាន និងពួកព្រហ្ម ១៨ កោដិ បានផឹកអមតរសហើយ ។

គប្បីជ្រាបទេសនានិទាន រហូតដល់ការប្រកាសព្រះធម្មចក្ក ដូចពណ៌នាមក ដូច្នេះ ។ សេចក្តីសង្ខេបមានប្រមាណប៉ុណ្ណេះ ចំណែកសេចក្តីពិស្តារគប្បីជ្រាបដោយអំណាចនៃព្រះសូត្រទាំងឡាយ មានអរិយបរិយេសនសូត្រ និងបព្វជ្ជាសូត្រជាដើម ព្រមទាំងអដ្ឋកថាទាំងឡាយ ។

## ទេសនានិទាន ចប់

និទានរបស់ព្រះអភិធម្ម ដែលសម្បូរដោយអធិគមនិទាន និងទេសនា-និទានយ៉ាងនេះ ក៏នៅមាននិទាន ៣ ទៀត គឺទូរេនិទាន ១ អវិទូរេនិទាន ១ សន្តិកេនិទាន ១ ។

បណ្តានិទានទាំង ៣ នោះ គប្បីជ្រាបទូរេនិទាន ចាប់តាំងអំពីបាទមូលរបស់ព្រះពុទ្ធ ទ្រង់ព្រះនាមទីបង្ករ រហូតដល់តុសិតបុរី គប្បីជ្រាបអវិទូ-រេនិទាន ចាប់តាំងអំពីតុសិតបុរី រហូតដល់ពោធិមណ្ឌល ពាក្យថា សម័យមួយ ព្រះមានព្រះភាគ ប្រថាប់នៅលើបណ្ឌុកម្ពលសិលាសនៈ ទៀបគល់បារិច្ឆត្តកៈ ក្នុងពួកទេវតាស្ថានតាវត្តិង្សនោះឯង បានត្រាស់អភិធម្មដល់ទេវតាទាំងឡាយជាន់តាវត្តិង្សនេះ ឈ្មោះថា សន្តិកេនិទានរបស់ព្រះអភិធម្មនោះ ។ និទានកថាមានប្រមាណប៉ុណ្ណេះ ។

## និទានកថា ចប់

# អដ្ឋកថា

# ចិត្តុប្បាទកណ្ឌ

## អធិប្បាយ បទតិកមាតិកា

[ ១ ] ឥឡូវនេះ ដល់ឱកាសនៃការពោលអភិធម្មកថា តាមដែលខ្ញុំឲ្យប្តេជ្ញាយ៉ាងនេះថា

កាលខ្ញុំពោលអភិធម្មកថានេះ ដោយអាការៈយ៉ាងនេះ សូម
សាធុជនទាំងឡាយ កុំមានចិត្តរាយមាយ ចូរតាំងចិត្តស្តាប់
ព្រោះកថាបែបនេះ រកបានដោយកម្រក្រៃលែង ដូច្នេះ ។

ក្នុងអភិធម្មកថានោះ បករណ៍ ៧ មានធម្មសង្គណិជាដើម ឈ្មោះថា អភិធម្ម សូម្បីក្នុងធម្មសង្គណិក៏ចែកចេញជា ៤ កណ្ឌ មានចិត្តុប្បាទកណ្ឌជាដើម ឯចិត្តុប្បាទកណ្ឌ ក៏នៅចែកចេញជា ២ គឺជាបទមាតិកា និងបទ-ភាជនីយ ។ ក្នុងចិត្តុប្បាទកណ្ឌនោះ មានមាតិកាជាខាងដើម ។ ឯមាតិកានោះ ក៏នៅចែកចេញជា ២ គឺតិកមាតិកា និងទុកមាតិកា ។ ក្នុងមាតិកាទាំង ២ យ៉ាងនោះ តិកមាតិកាជាខាងដើម សូម្បីក្នុងតិកមាតិកា ក៏មានកុសលត្តិកៈជាខាងដើម ក្នុងកុសលត្តិកៈក៏មានបទនេះថា **កុសលា ធម្មា** ជាខាងដើម ព្រោះហេតុនោះ

តាំងអំពីនេះទៅ សូមសាធុជនទាំងឡាយ មានចិត្តស្ងប់ តាំង
ចិត្តស្តាប់អភិធម្មកថាដ៏ជ្រាលជ្រៅនេះ ដែលខ្ញុំនឹងពោល ឲ្យ
ល្អចុះ ។

តិកៈនេះថា **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**

ឈ្មោះថា កុសលត្តិកៈ បានឈ្មោះតាមបទដំបូង ។ តិកៈនេះថា **សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា** ឈ្មោះថា **វេទនាត្តិកៈ** បានឈ្មោះតាមបទទាំងពួង ។ បណ្ឌិតគប្បីជ្រាបឈ្មោះតិកៈ និងទុកមាតិកាទាំងពួង ដោយអំណាចនៃបទខាងដើម ឬបទទាំងអស់ ដោយប្រការដូច្នេះ ។

តិកៈ និងទុកៈទាំងអស់នោះ ចែកជា ១៥ បរិច្ឆេទ គឺតិកៈមាន ១ បរិច្ឆេទ ទុកៈមាន ១៤ បរិច្ឆេទ ។ ទុកៈ ៦ មានពាក្យថា **ហេតូ ធម្មា ន ហេតូ ធម្មា** ជាដើម ហៅថា **ហេតុគោច្ឆកៈ** ( ក្រុមហេតុ ) ព្រោះតាំងទុកដូចកម្រងផ្កាកណិការដោយការទាក់ទងគ្នា ទាំងគម្ពីរភាព និងដោយអត្ថដោយសេចក្តី ។ បន្ទាប់អំពីនោះទៅ ទុកៈ ៧ មានពាក្យថា **សប្បច្ចយា ធម្មា អប្បច្ចយា ធម្មា** ដូច្នេះជាដើម ជាទុកៈដែលមិនទាក់ទងគ្នានិងគ្នា គប្បីជ្រាបថាជាចូឡន្តរទុកៈ ព្រោះលោកជ្រើសរើសយកទុកៈ ដែលដូចគ្នាសុទ្ធ តាំងទុកក្នុងរវាងគោច្ឆកៈ និងព្រោះជាទុកៈដែលតូចជាងទុកៈក្នុងរវាងពួកដទៃ ។ បន្ទាប់អំពីនោះ គប្បីជ្រាបថា ជាអាសវគោច្ឆកៈដោយអំណាចនៃទុកៈ ៦ មានអាសវទុកៈជាដើម ។ គប្បីជ្រាបសញ្ញោជនគោច្ឆកៈដោយអំណាចនៃទុកៈ ៦ មានសញ្ញោជនទុកៈជាដើម ។ម្យ៉ាងទៀត គប្បីជ្រាបគន្ថគោច្ឆកៈ ឱឃគោច្ឆកៈ យោគគោច្ឆកៈ និងនីវរណគោច្ឆកៈដោយអំណាចនៃទុកៈ មានគន្ថៈ ឱឃៈ យោគៈ និងនីវរណទុកៈជាដើម ។ គប្បីជ្រាបបរាមាសគោច្ឆកៈ ដោយអំណាចនៃទុកៈ ៥ មានបរាមាសទុកៈជាដើម ។

ព្រោះហេតុនោះ ទាំងអស់គប្បីជ្រាបថា រួមជា ៧ គោច្ឆកៈ ។ បន្ទាប់អំពីនោះ ទុកៈ ១៤ មានពាក្យជាដើមថា **សារម្មណា ធម្មា** ឈ្មោះថា **មហន្តរទុកៈ** ។ បន្ទាប់អំពីនោះ ទុកៈ ៦ មានឧបាទានទុកៈជាដើម ឈ្មោះថា ឧបាទានគោច្ឆកៈ ។ បន្ទាប់អំពីនោះ ទុកៈ ៨ មានកិលេសទុកៈជាដើម ឈ្មោះថា **កិលេសគោច្ឆកៈ** ។ បន្ទាប់អំពីនោះ ទុកៈ ១៨ មាន **ទស្សនេន បហាតព្វហេតុកា** ជាដើម ឈ្មោះថា **បិដ្ឋិទុកៈ** ព្រោះលោកតាំងទុកក្នុងទីបំផុតនៃអភិធម្មមាតិកា ។ ចំណែកទុកៈ ៤២ មានពាក្យថា **វិជ្ជាភាគិនោ ធម្មា អវិជ្ជាភាគិនោ ធម្មា** ជាដើម ឈ្មោះថា **សុត្តន្តិកទុកៈ** ។ តិកៈ និងទុកៈទាំងអស់នេះ គប្បីជ្រាបថា លោកបានកំណត់ ១៥ បរិច្ឆេទ ដូចពណ៌នាមក ដូច្នេះ ។

តិកៈ និងទុកៈទាំងនេះ ដែលកំណត់យ៉ាងនេះហើយ នៅចែកជា ២ កោដ្ឋាសៈទៀត គឺ **សប្បទេស** ( សម្តែងមិនអស់ ) និង **និប្បទេស** ( សម្តែងដោយមិនសេសសល់ ) ។ ពិតហើយ បណ្តាចំណែកទាំង ២ នោះ តិកៈ ៩ និងទុកៈ ៧១ ឈ្មោះថា **សប្បទេស** ព្រោះកំណត់រូបធម៌ និងអរូបធម៌មិនទាន់អស់ ។ តិកៈ ១៣ និងទុកៈ ៧១ ដ៏សេសឈ្មោះថា **និប្បទេស** ។ បណ្តាតិកៈ និងទុកៈទាំងនោះ ពោលក្នុងតិកៈទាំងឡាយមុន តិកៈ ៩ នេះ គឺវេទនាត្តិកៈ វិតក្កត្តិកៈ បីតិត្តិកៈ ឧប្បន្នត្តិកៈ អតីតត្តិកៈ និងអារម្មណត្តិកៈ ៤ ទៀត ឈ្មោះថា **សប្បទេស** ។ ក្នុងទុកៈទាំងឡាយ ទុកៈទាំងនេះ គឺទុកៈបីៗ ក្នុងទីបំផុតនៃ ៩ គោច្ឆកៈ មាន

ហេតុគោច្ឆកៈជាដើម ឧបាទានគោច្ឆកៈជាទីបំផុត ទុកៈ ៤ ក្នុងទីបំផុតនៃកិលេសគោច្ឆកៈ មហន្តរទុកៈ ២ គឺចិត្តសម្បយុត្តធម៌ ចិត្តវិប្បយុត្តធម៌ ចិត្តសំសដ្ឋធម៌ ចិត្តវិសំសដ្ឋធម៌ និងទុកៈ ៣៨ ដ៏សេស ក្នុងសុត្តន្តិកទុកៈ វៀរទុកៈ ៤ នេះ គឺអធិវចនទុកៈ និរុត្តិទុកៈ បញ្ញត្តិទុកៈ និងនាមរូបទុកៈ ឈ្មោះថា **សប្បទេស**[១] រួមជា ៧១ បណ្ឌិតគប្បីជ្រាបតិកៈ និងទុកៈដែលសល់អំពីពោលហើយទាំងអស់ ថាជា **និប្បទេស** ដូច្នេះ ។

---

១- សប្បទេស មានទុកៈ ៧១ គឺសុត្តន្តិកទុកៈ ៣៨ ទុកៈ កិលេសគោច្ឆកៈ ៤ មហន្តរទុកៈ ២ ( ទុកៈបីៗ ក្នុងទីបំផុតនៃគោច្ឆកៈ ៩ ) ស្មើនឹង ២៧ រួមជា ៧១ ទុកៈ ។

# កុសលត្តិកៈទី ១

ឥឡូវនេះ ជាកិច្ចពណ៌នាបទ តាមបទមាតិកា មានពាក្យថា **កុសលា ធម្មា** ជាដើម ។ **កុសល** សព្ទ ប្រើក្នុងអត្ថថា **មិនមានរោគ មិនមានទោស ឈ្លាស និងមានសុខជាវិបាក** ។ ពិតហើយ **កុសល** សព្ទនេះ ប្រើក្នុងអត្ថថា **មិនមានរោគ** ដូចក្នុងប្រយោគជាដើមថា **កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ** ព្រះអង្គ មានសេចក្ដីសុខស្រួលទេឬ ព្រះអង្គមិនមានជំងឺតម្កាត់ទេឬ ដូច្នេះ ។

ប្រើក្នុងអត្ថថា **មិនមានទោស** ដូចក្នុងប្រយោគជាដើមថា **កតមោ បន ភន្តេ កាយសមាចារោ កុសលោ យោ ខោ មហារាជ កាយសមាចារោ អនវជ្ជោ** បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារជាកុសល តើដូចម្ដេច ។ បពិត្រមហារាជ កាយសមាចារ មិនមានទោស ដូច្នេះ និងដូចក្នុងប្រយោគជាដើមថា **បុន ចបរំ ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ កុសលេសុ ធម្មេសុ** បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ ក្នុងកុសលធម៌ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ដូច្នេះ ។

ប្រើក្នុងអត្ថថា **ឈ្លាស** ក្នុងប្រយោគជាដើមថា **កុសលោ ត្វំ រថស្ស អង្គបច្ចង្គានំ** ទ្រង់ជាបុគ្គលឈ្លាស ក្នុងអវយវៈតូចធំទាំងឡាយនៃរថដែរឬ

ទេ ដូច្នេះ និងប្រយោគថា **កុសលា នច្ចគីតស្ស សិក្ខិតា ចាតុរិត្ថិយោ** ស្ត្រីរបាំជាអ្នកឈ្លាសក្នុងការរាំ និងច្រៀងបានសិក្សា ( ក្នុងកិច្ចស្ត្រី ) ដូច្នេះ ។

ប្រើក្នុងអត្ថថា **មានសុខជាវិបាក** ដូចក្នុងប្រយោគជាដើមថា **កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ** ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ ដូច្នេះ និងប្រយោគថា **កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា** ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាកុសល ដូច្នេះ ។

ក្នុងទីនេះ កុសល សព្ទ គួរប្រើក្នុងអត្ថថា មិនមានរោគខ្លះ មិនមានទោសខ្លះ មានសុខជាវិបាកខ្លះ ។

ធម្ម សព្ទនេះ ប្រើក្នុងអត្ថថា **បរិយត្តិ ហេតុ គុណ** និង **និស្សត្តនិជ្ជីវ** ជាដើម ។ ពិតហើយ ធម្ម សព្ទនេះ ប្រើក្នុងអត្ថថា **បរិយត្តិ** ដូចក្នុងប្រយោគជាដើមថា **ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ** បុគ្គលពួកខ្លះក្នុងលោកនេះ រៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ហេតុ** ដូចក្នុងប្រយោគជាដើមថា **ហេតុម្ហិ ញាណំ ធម្មប្បដិសម្ភិទា** សេចក្ដីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា ដូច្នេះ ។

ប្រើក្នុងអត្ថថា **គុណ** ដូចក្នុងប្រយោគជាដើមថា **នហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ** សភាវៈទាំងពីរ គឺកុសលធម៌ ១ អកុសលធម៌ ១ មិនមែនមានផលស្មើគ្នាទេ អកុសលធម៌នាំសត្វទៅកាន់នរក កុសលធម៌ ញ៉ាំងសត្វឲ្យដល់នូវ

សុគតិ ដូច្នេះ ។

ប្រើក្នុងអត្ថថា **និស្សត្តនិជ្ជីវ** ដូចក្នុងប្រយោគជាដើមថា **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ** ពួកធម៌កើតមានក្នុងសម័យនោះ ដូច្នេះ និងក្នុងប្រយោគជាដើមថា **ធម្មេសុ ធម្មានុបស្សី វិហរតិ** ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ដូច្នេះ ។

ក្នុងទីនេះ ធម្ម សព្ទ ប្រើក្នុងអត្ថថា និស្សត្តនិជ្ជីវៈប៉ុណ្ណោះ ។

គប្បីជ្រាបសេចក្ដីនៃពាក្យថា កុសល ជាដើម ក្នុងទីនេះដូចតទៅ

សភាវៈ ដែលឈ្មោះថា **កុសល** ព្រោះអត្ថថា ញាំងបាបធម៌ ដែលបណ្ឌិតស្អប់ខ្ពើមឲ្យញាប់ញ័រ ឲ្យឃ្លាតឆ្ងាយ ឲ្យកម្រើក គឺឲ្យវិនាស ។ មួយវិញទៀត សភាវធម៌ណា រមែងដាប់ដំពាក់ដោយអាការដែលបណ្ឌិតស្អប់ខ្ពើម សភាវធម៌នោះ ឈ្មោះថា **កុស** ធម៌ដែលឈ្មោះថា **កុសល** ព្រោះអត្ថថា ដកឡើង គឺកាត់ **កុស** ពោល គឺអកុសលទាំងនោះ ។ ញាណ ឈ្មោះថា **កុស** ព្រោះធ្វើអកុសលដែលបណ្ឌិតស្អប់ខ្ពើមឲ្យអស់ ឬឲ្យស្រោលស្តើង ។ ឈ្មោះថា **កុសល** ព្រោះអត្ថថា ដែលញាណឈ្មោះ **កុស** នោះគប្បីកាត់ គឺគប្បីកាន់យក គប្បីឲ្យប្រព្រឹត្តទូទៅ ។ ម្យ៉ាងទៀត ឈ្មោះថា **កុសល** ព្រោះអត្ថថា សូម្បីធម៌ទាំងនេះ រមែងកាត់ចំណែកសង្កិលេស ដែលដល់ចំណែកទាំងពីរ គឺដែលកើតឡើងហើយ និងមិនទាន់កើត ដូចស្បូវភ្លាំងរមែងមុតចំណែកនៃដៃ ដែលស្ទាបចំហៀងទាំងពីរនៃស្មៅ ព្រោះហេតុនោះ ទើបឈ្មោះថា **កុសល** ព្រោះអត្ថថា កាត់ គឺទម្លាយអកុសល ដែលដូចជា

ស្បូវក្លាំង ដូច្នោះ ។

ចំណែកការៈ ដែលឈ្មោះថា **ធម៌** ព្រោះអត្ថថា រមែងទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន ។ មួយទៀត ឈ្មោះថា ធម៌ ព្រោះអត្ថថា ដែលបច្ច័យទាំងឡាយទ្រទ្រង់ ឬថា រមែងទ្រទ្រង់តាមសភាវៈ ។ ធម៌ដែលឈ្មោះថា **អកុសល** ព្រោះអត្ថថា មិនមែនជាកុសល ។ អធិប្បាយថា ធម៌ដែលជាបដិបក្ខចំពោះកុសល ដូចអមិត្តជាបដិបក្ខចំពោះមិត្ត និងដូចអលោភៈជាដើម ជាបដិបក្ខចំពោះលោភៈជាដើម ។ ធម៌ដែលឈ្មោះថា **អព្យាកត** ព្រោះអត្ថថា មិនធ្វើឲ្យជាក់ច្បាស់ អធិប្បាយថា ពោលមិនបានដោយភាពជាកុសល ឬអកុសល ។ បណ្ដាធម៌ទាំងបីនោះ កុសល មានការមិនមានទោស និងមានវិបាកជាសុខជាលក្ខណៈ អកុសល មានទោស និងមានវិបាកជាទុក្ខជាលក្ខណៈ អព្យាកតៈ មានអវិបាកជាលក្ខណៈ ។

សួរថា បទទាំងនេះ គឺ **កុសលា** ឬថា **ធម្មា** ជាដើម មានអត្ថដូចគ្នាតែមួយ ឬមានអត្ថផ្សេងពីគ្នា ។ ឆ្លើយថា ក្នុងសេចក្ដីនេះ មានអត្ថផ្សេងគ្នាបន្តិចបន្តួច បើពាក្យទាំងនេះ មានអត្ថដូចគ្នា ពាក្យថា **កុសលា ធម្មា** នេះ ក៏ដូចគ្នានឹងពាក្យដែលពោលថា **កុសលា កុសលា** បើមានអត្ថផ្សេងគ្នា ក៏នឹងប្រាកដថា ធម៌ពួក ៣ ក៏ជាធម៌ពួក ៦ និងធម៌ពួក ២ ក៏ជាធម៌ពួក ៤ និងពាក្យទាំងឡាយ ក៏មិនទាក់ទងគ្នា ។

ដូចកាលគេពោលថា កុសល រូប មនុស្សមានភ្នែក ក៏មិនមានសេចក្ដីទាក់ទងណាមួយជាមួយនឹងពាក្យទាំងឡាយ ដែលមិនធ្វើបញ្ចាំងអត្ថ ដល់គ្នា

និងគ្នា ដោយអំណាចនៃអត្ថ យ៉ាងណា សូម្បីក្នុងពាក្យថា **កុសលា ធម្មា** ជាដើមនេះ ក៏យ៉ាងនោះដូចគ្នា ពាក្យទាំងឡាយ នឹងមិនសម្ពន្ធគ្នានឹងបទទាំងឡាយ វៀរចាកការសម្ពន្ធក្នុងបទខាងដើម និងខាងចុងហើយ ឈ្មោះថាមិនមានប្រយោជន៍ ។ តទៅក៏នឹងជំទាស់គ្នានឹងសំណួរដែលថា **កតមេ ធម្មា កុសលា** ព្រោះថា មិនជា **ធម្មា កុសលា** ។ តែព្រះមានព្រះភាគត្រាស់ពាក្យនេះថា **កតមេ ធម្មា កុសលា** ។ ន័យម្យ៉ាងទៀត បើពាក្យទាំងឡាយនេះ មានអត្ថដូចគ្នា ភាពដែលធម៌មានកុសលជាដើម ដូចគ្នាតែមួយក៏នឹងប្រាកដ ព្រោះធម៌ទាំង ៣ ដូចគ្នា ។ ពិតហើយ ភាពតែមួយ រមែងប្រាកដដោយភាពដែលធម៌ទាំង ៣ មានបទនៃកុសលជាដើម ជាធម៌ ព្រោះហេតុនោះ សូម្បីកុសលជាដើម ដែលមានអត្ថមិនផ្សេងគ្នាដោយអត្ថ និងធម៌ ៣ យ៉ាង ក៏នឹងប្រាកដដូចគ្នាតែមួយ គឺពាក្យណាជាកុសល ពាក្យនោះជាអកុសល ជាអព្យាកតៈ ។ បើមិនព្រមទទួលធម៌ ៣ យ៉ាង ដូចគ្នាតែមួយ ក៏នឹងត្រូវពោលថា ធម៌ដែលមានសព្ទថា កុសលនៅខាងមុខម្យ៉ាង ធម៌ដែលមានសព្ទថា អកុសលនៅខាងមុខក៏ម្យ៉ាងទៀត ធម៌ដែលមានសព្ទថា អព្យាកតៈនៅខាងមុខក៏ម្យ៉ាងទៀត កាលបើយ៉ាងនេះ ភាវៈក្តី អភាវៈដទៃក្រៅអំពីភាវៈក្តី ក៏ឈ្មោះថា **ធម្ម** ព្រោះហេតុនោះ ធម៌ដែលមានអកុ-សលសព្ទនៅខាងមុខដទៃអំពីធម៌ដែលរាប់ជាភាវៈ ដែលមានកុសលសព្ទនៅខាងមុខ ក៏គប្បីជាអភាវៈទៅ សូម្បីធម៌ដែលមានអព្យាកតៈសព្ទនៅខាងមុខ សូម្បីធម៌មានកុសលសព្ទនៅខាងមុខដទៃអំពីធម៌ទាំងឡាយនោះ ក៏ជាអភាវៈ

ដូចគ្នា ។ សូម្បីកុសលជាដើមពួកដទៃ ក្រៅអំពីធម៌ដែលដល់នូវភាពជាអការៈយ៉ាងនេះ ក៏គប្បីជាអការៈនុ៎ះឯង ។

ពាក្យទាំងអស់នោះ មិនមែនជាហេតុសំខាន់ ព្រោះហេតុអ្វី ព្រោះពាក្យទាំងអស់នោះ សម្រេចដោយវោហារដែលដឹងគ្នា ។ ពិតហើយ វោហារដែលគេដឹង ដែលគេទទួលស្គាល់ក្នុងអត្ថទាំងឡាយដោយប្រការណាៗ ក៏សម្រេចបានដោយប្រការនោះ នុ៎ះឯង ការពោលដល់ធម៌ដែលមានកុសលជាបទខាងមុខ និងការពោលដល់កុសលដែលមានធម៌ជាបទខាងក្រោយក្នុងពាក្យជាដើមថា **កុសលា ធម្មា** ដូច្នេះ បណ្ឌិតទាំងឡាយមិនទទួល ព្រោះមិនមានសេចក្តីផ្សេងគ្នានៃអត្ថរបស់ខ្លួន ដូចមិនទទួលពាក្យយ៉ាងនេះថា **កុសលា កុសលា** និងមិនទទួលព្រោះមានអត្ថដែលមិនចុះបញ្ជាំងដល់គ្នានិងគ្នា ដូចសព្ទថា **កុសលា រូបំ ចក្ខុមា** ( កុសល រូប មនុស្សមានភ្នែក ) ។

ចំណែកកុសលសព្ទ ក្នុងពាក្យថា **កុសលា ធម្មា** នេះ បណ្ឌិតទទួលហើយដោយចុះបញ្ជាំងដល់អត្ថថា មិនមានទោស និងមានសុខជាវិបាក ។ អកុសលសព្ទ បណ្ឌិតទទួលហើយដោយការចុះបញ្ជាំងដល់អត្ថថា ជាទោស និងមានទុក្ខជាវិបាក ។ អព្យាកតសព្ទ បណ្ឌិតទទួលដោយការចុះបញ្ជាំងដល់អត្ថថា មិនមានវិបាក ។

**ធម្ម** សព្ទ បណ្ឌិតទទួលដោយការចុះបញ្ជាំងដល់អត្ថថា មានការទ្រទ្រង់នូវភាវៈរបស់ខ្លួនជាដើម ។ ធម្ម សព្ទនោះ កាលពោលទុកក្នុងរវាងសព្ទទាំងនោះ សព្ទណាមួយ ក៏រមែងសម្តែងដល់ភាពស្មើគ្នា នៃអត្ថ

របស់ខ្លួន ពិតហើយ សព្វទាំងអស់នេះ ឈ្មោះថា ធម៌ ព្រោះមានការទ្រទ្រង់ទុកនូវភារៈរបស់ខ្លួនជាដើម ជាលក្ខណៈ និងសូម្បីកុសលសព្វជាដើម ដែលលោកពោលនៅខាងមុខរបស់ធម្មសព្ទ ក៏រមែងឆ្លុះបញ្ចាំងដល់សេចក្តីប្លែកគ្នានៃអត្ថរបស់ខ្លួននៃធម្មសព្ទនោះ ។ ពិតហើយ ធម៌ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន សព្វទាំងអស់នេះ កាលពោលញែកគ្នា បណ្ឌិតទាំងឡាយក្នុងលោក ក៏ទទួលការឆ្លុះបញ្ចាំង ត្រឹមតែអត្ថរៀងៗ ខ្លួន កាលពោលរួមគ្នា ក៏ទទួលការឆ្លុះបញ្ចាំងអត្ថដែលស្មើគ្នារបស់ខ្លួន និងអត្ថដែលផ្សេងគ្នារបស់ខ្លួន ព្រោះហេតុនោះ ពាក្យណាដែលលោកកំណត់ដល់អត្ថដែលដូចគ្នា និងផ្សេងគ្នា ក្នុងពាក្យថា **ធម៌** នេះ ហើយពោលធ្វើឲ្យជាបទដែលគួរតិះដៀល ពាក្យទាំងអស់នោះ ទើបមិនមែនជាហេតុសំខាន់ ។ កិច្ចពណ៌នាតាមបទកុសលត្តិកៈ ត្រឹមប៉ុណ្ណេះសិន ។ សូម្បីតិកៈ និងទុកៈដ៏សេស ក៏គប្បីជ្រាបដោយន័យនេះឯង ។ ខាងមុខអំពីនេះទៅ ខ្ញុំនឹងពោលដល់ពាក្យដែលផ្សេងគ្នាប៉ុណ្ណោះ ។

# វេទនាតិកៈទី ២

ខាងដើមនេះ **សុខ** សព្ទ ក្នុងពាក្យថា **សុខាយ វេទនាយ** ជាដើម ចុះក្នុងអត្ថច្រើនយ៉ាង គឺ**សុខវេទនា សុខមូល សុខារម្មណ៍ សុខហេតុ សុខបច្ចយដ្ឋាន អព្យាបជ្ឈ** និង **និព្វាន** ជាដើម ។

មែនពិត **សុខ** សព្ទ នេះ ប្រើក្នុងអត្ថថា សុខវេទនា ដូចក្នុងប្រយោគជាដើមថា **សុខស្ស ច បហានា** ព្រោះលះបង់នូវសុខ ដូច្នេះ ។

ប្រើក្នុងអត្ថថា **សុខមូល** ដូចក្នុងប្រយោគជាដើមថា **សុខោ ពុទ្ធានំ ឧប្បាទោ** ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ដូច្នេះ ។ និងដូចក្នុងប្រយោគជាដើម **សុខា វិរាគតា លោកេ** ការប្រាសចាកតម្រេកជាសុខក្នុងលោក ដូច្នេះ ។

ប្រើក្នុងអត្ថថា **សុខារម្មណ៍** ដូចក្នុងប្រយោគជាដើមថា **យស្មា ច ខោ មហាលិ រូបំ សុខំ សុខានុបតិតំ សុខាវក្កន្តំ** ម្នាលមហាលិ តែរូបនេះ ជាសុខ មានសុខជាប់តាម មានសុខគ្របសង្កត់ ដូច្នេះ ។

ប្រើក្នុងអត្ថថា **សុខហេតុ** ដូចក្នុងប្រយោគជាដើមថា **សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានិ** ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុណ្យនេះ ជាឈ្មោះនៃសេចក្តីសុខ ដូច្នេះ ។

ប្រើក្នុងអត្ថថា **សុខបច្ចយដ្ឋាន** ដូចក្នុងប្រយោគជាដើមថា **យាវញ្ចិទំ ភិក្ខវេ ន សុករំ អក្ខានេន បាបុណិតុំ យាវ សុខា សគ្គា** ម្នាលភិក្ខុទាំងឡាយ តែដំណើរដែលតថាគតពោលទៅ ក៏មិនងាយនឹងដល់កម្រិតស្ថានសួគ៌ដែលមានសេចក្តីសុខបានឡើយ ដូច្នេះ ។ និងប្រយោគជាដើមថា

**ន តេ សុខំ បជានន្តិ យេ ន បស្សន្តិ នន្ទនំ** ពួកជនណាមិនបានឃើញនន្ទនវនឧទ្យាន ពួកជននោះ ឈ្មោះថា មិនស្គាល់ច្បាស់នូវសេចក្តីសុខទេ ដូច្នេះ ។

ប្រើក្នុងអត្ថថា **អព្យាបជ្ឈ** ដូចប្រយោគជាដើមថា **ទិដ្ឋធម្មសុខវិហារា ឯតេ ធម្មា** ធម៌ទាំងឡាយនេះ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ដូច្នេះ ។

ប្រើក្នុងអត្ថថា **និព្វាន** ដូចក្នុងប្រយោគជាដើមថា **និព្វានំ បរមំ សុខំ** ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ដូច្នេះ ។

ប៉ុន្តែក្នុងទីនេះ **សុខ** សព្ទនេះ ប្រើក្នុងអត្ថថា សុខវេទនាប៉ុណ្ណោះ ។

**វេទនា** សព្ទ ប្រើក្នុងអត្ថថា សោយអារម្មណ៍ប៉ុណ្ណោះ ដូចក្នុងប្រយោគជាដើមថា **វិទិតា វេទនា ឧប្បជ្ជន្តិ** តថាគត មានវេទនាកើតប្រាកដ ដូច្នេះ ។

**ទុក្ខ** សព្ទ ប្រើក្នុងអត្ថច្រើនយ៉ាង គឺ**ទុក្ខវេទនា ទុក្ខវត្ថុ ទុក្ខារម្មណ៍ ទុក្ខប្បច្ច័យ ទុក្ខប្បច្ចយដ្ឋាន**ជាដើម ។

ពិតហើយ **ទុក្ខ** សព្ទនេះ ប្រើក្នុងអត្ថថា **ទុក្ខវេទនា** ដូចក្នុងប្រយោគជាដើមថា **ទុក្ខស្ស ច បហានា** លះបង់ទុក្ខផង ដូច្នេះ ។

ប្រើក្នុងអត្ថថា **ទុក្ខវត្ថុ** ដូចក្នុងប្រយោគជាដើមថា **ជាតិបិ ទុក្ខា** កំណើត ( ទាំង ៤ មានជលាពុជជាដើម ) ជាកងទុក្ខ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ទុក្ខារម្មណ៍** ដូចក្នុងប្រយោគជាដើមថា **យស្មា ច ខោ មហាលិ រូបំ ទុក្ខំ ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ** ម្នាលមហាលិ តែរូបនេះ

ជាទុក្ខ មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ទុក្ខប្បច្ច័យ** ដូចក្នុងប្រយោគជាដើមថា **ទុក្ខោ ចាបស្ស ឧច្ចយោ** ការសន្សំនូវបាប រមែងនាំមកនូវសេចក្តីទុក្ខ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ទុក្ខប្បច្ចយដ្ឋាន** ដូចក្នុងប្រយោគជាដើមថា **យាវញ្ចិទំ ភិក្ខវេ ន សុករំ អក្ខានេន ចាបុណិតុំ យាវ ទុក្ខា និរយា** ម្នាលភិក្ខុទាំងឡាយ តែដំណើរដែលតថាគតពោលទៅ មិនងាយនឹងដល់កម្រិតនរកដែលមានទុក្ខបានឡើយ ដូច្នេះ ។ ប៉ុន្តែក្នុងទីនេះ **ទុក្ខ** សព្ទនេះ គប្បីជ្រាបថា ជាទុក្ខវេទនាប៉ុណ្ណោះ ។

គប្បីជ្រាបវចនត្ថៈ ( សេចក្តីនៃពាក្យ ) ក្នុងទីនេះ ។ ឈ្មោះថា **សុខ** ព្រោះធ្វើអ្នកសោយឲ្យសប្បាយ ។ ឈ្មោះថា **ទុក្ខ** ព្រោះធ្វើអ្នកសោយឲ្យលំបាក ។ ឈ្មោះថា **អទុក្ខមសុខ** ព្រោះអត្ថថា មិនមែនទុក្ខ និងមិនមែនសុខ ។ **ម** អក្ខរៈ លោកពោលដោយអំណាចនៃការភ្ជាប់បទ ។

ធម៌ទាំងអស់មានសុខជាដើម ឈ្មោះថា **វេទនា** ព្រោះអត្ថថា រមែងដឹង គឺសោយរសនៃអារម្មណ៍ ។ បណ្តាវេទនាទាំងនោះ សុខវេទនា មានការសោយអារម្មណ៍ដែលគួរប្រាថ្នាជាលក្ខណៈ ទុក្ខវេទនា មានការសោយអារម្មណ៍ ដែលមិនគួរប្រាថ្នាជាលក្ខណៈ អទុក្ខមសុខវេទនា មានការសោយអារម្មណ៍ខុសប្លែកអំពីវេទនាទាំងពីរជាលក្ខណៈ ។

**សម្បយុត្ត** សព្ទ ក្នុងវេទនាតិកៈនេះ គប្បីជ្រាបដូច្នេះ ឈ្មោះថា **សម្បយុត្ត** ព្រោះអត្ថថា ប្រកបដោយប្រការទាំងឡាយ ដោយប្រពៃ ។

សួរថា ដោយប្រការទាំងឡាយដូចម្ដេច ឆ្លើយថា ដោយប្រការទាំងឡាយមានការកើតឡើងព្រមគ្នាជាដើម ។ ពិតហើយ លោកពោលអត្ថនៃសម្ប-យោគដោយអំណាចនៃធម៌ទាំងឡាយ មានការកើតព្រមគ្នាជាដើមយ៉ាងនេះថា ក្រែងពួកធម៌ទីមួយប្រព្រឹត្តទៅមួយអន្លើ កើតមួយអន្លើ ប្រឡំព្រមកើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាដោយពួកធម៌ទីមួយឬ ។ ព្រោះបដិសេធបញ្ហានេះថា ពួកធម៌ទីមួយប្រកបដោយពួកធម៌ទីមួយមានឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ ឈ្មោះថា **សម្បយុត្ត** ព្រោះអត្ថថា ប្រកបហើយដោយប្រការទាំងឡាយ ដោយប្រពៃមានការកើតព្រមគ្នាជាដើមទាំងនេះ ។

# វិបាកត្តិកៈទី ៣

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃវិបាកធម៌ ដូចតទៅនេះ

ឈ្មោះថា **វិបាក** ព្រោះអត្ថថា ជាផលរបស់កុសល និងអកុសលកម្ម ដែលវិសេសជាងគ្នានិងគ្នា ។ ពាក្យថា **វិបាក** នេះ ជាឈ្មោះរបស់អរូបធម៌ទាំងឡាយដែលដល់ភាវៈឲ្យផលហើយ ។ បទថា **វិបាកធម្មធម្មា** បានដល់ ធម៌ទាំងឡាយរបស់វិបាកធម៌ទាំងឡាយ គឺធម៌ទាំងឡាយដែលញុំាងវិបាកឲ្យកើតឡើង អធិប្បាយថា ដូចសត្វទាំងឡាយ មានការកើត និងការចាស់ជាប្រក្រតី លោកហៅថា មានការកើតជាធម្មតា មានការចាស់ជាធម្មតា យ៉ាងណា ធម៌ទាំងឡាយ មានវិបាកជាសភាវៈ មានវិបាកជាប្រក្រតី ព្រោះធម៌ទាំងនេះ ញុំាងវិបាកឲ្យកើតឡើងក៏យ៉ាងនោះ ។ បទទី ៣ ពោលដោយការបដិសេធសភាវៈទាំងពីរ ។

## ឧបាទិន្នុបាទានិយត្តិកៈទី ៤

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃឧបាទិន្នុបាទានិយធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **ឧបាទិន្ន** ព្រោះកម្មប្រកបដោយតណ្ហាជាដើមកាន់យកហើយ ដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ គឺកាន់យកដោយភាពជាផល ។ ដែលឈ្មោះថា **ឧបាទានិយ** ព្រោះជាប្រយោជន៍ដល់ឧបាទានទាំងឡាយ ដោយចូលដល់ភាពជាអារម្មណ៍ ហើយសម្ពន្ធនឹងឧបាទាន ។ ពាក្យថា **ឧបាទានិយ** នេះ ជាឈ្មោះនៃធម៌ដែលជាអារម្មណប្បច្ច័យដល់ឧបាទាន ។ ឈ្មោះថា **ឧបាទិន្នុបាទានិយ** ព្រោះអត្ថថា ទាំងជាឧបាទិន្នៈ ទាំងជាឧបាទានិយៈ ។ ពាក្យថា **ឧបាទិន្នុបាទានិយ** ព្រោះអត្ថថា ជាឧបាទិន្នៈផង ជាឧបាទានិយៈផង ។ ពាក្យថា **ឧបាទិន្នុបាទានិយ** នេះ ជាឈ្មោះរបស់រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលកើតឡើងដោយកម្មដែលមានអាសវៈ ។ គប្បីជ្រាបអត្ថដែលប្រព្រឹត្តទៅ ខាងបដិសេធក្នុង ២ បទដ៏សេស ដោយប្រការដូច្នេះ ។

# សង្កិលិដ្ឋសង្កិលេសិកត្តិកៈទី ៥

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃសង្កិលិដ្ឋសង្កិលេសិកធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **សង្កិលេស** ព្រោះអត្ថថា ធ្វើសត្វឲ្យសៅហ្មង អធិប្បាយថា បៀតបៀន គឺឲ្យសត្វក្តៅក្រហាយ ។ ដែលឈ្មោះថា **សង្កិលិដ្ឋ** ព្រោះប្រកបព្រមហើយដោយសង្កិលេស ។ ឈ្មោះថា **សង្កិលេសិក** ព្រោះអត្ថថា គួរដល់សង្កិលេស ដោយធ្វើខ្លួនឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ឬថាប្រកបក្នុងសង្កិលេស ដោយការមិនឈានកន្លងភាពជាអារម្មណ៍របស់សង្កិ-លេសនោះ ។ ពាក្យថា **សង្កិលេសិក** នេះ ជាឈ្មោះរបស់ធម៌ទាំងឡាយដែលជាអារម្មណប្បច្ច័យដល់សង្កិលេស ។ ឈ្មោះថា **សង្កិលិដ្ឋសង្កិ-លេសិក** ព្រោះអត្ថថា ធម៌ទាំងនោះជាសង្កិលិដ្ឋៈផង ជាសង្កិលេសិកៈផង ។ គប្បីជ្រាបបទពីរដ៏សេសដោយន័យដែលពោលក្នុងតិកៈមុខនុ៎ះឯង ។

# វិតក្កត្តិកៈទី ៦

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃវិតក្កធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **សវិតក្ក** ព្រោះប្រព្រឹត្តទៅមួយអន្លើដោយវិតក្កដែលប្រព្រឹត្តទៅដោយអំណាចនៃការប្រកប ។ ធម៌ដែលឈ្មោះថា **សវិចារ** ព្រោះប្រព្រឹត្តទៅមួយអន្លើដោយវិចារ ធម៌ដែលឈ្មោះថា **សវិតក្កសវិចារ** ព្រោះធម៌ទាំងនោះ មានវិតក្ក និងមានវិចារ ។ ធម៌ដែលវៀរចាកវិតក្ក និងវិចារទាំងពីរ ឈ្មោះថា **អវិតក្កអវិចារ** ធម៌ដែលឈ្មោះថា **វិចារមត្ត** ព្រោះអត្ថថា បណ្តាវិតក្ក និងវិចារ ធម៌ដែលមានត្រឹមតែវិចារប៉ុណ្ណោះជាប្រមាណនៃវិតក្ក និងវិចារទាំងនោះ អធិប្បាយថា ធម៌នោះក្រៅអំពីវិចារហើយ រមែងមិនប្រកបជាមួយនឹងវិតក្ក ។ ធម៌ទាំងនោះ មិនមានវិតក្កផង មានត្រឹមតែវិចារផង ព្រោះហេតុនោះ ទើបឈ្មោះថា **អវិតក្កាវិចារមត្តា** ។

# **បីតិត្តិកៈទី ៧**

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃបីតិធម៌ដូចតទៅ

ធម៌ ដែលឈ្មោះថា **បីតិសហាគត** ព្រោះអត្ថថា ដល់ភាវៈនៃការប្រកប មានការកើតឡើងព្រមគ្នាជាដើមរួមនឹងបីតិ អធិប្បាយថា សម្បយុត្តដោយបីតិ ។ សូម្បីក្នុង ២ បទដ៏សេសក៏ន័យនេះឯង ឯអទុក្ខមសុខវេទនាលោកពោលក្នុងបទទី ៣ នេះថា ឧបេក្ខា ព្រោះថា អទុក្ខមសុខវេទនានោះចូលទៅសម្ទឹងយ៉ាងកណ្ដាលនូវការប្រព្រឹត្តិទៅនៃអាការរបស់សុខ និងទុក្ខ គឺមិនឲ្យប្រព្រឹត្តទៅតាមអាការនៃសុខ និងទុក្ខនោះ ព្រោះការតាំងនៅដោយអាការនៃភាពជាកណ្ដាល ព្រោះហេតុនោះ ទើបឈ្មោះថា ឧបេក្ខា ។ ព្រោះហេតុនោះ ទើបលោកពោលតិកៈនេះ ដោយកាន់យក ២ ពួក ចាកវេទនាតិកៈនុ៎ះឯង ហើយសម្ដែងសុខដែលមិនមានបីតិឲ្យប្លែកអំពីសុខដែលមានបីតិ ។

# ឧស្សូនត្តិកៈទី ៨

គប្បីជ្រាបសេចក្តីក្នុងពួក ៣ នៃទស្សនៈដូចតទៅ

ពាក្យថា **ឧស្សូន** បានដល់ សោតាបត្តិមគ្គ ពិតហើយ សោតាបត្តិមគ្គនោះ ព្រះមានព្រះភាគត្រាស់ថា **ឧស្សូន** ព្រោះឃើញព្រះនិព្វានជាលើកដំបូង ចំណែកគោត្រភូញាណ ឃើញព្រះនិព្វានមុនគេក៏ពិត គោត្រភូញាណសូម្បីឃើញព្រះនិព្វានហើយ ទោះបីយ៉ាងនោះក៏មិនហៅថា ទស្សនៈ ព្រោះមិនមានការលះកិលេស ដែលជាកិច្ចគួរធ្វើ ដូចបុរសដែលមកកាន់សម្នាក់របស់ព្រះរាជា ដោយករណីឯណានីមួយ សូម្បីឃើញព្រះរាជា ទ្រង់ប្រថាប់នៅលើ-កដំរី កំពុងយាងទៅតាមផ្លូវអំពីចម្ងាយ ត្រូវគេសួរថា អ្នកគាល់ព្រះរាជាហើយឬ សូម្បីឃើញហើយក៏ពោលថា ខ្ញុំនៅមិនទាន់បានគាល់ ព្រោះកិច្ចដែលបុគ្គលគប្បីធ្វើ ខ្លួននៅមិនទាន់បានធ្វើ ពិតហើយ គោត្រ-ភូញាណនោះ តាំងនៅក្នុងឋានៈនៃអាវជ្ជៈរបស់មគ្គ ។ ពាក្យថា **ភាវនា** បានដល់ មគ្គទាំង ៣ ដ៏សេស ។ ពិតហើយ មគ្គទាំង ៣ ដ៏សេស រមែងកើតឡើងក្នុងធម៌ដែលបឋមមគ្គឃើញហើយនុ៎ះឯង ដោយអំណាចនៃភាវនា រមែងមិនឃើញអ្វីៗ ដែលបឋមមគ្គមិនធ្លាប់ឃើញ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ហៅថា **ភាវនា** ។ បទទី ៣ ពោលដោយការបដិសេធបទទាំង ២ ខាងដើម ។

# ឧស្សនហេតុកត្តិកៈទី ៩

គប្បីជ្រាបសេចក្តីក្នុងតិកៈ ក្នុងលំដាប់នៃទស្សនត្តិកៈនោះដូចតទៅ

ហេតុដែលសោតាបត្តិមគ្គគប្បីលះ មានដល់ធម៌ទាំងនោះ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **ឧស្សនេនបហាតព្វហេតុកា** ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ ក្នុងបទទី ៣ មិនគប្បីកាន់យកសេចក្តីយ៉ាងនេះថា ហេតុដែលសោតាបត្តិមគ្គ និងមគ្គខាងលើ ៣ មិនគប្បីលះ មានដល់ធម៌ទាំងនោះ គប្បីកាន់យកន័យយ៉ាងនេះថា ហេតុដែលសោតាបត្តិមគ្គ និងដែលមគ្គខាងលើ ៣ គប្បីលះ មានដល់ធម៌ទាំងនោះ ក៏មិនមែន ។ ពិតហើយ កាលកាន់យកសេចក្តីក្រៅអំពីនេះ ក៏គប្បីជាការមិនកាន់យកអហេតុកធម៌ ព្រោះថា ហេតុដែលសោតាបត្តិមគ្គ និងដែលមគ្គខាងលើ ៣ គប្បីលះណាមាន ហេតុនោះឯងនៃអហេតុកធម៌ទាំងនោះ មិនមាន ។ ក្នុងសហេតុកធម៌ទាំងឡាយ រមែងមានការលះធម៌ដែលមានហេតុជាទោស មិនមែនលះហេតុ ។ ពិតហើយ ខ្ញុំពោលដល់ហេតុនោះឯង នៃធម៌ដែលមានទោសទាំងនោះថា ដែលសោតាបត្តិមគ្គ និងមគ្គខាងលើ ៣ គប្បីលះ ... ក៏មិនមែន ដូច្នេះ មិនមែនពោលដល់ធម៌ទាំងនោះ សូម្បីហេតុ និងធម៌ទាំង ២ នេះ ក៏មិនបំណងយក ព្រោះហេតុនោះ គប្បីកាន់យកសេចក្តីនេះថា ហេតុដែលសោតាបត្តិមគ្គ និងមគ្គ ៣ ខាងលើ គប្បីប្រហារមានដល់ធម៌ទាំងនោះ ក៏មិនមែន ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា មិនមានទាំងហេតុដែលសោតាបត្តិមគ្គ និងមគ្គខាងលើគប្បីលះ ។

# អាចយគាមិត្តិកៈទី ១០

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃអាចយគាមិធម៌ដូចតទៅ

ធម៌ណាដែលកម្មកិលេសកសាង ព្រោះហេតុនោះ ទើបធម៌នោះ ឈ្មោះថា **អាចយ** ។ ពាក្យថា **អាចយ** នេះ ជាឈ្មោះរបស់ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងបដិសន្ធិ ចុតិ និងគតិ ។ ធម៌ទាំងឡាយដែលឈ្មោះថា **អាចយគាមី** ព្រោះអត្ថថា ដល់អាចយៈ ព្រោះធម៌នោះជាហេតុដែលញ៉ាំងបដិសន្ធិឲ្យសម្រេច ឬថា ញ៉ាំងបុគ្គលដែលមានកម្មក្កិលេសទាំងឡាយប្រព្រឹត្តទៅឲ្យដល់អាចយៈ តាមដែលពោលហើយនោះឯង ។ ពាក្យថា **អាចយ-គាមិ** នេះ ជាឈ្មោះរបស់កុសល និងអកុសលដែលមានអាសវៈ ។ ព្រះនិព្វានប្រាសចាកការសន្សំកពូន ព្រោះប្រាសចាកការសន្សំកពូន គឺអាចយៈនោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា **អបចយ** ។ ធម៌ពួកណាដល់ព្រះនិព្វាន ដែលជាអបចយធម៌ ព្រោះធ្វើព្រះនិព្វាននោះឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **អបចយគាមី** ។ ពាក្យថា **អបចយគាមី** នេះ ជាឈ្មោះរបស់អរិយមគ្គ ។ម្យ៉ាងទៀត កម្មក្កិលេសទាំងឡាយណា សន្សំកពូនបដិសន្ធិ និងចុតិឲ្យប្រព្រឹត្តទៅ ដូចជាងឥដ្ឋកពូនកំពែង ព្រោះហេតុនោះ ទើបកម្មក្កិលេសទាំងនោះ ឈ្មោះថា **អាចយគាមី** ។ ធម៌ទាំងឡាយណាមិនសន្សំកពូនបដិសន្ធិ និងចុតិនោះឲ្យប្រព្រឹត្តទៅ ដូចបុរសទម្លាយឥដ្ឋដែលកសាងហើយ ព្រោះហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា **អបចយគាមី** ។ បទទី ៣ លោកពោលបដិសេធ ២ បទខាងដើម ។

# សេក្ខត្តិកៈទី ១១

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃសេក្ខធម៌ដូចតទៅ

ឈ្មោះថា **សេក្ខ** ព្រោះកើតហើយក្នុងសិក្ខា ៣ ដូច្នេះខ្លះ ឈ្មោះថា **សេក្ខ** ព្រោះជាធម៌របស់ព្រះសេក្ខៈ ៧ ដូច្នេះខ្លះ ឈ្មោះថា **សេក្ខ** ព្រោះកំពុងសិក្សាដោយនៅមិនទាន់សម្រេចការសិក្សានុ៎ះឯង ។ ឈ្មោះថា **អសេក្ខ** ព្រោះមិនចាំបាច់សិក្សា ព្រោះមិនមានវត្ថុដែលគប្បីសិក្សា ឲ្យក្រៃលែងឡើងតទៅទៀត ។ ម្យ៉ាងទៀត ឈ្មោះថា **អសេក្ខ** ព្រោះព្រះសេក្ខបុគ្គល ដល់នូវសេចក្ដីចម្រើនបំផុតហើយ ។ ពាក្យថា **អសេក្ខ** នេះ ជាឈ្មោះរបស់ធម៌ គឺអរហត្តផល ។ បទទី ៣ លោកពោលដោយបដិសេធ ២ បទខាងដើម ។

# បរិត្តត្តិកៈទី ១២

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃបរិត្តធម៌ដូចតទៅ

វត្ថុមានប្រមាណតិចតួច ហៅថា **បរិត្ត** ព្រោះជារបស់បែកធ្លាយទៅដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា **បរិត្តំ គោមយបិណ្ឌំ** ដុំអាចម៍គោបន្តិច ដូច្នេះ សូម្បីធម៌ទាំងនេះ ក៏ប្រៀបដូចរបស់បន្តិចបន្តួច ព្រោះមានអានុភាពតិច ព្រោះហេតុនោះ ទើបឈ្មោះថា **បរិត្ត** ។ ពាក្យថា **បរិត្ត** នេះជាឈ្មោះរបស់កាមាវចរធម៌ ។ ធម៌ដែលឈ្មោះថា **មហគ្គត** ព្រោះអត្ថថាដល់នូវភាពជាធំ ព្រោះអាចគ្របសង្កត់កិលេស ព្រោះមានផលបរិបូណ៌ និងព្រោះការបន្តដ៏វែងឆ្ងាយ ឬថា បុគ្គលដែលបដិបត្តិហើយដល់នូវភាពជាអ្នកប្រសើរដោយឆន្ទៈ វិរិយៈ ចិត្តៈ បញ្ញាដ៏ធំ ដូច្នេះខ្លះ ។ ធម៌ទាំងឡាយ មានរាគៈជាដើមធ្វើឲ្យមានប្រមាណ ឈ្មោះថា **បមាណធម៌** ។ ធម៌ទាំងឡាយដែលឈ្មោះថា **អប្បមាណ** ព្រោះអត្ថថា បមាណធម៌មិនមានដល់ធម៌ទាំងនេះដោយអារម្មណ៍ ឬដោយសម្បយោគ និងជាធម៌បដិសេធបមាណធម៌ ។

# **បរិត្តារម្មណត្តិកៈទី ១៣**

*គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃបរិត្តារម្មណធម៌ដូចតទៅ*

*ធម៌ដែលឈ្មោះថា* **បរិត្តារម្មណា** *ព្រោះអារម្មណ៍របស់ធម៌ទាំងនេះតូចឆ្មារ សូម្បីក្នុង ២ បទដ៏សេសក៏ន័យនេះឯង ។*

# ហីនត្តិកៈទី ១៤

*គប្បីជ្រាបវិគ្គហៈ ក្នុងពួក ៣ នៃហីនធម៌ ដូចតទៅ*

*បទថា* **ហីនា** *បានដល់ ធម៌ដ៏លាមក គឺអកុសលធម៌ ។ ធម៌ទាំងឡាយ មានក្នុងកណ្ដាលនៃធម៌ដ៏ថោកទាប និងឧត្ដមមាន ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា* **មជ្ឈិមា** *គឺធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស ក្រៅអំពីធម៌ដ៏ថោកទាប និងបណីតធម៌ ។* **លោកុត្តរធម៌** *ឈ្មោះថា* **បណីត** *ព្រោះអត្ថថា ឧត្ដម និងព្រោះអត្ថថា មិនក្ដៅក្រហាយ ។*

# មិច្ឆត្តិកៈទី ១៥

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃមិច្ឆត្តធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **មិច្ឆត្ត** ព្រោះអត្ថថា ជាសភាវៈខុស ព្រោះមិនប្រព្រឹត្ត ទៅ ដូចជនទាំងឡាយ សូម្បីសង្ឃឹមយ៉ាងនេះថា ធម៌ទាំងនេះ នឹងនាំ ប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់អញ ដូច្នេះ និងព្រោះប្រព្រឹត្តទៅ ដោយវិបរិតជាដើមថា សូម្បីក្នុងអសុភៈជាដើមនោះឯងថាជាសុភៈ ។ ធម៌ ទាំងនោះ ឈ្មោះថា **និយត** ព្រោះកាលនៅមានការឲ្យវិបាក ក៏ឲ្យវិបាកក្នុង វាងនៃការទម្លាយខន្ធទាំងឯង ។ ធម៌ទាំងឡាយនោះ ជាមិច្ឆត្តៈផង ជានិយតៈ ផង ព្រោះហេតុនោះ ទើបឈ្មោះថា **មិច្ឆត្តនិយត** ។ ធម៌ដែលឈ្មោះថា **សម្មត្ត** ព្រោះអត្ថថា ជាសភាវៈត្រឹមត្រូវ ដោយអត្ថដែលខុសអំពីមិច្ឆត្តៈ ដែលពោលហើយ ។ ធម៌ទាំងនោះ ជាសម្មត្តៈផង ជានិយតៈផង ដោយឲ្យ ផល មិនមានរវាងចន្លោះទាំងឯង ព្រោះហេតុនោះ ទើបឈ្មោះថា **សម្មត្ត-និយត** ។ ធម៌ទាំងឡាយណាឲ្យផលមិនពិតប្រាកដ ដោយប្រការទាំងពីរនោះ ព្រោះហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា **អនិយតា** ។

# មគ្គារម្មណត្តិកៈទី ១៦

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃមគ្គារម្មណធម៌ដូចតទៅ

ឈ្មោះថា **មគ្គ** ព្រោះអត្ថថា ស្វែងរក ស្វះស្វែងរកព្រះនិព្វាន ម្យ៉ាងទៀត ឈ្មោះថា **មគ្គ** ព្រោះអត្ថថា ឈានមុខក្នុងការសម្លាប់កិលេសទាំងឡាយ ។ មគ្គជាអារម្មណ៍របស់ធម៌ទាំងនោះ ហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **មគ្គារម្មណ** ។ មគ្គសូម្បីប្រកបដោយអង្គ ៨ ក៏ជាហេតុរបស់ធម៌ទាំងនោះ ព្រោះអត្ថថា ជាបច្ច័យ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **មគ្គហេតុក** ។ ហេតុទាំងឡាយ សម្បយុត្តដោយមគ្គ ឬថាហេតុទាំងឡាយក្នុងមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា **មគ្គហេតុ** ។ មគ្គ-ហេតុទាំងនោះ ជាហេតុរបស់ធម៌ទាំងនោះ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **មគ្គហេតុក** ។ សម្មាទិដ្ឋិនុ៎ះឯងជាមគ្គផង ជាហេតុផង ព្រោះហេតុនោះ មគ្គផង ហេតុផង មានដល់ធម៌ទាំងនោះ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **មគ្គហេតុក** ។ មគ្គជាអធិបតីនៃធម៌ទាំងនោះ ដោយអត្ថថា គ្របសង្កត់ប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **មគ្គាធិបតិ** ។

## ឧប្បន្នត្តិកៈទី ១៧

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃឧប្បន្នធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **ឧប្បន្ន** ព្រោះអត្ថថា កើតឡើង ដំណើរទៅ ប្រព្រឹត្តទៅ ចាប់តាំងអំពីឧប្បាទក្ខណៈ រហូតដល់ភង្គក្ខណៈ ។ ធម៌ដែលឈ្មោះថា **អនុប្បន្ន** ព្រោះអត្ថថា កើតឡើងហើយក៏មិនមែន ។ ធម៌ពួកណានឹងកើតឡើងពិតប្រាកដ ព្រោះជាចំណែកមួយនៃហេតុដែលសម្រេចហើយ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **ឧប្បាទិ** ។

# អតីតត្តិកៈទី ១៨

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃអតីតធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **អតីត** ព្រោះអត្ថថា ដល់សភាវៈរបស់ខ្លួន ឬដល់ឧប្បាទក្ខណៈជាដើមហើយ ក៏កន្លងទៅ ។ ធម៌ដែលឈ្មោះថា **អនាគត** ព្រោះមិនដល់សភាវៈរបស់ខ្លួន ឬឧប្បាទក្ខណៈជាដើមទាំងពីរនោះ ។ ធម៌ដែលឈ្មោះថា **បច្ចុប្បន្ន** ព្រោះអាស្រ័យហេតុនោះៗ កើតឡើង ។

# អតីតារម្មណត្តិកៈទី ១៩

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃអនន្តរធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **អតីតារម្មណា** ព្រោះអារម្មណ៍របស់ធម៌ទាំងនោះជាអតីត ។ សូម្បីពីរបទដ៏សេសក៏ន័យនេះដូចគ្នា ។

# អជ្ឈត្តត្តិកៈទី ២០

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃអជ្ឈត្តធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **អជ្ឈត្ត** ព្រោះអត្ថថា ធ្វើខ្លួនឲ្យជាធំដូចបំណងយ៉ាងនេះថា ពួកយើងកាលរស់នៅយ៉ាងនេះ ពួកយើងនឹងប្រកាន់យកជាអត្តា ដូច្នេះ ។ ចំណែក **អជ្ឈត្ត** សព្ទនេះ ប្រើក្នុងអត្ថ ៤ យ៉ាង គឺ **គោចរជ្ឈត្ត** ( អារម្មណ៍ទូទៅ ) ១ **និយកជ្ឈត្ត** ( ធម៌ដែលកើតក្នុងខ្លួន ) ១ **អជ្ឈត្តជ្ឈត្ត** ( អជ្ឈត្តាយតនៈ ៦ ) ១ **វិសយជ្ឈត្ត** ( ផលសមាបត្តិ ) ១ ។

ពិតមែន **អជ្ឈត្ត** សព្ទនេះ ប្រើក្នុងអត្ថថា **គោចរជ្ឈត្ត** ដូចក្នុងប្រយោគជាដើមថា **តេនានន្ទ ភិក្ខុនា តស្មឹយេវ បុរិមស្មឹ សមាធិនិមិត្តេ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេតព្វំ** ម្នាលអានន្ទ ភិក្ខុនោះត្រូវតាំងចិត្តខាងក្នុង ក្នុងសមាធិនិមិត្ត ពីមុននោះវិញ ដូច្នេះ និងដូចក្នុងប្រយោគថា **អជ្ឈត្តរតោ សមាហិតោ** ជាអ្នកមានចិត្តតម្កល់មាំ តែងមានចិត្តត្រេកអរក្នុងធម៌ ដូច្នេះ ។

ប្រើក្នុងអត្ថថា **និយកជ្ឈត្ត** ដូចក្នុងប្រយោគជាដើមថា **អជ្ឈត្តំ សម្បសាទនំ** ជាធម្មជាតច្បាស់ប្រាកដក្នុងខ្លួន មានសេចក្តីជ្រះថ្លា គឺសទ្ធា ដូច្នេះ និងដូចក្នុងប្រយោគជាដើមថា **អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ** ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី ដូច្នេះ ។

ប្រើក្នុងអត្ថថា **អជ្ឈត្តជ្ឈត្ត** ដូចក្នុងប្រយោគជាដើមថា **ឆ អជ្ឈត្តិកានិ អាយតនានិ** អាយតនៈខាងក្នុង ៦ ដូច្នេះ ។

ប្រើក្នុងអត្ថថា **វិសយជ្ឈត្ត** ដូចក្នុងប្រយោគជាដើមថា **អយំ ខោ បនានន្ទ វិហារោ តថាគតេន អភិសម្ពុទ្ធោ យទិទំ សព្វនិមិត្តានំ**

**អមនសិការា អជ្ឈត្តំ សុញ្ញតំ ឧបសម្បជ្ជ វិហារតិ** ម្នាលអានន្ទ វិហារធម៌ ( ការនៅ ) ក្នុងទីស្ងាត់ តថាគតបានត្រាស់ដឹងហើយ គឺបានសម្រេចនូវសុញ្ញតផលសមាបត្តិក្នុងសន្តាន ព្រោះមិនធ្វើទុកក្នុងចិត្តនូវសង្ខតនិមិត្តទាំងអស់ ( មានរូបជាដើម ) ដូច្នេះ ។ អធិប្បាយថា ប្រើក្នុងឋានៈដ៏ធំក្រៃលែង ។ ពិតហើយ **ផលសមាបត្តិ** ឈ្មោះថា ឋានៈដ៏ធំក្រៃលែងរបស់ព្រះពុទ្ធទាំងឡាយ ។ ចំណែក **អជ្ឈត្ត** សព្ទក្នុងទីនេះ សំដៅយក **និយ-កជ្ឈត្ត** ព្រោះហេតុនោះ ធម៌ដែលប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន ចំពោះបុគ្គលនីមួយៗ គប្បីជ្រាបថា ជាអជ្ឈត្តធម៌ ។ ចំណែកធម៌ដែលជាខាងក្រៅពីអជ្ឈត្តធម៌នោះ ទាក់ទងដោយឥន្ទ្រិយក្តី មិនទាក់ទងដោយឥន្ទ្រិយក្តី ឈ្មោះថា **ពហិទ្ធាធម៌** ។ បទទី ៣ លោកពោលដោយអំណាចរួមបទទាំង ២ នោះ ។

ចំណែកពួក ៣ នៃអនន្តរៈ ( អតីតារម្មណត្តិកៈ ) លោកពោលធ្វើធម៌ទាំង ៣ ប្រការ ( អជ្ឈត្តៈជាដើម ) ទាំងនោះឯង ឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ។

## **សនិទស្សនត្តិកៈទី ២២**

គប្បីជ្រាបវិគ្គហៈក្នុងពួក ៣ នៃសនិទស្សនធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **សនិទស្សន** ព្រោះប្រព្រឹត្តទៅ មួយអន្លើដោយការឃើញ ពោល គឺការៈដែលរូបនោះដែលចក្ខុវិញ្ញាណគប្បីឃើញ ។ ធម៌ដែលឈ្មោះថា **សប្បដិឃ** ព្រោះប្រព្រឹត្តទៅជាមួយនឹងបដិឃៈ ពោល គឺការៈ គឺការប៉ះខ្ទប់ ។ ធម៌ដែលឈ្មោះថា **សនិទស្សនសប្បដិឃ** ព្រោះធម៌ទាំងនោះប្រព្រឹត្តទៅ មួយអន្លើដោយការឃើញ និងការប៉ះខ្ទប់ ។ ឈ្មោះថា **អនិទស្សន** ព្រោះនិទស្សនៈ ពោល គឺភាពដែលរូបដែលចក្ខុវិញ្ញាណគប្បីឃើញ មិនមានដល់ធម៌ទាំងនោះ ។ ឈ្មោះថា **អនិទស្សនសប្បដិឃ** ព្រោះធម៌ទាំងនោះ ជាអនិទស្សនៈផង ជាសប្បដិឃៈផង ដោយន័យដែលពោលហើយនោះឯង ។ បទទី ៣ ពោលបដិសេធបទទាំង ២ ។

**អដ្ឋកថាតិកមាតិ មាន១បុព្វបទមានប្រមាណប៉ុណ្ណោះ**

**អដ្ឋកថាបទតិកមាតិកា ចប់**

# អភិធម្មបិដក

## អភិធម្មមាតិកា

[ ២ ] ពួកធម៌ជាហេតុ ពួកធម៌មិនមែនជាហេតុ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ប្រកបដោយហេតុ ពួកធម៌ប្រាសចាកហេតុ ពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ពួកធម៌ជាហេតុផង ប្រកបដោយហេតុផង ពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ពួកធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌មិនមែនជាហេតុផង មិនប្រព្រឹត្តទៅជាមួយនឹងហេតុផង ។

ពួកហេតុ ចប់

[ ៣ ] ពួកធម៌ប្រកបដោយបច្ច័យ ពួកធម៌មិនមានបច្ច័យ ពួកធម៌មានបច្ច័យតាក់តែង ពួកធម៌ឥតបច្ច័យតាក់តែង ពួកធម៌ប្រកបដោយការឃើញ ពួកធម៌មិនប្រកបដោយការឃើញ ពួកធម៌ប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការប៉ះពាល់ ពួកធម៌មានរូប ពួកធម៌មិនមានរូប ពួកធម៌ជាលោកិយ ពួកធម៌ជាលោកុត្តរ ពួកធម៌គួរដឹងច្បាស់ដោយវិញ្ញាណនីមួយ គឺចក្ខុវិញ្ញាណ ឬសោតវិញ្ញាណជាដើម ពួកធម៌ដែលមិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ ។

ចូឡន្តរទុកៈ ចប់

[ ៤ ] ពួកធម៌ជាអាសវៈ ពួកធម៌មិនមែនជាអាសវៈ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ប្រកបដោយអាសវៈ ពួកធម៌ប្រាសចាកអាសវៈ ពួកធម៌ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ពួកធម៌ជាអាសវៈផង ប្រកបដោយអាសវៈផង ពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។

**ពួកអាសវៈ ចប់**

[ ៥ ] ពួកធម៌ជាសញ្ញោជនៈ ( ធម៌ចងសត្វទុកក្នុងវដ្តៈ ) ពួកធម៌មិនមែនជាសញ្ញោជនៈ ពួកធម៌ជាប្រយោជន៍ ឬសមគួរដល់សញ្ញោជនៈ ពួកធម៌មិនមែនជាប្រយោជន៍ ឬមិនសមគួរដល់សញ្ញោជនៈ ពួកធម៌ប្រកបដោយសញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈ ពួកធម៌ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ពួកធម៌ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ពួកធម៌គ្រាន់តែប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈផង មិនជាប្រយោជន៍ដល់សញ្ញោជនៈផង ។

**ពួកសញ្ញោជនៈ ចប់**

[ ៦ ] ពួកធម៌ជាគន្ថៈ ( ធម៌ជោតក្រងសត្វទុកក្នុងវដ្តៈដោយអំណាច ចុតិ និងបដិសន្ធិ ) ពួកធម៌មិនមែនជាគន្ថៈ ពួកធម៌ដែលគន្ថៈគប្បីជោតក្រង ពួកធម៌ដែលគន្ថៈមិនគប្បីជោតក្រង ពួកធម៌ប្រកបដោយគន្ថៈ ពួកធម៌ប្រាសចាកគន្ថៈ ពួកធម៌ជាគន្ថៈផង ដែលគន្ថៈគប្បីជោតក្រងផង ពួកធម៌ដែលគន្ថៈគប្បីជោតក្រង តែមិនមែនជាគន្ថៈ ពួកធម៌ជាគន្ថៈផង ប្រកបដោយគន្ថៈផង ពួកធម៌គ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈ ពួកធម៌ប្រាសចាកគន្ថៈ តែគន្ថៈគប្បីជោតក្រង ពួកធម៌ប្រាសចាកគន្ថៈផង ដែលគន្ថៈមិនគប្បីជោតក្រងផង ។

ពួកគន្ថៈ ចប់

[ ៧ ] ពួកធម៌ជាឱឃៈ ( ធម៌ញាំងសត្វឲ្យលង់នៅក្នុងវដ្តៈ ) ពួកធម៌មិនមែនជាឱឃៈ ពួកធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រកបដោយឱឃៈ ពួកធម៌ប្រាសចាកឱឃៈ ពួកធម៌ជាឱឃៈផង ដែលឱឃៈគប្បីប្រព្រឹត្តកន្លងផង ពួកធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លង តែមិនមែនជាឱឃៈ ពួកធម៌ជាឱឃៈផង ប្រកបដោយឱឃៈផង ពួកធម៌គ្រាន់តែប្រកបដោយឱឃៈ តែមិនមែនជាឱឃៈ ពួកធម៌ប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រាសចាកឱឃៈផង ឱឃៈមិនគប្បីប្រព្រឹត្តកន្លងផង ។

ពួកឱឃៈ ចប់

[ ៨ ] ពួកធម៌ជាយោគៈ ( ធម៌ញ៉ាំងសត្វឲ្យជាប់នៅក្នុងវដ្ដៈ ) ពួកធម៌មិនមែនជាយោគៈ ពួកធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រកបដោយយោគៈ ពួកធម៌ប្រាសចាកយោគៈ ពួកធម៌ជាយោគៈផង ដែលយោគៈគប្បីប្រព្រឹត្តកន្លងផង ពួកធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លង តែមិនមែនជាយោគៈ ពួកធម៌ជាយោគៈផង ប្រកបដោយយោគៈផង ពួកធម៌គ្រាន់តែប្រកបដោយយោគៈ តែមិនមែនជាយោគៈ ពួកធម៌ប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រាសចាកយោគៈផង ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងផង ។

ពួកយោគៈ ចប់

[ ៩ ] ពួកធម៌ជានីវរណៈ ( ធម៌រួបរឹតចិត្តសត្វ ) ពួកធម៌មិនមែនជានីវរណៈ ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ ពួកធម៌មិនជាប្រយោជន៍ដល់នីវរណៈ ពួកធម៌ប្រកបដោយនីវរណៈ ពួកធម៌ប្រាសចាកនីវរណៈ ពួកធម៌ជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ ពួកធម៌ជានីវរណៈផង ប្រកបដោយនីវរណៈផង ពួកធម៌គ្រាន់តែប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈ ពួកធម៌ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ ពួកធម៌ប្រាសចាកនីវរណៈផង មិនជាប្រយោជន៍ដល់នីវរណៈផង ។

ពួកនីវរណៈ ចប់

[ ១០ ] ពួកធម៌ជាបរាមាសៈ ( សេចក្តីប្រកាន់ខុស ) ពួកធម៌មិនមែនជាបរាមាសៈ ពួកធម៌ដែលបរាមាសៈស្ទាបអង្អែល ( ធម៌ដែលជ្រោកជ្រាកដោយបរាមាសៈ ) ពួកធម៌ដែលពួកបរាមាសៈ មិនបានស្ទាបអង្អែល ពួកធម៌ប្រកបដោយបរាមាសៈ ពួកធម៌ដែលប្រាសចាកបរាមាសៈ ពួកធម៌ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង ពួកធម៌គ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ ពួកធម៌ប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែល ពួកធម៌ប្រាសចាកបរាមាសៈផង បរាមាសៈមិនបានស្ទាបអង្អែលផង ។

## ពួកបរាមាសៈ ចប់

[ ១១ ] ពួកធម៌ប្រកបដោយអារម្មណ៍ ពួកធម៌មិនមានអារម្មណ៍ ពួកធម៌ជាចិត្ត ពួកធម៌មិនមែនជាចិត្ត ពួកធម៌ជាចេតសិក ពួកធម៌មិនមែនជាចេតសិក ពួកធម៌ប្រកបដោយចិត្ត ពួកធម៌ប្រាសចាកចិត្ត ពួកធម៌ច្រឡូកច្រឡំដោយចិត្ត ពួកធម៌មិនច្រឡូកច្រឡំដោយចិត្ត ពួកធម៌តាំងឡើងដោយចិត្ត ពួកធម៌មិនតាំងឡើងដោយចិត្ត ពួកធម៌កើតជាមួយនឹងចិត្ត ពួកធម៌មិនកើតជាមួយនឹងចិត្ត ពួកធម៌ប្រព្រឹត្តទៅតាមចិត្ត ពួកធម៌មិនប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ច្រឡូកច្រឡំតាំងឡើងដោយចិត្ត ពួកធម៌មិនច្រឡូកច្រឡំមិនតាំងឡើងដោយចិត្ត ពួកធម៌ច្រឡូកច្រឡំ តាំងឡើងកើតជាមួយនឹងចិត្ត ពួកធម៌មិនច្រឡូកច្រឡំ មិនតាំងឡើងមិនកើតជាមួយនឹងចិត្ត ពួកធម៌ច្រឡូកច្រឡំតាំង

ឡើងប្រព្រឹត្តទៅតាមចិត្ត ពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ ពួកធម៌ជាឧបាទា ( ឧបាទាយរូប ) ពួកធម៌មិនមែនជាឧបាទា ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ។

## មហន្តរទុកៈ ចប់

[ ១២ ] ពួកធម៌ជាឧបាទាន ( សេចក្តីប្រកាន់មាំ ) ពួកធម៌មិនមែនជាឧបាទាន ពួកធម៌ជាប្រយោជន៍ដល់ឧបាទាន ពួកធម៌មិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ប្រកបដោយឧបាទាន ពួកធម៌ប្រាសចាកឧបាទាន ពួកធម៌ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង ពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ប្រាសចាកឧបានទានផង មិនជាប្រយោជន៍ដល់ឧបាទានផង ។

## ពួកឧបាទាន ចប់

[ ១៣ ] ពួកធម៌ជាកិលេស ( ធម៌សៅហ្មង ) ពួកធម៌មិនមែនជាកិលេស ពួកធម៌គួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌មិនគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ដែលសៅហ្មងហើយ ពួកធម៌ដែលមិនសៅហ្មង

ហើយ ពួកធម៌ប្រកបដោយកិលេស ពួកធម៌ប្រាសចាកកិលេស ពួកធម៌ជាកិលេសផង គួរដើម្បីដល់នូវសេចក្ដីសៅហ្មងផង ពួកធម៌គ្រាន់តែគួរដើម្បីដល់នូវសេចក្ដីសៅហ្មង តែមិនមែនជាកិលេស ពួកធម៌ជាកិលេសផង សៅហ្មងហើយផង ពួកធម៌គ្រាន់តែសៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង ពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស ពួកធម៌ប្រាសចាកកិលេស តែគួរដើម្បីដល់នូវសេចក្ដីសៅហ្មង ពួកធម៌ប្រាសចាកកិលេសផង មិនគួរដើម្បីដល់នូវសេចក្ដីសៅហ្មងផង ។

## ពួកកិលេស ចប់

[ ១៤ ] ពួកធម៌ដែលគួរលះបង់ដោយទស្សនៈ ( សោតាបត្តិមគ្គ ) ពួកធម៌ដែលមិនគួរលះបង់ដោយទស្សនៈ ពួកធម៌ដែលគួរលះបង់ដោយភាវនា ( មគ្គ ៣ ខាងលើ ) ពួកធម៌ដែលមិនគួរលះបង់ដោយភាវនា ពួកធម៌មានហេតុដែលគួរលះបង់ដោយទស្សនៈ ពួកធម៌មិនមានហេតុដែលគួរលះបង់ដោយទស្សនៈ ពួកធម៌មានហេតុដែលគួរលះបង់ដោយភាវនា ពួកធម៌មិនមានហេតុដែលគួរលះបង់ដោយភាវនា ពួកធម៌ប្រកបដោយវិតក្កៈ ( ការត្រិះរិះ ) ពួកធម៌មិនមានវិតក្កៈ ពួកធម៌ប្រកបដោយវិចារ ( ការពិចារណា ) ពួកធម៌មិនមានវិចារ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ ( ការត្រេកអរ ) ពួកធម៌មិនមានបីតិ ពួកធម៌ប្រកបដោយបីតិ ពួកធម៌មិនប្រកបដោយបីតិ ពួកធម៌ប្រកបដោយសុខ ពួកធម៌មិនប្រកបដោយសុខ ពួកធម៌ប្រកបដោយឧបេក្ខា

ពួកធម៌មិនប្រកបដោយឧបេក្ខា ពួកធម៌ជាកាមាវចរ ( ប្រព្រឹត្តទៅក្នុងកាម ) ពួកធម៌មិនមែនជាកាមាវចរ ពួកធម៌ជារូបាវចរ ពួកធម៌មិនមែនជារូបាវចរ ( ប្រព្រឹត្តទៅក្នុងរូប ) ពួកធម៌ជាអរូបាវចរ ( ប្រព្រឹត្តទៅក្នុងអរូប ) ពួកធម៌មិនជាអរូបាវចរ ពួកធម៌ជាបរិយាបន្នៈ ( រាប់បញ្ចូលក្នុងតេភូមិកវដ្ដៈ ) ពួកធម៌ជាអបរិយាបន្នៈ ពួកធម៌ជានិយ្យានិកៈ ( ធម៌កាត់នូវវដ្ដមូលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ហើយចេញចាកវដ្ដៈ ) ពួកធម៌មិនមែនជានិយ្យានិកៈ ពួកធម៌ទៀង ពួកធម៌មិនទៀង ពួកធម៌ប្រកបដោយឧត្តរៈ ( ការរើឡើងនូវខ្លួន ) ពួកធម៌មិនមានឧត្តរៈ ពួកធម៌ប្រកបដោយរណៈ ( សត្រូវ ) ពួកធម៌មិនមានរណៈ ។

**បិដ្ឋិទុកៈ ចប់**

**អភិធម្មមាតិកា ចប់**

# អភិធម្មបិដក

## សុត្តន្តមាតិកា

[ ១៥ ] ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃអវិជ្ជា ពួកធម៌ប្រៀបដូចផ្លេកបន្ទោរ ពួកធម៌ប្រៀបដូចពេជ្រ ពួកធម៌ពាល ពួកធម៌បណ្ឌិត ពួកធម៌ខ្មៅ ពួកធម៌ស ពួកធម៌ដុតកម្តៅ ពួកធម៌មិនដុតកម្តៅ ពួកធម៌ជាឈ្មោះ ពួកធម៌ជាគន្លងនៃឈ្មោះ ពួកធម៌ជានិរុត្តិ ពួកធម៌ជាគន្លងនៃនិរុត្តិ ពួកធម៌ជាបញ្ញត្តិ ពួកធម៌ជាគន្លងនៃបញ្ញត្តិ នាម និងរូប អវិជ្ជា និងភវតណ្ហា ភវទិដ្ឋិ និងវិភវទិដ្ឋិ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ អន្តវាទិដ្ឋិ និងអនន្តវាទិដ្ឋិ បុព្វន្តានុទិដ្ឋិ និងអបរន្តានុទិដ្ឋិ សេចក្តីមិនខ្មាសបាប និងសេចក្តីមិនក្តៅនឹងបាប សេចក្តីខ្មាសបាប និងសេចក្តីក្តៅនឹងបាប ភាពនៃបុគ្គលប្រដៅក្រ និងភាពនៃបុគ្គលមានមិត្តអាក្រក់ ភាពនៃបុគ្គលប្រដៅងាយ និងភាពនៃបុគ្គលមានមិត្តល្អ សេចក្តីឈ្លាសក្នុងអាបត្តិ និងសេចក្តីឈ្លាសក្នុងការចេញចាកអាបត្តិ សេចក្តីឈ្លាសក្នុងសមាបត្តិ និងសេចក្តីឈ្លាសក្នុងការចេញចាកសមាបត្តិ សេចក្តីឈ្លាសក្នុងធាតុ និងសេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត សេចក្តីឈ្លាសក្នុងអាយតនៈ និងសេចក្តីឈ្លាសក្នុងបដិច្ចសមុប្បាទ សេចក្តីឈ្លាសក្នុងហេតុ និងសេចក្តីឈ្លាសក្នុងការមិនមែនជាហេតុ សេចក្តីត្រង់ និងសេចក្តីទន់ភ្លន់ សេចក្តីអត់សង្កត់ និងសេចក្តីស្ងួត សេចក្តីរាក់ទាក់ និងការស្រុះស្រួលទទួល ការមិនរក្សាទ្វារក្នុងឥន្ទ្រិយ និងសេចក្តីមិនដឹងប្រមាណក្នុងភោជន ការរក្សាទ្វារក្នុងឥន្ទ្រិយ និងសេចក្តីដឹងប្រមាណក្នុងភោជន សេចក្តីភ្លេចស្មារតី និងសេចក្តីមិនដឹងខ្លួន ស្មារតី និងសេចក្តីដឹងខ្លួន កម្លាំង គឺ

ការពិចារណា និងកម្លាំងភាវនា សមថៈ និងវិបស្សនា និមិត្តរបស់សមថៈ និង និមិត្តនៃការផ្គងឡើង ការផ្គងឡើង និងសេចក្តីមិនរាយមាយ វិបត្តិនៃសីល និងវិបត្តិនៃទិដ្ឋិ ការបរិបូណ៌នៃសីល និងការបរិបូណ៌នៃទិដ្ឋិ សេចក្តីបរិសុទ្ធនៃសីល និងសេចក្តីបរិសុទ្ធនៃទិដ្ឋិ សេចក្តីបរិសុទ្ធនៃទិដ្ឋិ និងសេចក្តីព្យាយាមរបស់បុគ្គលដែលមានទិដ្ឋិសមគួរ សេចក្តីសង្វេគក្នុងទីដែលគួរសង្វេគទាំងឡាយ និងសេចក្តីព្យាយាមដោយឧបាយនៃបុគ្គល ដែលមានសេចក្តីសង្វេគ សេចក្តីមិនសន្តោស ក្នុងកុសលធម៌ទាំងឡាយ និងសេចក្តីមិនថយ ក្នុងព្យាយាម វិជ្ជា និងវិមុត្តិ សេចក្តីដឹងក្នុងធម៌ជាគ្រឿងអស់ទៅនៃកិលេស និងសេចក្តីដឹងក្នុងធម៌ដែលធ្វើកិលេសមិនឲ្យកើតឡើងទៀត ។

**សុត្តន្តមាតិកា ចប់**

**មាតិកា ចប់**

# អដ្ឋកថា

## បធទុកមាតិកា

### ហេតុគោច្ឆកៈ

[ ២-១៤ ] ក្នុងទុកមាតិកា ខ្ញុំនឹងអធិប្បាយបទដែលនៅមិនទាន់មកក្នុងតិកៈទាំងឡាយប៉ុណ្ណោះ នឹងអធិប្បាយបទក្នុងហេតុគោច្ឆកៈមុន ។

បទថា **ហេតុធម្មា** បានដល់ ធម៌ទាំងឡាយ ពោល គឺហេតុ ដោយអត្ថថា ជាឫសគល់ បាឋៈថា **ហេតូ ធម្មា** ដូច្នេះក៏មាន ។ បទថា **ន ហេតូ** ជាពាក្យបដិសេធហេតុទាំងនោះដោយពិត ។ ធម៌ដែលឈ្មោះថា **សហេតុកា** ព្រោះមានហេតុ ប្រព្រឹត្តទៅដោយសម្បយោគ ។ ធម៌ដែលឈ្មោះថា **អហេតុកា** ព្រោះហេតុដែលប្រព្រឹត្តទៅរបស់ធម៌ទាំងឡាយ ដូចយ៉ាងនោះមិនមាន ។ ធម៌ដែលឈ្មោះថា **ហេតុសម្បយុត្តា** ព្រោះសម្បយុត្តដោយហេតុដោយមានឯកុប្បាទជាដើម ។ ធម៌ដែលឈ្មោះថា **ហេតុវិប្បយុត្តា** ព្រោះមិនប្រកបដោយហេតុ ។

ទុកៈទាំង ២ ( គឺសហេតុកទុកៈ និងហេតុសម្បយុត្តទុកៈ ) នេះ ដោយអត្ថ មិនមានសេចក្ដីផ្សេងគ្នាក៏ពិត តែព្រះមានព្រះភាគក៏ត្រាស់ទុកៈទាំង ២ ដោយការពីរោះនៃទេសនា ឬដោយអធ្យាស្រ័យរបស់បុគ្គលទាំងឡាយ គឺសត្វដែលនឹងត្រាស់ដឹងដោយធម៌យ៉ាងនោះ តអំពីនោះ ក៏ទ្រង់ប្រកបទុកៈដំបូង ដោយអំណាចឯកទេសទាំងអស់ ជាមួយនឹងទុកៈទី ២ និងទី ៣ ហើយត្រាស់ទុកៈ ៣ ដទៃទៀត តាមដែលកើតបានដោយអំណាចនៃពាក្យ

ទាំងនោះ មានពាក្យថា **ហេតូ ន ហេតូ** ជាដើម ។ បណ្តាទុកៈទាំងនោះ បទថា **ហេតូ ចេវ ធម្មា សហេតុកា ច** នេះ រមែងកើតឡើងយ៉ាងណា សូម្បីទុកៈនេះថា **ហេតូ ចេវ ធម្មា អហេតុកា ច** ក៏រមែងកើតឡើងយ៉ាងនោះដែរ ។ មួយទៀត ពាក្យថា **សហេតុកា ចេវ ធម្មា ន ច ហេតូ** នេះ រមែងកើតយ៉ាងណា សូម្បីពាក្យនេះថា **អហេតុកា ចេវ ធម្មា ន ច ហេតូ** ក៏រមែងកើតយ៉ាងនោះ ។ សូម្បីក្នុងការប្រកបជាមួយនឹងហេតុសម្បយុត្តទុកៈក៏ន័យនេះឯង ។

ក្នុង **នហេតុសហេតុកទុកៈ** នោះ បទថា **ន ហេតូ ធម្មា សហេតុកាបិ អហេតុកាបិ** ក៏គ្រប់គ្រាន់ឲ្យយល់សេចក្តីបាន ព្រះមានព្រះភាគត្រាស់ពាក្យថា **ខោ បន** ក្នុងពាក្យថា **ន ហេតូ ខោ បន ធម្មា** ឯណាបន្ថែមចូលមក បណ្ឌិតគប្បីជ្រាបអត្ថទៀតជាច្រើនថា ទ្រង់សង្គ្រោះដោយអំណាចនៃពាក្យថា **ខោ បន** នោះ ។ សួរថា ទ្រង់សង្គ្រោះដូចម្តេច ឆ្លើយថា សង្គ្រោះជា **ន ហេតូ ធម្មា** ត្រឹមតែប៉ុណ្ណោះក៏មិនមែន ដោយពិត សូម្បីធម៌ពួកដទៃ ក៏ជា **សហេតុកា** ខ្លះ **អហេតុកា** ខ្លះ ព្រោះហេតុនោះ កាលបើយ៉ាងនេះដោយពិត រមែងមានសូម្បីដោយប្រការដទៃ ។ លោកអធិប្បាយថា ដូចធម៌មិនជាហេតុ មានហេតុខ្លះ មិនមានហេតុខ្លះ យ៉ាងណា ធម៌ជាហេតុក៏មានហេតុខ្លះ មិនមានហេតុខ្លះ យ៉ាងនោះ ម្យ៉ាងទៀត ធម៌មិនជាហេតុ មានហេតុខ្លះ មិនមានហេតុខ្លះ យ៉ាងណា ធម៌មិនជាហេតុក៏សម្បយុត្តដោយហេតុខ្លះ វិប្បយុត្តចាកហេតុខ្លះ ក៏យ៉ាងនោះ ។

# ចូឡន្តរទុកៈ

គប្បីជ្រាបវិគ្គហៈក្នុងពួក ២ នៃចូឡន្តរទុកៈដូចតទៅ

ធម៌ដែលឈ្មោះថា **សប្បច្ចយា** ព្រោះប្រព្រឹត្តទៅព្រមគ្នានឹងបច្ច័យដែលឲ្យសម្រេចដល់ខ្លួន ។ ធម៌ដែលឈ្មោះថា **អប្បច្ចយា** ព្រោះបច្ច័យ ក្នុងឧប្បាទ ( ការកើត ) ឬក្នុងឋិតិ ( ការតាំងនៅ ) មិនមានដល់ធម៌ទាំងនោះ ។ ធម៌ដែលឈ្មោះថា **សង្ខតា** ព្រោះបច្ច័យទាំងឡាយ ប្រជុំគ្នាតាក់តែង ។ ឈ្មោះថា **អសង្ខតា** ព្រោះបច្ច័យទាំងឡាយមិនប្រជុំគ្នាតាក់តែង ។ ឈ្មោះថា **រូបិនោ** ព្រោះរូបនៃធម៌ទាំងនោះ មានដោយអំណាចនៃអវិនិព្ភោគ ( រូបដែលបែកគ្នាមិនបាន ) ។ ឈ្មោះថា **អរូបិនោ** ព្រោះរូបនៃធម៌ទាំងនោះមិនមានយ៉ាងនោះ ។ មួយទៀត រូបដែលមានការវិនាសទៅជាលក្ខណៈ នៃធម៌ទាំងនោះមាន ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **រូបិនោ** ។ ធម៌ទាំងឡាយដែលមិនមានរូប ឈ្មោះថា **អរូបិនោ** ។

វដ្ដៈ ត្រាស់ហៅថា លោក ព្រោះអត្ថថា វិនាស ។ ធម៌ទាំងឡាយប្រកបហើយក្នុងលោក ដោយការជាប់ទាក់ទងគ្នាក្នុងលោកនោះ ព្រោះហេតុនោះ ទើបឈ្មោះថា លោកិយ ធម៌ទាំងឡាយឈ្មោះថា ឧត្តរៈ ព្រោះឆ្លងឡើងហើយអំពីលោកនោះ ។ ធម៌ណាឆ្លងផុតហើយ អំពីលោកដោយការប្រព្រឹត្តទៅ មិនទាក់ទងក្នុងលោក ព្រោះហេតុនោះ ទើបធម៌នោះឈ្មោះថា លោកុត្តរ ។

បទថា **កេនចិ វិញ្ញេយ្យា** បានដល់ គប្បីដឹងដោយចក្ខុវិញ្ញាណ ឬសោតវិញ្ញាណយ៉ាងណាមួយ ក្នុងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ។

បទថា **កេនចិ ន វិញ្ញេយ្យា** បានដល់ មិនគប្បីដឹងដោយចក្ខុវិញ្ញាណ ឬ សោតវិញ្ញាណនេះទុំះឯង ។ កាលបើហេតុយ៉ាងនោះមាន ទុកៈនៃបទសូម្បី ទាំង ២ រមែងផ្សេងគ្នាដោយអត្ថ ។

# អាសវគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈក្នុងអាសវគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **អាសវា** ព្រោះអត្ថថា ហូរទៅ អធិប្បាយថា អាសវៈទាំងនោះ រមែងហូរទៅ គឺរមែងប្រព្រឹត្តទៅតាមផ្លូវភ្នែកខ្លះ ។បេ។ តាមផ្លូវចិត្តខ្លះ ។ម្យ៉ាងវិញទៀត ធម៌ដែលឈ្មោះថា **អាសវា** ព្រោះអត្ថថា កាលពោលដោយធម៌ រមែងហូរទៅដល់គោត្រភូ ពោលដោយភូមិ ( ឱកាស ) រមែងហូរទៅដល់ភវគ្គព្រហ្ម អធិប្បាយថា ធ្វើធម៌ទាំងនេះ និងភូមិនោះ ក្នុងខាងក្នុងប្រព្រឹត្តទៅ ។ ព្រោះថា **អា** អក្ខរៈនេះ មានអត្ថថា ធ្វើទុក ខាងក្នុង ដែលឈ្មោះថា **អាសវា** ព្រោះដូចជាគ្រឿងត្រាំ មានគ្រឿងស្រវឹង ជាដើម ដោយអត្ថថា ត្រាំទុកយូរ ។ ពិតហើយ គ្រឿងត្រាំដែលត្រាំទុក យូរ មានគ្រឿងស្រវឹងជាដើម លោកហៅថា អាសវៈ ។ ឈ្មោះថា អាសវៈ ព្រោះអត្ថថា ត្រាំទុកយូរ អាសវៈទាំងនោះ ក៏សមគួរជាយ៉ាងនោះ ។ សម ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ទសកនិបាត ) ថា ម្នាលភិក្ខុទាំង ឡាយ ទីបំផុតខាងដើមរបស់អវិជ្ជាមិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុន អំពីកាលនេះ ដូច្នេះជាដើម ។ មួយទៀត ឈ្មោះថា អាសវៈ ព្រោះអត្ថថា

ហូរទៅកាន់សំសារទុក្ខដ៏យូរអង្វែង គឺញ៉ាំងសង្សារទុក្ខឲ្យកើត ធម៌ពួកដទៃក្រៅអំពីអាសវៈនោះ ឈ្មោះថា **នោ អាសវា** ។ ធម៌ដែលឈ្មោះថា **សាសវា** ព្រោះមានអាសវៈ ព្រមទាំងធ្វើខ្លួនឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ។ ឈ្មោះថា **អនាសវា** ព្រោះអត្ថថា អាសវៈរបស់ធម៌ទាំងនោះដែលកំពុងប្រព្រឹត្តទៅយ៉ាងនេះមិនមាន ។ គប្បីជ្រាបពាក្យដ៏សេស ដោយន័យដែលពោលមកហើយ ក្នុងហេតុគោច្ឆកៈនោះឯង ។ ចំណែកសេចក្តីដែលប្លែកគ្នា មានដូចតទៅនេះ ក្នុងហេតុគោច្ឆកៈនោះ ទុកៈចុងក្រោយថា **ន ហេតូ ខោ បន ធម្មា សហេតុកាបិ អហេតុកាបិ** នេះ ព្រះមានព្រះភាគត្រាស់ដាក់បទទីពីរនៃទុកៈដំបូងក្នុងខាងដើម យ៉ាងណា ក្នុងអាសវគោច្ឆកៈនេះ មិនត្រាស់ទុកៈចុងក្រោយថា **នោ អាសវា ខោ បន ធម្មា សាសវាបិ អនាសវាបិ** ក៏យ៉ាងនោះ ព្រះមានព្រះភាគមិនត្រាស់ក៏ពិត ទោះបីជាយ៉ាងនោះ ក៏គប្បីជ្រាបសេចក្តីនេះ និងសេចក្តីផ្សេងគ្នា ដោយន័យដែលត្រាស់ក្នុងហេតុ-គោច្ឆកៈនោះឯង ។

## សញ្ញោជនគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈ ក្នុងសញ្ញោជនគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **សញ្ញោជនា** ព្រោះអត្ថថា ប្រកប គឺចងបុគ្គលដែលមានសញ្ញោជនៈក្នុងវដ្តៈ ។ ធម៌ដទៃក្រៅអំពីនោះ ឈ្មោះថា **នោ**

**សញ្ញោជនា** ។ ធម៌ដែលឈ្មោះថា **សញ្ញោជនិយា** ព្រោះអត្ថថា ចូលដល់ភាពជាអារម្មណ៍ ឧបការៈដល់សញ្ញោជនៈទាំងឡាយ ដោយការទាក់ទងជាមួយសញ្ញោជនៈ ពាក្យថា **សញ្ញោជនិយា** នេះ ជាឈ្មោះនៃធម៌ ដែលជាអារម្មណប្បច្ច័យដល់សញ្ញោជនៈ ។ ធម៌ដែលមិនមែនជាសញ្ញោជនិយៈ ឈ្មោះថា **អសញ្ញោជនិយា** ។ ពាក្យដែលនៅសល់ គប្បីប្រកបដោយន័យដែលពោលមកហើយ ក្នុងហេតុគោច្ឆកៈនោះឯង ។

## គន្ថគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈក្នុងគន្ថគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **គន្ថា** ព្រោះអត្ថថា ចង គឺចងបុគ្គល ដែលមានកិលេសទុកក្នុងវដ្តៈ ដោយអំណាចចុតិ និងបដិសន្ធិ ។ ធម៌ក្រៅអំពីនោះ ឈ្មោះថា **នោ គន្ថា** ។ ធម៌ដែលឈ្មោះថា **គន្ថនិយា** ព្រោះអត្ថថា ត្រូវគន្ថធម៌ចងដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ ពាក្យដ៏សេស គប្បីប្រកបដោយន័យដែលពោលហើយ ក្នុងហេតុគោច្ឆកៈនុ៎ះឯង ពាក្យដ៏សេសក្រៅអំពីដែលត្រាស់ទុក សូម្បីក្នុងទុកៈដទៃអំពីទុកៈទាំងនេះ គប្បីជ្រាបតាមន័យដែលពោលក្នុងទុកៈនោះៗ ឯង ដូចដែលត្រាស់ក្នុងទុកៈនេះ ។

## ឱឃគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈក្នុងឱឃគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **ឱឃា** ព្រោះអត្ថថា រមែងជន់លិច គឺញុំាងសត្វដែលមានកិលេសឲ្យលង់នៅក្នុងវដ្តៈ ដែលឈ្មោះថា **ឱឃនិយា** ព្រោះត្រូវឱឃធម៌ទាំងឡាយឈានកន្លងដោយធ្វើឲ្យជាអារម្មណ៍ ហើយឈានកន្លង ។ ធម៌ដែលជាអារម្មណ៍ របស់ឱឃៈទាំងឡាយនោះឯង គប្បីជ្រាបថាជាឱឃនិយៈ ។

## យោគគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈក្នុងយោគគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **យោគា** ព្រោះប្រកបសត្វដែលមានកិលេសទុកក្នុងវដ្តៈ គប្បីជ្រាបយោគនិយធម៌ដូចឱឃនិយធម៌ ។

## នីវរណគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈក្នុងនីវរណគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **នីវរណា** ព្រោះរាំង គឺហ៊ុមព័ទ្ធចិត្ត គប្បីជ្រាបនីវរណិយធម៌ ដូចសញ្ញោជនិយធម៌ ។

## បរាមាសគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈក្នុងបរាមាសគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **បរាមាសា** ព្រោះអត្ថថា រមែងប្រកាន់ដោយភាពជាយ៉ាងដទៃ ព្រោះប្រព្រឹត្តទៅ ដោយអំណាចដែលឈានកន្លងអាការនៃធម៌ទាំងឡាយ ដែលមានការមិនទៀងជាដើម តាមសេចក្តីពិត ថាជាធម៌ទៀងជាដើម ឈ្មោះថា **បរាមដ្ឋា** ព្រោះត្រូវបរាមាសធម៌ទាំងឡាយ ប្រកាន់ដោយការធ្វើឲ្យជាអារម្មណ៍ ។

## មហន្តរទុកៈ

គប្បីជ្រាបវិគ្គហៈក្នុងពួក ២ នៃមហន្តរធម៌ដូចតទៅ

ធម៌ដែលឈ្មោះថា **សារម្មណា** ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមជាមួយអារម្មណ៍ ព្រោះមិនកាន់យកអារម្មណ៍ហើយ ក៏ប្រព្រឹត្តទៅមិនបាន ។ អារម្មណ៍របស់ធម៌ទាំងនោះ មិនមាន ព្រោះហេតុនោះ ទើបធម៌ទាំងនោះឈ្មោះថា **អនារម្មណា** ។

ធម៌ដែលឈ្មោះថា **ចិត្តា** ព្រោះអត្ថថា គិត ម្យ៉ាងទៀត ឈ្មោះថា **ចិត្តា** ព្រោះអត្ថថា វិចិត្រ ។ ធម៌ដែលប្រកបក្នុងចិត្តដោយមិនបែកចាកគ្នាឈ្មោះថា **ចេតសិកា** ។ ធម៌ដែលជាប់ទាក់ទងនឹងចិត្តតាំងអំពីកើត រហូតដល់រលត់ ដោយការចូលទៅប្រកបគ្នាជានិច្ច ឈ្មោះថា **ចិត្តសំសដ្ឋា** ធម៌សូម្បីកាលប្រព្រឹត្តទៅព្រមជាមួយនឹងចិត្ត តែមិនជាប់ទាក់ទងនឹងចិត្ត ព្រោះ

មិនចូលទៅប្រកបគ្នាជានិច្ច ឈ្មោះថា **ចិត្តវិសំសដ្ឋា** ។

ឈ្មោះថា **សមុដ្ឋាន** ព្រោះអត្ថថា ជាហេតុតាំងឡើង ។ ចិត្តជាសមុដ្ឋានរបស់ធម៌ទាំងនោះ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **ចិត្តសមុដ្ឋានា** ។ ធម៌ដែលកើតព្រមគ្នា ឈ្មោះថា **សហភូ** ព្រោះកើតព្រមគ្នា ។ ធម៌ដែលកើតព្រមគ្នាជាមួយចិត្ត ឈ្មោះថា **ចិត្តសហភុនោ** ។ ដែលឈ្មោះថា **អនុបរិវត្តិ** ព្រោះអនុលោមតាមគ្នាទៅ ។ អនុលោមតាមអ្វី អនុលោមតាមចិត្ត ។ ធម៌ដែលអនុលោមទៅតាមចិត្ត ឈ្មោះថា **ចិត្តា-នុបរិវត្តិនោ** ។ ដែលឈ្មោះថា **ចិត្តសំសដ្ឋសមុដ្ឋានា** ព្រោះលាយដោយចិត្ត និងមានចិត្តជាសមុដ្ឋាន ធម៌ដែលឈ្មោះថា **ចិត្តសំសដ្ឋសមុដ្ឋាន-សហភុនោ** ព្រោះលាយឡំដោយចិត្ត មានចិត្តជាសមុដ្ឋាន និងកើតព្រមជាមួយនឹងចិត្ត ។ ធម៌ដែលឈ្មោះថា **ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ** ព្រោះលាយឡំដោយចិត្ត មានចិត្តជាសមុដ្ឋាន និងអនុលោមតាមចិត្ត ។ បទទាំងអស់ដ៏សេស គប្បីជ្រាបដោយការបដិសេធបទដែលពោលហើយ ។

ធម៌ដែលជាខាងក្នុងនុ៎ះឯង ឈ្មោះថា **អជ្ឈត្តិកា** តាមដែលពោលនៅក្នុងអជ្ឈត្តត្តិកៈ សំដៅយកអជ្ឈត្តជ្ឈត្តធម៌ ( គឺអជ្ឈត្តាយតនៈ ) ។ ធម៌ដែលឈ្មោះថា **ពាហិរា** ព្រោះជាខាងក្រៅចាកអជ្ឈត្តិកធម៌នោះ ។ ធម៌ដែលឈ្មោះថា **ឧបាទា** ព្រោះអាស្រ័យភូតរូបទាំងឡាយកើតឡើង តែមិនមែនដូចភូតបិសាច ដែលចូលសណ្ឋិត ។ ធម៌ដែលឈ្មោះថា **អនុបាទា** ព្រោះមិនអាស្រ័យមហាភូតរូបកើត ។

## ឧបាទានគោច្ឆកៈ

គប្បីជ្រាបវិគ្គហៈក្នុងឧបាទានគោច្ឆកៈដូចតទៅ

ធម៌ដែលឈ្មោះថា **ឧបាទានា** ព្រោះប្រកាន់យ៉ាងក្រៃលែង អធិប្បាយថា ប្រកាន់យ៉ាងមាំ ។ ធម៌ដទៃក្រៅអំពីឧបាទាននោះ ឈ្មោះថា **នោឧបាទានា** ។

## កិលេសគោច្ឆកៈ

ក្នុងកិលេសគោច្ឆកៈ គប្បីជ្រាបអត្ថដោយន័យដែលពោលក្នុងសង្កិ-លិដ្ឋតិកៈនោះឯង ។

## បិដ្ឋិទុកៈ

គប្បីជ្រាបវិគ្គហៈក្នុងពួក ២ នៃបិដ្ឋិធម៌ដូចតទៅ

ធម៌ពួកណា រមែងត្រាច់ទៅក្នុងកាម ព្រោះហេតុនោះ ទើបធម៌ទាំងនោះឈ្មោះថា **កាមាវចរា** ។ ឈ្មោះថា **រូបាវចរា** ព្រោះត្រាច់ទៅក្នុងរូប ។ ឈ្មោះថា **អរូបាវចរា** ព្រោះត្រាច់ទៅក្នុងអរូប ។ ក្នុងទុកៈនេះ មានសេចក្ដីសង្ខេបត្រឹមតែប៉ុណ្ណេះ ចំណែកសេចក្ដីពិស្ដារ នឹងមានជាក់ច្បាស់ខាងមុខ ។

ធម៌ពួកណាទាក់ទង គឺឈមចុះខាងក្នុង ក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **បរិយាបន្នា** ។ ធម៌ដែល

មិនទាក់ទងក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ឈ្មោះថា **អបរិយាបន្នា** ។

ធម៌ពួកណា កាត់មូលនៃវដ្តៈ ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ចេញទៅអំពីវដ្តៈ ព្រោះហេតុនោះ ទើបធម៌ទាំងនោះឈ្មោះថា **និយ្យានិកា** ។ ធម៌ដែលមិននាំចេញទៅដោយលក្ខណៈនេះ ឈ្មោះថា **អនិយ្យានិកា** ។

ធម៌ដែលឈ្មោះថា **និយតា** ព្រោះឲ្យផលពិតប្រាកដក្នុងលំដាប់នៃចុតិ ឬនៃការប្រព្រឹត្តិទៅរបស់ខ្លួន ។ ឈ្មោះថា **អនិយតា** ព្រោះមិនឲ្យផលពិតប្រាកដយ៉ាងនោះ ។ ធម៌ដែលឈ្មោះថា **ឧត្តរ** ព្រោះឆ្លងផុត គឺលះបង់ធម៌ពួកដទៃទៅ ។ ឈ្មោះថា **សឧត្តរ** ព្រោះមានឧត្តរធម៌ដែលអាចឆ្លងផុតទៅ ។ ឈ្មោះថា **អនុត្តរ** ព្រោះធម៌ដែលក្រៃលែងជាងធម៌ទាំងនោះមិនមាន ។ សត្វទាំងឡាយរមែងទួញយំព្រោះធម៌ទាំងនោះ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **រណាៈ** ។ ពាក្យថា **រណា** នេះ ជាឈ្មោះរបស់កិលេស មានរាគៈជាដើមដែលសត្វទាំងឡាយត្រូវកិលេសគ្របសង្កត់ហើយ រមែងទួញយំ កន្ទក់កន្ទេញដោយប្រការផ្សេងៗ ធម៌ដែលឈ្មោះថា **សរណា** ព្រោះមានរណធម៌ ដោយអំណាចនៃសម្បយោគ និងដោយអំណាចនៃការតាំងនៅ ក្នុងឋានៈតែមួយនៃការលះ ។ ធម៌ដែលឈ្មោះថា **អសរណា** ព្រោះសរណធម៌របស់ធម៌ទាំងនេះ មិនមានដោយអាការនោះ ។

បទទុកមាតិកា ចប់

# បទសុត្តន្តិកទុកមាតិកា

[ ១៥ ] គប្បីជ្រាបវិគ្គហៈក្នុងពួក ២ នៃសុត្តន្តិកមាតិកាដូចតទៅ

ធម៌ពួកណា រមែងសេពវិជ្ជាដោយអំណាចនៃសម្បយោគ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **វិជ្ជាភាគិនោ** ។ មួយទៀត ធម៌ពួកណា រមែងប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា គឺក្នុងកោដ្ឋាសៈនៃវិជ្ជា ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **វិជ្ជាភាគិនោ** ។ ក្នុង **វិជ្ជាភាគិនោ** នោះ វិជ្ជាមាន ៨ គឺវិបស្សនាញាណ ១ មនោមយិទ្ធិ ១ អភិញ្ញា ៦ ។ ពោលដោយអត្ថដំបូង ធម៌ដែលសម្បយុត្តដោយវិជ្ជាទាំងនោះ ឈ្មោះថា **វិជ្ជា-ភាគិនោ** ។ ពោលដោយអត្ថក្រោយ បណ្តាវិជ្ជាទាំង ៨ នោះ វិជ្ជាណាមួយ ឈ្មោះថា **វិជ្ជា** ។ វិជ្ជាទាំងឡាយដ៏សេសជា **វិជ្ជាភាគិនោ** ព្រោះហេតុនោះ វិជ្ជាក្តី ធម៌ដែលសម្បយុត្តដោយវិជ្ជាក្តី គប្បីជ្រាបថាជា **វិជ្ជាភាគិនោ** ទុះឯង ដោយប្រការដូច្នេះ តែក្នុងទីនេះ បំណងយកធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។ ធម៌ពួកណា រមែងសេពអវិជ្ជា ដោយអំណាចនៃសម្បយោគ ព្រោះហេតុនោះ ទើបធម៌ទាំងនោះឈ្មោះថា **អវិជ្ជាភាគិនោ** ។ ធម៌ពួកណា ប្រព្រឹត្តទៅក្នុងចំណែកនៃអវិជ្ជា គឺក្នុងកោដ្ឋាសៈនៃអវិជ្ជា ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **អវិជ្ជាភាគិនោ** ។ ក្នុងអវិជ្ជាភាគិនោនោះ អវិជ្ជាមាន ៤ គឺងងឹតដែលបិទបាំងទុក្ខ ងងឹតដែលបិទបាំងសមុទយៈជាដើម ។ ដោយន័យដំបូងនោះឯង ធម៌ដែលសម្បយុត្តដោយអវិជ្ជាទាំងនោះ ក៏ឈ្មោះថា **អវិជ្ជាភាគិនោ** ។ ដោយន័យក្រោយ បណ្តាអវិជ្ជាទាំងនោះ អវិជ្ជាណា

មួយ ក៏ឈ្មោះថា **អវិជ្ជា** ។ អវិជ្ជាដ៏សេស ឈ្មោះថា **អវិជ្ជាភាគិនោ** ព្រោះហេតុនោះ អវិជ្ជាក្តី ធម៌ដែលសម្បយុត្តដោយអវិជ្ជាក្តី គប្បីជ្រាបថា អវិជ្ជាភាគិនោទាំងឯង ដោយប្រការដូច្នេះ ។ ក្នុងទីនេះ បំណងយកធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។

ធម៌ដែលឈ្មោះថា **វិជ្ជូបមា** ព្រោះអត្ថថា ធម៌ទាំងនោះ ប្រៀបដោយផ្លេកបន្ទោរ ព្រោះមិនអាចកម្ចាត់ងងឹត គឺកិលេសបាន ព្រោះគ្របសង្កត់បានទៀត ។ ដែលឈ្មោះថា **វជិរូបមា** ព្រោះអត្ថថា ធម៌ទាំងនោះ ប្រៀបដោយរន្ទះ[1] ព្រោះអាចកម្ចាត់កិលេសដោយឥតសេសសល់ ។ ធម៌ដែលឈ្មោះថា **ពាលា** ព្រោះជាធម៌តាំងនៅក្នុងបុគ្គលពាលទាំងឡាយដោយចូលទៅជិតធម៌ដែលបុគ្គលពាលតាំងនៅ ។ ដែលឈ្មោះថា **បណ្ឌិតា** ព្រោះជាធម៌តាំងនៅក្នុងបណ្ឌិតទាំងឡាយ ។ មួយទៀត ឈ្មោះថា **ពាលា** ព្រោះធ្វើឲ្យជាមនុស្សល្ងង់ ។ ឬឈ្មោះថា **បណ្ឌិតា** ព្រោះធ្វើឲ្យជាមនុស្សឈ្លាស ។ ធម៌ខ្មៅ គឺធម៌ដែលធ្វើចិត្តមិនឲ្យមានពន្លឺ ឈ្មោះថា **កណ្ហា** ។ ធម៌ស គឺធម៌ដែលធ្វើចិត្តឲ្យមានពន្លឺ ឈ្មោះថា **សុក្កា** ។ មួយទៀត ឈ្មោះថា **កណ្ហា** ព្រោះជាហេតុឲ្យកំណើតក្នុងចំណែកខ្មៅ ។ ឈ្មោះថា **សុក្កា** ព្រោះជាហេតុឲ្យកំណើតក្នុងចំណែក-ស ។ ដែលឈ្មោះថា **តបនីយា** ព្រោះដុតក្នុងលោកនេះ និងលោកខាងមុខ ។ ធម៌ដែលមិនមែនជាធម៌ធ្វើឲ្យក្តៅក្រហាយ ឈ្មោះថា **អតបនីយា** ។

---

១- បិដកខ្មែរជា ពេជ្រ ។

ទុកៈ ៣ មានអធិវចនទុកៈជាដើម ពោលដោយអត្ថ មិនមានការផ្សេង គ្នា ។ ក្នុងអធិវចនទុកៈជាដើមនេះ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ពិតមែន ពាក្យថា **សិរិវឌ្ឍកោ ធនវឌ្ឍកោ** ជាដើម ដែលធ្វើត្រឹមតែជាពាក្យប៉ុណ្ណោះ ឲ្យជាធំប្រព្រឹត្តទៅ ឈ្មោះថា **អធិវចនា** ។ ធម៌ដែលជាគន្លងនៃឈ្មោះទាំង ឡាយ ឈ្មោះថា **អធិវចនបថា** ។ វាចាដែលពោលធ្វើឲ្យមានហេតុដោយ ពិស្តារ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណាតាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះ ហៅ ថា សង្ខារ ដូច្នេះ ឈ្មោះថា **និរុត្តិ** ។ ធម៌ដែលជាគន្លងនៃនិរុត្តិធម៌ទាំង ឡាយ ឈ្មោះថា **និរុត្តិបថា** ។ ធម៌ដែលឈ្មោះថា **បញ្ញត្តិ** ព្រោះការ ប្រាប់ឲ្យដឹងដោយប្រការនោះៗ យ៉ាងនេះថា **តក្កោ** សេចក្ដីត្រិះរិះ **វិតក្កោ** ការរិះគិត **សង្កប្បោ** តម្រិះ ។ ធម៌ដែលជាគន្លងនៃបញ្ញត្តិទាំងឡាយ ហៅថា **បញ្ញត្តិបថា** ។ ក្នុងទីនេះ សូម្បីពោលទុកៈមួយ ក៏គប្បីជ្រាបការប្រកបក្នុង ពាក្យនៃទុកៈដទៃដោយន័យដែលពោលហើយ ក្នុងហេតុគោច្ឆកៈនុ៎ះឯង ។

គប្បីជ្រាបវិគ្គហៈក្នុងពួក ២ នៃនាមរូបដូចតទៅ

ធម៌ដែលឈ្មោះថា **នាមំ** ព្រោះអត្ថថា ការតាំងឈ្មោះ ព្រោះអត្ថថា បង្អោនទៅ ឬព្រោះអត្ថថា ការឲ្យបង្អោនទៅ ។ ធម៌ដែលឈ្មោះថា **រូបំ** ព្រោះអត្ថថា បែកធ្លាយទៅ ។ ក្នុងសុត្តន្តិកទុកៈនេះ មានសេចក្ដីសង្ខេបត្រឹម ប៉ុណ្ណេះ ចំណែកសេចក្ដីពិស្តារ នឹងមានជាក់ច្បាស់ក្នុងនិក្ខេបកណ្ឌ ។

ការមិនដឹងក្នុងសច្ចៈទាំងឡាយ មានទុក្ខសច្ចជាដើម ឈ្មោះថា **អវិជ្ជា** ។

សេចក្ដីប្រាថ្នាក្នុងភព ឈ្មោះថា **ភវតណ្ហា** ។ សស្សតៈ លោកហៅថា ភវៈ ទិដ្ឋិដែលកើតឡើងដោយអំណាចនៃការយល់ឃើញថា ទៀង ឈ្មោះថា **ភវ-ទិដ្ឋិ** ។ ការដាច់សូន្យ លោកហៅថា **វិភវ** ទិដ្ឋិដែលកើតឡើងដោយអំណាចនៃការដាច់សូន្យ ឈ្មោះថា **វិភវទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅថា អត្តានិងលោកទៀង ឈ្មោះថា **សស្សតទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅថា អត្តានិងលោកដាច់សូន្យ ឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅថា អត្តានិងលោកមានទីបំផុត ឈ្មោះថា **អន្តវាទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅថា អត្តានិងលោកមិនមានទីបំផុត ឈ្មោះថា **អនន្តវាទិដ្ឋិ** ។ ទិដ្ឋិដែលអនុលោមតាមខន្ធចំណែកអតីត ឈ្មោះថា **បុព្វន្តានុទិដ្ឋិ** ។ ទិដ្ឋិដែលអនុលោមតាមខន្ធចំណែកអនាគត ឈ្មោះថា **អបរន្តានុទិដ្ឋិ** ។

ការមិនខ្មាសដែលទ្រង់ឲ្យពិស្ដារ ( ក្នុងអភិធម្មធម្មសង្គណិ ) យ៉ាងនេះថា ត្រង់ដែលបុគ្គលមិនខ្មាសដោយអំពើដែលគួរខ្មាស ដូច្នេះជាដើម ឈ្មោះថា **អហិរិកំ** អាការដែលមិនខ្លាចបាប ដែលទ្រង់ឲ្យពិស្ដារយ៉ាងនេះថា ត្រង់ដែលបុគ្គលមិនតក់ស្លុតដោយអំពើដែលគួរតក់ស្លុត ដូច្នេះជាដើម ឈ្មោះថា **អនោត្តប្បំ** សេចក្ដីខ្មាស ឈ្មោះថា **ហិរិ** សេចក្ដីខ្លាច ឈ្មោះថា **ឱត្តប្បំ** ។

គប្បីជ្រាបវិគ្គហៈក្នុងទោវចស្សតាជាដើមដូចតទៅនេះ បុគ្គលឈ្មោះថា **ទុព្វច** ព្រោះអត្ថថា ការពោលប្រដៅបុគ្គលដែលកាន់យកការជំទាស់ផ្សេងៗ បុគ្គលដែលចូលចិត្តលើកវាទៈ បុគ្គលមិនអើពើនោះ ធ្វើបានដោយ

ក្រ កម្មរបស់បុគ្គលប្រដៅក្រនោះ ឈ្មោះថា **ទោវចស្ស** ។ ភាវៈនៃកម្ម របស់បុគ្គលប្រដៅក្រនោះ ឈ្មោះថា **ទោវចស្សតា** ។ បុគ្គលដ៏លាមក មិនមានសទ្ធាជាដើម ជាមិត្តរបស់បុគ្គលនោះមាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ទាបមិត្ត** ភាវៈនៃបាបមិត្តនោះ ឈ្មោះថា **ទាបមិត្តតា** ។ គប្បីជ្រាប **សោវចស្សតា** និង **កល្យាណមិត្តតា** ដោយន័យដែលផ្ទុយគ្នានឹងពាក្យដែលពោលហើយនុ៎ះឯង ។

ភាពជាអ្នកឈ្លាសក្នុងអាបត្តិទាំងឡាយ ដែលត្រាស់ ( ក្នុងអភិធម្មធម្មសង្គណិ ) យ៉ាងនេះថា ពួកអាបត្តិមានកងនៃអាបត្តិ ៥ ក្តី ពួកអាបត្តិមានកងនៃអាបត្តិ ៧ ក្តី ដូច្នេះ ឈ្មោះថា **អាបត្តិកុសលតា** ។ ភាពជាអ្នកឈ្លាសក្នុងការចេញចាកអាបត្តិទាំងនោះ ឈ្មោះថា **អាបត្តិវុដ្ឋានកុសលតា** ។ ភាពជាអ្នកឈ្លាសក្នុងសមាបត្តិទាំងឡាយ ឈ្មោះថា **សមាបត្តិកុសលតា** ។ ពាក្យនេះ ជាឈ្មោះរបស់បញ្ញា ដែលកំណត់អប្បនារបស់សមាបត្តិទាំងឡាយ ។ ភាពជាអ្នកឈ្លាស ក្នុងការចេញចាកសមាបត្តិទាំងឡាយ ឈ្មោះថា **សមាបត្តិវុដ្ឋានកុសលតា** ។ ភាពជាអ្នកឈ្លាសក្នុងធាតុ ១៨ ឈ្មោះថា **ធាតុកុសលតា** ។ ភាពជាអ្នកឈ្លាស ក្នុងការមនសិការធាតុទាំងនោះឯង ឈ្មោះថា **មនសិការកុសលតា** ។ ភាពជាអ្នកឈ្លាសក្នុងអាយតនៈ មានចក្ខាយតនៈជាដើម ឈ្មោះថា **អាយតនកុសលតា** ។ ភាពជាអ្នកឈ្លាសក្នុងបដិច្ចសមុប្បាទមានអង្គ ១២ ឈ្មោះថា **បដិច្ចសមុប្បាទកុសលតា** ។ ភាពជាអ្នកឈ្លាសក្នុងឋានៈនោះៗ ឈ្មោះថា

**ឋានកុសលតា** ។ ហេតុ ត្រាស់ហៅថា **ឋានៈ** ពិតហើយ ផល ឈ្មោះថា **រមែងតាំងនៅ**ក្នុងឋានៈនោះ ព្រោះទាក់ទងដោយឋានៈនោះប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបត្រាស់ហៅហេតុថា **ឋាន** ។ ភាពជាអ្នកឈ្លាស ក្នុងអដ្ឋានៈទាំងឡាយ ឈ្មោះថា **អដ្ឋានកុសលតា** ។

ភាវៈនៃសេចក្តីត្រង់ ឈ្មោះថា **អជ្ជវោ** ។ ភាវៈនៃសេចក្តីទន់ភ្លន់ ឈ្មោះថា **មទ្ទវោ** ។ ភាវៈនៃការអត់ធន់ ពោល គឺការអត់ធ្មត់ ឈ្មោះថា **ខន្តិ** ។ ភាវៈនៃបុគ្គលត្រេកអរក្នុងកម្មល្អ ឈ្មោះថា **សោរច្ចំ** ។ ភាពជាបុគ្គលមានវាចាទន់ភ្លន់ គឺភាពជាអ្នកត្រេកអរ និងទន់ភ្លន់ ឈ្មោះថា **សាខល្យំ** ។ ការបដិសណ្ឋារៈដោយធម៌ និងអាមិសទាំងឡាយ ដោយមិនឲ្យមានទោសរបស់ខ្លួន និងអ្នកដទៃ ឈ្មោះថា **បដិសន្ថារោ** ។ ភាពជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ មានចិត្តជាគម្រប់ ៦ គឺភាពជាអ្នកទម្លាយឥន្ទ្រិយសំវរៈ ឈ្មោះថា **ឥន្ទ្រិយេសុ អគុត្តទ្វារតា** ។ ភាវៈនៃការមិនដឹងប្រមាណក្នុងភោជន ដោយអំណាចនៃការទទួល និងការបរិភោគ ឈ្មោះថា **ភោជនេ អមត្តញ្ញុតា** ។ គប្បីជ្រាបពួក ២ ក្នុងលំដាប់តមក ដោយអំណាចនៃការបដិសេធពាក្យដែលពោលហើយ ។ ភាវៈនៃបុគ្គលវង្វេងភ្លេចស្មារតី គឺការនៅប្រាសចាកសតិ ឈ្មោះថា **មុដ្ឋស្សច្ចំ** ។ ការមិនដឹងខ្លួន ឈ្មោះថា **អសម្បជញ្ញំ** ។ ធម៌ដែលឈ្មោះថា **សតិ** ព្រោះរឭកបាន ឈ្មោះថា **បញ្ញា** ព្រោះដឹងដោយទូទៅ ។ ពល ពោល គឺការពិចារណា ឈ្មោះថា **បដិសង្ខានពលំ** ព្រោះអត្ថថា មិនញាប់ញ័រក្នុងនិមិត្ត ឬក្នុងអារម្មណ៍ដែលមិនទាន់

ពិចារណា ។ ពលដែលកើតឡើងដល់អ្នកចម្រើនពោជ្ឈង្គ ៧ ដោយមានវិរិយៈជាប្រធាន ឈ្មោះថា **ភាវនាពលំ** ។ ធម៌ដែលឈ្មោះថា **សមថោ** ព្រោះធ្វើធម៌ដែលជាសត្រូវឲ្យស្ងប់ ។ ឈ្មោះថា **វិបស្សនា** ព្រោះឃើញដោយអាការផ្សេងៗ ដោយអំណាចនៃការមិនទៀងជាដើម ។ សមថៈនុ៎ះឯងជា **សមថនិមិត្ត** ដោយអំណាចនៃនិមិត្តរបស់សមថៈដំបូង ដែលព្រះយោគាវចរកាន់យកអាការនោះហើយ ឲ្យប្រព្រឹត្តទៅទៀត ។ សូម្បីក្នុងបគ្គាហនិមិត្តក៏ន័យនេះដូចគ្នា ។ ធម៌ដែលឈ្មោះថា **បគ្គាហោ** ព្រោះផ្គងនូវសម្បយុត្តធម៌ ។ ឈ្មោះថា **អវិក្ខេបោ** ព្រោះមិនរាយមាយ ។

ការវិបត្តិនៃសីល គឺការមិនសង្រួមដែលធ្វើសីលឲ្យវិនាស ឈ្មោះថា **សីលវិបត្តិ** ។ ការវិបត្តិនៃទិដ្ឋិ គឺមិច្ឆាទិដ្ឋិដែលធ្វើសម្មាទិដ្ឋិឲ្យវិនាស ឈ្មោះថា **ទិដ្ឋិវិបត្តិ** ។ ការដល់ព្រមនៃសីលដោយធ្វើសីល ឲ្យដល់ព្រមដោយធ្វើសីលឲ្យបរិបូណ៌ គឺការស្ងប់ស្ងៀម ឈ្មោះថា **សីលសម្បទា** ។ ញាណដែលបរិបូណ៌ដោយទិដ្ឋិ ជាការដល់ព្រមដោយទិដ្ឋិ ឈ្មោះថា **ទិដ្ឋិសម្បទា** ។ សេចក្តីបរិសុទ្ធនៃសីល ពោល គឺសីលដែលដល់នូវភាពជាវិសុទ្ធិ ឈ្មោះថា **សីលវិសុទ្ធិ** ។ ការបរិសុទ្ធនៃទិដ្ឋិ ពោល គឺការយល់ឃើញ ដែលអាចឲ្យសម្រេចវិសុទ្ធិ គឺព្រះនិព្វាន ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ។ បទថា **ទិដ្ឋិវិសុទ្ធិខោ បន យថា ទិដ្ឋិស្ស ច បធានំ** បានដល់ ទិដ្ឋិវិសុទ្ធិ ពោល គឺកម្មស្សកតាញាណជាដើម និងសេចក្តីព្យាយាមដែលសម្បយុត្តដោយទិដ្ឋិវិសុទ្ធិនោះឯង របស់បុគ្គលដែលមានសេចក្តីយល់ត្រូវ មានការយល់ឃើញដ៏សមគួរ

មានការយល់ឃើញដ៏ល្អ ។ សេចក្តីសង្វេគ ពោល គឺសេចក្តីខ្លាចដែលកើតឡើង ព្រោះអាស្រ័យជាតិជាដើម ឈ្មោះថា **សំវេគោ** ។ ហេតុ មានជាតិជាដើម ដែលញុំាងសេចក្តីតក់ស្លុតក្នុងចិត្តឲ្យកើតឡើង ឈ្មោះថា **សំវេជ-និយដ្ឋានំ** ។ សេចក្តីព្យាយាមដែលជាឧបាយ របស់អ្នកដែលមានសេចក្តីតក់ស្លុតក្នុងចិត្ត ដែលកើតឡើងហើយយ៉ាងនេះ ឈ្មោះថា **សំវិគ្គស្ស ច យោនិសោបធានំ** ។ ភាពជាអ្នកមិនសន្តោស ក្នុងការបំពេញកុសលធម៌ ឈ្មោះថា **អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ** ។ ភាពដែលមិនទាន់សម្រេចអរហត្តហើយមិនថយក្រោយ និងមិនបន្ធូយសេចក្តីព្យាយាម ឈ្មោះថា **អប្បដិវានិតា ច បធានស្មឹ** ។ ឈ្មោះថា **វិជ្ជា** ព្រោះដឹងច្បាស់ ។ ឈ្មោះថា **វិមុត្តិ** ព្រោះរួចផុត ។ ញាណក្នុងអរិយមគ្គ ដែលធ្វើនូវការអស់កិលេស ឈ្មោះថា **ខយេ ញាណំ** ។ ញាណក្នុងអរិយផលដែលកើតឡើងក្នុងទីបំផុតនៃការមិនកើតឡើងនៃកិលេសដែលមគ្គនោះៗ កាត់ផ្តាច់ ដែលមិនកើតឡើងដោយអំណាចបដិសន្ធិ ឈ្មោះថា **អនុប្បាទេ ញាណំ** ។

**អដ្ឋកថាមាតិកាអនុបុព្វបទមានប្រមាណប៉ុណ្ណោះ**

**បទសុត្តន្តិកទុកមាតិកា ចប់**

# អភិធម្មបិដក

## បឋភាជនីយ

[ ១៦ ] ពួកធម៌ជាកុសល ដូចម្តេចខ្លះ ។ ចិត្តជាកាមាវចរកុសល ប្រឡំដោយសោមនស្ស ប្រកបដោយញាណ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬថា ប្រារព្ធតែអារម្មណ៍ណាមួយហើយកើតឡើង ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្ក វិចារ បីតិ សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សម្បជញ្ញៈ សមថៈ វិបស្សនា សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណាដែលកើតឡើងដោយអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

# អដ្ឋកថា

## បទភាជនីយកាមាវចរកុសល

[ ១៦ ] ឥឡូវនេះ ដើម្បីសម្តែងធម៌ទាំងឡាយ ដែលទ្រង់រួបរួមដោយមាតិកា តាមដែលទ្រង់តាំងទុកដោយប្រភេទផ្សេងៗ ទើបផ្តើមបទភាជនីយនេះថា **កតមេ ធម្មា កុសលា** ដូច្នេះជាដើម ។

ក្នុងបទភាជនីយនោះ ព្រះមានព្រះភាគទ្រង់សម្តែងកាមាវចរកុសលចិត្តដួងទីមួយនេះណាថា **យស្មឹ សមយេ កាមាវចរំ ចិត្តំ ឧប្បន្នំ ហោតិ** ដូច្នេះ ក្នុងនិទ្ទេសនៃកាមាវចរកុសលនោះ មានមហាវារៈ ៣ គឺធម្មវវត្ថានវារៈ ១ សង្គហវារៈ ១ សុញ្ញតវារៈ ១ ។

បណ្តាវារៈទាំង ៣ នោះ ធម្មវវត្ថានវារៈ ទ្រង់តាំងទុក ២ យ៉ាងដោយអំណាចនៃឧទ្ទេសវារៈ និងនិទ្ទេសវារៈ បណ្តាឧទ្ទេសវារៈ និងនិទ្ទេសវារៈទាំង ២ នោះ ឧទ្ទេសវារៈមាន ៤ បរិច្ឆេទ គឺបុច្ឆា សមយនិទ្ទេស ធម្មនិទ្ទេស អប្បនា ។ បណ្តាឧទ្ទេសវារៈ ៤ បរិច្ឆេទនោះ បរិច្ឆេទថា **កតមេ ធម្មា កុសលា** នេះ ឈ្មោះថា **បុច្ឆា** បរិច្ឆេទថា **យស្មឹ សមយេ កាមាវចរំ ។បេ។ តស្មឹ សមយេ** នេះ ឈ្មោះថា **សមយនិទ្ទេស** បរិច្ឆេទថា **ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ** នេះ ឈ្មោះថា **ធម្មនិទ្ទេស** បរិច្ឆេទថា **យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា កុសលា** នេះ ឈ្មោះថា **អប្បនា** ( សរុប ) ។

បរិច្ឆេទពោលដោយពាក្យសួរទីមួយ របស់ឧទ្ទេសវារៈដែលតាំងទុក ៤ បរិច្ឆេទយ៉ាងនេះ ដូចតទៅនេះថា

បណ្តាបរិច្ឆេទទាំង ៤ នោះ បរិច្ឆេទពោលដោយពាក្យសួរថា ធម៌ជាកុសល តើដូចម្តេច នេះ ឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។ មែនពិតសំណួរមាន ៥ យ៉ាង គឺ**អទិដ្ឋជោតនាបុច្ឆា** សួរដើម្បីឲ្យយល់នូវវត្ថុដែលមិនដឹង ១ **ទិដ្ឋសំសន្ទនាបុច្ឆា** សួរដើម្បីប្រៀបធៀបនឹងវត្ថុដែលដឹងហើយ ១ **វិមតិច្ឆេទនាបុច្ឆា** សួរដើម្បីកាត់សេចក្តីសង្ស័យ ១ **អនុមតិបុច្ឆា** សួរដើម្បីសេចក្តីយល់ឃើញត្រូវ ១ **កថេតុកម្យតាបុច្ឆា** សួរដើម្បីប្រាថ្នានឹងឆ្លើយដោយខ្លួនឯង ១ ។

ពាក្យសួរទាំងនោះ មានសេចក្តីផ្សេងគ្នាដូច្នេះ គឺ**អទិដ្ឋជោតនាបុច្ឆា** តើដូចម្តេច ដោយប្រក្រតី លក្ខណៈដែលខ្លួនមិនដឹង មិនឃើញ មិនបានពិចារណា មិនបានត្រិះរិះ មិនជាក់ច្បាស់ មិនទាន់ប្រាកដ បុគ្គលរមែងសួរបញ្ហាដើម្បីដឹង ដើម្បីឃើញ ដើម្បីពិចារណា ដើម្បីត្រិះរិះ ដើម្បីឲ្យប្រាកដនូវលក្ខណៈនោះ នេះ ឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** ។

**ទិដ្ឋសំសន្ទនាបុច្ឆា** តើដូចម្តេច ដោយប្រក្រតីលក្ខណៈ ដែលខ្លួនដឹងហើយ ឃើញហើយ ពិចារណាហើយ ត្រិះរិះហើយ ជាក់ច្បាស់ហើយ ប្រាកដហើយ បុគ្គលរមែងសួរបញ្ហាដើម្បីប្រៀបធៀបជាមួយបណ្ឌិតពួកដទៃ នេះ ឈ្មោះថា **ទិដ្ឋសំសន្ទនាបុច្ឆា** ។

**វិមតិច្ឆេទនាបុច្ឆា** តើដូចម្តេច ដោយប្រក្រតី បុគ្គលដែលស្ទុះទៅកាន់សេចក្តីសង្ស័យងឿងឆ្ងល់ កើតនូវការឃើញជាពីរថា យ៉ាងនេះឬហ្ន៎ មិនមែនយ៉ាងនេះឬហ្ន៎ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ បុគ្គលរមែងសួរ

ប្រស្នា ដើម្បីកាត់សេចក្ដីសង្ស័យ នេះ ឈ្មោះថា **វិមតិច្ឆេទនាបុច្ឆា** ។

**អនុមតិបុច្ឆា** តើដូចម្ដេច ព្រះមានព្រះភាគ រមែងត្រាស់សួរបញ្ហាដើម្បីការឃើញត្រូវរបស់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្ដីនោះថាដូចម្ដេច រូបទៀង ឬមិនទៀង ។ រូបមិនទៀងទេ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។ ក៏របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នុ៎ះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ នេះឈ្មោះថា **អនុមតិបុច្ឆា** ។

**កថេតុកម្យតាបុច្ឆា** តើដូចម្ដេច ព្រះមានព្រះភាគរមែងត្រាស់សួរបញ្ហាដើម្បីបំណងត្រាស់ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះមាន ៤ សតិប្បដ្ឋាន ៤ តើអ្វីខ្លះ នេះ ឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។

បណ្ដាបុច្ឆាទាំង ៥ នោះ បុច្ឆា ៣ ខាងដើម មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ព្រោះហេតុអ្វី ។ ព្រោះធម៌អ្វីៗ ដែលបច្ច័យតាក់តែងហើយ ក្នុងកាលទាំង ៣ ឬផុតចាកកាល ជាអសង្ខតៈដែលមិនមានបច្ច័យតាក់តែង ដែលព្រះពុទ្ធទាំងឡាយ ទ្រង់មិនឃើញហើយ មិនភ្លឺហើយ មិនពិចារណា មិនត្រិះរិះ មិនជាក់ច្បាស់ មិនប្រាកដហើយមិនមាន ព្រោះហេតុនោះ ទើប **អទិដ្ឋជោតនាបុច្ឆា** មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ធម្មជាតណាដែលព្រះមានព្រះភាគទ្រង់ចាក់ធ្លុះហើយ ដោយព្រះញាណរបស់ព្រះអង្គ កិច្ចដែល

ត្រូវប្រៀបធៀបធម្មជាតនោះ ជាមួយនឹងអ្នកដទៃជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី រមែងមិនមាន ព្រោះហេតុនោះ ទើប**ទិដ្ឋសំសន្ទនាបុច្ឆា** របស់ព្រះមានព្រះភាគមិនមាន ព្រោះព្រះមានព្រះភាគ មិនមានសេចក្តីសង្ស័យ ទ្រង់ឆ្លងផុតចាកវិចិកិច្ឆាហើយ មានសេចក្តីសង្ស័យកម្ចាត់បង់បានហើយក្នុងធម៌ទាំងពួង ហេតុនោះ ទើប**វិមតិច្ឆេទនាបុច្ឆា**របស់ព្រះអង្គមិនមាន ។ ប៉ុន្តែបុច្ឆា ២ ក្រៅពីនេះ មានដល់ព្រះមានព្រះភាគ ។ ក្នុងបុច្ឆាទាំង ២ នោះ គប្បីជ្រាបពាក្យថា **កតមេ ធម្មា កុសលា** នេះ ថាជា **កថេតុកម្យតាបុច្ឆា** ។

បណ្តាបទទាំងនោះ ព្រះមានព្រះភាគ រមែងត្រាស់សួរក្នុងធម៌ដែលគប្បីលើកឡើងសម្តែងដោយបទថា **កតមេ** ព្រោះថា ត្រឹមពាក្យថា **ធម្មា កុសលា** បុគ្គលណាមួយ ក៏មិនអាចដឹងបានថាធ្វើអ្វីហើយ ឬថា រមែងធ្វើអ្វី តែកាលត្រាស់ពាក្យថា **កតមេ** ហើយ ភាពដែលធម៌ទាំងនោះដែលព្រះអង្គលើកមកសួរហើយ រមែងប្រាកដ ដោយហេតុនោះ ទើបខ្ញុំពោលថា ព្រះមានព្រះភាគ រមែងត្រាស់សួរក្នុងធម៌ ដែលគប្បីលើកឡើងសម្តែងដោយពាក្យថា **កតមេ** ។ ដោយពីរបទថា **ធម្មា កុសលា** ដូច្នេះ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ដែលត្រាស់សួរដោយសំណួរ ( ថា **កតមេ** ) ។ អត្ថនៃពាក្យថា **ធម្មា កុសលា** ទាំងនោះ ខ្ញុំបានចែកជាក់ច្បាស់ខាងដើមហើយ ។

សួរថា តើព្រោះហេតុអ្វី ក្នុងទីនេះមិនត្រាស់ពាក្យថា **កុសលា ធម្មា** ដូចក្នុងមាតិកាតែទ្រង់ធ្វើលំដាប់ពាក្យថា **ធម្មា កុសលា** ទៅវិញ ឆ្លើយថា

ដើម្បីសម្តែងទេសនាធម៌ទាំងឡាយដោយប្រភេទ ហើយសម្តែងធម៌ដែលចែកប្រភេទហើយ ដ្បិតថា ក្នុងអភិធម្មនេះ គប្បីសម្តែងចំពោះសភាវៈធម៌ ។ ធម៌ទាំងនោះ មានប្រភេទមិនមែនតិចដោយប្រភេទផ្សេងៗ មានកុសលជាដើម ព្រោះហេតុនោះ ក្នុងអភិធម្មនេះ គប្បីសម្តែងសភាវធម៌ទាំងឡាយប៉ុណ្ណោះ ទេសនានេះ មិនមែនសម្តែងដោយវោហារ ឯសភាវធម៌ទាំងនោះ គប្បីសម្តែងដោយប្រភេទផ្សេងៗ មិនមែនតិច មិនមែនសម្តែងត្រឹមតែធម៌ ព្រោះទេសនាដោយប្រភេទផ្សេងៗ រមែងនាំមកនូវញាណ ក្នុងការចែកជាក្រុម ជាដុំ និងញាណក្នុងបដិសម្ភិទា ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងទេសនាធម៌ទាំងឡាយ ដោយប្រភេទយ៉ាងនេះថា **កុសលា ធម្មា** ដូច្នេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម៌ដែលគប្បីសម្តែងដោយប្រភេទនោះៗ ទើបទ្រង់ធ្វើលំដាប់នៃបទនេះថា **កតមេ ធម្មា កុសលា** ដ្បិតថា កាលទ្រង់សម្តែងធម៌ទាំងឡាយដែលចែកប្រភេទហើយ ប្រភេទដែលទ្រង់សម្តែង រមែងត្រឹមត្រូវ និងគប្បីដឹងបានងាយ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ** ដូចតទៅ

> ព្រះមានព្រះភាគ ជាមុនី ទ្រង់សម្តែងចិត្តក្នុងសម័យ ដើម្បី
> កំណត់សម័យដោយចិត្ត សម្តែងធម៌ទាំងឡាយ ដោយប្រភេទ
> ក្នុងសម័យនោះ ដូច្នេះ ។

ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា **យស្មឹ សមយេ**

**កាមាវចរំ កុសលំ ចិត្តំ** ជាដើម ក៏ឈ្មោះថា ទ្រង់សម្ដែងចិត្តក្នុងសម័យ ។ ព្រោះហេតុអ្វី ព្រោះដើម្បីទ្រង់កំណត់សម័យ យ៉ាងនេះថា **តស្មឹ សមយេ** ក្នុងកាលជាទីបំផុតដោយចិត្តដែលកំណត់សម័យនោះ ដូច្នេះហើយ ក៏ឲ្យដឹងធម៌ទាំងឡាយនោះ មានផស្សៈ និងវេទនាជាដើម ដែលជាប្រភេទដែលដឹងតាមបានដោយក្រ ដោយអំណាចនៃសន្តតិ សមូហៈ កិច្ច អារម្មណ៍ និងឃនៈ ក្នុងសម័យដែលទ្រង់កំណត់ចិត្តនោះ យ៉ាងនេះថា សូម្បីកាលមានសម័យផ្សេងគ្នា បើសម័យណាមានចិត្ត សម័យនោះឯង ផស្សៈក៏មាន វេទនាក៏មាន ។

ឥឡូវនេះ ការពណ៌នាតាមលំដាប់បទ ក្នុងពាក្យថា **យស្មឹ សមយេ** ជាដើមនេះដូចតទៅ

បទថា **យស្មឹ** ជាអត្ថសម្ដែងដល់សត្តមីវិភត្តិ ដោយមិនពិតប្រាកដ ។ បទថា **សមយេ** ជាពាក្យសម្ដែងដល់សម័យ ដែលសម្ដែងដោយមិនកំណត់ ។ ទ្រង់សម្ដែងសម័យដោយមិនកំណត់ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ក្នុងពាក្យថា **យស្មឹ សមយេ** នោះ **សមយ** សព្ទ លោកប្រើក្នុងអត្ថថា

> ព្រមព្រៀង ខណៈ កាល ការប្រជុំ ហេតុ ទិដ្ឋិ ការបាន
> ចំពោះ ការលះ ការចាក់ធ្លុះ ។

ពិតហើយ **សមយ** សព្ទនោះ ប្រើក្នុងអត្ថថា **ព្រមព្រៀង** ដូចក្នុងប្រយោគជាដើមថា **អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច**

**សមយញ្ច ឧទានាយ** បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក ដូច្នេះ ។

ប្រើក្នុងអត្ថថា **ខណៈ** ដូចក្នុងប្រយោគជាដើមថា **ឯកោវ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យនៃការនៅប្រព្រឹត្តព្រហ្មចារ្យមានតែមួយ ដូច្នេះ ។

ប្រើក្នុងអត្ថថា **កាល** ដូចក្នុងប្រយោគជាដើមថា **ឧណ្ហសមយោ បរិឡាហសមយោ** សម័យក្តៅ សម័យស្អុះស្អាប់ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ការប្រជុំ** ដូចក្នុងប្រយោគជាដើមថា **មហាសមយោ បវនស្មឹ** ថ្ងៃនេះជាថ្ងៃប្រជុំធំក្នុងដងព្រៃធំ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ហេតុ** ដូចក្នុងប្រយោគជាដើមថា **សមយោបិ ខោ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ ភគវា ខោ សាវត្ថិយំ វិហរតិ ភគវាបិ មំ ជានិស្សតិ ភទ្ទាលិ នាម ភិក្ខុ សត្ថុសាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ** ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ព្រះមានព្រះភាគគង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជាហេតុដែលអ្នកមិនបានដឹង ដូច្នេះ ។

ប្រើក្នុងអត្ថថា **ទិដ្ឋិ** ដូចក្នុងប្រយោគជាដើមថា **តេន ខោ បន សម-យេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្ប-**

**វាទកេ តិន្ទុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ** សម័យនោះឯង បរិព្វាជកឈ្មោះឧគ្គាហមាន: ជាសមណមុណ្ឌិកាបុត្ត អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវទិដ្ឋិ ( លទ្ធិ ) ដូច្នេះ ។

ប្រើក្នុងអត្ថថា **ការបានចំពោះ** ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយកោ អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ** បណ្ឌិតជាអ្នកមិនប្រមាទ តែងបានចំពោះនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ណាក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ទាំងពីរនោះ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ការលះ** ដូចក្នុងប្រយោគជាដើមថា **សម្មា ឆាឆាភិ-សមយា អន្តមកាសិ ទុក្ខស្ស** ធ្វើនូវទីបំផុតកងទុក្ខដោយហេតុដែលបានលះបង់នូវមានះចោលដោយប្រពៃ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ការចាក់ធ្លុះ** ដូចក្នុងប្រយោគជាដើមថា **ទុក្ខស្ស បីឡ-ឆដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ** ទុក្ខមានអត្ថថា បៀតបៀន មានបច្ច័យតាក់តែង ធ្វើឲ្យក្តៅក្រហាយ ប្រែប្រួល និងគួរចាក់ធ្លុះ ដូច្នេះ ។ ក្នុង **សមយ** សព្ទ ដែលមានអត្ថច្រើនយ៉ាង ដូចពោលមកនេះ

**សមយ** សព្ទ ក្នុងអធិការនេះ វិញ្ញូជនគប្បីជ្រាបថា មក

ដោយអត្ថ ៥ យ៉ាង គឺការព្រមព្រៀង ១ ខណៈ ១ កាល ១ ការប្រជុំ ១ ហេតុ ១ ។

ពិតហើយ បណ្ដា **សមយ** សព្ទ ទាំង ៩ យ៉ាងនោះ ក្នុងអធិការពោលដោយកុសលនេះថា **យស្មឹ សមយេ កាមាវចរំ កុសលំ** ដូច្នេះ បណ្ឌិតគប្បីជ្រាប **សមយ** សព្ទ ៥ មានការព្រមព្រៀងជាដើមតទៅ

បណ្ដា **សមយ** សព្ទទាំងនោះ ការព្រមព្រៀងនៃបច្ច័យ គប្បីជ្រាបថា ការព្រមព្រៀង ចំណែកខណៈទី ៩ គប្បីជ្រាបថាជាខណៈមួយដែរ ម្យ៉ាងទៀត ចក្កសូម្បីទាំង ៤ ក៏គប្បីជ្រាបថា ជាខណៈ ។

ពិតហើយ ការព្រមព្រៀងនៃបច្ច័យទាំងឡាយ ដែលតាំងនៅដោយភាពជាហេតុ ដែលញ៉ាំងផលទូទៅឲ្យសម្រេចនោះ បណ្ឌិតគប្បីជ្រាបថា ជាការព្រមព្រៀងក្នុងទីនេះ ។ ចំណែកខណៈទី ៩ ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យនៃការនៅប្រព្រឹត្តព្រហ្មចារ្យមានតែមួយ ដូច្នេះ គប្បីជ្រាបថា ជាខណៈមួយ ។ ម្យ៉ាងទៀត ចក្ក ៤ គឺ **បដិរូបទេសវាសោ** ការនៅក្នុងប្រទេសដ៏សមគួរ ១ **សប្បុរិសូបនិស្សយ** ការសេពគប់សប្បុរស ១ **អត្តសម្មាបណិធិ** ការតម្កល់ខ្លួនដោយប្រពៃ ១ **បុព្វេកតបុញ្ញតា** ភាពជាអ្នកមានបុណ្យ ធ្វើទុកហើយក្នុងកាលមុន ១ ។

ដែលព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) នេះ

ថា ម្នាលភិក្ខុទាំងឡាយ ចក្កនេះមាន ៤ ចក្ក ៤ តែងប្រព្រឹត្តទៅ ( ដើម្បីជាប្រយោជន៍ ) ដល់ពួកទេវតា និងមនុស្ស ដែលប្រកបដោយចក្ក ដូច្នេះ គប្បីជ្រាបថា ជា **ខណៈ** ដោយអត្ថថា ព្រោះរួមចក្កទាំង ៤ នោះ ចូលគ្នាតែមួយ ដ្បិតថា ចក្កទាំង ៤ នោះ ជាឱកាសក្នុងការធ្វើកុសលឲ្យកើតឡើង ។ កាលជ្រាប **សមយ** សព្ទ គឺការព្រមព្រៀង និងខណៈយ៉ាងនេះហើយ បណ្ឌិតគប្បីជ្រាបពាក្យចន្លុលបង្ហាញក្នុង **សមយ** សព្ទទាំងឡាយ មានកាលជាដើមនេះតទៅ

កាលដែលបញ្ញត្តិហើយ ព្រោះអាស្រ័យធម៌នោះៗ ត្រឹមតែជាវោហារ គំនរនៃធម៌ មានផស្សៈជាដើម គប្បីជ្រាបថា ជាការប្រជុំ ។

បញ្ញត្តិ ឈ្មោះថា **កាល** ព្រោះអាស្រ័យធម៌នោះៗ យ៉ាងនេះ គឺព្រោះអាស្រ័យធម៌ទាំងឡាយដោយន័យជាដើមថា កាលនៃចិត្ត កាលនៃរូប ឬព្រោះអាស្រ័យការប្រព្រឹត្តិធម៌ដោយន័យជាដើមថា អតីត អនាគត ឬព្រោះអាស្រ័យលំដាប់នៃធម៌ដោយន័យជាដើមថា កាលនេះ ជាកាលនៃពូជ កាលនេះ ជាកាលនៃពន្លក ឬព្រោះអាស្រ័យលក្ខណៈនៃធម៌ដោយន័យជាដើមថា នេះជាកាលកើត នេះជាកាលចាស់ ឬព្រោះអាស្រ័យកិច្ចនៃធម៌ដោយន័យជាដើមថា កាលជាទីសោយអារម្មណ៍ កាលជាទីចាំអារម្មណ៍ ឬព្រោះអាស្រ័យកិច្ចដែលសត្វត្រូវធ្វើ ដោយន័យជាដើមថា នេះជាកាលងូតទឹក ជាកាលផឹកទឹក ឬព្រោះអាស្រ័យឥរិយាបថដោយន័យជាដើមថា កាលដែល

ដើរ កាលដែលឈរ ឬព្រោះអាស្រ័យការគោចររបស់ព្រះចន្ទ និងព្រះអាទិត្យជាដើមដោយន័យជាដើមថា កាល ( ពេល ) ព្រឹក ល្ងាច ថ្ងៃត្រង់ ពាក់កណ្តាលអធ្រាត្រ ឬព្រោះអាស្រ័យការប្រជុំនៃកាល ពោល គឺពេលថ្ងៃ និងពេលយប់ជាដើម ដោយន័យជាដើមថា កន្លះខែ មួយខែ ។ កាលនោះ បណ្ឌិតគប្បីជ្រាបថា ត្រឹមតែជាបញ្ញត្តិប៉ុណ្ណោះ ព្រោះមិនមានដោយសភាវៈ ។

ចំណែកពួកនៃធម៌ទាំងឡាយ មានផស្សៈ និងវេទនាជាដើមនោះ លោកចង្អុលបង្ហាញថា ជាការប្រជុំ ក្នុងអធិការនេះ ។ កាលជ្រាប **សមយ** សព្ទ ដែលប្រើក្នុងអត្ថថា **កាល និងការប្រជុំ** យ៉ាងនេះហើយ គប្បីជ្រាប **សមយ** សព្ទ ដែលប្រើក្នុងអត្ថថា **ហេតុ** ដូចតទៅនេះ

> ក្នុង **សមយ** សព្ទនេះ បច្ច័យ ឈ្មោះថា ហេតុ បណ្ឌិត
> គប្បីជ្រាបភាពដែលហេតុនោះមានច្រើនយ៉ាង ដោយអំណាច
> ទ្វារ ឬដោយអំណាចបច្ច័យទាំងឡាយ ។

ពិតហើយ ក្នុងអធិការនេះ បច្ច័យនុ៎ះឯង ឈ្មោះថា **ហេតុ** បណ្ឌិតគប្បីជ្រាបភាពដែលហេតុនោះមានច្រើនយ៉ាង ដោយអំណាចនៃទ្វារ ឬបច្ច័យទាំងឡាយ ។ គប្បីជ្រាបយ៉ាងដូចម្តេច ។ ពិតហើយ ព្រះមានព្រះភាគត្រាស់បច្ច័យទាំងឡាយមានចក្ខុ រូប អាលោកៈ និងមនសិការជាដើមនៃចក្ខុវិញ្ញាណជាដើម ដែលកើតឡើងក្នុងចក្ខុទ្វារជាដើម និងត្រាស់បច្ច័យ ២៤ ក្នុងមហាបករណ៍ដោយន័យជាដើមថា **ហេតុប្បច្ចយោ** ដូច្នេះ ។ បណ្តាបច្ច័យទាំងនោះ វៀរលែងវិបាកប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ បច្ច័យដ៏សេស ជា

បច្ច័យដល់កុសលធម៌ទាំងអស់ ។ តែក្នុងអធិការនេះ លោកបំណងយកធម៌ទាំងអស់នោះជាហេតុ បណ្ឌិតគប្បីជ្រាបថា ហេតុនោះ មានបច្ច័យច្រើនយ៉ាងដោយអំណាចនៃទ្វារ ឬដោយអំណាចនៃបច្ច័យនេះយ៉ាងនេះ ។ អត្ថទាំង ៥ មានការព្រមព្រៀងជាដើមទាំងនេះ គប្បីជ្រាបថា លោកកំណត់ដោយ **សមយ** សព្ទ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

បើមានពាក្យសួរថា ព្រោះហេតុអ្វី ក្នុងអត្ថទាំងនេះ លោកមិនកំណត់យកអត្ថណាមួយត្រឹមតែមួយ តែកំណត់យកទាំងអស់ ។ ឆ្លើយថា ព្រោះសម្តែងអត្ថដែលផ្សេងពីគ្នានោះៗ ដោយ **សមយ** សព្ទនោះៗ ។

ពិតហើយ បណ្តា **សមយ** សព្ទទាំងនោះ **សមយ** សព្ទ ពោល គឺការព្រមព្រៀង រមែងសម្តែងដល់ការប្រព្រឹត្តិទៅដោយហេតុ មិនមែនតិចដោយ **សមយ** សព្ទនោះ រមែងមានការបដិសេធវាទៈ ដែលមានហេតុមួយ ។ ធម្មតាការព្រមព្រៀង រមែងសំដៅដល់វត្ថុដែលអាស្រ័យគ្នានិងគ្នាក្នុងការញ៉ាំងផលទូទៅឲ្យសម្រេច ព្រោះហេតុនោះ ទើបលោកសម្តែងអត្ថនេះថា ឈ្មោះថា **អ្នកសាងតែម្នាក់ រមែងមិនមាន** ។ ដោយសភាវៈកាលអ្នកសាងមាន មិនគួរសម្ទឹងដល់ហេតុដទៃ ព្រោះហេតុនោះ ដោយលក្ខណៈយ៉ាងនេះ ជាការបដិសេធពាក្យជាដើមថា សុខ និងទុក្ខដែលខ្លួនធ្វើខ្លួនឯង ដោយសម្តែងដល់ភាពមិនមានអ្នកធ្វើត្រឹមតែម្នាក់នោះ ។

ក្នុងពាក្យដែលពោលមកហើយនោះ បើមានពាក្យចោទសួរថា ពាក្យណាដែលពោលហើយថា ៤ រមែងសម្តែងដល់ការប្រព្រឹត្តិទៅដោយហេតុ

មិនមែនតិច ពាក្យ ៣ នោះ មិនត្រូវ ព្រោះហេតុអ្វី ព្រោះធម៌ដែលមិនមែនជាហេតុក្នុងការមិនព្រមព្រៀងគ្នា ក៏មិនដល់នូវភាពជាហេតុក្នុងការព្រមព្រៀង ពិតហើយ កាលមនុស្សខ្វាក់ម្នាក់មិនអាចឃើញ មនុស្សខ្វាក់ខ្វាក់រាប់រយនាក់ក៏មិនឃើញ ។

គួរឆ្លើយថា មិនមែនមិនត្រូវ ។ ភាពដែលហេតុទាំងឡាយ ប្រកបគ្នាឈ្មោះថា ការព្រមព្រៀង ព្រោះញុំាងផលដែលកើតអំពីហេតុ រួមគ្នាឲ្យសម្រេច មិនមែនត្រឹមតែការប្រជុំនៃហេតុមិនមែនតិចនោះឡើយ ។ ឈ្មោះថា ការឃើញរបស់មនុស្សខ្វាក់ខ្វាក់ទាំងឡាយ មិនមែនផលដែលកើតអំពីការរួមគ្នា ។ ព្រោះហេតុអ្វី ព្រោះទោះបីមានមនុស្សខ្វាក់ខ្វាក់រាប់រយ ការឃើញនោះក៏មានមិនបាន ។ ការឃើញនោះ ជាផលកើតអំពីហេតុរួមគ្នានៃហេតុទាំងឡាយ មានចក្ខុជាដើម ព្រោះកាលមានចក្ខុទាំងនោះជាដើម ទើបការឃើញមាន ។ មួយវិញទៀត ធម៌មិនជាហេតុក្នុងការមិនព្រមព្រៀង ក៏ជាហេតុក្នុងការព្រមព្រៀងបាន ។ សេចក្តីនេះ គប្បីជ្រាបដោយការមិនមានផលក្នុងការមិនព្រមព្រៀង តែមានផលក្នុងការព្រមព្រៀង ព្រោះថា កាលចក្ខុជាដើមខ្វះខាត ចក្ខុវិញ្ញាណជាដើមក៏មានមិនបានដែរ និងកាលចក្ខុជាដើមមិនខ្វះខាត ទើបចក្ខុវិញ្ញាណជាដើមសម្រេចយ៉ាងប្រចក្សដល់សត្វលោក នេះជាការសម្តែងអត្ថដោយ **សមយ** សព្ទ គឺការព្រមព្រៀងជាមុន ។

ចំណែកខណៈទី ៩ ដែលវៀរហើយចាកអខណៈ ៨ និងខណៈ ព្រោះអត្ថថា ឱកាស ពេល គឺចក្ក ៤ មានការនៅក្នុងប្រទេសដ៏សមគួរជាដើម

ដែលពោលហើយឯណា ខណៈនោះ វៀរការព្រមព្រៀងនៃខណៈមានភាពជាមនុស្ស ការឧប្បត្តិកឡើងនៃព្រះពុទ្ធ ការស្ដាប់ព្រះសទ្ធម្ម និងសម្មាទិដ្ឋិជាដើម រមែងមានមិនបាន ។ ភាពជាមនុស្សជាដើម ជាភាវៈដែលបានដោយក្រដោយការឧបមា ដោយអណ្ដើកខ្វាក់ជាដើម កុសលដែលជាឧបការៈដល់លោកុត្តរធម៌ទាំងឡាយ ដែលប្រកបដោយខណៈ ដោយល្អក្រៃលែង ជារបស់ដែលរកបានដោយក្រពិត ព្រោះខណៈ ជារបស់រកបានដោយក្រ ដូចពណ៌នាមក ដូច្នេះ ។

បណ្ដា **សមយ** សព្ទ តាមដែលពោលហើយនោះ **សមយ** សព្ទ ពោល គឺខណៈ រមែងសម្ដែងថា កុសលកើតឡើងបានដោយក្រ ។ ពោលដោយឋានៈដែលសម្ដែងយ៉ាងនេះ រមែងជាការដែលលោកបដិសេធការនៅដោយសេចក្ដីប្រមាទរបស់ជន ដែលបាននូវខណៈហើយ ធ្វើខណៈឲ្យជាមោឃៈ ដោយមិនព្យាយាមសាងកុសលនោះ ដែលប្រកបដោយខណៈ ។ នេះជាការសម្ដែងអត្ថដោយ **សមយ** សព្ទ គឺខណៈ ។

ធម្មតាការប្រព្រឹត្តិទៅរបស់កុសលចិត្តនេះ ជារបស់តិចក្រៃលែង ឯការដែលកុសលចិត្តនោះ ជារបស់តិចក្រៃលែងនោះ គប្បីជ្រាបដោយអំណាចនៃអដ្ឋកថាព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ សម្ទុះនៃបុរសនោះយ៉ាងណាក្ដី សម្ទុះនៃព្រះចន្ទ និងព្រះអាទិត្យទាំងឡាយយ៉ាងណាក្ដី សម្ទុះនៃទេវតាទាំងឡាយ ដែលស្ទុះទៅអំពីខាងមុខព្រះចន្ទ និងព្រះអាទិត្យយ៉ាងណាក្ដី អាយុសង្ខារទាំងឡាយ រមែងអស់ទៅឆាប់រហ័សជាងសម្ទុះទាំងនោះទៅទៀត[១]

១- បិ. ៣២ ទំ. ២៦២ ។

ដូច្នេះ ។ ពិតហើយ សូត្រនេះ ព្រះមានព្រះភាគត្រាស់កាលតិចតួចរបស់រូបជីវិតិន្ទ្រិយមុន ។ រូបបច្ចុប្បន្នតាំងនៅត្រឹមណា ចិត្ត ១៦ ដួងកើតឡើងហើយរលត់ត្រឹមនោះ ។ សូម្បីការឧបមាដោយការដែលចិត្តទាំងនោះ ជារបស់មានកំណត់កាលតិចតួច រមែងមិនមាន ដោយប្រការដូច្នេះ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ កើតឡើង និងរលត់ទៅរហ័សក្រៃពេក មិនងាយនឹងធ្វើឧបមាបានឡើយ ដូច្នេះ ។ បណ្តា **សមយ** សព្ទទាំងនេះ **សមយ** សព្ទ ពោល គឺកាល រមែងសម្តែងដល់ភាពតិចតួចក្រៃលែងនៃកាលដែលប្រព្រឹត្តទៅនៃកុសលចិត្ត ដោយប្រការដូច្នេះ ។ ពោលដោយឋានៈដែលទ្រង់សម្តែងយ៉ាងនេះ ចិត្តនេះ ចាក់ធ្លុះបានដោយកម្រ ដូចការដោតកែវមុក្តា ដោយអាស្រ័យពន្លឺនៃផ្លេកបន្ទោរ ព្រោះកុសលចិត្តមានវេលាប្រព្រឹត្តទៅតិចក្រៃលែង ព្រោះហេតុនោះ ទើបទ្រង់ប្រទានឱវាទថា អ្នកទាំងឡាយ គប្បីធ្វើសេចក្តីឧស្សាហៈធំ និងសេចក្តីអើពើក្នុងការចាក់ធ្លុះចិត្តនេះ ដូច្នេះ ។ នេះជាការសម្តែងអត្ថ ដោយ **សមយ** សព្ទ គឺកាល ។

ចំណែក **សមយ** សព្ទ ពោល គឺការប្រជុំ រមែងសម្តែងការកើតឡើងព្រមគ្នានៃធម៌សូម្បីមិនមែនតិច ពិតហើយ គំនរនៃធម៌ មានផស្សៈជាដើម លោកពោលថា ការប្រជុំ ដូច្នេះ ។ មួយទៀត ចិត្តដែលកើតឡើងក្នុងគំនរនៃធម៌នោះ រមែងកើតឡើងព្រមជាមួយធម៌ទាំងនោះ ព្រោះហេតុនោះ ទើបលោកសម្តែងការកើតឡើងព្រមគ្នានៃធម៌មិនមែនតិច ។ ពោលដោយ

ឋានៈដែលសម្ដែងយ៉ាងនេះ ជាការបដិសេធការកើតឡើងនៃធម៌តែមួយទុំះឯង ។ នេះជាការសម្ដែងអត្ថ ដោយ **សមយ** សព្ទ គឺការប្រជុំ ។

ចំណែក **សមយ** សព្ទ ពោល គឺហេតុ រមែងសម្ដែងការប្រព្រឹត្តិទៅដែលប្រកបដោយធម៌ដទៃ ។ ពិតហើយ បទថា **យស្មឹ សមយេ** មានអធិប្បាយថា កាលបើហេតុយ៉ាងណាមាន កុសលចិត្ត រមែងកើតឡើងព្រោះហេតុនោះ កាលហេតុយ៉ាងនោះមាន ទើបសម្ដែងភាពដែលកុសលចិត្តប្រព្រឹត្តទៅ ដោយអាស្រ័យហេតុដទៃ ព្រោះមានហេតុដែលប្រព្រឹត្តទៅ ។ ពោលដោយឋានៈដែលសម្ដែងយ៉ាងនេះ ជាការបដិសេធការសម្គាល់ខុសថា ធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបាន ។ នេះជាការសម្ដែងអត្ថដោយ **សមយ** សព្ទ គឺហេតុ ។

បណ្ដាបទទាំងនោះ បទថា **យស្មឹ សមយេ** បានដល់ ក្នុងកាលណាដោយអំណាចនៃ **សមយ** សព្ទ គឺកាល អធិប្បាយថា ក្នុងការប្រជុំណាដោយអំណាចនៃ **សមយ** សព្ទ គឺការប្រជុំ ។ គប្បីជ្រាបអត្ថនៃ **សមយ** សព្ទទាំងឡាយ គឺខណៈ ការព្រមព្រៀង និងហេតុថា កាលខណៈណា ការព្រមព្រៀងណា ហេតុណាមាន កាមាវចរកុសលចិត្ត រមែងកើតឡើង កាលខណៈជាដើមនោះឯងមាន ធម៌ទាំងឡាយ មានផស្សៈជាដើម ក៏កើតឡើង ។ **សមយ** ពោល គឺកាល និងការប្រជុំជាទីទទួលនៃធម៌ ដែលត្រាស់ក្នុងចិត្តុប្បាទកណ្ឌ ព្រោះហេតុនោះ ទើបសម័យ ក្នុង **សមយ** សព្ទ ពោល គឺកាល និងការប្រជុំនេះ ធ្វើជាសត្តមីវិភត្តិដោយអំណាចជាទីទទួល ។ ម្យ៉ាង

ទៀត កិរិយានៃផស្សៈជាដើមនោះ កំណត់បានដោយកិរិយានៃសម័យ ពោល គឺខណៈ ការព្រមព្រៀង និងហេតុ ព្រោះហេតុនោះ ទើបសម័យក្នុង **សមយ** សព្ទ ពោល គឺខណៈ ការព្រមព្រៀង និងហេតុនេះ ធ្វើជាសត្តមីវិភត្តិដោយអំណាចកំណត់កិរិយាដោយកិរិយា ។

បទថា **កាមាវចរំ** បានដល់ ចិត្តដែលទាក់ទងក្នុងកាមាវចរធម៌ទាំងឡាយ ដែលត្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ដោយន័យជាដើមថា ពួកធម៌ជាកាមាវចរ តើដូចម្តេច ។ ខាងក្រោមកំណត់យកអវីចិនរកជាទីបំផុត ខាងលើកំណត់យកបរនិម្មិតវសវត្តីទេវលោកជាទីបំផុត ដូច្នេះ ។ ក្នុងកាមាវចរនោះ មានអត្ថនៃពាក្យដូចតទៅនេះ

ពោលដោយសង្ខេប កាមមាន ២ គឺវត្ថុកាម និងកិលេសកាម ។ បណ្តាកាមទាំង ២ នោះ ពោលដោយអត្ថ កិលេសកាម បានដល់ ឆន្ទរាគៈ វត្ថុកាម បានដល់ វដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ មួយទៀត ក្នុងកាមទាំងនោះ កិលេសកាម ឈ្មោះថា **កាម** ព្រោះអត្ថថា ប្រាថ្នា ។ វត្ថុកាម ឈ្មោះថា **កាម** ព្រោះអត្ថថា វត្ថុដែលគេប្រាថ្នា ។ កាមទាំង ២ យ៉ាងនោះ រមែងត្រាច់ទៅក្នុងប្រទេសណាដោយអំណាចនៃការប្រព្រឹត្តិទៅ ប្រទេសនោះ មាន ១១ គឺអបាយភូមិ ៤ មនុស្សភូមិ ១ ទេវលោក ៦ ។ កាមរមែងត្រាច់ទៅក្នុងប្រទេសនេះ ព្រោះហេតុនោះ ទើបប្រទេសនេះ ឈ្មោះថា **កាមាវចរ** ដូចទីជាទីត្រាច់ទៅជាមួយពួកឈ្មួញរទេះ ។ ដូចបុគ្គលដែលទៅជាមួយពួកឈ្មួញរទេះ រមែងត្រាច់ទៅក្នុងប្រទេសណា ប្រទេស

នោះ លោកហៅថា ទីជាទីត្រាច់ទៅជាមួយនឹងពួកឈ្មួញរទេះ ព្រោះទោះបីមានសត្វជើង ២ ជើង ៤ ពួកដទៃត្រាច់ទៅផង លោកក៏កំណត់ចំពោះជនដែលត្រាច់ទៅទាំងនោះយ៉ាងណា ប្រទេសនេះ លោកក៏ហៅថា កាមាវចរប៉ុណ្ណោះ ព្រោះកាលរូបាវចរជាដើមពួកដទៃត្រាច់ទៅក្នុងប្រទេសនោះ លោកក៏កំណត់យកចំពោះកាមាវចរទាំងនោះប៉ុណ្ណោះ យ៉ាងនោះដែរ ។ កាមនេះ លោកហៅថា កាមប៉ុណ្ណោះ ព្រោះលុបបទក្រោយចេញ ដូចរូបភព លោកហៅថា រូប ។ ចិត្តនេះ រមែងត្រាច់ទៅក្នុងកាម ពោល គឺប្រទេស ១១ នេះ ព្រោះហេតុនោះ ទើបហៅថា **កាមាវចរ** ដោយប្រការដូច្នេះ ។

ពិតហើយ ចិត្តនេះ រមែងត្រាច់ទៅក្នុងរូបភព និងអរូបភពបានខ្លះក៏ពិត តែដំរីធំដែលបានឈ្មោះថា ដំរីចម្បាំង ព្រោះឈមចុះកាន់សង្គ្រាម សូម្បីដំរីនោះត្រាច់ទៅក្នុងនគរ គេក៏ហៅថា ដំរីចម្បាំងនោះឯង សត្វចំនួនច្រើនដែលត្រាច់ទៅលើគោក និងក្នុងទឹក សូម្បីនៅក្នុងទីមិនមែនគោក និងមិនមែនទឹក គេក៏ហៅថា សត្វគោក និងសត្វទឹក យ៉ាងណា ចិត្តនេះ សូម្បីត្រាច់ទៅក្នុងទីដទៃៗ ក៏គប្បីជ្រាបថា ជាកាមាវចរ ( ត្រាច់ទៅក្នុងកាម ) យ៉ាងនោះដូចគ្នា ។ម្យ៉ាងទៀត កាមរមែងត្រាច់ទៅក្នុងចិត្តនេះ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ចិត្តនេះ ក៏ហៅថា កាមាវចរ ។ កាមនោះរមែងត្រាច់ទៅ សូម្បីក្នុងរូបភព និងអរូបភពក៏ពិតមែនហើយ ទោះបីជាដូច្នោះក៏គប្បីជ្រាបឧបមានេះ ដូចគេពោលថា សត្វដែលឈ្មោះថា **កូនគោ** ព្រោះភេទ ដែលឈ្មោះថា **ក្របី** ព្រោះដេកនៅលើផែនដី សត្វមានចំនួនប៉ុនណា

ទោះរោទ៍ក្តី ដេកលើផែនដីក្តី សត្វទាំងអស់នោះ មិនមានឈ្មោះយ៉ាងនោះទេ ។ម្យ៉ាងវិញទៀត ចិត្តណា រមែងត្រាច់ទៅកាន់បដិសន្ធិក្នុងកាម ពោលគឺកាមភព ព្រោះហេតុនោះ ទើបចិត្តនោះ ឈ្មោះថា **កាមាវចរ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **កុសលំ** ដូចតទៅ ឈ្មោះថា **កុសល** ដោយអត្ថទាំងឡាយ មានការកាត់បង់បាបទាំងឡាយជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **កុសល** ដោយអត្ថថា មិនមានរោគ ដោយអត្ថថា មិនមានទោស និងដោយអត្ថថា កើតអំពីភាពឈ្លាស ។

បណ្ឌិតគប្បីជ្រាបចិត្ត ឈ្មោះថា **កុសល** ដោយអត្ថថា មិនមានរោគ ព្រោះមិនមានការសោប់សោល់ដោយកិលេស មិនមានជំងឺ គឺកិលេស មិនមានព្យាធិ គឺកិលេស ក្នុងអរូបធម៌ឡើយ ដូចពាក្យដែលលោកពោលថា ឈ្មោះថា **កុសល** ដោយអត្ថថា មិនមានរោគ ព្រោះមិនមានការសោប់សោល់ ព្រោះមិនមានរោគ ព្រោះមិនមានព្យាធិក្នុងរាងកាយ ដូចក្នុងពាក្យថា លោកដ៏ចម្រើន មានសេចក្តីសុខស្រួល ( មិនមានរោគ ) ទេឬ ។ ឯចិត្តឈ្មោះថា **កុសល** ដោយអត្ថថា មិនមានទោស ព្រោះការមិនមានទោសដែលគួរវៀរ គឺកិលេស ទោសដែលប្រទូស្ត គឺកិលេស និងទោសដែលក្រវល់ក្រវាយ គឺកិលេស ។ បញ្ញា លោកហៅថា កោសល្យ ( ភាពជាអ្នកឈ្លាស ) ។ ចិត្ត ឈ្មោះថា **កុសល** ដោយអត្ថថា កើតអំពីការឈ្លាស ព្រោះកើតអំពីបញ្ញា ឈ្មោះថា **កោសល្ល** ។

ចិត្តដែលសម្បយុត្តដោយបញ្ញា ចូរស្មេះទុកសិន ចិត្តដែលប្រាសចាក

បញ្ញា តើជាកុសលដូចម្តេច ចិត្តដែលប្រាសចាកបញ្ញានោះក៏ជាកុសលនោះឯង ដោយ **រុឡ្ហិ** សព្ទ ( ពាក្យពោលផ្សេងតែន័យផ្សេង ) ។ ដូចផ្ចិតដែលបុគ្គលធ្វើដោយកន្ទេលផែងជាដើម មិនបានធ្វើដោយស្លឹកត្នោត គេក៏ហៅថាផ្ចិតស្លឹកត្នោតនុ៎ះឯង ដោយ **រុឡ្ហិ** សព្ទ ព្រោះវត្ថុនោះដូចគ្នា យ៉ាងណា ចិត្តសូម្បីប្រាសចាកបញ្ញា បណ្ឌិតគប្បីជ្រាបថា ជាកុសលនោះឯង យ៉ាងនោះ ។ តែបើពោលដោយនិប្បរិយាយ ( ដោយត្រង់ ) ចិត្តដែលសម្បយុត្តដោយបញ្ញា បានឈ្មោះថា **កុសល** ដោយអត្ថ ៣ យ៉ាង គឺដោយអត្ថថា មិនមានរោគ ដោយអត្ថថា មិនមានទោស ដោយអត្ថថា កើតអំពីការឈ្លាស ។ ចិត្តដែលប្រាសចាកបញ្ញា បានឈ្មោះថា **កុសល** ដោយអត្ថ ២ យ៉ាង ( ខាងដើម ) ប៉ុណ្ណោះ ។ ព្រោះហេតុនោះ ចិត្តណា ដែលពោលហើយ ដោយការបរិយាយដល់ជាតកក្តី ដោយការបរិយាយដល់ពាហិរសូត្រក្តី ដោយការបរិយាយដល់ព្រះអភិធម្មក្តី ចិត្តទាំងអស់នោះ រមែងបានក្នុងចិត្តនេះ ដោយអត្ថទាំង ៣ ។

កុសលចិត្តនេះ ពោលដោយលក្ខណាទិចតុក្កៈ **អនវជ្ជសុខវិបាកលក្ខណំ** មានវិបាកជាសុខ ដែលមិនមានទោស ជាលក្ខណៈ **អកុសលវិទ្ធំសនរសំ** មានការកម្ចាត់បង់អកុសលជាកិច្ច **វោទានបច្ចុបដ្ឋានំ** មានសេចក្តីផូរផង់ជាបច្ចុប្បដ្ឋាន **យោនិសោមនសិការបទដ្ឋានំ** មានយោនិសោមនសិការ ជាបទដ្ឋាន **អនវជ្ជបទដ្ឋានំ វា** ឬមានការមិនមានទោសជាបទដ្ឋាន ។

ម្យ៉ាងទៀត **អនវជ្ជលក្ខណំ** ចិត្តដែលជាកុសលមានការមិនមានទោស

ជាលក្ខណៈនោះឯង ព្រោះជាបដិបក្ខចំពោះធម៌ដែលមានទោស **វោទាន ភាវរសំ** មានសេចក្ដីផូរផង់ជាកិច្ច **ឥដ្ឋវិបាកបច្ចុបដ្ឋានំ** មានវិបាកដែលគួរប្រាថ្នាជាបច្ចុប្បដ្ឋាន **យថាវុត្តបទដ្ឋានំ** មានធម៌តាមដែលពោលហើយនោះឯងជាបទដ្ឋាន ។

បណ្ដាលក្ខណៈជាដើម សភាវៈ ឬការស្មើគ្នានៃធម៌នោះៗ ឈ្មោះថា លក្ខណៈ នាទី ឬគុណសម្បត្តិ ឈ្មោះថា កិច្ច អាការប្រាកដ ឬផល ឈ្មោះថា បច្ចុប្បដ្ឋាន ហេតុជិត ឈ្មោះថា បទដ្ឋាន ហេតុនោះ ខ្ញុំពោលលក្ខណៈជាដើម ក្នុងទីណា គប្បីជ្រាបការផ្សេងគ្នានៃលក្ខណៈជាដើមនោះដោយន័យនេះឯង ក្នុងទីនោះៗ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចិត្តំ** ដូចតទៅ

ធម្មជាតដែលឈ្មោះថា **ចិត្ត** ព្រោះអត្ថថា គិតនូវអារម្មណ៍ គឺដឹងច្បាស់ ។ ម្យ៉ាងទៀត សព្ទថា **ចិត្ត** នេះ ទូទៅដល់ចិត្តទាំងពួង ព្រោះហេតុនោះ ក្នុងបទថា **ចិត្តំ** នេះ ចិត្តណាជាកុសល អកុសល និងមហាកិរិយាចិត្ត ជាលោកិយ ចិត្តនោះឈ្មោះថា **ចិត្ត** ព្រោះអត្ថថា រមែងសន្សំសន្តានរបស់ខ្លួនដោយអំណាចនៃជវនវិថី ។ ឈ្មោះថា **ចិត្ត** ព្រោះអត្ថថា ជាវិបាកដែលកម្ម និងកិលេសទាំងឡាយសន្សំហើយ ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទថា **ចិត្តំ** នេះ យ៉ាងនេះថា ចិត្តទាំងអស់ ឈ្មោះថា **ចិត្ត** ព្រោះភាពជាធម្មជាតវិចិត្រតាមសមគួរ ។ ឈ្មោះថា **ចិត្ត** ព្រោះធ្វើឲ្យវិចិត្រ ។ បណ្ដាចិត្តទាំងនោះ ចិត្តមានរាគៈម្យ៉ាង ចិត្តមានទោសៈម្យ៉ាង ចិត្តមានមោហៈ

ម្យ៉ាង ចិត្តជាកាមាវចរម្យ៉ាង ចិត្តជារូបាវចរជាដើមក៏ម្យ៉ាង ចិត្តមានរូបជាអារម្មណ៍ម្យ៉ាង ចិត្តមានសំឡេងជាដើមជាអារម្មណ៍ក៏ម្យ៉ាង បណ្តាចិត្តដែលមានរូបជាអារម្មណ៍ ចិត្តដែលមានពណ៌ខៀវ ជាអារម្មណ៍ម្យ៉ាង ចិត្តដែលមានពណ៌លឿងជាដើមជាអារម្មណ៍ក៏ម្យ៉ាង សូម្បីចិត្តដែលមានសំឡេងជាដើមជាអារម្មណ៍ ក៏ន័យនេះឯង ។ ក្នុងចិត្តទាំងអស់នោះ ហីនចិត្តម្យ៉ាង មជ្ឈិមចិត្តម្យ៉ាង បណីតចិត្តម្យ៉ាង ក្នុងចិត្តដែលជាហីនចិត្តជាដើម ចិត្តដែលមានឆន្ទៈជាអធិបតីម្យ៉ាង ចិត្តដែលមានវីរិយៈជាអធិបតីម្យ៉ាង ចិត្តដែលមានចិត្តជាអធិបតីម្យ៉ាង ចិត្តមានវីមំសាជាអធិបតីម្យ៉ាង ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ចិត្តនេះ ជាធម្មជាតវិចិត្រ ដោយអំណាចនៃសម្បយុត្តធម៌ ភូមិ អារម្មណ៍ ហីនៈ មជ្ឈិម បណីត និងអធិបតីទាំងនេះ ។ បណ្តាចិត្តទាំងនេះ ចិត្តនោះ ជាចិត្តតែមួយនោះឯងក៏មិនមែនក៏ពិត តែព្រោះភាពវិចិត្រទាំងឡាយសង្គ្រោះចូលក្នុងខាងក្នុង សូម្បីចិត្តមួយដួង ដួងណាមួយ បណ្តាចិត្តទាំងឡាយនេះ ក៏គួរហៅថា ចិត្ត ព្រោះជាធម្មជាតវិចិត្រ ។ ឈ្មោះថា ចិត្ត ព្រោះភាពវិចិត្រយ៉ាងនេះ ។

ឈ្មោះថា **ចិត្ត** ព្រោះធ្វើឲ្យវិចិត្រ តើដូចម្តេច ។ ពិតហើយ ឈ្មោះថា វិចិត្រដទៃក្រៃលែងជាងចិត្រកម្មមិនមានក្នុងលោក ។ ធម្មតាក្បូរក្បាច់ ក្នុងចិត្រកម្មនោះ ក៏ជាការវិចិត្រ គឺភាពស្រស់ស្អាតក្រៃលែង ។ ពួកវិចិត្រករកាលធ្វើចិត្រកម្មនោះ ក៏កើតសញ្ញាដ៏វិចិត្រថា រូបមានប្រការផ្សេងៗ អញគួរធ្វើយ៉ាងនេះក្នុងទីនេះ ដូច្នេះ ។ ការធ្វើដ៏វិចិត្រដែលសម្រេចហើយដោយ

កិច្ច មានការគូរ ការលាយពណ៌ ការធ្វើពណ៌ឲ្យមានពណ៌រុងរឿង និងការផ្លាស់ពណ៌ជាដើម រមែងកើតឡើងដោយសញ្ញាដ៏វិចិត្រ រូបដ៏វិចិត្រ យ៉ាងណាមួយក្នុងការវិចិត្រ ពោល គឺក្បូរក្បាច់ រមែងសម្រេចអំពីការធ្វើដ៏វិចិត្រនោះ ។ បន្ទាប់អំពីនោះ ព្រោះគិតថា រូបនេះ ចូរមានខាងលើនៃរូបនេះ រូបនេះ ចូរមានខាងក្រោម រូបនេះ ចូរមានត្រង់ខាងទាំងពីរ ដូច្នេះ ការសម្រេចនៃរូបដ៏វិចិត្រដ៏សេសដោយការធ្វើតាមគំនិត រមែងមាន សិប្បៈដ៏វិចិត្រក្នុងលោកឯណានីមួយ ទាំងអស់នោះ ដែលចិត្តនោះឯង ធ្វើដោយប្រការដូច្នេះ សូម្បីចិត្តដែលឲ្យសម្រេចភាពវិចិត្រនោះ ក៏ឈ្មោះថា **ចិត្ត** ដូចគ្នានោះឯង ព្រោះវិចិត្រនៃការធ្វើនេះ ដោយអាការយ៉ាងនេះ ។ម្យ៉ាងទៀត ចិត្តនុ៎ះឯងឈ្មោះថា វិចិត្រជាងចិត្រកម្មនោះ ព្រោះឲ្យសម្រេចចិត្រកម្មគ្រប់ប្រភេទតាមដែលគិត ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ រូបគំនូរ អ្នកទាំងឡាយបានឃើញហើយឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ រូបគំនូរនោះគេរចនាដោយការវិចិត្រ ជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះឯងវិចិត្រដោយវិសេសជាងរូបគំនូរដែលគេរចនា ដូច្នេះ ។

មួយទៀត ការវិចិត្រដែលប្រព្រឹត្តទៅខាងក្នុងមានដោយកម្ម ភេទ សញ្ញា និងវោហារជាដើម ក្នុងគតិទាំងឡាយ មានទេវតា មនុស្ស នរក និងសត្វតិរច្ឆាននេះឯណា ការវិចិត្រនោះ ក៏ចិត្តធ្វើឲ្យវិចិត្រហើយនោះឯង ។

ពិតហើយ កុសលកម្ម និងអកុសលកម្មដែលមាន កម្មមានកាយកម្មជា

ដើម ដែលប្រព្រឹត្តទៅដោយន័យ មានទាន សីល ការមិនបៀតបៀន និង ការមិនអួតអាងជាដើម សម្រេចហើយដោយចិត្ត ឈ្មោះថា មានការផ្សេង គ្នានៃកម្ម ។ សណ្ឋាននៃអវយវៈ មានដៃ ជើង ពោះ ក និងមុខជាដើមក្នុង គតិទាំងឡាយនោះៗ ផ្សេងគ្នាទៅដោយការផ្សេងគ្នានៃកម្មនុ៎ះឯង ឈ្មោះថា **ការផ្សេងគ្នានៃភេទ** ។ កាលសញ្ញាកើតឡើងថា នេះជាស្រី នេះជាប្រុស ដោយអំណាចនៃសណ្ឋាន តាមដែលកាន់យក ព្រោះការផ្សេងគ្នានៃភេទ ឈ្មោះថា **ការផ្សេងគ្នានៃសញ្ញា** ។ កាលជនទាំងឡាយហៅដោយពាក្យថា ស្រី ឬថា ប្រុសដោយសមគួរដល់សញ្ញា ព្រោះការផ្សេងគ្នានៃសញ្ញា ឈ្មោះ ថា **ការផ្សេងគ្នានៃវោហារ** ។ តែព្រោះហេតុដែលបុគ្គលធ្វើកម្មដែលឲ្យកើត អត្តភាពនោះៗ ដោយអំណាចនៃការផ្សេងគ្នានៃវោហារយ៉ាងនេះថា ខ្ញុំនឹងជា ស្រី ខ្ញុំនឹងជាប្រុស ខ្ញុំនឹងជាក្សត្រិយ៍ ខ្ញុំនឹងជាព្រាហ្មណ៍ ហេតុនោះ ទើប ឈ្មោះថា **ការផ្សេងគ្នានៃកម្ម** ព្រោះការផ្សេងគ្នានៃវោហារ ។ ព្រោះការ ផ្សេងគ្នានៃកម្មនោះៗ កាលនឹងញ៉ាំងភពតាមដែលប្រាថ្នាឲ្យកើតឡើង រមែង ឲ្យកើតឡើងដោយអំណាចគតិ ហេតុនោះ ទើបឈ្មោះថា **ការផ្សេងគ្នានៃគតិ** ព្រោះការផ្សេងគ្នានៃកម្ម ។

មួយទៀត ការដែលសត្វទាំងឡាយនោះៗ កើតជាសត្វមិនមានជើង និង សត្វជើង ២ ជាដើម ក្នុងគតិនោះៗ កើតជាសត្វខ្ពស់ និងទាបជាដើម ក្នុង កំណើតនោះៗ កើតជាអ្នកមានពណ៌សម្បុរល្អ និងសម្បុរអាក្រក់ជាដើម ក្នុង អត្តភាពនោះៗ ជាអ្នកមានលាភ និងមិនមានលាភជាដើម ក្នុងលោកធម៌ទាំង

ឡាយ រមែងប្រាកដ ព្រោះការផ្សេងគ្នានៃកម្មនុ៎ះឯង ព្រោះហេតុនោះ ការវិចិត្រដែលប្រព្រឹត្តទៅក្នុងខាងក្នុង មានកម្ម ភេទ សញ្ញា និងវោហារជាដើម ក្នុងគតិទាំងឡាយ មានទេវតា មនុស្ស នរក និងសត្វតិរច្ឆាន ទាំងអស់នុ៎ះឯង គប្បីជ្រាបថា ដែលចិត្តនោះឯង ធ្វើហើយ ។ សេចក្តីនេះ គប្បីជ្រាបដោយអំណាចព្រះសូត្រ ដែលនៅមិនទាន់ឡើងកាន់សង្គីតិនេះ ។ សមដូចដែលលោកពោលថា ការកំណត់ប្រភេទនៃការផ្សេងគ្នារបស់ភេទមានច្រើន រមែងមានដោយអំណាចនៃការកំណត់ប្រភេទនៃការផ្សេងគ្នានៃកម្ម ដែលមានច្រើន ការកំណត់ប្រភេទនៃការផ្សេងគ្នានៃសញ្ញាដែលមានច្រើន រមែងមានដោយអំណាចនៃការកំណត់ប្រភេទ នៃការផ្សេងគ្នា នៃភេទដែលមានច្រើន ការកំណត់ប្រភេទនៃការផ្សេងគ្នារបស់វោហារដែលមានច្រើន រមែងមានដោយអំណាចនៃការកំណត់ប្រភេទនៃការផ្សេងគ្នារបស់សញ្ញាដែលមានច្រើន ការកំណត់ប្រភេទនៃការផ្សេងគ្នានៃកម្មដែលមានច្រើន រមែងមានដោយអំណាចនៃការកំណត់ប្រភេទនៃការផ្សេងគ្នានៃវោហារដែលមានច្រើន ការផ្សេងគ្នានៃគតិរបស់សត្វទាំងឡាយ គឺមិនមានជើង មានជើង ២ មានជើង ៤ មានជើងច្រើន មានរូប មិនមានរូប មានសញ្ញា មិនមានសញ្ញា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន រមែងប្រាកដ ព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម ការផ្សេងគ្នានៃឧប្បត្តិរបស់សត្វទាំងឡាយ គឺខ្ពស់ ទាប ថោកទាប ប្រណីត ទៅកាន់សុគតិ និងទុគ្គតិ រមែងប្រាកដ ព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម ការផ្សេងគ្នាក្នុងអត្តភាពរបស់សត្វទាំងឡាយ គឺភាពជាអ្នកមានពណ៌

សម្បុរល្អ និងពណ៌សម្បុរអាក្រក់ ភាពជាអ្នកមានជាតិល្អ និងមិនល្អ ភាពជាអ្នកមានទ្រង់ទ្រាយល្អ និងមិនល្អ រមែងប្រាកដ ព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម ការផ្សេងគ្នាក្នុងលោកធម៌របស់សត្វទាំងឡាយ ក្នុងការមានលាភ ឥតលាភ មានយស ឥតយស និន្ទា សរសើរ សុខ និងទុក្ខ រមែងប្រាកដ ព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម ដូច្នេះ ។

នៅមានតទៅដទៃទៀត ព្រះមានព្រះភាគក៏ត្រាស់ថា

ភេទ រមែងប្រព្រឹត្តទៅព្រោះកម្ម សញ្ញា រមែងប្រព្រឹត្តទៅព្រោះភេទ សត្វទាំងឡាយ រមែងដល់នូវការផ្សេងគ្នា ព្រោះសញ្ញាថា នេះជាស្រី ឬជាប្រុស ដូច្នេះ ។

លោក ប្រព្រឹត្តទៅដោយកម្ម ពពួកសត្វ ប្រព្រឹត្តទៅដោយកម្ម សត្វទាំងឡាយ មានកម្មជាចំណង ( ហេតុ ) ដូចជាប្រែកទប់របស់រថ កាលប្រព្រឹត្តទៅ បុគ្គលរមែងបាននូវកិត្តិសព្ទដោយកម្ម បាននូវសេចក្តីសរសើរដោយកម្ម បាននូវសេចក្តីវិនាសផង បាននូវសេចក្តីបៀតបៀនផង បាននូវការជាប់ចំណងផង ក៏ដោយកម្ម បុគ្គលបានដឹងនូវកម្មនោះថា មានអំពើផ្សេងៗ គ្នាហើយ ហេតុអ្វីក៏និយាយថា កម្មមិនមានក្នុងលោក ដូច្នេះ ។

ម្នាលមាណព សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មាន

កម្មជាគ្រឿងវេញក កម្មតែងចែកសត្វទាំងឡាយ ដើម្បីឲ្យថោក ទាប និងខ្ពង់ខ្ពស់ ។ បណ្ឌិតគប្បីជ្រាបភាពនៃចិត្តជាធម្មជាត វិចិត្រព្រោះការវិចិត្រដោយការធ្វើ ដូចពណ៌នាមក ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបភាពដែលចិត្តជាធម្មជាតវិចិត្រ ព្រោះវិចិត្រដោយការធ្វើដូចពណ៌នាមកនេះ ។ ពិតហើយ ការវិចិត្រទាំងអស់នេះ ចិត្តនុ៎ះឯងក៏ធ្វើហើយ ។ ចិត្តនោះឯងជាធម្មជាតវិចិត្រ ជាងការវិចិត្រដែលប្រព្រឹត្តទៅខាងក្នុងដែលចិត្តធ្វើហើយ ដូចពោលមកហើយនោះ ព្រោះមិនមានការធ្វើភាពវិចិត្រណាមួយនៃចិត្ត ដែលមិនបានឱកាស ឬចិត្តដែលខ្វះខាតដោយបច្ច័យដ៏សេស ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាននេះដ៏វិចិត្រយ៉ាងណា ចិត្តណាដែលវិចិត្រយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញ សូម្បីនូវពួកធម៌មួយ ដទៃអំពីចិត្តនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆានទាំងនោះឯង តែងគិតដោយចិត្តដូចគ្នា ។ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះឯងវិចិត្រដោយវិសេស ជាងពួកសត្វតិរច្ឆាននោះ ដូច្នេះ ។

គប្បីជ្រាបវិគ្គហៈ ក្នុងពាក្យថា **ឧប្បន្នំ ហោតិ** នេះ ដូចតទៅនេះ

ឈ្មោះថា **ឧប្បន្ន** មានច្រើនប្រភេទ ដោយអំណាចនៃ**វត្តមានឧប្បន្ន ១ ភូតាបគតឧប្បន្ន ១ ឱកាសកតឧប្បន្ន ១ ភូមិលទ្ធឧប្បន្ន ១** ។

បណ្តាវត្ត មានឧប្បន្នជាដើមទាំងនោះ ធម្មជាតទាំងអស់ ពោល គឺ

សេចក្តីព្រមព្រៀងដោយការកើតឡើង ការចាស់ និងការរលត់ ឈ្មោះថា **វត្តមានឧប្បន្ន** ។ កុសល និងអកុសលដែលសោយរសនៃអារម្មណ៍ហើយរលត់ទៅ ពោល គឺសោយហើយ ក៏រលត់ទៅ កុសល និងអកុសលដែលចូលដល់ពួក ៣ មានឧប្បាទក្ខណៈជាដើម ហើយក៏រលត់ ពោល គឺកើតហើយក៏រលត់ទៅ កុសល និងអកុសល ដែលបច្ច័យប្រជុំតាក់តែងដ៏សេស ឈ្មោះថា **ភូតាបគតឧប្បន្ន** កម្មដែលពោលដោយន័យជាដើមថា កម្មទាំងឡាយណា ដែលធ្វើទុកហើយក្នុងកាលមុនជាដើម សូម្បីជាអតីត ក៏ឈ្មោះថា **ឱកាសកតឧប្បន្ន** ព្រោះហាមវិបាកដទៃ ហើយឲ្យឱកាសដល់វិបាករបស់ខ្លួន ហើយតាំងនៅ វិបាកដែលមានឱកាស ដែលធ្វើហើយយ៉ាងនោះ ទោះបីមិនទាន់កើតឡើង ក៏ឈ្មោះថា **ឱកាសកតឧប្បន្ន** ព្រោះគង់តែកើតឡើងពិតប្រាកដ ក្នុងកាលណាបានឱកាសយ៉ាងនោះ ។ អកុសលដែលមិនទាន់បានដកឡើង ក្នុងភូមិទាំងឡាយនោះៗ ឈ្មោះថា **ភូមិលទ្ធឧប្បន្ន** ។ បណ្ឌិតគប្បីជ្រាបសេចក្តីផ្សេងគ្នានៃភូមិ និងភូមិលទ្ធៈ ក្នុងពាក្យថា **ភូមិលទ្ធ-ឧប្បន្ន** ដូចតទៅ ខន្ធ ៥ ប្រព្រឹត្តទៅក្នុងភូមិ ៣ ជាអារម្មណ៍របស់វិបស្សនា ឈ្មោះថា **ភូមិ** កិលេសដែលគួរដល់ការកើតឡើងក្នុងខន្ធទាំងនោះ ឈ្មោះថា **ភូមិលទ្ធ** ( មានភូមិដែលបានហើយ ) ។ ពិតហើយ ភូមិទាំងនោះ ឈ្មោះថា **ដែលកិលេសនោះបានហើយ** ព្រោះហេតុនោះ ទើបលោកហៅថា ភូមិលទ្ធៈ ( មានភូមិដែលបានហើយ ) បណ្តាឧប្បន្ន ៤ តាមដែលពោលមកហើយយ៉ាងនេះ ក្នុងពាក្យថា **ឧប្បន្នំ ហោតិ** នេះ លោកបំណង

យកវត្ថុមានឧប្បន្ន ។

គប្បីជ្រាបវិនិច្ឆ័យសេចក្តីក្នុងពាក្យថា **ឧប្បន្នំ ហោតិ** ដូចតទៅនេះ

ធម៌ដែលឈ្មោះថា **ឧប្បន្ន** ព្រោះអត្ថថា ឃ្លាតចាកធម៌ចំណែកខាងដើម ( គឺអតីត ) ផ្ចោះមុខចំពោះឧប្បាទក្ខណៈជាដើម ។ **ឧប្បន្ន** សព្ទនេះ ប្រើក្នុងអត្ថច្រើនយ៉ាង គឺ**អតីត បានចំពោះ តាំងឡើងព្រម សង្កត់មិនបាន កាត់មិនបាន ដល់ខណៈទាំង ៣** ។

**ឧប្បន្ន** សព្ទនេះ ប្រើក្នុងអត្ថថា **អតីត** ដូចក្នុងប្រយោគជាដើមថា **តេន ខោ បន ភិក្ខវេ សមយេន កកុសន្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ** ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគ ព្រះនាមកកុសន្ធ-អរហន្តសម្មាសម្ពុទ្ធ បានកើតឡើងក្នុងលោក ក្នុងសម័យនោះដែរ ដូច្នេះ ។

ប្រើក្នុងអត្ថថា **បានចំពោះ** ដូចក្នុងប្រយោគជាដើមថា **អាយស្មតោ អានន្ទស្ស អតិរេកចីវរំ ឧប្បន្នំ ហោតិ** អតិរេកចីវរកើតឡើងដល់ព្រះអានន្ទដ៏មានអាយុ ដូច្នេះ ។

ប្រើក្នុងអត្ថថា **តាំងឡើងព្រម** ដូចក្នុងប្រយោគជាដើមថា **សេយ្យថាបិ ភិក្ខវេ ឧប្បន្នំ មហាមេឃំ តមេនំ មហាវាតោ អន្តរាយេវ អន្តរធាបេតិ** ម្នាលភិក្ខុទាំងឡាយ ខ្យល់ខ្លាំង រមែងញុំាងភ្លៀងធំដែលកើតឡើងនោះ ឲ្យវិនាសក្នុងចន្លោះទៅបាន ដូច្នេះ ។

ប្រើក្នុងអត្ថថា **សង្កត់មិនបាន** ដូចក្នុងប្រយោគជាដើមថា **ឧប្បន្នំ គមិកចិត្តំ ឧប្បជ្ជិតោនយំ** គមិកចិត្ត ( ចិត្តប្រាថ្នានឹងទៅ ) កើតឡើង

ហើយបន្ទោបង់បានដោយកម្រ ដូច្នេះ និងដូចប្រយោគជាដើមថា **ឧប្បន្នុ-ប្បន្នេ ចាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ** តែងញុំាង អកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើង ឲ្យសាបសូន្យទៅ ដោយទំនងដ៏សមគួរ ដូច្នេះ ។

ប្រើក្នុងអត្ថថា **កាត់មិនបាន** ដូចក្នុងប្រយោគជាដើមថា **អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ ចាបកេ អកុសលេ ធម្មេ ឋានសោ អន្តរាយេវ អន្តរធាបេតិ** ភិក្ខុកាលចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងញុំាងអកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងហើយ ឲ្យវិនាសក្នុងចន្លោះទៅបាន ដូច្នេះ ។

ប្រើក្នុងអត្ថថា **ដល់នូវខណៈទាំង ៣** ដូចក្នុងប្រយោគជាដើមថា **ឧប្បជ្ជមានំ ឧប្បន្នន្តិ អាមន្តា** ចិត្តកំពុងកើតឡើង ( ក៏មាន ) កើតឡើងហើយ ( ក៏មាន ) ឬ ។ អើ ។ ដូច្នេះ ។ សូម្បី **ឧប្បន្ន** សព្ទ ក្នុងទីនេះ ក៏គប្បីជ្រាបថា ប្រើក្នុងអត្ថថា ដល់ខណៈទាំង ៣ ប៉ុណ្ណោះ ព្រោះហេតុនោះ ក្នុងពាក្យថា **ឧប្បន្នំ ហោតិ** នេះ គប្បីជ្រាបសេចក្ដីសន្និដ្ឋានេះថា ដល់ខណៈទាំង ៣ គឺ កំពុងប្រព្រឹត្តទៅ បានដល់ បច្ចុប្បន្ន ។

ពាក្យថា **ចិត្តំ ឧប្បន្នំ ហោតិ** នេះ ជាប្រធាននៃទេសនាប៉ុណ្ណោះ ចិត្តសុទ្ធៗតែម្យ៉ាងប៉ុណ្ណោះ រមែងមិនកើតឡើង ។ ព្រោះហេតុនោះ កាលគេពោលថា ព្រះរាជាយាងមកហើយ ដូច្នេះ ព្រះរាជាទ្រង់លះបង់បរិស័ទហើយ

យានមកមួយព្រះអង្គឯងក៏មិនមែន តែតាមពិត រមែងប្រាកដថា យានមកជាមួយនឹងបរិស័ទនោះឯងយ៉ាងណា ចិត្តនេះក៏យ៉ាងនោះ បណ្ឌិតគប្បីជ្រាបថា កើតឡើងព្រមជាមួយនឹងកុសលធម៌ជាង ៥០ ដោយពិត ។ មួយទៀត ពាក្យថា **ចិត្តំ ឧប្បន្នំ ហោតិ** នេះ ព្រះមានព្រះភាគត្រាស់ ដោយអត្ថថាជាប្រធាន ។

ពិតហើយ សម្ដីដល់លោកិយធម៌ហើយ ចិត្តក៏ជាធំ ជាធុរៈ ជាប្រធាន តែសម្ដីដល់លោកុត្តរធម៌ហើយ បញ្ញាជាធំ ជាធុរៈ ជាប្រធាន ព្រោះហេតុនោះឯង ព្រះមានព្រះភាគ កាលត្រាស់សម្ដែងព្រះវិន័យសួរបញ្ហា ក៏មិនត្រាស់សួរថា អ្នកមានផស្សៈដូចម្ដេច មានវេទនាដូចម្ដេច មានសញ្ញាដូចម្ដេច មានចេតនាដូចម្ដេច រមែងត្រាស់សួរធ្វើចិត្តប៉ុណ្ណោះ ឲ្យជាធុរៈថា ម្នាលភិក្ខុ អ្នកមានសេចក្ដីគិតដូចម្ដេច ដូច្នេះ កាលភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានថេយ្យចិត្តគិតលួចទេ ដូច្នេះ ព្រះអង្គក៏មិនត្រាស់ថា មិនមានអាបត្តិដល់ភិក្ខុដែលមិនមានថេយ្យផស្សៈជាដើម តែទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនមានថេយ្យចិត្ត ឥតមានអាបត្តិអ្វីឡើយ ដូច្នេះ ។

មិនមែនចំពោះព្រះតម្រាស់ ក្នុងការសម្ដែងព្រះវិន័យតែម្យ៉ាងប៉ុណ្ណោះទេ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងលោកិយទេសនាដទៃ ក៏ទ្រង់សម្ដែងធ្វើចិត្តនោះឯងឲ្យជាធុរៈ ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែក

ខាងអកុសល ជាពួកនៃអកុសល ធម៌ជាអកុសលទាំងអស់នោះ មានចិត្តជាប្រធាន ចិត្ត រមែងកើតមុនធម៌ទាំងនោះ ដូច្នេះ ។

និងដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយធម្មបទ ) ថា

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត ( មានចិត្តជាធំ ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្ត ត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី ( នូវទុច្ចរិត ) ព្រោះទុច្ចរិតទាំងនោះ ទុក្ខ រមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះ វិលតាមជានជើងគោ ដែលកំពុងអូសទៅ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី ( នូវសុចរិត ) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ដូច្នេះ ។

និងដូចព្រះតម្រាស់ក្នុង ( សំយុត្តនិកាយ សគាថវគ្គ ) ថា

ចិត្តតែងនាំសត្វលោកទៅ ចិត្តតែងកើចកន្ត្រាក់សត្វលោកទៅ សត្វទាំងពួង តែងប្រព្រឹត្តទៅតាមអំណាចធម៌មួយ គឺចិត្ត ដូច្នេះ ។

និងដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ជាគ្រឿងសៅហ្មងនៃចិត្ត រមែងជ្រោកជ្រាក ពួកសត្វដែលមានធម៌ជាគ្រឿងផូរផង់នៃចិត្ត រមែងបរិសុទ្ធ ដូច្នេះ ។ និង

ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះ មានរស្មីផ្សាយចេញ ប៉ុន្តែភវង្គចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុក ចូលមកធ្វើឲ្យសៅហ្មង ដូច្នេះ ។ និងដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា ម្នាលគហបតី កាលបើចិត្តដែលបុគ្គលមិនបានរក្សាហើយ កាយកម្មក៏ឈ្មោះថា មិនបានរក្សាផង វចីកម្មក៏ឈ្មោះថា មិនបានរក្សាផង មនោកម្មក៏ឈ្មោះថា មិនបានរក្សាផងដែរ ម្នាលគហបតី កាលបើចិត្តដែលបុគ្គលរក្សាហើយ ។បេ។ ម្នាលគហបតី កាលបើចិត្តព្យាបាទហើយ ។បេ។ ម្នាលគហបតី កាលបើចិត្តមិនព្យាបាទហើយ ។បេ។ ម្នាលគហបតី កាលបើចិត្តជោកដោយរាគាទិក្កិលេសហើយ ។បេ។ ម្នាលគហបតី កាលបើចិត្តមិនជោក កាយកម្មក៏ឈ្មោះថា មិនជោក វចីកម្មក៏ឈ្មោះថា មិនជោក មនោកម្មក៏ឈ្មោះថា មិនជោកដោយរាគាទិក្កិលេស ដូច្នេះ ។

សម្ដីងដល់លោកិយធម៌យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ចិត្តជាធំ ជាធុរៈ ជាប្រធាន ។ បណ្ដាព្រះសូត្រដែលពោលហើយនេះ គប្បីជ្រាបថា លោកមិនកាន់យកសូត្រមួយ ឬសូត្រពីរ តែកាន់យកសូត្រទាំងអស់ ដើម្បីតាមរក្សានូវសូត្រ ។

ព្រះមានព្រះភាគ កាលត្រាស់សួរលោកុត្តរធម៌ ក៏មិនត្រាស់សួរថា អ្នកសម្រេចផស្សៈដូចម្ដេច សម្រេចវេទនាដូចម្ដេច សម្រេចសញ្ញាដូចម្ដេច សម្រេចចេតនាដូចម្ដេច និងសម្រេចចិត្តដូចម្ដេច ទ្រង់សួរធ្វើបញ្ញាឲ្យជាធុរៈថា ម្នាលភិក្ខុ អ្នកសម្រេចនូវបញ្ញាដូចម្ដេច អ្នកសម្រេចមគ្គប្បញ្ញាទីមួយ

ឬក៏ទីពីរ ។បេ។ ទីបី ។បេ។ អ្នកក៏សម្រេចមគ្គប្បញ្ញាទីបួនដោយមានបញ្ញាជាធំ មានបញ្ញាជាធុរៈ ដូច្នេះ ។

ក្នុងទីនេះ គប្បីជ្រាបព្រះសូត្រជាដើមយ៉ាងនេះថា កុសលធម៌ទាំងឡាយដែលក្រៃលែងដោយបញ្ញាមិនសាបសូន្យទៅ និងដូចព្រះតម្រាស់មួយទៀតថា ប្រាជ្ញាមានសេចក្តី ( អត្ថ ) ថាដូចម្តេចខ្លះ និងព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ សទ្ធាដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះ ក៏តាំងនៅស៊ប់ វិរិយៈដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះក៏តាំងនៅស៊ប់ សតិដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះ ក៏តាំងនៅស៊ប់ សមាធិដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះ ក៏តាំងនៅស៊ប់ ចំពោះអរិយសាវកដែលមានបញ្ញា ដូច្នេះ ។ ព្រោះហេតុនោះ សម្ដីងដល់លោកុត្តរធម៌ហើយ គប្បីជ្រាបថា បញ្ញាជាធំ ជាធុរៈ ជាប្រធាន ។ នេះជាលោកិយទេសនា ។ ព្រោះហេតុនោះ កាលទ្រង់សម្ដែងចិត្តឲ្យជាធុរៈ ទើបត្រាស់ថា **ចិត្តំ ឧប្បន្នំ ហោតិ** ដូច្នេះ ។

ពាក្យថា **សោមនស្សសហគតំ** បានដល់ ដល់ភាវៈមានការកើតព្រមគ្នាជាដើមជាមួយនឹងសោមនស្ស ពោល គឺការសោយអារម្មណ៍ដែលគួរត្រេកអរ ។ **សហគត** សព្ទនេះ ប្រើក្នុងអត្ថទាំងនេះ គឺភាពជាយ៉ាងនោះ លាយឡំ អាស្រ័យអារម្មណ៍ និងការច្រឡូកច្រឡំ ។

បណ្ដាអត្ថទាំងនោះ **សហគត** សព្ទនេះ គប្បីជ្រាបថា ប្រើក្នុងអត្ថថា **ភាពជាយ៉ាងនោះ** ដូចក្នុងប្រយោគជាដើមថា **យាយំ តណ្ហា បោនោព្ភវិកា**

**ឆន្ទរាគសហគតា** អរិយសច្ច គឺតណ្ហានេះឯង ជាធម្មជាតនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្ដីរីករាយ និងសេចក្ដីត្រេកត្រអាល ដូច្នេះ ។ អធិប្បាយថា ជាសេចក្ដីត្រេកត្រអាលដោយរាគៈ ។

មានក្នុងអត្ថថា **លាយឡំ** ដូចក្នុងប្រយោគជាដើមថា **យាយំ ភិក្ខវេ វីមំសា កោសជ្ជសហគតា កោសជ្ជសម្បយុត្តា** ម្នាលភិក្ខុទាំងឡាយ វីមំសាឯណាប្រកបដោយកោសជ្ជៈ សម្បយុត្តដោយកោសជ្ជៈ ដូច្នេះ ។ ក្នុងអធិការនេះ គប្បីជ្រាបអធិប្បាយថា វីមំសានេះ លាយឡំហើយដោយសេចក្ដីខ្ជិលច្រអូស ដែលកើតឡើងក្នុងចន្លោះៗ ។

ប្រើក្នុងអត្ថថា **អាស្រ័យ** ដូចក្នុងប្រយោគជាដើមថា **អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ** ( ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ) ចម្រើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដូច្នេះ ។ អធិប្បាយថា អាស្រ័យអដ្ឋិកសញ្ញា ចម្រើនអដ្ឋិកសញ្ញា បានចំពោះហើយ ( នូវសតិសម្ពោជ្ឈង្គ ) ។

ប្រើក្នុងអត្ថថា **អារម្មណ៍** ដូចក្នុងប្រយោគជាដើមថា **លាភី ហោតិ រូបសហគតានំ វា សមាបត្តីនំ អរូបសហគតានំ វា** ជាអ្នកបានសមាបត្តិដែលសហគតៈដោយរូប ឬសមាបត្តិដែលសហគតៈដោយអរូប ដូច្នេះ អធិប្បាយថា មានរូប ឬអរូបជាអារម្មណ៍ ។

ប្រើក្នុងអត្ថថា **ប្រឡូកប្រឡំ** ដូចក្នុងប្រយោគជាដើមថា **ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ**

សុខនេះ ជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំ ប្រកបដោយបីតិនេះ ដូច្នេះ **សហគត** សព្ទ ក្នុងទីនេះបំណងយក ការប្រឡូកប្រឡំនេះប៉ុណ្ណោះ ។ ពិតហើយ ចិត្តដែលប្រឡូកប្រឡំជាមួយនឹងសោមនស្សក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ថា សោមនស្សសហគតៈ ដូច្នេះ ។

មួយទៀត **សំសដ្ឋ** សព្ទនេះ ក៏ប្រើក្នុងអត្ថច្រើនយ៉ាង គឺក្នុងសេចក្តីថា **ដូចគ្នា កិលេសលិចស្រោច សេចក្តីស្និទ្ធស្នាលជាមិត្ត** និង **កើតព្រមគ្នា** ។

ពិតហើយ **សំសដ្ឋ** សព្ទនេះ ប្រើក្នុងអត្ថថា **ដូចគ្នា** ដូចក្នុងប្រយោគជាដើមថា **កិសេ ថូលេ វិវជ្ជេត្វា សំសដ្ឋា យោជិតា ហយា** អ្នកទាំងឡាយត្រូវវៀរបង់នូវពួកសេះស្គម និងសេះធាត់ចេញ ហើយទឹមតែពួកសេះ ដែលប្រកប ( ដោយវ័យ សម្បុរ សម្មុះ កម្លាំង ) វិញ ដូច្នេះ ។

ប្រើក្នុងអត្ថថា **កិលេសលិចស្រោច** ដូចក្នុងប្រយោគជាដើមថា **សំសដ្ឋាវ តុម្ហេ អយ្យេ វិហរថ** ម្នាលនាង នាងទាំងឡាយ ចូរនៅប្រឡូកប្រឡំ ( ដោយពួកគ្រហស្ថ ) ចុះ ដូច្នេះ ។

ប្រើក្នុងអត្ថថា **សេចក្តីស្និទ្ធស្នាលជាមិត្ត** ដូចក្នុងប្រយោគជាដើមថា **គិហីហិ សំសដ្ឋោ វិហរតិ** ជាអ្នកប្រឡូកប្រឡំដោយពួកគ្រហស្ថ ដូច្នេះ ។

ប្រើក្នុងអត្ថថា **កើតព្រមគ្នា** ដូចក្នុងប្រយោគជាដើមថា **ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ** សេចក្តីសុខនេះ ជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំ ប្រកបដោយបីតិនេះ ដូច្នេះ ។ **សំសដ្ឋ** សព្ទ ក្នុងទីនេះ បំណងយកក្នុងអត្ថថា

**កើតព្រមគ្នា** ក៏ក្នុងអត្ថទាំងនេះ ធម៌ដែលសហគតៈ ឈ្មោះថា មិនកើតព្រមគ្នា មិនប្រឡូកប្រឡំគ្នា មិនសម្បយុត្តគ្នា រមែងមិនមាន តែធម៌ដែលកើតព្រមគ្នា ប្រឡូកប្រឡំគ្នា សម្បយុត្តគ្នា មានខ្លះ មិនមានខ្លះ ។ ពិតហើយ កាលរូបធម៌ និងអរូបធម៌កើតព្រមគ្នា រូប រមែងកើតព្រមគ្នានឹងអរូប តែមិនប្រឡូកប្រឡំគ្នា មិនសម្បយុត្តគ្នា អរូបក៏ដូចគ្នា កើតព្រមជាមួយរូប តែមិនប្រឡូកប្រឡំគ្នា មិនសម្បយុត្តគ្នា ឯរូបកើតព្រមនឹងរូប ក៏មិនប្រឡូកប្រឡំគ្នា មិនសម្បយុត្តគ្នា ។ ចំណែកអរូបដោយពិតប្រាកដនោះឯង កើតព្រមគ្នា ប្រឡូកប្រឡំគ្នា សម្បយុត្តគ្នា ជាមួយអរូបនោះឯង ព្រោះហេតុនោះ ទ្រង់សំដៅយកការកើតព្រមគ្នា ការប្រឡូកប្រឡំគ្នា សម្បយុត្តគ្នានោះ ទើបត្រាស់ពាក្យថា **សោមនស្សសហគតំ** ដូច្នេះ ។

បទថា **ញាណសម្បយុត្តំ** បានដល់ សម្បយុត្តហើយដោយញាណ អធិប្បាយថា ប្រកបដោយអាការ មានការកើតព្រមគ្នាជាដើម ស្មើគ្នា ។ ពាក្យណាដែលគួរពោលក្នុងពាក្យថា ញាណសម្បយុត្តនេះ ពាក្យនោះ ខ្ញុំបានពោលហើយ ក្នុងវេទនាត្តិកៈ ក្នុងការពណ៌នាបទមាតិកានុ៎ះឯង ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ញាណនោះ សម្បយុត្តដោយលក្ខណៈនេះ គឺកើតព្រមគ្នា ( **ឯកុប្បាទ** ) រលត់ព្រមគ្នា ( **ឯកនិរោធ** ) មានវត្ថុជាមួយគ្នា ( **ឯកវត្ថុក** ) មានអារម្មណ៍ជាមួយគ្នា ( **ឯការម្មណ** ) ។ ចំណែកនិទ្ទេសដោយឧក្រិដ្ឋមានដូច្នេះ ក្នុងអរូប សូម្បីវៀរភាពមានវត្ថុជាមួយគ្នា ក៏បានសម្បយោគ ។ សួរថា ដោយពាក្យមានប្រមាណប៉ុណ្ណេះ លោកពោល

ដូចម្តេច ឆ្លើយថា លោកពោលមហាចិត្តដែលសហគតៈ ដោយសោមនស្ស ក្នុងកាមាវចរកុសលទាំងឡាយ ជាតិហេតុកញ្ញាណសម្បយុត្ត-អសង្ខារិក ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់កាន់យកកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដោយសំណួរដែលមិនបានកំណត់ពិតប្រាកដថា ពួកធម៌ជាកុសល ដូចម្តេចខ្លះ ។ ទ្រង់វៀរកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទ្រង់កាន់យកកាមាវចរកុសលចិត្ត ៨ ដួង ដោយព្រះតម្រាស់ថា ចិត្តជាកាមាវចរកុសល ... កើតឡើង ។ ទ្រង់វៀរចិត្ត ដែលសហគតៈដោយឧបេក្ខា ៤ ដួង អំពីកាមាវចរកុសលចិត្ត ៨ ដួងនោះឯង ហើយទ្រង់កាន់យកចំពោះចិត្តដែលសហគតៈដោយសោមនស្ស ៤ ដួង ដោយព្រះតម្រាស់ថា **សោមនស្សសហគតំ** ។ ទ្រង់វៀរចាកចិត្តដែលសម្បយុត្តដោយញាណ ២ ដួង អំពីចិត្តដែលសហគតៈដោយសោមនស្សនោះឯង ហើយទ្រង់កាន់យកចំពោះចិត្តដែលសម្បយុត្តដោយញាណ ២ ដួង ដោយព្រះតម្រាស់ថា **ញាណសម្បយុត្តំ** ។ ចំណែកភាពដែលចិត្ត ជាអសង្ខារិក ទ្រង់មិនបានប្រារព្ធ ព្រោះមិនបានត្រាស់ ។ សូម្បីទ្រង់មិនបានប្រារព្ធភាពដែលចិត្តជាអសង្ខារិកក៏ពិត តែទោះបីមិនបានត្រាស់ថា **អសង្ខារេន** ( មិនមានអ្នកដឹកនាំ ) ទុកក្នុងទីនេះ បណ្ឌិតក៏គប្បីជ្រាបភាពដែលចិត្តជាអសង្ខារិក ដោយព្រះតម្រាស់ថា **សសង្ខារេន** ( ដោយមានអ្នកដឹកនាំ ) ខាងមុខ ។ ព្រះសម្មាសម្ពុទ្ធទ្រង់កំណត់ដើម្បីចែកសម្តែងមហាចិត្តនេះ តាំងអំពីដើមនោះឯង ទើបទ្រង់ផ្តើមទេសនានេះ ហេតុនោះ ក្នុងសេចក្តីនេះ គប្បីជ្រាបថា លោក

ធ្វើសេចក្តីសន្និដ្ឋានយ៉ាងនេះ ។

ឥឡូវនេះ ដើម្បីសម្តែងចិត្តនោះឯងដោយអារម្មណ៍ ទើបត្រាស់ពាក្យថា **រូបារម្មណំ វា** ជាដើម ។

ពិតហើយ ព្រះមានព្រះភាគ កាលសម្តែងអរូបធម៌ទាំងឡាយ រមែងទ្រង់សម្តែងដោយវត្ថុ ឬដោយអារម្មណ៍ ឬទាំងវត្ថុ និងអារម្មណ៍ ឬថា ដោយភាវៈ គឺកិច្ចរបស់ខ្លួន ។ អរូបធម៌ទាំងឡាយដែលទ្រង់សម្តែងដោយវត្ថុ ដូចក្នុងប្រយោគជាដើមថា ចក្ខុសម្ផស្ស ។បេ។ មនោសម្ផស្ស វេទនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាដែលកើតអំពីមនោសម្ផស្ស ចក្ខុ-វិញ្ញាណ ។បេ។ មនោវិញ្ញាណ ។ ទ្រង់សម្តែងអរូបធម៌ទាំងឡាយដោយអារម្មណ៍ ដូចក្នុងប្រយោគជាដើមថា រូបសញ្ញា ( សេចក្តីសម្គាល់ក្នុងរូប ) ។បេ។ ធម្មសញ្ញា ( សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ ) រូបសញ្ចេតនា ( ការគិតសន្សំនូវរូបារម្មណ៍ ) ។បេ។ ធម្មសញ្ចេតនា ។ ទ្រង់សម្តែងអរូបធម៌ទាំងឡាយ ទាំងវត្ថុ និងអារម្មណ៍ ដូចក្នុងប្រយោគជាដើមថា ព្រោះអាស្រ័យចក្ខុ និងរូប ទើបចក្ខុវិញ្ញាណកើតឡើង ប្រជុំនៃធម៌ទាំង ៣ ( នេះ ) ហៅថា ផស្សៈ ។បេ។ ព្រោះអាស្រ័យចិត្ត និងធម៌ ទើបមនោវិញ្ញាណកើតឡើង ប្រជុំនៃធម៌ទាំង ៣ ហៅថា ផស្សៈ ដូច្នេះ ។ ទ្រង់សម្តែងអរូបធម៌ទាំងឡាយដោយភាវៈ គឺកិច្ចរបស់ខ្លួន ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ កើតមានព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ ដូច្នេះ ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់

សម្តែង ( ចិត្ត ) ដោយអារម្មណ៍ក្នុងទីនេះ ទើបត្រាស់ពាក្យថា **រូបារម្មណំ វា** ជាដើម ។

បណ្តារូបារម្មណ៍ជាដើមនោះ រូបមានសមុដ្ឋាន ៤ ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងឯង ជារូបារម្មណ៍ ។ សំឡេងមានសមុដ្ឋាន ២ ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងឯងជាសទ្ទារម្មណ៍ ។ ក្លិនមានសមុដ្ឋាន ៤ ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងឯងជាគន្ធារម្មណ៍ ។ រសមានសមុដ្ឋាន ៤ ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងឯងជារសារម្មណ៍ ។ ផោដ្ឋព្វៈមានសមុដ្ឋាន ៤ ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងឯងជាផោដ្ឋព្វារម្មណ៍ ។ ធម៌ទាំងឡាយទាំងឯង ពោល គឺគោចរ ( អារម្មណ៍ ) របស់ចិត្តដ៏សេសអំពីធម៌ដែលពោលហើយ ដែលមានសមុដ្ឋាន ១ មានសមុដ្ឋាន ២ មានសមុដ្ឋាន ៣ មានសមុដ្ឋាន ៤ សូម្បីមិនកើតអំពីសមុដ្ឋានណាៗ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ទាំងជាធម៌ដែលមិនគប្បីពោលយ៉ាងនោះ ជាធម្មារម្មណ៍ តែអាចារ្យពួកខ្លះពោលថា ធម៌ទាំងឡាយពួកណា សូម្បីមានរូបជាដើមដែលមិនមកកាន់គន្លង ( ផ្លូវភ្នែកជាដើម ) ធម៌ទាំងនោះ ក៏ជាធម្មារម្មណ៍នោះឯង អាចារ្យទាំងនោះ ត្រូវបដិសេធដោយសូត្រនេះ ។ សេចក្តីនេះ សមដូចពាក្យដែលព្រះសារីបុត្តត្ថេរ ពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ កាលបើឥន្ទ្រិយទាំង ៥ ប្រការនេះឯងមានវិស័យផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ មានចិត្តជាទីពឹង មានចិត្តទទួលវិស័យ

ដែលកើតជាអារម្មណ៍របស់ឥន្ទ្រិយទាំង ៥ នោះ ដូច្នេះ ។

ពិតហើយ អារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ឈ្មោះថា ជាគោចរវិស័យរបស់ឥន្ទ្រិយទាំង ៥ នោះ ទើបធ្វើឲ្យបានអត្ថនេះថា រូបារម្មណ៍ជាដើមនោះដែលចិត្តសោយ ក៏នៅជារូបារម្មណ៍ជាដើមនោះឯង និងធ្វើឲ្យបានអត្ថនេះឯងថា ព្រោះទិព្វចក្ខុញ្ញាណជាដើម មានរូបជាដើមជាអារម្មណ៍ ។ ពិតហើយ គប្បីជ្រាបការកំណត់អារម្មណ៍ ដោយន័យដែលពោលហើយថា រូបារម្មណ៍ជាដើម ដែលមិនមកកាន់គន្លងនោះឯង ជាអារម្មណ៍របស់ទិព្វ-ចក្ខុញ្ញាណជាដើម តែរូបារម្មណ៍ជាដើមនោះ មិនជាធម្មារម្មណ៍ ។

បណ្តារូបារម្មណ៍ជាដើមនោះ អារម្មណ៍នីមួយៗ រមែងមកកាន់គន្លងក្នុងទ្វារទាំងពីរ អារម្មណ៍ ១ ទ្វារ ២ ។ ពិតហើយ រូបារម្មណ៍ ប៉ះខ្ទប់ចក្ខុបសាទហើយ មកកាន់គន្លងមនោទ្វារក្នុងខណៈនោះមួយរំពេច អធិប្បាយថា ជាបច្ច័យដល់ភវង្គចលនៈ ។ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសា-រម្មណ៍ ផោដ្ឋព្វារម្មណ៍ ក៏ន័យនេះឯង ។ ដូចបក្សីហើរមកតាមអាកាស ទំត្រង់ចុងឈើនុ៎ះឯង រមែងប៉ះនឹងមែកឈើផង ស្រមោលរបស់បក្សីនោះរមែងប៉ះផែនដីផង ។ ការប៉ះនឹងមែកឈើ និងការផ្សាយទៅនៃស្រមោលត្រង់ផែនដី រមែងមានក្នុងខណៈតែមួយ មិនមុនមិនក្រោយ យ៉ាងណា ការប៉ះខ្ទប់នឹងចក្ខុបសាទជាដើម របស់រូបដែលជាបច្ចុប្បន្នជាដើម និងការមកកាន់គន្លងមនោទ្វារ ព្រោះអាចឲ្យភវង្គញ័រ រមែងមានក្នុងខណៈតែមួយនុ៎ះឯង មិនមុនមិនក្រោយ ក៏យ៉ាងនោះ ។ លំដាប់នោះ មហាកុសលចិត្តនេះ

ក៏កើតឡើងក្នុងអារម្មណ៍ឯណានីមួយនៃអារម្មណ៍ទាំងនោះ បន្ទាប់អំពីអហេតុកចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើម ដែលកាត់កវត្តហើយកើតឡើងក្នុងចក្ខុទ្វារជាដើម មានវោដ្ឋព្វនចិត្តជាទីបំផុត ។ តែក្នុងមនោទ្វារសុទ្ធៗ មិនមានកិច្ចនៃការប៉ះខ្ទប់នឹងបសាទដោយបកតិអារម្មណ៍ទាំងនេះ រមែងមកកាន់គន្លងដោយអំណាចនៃរូបដែលឃើញហើយ សំឡេងដែលបានឮហើយ ក្លិនដែលបានហិតហើយ រសដែលបានលិទ្ធហើយ កាយដែលបានប៉ះខ្ទប់ហើយប៉ុណ្ណោះ ។

សួរថា អារម្មណ៍ទាំងនេះ មកកាន់គន្លងដូចម្ដេច ឆ្លើយថា បុគ្គលខ្លះក្នុងលោកនេះ ធ្វើប្រទក្សិណមហាចេតិយ ដែលប្រដាប់តាក់តែងហើយ បូកលាបដោយបាយអ វិចិត្រដោយពណ៌ មានហរតាល និងមនោសិលាជាដើម មានការលើកទង់ជ័យ និងទង់ផ្កាលាមានប្រការផ្សេងៗ ចងហើយដោយសំណុំផ្កា ព័ទ្ធហើយដោយប្រទីប និងមាល័យ រុងរឿងដោយសិរី គួរជាទីរីករាយនៃចិត្តយ៉ាងក្រៃលែង ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ត្រង់ទីនៃព្រះចេតិយ ១៦ ជាន់ ហើយឈរផ្គងអញ្ជលី រមិលមើល កាន់យកនូវបីតិមានព្រះពុទ្ធជាអារម្មណ៍ ។ កាលបុគ្គលនោះឃើញព្រះចេតិយ ញុំាងបីតិមានព្រះពុទ្ធជាអារម្មណ៍ ឲ្យកើតឡើងយ៉ាងនេះហើយ ខាងក្រោយ ទៅក្នុងទីណាមួយ អង្គុយនៅក្នុងទីសម្រាកក្នុងវេលាយប់ និងក្នុងវេលាថ្ងៃ ហើយរឭកមហាចេតិយដែលប្រដាប់តាក់តែងហើយ ដូចមកកាន់គន្លងក្នុងចក្ខុទ្វារនុ៎ះឯង ដូចជាវេលាដែលធ្វើប្រទក្សិណ ហើយថ្វាយបង្គំព្រះចេតិយ ។ រូបារម្មណ៍

រមែងមកកាន់គន្លងដោយអំណាចនៃរូប ដែលខ្លួនឃើញមកអំពីមុន ដោយប្រការដូច្នេះ ។

មួយទៀត កាលបុគ្គលឮសំឡេងព្រះធម្មកថិក សម្តែងធម្មកថា ដោយសំឡេងដ៏ពីរោះ ឬឮសំឡេងដែលគេស្វាធ្យាយដោយសំឡេងដ៏ពីរោះ ខាងក្រោយមក ក៏ទៅអង្គុយនៅក្នុងទីណាមួយ ហើយរឭកធម្មកថា ឬសំឡេងសរភញ្ញ ដូចជាមកកាន់គន្លងក្នុងសោតទ្វារ និងដូចក្នុងវេលាឲ្យសាធុការហើយស្តាប់ធម៌ ។ សទ្ទារម្មណ៍ រមែងមកកាន់គន្លងដោយអំណាចនៃសំឡេងដែលស្តាប់ហើយ ដោយប្រការដូច្នេះ ។

មួយទៀត កាលបុគ្គលបានគ្រឿងក្រអូប ឬផ្កាដែលមានក្លិនក្រអូបហើយបូជាអាសនៈ ឬព្រះចេតិយដោយចិត្តដែលមានក្លិនជាអារម្មណ៍ ខាងក្រោយមក អង្គុយក្នុងទីណាមួយហើយរឭក គន្ធារម្មណ៍នោះ រមែងដូចជាមកកាន់គន្លងក្នុងឃានទ្វារ ដូចជាវេលាដែលធ្វើការបូជា ។ គន្ធារម្មណ៍នោះ រមែងមកកាន់គន្លងដោយអំណាចនៃក្លិនដែលធ្លាប់ហិតហើយ ដោយប្រការដូច្នេះ ។

មួយវិញទៀត កាលបុគ្គលចែករំលែក របស់ទំពា និងរបស់បរិភោគដ៏ប្រណីតដល់សព្រហ្មចារីទាំងឡាយ ហើយបរិភោគ តមកខាងក្រោយ បានភោជនមានស្ងោគែលលកជាដើម ក្នុងទីណាមួយ ហើយរឭកថា ក្នុងវេលាឯណោះ អញចែករំលែកភោជនដ៏ប្រណីតដល់សព្រហ្មចារីទាំងឡាយ ហើយបរិភោគ រសារម្មណ៍នោះ ដូចជាមកកាន់គន្លងក្នុងជិវ្ហាទ្វារ ដូចជាវេលាដែលបរិភោគ រសារម្មណ៍រមែងមកកាន់គន្លង ដោយអំណាចនៃរសដែលខ្លួនបាន

លិទ្ធភ្លក្សហើយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត កាលបុគ្គលប្រើប្រាស់គ្រែ និងតាំង កម្រាល ឬសំពត់ដណ្តប់មានសាច់ទន់ មានសម្ផស្សជាសុខ ខាងក្រោយមក ត្រូវដេកលើទីដំណេកដែលមិនល្អក្នុងទីណាមួយ ក៏រឭកថា កាលពីមុនអញប្រើប្រាស់គ្រែ និងតាំងដ៏ទន់ ដូច្នេះ ផោដ្ឋព្វារម្មណ៍នោះ ដូចជាមកកាន់គន្លងក្នុងកាយទ្វារ ដូចជាវេលាដែលសោយសម្ផស្សដ៏ល្អ ។ ផោដ្ឋព្វារម្មណ៍រមែងមកកាន់គន្លងដោយអំណាចនៃការប៉ះខ្ទប់ ដោយប្រការដូច្នេះ ។

ក្នុងមនោទ្វារសុទ្ធៗ កិច្ចនៃការប៉ះខ្ទប់បសាទ ( ទាំង ៥ ) រមែងមិនមាន ដោយប្រការដូច្នេះ ។ អារម្មណ៍ទាំងនេះ គប្បីជ្រាបថា រមែងមកកាន់គន្លងដោយអំណាចនៃរូបដែលធ្លាប់ឃើញហើយ សំឡេងដែលធ្លាប់ឮហើយ ក្លិនដែលធ្លាប់ហិតហើយ រសដែលធ្លាប់លិទ្ធភ្លក្សហើយ និងផោដ្ឋព្វៈដែលធ្លាប់ប៉ះខ្ទប់ហើយតាមប្រក្រតី ដូច្នេះ ។

ឥឡូវនេះ នៅមានន័យដទៃដែលផុតចាកអដ្ឋកថា ក្នុងការដែលអារម្មណ៍ដល់គន្លងមនោទ្វារដោយអំណាចនៃរូប ដែលធ្លាប់ឃើញហើយជាដើម តាមប្រក្រតី ។ ខាងដើម បណ្ឌិតគប្បីជ្រាបអារម្មណ៍ទាំងឡាយ មានរូបដែលធ្លាប់ឃើញហើយជាដើមទាំងនេះថា អារម្មណ៍ដែលឃើញមក ដែលបានឮមក ដែលទាក់ទងគ្នាទាំងពីរយ៉ាងនោះ ។ ក្នុងពាក្យថា ដែលឃើញមកជាដើមនោះ អារម្មណ៍ដែលធ្លាប់ទទួល ដោយអំណាចនៃទ្វារ ៥ ឈ្មោះថាដែលឃើញមក ។ រូបជាដើមដែលមិនឃើញដោយភ្នែកខ្លួនឯង តែទទួល

យកដោយអំណាចបានឮមក ឈ្មោះថា ដែលបានឮមក ។ អារម្មណ៍ដែលទាក់ទងដោយអាការទាំងពីរយ៉ាងនេះ ឈ្មោះថា ដែលទាក់ទងគ្នាទាំងពីរយ៉ាងនោះ ។ បណ្ឌិតគប្បីជ្រាបថា អារម្មណ៍ទាំងនេះ រមែងមកកាន់គន្លងក្នុងមនោទ្វារដោយអំណាចនៃអារម្មណ៍ ដែលឃើញមកជាដើមនេះ ដោយប្រការដូច្នេះ ។ ក្នុងអារម្មណ៍ដែលឃើញមកជាដើមនោះ ពោលដោយអំណាចនៃអារម្មណ៍ដែលឃើញមកមុន ការដែលអារម្មណ៍មកកាន់គន្លងក្នុងមនោទ្វារ ខ្ញុំពោលហើយ ដោយ ៥ ន័យខាងដើមនុ៎ះឯង ។

ចំណែកជនពួកខ្លះ បានឮថា រូបមានសភាពបែបនេះ របស់ព្រះមានព្រះភាគកើតដោយបុណ្យដ៏ប្រសើរក្រៃលែង ព្រះសូរសៀងក៏ពីរោះក្រៃលែងក្លិនទីខ្លះនៃក្លិនផ្កាណាមួយក្រអូបក្រៃលែង រសរបស់ផ្លែឈើណាមួយក៏ឆ្ងាញ់ក្រៃលែង សម្ផស្សរបស់សំពត់ដណ្តប់ជាដើមក៏ជាសុខក្រៃលែង ដូច្នេះ ។ រូបជាដើមទាំងនោះ ត្រឹមតែបានស្តាប់មកប៉ុណ្ណោះ មិនបានប៉ះខ្ទប់នឹងបសាទមានចក្ខុបសាទជាដើមឡើយ រមែងមកកាន់គន្លងក្នុងមនោទ្វារ របស់បុគ្គលនោះ លំដាប់នោះ ចិត្តនោះ របស់បុគ្គលនោះ រមែងប្រព្រឹត្តទៅក្នុងរូប ឬក្នុងសំឡេងនោះ ដោយអំណាចសេចក្តីជ្រះថ្លា ឬថា រមែងប្រព្រឹត្តទៅក្នុងក្លិនជាដើម ដោយអំណាចសេចក្តីប្រាថ្នានឹងថ្វាយទានដល់ព្រះអរិយៈទាំងឡាយ ឬថា រមែងប្រព្រឹត្តទៅក្នុងទានទាំងឡាយ ដែលបុគ្គលពួកដទៃថ្វាយហើយ ដោយអំណាចនៃការអនុមោទនា ។ អារម្មណ៍ទាំងនេះ រមែងមកកាន់គន្លងក្នុងមនោទ្វារដោយអំណាចនៃអារម្មណ៍ដែលបានឮមក ដោយប្រការដូច្នេះ ។

ចំណែកបុគ្គលដទៃទៀត បានឃើញមកឯង ឬបានឮរូបជាដើម តាមដែលពោលហើយ ។ អារម្មណ៍ទាំងនោះ រមែងមកកាន់គន្លងក្នុងមនោទ្វារ របស់បុគ្គលនោះ ដោយទាក់ទងគ្នាជាមួយអារម្មណ៍ដែលបានឃើញមកឯង ឬបានឮមកដោយមិនប៉ះខ្ទប់នឹងចក្ខុបសាទជាដើមនុ៎ះឯង ដោយន័យជាដើមថា រូបបែបនេះ នឹងមានដល់ព្រះពុទ្ធដែលទ្រង់កើតឡើងក្នុងកាលតទៅ ។ ពេលនោះ មហាកុសលចិត្តនេះ ដែលមានអារម្មណ៍ណាមួយ បណ្ដាអារម្មណ៍ទាំងឡាយ មានរូបជាដើមនោះ របស់បុគ្គលនោះក៏នឹងប្រព្រឹត្តទៅ ដោយន័យដែលពោលក្នុងខាងដើមនុ៎ះឯង អារម្មណ៍ទាំងឡាយ មានរូបជាដើមទាំងនេះ រមែងមកកាន់គន្លងក្នុងមនោទ្វារ ដោយអំណាចការទាក់ទងគ្នាទាំងពីរយ៉ាងនោះ ដោយប្រការដូច្នេះ ។

ពាក្យដែលពោលមកនេះត្រឹមតែជាគន្លងប៉ុណ្ណោះ ចំណែកសេចក្ដីពិស្ដារ បណ្ឌិតគប្បីជ្រាបការមកកាន់គន្លងក្នុងមនោទ្វារ របស់អារម្មណ៍ទាំងនោះឯង ដោយអំណាចនៃសទ្ធា ការពេញចិត្ត ការត្រិះរិះតាមអាការ ការអត់ធន់ចំពោះការសម្លឹងដោយទិដ្ឋិជាដើម ។ អារម្មណ៍ដែលមកកាន់គន្លងទាំងនេះ ដោយអាការយ៉ាងនេះជាការពិតខ្លះ មិនពិតខ្លះ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ មិនកាន់យកន័យនេះក្នុងអដ្ឋកថា ។ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជវនចិត្តមានអារម្មណ៍មួយ រមែងកើតក្នុងទ្វារម្ដងពីរទ្វារ ។ ពិតហើយ ជវនចិត្តដែលមានរូបជាអារម្មណ៍ រមែងកើតឡើងទាំងក្នុងចក្ខុទ្វារ និងក្នុងមនោទ្វារ សូម្បីក្នុងសទ្ទារម្មណ៍ជាដើម ក៏ន័យនេះឯង ។ បណ្ដា

ជវនចិត្ត ដែលមានរូបជាអារម្មណ៍ជាដើមនោះ ជវនចិត្តដែលមានរូបជាអារម្មណ៍ដែលកើតក្នុងមនោទ្វារ មាន ៣ យ៉ាង គឺ **ទានមយ** ជវនចិត្តកើតអំពីការឲ្យទាន ១ **សីលមយ** ជវនចិត្តកើតអំពីការរក្សាសីល ១ **ភាវនាមយ** ជវនចិត្តកើតអំពីភាវនា ១ ។

ក្នុងជវនចិត្តដែលកើតអំពីការឲ្យទានជាដើមទាំងនោះ ប្រការនីមួយៗ ក៏មាន ៣ យ៉ាង គឺកាយកម្ម វចីកម្ម និងមនោកម្ម ។ សូម្បីក្នុងសទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ជាដើម ក៏ន័យនេះដូចគ្នា បណ្ដាជវនចិត្តដែលមានរូបជាអារម្មណ៍ទាំងនោះ មហាកុសលចិត្តមួយដួង កាលធ្វើរូបឲ្យជាអារម្មណ៍កើតឡើង រមែងធ្វើពណ៌ដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត គួរត្រេកអរ ពោល គឺសុភនិមិត្តឯណានីមួយក្នុងផ្កា វត្ថុ និងធាតុទាំងឡាយដែលមានពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម និងពណ៌ស ឲ្យជាអារម្មណ៍កើតឡើង ។ សួរថា ឥដ្ឋារម្មណ៍ ( អារម្មណ៍ដែលគួរប្រាថ្នា ) នោះ ជាទីតាំងនៃលោភៈ មិនមែនឬ តើហេតុដូចម្ដេចទើបកើតមានឈ្មោះថា **កុសល** ។ ឆ្លើយថា ចិត្តនេះ ឈ្មោះថា ជា **កុសល** ដោយអំណាចនៃចិត្តដែលកំណត់ ដោយអំណាចនៃចិត្តដែលបង្អោនទៅ ដោយអំណាចនៃការប្រព្រឹត្តិល្អ ដោយអំណាចនៃការចងចិត្ត ។

ពិតហើយ បុគ្គលណាកំណត់ចិត្តក្នុងការធ្វើកុសលថា កុសលប៉ុណ្ណោះ អញគួរធ្វើ ទាញចិត្តត្រឡប់អំពីការប្រព្រឹត្តអកុសល ហើយបង្អោនទៅក្នុងការធ្វើកុសល ប្រព្រឹត្តល្អដោយការប្រព្រឹត្តកុសលទុំះឯងដោយការធ្វើរឿយៗ

និងធ្វើការពិចារណា ឲ្យប្រព្រឹត្តទៅដោយឧបាយ ដោយឧបនិស្ស័យទាំងឡាយ មានការនៅក្នុងប្រទេសដ៏សមគួរ ការសេពគប់សប្បុរស ការស្តាប់ព្រះសទ្ធម្ម ភាពជាអ្នកមានបុណ្យបានធ្វើទុកក្នុងកាលមុនជាដើម ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ជាកុសលដោយអាការនេះ គឺចិត្តដែលកំណត់ ចិត្តដែលបង្អោនទៅ ការប្រព្រឹត្តិល្អ និងការចងចិត្ត ភាពដែលចិត្តសហគតៈដោយសោមនស្សក្នុងមហាកុសលចិត្តនេះ គប្បីជ្រាបដោយអំណាចនៃអារម្មណ៍ ។ ពិតហើយ ចិត្តនេះ ឈ្មោះថា សហគតៈដោយសោមនស្ស ព្រោះការកើតឡើងក្នុងអារម្មណ៍ដែលគួរប្រាថ្នា ។ ម្យ៉ាងទៀត ភាពជាអ្នកច្រើនដោយសទ្ធាជាដើម ក៏ជាហេតុក្នុងការដែលចិត្តសហគតៈដោយសោមនស្សនេះដូចគ្នា ។ ពិតហើយ សូម្បីឃើញរូបរបស់ព្រះតថាគត ដែលជាឥដ្ឋារម្មណ៍ដោយចំណែកមួយ សោមនស្សក៏មិនកើតឡើងដល់ជនទាំងឡាយដែលមិនមានសទ្ធា និងជាមិច្ឆាទិដ្ឋិ ។ ម្យ៉ាងទៀត ជនពួកណា មិនឃើញអានិសង្សក្នុងការសាងកុសល កាលជនទាំងនោះ សូម្បីត្រូវបុគ្គលដទៃធ្វើឲ្យកើតឧស្សាហៈធ្វើនូវកុសល សោមនស្សក៏មិនកើត ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបភាពដែលចិត្ត សហគតៈដោយសោមនស្សក្នុងមហាកុសលចិត្តនេះយ៉ាងនេះ គឺភាពជាអ្នកច្រើនដោយសទ្ធា ភាពជាអ្នកមានទិដ្ឋិបរិសុទ្ធ និងភាពជាអ្នកមានប្រក្រតីឃើញអានិសង្ស ។ ម្យ៉ាងទៀត គប្បីជ្រាបភាពដែលចិត្តដែលសហគតៈដោយសោមនស្ស ក្នុងមហាកុសលចិត្តនេះដោយហេតុទាំងនេះ គឺធម៌ ១១ យ៉ាង រមែងប្រព្រឹត្តទៅ ដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គ

គឺពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ឧបសមានុស្សតិ ១ ការវៀរបុគ្គលដែលសៅហ្មង ១ ការសេពគប់នឹងបុគ្គលដែលគួរស្រឡាញ់ ១ ការពិចារណាព្រះសូត្រដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ១ ភាពជាអ្នកបង្អោនទៅក្នុងបីតិសម្ពោជ្ឈង្គនោះ ១ ។

ចំណែកសេចក្ដីពិស្ដារនៃធម៌ដែលជាហេតុទាំងនេះ នឹងមានជាក់ច្បាស់ក្នុងពោជ្ឈង្គវិភង្គ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបភាពដែលចិត្តសម្បយុត្តដោយញាណក្នុងមហាកុសលចិត្តនេះ ដោយហេតុទាំងនេះ គឺដោយកម្ម ដោយការចូលដល់ដោយការចាស់ជុំវិញនៃឥន្ទ្រិយ ដោយភាពជាអ្នកឆ្ងាយចាកកិលេស ។

ពិតហើយ បុគ្គលណាសម្ដែងធម៌ដល់ពួកជនដទៃ ឲ្យសិក្សាសិប្បាយតនៈ ( វិជ្ជាជិះដំរី ជិះសេះ និងបររថជាដើម ) កម្មាយតនៈ ( វិជ្ជាកសិកម្ម ពាណិជ្ជកម្ម និងហត្ថកម្មជាដើម ) និងវិជ្ជដ្ឋាន ( តារាសាស្រ្ត ហោរាសាស្រ្ត វេជ្ជសាស្រ្ត និងសេយ្យសាស្រ្ត ) ដែលមិនមានទោស ថ្វាយគ្រឿងសក្ការៈហើយ អារាធនាព្រះធម្មកថិក ឲ្យសម្ដែងធម៌ តាំងសេចក្ដីប្រាថ្នាថា ក្នុងកាលតទៅ ខ្ញុំនឹងជាអ្នកមានបញ្ញាហើយឲ្យទាន មានប្រការផ្សេងៗ កុសលចិត្តចូលទៅអាស្រ័យកម្មបែបនេះ កាលកើតដល់បុគ្គលនោះ រមែងកើតឡើងដោយញាណសម្បយុត្ត ។ ម្យ៉ាងទៀត កាលបុគ្គលនោះ កើតក្នុងលោកដែលមិនមានការបៀតបៀន កុសលចិត្តដែលកើតឡើង រមែងកើត

ឡើងជាញាណសម្បយុត្ត ព្រោះអាស្រ័យការចូលដល់ដោយន័យ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) នេះថា ចំណែកធម៌ទាំងឡាយ រមែងប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្ដីសុខក្នុងទេវនិកាយនោះ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា ជាការយឺតយូរ ឯសត្វនោះវេលាដល់នូវគុណវិសេសក៏ឆាប់រហ័សជាងសតិនោះ ដូច្នេះជាដើម ។ មួយទៀត កុសលចិត្តកាលកើតឡើង រមែងកើតឡើងជាញាណសម្បយុត្ត ព្រោះអាស្រ័យការចាស់ជុំវិញនៃឥន្ទ្រិយ របស់បុគ្គលដែលចូលដល់ភាពចាស់ជុំវិញនៃឥន្ទ្រិយ គឺដែលដល់បញ្ញាទសកវ័យ ( អាយុ ៤០ ដល់ ៥០ ឆ្នាំ ) ។ បុគ្គលពួកណា សង្កត់កិលេសទាំងឡាយបានហើយ កុសលចិត្តដែលកើតឡើង រមែងកើតឡើងជាញាណសម្បយុត្ត ព្រោះអាស្រ័យភាពដែលបុគ្គលទាំងនោះ ជាអ្នកឆ្ងាយចាកកិលេស សមដូចដែលព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

> ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្ដីវិនាសប្រាជ្ញា រមែង
> កើតអំពីការមិនប្រកប ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបភាពដែលចិត្តសម្បយុត្តដោយញាណ ដោយហេតុទាំងនេះ គឺដោយកម្ម ដោយការចូលដល់ ដោយការចាស់ជុំវិញនៃឥន្ទ្រិយ ដោយភាពជាអ្នកឆ្ងាយចាកកិលេស ដោយប្រការដូច្នេះ ។

មួយវិញទៀត គប្បីជ្រាបភាពដែលចិត្តសម្បយុត្តដោយញាណ ក្នុងមហាកុសលចិត្តនេះ ដោយហេតុទាំងឡាយនេះ គឺធម៌ ៧ រមែងប្រព្រឹត្តទៅ

ដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ គឺ **បរិបុច្ឆកតា** ការសាកសួរ ១ **វត្ថុវិសទកិរិយា** ការធ្វើវត្ថុខាងក្នុង និងខាងក្រៅឲ្យស្អាត ១ **ឥន្ទ្រិយ-សមត្តបដិបាទនតា** ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ១ **ទុប្បញ្ញបុគ្គលបរិវជ្ជនា** ការវៀរបុគ្គលអាប់ឥតប្រាជ្ញា ១ **បញ្ញវន្តបុគ្គលសេវនា** ការសេពគប់បុគ្គលអ្នកមានបញ្ញា ១ **គម្ភីរញាណចរិយបច្ចវេក្ខណា** ការពិចារណាចរិយាដោយញាណដ៏ជ្រាលជ្រៅ ១ **តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ១ ។

ចំណែកសេចក្តីពិស្តារនៃហេតុទាំង ៧ នេះ នឹងជាក់ច្បាស់ក្នុងអដ្ឋកថានៃពោជ្ឈង្គវិភង្គ ។ កុសលចិត្តដែលកើតឡើងជាញាណសម្បយុត្ត ដោយអាការយ៉ាងនេះ ឈ្មោះថា **អសង្ខារិក** ព្រោះចិត្តនោះ កើតឡើងដោយអសង្ខារ ( មិនមានការដឹកនាំ ) ដោយមិនមានបយោគ ( មិនមានសេចក្តីព្យាយាម ) ដោយមិនត្រូវគិតដោយឧបាយ ។ កុសលចិត្ត ដែលឈ្មោះថា អសង្ខារិកនេះ មានពណ៌ដែលគួរប្រាថ្នាជាអារម្មណ៍កើតឡើងនោះឯង រមែងកើតឡើងដោយកំណត់ ៣ យ៉ាង គឺទានមយ សីលមយ និងភាវនាមយ ។

សួរថា កុសលញាណសម្បយុត្តចិត្ត ដែលឈ្មោះថា អសង្ខារិក ក្នុងទានមយជាដើមនោះ កើតឡើងបានយ៉ាងដូចម្តេច ឆ្លើយថា កាលណាបុគ្គលបានផ្កាឯណាមួយ បណ្តាផ្កាដែលមានពណ៌ខៀវ លឿង ក្រហម និងសជាដើម ហើយរំឭកដល់ពណ៌ផ្កានោះ ហើយបូជាព្រះពុទ្ធរតនៈជាដើម ដោយគិតថា

អញថ្វាយពណ៌ជាទាន កាលនោះ បុណ្យរមែងសម្រេចដោយទាន ។ ក្នុងទានមយនោះ មានរឿងពោលដូច្នេះថា

បានឮថា អ្នករក្សាឃ្លាំង មានឈ្មោះថា **សង្ឃមិត្ត** បានសំពត់រំលេចដោយមាសមួយផ្ទាំង ទើបគិតថា សំពត់នេះមានពណ៌លឿងដូចមាស សូម្បីព្រះសម្មាសម្ពុទ្ធ ក៏មានព្រះឆវីវណ្ណដូចមាស សំពត់មានពណ៌មាស សមគួរដល់អ្នកដែលមានពណ៌សម្បុរដូចមាសប៉ុណ្ណោះ ពួកយើងនឹងឲ្យពណ៌ជាទាន ដូច្នេះ ទើបឲ្យលើកឡើងព័ទ្ធមហាចេតិយ ។ កុសលញាណសម្បយុត្តចិត្តក្នុងកាលបែបនេះ បណ្ឌិតគប្បីជ្រាបថាជា **ទានមយ** ។

កាលណាបុគ្គលបានទេយ្យធម៌យ៉ាងនោះឯង ហើយបូជាព្រះរតនត្រ័យមានព្រះពុទ្ធរតនៈជាដើម ដោយការគិតថា នុ៎ះជាវង្សត្រកូល ជាបែបផែននៃត្រកូល ជាប្រពៃណីរបស់ត្រកូល ជាវត្តរបស់យើង ដូច្នេះ កាលនោះរមែងជា **សីលមយ** ។

កាលណាបុគ្គលធ្វើការបូជាព្រះត្រៃរត្នដោយវត្ថុបែបនោះ ហើយផ្ដើមចម្រើនការអស់ទៅ និងសូន្យទៅដោយមនសិការថា ពណ៌នេះនឹងដល់នូវការអស់ទៅ នឹងដល់នូវការសូន្យទៅ ដូច្នេះ កាលនោះរមែងជា **ភាវនាមយ** ។

ម្យ៉ាងទៀត កុសលញាណសម្បយុត្តចិត្តដែលជាទានមយ កំពុងប្រព្រឹត្តទៅ រមែងប្រព្រឹត្តទៅដល់បុគ្គលអ្នកបូជាព្រះត្រៃរត្ន ដោយដៃរបស់ខ្លួនក្នុងកាលណា ក្នុងកាលនោះជាកាយកម្ម ។ ក្នុងកាលណាបុគ្គលបូជាព្រះត្រៃរត្ន ទើបបញ្ជូនបុត្ត ភរិយា ទាសៈ កម្មករ និងអ្នកបម្រើជាដើមឲ្យបូជា ក្នុងកាល

នោះ ជាវចីកម្ម ។ ក្នុងកាលណា បុគ្គលប្រារព្ធវត្ថុទានដែលមាននៅ មាន ប្រការតាមដែលពោលហើយនោះឯង ហើយគិតថា យើងនឹងឲ្យពណ៌ជាទាន ដូច្នេះ ក្នុងកាលនោះ ជាមនោកម្ម ។

ម្យ៉ាងវិញទៀត ក្រឡេកមើលគន្លងព្រះវិន័យហើយ ឈ្មោះថា ទាន រមែងមានដោយលក្ខណៈនេះថា ការបន្លឺវាចាថា ខ្ញុំនឹងឲ្យ នឹងធ្វើ ដូច្នេះ តែបើក្រឡេកមើលគន្លងព្រះអភិធម្មហើយ ចិត្តរមែងជាកុសល ចាប់ផ្តើម អំពីវេលាដែលចិត្តគិតប្រារព្ធដល់វត្ថុ ដែលមាននៅថា ខ្ញុំនឹងឲ្យ ដូច្នេះ ។ លោកអធិប្បាយថា ក្នុងសម័យខាងក្រោយមក បុគ្គលនោះ នឹងធ្វើកិច្ចដែល គួរធ្វើដោយកាយ ឬដោយវាចា ។ ទានមយតាមដែលពោលមកនេះ ទើប មាន ៣ យ៉ាង គឺកាយកម្ម វចីកម្ម និងមនោកម្ម ។

ក្នុងកាលណា បុគ្គលបានវត្ថុមានប្រការតាមដែលពោលហើយនោះ រមែង បូជាព្រះត្រៃរត្នដោយដៃរបស់ខ្លួន ដោយអំណាចនៃវង្សត្រកូលជាដើម ក្នុង កាលនោះ កុសលចិត្តនោះ ក៏ជាសីលមយ ឬជាកាយកម្ម ។ ក្នុងកាលណា បញ្ជូនបុត្ត និងករិយាជាដើម ឲ្យបូជាដោយអំណាចនៃវង្សត្រកូលជាដើម ក្នុង កាលនោះ កុសលចិត្តនោះ ជាវចីកម្ម ។ ក្នុងកាលណាបុគ្គលប្រារព្ធវត្ថុដែល មានថា នុ៎ះជាវង្សត្រកូល ជាបែបផែនត្រកូល ជាប្រពៃណីត្រកូល ជាវត្ត របស់យើង ហើយគិតថា ខ្ញុំនឹងឲ្យពណ៌ជាទាន ក្នុងកាលនោះ កុសលចិត្ត នោះ ជាមនោកម្ម ។ កុសលចិត្តដែលជាសីលមយ មាន ៣ យ៉ាង គឺ កាយកម្ម វចីកម្ម និងមនោកម្ម ដោយប្រការដូច្នេះ ។

ក្នុងកាលណា បុគ្គលបានវត្ថុមានប្រការដូចពោលហើយនោះ បូជាព្រះត្រៃរត្ន ហើយដើរចង្ក្រម ផ្តើមចម្រើនការអស់ទៅ សូទ្យទៅ ក្នុងកាលនោះ កុសលចិត្ត ជាការទាមយ ជាកាយកម្ម ។ កាលបុគ្គលផ្តើមតាំងការពិចារណាដោយវាចា ជាវចីកម្ម កាលបុគ្គលមិនកម្រើកកាយ និងវាចា ផ្តើមពិចារណាដោយចិត្តប៉ុណ្ណោះ ជាមនោកម្មនោះឯង ។ កុសលចិត្តដែលជាការទាមយ មាន ៣ យ៉ាង គឺកាយកម្ម វចីកម្ម និងមនោកម្ម ដោយប្រការដូច្នេះ ។ ក្នុងអធិការនេះ ព្រះធម្មរាជាទ្រង់ចែកសម្តែងកុសលដែលមានរូបជាអារម្មណ៍ ដោយកម្មទ្វារ ៩ យ៉ាង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ ដោយប្រការដូច្នេះ ។ សូម្បីក្នុងសទ្ទារម្មណ៍ជាដើម ក៏ន័យនេះឯង ។

សេចក្តីពិត កុសលចិត្តនេះធ្វើសំឡេងដែលជាទីតាំងនៃសេចក្តីត្រេកអរក្នុងសំឡេងស្គរជាដើម ឲ្យជាអារម្មណ៍កើតឡើង មានកំណត់ ៣ យ៉ាង ដោយន័យដែលពោលមកហើយនុ៎ះឯង ។ បណ្តាកុសលចិត្តដែលជាទានមយជាដើមទាំងនោះ ធម្មតាបុគ្គលណាមួយ មិនអាចដាក់សំឡេងក្នុងដៃ ហើយឲ្យ ដូចដកក្រអៅឈូកឡើង ហើយដាក់ក្នុងដៃ និងដូចដាក់បាច់ផ្កាឧប្បលខៀវក្នុងដៃ តែកាលបុគ្គលឲ្យសំឡេង មួយអន្លើដោយវត្ថុ ( ដូចជាស្គរ ជួងជាដើម ) ឈ្មោះថា រមែងឲ្យសំឡេងជាទាន ព្រោះហេតុនោះ ក្នុងកាលណា បុគ្គលគិតថា អញនឹងឲ្យសំឡេងជាទាន ទើបធ្វើការបូជាព្រះត្រៃរត្ន ដោយតូរ្យតន្ត្រីណានីមួយ មានស្គរ និងសម្ភោរជាដើម វាយស្គរជាដើម ដោយគិតថា នេះជាការឲ្យសំឡេងជាទានរបស់អញ ឲ្យកេសជ្ជៈ

ប្រេង ស្ករអំពៅជាដើម ដើម្បីប្រយោជន៍ដល់សំឡេង ដល់កិច្ចជាធម្មកថិកទាំងឡាយ ឃោសនាការស្តាប់ធម៌ សូត្រសរភញ្ញ ពោលធម្មកថា ឧបនិសិន្នកថា អនុមោទនាកថា ក្នុងកាលនោះ កុសលចិត្តនោះ រមែងជាទានមយ ។ ក្នុងកាលណា បុគ្គលធ្វើវិធីយ៉ាងនេះឯង ដោយអំណាចនៃវង្សត្រកូលជាដើម ដោយអំណាចនៃវត្ត ក្នុងកាលនោះ កុសលចិត្តនោះ រមែងជាសីលមយ ។ ក្នុងកាលណា បុគ្គលធ្វើវិធីទាំងអស់នោះ ហើយផ្តើមពិចារណាថា សំឡេងមានប្រមាណប៉ុណ្ណេះ សូម្បីឮដល់ព្រហ្មលោកក៏នឹងដល់នូវការអស់ទៅ នឹងដល់នូវការសូន្យទៅ ក្នុងកាលនោះ កុសលចិត្តនោះ រមែងជាភាវនាមយ ។

បណ្តាបុញ្ញកិរិយាវត្ថុទាំងនោះ នឹងពោលកុសលចិត្ត ដែលជាទានមយមុន ។ ក្នុងកាលណា បុគ្គលកាន់យកគ្រឿងតូរ្យតន្ត្រី មានស្គរជាដើម ធ្វើការបូជាព្រះត្រៃរត្នដោយដៃរបស់ខ្លួន សូម្បីនឹងតាំងទុក ដើម្បីបូជាជាប្រចាំក៏ទុកដាក់ដោយដៃរបស់ខ្លួន រមែងដើរប្រកាសការស្តាប់ធម៌ ដោយគិតថា នេះជាការឲ្យសំឡេងជាទានរបស់អញ រមែងទៅដើម្បីពោលធម្មកថា សូត្រសរភញ្ញ ក្នុងកាលនោះ កុសលចិត្តនោះ ជាកាយកម្ម ។ ក្នុងកាលណា ប្រើបុគ្គលដទៃថា ម្នាលអ្នកទាំងឡាយ ចូរអ្នកទៅ ចូរធ្វើសំឡេងជាទាន បូជាព្រះត្រៃរត្នជំនួសយើងទាំងឡាយ ដូច្នេះ គិតថា អញនឹងឲ្យសំឡេងជាទានទើបប្រើបុគ្គលដទៃថា អ្នកទាំងឡាយ ចូរទុកដាក់ស្គរនេះ សម្ភោរនេះ ត្រង់លានព្រះចេតិយ ប្រកាសការស្តាប់ធម៌ ពោលធម្មកថា សូធ្យសរភញ្ញដោយខ្លួនឯង ក្នុងកាលនោះ កុសលចិត្តនោះ ជាវចីកម្ម ។ ក្នុងកាលណា បុគ្គល

មិនកម្រើកកាយ និងវាចា លះវត្ថុដែលមានដោយចិត្តថា អញនឹងឲ្យសំឡេងជាទាន ក្នុងកាលនោះ កុសលចិត្ត ជាមនោកម្ម ។

កុសលចិត្តដែលជាសីលមយ កាលបុគ្គលគិតថា ឈ្មោះថា ការឲ្យសំឡេងជាទាន ជាវង្សត្រកូល ជាបែបផែនត្រកូល ជាប្រពៃណីត្រកូលរបស់ពួកយើងដូច្នេះ ការធ្វើស្គរជាដើម ឲ្យជាគ្រឿងបូជាព្រះរតនត្រ័យ ដោយដៃរបស់ខ្លួន ដាក់ស្គរជាដើមត្រង់លានព្រះចេតិយជាដើម ដោយដៃរបស់ខ្លួនប្រគេនភេសជ្ជៈ ដើម្បីជាប្រយោជន៍ដល់សំឡេង ដល់ធម្មកថិកទាំងឡាយដោយដៃរបស់ខ្លួន និងទៅដើម្បីប្រយោជន៍ដល់ការប្រកាសការស្ដាប់ធម៌ពោលធម្មកថា សូត្រសរភញ្ញដោយកាន់យកវត្តជាធំ ជាកាយកម្ម ។ កាលប្រើបុគ្គលដទៃថា ឈ្មោះថា ការឲ្យសំឡេងជាទាន ជាវង្សត្រកូល ជាបែបផែនត្រកូល ជាប្រពៃណីត្រកូលរបស់យើង ចូរអ្នកទាំងឡាយទៅ ចូរធ្វើការបូជាពុទ្ធរតនៈជាដើម ដូច្នេះ និងកាលធ្វើការពោលធម៌ ឬសូត្រសរភញ្ញដោយខ្លួនឯង ដោយអំណាចនៃវង្សត្រកូលនោះឯង ជាវចីកម្ម ។ កាលគិតថា ឈ្មោះថា ការឲ្យសំឡេងជាទាន ជាវង្សត្រកូលរបស់អញ អញនឹងឲ្យសំឡេងជាទានដូច្នេះ មិនកម្រើកកាយ និងវាចា លះវត្ថុដែលមានដោយចិត្តនោះឯង ក្នុងកាលនោះ ជាមនោកម្ម ។

កុសលចិត្តដែលជាភាវនាមយ ក្នុងកាលណា បុគ្គលកំពុងដើរ ផ្ដើមចម្រើនការអស់ទៅ សូន្យទៅក្នុងសំឡេង ក្នុងកាលនោះ ជាកាយកម្ម ។ ឬកាលបុគ្គលមិនកម្រើកកាយ ពិចារណាតាមវាចា ជាវចីកម្ម កាលបុគ្គល

មិនកម្រើកកាយ និងវាចា ពិចារណានូវសទ្ទាយតនៈដោយចិត្តនោះឯង ជាមនោកម្ម ។ ព្រះធម្មរាជាទ្រង់សំដែងកុសលចិត្ត មានសំឡេង ជាអារម្មណ៍ ដោយកម្មទ្វារ ៩ យ៉ាង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ ដូចពណ៌នាមក ដូច្នេះ ។

កុសលចិត្តនេះ ធ្វើក្លិនដែលគួរគាប់ចិត្ត ក្នុងក្លិនដែលកើតអំពីឫសឈើជាដើម ឲ្យជាអារម្មណ៍កើតឡើង ដោយការកំណត់ ៣ យ៉ាង ដោយន័យដែលពោលហើយខាងដើមនុ៎ះឯង ។ ក្នុងកំណត់ ៣ យ៉ាងនោះ ក្នុងកាលណាបុគ្គលបានក្លិនក្រអូបណានីមួយ មានក្លិនដែលកើតអំពីឫសឈើជាដើម ហើយចងចិត្តដោយអំណាចនៃក្លិន គិតថា អញនឹងឲ្យក្លិនជាទាន ដូច្នេះ ទើបបូជាព្រះពុទ្ធរតនៈជាដើម ក្នុងកាលនោះ កុសលចិត្ត ជាទានមយ ។ បណ្ឌិតគប្បីជ្រាបពាក្យទាំងអស់ ដោយពិស្តារដោយន័យដែលពោលក្នុងការឲ្យពណ៌ជាទាននុ៎ះឯង ព្រះធម្មរាជាទ្រង់សំដែងនូវកុសលចិត្ត មានក្លិនជាអារម្មណ៍ដោយកម្មទ្វារ ៩ យ៉ាង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ ដោយប្រការដូច្នេះ ។

កុសលចិត្តនេះ ដែលធ្វើរសគួរជាទីគាប់ចិត្ត មានរសកើតអំពីឫសឈើជាដើមឲ្យជាអារម្មណ៍ រមែងកើតឡើងមានកំណត់ ៣ យ៉ាង ដោយន័យដែលពោលហើយខាងដើមនុ៎ះឯង ក្នុងកំណត់ ៣ យ៉ាងនោះ ក្នុងកាលណាបុគ្គលបានវត្ថុ មានរសជាទីត្រេកអរណាមួយ មានរសកើតអំពីឫសឈើជាដើម ហើយចងចិត្តដោយអំណាចនៃរស រមែងឲ្យ រមែងលះបង់ ដោយ

គិតថា អញនឹងឲ្យរសជាទាន ក្នុងកាលនោះ កុសលចិត្ត ជាទានមយ ។ គប្បីជ្រាបសេចក្ដីទាំងពួងដោយពិស្ដារ តាមន័យដែលពោល ក្នុងការឲ្យពណ៌ជាទាននោះឯង ។ ក្នុងកុសលចិត្តដែលជាសីលមយ ក្នុងការឲ្យរសជាទាននេះ មានរឿងជាច្រើនមកក្នុងមហាអដ្ឋកថា ដូចជារឿងរបស់ព្រះបាទទុដ្ឋគាមណិអភ័យ ដែលទ្រង់ព្រះតម្រិះថា ធម្មតាការមិនប្រគេនសង្ឃទានហើយបរិភោគ អញមិនធ្លាប់ប្រព្រឹត្តឡើយ ដូច្នេះ ទើបប្រគេនទានដល់ភិក្ខុប្រមាណ ១២,០០០ រូប ហើយទើបសោយព្រះក្រយាហារ មានរសល្អ ។ សេចក្ដីផ្សេងគ្នាមានត្រឹមប៉ុណ្ណេះ ។ ព្រះមានព្រះភាគ ជាព្រះធម្មរាជា ទ្រង់ចែកសម្ដែងកុសលចិត្ត មានរសជាអារម្មណ៍ដោយកម្មទ្វារ ៩ យ៉ាងដោយអំណាចបុញ្ញកិរិយាវត្ថុ ៣ នុ៎ះឯង ដោយប្រការដូច្នេះ ។

សូម្បីក្នុងផោដ្ឋព្វារម្មណ៍ មហាភូតរូប ៣ គឺបឋវីធាតុ តេជោធាតុ វាយោធាតុ ឈ្មោះថា **ផោដ្ឋព្វារម្មណ៍** ។ ក្នុងទីនេះ បណ្ឌិតកុំលើកមហាភូតរូប ៣ ទាំងនេះ មកអធិប្បាយ គប្បីលើកគ្រែនិងតាំងជាដើមមកអធិប្បាយ ។ ពិតណាស់ ក្នុងកាលណា បុគ្គលបានវត្ថុដែលត្រូវប៉ះពាល់ គួរជាទីប្រាថ្នាយ៉ាងណានីមួយក្នុងវត្ថុទាំងឡាយ មានគ្រែនិងតាំងជាដើម ហើយគិតដោយអំណាចនៃការប៉ះពាល់ រមែងឲ្យ រមែងបរិច្ចាគ ដោយគិតថា អញនឹងឲ្យផោដ្ឋព្វៈជាទាន ក្នុងកាលនោះ កុសលចិត្ត ជាទានមយ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីទាំងពួងដោយពិស្ដារតាមន័យដែលពោល ក្នុងការឲ្យពណ៌ជាទាននុ៎ះឯង ។ ព្រះធម្មរាជា ទ្រង់ចែកសម្ដែងកុសលចិត្ត មានផោដ្ឋព្វៈជា

អារម្មណ៍ ដោយកម្មទ្វារ ៩ យ៉ាង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ ដោយប្រការដូច្នេះ ។

ចំណែកក្នុងធម្មារម្មណ៍ ធម៌ទាំងឡាយដែលជាបរិយាបន្នៈ ( ទាក់ទងក្នុងវដ្តៈ ) និងអបរិយាបន្នៈក្នុងធម្មាយតនៈទាំងនេះ គឺអាយតនៈខាងក្នុង ៦ លក្ខណៈ ៣ អរូបក្ខន្ធ ៣ សុខុមរូប ១៥ និព្វាន និងបញ្ញត្តិ ឈ្មោះថា **ធម្មារម្មណ៍** ។ តែក្នុងទីនេះ បណ្ឌិតកុំលើកយកធម៌ទាំងនេះ មកអធិប្បាយ គប្បីលើកការឲ្យឱជៈ ការឲ្យទឹកបានៈ និងការឲ្យជីវិតជាទានមកអធិប្បាយ ។ ពិតហើយ កុសលចិត្តនេះ ធ្វើធម្មារម្មណ៍ដែលគួរត្រេកអរក្នុងឱជៈជាដើមឲ្យជាអារម្មណ៍ កើតឡើងដោយការកំណត់ ៣ យ៉ាង ដោយន័យដែលពោលហើយខាងដើមនុ៎ះឯង ។

ក្នុងកំណត់ ៣ យ៉ាងនោះ កាលណាបុគ្គលគិតថា អញនឹងឲ្យឱជៈជាទាន ទើបប្រគេនសប្បិ និងនវនីតជាដើម គិតថា អញនឹងឲ្យទឹកបានៈជាទាន ទើបប្រគេនទឹកបានៈ ៨ យ៉ាង គិតថា អញនឹងឲ្យជីវិតជាទាន ទើបថ្វាយសលាកភត្ត បក្ខិយភត្ត និងសង្ឃភត្តជាដើម ប្រគេនភេសជ្ជៈដល់ភិក្ខុដែលមិនមានផាសុក ( មានជំងឺ ) ទាំងឡាយ ឲ្យគ្រូពេទ្យមកព្យាបាល ឲ្យដុតសំណាញ់ ឲ្យរុះរើលប ឲ្យបំផ្លាញទ្រុងបក្សី ឲ្យរួចចេញពីគុក ឲ្យគេវាយស្គរហាមសម្លាប់សត្វ ធ្វើកម្មបែបនេះសូម្បីដទៃៗ ទៀត ដើម្បីការពារជីវិត ក្នុងកាលនោះ កុសលចិត្តក៏ជាទានមយ ។ មួយទៀត ក្នុងកាលណាបុគ្គលគិតថា ការឲ្យឱជៈជាទាន ឲ្យទឹកបានៈជាទាន ឲ្យជីវិតជាទាន ជាវង្សត្រកូល

ជាបែបផែនរបស់ត្រកូល ជាប្រពៃណីរបស់ត្រកូលរបស់យើង ដូច្នេះ ទើបញ៉ាំងទាន មានឱជះជាដើម ឲ្យប្រព្រឹត្តទៅដោយកាន់យកវត្តជាធំ ក្នុងកាលនោះ កុសលចិត្តជាសីលមយ ។ ក្នុងកាលណា ផ្តើមចម្រើនការអស់ទៅសូន្យទៅក្នុងធម្មារម្មណ៍ ក្នុងកាលនោះ កុសលចិត្តជាភាវនាមយ ។ម្យ៉ាងទៀត កុសលចិត្តដែលជាទានមយ សូម្បីកំពុងប្រព្រឹត្តទៅ ក្នុងវេលាដែលបុគ្គលឲ្យឱជះជាទាន ឲ្យទឹកបានះជាទាន ឲ្យជីវិតជាទាន ដោយដៃរបស់ខ្លួនជាកាយកម្ម ។ ក្នុងកាលដែលប្រើបុត្ត និងភរិយាជាដើម ឲ្យថ្វាយទាន ជាវចីកម្ម ក្នុងកាលដែលមិនកម្រើកកាយ និងវាចា គិតដោយចិត្តថា អញនឹងឲ្យវត្ថុដែលមាននៅ ដោយអំណាចនៃការឲ្យឱជះជាទាន ឲ្យទឹកបានះជាទានឲ្យជីវិតជាទាន ដូច្នេះ ជាមនោកម្ម ។

ម្យ៉ាងទៀត ក្នុងកាលណា បុគ្គលឲ្យវត្ថុដែលមាននៅ មានប្រការដូចដែលពោលមកហើយដោយដៃរបស់ខ្លួន ដោយអំណាចនៃវង្សត្រកូលជាដើមក្នុងកាលនោះ កុសលចិត្តដែលជាសីលមយ រមែងជាកាយកម្ម ។ ក្នុងកាលណា ប្រើកូន និងប្រពន្ធជាដើមឲ្យឲ្យ ដោយអំណាចនៃវង្សត្រកូលជាដើមនុ៎ះឯង ក្នុងកាលនោះ ជាវចីកម្ម ។ ក្នុងកាលណា គិតដោយចិត្តថាអញនឹងឲ្យវត្ថុដែលមាននៅ មានប្រការតាមដែលពោលហើយដោយអំណាចនៃវង្សត្រកូលជាដើមនុ៎ះឯង ក្នុងកាលនោះ ជាមនោកម្ម ។

មួយទៀត កាលបុគ្គលដើរចង្ក្រម ផ្តើមតាំងការអស់ទៅ សូន្យទៅក្នុងធម្មារម្មណ៍ កុសលចិត្តដែលជាភាវនាមយ ជាកាយកម្ម ។ កាលបុគ្គល

មិនកម្រើកកាយ ហើយផ្ដើមចម្រើនការអស់ទៅ សូន្យទៅដោយវាចា ជាវចីកម្ម ។ កាលបុគ្គល មិនកម្រើកកាយ និងវាចា ផ្ដើមចម្រើនការអស់ទៅសូន្យទៅ ក្នុងធម្មារម្មណ៍ដោយចិត្តប៉ុណ្ណោះ ជាមនោកម្ម ។ កុសលចិត្តដែលជាកាមាវចរ រមែងមាន ៣ យ៉ាង គឺកាយកម្ម វចីកម្ម និងមនោកម្ម ដោយប្រការដូច្នេះ ។ ព្រះធម្មរាជា ទ្រង់ចែកសម្ដែងកុសលចិត្តដែលជាធម្មារម្មណ៍ក្នុងទីនេះ ដោយកម្មទ្វារ ៩ យ៉ាង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ ដូចពណ៌នាមក ដូច្នេះ ។

ចិត្តនេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងហើយយ៉ាងនេះ ដោយអំណាចនៃវត្ថុផ្សេងគ្នា និងអារម្មណ៍ផ្សេងគ្នា ។ តែក្នុងវត្ថុណាមួយ រមែងបានចិត្តនេះដោយអំណាចនៃអារម្មណ៍ច្រើនយ៉ាងនេះឯង ។ សួរថា បានដូចម្ដេច ឆ្លើយថា ក្នុងបច្ច័យ ៤ ចំពោះក្នុងចីវរ បណ្ឌិត រមែងបានអារម្មណ៍ ៦ យ៉ាង ។ ពិតហើយ ពណ៌នៃចីវរដែលជ្រលក់ថ្មីៗ ជាពណ៌ដែលគួរពេញចិត្ត គួររមិលមើល នេះហៅថា មានពណ៌ជាអារម្មណ៍ ។ ក្នុងវេលាប្រើប្រាស់ រមែងមានសំឡេង បដ: បដ: នេះជាសទ្ទារម្មណ៍ ។ ក្នុងសំពត់នោះ មានក្លិនសម្បុកមក្លៀជាដើម នេះជាគន្ធារម្មណ៍ ។ ចំណែករសារម្មណ៍ លោកពោលដោយអំណាចនៃរស គឺ ការប្រើប្រាស់ ។ ក្នុងសំពត់នោះ មានសម្ផស្សជាសុខ នេះជាផោដ្ឋព្វារម្មណ៍ ។ សុខវេទនា កើតឡើងព្រោះអាស្រ័យចីវរនេះជាធម្មារម្មណ៍ ។ រសារម្មណ៍ក្នុងបិណ្ឌបាត រមែងបានរសារម្មណ៍ដោយត្រង់ បណ្ឌិតគប្បីលើកអារម្មណ៍ផ្សេងៗ ក្នុងបច្ច័យ ៤ មកអធិប្បាយយ៉ាង

នេះហើយ ជ្រាបការផ្សេងគ្នានៃចិត្តដែលជាទានមយជាដើម ។

មួយទៀត អារម្មណ៍នៃចិត្តនេះ ជាចំណង ( គ្រឿងតោងរបស់ចិត្ត ) ព្រោះវៀរចាកអារម្មណ៍ហើយ ចិត្តក៏មិនកើតឡើង ។ ចំណែកទ្វារ មិនមែនជាចំណង ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកម្មជាសភាវៈមិនចង ។ ពិតហើយ កាលកម្មមិនចងចិត្ត សូម្បីទ្វារក៏ឈ្មោះថា មិនចង ដូចគ្នា ។

# ទ្វារនៃកាមាវចរកុសល

## ទ្វារនៃកាយកម្ម

ទ្វារកថាក្នុងមហាអដ្ឋកថា លោកពោលក្នុងទីនេះ ដើម្បីប្រកាសសេចក្តីនេះ ។ ក្នុងមហាអដ្ឋកថានោះ ពាក្យមានប្រមាណប៉ុណ្ណេះ ជាការតាំងមាតិកានៃទ្វារកថា គឺកម្ម ៣ ទ្វារនៃកម្ម ៣ វិញ្ញាណ ៥ ទ្វារនៃវិញ្ញាណ ៥ ផស្សៈ ៦ ទ្វារនៃផស្សៈ ៦ អសំវរៈ ៨ ទ្វារនៃអសំវរៈ ៨ សំវរៈ ៨ ទ្វារនៃសំវរៈ ៨ កុសលកម្មបថ ១០ អកុសលកម្មបថ ១០ ។

ក្នុងការតាំងមាតិកាទាំងនោះ កម្ម ៣ យ៉ាង លោកពោលមុនក៏ពិតមែន តែក៏វៀរកម្មទាំង ៣ នោះ ហើយផ្តើមសម្តែងចែកទ្វារនៃកម្ម ៣ មុន ។

សួរថា ទ្វារនៃកម្ម ៣ តើដូចម្តេច ឆ្លើយថា ទ្វារនៃកាយកម្ម ទ្វារនៃវចីកម្ម ទ្វារនៃមនោកម្ម ។

ក្នុងទ្វារនៃកាយកម្មនោះ កាយមាន ៤ យ៉ាង គឺឧបាទិន្នកកាយ ( កាយដែលមានចិត្តគ្រប់គ្រង ) ១ អាហារសមុដ្ឋានកាយ ១ ឧតុសមុដ្ឋានកាយ ១ ចិត្តសមុដ្ឋានកាយ ១ បណ្តាកាយទាំង ៤ នោះ រូបដែលមានកម្មជាសមុដ្ឋាន ៨[១] មានចក្ខាយតនៈជាដើម មានជីវិតិន្ទ្រិយជាទីបំផុត រូប ៨ គឺធាតុ ៤ វណ្ណៈ គន្ធៈ រសៈ ឱជា ដែលមានកម្មជាសមុដ្ឋាននោះឯង ឈ្មោះថា **ឧបាទិន្នកកាយ** ។

រូបទាំង ៨ នោះឯង កើតអំពីអាហារ ឈ្មោះថា **អាហារសមុដ្ឋានិក-**

១- ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ ឥត្ថី បុរិស ជីវិតិន្ទ្រិយ ។

**កាយ** រូប ៨ កើតអំពីឧតុ ឈ្មោះថា **ឧតុសមុដ្ឋានិកកាយ** រូប ៨ កើតអំពីចិត្ត ឈ្មោះថា **ចិត្តសមុដ្ឋានិកកាយ** ។

បណ្តាឧបាទិន្នកកាយជាដើមនោះ ពាក្យថា ទ្វារនៃកាយកម្ម មិនបានជាឈ្មោះនៃឧបាទិន្នកកាយ មិនបានជាឈ្មោះនៃកាយក្រៅពីនេះ តែក្នុងរូប ៨ មានចិត្តជាសមុដ្ឋាន មានវិញ្ញត្តិរូបមួយ រូបនេះ ដែលទ្រង់សំដៅយក ត្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ថា រូបជាកាយវិញ្ញត្តិនោះ តើដូចម្តេច ។ ការទប់កាយ ការគាំទ្រកាយ ការទប់ទល់កាយ ការកម្រើកកាយ អាការញុំាងកាយឲ្យកម្រើក ភាពញុំាងកាយឲ្យកម្រើកណា នៃបុគ្គលមានចិត្តជាកុសលក្តី មានចិត្តជាអកុសលក្តី មានចិត្តជាអព្យាក្រឹតក្តី កាលឈានទៅមុខក្តី ឈានថយក្រោយក្តី សម្លឹងមើលក្តី ក្រឡេកមើលក្តី បត់ចូលក្តី លាចេញក្តី នេះរូបជាកាយវិញ្ញត្តិ ដូច្នេះ ឈ្មោះថា ទ្វារនៃកាយកម្ម ។

ពិតហើយ ចិត្តដែលកើតឡើងថា អញនឹងឈានទៅមុខ នឹងឈានថយក្រោយ ដូច្នេះ រមែងញុំាងរូបឲ្យតាំងឡើង ។ ក្នុងខណៈនៃចិត្តដែលកើតឡើងនោះ វាយោធាតុមានចិត្តជាសមុដ្ឋានក្នុងខាងក្នុងនៃរូបកលាបៈទាំង ៨ នេះ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ វណ្ណៈ គន្ធៈ រសៈ ឱជា ដែលអាស្រ័យធាតុទាំង ៤ នោះ រមែងឧបត្ថម្ភ ទ្រទ្រង់ ញុំាងរូបកាយដែលកើតព្រមជាមួយនឹងខ្លួននោះឲ្យកម្រើក ឲ្យឈានទៅមុខ ឲ្យឈានថយក្រោយ ។

ក្នុងរូបកលាបៈទាំង ៨ នោះ វាយោធាតុដែលតាំងឡើងដោយចិត្តដូង

ដំបូងក្នុងជវនចិត្ត ៧ ដួង ក្នុងអាវជ្ជនវិថីមួយ រមែងអាចឧបត្ថម្ភទ្រទ្រង់នូវរូបកាយ ដែលកើតព្រមជាមួយនឹងខ្លួនបាន តែមិនអាចឲ្យកម្រើកទៅមក សូម្បីក្នុងជវនចិត្តដួងទី ២ ជាដើម ក៏ន័យនេះឯង ។ ចំណែកវាយោធាតុដែលតាំងឡើងដោយជវនចិត្តដួងទី ៧ បានវាយោធាតុដែលតាំងឡើងដោយជវនចិត្ត ៦ ដួងខាងដើម ជាបច្ច័យឧបត្ថម្ភហើយ រមែងអាចដើម្បីឧបត្ថម្ភ ដើម្បីទ្រទ្រង់ ដើម្បីញុំាងរូបកាយ ដែលកើតព្រមជាមួយនឹងខ្លួនឲ្យកម្រើក ឲ្យឈានទៅមុខ ឲ្យត្រឡប់ថយក្រោយ ឲ្យក្រឡេកមើល ឲ្យងាកឆ្វេងស្តាំ ឲ្យបត់ចូល ឲ្យលាចេញ ព្រោះហេតុនោះ ទើបឈ្មោះថា កើតការដើរទៅ ឈ្មោះថា កើតការដើរមក ឈ្មោះថា កើតការដើរទៅដើរមក គឺរមែងឲ្យដល់ពាក្យ ដែលបុគ្គលគប្បីពោលថា ទៅបានមួយយោជន៍ ទៅបាន ១០ យោជន៍ ដូច្នេះ ។

ដូចកាលរទេះដែលគប្បីអូសទៅដោយនឹម ៧ នឹម គោដែលទឹមហើយក្នុងនឹមដំបូង រមែងអាចដើម្បីគាំទ្រ ដើម្បីទ្រទ្រង់នូវនឹមបានមុន តែមិនអាចឲ្យកង់វិលទៅ សូម្បីក្នុងគូទី ២ ជាដើម ក៏ន័យនេះដូចគ្នា តែក្នុងកាលណាសារថីដែលឈ្លាសវៃ ទឹមគោគូទី ៧ ក្នុងនឹម អង្គុយនៅលើទូករទេះ កាន់ខ្សែហើយ យកចុងជន្លួញជញគូនៃគោ ចាប់ផ្តើមពីគូដំបូងបង្អស់ ក្នុងកាលនោះ គូនៃគោទាំងអស់នោះឯងក៏រួមកម្លាំងគ្នាទ្រទ្រង់នូវនឹម និងឲ្យកង់វិលទៅ រមែងដល់នូវពាក្យដែលបុគ្គលគប្បីនិយាយបានថា គោនាំរទេះទៅបាន ១០ យោជន៍ ២០ យោជន៍ យ៉ាងណា បណ្ឌិតគប្បីជ្រាបពាក្យ

ឧបមាឧបមេយ្យក្នុងរឿងនេះ ក៏យ៉ាងនោះ ។

ក្នុងកាយទាំង ៤ នោះ កាយដែលមានចិត្តជាសមុដ្ឋាន មិនមែនវិញ្ញត្តិ តែវិការនៃអាការមួយដែលអាចដើម្បីជាបច្ច័យ ដើម្បីគាំទ្រ ដើម្បីទ្រទ្រង់ទុក ដើម្បីញុំាងរូបកាយដែលកើតព្រមគ្នានឹងវាយោធាតុ ដែលមានចិត្តជាសមុដ្ឋាន ឲ្យកម្រើកបាន នេះឈ្មោះថា **វិញ្ញត្តិ** ។ វិញ្ញត្តិនោះ មិនមែនមានចិត្តជាសមុដ្ឋាន ដូចរូប ៨ យ៉ាង ។ ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ជរា មរណៈមិនទៀង ជាធម្មជាតដែលបច្ច័យប្រជុំតាក់តែង ដូច្នេះជាដើម យ៉ាងណា វិញ្ញត្តិនោះ ឈ្មោះថាមានចិត្តជាសមុដ្ឋាន ព្រោះរូបទាំងឡាយ មានចិត្តជាសមុដ្ឋានជាវិញ្ញត្តិ ក៏យ៉ាងនោះ ។

វិញ្ញត្តិនោះ ហៅថា **វិញ្ញត្តិ** ព្រោះប្រកាសឲ្យដឹង ។ សួរថា ប្រកាសឲ្យដឹងអ្វី ឆ្លើយថា ប្រកាសឲ្យដឹងការធ្វើផ្លូវកាយណាមួយ ពិតហើយ បុគ្គលឈរនៅក្នុងគន្លងនៃចក្ខុ លើកដៃ ឬជើង គ្រវីក្បាល ឬញាក់ចិញ្ចើម អាការនៃដៃជាដើមនេះ រមែងដឹងច្បាស់បានដោយចក្ខុ ។ វិញ្ញត្តិមិនដឹងបានដោយភ្នែក តែដឹងបានដោយចិត្តប៉ុណ្ណោះ ព្រោះថា បុគ្គលរមែងឃើញអារម្មណ៍ គឺពណ៌កម្រើកទៅមក ដោយអំណាចនៃការកម្រើកដៃជាដើម ដោយភ្នែក តែបុគ្គលគិតដល់រូបដែលប្រកាសឲ្យដឹងដោយចិត្តតាមមនោទ្វារហើយ ទើបដឹងថា បុគ្គលនេះ ប្រហែលជាឲ្យយើងធ្វើវត្ថុនេះ និងវត្ថុនេះ ដូច្នេះ ។

ដូចពួកមនុស្សឲ្យចងស្លឹកត្នោតជាដើម លើចុងឈើ ក្នុងទីដែលមានទឹក

ក្នុងរដូវប្រាំងក្នុងព្រៃ ដោយបំណងថា ជនទាំងឡាយនឹងដឹងថា ទឹកមានក្នុងទីនេះ ដោយសញ្ញានេះ ឬលើកទង់ឡើងត្រង់ទ្វារនៃតៀមស្រា ឬខ្យល់បក់ដើមឈើខ្ពស់ឲ្យកម្រើក ឬកាលត្រីហែបហែលនៅក្នុងទឹក ពពុះទឹកក៏ផុសឡើងខាងលើ ឬកម្ទេចស្មៅ ស្លឹកឈើ ត្រូវជំនន់ទឹកជំបន្សាត់ទៅជាប់តាមប្រាំងតាមផ្លូវដែលទឹកធ្លាប់ជន់កន្លងមកហើយ បុគ្គលឃើញស្លឹកត្នោត ទង់ មែកឈើកម្រើក ពពុះទឹក កម្ទេចស្មៅ ស្លឹកឈើក្នុងទីនោះ រមែងដឹងដោយមនោវិញ្ញាណនូវវត្ថុ ដែលខ្លួនមិនឃើញដោយភ្នែកថា ក្នុងទីនេះ នឹងមានទឹក នឹងមានសុរា ដើមឈើនេះគង់ត្រូវខ្យល់បក់ ខាងក្នុងទឹកនឹងមានត្រី ទឹកជំនន់ហូរលិចក្នុងទីមានប្រមាណប៉ុណ្ណេះ យ៉ាងណា សូម្បីវិញ្ញត្តិក៏យ៉ាងនោះដូចគ្នា មិនដឹងដោយភ្នែក ដឹងបានដោយចិត្ត ព្រោះថា បុគ្គលរមែងឃើញអារម្មណ៍ គឺពណ៌កម្រើកទៅមកដោយអំណាចនៃការលើកដៃជាដើម ដោយភ្នែកប៉ុណ្ណោះ តែបុគ្គលនោះ គិតដល់រូបដែលប្រកាសឲ្យដឹងដោយចិត្តតាមមនោទ្វារ ទើបដឹងថា បុគ្គលនេះ ប្រហែលជាឲ្យអញធ្វើវត្ថុនេះ និងវត្ថុនេះ ។

វិញ្ញត្តិនេះ ឈ្មោះថា **វិញ្ញត្តិ** ព្រោះការប្រកាសឲ្យដឹងតែម្យ៉ាងក៏ទេ តាមពិត ឈ្មោះថា **វិញ្ញត្តិ** នោះឯង ព្រោះគួរដឹងបានក៏មាន ។ វិញ្ញត្តិនេះរមែងប្រាកដដល់ជនទាំងឡាយពួកដទៃ ដោយហោចសូម្បីដល់សត្វតិរច្ឆាន ។ ពិតហើយ សត្វតិរច្ឆានទាំងឡាយ មានឆ្កែស្រុក ឆ្កែចចក ក្អែក គោជាដើម ដែលប្រជុំគ្នាក្នុងទីនោះៗ កាលបុគ្គលចាប់ដំបង ឬដុំដីសម្ដែងអាការប្រទូស្ត ក៏ដឹងថា មនុស្សនេះចង់ប្រហារពួកយើង រមែងគេចទៅក្នុងទីណា

មួយ ៗ តែវិញ្ញត្តិក៏មានសូម្បីក្នុងវេលា ដែលមិនប្រាកដដល់បុគ្គលដទៃដែលនៅខាងក្នុងកំពែង និងជញ្ជាំងផ្ទះជាដើម ៗ ក្នុងខណៈនោះ វិញ្ញត្តិមិនប្រាកដក៏ពិត តែក៏ឈ្មោះថា វិញ្ញត្តិទុំះឯង ព្រោះប្រាកដដល់បុគ្គលដែលនៅចំពោះមុខ ៗ

សួរថា កាលកាយដែលមានចិត្តជាសមុដ្ឋានកំពុងកម្រើក កាយដែលមានសមុដ្ឋាន ៣ យ៉ាងទៀត រមែងកម្រើកទៅផង ឬក៏មិនកម្រើកទេ ៗ ឆ្លើយថា កាយដែលមានសមុដ្ឋាន ៣ ទៀតនោះ ក៏កម្រើកទៅដូចគ្នា ៗ កាយដែលមានសមុដ្ឋាន ៣ នោះ មានគតិដូចកាយដែលមានចិត្តជាសមុដ្ឋានស្របតាមកាយ ដែលមានចិត្តជាសមុដ្ឋានដោយពិត ៗ ដូចកាលទឹកកំពុងហូរទៅ សូម្បីកំណាត់ឈើស្ងួត ស្មៅស្ងួត ស្លឹកឈើស្ងួតជាដើមដែលធ្លាក់ទៅក្នុងទឹក ក៏រមែងហូរទៅតាមទឹកនោះឯង គឺកាលទឹកហូរទៅ សំណាត់ឈើស្ងួតជាដើម ក៏រមែងអណ្តែតទៅ កាលទឹកឈប់ សំណាត់ឈើស្ងួតជាដើមនោះ ក៏ឈប់ យ៉ាងណា បណ្ឌិតគប្បីជ្រាបឧបមាឧបមេយ្យក្នុងរឿងនេះក៏យ៉ាងនោះ វិញ្ញត្តិក្នុងរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាននេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ទ្វារនៃកាយកម្ម ដោយប្រការដូច្នេះ ៗ

ចេតនាដែលឲ្យសម្រេចក្នុងទ្វារនោះ ជាហេតុឲ្យបុគ្គលសម្លាប់សត្វ កាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ ប្រព្រឹត្តមិច្ឆាចារ លះបង់នូវសីល មានបាណាតិបាតជាដើម សេចក្តីនេះ ឈ្មោះថា **កាយកម្ម** ៗ កាលបើវាទីមានទៅយ៉ាងនេះ បណ្ឌិតក៏គប្បីតម្កល់ទុក ដោយន័យរបស់ពាក្យថា **កាយ**

**ជាទ្វារ** ចេតនាដែលសម្រេចក្នុងទ្វារនោះ ជាកាយកម្ម គឺជាកុសល ឬជាអកុសល ។ តែកាលបវរាំទីមិនមាន ក៏គប្បីតម្កល់តិកៈថា ជាកុសល ឬអកុសល ឬអព្យាកតៈដូច្នេះឲ្យបរិបូរណ៍ ។ ក្នុងសេចក្ដីនោះ ប្រៀបដូចទ្វារនគរ រមែងតាំងទុកក្នុងទីដែលគេសាងហើយ រមែងមិនឃ្លាតទៅឃ្លាតមក សូម្បីត្រឹមតែមួយធ្លាប់ ចំណែកមហាជន រមែងត្រាច់ទៅតាមទ្វារនោះៗ យ៉ាងណា ទ្វារក៏យ៉ាងនោះដូចគ្នា នឹងត្រាច់ទៅមិនបានទេ ចំណែកកម្ម រមែងត្រាច់ទៅដោយការកើតឡើងក្នុងទ្វារនោះៗ ដោយហេតុនោះ ទើបបោរាណាចារ្យទាំងឡាយពោលថា

> កម្មទាំងឡាយ រមែងត្រាច់ទៅក្នុងទ្វារ ទ្វារទាំងឡាយ មិនត្រាច់ទៅក្នុងទ្វារ ព្រោះហេតុនោះ ទើបលោកកំណត់កម្មទាំងឡាយ ជាមួយនឹងទ្វារទាំងឡាយទុកជាមួយគ្នា ដូច្នេះ ។

ក្នុងគាថានោះ អធិប្បាយថា ទ្វាររមែងបានឈ្មោះតាមកម្ម សូម្បីកម្មក៏បានឈ្មោះតាមទ្វារ ។ ដូចទីជាទីកើតឡើងនៃវិញ្ញាណជាដើម រមែងបានឈ្មោះថា ទ្វារនៃវិញ្ញាណ ទ្វារនៃផស្សៈ ទ្វារនៃការមិនសង្រួម ទ្វារនៃការសង្រួម ដូច្នេះ យ៉ាងណា ទីជាទីកើតឡើងនៃកាយកម្ម ក៏បានឈ្មោះថា ទ្វារនៃកាយកម្មយ៉ាងនោះ ។ សូម្បីក្នុងទ្វារនៃវចីកម្ម និងមនោកម្ម ក៏ន័យនេះដូចគ្នា ។ មួយទៀត ទេវតាដែលស្ថិតនៅលើដើមឈើនោះៗ រមែងបានឈ្មោះតាមដើមឈើនោះៗ ថា ទេវតាដើមរកា ទេវតាដើមល្ហុសផ្អុង ទេវតាដើមពន្រ យ៉ាងណា សូម្បីកម្មដែលបុគ្គលធ្វើហើយដោយកាយទ្វារ រមែងបាន

ឈ្មោះតាមទ្វារថា កាយកម្មយ៉ាងនោះដូចគ្នា ។ សូម្បីក្នុងវចីកម្ម និងមនោកម្ម ក៏ន័យនេះដូចគ្នា ។ ក្នុងកាយ និងកម្មនោះ កាយម្យ៉ាង កម្មម្យ៉ាង តែលោកហៅកាយ និងកម្មនោះថា **កាយកម្ម** ព្រោះកម្មនោះ ធ្វើដោយកាយ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា

*បើកម្មធ្វើដោយកាយ ហៅថា កាយកម្ម កាយ និងកាយកម្ម លោកក៏កំណត់ទុកជាមួយគ្នា បើកម្មធ្វើដោយម្ជុល ហៅថា សូចិកម្ម ម្ជុល និងសូចិកម្ម លោកក៏កំណត់ទុកជាមួយគ្នា បើកម្មធ្វើដោយកាំបិត ហៅថា វាសិកម្ម កាំបិត និងវាសិកម្ម លោកក៏កំណត់ទុកជាមួយគ្នា បើកម្មធ្វើដោយបុរស ហៅថា បុរិសកម្ម បុរស និងបុរិសកម្ម លោកក៏កំណត់ទុកជាមួយគ្នា ។ បើកម្មធ្វើដោយកាយ ក៏ហៅថា កាយកម្ម កាយ និងកាយ-កម្ម លោកកំណត់ទុកជាមួយគ្នា ដោយប្រការដូច្នេះឯង ។*

កាលបើយ៉ាងនេះ ការកំណត់ចំពោះទ្វារក៏មិនត្រូវ ការកំណត់ចំពោះកម្មក៏មិនត្រូវ សួរថា មិនត្រូវយ៉ាងដូចម្តេច ឆ្លើយថា វចីកម្ម ក៏ប្រព្រឹត្តទៅក្នុងកាយវិញ្ញត្តិបាន ព្រោះពាក្យថា កម្មទាំងឡាយ រមែងត្រាច់ទៅក្នុងទ្វារ ដោយហេតុនោះ ការកំណត់កាយវិញ្ញត្តិនោះថា ទ្វារនៃកាយកម្មដូច្នេះ ក៏មិនត្រូវទាំងកាយកម្ម ក៏រមែងប្រព្រឹត្តទៅក្នុងវចីវិញ្ញត្តិបាន ដោយហេតុនោះ ការកំណត់កាយកម្មនោះថា កាយកម្មក៏មិនត្រូវ ។ ការកំណត់យ៉ាងនោះមិនមែនត្រូវ ។ ព្រោះហេតុអ្វី ព្រោះកាយកម្មនោះប្រព្រឹត្តទៅដោយច្រើន និងព្រោះ

កាយកម្មនោះ ប្រព្រឹត្តទៅច្រើនក្នុងកាយទ្វារនោះ ។ ពិតហើយ កាយកម្មប៉ុណ្ណោះ រមែងប្រព្រឹត្តទៅដោយច្រើនក្នុងកាយវិញ្ញត្តិ វចីកម្មក្រៅនេះ មិនប្រព្រឹត្តទៅដោយច្រើន ព្រោះហេតុនោះ ភាពដែលកាយវិញ្ញត្តិនេះជាទ្វារនៃកាយកម្មសម្រេចហើយ ដោយការប្រព្រឹត្តិទៅដោយច្រើននៃកាយកម្ម ប្រៀបដូចស្រុកព្រាហ្មណ៍ ចម្ការស្វាយ និងព្រៃខ្ទឹងជាដើម ឈ្មោះថា ស្រុកព្រាហ្មណ៍ជាដើម ព្រោះហេតុនោះ ទើបការកំណត់ទ្វារ ត្រូវ ។ កាយកម្ម រមែងប្រព្រឹត្តទៅច្រើនក្នុងកាយទ្វារនោះឯង ចំណែកក្នុងវចីទ្វារប្រព្រឹត្តទៅតិច ។ ព្រោះហេតុនោះ ភាពដែលកាយកម្មនេះ ជាកាយកម្មសម្រេចហើយដោយការប្រព្រឹត្តិទៅច្រើនក្នុងកាយទ្វារ ប្រៀបដូចគោចររបស់នាយព្រានព្រៃ និងក្រមុំចាស់ជាដើម ឈ្មោះថា គោចររបស់នាយព្រានព្រៃជាដើម ព្រោះហេតុនោះ សូម្បីការកំណត់កម្ម ទើបត្រឹមត្រូវ ដោយប្រការដូច្នេះ ។

## ទ្វារនៃកាយកម្ម ចប់

# ទ្វារនៃវចីកម្ម

ក្នុងកថាពោលអំពីទ្វារនៃវចីកម្ម ឈ្មោះថា **វាចា** មាន ៣ យ៉ាង គឺ ចេតនា វិរតិ សទ្ទៈ បណ្ដាវាចាទាំង ៣ យ៉ាងនោះ វាចានេះ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ឈ្មោះថា សុភាសិត មិនមែនទុព្ភាសិតទេ ជាវាចាមិនមានទោសផង ដែលអ្នកប្រាជ្ញមិនតិះដៀលផង ដូច្នេះ ឈ្មោះថា **ចេតនាវាចា** ។ វាចានេះ ( អភិធម្មវិភង្គ ) ថា ការវាង ការគេចចេញ វចីទុច្ចរិតទាំង ៤ ។បេ។ នេះហៅថា សម្មាវាចា ដូច្នេះ ឈ្មោះថា **វិរតិវាចា** ។ វាចានេះ ( ក្នុងអភិធម្ម ធម្មសង្គណី ) ថា វាចា ការបន្លឺ គន្លងពាក្យ ការពោល ការគឹកកង កម្ម គឺការគឹកកង គឺវាចា វចីភេទ ដូច្នេះ ឈ្មោះថា **សទ្ទវាចា** ។ បណ្ដាវាចាទាំង ៣ នោះ ពាក្យថា **វចីកម្មទ្វារ** មិនមែនជាឈ្មោះរបស់ចេតនា មិនមែនជាឈ្មោះរបស់វិរតិ តែវិញ្ញត្តិណាមួយដែលមានសំឡេងរួមផង មាននៅ រូបនេះដែលទ្រង់សំដៅយក ត្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ថា រូបជាវចីវិញ្ញត្តិនោះ តើដូចម្ដេច ។ វាចា ការបន្លឺ គន្លងពាក្យ ការពោល ការគឹកកង កម្ម គឺការគឹកកង គឺវាចា វចីភេទណា នៃបុគ្គលមានចិត្តជាកុសលក្ដី មានចិត្តជាអកុសលក្ដី មានចិត្តជាអព្យាក្រឹតក្ដី នេះហៅថា វាចា គឺ ការកម្រើកសម្ដី ការញុំាងសម្ដីឲ្យកម្រើក ភាពនៃការញុំាងសម្ដីឲ្យកម្រើក នេះរូបជាវចីវិញ្ញត្តិ ដូច្នេះ ឈ្មោះថា ទ្វារនៃវចីកម្ម ។

ពិតហើយ កាលបុគ្គលត្រិះរិះថា អញនឹងពោលពាក្យនេះ អញនឹងពោលពាក្យនោះ ឈ្មោះថា សំឡេងដែលផ្សាយទៅនៃវិតក្ក រមែងកើត

ឡើង ។ វាទៈនេះ មកក្នុងមហាអដ្ឋកថាថា សំឡេងនេះ គប្បីដឹងដោយសោតៈមិនបាន គប្បីដឹងបានដោយចិត្ត តែក្នុងអដ្ឋកថាដែលមកទាំងឡាយអធិប្បាយពាក្យថា សំឡេងដែលផ្សាយទៅនៃវិតក្ក ជាសំឡេងរបស់អ្នកដែលដេកលក់ និងប្រមាទហើយជាដើម ដែលកំពុងមមើ ដែលកើតឡើងដោយអំណាចនៃការផ្សាយទៅនៃវិតក្ក ។ ពាក្យថា **ស្តាប់ហើយ** នោះសេចក្តីថា កាលបុគ្គលនោះស្តាប់ហើយ ត្រិះរិះនូវរឿងណា សំឡេងដែលផ្សាយទៅនៃវិតក្កនោះកើតឡើងហើយ ដោយអំណាចនៃរឿងនោះ ក៏អាចស្មានបានថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នកយ៉ាងនោះខ្លះ កាលពោលដោយប្រការដូច្នោះហើយ ក៏ពោលសូម្បីរឿងទាំងឡាយ ។ សូម្បីក្នុងបដ្ឋានក៏មានព្រះបាលីដែលមកហើយថា សទ្ទាយតនៈ មានចិត្តជាសមុដ្ឋានជាបច្ច័យដល់សោតវិញ្ញាណដោយអារម្មណប្បច្ច័យ ដូច្នេះ ព្រោះហេតុនោះឈ្មោះថា សំឡេងដែលផ្សាយទៅនៃវិតក្ក ដែលដឹងមិនបានដោយសោតៈដែលកើតឡើង វៀរចាកការប៉ះខ្ទប់នឹងវិញ្ញត្តិ ទើបមិនមាន ចិត្តកាលកើតឡើងថា ខ្ញុំនឹងពោលពាក្យនេះ ខ្ញុំនឹងពោលពាក្យនោះ ដូច្នេះ រមែងញ៉ាំងរូបឲ្យតាំងឡើង ៨ រូប គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ វណ្ណៈ គន្ធៈ រសៈ ឱជា ។ បឋវីធាតុ ដែលមានចិត្តជាសមុដ្ឋានក្នុងខាងក្នុងនៃរូបទាំង ៨ នោះ ប៉ះខ្ទប់នូវឧបាទិន្នកកាយជាមុនសិន ទើបកើតឡើងសំឡេង រមែងកើតឡើង ព្រមនឹងការប៉ះខ្ទប់នៃបឋវីធាតុនោះ សំឡេងនេះឈ្មោះថា សំឡេងដែលមានចិត្តជាសមុដ្ឋាន សំឡេងនេះ មិនមែនជាវិញ្ញត្តិ

ប៉ុន្តែ វិការនៃអាការម្យ៉ាង ដែលកើតអំពីបច្ច័យនៃការប៉ះខ្ទប់ឧបាទិន្នកកាយរបស់បឋវីធាតុ ដែលមានចិត្តជាសមុដ្ឋាននោះមាន វិការនេះ ឈ្មោះថា **វចីវិញ្ញត្តិ** ក្រៅអំពីនេះ ពាក្យទាំងពួង មានជាដើមថា វចីវិញ្ញត្តិនោះ មិនមានចិត្តជាសមុដ្ឋាន ដូចរូបទាំង ៨ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនុ៎ះឯង ។

ពិតហើយ សូម្បីក្នុងទីនេះ បុគ្គលស្តាប់សំឡេងរបស់អ្នកដែលហៅថា តិស្ស: ទត្ត: មិត្ត: ដូច្នេះហើយ គិតដល់វិញ្ញត្តិដោយចិត្តដែលកើតតាមមនោទ្វារហើយ រមែងដឹងថា អ្នកនេះប្រហែលជានឹងឲ្យធ្វើវត្ថុនេះ និងវត្ថុនេះ ។ មួយទៀត សូម្បីវចីវិញ្ញត្តិនេះ ក៏រមែងប្រាកដដល់សត្វតិរច្ឆាន ដូចកាយ-វិញ្ញត្តិ ។ ពិតហើយ សូម្បីសត្វតិរច្ឆានទាំងឡាយ ស្តាប់សំឡេងថា អ្នកចូរមក ចូរអ្នកទៅ ដូច្នេះ ក៏ដឹងថា បុគ្គលនេះ ប្រហែលនឹងឲ្យធ្វើវត្ថុឈ្មោះនេះ ទើបដើរមក និងដើរទៅ ។ វារៈនេះថា សំឡេងរមែងញ៉ាំងកាយដែលមានសមុដ្ឋាន ៣ យ៉ាង ឲ្យកម្រើក ឬមិនឲ្យកម្រើក ដូច្នេះ មិនមានក្នុងវចីវិញ្ញត្តិនេះ សូម្បីកិច្ច គឺការឧបត្ថម្ភនៃវចីវិញ្ញត្តិ ដែលមានចិត្តដូងមុនជាសមុដ្ឋានក៏មិនមាន ប៉ុន្តែ ចេតនាណាដែលឲ្យសម្រេច សូម្បីក្នុងវចីទ្វារនោះ និងចេតនាដែលជាហេតុនិយាយកុហក ពោលពាក្យញុះញង់ ពោលពាក្យគ្រោតគ្រាត និយាយរោយរាយ វៀរចាកមុសាវាទជាដើម ចេតនានេះ ឈ្មោះថា **វចីកម្ម** ។ ខាងមុខអំពីនេះ បណ្ឌិតគប្បីជ្រាបការកំណត់កម្ម និងការកំណត់ទ្វារ ដោយន័យដែលពោលខាងដើមនោះឯង ។

**ទ្វារនៃវចីកម្ម ចប់**

# ទ្វារនៃមនោកម្ម

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងកថាពោលអំពីទ្វារនៃមនោកម្មដូចតទៅ

ចិត្តមាន ៤ យ៉ាង គឺចិត្តដែលជាកាមាវចរជាដើម ឈ្មោះថា **មនោ** ក្នុង ៤ យ៉ាងនោះ ចិត្តទាំងអស់មាន ៨៩ ដួង គឺចិត្តដែលជាកាមាវចរ ៥៤ ដួង ចិត្តដែលជារូបាវចរ ១៥ ដួង ចិត្តដែលជាអរូបាវចរ ១២ ដួង ចិត្តដែលជាលោកុត្តរ ៨ ដួង ។ បណ្ដាចិត្តទាំងនោះ ធម្មតាចិត្តនេះ មិនគួរពោលថា មិនជាមនោទ្វារ ដូចធម្មតាចេតនានេះ មិនគួរពោលថា មិនជាកម្ម ព្រោះដោយហោចទៅ សូម្បីចេតនាដែលសម្បយុត្តដោយបញ្ចវិញ្ញាណ ( វិញ្ញាណ ៥ ) ក្នុងមហាបករណ៍ ក៏ទ្រង់សម្ដែងថា ជាកម្មទុំះឯង យ៉ាងណា ធម្មតាចិត្តនេះ ក៏មិនគួរពោលថា មិនជាមនោទ្វារយ៉ាងនោះដូចគ្នា ។

ក្នុងអធិការពោលអំពីមនោទ្វារនេះ មានអ្នកចោទសួរ ពោលថា ធម្មតាកម្មនេះ រមែងធ្វើនូវអ្វី ឆ្លើយថា រមែងប្រមូលមក រមែងតាក់តែង រមែងរួបរួម រមែងតាំងចិត្ត រមែងត្រិះរិះ រមែងឲ្យសម្រេច ។ សួរថា កាលបើដូច្នេះ ចេតនាក្នុងបញ្ចវិញ្ញាណ រមែងប្រមូលមក រមែងតាក់តែង រមែងរួបរួមនូវអ្វី ឆ្លើយថា រមែងប្រមូលមក រមែងតាក់តែង រមែងរួបរួមនូវសហជាតធម៌ទាំងឡាយ ។ ពិតហើយ ចេតនាក្នុងបញ្ចវិញ្ញាណនោះ រមែងប្រមូលមក រមែងតាក់តែង រមែងរួបរួម រមែងតាំងចិត្ត រមែងត្រិះរិះ រមែងឲ្យសម្រេចសម្បយុត្តក្ខន្ធ ដែលកើតឡើងព្រមគ្នា ។ ម្យ៉ាងវិញទៀត មានប្រយោជន៍អ្វីដោយការពោលដល់សេចក្ដីនេះ ព្រោះលោកបានពោលពាក្យ

នេះ ដោយអំណាចនៃការរួបរួមចិត្តទុកទាំងអស់ ។ ក្នុងអធិការពោល អំពីមនោទ្វារនេះ មានពាក្យសន្និដ្ឋានដូច្នេះថា ចិត្ត ២៩ ដួង គឺកុសល និង អកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ទ្វារនៃមនោកម្ម តែចេតនា ណាដែលឲ្យសម្រេចក្នុងមនោទ្វារនោះ និងចេតនាណាដែលជាហេតុកាន់យក នូវអភិជ្ឈា ព្យាបាទ មិច្ឆាទស្សនៈ និងការមិនមានអភិជ្ឈា មិនព្យាបាទ និង សម្មាទស្សនៈ ចេតនានេះ ឈ្មោះថា មនោកម្ម ។ ខាងមុខអំពីនេះទៅ បណ្ឌិតគប្បីជ្រាបការកំណត់កម្ម និងការកំណត់ទ្វារទាំងអស់ ដោយន័យ ដែលពោលខាងដើមនុ៎ះឯង ដូច្នេះ ។ ទាំងនេះ ឈ្មោះថា ទ្វារនៃកម្ម ៣ ។

## ទ្វារនៃមនោកម្ម ចប់

# កម្មកថា

ខ្ញុំបានសម្តែងទ្វារនៃកម្មទាំងនេះ វៀរកម្ម ៣ ពួកណា ឥឡូវនេះ នឹងពោលដោយពិស្តារដល់ការតាំងមាតិកា ក្នុងកថាដែលពោលដោយទ្វារដែលពោលផ្អាកទុក ផ្តើមតាំងអំពីកម្មទាំង ៣ នោះ ។ ពិតហើយ កម្ម ៣ គឺ កាយកម្ម វចីកម្ម និងមនោកម្ម សួរថា ឈ្មោះថា កម្មនេះ បានដល់អ្វីខ្លះ ឆ្លើយថា បានដល់ចេតនា និងធម៌ដែលសម្បយុត្តដោយចេតនាខ្លះ ។ បណ្តាធម៌ទាំងពីរនោះ ក្នុងកាលដែលចេតនាជាកម្ម មានព្រះសូត្រទាំងនេះពោល ( ក្នុងអង្គុត្តរនិកាយ ឆក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាថា ជាកម្ម ព្រោះបុគ្គលគិតហើយ ទើបធ្វើកម្មដោយកាយ វាចាចិត្ត ដូច្នេះ ។ និងដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ម្នាលអានន្ទ កាលបើកាយមាន សុខ និងទុក្ខខាងក្នុង រមែងកើតឡើងព្រោះកាយសញ្ចេតនាជាហេតុ ម្នាលអានន្ទ កាលបើវាចាមាន សុខ និងទុក្ខខាងក្នុង រមែងកើតឡើងព្រោះវចីសញ្ចេតនាជាហេតុ ម្នាលអានន្ទ កាលបើមនោមាន សុខ និងទុក្ខខាងក្នុង រមែងកើតឡើងព្រោះមនោសញ្ចេតនា ជាហេតុក៏មាន ដូច្នេះ ។ និងដូចព្រះតម្រាស់ ( ក្នុងអភិធម្មកថាវត្ថុ ) ថា ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ៣ ប្រការ ជាអកុសលកាយកម្ម មានទុក្ខជាកម្រៃ មានទុក្ខជាវិបាក ម្នាលភិក្ខុទាំងឡាយ វចីសញ្ចេតនា ៤ ប្រការជាអកុសលវចីកម្ម ។បេ។ ម្នាលភិក្ខុទាំងឡាយ មនោសញ្ចេតនា ៣ ប្រការ ជាកុសលមនោកម្ម មានសុខជាកម្រៃ មានសុខជាវិបាក ដូច្នេះ ។ និងដូចព្រះតម្រាស់ថា ម្នាលអានន្ទ បើសមិទ្ធិមោឃបុរស ( មោឃ-

បុរសឈ្មោះសមិទ្ធិ ) នេះ ត្រូវបាដលិបុត្តបរិព្វាជក សួរយ៉ាងនេះហើយ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោបាដលិបុត្ត បុគ្គលណាធ្វើកម្មប្រកប ដោយចេតនា ដោយកាយ វាចា ចិត្ត ជាកម្មគួរដល់ការទទួលសេចក្ដី សុខ ។បេ។ បុគ្គលនោះ រមែងទទួលអទុក្ខមសុខ ម្នាលអានន្ទ សមិទ្ធិ-មោឃបុរស កាលដោះស្រាយយ៉ាងនេះហើយ ឈ្មោះថា ដោះស្រាយដោយ ប្រពៃ គប្បីដោះស្រាយចំពោះបាដលិបុត្តបរិព្វាជក ដូច្នេះ ។ ក្នុងកាពដែល ចេតនាជាកម្ម មានព្រះសូត្រប្រមាណប៉ុណ្ណេះសិន ។

ចំណែកធម៌ដែលសម្បយុត្តដោយចេតនាជាកម្ម សម្ដែងដោយកម្ម-ចតុក្កៈ សមដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាល ភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា ដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅ មានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្ម ស មានវិបាកសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅ ទាំងស មាន វិបាកទាំងខ្មៅទាំងសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅ មិនស មាន វិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ... ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើ ដូចម្ដេច ។ សតិសម្ពោជ្ឈង្គ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ម្នាលភិក្ខុទាំង ឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្ត ទៅដើម្បីអស់កម្ម ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាក

មិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្ដេច ។ សេចក្ដីយល់ឃើញត្រូវ ។បេ។ ការតម្កល់ចិត្តត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ដូច្នេះ ។

ធម៌ ១៥ យ៉ាង មានពោជ្ឈង្គ និងអង្គនៃមគ្គទាំងនេះ ទ្រង់សំដែងដោយកម្មចតុក្កៈ ដោយប្រការដូច្នេះ ។ មួយទៀត គប្បីជ្រាបធម៌ដែលសម្បយុត្តដោយចេតនា ២១ ជាមួយនឹងធម៌ទាំង ៦ នេះ គឺអភិជ្ឈាព្យាបាទ មិច្ឆាទិដ្ឋិ អនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ។

បណ្ដាធម៌ទាំងនោះ លោកុត្តរមគ្គ កាលរួមជាពួក ក៏រមែងរួមកម្ម ៣ យ៉ាង មានកាយកម្មជាដើម ។ ពិតហើយ ការសង្រួមចាកការប្រព្រឹត្តិកន្ទងភាពជាអ្នកទ្រុស្តសីល តាមផ្លូវកាយ គប្បីជ្រាបថា ជាកាយិកៈ ។ ការសង្រួមចាកការកន្ទងភាពទ្រុស្តសីលផ្លូវវាចា គប្បីជ្រាបថា ជា**វាចសិកៈ** ។ សម្មាកម្មន្តៈជាកាយកម្ម សម្មាវាចាជាវចីកម្ម កាលកាន់យកកម្មទាំងពីរពួកនេះ សម្មាអាជីវៈ រមែងឈ្មោះថា ជាការកាន់យកហើយ ព្រោះជាពួកនៃកម្មទាំងពីរនោះឯង ។ ចំណែកការសង្រួមចាកការប្រព្រឹត្តិកន្ទងភាពជាអ្នកទ្រុស្តសីលតាមផ្លូវចិត្ត គប្បីជ្រាបថា ជា**មានសិកៈ** ។ **មានសិកៈ**នោះមាន ៥ យ៉ាង ដោយអំណាចនៃទិដ្ឋិ សង្កប្បៈ វាយាមៈ សតិ និងសមាធិ **មានសិកៈ**ទាំង ៥ យ៉ាងនេះ ឈ្មោះថា **មនោកម្ម** ។ លោកុត្តរមគ្គ កាលរួមជាពួក ក៏រមែងរួមកម្មទាំង ៣ យ៉ាង ដោយប្រការដូច្នេះ ។

ក្នុងទីនេះ ឈ្មោះថា **ការប្រៀបធៀបនឹងទ្វារ** មានដូច្នេះថា ពិតហើយ

កម្មដែលដល់ការកម្រើកក្នុងកាយទ្វារ និងវចីទ្វារ តែមិនដល់កម្មបថ ក៏មាន កម្មដែលដល់ការប្រាកដ ប្រព្រឹត្តទៅក្នុងមនោទ្វារ តែមិនដល់កម្មបថ ក៏មាន ទើបលោកកាន់យកកម្មនោះៗ ( ដែលមិនមែនជាកម្មបថ ) ធ្វើឲ្យជាពួក របស់ទ្វារនោះៗ ឯង ។

ក្នុងរឿងនោះ មានន័យដូចតទៅនេះ បុគ្គលណាគិតថា នឹងទៅបរបាញ់ម្រឹគ ទើបធ្វើធ្នូ វេញខ្សែ សំលៀងលំពែង បរិភោគអាហារ ស្លៀកសំពត់ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ កម្មក៏ដល់នូវការកម្រើកហើយក្នុងកាយ-ទ្វារ ។ បុគ្គលនោះ ត្រាច់ទៅក្នុងព្រៃអស់មួយថ្ងៃ មិនបាននូវអ្វីឡើយ ដោយហោចទៅសូម្បីតែទន្សាយ និងឆ្មា ។ សួរថា អកុសលនេះ ឈ្មោះថា ជា **កាយកម្មឬទេ** ឆ្លើយថា មិនមែនជាកាយកម្ម ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះមិនដល់កម្មបថ ។ តែគប្បីជ្រាបថា អកុសលនេះ ឈ្មោះថា កាយទុច្ចរិតតែម្យ៉ាង ។ សូម្បីក្នុងការធ្វើឧបករណ៍ចាប់ត្រីជាដើម ក៏ន័យនេះដូចគ្នា ។

ក្នុងវចីទ្វារ កាលបុគ្គលប្រាប់ថា យើងនឹងទៅបាញ់ម្រឹគ ចូរពួកអ្នកត្រៀមធ្នូជាដើមដោយរហ័សចុះ ដូច្នេះ កាលមិនបានអ្វីនីមួយក្នុងព្រៃដោយន័យមុនទុំះឯង កម្មនោះ ដល់នូវការកម្រើកក្នុងវចីទ្វារក៏ពិតមែន តែទោះបីជាដូច្នោះ ក៏មិនជាវចីកម្ម ព្រោះមិនដល់កម្មបថ ។ គប្បីជ្រាបថា អកុសលនោះ ឈ្មោះថា ជាវចីទុច្ចរិតតែម្យ៉ាង ។

ចំណែកក្នុងមនោទ្វារ កាលវធកចេតនា ( ចិត្តគិតនឹងសម្លាប់ ) គ្រាន់

តែកើតឡើងប៉ុណ្ណោះ ក៏រមែងចាត់ជាកម្មបថនោះឯង ។ ការចាត់ជាកម្មបថនោះ រមែងមានដោយអំណាចនៃព្យាបាទ មិនមែនដោយអំណាចនៃបាណាតិបាត ។ ពិតហើយ កាយកម្មដែលជាអកុសល រមែងតាំងឡើងក្នុងកាយទ្វារ និងវចីទ្វារ មិនតាំងឡើងក្នុងមនោទ្វារ ។ វចីកម្មដែលជាអកុសលក៏ដូចគ្នា ។ តែមនោកម្មដែលជាអកុសល រមែងតាំងឡើងក្នុងទ្វារទាំង ៣ ។ កាយកម្ម វចីកម្ម និងមនោកម្មដែលជាកុសលក៏ដូចគ្នា ។

សួរថា សេចក្ដីនេះ ដូចម្ដេច ។ ឆ្លើយថា កាលបុគ្គលសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយដៃរបស់ខ្លួន ប្រព្រឹត្តមិច្ឆាចារ កម្ម រមែងជាកាយកម្មប៉ុណ្ណោះ សូម្បីទ្វារក៏ជាកាយទ្វារដូចគ្នា កាយកម្មដែលជាអកុសល រមែងតាំងឡើងក្នុងកាយទ្វារយ៉ាងនេះមុន ចំណែកអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ រមែងប្រព្រឹត្តទៅក្នុងចំណែកនៃចេតនាខ្លះ ជាអព្វោហារិក ( ពោលអាងមិនបានថា មាន ឬមិនមាន ) ខ្លះ ។

តែកាលបុគ្គលប្រើថា ចូរអ្នកទៅសម្លាប់អ្នកនេះ ចូរលួចទ្រព្យរបស់មនុស្សឈ្មោះនេះ កម្ម ជាកាយកម្ម ចំណែកទ្វារ ជាវចីទ្វារ ។ កាយកម្មដែលជាអកុសល រមែងតាំងឡើងក្នុងវចីទ្វារយ៉ាងនេះ ។ ចំណែកអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ ប្រព្រឹត្តទៅក្នុងចំណែកចេតនាខ្លះ ជាអព្វោហារិកខ្លះ ។ ឈ្មោះថា ពាក្យអធិប្បាយដែលដូចគ្នារបស់អាចារ្យទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។

ចំណែកអាចារ្យវិតណ្ឌវាទីពោលថា កាយកម្មដែលជាអកុសល រមែងតាំងឡើងក្នុងមនោទ្វារក៏មាន អាចារ្យវិតណ្ឌវាទីនោះ ត្រូវអាចារ្យដទៃចោទសួរថា ចូរអ្នកនាំសូត្រដែលលើកឡើងកាន់សង្គាយនាទាំង ៣ លើក ដូច្នេះ ទើបនាំសូត្រឈ្មោះកុលុម្ពនេះមកថា ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ មានឫទ្ធិ ដល់នូវភាពស្ទាត់ជំនាញដោយចិត្ត ប្រមើលមើលសត្វក្នុងផ្ទៃរបស់ស្ត្រីដទៃដោយចិត្តដ៏លាមកថា ឱហ្ន៎ សត្វក្នុងផ្ទៃនេះ កុំគប្បីប្រសូតមកដោយសួស្តី ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ការសម្លាប់សត្វក្នុងផ្ទៃ រមែងមានដោយអាការយ៉ាងនេះ ដូច្នេះ ។

អាចារ្យវិតណ្ឌវាទី កាលនាំសូត្រនេះមកហើយ ទើបពោលថា ត្រឹមតែគិតប៉ុណ្ណោះ សត្វកើតក្នុងគភ៌របស់ស្ត្រីនោះ ក៏អន្តរធានទៅ ដូចដុំពពុះទឹក ក្នុងការអន្តរធាននៃគភ៌នេះ មានការកម្រើកចំណែកនៃកាយ ឬចំណែកនៃវាចាអំពីណា កាយកម្មដែលជាអកុសលនេះ រមែងតាំងឡើងក្នុងមនោទ្វារប៉ុណ្ណោះ ។

អាចារ្យទាំងឡាយ ពោលនឹងអាចារ្យវិតណ្ឌវាទីនោះថា ពួកយើងនឹងពិចារណាសេចក្តីនៃព្រះសូត្ររបស់អ្នក ដូច្នេះហើយ នាំគ្នាពិចារណាដោយន័យដែលអាចារ្យវិតណ្ឌវាទីពោល ហើយសួរថា អ្នកពោលដល់ការសម្លាប់សត្វដទៃដោយឫទ្ធិ ធម្មតាឫទ្ធិនោះ មាន ១០ យ៉ាង គឺអធិដ្ឋានឥទ្ធិ វិកុព្វនឥទ្ធិ មនោមយិទ្ធិ ញាណវិប្ផារឥទ្ធិ សមាធិវិប្ផារឥទ្ធិ អរិយឥទ្ធិ កម្មវិបាកជឥទ្ធិ បុញ្ញវតោឥទ្ធិ វិជ្ជាមយឥទ្ធិ ភាវនាមយឥទ្ធិដែលឈ្មោះថា **ឫទ្ធិ**

ដោយអត្ថថា សម្រេច ព្រោះការប្រកបដោយប្រពៃក្នុងកម្មនោះៗ ជាបច្ច័យ បណ្ដាឫទ្ធិទាំងនោះ អ្នកពោលដល់ឫទ្ធិណា ។ អាចារ្យវិតណ្ឌវាទី ឆ្លើយថា ការនាមយិទ្ធិ ។ សួរថា កម្ម គឺការសម្លាប់សត្វដទៃមិនបានដោយការនាមយិទ្ធិឬ ។ អាចារ្យវិតណ្ឌវាទី ឆ្លើយថា មែន ។ អាចារ្យពួកខ្លះពោលថា ការសម្លាប់សត្វដទៃដោយការនាមយិទ្ធិនោះ មានត្រឹមតែម្ដង ។ ដូចក្អមពេញដោយទឹក បុគ្គលប្រាថ្នានឹងប្រហារអ្នកដទៃ ទើបគ្រវែងទៅហើយ សូម្បីក្អមក៏បែក សូម្បីទឹកក៏វិនាសទៅ យ៉ាងណា កម្ម គឺការសម្លាប់អ្នកដទៃដោយការនាមយិទ្ធិ រមែងមានបានត្រឹមតែម្ដងយ៉ាងនោះដូចគ្នា បន្ទាប់ពីនោះមក ឫទ្ធិនោះ ក៏វិនាសសាបសូន្យ ។

លំដាប់នោះ អាចារ្យវិតណ្ឌវាទីពោលថា កម្ម គឺការប្រហារអ្នកដទៃដោយការនាមយិទ្ធិ មិនបានមានមួយលើក ពីរលើកប៉ុណ្ណោះទេ ដូច្នេះហើយក៏មិនយល់ព្រមចំពោះពាក្យចង្អុលបង្ហាញ ត្រូវអាចារ្យទាំងឡាយសួរថា ការនាមយិទ្ធិជាកុសល ជាអកុសល ឬជាអព្យាកតៈ សម្បយុត្តដោយសុខវេទនា ដោយទុក្ខវេទនា ឬអទុក្ខមសុខវេទនា មានវិតក្កៈ មានវិចារ មិនមានវិតក្កៈ មានតែវិចារ ឬមិនមានវិតក្កៈមិនមានវិចារ ជាកាមាវចរ ជារូបាវចរ ឬជាអរូបាវចរ ទើបឆ្លើយថា បុគ្គលណាដឹងបញ្ហានេះ បុគ្គលនោះរមែងពោលយ៉ាងនេះថា ការនាមយិទ្ធិរមែងជាកុសលខ្លះ ជាអព្យាកតៈខ្លះ ជាទីតាំងរបស់អទុក្ខមសុខវេទនា មិនមានវិតក្កៈ មិនមានវិចារ និងជារូបាវចរប៉ុណ្ណោះ ដូច្នេះ ។ អាចារ្យទាំងឡាយ គប្បីពោលនឹងអាចារ្យ

វិតណ្ឌវាទីនោះថា ចេតនាដែលញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះ រមែងរួមចូលគ្នាបានជាមួយនឹងចំណែកណា បណ្តាកុសលជាដើម ។ អាចារ្យវិតណ្ឌវាទីកាលដឹង ក៏នឹងឆ្លើយថា ចេតនាដែលញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លងជាអកុសល ជាទីតាំងនៃទុក្ខវេទនា មានវិតក្ក មានវិចារ ជាកាមាវចរប៉ុណ្ណោះ ។ អាចារ្យទាំងឡាយ ពោលនឹងអាចារ្យវិតណ្ឌវាទីថា កាលបើយ៉ាងនោះ បញ្ហារបស់អ្នកមិនសមនឹងកុសលត្តិកៈ មិនសមនឹងវេទនាតិកៈ មិនសមនឹងវិតក្កត្តិកៈ មិនសមនឹងភូមន្តរៈ ( ភូមិ គឺកាមាវចរជាដើម ) ។ អាចារ្យវិតណ្ឌវាទីនឹងពោលថា សូត្រជំយ៉ាងនេះ មិនមានប្រយោជន៍ឬ ។ ពួកអាចារ្យគប្បីឆ្លើយថា មិនមែនមិនមានប្រយោជន៍ទេ ប៉ុន្តែ លោក រមែងមិនដឹងអត្ថនៃសូត្រនោះក្នុងពាក្យនេះថា សមណៈ ឬព្រាហ្មណ៍នោះ មានឫទ្ធិដល់នូវភាពស្ទាត់ជំនាញតាមផ្លូវចិត្ត លោកមិនបំណងយកការនាមឃិទ្ធិ តែបំណងយកអថព្វនិទ្ធិ ( មន្តអថ៌ន ) ។ ព្រោះអថព្វនិទ្ធិនោះ កាលបានរមែងបានក្នុងពាក្យនេះថា លោកអ្នកមានឫទ្ធិ ដល់នូវភាពជំនាញផ្លូវចិត្ត តែអថព្វនិទ្ធិនោះ ផុតចាកកាយទ្វារ និងវចីទ្វារហើយ ក៏មិនអាចធ្វើបាន ព្រោះថា បុគ្គលអ្នកប្រកបអថព្វនិទ្ធិទាំងឡាយត្រូវបរិភោគវត្ថុដែលមិនប្រៃ ក្រាលកម្រាលស្មៅដេកលើផែនដី បំពេញតបៈអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ គាក់តែងផ្ទៃដីក្នុងព្រៃខ្មោច ហើយឈរនៅក្នុងជំហានជើងទី ៧ បង្វិលដៃវិលទៅមក រាយមន្តដោយមាត់ ពេលនោះ ទើបការធ្វើរបស់ពួកគេសម្រេច សូម្បីឫទ្ធិនេះ ផុតចាកកាយទ្វារ និងវចីទ្វារ ហើយក៏មិនអាចធ្វើបាន ដោយប្រការ

ដូច្នេះ ។ ក្នុងសេចក្ដីនេះ គប្បីដល់នូវសេចក្ដីយល់ព្រមថា កាយកម្ម រមែង មិនតាំងឡើងក្នុងមនោទ្វារ ។

កាលបុគ្គលពោលពាក្យមុសាវាទជាដើម ដោយក្បាល និងដៃ កម្មជាវចីកម្ម តែទ្វារ ជាកាយទ្វារ ។ សូម្បីវចីកម្មដែលជាអកុសល ក៏រមែងតាំងឡើងក្នុងកាយទ្វារ ដោយប្រការដូច្នេះ ។ ចំណែកអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ដែលកើតព្រមជាមួយចិត្តទាំងនោះ រមែងជាចំណែកនៃចេតនាខ្វះ ជាអព្វោហារិកខ្វះ ។ កាលបុគ្គលធ្វើការបន្ទឺវាចា ពោលមុសាវាទជាដើម សូម្បីកម្មក៏ជាវចីកម្ម សូម្បីទ្វារក៏ជាវចីទ្វារដូចគ្នា វចីកម្មដែលជាអកុសល រមែងតាំងឡើងក្នុងវចីទ្វារ ដោយប្រការដូច្នេះ ។ ចំណែកអភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ ជាចំណែករបស់ចេតនាខ្វះ ជាអព្វោហារិកខ្វះ ឈ្មោះថា ពាក្យចន្លុលបង្ហាញដែលដូចគ្នារបស់អាចារ្យទាំងឡាយមានត្រឹមប៉ុណ្ណេះ ។

ចំណែកអាចារ្យវិតណ្ឌវាទីពោលថា វចីកម្មដែលជាអកុសល រមែងតាំងឡើងក្នុងមនោទ្វារក៏បាន ។ អាចារ្យវិតណ្ឌវាទីនោះ ត្រូវអាចារ្យជទៃសាកសួរថា ចូរលោកនាំសូត្រដែលឡើងកាន់សង្គាយនាទាំង ៣ ដងមក ទើបនាំសូត្រនេះ អំពីឧបោសថក្ខន្ធកៈមកថា ភិក្ខុណាមួយកាលដែលខ្ញុំប្រកាសឲ្យដឹងអស់វារៈជាគម្រប់បីដង ទើបរឭកឃើញ តែមិនប្រាប់អាបត្តិដែលមានភិក្ខុនោះ ត្រូវសម្បជានមុសាវាទ ដូច្នេះ ។ កាលលោកនាំសូត្រនេះមកហើយ ក៏ពោលថា ភិក្ខុនោះ មិនធ្វើឲ្យជាក់ច្បាស់នូវអាបត្តិយ៉ាងនេះ ជាអ្នក

នៅស្ងៀម រមែងត្រូវអាបត្តិដទៃ ការកម្រើកចំណែកនៃកាយ ឬវាចាក្នុងទីនេះមានអំពីទីណា វចីកម្មដែលជាអកុសលនេះ រមែងតាំងឡើងក្នុងមនោទ្វារនុ៎ះឯង ដូច្នេះ ។

អាចារ្យទាំងឡាយ គប្បីសួរវិតណ្ឌវាទីនោះថា សូត្រដែលលោកពោលនេះ មានសេចក្តីដែលគួរណែនាំ ឬមានសេចក្តីអធិប្បាយហើយយ៉ាងណា ។ អាចារ្យវិតណ្ឌវាទីពោលថា សូត្ររបស់ខ្ញុំនេះមានសេចក្តីអធិប្បាយហើយ ត្រូវពោលដាស់តឿនថា អ្នកកុំនិយាយយ៉ាងនេះ ពួកយើងនឹងនាំគ្នាពិចារណាមើលសេចក្តីរបស់សូត្រនោះហើយ គប្បីសួរយ៉ាងនេះថា មានអាបត្តិអ្វី ព្រោះសម្បជានមុសាវាទ ។ កាលអាចារ្យវិតណ្ឌវាទីដឹង ក៏នឹងប្រាប់ថា ជាអាបត្តិទុក្កដ ព្រោះសម្បជានមុសាវាទ បន្ទាប់ពីនោះ ក៏គប្បីត្រូវពោលជំទាស់ដោយពាក្យជាដើមថា វិន័យមានមូល ២ យ៉ាង គឺកាយ និងវាចា ពិតហើយ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិអាបត្តិទាំងអស់ក្នុងទ្វារទាំង ២ នេះប៉ុណ្ណោះ ដែលឈ្មោះថា ការបញ្ញត្តិអាបត្តិ ក្នុងមនោទ្វាររមែងមិនមានបុគ្គលណាបញ្ញត្តិអាបត្តិក្នុងឋានៈ ដែលព្រះសាស្តាមិនបានបញ្ញត្តិ ពោលបង្កាច់ព្រះសម្មាសម្ពុទ្ធ ទម្លាយជិនចក្ក បុគ្គលនោះ បេះវិន័យជ្រុល អាចារ្យទាំងឡាយ កាលសង្កត់សង្កិនហើយ ក៏សួរបញ្ហាឲ្យក្រៃលែងឡើងទៀតយ៉ាងនេះថា សម្បជានមុសាវាទ រមែងតាំងឡើងអំពីការធ្វើ ឬមួយព្រោះការមិនធ្វើ កាលវិតណ្ឌវាទីដឹង ក៏នឹងប្រាប់ថា អំពីការធ្វើ បន្ទាប់អំពីនោះ ក៏គប្បីប្រាប់ថា ភិក្ខុមិនធ្វើឲ្យជាក់ច្បាស់នូវអាបត្តិ រមែងធ្វើកិរិយាដូចម្តេច

វិតណ្ឌវាទីកាលមិនឃើញការធ្វើដោយពិត ក៏នឹងដល់នូវសេចក្ដីលំបាក ។ លំដាប់នោះ អាចារ្យទាំងឡាយ គប្បីឲ្យវិតណ្ឌវាទីនោះចុះចាញ់ដោយសេចក្ដីនៃសូត្រនេះ ។ ក្នុងសូត្រនេះ មានសេចក្ដីដូចតទៅនេះ សួរថា មុសាវាទដែលលោកពោលថា ជាសម្បជានមុសាវាទពោលដោយអាបត្តិ ជាអាបត្តិអ្វី គឺជាអាបត្តិប្រភេទណា ឆ្លើយថា ជាអាបត្តិទុក្កដ ។ ឯអាបត្តិទុក្កដនោះ គប្បីជ្រាបថា មិនមែនអាបត្តិដោយលក្ខណៈនៃមុសាវាទ តែជាអាបត្តិដែលមានការមិនធ្វើក្នុងវចីទ្វារជាសមុដ្ឋាន ដោយព្រះតម្រាស់របស់ព្រះមានព្រះភាគសមដូចពាក្យដែលទ្រង់សម្ដែងក្នុងគម្ពីរបរិវារ សេទមោចនគាថាថា

> ភិក្ខុកាលមិនចរចានឹងមនុស្សណាមួយ មួយទៀត កាលនឹងបញ្ចេញវាចា ក៏មិនបានពោលចំពោះអ្នកដទៃឡើយ តែភិក្ខុ ( នោះ ) ត្រឡប់ត្រូវអាបត្តិប្រកបដោយវាចា មិនត្រូវអាបត្តិប្រកបដោយកាយ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃបានគិតមកហើយ ដូច្នេះ ។

ក្នុងទីនេះ គប្បីដល់នូវសេចក្ដីយល់ព្រមថា វចីកម្មដែលជាអកុសលរមែងមិនតាំងឡើងក្នុងមនោទ្វារ ដោយប្រការដូច្នេះ ។

ក៏ប៉ុន្តែ ក្នុងកាលណាបុគ្គលមានចិត្តសហគតៈដោយអភិជ្ឈា ញុំាំងចំណែកនៃកាយឲ្យកម្រើក ធ្វើកិច្ចមានការកាន់យកដោយដៃជាដើម មានចិត្តសហគតៈដោយព្យាបាទ ធ្វើកិច្ចមានការកាន់ដំបងជាដើម មានចិត្តសហគតៈ

ដោយមិច្ឆាទិដ្ឋិ គិតថា ព្រះខន្ទកុមារ ព្រះសិវៈដ៏ប្រសើរ ទើបធ្វើកិច្ច មានអភិវាទ អញ្ជលិកម្ម និងតាក់តែងតាំងតូបសម្រាប់ក្ងត ដើម្បីព្រះខន្ទកុមារ និងព្រះសិវៈនោះ ក្នុងកាលនោះ កម្មជាមនោកម្ម តែទ្វារជាកាយទ្វារ មនោកម្មដែលជាអកុសល រមែងតាំងឡើងក្នុងកាយទ្វារ ដោយប្រការដូច្នេះ តែចេតនាក្នុងទីនេះ ជាអព្វោហារិក ។

ក្នុងកាលណា បុគ្គលមានចិត្តសហគតៈដោយអភិជ្ឈា ញុំាងចំណែកនៃវាចាឲ្យកម្រើក សម្លឹងមើលវត្ថុដែលគួរចង់បានរបស់អ្នកដទៃដោយនិយាយថា ឱហ្ន៎ របស់អ្នកដទៃគប្បីក្លាយជារបស់អញ មានចិត្តសហគតៈដោយព្យាបាទពោលថា សូមសត្វទាំងនេះត្រូវបៀតបៀន ត្រូវសម្លាប់ ចូរដាច់សូន្យ ឬថា ចូរកុំមាន មានចិត្តសហគតៈដោយមិច្ឆាទិដ្ឋិ រមែងពោលថា ទានដែលបុគ្គលឲ្យហើយមិនមានផល យញ្ញដែលបុគ្គលបូជាហើយមិនមានផលជាដើម ក្នុងកាលនោះ កម្មជាមនោកម្ម តែទ្វារជាវចីទ្វារ មនោកម្មដែលជាអកុសល រមែងតាំងឡើងក្នុងវចីទ្វារ ដោយប្រការដូច្នេះ ចេតនាក្នុងទីនេះ ក៏ជាអព្វោហារិក ។

ក្នុងកាលណាបុគ្គលមិនញុំាងចំណែកនៃកាយ និងវាចាឲ្យកម្រើក អង្គុយហើយក្នុងទីកំបាំង ឲ្យចិត្តទាំងឡាយកើតឡើង សហគតៈដោយអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ក្នុងកាលនោះ កម្មជាមនោកម្ម សូម្បីទ្វារក៏ជាមនោទ្វារដូចគ្នា មនោកម្មដែលជាអកុសល រមែងតាំងឡើងក្នុងមនោទ្វារ ដោយប្រការដូច្នេះ ។ ក្នុងទីនេះចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី រមែងតាំង

ឡើងក្នុងមនោទ្វារប៉ុណ្ណោះ មនោកម្មដែលជាអកុសល បណ្ឌិតគប្បីជ្រាបថា រមែងតាំងឡើងក្នុងទ្វារទាំង ៣ ដូចពណ៌នាមក ដូច្នេះ ។

ក្នុងពាក្យដែលលោកពោលថា **កាយកម្ម វចីកម្ម និងមនោកម្ម** ដែលជាកុសលក៏ដូចគ្នា មានន័យដូចតទៅនេះ

ពិតហើយ ក្នុងកាលណា បុគ្គលមិនអាចពោលវាចាដោយហេតុខ្លះ រមែងកាន់យកសិក្ខាបទទាំងនេះដោយដៃ និងក្បាល ដើម្បីឲ្យដឹងថា ខ្ញុំវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ ក្នុងកាលនោះ កម្មជាកាយកម្ម ទ្វារក៏ជាកាយទ្វារដូចគ្នា កាយកម្មដែលជាកុសលរមែងតាំងឡើងក្នុងកាយទ្វារយ៉ាងនេះ ។ ធម៌ មានអនភិជ្ឈាជាដើមដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ រមែងជាចំណែកចេតនាខ្លះ ជាអព្វោហារិកខ្លះ ។

តែក្នុងកាលណា បុគ្គលបន្លឺវាចាទទួលសិក្ខាបទទាំងឡាយនោះឯង ក្នុងកាលនោះ កម្មជាកាយកម្មតែទ្វារជាវចីទ្វារ កាយកម្មដែលជាកុសល រមែងតាំងឡើងក្នុងវចីទ្វារយ៉ាងនេះ ធម៌ មានអនភិជ្ឈាជាដើម ដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ រមែងជាចំណែកនៃចេតនាខ្លះ ជាអព្វោហារិកខ្លះ ។

តែក្នុងកាលណា កាលភិក្ខុឲ្យសិក្ខាបទទាំងនោះ បុគ្គលមិនញ៉ាំងចំណែកនៃកាយ និងវាចាឲ្យកម្រើក រមែងទទួលយកដោយចិត្តប៉ុណ្ណោះថា ខ្ញុំព្រះករុណា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ ដូច្នេះ ក្នុងកាលនោះ កម្ម ជាកាយកម្ម ចំណែកទ្វារ ជាមនោកម្ម កាយកម្មដែលជាកុសល រមែងតាំងឡើងក្នុងមនោទ្វារយ៉ាងនេះ ធម៌ មានអនភិជ្ឈា

ជាដើមដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ រមែងជាចំណែកនៃចេតនាខ្លះ ជាអព្វោហារិកខ្លះ ។

កាលបុគ្គលទទួលសិក្ខាបទទាំង ៤ មានចេតនាជាគ្រឿងវៀរចាកមុសា-វាទជាដើម ដោយកាយទ្វារជាដើម ដោយន័យដែលពោលមកហើយនុ៎ះឯង វចីកម្មដែលជាកុសល បណ្ឌិតគប្បីជ្រាបថា រមែងតាំងឡើងក្នុងទ្វារទាំង ៣ ក្នុងទីនេះ ធម៌ មានអនភិជ្ឈាជាដើម រមែងជាចំណែករបស់ចេតនាខ្លះ ជាអព្វោហារិកខ្លះ ។

តែបុគ្គលញ៉ាំងចំណែកនៃកាយឲ្យកម្រើកដោយចិត្ត ដែលសហគតៈដោយអនភិជ្ឈាជាដើម ធ្វើការបោសសំអាតលានព្រះចេតិយ ធ្វើការបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម និងថ្វាយបង្គំព្រះចេតិយជាដើម កម្មជាមនោកម្ម តែទ្វារជាកាយទ្វារ មនោកម្មដែលជាកុសល រមែងតាំងឡើងក្នុងកាយទ្វារយ៉ាងនេះ ប៉ុន្តែចេតនាក្នុងទីនេះ ជាអព្វោហារិកប៉ុណ្ណោះ កាលបុគ្គលមានចិត្តសហគតៈដោយអនភិជ្ឈា ញ៉ាំងចំណែកនៃវាចាឲ្យកម្រើក មិនរំពៃមើលថា ឱហ្ន៎ វត្ថុដែលគួរត្រេកអររបស់អ្នកដទៃ កុំគប្បីក្លាយជារបស់អញដូច្នេះ មានចិត្តសហគតៈដោយអព្យាបាទ ពោលថា សត្វទាំងពួងកុំបីមានពៀរ កុំបៀតបៀនគ្នា កុំមានសេចក្តីទុក្ខ សូមមានសេចក្តីសុខ រក្សាខ្លួនចុះ មានចិត្តសហគតៈដោយសម្មាទិដ្ឋិ បន្លឺវាចាថា ទានដែលបុគ្គលឲ្យហើយ មានផលជាដើម កម្មជាមនោកម្ម តែទ្វារជាវចីកម្ម ។ មនោកម្មដែលជាកុសល រមែងតាំងឡើងក្នុងវចីទ្វារយ៉ាងនេះ ។ ឯចេតនាក្នុងទីនេះ ជាអព្វោហារិក

តែកាលបុគ្គលមិនឲ្យកាយ និងវាចាកម្រើក អង្គុយនៅក្នុងទីស្ងាត់ ឲ្យចិត្តដែលសហគតៈដោយអនភិជ្ឈាជាដើមកើតឡើងដោយចិត្តប៉ុណ្ណោះ កម្មជាមនោកម្ម សូម្បីទ្វារក៏ជាមនោទ្វារដូចគ្នា ។ មនោកម្មដែលជាកុសល រមែងតាំងឡើងក្នុងមនោទ្វារយ៉ាងនេះ តែក្នុងទីនេះ ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី រមែងតាំងឡើងក្នុងមនោទ្វារប៉ុណ្ណោះ ។

បណ្តាកម្ម និងទ្វារទាំងនោះ បុគ្គលកាលពោលថា ក្នុងបាណាតិបាត និងអទិន្នាទាន ដែលតាំងឡើងដោយការប្រើឲ្យអ្នកដទៃធ្វើ កម្មក៏ជាកាយកម្ម ទ្វារក៏ជាកាយទ្វារ ដោយអំណាចនៃកម្មនុ៎ះឯង ឈ្មោះថា រមែងរក្សាកម្ម រមែងទម្លាយទ្វារ ។ កាលពោលថា បណ្តាមុសាវាទជាដើម ដែលតាំងឡើងដោយដៃ និងក្បាល ទ្វារក៏ជាកាយទ្វារ កម្មក៏ជាកាយកម្ម ដោយអំណាចនៃទ្វារនុ៎ះឯង ឈ្មោះថា រមែងរក្សាទ្វារ រមែងទម្លាយកម្ម ព្រោះហេតុនោះ មិនគួរទម្លាយទ្វារដោយគំនិតថា អញនឹងរក្សាកម្ម និងមិនគប្បីទម្លាយកម្មដោយគំនិតថា អញនឹងរក្សាទ្វារ មួយទៀត បណ្ឌិតគប្បីជ្រាបកម្ម និងទ្វារដោយន័យតាមដែលពោលហើយនុ៎ះឯង ព្រោះថា កាលបុគ្គលពោលយ៉ាងនេះ រមែងមិនទម្លាយកម្ម និងទ្វារដូច្នេះឯង ។

**កម្មកថា ចប់**

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យវិញ្ញាណ ៥ និងទ្វារនៃវិញ្ញាណ ៥ ដូចតទៅ

ឈ្មោះថា វិញ្ញាណ គឺចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ ។

ឈ្មោះថា ទ្វារវិញ្ញាណ ៥ គឺ ទ្វារនៃចក្ខុវិញ្ញាណ ១ ទ្វារនៃសោតវិញ្ញាណ ១ ទ្វារនៃឃានវិញ្ញាណ ១ ទ្វារនៃជិវ្ហាវិញ្ញាណ ១ ទ្វារនៃកាយវិញ្ញាណ ១ ។

ចេតនាដែលកើតឡើងដោយអំណាចនៃទ្វារទាំង ៥ នេះ បណ្ឌិតគប្បីជ្រាបថា មិនជាកាយកម្ម មិនជាវចីកម្ម ត្រឹមតែជាមនោកម្មប៉ុណ្ណោះ ។ តែឈ្មោះថា **សម្ផស្ស** ទាំងនេះ មាន ៦ គឺ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស ។ ឈ្មោះថា **ទ្វារនៃសម្ផស្ស** ទាំងនេះ មាន ៦ គឺទ្វារនៃចក្ខុសម្ផស្ស ទ្វារនៃសោតសម្ផស្ស ទ្វារនៃឃានសម្ផស្ស ទ្វារនៃជិវ្ហាសម្ផស្ស ទ្វារនៃកាយសម្ផស្ស ទ្វារនៃមនោសម្ផស្ស ។

ឈ្មោះថា **អសំវរៈ** ទាំង ៨ នេះ គឺចក្ខុអសំវរៈ សោតអសំវរៈ ឃានអសំវរៈ ជិវ្ហាអសំវរៈ បសាទកាយអសំវរៈ ចោបនកាយអសំវរៈ វាចាអសំវរៈ មនោអសំវរៈ ។ អសំវរៈទាំង ៨ នោះ ពោលដោយអត្ថ បានដល់ ធម៌ទាំង ៥ នេះ គឺភាពជាអ្នកទ្រុស្តសីល ភាពជាអ្នកវង្វេង ការមិនដឹង សេចក្តីមិនអត់ធន់ និងសេចក្តីខ្ជិលច្រអូស ។ បណ្តាធម៌ទាំង ៥ នោះ

សូម្បីធម៌មួយ រមែងមិនកើតឡើងក្នុងចិត្តទាំងឡាយ ក្នុងបញ្ចទ្វារ មានវោដ្ឋ-ព្វនចិត្តជាទីបំផុត តែរមែងកើតក្នុងខណៈនៃជវនចិត្តប៉ុណ្ណោះ ។ ធម៌នោះ ទោះបីកើតឡើងក្នុងជវនចិត្ត លោកក៏ហៅថា **អសំវរៈ** ( ការមិនសង្រួម ) ក្នុងទ្វារ ៥ ។

ពិតហើយ ផស្សៈកើតព្រមនឹងចក្ខុវិញ្ញាណ ឈ្មោះថា ចក្ខុសម្ផស្ស ចេតនា ឈ្មោះថា មនោកម្ម ចិត្តនោះ ឈ្មោះថា ទ្វារនៃមនោកម្ម ។ ក្នុងចក្ខុវិញ្ញាណនេះ អសំវរៈ ៥ យ៉ាង មិនទាន់មាន ។ ផស្សៈដែលកើតព្រមនឹងសម្បដិច្ឆន្នចិត្ត ឈ្មោះថា មនោសម្ផស្ស ចេតនា ឈ្មោះថា មនោកម្ម ចិត្តនោះ ឈ្មោះថា ទ្វារនៃមនោកម្ម ។ ក្នុងសម្បដិច្ឆន្នចិត្តនេះ អសំវរៈក៏មិនទាន់មាន ។ ក្នុងសន្តីរណចិត្ត និងវោដ្ឋព្វនចិត្ត ក៏ន័យនេះឯង តែផស្សៈដែលកើតព្រមនឹងជវនចិត្ត ឈ្មោះថា មនោសម្ផស្ស ចេតនា ឈ្មោះថា មនោកម្ម ចិត្តនោះ ឈ្មោះថា ទ្វារនៃមនោកម្ម ។ ការមិនសង្រួមក្នុងជវនចិត្តនោះ ឈ្មោះថា **ចក្ខុអសំវរៈ** ( ការមិនសង្រួមតាមផ្លូវភ្នែក ) ។ ក្នុងសោត-ទ្វារ ឃានទ្វារ ជិវ្ហាទ្វារ បសាទកាយទ្វារ ក៏មានន័យនេះដូចគ្នា ។

ក្នុងកាលណាជវនចិត្តតាមមនោទ្វារ មានអារម្មណ៍ណាមួយ មានរូបជាដើមជាអារម្មណ៍ រមែងកើតឡើង ញុំាងការកម្រើកកាយទ្វារស្ងួតៗ វៀរវិចិទ្វារឲ្យប្រព្រឹត្តទៅ ក្នុងកាលនោះផស្សៈដែលកើតព្រមនឹងចិត្តនោះ ឈ្មោះថា មនោសម្ផស្ស ចេតនា ឈ្មោះថា កាយកម្ម តែចិត្តនោះ ជាអព្យាហារិក មិនដល់នូវការរាប់ថា ជាមនោទ្វារ ព្រោះការកម្រើកកើតហើយ ។ ការមិន

សង្រួមក្នុងជវនៈនេះ ឈ្មោះថា ការមិនសង្រួមតាមផ្លូវកាយ ។

ក្នុងកាលណាជវនចិត្តបែបនោះឯងកើតឡើង ញុំាងការកម្រើកក្នុងវចីទ្វារ សុទ្ធៗ វៀរកាយទ្វារឲ្យប្រព្រឹត្តទៅ ក្នុងកាលនោះ ផស្សៈដែលកើតព្រមនឹងចិត្តនោះ ឈ្មោះថា មនោសម្ផស្ស ចេតនា ឈ្មោះថា វចីកម្ម តែចិត្តនោះ ជាអព្វោហារិក មិនដល់នូវការរាប់ថា ជាមនោទ្វារ ព្រោះការកម្រើកកើតឡើងហើយ ។ ការមិនសង្រួមក្នុងជវនចិត្តនេះ ឈ្មោះថា ការមិនសង្រួមតាមផ្លូវវាចា ។

តែក្នុងកាលណាជវនចិត្តបែបនោះ វៀរចាកកាយទ្វារ និងវចីទ្វារ ជាមនោទ្វារសុទ្ធៗ កើតឡើង ក្នុងកាលនោះ ផស្សៈដែលកើតព្រមនឹងចិត្តនោះ ឈ្មោះថា មនោសម្ផស្ស ចេតនា ឈ្មោះថា មនោកម្ម ចំណែកចិត្តនោះ ឈ្មោះថា ទ្វារនៃមនោកម្ម ។ ការមិនសង្រួមក្នុងជវនចិត្តនេះ ឈ្មោះថា ការមិនសង្រួមតាមផ្លូវចិត្ត ។

បណ្ឌិតគប្បីជ្រាបទ្វារនៃអសំវរៈទាំង ៨ នេះ គឺទ្វារនៃអសំវរៈតាមផ្លូវភ្នែក ទ្វារនៃអសំវរៈតាមផ្លូវសោតៈ ឃានៈ ជិវ្ហា បសាទកាយ ចោបនកាយ វាចា មនោ ដោយអំណាចនៃអសំវរៈទាំង ៨ នេះ ដោយប្រការដូច្នេះ ។

ចំណែកឈ្មោះថា **សំវរៈ** ទាំង ៨ នេះ គឺចក្ខុសំវរៈ សោតសំវរៈ ឃានសំវរៈ ជិវ្ហាសំវរៈ បសាទកាយសំវរៈ ចោបនកាយសំវរៈ វាចាសំវរៈ មនោសំវរៈ ។ បណ្តាសំវរៈទាំងនោះ ពោលដោយអត្ថ បានដល់ ធម៌ទាំង ៥ នេះ គឺ **សីល សតិ ញាណ ខន្តិ វិរិយៈ** ។ បណ្តាធម៌ទាំង ៥ នោះ

សូម្បីធម៌មួយ រមែងមិនកើតក្នុងចិត្តទាំងឡាយក្នុងបញ្ចទ្វារ មានវោដ្ឋព្វនចិត្តជាទីបំផុត ធម៌នោះ រមែងកើតក្នុងខណៈនៃជវនចិត្តប៉ុណ្ណោះ សូម្បីកើតក្នុងជវនចិត្ត លោកក៏ហៅថា សំវរៈក្នុងបញ្ចទ្វារ ។

បណ្ឌិតគប្បីជ្រាបការកើតឡើងនៃសំវរៈទាំងអស់នោះ ដោយន័យដែលពោលហើយក្នុងអសំវរៈ ដែលមានពាក្យថា ផស្សៈដែលកើតព្រមនឹងចក្ខុ-វិញ្ញាណ ឈ្មោះថា ចក្ខុសម្ផស្សជាដើម ។ គប្បីជ្រាបទ្វារនៃអសំវរៈទាំង ៨ នេះ គឺទ្វារនៃសំវរៈផ្លូវភ្នែក ។បេ។ ទ្វារនៃសំវរៈផ្លូវមនោ ដោយអំណាចនៃសំវរៈទាំង ៨ នេះ ដោយប្រការដូច្នេះ ។

# អកុសលកម្មបថ

ឈ្មោះថា អកុសលកម្មបថទាំងនេះ មាន ១០ គឺបាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ ។

បណ្ដាអកុសលកម្មបថទាំងនោះ ការញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ឈ្មោះថា **បាណាតិបាត** លោកអធិប្បាយថា ការទម្លាយជីវិត គឺការសម្លាប់សត្វ ។ ក្នុងពាក្យថា បាណាតិបាតនេះ ពាក្យថា **បាណា** ដោយវោហារ បានដល់ សត្វ ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ ២ យ៉ាង ។ វធកចេតនា ( ចេតនាគិតនឹងសម្លាប់ ) ដែលជាហេតុឲ្យការព្យាយាមចូលទៅផ្ដាច់ជីវិតិន្ទ្រិយតាំងឡើង ដែលប្រព្រឹត្តទៅតាមកាយទ្វារ ឬវចីទ្វារ ទ្វារណាមួយរបស់បុគ្គលដែលដឹងថា សត្វនោះមានជីវិត ឈ្មោះថា **បាណាតិបាត** ។ បណ្ដាសត្វទាំងឡាយ មានសត្វតិរច្ឆានជាដើមដែលមិនមានគុណ បាណាតិបាតនោះ ឈ្មោះថា មានទោសតិច ព្រោះជាសត្វតូច ឈ្មោះថា មានទោសច្រើន ព្រោះសត្វរាងកាយធំ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមានសេចក្ដីព្យាយាមច្រើន ។ សូម្បីមានសេចក្ដីព្យាយាមស្មើគ្នា ក៏មានទោសច្រើន ព្រោះវត្ថុធំ បណ្ដាសត្វដែលមានគុណ មានមនុស្សជាដើម បាណាតិបាតនោះ ឈ្មោះថា មានទោសតិច ព្រោះសត្វ ( មនុស្ស ) មានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះសត្វមានគុណច្រើន ។ កាលសត្វនោះមានសរីរៈ និងគុណស្មើគ្នា គប្បីជ្រាបថា បាណាតិបាតមានទោសតិច ព្រោះកិលេសទាំងឡាយ និងសេចក្ដីព្យាយាមខ្សោយ ឈ្មោះថា មាន

ទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ។ បាណាតិបាតនោះ មានអង្គ ៥ គឺ **បាណោ** សត្វមានជីវិត ១ **បាណសញ្ញិតា** ដឹងថា សត្វមានជីវិត ១ **វធកចិត្តំ** មានចិត្តគិតនឹងសម្លាប់ ១ **ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ១ **តេន មរណំ** សត្វស្លាប់ដោយការព្យាយាមនោះ ១ ។

បាណាតិបាតនោះ មានប្រយោគ ៦ គឺសាហត្ថិកប្បយោគ ធ្វើដោយខ្លួនឯង ១ អាណត្តិកប្បយោគ ប្រើគេឲ្យធ្វើ ១ និស្សគ្គិយប្បយោគ បោះគ្រឿងប្រហារទៅ ១ ថាវរប្បយោគ ដាក់គ្រឿងប្រហារដែលមាំទាំ ១ វិជ្ជាមយប្បយោគ ប្រើមន្ត ១ ឥទ្ធិមយប្បយោគ ប្រើអឫទ្ធិ ១ ។

សេចក្តីនេះ បើខ្ញុំឲ្យពិស្តារក៏នាំឲ្យយឺតយូរ ព្រោះហេតុនោះ ខ្ញុំមិនពណ៌នាសេចក្តីនោះ និងសេចក្តីដទៃឲ្យពិស្តារទេ បុគ្គលត្រូវការសេចក្តីពិស្តារ គប្បីមើលអដ្ឋកថាព្រះវិន័យ ឈ្មោះ សមន្តប្បាសាទិកា ហើយកាន់យកចុះ ។

ការកាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** លោកអធិប្បាយថា ការនាំកណ្ឌៈ ( ទ្រព្យ ) របស់ជនដទៃទៅ គឺការលួច ការប្លន់ ។ បណ្តាបទទាំងនោះ បទថា **អទិន្នំ** បានដល់ វត្ថុដែលបុគ្គលដទៃហួងហែង អធិប្បាយថា បុគ្គលដទៃធ្វើតាមគាប់ចិត្តក្នុងទ្រព្យណា មិនមានខុស មិនមានទោស ( ហៅថា ទ្រព្យអ្នកដទៃ ) ថេយ្យចេតនាដែលជាហេតុឲ្យព្យាយាមកាន់យកទ្រព្យនោះតាំងឡើង របស់បុគ្គលដែលមានការសម្គាល់ក្នុងវត្ថុដែលបុគ្គលដទៃហួងហែងនោះថា អ្នកដទៃហួងហែង ឈ្មោះថា **អទិន្នាទាន** ។ អទិន្នាទាននោះ ឈ្មោះថា មានទោសតិច ព្រោះទ្រព្យអ្នក

ដទៃថោកថយ ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យប្រណីត ។ ព្រោះហេតុអ្វីទើបមានទោសច្រើន ព្រោះទ្រព្យដែលលួចទៅនោះជារបស់ប្រណីត កាលវត្ថុស្មើគ្នា អទិន្នាទាននោះ ឈ្មោះថា មានទោសច្រើន ព្រោះ ( លួច ) ទ្រព្យរបស់បុគ្គលដែលមានគុណច្រើន ឈ្មោះថា មានទោសតិច ព្រោះ ( លួច ) ទ្រព្យរបស់បុគ្គលដែលមានគុណតិចជាងនោះៗ ដោយប្រៀបធៀបនឹងបុគ្គលអ្នកមានគុណច្រើននោះៗ ។

អទិន្នាទាននោះ មានអង្គ ៥ គឺ **បរបរិគ្គហិតំ** ទ្រព្យដែលអ្នកដទៃហួងហែងរក្សា ១ **បរបរិគ្គហិតសញ្ញិតា** ដឹងថា ទ្រព្យអ្នកដទៃហួងហែងរក្សា ១ **ថេយ្យចិត្តំ** មានចិត្តគិតនឹងលួច ១ **ឧបក្កមោ** ព្យាយាមនឹងលួច ១ **តេន ហរណំ** លួចបានដោយព្យាយាមនោះ ១ ។

អទិន្នាទាននោះ មានប្រយោគ ៦ មានសាហត្ថិកប្បយោគជាដើម ប្រយោគទាំងនោះ រមែងប្រព្រឹត្តទៅដោយអំណាចនៃអវហារ ( ការលួច ) ទាំង ៥ នេះ តាមសមគួរ គឺ **ថេយ្យាវហារ** ការលួចដោយការលួច ១ **បសយ្ហាវហារ** ការលួចដោយការប្លន់ ១ **បដិច្ឆន្នាវហារ** ការលួចដោយការបិទបាំង ១ **បរិកប្បាវហារ** ការលួចដោយកំណត់ ១ **កុសាវហារ** ការលួចដោយប្តូរស្លាក ១ ។

សេចក្តីក្នុងទីនេះ លោកសម្តែងដោយសង្ខេប ឯសេចក្តីពិស្តារលោកពោលក្នុងសមន្តបា្បសាទិកាហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា កាមេសុមិច្ឆាចារដូចតទៅ

បទថា **កាមេសុ** បានដល់ ការសេពមេថុន ។ ការប្រព្រឹត្តិអាក្រក់ ដែលបណ្ឌិតតិះដៀលដោយចំណែកមួយ ឈ្មោះថា **មិច្ឆាចារ** ។ តែកាល ពោលដោយលក្ខណៈ បានដល់ ចេតនាជាហេតុឈានកន្លងឋានៈដែលមិន គួរ ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយបំណងអសទ្ធម្ម ឈ្មោះថា **កាមេសុមិច្ឆាចារ** ។

ក្នុងកាមេសុមិច្ឆាចារនោះ ស្រី ២០ ពួក ឈ្មោះថា អគមនីយដ្ឋាននៃ បុរស បានដល់ ស្រីដែលមាតារក្សាជាដើម ១០ ពួកដំបូង គឺ

ស្រីដែលមាតារក្សា ១ ស្រីដែលបិតារក្សា ១ ស្រីដែលមាតាបិតារក្សា ១ ស្រីដែលបងប្អូនប្រុសរក្សា ១ ស្រីដែលបងប្អូនស្រីរក្សា ១ ស្រីដែល ញាតិរក្សា ១ ស្រីដែលត្រកូលរក្សា ១ ស្រីដែលមានធម៌រក្សា ១ ស្រី ដែលគេដណ្តឹង ( នារីទុក ) ១ ស្រីដែលព្រះរាជាដាក់អាជ្ញា ១ ។

ស្រីដែលជាភរិយា មានការលោះមកដោយទ្រព្យជាដើមទាំងនេះ គឺ ភរិយាដែលលោះមកដោយទ្រព្យ ១ ភរិយាដែលនៅរួមដោយសេចក្តីពេញ ចិត្ត ១ ភរិយាដែលនៅរួមដោយភោគៈ ១ ភរិយាដែលនៅរួមដោយសំពត់ ១ ភរិយាដែលធ្វើពិធីជ្រមុជទឹក ១ ភរិយាដែលប្រុសដាក់ទ្រនូលចុះអំពី ក្បាល ១ ភរិយាដែលជាទាសីក្នុងផ្ទះ ១ ភរិយាដែលជួលឲ្យមកធ្វើការ ១ ភរិយាដែលជាឈ្លើយ ( ចាប់បានក្នុងសង្គ្រាម ) ១ ភរិយាដែលនៅរួមម្តង ម្កាល ១ ។

បុរសដទៃៗ ឈ្មោះថា **អគមនីយដ្ឋាន** ( គឺឋានៈដែលមិនគួរសេពគប់ )

នៃស្រី ១២ ពួក ។ ក្នុងស្រី ២០ ពួកនោះ ស្រី ១២ ពួក គឺស្រីដែលគេដណ្តឹង ( នាវទុក ) ១ ស្រីដែលព្រះរាជាដាក់អាជ្ញា ១ រួមនឹងកិរិយា ១០ ពួក មានស្រីដែលលោះមកដោយទ្រព្យជាដើម ។ នេះ ឈ្មោះថា **អគមនីយដ្ឋាន** ( ស្ត្រីដែលបុរសមិនគួរចូលទៅសេពគប់ និងស្ត្រីដែលមិនគួរចូលសេពគប់បុរស ) ។

មិច្ឆាចារនេះ ឈ្មោះថា មានទោសតិច ព្រោះអគមនីយដ្ឋាន វៀរចាកគុណ មានសីលជាដើម ឈ្មោះថា មានទោសច្រើន ព្រោះអគមនីយដ្ឋានដល់ព្រមដោយគុណ មានសីលជាដើម ។ មិច្ឆាចារនោះ មានអង្គ ៤ គឺ **អគមនីយវត្ថុ** វត្ថុដែលមិនគួរសេពគប់ ១ **តស្មឹ សេវនចិត្តំ** មានចិត្តគិតនឹងសេពក្នុងអគមនីយវត្ថុនោះ ១ **សេវនប្បយោគោ** ព្យាយាមនឹងសេព ១ **មគ្គេន មគ្គប្បដិបត្តិអធិវាសនំ** ញុំាំងមគ្គនិងមគ្គឲ្យដល់គ្នា ១ ។ ប្រយោគរបស់មិច្ឆាចារនោះ មាន ១ គឺសាហត្ថិកប្បយោគប៉ុណ្ណោះ ។

សេចក្តីព្យាយាមតាមផ្លូវវាចា ឬសេចក្តីព្យាយាមតាមផ្លូវកាយដែលទម្លាយប្រយោជន៍របស់បុគ្គលអ្នកប្រាថ្នាពោលឲ្យខុស ឈ្មោះថា **មុសា** ។ ចេតនាដែលជាហេតុឲ្យការព្យាយាមផ្លូវកាយ ឬផ្លូវវាចា ដែលប្រាថ្នានឹងពោលឲ្យឃៀងឃ្លាតជាប្រការដទៃ ដល់បុគ្គលដទៃតាំងឡើង ដោយប្រាថ្នានឹងពោលឲ្យឃៀងឃ្លាត ឈ្មោះថា **មុសាវាទ** ។ ន័យម្យ៉ាងទៀត រឿងដែលមិនពិតមិនមែនជារបស់ពិត ឈ្មោះថា **មុសា** ។ ការឲ្យបុគ្គលដឹងរឿងមិនពិត មិនប្រាកដនោះដោយភាវៈជាពិត ជាប្រាកដ ឈ្មោះថា វាទៈ ។ ពោលដោយ

លក្ខណៈ ចេតនារបស់បុគ្គល ដែលបំណងឲ្យអ្នកដទៃដឹងរឿងមិនពិត ថាជារឿងពិត ដែលធ្វើវិញ្ញត្តិយ៉ាងនោះឲ្យតាំងឡើង ហៅថា មុសាវាទ ។ មុសាវាទនោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលត្រូវបំផ្លាញនោះតិច ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ ដែលត្រូវបំផ្លាញនោះច្រើន ។ម្យ៉ាងទៀត មុសាវាទរបស់គ្រហស្ថទាំងឡាយ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា មិនមាន ដូច្នេះ ព្រោះមិនបំណងឲ្យវត្ថុដែលមានរបស់ខ្លួន ឈ្មោះថា មានទោសតិច ។ មុសាវាទដែលខ្លួនជាសាក្សី ពោលដើម្បីទម្លាយប្រយោជន៍ ឈ្មោះថា មានទោសច្រើន ។ មុសាវាទរបស់បព្វជិតទាំងឡាយ ដែលប្រព្រឹត្តទៅដោយន័យបូរណកថាថា ប្រេងក្នុងស្រុកថ្ងៃនេះហូរដូចស្ទឹង ដោយប្រាថ្នានឹងនាំគ្នាសើចលេង ព្រោះបានប្រេង ឬសប្បិតិចតួច ឈ្មោះថា មានទោសតិច តែមុសាវាទរបស់បព្វជិតពោលដោយន័យជាដើមថា មិនឃើញ ថាឃើញ ដូច្នេះ ឈ្មោះថា មានទោសច្រើន ។ មុសាវាទនោះ មានអង្គ ៤ គឺ **អតថំ វត្ថុ** រឿងមិនពិត ១ **វិសំវាទនចិត្តំ** គិតនឹងពោលឲ្យឃ្លៀងឃ្លាត ១ **តជ្ជោ វាយាមោ** ព្យាយាមពោលដោយគំនិតនោះ ១ **បរស្ស តទត្ថវិជាននំ** អ្នកដទៃដឹងនូវសេចក្ដីនោះ ១ ។ ប្រយោគរបស់មុសាវាទមានតែមួយប៉ុណ្ណោះ គឺសាហត្ថិកប្បយោគ ។

បយោគនោះ គប្បីជ្រាបដោយការធ្វើកិរិយារបស់អ្នកពោល ឲ្យឃ្លៀងឃ្លាតដោយកាយ ដោយរបស់ជាប់នឹងកាយ ឬដោយវាចា ។ បើបុគ្គលដទៃ

ដឹងសេចក្ដីនោះដោយកិរិយានោះ កិរិយានេះ ជាកម្មពន្ធ ( ចំណងកម្ម ) ដែលជាមុសាវាទក្នុងខណៈនៃចេតនា ដែលធ្វើកិរិយាឲ្យតាំងឡើងនោះឯង ។ មួយទៀត កាលបុគ្គលប្រើថា ចូរអ្នកពោលពាក្យនេះដល់បុគ្គលនេះ ដោយប្រការដែលឲ្យបុគ្គលដទៃពោលឲ្យឃើញឃ្លាតដោយកាយ ដោយរបស់ជាប់នឹងកាយ ឬដោយវាចាដូច្នេះក្ដី សរសេរសំបុត្របោះទៅខាងមុខក្ដី សរសេរជាប់ត្រង់ជញ្ជាំងផ្ទះជាដើម ដោយបំណងថា បុគ្គលគប្បីជ្រាបសេចក្ដីនេះយ៉ាងនេះ ដូច្នេះក្ដី ហេតុនោះ ប្រយោគទាំងឡាយ គឺអាណត្តិកប្បយោគ និស្សគ្គិយប្បយោគ ថាវរប្បយោគ ក៏រមែងសមគួរក្នុងមុសាវាទនេះ តែព្រោះមិនមានមកក្នុងអដ្ឋកថាទាំងឡាយ ទើបគួរពិចារណាសិន ហើយសឹមកាន់យក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបិសុណាវាចាជាដើមដូចតទៅនេះ

បុគ្គលធ្វើខ្លួនឲ្យជាទីស្រឡាញ់ ក្នុងហទយៈរបស់បុគ្គលដែលខ្លួនពោលវាចានោះផង ធ្វើការសោបសូន្យដល់បុគ្គលដទៃផង ដោយវាចាណា វាចានោះ ឈ្មោះថា **បិសុណាវាចា** ។

បុគ្គលណា ធ្វើខ្លួនឯងខ្លះ ធ្វើអ្នកដទៃខ្លះ ឲ្យគ្រោតគ្រាតដោយវាចាណា ឬវាចាណា ជាវាចាគ្រោតគ្រាតឯង មិនពីរោះ មិនចាប់ចិត្ត វាចានេះឈ្មោះថា **ផរុសវាចា** ។

បុគ្គលពោលរោយរាយ គឺឥតប្រយោជន៍ដោយវាចាណា វាចានោះឈ្មោះថា **សម្ផប្បលាបៈ** ។ ចេតនាដែលជាហេតុរបស់វាចាទាំងនោះ ក៏បាន

ឈ្មោះថា **បិសុណាវាចា** ជាដើមនុ៎ះឯង ។ ចេតនានោះឯង លោកបំណង យកក្នុងទីនេះ ។

បណ្ដាវាចាទាំងនោះ ចេតនារបស់បុគ្គលអ្នកមានចិត្តសៅហ្មង ដែលជាហេតុឲ្យនូវការព្យាយាមផ្លូវកាយ និងវាចាតាំងឡើង ដើម្បីការបែកគ្នារបស់ជនដទៃ ឬដើម្បីឲ្យខ្លួនជាទីស្រឡាញ់ ឈ្មោះថា **បិសុណាវាចា** ។ ចេតនាដែលជាបិសុណាវាចានោះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គលដែលខ្លួនធ្វើឲ្យបែកគ្នាមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះបុគ្គលនោះមានគុណច្រើន ។ បិសុណាវាចានោះ មានអង្គប្រកប ៤ យ៉ាង គឺ **ភិន្ទិ-តព្វោ បរោ** មានជនដទៃដែលខ្លួនត្រូវធ្វើឲ្យបែកគ្នា ១ **ភេទបុរេក្ខារតា** ភាពជាអ្នកមានចេតនាពោលឲ្យបែកគ្នា ១ ដោយបំណងថា ជនទាំងនេះនឹងប្រព្រឹត្តទៅផ្សេងៗ គ្នាដោយឧបាយយ៉ាងនេះ ឬថា ជាអ្នកប្រាថ្នានឹងធ្វើខ្លួនឲ្យជាទីស្រឡាញ់ដោយបំណងថា អញនឹងជាទីស្រឡាញ់ នឹងជាទីស្និទ្ធស្នាលដោយឧបាយយ៉ាងនេះ **តជ្ជោ វាយាមោ** មានសេចក្ដីព្យាយាមកើតឡើងដោយចិត្តនោះ ១ **តស្ស តទត្ថវិជាននំ** បុគ្គលនោះដឹងសេចក្ដីនោះ ១ ។

កាលបុគ្គលដទៃមិនបែកគ្នា កម្មបថក៏មិនដាច់ កាលបុគ្គលបែកគ្នានុ៎ះឯង កម្មបថក៏ដាច់ ។

ចេតនាគ្រោតគ្រាតដោយចំណែកមួយ ដែលជាហេតុឲ្យសេចក្ដីព្យាយាមផ្លូវកាយ និងវាចា ដែលកាត់សេចក្ដីស្រឡាញ់របស់អ្នកដទៃតាំងឡើង ឈ្មោះថា **ផរុសវាចា** ។ ដើម្បីសេចក្ដីជាក់ច្បាស់នៃផរុសវាចានោះ មានរឿងនេះ

ជាឧទាហរណ៍ ។

បានឮថា ទារកម្នាក់មិនស្តាប់សម្តីរបស់មាតា ចូលទៅកាន់ព្រៃ មាតាមិនអាចឲ្យគេត្រឡប់បាន ទើបជេរថា សូមឲ្យមេក្របីកាចដេញវែងវា លំដាប់នោះ មេក្របីក្នុងព្រៃបានប្រាកដដល់ទារកនោះ ដូចពាក្យមាតានោះពោលទុំះ ឯង ទារកបានធ្វើសច្ចកិរិយាថា ម៉ែរបស់អញនិយាយពាក្យណាដោយមាត់ ( មិនគិតប្រទូស្ត ) សូមពាក្យនោះ កុំមាន បើម៉ែគិតរឿងណាដោយការតាំងចិត្ត សូមរឿងនោះមានចុះ មេក្របីក៏បានឈរនៅ ដូចបុគ្គលចងក្នុងទីនោះឯង ។ ការនិយាយដែលកាត់នូវសេចក្តីស្រឡាញ់យ៉ាងនេះ រមែងមិនឈ្មោះថា **ផរុសវាចា** ព្រោះចិត្តទន់ភ្លន់ ។ មែនពិត ក្នុងកាលខ្លះ មាតា និងបិតារមែងនិយាយនឹងកូនតូចយ៉ាងនេះថា សូមឲ្យពួកចោរកាប់ពួកឯងឲ្យជាកំណាត់តូចធំ តែលោកទាំងពីរនោះ មិនប្រាថ្នាឲ្យគ្រោះឧប្បលធ្លាក់ទៅត្រូវកូនទាំងនោះ មួយទៀត ក្នុងកាលខ្លះ អាចារ្យ និងឧបជ្ឈាយ៍ពោលនឹងសិស្សយ៉ាងនេះថា ពួកនេះមិនមានហិរិ មិនមានឱត្តប្បៈ និយាយអ្វី ពួកឯង ចូរដេញគេចេញទៅ តែតាមការពិតលោកទាំងនោះ រមែងប្រាថ្នានូវការដល់ព្រមនៃការរៀនសូត្រ និងការសម្រេចមគ្គផលរបស់សិស្សទាំងនោះ ព្រោះចិត្តទន់ភ្លន់ ទើបមិនឈ្មោះថា **ផរុសវាចា** យ៉ាងណា ព្រោះវាចាផ្អែមល្ហែមមិនបានឈ្មោះថា ជាផរុសវាចា ក៏មិនមែន ដ្បិតថា វាចារបស់បុគ្គលដែលបំណងឲ្យអ្នកដទៃស្លាប់ថា ចូរពួកអ្នក ឲ្យបុគ្គលនេះ ដេកជាសុខចុះ ដូច្នេះ មិនចាត់ជាផរុសវាចាក៏មិនមែន វាចានោះជាផរុសវាចាដោយពិត ព្រោះមាន

ចិត្តគ្រោតគ្រាត ។ ផរុសវាចានោះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គលនោះមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះបុគ្គលនោះ មានគុណច្រើន ។ ផរុសវាចានោះ មានអង្គ ៣ គឺ **អក្កោសិតព្វោ បរោ** មានជនដទៃដែលខ្លួនគប្បីជេរ ១ **កុបិតចិត្តំ** មានចិត្តខឹងក្រោធ ១ **អក្កោសនា** បានជេរ ១ ។

អកុសលចេតនា ដែលជាហេតុឲ្យបុគ្គលដទៃ ដឹងវត្ថុដែលមិនមែនជាប្រយោជន៍ ដែលធ្វើសេចក្តីព្យាយាមផ្លូវកាយ និងវាចាឲ្យតាំងឡើង ឈ្មោះថា **សម្ផប្បលាបៈ** ។ សម្ផប្បលាបៈនោះ ឈ្មោះថា មានទោសតិច ព្រោះមានការសេពតិច ឈ្មោះថា មានទោសច្រើន ព្រោះមានការសេពច្រើន ។ សម្ផប្បលាបៈនោះ មានអង្គ ២ គឺ **ភារតយុទ្ធសីតាហរណាទិនិរត្ថកកថាបុរេក្ខារតា** ភាពជាអ្នកមានចេតនានិយាយរឿងឥតប្រយោជន៍ មានការតយុទ្ធ និងការលួចនាងសីតាទៅជាដើម ១ **តថារូបីកថាកថនំ** បានពោលវាចាបែបនោះ ១ ។

កាលបុគ្គលដទៃមិនកាន់យកពាក្យនោះ កម្មបថក៏មិនដាច់ កាលមានជនដទៃកាន់យក សម្ផប្បលាបៈនុ៎ះឯង ទើបកម្មបថដាច់ ។

ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា សម្លឹងរំពៃ អធិប្បាយថា ធម្មជាតបែរមុខចំពោះទ្រព្យអ្នកដទៃប្រព្រឹត្តទៅ ភាពជាធម្មជាតបង្អោនទៅកាន់សម្បត្តិរបស់អ្នកដទៃនោះ ។ អភិជ្ឈានោះ មានការសម្លឹងរំពៃតណ្ហៈរបស់បុគ្គលដទៃជាលក្ខណៈយ៉ាងនេះថា ឱហ្ន៎ ទ្រព្យនេះគប្បីជារបស់អញ ។ ឈ្មោះថា

មានទោសតិច និងទោសច្រើន ដូចអទិន្នាទាន ។ អភិជ្ឈានោះ មានអង្គ ២ គឺ **បរភណ្ឌំ** ទ្រព្យរបស់អ្នកដទៃ ១ **អត្តនោ បរិណាមនំ** បង្អោនមកដើម្បីខ្លួន ១ ។

មែនពិត កាលសេចក្ដីលោភដែលមានរបស់អ្នកដទៃជាទីតាំងកើតហើយ កម្មបថនៅមិនទាន់ដាច់ រហូតដល់បុគ្គលនោះបង្អោនមកដើម្បីខ្លួន ដោយគិតថា ឱហ្ន៎ វត្ថុនេះគប្បីជារបស់អញ ។

ឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ធ្វើ ញុំាងប្រយោជន៍ និងសេចក្ដីសុខឲ្យវិនាសទៅ ។ ព្យាបាទនោះ មានការប្រទូស្ត ដើម្បីឲ្យអ្នកដទៃវិនាសជាលក្ខណៈ មានទោសតិច និងមានទោសច្រើន ដូចផរុសវាចា ។ ព្យាបាទនោះ មានអង្គ ២ គឺ **បរសត្តោ** សត្វដទៃ ១ **តស្ស ច វិនាសចិន្តា** ការគិតដែលឲ្យសត្វនោះវិនាសទៅ ១ ។ មែនពិត កាលសេចក្ដីក្រោធមានសត្វដទៃជាទីតាំងកើតឡើងហើយ កម្មបថនៅមិនទាន់ដាច់ទៅដរាបដល់ចិត្តគិតឲ្យសត្វវិនាសថា ធ្វើដូចម្ដេចហ្ន៎ សត្វនេះ គប្បីដាច់សូន្យ គប្បីវិនាស ។

ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា យល់ឃើញខុសដោយការមិនកាន់យកតាមសេចក្ដីពិត ។ មិច្ឆាទិដ្ឋិនោះ មានការយល់ខុសជាលក្ខណៈ ដោយន័យជាដើមថា ទានដែលបុគ្គលឲ្យហើយមិនមានផល ។ ឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចសម្ផប្បលាបៈ ។ ម្យ៉ាងទៀត អនិយតមិច្ឆាទិដ្ឋិ មានទោសតិច និយតមិច្ឆាទិដ្ឋិ មានទោសច្រើន ។ មិច្ឆាទិដ្ឋិនោះ មានអង្គ ២ គឺ **វត្ថុនោ ច គហិតាការវិបរីតតា** រឿងវិបរិតដោយ

អាការដែលបុគ្គលកាន់យក ១ **យថា ច តំ គណ្ហាតិ តថាភាវេន តស្សុប្បដ្ឋានំ** សេចក្តីប្រាកដនៃរឿងនោះ ដោយសេចក្តីមិនពិតតាមដែលកាន់យក ១ ។ បណ្តាមិច្ឆាទិដ្ឋិទាំងនោះ កម្មបថរមែងដាច់ទៅ ព្រោះនត្ថិកទិដ្ឋិ អហេតុកទិដ្ឋិ និងអកិរិយទិដ្ឋិប៉ុណ្ណោះ កម្មបថ រមែងមិនដាច់ទៅ ព្រោះទិដ្ឋិដទៃៗ ។

គប្បីជ្រាបវិនិច្ឆ័យអកុសលកម្មបថទាំង ១០ នេះ ដោយអាការ ៥ គឺ **ធម្មតោ** ដោយធម៌ ១ **កោដ្ឋាសតោ** ដោយកោដ្ឋាសៈ ១ **អារម្មណតោ** ដោយអារម្មណ៍ ១ **វេទនាតោ** ដោយវេទនា ១ **មូលតោ** ដោយមូល ១ ។

បណ្តាអាការទាំង ៥ នោះ ពាក្យថា **ដោយធម៌** ក្នុងអកុសលកម្មបថទាំង ១០ នោះ អកុសលកម្មបថ ៧ តាមលំដាប់ ( គឺកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ) ជាធម៌ គឺចេតនានោះឯង អកុសលកម្មបថ ៣ មានអភិជ្ឈាជាដើម ជាធម៌ដែលសម្បយុត្តជាមួយនឹងចេតនា ។

ពាក្យថា **ដោយកោដ្ឋាស** អកុសលកម្មបថ ៨ គឺអកុសលកម្មបថ ៧ តាមលំដាប់ និងមិច្ឆាទិដ្ឋិ ១ ជាកម្មបថប៉ុណ្ណោះ មិនជាមូល ។ អភិជ្ឈា និងព្យាបាទជាកម្មបថផង ជាមូលផង ។ ពិតហើយ ពោលដោយមូល អភិជ្ឈាជាលោភៈ ជាអកុសលមូល ព្យាបាទជាទោសៈ ជាអកុសលមូល ។

ពាក្យថា **ដោយអារម្មណ៍** បាណាតិបាតមានសង្ខារជាអារម្មណ៍ ព្រោះមានជីវិតិន្ទ្រិយជាអារម្មណ៍ **អទិន្នាទាន** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ **មិច្ឆាចារ** មានសង្ខារជាអារម្មណ៍ ដោយអំណាចផោដ្ឋព្វៈ

អាចារ្យពួកខ្លះពោលថា មិច្ឆាចារមានសត្វជាអារម្មណ៍ ដូច្នេះក៏មាន **មុសា-វាទ** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ **បិសុណាវាចា** មានអារម្មណ៍ដូចមុសាវាទ **ផរុសវាចា** មានសត្វជាអារម្មណ៍ប៉ុណ្ណោះ **សម្ផប្ប-លាបៈ** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ដោយអំណាចធម៌ គឺ ទិដ្ឋៈ សុតៈ មុតៈ វិញ្ញាតៈ ។ **អភិជ្ឈា** ក៏ដូចគ្នា ។ **ព្យាបាទ** មានសត្វជាអារម្មណ៍ប៉ុណ្ណោះ **មិច្ឆាទិដ្ឋិ** មានសង្ខារជាអារម្មណ៍ប៉ុណ្ណោះដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

ពាក្យថា **ដោយវេទនា** បាណាតិបាតជាទុក្ខវេទនា ។ មែនពិត ព្រះរាជាទាំងឡាយឃើញចោរហើយ ទ្រង់សើចត្រាស់ថា ចូរពួកអ្នកទៅ ចូរសម្លាប់វាក៏ពិត ទោះបីជាដូច្នោះ ចេតនាដែលដល់នូវការសម្រេចព្រះហឫទ័យរបស់ព្រះរាជាទាំងនោះ ក៏ជាចេតនាសម្បយុត្តដោយទុក្ខវេទនាដោយពិត ។ អទិន្នាទានមានវេទនា ៣ មែនពិត អទិន្នាទាននោះ កាលបុគ្គលឃើញភណ្ឌៈរបស់អ្នកដទៃ រីករាយត្រេកអរកាន់យកក៏ជាសុខវេទនា កាលមានសេចក្ដីភ័យខ្លាចកាន់យក ក៏ជាទុក្ខវេទនា ឬកាលពិចារណាផលនៃអទិន្នាទានដែលត្រូវទទួល ក៏ជាទុក្ខវេទនាដូចគ្នា តែក្នុងវេលាដែលលួចទៅ តាំងនៅក្នុងភាវៈជាអ្នកព្រងើយ អទុក្ខមសុខវេទនាក៏កើតឡើង ។ មិច្ឆាចារ មានវេទនា ២ គឺសុខវេទនា និងអទុក្ខមសុខវេទនា តែក្នុងចិត្តដែលសម្រេចមិនជាឧបេក្ខា-វេទនា **មុសាវាទ** មានវេទនា ៣ ដោយន័យដែលពោលហើយក្នុងអទិន្នាទាននុ៎ះឯង **បិសុណាវាចា** ក៏មានវេទនា ៣ ដូចគ្នា **ផរុសវាចា** ជាទុក្ខវេទនា

**សម្ផប្បលាបៈ** មានវេទនា ៣ ពិតហើយ ក្នុងវេលាបុគ្គលត្រេកអររីករាយ កាលបុគ្គលដទៃកំពុងឲ្យសាធុការ កំពុងគ្រវីផ្ទាំងសំពត់ជាដើម ពោលរឿងមានរឿងលួចនាងសិតា និងរឿងចម្បាំងភារតៈជាដើម សម្ផប្បលាបៈនោះរមែងជាសុខវេទនា ។ កាលបុគ្គលម្នាក់ឲ្យថ្លៃឈ្នួលមុន តែក្នុងកាលខាងក្រោយពោលថា ចូរលោកនិយាយរឿងតាំងតែពីដើម ដូច្នេះ ក្នុងវេលាដែលកំពុងនិយាយរឿង ទោមនស្សកើតឡើង ដោយគិតថា យើងនឹងពោលបកិណ្ណកកថាឲ្យជាប់តគ្នា ឬក៏មិនពោលហ្ន៎ ដូច្នេះ រមែងជាទុក្ខវេទនា ។ កាលគេពោលកថាព្រងើយៗ រមែងជាអទុក្ខមសុខវេទនា **អភិជ្ឈា** មានវេទនា ២ គឺសុខវេទនា និងឧបេក្ខាវេទនា **មិច្ឆាទិដ្ឋិ** ក៏មានវេទនា ២ ដូចអភិជ្ឈា **ព្យាបាទ** ជាទុក្ខវេទនា ។

ពាក្យថា **ដោយមូល** គឺបាណាតិបាត មានមូល ២ គឺទោសមូល និងមោហមូល ។ **អទិន្នាទាន** ក៏មានមូល ២ គឺទោសមូល និងមោហមូល ឬលោភមូល និងមោហមូល **មិច្ឆាចារ** ក៏មានមូល ២ គឺលោភមូល និងមោហមូលទុ៎ះឯង **មុសាវាទ** មានមូល ២ គឺទោសមូល និងមោហមូល ឬលោភមូល និងមោហមូល **បិសុណាវាចា** និង**សម្ផប្បលាបៈ** ក៏មានមូល ២ ដូចគ្នា **ផរុសវាចា** មានមូល ២ គឺទោសមូល និងមោហមូល **អភិជ្ឈា** មានមូលមួយ គឺមោហមូល **ព្យាបាទ**ក៏មានមូលមួយដូចគ្នា **មិច្ឆាទិដ្ឋិ** មានមូល ២ គឺលោភមូល និងមោហមូលនោះឯង ។

អកុសលកម្មបថ ចប់

# កុសលកម្មបថ

ធម៌ទាំង ១០ យ៉ាងនេះ គឺការវៀរចាកបាណាតិបាតជាដើម ( មាន ៧ យ៉ាង ) អនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ឈ្មោះថា កុសលកម្មបថ ។

បណ្ដាកុសលកម្មបថទាំង ១០ នោះ បាណាតិបាតជាដើម មានសេចក្ដីដូចដែលពោលហើយនុ៎ះឯង ធម៌ដែលឈ្មោះថា **វិរតិ** ព្រោះអត្ថថា ជាហេតុវៀរចាកបាណាតិបាតជាដើម ឬជាធម្មជាតវៀរចាក ឬត្រឹមតែជាការវៀរប៉ុណ្ណោះ ។ វិរតិណាដែលសម្បយុត្តដោយកុសលចិត្តរបស់បុគ្គលដែលវៀរចាកបាណាតិបាត ដែលត្រាស់យ៉ាងនេះថា ការវៀរ ការចៀសវាងចាកបាណាតិបាត ក្នុងសម័យនោះឯណា ដូច្នេះជាដើម វិរតិនោះ មាន ៣ ប្រភេទ គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ។

បណ្ដាវិរតិ ៣ ប្រភេទនោះ វិរតិកាលកើតឡើងដល់បុគ្គលអ្នកមិនបានសមាទានសិក្ខាបទទាំងឡាយ ដែលពិចារណាដល់ជាតិ វ័យ និងការចេះដឹងជាដើមរបស់ខ្លួន ហើយមិនឈ្លានកន្លងវត្ថុដែលប្រាកដចំពោះមុខ ដោយគិតថា ការធ្វើបែបនេះ មិនសមគួរដល់ពួកយើង គប្បីជ្រាបថាជា ***សម្បត្តវិរតិ*** ។ ក្នុងសម្បត្តវិរតិនោះ មានរឿងនេះជាឧទាហរណ៍ ដូចវិរតិរបស់ឧបាសកឈ្មោះ **ចក្កនៈ** ក្នុងកោះសីហឡដូចតទៅ

បានឮថា រោគកើតឡើងដល់មាតារបស់ឧបាសកចក្កនៈនោះ ក្នុងវេលាដែលគាត់នៅក្មេងនោះឯង គ្រូពេទ្យប្រាប់ថា គួរបានសាច់ទន្សាយស្រស់លំដាប់នោះ ទើបបងប្រុសរបស់ឧបាសកចក្កនៈ បញ្ជូនឲ្យនាយចក្កនៈទៅដោយពាក្យថា ចក្កនៈ ចូរបាត្រាច់ទៅរកក្នុងស្រែ ចក្កនៈនោះក៏ទៅក្នុងទី

នោះ ។ ក្នុងសម័យនោះ មានទន្សាយមួយ មកដើម្បីស៊ីស្រូវខ្ចី ទន្សាយ ឃើញចក្កនៈនោះក៏ស្ទុះទៅដោយរហ័ស ត្រូវល្ហិតុំជាប់ ទើបបញ្ចេញសំឡេង កិរិ កិរិ ។ ចក្កនៈទៅតាមសំឡេងនោះ ចាប់ទន្សាយបានហើយគិតថា អញ នឹងផ្សំថ្នាំឲ្យមាតា ហើយគិតបន្តទៀតថា អញសម្លាប់សត្វដទៃ ព្រោះជីវិត មាតាជាហេតុ នេះមិនសមគួរដល់ពួកអញ បន្ទាប់អំពីនោះ ទើបលែងទន្សាយ ទៅដោយពោលថា ចូរឯងទៅស៊ីស្មៅ និងទឹកជាមួយទន្សាយទាំងឡាយក្នុង ព្រៃចុះ ។ កាលត្រូវបងប្រុសសួរថា នែប្អូន ឯងបានទន្សាយហើយឬ ទើប តំណាលរឿងទាំងអស់នោះ ។ លំដាប់នោះ ទើបត្រូវបងប្រុសជេរ នាយ ចក្កនៈនោះ ទៅកាន់សម្នាក់មាតា ហើយឈរពោលអធិដ្ឋានសច្ចៈជាដើមថា តាំងអំពីកើតមក ខ្ញុំមិនដែលស្គាល់ការក្លែងផ្តាច់បង់ជីវិតសត្វឡើយ រំពេច នោះ មាតារបស់ចក្កនៈ ក៏ជាសះស្បើយអំពីរោគ ។

វិរតិកាលកើតឡើង ដល់បុគ្គលអ្នកសមាទានសិក្ខាបទទាំងឡាយ ក្នុង វេលាសមាទានសិក្ខាបទនុ៎ះឯង និងក្នុងកាលតទៅ ទោះបីត្រូវលះបង់ជីវិត របស់ខ្លួនក៏មិនប្រព្រឹត្តកន្លងវត្ថុ គប្បីជ្រាបថា ជា **សមាទានវិរតិ** ។ ដូច វិរតិរបស់ឧបាសកដែលអាស្រ័យនៅត្រង់ភ្នំឈ្មោះថា **ឧត្តរវឌ្ឍមាន** ។

បានឮថា ឧបាសកនោះទទួលសិក្ខាបទទាំងឡាយ ក្នុងសម្នាក់របស់ព្រះ ថេរៈ បិង្គលពុទ្ធរក្ខិតៈ ដែលនៅក្នុងអម្ពរិយវិហារ ហើយទៅភ្ជួរស្រែ ។ គ្រា នោះ គោរបស់គាត់បាត់ទៅ គាត់តាមរកគោនោះ ទើបឡើងទៅលើភ្នំឈ្មោះ **ឧត្តរវឌ្ឍមាន** ពស់ធំបានរួតគាត់ ក្នុងពេលនោះគាត់គិតថា អញនឹងកាត់

ក្បាលពស់នោះ ដោយកាំបិតដ៏មុតនេះ ហើយគិតបន្តទៀតថា អញទទួលសិក្ខាបទទាំងឡាយក្នុងសម្នាក់គ្រូ ដែលគួរដល់ការសរសើរ ហើយទម្លាយ ( សិក្ខាបទ ) ចេញ ការណ៍នោះ មិនសមគួរដល់អាត្មាអញឡើយ ។ គាត់គិតយ៉ាងនេះ អស់វារៈ ៣ ដង ហើយសម្រេចចិត្តថា អញនឹងលះបង់ជីវិត អញមិនលះបង់សិក្ខាបទ ទើបបោះកាំបិតដ៏មុតដែលនៅលើស្មាទៅក្នុងព្រៃ រំពេចនោះឯង ពស់ធំក៏លែងគាត់ បានលូនចៀសចេញទៅហើយ ។

វិរតិដែលសម្បយុត្តដោយអរិយមគ្គ គប្បីជ្រាបថា ជា **សមុច្ឆេទវិរតិ** ។ ចាប់ផ្តើមអំពីសមុច្ឆេទវិរតិកើតឡើងហើយ សូម្បីចិត្តរបស់ព្រះអរិយបុគ្គលទាំងឡាយ ក៏មិនកើតឡើងថា អញនឹងសម្លាប់សត្វ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យកុសលកម្មបថទាំងនេះ ដោយអាការ ៥ យ៉ាង ដូចអកុសលកម្មបថ គឺដោយធម៌ ដោយកោដ្ឋាសៈ ដោយអារម្មណ៍ ដោយវេទនា និងដោយមូល ។

បណ្តាអាការទាំង ៥ នោះ **ដោយធម៌** ក្នុងកុសលកម្មបថទាំង ១០ នោះ កុសលកម្មបថ ៧ ដោយលំដាប់ ( កាយសុចរិត ៣ វចីសុចរិត ៤ ) ជាចេតនាផង ជាវិរតិផង កម្មបថ ៣ ខាងចុង ជាធម៌សម្បយុត្តដោយចេតនាប៉ុណ្ណោះ ។

**ដោយកោដ្ឋាសៈ** កុសលកម្មបថ ៧ តាមលំដាប់ ជាកម្មបថតែម្យ៉ាង មិនជាមូល ។ កុសលកម្មបថ ៣ ខាងចុង ជាកម្មបថផង ជាមូលផង ។ ពិតណាស់ ពោលដោយមូល អនភិជ្ឈាជាអលោភៈ ជាកុសលមូល អព្យាបាទ

ជាអទោសៈ ជាកុសលមូល សម្មាទិដ្ឋិជាអមោហៈ ជាកុសលមូល ។

**ដោយអារម្មណ៍** អារម្មណ៍ទាំងឡាយរបស់អកុសលកម្មបថ មានបាណាតិបាតជាដើមនុ៎ះឯង ក៏ជាអារម្មណ៍របស់កុសលកម្មទាំងនោះ ។ ពិតហើយ ការវៀរចាកវត្ថុដែលគប្បីប្រព្រឹត្តកន្លងនុ៎ះឯង ឈ្មោះថា **វេរមណី** ។ ដូចអរិយមគ្គ មាននិព្វានជាអារម្មណ៍ រមែងលះបង់កិលេសទាំងឡាយ យ៉ាងណា កម្មបថទាំងនេះ មានជីវិតិន្ទ្រិយជាដើមជាអារម្មណ៍ គប្បីជ្រាបថា រមែងលះភាពជាអ្នកទ្រុស្តសីលទាំងឡាយ មានបាណាតិបាតជាដើម យ៉ាងនោះ ។

**ដោយវេទនា** កុសលកម្មបថទាំងអស់ជាសុខវេទនា ឬឧបេក្ខាវេទនា ។ ពិតហើយ សម្ល័ងដល់កុសលហើយ ឈ្មោះថា ទុក្ខវេទនា រមែងមិនមាន ។

**ដោយមូល** កុសលកម្មបថ ៧ តាមលំដាប់របស់បុគ្គលដែលវៀរដោយចិត្ត ដែលជាញាណសម្បយុត្ត រមែងមានមូល ៣ គឺ**អលោភមូល អទោសមូល អមោហមូល** របស់បុគ្គលដែលវៀរដោយចិត្តមិនប្រកបដោយញាណ មានមូល ២ **អនភិជ្ឈា**របស់បុគ្គលដែលវៀរដោយចិត្ត ញាណសម្បយុត្តមានមូល ២ របស់បុគ្គលដែលវៀរដោយចិត្ត មិនប្រកបដោយញាណ មានមូល ១ ។ អលោភៈមិនជាមូលរបស់ខ្លួនឯង នឹងដល់ខ្លួនឯង ក្នុង**ព្យាបាទ**ក៏មាន ន័យនេះឯង **សម្មាទិដ្ឋិ** មានមូល ២ គឺអលោភមូល អទោសមូល ឈ្មោះថា **កុសលកម្មបថ** មាន ១០ នេះ ដោយប្រការដូច្នេះ ។

# ពោលដោយការប្រៀបធៀបកម្មបថ

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបការប្រៀបធៀបកម្មបថ ក្នុងទីនេះ ។ ពិតហើយ អសំវរៈដែលកើតឡើង ដោយអំណាចទ្វារនៃផស្សៈ ៥ រមែងជាមនោកម្ម ជាចំណែកអកុសលប៉ុណ្ណោះ ។ អសំវរៈដែលកើតឡើងដោយអំណាចទ្វារនៃមនោសម្ផស្ស រមែងជាកម្មសូម្បីទាំង ៣ យ៉ាង ។ ព្រោះថាអសំវរៈនោះ ទោះបីដល់ការកម្រើកក្នុងកាយទ្វារហើយ រមែងជាកាយកម្មខាងអកុសល ដល់នូវការកម្រើកក្នុងវចីទ្វារ ក៏ជាវចីកម្មខាងអកុសល មិនដល់នូវការកម្រើកក្នុងទ្វារទាំង ២ ក៏ជាមនោកម្មខាងអកុសល ។ អសំវរៈដែលកើតឡើងដោយអំណាចទ្វារនៃអសំវរៈ ៥ ជាមនោកម្មខាងអកុសលប៉ុណ្ណោះ ។ អសំវរៈដែលកើតឡើងដោយអំណាចទ្វារនៃអសំវរៈ ដែលមានការកម្រើកកាយ រមែងជាកាយកម្មខាងអកុសលប៉ុណ្ណោះ ។ អសំវរៈដែលកើតឡើងដោយអំណាចទ្វារនៃអសំវរៈផ្លូវវាចា រមែងជាវចីកម្មខាងអកុសលប៉ុណ្ណោះ ។ អសំវរៈដែលកើតឡើង ដោយអំណាចទ្វារនៃអសំវរៈផ្លូវចិត្ត រមែងជាមនោកម្មខាងអកុសលប៉ុណ្ណោះ ។ កាយទុច្ចរិត ៣ ជាកាយកម្មខាងអកុសលប៉ុណ្ណោះ ។ វចីទុច្ចរិត ៤ ក៏ជាវចីកម្មខាងអកុសលប៉ុណ្ណោះ ។ មនោទុច្ចរិត ៣ ក៏ជាមនោកម្មខាងអកុសលប៉ុណ្ណោះ ។

សូម្បីសំវរៈដែលកើតដោយអំណាចទ្វារនៃផស្សៈ ៥ ក៏ជាមនោកម្មខាងកុសលប៉ុណ្ណោះ ។ ចំណែកសំវរៈនេះ កើតឡើងដោយអំណាចទ្វារនៃមនោសម្ផស្ស ក៏ជាកម្មទាំង ៣ ដូចអសំវរៈ ។ សំវរៈសូម្បីកើតឡើងហើយដោយអំណាចទ្វារនៃសំវរៈ ៥ ក៏ជាមនោកម្មខាងកុសលប៉ុណ្ណោះ ។ សំវរៈ

ដែលកើតឡើងដោយអំណាចទ្វារនៃសំវរៈ ដែលមានការកម្រើកកាយ ក៏ជាកាយកម្មខាងកុសលប៉ុណ្ណោះ ។ សំវរៈដែលកើតឡើងដោយអំណាចទ្វារនៃសំវរៈផ្លូវវាចា ក៏ជាវចីកម្មខាងកុសលប៉ុណ្ណោះ ។ សំវរៈដែលកើតឡើងដោយអំណាចទ្វារនៃសំវរៈផ្លូវចិត្ត ក៏ជាមនោកម្ម ខាងកុសលប៉ុណ្ណោះ ។ កាយសុចរិត ៣ រមែងជាកាយកម្មខាងកុសលប៉ុណ្ណោះ ។ វចីសុចរិត ៤ រមែងជាវចីកម្មខាងកុសលប៉ុណ្ណោះ ។ មនោសុចរិត ៣ ក៏ជាមនោកម្មខាងកុសលដូចគ្នា ។

កាយកម្មខាងអកុសល រមែងមិនកើតឡើងដោយអំណាចទ្វារនៃសម្ផស្ស ៥ តែរមែងកើតឡើង ដោយអំណាចទ្វារនៃមនោសម្ផស្សប៉ុណ្ណោះ ។ វចីកម្មខាងអកុសលក៏ដូចគ្នា តែមនោកម្មខាងអកុសល រមែងកើតឡើងដោយអំណាចទ្វារនៃសម្ផស្ស ៦ នោះឯង ។ មនោកម្មនោះ ដល់នូវការកម្រើកក្នុងកាយ-ទ្វារ និងវចីទ្វារ ហើយក៏ជាកាយកម្ម និងវចីកម្មខាងអកុសល ។ មនោកម្មនោះ មិនដល់នូវការកម្រើកក្នុងកាយទ្វារ និងវចីទ្វារ ក៏ជាមនោកម្មខាងអកុ-សលប៉ុណ្ណោះ ។ ដូចកាយកម្មខាងអកុសល រមែងមិនកើតឡើងដោយអំណាចទ្វារនៃសម្ផស្ស ៥ យ៉ាងណា កាយកម្មខាងអកុសល ក៏រមែងមិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈ ៥ យ៉ាងនោះ រមែងកើតឡើងដោយអំណាចទ្វារនៃអសំវរៈដែលមានការកម្រើកកាយ និងដោយអំណាចទ្វារនៃអសំវរៈផ្លូវវាចា រមែងមិនកើតដោយអំណាចទ្វារនៃអសំវរៈផ្លូវចិត្ត ។ វចី-កម្មខាងអកុសល រមែងកើតឡើងដោយអំណាចទ្វារនៃអសំវរៈ ៥ រមែង

កើតឡើងដោយអំណាចទ្វារនៃអសំវរៈ ដែលមានការកម្រើកកាយ និងអសំវរៈផ្លូវវាចា រមែងមិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈផ្លូវចិត្ត ។ មនោកម្មខាងអកុសល រមែងកើតដោយអំណាចទ្វារនៃអសំវរៈ ៨ នុ៎ះឯងសូម្បីក្នុងកាយកម្មដែលជាចំណែកកុសលជាដើម ក៏ន័យនេះដូចគ្នា ។

ចំណែកសេចក្ដីផ្សេងគ្នាមានដូចតទៅនេះ

កាយកម្ម និងវចីកម្មខាងអកុសល រមែងមិនកើតឡើងដោយអំណាចទ្វារនៃអសំវរៈផ្លូវចិត្តយ៉ាងណា កាយកម្ម និងវចីកម្មខាងកុសល រមែងមិនកើតឡើងដោយអំណាចទ្វារនៃសំវរៈ តាមផ្លូវមនោទ្វារយ៉ាងនោះ ក៏មិនមែន ។ កាយកម្ម និងវចីកម្ម ខាងកុសលទាំងនេះ រមែងកើតក្នុងទ្វារនៃសំវរៈផ្លូវចិត្តដល់បុគ្គលដែលមិនញ៉ាំងចំណែកនៃកាយ និងវាចាឲ្យកម្រើក ទទួលសិក្ខាបទទាំងឡាយ ។ ដោយប្រការដូចពោលមកនេះ កុសលចិត្តដែលជាកាមាវចររមែងកើតឡើងក្នុងមនោទ្វារនោះ ដោយអំណាចទ្វារនៃកម្ម ៣ យ៉ាង រមែងមិនកើតឡើងដោយអំណាចទ្វារនៃវិញ្ញាណ ៥ ។ កុសលចិត្តដែលជាកាមា-វចរ រមែងកើតឡើងដោយអំណាចទ្វារនៃសម្ផស្សតែមួយ ដោយន័យនេះថាការសោយអារម្មណ៍ជាសុខ ជាទុក្ខ ឬអទុក្ខមសុខនេះឯណា រមែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ រមែងមិនកើតឡើង ដោយអំណាចទ្វារនៃអសំវរៈ ៨ រមែងកើតឡើងដោយអំណាចទ្វារនៃសំវរៈ ៨ រមែងមិនកើតឡើងដោយអំណាចនៃអកុសលកម្មបថ ១០ រមែងកើតឡើងដោយអំណាចនៃកុសលកម្មបថ ១០ ។ ព្រោះហេតុនោះ កុសលចិត្តនេះ រមែងកើតឡើង

ដោយអំណាចទ្វារនៃកម្ម ៣ យ៉ាង ឬដោយអំណាចទ្វារនៃសម្ផស្ស ៦ ឬដោយអំណាចទ្វារនៃសំវរៈ ៨ ឬដោយអំណាចនៃកុសលកម្មបថ ១០ ។ កាលត្រាស់ពាក្យថា កាមាវចរកុសលចិត្ត ។បេ។ មានរូបជាអារម្មណ៍ ។បេ។ មានធម៌ជាអារម្មណ៍ ។បេ។ កើតឡើងដូច្នេះ កាមាវចរកុសលចិត្តទាំងអស់ក៏ឈ្មោះថា ត្រាស់ហើយដែរ ។

ពោលដោយការប្រៀបធៀបកម្មបថ ចប់

ទ្វារកថា ចប់

គប្បីជ្រាបការប្រកបសេចក្ដីអធិប្បាយ ក្នុងព្រះបាលីថា **យំ យំ វា បនារព្ភ** នេះ ដូចតទៅ បណ្ដារូបារម្មណ៍ជាដើម តាមដែលពោលហើយខាងដើម ប្រារព្ធរូបជាអារម្មណ៍ អធិប្បាយថា ធ្វើរូបឲ្យជាអារម្មណ៍ ឬប្រារព្ធសំឡេងជាអារម្មណ៍ ។បេ។ ឬប្រារព្ធធម៌ជាអារម្មណ៍កើតឡើង ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ រមែងដូចទ្រង់ទទួលអារម្មណ៍ណាមួយត្រឹមតែអារម្មណ៍មួយប៉ុណ្ណោះ ។ ក្នុងអារម្មណ៍ទាំងនេះរបស់ចិត្តនេះ ចិត្តនេះក្នុងសម័យមួយ ប្រារព្ធរូបារម្មណ៍របស់បុគ្គលម្នាក់កើតឡើងហើយ ឬក្នុងសម័យដទៃទៀត ប្រារព្ធអារម្មណ៍ដទៃក្នុងសំឡេងជាដើម របស់បុគ្គលដទៃ រមែងកើតឡើងនោះឯង ។ មួយទៀត កាលចិត្តនេះកើតឡើងយ៉ាងនេះ ក៏មិនមានលំដាប់នេះថា មានការប្រារព្ធរូបារម្មណ៍មុនក្នុងភពមួយ ប្រព្រឹត្តទៅហើយទើបប្រារព្ធសទ្ទារម្មណ៍ក្នុងកាលខាងក្រោយ ។ បណ្ដាអារម្មណ៍ មានរូបជា

ដើម សូម្បីកំណត់នេះថា មានពណ៌ខៀវជាអារម្មណ៍មុនហើយ មានពណ៌លឿងជាអារម្មណ៍ក្នុងកាលខាងក្រោយដូច្នេះ ក៏មិនមាន ។ ព្រោះហេតុនោះ ដើម្បីសម្តែងចិត្តមានអារម្មណ៍គ្រប់យ៉ាងនេះ និងការមិនមានលំដាប់ សូម្បីក្នុងការមិនមានលំដាប់ ក៏គង់មិនមានការកំណត់អារម្មណ៍ មានពណ៌ខៀវ និងពណ៌លឿងជាដើម ទើបត្រាស់ពាក្យថា **យំ យំ វា បនារព្ភ** ។ ពាក្យនេះ លោកអធិប្បាយថា បណ្តាអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមទាំងនេះ មិនមែនមានអារម្មណ៍ឯណានីមួយ ត្រឹមតែអារម្មណ៍មួយប៉ុណ្ណោះទេ ដែលពិតហើយ ប្រារព្ធអារម្មណ៍ណាមួយកើតឡើងក៏បាន ។ ចិត្តនោះកាលកើតឡើងយ៉ាងនេះ ក៏មិនកើតឡើងយ៉ាងនេះថា ប្រារព្ធរូបជាអារម្មណ៍សិន ខាងក្រោយសឹមប្រារព្ធសំឡេងជាអារម្មណ៍ តែប្រារព្ធអារម្មណ៍ណាមួយក៏បាន កើតឡើង ។ អធិប្បាយថា ធ្វើអារម្មណ៍ណាក៏ដោយ បណ្តារូបារម្មណ៍ជាដើម កើតឡើងដោយបដិលោម ឬដោយអនុលោម ឬដោយន័យមានអារម្មណ៍មួយចន្លោះ ឬពីរចន្លោះជាដើម ។ ក្នុងរូបារម្មណ៍ទាំងឡាយ ក៏មិនកើតដោយកំណត់នេះថា ចិត្តមានពណ៌ខៀវជាអារម្មណ៍មុន ខាងក្រោយសឹមមានពណ៌លឿងជាអារម្មណ៍ តែប្រារព្ធអារម្មណ៍ណាមួយក៏បាន អធិប្បាយថា ចិត្តប្រារព្ធរូបារម្មណ៍យ៉ាងណានីមួយ បណ្តារូបារម្មណ៍ទាំងឡាយ មានពណ៌ខៀវ និងពណ៌លឿងជាដើម កើតឡើង ។ សូម្បីក្នុងសទ្ទារម្មណ៍ជាដើម ក៏ន័យនេះឯង នេះជាការប្រកបសេចក្តីអធិប្បាយមួយបែប ។

នៅមានការប្រកបសេចក្តីអធិប្បាយដទៃទៀតដូចតទៅ

រូបជាអារម្មណ៍របស់ចិត្តនេះមាន ព្រោះហេតុនោះ ទើបចិត្តនេះ ឈ្មោះថា **មានរូបជាអារម្មណ៍** ។បេ។ ធម៌ជាអារម្មណ៍របស់ចិត្តនេះមាន ព្រោះហេតុនោះ ទើបចិត្តនេះ ឈ្មោះថា **មានធម៌ជាអារម្មណ៍** ។ ព្រះមានព្រះភាគត្រាស់ថា ចិត្តមានរូបជាអារម្មណ៍ ។បេ។ ឬមានធម្មារម្មណ៍កើតឡើងដោយប្រការដូច្នេះហើយ ទើបត្រាស់ទៀតថា ឬថា ប្រារព្ធតែអារម្មណ៍ណាមួយហើយកើតឡើង ដូច្នេះ សេចក្តីនៃព្រះតម្រាស់ដែលត្រាស់នោះ គប្បីជ្រាបថា ចិត្តប្រារព្ធអារម្មណ៍ឯណាមួយកើតឡើង ដោយន័យដែលពោលហើយខាងដើមក្នុងរូបជាដើមទាំងនេះ ។ ចំណែកក្នុងមហាអដ្ឋកថា មានសេចក្តីពោលត្រឹមប៉ុណ្ណេះថា ពាក្យថា ប្រារព្ធតែអារម្មណ៍ណាមួយ ហើយកើតឡើងនេះ ព្រះពុទ្ធអង្គត្រាស់ដើម្បីនឹងត្រាស់ថា មិនមានអ្វីថ្មីក្នុងយេវាបទកន័យ ( ក្នុងចំណែកដែលប្រៀបគ្នាបាន ) ទ្រង់កាន់យកពាក្យដែលទ្រង់កាន់យកហើយខាងដើមនោះឯង ហើយត្រាស់ថា ប្រារព្ធរូប ។បេ។ ឬប្រារព្ធធម៌ ឬប្រារព្ធអារម្មណ៍នេះ ឬអារម្មណ៍នោះ ដូច្នេះ ។

# ធម្មុទ្ទេសវារ

## អធិប្បាយ ពួក ៩ មានផស្សៈជាដើម

ពាក្យថា **តស្មឹ សមយេ** នេះ ជាពាក្យបដិនិទ្ទេស ( គឺការត្រឡប់មក អធិប្បាយម្តងទៀត ) ដោយកំណត់សម័យ ដែលទ្រង់លើកឡើងសម្តែង ដោយមិនពិតប្រាកដ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបសេចក្តីនៃពាក្យថា **តស្មឹ សមយេ** នោះថា កាមាវចរកុសលចិត្ត កើតឡើងក្នុងសម័យណា ផស្សៈ ។បេ។ អវិក្ខេបៈ ក៏កើតឡើងក្នុងសម័យនោះឯង ។

ក្នុងពាក្យនោះ គប្បីជ្រាបថា ចិត្តរមែងកើតដោយប្រការណា ក្នុងធម៌ទាំងឡាយ មានផស្សៈជាដើម ផស្សៈរមែងកើតដោយប្រការនោះ ។ សេចក្តីនេះដូចម្តេច គប្បីធ្វើការប្រកបពាក្យអធិប្បាយ ដោយអំណាចនៃពាក្យតាមតែនឹងបាន ដោយន័យជាដើមថា រមែងជាកាមាវចរ ជាកុសល ជាធម៌កើតឡើង ជាធម៌សហគតៈដោយសោមនស្ស ។ ព្រោះថា ពាក្យថា ជាធម៌សហគតៈដោយសោមនស្ស រមែងមិនបានក្នុងវេទនា និងពាក្យថាជាធម៌សហគតៈដោយញាណ រមែងមិនបានក្នុងបញ្ញិន្ទ្រិយ ព្រោះហេតុនោះ ទើបពោលថា ដោយអំណាចនៃពាក្យតាមតែនឹងបាន ។ ពាក្យដែលពោលមកនេះ ជាមតិរបស់អាចារ្យទាំងឡាយ ដែលផុតចាកអដ្ឋកថា ពាក្យដែលពោលនេះ មិនគួរឃើញជាសារៈ ។

សួរថា ព្រោះហេតុអ្វី ក្នុងពាក្យថា **ផស្សោ ហោតិ** ជាដើមនេះ ទើបព្រះមានព្រះភាគត្រាស់ផស្សៈមុន ។ ឆ្លើយថា ព្រោះជាការប្រជុំរួមគ្នានៃ

ចិត្តជាគ្រាដំបូង ។ ពិតហើយ ផស្សៈជាធម៌ញុំាងចិត្តឲ្យធ្លាក់ទៅមុន ក្នុងអារម្មណ៍ ពាល់ត្រូវអារម្មណ៍កើតឡើង ព្រោះហេតុនោះ ទើបត្រាស់ផស្សៈមុន ចិត្តពាល់ត្រូវអារម្មណ៍ដោយផស្សៈ សោយអារម្មណ៍ដោយវេទនា ចាំអារម្មណ៍បានដោយសញ្ញា រមែងគិតដោយចេតនា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលអារម្មណ៍ ( ផស្សៈ ) ពាល់ត្រូវហើយ រមែងដឹងច្បាស់ ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងគិត ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងចាំបាន ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា ផស្សៈនេះ ជាបច្ច័យដែលមានកម្លាំងរបស់សម្បយុត្តធម៌ដែលកើតព្រមគ្នា ដូចនិយាយដល់ប្រាសាទ ឈ្មោះថា សសរជាបច្ច័យសំខាន់ របស់ទព្វសម្ភារដ៏សេស ។ ធ្នឹម ដែរណែង មេដញ្ជាំងកំពូល បន្ទង់ ហោជាង ផ្ទោង ផ្ទាន ជាវត្ថុជាប់ទាក់ទងដោយសសរ តាំងនៅលើសសរ ។ ពិតហើយ ផស្សៈនេះ ដូចជាសសរ សម្បយុត្តធម៌ដែលកើតព្រមគ្នាដ៏សេស ដូចគ្នានឹងទព្វសម្ភារ ព្រោះហេតុនោះ ទើបត្រាស់ផស្សៈមុន តែសេចក្តីដែលពោលហើយនេះ មិនមែនជាហេតុ ព្រោះថាធម៌នេះ មិនបានដើម្បីនឹងពោលថា បណ្តាធម៌ដែលកើតឡើងក្នុងចិត្តមួយដួងសម្បយុត្តធម៌នេះកើតមុន សម្បយុត្តធម៌នេះកើតក្រោយ ដូច្នេះ ទាំងហេតុរបស់ផស្សៈ សូម្បីក្នុងភាពជាបច្ច័យដែលមានកម្លាំងក៏មិនប្រាកដ ។ ព្រះមានព្រះភាគត្រាស់ផស្សៈមុន ដោយវារៈនៃទេសនាប៉ុណ្ណោះ ។ តាមការពិត សូម្បីនឹងនាំមកពោលថា វេទនារមែងកើតឡើង ផស្សៈរមែងកើត

ឡើង សញ្ញារមែងកើតឡើង ផស្សៈរមែងកើតឡើង ចេតនារមែងកើតឡើង ផស្សៈរមែងកើតឡើង ចិត្តរមែងកើតឡើង ផស្សៈរមែងកើតឡើង វេទនារមែងកើតឡើង សញ្ញារមែងកើតឡើង ចេតនារមែងកើតឡើង វិតក្ករមែងកើតឡើងដូច្នេះ ក៏គួរ ។ ផស្សៈនុ៎ះឯង គប្បីជ្រាបថា ត្រាស់មុនគេ ដោយវារៈនៃទេសនា ។ មួយទៀត ក្នុងផស្សៈនេះ យ៉ាងណា សូម្បីក្នុងធម៌ដ៏សេសក្រៅនេះ ក៏មិនគួរស្វែងរកលំដាប់មុន ក៏យ៉ាងនោះ តែគប្បីស្វែងរកធម៌ទាំងឡាយ មានវចនត្ថៈ លក្ខណៈ កិច្ចជាដើមប៉ុណ្ណោះដូចតទៅ គឺ

ធម៌ដែលឈ្មោះថា ផស្សៈ ព្រោះអត្ថថា ប៉ះខ្ទប់អារម្មណ៍ ។ ផស្សៈនោះ មានលក្ខណាទិចតុក្កៈដូច្នេះ

**ផុសនលក្ខណោ** មានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ **សំឃដនរសោ** មានការផ្សារភ្ជាប់ជាកិច្ច **សន្និបាតបច្ចុប្បដ្ឋានោ** មានការប្រជុំព្រមគ្នាជាអាការប្រាកដ **អាបាថគតវិសយបទដ្ឋានោ** មានអារម្មណ៍មកកាន់គន្លងជាហេតុជិត ។

ពិតហើយ ផស្សៈនេះ ទោះបីជានាមធម៌ ក៏ប្រព្រឹត្តទៅដោយអាការពាល់ត្រូវអារម្មណ៍នោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា មានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ ។ ផស្សៈនេះ មិនជាប់ជាមួយអ្វីសូម្បីតែមួយ ដូចរូប ( ពណ៌ ) មិនជាប់ជាមួយចក្ខុ សំឡេងមិនជាប់ជាមួយសោតៈ តែក៏ផ្សារភ្ជាប់ចិត្តនឹងអារម្មណ៍ ព្រោះហេតុនោះ ទើបឈ្មោះថា មានការផ្សារភ្ជាប់ជាកិច្ច ។ ម្យ៉ាងទៀត គប្បីជ្រាបថា មានការផ្សារភ្ជាប់ជាកិច្ច ដោយកិច្ចមានការដល់

ព្រមជាអត្ថ ព្រោះផស្សៈកើតដោយផ្សារភ្ជាប់វត្ថុ និងអារម្មណ៍ សមដូចពាក្យដែលព្រះអដ្ឋកថាចារ្យ ពោលថា ផស្សៈដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានលក្ខណៈមិនប៉ះខ្ទប់អារម្មណ៍មិនមាន ។ ផស្សៈដែលមានការផ្សារភ្ជាប់ជាកិច្ច រមែងប្រព្រឹត្តទៅតាមបញ្ចទ្វារប៉ុណ្ណោះ ។ ពិតហើយ ពាក្យថា មានការប៉ះខ្ទប់អារម្មណ៍ ជាលក្ខណៈក្តី មានការផ្សារភ្ជាប់ជាកិច្ចក្តី ជាឈ្មោះរបស់ផស្សៈដែលប្រព្រឹត្តទៅតាមបញ្ចទ្វារ ។ ពាក្យថា មានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ ជាឈ្មោះរបស់ផស្សៈ ដែលប្រព្រឹត្តទៅតាមមនោទ្វារប៉ុណ្ណោះ តែពាក្យថា មានការផ្សារភ្ជាប់ជាកិច្ច មិនបានជាឈ្មោះរបស់ផស្សៈដែលប្រព្រឹត្តទៅតាមមនោទ្វារទេ ។ កាលលោកពោលពាក្យនេះ ហើយបាននាំសូត្រនេះ ( មិលិន្ទបញ្ហា ) មកអាងថា បពិត្រមហារាជ ពពែពីរក្បាលជល់គ្នា គប្បីឃើញចក្ខុដូចពពែទីមួយ គប្បីឃើញរូបដូចពពែទីពីរ គប្បីឃើញផស្សៈដូចការជល់គ្នារបស់ពពែពីរក្បាលនោះ ផស្សៈមានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ និងមានការផ្សារភ្ជាប់គ្នាជាកិច្ច ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត បពិត្រមហារាជ ដូចបាតដៃទាំងគូប៉ះខ្ទប់គ្នា ។បេ។ បាតដៃទាំងពីរប៉ះខ្ទប់គ្នា គឺគប្បីឃើញចក្ខុដូចបាតដៃទីមួយ គប្បីឃើញរូបដូចបាតដៃទីពីរ គប្បីឃើញផស្សៈ ដូចការប៉ះគ្នារបស់បាតដៃទាំងពីរនោះ ផស្សៈមានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ និងមានការផ្សារភ្ជាប់គ្នាជាកិច្ច ដោយប្រការដូច្នេះ ។ បណ្ឌិតគប្បីធ្វើឲ្យពិស្តារ ។

ម្យ៉ាងទៀត ត្រាស់ធម៌មានចក្ខុវិញ្ញាណជាដើម ដោយឈ្មោះថា ចក្ខុជា

ដើម ក្នុងពាក្យជាដើមថា **ចក្ខុនា រូបំ ទិស្វា** ឃើញរូបដោយចក្ខុហើយ យ៉ាងណា សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបថា ចក្ខុវិញ្ញាណជាដើមទាំងនោះត្រាស់ដោយឈ្មោះចក្ខុជាដើម យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ក្នុងពាក្យជាដើមថា គប្បីឃើញចក្ខុដូចពពែមួយ គប្បីឃើញអត្ថដោយន័យនេះថា គប្បីឃើញចក្ខុវិញ្ញាណដូចពពែមួយ ។ កាលបើដូច្នេះ ក្នុងសូត្រនេះ ព្រោះការផ្សារភ្ជាប់ចិត្តនឹងអារម្មណ៍ ទើបផស្សៈសម្រេចថា មានការផ្សារភ្ជាប់ជាកិច្ចដោយ កិច្ចដែលមានកិច្ចជាអត្ថនោះឯង ។

ផស្សៈនោះ ឈ្មោះថា មានការប្រជុំព្រមគ្នាជាអាការប្រាកដ ព្រោះសម្តែងឲ្យដឹងដោយអំណាចនៃការធ្វើរបស់ខ្លួន ពោល គឺការប្រជុំព្រមគ្នារបស់ធម៌ ៣ ( អារម្មណ៍ វត្ថុ វិញ្ញាណ ) ។ ពិតហើយ ផស្សៈនេះ ប្រកាសឲ្យដឹងដោយអំណាចនៃការធ្វើ ក្នុងទីនោះៗ យ៉ាងនេះថា ឈ្មោះថា **ផស្សៈ** ព្រោះមានការប្រជុំសភាវធម៌ ៣ យ៉ាង ព្រោះហេតុនោះ គប្បីជ្រាបអត្ថនៃបទព្រះសូត្រនេះថា ឈ្មោះថា **ផស្សៈ** ព្រោះមានការប្រជុំនៃសភាវធម៌ ៣ ដូច្នេះ មិនមែនឈ្មោះថា ផស្សៈត្រឹមតែជាការប្រជុំប៉ុណ្ណោះទេ ។

ផស្សៈ រមែងប្រាកដដោយអាការនោះឯង ព្រោះប្រកាសឲ្យដឹងយ៉ាងនេះ ព្រោះហេតុនោះ ទើបពោលថា មានការប្រជុំព្រមគ្នាជាអាការប្រាកដ ។ មួយទៀត ផស្សៈនោះ ឈ្មោះថា មានវេទនាជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ជាផល គឺ ប្រាកដ ។ ពិតហើយ ផស្សៈនេះ រមែងញ៉ាំងវេទនាឲ្យប្រាកដ គឺរមែងឲ្យកើតឡើង ។ មួយទៀត ផស្សៈនេះ កាលឲ្យវេទនាកើតឡើង

គប្បីជ្រាបថា សូម្បីមានបច្ច័យដទៃ ពោល គឺវត្ថុ និងអារម្មណ៍ តែក៏ធ្វើឲ្យវេទនាកើតឡើងចំពោះក្នុងចិត្ត ដែលជាទីអាស្រ័យរបស់ខ្លួនប៉ុណ្ណោះ ព្រោះខ្លួនអាស្រ័យចិត្ត មិនធ្វើឲ្យកើតវេទនាក្នុងវត្ថុ ឬក្នុងអារម្មណ៍ សូម្បីជាបច្ច័យរបស់ខ្លួន ដូចកម្តៅដែលអាស្រ័យនៅក្នុងជាតុ គឺអាចម៍ល័ក្ត រមែងធ្វើឲ្យកើតការទន់ក្នុងល័ក្ត ជាទីអាស្រ័យរបស់ខ្លួន ព្រោះកម្តៅខាងក្រៅជាបច្ច័យតែមិនធ្វើឲ្យកើតការទន់ក្នុងការក្តៅ ពោល គឺរងើកដែលប្រាសចាកអណ្តាតភ្លើងក្នុងខាងក្រៅ សូម្បីជាបច្ច័យរបស់ខ្លួន ។ ផស្សៈនេះ លោកហៅថាមានអារម្មណ៍ដែលមកកាន់គន្លងជាហេតុជិត ព្រោះការកើតឡើងនៃផស្សៈមិនមានការទើសទាក់ក្នុងអារម្មណ៍ ដែលប្រមូលមកដើម្បីការកើតនៃផស្សៈនោះឯង ដែលឥន្ទ្រិយតាក់តែងហើយ ដូច្នេះ ។

ធម៌ដែលឈ្មោះថា **វេទនា** ព្រោះអត្ថថា សោយអារម្មណ៍ វេទនានោះមានលក្ខណាទិចតុក្កៈដូច្នេះ

**វេទយិតលក្ខណា** មានការទទួលដឹងអារម្មណ៍ជាលក្ខណៈ **អនុភវនរសា** មានការសោយអារម្មណ៍ជាកិច្ច ឬ **ឥដ្ឋាការសម្ភោគរសា** មានការសោយអាការដែលគាប់ចិត្តជាកិច្ច **ចេតសិកអស្សាទបច្ចុប្បដ្ឋានា** មានការត្រេកអរផ្លូវចិត្តជាអាការប្រាកដ **បស្សទ្ធិបទដ្ឋានា** មានការស្ងប់ជាហេតុជិត ។

ពិតហើយ វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មិនទទួលដឹងអារម្មណ៍ជាលក្ខណៈ រមែងមិនមាន តែលោកពោលថា វេទនា មានការ

សោយនូវអារម្មណ៍ជាកិច្ច រមែងបានចំពោះក្នុងសុខវេទនាប៉ុណ្ណោះ ហើយត្រឡប់បដិសេធវាទៈនោះទៀត ហើយសម្តែងសេចក្តីនេះថា សុខវេទនាក្តី ទុក្ខវេទនាក្តី ឧបេក្ខាវេទនាក្តី ទាំងអស់ មានការសោយអារម្មណ៍ជាកិច្ច ។ ពិតហើយ និយាយដល់ឋានៈនៃការសោយអារម្មណ៍ជាកិច្ចហើយ សម្បយុត្តធម៌ដ៏សេស រមែងសោយអារម្មណ៍ត្រឹមចំណែកខ្លះ គឺផស្សៈ ក៏មានត្រឹមតែការប៉ះខ្ទប់អារម្មណ៍ប៉ុណ្ណោះ សញ្ញាមានត្រឹមតែការចាំអារម្មណ៍ប៉ុណ្ណោះ ចេតនាមានត្រឹមតែការតាំងចិត្តប៉ុណ្ណោះ វិញ្ញាណត្រឹមតែមានការដឹងច្បាស់នូវអារម្មណ៍ប៉ុណ្ណោះ តែវេទនាប៉ុណ្ណោះ រមែងសោយរសនៃអារម្មណ៍ដោយចំណែកមួយ ដោយភាពជាម្ចាស់ ព្រោះភាពជាធំ ភាពជាអ្នកសមគួរ ពិតណាស់ វេទនាប្រៀបដូចព្រះរាជា ធម៌ដ៏សេសដូចអ្នកពិសេស អ្នកពិសេសញ៉ាំងភោជនមានរសដ៏ឆ្ងាញ់ផ្សេងៗ ឲ្យរៀបរយ ហើយដាក់ស្នុកប្រថាប់ត្រា លើកយកទៅដាក់ក្នុងសម្នាក់ព្រះរាជា ទម្លាយត្រាហើយបើកស្នុក ហើយដួសយកចំណែកខាងលើនៃសម្លទាំងអស់ ដាក់ភាជនៈដើម្បីភ្លក្សមើលថា មានទោស ឬមិនមានទោស បន្ទាប់មក ក៏បង្អោនភោជនមានរសផ្សេងៗ ទៅថ្វាយព្រះរាជា ព្រះរាជាប៉ុណ្ណោះទ្រង់ជាម្ចាស់ សោយបានតាមប្រាថ្នា ព្រោះទ្រង់ជាធំ និងព្រោះទ្រង់ជាអ្នកសមគួរ ។ ធម៌ក្រៅអំពីនោះ សោយរសអារម្មណ៍បានចំណែកខ្លះ ដូចអ្នកពិសេស បានត្រឹមតែភ្លក្សព្រះក្រយាចំណែកខ្លះប៉ុណ្ណោះ ពិតហើយ ធម៌ដ៏សេស រមែងសោយរសអារម្មណ៍ បានត្រឹមចំណែកខ្លះប៉ុណ្ណោះ ដូចអ្នកពិសេសភ្លក្សភត្តត្រឹមតែចំណែកខ្លះប៉ុណ្ណោះ ។ វេទនា រមែង

សោយរសនៃអារម្មណ៍ដោយភាពជាម្ចាស់ ព្រោះភាពជាធំ ព្រោះភាពជាអ្នកសមត្ថ ដូចព្រះរាជាទ្រង់ជាម្ចាស់ រមែងសោយបានតាមគាប់ព្រះហឫទ័យ ព្រោះទ្រង់ជាធំ ជាអ្នកសមត្ថ ព្រោះហេតុនោះ ទើបលោកពោលថា វេទនាមានការសោយអារម្មណ៍ជាកិច្ច ។

ក្នុងការកំណត់អត្ថទីពីរ វេទនាដែលលោកបំណាងយកក្នុងទីនេះ លោកពោលថា វេទនាមានការសោយអាការដែលគួរប្រាថ្នាជាកិច្ច ព្រោះអត្ថថា សោយរសនៃអារម្មណ៍ មានអាការគួរប្រាថ្នាតាមដែលបានជួប វេទនានេះកាលពោលដោយការគាប់ចិត្ត លោកពោលថា មានសេចក្តីពេញចិត្តផ្លូវចិត្តជាអាការប្រាកដ សំដៅដល់ការប្រាកដដោយសភាវៈរបស់ខ្លួននោះឯង ព្រោះបុគ្គលអ្នកមានកាយស្ងប់ហើយ រមែងសោយសេចក្តីសុខ ហេតុនោះគប្បីជ្រាបថា វេទនា មានសេចក្តីស្ងប់ជាហេតុជិត ដូច្នេះ ។

ធម៌ដែលឈ្មោះថា **សញ្ញា** ព្រោះអត្ថថា ចាំអារម្មណ៍ មានពណ៌ខៀវជាដើម សញ្ញានោះ មានលក្ខណាទិចតុក្កៈដូច្នេះ

**សញ្ជាននលក្ខណា** មានការចាំបានជាលក្ខណៈ **បច្ចាភិញ្ញាណរសា** មានការធ្វើគ្រឿងចំណាំជាកិច្ច ។

ពិតហើយ សញ្ញាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានការចាំមិនបានជាលក្ខណៈមិនមាន ។ សញ្ញាទាំងអស់ មានការចាំជាលក្ខណៈនោះឯង ។ ក្នុងទីនេះ សញ្ញាណាចាំបានដោយគ្រឿងចំណាំ សញ្ញានោះ ឈ្មោះថា មានការធ្វើគ្រឿងចំណាំជាកិច្ច ។

គប្បីជ្រាបការប្រព្រឹត្តិទៅនៃសញ្ញានោះ ក្នុងវេលាដែលជាងឈើធ្វើគ្រឿងចំណាំត្រង់ឈើ ហើយចាំគ្រឿងចំណាំនោះ ដោយគ្រឿងចំណាំនោះទៀត ក្នុងវេលាកំណត់គ្រឿងចំណាំ ដោយប្រជ្រុយជាដើមរបស់បុរស ហើយចាំគ្រឿងចំណាំរបស់បុគ្គលនោះទៀតថា បុគ្គលនេះ ឈ្មោះនោះ ដោយគ្រឿងចំណាំនោះ ក្នុងវេលាដែលនាយឃ្លាំងអ្នករក្សាគ្រឿងប្រដាប់ព្រះរាជា ចងផ្លាកសញ្ញាឈ្មោះទុកត្រង់គ្រឿងប្រដាប់នោះៗ កាលព្រះរាជាត្រាស់ថា ចូរនាំគ្រឿងប្រដាប់ឈ្មោះនោះមក ។ នាយឃ្លាំងក៏អុជប្រទីប ហើយចូលទៅក្នុងបន្ទប់ដោយប្រទីបនោះ អានផ្លាកឈ្មោះហើយ ក៏នាំគ្រឿងប្រដាប់នោះឯងមកបាន ។

ន័យម្យ៉ាងទៀត កាលពោលដោយការរួបរួមធម៌ទាំងអស់ សញ្ញា **សញ្ជានលក្ខណា** មានការចាំបានជាលក្ខណៈ **សញ្ជាននបច្ចយនិមិត្តករណរសា** មានការធ្វើនិមិត្តជាបច្ច័យឲ្យចាំបានជាកិច្ច ដូចជាងឈើជាដើមធ្វើគ្រឿងចំណាំត្រង់ឈើជាដើម **យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុប្បដ្ឋានា** មានការធ្វើនូវការកាន់យកមាំ ដោយអំណាចនៃនិមិត្តតាមដែលខ្លួនកាន់យកហើយជាអាការប្រាកដ ដូចមនុស្សខ្វាក់ភ្នែកបង្ហាញដំរី ឬ **អារម្មណេ អនោគាឡ្ហវុត្តិតាយ អចិរដ្ឋានបច្ចុប្បដ្ឋានា** មានការតាំងនៅក្នុងអារម្មណ៍មិនយូរជាអាការប្រាកដ ព្រោះមិនឈមចុះក្នុងអារម្មណ៍ ដូចផ្លេកបន្ទោរ **យថាឧបដ្ឋិតវិសយបទដ្ឋានា** មានអារម្មណ៍តាមដែលប្រាកដ ជាហេតុជិត ដូចសញ្ញាដែលកើតឡើងដល់កូនម្រឹគទាំងឡាយក្នុងតុម្ពស្មៅថាជា

មនុស្ស ។ ក្នុងទីនេះ សញ្ញាណាជាញាណសម្បយុត្ត សញ្ញានោះ គប្បីជ្រាបថា ប្រព្រឹត្តទៅតាមញាណនុ៎ះឯង ដូចបណ្ដាធម៌ដែលជាអង្គប្រកបនៃបបរី ( សសម្ភារបបរី ) ជាដើម ធម៌ដ៏សេស រមែងអនុលោមតាមបបរីជាដើម ។

ធម៌ដែលឈ្មោះថា **ចេតនា** ព្រោះអត្ថថា តាំងចិត្ត អធិប្បាយថា រួបរួមធម៌ទាំងឡាយ ដែលប្រកបជាមួយខ្លួនមកទុកក្នុងអារម្មណ៍ ចេតនានោះមានលក្ខណាទិចតុក្កៈដូច្នេះ

**ចេតយិតលក្ខណា** មានការតាំងចិត្តជាលក្ខណៈ គឺមានការផ្ដោតចិត្តជាលក្ខណៈ **អាយូហនរសា** មានការប្រមូលមកជាកិច្ច ។ មែនពិត ចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានការមិនផ្ដោតចិត្តជាលក្ខណៈមិនមាន ។ ចេតនាទាំងអស់ មានការតាំងចិត្តជាលក្ខណៈទាំងអស់នោះឯង ចេតនាដែលមានការប្រមូលមកជាកិច្ច រមែងកើតបាន ទាំងកុសល និងអកុសលនោះឯង និយាយដល់ឋានៈនៃការប្រមូលមកនូវកុសលកម្ម និងអកុសលកម្មហើយ សម្បយុត្តធម៌ដ៏សេស ក៏មានកិច្ចត្រឹមតែចំណែកខ្លះប៉ុណ្ណោះ តែចេតនាមានឧស្សាហៈក្រៃលែង មានសេចក្ដីព្យាយាមក្រៃលែង គឺមានឧស្សាហៈទ្វេដង មានសេចក្ដីព្យាយាមទ្វេដង ដោយហេតុនោះ ទើបបោរាណាចារ្យពោលថា ចេតនានេះ តាំងនៅក្នុងសភាវៈជាម្ចាស់ពិត ។ ម្ចាស់ស្រែ ហៅថាម្ចាស់ពិត ដូចបុរសជាម្ចាស់ស្រែបបួលបុរសរួមកម្លាំងគ្នា ៥៥ នាក់ ចុះស្រែព្រមគ្នាដោយប្រាប់ថា យើងនឹងច្រូតស្រូវ ដូច្នេះ ម្ចាស់របស់ស្រែ មាន

ឧស្សាហៈក្រៃលែង មានព្យាយាមក្រៃលែង គឺមានឧស្សាហៈទ្វេដង មាន ព្យាយាមទ្វេដង រមែងពោលថា ចូរពួកអ្នកប្រូតស្រូវជាប់តគ្នាទៅជាដើម ប្រាប់ព្រំប្រទល់ ចាត់ចែងស្រា អាហារ និងគ្រឿងក្រអូបជាដើម យកទៅ ឲ្យជនទាំងនោះ រមែងឲ្យមុខ ( សម្រាប់ប្រូត ) ប៉ុនៗ គ្នា យ៉ាងណា ឧបមេយ្យនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះចុះ ។ ពិតហើយ ចេតនា ដូច បុរសម្ចាស់ស្រែ កុសលធម៌ ៥៥ ដែលកើតឡើងដោយអំណាចជាអង្គ របស់ចិត្ត ដូចបុរសអ្នករួមកម្លាំងគ្នា ៥៥ នាក់ ។ និយាយដល់ឋានៈនៃ ការប្រមូលមកនូវកុសលកម្ម និងអកុសលកម្មហើយ ចេតនាមានសេចក្តី ឧស្សាហៈទ្វេដង មានសេចក្តីព្យាយាមទ្វេដង ដូចវេលាដែលបុរសម្ចាស់ស្រែ ធ្វើនូវឧស្សាហៈទ្វេដង មានព្យាយាមទ្វេដង ។ បណ្ឌិតគប្បីជ្រាបភាពដែល ចេតនានោះ មានការប្រមូលមកជាកិច្ច ដោយប្រការដូច្នេះ ។

ចេតនានោះ **សំវិធានបច្ចុប្បដ្ឋានា** មានការចាត់ចែង ជាអាការ ប្រាកដ ។ ពិតហើយ ចេតនានេះ កាលចាត់ចែង រមែងប្រាកដដូចសិស្ស ច្បង និងមេជាងជាដើមដែលអាចធ្វើកិច្ចរបស់ខ្លួន និងរបស់អ្នកដទៃឲ្យសម្រេច ។ ដូចសិស្សច្បងឃើញឧបជ្ឈាយ៍មកអំពីចម្ងាយ កាលខ្លួនឯងកំពុងស្វាធ្យាយ ក៏គង់ជាស់តឿនសិស្សធម្មតា ក្រៅអំពីនេះឲ្យស្វាធ្យាយ តាមអធ្យាស្រ័យ រៀងៗ ខ្លួន កាលសិស្សច្បងនោះផ្តើមស្វាធ្យាយ សិស្សធម្មតាទាំងនោះ ក៏ ស្វាធ្យាយ ព្រោះអនុលោមតាមសិស្សច្បងនោះ យ៉ាងណា និងប្រៀបដូចមេ ជាង កាលខ្លួនឯងចាំង ក៏ញ៉ាំងជាងចាំងដទៃទៀតឲ្យប្រព្រឹត្តទៅក្នុងកម្ម គឺ

ការចាំងរៀងៗ ខ្លួន ព្រោះថា កាលមេជាងនោះផ្ដើមចាំង ជាងចាំងទាំងនោះ ក៏ចាំងតាមមេជាងនោះ យ៉ាងណា និងប្រៀបដូចមេទ័ព កាលខ្លួនឯងច្បាំង ក៏ជាស់តឿនអ្នកចម្បាំងក្រៅអំពីនេះ ឲ្យធ្វើការច្បាំង ព្រោះថា កាលមេទ័ព ផ្ដើមធ្វើចម្បាំង អ្នកចម្បាំងទាំងនោះ ក៏ធ្វើចម្បាំងតាមមេទ័ពនោះ យ៉ាងណា សូម្បីចេតនានេះ ក៏យ៉ាងនោះ ប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយកិច្ចរបស់ខ្លួន ក៏ញុំាងសម្បយុត្តធម៌ដទៃៗ ឲ្យប្រព្រឹត្តទៅក្នុងការធ្វើរៀងៗ ខ្លួន ព្រោះថា កាលចេតនានោះផ្ដើមកិច្ចរបស់ខ្លួន សូម្បីធម៌ដែលសម្បយុត្តជាមួយនឹងចេតនានោះ ក៏ផ្ដើមកិច្ចរបស់ខ្លួន ដោយហេតុនោះ ទើបខ្ញុំពោលថា ដូចសិស្សច្បង និងមេជាងជាដើម ដែលធ្វើកិច្ចរបស់ខ្លួន និងរបស់អ្នកដទៃឲ្យសម្រេច ។ ចេតនានេះ ក្នុងការរឭកដល់ការងារក៏ប្រញាប់ប្រញាល់ជាដើម គប្បីជ្រាបថា រមែងប្រាកដប្រព្រឹត្តទៅដោយឧស្សាហៈនៃសម្បយុត្តធម៌ទាំងឡាយ ។

អធិប្បាយនៃពាក្យថា ចិត្ត ខ្ញុំពោលដោយន័យជាដើមថា ធម៌ដែលឈ្មោះថា ចិត្ត ព្រោះអត្ថថា គិតនូវអារម្មណ៍ ។ កាលពោលដោយលក្ខណៈជាដើម ( ដូច្នេះថា )

**វិជាននលក្ខណំ** ចិត្តមានការដឹងច្បាស់នូវអារម្មណ៍ជាលក្ខណៈ **បុព្វង្គមរសំ** មានភាពជាប្រធានជាកិច្ច **សន្ធានបច្ចុប្បដ្ឋានំ** មានការជាប់បន្តគ្នាជាបច្ចុប្បដ្ឋាន **នាមរូបបទដ្ឋានំ** មាននាមរូបជាបទដ្ឋាន ។

ពិតហើយ ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មិនមានការដឹងច្បាស់នូវអារម្មណ៍ជាលក្ខណៈរមែងមិនមាន ។ ចិត្តទាំងអស់ មានការដឹង

ច្បាស់នូវអារម្មណ៍នោះឯង ។ កាលនិយាយដល់ទ្វារហើយ ចិត្តក៏ជាប្រធាន គឺមានប្រក្រតីត្រាច់ទៅមុន ក្នុងទីជាទីដែលធ្វើអារម្មណ៍ឲ្យជាក់ច្បាស់ ។ ពិតហើយ បុគ្គលរមែងដឹងច្បាស់នូវរូបារម្មណ៍ដែលឃើញដោយចក្ខុ ដោយចិត្តនុ៎ះឯង ។បេ។ រមែងដឹងច្បាស់នូវធម្មារម្មណ៍ ដែលដឹងហើយដោយចិត្តនោះឯង ដូចអ្នករក្សានគរអង្គុយនៅត្រង់ផ្លូវបែកជា ៤ ក្នុងកណ្ដាលនគរ រមែងពិចារណា រមែងកំណត់ជនដែលទៅមកថា ជននេះជាអ្នកស្រុកនេះ ជននេះជាអ្នកដំណើរ យ៉ាងណា គប្បីជ្រាបឧបមេយ្យយ៉ាងនោះ ។ សេចក្ដីនេះ ដូចពាក្យដែលព្រះមហាថេរៈ មាននាមថានាគសេន ពោលថា បពិត្រមហារាជធម្មតាអ្នករក្សានគរ អង្គុយនៅត្រង់ផ្លូវបែកជា ៤ កណ្ដាលនគរ គប្បីឃើញបុគ្គលដែលមកអំពីទិសខាងកើត គប្បីឃើញបុគ្គលដែលមកអំពីទិសខាងលិច អំពីទិសទក្សិណ អំពីទិសឧត្តរ យ៉ាងណា បពិត្រមហារាជ យ៉ាងនោះឯង បុគ្គលរមែងឃើញរូបណាដោយចក្ខុ រមែងដឹងច្បាស់នូវរូបនោះដោយវិញ្ញាណ រមែងស្ដាប់សំឡេងណាដោយសោតៈ រមែងធុំក្លិនដោយឃានៈ រមែងភ្លក្សរសដោយជិវ្ហា រមែងពាល់ត្រូវផោដ្ឋព្វៈដោយកាយ រមែងដឹងច្បាស់នូវធម៌ដោយចិត្ត បុគ្គលរមែងដឹងច្បាស់នូវវត្ថុនោះៗ ដោយវិញ្ញាណ ដូច្នេះ ។ បើនិយាយដល់ទ្វារហើយ ចិត្តប៉ុណ្ណោះជាប្រធាន ជាធម្មជាតត្រាច់ទៅខាងមុខ ក្នុងឋានៈដែលធ្វើអារម្មណ៍ឲ្យជាក់ច្បាស់យ៉ាងនេះ ព្រោះហេតុនោះ ទើបខ្ញុំពោលថា មានភាពជាប្រធានជាកិច្ច ដូច្នេះ ។

ចិត្តនេះ ឈ្មោះថា មានការជាប់តគ្នាជាអាការប្រាកដព្រោះចិត្តក្រោយៗ

កាលកើតឡើង រមែងប្រាកដជាប់តគ្នានោះឯង ព្រោះធ្វើចិត្តខាងដើមៗ ឲ្យជាប់តគ្នានុ៎ះឯង ។ តែក្នុងបញ្ចវោការភព ( ភពដែលមានខន្ធ ៥ ) ចិត្តនោះមាននាមរូបជាហេតុជិត ក្នុងចតុវោការភព មាននាមប៉ុណ្ណោះជាហេតុជិតដោយពិតប្រាកដ ព្រោះហេតុនោះ ទើបខ្ញុំពោលថា ចិត្តមាននាម និងរូបជាហេតុជិត ដូច្នេះ ។

សួរថា ចិត្តនេះ ជាចិត្តដូងតែមួយជាមួយនឹងចិត្តដែលសម្តែងមកខាងដើម ឬជាចិត្តដូនដទៃ ឆ្លើយថា ជាដួងតែមួយនុ៎ះឯង ។ សួរថា កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបពោលទៀត ឆ្លើយថា ពាក្យនេះ មិនទាន់បានពិចារណាក្នុងអដ្ឋកថា ។ ក្នុងពាក្យនេះ មានការប្រែកបដូច្នេះ ដូចព្រះអាទិត្យជាដើមដែលបញ្ញត្តិព្រោះអាស្រ័យរូបជាដើម ពោលដោយសេចក្តី ក៏មិនមែនវត្ថុដទៃក្រៅអំពីរូបជាដើម ដោយហេតុនោះនុ៎ះឯង សូម្បីពោលយ៉ាងនេះថា សម័យណា ព្រះអាទិត្យរមែងរះឡើង សម័យនោះ រូប គឺពន្លឺនៃព្រះអាទិត្យនោះ រមែងប្រាកដ ដូច្នេះ ដែលឈ្មោះថា ព្រះអាទិត្យដទៃក្រៅអំពីរូបជាដើម រមែងមិនមាន យ៉ាងណា ចិត្តនេះ រមែងយ៉ាងនោះក៏ទេ ព្រះអង្គទ្រង់បញ្ញត្តិ ព្រោះអាស្រ័យធម៌ទាំងឡាយ មានផស្សៈជាដើម ។ តែកាលពោលដោយអត្ថ ចិត្តនោះក៏ម្យ៉ាងទៀតក្រៅអំពីធម៌ទាំងឡាយ មានផស្សៈជាដើមទាំងនោះដោយពិត ព្រោះហេតុនោះ ចិត្តនេះបណ្ឌិតគប្បីជ្រាបថា ទ្រង់ត្រាស់ទុកទៀត ដើម្បីសម្តែងសេចក្តីនេះថា សម័យណាចិត្តកើតឡើង សម័យនោះចិត្តនោះដទៃចាកធម៌ទាំងឡាយ មានផស្សៈជាដើម ដោយ

អត្ថ រមែងមានដោយពិតប្រាកដនោះឯង ។

ម្យ៉ាងទៀត ដូចកាលព្រះអង្គ ទ្រង់កំណត់សម័យដោយបុគ្គល ដែលចម្រើនមគ្គក្នុងព្រះតម្រាស់ ( អភិធម្ម ធម្មសង្គណី ) ជាដើមថា បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព ។បេ។ ឈ្មោះបឋវីកសិណក្នុងសម័យណា ផស្សៈក៏កើតមាន វេទនាក៏កើតមានក្នុងសម័យនោះ ដូច្នេះ បុគ្គលណាចម្រើនមគ្គ ពោលដោយអត្ថ បុគ្គលនោះ ឈ្មោះថា កើតឡើងក៏ទេ ព្រោះហេតុនោះឯង ក្នុងសេចក្ដីដែលពោលហើយនោះ ទើបត្រាស់ថា ផស្សៈរមែងមាន វេទនារមែងមាន យ៉ាងណា តែមិនបានត្រាស់ថា បុគ្គលណាចម្រើនមគ្គ បុគ្គលនោះ រមែងមាន ក៏យ៉ាងនោះ ។ តែកាលទ្រង់កំណត់សម័យដោយចិត្ត ក្នុងព្រះតម្រាស់ជាដើមថា **យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ** ចិត្តជាកាមាវចរកុសលកើតឡើងក្នុងសម័យណា ដូច្នេះ ចិត្តទ្រង់កំណត់ដោយសម័យ ពោលដោយអត្ថហើយ រមែងមិនកើតឡើងយ៉ាងនោះក៏មិនមែន តែត្រាស់ថា ផស្សៈក៏កើតមាន វេទនាក៏កើតមាន ក្នុងកាលនោះ យ៉ាងណា គប្បីជ្រាបថា ត្រាស់ចិត្តនេះទៀតដើម្បីសម្ដែងអត្ថនេះថា ចិត្តរមែងមាន ក៏យ៉ាងនោះ ។ ក្នុងសេចក្ដីនេះ មានបទសន្និដ្ឋានដូចតទៅនេះថា

ព្រះមានព្រះភាគ ទ្រង់សម្ដែងចិត្តដើម្បីប្រមូលមកក្នុងឧទ្ទេសវារៈ និងដើម្បីចែកក្នុងនិទ្ទេសវារៈ ពិតហើយ ព្រះអង្គទ្រង់កំណត់សម័យតែម្យ៉ាងដោយចិត្តសព្វ ដែលមានក្នុងខាងដើម ( ឧទ្ទេសវារៈ ) តែដើម្បីទ្រង់

សម្តែងធម៌ដែលមានក្នុងសម័យ ដែលមានការកំណត់ដោយចិត្តនោះ ទើបផ្តើមត្រាស់ថា ផស្សៈក៏កើតមានជាដើម សូម្បីចិត្តក៏កើតមានក្នុងសម័យនោះដូចគ្នា ព្រោះហេតុនោះ ដើម្បីប្រមូលមកនូវចិត្តនោះ ទើបត្រាស់ពាក្យថា ចិត្តនេះទៀត ។ មួយទៀត កាលមិនត្រាស់ពាក្យថា ចិត្តនេះ ក្នុងទីនេះក៏មិនអាចដើម្បីចែកក្នុងនិទ្ទេសវារៈបានថា ចិត្តកើតមានក្នុងសម័យនោះ តើដូចម្តេច ។ កាលបើយ៉ាងនេះ ការចែកចិត្តនោះឯងក៏នឹងបាត់ទៅ ព្រោះហេតុនោះនុ៎ះឯង គប្បីជ្រាបថា ដើម្បីការចែកចិត្តនោះក្នុងនិទ្ទេសវារៈ ទើបត្រាស់ចិត្តនេះទៀត ។

ម្យ៉ាងទៀត ក្នុងអដ្ឋកថា លោកវិចារណាថា ពាក្យថា ចិត្តកើតមាន ក្នុងបទថា **ឧប្បន្នំ ហោតិ** នេះ ត្រឹមតែជាមាតិកានៃទេសនាប៉ុណ្ណោះ តែចិត្តត្រឹមតែម្យ៉ាងប៉ុណ្ណោះកើតឡើងក៏មិនមែន ហេតុនោះ ក្នុងបទថា ចិត្តកើតមាននេះ ក៏មិនបានកាន់យកចិត្តតែម្យ៉ាង តែកាន់យកចិត្ត និងកុសលធម៌ជាង ៥០ នោះឯង ។ កាលបើយ៉ាងនេះ ទើបផ្តើមត្រាស់ថា ផស្សៈក៏មានជាដើម ដើម្បីកំណត់ធម៌ គឺចិត្ត និងចេតសិកទាំងអស់ដោយសង្ខេប ក្នុងបទថា ចិត្តកើតមាននោះ ហើយសម្តែងដោយប្រភេទដោយសរុបនោះឯង ក្នុងនិទ្ទេសនេះ ។ ដោយប្រការយ៉ាងនេះ គប្បីជ្រាបថា សូម្បីចិត្តក៏គប្បីត្រាស់ដូចធម៌មានផស្សៈជាដើមនោះឯង ។

# អធិប្បាយ

## ពួកអង្គឈានមានវិតក្កជាដើម

ធម៌ដែលឈ្មោះថា **វិតក្កៈ** ព្រោះអត្ថថា ត្រិះរិះ ម្យ៉ាងទៀត ការត្រិះរិះ ឈ្មោះថា **វិតក្កៈ** ។ មានពាក្យអធិប្បាយថា ការទល់ទ្រអារម្មណ៍ ។ វិតក្កនេះ **អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ** មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ ពិតហើយ វិតក្កនោះ លើកចិត្តឡើងកាន់អារម្មណ៍ ដូចបុគ្គលខ្លះអាស្រ័យញាតិ ឬមិត្តដែលជារាជវល្លភៈ ទើបចូលទៅកាន់រាជ-និវេសន៍បាន យ៉ាងណា ចិត្តក៏អាស្រ័យវិតក្កលើកឡើងកាន់អារម្មណ៍យ៉ាងនោះ ព្រោះហេតុនោះ ទើបវិតក្កនោះ លោកពោលថា មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ ។

មួយទៀត ព្រះនាគសេនត្ថេរពោលថា វិតក្កមានការគោះអារម្មណ៍ជាលក្ខណៈ សូមថ្វាយព្រះពរមហារាជ ប្រៀបដូចបុគ្គលវាយស្គរ ក្រោយអំពីនោះ ក៏មានសំឡេងស្គរលាន់ឮចេញទៅ យ៉ាងណា បពិត្រមហារាជ គប្បីជ្រាបវិតក្កដូចការវាយស្គរ គប្បីជ្រាបវិចារដូចសំឡេងស្គរដែលលាន់រំពងយ៉ាងនោះ ។

វិតក្កនោះ **អាហននបរិយាហននរសោ** មានការធ្វើឲ្យចិត្តប៉ះខ្ទប់នឹងអារម្មណ៍រឿយៗ ជាកិច្ច ពិតហើយ លោកពោលថា ព្រះយោគាវចររមែងធ្វើអារម្មណ៍ ឲ្យជាធម្មជាតដែលវិតក្កប៉ះខ្ទប់ហើយរឿយៗ ដោយចិត្តនោះ វិតក្កនោះ **អារម្មណេ ចិត្តស្ស អានយនបច្ចុប្បដ្ឋានោ** មានការនាំចិត្តមកក្នុងអារម្មណ៍ជាអាការប្រាកដ **សេសខន្ធត្តយបទដ្ឋានោ** មានខន្ធ

៣ ដែលសល់ ( វេទនា សញ្ញា វិញ្ញាណ ) ជាហេតុជិត[១] ។

ធម៌ដែលឈ្មោះថា **វិចារោ** ព្រោះជាហេតុឲ្យចិត្តត្រាច់ទៅក្នុងអារម្មណ៍ ។ ម្យ៉ាងទៀត ការត្រាច់ទៅ ឈ្មោះថា **វិចារ** អធិប្បាយថា ការសញ្ចរទៅតាមអារម្មណ៍ ។

វិចារនេះ **អារម្មណានុមជ្ជនលក្ខណោ** មានការស្ទាបអង្អែលនូវអារម្មណ៍ជាលក្ខណៈ **តត្ថ សហជាតានុយោជនរសោ** មានការប្រកបសហជាតធម៌ក្នុងអារម្មណ៍នោះជាកិច្ច **ចិត្តស្ស អនុប្បពន្ធបច្ចុបដ្ឋានោ** មានការចងចិត្តក្នុងអារម្មណ៍ជាអាការប្រាកដ ។

មួយទៀត កាលការមិនបែកចាកគ្នានៃវិតក្ក និងវិចារ ក្នុងចិត្តប្បាទកន្លែងខ្លះ សូម្បីមាននៅដោយអាការយ៉ាងនេះ ការដែលចិត្តធ្លាក់ទៅក្នុងអារម្មណ៍ជាលើកដំបូង ឈ្មោះថា **វិតក្ក** ព្រោះអត្ថថា ជាធម៌គ្រោតគ្រាត ព្រោះអត្ថថា ជាធម៌ដល់មុន ព្រោះអត្ថថា លើកចិត្តឡើងកាន់អារម្មណ៍ ដូចការគោះរគាំង ។ ការចងជាប់ក្នុងអារម្មណ៍ ឈ្មោះថា **វិចារ** ព្រោះអត្ថថា ជាធម៌សុខុម ព្រោះអត្ថថា ស្ទាបអង្អែលក្នុងអារម្មណ៍ ដូចសំឡេងខ្ទរបស់រគាំង ដូច្នោះ ។ ក្នុងធម៌ ២ យ៉ាងនោះ វិតក្ក មានការផ្សាយទៅ ជាការផ្សាយទៅដោយជុំវិញ ក្នុងកាលកើតឡើងនៃចិត្តចាប់អារម្មណ៍ជាលើកដំបូង ដូចការទទះស្លាបរបស់បក្សី ដែលចង់ហើរទៅក្នុងអាកាស និងដូចកន្លង់មានចិត្តជាប់ជំពាក់ក្នុងក្លិន ហើរតម្រង់ទៅរកផ្កាបទុម ដូច្នោះ ។ វិចារ មានការ

---

១- ហេតុជិតនេះ លោកនាំអំពីទីដទៃមកបន្ថែមក្នុងទីនេះ ។

ប្រព្រឹត្តិទៅស្ងប់ មិនមានការផ្សាយទៅនៃចិត្ត ដូចការត្រដាងស្លាបរបស់បក្សីដែលចង់ហើរទៅឰដ៏អាកាស និងដូចកន្ទង់ដែលហើរតម្រង់ទៅរកផ្កាបទុម ហើយហើរធ្លែលពីខាងលើ ដូច្នោះ ។

ប៉ុន្តែ ក្នុងអដ្ឋកថាទុកនិបាត លោកពោលថា វិតក្កប្រព្រឹត្តទៅដោយការលើកចិត្តឡើងកាន់អារម្មណ៍ ដូចបក្សីធំហើរឰដ៏អាកាស ទទះស្លាបទាំងពីរឲ្យជក់ខ្យល់ ហើយឲ្យស្លាបទាំងពីរជក់ខ្យល់ហើរទៅ ព្រោះថា វិតក្កនោះមានអារម្មណ៍មួយដោយពិត ចំណែកវិចារប្រព្រឹត្តទៅដោយការស្ទាបអង្អែលអារម្មណ៍ ដូចបក្សីធំទទះស្លាបដើម្បីឲ្យជក់ខ្យល់ប្រព្រឹត្តទៅ ព្រោះថា វិចារនោះ មានការស្ទាបអង្អែលនូវអារម្មណ៍ ដូច្នេះ ។ ពាក្យក្នុងអដ្ឋកថាទុកនិបាតនោះ សមគួរក្រៃលែងក្នុងការដែលចិត្តជាប់ក្នុងអារម្មណ៍ប្រព្រឹត្តទៅ ។ ប៉ុន្តែការផ្សេងគ្នានៃវិតក្ក និងវិចារនោះ រមែងប្រាកដច្បាស់ ក្នុងឈានទីមួយ និងទីពីរ ។

ម្យ៉ាងទៀត កាលបុគ្គលយកដៃម្ខាងចាប់ភាជន៍សំរិទ្ធដែលមានច្រែះទុកឲ្យមាំ ហើយយកដៃម្ខាងទៀតដុសខាត់ដោយលម្អិតប្រេង ឬអាចម៍សត្វដែលសមគួរ វិតក្កដូចដៃដែលចាប់ទុកយ៉ាងមាំ វិចារដូចដៃដែលដុសខាត់ មួយទៀត កាលស្មូនផ្ទាំងប្រើឈើវាយក្ដារយន្តធ្វើភាជនៈ វិតក្កដូចដៃដែលចាប់ទុក វិចារដូចដៃដែលបង្វិលទៅខាងណោះ និងខាងណេះ ។ មួយទៀត កាលបុគ្គលធ្វើរង្វង់មូល វិតក្ក គឺការផ្ដោតនូវអារម្មណ៍ ដូចដែកស្រួចដែលបោះទុកត្រង់កណ្ដាល វិចារស្ទាបអង្អែលអារម្មណ៍ ដូចដែកស្រួចដែលវិល

ទៅជុំវិញខាងក្រៅ ដូច្នោះ ។

ធម៌ដែលឈ្មោះថា **បីតិ** ព្រោះឆ្អែត ។ បីតិនោះ **សម្បិយាយន-លក្ខណា** មានការត្រេកអរជាលក្ខណៈ **កាយចិត្តបីណនរសា** មានការធ្វើកាយ និងចិត្តឲ្យឆ្អែតជាកិច្ច **ផរណរសា វា** ឬមានការជ្រួតជ្រាបទៅជាកិច្ច **ឱទគ្យបច្ចុប្បដ្ឋានា** មានការអណ្តែតកាយ និងចិត្តជាអាការប្រាកដ ។

បីតិនោះ មាន ៥ យ៉ាង គឺខុទ្ទកាបីតិ ១ ខណិកាបីតិ ១ ឱក្កន្តិកាបីតិ ១ ឧព្វេង្គាបីតិ ១ ផរណាបីតិ ១ ។

បណ្តាបីតិទាំងនោះ ខុទ្ទកាបីតិ អាចធ្វើត្រឹមរោមក្នុងសរីរក្តិកាយ ឲ្យបះឡើងប៉ុណ្ណោះ ខណិកាបីតិ ដូចគ្នានឹងការកើតឡើងនៃផ្លេកបន្ទោរមួយខណៈៗ ឱក្កន្តិកាបីតិ ឈានចុះកាន់សរីរក្តិកាយហើយ កាលចុះកាន់ហើយ ក៏បែកធ្លាយទៅ ដូចរលកប៉ះច្រាំងសមុទ្រហើយបែកទៅ ឧព្វេង្គាបីតិ ជាបីតិមានកម្លាំង ធ្វើកាយឲ្យអណ្តែតឡើង ដល់នូវការអណ្តែតទៅឰដ៏អាកាសបាន ។

ពិតហើយ ព្រះមហាតិស្សត្ថេរអ្នកនៅក្នុងបុណ្ណវល្លិកវិហារ ក្នុងថ្ងៃពេញបូណ៌មី វេលាល្ងាចទៅកាន់លានព្រះចេតិយ ឃើញពន្លឺព្រះចន្ទ ទើបបែរមុខទៅកាន់មហាចេតិយ ហើយពិចារណាថា វេលានេះ ពួកបរិស័ទ ៤ កំពុងនាំគ្នាថ្វាយបង្គំព្រះចេតិយហ្ន៎ ញុំាងឧព្វេង្គាបីតិ មានព្រះពុទ្ធជាអារម្មណ៍ ឲ្យកើតឡើងដោយអំណាចអារម្មណ៍ដែលឃើញតាមប្រក្រតី អណ្តែតឡើងឰដ៏អាកាស ហើយទៅឈរនៅចំពោះទីលាននៃមហាចេតិយនុ៎ះឯង ដូចរូបដ៏វិចិត្រដែលគេចោលទៅក្នុងទីដែលបូកលាបដោយបាយ-**អ** ។

មួយទៀត សូម្បីកុលធីតាម្នាក់ក្នុងស្រុក វត្តកាលកៈ ដែលអាស្រ័យនៅជិតគិរិកណ្ឌកវិហារ អណ្តែតឡើងទៅព្ធដ៏អាកាសដោយឧព្វេង្គាបីតិ មានពុទ្ធគុណជាអារម្មណ៍ដ៏មានកម្លាំង ។ បានឮថា មាតាបិតារបស់កុលធីតានោះ កាលទៅវិហារដើម្បីស្តាប់ធម៌ក្នុងវេលាល្ងាច បានប្រាប់ថា នែកូន នាងមានភារៈធ្ងន់ មិនអាចត្រាច់ទៅក្នុងវេលាដែលមិនគួរ ជាមួយពួកយើងបាន ពួកយើងនឹងស្តាប់ធម៌ ឲ្យចំណែកបុណ្យនោះដល់នាង ហើយនាំគ្នាទៅ ។ កុលធីតានោះទោះបីចង់ទៅ តែមិនអាចជំទាស់ពាក្យរបស់មាតាបិតាបាន ទើបនៅក្នុងផ្ទះ ឈរសម្លឹងមើលលានព្រះចេតិយក្នុងអាកាស ត្រង់គិរិកណ្ឌវិហារ ដោយពន្លឺព្រះចន្ទ ត្រង់ទ្វារផ្ទះ បានឃើញប្រទីបដែលបូជាព្រះចេតិយ និងបរិស័ទ ៤ ធ្វើការបូជាព្រះចេតិយដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ហើយធ្វើប្រទក្សិណ បានស្តាប់ឮសំឡេងស្វាធ្យាយ ជាគណៈរបស់ភិក្ខុសង្ឃ ។ ពេលនោះ នាងគិតថា ឱមនុស្សអ្នកមានបុណ្យទាំងនេះ នាំគ្នាទៅកាន់វិហារ រមែងបានដើម្បីដើរប្រទក្សិណត្រង់លានចេតិយ និងបានស្តាប់ធម្មកថាដ៏ពីរោះបែបនេះ ដូច្នេះហើយ កំពុងសម្លឹងមើលចេតិយដូចជាគំនរកែវមុក្តាទុំះឯង ឧព្វេង្គាបីតិក៏កើតឡើង ។ នាងអណ្តែតទៅព្ធដ៏អាកាស ចុះនៅត្រង់លានព្រះចេតិយ តាមផ្លូវអាកាស មុនមាតាបិតាមកដល់នោះឯង ហើយថ្វាយបង្គំព្រះចេតិយ ឈរស្តាប់ធម៌ ។ ពេលនោះ មាតា និងបិតាក៏មកដល់ ហើយសួរកុលធីតានោះថា នែកូន នាងមកតាមផ្លូវណា នាងឆ្លើយថា មកតាមផ្លូវអាកាស មិនបានតាមផ្លូវថ្នល់ មាតាបិតាពោលថា នែកូន ធម្មតា

ព្រះវីណាស្រេពទាំងឡាយ ទើបត្រាច់ទៅឰដ៏អាកាសបាន នាងមកបានដូចម្តេច នាងឆ្លើយថា កាលខ្ញុំឈរសម្លឹងមើលព្រះចេតិយ ដោយពន្លឺព្រះចន្ទ បីតិដ៏មានកម្លាំង មានពុទ្ធគុណជាអារម្មណ៍ក៏កើតឡើង ខណៈនោះ ខ្ញុំមិនដឹងថា ខ្លួនឯងឈរ ឬអង្គុយ អណ្តែតទៅឰដ៏អាកាសដោយនិមិត្តដែលកាន់យកនុ៎ះឯង ហើយឈរនៅត្រង់លានព្រះចេតិយ ។ ឧព្វេង្គាបីតិឲ្យអណ្តែតទៅក្នុងអាកាស រមែងមានដោយន័យដែលពោលមកហើយ ។

ចំណែកផរណាបីតិ កើតឡើងហើយ ក៏ផ្សាយទៅពេញសរីរៈទាំងអស់ ហើយជ្រួតជ្រាបទៅ ដូចតម្រងបស្សាវៈដែលពេញ និងដូចជ្រលងភ្នំដែលជំនន់ទឹកជំហូរចូលទៅ ។

បីតិ ៥ យ៉ាងនេះ កាលកាន់យកគភ៌ ដល់នូវការចាស់ក្លាដោយជុំវិញ រមែងញ៉ាំងបស្សទ្ធិ ២ យ៉ាង គឺកាយបស្សទ្ធិ និងចិត្តបស្សទ្ធិឲ្យបរិបូណ៌ ។ បស្សទ្ធិ កាលកាន់យកគភ៌ ដល់នូវការចាស់ក្លាជុំវិញ រមែងញ៉ាំងសុខ ២ យ៉ាង គឺកាយិកសុខ និងចេតសិកសុខឲ្យបរិបូណ៌ សេចក្តីសុខកាលកាន់យកគភ៌ ដល់នូវការចាស់ក្លាដោយជុំវិញ រមែងញ៉ាំងសមាធិ ៣ យ៉ាង គឺខណិ-កសមាធិ ឧបចារសមាធិ អប្បនាសមាធិឲ្យបរិបូណ៌ ។ បណ្តាបីតិទាំងនោះ បីតិ ២ យ៉ាងក្រៅអំពីនេះ ( បីតិដែលញ៉ាំងខណិកសមាធិ និងឧបចារ-សមាធិឲ្យបរិបូណ៌ ) វៀរបីតិដែលញ៉ាំងអប្បនាសមាធិឲ្យបរិបូណ៌ រមែងគួរក្នុងអធិការនេះ ។

ធម៌ដែលឈ្មោះថា **សុខំ** ព្រោះអត្ថថា សប្បាយ អធិប្បាយថា សេចក្តី

សុខកើតដល់បុគ្គលណា ក៏ធ្វើបុគ្គលនោះឲ្យដល់នូវសេចក្ដីសុខ ។ ម្យ៉ាងទៀត ធម្មជាតណា រមែងទំពាស៊ីយ៉ាងល្អ និងរមែងជីក ( ទម្លាយ ) អាពាធតាមផ្លូវកាយ តាមផ្លូវចិត្ត ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សុខ** ។ សុខនេះ ជាឈ្មោះរបស់សោមនស្សវេទនា ។ បណ្ឌិតគប្បីជ្រាបលក្ខណៈជាដើមរបស់សុខនោះ ដោយន័យដែលពោលហើយក្នុងបទនៃវេទនានុ៎ះឯង ។

ម្យ៉ាងទៀត សុខ **សាតលក្ខណំ** មានការត្រេកអរជាលក្ខណៈ **សម្ប-យុត្តានំ ឧបព្រូហានរសំ** មានការញុំាងសម្បយុត្តធម៌ទាំងឡាយ ឲ្យចម្រើនជាកិច្ច **អនុគ្គហណបច្ចុប្បដ្ឋានំ** មានការអនុគ្រោះជាអាការប្រាកដ មួយទៀត កាលបីតិ និងសុខទាំងនោះ មិនបែកចាកគ្នា មាននៅក្នុងចិត្តជួនខ្លះ សេចក្ដីត្រេកអរក្នុងការបាននូវឥដ្ឋារម្មណ៍ ជាបីតិ ការសោយរសអារម្មណ៍ដែលបានហើយជាសុខ បីតិមានក្នុងទីណា សុខក៏មានក្នុងទីនោះ សុខមានក្នុងទីណា ក្នុងទីនោះ មិនប្រាកដថាមានបីតិ បីតិលោកសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ សុខលោកសង្គ្រោះចូលក្នុងវេទនាខន្ធ ។ បីតិដូចការឆ្អែតក្នុងការបានឃើញ ឬបានឮថា មានព្រៃ និងមានទឹករបស់បុគ្គលដែលអស់កម្លាំង ក្នុងផ្លូវកន្តារ ។ សុខដូចការសប្បាយក្នុងការចូលទៅកាន់ម្លប់នៃព្រៃ និងប្រើប្រាស់ទឹក ។

ដូចបុរសដើរផ្លូវកន្តារវែងឆ្ងាយ មានញើសជោកខ្លួន មានសេចក្ដីស្រេកឃើញបុរសដើរតាមផ្លូវប្រសព្វគ្នាមក ក៏សួរថា មានទឹកផឹក ក្នុងទីណាខ្លះ

បុរសនោះឆ្លើយថា ឆ្លងដងព្រៃ ( នេះ ) ទៅ មានស្រះកើតឯង និងព្រៃខ្ពស់ អ្នកទៅក្នុងទីនោះនឹងបាន ដូច្នេះ បុរសនោះស្តាប់ពាក្យរបស់បុរសនោះហើយក៏មានចិត្តត្រេកអរ កាលបុរសនោះទៅអំពីទីនោះ ឃើញត្របក ទងស្លឹក ផ្កាឧប្បលជាដើម ធ្លាក់ដេរដាសពេញផែនដី ជាអ្នកមានចិត្តត្រេកអរយ៉ាងល្អ កាលដើរទៅឃើញបុរស មានសំពត់សើម សក់សើម បានឮសំឡេងមាន់ព្រៃ និងក្ងោកជាដើម ឃើញដងព្រៃដែលខៀវស្រងាត់ដូចបណ្តាញកែវមណី កើតត្រង់ជាតស្រះ ឃើញផ្កាឧប្បល និងផ្កាកុមុទជាដើមដែលកើតក្នុងស្រះ ឃើញទឹកថ្លាស្អាត បុរសនោះ ក៏មានសេចក្តីត្រេកអរក្រៃលែង ទើបចុះទៅកាន់ស្រះកើតឯង ងូត និងផឹកតាមគាប់ចិត្ត រម្ងាប់សេចក្តីក្រវល់ក្រវាយហើយ ទំពាស៊ីក្រអៅឈូកជាដើម ប្រដាប់ផ្កាឧប្បលខៀវជាដើម យកក្រអៅឈូក-សពាក់ត្រង់ស្មា ឡើងអំពីស្រះស្លៀកសំពត់ យកសំពត់ហាលក្នុងទីមានកម្តៅថ្ងៃ ដេកក្រោមម្លប់ដ៏ត្រជាក់ កាលខ្យល់បក់មកត្រសៀកៗ គប្បីពោលថា សុខហ្ន៎ សុខហ្ន៎ ដូច្នេះ ពាក្យឧបមាជាគ្រឿងប្រៀបធៀបគប្បីឃើញយ៉ាងនេះថា

បីតិមានអាការត្រេកអរក្នុងអារម្មណ៍ ដែលជាចំណែកខាងដើម គប្បីឃើញដូចវេលាដែលត្រេកអរ រាប់ចាប់តាំងអំពីវេលាដែលបុរសនោះ បានឮថា មានស្រះកើតឯង និងដងព្រៃរហូតដល់ការឃើញទឹក ។ សុខតាំងនៅដោយអាការសោយរសនៃអារម្មណ៍ដ៏មានកម្លាំង គប្បីឃើញដូចបុគ្គលងូតទឹក ផឹកទឹកហើយ ដេកគិតថា សុខហ្ន៎ សុខហ្ន៎ ក្រោមម្លប់ឈើដ៏ត្រជាក់

កាលខ្យល់បក់ត្រសៀកៗ មក ។ សុខនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់ហើយ ព្រោះការប្រាកដក្នុងសម័យនោះៗ ។ ពាក្យនេះ លោក អធិប្បាយថា បីតិមានក្នុងទីណា សុខក៏មាននៅក្នុងទីនោះ ។

ភាវៈនៃចិត្តមានអារម្មណ៍ដ៏ប្រសើរតែមួយ ឈ្មោះថា **ចិត្តស្សេកគ្គតា** ពាក្យនេះ ជាឈ្មោះរបស់សមាធិ ។ ក្នុងធម៌ មានលក្ខណៈជាដើមរបស់ សមាធិនោះ លោកពោលក្នុងអដ្ឋកថាមុនហើយ ។

សមាធិនោះ **បាមោក្ខលក្ខណោ** មានភាពជាប្រធានជាលក្ខណៈ **អវិក្ខេបលក្ខណោ** ច ឬមានការមិនរាយមាយជាលក្ខណៈ ។

សមាធិ ឈ្មោះថា ជាប្រធាននៃធម៌ទាំងអស់នោះ ព្រោះកុសលធម៌ទាំង ពួងសម្រេចដោយសមាធិចិត្ត ដូចជហ្វាផ្ទះកំពូល ឈ្មោះថា ជាប្រធាននៃ ទព្វសម្ភាររបស់ផ្ទះដ៏សេស ។ ដោយហេតុនោះ ទើបព្រះនាគសេនត្ថេរពោល ថា បពិត្រមហារាជ ជហ្វាទាំងឡាយឯណានៃផ្ទះកំពូល ជហ្វាទាំងអស់នោះ ប្រជុំចុះត្រង់កំពូល បង្អោនទៅត្រង់កំពូល ទៅប្រជុំគ្នាត្រង់កំពូល ឈមទៅ ត្រង់កំពូល កំពូលផ្ទះ បណ្ឌិតពោលថា ប្រសើរជាងជហ្វាទាំងនោះ យ៉ាង ណា សូមថ្វាយព្រះពរមហារាជ កុសលធម៌ប្រភេទណាមួយ កុសលធម៌ ទាំងអស់នោះ បង្អោនទៅកាន់សមាធិ ប្រជុំចុះត្រង់សមាធិ ឈមចុះទៅកាន់ សមាធិ សមាធិ បណ្ឌិតហៅថា ប្រសើរជាងកុសលធម៌ទាំងនោះ ក៏យ៉ាង នោះ ។

សមាធិ ឈ្មោះថា មានការមិនរាយមាយ ជាលក្ខណៈ ព្រោះមិនឲ្យ

សហជាតធម៌ទាំងឡាយ រាយមាយ ខ្ចាត់ខ្ចាយ ដូចព្រះរាជាជាធំជាងសេនា យាងទៅកាន់ទីដែលសេនាប្រជុំគ្នាកុះករ ក្នុងទីដែលព្រះអង្គយាងទៅ សេនារមែងដល់ព្រម ទម្លាយសេនាដែលជាសត្រូវ រមែងអនុលោមតាមព្រះរាជានុ៎ះឯង ។

ម្យ៉ាងទៀត ឈ្មោះថា **សមាធិ** ពោល គឺឯកគ្គតានៃចិត្តនេះ **អវិសារ-លក្ខណោ** មានការមិនរវើរវាយជាលក្ខណៈ **អវិក្ខេបលក្ខណោ** វា ឬ មានការមិនរាយមាយជាលក្ខណៈ **សហជាតធម្មានំ សម្បិណ្ឌនរសោ** មានការប្រមូលមកនូវសហជាតធម៌ទាំងឡាយ ឲ្យចូលគ្នាជាកិច្ច ដូចទឹកប្រមូលលម្អិតសម្រាប់ងូតទឹក ( ឲ្យជាប់គ្នា ) **ឧបសមបច្ចុបដ្ឋានោ** មានការចូលទៅស្ងប់ជាអាការប្រាកដ **ញាណបច្ចុបដ្ឋានោ** វា ឬមានបញ្ញាជាអាការប្រាកដ អធិប្បាយថា បុគ្គលមានចិត្តតាំងមាំហើយ រមែងជ្រាបច្បាស់ រមែងឃើញតាមសេចក្តីពិត ពោលដោយពិសេស សមាធិ **សុខបទដ្ឋានោ** មានសុខជាហេតុជិត បណ្ឌិតគប្បីជ្រាបការតាំងនៅនៃចិត្ត ដូចការតាំងនៅនៃអណ្តាតប្រទីបទាំងឡាយ ក្នុងទីដែលប្រាសចាកខ្យល់ ដូច្នោះ ។

# អធិប្បាយ

## ពួកឥន្ទ្រិយមានសទ្ធាជាដើម

ធម៌ដែលឈ្មោះថា **សទ្ធា** ព្រោះអត្ថថា ជាហេតុឲ្យជឿ ឬជឿឯង ឬត្រឹមតែជាការជឿប៉ុណ្ណោះ ។ សទ្ធានោះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ជាអធិបតី ដោយគ្របសង្កត់ការមិនមានសទ្ធា ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃ ក្នុងការបង្អោនចិត្តជឿ ជាលក្ខណៈ ។ ឥន្ទ្រិយ គឺសទ្ធា ឈ្មោះថា **សទ្ធិន្ទ្រិយ** ។

សទ្ធានោះ **សម្បសាទនលក្ខណា** មានការជ្រះថ្លាជាលក្ខណៈ **សម្បក្ខន្ទនលក្ខណា** ច ឬមានការស្ទុះទៅជាលក្ខណៈ ។

សទ្ធា កាលកើតឡើង រមែងគ្របសង្កត់នីវរណៈទាំងឡាយ រមែងឲ្យកិលេសស្ងប់ រមែងឲ្យចិត្តផូរផង់ រមែងធ្វើចិត្តមិនឲ្យល្អក់ ដូចកែវមណីរបស់ស្តេចចក្កពត្តិ ដែលធ្វើទឹកឲ្យថ្លាស្អាត ដាក់ក្នុងទឹកហើយ អាចធ្វើឲ្យទឹកថ្លា រមែងធ្វើកក់ សារាយ ចក ល្បាប់ឲ្យស្ងប់ រមែងឲ្យទឹកថ្លាស្អាតមិនល្អក់ ដូច្នោះ ។ កុលបុត្តជាយោគាវចរឲ្យទានក្តី សមាទានសីលក្តី ធ្វើឧបោសថកម្មក្តី ចម្រើនភាវនាក្តី ដោយចិត្តផូរផង់ គប្បីជ្រាបសទ្ធានោះយ៉ាងនេះមុនថា មានសេចក្តីជ្រះថ្លា ជាលក្ខណៈ ព្រោះហេតុនោះ ទើបព្រះនាគសេនត្ថេរថ្វាយព្រះពរស្តេចមិលិន្ទថា បពិត្រមហារាជ ស្តេចចក្កពត្តិធ្វងស៊ីងតូច ព្រមទាំងចតុរង្គិនីសេនា ទឹកនោះប៉ះខ្ទប់ដោយដំរី សេះ រថ និងពលថ្មើរជើងទាំងឡាយ ក៏ល្អក់ជាល្បាប់ ព្រះរាជាទ្រង់ធ្វងទៅហើយ ទើបបញ្ជាមនុស្សទាំងឡាយថា នែអ្នក ចូរពួកអ្នកនាំទឹកផឹកមក យើងនឹងផឹកទឹកនោះ

ព្រះរាជាមានកែវមណីសម្រាប់ធ្វើទឹកឲ្យថ្លាស្អាត ពួកមនុស្សក៏ក្រាបទូលថា ព្រះករុណាថ្លៃវិសេស ហើយយកកែវមណីដែលធ្វើទឹកឲ្យថ្លានោះ ដាក់ក្នុងទឹក ។ ភក់ សារាយ ចក និងភក់ ក៏ស្ងប់ដំណាលគ្នានឹងការដាក់កែវមណីនោះទៅក្នុងទឹក ទឹកគប្បីជាទឹកថ្លាស្អាត មិនល្អក់ បន្ទាប់អំពីនោះ ពួកមនុស្សក៏បង្អោនទឹកផឹក ថ្វាយព្រះរាជា ក្រាបទូលថា សូមព្រះសម្មតិទេព ទ្រង់សោយទឹក ។

សូមថ្វាយព្រះពរមហារាជ ព្រះអង្គគប្បីឃើញចិត្តដូចទឹក គប្បីឃើញកុលបុត្តដែលជាយោគាវចរ ដូចមនុស្សទាំងនោះ គប្បីឃើញកិលេសទាំងឡាយដូចភក់ សារាយ ចក ល្បាប់ គប្បីឃើញសទ្ធាដូចកែវមណីដែលធ្វើទឹកឲ្យថ្លាស្អាត សូមថ្វាយព្រះពរមហារាជ សទ្ធា កាលកើត រមែងគ្របសង្កត់នីវរណៈទាំងឡាយ ចិត្តប្រាសចាកនីវរណៈក៏ថ្លាស្អាត មិនល្អក់ ដូចកាលដាក់កែវមណីដែលធ្វើទឹកឲ្យថ្លាស្អាតហើយ ភក់ សារាយ ចក ល្បាប់ រមែងស្ងប់ ទឹករមែងថ្លាស្អាតមិនល្អក់ ក៏ដូច្នោះ ។

ដូចពួកជនដែលខ្លាចមកដល់មហានទីដែលពេញច្រាំង ដែលដេរដាសដោយសត្វក្រពើ មករ និងអារក្សទឹកជាដើម ក៏ឈរត្រង់ច្រាំងស្ទឹងទាំងពីរ ចំណែកទាហានធំ អ្នកអង់អាចក្នុងសង្គ្រាមមកដល់ក៏សួរថា ព្រោះហេតុអ្វីទើបពួកលោកឈរ កាលពួកសេនាពោលថា ពួកយើងមិនអាចឆ្លង ព្រោះមានភ័យចំពោះមុខ ទើបចាប់ដាវដែលសំលៀងល្អហើយ ពោលថា ពួកលោកចូរមកខាងក្រោយយើង កុំខ្លាចឡើយ ហើយចុះទៅក្នុងស្ទឹងការពារ

ក្រពើជាដើម ដែលមកហើយ ធ្វើសួស្តីដល់ពួកមនុស្សទាំងឡាយ នាំអំពីត្រើយអាយទៅកាន់ត្រើយនាយ នាំអំពីត្រើយនាយ ទៅកាន់ត្រើយអាយ យ៉ាងណា កាលបុគ្គលឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ចម្រើនភាវនា សទ្ធា រមែងជាប្រធាន ជាភាវៈនាំមុខទៅ ព្រោះហេតុនោះ ទើបពោលថា សទ្ធា មានការស្ទុះទៅជាលក្ខណៈ ដូច្នេះ ។

ម្យ៉ាងទៀត សទ្ធា **សទ្ទហនលក្ខណា** មានការជឿជាលក្ខណៈ **ឱកប្បនលក្ខណា** វា ឬមានការផ្តោតចិត្តមាំជាលក្ខណៈ **បសាទនរសា** មានសេចក្តីថ្លៃថ្លាផង់ជាកិច្ច ដូចឧទកប្បសាទកមណី **បក្ខន្ទនរសា** វា ឬមានការស្ទុះទៅជាកិច្ច ដូចការឆ្លងអន្លង់ទឹក **អកាលុសិយបច្ចុប្បដ្ឋានា** មានការមិនល្អក់ជាអាការប្រាកដ **អធិមុត្តិបច្ចុប្បដ្ឋានា** វា ឬមានការបង្អោនចិត្តជឿជាអាការប្រាកដ **សទ្ធេយ្យវត្ថុបទដ្ឋានា** មានវត្ថុជាទីតាំងនៃសទ្ធា ជាហេតុជិត **សោតាបត្តិយង្គបទដ្ឋានា** វា ឬមានសោតាបត្តិយង្គៈជាហេតុជិត ។ បណ្ឌិតគប្បីឃើញសទ្ធាដូចដៃ ដូចទ្រព្យសម្បត្តិ និងដូចគ្រាប់ពូជ ។

ភាវៈនៃបុគ្គលដែលក្លាហាន ឈ្មោះថា **វីរិយៈ** ឬការងាររបស់បុគ្គលអ្នកក្លាហាន ឈ្មោះថា **វីរិយៈ** ឬថា ឈ្មោះថា **វីរិយៈ** ព្រោះអត្ថថា គប្បីប្រព្រឹត្តទៅ គឺឲ្យប្រព្រឹត្តទៅដោយវិធី គឺដោយន័យ ដោយឧបាយ ។ វីរិយៈនោះឯង ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ជាអធិបតី ដោយគ្របសង្កត់កោសជ្ជៈ ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃក្នុងលក្ខណៈនៃសេចក្តីព្យាយាម ។ សេចក្តីព្យាយាមនុ៎ះឯង ឈ្មោះថា

**វីរិយិន្ទ្រិយ ។**

*វីរិយៈនេះ* **ឧបត្ថម្ភនលក្ខណំ** *មានការឧបត្ថម្ភ គឺទ្រទ្រង់ទុកជាលក្ខណៈ* **បគ្គហណលក្ខណំ** *ច ឬមានការផ្គងទុកជាលក្ខណៈ ដូចផ្ទះចាស់ រមែងតាំងនៅបានដោយចន្ទល់ដែលទ្រទុកយ៉ាងណា ព្រះយោគាវចរក៏ដូចគ្នានុ៎ះឯង ជាអ្នកបានសេចក្តីព្យាយាមឧបត្ថម្ភហើយ រមែងមិនសាបសូន្យចាកកុសលធម៌ទាំងពួង ។ គប្បីជ្រាបភាពដែលវីរិយិន្ទ្រិយនោះ មានការឧបត្ថម្ភ គឺទ្រទ្រង់ទុកជាលក្ខណៈយ៉ាងនេះមុន ដោយហេតុនោះ ទើបព្រះនាគសេនត្ថេរថ្វាយព្រះពរស្តេចមិលិន្ទថា បពិត្រមហារាជ វីរិយៈ មានការឧបត្ថម្ភជាលក្ខណៈ កុសលធម៌ទាំងអស់ មានវីរិយៈឧបត្ថម្ភហើយ រមែងមិនវិនាសទៅ ដូចផ្ទះចាស់រកកល់នឹងដួល បុរសយកបង់បាញ់មកទល់ ផ្ទះដែលមានបង់បាញ់ទល់ហើយនោះ ក៏មិនគប្បីដួលទៅ ដូច្នោះ ។*

*ដូចកងទ័ពតូច និងកងទ័ពធំ ធ្វើសង្គ្រាមនឹងគ្នា កងទ័ពតូចដកថយមកពេលនោះ ពួកគេគប្បីក្រាបទូលព្រះរាជា ព្រះរាជាគប្បីបញ្ជូនពល និងពាហនៈទៅ កងទ័ពរបស់ព្រះអង្គដែលពល និងពាហនៈគាំទ្រហើយ គប្បីញ៉ាំងកងទ័ពរបស់សត្រូវឲ្យចាលចាញ់យ៉ាងណា វីរិយៈក៏យ៉ាងនុ៎ះឯង រមែងមិនធ្វើឲ្យសម្បយុត្តធម៌ដែលកើតព្រមគ្នា ឲ្យរួញរា ឲ្យថយត្រឡប់ រមែងលើក គឺរមែងផ្គង ដោយហេតុនោះ ទើបពោលថា* **វីរិយៈ** *មានការផ្គង ជាលក្ខណៈ ។*

*ម្យ៉ាងទៀត វីរិយៈ* **ឧស្សាហលក្ខណំ** *មានការខ្មីឃ្មាត ជាលក្ខណៈ*

**សហជាតធម្មានំ ឧបត្ថម្ភនរសំ** មានការឧបត្ថម្ភសហជាតធម៌ទាំងឡាយជាកិច្ច **អសំសីទនភាវបច្ចុប្បដ្ឋានំ** មានសេចក្តីមិនរាថយ ជាអាការប្រាកដ **សំវេគបទដ្ឋានំ** មានសេចក្តីសំវេគជាហេតុជិត ព្រោះព្រះបាលីថា ជាអ្នកតក់ស្លុត ទើបតម្កល់នូវសេចក្តីព្យាយាមដោយឧបាយនៃប្រាជ្ញា ដូច្នេះ **វីរយា–រម្ភវត្ថុបទដ្ឋានំ វា** ឬមានវត្ថុនៃការប្រារព្ធព្យាយាមជាហេតុជិត ។ បណ្ឌិតគប្បីជ្រាបថា សេចក្តីព្យាយាមដែលផ្តើមដោយប្រពៃ ជាហេតុនៃសម្បត្តិទាំងពួង ដូច្នេះ ។

ធម៌ដែលឈ្មោះថា **សតិ** ព្រោះជាហេតុរឭក ឬរមែងរឭកឯង ឬត្រឹមតែជាការរឭកប៉ុណ្ណោះ ។ សតិនោះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ជាអធិបតីដោយគ្របសង្កត់ភាពជាអ្នកមិនមានស្មារតី ។ មួយវិញទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំ ជាងធម៌ដទៃក្នុងលក្ខណៈនៃការប្រាកដ ។ ឥន្ទ្រិយ គឺសតិ ឈ្មោះថា **សតិន្ទ្រិយ** ៗ សតិនេះ **អបិលាបនលក្ខណា** មានការឲ្យរឭកជាលក្ខណៈ **ឧបគ្គណ្ហនលក្ខណា ច** ឬមានការចូលទៅផ្គងជាលក្ខណៈ សតិរមែងឲ្យកំណត់ រមែងឲ្យរឭកនូវកុសលធម៌ ដោយប្រពៃ ដូចអ្នករក្សាឃ្លាំងរបស់ព្រះរាជា រក្សារតនៈ ១០ ប្រការ ញុំាងព្រះរាជាឲ្យកំណត់ ឲ្យរឭកដល់ឥស្សរិយសម្បត្តិក្នុងវេលាល្ងាច និងក្នុងវេលាព្រឹក ដោយហេតុនោះ ទើបព្រះនាគសេនត្ថេរពោលថា បពិត្រមហារាជ អ្នករក្សាឃ្លាំងរបស់ស្តេចចក្កពត្តិ រមែងឲ្យស្តេចចក្កពត្តិទ្រង់រឭកឯង ដល់ឥស្សរិយសម្បត្តិទាំងក្នុងវេលាល្ងាច ទាំងក្នុងវេលាព្រឹកថា បពិត្រព្រះសម្មតិ–

ទេព ដំរីមានប្រមាណប៉ុណ្ណេះ សេះមានប្រមាណប៉ុណ្ណេះ រថមានប្រមាណប៉ុណ្ណេះ ពលថ្មើរជើងមានប្រមាណប៉ុណ្ណេះ ប្រាក់មានប្រមាណប៉ុណ្ណេះ មាសមានប្រមាណប៉ុណ្ណេះ សម្បត្តិទាំងពួងមានប្រមាណប៉ុណ្ណេះ សូមព្រះសម្មតិទេពរឭកដល់ឥស្សរិយសម្បត្តិនោះ យ៉ាងណា សូមថ្វាយព្រះពរមហារាជ សតិក៏យ៉ាងនោះដូចគ្នា រមែងឲ្យរឭកដល់កុសលធម៌ទាំងឡាយ គឺសតិប្បដ្ឋានទាំង ៤ នេះ សម្មប្បធានទាំង ៤ នេះ ឥទ្ធិបាទទាំង ៤ នេះ ឥន្ទ្រិយទាំង ៥ នេះ ពលទាំង ៥ នេះ ពោជ្ឈង្គទាំង ៧ នេះ នេះអរិយមគ្គប្រកបដោយអង្គ ៨ នេះសមថៈ នេះវិបស្សនា ទាំងនេះជាអរិយសច្ច នេះជាវិជ្ជា នេះជាវិមុត្តិ ទាំងនេះជាលោកុត្តរធម៌ មហាបពិត្រ សតិមានការឲ្យរឭកជាលក្ខណៈ យ៉ាងនេះឯង ។

សតិ ពិចារណាគតិទាំងឡាយនៃធម៌ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ដឹងថា ធម៌ទាំងឡាយ មានកាយទុច្ចរិតជាដើមទាំងនេះ មិនមានប្រយោជន៍ រមែងបន្ទោបង់ធម៌ដែលមិនជាប្រយោជន៍ ដឹងថា ធម៌ មានកាយសុចរិតជាដើម ទាំងនេះជាប្រយោជន៍ រមែងផ្គងធម៌ដែលជាប្រយោជន៍ ដូចបរិនាយកកែវរបស់ស្តេចចក្កពត្តិ ដឹងវត្ថុដែលមិនជាប្រយោជន៍ និងវត្ថុដែលជាប្រយោជន៍របស់ស្តេចចក្កពត្តិ រមែងនាំវត្ថុដែលមិនជាប្រយោជន៍ចេញទៅ រមែងបង្អោនចូលមកនូវវត្ថុជាប្រយោជន៍ ដោយហេតុនោះ ទើបព្រះនាគសេនត្ថេរ ថ្វាយព្រះពរព្រះរាជាថា បពិត្រមហារាជ បរិនាយកកែវរបស់ស្តេចចក្កពត្តិ រមែងដឹងវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ដល់

ស្តេចចក្កពត្តិថា វត្ថុទាំងនេះជាប្រយោជន៍ដល់ព្រះរាជា វត្ថុទាំងនេះមិនជាប្រយោជន៍ វត្ថុទាំងនេះជាឧបការៈ វត្ថុទាំងនេះមិនជាឧបការៈ ដូច្នេះ បន្ទាប់អំពីនោះ ក៏បន្ទោបង់ ( កម្ចាត់ ) វត្ថុមិនជាប្រយោជន៍ រមែងផ្គងវត្ថុដែលជាប្រយោជន៍ យ៉ាងណា សូមថ្វាយព្រះពរមហារាជ សតិក៏យ៉ាងនោះដូចគ្នា នោះឯង កាលកើតឡើង រមែងពិចារណាគតិទាំងឡាយនៃធម៌ ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ថា ធម៌ទាំងនេះជាប្រយោជន៍ ធម៌ទាំងនេះមិនជាប្រយោជន៍ ធម៌ទាំងនេះ មានឧបការៈ ធម៌ទាំងនេះ មិនមានឧបការៈ ដូច្នេះ បន្ទាប់អំពីនោះ រមែងបន្ទោបង់ធម៌ដែលមិនជាប្រយោជន៍ រមែងផ្គងធម៌ដែលជាប្រយោជន៍ បពិត្រមហារាជ សតិមានការផ្គងជាលក្ខណៈ យ៉ាងនេះឯង ។

ន័យម្យ៉ាងទៀត សតិ **អបិលាបនលក្ខណា** មានការរឭកជាលក្ខណៈ **អសម្មោសនរសា**[១] មានការមិនវង្វេងភ្លេចជាកិច្ច **អារក្ខបច្ចុប្បដ្ឋានា** មានការរក្សាជាអាការប្រាកដ **វិសយាភិមុខី ភាវបច្ចុបដ្ឋានា** មានការផ្ទោះមុខទៅកាន់អារម្មណ៍ជាហេតុជិត **ថិរសញ្ញាបទដ្ឋានា វា** ឬមានការចាំបានដ៏មាំទាំជាហេតុជិត **កាយាទិសតិប្បដ្ឋានបទដ្ឋានា វា** ឬមានសតិប្បដ្ឋានមានកាយានុបស្សនាសតិប្បដ្ឋានជាដើមជាអាការប្រាកដ បណ្ឌិតគប្បីឃើញសតិដូចសសរខឿន ព្រោះតាំងនៅមាំក្នុងអារម្មណ៍ និងដូចនាយទ្វារ ជាអ្នករក្សាទ្វារ ព្រោះរក្សាទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ។

---

១- ច្បាប់ខ្លះជា អសម្មោហនរសា តែក្នុងទីនេះ យើងកាន់យកតាមច្បាប់ឆដ្ឋសង្គាយនា ។

ធម៌ដែលឈ្មោះថា **សមាធិ** ព្រោះចិត្តតាំងមាំ គឺតាំងមាំដោយល្អក្នុងអារម្មណ៍ ។ សមាធិនោះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ជាអធិបតី ព្រោះគ្របសង្កត់សេចក្តីរាយមាយ ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈនៃការមិនរាយមាយ ។ ឥន្ទ្រិយ គឺសមាធិ ឈ្មោះថា **សមាធិន្ទ្រិយ** ធម៌ មានលក្ខណៈជាដើមរបស់សមាធិនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយ ខាងដើមនុ៎ះឯង ។

ធម៌ដែលឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ដឹងទូទៅ ។ សួរថា ដឹងទូទៅនូវអ្វី ឆ្លើយថា ដឹងទូទៅនូវអរិយសច្ចទាំងឡាយ ដោយន័យជាដើមថា នេះទុក្ខ ។ តែក្នុងអដ្ឋកថាលោកពោលថា ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ឲ្យដឹងទូទៅ ។ សួរថា ឲ្យដឹងទូទៅនូវអ្វី ឆ្លើយថា ឲ្យដឹងអនិច្ចំ ទុក្ខំ អនត្តា ។

បញ្ញានោះ ឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាអធិបតី ព្រោះគ្របសង្កត់អវិជ្ជា ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈនៃការឃើញ ។ ឥន្ទ្រិយ គឺបញ្ញា ឈ្មោះថា **បញ្ញិន្ទ្រិយ** ។ បញ្ញានោះ **ឱភាសនលក្ខណា** មានការបំភ្លឺជាលក្ខណៈ **បជាននលក្ខណា វា** ឬមានការដឹងទូទៅជាលក្ខណៈ ដូចកាលបុគ្គលអុជប្រទីបឲ្យភ្លឺក្នុងវេលាយប់ ក្នុងផ្ទះដែលមានជញ្ជាំង ៤ ទិស ងងឹតរមែងអស់ទៅ ពន្លឺរមែងប្រាកដយ៉ាងណា បញ្ញាមានការបំភ្លឺយ៉ាងនោះដូចគ្នា ។ ធម្មតាពន្លឺស្មើដោយពន្លឺរបស់បញ្ញា រមែងមិនមាន ។ មែនពិត កាលមហាបុរសអ្នកមានបញ្ញា

អន្ធយដោយក្អែនតែមួយ ម៉ឺនលោកធាតុក៏មានពន្លឺតែមួយ ។ ដោយហេតុនោះ ទើបព្រះនាគសេនត្ថេរពោលថា បពិត្រមហារាជ បុរសគប្បីយកប្រទីបចូលទៅតម្កល់ទុកក្នុងផ្ទះដែលងងឹត ប្រទីបដែលនាំចូលទៅហើយ រមែងកម្ចាត់បង់ងងឹត រមែងញុំាងឱភាសឲ្យកើតឡើង រមែងញុំាងពន្លឺឲ្យរុងរឿង រមែងធ្វើរូបទាំងឡាយ ឲ្យប្រាកដយ៉ាងណា បពិត្រមហារាជ បញ្ញាក៏យ៉ាងនោះដូចគ្នា កាលកើតឡើង រមែងកម្ចាត់បង់ងងឹត គឺអវិជ្ជា រមែងញុំាងឱភាស គឺវិជ្ជាឲ្យកើត រមែងញុំាងពន្លឺ គឺញាណឲ្យរុងរឿង និងរមែងធ្វើអរិយសច្ចទាំងឡាយ ឲ្យប្រាកដ បពិត្រមហារាជ បញ្ញាមានការបំភ្លឺ ជាលក្ខណៈ ដោយប្រការដូច្នេះឯង ។

ម្យ៉ាងទៀត បញ្ញា កាលកើតឡើង រមែងដឹងនូវធម៌ទាំងឡាយដែលជាកុសល និងអកុសលដែលគួរសេព និងមិនគួរសេព ថោកទាប និងប្រណីត ស និងខ្មៅ និងដែលចូលគ្នាបាន និងមិនចូលគ្នាបាន ដូចគ្រូពេទ្យអ្នកឈ្លាស រមែងដឹងនូវភេសជ្ជៈជាដើម ដែលជាទីសប្បាយ និងមិនជាទីសប្បាយ ដល់បុគ្គលអ្នកមានជំងឺ ដូច្នោះ ។ សមដូចពាក្យដែលព្រះធម្មសេនាបតី ពោលថា ម្នាលអាវុសោ បុគ្គលដែលចេះដឹងច្បាស់ហ្នឹងឯង ដែលហៅថា អ្នកមានប្រាជ្ញា ចុះបុគ្គលនោះដឹងច្បាស់នូវអ្វី ដឹងច្បាស់ថា នេះទុក្ខ ដូច្នេះ សេចក្តីនេះ បណ្ឌិតគប្បីឲ្យពិស្តារ ។ គប្បីជ្រាបថា បញ្ញានោះ មានការដឹងទូទៅជាលក្ខណៈ ដោយប្រការដូច្នេះ ។

ន័យម្យ៉ាងទៀត បញ្ញា **យថាសភាវបដិវេធលក្ខណា** មានការចាក់

ចុះតាមសេចក្តីពិតជាលក្ខណៈ **អក្ខលិតបដិវេធលក្ខណា** វា ឬមានការចាក់ធ្លុះ មិនភ្លាំងភ្លាត់ជាលក្ខណៈ ដូចការចាក់របស់កូនសរដែលនាយខ្មាន់ធ្នូអ្នកឈ្លាសបាញ់ទៅ ដូច្នោះ **វិសយោភាសរសា** មានការបំភ្លឺឲ្យឃើញអារម្មណ៍ជាកិច្ច ដូចប្រទីប **អសម្មោហបច្ចុបដ្ឋានា** មានការមិនវង្វេងជាអាការប្រាកដ ដូចអ្នកចង្អុលផ្លូវត្រូវដល់បុគ្គលដែលទៅព្រៃ ។

ធម៌ដែលឈ្មោះថា **មនៈ** ព្រោះដឹង អធិប្បាយថា ដឹងច្បាស់ ។ តែព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ឈ្មោះថា **មនៈ** ព្រោះស្ទាបស្ទង់ គឺដឹងអារម្មណ៍ ដូចបុគ្គលវាស់ដោយនាឡិ និងដូចបុគ្គលថ្លឹងដោយជញ្ជីងធំដូច្នោះ ។ មនៈនោះឯង ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈនៃការដឹង ។ ឥន្ទ្រិយ គឺមនៈ ឈ្មោះថា មនិន្ទ្រិយ ។ មនៈនេះជាពាក្យវេវចនៈរបស់ចិត្ត តាមដែលពោលហើយខាងដើម ។

បុគ្គល ឈ្មោះថា **សុមនៈ** ព្រោះមានចិត្តស្អាត ព្រោះប្រកបដោយបីតិនិងសោមនស្ស ។ ភាវៈនៃបុគ្គលអ្នកមានចិត្តល្អ ឈ្មោះថា **សោមនស្ស** សោមនស្សនោះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំ ជាងធម៌ដទៃក្នុងលក្ខណៈនៃសេចក្តីត្រេកអរ ។ ឥន្ទ្រិយ គឺសោមនស្ស ឈ្មោះថា **សោមនស្សិន្ទ្រិយ** សោមនស្សិន្ទ្រិយនេះ ជាវេវចនៈរបស់វេទនាតាមដែលពោលហើយ ខាងដើមនោះឯង ។

ធម៌ដែលឈ្មោះថា **ជីវិត** ព្រោះជាហេតុឲ្យធម៌ដែលសម្បយុត្តដោយធម៌នោះរស់នៅ ។ ជីវិតនោះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាង

ធម៌ដទៃ ក្នុងលក្ខណៈនៃការតាមរក្សា ។ ឥន្ទ្រិយ គឺជីវិត ឈ្មោះថា **ជីវិ-តិន្ទ្រិយ** ជីវិតិន្ទ្រិយនោះជាអធិបតីក្នុងការប្រព្រឹត្តទៅនិងបន្ត ។ កាលពោលដោយលក្ខណៈរបស់ខ្លួនជាដើម ជីវិតិន្ទ្រិយ **អនុបាលនលក្ខណា** មានការតាមរក្សាធម៌ដែលកើតហើយដោយមិនប្រាសចាកខ្លួនជាលក្ខណៈ **បវត្តនរសំ** មានការប្រព្រឹត្តិទៅនៃសម្បយុត្តធម៌ទាំងនោះជាកិច្ច **ឋបនបច្ចុបដ្ឋានំ** មានការតម្រង់នៅនៃសម្បយុត្តធម៌ទាំងនោះនុ៎ះឯង ជាអាការៈប្រាកដ **យាបយិ-តព្វធម្មបទដ្ឋានំ** មានធម៌ ( គឺវេទនា សញ្ញា វិញ្ញាណ ) ដែលរស់នៅជាហេតុជិត ។ កាលមានការទ្រទ្រង់ មានការតាមរក្សាជាលក្ខណៈជាដើម ជីវិតិន្ទ្រិយ ក៏រមែងតាមរក្សាធម៌ដែលមានក្នុងខណៈដែលមានប៉ុណ្ណោះ ដូចទឹកតាមរក្សានូវផ្កាឧប្បលជាដើម ម្យ៉ាងទៀត រមែងតាមរក្សាធម៌ទាំងឡាយដែលកើតឡើងព្រោះបច្ច័យ តាមសមគួរដល់ខ្លួន ដូចមេដោះចិញ្ចឹមទារក និងឲ្យប្រព្រឹត្តទៅដោយសម្ពន្ធនឹងធម៌ដែលខ្លួនឲ្យប្រព្រឹត្តទៅឯង ដូចអ្នកកាន់ចង្កូតទូក ញុំាងទូកឲ្យអណ្តែតទៅ ជីវិតិន្ទ្រិយនោះ ឲ្យប្រព្រឹត្តលើភង្គក្ខណៈមិនបាន ព្រោះភាវៈនៃខ្លួន និងធម៌ដែលខ្លួនឲ្យប្រព្រឹត្តទៅ មិនមានរមែងមិនតាំងនៅក្នុងភង្គក្ខណៈ ព្រោះខ្លួនឯងក៏ត្រូវរលត់ ដូចប្រេងក្នុងប្រទេះអស់ទៅ អណ្តាតប្រទីបក៏រលត់ទៅ បណ្ឌិតមិនគប្បីឃើញថា ជីវិតិន្ទ្រិយវៀរចាកអានុភាពនៃការតាមរក្សា ការឲ្យប្រព្រឹត្តទៅ ការតម្រង់ទុក ព្រោះធ្វើការតាមរក្សាជាដើមនោះៗ ឲ្យសម្រេចក្នុងខណៈតាមដែលពោលហើយ ។

# អធិប្បាយ

## ពួកអដ្ឋមគ្គមានសម្មាទិដ្ឋិជាដើម

គប្បីជ្រាបវិគ្គហៈក្នុងបទថា **សម្មាទិដ្ឋិ** ជាដើម ដូចតទៅនេះ

អដ្ឋមគ្គដែលឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា ឃើញ ។ ឈ្មោះថា **សម្មាសង្កប្ប** ព្រោះអត្ថថា លើកឡើង ។ ឈ្មោះថា **សម្មាវាយាម** ព្រោះអត្ថថា ផ្គង ។ ឈ្មោះថា **សម្មាសតិ** ព្រោះអត្ថថា ប្រាកដ ឈ្មោះថា **សម្មាសមាធិ** ព្រោះអត្ថថា មិនរវើរវាយ ។ បើពោលដោយវចនត្ថៈ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះឃើញត្រូវ ឬថា ជាហេតុឲ្យឃើញត្រូវ ។ ឈ្មោះថា **សម្មាសង្កប្ប** ព្រោះត្រិះរិះត្រូវ ឬជាហេតុឲ្យត្រិះរិះត្រូវ ។ ឈ្មោះថា **សម្មាវាយាម** ព្រោះព្យាយាមត្រូវ ឬថា ជាហេតុឲ្យព្យាយាមត្រូវ ។ ឈ្មោះថា **សម្មាសតិ** ព្រោះរឭកត្រូវ ឬថា ជាហេតុឲ្យរឭកត្រូវ ។ មយ៉ាងទៀត គប្បីជ្រាបវចនត្ថៈរបស់អដ្ឋមគ្គនោះៗ ដោយន័យនេះថា ទិដ្ឋិដែលបណ្ឌិតសរសើរហើយ ជាទិដ្ឋិល្អ ឈ្មោះថា **សម្មាទិដ្ឋិ** ។ ចំណែកធម៌ មានលក្ខណៈជាដើម ខ្ញុំបានពោលហើយខាងដើមនុ៎ះឯង ។

# អធិប្បាយ

## ពួកពលមានសទ្ធាជាដើម

គប្បីជ្រាបវិគ្គហៈក្នុងបទថា **សទ្ធាពល** ជាដើមដូចតទៅ

សទ្ធាពលជាដើម មានអត្ថតាមដែលពោលហើយនោះឯង តែគប្បីជ្រាបថា ឈ្មោះថា ពល ព្រោះថា មិនញាប់ញ័រ ។ បណ្ដាធម៌ទាំងនោះ ធម៌ដែលឈ្មោះថា **សទ្ធាពល** ព្រោះមិនញាប់ញ័រ ក្នុងភាពជាអ្នកមិនមានសទ្ធា ឈ្មោះថា **វីរិយពល** ព្រោះមិនញាប់ញ័រ ក្នុងសេចក្ដីខ្ជិលច្រអូស ឈ្មោះថា **សតិពល** ព្រោះមិនញាប់ញ័រ ក្នុងការមិនមានសតិ ឈ្មោះថា **សមាធិពល** ព្រោះមិនញាប់ញ័រក្នុងការរាយមាយ ឈ្មោះថា **បញ្ញាពល** ព្រោះមិនញាប់ញ័រក្នុងអវិជ្ជា ។ ឈ្មោះថា **ហិរិពល** ព្រោះមិនញាប់ញ័រ ក្នុងការមិនខ្មាសបាប ឈ្មោះថា **ឱត្តប្បពល** ព្រោះមិនញាប់ញ័រក្នុងការមិនខ្លាចបាប នេះជាការពណ៌នាអត្ថដោយអំណាចបទទាំងពីរដោយប្រការដូច្នេះ ។

បណ្ដាពលទាំង ៧ នោះ ពល ៥ ខាងដើម ខ្ញុំប្រកាសហើយក្នុងខាងដើម ដោយលក្ខណៈជាដើមនុ៎ះឯង ។ គប្បីជ្រាបវិគ្គហៈពល ២ ខាងចុងដូចតទៅនេះ ធម៌ ដែលឈ្មោះថា **ហិរិ** ព្រោះខ្មាសចំពោះកាយទុច្ចរិតជាដើម ពាក្យថា ហិរិនេះ ជាឈ្មោះនៃការខ្មាស ឈ្មោះថា **ឱត្តប្បៈ** ព្រោះខ្លាចចំពោះកាយទុច្ចរិតជាដើមនោះដូចគ្នា ពាក្យថា ឱត្តប្បៈនេះ ជាឈ្មោះនៃការខ្លាចចំពោះបាប ។ ដើម្បីសម្ដែងការផ្សេងគ្នានៃហិរិ និងឱត្តប្បៈទាំង ២ នោះ ទើបលោកតាំងមាតិកានេះថា សមុដ្ឋាន អធិបតី ការខ្មាស ការខ្លាច និងលក្ខណៈ ហើយពោលពាក្យដោយពិស្ដារដូច្នេះថា

**ហិរិ** មានហេតុខាងក្នុងជាសមុដ្ឋាន **ឱត្តប្បៈ** មានហេតុខាងក្រៅ ជាសមុដ្ឋាន **ហិរិ** មានខ្លួនជាអធិបតី **ឱត្តប្បៈ** មានលោកជាអធិបតី **ហិរិ** តាំងនៅដោយសភាពនៃការខ្មាស **ឱត្តប្បៈ** តាំងនៅដោយសភាពនៃការខ្លាច **ហិរិ** មានការគោរពជឿស្តាប់ជាលក្ខណៈ **ឱត្តប្បៈ** មានការខ្លាចទោស និងឃើញភ័យជាលក្ខណៈ ។

បណ្តាហិរិ និងឱត្តប្បៈទាំងនោះ បុគ្គលរមែងឲ្យហិរិដែលមានហេតុខាងក្នុងជាសមុដ្ឋានតាំងឡើង ដោយហេតុ ៤ គឺពិចារណាដល់ជាតិ ពិចារណាដល់វ័យ ពិចារណាដល់ភាពជាអ្នកអង់អាច ពិចារណាដល់ភាពជាពហូស្សូត ។ សួរថា ពិចារណាដូចម្តេច ឆ្លើយថា ខាងដើមបុគ្គលពិចារណាដល់ជាតិយ៉ាងនេះថា ដែលឈ្មោះថា ការធ្វើអំពើអាក្រក់នេះ មិនមែនកម្មរបស់បុគ្គលដែលបរិបូរណ៍ដោយជាតិ ការងារនេះ ជារបស់បុគ្គលអ្នកមានជាតិថោកថយមានពួកអ្នកនេសាទជាដើម ការធ្វើកម្មនេះ មិនសមគួរដល់បុគ្គលដែលបរិបូរណ៍ដោយជាតិ អម្បាលដូចអាត្មាអញ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា ញ៉ាំងហិរិឲ្យតាំងឡើង ។ មួយទៀត បុគ្គលពិចារណាដល់វ័យយ៉ាងនេះថា ដែលឈ្មោះថា ការធ្វើបាបនេះ ជាការធ្វើដែលពួកក្មេងៗ ទាំងឡាយគប្បីធ្វើ ការធ្វើកម្មនេះ មិនសមគួរដល់អ្នកដែលស្ថិតនៅក្នុងវ័យដូចជាអញ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា រមែងញ៉ាំងហិរិឲ្យតាំងឡើង ។ មួយទៀត បុគ្គលពិចារណាដល់ភាពជាអ្នកក្លៀវក្លាយ៉ាងនេះថា ដែលឈ្មោះថា ការធ្វើបាបនេះ ជាការធ្វើរបស់បុគ្គលដែល

មានជាតិជាអ្នកទន់ខ្សោយ ការធ្វើកម្មនេះ មិនសមគួរដល់បុគ្គលដែលបរិបូរណ៍ដោយភាពក្លៀវក្លាដូចជាអញ ហើយមិនធ្វើបាបមានបាណាតិបាតជាដើម ឈ្មោះថា រមែងញ៉ាំងហិរិឲ្យតាំងឡើង ។ មួយទៀត បុគ្គលពិចារណាដល់ភាពជាពហូសូតយ៉ាងនេះថា ដែលឈ្មោះថា ការធ្វើបាបនេះ ជាការធ្វើរបស់បុគ្គលអន្ធពាល មិនមែនរបស់បណ្ឌិត ការធ្វើកម្មនេះ មិនសមគួរដល់បុគ្គល ដែលជាពហូសូត ដែលជាបណ្ឌិតដូចជាអញ ហើយមិនធ្វើបាបមានបាណាតិបាតជាដើម ឈ្មោះថា រមែងញ៉ាំងហិរិឲ្យតាំងឡើង ។ បុគ្គលឈ្មោះថា ញ៉ាំងហិរិដែលមានហេតុខាងក្នុងជាសមុដ្ឋានឲ្យតាំងឡើង ដោយហេតុ ៤ យ៉ាង ដោយអាការយ៉ាងនេះ ។ កាលឲ្យតាំងឡើង គឺឲ្យហិរិចូលទៅក្នុងចិត្តរបស់ខ្លួនហើយ រមែងមិនធ្វើបាបកម្ម ។ ឈ្មោះថា **ហិរិ** មានហេតុខាងក្នុងជាសមុដ្ឋាន ដោយប្រការដូច្នេះ ។

សួរថា ឈ្មោះថា **ឱត្តប្បៈ** មានហេតុខាងក្រៅជាសមុដ្ឋាន ដូចម្ដេច ឆ្លើយថា ពិតហើយ បុគ្គលកាលពិចារណាយ៉ាងនេះថា បើអ្នកធ្វើបាប អ្នកក៏នឹងត្រូវបរិស័ទ ៤ តិះដៀល

> វិញ្ញូជនទាំងឡាយ នឹងតិះដៀលអ្នក ដូចអ្នកនគរតិះដៀល
> របស់មិនស្អាត នែភិក្ខុ អ្នកត្រូវបុគ្គលមានសីលលះបង់នឹង
> ធ្វើដូចម្ដេច ដូច្នេះ ។

បុគ្គលនោះ រមែងមិនធ្វើបាបកម្ម ព្រោះឱត្តប្បៈដែលមានហេតុខាងក្រៅជាសមុដ្ឋាន ។ ឈ្មោះថា **ឱត្តប្បៈ** មានហេតុខាងក្រៅជាសមុដ្ឋាន ដោយ

ប្រការដូច្នេះ ។

សួរថា ឈ្មោះថា **ហិរិ** មានខ្លួនជាអធិបតី តើដូចម្ដេច ឆ្លើយថា កុលបុត្តពួកខ្លះ ក្នុងលោកនេះ ធ្វើខ្លួនឲ្យជាធំ ឲ្យជាប្រធាន ហើយគិតថា ការធ្វើអំពីអាក្រក់ មិនសមគួរដល់បុគ្គលដូចអញ ដែលបួសដោយសទ្ធា ជាពហូសូត ជាអ្នកបដិបត្តិធុតង្គ ហើយមិនធ្វើបាបកម្ម ។ ឈ្មោះថា **ហិរិ** មានខ្លួនជាអធិបតីយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា ភិក្ខុនេះ ធ្វើខ្លួនឯងឲ្យជាអាធិបតេយ្យ ហើយ រមែងលះបង់អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ដូច្នេះ ។

សួរថា ឈ្មោះថា **ឱត្តប្បៈ** មានលោកជាអធិបតី ដូចម្ដេច ឆ្លើយថា កុលបុត្តពួកខ្លះ ក្នុងលោកនេះ ធ្វើលោកឲ្យជាធំ ឲ្យជាប្រធាន ហើយមិនធ្វើបាបកម្ម ដូចព្រះតម្រាស់ថា លោកសន្និវាសនេះសោតក៏ធំ ទោះក្នុងលោកសន្និវាសធំមែន ក៏គង់មានសមណព្រាហ្មណ៍ ជាអ្នកមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តបុគ្គលដទៃ ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងច្បាស់នូវចិត្តដោយចិត្ត ពួកសមណព្រាហ្មណ៍ទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្តនេះ ចេញចាកផ្ទះ មកបួសដោយសទ្ធាហើយ នៅតែប្របូកប្របល់ដោយធម៌ជាអកុសលដ៏លាមក ។ ម្យ៉ាងទៀត គង់មានពួកទេវតាដែលមានឫទ្ធិ មានទិព្វចក្ខុដឹងចិត្តបុគ្គលដទៃ ពួកទេវតាទាំងនោះ តែងឃើញ

អំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងចិត្តដោយចិត្ត ពួកទេវតាទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្តនេះ ចេញចាកផ្ទះ មកបួសដោយសទ្ធាហើយ នៅតែប្របូកប្របល់ដោយធម៌ជាអកុសលដ៏លាមក ... លុះភិក្ខុនោះប្រារព្ធលោក ឲ្យជាអាធិបតេយ្យហើយ តែងលះបង់អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាតដូច្នេះ ឈ្មោះថា **ឱត្តប្បៈ** មានលោកជាអធិបតី ដោយប្រការដូច្នេះ ។

បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងពាក្យថា ហិរិដែលតាំងឡើងដោយសភាវៈ គឺសេចក្ដីខ្មាស និងឱត្តប្បៈដែលតាំងឡើងដោយសភាវៈ គឺសេចក្ដីខ្លាចតទៅ ពាក្យថា **ខ្មាស** បានដល់ អាការដែលគួរខ្មាស អធិប្បាយថា ហិរិតាំងនៅដោយសភាវៈដែលគួរខ្មាសនោះ ។ ពាក្យថា **ខ្លាច** បានដល់ ខ្លាចអបាយ អធិប្បាយថា ឱត្តប្បៈតាំងនៅដោយសភាវៈដែលខ្លាចនោះ ។ ហិរិនិងឱត្តប្បៈទាំងពីរនោះ រមែងប្រាកដក្នុងការវៀរចាកអំពើអាក្រក់ ។ ពិតហើយ ជនពួកខ្លះឈានចុះកាន់ធម៌ គឺសេចក្ដីខ្មាសក្នុងខាងក្នុង រមែងមិនធ្វើបាបដូចកុលបុត្តពួកខ្លះ ធ្វើការបន្ទោបង់ឧច្ចារបស្សាវៈជាដើម ឃើញបុគ្គលតែម្នាក់ដែលខ្លួនគួរខ្មាស ក៏គប្បីដល់នូវអាការខ្មាស គប្បីពួនហើយ ជាអ្នកខ្មាសហើយ ( មិនធ្វើការបន្ទោបង់ឧច្ចារបស្សាវៈ ) ដូច្នោះ ។ ជនពួកខ្លះជាអ្នកខ្លាចចំពោះភ័យក្នុងអបាយហើយ ក៏មិនធ្វើបាបកម្ម ។

ក្នុងអធិការនៃហិរិ និងឱត្តប្បៈនោះ មានសេចក្ដីឧបមាដូច្នេះ ប្រៀបដូច

ដុំដែក ២ ដុំ មួយដុំត្រជាក់តែប្រឡាក់លាមក មួយដុំក្តៅ បណ្តាដុំដែកទាំង ២ នោះ បណ្ឌិតរង្កៀសចំពោះដុំដែកដែលត្រជាក់តែប្រឡាក់លាមក ទើបមិនចាប់ រង្កៀសដុំដែកក្តៅនេះ ព្រោះខ្លាចចំពោះក្តៅ ទើបមិនចាប់ ។ ក្នុងឧបមានោះ គប្បីជ្រាបការដែលបុគ្គលឈានចុះកាន់ធម៌ គឺសេចក្តីខ្មាសខាងក្នុងហើយមិនធ្វើបាប ដូចការមិនចាប់ដុំដែកត្រជាក់ ដែលប្រឡាក់លាមក ព្រោះសេចក្តីរង្កៀស ។ គប្បីជ្រាបការមិនធ្វើបាប ព្រោះខ្លាចអបាយ ដូចបុគ្គលមិនចាប់ដុំដែកក្តៅ ព្រោះខ្លាចក្តៅ ដូច្នោះ ។

ហិរិ មានសេចក្តីគោរពជឿស្តាប់ជាលក្ខណៈ ឱត្តប្បៈមានសេចក្តីខ្លាចទោស និងឃើញនូវភ័យជាលក្ខណៈ ។ ព្រោះហេតុនោះ ធម៌ទាំង ២ នេះ ទើបប្រាកដក្នុងការវៀរចាកបាបដូចគ្នា ។ ពិតហើយ ជនពួកខ្លះញុំាងហិរិដែលមានសេចក្តីគោរពជឿស្តាប់ជាលក្ខណៈ ឲ្យតាំងឡើងដោយហេតុ ៤ គឺ ពិចារណាដល់ជាតិដែលជាធំ ពិចារណាដល់សាស្តាដែលជាធំ ពិចារណាដល់ភាពជាទាយាទដែលជាធំ ពិចារណាដល់សព្រហ្មចារីដែលជាធំ ហើយមិនធ្វើបាប ។ ជនពួកខ្លះ ញុំាងឱត្តប្បៈដែលមានសេចក្តីខ្លាចទោស និងឃើញភ័យជាលក្ខណៈ ឲ្យតាំងឡើងដោយហេតុ ៤ គឺភ័យកើតអំពីការតិះដៀលខ្លួនឯង ១ ភ័យកើតអំពីការតិះដៀលរបស់អ្នកដទៃ ១ ភ័យកើតអំពីអាជ្ញា ១ ភ័យកើតអំពីទុគ្គតិ ១ ហើយមិនធ្វើបាប ។ បណ្តាហេតុទាំង ៨ នោះ បណ្ឌិតគប្បីពោលដល់ការពិចារណាជាតិដែលជាធំជាដើម និងភ័យកើតអំពីការតិះដៀលខ្លួនឯងជាដើមឲ្យពិស្តារ ។

# អធិប្បាយ

## ពួកធម៌ដែលជាមូលមានអលោភៈជាដើម

ធម៌ដែលឈ្មោះថា **អលោភៈ** ព្រោះមិនជាហេតុឲ្យលោភ ឬថា ខ្លួនឯងមិនលោភ ឬត្រឹមតែជាសេចក្ដីមិនលោភ ។ សូម្បីក្នុងអទោសៈ និងអមោហៈ ក៏ន័យនេះដូចគ្នា បណ្ដាធម៌ទាំង ៣ នោះ ។

អលោភៈ **អគេធលក្ខណោ** មានចិត្តមិនត្រេកអរក្នុងអារម្មណ៍ជាលក្ខណៈ **អលគ្គភាវលក្ខណោ វា** ឬមានភាវៈនៃចិត្តមិនជាប់ជំពាក់ក្នុងអារម្មណ៍ជាលក្ខណៈ ដូចដំណក់ទឹកមិនជាប់លើស្លឹកឈូក **អបរិគ្គហរសោ** មានការមិនហួងហែងជាកិច្ច ដូចភិក្ខុរួចផុតហើយ **អនល្លីនភាវបច្ចុបដ្ឋានោ** មានការមិនជាប់ចិត្តជាអាការប្រាកដ ដូចបុរសអ្នកធ្លាក់ទៅក្នុង ( រណ្ដៅ ) របស់មិនស្អាត មិនជាប់ចិត្ត ដូច្នោះ ។

អទោសៈ **អចណ្ឌិក្កលក្ខណោ** មានការមិនកាចជាលក្ខណៈ **អវិរោធលក្ខណោ វា** ឬមានការមិនទទឹងក្រោធជាលក្ខណៈ ដូចមិត្តអ្នកជួយសង្គ្រោះ **អឃាតវិនយរសោ** មានការកម្ចាត់នូវសេចក្ដីចងអាឃាតជាកិច្ច **បរិឡាហវិនយរសោ វា** ឬមានការកម្ចាត់សេចក្ដីក្ដៅក្រហាយជាកិច្ច ដូចខ្លឹមចន្ទន៍ **សោម្មភាវបច្ចុបដ្ឋានោ** មានសេចក្ដីត្រជាក់ជាអាការប្រាកដ ដូចព្រះចន្ទពេញបូណ៌មី ។ ចំណែកអមោហៈ ព្រមទាំងលក្ខណៈជាដើម លោកតាំងបទអធិប្បាយដូចបញ្ញិន្ទ្រិយ តាមដែលពោលមកហើយខាងដើមនុ៎ះឯង ។

មួយទៀត ក្នុងធម៌ទាំង ៣ នេះ អលោភៈជាសត្រូវចំពោះមន្ទិល គឺ

សេចក្ដីកំណាញ់ អទោសៈជាសត្រូវចំពោះមន្ទិល គឺភាពជាអ្នកទ្រុស្ដសីល អមោហៈជាសត្រូវចំពោះសេចក្ដីមិនចម្រើនក្នុងកុសលធម៌ទាំងឡាយ ។ ក្នុងគុណធម៌ទាំងនោះ អលោភៈ ជាហេតុនៃទាន អទោសៈ ជាហេតុនៃសីល អមោហៈ ជាហេតុនៃភាវនា ។ បណ្ដាគុណធម៌ទាំងនោះ បុគ្គលមានសេចក្ដីមិនលោភ រមែងកាន់យកមិនច្រើន ព្រោះអ្នកលោភ ទើបកាន់យកច្រើន បុគ្គលមិនមានទោសៈ រមែងកាន់យកមិនខ្វះខាត ( រក្សាសីលមិនខ្វះខាត ) ព្រោះបុគ្គលត្រូវទោសៈប្រទូស្ដ ទើបកាន់យកខ្វះខាត ។ បុគ្គលមិនវង្វេង រមែងកាន់យកមិនវិបរិត ព្រោះអ្នកវង្វេង ទើបកាន់យកវិបរិត ។

មួយទៀត ក្នុងគុណធម៌ទាំងនេះ បុគ្គលទ្រទ្រង់ចាំទោសដែលមាននៅដោយភាពជាទោស រមែងបើកបង្ហាញទោសទាំងឡាយទៅ ព្រោះការមិនលោភ ព្រោះថា បុគ្គលលោភហើយ រមែងបិទបាំងទោស ។ បុគ្គលទ្រទ្រង់ចាំគុណដែលមាននៅដោយភាពជាគុណ រមែងប្រកាសគុណទាំងឡាយ ឲ្យប្រព្រឹត្តទៅ ព្រោះការមិនមានទោសៈ ព្រោះថា បុគ្គលមានទោសៈប្រទូស្ដហើយ រមែងលុបគុណអ្នកដទៃ ។ បុគ្គលទ្រទ្រង់ចាំនូវសភាវៈតាមសេចក្ដីពិតដោយសភាវៈតាមសេចក្ដីពិត រមែងប្រកាសសភាវៈតាមសេចក្ដីពិត ឲ្យប្រព្រឹត្តទៅ ព្រោះសេចក្ដីមិនវង្វេង ព្រោះថា បុគ្គលវង្វេងហើយ រមែងកាន់យកវត្ថុដែលពិត ថាជាវត្ថុដែលមិនពិត កាន់យកវត្ថុដែលមិនពិត ថាជាវត្ថុដែលពិត ។

មួយទៀត ទុក្ខមានការព្រាត់ប្រាសចាករបស់ដែលជាទីស្រឡាញ់ រមែង

មិនមានព្រោះការមិនលោភ ព្រោះមនុស្សលោភហើយ មានសភាវៈនៃរបស់ជាទីស្រឡាញ់ និងព្រោះអត់ធន់ចំពោះការព្រាត់ប្រាសចាករបស់ដែលជាទីស្រឡាញ់មិនបាន ។ ទុក្ខដែលជួបនឹងរបស់ដែលមិនជាទីស្រឡាញ់ រមែងមិនមានព្រោះមិនមានទោសៈ ព្រោះបុគ្គលមានទោសៈប្រទូស្ត មានសភាវៈកាន់យកវត្ថុដែលមិនជាទីស្រឡាញ់ និងព្រោះអត់ធន់ ចំពោះការជួបនឹងវត្ថុដែលមិនជាទីស្រឡាញ់មិនបាន ។ ទុក្ខមានការមិនបានវត្ថុ ដែលគួរប្រាថ្នារមែងមិនមាន ព្រោះសេចក្តីមិនវង្វេង ព្រោះបុគ្គលអ្នកមិនវង្វេង មានការចម្រើន ពិចារណាយ៉ាងនេះថា ពួកអ្នកគប្បីបានវត្ថុនោះក្នុងទីនេះ អំពីទីណាជាដើម ។

មួយទៀត បណ្តាគុណធម៌ទាំងនេះ ជាតិទុក្ខរមែងមិនមាន ព្រោះអលោភៈ ព្រោះអលោភៈជាបដិបក្ខចំពោះតណ្ហា និងព្រោះជាតិទុក្ខ មានតណ្ហាជាមូល ។ ជរាទុក្ខរមែងមិនមានព្រោះអទោសៈ ព្រោះបុគ្គលមានទោសៈក្តៅក្លា ជាអ្នកមានសភាវៈ គឺកាពជរាយ៉ាងឆាប់រហ័ស ។ មរណទុក្ខរមែងមិនមានព្រោះអមោហៈ ព្រោះការស្លាប់របស់បុគ្គលដែលវង្វេងជាទុក្ខ តែទុក្ខនោះ រមែងមិនមានដល់បុគ្គលដែលមិនវង្វេង ។

មួយទៀត ការនៅរួមគ្នាជាសុខរបស់គ្រហស្ថទាំងឡាយ ព្រោះការមិនលោភ ការនៅរួមគ្នាជាសុខរបស់បព្វជិតទាំងឡាយព្រោះការមិនវង្វេង ការនៅរួមគ្នាជាសុខរបស់គ្រហស្ថ និងបព្វជិត សូម្បីទាំងអស់ ព្រោះការមិនមានទោសៈ ។

មួយទៀត ពោលដោយពិសេស ក្នុងគុណធម៌ទាំងនោះ ការកើតឡើងក្នុងបិត្តិវិស័យ រមែងមិនមានព្រោះការមិនលោភ ។ ពិតហើយ សត្វទាំងឡាយដោយច្រើន រមែងចូលដល់បិត្តិវិស័យ ព្រោះតណ្ហា តែការមិនលោភជាបដិបក្ខចំពោះតណ្ហា ។ ការកើតក្នុងនរក រមែងមិនមានព្រោះការមិនមានទោសៈ ពិតហើយ សត្វទាំងឡាយ រមែងចូលដល់នរកព្រោះទោសៈ ដ្បិតនរកដូចគ្នានឹងទោសៈ ព្រោះជាធម្មជាតអាក្រក់ តែអទោសៈជាបដិបក្ខចំពោះទោសៈ ។ ការកើតក្នុងកំណើតសត្វតិរច្ឆាន រមែងមិនមាន ព្រោះការមិនវង្វេង មែនពិត សត្វទាំងឡាយអ្នកវង្វេងជានិច្ច រមែងចូលដល់កំណើតសត្វតិរច្ឆានព្រោះមោហៈ តែអមោហៈជាបដិបក្ខចំពោះមោហៈ ។ បណ្តាគុណធម៌ទាំងនោះ អលោភៈ រមែងមិនធ្វើនូវការជាប់ជំពាក់ដោយអំណាចនៃរាគៈ អទោសៈ រមែងមិនធ្វើនូវការជាប់ជំពាក់ដោយអំណាចនៃទោសៈ អមោហៈ រមែងមិនធ្វើភាពមិនជាកណ្តាលដោយអំណាចនៃមោហៈ ។

មួយទៀត ពោលដោយគុណធម៌ទាំងនេះ សូម្បីទាំង ៣ រមែងបានសញ្ញាទាំង ៣ នេះ តាមលំដាប់ គឺ **នេក្ខម្មសញ្ញា អព្យាបាទសញ្ញា អវិហឹសាសញ្ញា** និងសញ្ញាទាំង៣នេះគឺ **អសុភសញ្ញា អប្បមាណសញ្ញា ធាតុសញ្ញា ។** ការវៀរធម៌ជាទីបំផុត(អន្តធម៌) គឺ កាមសុខល្លិកានុយោគ រមែងមានព្រោះអលោភៈ ការវៀរចាកនូវធម៌ជាទីបំផុត ( អន្តធម៌ ) គឺ អត្តកិលមថានុយោគ រមែងមានព្រោះអទោសៈ ការប្រព្រឹត្តិទៅដោយកិច្ចបដិបត្តិដែលជាមជ្ឈិមា រមែងមានព្រោះអមោហៈ ។ មួយទៀត ការទម្លាយ

អភិជ្ឈាកាយគន្ថៈ រមែងមានព្រោះអលោភៈ ការទម្លាយព្យាបាទកាយគន្ថៈ រមែងមានព្រោះអទោសៈ ការទម្លាយគន្ថៈទាំង ២ ដ៏សេស រមែងមានព្រោះអមោហៈ ។ ម្យ៉ាងទៀត សតិប្បដ្ឋាន ២ ខាងដើម រមែងសម្រេចដោយអានុភាពនៃគុណធម៌ ២ ខាងដើម សតិប្បដ្ឋាន ២ ខាងចុង រមែងសម្រេចដោយអានុភាពនៃគុណធម៌ខាងចុង ( អមោហៈ ) ប៉ុណ្ណោះ ។

មួយទៀត បណ្តាគុណធម៌ទាំងនេះ អលោភៈរមែងជាបច្ច័យដល់ការមិនមានរោគ ព្រោះបុគ្គលមិនលោភហើយ រមែងមិនសេពអសប្បាយដែលគួរលោភ ព្រោះហេតុនោះ ទើបបុគ្គលដែលមិនលោភមិនមានរោគ ។ អទោសៈរមែងជាបច្ច័យដល់ភាពជាកំលោះក្រមុំ ព្រោះបុគ្គលមិនមានទោសៈប្រទូស្តហើយក៏មិនត្រូវភ្លើង គឺទោសៈដែលនាំមកនូវភាពជាអ្នកមានស្បែកជ្រីវជ្រួញនិងសក់ស្កូវដុតរោល រមែងជាកំលោះក្រមុំ ( នៅក្មេង ) បានយូរ ។ អមោហៈ រមែងជាបច្ច័យដល់ភាពជាអ្នកមានអាយុវែង ព្រោះបុគ្គលអ្នកមិនវង្វេង ដឹងវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ក៏វៀរវត្ថុដែលមិនជាប្រយោជន៍ សេពវត្ថុដែលជាប្រយោជន៍ ទើបជាអ្នកមានអាយុវែង ។

មួយទៀត បណ្តាគុណធម៌ទាំងនោះ អលោភៈជាបច្ច័យដល់ភោគសម្បត្តិ ព្រោះបុគ្គលមិនលោភហើយ ក៏ជាអ្នកបានចំពោះនូវភោគៈ ដោយចាគៈ ។ អទោសៈជាបច្ច័យដល់ការបានមិត្តសម្បត្តិ ព្រោះកាលបុគ្គលមិនមានទោសៈប្រទូស្តហើយ ក៏បានមិត្ត និងការមិនសាបសូន្យចាកមិត្តដោយមេត្តា ។ អមោហៈជាបច្ច័យដល់អត្តសម្បត្តិ ព្រោះបុគ្គលមិនវង្វេង កាលធ្វើប្រយោជន៍

របស់ខ្លួនទុំ:ឯងរមែងឈ្មោះថា ញ៉ាំងខ្លួនឲ្យដល់ព្រម ។ អលោភៈជាបច្ច័យដល់ទិព្វវិហារ អទោសៈជាបច្ច័យដល់ព្រហ្មវិហារ អមោហៈជាបច្ច័យដល់អរិយវិហារ ។

មួយទៀត បណ្តាគុណធម៌ទាំងនោះ បុគ្គលរលត់ស្ងប់ក្នុងសត្វ និងសង្ខារទាំងឡាយ ជាចំណែកខ្លួនបានដោយអលោភៈ ព្រោះសត្វ និងសង្ខារទាំងនោះវិនាសទៅ ក៏មិនមានសេចក្តីទុក្ខដែលមានការជាប់ទាក់ទងគ្នា ជាហេតុ ។ បុគ្គលរលត់ស្ងប់ក្នុងសត្វ និងសង្ខារទាំងឡាយ ជាចំណែកដទៃ បានដោយអទោសៈ ព្រោះបុគ្គលមិនមានទោសៈប្រទូស្តហើយ ក៏មិនមានសេចក្តីសម្គាល់សូម្បីក្នុងបុគ្គលទាំងឡាយដែលចងពៀរនឹងគ្នាថា មានពៀរចំពោះគ្នា បុគ្គលរលត់ស្ងប់ក្នុងសត្វ និងសង្ខារទាំងឡាយ ក្នុងចំណែកជាកណ្តាលបានដោយអមោហៈ ព្រោះបុគ្គលមិនវង្វេង ក៏មិនមានការជាប់ទាក់ទងគ្នាទាំងអស់ ។

ការឃើញអនិច្ចំ រមែងមានដោយអលោភៈ ព្រោះបុគ្គលលោភហើយរមែងមិនឃើញសង្ខារ សូម្បីមិនទៀង ដោយភាពជាអ្នកមិនទៀង ដោយប្រាថ្នានឹងប្រើប្រាស់ ។ ការឃើញទុក្ខ រមែងមានដោយអទោសៈ ព្រោះមនុស្សមានអធ្យាស្រ័យមិនមានទោសៈ កំណត់ លះបង់អាឃាតវត្ថុបានហើយរមែងឃើញសង្ខារទុំ:ឯងដោយភាពជាទុក្ខ ។ ការឃើញអនត្តា រមែងមានដោយអមោហៈ ព្រោះមនុស្សមិនវង្វេង ជាអ្នកឈ្លាសក្នុងការកាន់យកសភាវៈតាមសេចក្តីពិត រមែងដឹងខន្ធ ៥ ដែលមិនមែនជាធំ ដោយមិន

មែនជាធំ ។ ការឃើញអនិច្ចំជាដើម រមែងមានព្រោះគុណធម៌ទាំង ៣ នេះយ៉ាងណា សូម្បីគុណធម៌ទាំង ៣ នោះ ក៏រមែងមាន ព្រោះការឃើញអនិច្ចំជាដើម យ៉ាងនោះដូចគ្នា ។ ពិតហើយ សេចក្ដីមិនលោភ រមែងមានព្រោះការឃើញអនិច្ចលក្ខណៈ ការមិនខឹងក្រោធ រមែងមានព្រោះការឃើញទុក្ខលក្ខណៈ ការមិនវង្វេង រមែងមានព្រោះការឃើញអនត្តលក្ខណៈ ព្រោះថា បុគ្គលណាដឹងដោយប្រពៃថា វត្ថុនេះជារបស់មិនទៀង ដូច្នេះហើយ គប្បីឲ្យសេចក្ដីស្រឡាញ់ កើតឡើងដើម្បីត្រូវការវត្ថុមិនទៀងនោះ ឬដឹងសង្ខារទាំងឡាយថាជាទុក្ខ ដូច្នេះ គប្បីញ៉ាំងសេចក្ដីទុក្ខដែលកើតអំពីសេចក្ដីក្រោធខឹងដែលជាទុក្ខដោយចំណែកមួយឲ្យកើតឡើង និងដឹងដល់ភាពទទេនៃអត្តាហើយគប្បីដល់នូវការវង្វេងនោះ ។

# អធិប្បាយ

## ពួកកម្មបថមានអនភិជ្ឈាជាដើម

ធម៌ដែលឈ្មោះថា **អនភិជ្ឈា** ព្រោះមិនសម្លឹងរំពៃ ។ ឈ្មោះថា **អព្យាបាទ** ព្រោះញ៉ាំងសុខតាមផ្លូវកាយ និងសុខតាមផ្លូវចិត្ត ប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ និងកេរ្តិ៍ឈ្មោះដែលបានចំពោះហើយដោយអានុភាពនៃសេចក្តីល្អ ឲ្យវិនាសទៅ ។ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះរមែងឃើញដោយប្រពៃ ឬជាការយល់ឃើញត្រូវ ។ បទថា **អនភិជ្ឈា** ជាដើមទាំងនោះ ជាឈ្មោះនៃធម៌ មានអលោភៈជាដើមនុ៎ះឯង ។ ធម៌ទាំងនេះ គប្បីជ្រាបថា ក្នុងខាងដើម លោកកាន់យកដោយអំណាចនៃភាពជាមូល ក្នុងទីនេះ គប្បីជ្រាបថា លោកកាន់យកដោយអំណាចនៃកម្មបថ ។

# អធិប្បាយ

## ធម៌ ២ នៃធម៌ជាលោកបាល

សូម្បីហិរិ និងឱត្តប្បៈក៏គប្បីជ្រាបថា ខាងដើម លោកកាន់យកដោយអំណាចនៃភាពជាពល ក្នុងទីនេះ លោកកាន់យកដោយអំណាចនៃលោកបាល ។ ពិតហើយ ធម៌ទាំង ២ នេះ រមែងរក្សាលោក ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ទុកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ស ២ ប្រការនេះ តែងរក្សានូវសត្វលោក ។ ធម៌ស ២ ប្រការ គឺអ្វីខ្លះ ។ គឺហិរិ ១ ឱត្តប្បៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ( បើ ) ធម៌សទាំងឡាយ ២ ប្រការនេះ មិនរក្សានូវសត្វលោកទេ ត្រង់ពាក្យថា មាតាក្តី ថាម្តាយមីងក្តី ថាម្តាយធំក្តី ថាភរិយារបស់អាចារ្យក្តី ថាប្រពន្ធរបស់គ្រូក្តី មិនប្រាកដក្នុងលោកនេះឡើយ សត្វលោកនឹងដល់នូវការប្រឡូកប្រឡំដូចសត្វពពែ ចៀម មាន់ ជ្រូក សុនខ និងចចកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ស ២ ប្រការនេះ តែងរក្សានូវសត្វលោក បានជាពាក្យថា មាតាក្តី ថាម្តាយមីងក្តី ថាម្តាយធំក្តី ថាភរិយារបស់អាចារ្យក្តី ថាប្រពន្ធរបស់គ្រូក្តី តែងមានប្រាកដ ( ក្នុងលោក ) ដូច្នេះ ។

# អធិប្បាយ

## យុគលធម៌មានបស្សទ្ធិជាដើម

សេចក្ដីស្ងប់កាយ ឈ្មោះថា **កាយបស្សទ្ធិ** សេចក្ដីស្ងប់ចិត្ត ឈ្មោះថា **ចិត្តបស្សទ្ធិ** ពាក្យថា កាយ ក្នុងពាក្យថា **កាយបស្សទ្ធិ** នេះ បានដល់ ខន្ធ ៣ មានវេទនាខន្ធជាដើម មួយទៀត បស្សទ្ធិធម៌ទាំង ២ នេះ រួមគ្នា ហើយ គប្បីឃើញថា

កាយបស្សទ្ធិ និងចិត្តបស្សទ្ធិ **កាយចិត្តទរថវូបសមលក្ខណា** មាន ការរម្ងាប់សេចក្ដីក្រវល់ក្រវាយ តាមផ្លូវកាយ និងផ្លូវចិត្តជាលក្ខណៈ **កាយ-ចិត្តទរថនិម្មទ្ទនរសា** មានការកម្ចាត់សេចក្ដីក្រវល់ក្រវាយតាមផ្លូវកាយ និង ផ្លូវចិត្តជាកិច្ច **កាយចិត្តានំ អបរិប្ផន្ទសីតិភាវបច្ចុប្បដ្ឋានា** មានសេចក្ដី ត្រជាក់ស្ងប់ មិនក្ដៅក្រហាយនៃកាយ និងចិត្តជាអាការប្រាកដ **កាយចិត្ត-បទដ្ឋានា** មានកាយ ( ចេតសិក ) និងចិត្តជាហេតុជិត ជាបដិបក្ខចំពោះ កិលេស មានឧទ្ធច្ចៈដែលធ្វើការមិនស្ងប់នៃកាយ និងចិត្ត ។

ការស្រាលនៃកាយ ឈ្មោះថា **កាយលហុតា** ។ ការស្រាលនៃចិត្ត ឈ្មោះថា **ចិត្តលហុតា** ។

គប្បីឃើញថា លហុតាទាំង ២ នោះ **កាយចិត្តគរុភាវវូបសម-លក្ខណា** មានការស្ងប់ភាពធ្ងន់នៃកាយ និងចិត្តជាលក្ខណៈ **កាយចិត្តគរុ-ភាវនិម្មទ្ទនរសា** មានការកម្ចាត់សេចក្ដីធ្ងន់កាយ និងចិត្តជាកិច្ច **កាយចិត្តានំ អទន្ធតាបច្ចុប្បដ្ឋានា** មានការមិនយឺតយូរនៃកាយ និងចិត្តជាអាការប្រាកដ

**កាយចិត្តបទដ្ឋានា** មានកាយ និងចិត្តជាហេតុជិត ជាបដិបក្ខចំពោះកិលេស មានថីនមិទ្ធៈជាដើម ដែលធ្វើភាពធ្ងន់នៃកាយ និងចិត្ត ។

ការទន់នៃកាយ ឈ្មោះថា **កាយមុទុតា** ។ ការទន់នៃចិត្ត ឈ្មោះថា **ចិត្តមុទុតា** ។

គប្បីឃើញថា មុទុតាទាំង ២ នោះ **កាយចិត្តថទ្ធភាវវូបសមលក្ខណា** មានការស្ងប់ការរឹងនៃកាយ និងចិត្តជាលក្ខណៈ **កាយចិត្តថទ្ធភាវនិម្មទ្ទនរសា** មានការកម្ចាត់ភាពរឹងនៃកាយ និងចិត្តជាកិច្ច **អប្បដិឃាតបច្ចុប្បដ្ឋានា** មានការមិនចង្អៀតចង្អល់ចិត្តជាអាការប្រាកដ **កាយចិត្តបទដ្ឋានា** មានកាយ និងចិត្តជាហេតុជិត ជាបដិបក្ខចំពោះកិលេស មានទិដ្ឋិ និងមានះជាដើមដែលធ្វើកាយ និងចិត្តឲ្យរឹង ។

ភាពដែលកាយគួរដល់ការងារ ឈ្មោះថា **កាយកម្មញ្ញតា** ភាពដែលចិត្តគួរដល់ការងារ ឈ្មោះថា **ចិត្តកម្មញ្ញតា** ។

គប្បីឃើញថា កម្មញ្ញតាទាំង ២ នោះ **កាយចិត្តអកម្មញ្ញភាវវូបសមលក្ខណា** មានការស្ងប់ភាពដែលកាយ និងចិត្តមិនគួរដល់ការងារ ជាលក្ខណៈ **កាយចិត្តានំ អកម្មញ្ញភាវនិម្មទ្ទនរសា** មានការកម្ចាត់ភាពដែលកាយ និងចិត្តមិនគួរដល់ការងារជាកិច្ច **កាយចិត្តានំ អារម្មណករណសម្បត្តិបច្ចុប្បដ្ឋានា** មានការដល់ព្រមដោយការធ្វើកាយ និងចិត្តសមគួរដល់អារម្មណ៍ជាអាការប្រាកដ **កាយចិត្តបទដ្ឋានា** មានកាយនិងចិត្តជាហេតុជិត ។

ជាបដិបក្ខចំពោះនីវរណៈដ៏សេសដែលធ្វើភាពដែលកាយ និងចិត្ត មិនគួរដល់ការងារ ។ និងគប្បីឃើញកម្មញ្ញតាទាំង ២ នោះ ជាធម៌នាំមកនូវសេចក្ដីជ្រះថ្លា ក្នុងវត្ថុដែលជាទីតាំងនៃសេចក្ដីជ្រះថ្លាទាំងឡាយ ជាធម៌នាំមកនូវសេចក្ដីក្សេម សមគួរក្នុងការធ្វើប្រយោជន៍ និងសេចក្ដីចម្រើន ដូចសេចក្ដីបរិសុទ្ធនៃមាស ដូច្នោះ ។

ភាពដែលកាយស្ទាត់ជំនាញ ឈ្មោះថា **កាយបាគុញ្ញតា** ភាពដែលចិត្តស្ទាត់ជំនាញ ឈ្មោះថា **ចិត្តបាគុញ្ញតា** ។

គប្បីឃើញថា បាគុញ្ញតាទាំង ២ នោះ **កាយចិត្តានំ អគេលញ្ញភាវលក្ខណា** មានភាពដែលកាយ និងចិត្ត មិនមានជំងឺជាលក្ខណៈ **កាយចិត្តគេលញ្ញនិម្មទ្ទនរសា** មានការកម្ចាត់ជំងឺនៃកាយ និងចិត្តជាកិច្ច **និរាទីនវបច្ចុប្បដ្ឋានា** មានការប្រាសចាកទោស ជាអាការប្រាកដ **កាយចិត្តបទដ្ឋានា** មានកាយ និងចិត្តជាហេតុជិត ។

ជាបដិបក្ខចំពោះកិលេស មានភាពជាអ្នកមិនមានសទ្ធាជាដើម ដែលធ្វើនូវជំងឺនៃកាយ និងចិត្ត ។

សេចក្ដីត្រង់នៃកាយ ឈ្មោះថា **កាយុជុកតា** សេចក្ដីត្រង់នៃចិត្តឈ្មោះថា **ចិត្តុជុកតា** ។

គប្បីជ្រាបថា ឧជុកតាទាំង ២ នោះ **កាយចិត្តានំ អជ្ជវលក្ខណា** មានការត្រង់នៃកាយ និងចិត្តជាលក្ខណៈ **កាយចិត្តកុដិលភាវនិម្មទ្ទនរសា** មានការកម្ចាត់ការវៀចនៃកាយ និងចិត្តជាកិច្ច **អជិម្ហតាបច្ចុប្បដ្ឋានា** មានភាព

ស្មោះត្រង់នៃកាយ និងចិត្តជាអាការប្រាកដ **កាយចិត្តុជុកតា** មានកាយ និងចិត្តជាហេតុជិត ។

ជាបដិបក្ខចំពោះកិលេស មានមាយា និងសាថេយ្យៈជាដើម ដែលធ្វើសេចក្តីវៀចវេរនៃកាយ និងចិត្ត ។

ធម៌ដែលឈ្មោះថា **សតិ** ព្រោះរឭក ឈ្មោះថា **សម្បជញ្ញៈ** ព្រោះដឹងខ្លួន អធិប្បាយថា រមែងដឹងដោយប្រការផ្សេងៗ ជុំវិញបណ្តាធម៌ទាំង ២ នោះ គប្បីជ្រាបសម្បជញ្ញៈទាំង ៤ ប្រភេទនេះ គឺសាត្ថកសម្បជញ្ញៈ សប្បាយសម្បជញ្ញៈ គោចរសម្បជញ្ញៈ អសម្មោហសម្បជញ្ញៈ ។ ចំណែកលក្ខណៈជាដើម របស់សតិ និងសម្បជញ្ញៈទាំងនោះ គប្បីជ្រាបដោយន័យដែលពោលក្នុងសតិន្ទ្រិយ និងបញ្ញិន្ទ្រិយនុ៎ះឯង គួរនៃធម៌នេះ ត្រាស់ខាងដើមហើយ ក្នុងទីនេះ ត្រាស់ទៀត ដោយអំណាចនៃភាពជាធម៌មានឧបការដោយប្រការដូច្នេះ ។

ធម៌ដែលឈ្មោះថា **សមថៈ** ព្រោះស្ងប់ធម៌ដែលជាសត្រូវ មានកាមច្ឆន្ទៈជាដើម ។ ឈ្មោះថា **វិបស្សនា** ព្រោះឃើញធម៌ទាំងឡាយ ដោយអាការផ្សេងៗ ដោយអំណាចនៃការមិនទៀងជាដើម ដោយអត្ថ វិបស្សនានេះ ក៏គឺបញ្ញានុ៎ះឯង ។ លក្ខណៈជាដើមនៃធម៌ទាំង ២ គឺសមថៈ និងវិបស្សនានេះ បានពោលហើយខាងដើមនុ៎ះឯង តែការយកក្នុងទីនេះទៀត ដោយអំណាចនៃយុគនទ្ធធម៌ ( ធម៌ដែលជាគូដូចនឹម ) ។

ធម៌ដែលឈ្មោះថា **បគ្គាហៈ** ព្រោះផ្គងសហជាតធម៌ទាំងឡាយ ។

ដែលឈ្មោះថា **អវិក្ខេប:** ព្រោះការមិនរវើរវាយដោយភាពជាបដិបក្ខចំពោះការរាយមាយ គឺឧទ្ធច្ច: ។ លក្ខណ:ជាដើមនៃធម៌ទាំងនេះ បានពោលហើយខាងដើមនុ៎ះឯង ។ ធម៌ទាំង ២ នេះ គប្បីជ្រាបថា កាន់យកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ការប្រកបវីរិយ: និងសមាធិនោះឯង ។

# អធិប្បាយ
## ពាក្យថា យេវាបនកន័យ

ពាក្យថា **យេវាបន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា កុសលា** ( ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងដោយអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ) អធិប្បាយថា កុសលធម៌ជាង ៥០ នេះ ព្រះមានព្រះភាគទ្រង់លើកឡើងសម្តែងដោយលំដាប់ថា ផស្ស:រមែងមាន ។បេ។ អវិក្ខេប: រមែងមាន តែម្យ៉ាងក៏ទេ តាមពិត ទ្រង់សម្តែងថា មហាកុសលចិត្តដែលជាអសង្ខារិកដួងទីមួយ សហគត:ដោយសោមនស្ស ជា**តិ**ហេតុក:ខាងកាមាវចរ កើតឡើងក្នុងសម័យណា ធម៌ពួកដទៃដែលជាយេវាបនកធម៌ ដែលសម្បយុត្តដោយធម៌ទាំងនោះនុ៎ះឯង មានផស្ស:ជាដើម ប្រព្រឹត្តទៅដែលអាស្រ័យបច្ច័យដ៏សមគួររៀងៗ ខ្លួន កើតឡើងជា **អរូប** ព្រោះការមិនមានរូបជាធម៌ដែលរកបានតាមសភាវ:មាននៅក្នុងសម័យនោះ ធម៌ទាំងអស់នេះ ជា

កុសល ។

ព្រះមានព្រះភាគ ជាធម្មរាជា កាលសម្តែងធម៌ច្រើនជាង ៥០ ដែលលើកឡើងក្នុងបាលី ដោយអំណាចនៃចំណែកប្រកបរបស់ចិត្ត ដោយពុទ្ធវចនៈ មានប្រមាណប៉ុណ្ណោះហើយ ទើបទ្រង់សម្តែងធម៌ ៩ យ៉ាងដទៃទៀត ដោយអំណាចនៃយេវាបនកធម៌ ។ ពិតហើយ បណ្តាបទក្នុងព្រះសូត្រទាំងនោះ ធម៌ទាំង ៩ នេះ រមែងប្រាកដ គឺឆន្ទៈ ១ អធិមោក្ខ ១ មនសិការ ១ តត្រមជ្ឈត្តតា ១ ករុណា ១ មុទិតា[1] ១ កាយទុច្ចរិតវិរតិ ១ វចីទុច្ចរិតវិរតិ ១ មិច្ឆាជីវវិរតិ ១ ។ មួយទៀត ក្នុងមហាកុសលចិត្តដួងទីមួយនេះ ឆន្ទៈក្នុងកុសលធម៌នៃភាពជាអ្នកប្រាថ្នាដើម្បីធ្វើក៏មាន តែទ្រង់មិនបានលើកក្នុងព្រះបាលី ដោយអំណាចនៃចំណែកប្រកបរបស់ចិត្តក្នុងទីនេះ ឆន្ទៈនោះ ទ្រង់កាន់យកដោយអំណាចនៃយេវាបនកធម៌ ។

អធិមោក្ខ មនសិការ តត្រមជ្ឈត្តតា និងបុព្វភាគនៃមេត្តា ក៏មាន ។ កាលអទោសៈទ្រង់កាន់យកហើយ បុព្វភាគរបស់មេត្តានោះ ក៏ឈ្មោះថាទ្រង់កាន់យកដូចគ្នា ។ ទោះបីបុព្វភាគរបស់ករុណា បុព្វភាគរបស់មុទិតា បុព្វភាគរបស់ឧបេក្ខាក៏មាន តែកាលតត្រមជ្ឈត្តតាទ្រង់កាន់យកហើយ បុព្វភាគរបស់ឧបេក្ខានោះ ក៏រមែងជាការដែលកាន់យកហើយដោយពិត សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈក៏មាន តែទ្រង់មិនបានលើកឡើងក្នុងបាលី ដោយអំណាចនៃចំណែកប្រកបរបស់ចិត្ត ក្នុងទីនេះ ធម៌ មានសម្មាវាចា

---

១- ច្បាប់ស្យាមជា មុទុតា ។

ជាដើមនោះ ក៏កាន់យកដោយអំណាចនៃយេវាបនកធម៌ តែក្នុងធម៌ទាំង ៩ ប្រការនេះ ធម៌ ៤ យ៉ាង ដែលបានក្នុងខណៈតែមួយ គឺឆន្ទៈ ១ អធិមោក្ខ ១ មនសិការ ១ តត្រមជ្ឈត្តតា ១ ធម៌ដ៏សេសក្រៅអំពីនោះ បានក្នុងខណៈផ្សេងគ្នា ។

ពិតហើយ ក្នុងកាលណាបុគ្គលលះមិច្ឆាវាចាដោយចិត្តដួងនេះ បំពេញសម្មាវាចាដោយអំណាចវិរតិ ក្នុងកាលនោះ ធម៌ទាំង ៥ នេះ គឺធម៌ ៤ មានឆន្ទៈជាដើម និងសម្មាវាចា រមែងកើតក្នុងខណៈតែមួយ ។ កាលណាបុគ្គលលះមិច្ឆាកម្មន្តៈ បំពេញសម្មាកម្មន្តៈដោយអំណាចវិរតិ ។បេ។ លះមិច្ឆាអាជីវៈ បំពេញសម្មាអាជីវៈ ដោយអំណាចវិរតិ ។បេ។ កាលណាធ្វើបរិកម្មដោយករុណា ។បេ។ ធ្វើបរិកម្មដោយមុទិតា ក្នុងកាលនោះ ធម៌ទាំង ៥ នេះ គឺធម៌ ៤ យ៉ាង មានឆន្ទៈជាដើម និងបុព្វភាគរបស់មុទិតា រមែងកើតក្នុងខណៈតែមួយ ។ ក្រៅអំពីនេះហើយ កាលបុគ្គលឲ្យទាន បំពេញសីល ចម្រើនភាវនា រមែងបានធម៌ ៤ យ៉ាង ( ឆន្ទៈ អធិមោក្ខ មនសិការ តត្រមជ្ឈត្តតា ) ដែលជាចំណែកប្រកបដែលពិតប្រាកដ ។

បណ្តាយេវាបនកធម៌ទាំង ៩ នេះ ដូចដែលពណ៌នាមកនេះ ពាក្យថា ឆន្ទៈនោះ ជាឈ្មោះរបស់កត្តុកម្យតា ។

ព្រោះហេតុនោះ ឆន្ទៈនោះ **កត្តុកម្យតាលក្ខណោ** មានភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើជាលក្ខណៈ **អារម្មណបរិយេសនរសោ** មានការស្វែងរកអារម្មណ៍ជាកិច្ច **អារម្មណេន អត្ថិកតាបច្ចុប្បដ្ឋានោ** មានសេចក្តីត្រូវការ

អារម្មណ៍ជាអាការប្រាកដ **តទេវស្ស បទដ្ឋានំ** មានអារម្មណ៍របស់ឆន្ទៈនោះឯងជាហេតុជិត ។

ឆន្ទៈនេះ ក្នុងការកាន់យកអារម្មណ៍ បណ្ឌិតគប្បីឃើញដូចការលាតដៃចេញទៅ ។

ការបង្អោនចិត្តជឿ ឈ្មោះថា **អធិមោក្ខ** អធិមោក្ខនោះ **សន្និដ្ឋានលក្ខណោ** មានការចុះចិត្តស៊ប់ជាលក្ខណៈ **អសំសប្បនរសោ** មានការមិនរារែកជាកិច្ច **និច្ឆយបច្ចុប្បដ្ឋានោ** មានការសម្រេចចិត្ត ជាអាការប្រាកដ **សន្និដ្ឋាតព្វធម្មបទដ្ឋានោ** មានធម៌ដែលគប្បីដាក់ចិត្តជឿស៊ប់ ជាហេតុជិត អធិមោក្ខនេះគប្បីឃើញដូចសសរខឿន ព្រោះការមិនញាប់ញ័រក្នុងអារម្មណ៍ ។

ការធ្វើ ឈ្មោះថា **ការៈ** ការធ្វើទុកក្នុងចិត្ត ឈ្មោះថា **មនសិការ** ធម៌ដែលឈ្មោះថា **មនសិការ** ព្រោះធ្វើចិត្តមិនឲ្យដូចមុន អំពីចិត្តដួងដំបូង ( ធ្វើចិត្តឲ្យឡើងកាន់វិថិអំពីភវង្គចិត្ត ) ។ មនសិការនេះ មាន ៣ ប្រការ គឺអារម្មណបដិបាទកៈ ១ វីថិបដិបាទកៈ ១ ជវនបដិបាទកៈ ១ ។

បណ្តាមនសិការទាំង ៣ នោះ មនសិការដែលធ្វើចិត្តឲ្យទទួលអារម្មណ៍ ឈ្មោះថា មនសិការព្រោះធ្វើទុកក្នុងចិត្ត ។

មនសិការដែលធ្វើចិត្ត ឲ្យទទួលអារម្មណ៍នោះ **សារណលក្ខណោ**[១] មានការធ្វើសម្បយុត្តធម៌ ឲ្យទទួលអារម្មណ៍ជាលក្ខណៈ **សម្បយុត្តានំ អារម្មណេ សម្បយោជនរសោ**[២] មានការប្រកបសម្បយុត្តធម៌ទាំងឡាយ

---

១- ច្បាប់របស់ស្យាមជា សារម្មណលក្ខណោ ។

២- ច្បាប់របស់ស្យាមជា អារម្មណេន សំយោជនរសោ ។

ទុកដោយអារម្មណ៍ជាកិច្ច **អារម្មណាភិមុខភាវបច្ចុបដ្ឋានោ** មានមុខឆ្ពោះទៅកាន់អារម្មណ៍ជាអាការប្រាកដ ។ ទាក់ទងដោយសង្ខារក្ខន្ធ ( មានអារម្មណ៍ជាហេតុជិត ) គប្បីឃើញដូចនាយសារថី ព្រោះញុំាងសម្បយុត្តធម៌ ឲ្យប្រព្រឹត្តទៅក្នុងអារម្មណ៍ ។ ចំណែកពាក្យថា វីថិបដិបាទកៈនេះ ជាឈ្មោះរបស់បញ្ចទ្វារាវជ្ជនចិត្ត ។ ពាក្យថា ជវនបដិបាទកៈនេះ ជាឈ្មោះរបស់មនោទ្វារាវជ្ជនចិត្ត ។ មនសិការទាំង ២ នេះ លោកមិនប្រាថ្នាយកក្នុងទីនេះ ។

ភាពជាកណ្តាលក្នុងធម៌ទាំងនោះ ឈ្មោះថា **តត្រមជ្ឈត្តតា** ។

តត្រមជ្ឈត្តតានោះ **ចិត្តចេតសិកានំ សមវាហិតលក្ខណា** មានការទ្រទ្រង់នូវចិត្ត និងចេតសិក ឲ្យស្មើគ្នាជាលក្ខណៈ **ឩនាធិកនិវារណរសា** មានការហាមចិត្ត និងចេតសិកមិនឲ្យលើស និងខ្វះជាកិច្ច **បក្ខបាតុបច្ឆេទនរសា វា** ឬមានការដាច់ចាកការធ្លាក់ទៅក្នុងចំណែកណាមួយជាកិច្ច **មជ្ឈត្តភាវបច្ចុបដ្ឋានា** មានភាពជាកណ្តាលជាអាការប្រាកដ ដោយអំណាចនៃភាពព្រងើយកន្តើយចំពោះចិត្ត និងចេតសិក ( និងមានសម្បយុត្តធម៌ជាហេតុជិត ) តត្រមជ្ឈត្តតានេះ គប្បីឃើញដូចសារថីអ្នកព្រងើយកន្តើយចំពោះសេះអាជានេយ្យទាំងឡាយ ដែលរត់ទៅរៀបរយ ដូច្នោះ ។

ករុណា និងមុទិតា នឹងមានជាក់ច្បាស់ក្នុងនិទ្ទេសនៃព្រហ្មវិហារ ។ តាមពិត មានសេចក្តីប្លែកគ្នាត្រឹមតែប៉ុណ្ណេះថា ករុណា និងមុទិតានោះ ដែលដល់នូវអប្បនាជារូបាវចរ ក្នុងទីនេះ ជាកាមាវចរ ។

ការវៀរចាកកាយទុច្ចរិត ឈ្មោះថា **កាយទុច្ចរិតវិរតិ** ។ វិរតិ ២ ដ៏សេសក៏ន័យនេះឯង ។ ពោលដោយលក្ខណៈជាដើម

វិរតិទាំង ៣ នោះ **កាយទុច្ចរិតាទិវត្ថូនំ អវីតិក្កមលក្ខណា** មានការមិនឈានកន្លងវត្ថុ មានកាយទុច្ចរិតជាដើម ជាលក្ខណៈ អធិប្បាយថា មានការមិនញាំញីសត្វជាលក្ខណៈ **កាយទុច្ចរិតាទិវត្ថុតោ សង្កោចនរសា** មានការងាកមុខចេញចាកវត្ថុ មានកាយទុច្ចរិតជាដើមជាកិច្ច **អកិរិយបច្ចុប្បដ្ឋានា** មានការមិនធ្វើកាយទុច្ចរិតជាដើម ជាអាការប្រាកដ **សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានា** មានគុណ គឺសទ្ធា ហិរិ ឱត្តប្បៈ និងសេចក្តីប្រាថ្នាតិចជាដើមជាហេតុជិត គប្បីឃើញវិរតិទាំង ៣ នោះ ជាចិត្តដែលចៀសវាងការធ្វើបាប ។

វារៈនៃធម្មុទ្ទេស ( ធម៌ដែលទ្រង់លើកឡើងសម្តែង ) នេះមានបទធម៌សូម្បីទាំងអស់ ៦៥ បទ គឺធម៌ ៥៦ មានផស្សៈជាដើម និងធម៌ ៩ ដែលត្រាស់ដោយអំណាចនៃយេវាបនកធម៌ ។

បណ្តាបទទាំងនោះ គ្រាខ្លះ ក្នុងខណៈជាមួយគ្នា មាន ៦១ បទ គ្រាខ្លះមានត្រឹមតែ ៦០ បទ ពិតហើយ បទធម៌ដែលត្រាស់ដោយអំណាចនៃការបំពេញសម្មាវាចាជាដើមទាំងនោះ ក្នុងវេលាប្រព្រឹត្ត រមែងមាន ៦១ បទ ក្នុងឋាន ៥ ( វិរតិ ៣ អប្បមញ្ញា ២ ) ។ រមែងមាន ៦០ ក្នុងឋានៈមួយដែលផុតចាកឋានៈទាំង ៥ នោះ តែវៀរយេវាបនកធម៌ បទធម៌ដែលទ្រង់កាន់យកដោយអំណាចនៃបទតាមដែលទ្រង់លើកឡើង ទុកក្នុងព្រះបាលី

មាន ៥៦ បទ ។ តែបើរាប់បទដែលមិនជាន់គ្នាក្នុងបាលីនេះ ក៏មានបទធម៌ ៣០ គឺពួក ៥ នៃផស្សៈ ( **ផស្សបញ្ចកំ** ) វិតក្ក ១ វិចារ ១ បីតិ ១ ចិត្តេកគ្គតា ១ ឥន្ទ្រិយ ៥ ពល ២ គឺហិរិពល ឱត្តប្បពល មូល ២ គឺអលោភៈ អទោសៈ ធម៌ ១២ មានកាយបស្សទ្ធិ ចិត្តបស្សទ្ធិជាដើម ។

បណ្ដាធម៌ទាំង ៣០ នោះ ធម៌ ១៨ ទ្រង់មិនចែក ធម៌ ១២ ទ្រង់ចែក ។ ធម៌ ១៨ ប្រការដូចម្ដេច ។ ធម៌ ១៨ ប្រការនេះ គឺផស្សៈ ១ សញ្ញា ១ ចេតនា ១ វិចារ ១ បីតិ ១ ជីវិតិន្ទ្រិយ ១ ធម៌ ១២ មានកាយបស្សទ្ធិជាដើម ទ្រង់មិនចែក ។ ធម៌ទាំង ១២ ប្រការនេះ គឺវេទនា ១ ចិត្ត ១ វិតក្ក ១ ចិត្តេកគ្គតា ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ហិរិពល ១ ឱត្តប្បពល ១ អលោភៈ ១ អទោសៈ ១ ទ្រង់ចែក ។

បណ្ដាធម៌ទាំងនោះ ធម៌ ៧ ប្រការ ចែកក្នុង ២ ឋានៈ ធម៌មួយប្រការ ចែកក្នុង ៣ ឋានៈ ធម៌ពីរប្រការចែកក្នុង ៤ ឋានៈ ធម៌មួយប្រការចែកក្នុង ៦ ឋានៈ ធម៌មួយប្រការចែកក្នុង ៧ ឋានៈ ។

ធម៌ ៧ ប្រការនេះ គឺចិត្ត វិតក្ក សទ្ធា ហិរិ ឱត្តប្បៈ អលោភៈ អទោសៈ ចែកក្នុង ២ ឋានៈ តើដូចម្ដេច ។ ពិតហើយ បណ្ដាធម៌ទាំង ៧ ប្រការនោះ ចិត្តសម្ដៅដល់ធម៌មានពួក ៥ នៃផស្សៈមុន ហៅថា ចិត្ត សម្ដៅដល់ឥន្ទ្រិយ ហៅថា មនិន្ទ្រិយ ។ វិតក្កសម្ដៅដល់អង្គនៃឈាន ហៅថា វិតក្ក សម្ដៅដល់មគ្គ ហៅថា សម្មាសង្កប្ប ។ សទ្ធាសម្ដៅដល់ឥន្ទ្រិយ

ហៅថា សទ្ធិន្ទ្រិយ សម្ព័ន្ធដល់ពល ហៅថា សទ្ធាពល ហិរិសម្ព័ន្ធដល់ពល ហៅថា ហិរិពល សម្ព័ន្ធដល់ធម៌ពួក ២ នៃលោកបាល ហៅថា ហិរិ ។ សូម្បីក្នុងឱត្តប្ប: ក៏ន័យនេះដូចគ្នា ។ អលោភ:សម្ព័ន្ធដល់មូល ហៅថា អលោភ: សម្ព័ន្ធដល់កម្មបថ ហៅថា អនភិជ្ឈា ។ អទោស:សម្ព័ន្ធដល់មូល ហៅថា អទោស: សម្ព័ន្ធដល់កម្មបថ ហៅថា អព្យាបាទ ។ ធម៌ ៧ ប្រការនេះ ចែកហើយក្នុង ២ ឋាន: ។

ចំណែកវេទនា សម្ព័ន្ធដល់ពួក ៥ នៃផស្ស: ហៅថា វេទនា សម្ព័ន្ធដល់អង្គឈាន ហៅថា សុខ សម្ព័ន្ធដល់ឥន្ទ្រិយ ហៅថា សោមនស្សិន្ទ្រិយ ។ ធម៌មួយប្រការនេះ ចែកក្នុង ៣ ឋាន: យ៉ាងនេះ ។ ចំណែកវិរិយ: សម្ព័ន្ធដល់ឥន្ទ្រិយ ហៅថា វិរិយិន្ទ្រិយ សម្ព័ន្ធដល់អង្គមគ្គ ហៅថា សម្មា-វាយាម: សម្ព័ន្ធដល់ពល ហៅថា វិរិយពល សម្ព័ន្ធដល់បិដ្ឋិទុក: ហៅថា បគ្គាហ: ។ សតិសម្ព័ន្ធដល់ឥន្ទ្រិយ ហៅថា សតិន្ទ្រិយ សម្ព័ន្ធដល់អង្គមគ្គ ហៅថា សម្មាសតិ សម្ព័ន្ធដល់ពល ហៅថា សតិពល សម្ព័ន្ធដល់បិដ្ឋិទុក: ហៅថា សតិ ។ ធម៌ ២ ប្រការនេះ ចែកក្នុង ៤ ឋាន: ដោយប្រការដូច្នេះ ។

ចំណែកសមាធិសម្ព័ន្ធដល់អង្គឈាន ហៅថា ចិត្តេកគ្គតា សម្ព័ន្ធដល់ឥន្ទ្រិយ ហៅថា សមាធិន្ទ្រិយ សម្ព័ន្ធដល់អង្គមគ្គ ហៅថា សម្មាសមាធិ សម្ព័ន្ធដល់ពល ហៅថា សមាធិពល សម្ព័ន្ធដល់បិដ្ឋិទុក: ហៅថា សមថ: និងអវិក្ខេប: ធម៌មួយប្រការនេះ ចែកក្នុង ៦ ឋាន: ដោយប្រការដូច្នេះ ។

ចំណែកបញ្ញា សម្ដីងដល់ឥន្រ្ទិយ ហៅថា បញ្ញិន្ទ្រិយ សម្ដីងដល់អង្គមគ្គ ហៅថា សម្មាទិដ្ឋិ សម្ដីងដល់ពល ហៅថា បញ្ញាពល សម្ដីងដល់មូល ហៅថា អមោហៈ សម្ដីងដល់កម្មបថ ហៅថា សម្មាទិដ្ឋិ សម្ដីងដល់បិដ្ឋិទុកៈ ហៅថា សម្បជញ្ញៈ និងវិបស្សនា ធម៌មួយប្រការនេះ ចែកក្នុង ៧ ឋានៈ ដោយប្រការដូច្នេះ ។

បើមានបុគ្គលណាសួរថា ក្នុងព្រះបាលីនេះ ឈ្មោះថា បទដែលមិនធ្លាប់មាន មិនមានទេ ព្រោះព្រះអង្គទ្រង់កំណត់ធម៌ ដែលទ្រង់កាន់យកហើយក្នុងខាងដើមនុ៎ះឯង មកធ្វើបទឲ្យពេញក្នុងឋានៈនោះៗ ព្រះពុទ្ធអង្គទ្រង់មិនដឹងហើយ ទើបត្រាស់កថាដែលមិនមានអនុសន្ធិ ដូចទ្រព្យដែលពួកចោរលួចយកមកគរទុក និងដូចស្មៅដែលហ្វូងគោជាន់នៅត្រង់ផ្លូវដើរ ដូច្នេះសោតគប្បីបដិសេធថា មិនគួរពោលយ៉ាងនោះ ហើយពោលថា ធម្មតាទេសនារបស់ព្រះពុទ្ធទាំងឡាយដែលមិនមានអនុសន្ធិ មិនមាន ជាទេសនាដែលមានអនុសន្ធិទាំងអស់ សូម្បីពាក្យដែលទ្រង់មិនជ្រាបហើយត្រាស់ ក៏មិនមានរឿងទាំងអស់ ព្រះអង្គទ្រង់ជ្រាបហើយ ទើបត្រាស់នោះឯង ។ ពិតហើយព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបកិច្ចរបស់ធម៌ទាំងនោះ កាលទ្រង់ជ្រាបកិច្ចនោះហើយ ទើបទ្រង់លើកឡើងចែកទៅតាមកិច្ច ទ្រង់ជ្រាបថា ធម៌ ១៨ យ៉ាង មានកិច្ចមួយ ទើបទ្រង់លើកឡើងចែកក្នុងឋានៈតែមួយឋានៈ ទ្រង់ជ្រាបធម៌ ៧ យ៉ាង មានកិច្ចមួយ ២ ឋានៈ ទើបទ្រង់លើកឡើងចែកធម៌នីមួយៗ ជា ២ ឋានៈ ទ្រង់ជ្រាបថា វេទនាមានកិច្ច ៣ ឋានៈ ទើបទ្រង់លើកឡើង

ចែកជា ៣ ឋានៈ ទ្រង់ជ្រាបថា វីរិយៈ និងសតិនីមួយៗ មានកិច្ច ៤ ឋានៈ ទ្រង់លើកឡើងចែកធម៌នីមួយៗ នោះ ជា ៤ ឋានៈ ទ្រង់ជ្រាបថា សមាធិមានកិច្ច ៦ ឋានៈ ទើបទ្រង់លើកឡើងចែកជា ៦ ឋានៈ ទ្រង់ជ្រាបថា បញ្ញាមានកិច្ច ៧ ឋានៈ ទើបទ្រង់លើកឡើងចែកក្នុងឋានៈ ៧ ។ ក្នុងសេចក្ដីនោះ មានឧបមាដូច្នេះ

បានឮថា ព្រះរាជាមួយព្រះអង្គ ទ្រង់ជាបណ្ឌិត ទ្រង់ប្រថាប់នៅក្នុងទីចំពោះព្រះអង្គហើយ ទ្រង់ព្រះតម្រិះថា ទ្រព្យក្នុងឃ្លាំងនេះ មិនគប្បីត្រូវចាយវាយដោយខ្ជះខ្ជាយ យើងនឹងបន្ថែមថ្លៃឈ្នួលដ៏សមគួរ ដល់អ្នកដែលចេះសិល្បសាស្ត្រ ។ ព្រះរាជាក៏ត្រាស់ឲ្យហៅ អ្នកចេះសិល្បសាស្ត្រទាំងអស់មកប្រជុំគ្នា ហើយត្រាស់ថា ចូរពួកអ្នកអញ្ជើញមនុស្សដែលមានចំណេះដឹងតែមួយបែបមក ។ ជនទាំង ១៨ ដែលត្រូវត្រាស់ហៅយ៉ាងនេះ ក៏ក្រោកឡើងមក ។ ទ្រង់ក៏ព្រះរាជទានឲ្យជនទាំងនោះម្នាក់មួយចំណែក ។ កាលព្រះរាជាត្រាស់ថា អ្នកចេះសិល្បសាស្ត្រ ២ បែប ចូរមក ជន ៧ នាក់នាំគ្នាចូលមកគាល់ ព្រះអង្គក៏ទ្រង់ព្រះរាជទានឲ្យជនទាំងនោះ ម្នាក់ ២ ចំណែក កាលត្រាស់ថា អ្នកចេះសិល្បសាស្ត្រ ៣ បែប ចូរមក មានមនុស្សត្រឹមតែម្នាក់ ចូលមកគាល់ ព្រះអង្គក៏ព្រះរាជទានឲ្យមនុស្សនោះ ៣ ចំណែក កាលព្រះអង្គត្រាស់ថា អ្នកចេះសិល្បសាស្ត្រ ៤ បែប ចូរមក ក៏មានមនុស្ស ២ នាក់ចូលមកគាល់ ព្រះអង្គក៏ព្រះរាជទានឲ្យមនុស្សម្នាក់ៗ ៤ ចំណែក កាលព្រះអង្គត្រាស់ថា អ្នកចេះសិល្បសាស្ត្រ ៥ យ៉ាង ចូរ

មក សូម្បីមនុស្សម្នាក់ក៏មិនមក កាលត្រាស់ថា អ្នកចេះសិល្ប: ៦ យ៉ាង ចូរមក មានត្រឹមតែមនុស្សម្នាក់ប៉ុណ្ណោះចូលមក ព្រះអង្គក៏ព្រះរាជទាន ឲ្យ ៦ ចំណែក ដល់គេ កាលត្រាស់ថា អ្នកចេះសិល្ប: ៧ បែប ចូរមក ក៏ មានត្រឹមតែម្នាក់ប៉ុណ្ណោះ ចូលមក ទ្រង់ក៏ព្រះរាជទានដល់បុគ្គលនោះ ៧ ចំណែក ។

ក្នុងរឿងនោះ មានសេចក្ដីឧបមាដូច្នេះ ព្រះសម្មាសម្ពុទ្ធទ្រង់ជាធម្មរាជា មិនមាននរណាក្រៃលែងជាង ប្រៀបដូចព្រះរាជាជាបណ្ឌិត ធម៌ទាំងឡាយ ដែលកើតឡើង ដោយអំណាចនៃភាពជាអង្គនៃចិត្ត ប្រៀបដូចជនអ្នកចេះ សិល្បសាស្ត្រ ការដែលព្រះអង្គទ្រង់លើកធម៌ទាំងនោះឡើង ចែកដោយ អំណាចនៃកិច្ច ប្រៀបដូចការបន្ថែមថ្លៃឈ្នួលឲ្យសមគួរដល់អ្នកចេះសិល្ប-សាស្ត្រ ។

ធម៌ទាំងអស់នេះ ក៏ជាគំនរនៃធម៌ ១៧ ពួក គឺពួកធម៌ ៥ មានផស្ស: ជាដើម ១ អង្គនៃឈាន ១ ឥន្ទ្រិយ ១ អង្គនៃមគ្គ ១ ពល ១ មូល ១ កម្មបថ ១ លោកបាល ១ បស្សទ្ធិ ១ លហុតា ១ មុទិតា ១ កម្មញ្ញតា ១ បាគុញ្ញតា ១ ឧជុកតា ១ សតិសម្បជញ្ញ: ១ សមថវិបស្សនា ១ បគ្គាហាវិក្ខេប: ១ ដូច្នេះ ។

ធម្មុទ្ទេសវារ ចប់

# អភិធម្មបិដក

## ធម្មសង្គណី

[ ១៧ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈ កើតមានក្នុងសម័យនោះ ។

[ ១៨ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់សេចក្តីឆ្ងាញ់ពិសា និងសេចក្តីសុខនោះ ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។

[ ១៩ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា សេចក្តីសម្គាល់ ភាពនៃសេចក្តីសម្គាល់ណា ដែលកើតអំពីសម្ផស្សនៃមនោ-វិញ្ញាណធាតុ ដ៏សមគួរដល់កុសលសញ្ញានោះ ក្នុងសម័យនោះ នេះសញ្ញា កើតមានក្នុងសម័យនោះ ។

[ ២០ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា សេចក្តីរិះគិត ភាពនៃការត្រិះរិះណា ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណ-ធាតុ ដ៏សមគួរដល់កុសលចេតនានោះ ក្នុងសម័យនោះ នេះចេតនាកើតមាន ក្នុងសម័យនោះ ។

[ ២១ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដ៏សមគួរដល់ធម៌ មានផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះចិត្ត កើតមានក្នុងសម័យនោះ ។

[ ២២ ] វិតក្ក កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្ត គឺសម្មាសង្កប្បៈណា ក្នុងសម័យនោះ នេះវិតក្កកើតមានក្នុងសម័យនោះ ។

[ ២៣ ] វិចារ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រួតត្រាការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការផ្គងនូវចិត្ត ការសម្ញឹងមើលណា ក្នុងសម័យនោះ នេះវិចារកើតមានក្នុងសម័យនោះ ។

[ ២៤ ] បីតិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល សេចក្តីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណរ ការអណ្តែតអណ្តូង សេចក្តីត្រេកអរ របស់ចិត្តណា ក្នុងសម័យនោះ នេះបីតិកើតមានក្នុងសម័យនោះ ។

[ ២៥ ] សុខ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីផស្សៈរបស់ចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីផស្សៈរបស់ចិត្តណា ក្នុងសម័យនោះ នេះសុខកើតមាន

ក្នុងសម័យនោះ ។

[ ២៦ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅរបស់ចិត្ត ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ សភាពចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។

[ ២៧ ] សទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ជំនឿ សេចក្តីជឿ សេចក្តីជឿស៊ប់ សេចក្តីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលណា ក្នុងសម័យនោះ នេះសទ្ធិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ២៨ ] វីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សង្ខាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្ខាត ការមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈណា ក្នុងសម័យនោះ នេះវីរិយិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ២៩ ] សតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា ក្នុងសម័យនោះ នេះសតិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣០ ] សមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅរបស់ចិត្ត ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ៣១ ] បញ្ញិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល គ្រឿងសស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះបញ្ញិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣២ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតិដ៏ផូរផង់ ភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដ៏សមគួរដល់ធម៌ មានផស្សៈជាដើមនោះណា ក្នុងសម័យនោះ

នេះមនិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៣ ] សោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីផស្សៈនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតឡើងអំពីផស្សៈនៃចិត្តណា ក្នុងសម័យនោះ នេះសោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ៣៤ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ អាយុ ការស្ថិតនៅ ការយឺននៅ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តិទៅ ការរក្សានៃអរូបធម៌ទាំងនោះ គឺ ជីវិត ជីវិតិន្ទ្រិយណា ក្នុងសម័យនោះ នេះជីវិតិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៥ ] សម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្ដីជ្រះស្អាត ភាពនៃអ្នកមានសេចក្ដីក្ដីច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជាជន្ទញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះសម្មាទិដ្ឋិកើតមានក្នុងសម័យនោះ ។

[ ៣៦ ] សម្មាសង្កប្បៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្ត គឺសម្មាសង្កប្បៈណា ក្នុងសម័យនោះ នេះសម្មាសង្កប្បៈកើតមានក្នុងសម័យនោះ ។

[ ៣៧ ] សម្មាវាយាមៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សន្ធាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសន្ធាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ចុះនូវធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈណា ក្នុងសម័យនោះ នេះសម្មាវាយាមៈកើតមានក្នុងសម័យនោះ ។

[ ៣៨ ] សម្មាសតិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា ក្នុងសម័យនោះ នេះសម្មាសតិកើតមានក្នុងសម័យនោះ ។

[ ៣៩ ] សម្មាសមាធិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសម្មាសមាធិកើតមានក្នុងសម័យនោះ ។

[ ៤០ ] សទ្ធាពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ជំនឿ សេចក្តីជឿ សេចក្តីជឿស៊ប់ សេចក្តីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលណា ក្នុងសម័យនោះ នេះសទ្ធាពលកើតមានក្នុងសម័យនោះ ។

[ ៤១ ] វិរិយពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឧហាត សង្ខាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្វាត ការមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវិរិយៈ វិរិយិន្ទ្រិយ វិរិយពល សម្មាវាយាមៈណា ក្នុងសម័យនោះ នេះវិរិយពលកើតមានក្នុងសម័យនោះ ។

[ ៤២ ] សតិពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា ក្នុងសម័យនោះ នេះសតិពលកើតមានក្នុងសម័យនោះ ។

[ ៤៣ ] សមាធិពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសមាធិពលកើតមាន ក្នុងសម័យនោះ ។

[ ៤៤ ] បញ្ញាពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា

សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចជាផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្រ្តា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះបញ្ញាពលកើតមាន ក្នុងសម័យនោះ ។

[ ៤៥ ] ហិរិពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលខ្មាសដោយវត្ថុដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមកក្នុងសម័យនោះ នេះហិរិពលកើតមាន ក្នុងសម័យនោះ ។

[ ៤៦ ] ឱត្តប្បពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលតក់ស្លុតដោយវត្ថុដែលគួរតក់ស្លុត តក់ស្លុតដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះឱត្តប្បពលកើតមាន ក្នុងសម័យនោះ ។

[ ៤៧ ] អលោភៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការមិនចង់បាន ការមិនជាប់ជំពាក់ សេចក្តីមិនជាប់ជំពាក់ ការមិនត្រេកអរខ្លាំង ការមិនត្រេកត្រអាល សេចក្តីមិនត្រេកត្រអាល ការមិនសម្លឹងចំពោះ គឺ

អលោភៈជាកុសលមូលណា ក្នុងសម័យនោះ នេះអលោភៈ កើតមានក្នុងសម័យនោះ ។

[ ៤៨ ] អទោសៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនខឹង ការមិនប្រទូស្ត សេចក្តីមិនប្រទូស្ត ការមិនព្យាបាទ សេចក្តីមិនព្យាបាទ គឺអទោសៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអទោសៈ កើតមានក្នុងសម័យនោះ ។

[ ៤៩ ] អមោហៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការសម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល គ្រឿងសស្រ្តា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ គឺអមោហៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអមោហៈកើតមានក្នុងសម័យនោះ ។

[ ៥០ ] អនភិជ្ឈា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការមិនចង់បាន ការមិនជាប់ជំពាក់ សេចក្តីមិនជាប់ជំពាក់ ការមិនត្រេកអរខ្លាំង ការមិនត្រេកត្រអាល សេចក្តីមិនត្រេកត្រអាល ការមិនសម្លឹងចំពោះ គឺ

អលោភៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអនភិជ្ឈាកើតមានក្នុងសម័យនោះ ។

[ ៥១ ] អព្យាបាទ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនខឹង ការមិនប្រទូស្ត សេចក្តីមិនប្រទូស្ត ការមិនព្យាបាទ សេចក្តីមិនព្យាបាទ គឺអទោសៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអព្យាបាទកើតមានក្នុងសម័យនោះ ។

[ ៥២ ] សម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្ទួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល គ្រឿងសស្ត្រា គឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះសម្មាទិដ្ឋិកើតមាន ក្នុងសម័យនោះ ។

[ ៥៣ ] ហិរិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលខ្មាសដោយវត្ថុដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះហិរិកើតមានក្នុងសម័យនោះ ។

[ ៥៤ ] ឧត្តប្បៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលតក់ស្លុតដោយវត្ថុ ដែលគួរតក់ស្លុត តក់ស្លុតដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះឧត្តប្បៈ កើតមានក្នុងសម័យនោះ ។

[ ៥៥ ] សេចក្តីស្ងប់កាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្ងប់ សេចក្តីរម្ងាប់ ការស្ងប់ ការរម្ងាប់ សេចក្តីស្ងៀមស្ងាត់ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធក្នុងសម័យនោះ នេះសេចក្តីស្ងប់កាយ កើតមានក្នុងសម័យនោះ ។

[ ៥៦ ] សេចក្តីស្ងប់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្ងប់ សេចក្តីរម្ងាប់ ការស្ងប់ ការរម្ងាប់ សេចក្តីស្ងៀមស្ងាត់ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីស្ងប់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ៥៧ ] សេចក្តីស្រាលកាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្រាល ការបង្អោនទៅរហ័ស សេចក្តីមិនយឺតយូរ សេចក្តីមិនទម្រន់ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីស្រាលកាយ កើតមានក្នុងសម័យនោះ ។

[ ៥៨ ] សេចក្តីស្រាលចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្រាល ការបង្អោនទៅដោយរហ័ស សេចក្តីមិនយឺតយូរ សេចក្តីមិនទម្រន់ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីស្រាលចិត្តកើត

មានក្នុងសម័យនោះ ។

[ ៥៩ ] សេចក្តីទន់កាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីទន់ សេចក្តីទោរ សេចក្តីមិនរឹង មិនរបឹងណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីទន់កាយ កើតមានក្នុងសម័យនោះ ។

[ ៦០ ] សេចក្តីទន់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីទន់ សេចក្តីទោរ សេចក្តីមិនរឹង មិនរបឹងណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីទន់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ៦១ ] កាយគួរដល់ការងារ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការគួរដល់ការងារ សេចក្តីគួរដល់ការងារ សភាពគួរដល់ការងារណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះកាយគួរដល់ការងារ កើតមានក្នុងសម័យនោះ ។

[ ៦២ ] ចិត្តគួរដល់ការងារ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការគួរដល់ការងារ សេចក្តីគួរដល់ការងារ សភាពគួរដល់ការងារណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះចិត្តគួរដល់ការងារ កើតមានក្នុងសម័យនោះ ។

[ ៦៣ ] សេចក្តីស្ទាត់កាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ទាត់ សេចក្តីស្ទាត់ សភាពស្ទាត់ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធក្នុងសម័យនោះ នេះសេចក្តីស្ទាត់កាយកើតមានក្នុងសម័យនោះ ។

[ ៦៤ ] សេចក្តីស្ងាត់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ងាត់ សេចក្តីស្ងាត់ សភាពស្ងាត់ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីស្ងាត់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ៦៥ ] សេចក្តីត្រង់កាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រង់ សេចក្តីត្រង់ ការមិនវៀច មិនកោង មិនវំពត់ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីត្រង់កាយ កើតមានក្នុងសម័យនោះ ។

[ ៦៦ ] សេចក្តីត្រង់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រង់ សេចក្តីត្រង់ ការមិនវៀច មិនកោង មិនវំពត់ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីត្រង់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ៦៧ ] សតិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះ ស្មារតី ការនឹកឃើញ ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា ក្នុងសម័យនោះ នេះសតិកើតមានក្នុងសម័យនោះ ។

[ ៦៨ ] សម្បជញ្ញៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្តីជ្រះស្អាត ភាពនៃអ្នកមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត ការយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្ម-

ជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្ទញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះសម្បជញ្ញៈ កើតមានក្នុងសម័យនោះ ។

[ ៦៩ ] សមថៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសមថៈ កើតមានក្នុងសម័យនោះ ។

[ ៧០ ] វិបស្សនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្តីជ្រះស្អាត ភាពនៃអ្នកមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្ទញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះវិបស្សនា កើតមានក្នុងសម័យនោះ ។

[ ៧១ ] សេចក្តីផ្គងឡើង កើតមានក្នុងសម័យនោះ តើដូចម្តេច ។

ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ឃ្មាតខ្មី ខ្នះខ្នែង សេចក្ដីសង្វាត មិនធូរថយ ការមិនដាក់ចុះនូវសេចក្ដីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវិរិយៈ វិរិយិន្ទ្រិយ វិរិយពល សម្មាវាយាមៈណា ក្នុងសម័យនោះ នេះសេចក្ដីផ្គងឡើង កើតមានក្នុងសម័យនោះ ។

[ ៧២ ] សេចក្ដីមិនរាយមាយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសេចក្ដីមិនរាយមាយ កើតមានក្នុងសម័យនោះ ។

[ ៧៣ ] មួយទៀត ពួកអរូបធម៌ដទៃណា ដែលកើតឡើងដោយអាស្រ័យហេតុ រមែងកើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

**បទភាជនីយ ចប់**

**បឋមភាណវារ ចប់**

# អដ្ឋកថា

## និទ្ទេសវារ កាមាវចរកុសល

[ ១៧ ] ឥឡូវនេះ លោកបំណងនឹងចែកបទ ៥៦ ដែលលើកឡើងកាន់ព្រះបាលី ក្នុងធម្មុទ្ទេសវារទាំងនោះឯង ទើបទ្រង់ផ្ដើមនិទ្ទេសវារដោយន័យជាដើមថា **កតមោ តស្មឹ សមយេ ផស្សោ ហោតិ** ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ដូច្នេះ ។

គួរជ្រាបសេចក្ដីនេះនៃសំណួរ ក្នុងនិទ្ទេសនោះជាមុនសិន ហើយគប្បីជ្រាបសេចក្ដីក្នុងសំណួរទាំងអស់ដោយន័យនេះថា មហាចិត្តដែលជាអសង្ខារិក សហគតៈដោយសោមនស្ស ជាតិហេតុកៈ ខាងកាមាវចរកុសល កើតឡើងក្នុងសម័យណា ក្នុងសម័យនោះ ផស្សៈណា ដែលទ្រង់ត្រាស់ថា កើតមានផស្សៈនោះ តើដូចម្ដេច ។

បទថា **យោ តស្មឹ សមយេ ផស្សោ** សេចក្ដីថា ការប៉ះខ្ទប់ដែលកើតឡើងដោយអំណាចនៃធម៌ដែលប៉ះខ្ទប់ឯណា ការប៉ះខ្ទប់នោះ ក្នុងសម័យនោះ ។ ពាក្យថា ផស្សៈនេះ ឈ្មោះថា ជាបទសភាវធម៌ ព្រោះសម្ដែងសភាវៈរបស់ផស្សៈ ។ បទថា **ផុសនា** បានដល់ អាការដែលពាល់ត្រូវ ។ បទថា **សម្ផុសនា** បានដល់ អាការដែលប៉ះខ្ទប់ព្រមគ្នានុ៎ះឯង ទ្រង់បន្ថែមបទឧបសគ្គ ហើយត្រាស់ថា **សម្ផុសនា** ។ បទថា **សម្ផុសិតត្តំ** បានដល់ភាវៈដែលត្រូវប៉ះខ្ទប់ហើយ ។ ក៏ក្នុងនិទ្ទេសវារនេះ មានពាក្យប្រកបសេចក្ដីដូចតទៅ

ផស្សៈឯណា រមែងមានដោយអំណាចនៃធម៌ដែលពាល់ត្រូវ ក្នុងសម័យនោះ កិរិយាដែលប៉ះខ្ទប់ឯណា រមែងមានក្នុងសម័យនោះ កិរិយាដែលពាល់ត្រូវឯណា រមែងមានក្នុងសម័យនោះ ការពាល់ត្រូវឯណា រមែងមានក្នុងសម័យនោះ ។ មួយាងទៀត ផស្សៈឯណា រមែងមានដោយអំណាចនៃធម៌ដែលប៉ះខ្ទប់ក្នុងសម័យនោះ ដោយបរិយាយដទៃ ទ្រង់ត្រាស់ហៅថា **ផុសនា** ( ការពាល់ត្រូវ ) **សម្ផុសនា** ( ការប៉ះពាល់ ) **សម្ផុសិតត្តា** ( ការទង្គិកទង្គិច ) សភាវៈនេះ ឈ្មោះថា **ផស្សៈ** រមែងមានក្នុងសម័យនោះ ។ ក្នុងនិទ្ទេសទាំងឡាយ ធម៌ មានវេទនាជាដើម គប្បីជ្រាបយោជនាចំពោះបទដោយន័យនេះ ។ ចំណែកសេចក្ដីវិនិច្ឆ័យ ក្នុងការចែកបទដែលប្រើដោយទូទៅ ក្នុងបទទាំងអស់ ក្នុងនិទ្ទេសវារដូចតទៅនេះ

ព្រះមានព្រះភាគ កាលទ្រង់ចែកកាមាវចរមហាកុសលចិត្តដួងទីមួយហើយ ទ្រង់ដាក់បទធម៌ជាង ៥០ ដោយអំណាចនៃមាតិកា ទើបទ្រង់កាន់យកបទធម៌ជាង ៥០ បទនេះ មួយបទៗ លើកឡើងចែកទៀត បទធម៌ទាំងនោះកាលដល់នូវការចែក រមែងដល់នូវការចែកដោយហេតុ ៣ ប្រការ ។ បទធម៌ទាំងនោះ កាលផ្សេងគ្នា ក៏រមែងផ្សេងគ្នាដោយហេតុ ៤ ប្រការ ។ ក្នុងនិទ្ទេសវារនេះ កាលសម្ដែងដោយប្រការដទៃទៀត រមែងបានឋានៈ ២ ប្រការ ។ បានយ៉ាងដូចម្ដេច ពិតហើយ បទទាំងនោះ រមែងដល់នូវការចែកដោយហេតុទាំង ៣ ប្រការនេះ គឺដោយអំណាចព្យញ្ជនៈ ១ ដោយអំណាចឧបសគ្គ ១ ដោយអំណាចអត្ថ ១ ។

បណ្ដាហេតុទាំង ៣ ប្រការនោះ បណ្ឌិតគប្បីជ្រាបដល់ការចែកដោយអំណាចនៃព្យញ្ជនៈ ( អភិធម្ម ធម្មសង្គណិ ) យ៉ាងនេះថា **កោធោ** ការក្រោធ **កុជ្ឈនា** ការខឹង **កុជ្ឈិតត្តំ** ភាពនៃចិត្តខឹង **ទោសោ** សេចក្ដីប្រទូស្ដ **ទុស្សនា** អាការប្រទូស្ដ **ទុស្សិតត្តំ** ភាពនៃចិត្តប្រទូស្ដ ពិតហើយ ក្នុងហេតុទាំងនេះ សេចក្ដីក្រោធតែម្យ៉ាងប៉ុណ្ណោះ ដល់នូវការចែកយ៉ាងនេះ ដោយអំណាចនៃព្យញ្ជនៈ ។

ចំណែកការចែកដោយអំណាចនៃឧបសគ្គ គប្បីជ្រាបយ៉ាងនេះថា **ចារោ** ការត្រួតត្រា **វិចារោ** ការពិចារណា **អនុវិចារោ** ការពិនិត្យមើល **ឧបវិចារោ** ការសង្កេតមើល ។

គប្បីជ្រាបដល់ការចែកដោយអំណាចនៃអត្ថយ៉ាងនេះថា **បណ្ឌិច្ចំ** ភាពនៃបណ្ឌិត **កោសល្លំ** ភាពនៃអ្នកឈ្លាស **នេបុញ្ញំ** ភាពនៃបុគ្គលមានសេចក្ដីជ្រះស្អាត **វេភព្យា** ភាពនៃបុគ្គលមានសេចក្ដីភ្លឺច្បាស់ **ចិន្តា** សេចក្ដីគិត **ឧបបរិក្ខា** សេចក្ដីយល់ ។ បណ្ដាការចែកបទធម៌ទាំងនោះ ការចែកទាំង ៣ នេះ រមែងបានក្នុងនិទ្ទេសនៃបទផស្សៈមុន ។ ពិតហើយ បទថា **ផស្សោ** ផស្សៈ **ផុសនា** ការពាល់ត្រូវ បានដល់ ការចែកដោយអំណាចព្យញ្ជនៈ ។ បទថា **សម្ផុសនា** ការប៉ះពាល់ បានដល់ ការចែកដោយឧបសគ្គ ។ បទថា **សម្ផុសិតត្តំ** ការទង្គិកទង្គិច បានដល់ ការចែកដោយអត្ថ ។ គប្បីជ្រាបការចែកក្នុងនិទ្ទេសនៃបទទាំងពួងដោយន័យនេះ ។

ចំណែកធម៌ទាំងឡាយ កាលមានបទផ្សេងគ្នា រមែងផ្សេងគ្នាដោយហេតុ

៤ ប្រការនេះ គឺ **នាមនានត្តេន** សេចក្ដីផ្សេងគ្នាដោយឈ្មោះ ១ **លក្ខ-ណនានត្តេន** សេចក្ដីផ្សេងគ្នាដោយលក្ខណៈ ១ **កិច្ចនានត្តេន** សេចក្ដីផ្សេងគ្នាដោយកិច្ច ១ **បដិក្ខេបនានត្តេន** សេចក្ដីផ្សេងគ្នាដោយការបដិសេធ ១ បណ្ដាការផ្សេងគ្នាទាំងនោះ គប្បីជ្រាបការផ្សេងគ្នាដោយនាមនានត្តយ៉ាងនេះ ក្នុងទីនេះថា ធម៌ទាំង ២ នេះ គឺព្យាបាទក្ដី ទោសៈក្ដី ក្នុងប្រយោគ ( អភិធម្ម ធម្មសង្គណិ ) នេះថា ព្យាបាទ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីខឹង ការប្រទូស្ត ... ណា ក្នុងសម័យនោះ ដូច្នេះ គឺសេចក្ដីក្រោធនោះឯង តែដល់នូវការផ្សេងគ្នាដោយឈ្មោះ ។

ពិតហើយ ខន្ធទាំង ៥ មានគំនរមួយប៉ុណ្ណោះ ព្រោះអត្ថថា ជាគំនរ តែក្នុងគំនរមួយនេះ ជា ៥ គំនរ ដោយលក្ខណនានត្ត គឺរូប មានការបែកធ្លាយជាលក្ខណៈ វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ សញ្ញា មានការចាំអារម្មណ៍ជាលក្ខណៈ ចេតនា មានការតាំងចិត្តជាលក្ខណៈ វិញ្ញាណ មានការដឹងអារម្មណ៍ជាលក្ខណៈ ។ គប្បីជ្រាបលក្ខណនានត្ត ដោយប្រការដូច្នេះ ។

ពោលដោយកិច្ចនានត្ត សេចក្ដីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ មកហើយក្នុងឋានៈទាំង ៤ យ៉ាង ( ក្នុងអភិធម្ម វិភង្គ ) នេះថា ភិក្ខុក្នុងសាសនានេះ ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធសេចក្ដីព្យាយាម ផ្គង់ចិត្ត តម្កល់ចិត្ត ដើម្បីញ៉ាំងពួកធម៌អកុសលដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដូច្នេះ ។ គប្បីជ្រាបកិច្ចនានត្ត ដោយប្រការដូច្នេះ ។

គប្បីជ្រាបការផ្សេងគ្នា ដោយបដិក្ខេបនានត្ត ដូចក្នុងប្រយោគជាដើមថា អធម៌ ៤ ប្រការ គឺភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីលុបគុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ដូច្នេះ ។

ការផ្សេងគ្នាទាំង ៤ យ៉ាងនេះ រមែងបានក្នុងផស្សៈប៉ុណ្ណោះក៏ទេ រមែងបានក្នុងធម៌ទាំងអស់ មានពួក ៥ មានផស្សៈជាដើម ។ ពិតហើយ បទថា **ផស្សោ** ជាឈ្មោះរបស់ផស្សៈ ។បេ។ បទថា **ចិត្តំ** ជាឈ្មោះរបស់ចិត្ត ( នេះហៅថា នាមនានត្ត ) ។ ផស្សៈ មានការពាល់ត្រូវជាលក្ខណៈ វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ សញ្ញា មានការចាំអារម្មណ៍ជាលក្ខណៈ ចេតនា មានការតាំងចិត្តជាលក្ខណៈ វិញ្ញាណ មានការដឹងអារម្មណ៍ជាលក្ខណៈ ( នេះហៅថា លក្ខណនានត្ត ) ។ មួយទៀត ផស្សៈ មានការពាល់ត្រូវជាកិច្ចប៉ុណ្ណោះ វេទនា មានការសោយអារម្មណ៍ជាកិច្ច សញ្ញា មានការចាំអារម្មណ៍ជាកិច្ច ចេតនា មានការតាំងចិត្តជាកិច្ច វិញ្ញាណ មានការដឹងអារម្មណ៍ជាកិច្ច ។ គប្បីជ្រាបកិច្ចនានត្តយ៉ាងនេះ ដោយប្រការដូច្នេះ ។

ការផ្សេងគ្នាដោយបដិក្ខេបនានត្តក្នុងធម៌ពួក ៥ មានផស្សៈជាដើម មិនមាន ។ តែក្នុងនិទ្ទេសនៃធម៌ មានអលោភៈជាដើម ដោយន័យជាដើមថា ការមិនលោភ កិរិយាដែលមិនលោភ ភាពជាអ្នកមិនលោភ ដូច្នេះ គប្បី

ជ្រាបការផ្សេងគ្នាដោយការផ្សេងគ្នា គឺ ការបដិសេធ ដោយប្រការដូច្នេះ ។ គប្បីជ្រាបការផ្សេងគ្នាទាំង ៤ យ៉ាង ដោយអំណាចនៃបទ តាមដែលបាន ក្នុងនិទ្ទេសនៃបទទាំងអស់ ដោយប្រការដូច្នេះ ។

ចំណែកការសម្ដែងដោយប្រការដទៃទៀត រមែងបាន ២ ឋានៈយ៉ាងនេះ គឺ **បទត្ថុតិ** ( បទសួស្ដី ) **ទឡ្ហីកម្ម** ( បទដែលធ្វើសេចក្ដីឲ្យមាំ ) មែនពិត កាលព្រះមានព្រះភាគត្រាស់ថា ផស្សៈ ត្រឹមតែម្ដងដូចការសង្កត់ចុងឈើច្រត់ចុះ មួយបទនៅមិនទាន់ឈ្មោះថាពាល់ត្រូវហើយ ការប្រជាប់ហើយ តាក់តែងហើយ កាលត្រាស់រឿយៗ ថា **ផស្សោ ផុសនា សម្ផុ-សនា សម្ផុសិតត្តំ** ដោយអំណាចនៃព្យញ្ជនៈ ដោយអំណាចនៃឧបសគ្គ ដោយអំណាចនៃអត្ថ បទនោះឈ្មោះថា ពាល់ត្រូវហើយ ប្រជាប់ហើយ តាក់តែងហើយ ។ ប្រៀបដូចគីលៀង ផ្ងូតទឹកឲ្យព្រះរាជកុមារហើយ យកសំពត់គួរជាទីគាប់ចិត្តដណ្ដប់ហើយ យកផ្កាទាំងឡាយប្រដាប់ហើយ បន្តក់ថ្នាំភ្នែកហើយ បន្ទាប់អំពីនោះ ក៏យកមនោសិលា បន្តក់ថ្ងាសត្រឹមមួយចំណុចប៉ុណ្ណោះ ត្រឹមតែប៉ុណ្ណោះ នៅមិនទាន់ឈ្មោះថា មានស្នាមបន្តក់ដែលស្រស់ស្អាត តែកាលគីលៀងយកពណ៌ផ្សេងៗមកបន្តក់ជុំវិញ ទើបឈ្មោះថា មានស្នាមបន្តក់ដែលស្អាត យ៉ាងណា សេចក្ដីឧបមាជាគ្រឿងប្រៀបធៀបនេះ គប្បីឃើញយ៉ាងនោះចុះ ។ នេះឈ្មោះថា **បទត្ថុតិ ។** ការពោលរឿយៗ ទុំះឯងដោយអំណាចព្យញ្ជនៈ ដោយអំណាចអត្ថ និងដោយអំណាចឧបសគ្គ ឈ្មោះថា **ទឡ្ហីកម្ម ។** ប្រៀបដូចកាលពោលថា អាវុសោគ្គី ភន្តេគ្គី យក្សគ្គី ពស់

ក្តី មិនឈ្មោះថា ពោលធ្វើសេចក្តីឲ្យមាំ តែកាលពោលថា អាវុសោ អាវុសោ ភន្តេ ភន្តេ យក្ស យក្ស ពស់ ពស់ ដូច្នេះ ទើបឈ្មោះថា ពោលធ្វើសេចក្តីឲ្យមាំ យ៉ាងណា កាលព្រះមានព្រះភាគ ត្រាស់បទថា ផស្សៈ ក៏យ៉ាងនោះដូចគ្នា ដូចជាការសង្កត់ចុងឈើប្រត់ត្រឹមតែម្តង មិនឈ្មោះថា ជាការពោលធ្វើសេចក្តីឲ្យមាំ តែកាលត្រាស់រឿយៗ ថា **ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ** ដោយអំណាចព្យញ្ជនៈ ដោយអំណាចឧបសគ្គ និងដោយអំណាចអត្ថទុំ:ឯង ទើបឈ្មោះថា ជាការត្រាស់ធ្វើសេចក្តីឲ្យមាំ ការសម្តែងដោយបរិយាយដទៃ រមែងបានឋានៈ ២ ដោយប្រការដូច្នេះ ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងបទទាំងអស់ ក្នុងនិទ្ទេសនៃបទ ដែលបានដោយអំណាចនៃអត្ថនេះចុះ ។

បទថា **អយំ តស្មឹ សមយេ ផស្សោ ហោតិ** សេចក្តីថា កាមាវចរមហាកុសលចិត្តដួងទីមួយ រមែងកើតឡើងក្នុងសម័យណា ឈ្មោះថា ផស្សៈនេះ រមែងមានក្នុងសម័យនោះ ។ កិច្ចពណ៌នានិទ្ទេសបទនៃផស្សៈត្រឹមប៉ុណ្ណោះមុន បន្ទាប់អំពីនេះទៅ ខ្ញុំនឹងពណ៌នាត្រឹមតែការផ្សេងគ្នា ក្នុងនិទ្ទេសដទៃៗ នៃបទ មានវេទនាជាដើម ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលក្នុងនិទ្ទេសនៃផស្សៈនេះឯង ។

# អធិប្បាយ

## វេទនានិទ្ទេសជាដើម

[ ១៨-៧៣ ] ក្នុងបទថា **យំ តស្មឹ សមយេ** នេះ ព្រះមានព្រះភាគ ទ្រង់ផ្តើមពាក្យជាដើមថា វេទនាក្នុងសម័យនោះ ដូចម្តេច ដូច្នេះក៏ពិតមែន ទោះបីជាយ៉ាងនោះ ក៏ត្រាស់ពាក្យថា **យំ** ដោយអំណាចនៃបទថា សាតៈ ( សេចក្តីឆ្ងាញ់ពិសា ) វេទនាដែលគួរ ដែលសមដល់សេចក្តីឆ្ងាញ់ពិសា នោះ ត្រាស់ហៅថា **តជ្ជា** ក្នុងបទថា **តជ្ជាមនោវិញ្ញាណធាតុសម្ផស្សជំ** នេះ ។ ពិតហើយ **តជ្ជា** សព្ទនេះ មានអត្ថថា សមគួរក៏មាន ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា សមគួរដល់សេចក្តីសុខដែលជាទីត្រេកអរនោះ ពិតហើយ តជ្ជាសព្ទនេះ **តជ្ជំ តស្សារុប្បំ កថំ មន្តេតិ** អ្នកផងតែងប្រឹក្សាពាក្យដែលកើតអំពីអំពើនោះ សមគួរដល់អំពើនោះ ដូច្នេះ ។

ម្យ៉ាងទៀត ដែលឈ្មោះថា **តជ្ជា** ព្រោះកើតអំពីអារម្មណ៍ មានរូបា-រម្មណ៍ជាដើមទាំងនោះឯង កើតអំពីបច្ច័យនៃសេចក្តីសុខនេះ ។ ឈ្មោះថា ធាតុ ព្រោះអត្ថថា មិនមែនសត្វ ធាតុ គឺមនោវិញ្ញាណ ព្រោះហេតុនោះ ទើបឈ្មោះថា មនោវិញ្ញាណធាតុ ។ សេចក្តីត្រេកអរណា កើតអំពីសម្ផស្ស ឬកើតក្នុងសម្ផស្ស ព្រោះហេតុនោះ សេចក្តីត្រេកអរនោះ ឈ្មោះថា សម្ផស្សជៈ ។ ឈ្មោះថា ចេតសិក ព្រោះអាស្រ័យចិត្ត ។ ឈ្មោះថា សាតៈ ព្រោះអត្ថថា គាប់ចិត្ត ។ មានអធិប្បាយថា សេចក្តីត្រេកអរផ្គួរចិត្តណា ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដែលសមគ្នាដោយអត្ថ ដូច

ពោលហើយក្នុងសម័យនោះ សេចក្តីត្រេកអរផ្លូវចិត្តនេះ ឈ្មោះថា វេទនា មានក្នុងសម័យនោះ ។ គប្បីជ្រាបការប្រកបពាក្យទាំងពួង ដោយប្រការដូច្នេះ ។

ឥឡូវនេះ ក្នុងបទថា **ចេតសិកំ សុខំ** ជាដើម ព្រះមានព្រះភាគទ្រង់បដិសេធសេចក្តីសុខតាមផ្លូវកាយដោយបទថា ចេតសិក ទ្រង់បដិសេធទុក្ខតាមផ្លូវចិត្តដោយបទថា សុខ ។ បទថា **ចេតោសម្ផស្សជំ** បានដល់ កើតក្នុងសម្ផស្សនៃចិត្ត ។ បទថា **សាតំ សុខំ វេទយិតំ** បានដល់ សោយអារម្មណ៍ដែលគួរពេញចិត្ត មិនមែនអារម្មណ៍ដែលមិនគួរពេញចិត្ត សោយអារម្មណ៍ដែលជាសុខ មិនមែនអារម្មណ៍ដែលជាទុក្ខ ។ ចំណែក ៣ បទបន្ទាប់ ត្រាស់ដោយអំណាចឥត្ថីលិង្គ ។ សេចក្តីក្នុងបទទាំង ៣ នេះ មានត្រឹមប៉ុណ្ណេះថា វេទនាដែលគួរពេញចិត្ត មិនមែនវេទនាដែលមិនគួរពេញចិត្ត វេទនាដែលជាសុខ មិនមែនវេទនាដែលជាទុក្ខ ។

ក្នុងនិទ្ទេសនៃសញ្ញា ពាក្យថា **តជ្ជាមនោវិញ្ញាណធាតុសម្ផស្សជា** បានដល់ សញ្ញាកើតក្នុងសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់កុសលសញ្ញានោះ ។ បទថា **សញ្ញា** ជាឈ្មោះសភាវៈ ។ បទថា **សញ្ជានានា** បានដល់ អាការដែលចាំបាន ។ បទថា **សញ្ជានិតត្តំ** បានដល់ ភាវៈដែលចាំបាន ។ សូម្បីក្នុងនិទ្ទេសនៃចេតនា ក៏គប្បីជ្រាបដោយន័យនេះឯង ។

ក្នុងនិទ្ទេសនៃចិត្ត ដែលឈ្មោះថា ចិត្ត ព្រោះចិត្តជាធម្មជាតវិចិត្រ ។ ឈ្មោះថា មនោ ព្រោះកំណត់ដឹងអារម្មណ៍ ។ មនោនុ៎ះឯង ឈ្មោះថា

**មានសំ** ។ ពិតហើយ ធម៌ គឺរាគៈដែលសម្បយុត្តជាមួយចិត្ត ទ្រង់ហៅថា មានសៈ ក្នុងកន្ទុះគាថានេះថា **អន្តលិក្ខចរោ ចោសោ យ្វាយំ ចរតិ មានសោ** អន្ទាក់ គឺរាគៈណា ដែលត្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅក្នុងចិត្ត ដូច្នេះ ។

ព្រះអរហត្តទ្រង់ត្រាស់ហៅថា មានសៈ ដូចក្នុងព្រះគាថានេះថា

**កច្ចិន្នុ ភគវា តុយ្ហំ សាវកោ សាសនេ រតោ**
**អប្បត្តមានសោ សេខោ កាលំ កយិរា ជនេសុតា ។**

បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជនសាវករបស់ព្រះអង្គ ជាសេក្ខបុគ្គលមានបំណងមិនទាន់សម្រេច ( មិនទាន់សម្រេចអរហត្ត ) នៅត្រេកអរក្នុងសាសនា គប្បីធ្វើមរណៈកាល ដូចម្ដេចបាន ដូច្នេះ ។

តែក្នុងនិទ្ទេសនេះ មនោទ្ទុំឯង ឈ្មោះថា មានសៈ ព្រោះទ្រង់បន្ថែមបទនោះ ដោយអំណាចព្យញ្ជនៈ ។

ចិត្ត ឈ្មោះថា **ហទយំ** ។ ដើមទ្រូងហៅថា ហទយ ដូចក្នុងពាក្យនេះថា ខ្ញុំនឹងបន្សាត់ចិត្តលោក គឺធ្វើចិត្តឲ្យខូច ឬវះហឫទ័យ ( ដើមទ្រូង ) របស់លោក ដូច្នេះ ។ ចិត្ត ហៅថា ហទយ ដូចក្នុងប្រយោគនេះថា **ហទយា ហទយំ មញ្ញេ អញ្ញាយ តច្ឆត** សមីតិមាណពនេះ ហាក់ជាដឹងចិត្តដោយចិត្ត ហើយទើបចាំង ( នូវឈើ ) ដូច្នេះ ។ ហទយវត្ថុ ហៅថា ហទយ ដូចក្នុងប្រយោគជាដើមថា **វក្កំ ហទយំ** ទាច បេះដូង តែក្នុង

និទ្ទេសនេះ ចិត្តនោះឯង ហៅថា ហទយ ព្រោះអត្ថថា នៅខាងក្នុង ។ ចិត្តនុ៎ះឯង ឈ្មោះថា បណ្ឌរៈ ព្រោះអត្ថថា បរិសុទ្ធ ។ ពាក្យថា **បណ្ឌរៈ** នេះ សំដៅយកភវង្គចិត្ត ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះមានរស្មីផ្សាយចេញ ប៉ុន្តែចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុក ចូលមកធ្វើឲ្យសៅហ្មង ដូច្នេះ ។ មួយទៀត សូម្បីអកុសលក៏ត្រាស់ហៅថា បណ្ឌរៈដូចគ្នា ព្រោះចេញអំពីបណ្ឌរៈ ( ចិត្ត ) នោះ ដូចទឹកហូរចេញអំពីស្ទឹងគង្គា និងទឹកគោធាវរីហូរចេញអំពីស្ទឹងគោធាវរី ដូច្នោះ ។

ចំណែក មនោ សព្ទ ក្នុងបទថា **មនោ មនាយតនំ** នេះ មានអត្ថសម្តែងភាពដែលមនៈនុ៎ះឯង ជាអាយតនៈ ។ ដោយហេតុនោះ ទើបសម្តែងមនោសព្ទនោះថា សព្ទថា **មនោ** នេះ ឈ្មោះថា **មនាយតន** ព្រោះជាលំនៅនៃចិត្ត ដូចទេវាយតនៈ គឺលំនៅទេវតាក៏មិនមែន ដោយពិតអាយតនៈ គឺមនោ ឈ្មោះថា មនាយតនៈ ។ ក្នុងបទទាំងនោះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាទីអាស្រ័យនៅ ព្រោះអត្ថថា ជាប្រភពកើត ព្រោះអត្ថថា ជាទីប្រជុំ ព្រោះអត្ថថា ជាទីសម្រាប់កើត ព្រោះអត្ថថា ជាហេតុ ។

មែនពិត លំនៅក្នុងលោក ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **ឥស្សរាយតនំ** លំនៅរបស់ព្រះឥស្វរ **វាសុទេវាយតនំ** លំនៅរបស់ព្រះបាទវាសុទេព ។ ប្រភពកើត ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **សុវណ្ណាយតនំ** ប្រភពកើតនៃមាស **រតនាយតនំ** ប្រភពកើត

នៃរតនៈ តែក្នុងសាសនា ទីប្រជុំ ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា** ពួកសត្វតែងអាស្រ័យនឹងដើមឈើនោះ ប្រជុំគ្នាក្នុងទីជាទីរីករាយចិត្តជាដើម ដូច្នេះ ។ ទីកើត ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **ទក្ខិណាបថោ គុន្នំ អាយតនំ** ទក្ខិណាជនបថ ជាទីកើតនៃគោទាំងឡាយ ដូច្នេះ ។ ហេតុ ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **តត្រ តត្រេវ សក្ខិភព្វតំ ចាបុណាតិ សតិ សតិអាយតនេ** កាលបើហេតុនៃសតិមានហើយ ចិត្តក៏បានដល់នូវភាវៈជាក់ច្បាស់ ក្នុងធម៌នោះៗ ដូច្នោះឯង ដូច្នេះ ។ ក្នុងទីនេះ រមែងគួរទាំង ៣ អត្ថ គឺឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាទីកើត ព្រោះអត្ថថា ជាទីប្រជុំ និងព្រោះអត្ថថា ជាហេតុ ។

មែនពិត ធម៌ មានផស្សៈជាដើម រមែងកើតព្រមគ្នាក្នុងមនៈនេះ ព្រោះហេតុនោះ ទើបមនៈនេះឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាទីកើត ។ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ខាងក្រៅ រមែងប្រជុំចុះក្នុងមនៈនេះ ដោយភាពជាអារម្មណ៍ ព្រោះហេតុនោះ ទើបមនៈនេះ ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាទីប្រជុំ ។ មនៈនេះគប្បីជ្រាបថា ជាអាយតនៈ ព្រោះអត្ថថា ជាហេតុ ព្រោះជាហេតុ ដោយអត្ថថា ជាបច្ច័យ មានសហជាតប្បច្ច័យជាដើម ដល់ធម៌ទាំងឡាយ មានផស្សៈជាដើម ។ មនិន្ទ្រិយ មានអត្ថតាមដែលពោលមកហើយនុ៎ះឯង ។

ធម្មជាតដែលឈ្មោះថា វិញ្ញាណ ព្រោះដឹងច្បាស់ ១ន្ធ គឺវិញ្ញាណ

ឈ្មោះថា វិញ្ញាណក្ខន្ធ គប្បីជ្រាបសេចក្តីនៃវិញ្ញាណក្ខន្ធនោះដោយអំណាចភាពជាគំនរជាដើម ។ ពិតហើយ ខន្ធ ព្រះមានព្រះភាគត្រាស់ ដោយអត្ថថា ជាគំនរ ដូចក្នុងប្រយោគជាដើមថា **មហាឧទកក្ខន្ធោត្វេវ សង្ខ្យំ គច្ឆតិ** តាមពិតនោះ គឺដល់នូវការរាប់ថា គំនរទឹកធំ ដូច្នេះ ។ ខន្ធ ទ្រង់ត្រាស់ ដោយអត្ថថា គុណ ដូចក្នុងប្រយោគជាដើមថា **សីលក្ខន្ធោ សមាធិក្ខន្ធោ** សីលក្ខន្ធ ១ សមាធិក្ខន្ធ ១ ដូច្នេះ ។ ខន្ធ ត្រាស់ដោយអត្ថថា ត្រឹមតែជាបញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **អទ្ទសា ខោ ភគវា មហន្តំ ទារុក្ខន្ធំ** ព្រះមានព្រះភាគទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ ដូច្នេះ ។ តែក្នុងវិញ្ញាណក្ខន្ធនេះ ត្រាស់ខន្ធដោយរុឡ្ហីសព្ទ ( ពាក្យផ្សេង តែន័យផ្សេង ) ព្រោះអត្ថថា ជាគំនរ ចំណែកមួយនៃវិញ្ញាណក្ខន្ធ ទើបជាវិញ្ញាណមួយដួង ព្រោះហេតុនោះ វិញ្ញាណសូម្បីតែមួយដួង ដែលជាចំណែកមួយនៃវិញ្ញាណក្ខន្ធ ក៏ហៅថា វិញ្ញាណក្ខន្ធ ដោយការបន្ថែមឲ្យច្រើនឡើង ដូចបុគ្គលកាត់ចំណែកមួយនៃដើមឈើ លោកក៏ហៅថា កាត់ដើមឈើ ដូច្នោះ ។

បទថា **តជ្ជាមនោវិញ្ញាណធាតុ** បានដល់ មនោវិញ្ញាណធាតុដែលសមគួរដល់ធម៌ មានផស្សៈជាដើមទាំងនោះ ។ មែនពិត ក្នុងបទនេះ ចិត្តមួយដួងប៉ុណ្ណោះ លោកពោលឈ្មោះ ៣ យ៉ាង គឺឈ្មោះថា មនោ ព្រោះអត្ថថា កំណត់អារម្មណ៍ ឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹងច្បាស់អារម្មណ៍ ឈ្មោះថា ធាតុ ព្រោះអត្ថថា ជាសភាវៈ ឬព្រោះអត្ថថា មិន

មែនសត្វ ។ ហេតុនោះ ក្នុងពួក ៥ មានផស្សៈជាដើមនេះ ពោលដល់ផស្សៈមុន ព្រោះផស្សៈនោះ កើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដែលសមគ្គាក៏មិនមែន តែចិត្តក៏ជាមនោវិញ្ញាណធាតុដែលសមគ្គានោះឯង ហេតុនោះ ទើបទ្រង់មិនលើកបញ្ញត្តិថា ដែលកើតអំពីផស្សៈនៃមនោវិញ្ញាណធាតុដែលសមគ្គាក្នុង ២ បទនេះ ( ផស្សៈ និងចិត្ត ) ។ តែបញ្ញត្តិថា ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដែលសមគ្គា សូម្បីរកបានក្នុងបទវិតក្កជាដើម ក៏ទ្រង់មិនលើកឡើងសម្តែង ព្រោះបានកំណត់ហើយ ក្នុងពួក ៥ មានផស្សៈជាដើមនេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់ចែកធម៌ពួក ៥ មានផស្សៈជាដើមទាំងនេះ ចែកជាមួយផ្នែកៗ ហើយទ្រង់លើកឡើងកាន់បញ្ញត្តិ ឈ្មោះថា ធ្វើវត្ថុដែលធ្វើបានដោយក្រ ។ កាលបុគ្គលដាក់ទឹកផ្សេងៗ ប្រេងផ្សេងៗ ចូលទៅក្នុងភាជនៈមួយហើយកូរពេញមួយថ្ងៃ ការសម្លឹងមើលពណ៌ ឬការស្រង់ក្លិន ឬការភ្លក្សរស ក៏អាចដឹងការផ្សេងគ្នាបាន ព្រោះការផ្សេងគ្នានៃពណ៌ ក្លិន និងរស ។ ទោះបីជាដូច្នោះ គេក៏នាំគ្នាពោលថា ការធ្វើនោះជាការធ្វើបានដោយលំបាក ។ តែព្រះសម្មាសម្ពុទ្ធ កាលទ្រង់ចែកធម៌ គឺចិត្តនិងចេតសិកដែលមិនមែនរូបទាំងនេះ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍មួយ ធ្វើឲ្យជាផ្នែកៗ ហើយ ទ្រង់លើកឡើងកាន់បញ្ញត្តិ ឈ្មោះថា ទ្រង់ធ្វើវត្ថុដែលធ្វើបានលំបាកក្រៃលែង ។ ព្រោះហេតុនោះ ទើបព្រះនាគសេនត្ថេរ ថ្វាយព្រះពរស្តេចមិលិន្ទថា មហាបពិត្រ ព្រះមានព្រះភាគទ្រង់ធ្វើវត្ថុដែលធ្វើបាន

ដោយកម្រ ។

ស្តេចមិលិន្ទ ត្រាស់ថា បពិត្រព្រះនាគសេន ព្រះមានព្រះភាគទ្រង់ធ្វើអ្វីដែលធ្វើបានដោយកម្រ ។

ព្រះនាគសេនត្ថេរ ទូលថា មហាបពិត្រ ព្រះមានព្រះភាគ ទ្រង់ប្រាប់ការកំណត់ធម៌ គឺចិត្ត និងចេតសិកដែលមិនមែនរូបទាំងនេះ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយថា នេះជាផស្សៈ នេះជាវេទនា នេះជាសញ្ញា នេះជាចេតនា នេះជាចិត្ត ដូច្នេះ ឈ្មោះថា ធ្វើវត្ថុដែលធ្វើបានដោយកម្រ ។

ព្រះបាទមិលិន្ទត្រាស់ថា សូមលោកម្ចាស់ធ្វើឧបមា ។

ព្រះនាគសេនទូលថា មហាបពិត្រ ឧបមាដូចជនពួកខ្លះ ចូលមហាសមុទ្រដោយសំពៅ ហើយប្រើបាតដៃដួសទឹកភ្លក្សមើល គប្បីជ្រាបថា នេះជាទឹកស្ទឹងគង្គា នេះជាទឹកស្ទឹងយមុនា នេះជាទឹកស្ទឹងអចិរវតី នេះជាទឹកស្ទឹងសរភូ នេះជាទឹកស្ទឹងមហី ។

ព្រះបាទមិលិន្ទត្រាស់ថា បពិត្រព្រះនាគសេន ដឹងបានដោយលំបាក ។

ព្រះនាគសេន ទូលថា បពិត្រមហារាជ ការដែលព្រះមានព្រះភាគត្រាស់ប្រាប់ការកំណត់ធម៌ គឺចិត្ត និងចេតសិកដែលមិនមែនរូប ប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយថា នេះជាផស្សៈ ។បេ។ នេះជាចិត្ត ឈ្មោះថា ទ្រង់ធ្វើវត្ថុដែលធ្វើបានដោយលំបាកជាងនោះទៅទៀត ។

ក្នុងនិទ្ទេសនៃវិតក្ក ធម៌ដែលឈ្មោះថា **តក្កៈ** ព្រោះអំណាចនៃការត្រិះរិះ ។ បណ្ឌិតគប្បីជ្រាប ការប្រព្រឹត្តិទៅនៃការត្រិះរិះនោះ ដោយអំណាចនៃការ

ត្រិះរិះយ៉ាងនេះថា អ្នកត្រិះរិះប្រមាណប៉ុនណា អ្នកត្រិះរិះដល់ក្អម ត្រិះរិះដល់រទេះ ត្រិះរិះដល់យោជន៍ ត្រិះរិះដល់កន្លះយោជន៍ឬ នេះជាបទសម្ដែងសភាវៈនៃតក្កៈ ។ ធម៌ដែលឈ្មោះថា វិតក្ក ព្រោះអំណាចនៃការត្រិះរិះពិសេស ។ ពាក្យថា វិតក្កៈ នេះ ជាឈ្មោះនៃការត្រិះរិះដែលមានកម្លាំងច្រើនជាង ( តក្កៈនោះ ) ។ ធម៌ដែលឈ្មោះថា សង្កប្បៈ ព្រោះអំណាចនៃការកំណត់យ៉ាងល្អ ។ ធម៌ដែលឈ្មោះថា អប្បនា ព្រោះចិត្តដល់នូវភាពតែមួយចុះស៊ប់ក្នុងអារម្មណ៍ ។ ពាក្យទីពីរ ទ្រង់បន្ថែមឡើងដោយអំណាចឧបសគ្គ ។ ម្យ៉ាងទៀត អប្បនាដែលមានកម្លាំងជាង ឈ្មោះថា ព្យប្បនា ។ ធម្មជាតិដែលឈ្មោះថា **ចេតសោអភិរោបនា** ព្រោះលើកចិត្ត គឺតម្កល់ចិត្តទុកក្នុងអារម្មណ៍ ។ ធម៌ដែលឈ្មោះថា សម្មាសង្កប្បៈ ព្រោះជាសង្កប្បដែលដល់នូវភាពជាកុសល ដែលព្រះមានព្រះភាគទ្រង់សរសើរ ព្រោះជាការត្រិះរិះតាមសេចក្ដីពិត និងជាសេចក្ដីត្រិះរិះនាំសត្វចេញចាកវដ្តៈ ។

ក្នុងនិទ្ទេសនៃវិចារ ធម៌ដែលឈ្មោះថា ចារៈ ព្រោះត្រាច់ទៅក្នុងអា-រម្មណ៍ ។ បទនេះ ជាបទសម្ដែងសភាវៈរបស់ចារៈនោះ ដែលឈ្មោះថា វិចារ ព្រោះត្រាច់ទៅពិសេស ។ ឈ្មោះថា អនុវិចារ ព្រោះត្រាច់តាមទៅ ។ ឈ្មោះថា ឧបវិចារ ព្រោះត្រាច់ទៅជិត ។ បទទាំងនោះ ទ្រង់បន្ថែមដោយអំណាចឧបសគ្គ ។ ធម៌ដែលឈ្មោះថា **អនុសន្ធនតា** ព្រោះការតាំងចិត្តបន្តក្នុងអារម្មណ៍ ដូចការផ្ចាប់ព្រួញត្រង់ខ្សែធ្នូ ។ ធម៌ដែលឈ្មោះថា **អនុបេក្ខនតា** ព្រោះតាំងនៅដូចការសម្លឹងអារម្មណ៍ ។ ម្យ៉ាងទៀត ដែល

ឈ្មោះថា **អនុបេក្ខនតា** ព្រោះចិត្តមិនព្រងើយដោយអំណាចការត្រាច់ទៅពិសេស ។

ក្នុងនិទ្ទេសនៃបីតិ បទថា **បីតិ** ជាបទសម្តែងសភាវៈ ។ ភាវៈនៃបុគ្គលមានបាមោជ្ជហើយ ឈ្មោះថា បាមោជ្ជ ។ អាការនៃសេចក្តីសប្បាយ ឈ្មោះថា **អាមោទនា** អាការដែលស្រួល ឈ្មោះថា **បមោ–ទនា** ។ ការលាយបញ្ចូលគ្នានៃថ្នាំ ប្រេង ទឹកក្តៅ និងទឹកត្រជាក់ លោកហៅថា **មោទនា** យ៉ាងណា សូម្បីបីតិនេះក៏យ៉ាងនោះ ឈ្មោះថា **មោទនា** ព្រោះរួមធម៌ទាំងឡាយចូលគ្នា តែព្រះមានព្រះភាគទ្រង់ប្រជាប់ពាក្យ **មោទនា** ដោយឧបសគ្គ ហើយត្រាស់ថា **អាមោទនា** និង **បមោទនា** ។ ធម៌ដែលឈ្មោះថា **ហាស** ព្រោះធ្វើឲ្យរីករាយ ។ ឈ្មោះថា **បហាស** ព្រោះធ្វើឲ្យរីករាយទូទៅ ។ បទថា **បហាស** នេះ ជាឈ្មោះរបស់អាការដែលគួររីករាយត្រេកអរ ។ បទថា **វិត្តិ** បានដល់ ទ្រព្យជាគ្រឿងត្រេកអរ ( វិត្ត ) ។ ពាក្យថា **វិត្ត** នេះ ជាឈ្មោះរបស់ទ្រព្យ ។ បីតិនេះ ឈ្មោះថា **វិត្តិ** ព្រោះជាបច្ច័យឲ្យកើតសោមនស្ស ព្រោះដូចគ្នានឹងការត្រេកអរ ។ ដូចបុគ្គលមានទ្រព្យ អាស្រ័យទ្រព្យកើតសោមនស្ស យ៉ាងណា មនុស្សមានបីតិក៏អាស្រ័យបីតិកើតនូវសោមនស្សក៏យ៉ាងនោះ ។ ព្រោះហេតុនោះ ទើបទ្រង់ហៅបីតិថា **វិត្តិ** ។ ពាក្យថា **វិត្តិ** នេះ ជាឈ្មោះរបស់បីតិដែលតាំងនៅក្នុងសភាវៈនៃការត្រេកអរ ។ បុគ្គលអ្នកមានបីតិ ត្រាស់ហៅថា **ឧទគ្គ** ព្រោះកាយ និងចិត្តផុសឡើង គឺអណ្តែតឡើង ។ ភាវៈនៃកាយ និងចិត្តផុស

ឡើង អណ្តែតឡើង ឈ្មោះថា **ឧទ្ធច្ចំ** ។ ភាពជាអ្នកមានចិត្តជារបស់ខ្លួន ឈ្មោះថា **អត្តមនតា** ។ ពិតហើយ ចិត្តរបស់បុគ្គលមិនត្រេកអរ ( ក្រោធ ) មិនឈ្មោះថា ជាចិត្តរបស់ខ្លួន ព្រោះជាហេតុកើតនៃទុក្ខ ។ មួយទៀត ចិត្តរបស់បុគ្គលដែលត្រេកអរហើយ ឈ្មោះថា មានចិត្តជារបស់ខ្លួន ព្រោះជាហេតុឲ្យកើតសុខ ។ ដោយហេតុតាមដែលពោលមកនេះ ភាពជាអ្នកមានចិត្តជារបស់ខ្លួន ទើបឈ្មោះថា **អត្តមនតា** គឺមានចិត្តជារបស់ខ្លួន អធិប្បាយថា ភាវៈនៃបុគ្គលជាអ្នកមានចិត្តជារបស់ខ្លួន ។ ព្រោះភាពជាអ្នកមានចិត្តជារបស់ខ្លួននោះ មិនមែនរបស់បុគ្គលដទៃណាមួយ អធិប្បាយថា សភាពនោះជារបស់ចិត្តនោះឯង ។ មួយទៀត ព្រោះភាពជាអ្នកមានចិត្តជារបស់ខ្លួននោះ មិនមែនជាធម៌ដទៃ គឺជាចេតសិកធម៌ក៏យ៉ាងនោះ ទើបត្រាស់ថា **អត្តមនតា** ។

ក្នុងនិទ្ទេសនៃចិត្តស្សេកគ្គតា ធម្មជាតដែលឈ្មោះថា **ឋិតិ** ព្រោះតាំងមាំក្នុងអារម្មណ៍ដោយមិនញាប់ញ័រ ។ ពីរបទខាងក្រោយ លោកបន្ថែមបទឧបសគ្គចូលមក ។ ម្យ៉ាងទៀត ដែលឈ្មោះថា **សណ្ឋិតិ** ព្រោះប្រមូលសម្បយុត្តធម៌ទាំងឡាយមកតាំងទុកក្នុងអារម្មណ៍ ។ ដែលឈ្មោះថា **អវដ្ឋិតិ** ព្រោះឈមចុះកាន់អារម្មណ៍ គឺចូលទៅហើយតាំងនៅ ។ ពិតហើយ ខាងកុសលធម៌ ៤ គឺសទ្ធា សតិ សមាធិ បញ្ញា រមែងឈានចុះកាន់អារម្មណ៍ ។ ដោយហេតុនោះឯង ធម៌ គឺសទ្ធា ទ្រង់ត្រាស់ថា **ឱកប្បនា** ( សេចក្តីជឿស៊ប់ ) ។ សតិ ត្រាស់ថា **អបិលាបនតា** ( ការមិនកាន់ប្រឡំ ) ។

សមាធិ ត្រាស់ថា **អវដ្ឋិតិ** ( ការតាំងនៅស៊ប់ ) ។ បញ្ញា ត្រាស់ថា **បរិយោគាហណា** ( ការកាន់យក ) ។ ចំណែកខាងអកុសលធម៌ ៣ យ៉ាង គឺតណ្ហា ទិដ្ឋិ និងអវិជ្ជា រមែងឈមចុះកាន់អារម្មណ៍ ដោយហេតុនោះឯង ទើបធម៌ទាំងនោះទ្រង់ត្រាស់ថា ជាឱឃៈ តែក្នុងផ្នែកអកុសលនេះ ឯកគ្គតានៃចិត្តមិនជាសភាវៈមានកម្លាំង ប្រៀបដូចបុគ្គលយកទឹកស្រោចក្នុងទីដែលមានធូលី ទីនោះក៏រាបស្មើ ធូលីរមែងរម្ងាប់ទៅមួយជួរខណៈ កាលដីស្ងួត ធូលីក៏តាំងឡើងជាប្រក្រតីទៀត យ៉ាងណា ខាងអកុសល ឯកគ្គតានៃចិត្តមិនជាសភាវៈមានកម្លាំង ក៏យ៉ាងនោះ ។ តែខាងកុសល ឯកគ្គតានៃចិត្តមានកម្លាំងច្រើន ប្រៀបដូចបុគ្គលយកក្អមទឹកស្រោចក្នុងទីនោះ កាប់ដោយចបធ្វើនូវការជំ ជុសខាត់ លាបពណ៌ក្នុងទីនោះ រមែងប្រាកដដូចស្រមោលក្នុងកញ្ចក់ សូម្បីកន្លងទៅមួយរយឆ្នាំ ទីនោះក៏ជារបស់វិចិត្រ ដូចទើបនឹងធ្វើដូច្នោះ ។

ធម៌ដែលឈ្មោះថា **អវិសាហារ** ព្រោះជាបដិបក្ខចំពោះសេចក្តីរាយមាយដែលប្រព្រឹត្តទៅដោយអំណាចឧទ្ធច្ចៈ និងវិចិកិច្ឆា ។ ចិត្តដែលប្រព្រឹត្តទៅដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆានោះឯង ឈ្មោះថា រមែងរាយមាយ តែសេចក្តីរាយមាយបែបនោះមិនមាន ព្រោះហេតុនោះ ទើបសភាវៈនោះ ឈ្មោះថា **អវិក្ខេប** ។ ចិត្តដែលរសាត់ទៅដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆានោះឯង គឺឧទ្ធច្ចៈ និងវិចិកិច្ឆា រមែងនាំទៅផ្លូវនេះ និងផ្លូវនោះបាន តែភាវៈនេះជាភាវៈរបស់ចិត្ត ដែលមិនរសាត់ទៅដោយអាការយ៉ាងនោះ ព្រោះហេតុនោះ

ទើបឈ្មោះថា **អវិសាហាជមានសតា** ។

សមថ: ៣ យ៉ាង គឺចិត្តសមថ: អធិករណសមថ: និងសព្វសង្ខារ-សមថ: ឈ្មោះថា **សមថ:** ។

បណ្ដាសមថ:ទាំង ៣ នោះ ឯកគ្គតានៃចិត្តក្នុងសមាបត្តិ ៨ ឈ្មោះថា ចិត្តសមថ: ។ ពិតហើយ ព្រោះអាស្រ័យចិត្តសមថ:នោះ ការញាប់ញ័រនៃចិត្ត ការអន្ទះអន្ទែងនៃចិត្ត រមែងស្ងប់ គឺស្ងប់រម្ងាប់ ។ ព្រោះហេតុនោះ ទើបសមថ:នោះ ត្រាស់ហៅថា **ចិត្តសមថ:** ។ សមថ: ៧ យ៉ាង មានសម្មុខាវិន័យជាដើម ឈ្មោះថា អធិករណសមថ: ព្រោះអាស្រ័យអធិក-រណសមថ:នោះ អធិករណ៍ទាំងនោះ រមែងស្ងប់ គឺរមែងរម្ងាប់ ព្រោះហេតុនោះ ទើបសមថ:នោះ ត្រាស់ហៅថា **អធិករណសមថ:** ។ មួយទៀត ព្រោះសង្ខារទាំងអស់ អាស្រ័យព្រះនិព្វាន រមែងចូលទៅស្ងប់ គឺស្ងប់រម្ងាប់ ហេតុនោះ ទើបព្រះនិព្វាននោះ ត្រាស់ហៅថា **សព្វសង្ខារសមថ:** ។ ក្នុងអត្ថនេះ ទ្រង់ប្រាថ្នាយកចិត្តសមថ: ។ ធម៌ដែលឈ្មោះថា **សមាធិន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណ:នៃសមាធិ ។ ដែលឈ្មោះថា សមាធិពល ព្រោះមិនញាប់ញ័រក្នុងឧទ្ធច្ច: ។ បទថា **សម្មាសមាធិ** បានដល់ សមាធិតាមសេចក្ដីពិត សមាធិដែលជាគ្រឿងនាំចេញចាកវដ្ដ: សមាធិខាងកុសល ។

ក្នុងនិទ្ទេសនៃសទ្ធិន្ទ្រិយ ធម៌ដែលឈ្មោះថា **សទ្ធា** ព្រោះអំណាចនៃការជឿព្ទុទ្ធគុណជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **សទ្ធា** ព្រោះជឿ គឺ

ទៅកាន់រតនៈ មានព្រះពុទ្ធរតនៈជាដើម ។ អាការនៃការជឿ ឈ្មោះថា **សទ្ទហនា** ។ ដែលឈ្មោះថា **ឱកប្បនា** ព្រោះឈមចុះក្នុងពុទ្ធគុណជាដើម ដូចទម្លាយហើយជ្រែកចូលទៅ ។ ដែលឈ្មោះថា **អភិបសាទ** ព្រោះជាហេតុឲ្យសត្វទាំងឡាយ ជ្រះថ្លាយ៉ាងក្រៃលែងក្នុងពុទ្ធគុណជាដើម ឬថា ខ្លួនឯង រមែងជ្រះថ្លាក្រៃលែង ។ ឥឡូវនេះ ព្រោះព្រះមានព្រះភាគ កាលទ្រង់ប្រារព្ធបរិយាយដទៃដោយបទសមាស មានសទ្ធិន្ទ្រិយជាដើម ទ្រង់កាន់យកបទដើមហើយ ទ្រង់ធ្វើការចែកបទ សេចក្តីនេះ ជារឿងធម្មតាក្នុងព្រះអភិធម្ម ហេតុនោះ ទើបទ្រង់ត្រាស់ថា សទ្ធាទៀត ។ម្យ៉ាងវិញទៀត ភាពជាធំនៃស្រី ឈ្មោះថា ឥត្ថិន្ទ្រិយ យ៉ាងណា សទ្ធិន្ទ្រិយនេះយ៉ាងនោះក៏មិនមែន ។ ឥន្ទ្រិយ គឺសទ្ធានេះ ឈ្មោះថា **សទ្ធិន្ទ្រិយ** ដោយអាការយ៉ាងនេះ ទើបត្រាស់សទ្ធាទៀត ដើម្បីឲ្យដឹងដល់ការទាក់ទងនៃពាក្យដែលស្មើគ្នា ។ ក្នុងទំនងដូចគ្នានេះ គប្បីជ្រាបការប្រកបពាក្យសម្រាប់បទដើម ក្នុងនិទ្ទេសនៃបទទាំងពួងទៀត ។ ធម្មជាតដែលឈ្មោះថា **សទ្ធិន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃក្នុងលក្ខណៈនៃអធិមោក្ខ ។ ដែលឈ្មោះថា **សទ្ធាពល** ព្រោះមិនញាប់ញ័រក្នុងការមិនមានសទ្ធា ។

ក្នុងនិទ្ទេសនៃវីរិយិន្ទ្រិយ ពាក្យថា **ចេតសិកោ** នេះ ត្រាស់ដើម្បីសម្តែងភាពដែលវីរិយៈជាចេតសិកដោយពិតប្រាកដ ។ ពិតហើយ វីរិយៈនេះ សូម្បីពោលថា ជាកាយិកៈ គឺប្រព្រឹត្តទៅតាមផ្លូវកាយ ព្រោះកើតឡើងដល់បុគ្គលអ្នកដើរចង្រ្កមជាដើម ក្នុងសូត្រទាំងឡាយ ( ក្នុងសំយុត្តនិកាយ

មហាវារវគ្គ ) ជាដើមថា ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមណាប្រព្រឹត្តទៅក្នុងកាយ សេចក្តីព្យាយាមនោះ ជាវិរិយសម្ពោជ្ឈង្គ ១ សេចក្តីព្យាយាមណាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីព្យាយាមនោះ ជាវិរិយសម្ពោជ្ឈង្គ ១ រមែងមកកាន់ឧទ្ទេស ដោយប្រការដូច្នេះ ក៏មិនឈ្មោះថា ប្រព្រឹត្តទៅផ្លូវកាយដូចកាយវិញ្ញាណ ។ ដើម្បីសម្តែងថា វិរិយៈនោះ ប្រព្រឹត្តទៅតាមផ្លូវចិត្តតែម្យ៉ាង ទើបត្រាស់ថា **ចេតសិកោ** ។ ពាក្យថា **វីរិយារម្ភោ** បានដល់ការផ្តើម ពោល គឺសេចក្តីព្យាយាម ។ ដោយបទថា **វីរិយារម្ភោ** នេះ លោកបដិសេធការផ្តើមសេចក្តីព្យាយាមដ៏សេស ។ ពិតហើយ **អារម្ភ**សព្ទនេះ មកក្នុងអត្ថមិនមែនតិច គឺ **កម្ម អាបត្តិ កិរិយា វិរិយៈ ហឹសា វិកោបន** ( ការព្រាត់ប្រាស ) ។

ពិតហើយ មកក្នុងអត្ថថា **កម្ម** ដូចក្នុងប្រយោគជាដើមថា **យំកិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារម្ភបច្ចយា អារម្ភានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ** ទុក្ខនីមួយទាំងអស់តែងកើតឡើងព្រោះព្យាយាម ( កម្ម ) ជាបច្ច័យ ការមិនកើតឡើងនៃទុក្ខ ព្រោះរលត់នូវព្យាយាម ដូច្នេះ ។

មកក្នុងអត្ថថា **អាបត្តិ** ដូចក្នុងប្រយោគជាដើមថា **អារម្ភតិ ច វិប្បដិសារី ច ហោតិ** រមែងប្រារព្ធ ( ត្រូវអាបត្តិ ) ផង មានសេចក្តីក្តៅក្រហាយផង ដូច្នេះ ។

មកក្នុងអត្ថថា **កិរិយា** មានការបោះបង្គោលបូជាយញ្ញជាដើម ដូចក្នុងប្រយោគជាដើមថា **មហាយញ្ញា មហារម្ភា ន តេ ហោន្តិ មហាប្ផលា**

ការបូជាធំមានកិច្ចដែលត្រូវធ្វើច្រើន ការបូជាធំទាំងនោះ មិនមានផលឡើយ ដូច្នេះ ។

មកក្នុងអត្ថថា **វិរិយៈ** ដូចក្នុងប្រយោគជាដើមថា **អារភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ** អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាមក្នុងពុទ្ធសាសនា ដូច្នេះ ។

មកក្នុងអត្ថថា **ហឹសា** ដូចក្នុងប្រយោគជាដើមថា **សមណំ គោតមំ ឧទ្ទិស្ស បាណំ អារភន្តិ** ពួកជនតែងសម្លាប់ ( បៀតបៀន ) សត្វចំពោះព្រះសមណគោតម ដូច្នេះ ។

មកក្នុងអត្ថថា **វិកោបន** មានការកាត់ និងការកាប់ជាដើម ដូចក្នុងប្រយោគជាដើមថា **ពីជភូតគាមសមារម្ភា បដិវិរតោ ហោតិ** ភិក្ខុវៀរស្រឡះចាកការធ្វើពីជគាម និងភូតគាមឲ្យវិនាស ដូច្នេះ ។ តែក្នុងនិទ្ទេសនេះលោកបំណងយកវិរិយៈប៉ុណ្ណោះ ព្រោះហេតុនោះ ទើបត្រាស់ថា វិរិយារម្ភោ អធិប្បាយថា ការផ្តើម ពោល គឺសេចក្តីព្យាយាម ។ មែនពិត វិរិយៈត្រាស់ហៅថា **អារម្ភ** ដោយអំណាចនៃការផ្តើម ។ ពាក្យថា **អារម្ភោ** នេះ ជាបទសម្តែងសភាវៈរបស់វិរិយៈ ។ សភាវៈដែលឈ្មោះថា **និក្កម** ដោយអំណាចនៃការចេញទៅ ចាកការខ្ជិលច្រអូស ។ ដែលឈ្មោះថា **បរក្កម** ដោយអំណាចនៃការឈានចុះកាន់ប្រយោជន៍ដ៏ក្រៃលែងខាងមុខ ។ ដែលឈ្មោះថា **ឧយ្យាម** ដោយអំណាចសេចក្តីព្យាយាមចូលដល់ ។ ដែលឈ្មោះថា **វាយាម** ដោយអំណាចសេចក្តីព្យាយាម ប្រឹងប្រែង ។ ដែលឈ្មោះថា

**ឧស្សាហោ** ដោយអំណាចនៃសេចក្តីអត់ធន់ ។ ដែលឈ្មោះថា **ឧស្សោឡ្ហី** ដោយអំណាចនៃសេចក្តីឧស្សាហ៍ដ៏ក្រៃលែង ។ ដែលឈ្មោះថា **ថាម** ដោយអត្ថថា មាំទាំ ដែលឈ្មោះថា **ធិតិ** ព្រោះទ្រទ្រង់នូវការបន្តកុសលដោយអំណាចនៃការទ្រទ្រង់ ឬ ដោយការប្រព្រឹត្តិទៅមិនដាច់ខ្សែនៃចិត្ត និងចេតសិក ។

មួយវិញទៀត សភាវៈនោះឈ្មោះថា **និក្កម** ព្រោះបន្ទោបង់កាមទាំងឡាយ ឈ្មោះថា **បរក្កម** ព្រោះកាត់នូវចំណង ឈ្មោះថា **ឧយ្យាម** ព្រោះការដកឱយៈ ឈ្មោះថា **វាយាម** ព្រោះអត្ថថា ការទៅដល់ត្រើយ ឈ្មោះថា **ឧស្សាហោ** ព្រោះអត្ថថា ជាប្រធាន ឈ្មោះថា **ឧស្សោឡ្ហី** ព្រោះអត្ថថា មានប្រមាណក្រៃលែង ឈ្មោះថា **ថាម** ព្រោះអត្ថថា ដកឧបសគ្គ ( គ្រឿងរារាំង ) ឈ្មោះថា **ធិតិ** ព្រោះជាការធ្វើរបស់បុគ្គលដែលមានសេចក្តីត្រូវការ ។

ឈ្មោះថា **អសិថិលបរក្កមតា** ដោយអំណាចនៃការឈានទៅមិនធូរថយក្នុងវេលាប្រព្រឹត្តយ៉ាងនេះថា ស្បែក ១ សរសៃ ១ ឆ្អឹង ១ ចូរសល់នៅចុះ ដូច្នេះ អធិប្បាយថា សេចក្តីព្យាយាមដ៏មាំ សេចក្តីព្យាយាមយ៉ាងបួរផ្តាច់ ។ ព្រោះវីរិយៈនេះ មិនដាក់ចុះនូវឆន្ទៈ មិនដាក់ចុះនូវធុរៈ មិនឲ្យសេចក្តីខ្ជិលច្រអូសបាននូវឱកាស មិនលះបង់ នាំសេចក្តីពេញចិត្ត មិនធូរថយក្នុងឋានៈជាគ្រឿងសាងកុសលកម្ម ហេតុនោះ ទើបត្រាស់ វីរិយៈថា **អនិក្ខិត្តច្ឆន្ទតា** មិនដាក់ចុះនូវសេចក្តីប៉ុនប៉ង **អនិក្ខិត្តធុរតា** មិនដាក់

ចុះនូវធុរៈ ។ ដូចក្នុងទីដែលមានភក់ ម្ចាស់របស់គោពោលថា ចូរពួកអ្នកយកគោដែលអាចទាញនឹមទៅបាន គោនោះសូម្បីលុតជង្គង់លើផែនដី ក៏ស៊ូនាំទៅ មិនព្រមឲ្យនឹមធ្លាក់ដល់ដី យ៉ាងណា វីរិយៈក៏យ៉ាងនោះដូចគ្នា រមែងមិនបោះបង់ រមែងផ្គងធុរៈទៅក្នុងឋានៈជាគ្រឿងសាងកុសលកម្ម ព្រោះហេតុនោះ ទើបត្រាស់វីរិយៈថា **ធុរសម្បគ្គាហោ** ការផ្គងធុរៈ ។ ដែលឈ្មោះថា វីរិយិន្ទ្រិយ ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈនៃការផ្គង ។ ដែលឈ្មោះថា **វីរិយពល** ព្រោះមិនញាប់ញ័រក្នុងសេចក្តីខ្ជិលច្រអូស ។ ឈ្មោះថា **សម្មាវាយាម** ព្រោះសេចក្តីព្យាយាមក្នុងកុសលដែលនាំចេញអំពីសំសារវដ្តតាមសេចក្តីពិត ។

ក្នុងនិទ្ទេសនៃសតិន្ទ្រិយ ធម៌ដែលឈ្មោះថា **សតិ** ដោយអំណាចនៃការរឭក ។ ពាក្យនេះ ជាពាក្យសម្តែងសភាវៈរបស់សតិ ។ ឈ្មោះថា **អនុស្សតិ** ដោយអំណាចការតាមរឭក ដោយរឭករឿយៗ ។ ឈ្មោះថា **បដិស្សតិ** ដោយអំណាចការរឭកចំពោះ ដោយការរឭកដូចប្រព្រឹត្តទៅចំពោះមុខ ។ម្យ៉ាងទៀត ពាក្យដែលពោលហើយនេះ ត្រឹមតែជាការបន្ថែមដោយឧបសគ្គ ។ អាការដែលរឭក ឈ្មោះថា **សរណតា** ។ ព្រោះពាក្យថា **សរណតា** ជាឈ្មោះនៃសរណៈទាំង ៣ ហេតុនោះ ដើម្បីបដិសេធពាក្យដែលជាឈ្មោះនៃសរណៈទាំង ៣ នោះ ទើបទ្រង់ធ្វើសតិសព្ទដដែលទៀត ។ ក្នុងទីនេះ មានអធិប្បាយថា កិរិយាដែលរឭក គឺសតិ ។ ដែលឈ្មោះថា **ធារណតា** ព្រោះទ្រទ្រង់ចាំវត្ថុដែលបានស្តាប់ និងបានរៀន

មក ។ ភាវៈដែលមិនកាន់ប្រឡំ ព្រោះអត្ថថា ឈមចុះ គឺការចូលទៅក្នុងអារម្មណ៍ ឈ្មោះថា **អបិលាបនតា** ប្រៀបដូចសម្បកឃ្លោកជាដើមអណ្តែតនៅលើទឹក មិនលិចចូលទៅក្នុងទឹក យ៉ាងណា សតិអណ្តែតមិនលិចចូលទៅក្នុងអារម្មណ៍យ៉ាងនោះក៏មិនមែន ព្រោះសតិនោះ រមែងចូលទៅក្នុងអារម្មណ៍ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ការមិនកាន់ប្រឡំ ។ ដែលឈ្មោះថា **អសម្មុសនតា** ព្រោះការមិនភ្លេចភ្លាំងក្នុងការងារដែលធ្វើ និងពាក្យនិយាយ ដែលកន្លងមកយូរបាន ។ ដែលឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំជាងធម៌ដទៃ ក្នុងលក្ខណៈនៃការប្រាកដ ។ ឥន្ទ្រិយ គឺសតិ ហៅថា **សតិន្ទ្រិយ** ។ សតិនុ៎ះឯងជាឥន្ទ្រិយ ឈ្មោះថា សតិន្ទ្រិយ ។ ដែលឈ្មោះថា **សតិពល** ព្រោះមិនញាប់ញ័រក្នុងសេចក្តីប្រមាទ ។ ដែលឈ្មោះថា **សម្មាសតិ** ព្រោះជាសតិតាមសេចក្តីពិត ជាសតិនាំចេញចាកវដ្តៈ ជាសតិខាងកុសល ។

ក្នុងនិទ្ទេសនៃបញ្ញិន្ទ្រិយ ធម៌ដែលឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ការប្រកាសឲ្យដឹង គឺធ្វើសេចក្តីនោះៗ ឲ្យជាក់ច្បាស់ ។ ម្យ៉ាងទៀត ឈ្មោះថា **បញ្ញា** ព្រោះដឹងធម៌ទាំងឡាយដោយប្រការមានការមិនទៀងជាដើមនោះៗ ។ ពាក្យនេះ ជាបទសម្តែងសភាវៈ របស់បញ្ញានោះ ។ អាការដែលដឹងទូទៅ ឈ្មោះថា **បជាននា** ។ ដែលឈ្មោះថា **វិចយ** ព្រោះពិចារណាការមិនទៀងជាដើម ។ បទថា **បវិចយោ** ទ្រង់បន្ថែមឧបសគ្គ ។ ដែលឈ្មោះថា **ធម្មវិចយ** ព្រោះស្វែងរកធម៌ គឺសច្ចៈ ៤ ។ ដែលឈ្មោះថា **សល្លក្ខណា**

ដោយអំណាចការកំណត់អនិច្ចលក្ខណៈជាដើមបាន ។ សល្លក្ខណាទ្ទុំះឯង ត្រាស់ហៅថា **ឧបលក្ខណា បច្ចុបលក្ខណា** ដោយសេចក្តីផ្សេងគ្នានៃឧបសគ្គ ។ ភាវៈនៃបណ្ឌិត ឈ្មោះថា **បណ្ឌិច្ច** ។ ភាវៈនៃបុគ្គលអ្នកឈ្លាស ឈ្មោះថា **កោសល្ល** ។ ភាវៈនៃធម៌ដ៏ល្អិត ឈ្មោះថា **នេបុញ្ញ** ។ ភាវៈនៃការធ្វើឲ្យជាក់ច្បាស់នូវសេចក្តីមិនទៀងជាដើម ឈ្មោះថា **វេភព្យា** ។ ដែលឈ្មោះថា **ចិន្តា** ដោយអំណាចនៃការគិតនូវការមិនទៀងជាដើម ។ ម្យ៉ាងវិញទៀត ដែលឈ្មោះថា **ចិន្តា** ព្រោះកើតឡើងដល់បុគ្គលណា រមែងធ្វើបុគ្គលនោះឲ្យគិតដល់អនិច្ចលក្ខណៈជាដើម ។ ដែលឈ្មោះថា **ឧបបរិក្ខា** ព្រោះពិចារណាអនិច្ចលក្ខណៈជាដើម ។ បទថា **ភូរិ** ជាឈ្មោះរបស់បឋវី ( ផែនដី ) ។ បឋវីនេះ ដូចថា **ភូរិ** ព្រោះអត្ថថា ល្អិត និងធំទូលាយ ព្រោះហេតុនោះ ទើបឈ្មោះថា **ភូរិ** ។ ដោយហេតុនោះ ទើបពោលថា បឋវីហៅថា **ភូរិ** ។ បុគ្គលឈ្មោះថា មានបញ្ញាដូចផែនដី ព្រោះប្រកបដោយបញ្ញាដ៏ធំទូលាយដូចផែនដីនោះ ។ ម្យ៉ាងទៀត បទថា **ភូរិ** នេះ ជាឈ្មោះរបស់បញ្ញា ។ ដែលឈ្មោះថា **ភូរិ** ព្រោះត្រេកអរក្នុងអត្ថដែលពិត ។ ដែលឈ្មោះថា **មេធា** ព្រោះទម្លាយ បៀតបៀនកិលេស ដូចរន្ទះបាញ់ភ្នំថ្ម ។ ម្យ៉ាងទៀត ឈ្មោះថា **មេធា** ព្រោះអត្ថថា រៀន និងទ្រទ្រង់ចាំបានរហ័ស ។ ដែលឈ្មោះថា **បរិណាយិកា** ព្រោះកើតដល់សត្វណា រមែងនាំសត្វនោះទៅ ក្នុងកិច្ចបដិបត្តិប្រយោជន៍ និងក្នុងការចាក់ធ្លុះលក្ខណៈតាមសេចក្តីពិតក្នុងសម្បយុត្តធម៌ ។ ដែលឈ្មោះថា **វិបស្សនា** ព្រោះឃើញ

ច្បាស់ធម៌ទាំងឡាយដោយអំណាចនៃអនិច្ចលក្ខណៈជាដើម ។ ដែលឈ្មោះថា **សម្បជញ្ញ** ព្រោះដឹងអនិច្ចលក្ខណៈជាដើមដោយប្រការផ្សេងៗ ដោយប្រពៃ ។ ដែលឈ្មោះថា **បតោទ** ព្រោះចាក់ចិត្តដែលវៀចកោងរត់ទៅខុសផ្លូវ ឲ្យឡើងកាន់ផ្លូវ ដូចជន្ទញចាក់សេះសិន្ធពដែលរត់ទៅខុសផ្លូវ ឲ្យមកត្រូវផ្លូវ ។ បញ្ញាដូចជន្ទញ ឈ្មោះថា **បញ្ញាបតោទ** ។ ដែលឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការឃើញ ។ ឥន្ទ្រិយគឺបញ្ញា ហៅថា **បញ្ញិន្ទ្រិយ** ។ ដែលឈ្មោះថា **បញ្ញាពល** ព្រោះមិនញាប់ញ័រដោយអវិជ្ជា ។ បញ្ញាដូចសស្ត្រា ព្រោះអត្ថថា កាត់កិលេសឈ្មោះថា **បញ្ញាសត្ថំ** ។ ប្រាសាទ គឺបញ្ញា ព្រោះអត្ថថា ខ្ពស់ក្រៃលែងឈ្មោះថា **បញ្ញាបាសាទ** ។

ពន្លឺ គឺបញ្ញា ព្រោះអត្ថថា ភ្លឺទូទៅ ឈ្មោះថា **បញ្ញាអាលោក** ។ ឱកាសគឺបញ្ញា ព្រោះអត្ថថា បាំងបែង ឈ្មោះថា បញ្ញាឱភាស ។ គ្រឿងផ្ទុះ គឺបញ្ញា ព្រោះអត្ថថា រុងរឿង ឈ្មោះថា **បញ្ញាបជ្ជោត** ។ ពិតហើយ បុគ្គលដែលមានបញ្ញាអង្គុយហើយដោយភ្នែនមួយ មុឺននៃលោកធាតុក៏ភ្លឺរុងរឿងតែមួយ មានឱភាសជាមួយគ្នា មានពន្លឺជាមួយគ្នាតែមួយ ដោយហេតុនោះ ទើបព្រះអង្គត្រាស់ព្រះតម្រាស់នោះហើយ ។ ក្នុងបទទាំង ៣ នេះសូម្បីតែបទមួយក៏យល់ន័យបាន ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រទាំងនោះ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) តាមអជ្ឈាស្រ័យរបស់សត្វទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿងនេះមាន ៤ យ៉ាង ។

សេចក្តីរុងរឿង ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីរុងរឿងនៃព្រះចន្ទ ១ សេចក្តីរុងរឿងនៃព្រះអាទិត្យ ១ សេចក្តីរុងរឿងនៃភ្លើង ១ សេចក្តីរុងរឿងនៃប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីរុងរឿងទាំង ៤ នេះ សេចក្តីរុងរឿងដែលប្រសើរទុ៎ះ គឺសេចក្តីរុងរឿងនៃប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ រស្មីរុងរឿងនេះមាន ៤ យ៉ាង ។ រស្មីរុងរឿង ៤ យ៉ាង ។បេ។ ម្នាលភិក្ខុទាំងឡាយ រស្មីរុងរឿង ៤ យ៉ាងនេះឯង ដូច្នេះ ។ ក្នុងនិទ្ទេសនេះ ព្រះអង្គក៏ទ្រង់ធ្វើទេសនាដោយសមគួរដល់ព្រះសូត្រទាំងនោះដូចគ្នា ព្រោះថា កាលទ្រង់ចែកអត្ថដោយអាការមិនមែនតិច ទើបចែកល្អហើយ ។ សត្វទាំងឡាយពួកមួយ រមែងត្រាស់ដឹងបានដោយប្រការមួយ និងពួកដទៃក៏ត្រាស់ដឹងបានដោយប្រការដទៃ ។

រតនៈ គឺបញ្ញា ព្រោះអត្ថថា ធ្វើនូវការត្រេកអរ ព្រោះអត្ថថា ឲ្យនូវការត្រេកអរ ព្រោះអត្ថថា ឲ្យកើតនូវការរីករាយ ព្រោះអត្ថថា ធ្វើចិត្តឲ្យត្រេកអរ ព្រោះអត្ថថា ប្រាកដបានដោយក្រ ព្រោះអត្ថថា ថ្លឹងថ្លៃងមិនបាន ព្រោះអត្ថថា ជាគ្រឿងប្រើប្រាស់ របស់សត្វដែលមិនថោកថយ ឈ្មោះថា **បញ្ញារតនៈ** ។ ដែលឈ្មោះថា **អមោហៈ** ព្រោះជាហេតុឲ្យសត្វទាំងឡាយមិនវង្វេង ឬថា តួបញ្ញាខ្លួនឯង រមែងមិនវង្វេងក្នុងអារម្មណ៍ ឬថា វត្ថុនោះត្រឹមតែមិនវង្វេងទៅប៉ុណ្ណោះ ។ បទថា **ធម្មវិចយោ** មានន័យតាមដែលពោលហើយនោះឯង ។ សួរថា ព្រោះហេតុអ្វី ទើបត្រាស់ធម្មវិចយនេះទៀត

ឆ្លើយថា ដើម្បីសម្តែងភាពដែលអមោហៈជាបដិបក្ខចំពោះមោហៈ ។ ដោយហេតុនោះ ទើបទ្រង់សម្តែងពាក្យថា ធម្មវិចយនេះ ។ អមោហៈ មិនមែនជាធម៌ដទៃអំពីមោហៈតែម្យ៉ាងនោះទេ តែជាបដិបក្ខចំពោះមោហៈផងដែរ ។ ឈ្មោះថា **អមោហ** ពោល គឺធម្មវិចយនោះ ព្រះមានព្រះភាគទ្រង់បំណង យកក្នុងទីនេះ ។ ទិដ្ឋិដ៏ពិតជាគ្រឿងនាំចេញចាកវដ្តៈ និងជាចំណែកកុសល ឈ្មោះថា **សម្មាទិដ្ឋិ** ។

ក្នុងនិទ្ទេសនៃជីវិតិន្ទ្រិយ បទថា **យោ តេសំ អរូបីនំ ធម្មានំ អាយុ** សេចក្តីថា សភាវធម៌ដែលឈ្មោះថា **អាយុ** ព្រោះអត្ថថា ជាគ្រឿងបន្តសម្បយុត្តធម៌ ដែលជាអរូបទាំងនោះ ។ ពិតហើយ កាលអាយុនោះ មានអរូបធម៌ទាំងឡាយរមែងមានតទៅ ប្រព្រឹត្តទៅ ប្រព្រឹត្តទូទៅ ព្រោះហេតុនោះ ទើបត្រាស់ថា **អាយុ** ។ បទថា **អាយុ** នេះ ជាបទសម្តែងសភាវៈនៃការបន្តនោះ ។ កាលអាយុនៅមាននោះឯង អរូបធម៌ទាំងនោះ រមែងតាំងនៅ រមែងនាំទៅ រមែងឲ្យនាំទៅ រមែងកម្រើក រមែងប្រព្រឹត្តទៅ រមែងរក្សា ព្រោះហេតុនោះ ទើបត្រាស់ពាក្យជាដើមថា **ឋិតិ** ។ ចំណែកសេចក្តីនៃពាក្យក្នុងបទនេះដូច្នេះថា ដែលឈ្មោះថា **ឋិតិ** ព្រោះជាហេតុឲ្យតាំងនៅ ។ ដែលឈ្មោះថា **យបនា** ព្រោះនាំទៅ ឈ្មោះថា **យាបនា** ក៏ដូចគ្នា តែព្រះអង្គទ្រង់ធ្វើបទមុនឲ្យខ្លីដោយអំណាចនៃសត្វ ដែលត្រាស់ដឹងដោយអាការយ៉ាងនោះ ។ ដែលឈ្មោះថា **ឥរិយនា** ព្រោះជាហេតុឲ្យរំកិលទៅ ។ ដែលឈ្មោះថា **វត្តនា** ព្រោះប្រព្រឹត្តទៅ ។ ដែលឈ្មោះថា

**ចាលនា** ព្រោះរក្សា ។ ដែលឈ្មោះថា **ជីវិត** ព្រោះជាហេតុឲ្យសត្វរស់នៅ ។ ដែលឈ្មោះថា **ជីវិតិន្ទ្រិយ** ព្រោះភាពជាធំក្នុងលក្ខណៈនៃការតាមរក្សា ។

ក្នុងនិទ្ទេសនៃហិរិពល បទថា **យំ តស្មិំ សមយេ** បានដល់ ក្នុងសម័យនោះ ដោយធម៌ណា ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបអត្ថថា **យោ ធម្មោ តស្មិំ សមយេ** ( ធម៌ណារមែងខ្មាស ... ក្នុងសម័យនោះ ) ដូច្នេះ ព្រោះធ្វើលិង្គឲ្យជាវិបល្លាស ។ បទថា **ហិរិយិតព្វេន** ជាតតិយាវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ អធិប្បាយថា រមែងខ្មាស គឺរង្កៀសធម៌ មានកាយទុច្ចរិតជាដើម ដែលគួរដល់ការខ្មាស ។ បទថា **ចាបកានំ** បានដល់ លាមក ។ បទថា **អកុសលានំ ធម្មានំ** បានដល់ ធម៌ដែលកើតអំពីសេចក្ដីមិនឈ្លាស ។ សូម្បីពាក្យថា **សមាបត្តិយា** នេះ ក៏ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ អធិប្បាយថា រមែងខ្មាស គឺរមែងរង្កៀសនូវការដល់ព្រម ការបានចំពោះ និងការព្រមព្រៀងនៃ ( អកុសល ) ធម៌ទាំងនោះ ។

ក្នុងនិទ្ទេសនៃឱត្តប្បៈ បទថា **ឱត្តប្បិតព្វេន** ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃហេតុ អធិប្បាយថា រមែងកោតក្រែង គឺរមែងខ្លាចទុច្ចរិត មានកាយទុច្ចរិតជាដើម ដែលគួរដល់ការខ្លាចដែលជាហេតុនៃសេចក្ដីគួរខ្លាច និងការប្រកបដែលមានប្រការតាមដែលពោលហើយ ដែលជាហេតុនៃការខ្លាច ។

ក្នុងនិទ្ទេសនៃអលោភៈ ធម៌ដែលឈ្មោះថា **អលោភៈ** ព្រោះសេចក្ដី

មិនល្មោភ ម្យ៉ាងទៀត ឈ្មោះថា **អលោភៈ** ព្រោះរមែងមិនលោភ ។ បទថា **អលោភ** នេះ ជាបទសម្ដែងសភាវៈរបស់សេចក្ដីមិនលោភទុំះ ។ អាការដែលមិនលោភ ឈ្មោះថា **អលុព្ភនា** ។ បុគ្គលដែលដល់ព្រម ដោយលោភៈ ឈ្មោះថា **លុព្ភិតោ** ( បុគ្គលអ្នកលោភ ) ។ បុគ្គលមិនលោភ ឈ្មោះថា **អលុព្ភិតោ** ។ ភាវៈនៃបុគ្គលអ្នកមិនល្មោភ ឈ្មោះថា **អលុព្ភិតត្តំ** ។ ដែលឈ្មោះថា **អសារាគ** ព្រោះមិនត្រេកអរខ្លាំងដោយហាមការត្រេកអរខ្លាំង ។ អាការដែលមិនត្រេកត្រអាល ឈ្មោះថា **អសារជ្ជនា** ។ ភាវៈនៃបុគ្គលមិនត្រេកត្រអាល ឈ្មោះថា **អសារជ្ជិតត្តំ** ។ ដែលឈ្មោះថា **អនភិជ្ឈា** ព្រោះមិនសម្លឹងរំពៃ ។ បទថា **អលោភោ កុសលមូលំ** បានដល់ កុសលមូល ពោល គឺអលោភៈ ។ ពិតហើយ អលោភៈ ឈ្មោះថា **កុសលមូល** ព្រោះអត្ថថា ជាមូល គឺជាបច្ច័យដល់កុសលធម៌ទាំងឡាយខ្លះ ។ ឈ្មោះថា **កុសលមូល** ព្រោះកុសលនោះផង ជាមូលផង ដោយអត្ថថា ជាបច្ច័យផងដូច្នេះខ្លះ ។

ក្នុងនិទ្ទេសនៃអទោសៈ ធម៌ដែលឈ្មោះថា **អទោស** ព្រោះអំណាចការមិនប្រទូស្ត ។ ម្យ៉ាងទៀត ឈ្មោះថា **អទោស** ព្រោះមិនប្រទូស ។ បទថា **អទោស** នេះ ជាបទសម្ដែងសភាវៈរបស់អទោសៈនោះ ។ អាការដែលមិនប្រទូស្ត ឈ្មោះថា **អទុស្សនា** ។ ភាវៈនៃបុគ្គលអ្នកមិនប្រទូស្តហើយ ឈ្មោះថា **អទុស្សិតត្តំ** ។ ដែលឈ្មោះថា **អព្យាបាទ** ព្រោះមិនព្យាបាទ ដោយហាមសេចក្ដីព្យាបាទ ។ ដែលឈ្មោះថា **អព្យាបជ្ឈ**

ព្រោះមិនបៀតបៀន ដោយហាមសេចក្ដីទុក្ខដែលកើតអំពីសេចក្ដីក្រោធ ។ កុសលមូល ពោល គឺអទោសៈ ឈ្មោះថា **អទោសោ កុសលមូលំ** ។ កុសលមូលនោះ មានន័យតាមដែលពោលហើយនុ៎ះឯង ។

ក្នុងនិទ្ទេសនៃកាយបស្សទ្ធិជាដើម ខន្ធ ៣ ( វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ) ព្រះមានព្រះភាគទ្រង់បំណងយកថា **កាយ** ព្រោះហេតុនោះ ទើបត្រាស់ថា **វេទនាខន្ធស្ស** ជាដើម ។ ធម៌ដែលឈ្មោះថា **បស្សទ្ធិ** ព្រោះជាហេតុឲ្យធម៌ទាំងនោះស្ងប់ គឺប្រាសចាកសេចក្ដីក្រវល់ក្រវាយ ដល់នូវសេចក្ដីក្សេម ។ បទទី ២ ( **បដិប្បស្សទ្ធិ** ) ទ្រង់បន្ថែមដោយអំណាចឧបសគ្គ ។ អាការដែលស្ងប់ ឈ្មោះថា **បស្សម្ភនា** ។ បទទី ២ ( **បដិប្បស្សម្ភនា** ) ក៏ទ្រង់បន្ថែមដោយអំណាចឧបសគ្គ ។ ភាវៈនៃខន្ធ ៣ ដែលស្ងប់ ព្រោះព្រមព្រៀងដោយបស្សទ្ធិ ឈ្មោះថា **បដិប្បស្សម្ភិ-តត្តំ** ។ សេចក្ដីស្ងប់រម្ងាប់នូវការក្រវល់ក្រវាយព្រោះកិលេស នៃខន្ធ ៣ លោកពោលសូម្បីដោយបទទាំងអស់ ។ សេចក្ដីស្ងប់រម្ងាប់នូវការក្រវល់ក្រវាយនៃវិញ្ញាណក្ខន្ធ ទ្រង់ត្រាស់ដោយន័យទី ២ ។

អាការនៃភាវៈដែលស្រាល ឈ្មោះថា **លហុតា** ។ ពាក្យថា **លហុបរិណាមតា** មានវិគ្គហៈដូច្នេះថា ធម៌ដែលឈ្មោះថា **លហុបរិណាម** ព្រោះធម៌ទាំងនោះ មានការប្រែប្រួលទៅរហ័ស ។ ភាវៈនៃលហុបរិណាម-ធម៌ទាំងនោះ ឈ្មោះថា **លហុបរិណាមតា** អធិប្បាយថា អាចប្រែប្រួលដោយឆាប់រហ័ស ។ បទថា **អទន្ធនតា** ជាពាក្យបដិសេធសេចក្ដីធ្ងន់ គឺ

មិនមែនការៈធ្ងន់ ។ បទថា **អវិត្ថនតា** បានដល់ ការមិនរឹងត្អឹង ព្រោះការមិនមានការៈ គឺកិលេស មានថីនៈ និងមានះជាដើម ។ ម្យ៉ាងទៀត ការមិនរឹងត្អឹងព្រោះការមិនមានការៈ គឺកិលេស មានថីនៈ និងមិទ្ធៈជាដើម ឈ្មោះថា **អវិត្ថនតា** ។ ព្រះមានព្រះភាគត្រាស់អាការ គឺសេចក្តីស្រាលនៃខន្ធទាំង ៣ នោះ ដោយន័យដំបូង ត្រាស់អាការ គឺសេចក្តីស្រាលនៃវិញ្ញាណក្ខន្ធ ដោយន័យទី ២ ។

សេចក្តីទន់ ឈ្មោះថា **មុទុតា** ។ ពាក្យថា **មទ្ទវតា** មានវិគ្គហៈដូចតទៅនេះ ការស្និទ្ធ ភាពម៉ដ្ឋ ហៅថា **មទ្ទវៈ** ភាវៈនៃមទ្ទវៈនោះ ឈ្មោះថា **មទ្ទវតា** ។ ភាវៈដែលមិនរឹង ឈ្មោះថា **អកក្ខឡតា** ។ ភាវៈដែលមិនរបឹង ឈ្មោះថា **អកឋិនតា** ។ ក្នុងនិទ្ទេសនេះ ព្រះមានព្រះភាគត្រាស់អាការ គឺការទន់នៃខន្ធ ៣ ដោយន័យដំបូង និងនៃវិញ្ញាណក្ខន្ធដោយន័យខាងក្រោយ ។

ការសម្រេចនៃការងារ ឈ្មោះថា **កម្មញ្ញតា** គឺភាពគួរដល់ការប្រកបក្នុងការធ្វើកុសល ។ ពីរបទដ៏សេស ទ្រង់បន្ថែមមកដោយអំណាចព្យញ្ជនៈដោយពិត ។ ពិតហើយ សូម្បីដោយបទទាំង ២ ព្រះអង្គក៏ត្រាស់អាការ គឺសេចក្តីគួរដល់ការងារនៃខន្ធទាំង ៣ ដោយន័យដំបូង និងនៃវិញ្ញាណក្ខន្ធដោយន័យខាងក្រោយ ។

ភាវៈនៃសេចក្តីស្ទាត់ ឈ្មោះថា **បគុណតា** គឺការមិនសោប់សល់ការមិនអាពាធ ។ ពីរបទដ៏សេស ទ្រង់បន្ថែមដោយអំណាចព្យញ្ជនៈ ។

ក្នុងនិទ្ទេសនេះ ក៏ត្រាស់អាការ គឺការមិនមានជំងឺនោះឯង នៃខន្ធ ៣ ដោយន័យដំបូង និងនៃវិញ្ញាណក្ខន្ធដោយន័យខាងក្រោយ ។

ភាវៈនៃសេចក្តីត្រង់ ឈ្មោះថា **ឧជុកតា** គឺ ការប្រព្រឹត្តិទៅដោយអាការដែលត្រង់ ។ ភាវៈនៃខន្ធ ៣ និងវិញ្ញាណក្ខន្ធដែលត្រង់ ឈ្មោះថា **ឧជុកតា** ។ សេចក្តីបដិសេធនៃការវៀចដូចគោមូត្រ[១] ឈ្មោះថា **អជិម្ហតា** ។ ការបដិសេធការកោង ដូចវង់ព្រះចន្ទ ឈ្មោះថា **អវង្កតា** ។ បដិសេធសេចក្តីកោងដូចចុងនង្គ័ល ឈ្មោះថា **អកុដិលតា** ។ ពិតហើយ បុគ្គលណាធ្វើបាបហើយ ពោលថា ខ្ញុំមិនបានធ្វើ បុគ្គលនោះ ឈ្មោះថា ជាអ្នកវៀចដូចគោមូត្រ ព្រោះការទៅមិនត្រង់ បុគ្គលណា កំពុងធ្វើបាបហើយនិយាយថា ខ្ញុំមិនខ្លាចបាប បុគ្គលនោះ ឈ្មោះថា កោង ដូចវង់ព្រះចន្ទ ព្រោះការវៀចខ្លាំង បុគ្គលណាកំពុងធ្វើបាប តែពោលថា អ្នកណាមិនខ្លាចបាប បុគ្គលនោះ ឈ្មោះថា កោងដូចចុងនង្គ័ល ព្រោះមិនវៀចខ្លាំង ។

ម្យ៉ាងទៀត កម្មទ្វារ ៣ របស់បុគ្គលណាមិនបរិសុទ្ធ បុគ្គលនោះ ឈ្មោះថា ជាអ្នកកោងដូចគោមូត្រ ។ កម្មទ្វារ ២ ណាមួយ របស់បុគ្គលណាមិនបរិសុទ្ធ បុគ្គលនោះ ឈ្មោះថា ជាអ្នកកោងដូចរង្វង់វង់ព្រះចន្ទ ។ កម្មទ្វារមួយ ទ្វារណានីមួយរបស់បុគ្គលណាមិនបរិសុទ្ធ បុគ្គលនោះ ឈ្មោះថា ជាអ្នកកោងដូចចុងនង្គ័ល ។

ចំណែកអាចារ្យទីឃនិកាយពោលថា ភិក្ខុរបខ្លះក្នុងវ័យទាំងអស់ប្រព្រឹត្ត

---

១- ស្នាមទឹកនោមគោ ដែលវៀចចុះវៀចឡើង ខ្មែរយើងប្រើជាឈ្មោះវណ្ណយុត្ត ។

អនេសនា ២១ និងអគោចរ ៦ ភិក្ខុនេះ ឈ្មោះថា វៀចដូចគោមូត្រ ។ ភិក្ខុអង្គខ្លះ ក្នុងបឋមវ័យ បំពេញចតុប្បារិសុទ្ធិសីលបរិបូណ៌ ជាអ្នកខ្មាសរង្កៀសក្នុងបាប ប្រាថ្នាការសិក្សា ក្នុងមជ្ឈិមវ័យ និងបច្ឆិមវ័យ ដូចជាភិក្ខុអង្គមុន ភិក្ខុនេះឈ្មោះថា កោងដូចវង្វង់ព្រះចន្ទ ។ ភិក្ខុអង្គខ្លះ ក្នុងបឋមវ័យក្តី មជ្ឈិមវ័យក្តី រមែងបំពេញចតុប្បារិសុទ្ធិសីលបរិបូណ៌ ជាអ្នកមានខ្មាសរង្កៀសក្នុងបាប ប្រាថ្នាការសិក្សា តែក្នុងបច្ឆិមវ័យដូចជាភិក្ខុអង្គមុន ភិក្ខុនេះឈ្មោះថា កោងដូចចុងនង្គ័ល ។ ភាវៈរបស់បុគ្គលអ្នកកោងយ៉ាងនេះដោយអំណាចកិលេស ហៅថា **ជិម្ហតា** ( ការវៀច ) **វង្កតា** ( ការកោង ) **កុដិលតា** ( ការ-ង ) ព្រះមានព្រះភាគ ត្រាស់ការមិនវៀចជាដើម ដោយបដិសេធការវៀចជាដើមទាំងនោះ ។ ទ្រង់សម្តែងដោយខន្ធាធិដ្ឋាន ។ ពិតហើយ ការមិនវៀចជាដើមនេះ រមែងមានដល់ខន្ធទាំងឡាយ មិនមានដល់បុគ្គលទេ ដោយបទទាំងនេះ សូម្បីទាំងអស់យ៉ាងនេះ ព្រះមានព្រះភាគត្រាស់អាការ គឺការត្រង់នៃខន្ធទាំង ៣ ដោយន័យដំបូង ត្រាស់អាការ គឺការត្រង់នៃវិញ្ញាណក្ខន្ធដោយន័យក្រោយ ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះអង្គទ្រង់ត្រាស់អាការ គឺការត្រង់នៃអរូបធម៌ទាំងឡាយ ព្រោះការមិនមានកិលេស ។

ឥឡូវនេះ ពាក្យចែកដោយសង្ខេបនៃយេវាបនធម៌ទាំងឡាយ ដែលខ្ញុំ

សម្តែងហើយ ក្នុងធម្មុទ្ទេសវារនោះ ជាពាក្យបែកដែលខ្ញុំពោលសម្រាប់ អប្បនាវារ ( សរុប ) ដែលព្រះមានព្រះភាគត្រាស់ថា **យេ វា បន** ជាដើម ។

## និទ្ទេសវារ ចប់

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ចប់វារៈដោយការកំណត់ធម៌ដែលប្រដាប់ដោយបរិច្ឆេទ ៨ គឺក្នុងឧទ្ទេសវារ ៤ បរិច្ឆេទ មានបុច្ឆា ១ សមយនិទ្ទេស ១ ធម្មុទ្ទេស ១ អប្បនា ១ និងក្នុងនិទ្ទេសវារ ៤ បរិច្ឆេទ មានបុច្ឆា ១ សមយនិទ្ទេស ១ ធម្មុទ្ទេស ១ អប្បនា ១ ដូច្នេះឯង ។

# អភិធម្មបិដក

## កោដ្ឋសង្ខារ

[ ៧៤ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ៥ មគ្គប្រកបដោយអង្គ ៥ ពល ៧ ហេតុ ៣ ផស្សៈ ១ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារខន្ធ ១ វិញ្ញាណក្ខន្ធ ១ មនាយតនៈ ១ មនិន្ទ្រិយ ១ មនោវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬពួកអរូបធម៌ដទៃណា ដែលកើតឡើងដោយអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

[ ៧៥ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។ វេទនាខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ត្រេកអរជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ត្រេកអរជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាខន្ធកើតមានក្នុងសម័យនោះ ។ សញ្ញាខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា សេចក្តីសម្គាល់ សេចក្តីចាំបានណា ក្នុងសម័យនោះ នេះសញ្ញាខន្ធ កើតមានក្នុងសម័យនោះ ។ សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្ក វិចារ បីតិ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ

ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មា-សមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សម្បជញ្ញៈ សមថៈ វិបស្សនា សេចក្តីផ្គង សេចក្តីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណា ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតឡើងដោយអាស្រ័យហេតុ ក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។ វិញ្ញាណក្ខន្ធ កើតមានក្នុងសម័យនោះតើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះវិញ្ញាណក្ខន្ធកើតមានក្នុងសម័យនោះ ។ នេះពួកខន្ធ ៤ កើតមានក្នុងសម័យនោះ ។

[ ៧៦ ] អាយតនៈ ២ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ មនាយតនៈ ធម្មាយតនៈ ។ មនាយតនៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ

មនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះមនាយតនៈកើតមានក្នុងសម័យនោះ ។ ធម្មាយតនៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះធម្មាយតនៈកើតមានក្នុងសម័យនោះ ។ នេះអាយតនៈ ២ កើតមានក្នុងសម័យនោះ ។

[ ៧៧ ] ធាតុ ២ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ មនោ-វិញ្ញាណធាតុ ធម្មធាតុ ។ មនោវិញ្ញាណធាតុ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យធម្មជាតថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធមនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះមនោវិញ្ញាណធាតុ កើតមានក្នុងសម័យនោះ ។ ធម្មធាតុកើតមានក្នុងសម័យនោះ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះធម្មធាតុ កើតមានក្នុងសម័យនោះ ។ នេះធាតុ ២ កើតមានក្នុងសម័យនោះ ។

[ ៧៨ ] អាហារ ៣ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សាហារ មនោសញ្ចេតនាហារ វិញ្ញាណាហារ ។ ផស្សាហារ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិចទង្គិចណា ក្នុងសម័យនោះ នេះផស្សាហារ កើតមានក្នុងសម័យនោះ ។ មនោសញ្ចេតនាហារ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនាសេចក្តីរិះគិត ការតាក់តែងណា ក្នុងសម័យនោះ នេះមនោសញ្ចេតនាហារកើតមានក្នុងសម័យនោះ ។ វិញ្ញាណាហារ កើតមានក្នុងសម័យនោះ តើ

ដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះវិញ្ញាណាហារ កើតមានក្នុងសម័យនោះ ។ នេះអាហារ ៣ កើតមានក្នុងសម័យនោះ ។

[ ៧៩ ] ឥន្ទ្រិយ ៨ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ ។ សទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ជំនឿ សេចក្តីជឿ សេចក្តីជឿស៊ប់ សេចក្តីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលណា ក្នុងសម័យនោះ នេះសទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។ វីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឧហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្វាត ការមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈណា ក្នុងសម័យនោះ នេះវីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ ។ សតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះ ស្មារតី ការនឹកឃើញ ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា ក្នុងសម័យនោះ នេះសតិន្ទ្រិយកើត

មានក្នុងសម័យនោះ ។ សមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសមា-ធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។ បញ្ញិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីគិច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្ទួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ចុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះបញ្ញិន្ទ្រិយ កើតមានក្នុងសម័យនោះ ។ មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតិផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះមនិន្ទ្រិយ កើតមានក្នុងសម័យនោះ ។ សោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តី

សុខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ ។ ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការស្ថិតនៅ ការរស់នៅ ការយឺននៅ ការរំកិលទៅ ការប្រព្រឹត្តិទៅ ការរក្សានៃអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណា ក្នុងសម័យនោះ នេះជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ ។ នេះឥន្ទ្រិយ ៨ កើតមានក្នុងសម័យនោះ ។

[ ៨០ ] ឈានប្រកបដោយអង្គ ៥ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ វិតក្ក ១ វិចារ ១ បីតិ ១ សុខ ១ ឯកគ្គតារបស់ចិត្ត ១ ។ វិតក្កកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្ត គឺសម្មាសង្កប្បៈណា ក្នុងសម័យនោះ នេះវិតក្កកើតមានក្នុងសម័យនោះ ។ វិចារ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រួតត្រា ការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការផ្គងនូវចិត្ត ការសម្លឹងមើលណា ក្នុងសម័យនោះ នេះវិចារ កើតមានក្នុងសម័យនោះ ។ បីតិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល សេចក្តីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណារ ការអណ្តែតអណ្តូង សេចក្តីត្រេកអររបស់ចិត្តណា ក្នុងសម័យនោះ នេះបីតិ កើតមានក្នុងសម័យនោះ ។ សុខ កើតមានក្នុងសម័យនោះ តើដូចម្តេច ។

សេចក្ដីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សរបស់ចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសុខកើតមានក្នុងសម័យនោះ ។ ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ ។ នេះឈានប្រកបដោយអង្គ ៥ កើតមានក្នុងសម័យនោះ ។

[ ៨១ ] មគ្គប្រកបដោយអង្គ ៥ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាទិដ្ឋិកើតមានក្នុងសម័យនោះ តើដូចម្ដេច ។ បញ្ញា សេចក្ដីដឹងសព្វ សេចក្ដីពិចារណា សេចក្ដីជ្រើសរើស សេចក្ដីពិចារណាធម៌ សេចក្ដីកំណត់ សេចក្ដីកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្ដីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្ដីភ្លឺច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជាជន្ទញ់ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុង

សម័យនោះ នេះសម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ ។ សម្មាសង្កប្បៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្ត គឺសម្មាសង្កប្បៈណា ក្នុងសម័យនោះ នេះសម្មាសង្កប្បៈ កើតមានក្នុងសម័យនោះ ។ សម្មាវាយាមៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្ដីសង្វាត ការមិនធូរថយ ការមិនដាក់ចុះ នូវសេចក្ដីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវិរិយៈ វិរិយិន្ទ្រិយ វិរិយពល សម្មាវាយាមៈណា ក្នុងសម័យនោះ នេះសម្មាវាយាមៈ កើតមានក្នុងសម័យនោះ ។ សម្មាសតិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីរឭក សេចក្ដីរឭករឿយៗ សេចក្ដីរឭកចំពោះ ស្មារតី ការនឹកឃើញ ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណាក្នុងសម័យនោះ នេះសម្មាសតិ កើតមានក្នុងសម័យនោះ ។ សម្មាសមាធិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសម្មាសមាធិ កើតមានក្នុងសម័យនោះ ។ នេះមគ្គប្រកបដោយអង្គ ៥ កើតមានក្នុងសម័យនោះ ។

[ ៨២ ] ពល ៧ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សទ្ធា-

ពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល ។ សទ្ធាពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ជំនឿ សេចក្ដីជឿ សេចក្ដីជឿស៊ប់ សេចក្ដីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធា-ពលណា ក្នុងសម័យនោះ នេះសទ្ធាពល កើតមានក្នុងសម័យនោះ ។ វីរិយពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្ដីសង្វាត ការមិនធូរថយ ការមិនដាក់ចុះនូវសេចក្ដីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈណា ក្នុងសម័យនោះ នេះវីរិយពល កើតមានក្នុងសម័យនោះ ។ សតិពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីរឭក សេចក្ដីរឭករឿយៗ សេចក្ដីរឭកចំពោះ ស្មារតី ការនឹកឃើញ ការចាំបាន ការមិនកាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា ក្នុងសម័យនោះ នេះសតិពល កើតមានក្នុងសម័យនោះ ។ សមាធិពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយរបស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា ក្នុងសម័យនោះ នេះសមាធិពល កើតមានក្នុងសម័យនោះ ។ បញ្ញាពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ បញ្ញា សេចក្ដីដឹងសព្វ សេចក្ដីពិចារណា សេចក្ដីជ្រើស

រើស សេចក្ដីពិចារណាធម៌ សេចក្ដីកំណត់ សេចក្ដីកត់សម្គាល់ សេចក្ដីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្ដីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្ដីភ្លឺច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា ក្នុងសម័យនោះ នេះបញ្ញាពល កើតមានក្នុងសម័យនោះ ។ ហិរិពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលខ្មាសដោយវត្ថុ ដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះហិរិពល កើតមានក្នុងសម័យនោះ ។ ឱត្តប្បពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលតក់ស្លុត ដោយវត្ថុដែលគួរតក់ស្លុត តក់ស្លុតដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះឱត្តប្បពល កើតមានក្នុងសម័យនោះ ។ នេះពល ៧ កើតមាន ក្នុងសម័យនោះ ។

[ ៨៣ ] ហេតុ ៣ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ អលោភៈ អទោសៈ អមោហៈ ។ អលោភៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការមិនចង់បាន ការមិនជាប់ជំពាក់ សេចក្ដីមិនជាប់ជំពាក់ ការមិនត្រេកអរខ្លាំង ការមិនត្រេកត្រអាល សេចក្ដីមិនត្រេកត្រអាល ការមិនសម្លឹងចំពោះ គឺអលោភៈជាកុសលមូលណា ក្នុងសម័យនោះ នេះអលោភៈ កើតមានក្នុង

សម័យនោះ ។ អទោសៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីមិនខឹង ការមិនប្រទូស្ត សេចក្ដីមិនប្រទូស្ត ការមិនព្យាបាទ សេចក្ដីមិនព្យាបាទ គឺអទោសៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអទោសៈកើតមានក្នុងសម័យនោះ ។ អមោហៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ បញ្ញា សេចក្ដីដឹងសព្វ សេចក្ដីពិចារណា សេចក្ដីជ្រើសរើស សេចក្ដីពិចារណាធម៌ សេចក្ដីកំណត់ សេចក្ដីកត់សម្គាល់ សេចក្ដីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្ដីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្ដីភ្លឺច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្ដីដឹងល្អសភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ អមោហៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអមោហៈ កើតមានក្នុងសម័យនោះ ។ នេះហេតុ ៣ កើតមានក្នុងសម័យនោះ ។

[ ៨៤ ] ផស្សៈ ១ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈ ១ កើតមានក្នុងសម័យនោះ ។

[ ៨៥ ] វេទនា ១ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីទទួល

អារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនា ១ កើតមានក្នុងសម័យនោះ ។

[ ៨៦ ] សញ្ញា ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា សេចក្តីសម្គាល់ សេចក្តីចាំបានណា ក្នុងសម័យនោះ នេះសញ្ញា ១ កើតមានក្នុងសម័យនោះ ។

[ ៨៧ ] ចេតនា ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា សេចក្តីរិះគិត ការតាក់តែងណា ក្នុងសម័យនោះ នេះចេតនា ១ កើតមានក្នុងសម័យនោះ ។

[ ៨៨ ] ចិត្ត ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះចិត្ត ១ កើតមានក្នុងសម័យនោះ ។

[ ៨៩ ] វេទនាខន្ធ ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាខន្ធ ១ កើតមានក្នុងសម័យនោះ ។

[ ៩០ ] សញ្ញាខន្ធ ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា

សេចក្ដីសម្គាល់ សេចក្ដីចាំបានណា ក្នុងសម័យនោះ នេះសញ្ញាខន្ធ ១ កើតមានក្នុងសម័យនោះ ។

[ ៩១ ] សង្ខារក្ខន្ធ ១ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា វិតក្ក វិចារ បីតិ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ កាយប្បស្សទ្ធិ ចិត្តប្បស្សទ្ធិ កាយលហុតា ចិត្តលហុតា កាយមុទុតា ចិត្តមុទុតា កាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុកតា ចិត្តុជុកតា សតិ សម្បជញ្ញៈ សមថៈ វិបស្សនា បគ្គាហៈ អវិក្ខេបៈ ឬថាពួកអរូបធម៌ដទៃណា ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធដែលកើតឡើងដោយអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ ១ កើតមានក្នុងសម័យនោះ ។

[ ៩២ ] វិញ្ញាណក្ខន្ធ ១ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីគិត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាជ្ញា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដ៏សមគួរដល់ផស្សៈជាដើមនេះណា ក្នុងសម័យនោះ នេះវិញ្ញាណក្ខន្ធ ១ កើតមានក្នុងសម័យនោះ ។

[ ៩៣ ] មនាយតនៈ ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោ-វិញ្ញាណធាតុ ដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះមនាយតនៈ ១ កើតមានក្នុងសម័យនោះ ។

[ ៩៤ ] មនិន្ទ្រិយ ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះមនិន្ទ្រិយ ១ កើតមានក្នុងសម័យនោះ ។

[ ៩៥ ] មនោវិញ្ញាណធាតុ ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណ-ធាតុដ៏សមគួរដល់ផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះមនោវិញ្ញាណ-ធាតុ ១ កើតមានក្នុងសម័យនោះ ។

[ ៩៦ ] ធម្មាយតនៈ ១ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះធម្មាយតនៈ ១ កើតមានក្នុងសម័យនោះ ។

[ ៩៧ ] ធម្មធាតុ ១ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះធម្មធាតុ ១ កើតមានក្នុងសម័យនោះ ។

[ ៩៨ ] មួយទៀត ពួកអរូបធម៌ដទៃណា ដែលកើតដោយអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

កោដ្ឋាសវារ ចប់

# អដ្ឋកថា

## កោដ្ឋាសវារ

[ ៧៤-៩៨ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់ផ្តើមសង្គហវារៈដោយពាក្យជាដើមថា **តស្មឹ ខោ បន សមយេ ចត្តារោ ខន្ធា ហោន្តិ** ។ សង្គហវារៈនោះមាន ៣ យ៉ាង គឺឧទ្ទេសវារៈ និទ្ទេសវារៈ និងបដិនិទ្ទេស-វារៈ ។ បណ្តាសង្គហវារៈទាំង ៣ នោះ វារៈដែលមានពាក្យជាដើម យ៉ាងនេះថា **តស្មឹ ខោ បន សមយេ ចត្តារោ ខន្ធា** ដូច្នេះ គប្បីជ្រាបថា ជាឧទ្ទេសវារៈ ។ វារៈដែលមានពាក្យជាដើមថា **កតមេ តស្មឹ សមយេ ចត្តារោ ខន្ធា** ដូច្នេះ គប្បីជ្រាបថា ជានិទ្ទេសវារៈ ។ វារៈដែលមានពាក្យជាដើមថា **កតមោ តស្មឹ សមយេ វេទនាក្ខន្ធោ** ដូច្នេះ គប្បីជ្រាបថា ជាបដិនិទ្ទេសវារៈ ។

បណ្តាវារៈទាំងនោះ ក្នុងឧទ្ទេសវារៈ មាន ២៣ កោដ្ឋាស មានពាក្យថា **ចត្តារោ ខន្ធា** ជាដើម គប្បីជ្រាបសេចក្តីនៃកោដ្ឋាសទាំងនោះដូចតទៅ

កាមាវចរមហាកុសលចិត្តដួងទី ១ រមែងកើតឡើងក្នុងសម័យណា ក្នុងសម័យនោះ ធម៌ទាំងឡាយ ៥០ ជាង ដែលមកក្នុងព្រះបាលីកើតឡើងជាចំណែកប្រកបរបស់ចិត្ត វៀរយេវាបនកធម៌ កាលប្រមូលចូលគ្នាទាំងអស់ **ជាខន្ធ ៤** ដោយអត្ថថា ជាគំនរ ។ **ជាអាយតនៈ ២** ប៉ុណ្ណោះ ដោយអត្ថថា ជាទី-តតាមដែលពោលមកហើយខាងដើម ។ **ជាធាតុ ២** ប៉ុណ្ណោះ ដោយអត្ថថា ជាសភាវៈ ដោយអត្ថថា ជាសភាវៈទទេ ដោយអត្ថថា មិន

មែនសត្វ ។ ក្នុងធម៌ជាង ៥០ នេះ ធម៌ ៣ យ៉ាងប៉ុណ្ណោះ **ជាអាហារ** ដោយអត្ថថា នាំមក ពោល គឺជាបច្ច័យ ធម៌ដ៏សេស មិនជាអាហារ ។

សួរថា ធម៌ទាំង ៣ យ៉ាងនោះ មិនជាបច្ច័យដល់គ្នានិងគ្នាឬ ឬថា មិនជាបច្ច័យដល់រូបដែលមានធម៌នោះ ជាសមុដ្ឋានឬ ឆ្លើយថា មិនជាបច្ច័យក៏មិនមែន តែធម៌ទាំងនេះ រមែងជាបច្ច័យដោយប្រការនោះក៏បាន រមែងជាបច្ច័យដោយប្រការដទៃក៏បាន ព្រោះហេតុនោះ កាលធម៌ទាំងនោះជាបច្ច័យសូម្បីមាននៅ ក៏រមែងជាបច្ច័យដែលលើសមក ហេតុនោះ ទើបពោលថា ធម៌ទាំងនោះជាអាហារ ។

សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា បណ្តាធម៌ដែលជាអាហារទាំងនោះ ផស្សាហារ ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលមានចិត្ត និងចេតសិកដ៏សេសជាបច្ច័យ និងរមែងនាំមកនូវវេទនា ៣ ។ មនោសញ្ចេតនាហារ រមែងជាបច្ច័យដល់ធម៌ទាំងនោះ និងរមែងនាំមកនូវភព ៣ ។ វិញ្ញាណាហារ រមែងជាបច្ច័យដល់ធម៌ទាំងនោះ និងរមែងនាំមកនូវនាម និងរូបក្នុងបដិសន្ធិ ។

សួរថា វិញ្ញាណាហារនោះជាវិបាកប៉ុណ្ណោះ ចំណែកវិញ្ញាណនេះ ជាកុសលវិញ្ញាណ មិនមែនឬ ឆ្លើយថា វិញ្ញាណនេះជាកុសលវិញ្ញាណក៏ពិត តែលោកក៏ហៅថា វិញ្ញាណាហារដូចគ្នា ព្រោះដូចគ្នានឹងវិបាកវិញ្ញាណាហារនោះ ។ម្យ៉ាងទៀត ធម៌ទាំង ៣ នេះ ត្រាស់ហៅថា អាហារ ព្រោះអត្ថថា ជាធម៌ឧបត្ថម្ភ ។ ពិតហើយ ធម៌ទាំងនេះ ជាបច្ច័យឧបត្ថម្ភដល់សម្បយុត្តធម៌ទាំងឡាយ ដូចកពឡិង្ការាហារ ជាបច្ច័យឧបត្ថម្ភដល់រូបកាយ ។

ដោយហេតុនុ៎ះឯង ទើបទ្រង់ត្រាស់ ( ក្នុងមហាបដ្ឋាន ) ថា អាហារទាំងឡាយដែលមិនមានរូប ជាបច្ច័យនៃសម្បយុត្តធម៌ផង នៃរូបទាំងឡាយដែលកើតអំពីសម្បយុត្តធម៌នោះផង ដោយអាហារប្បច្ច័យ ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ទាំង ៣ នេះ ព្រះមានព្រះភាគត្រាស់ហៅថា អាហារ ដូចកពឡិង្ការាហារ ព្រោះជាបច្ច័យពិសេសនៃសន្តតិ ( ការបន្ត ) ក្នុងខាងក្នុង ។ ពិតហើយ កពឡិង្ការាហារជាបច្ច័យពិសេសដល់រូបកាយរបស់សត្វទាំងឡាយ ដែលមានកពឡិង្ការាហារជាអាហារក្នុងនាមកាយ ផស្សៈជាបច្ច័យពិសេសដល់វេទនា មនោសញ្ចេតនាជាបច្ច័យពិសេសដល់វិញ្ញាណ ។ វិញ្ញាណជាបច្ច័យពិសេសដល់នាមរូប ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ កាយនេះតាំងនៅដោយសារអាហារ អាស្រ័យអាហារ ទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ ដូច្នេះ និងដូចព្រះមានព្រះភាគត្រាស់ថា **ផស្សប្បច្ចយា វេទនា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ** ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ដូច្នេះ ។

ធម៌ ៨ ប៉ុណ្ណោះ ( សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា មន សោមនស្ស ជីវិត ) ជា **ឥន្ទ្រិយ** ដោយអត្ថថា ជាធំ ធម៌ដ៏សេសមិនឈ្មោះថាជា **ឥន្ទ្រិយ** ព្រោះហេតុនោះ ទើបត្រាស់ថា ឥន្ទ្រិយ ៨ ដូច្នេះ ។ ធម៌ ៥ ប៉ុណ្ណោះ **ជាអង្គឈាន** ដោយអត្ថថា ចូលទៅសម្លឹង ។ ដោយហេតុ

នោះ ទើបទ្រង់ត្រាស់ថា ឈានប្រកបដោយអង្គ ៥ ដូច្នេះ ។ ធម៌ ៥ ប៉ុណ្ណោះ **ជាអង្គមគ្គ** ដោយអត្ថថា នាំចេញ និងដោយអត្ថថា ជាហេតុ ដោយហេតុនោះ ទើបត្រាស់ថា មគ្គប្រកបដោយអង្គ ៥ ដូច្នេះ ។ ពិតហើយ អរិយមគ្គមានអង្គ ៨ ក៏ពិត តែក្នុងលោកិយចិត្តមិនបានវិរតិ ៣ ព្រមគ្នា ព្រោះហេតុនោះ ទើបត្រាស់ថា មគ្គប្រកបដោយអង្គ ៥ ។

សួរថា សូម្បីមគ្គដែលជាបុព្វភាគនៃវិបស្សនាក៏មានអង្គ ៨ ដូចលោកុត្តរមគ្គដែលមានអង្គ ៨ នេះ ដូចក្នុងសូត្រ ( សំយុត្តនិកាយ សឡាយ-តនវគ្គ ) នេះថា ម្នាលភិក្ខុ ពាក្យថា ផ្លូវដែលគួរទៅនុ៎ះ ជាឈ្មោះនៃមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដូច្នេះ ។ ព្រោះហេតុនោះ សូម្បីលោកិយមគ្គក៏គប្បីប្រកបដោយអង្គ ៨ ព្រោះសេចក្តីនេះ ជាការសម្តែងដោយ **យថា** សព្វមិនមែនឬ ឆ្លើយថា លោកិយមគ្គមិនគប្បីប្រកបដោយអង្គ ៨ ព្រោះទេសនានេះ ឈ្មោះថា សុត្តន្តិកទេសនា ជាការសម្តែងដោយអម ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិ-បណ្ណាសក ) ថា បុគ្គលនោះឯង ឈ្មោះថា មានកាយកម្ម វចីកម្ម និងអាជីវៈដ៏បរិសុទ្ធល្អ ក្នុងកាលមុនពិត ដូច្នេះ ។ ចំណែកទេសនានេះ ជាការសម្តែងដោយត្រង់ ព្រោះក្នុងលោកិយចិត្ត មិនបានវិរតិ ៣ ព្រមគ្នា ព្រោះហេតុនោះ ទើបត្រាស់ថា មគ្គប្រកបដោយអង្គ ៥ ដូច្នេះ ប៉ុណ្ណោះ ។

ធម៌ ៧ ប៉ុណ្ណោះ ( សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា ហិរិ ឱត្តប្បៈ ) ជាពល ដោយអត្ថថា មិនញាប់ញ័រ ។ ធម៌ ៣ ប៉ុណ្ណោះ ( អលោភៈ

អទោសៈ អមោហៈ ) ជាហេតុ ដោយអត្ថថា ជាមូល ។ ធម៌មួយប៉ុណ្ណោះ ជាផស្សៈ ដោយអត្ថថា ពាល់ត្រូវ ។ ធម៌មួយប៉ុណ្ណោះ ជាវេទនា ដោយអត្ថថា សោយអារម្មណ៍ ។ ធម៌មួយប៉ុណ្ណោះ ជាសញ្ញា ដោយអត្ថថា ចាំបាន ។ ធម៌មួយប៉ុណ្ណោះ ជាចេតនា ដោយអត្ថថា ផ្តោតចិត្ត ។ ធម៌មួយប៉ុណ្ណោះ ជាចិត្ត ដោយអត្ថថា គិត និងធ្វើឲ្យវិចិត្រ ។

ធម៌មួយប៉ុណ្ណោះ ជាវេទនាខន្ធ ដោយអត្ថថា ជាគំនរ និងដោយអត្ថថា សោយអារម្មណ៍ ។ ធម៌មួយប៉ុណ្ណោះ ជាសញ្ញាខន្ធ ដោយអត្ថថា ជាគំនរ និងដោយអត្ថថា ចាំបាន ។ ធម៌មួយប៉ុណ្ណោះ ជាសង្ខារក្ខន្ធ ដោយអត្ថថា ជាគំនរ និងដោយអត្ថថា តាក់តែង ។ ធម៌មួយប៉ុណ្ណោះ ជាវិញ្ញាណក្ខន្ធ ដោយអត្ថថា ជាគំនរ និងដោយអត្ថថា គិត និងធ្វើឲ្យវិចិត្រ ។ ធម៌មួយប៉ុណ្ណោះ ជាមនាយតនៈ ដោយអត្ថថា ដឹងច្បាស់ និងដោយអត្ថថា ជាអាយតនៈ តាមដែលពោលមកហើយខាងដើម ។ ធម៌មួយប៉ុណ្ណោះ ជាមនិន្ទ្រិយ ដោយអត្ថថា ដឹងច្បាស់ និងដោយអត្ថថា ជាធំ ។ ធម៌មួយប៉ុណ្ណោះ ជាមនោវិញ្ញាណធាតុ ដោយអត្ថថា ដឹងច្បាស់ ដោយអត្ថថា ជាសភាវៈ ជាសុញ្ញតៈ ជានិស្សត្តៈ មិនមែនធម៌ដ៏សេស ។ ធម៌ទាំងអស់ដ៏សេស វៀរចិត្ត ជាធម្មាយតនៈមួយ តែម្យ៉ាងនោះឯង និងជាធម្មធាតុតែម្យ៉ាងនោះឯង ដោយអត្ថតាមដែលពោលហើយ ។

ពោលដោយអប្បនាវារៈនេះថា **យេ វា បន តស្មឹ សមយេ** ក្នុងទីនេះក៏ទ្រង់សង្គ្រោះយេវាបនកធម៌ តាមដែលពោលហើយខាងដើមនោះឯង ។

យេវាបនកធម៌ក្នុងទីនេះ យ៉ាងណា ក្នុងទីទាំងពួងក៏យ៉ាងនោះ ។ បន្ទាប់អំពីនេះទៅ ខ្ញុំនឹងមិនវិចារណាអត្ថ មានប្រមាណប៉ុណ្ណោះទៀត ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងនិទ្ទេសវារ និងបដិនិទ្ទេសវារ ដោយន័យតាមដែលពោលហើយខាងដើមនុ៎ះឯង ។

**សង្គហវារ ចប់**

*សូម្បីពាក្យថា កោដ្ឋាសវារ ក៏ជាឈ្មោះរបស់សង្គហវារនោះឯង*

# អភិធម្មបិដក

## សុញ្ញតវារៈ

[ ៩៩ ] ពួកធម៌កើតមានក្នុងសម័យនោះ ពួកខន្ធ ពួកអាយតនៈ ពួកធាតុ ពួកអាហារ ពួកឥន្ទ្រិយ ឈាន មគ្គ ពួកពល ពួកហេតុ ផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ មនាយតនៈ មនិន្ទ្រិយ មនោវិញ្ញាណធាតុ ធម្មាយតនៈ ធម្មធាតុកើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

[ ១០០ ] ពួកធម៌ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកធម៌កើតមានក្នុងសម័យនោះ ។

[ ១០១ ] ពួកខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកខន្ធកើតមានក្នុងសម័យនោះ ។

[ ១០២ ] ពួកអាយតនៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ មនាយតនៈ ធម្មាយតនៈ នេះពួកអាយតនៈកើតមានក្នុងសម័យនោះ ។

[ ១០៣ ] ពួកធាតុ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ មនោ-វិញ្ញាណធាតុ ធម្មធាតុ នេះពួកធាតុកើតមានក្នុងសម័យនោះ ។

[ ១០៤ ] ពួកអាហារកើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សាហារ មនោសញ្ចេតនាហារ វិញ្ញាណាហារ នេះពួកអាហារ កើតមានក្នុងសម័យនោះ ។

[ ១០៥ ] ពួកឥន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។

សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ នេះពួកឥន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ១០៦ ] ឈាន កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ វិតក្ក វិចារ បីតិ សុខ ឯកគ្គតារបស់ចិត្ត នេះឈានកើតមានក្នុងសម័យនោះ ។

[ ១០៧ ] មគ្គ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ នេះមគ្គកើតមានក្នុងសម័យនោះ ។

[ ១០៨ ] ពួកពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សទ្ធា-ពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល នេះពួកពលកើតមានក្នុងសម័យនោះ ។

[ ១០៩ ] ពួកហេតុកើតមានក្នុងសម័យនោះ តើដូចម្ដេច ។ អលោភៈ អទោសៈ អមោហៈ នេះពួកហេតុកើតមានក្នុងសម័យនោះ ។

[ ១១០ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។បេ។ នេះផស្សៈ កើតមានក្នុងសម័យនោះ ។

[ ១១១ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។បេ។ នេះវេទនាកើតមានក្នុងសម័យនោះ ។

[ ១១២ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។បេ។ នេះសញ្ញាកើតមានក្នុងសម័យនោះ ។

[ ១១៣ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។បេ។ នេះ

ចេតនាកើតមានក្នុងសម័យនោះ ។

[ ១១៤ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះចិត្ត កើតមានក្នុងសម័យនោះ ។

[ ១១៥ ] វេទនាខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះវេទនាខន្ធកើតមានក្នុងសម័យនោះ ។

[ ១១៦ ] សញ្ញាខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះសញ្ញាខន្ធកើតមានក្នុងសម័យនោះ ។

[ ១១៧ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។

[ ១១៨ ] វិញ្ញាណក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះវិញ្ញាណក្ខន្ធកើតមានក្នុងសម័យនោះ ។

[ ១១៩ ] មនាយតនៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះមនាយតនៈកើតមានក្នុងសម័យនោះ ។

[ ១២០ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះមនិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ១២១ ] មនោវិញ្ញាណធាតុ កើតមានក្នុងសម័យនោះ តើដូចម្តេច ។បេ។ នេះមនោវិញ្ញាណធាតុកើតមានក្នុងសម័យនោះ ។

[ ១២២ ] ធម្មាយតនៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះធម្មាយតនៈកើតមានក្នុងសម័យនោះ ។

[ ១២៣ ] ធម្មធាតុ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះធម្មធាតុកើតមានក្នុងសម័យនោះ ។

[ ១២៤ ] មួយទៀត ពួកអរូបធម៌ដទៃណាកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

សុញ្ញតវារ ចប់

បឋមចិត្ត ចប់

# អដ្ឋកថា

## សុញ្ញតវារ បឋមចិត្ត

[ ៩៩-១២៤ ] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមសុញ្ញតវារ មានពាក្យថា **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ** ដូច្នេះ ។ សុញ្ញតវារនោះ កំណត់ ២ យ៉ាង គឺឧទ្ទេស និងនិទ្ទេស ។ បណ្ដាវារៈទាំងនោះ ក្នុងឧទ្ទេសវាររួមជាមួយពាក្យថា **ធម្មា ហោន្តិ** នេះផង មាន ២៤ កោដ្ឋាស ។ ក្នុងកោដ្ឋាសទាំងអស់ លោកមិនបានពោលកំណត់រាប់ថា មាន ៤ មាន ២ និងមាន ៣ ។ ព្រោះហេតុអ្វី ព្រោះកំណត់ក្នុងសង្គហវារហើយ ។ ដ្បិតថា ធម៌ទាំងឡាយដែលកំណត់ទុកក្នុងសង្គហវារនោះឯង លោកក៏ពោលក្នុងសុញ្ញតវារនេះ ។ ពិតហើយ សុញ្ញតវារនេះ រមែងមិនបានសត្វ ឬសភាវៈ ឬអត្តា ។ ធម៌ទាំងឡាយ ត្រាស់ដើម្បីសម្ដែងសុញ្ញតា ( ភាពទទេ ) នេះថា ធម៌ទាំងនេះត្រឹមតែជាធម៌ មិនមានខ្លឹមសារ មិនជាធំ ។ ព្រោះហេតុនោះ ក្នុងឧទ្ទេសវារនេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ក្នុងសម័យណា កាមាវចរមហាកុសលចិត្តដួងទី ១ កើតឡើង ក្នុងសម័យនោះ ធម៌ច្រើនជាង ៥០ ដែលកើតឡើងដោយអង្គប្រកបរបស់ចិត្ត ជាធម៌នោះឯង ដោយអត្ថថា ជាសភាវៈ មិនមែនអ្វីៗ ដទៃ គឺមិនមែនសត្វ មិនមែនភាវៈ មិនមែនជីវៈ មិនមែនបុរស មិនមែនបុគ្គល ។ មួយទៀត ធម៌នោះ រមែងឈ្មោះថា ខន្ធនោះឯង ដោយអត្ថថា ជាគំនរ ។ ក្នុងបទទាំងពួង គប្បីជ្រាបការប្រកបសេចក្ដី ដោយន័យដែលមានក្នុងកាលមុននុ៎ះឯង ព្រោះអង្គឈានដទៃអំពីឈាន ឬថា អង្គមគ្គដទៃ អំពីមគ្គមិនមាន ហេតុនោះ ទើបក្នុង

ទីនេះ ព្រះមានព្រះភាគត្រាស់ថា **ឈានំ ហោតិ មគ្គោ ហោតិ** ឈាន កើតមាន មគ្គកើតមាន ដូច្នេះ ។ ពិតហើយ ដែលឈ្មោះថា **ឈាន** ព្រោះអត្ថថា ចូលទៅសម្លឹង ដែលឈ្មោះថា **មគ្គ** ព្រោះអត្ថថា ជាហេតុ ។ សត្វ ឬភាវៈណានីមួយដទៃ មិនមាន ព្រោះហេតុនោះ គប្បីប្រកបសេចក្តីក្នុងបទ ទាំងពួងយ៉ាងនេះ ។ និទ្ទេសវារ មានសេចក្តីងាយយល់ហើយ ។

**សុញ្ញតវារ ចប់**

**ការពណ៌នាអត្ថនៃបឋមចិត្តដែលប្រដាប់ដោយមហាវារៈទាំង ៣ ចប់**

# អភិធម្មបិដក

## ទុតិយចិត្តជាដើម

[ ១២៥ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ចិត្ត ជាកាមាវចរកុសល ប្រទ្បំដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធតែអារម្មណ៍ណាមួយ ហើយកើតឡើងក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ។បេ។ នេះពួកធម៌ជាកុសល ។បេ។

### ទុតិយចិត្ត ចប់

[ ១២៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ចិត្ត ជាកាមាវចរកុសល ប្រទ្បំដោយសោមនស្ស ប្រាសចាកញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធតែអារម្មណ៍ណាមួយ ហើយកើតឡើងក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្ក វិចារ បីតិ សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អនភិជ្ឈា អព្យាបាទ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់

ចិត្ត សេចក្ដីត្រង់កាយ សេចក្ដីត្រង់ចិត្ត សតិ សមថៈ សេចក្ដីផ្គងឡើង សេចក្ដីមិនរាយមាយ កើតមានក្នុងសម័យនោះ ឬថា អរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមាន ក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

[ ១២៧ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៧ ឈានប្រកបដោយអង្គ ៥ មគ្គប្រកបដោយអង្គ ៤ ពល ៦ ហេតុ ២ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១២៨ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា វិតក្ក វិចារ បីតិ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មា-សតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អនភិជ្ឈា អព្យាបាទ ហិរិ ឱត្តប្បៈ សេចក្ដីស្ងប់កាយ សេចក្ដីស្ងប់ចិត្ត សេចក្ដីស្រាលកាយ សេចក្ដីស្រាលចិត្ត សេចក្ដីទន់កាយ សេចក្ដីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្ដីស្ទាត់កាយ សេចក្ដីស្ទាត់ចិត្ត សេចក្ដីត្រង់កាយ សេចក្ដីត្រង់ចិត្ត សតិ សមថៈ សេចក្ដីផ្គងឡើង សេចក្ដីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុង

សម័យនោះ ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ក៏កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

## តតិយចិត្ត ចប់

[ ១២៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ចិត្តជាកាមាវចរកុសល ប្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធតែអារម្មណ៍ណាមួយហើយកើតឡើងក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ។បេ។ នេះពួកធម៌ជាកុសល ។បេ។

## ចតុត្ថចិត្ត ចប់

[ ១៣០ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ចិត្តជាកាមាវចរកុសល ប្រឡំដោយឧបេក្ខា ប្រកបដោយញាណ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធតែអារម្មណ៍ណាមួយហើយកើតឡើងក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។ វេទនា សញ្ញា ចេតនា ចិត្ត វិតក្ក វិចារ ឧបេក្ខា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មា-

សមាធិ សទ្ធាពល វិរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សម្បជញ្ញៈ សមថៈ វិបស្សនា សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

[ ១៣១ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា កើតមានក្នុងសម័យនោះ នេះផស្សៈ កើតមានក្នុងសម័យនោះ ។ វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរ ដល់ផស្សៈជាដើមនោះ ការទទួលអារម្មណ៍មិនជាទុក្ខមិនជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនជាទុក្ខ មិនជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។បេ។ ឧបេក្ខាកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទុក្ខ មិនជាសុខដែល

កើតអំពីសម្ផស្សនៃចិត្ត វេទនាមិនជាទុក្ខ មិនជាសុខ ដែលកើតអំពីសម្ផស្ស នៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខា កើតមានក្នុងសម័យនោះ ។បេ។ ឧបេក្ខិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនជាទុក្ខ មិនជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខិន្ទ្រិយកើតមានក្នុងសម័យនោះ ។ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

[ ១៣២ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ៤ មគ្គប្រកបដោយអង្គ ៥ ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៣៣ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្ក វិចារ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ

សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សម្បជញ្ញៈ សមថៈ វិបស្សនា សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ឬថា ពួកអរូប-ធម៌ដទៃណា ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

## បញ្ចមចិត្ត ចប់

[ ១៣៤ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ចិត្តជាកាមាវចរកុសល ប្រទូំដោយឧបេក្ខាប្រកបដោយញាណ ប្រកបដោយសង្ខារ មានរូបជាអា-រម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធតែអារម្មណ៍ណាមួយហើយ កើតឡើងក្នុងសម័យណា ផស្សៈកើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយកើតមាន ។បេ។ នេះពួកធម៌ជាកុសល ។បេ។

## ឆដ្ឋចិត្ត ចប់

[ ១៣៥ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ចិត្ត ជាកាមាវចរកុសល ប្រទូំដោយឧបេក្ខា ប្រាសចាកញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធតែអារម្មណ៍ណាមួយហើយ កើតឡើងក្នុងសម័យណា ផស្សៈកើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្ក

វិចារ ឧបេក្ខា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អនភិជ្ឈា អព្យាបាទ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សមថៈ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុកើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៣៦ ] ខន្ធ ៤ កើតមាន ក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៧ ឈានប្រកបដោយអង្គ ៤ មគ្គប្រកបដោយអង្គ ៤ ពល ៦ ហេតុ ២ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៣៧ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្ក វិចារ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល ហិរិពល ឱត្តប្ប-

ពល អលោភៈ អទោសៈ អនភិជ្ឈា អព្យាបាទ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សមថៈ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណាក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

## សត្តមចិត្ត ចប់

[ ១៣៨ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ចិត្តជាកាមាវចរកុសល ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធតែអារម្មណ៍ណាមួយហើយ កើតឡើងក្នុងសម័យណា ផស្សៈ កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ កើតមាន ។បេ។ នេះពួកធម៌ជាកុសល ។

## អដ្ឋមចិត្ត ចប់

## កាមាវចរមហាកុសលចិត្តទាំង ៨ ចប់

## ទុតិយភាណវារ ចប់

# អដ្ឋកថា

## ទុតិយចិត្ត

[ ១២៥ ] ឥឡូវនេះ ដើម្បីសម្ដែងមហាកុសលចិត្ត មានចិត្តជួនទី ២ ជាដើម ទើបផ្ដើមពាក្យជាដើមថា **កតមេ ធម្មា** ដូច្នេះទៀត ។ សូម្បីក្នុងចិត្តទាំងអស់នោះ គប្បីជ្រាបមហាវារៈមួយជួនៗ ៣ វារៈ ដោយន័យដែលពោលមកហើយ ក្នុងបឋមចិត្ត និងមិនមែនមហាវារៈតែម្យ៉ាងប៉ុណ្ណោះ សូម្បីអត្ថនៃបទទាំងពួង ដែលដូចពាក្យដែលពោលក្នុងបឋមចិត្ត ក៏គប្បីជ្រាបដោយន័យដែលពោលហើយដូចគ្នា ។ ព្រោះថា ខាងមុខអំពីនេះទៅ ខ្ញុំនឹងពណ៌នាបទតាមលំដាប់នោះឯង គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃចិត្តជួនទី ២ មុន ។

ពាក្យថា **សសង្ខារេន** នេះប៉ុណ្ណោះ ជាពាក្យមិនធ្លាប់អធិប្បាយ ។ បទថា **សសង្ខារេន** នោះ មានអធិប្បាយដូចតទៅនេះ ធម៌ដែលឈ្មោះថា **សសង្ខារ** ព្រោះប្រព្រឹត្តទៅជាមួយនឹងសង្ខារ អធិប្បាយថា មានការដឹកនាំនោះ គឺមានការប្រកប មានឧបាយ មានពួកនៃបច្ច័យ ។ ពិតហើយ មហាកុសលចិត្តជួនទី ១ រមែងកើតឡើងដោយពួកនៃបច្ច័យ មានអារម្មណ៍ជាដើមឯណា ចិត្តជួនទី ២ នេះ ក៏រមែងកើតឡើងដោយពួកនៃបច្ច័យដោយមានការប្រកប មានឧបាយនោះដូចគ្នា ។

គប្បីជ្រាបការកើតឡើងនៃចិត្តជួនទី ២ នោះ យ៉ាងនេះថា ភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ អាស្រ័យនៅក្នុងទីបំផុតនៃវិហារ កាលដល់វេលាបោសលានព្រះចេតិយ ឬដល់វេលាបម្រើព្រះថេរៈ ឬដល់ថ្ងៃស្ដាប់ធម៌ ក៏គិតថា

កាលអញទៅហើយត្រឡប់មក នឹងឆ្ងាយណាស់ អញនឹងមិនទៅ ដូច្នេះ ហើយគិតតទៅទៀតថា ឈ្មោះថា ការដែលភិក្ខុមិនទៅបោសលានព្រះចេតិយ មិនទៅបម្រើព្រះថេរៈ ឬមិនទៅស្តាប់ធម៌ មិនសមគួរ អញនឹងទៅដូច្នេះ ទើបទៅ ។ កុសលចិត្តដែលកើតឡើងដល់ភិក្ខុនោះ ដោយសេចក្តីព្យាយាមរបស់ខ្លួនឯងយ៉ាងនេះ ឬដល់ភិក្ខុដែលត្រូវបុគ្គលដទៃពោលប្រៀនប្រដៅ សម្តែងទោសក្នុងការមិនធ្វើ និងអានិសង្សក្នុងការធ្វើវត្តជាដើម ឬដល់ភិក្ខុដែលត្រូវបញ្ជាឲ្យធ្វើដោយអំណាចនិគ្គហៈនោះឯងថា ចូរមក ចូរធ្វើវត្តនេះ ដូច្នេះ ឈ្មោះថា កើតឡើងដោយមានការដឹកនាំ ដោយមានពួកនៃបច្ច័យ ដូច្នេះ ។

**ទុតិយចិត្ត ចប់**

# តតិយចិត្ត

[ ១២៦-១២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចិត្តដួងទី ៣ ដូចតទៅនេះ

បទថា **ញាណវិប្បយុត្តំ** សេចក្តីថា ចិត្តមិនប្រកបដោយបញ្ញា ឈ្មោះថា **ញាណវិប្បយុត្ត** ។ ពិតហើយ ចិត្តដួងទី ៣ នេះ ជាចិត្តត្រេកអរហើយក្នុងអារម្មណ៍ តែក្នុងចិត្តដួងទី ៣ នេះ មិនមានបញ្ញា ( ញាណ ) ជាគ្រឿងកំណត់ ព្រោះហេតុនោះ ចិត្តដែលជាញាណវិប្បយុត្តនេះ បណ្ឌិតគប្បីជ្រាបថា រមែងកើតឡើងក្នុងកាលដែលពួកក្មេងតូចៗ ឃើញភិក្ខុហើយថ្វាយបង្គំដោយគិតថា ព្រះថេរៈនេះ របស់ពួកយើង និងក្នុងកាលដទៃៗមានការថ្វាយបង្គំព្រះចេតិយ និងការស្តាប់ធម៌ជាដើម ដោយន័យនុ៎ះឯង ។ ក្នុងព្រះបាលី ក្នុងឧទ្ទេសនៃចិត្តដួងទី ៣ នេះ បញ្ញាក្នុងទី ៧ អន្ទើ[១] មិនមាន ។ ពាក្យដ៏សេសប្រព្រឹត្តទៅតាមប្រក្រតីនោះឯង ។

**តតិយចិត្ត ចប់**

១- បញ្ញា ៧ អន្ទើ មានបញ្ញិន្ទ្រិយ សម្មាទិដ្ឋិជាដើម ។

# ចតុត្ថចិត្ត

[ ១២៩ ] សូម្បីក្នុងចិត្តដួងទី ៤ ក៏ន័យនេះដូចគ្នា តែចិត្តដួងទី ៤ នេះ ព្រោះព្រះបាលីថា **សសំខារេន** គប្បីជ្រាបថា រមែងមានក្នុងកាលដែលមាតាបិតាចាប់ក្បាលក្មេងតូចៗ ឲ្យឱនថ្វាយបង្គំព្រះចេតិយជាដើម ទោះបីក្មេងទាំងនោះ មិនប្រាថ្នានឹងថ្វាយបង្គំ ក៏រីករាយត្រេកអរ ។

**ចតុត្ថចិត្ត ចប់**

# បញ្ចមចិត្ត

[ ១៣០-១៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចិត្តដួងទី ៥ ដូចតទៅៈ

បទថា **ឧបេក្ខាសហគតំ** បានដល់ ប្រកបដោយឧបេក្ខាវេទនា ពិតហើយ ក្នុងចិត្តដួងទី ៥ នេះ រមែងជាកណ្ដាលក្នុងអារម្មណ៍ ។ ក្នុងចិត្តដួងទី ៥ នេះ មានញាណជាគ្រឿងកំណត់ដោយពិត ។ ក្នុងបាលី ព្រះមានព្រះភាគត្រាស់ថា ឧបេក្ខាកើតមានក្នុងពួក ៨ នៃឥន្ទ្រិយ ត្រាស់ថា ឧបេក្ខិន្ទ្រិយកើតមានដូច្នេះ ហើយទ្រង់ធ្វើទេសនាដោយការបដិសេធភាពសប្បាយ ភាពមិនសប្បាយ សុខ ទុក្ខ ក្នុងនិទ្ទេសនៃបទថា **វេទនា** ទាំងពួង ហើយត្រាស់អទុក្ខម-សុខវេទនា ។ គប្បីជ្រាបភាពដែលអទុក្ខមសុខវេទនានោះ ជាឧបេក្ខិន្ទ្រិយ ដោយអំណាចនៃការគ្រប់គ្រងភាពជាធំក្នុងលក្ខណៈ នៃភាពជាកណ្ដាល ។ មួយទៀត កាលពោលដោយលំដាប់នៃបទ ( ឧទ្ទេស ) បីតិ ក្នុងទីមួយ អន្ទើមិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់លើកឡើងនូវធម៌ ៥៥ ប្រការ កាន់ព្រះបាលីដោយអំណាចនៃអង្គប្រកបរបស់ចិត្ត ។ គប្បីជ្រាប វិនិច្ឆ័យក្នុងកោដ្ឋាសទាំងពួង និងក្នុងវារៈទាំងពួង ដោយអំណាចនៃធម៌ ទាំងនោះ ។

**បញ្ចមចិត្ត ចប់**

# ឆដ្ឋចិត្តជាដើម

[ ១៣៤-១៣៨ ] គប្បីជ្រាបចិត្តដួងទី ៦ ទី ៧ ទី ៨ ដោយន័យដែលពោលហើយក្នុងចិត្តដួងទី ២ ទី ៣ ទី ៤ នុ៎ះឯង ។ ក្នុងចិត្តដួងទី ៦ ទី ៧ ទី ៨ ទាំងនេះ មានត្រឹមតែការផ្លាស់វេទនា និងមិនមានបីតិ ។ ពាក្យដ៏សេស ជាមួយនឹងន័យនៃការកើតឡើងក៏យ៉ាងនោះដូចគ្នា ។ សូម្បីក្នុងវេលាបរិកម្ម ករុណា និងមុទិតា ការកើតឡើងនៃចិត្តទាំងនេះ លោកបានទទួលយល់ព្រមហើយ ក្នុងមហាអដ្ឋកថានោះឯង ។ ចិត្តទាំងនេះ ឈ្មោះថា កាមាវចរកុសលចិត្ត ៨ ដួង ។

ឆដ្ឋចិត្តជាដើម ចប់

# បុញ្ញកិរិយាវត្ថុជាដើម

កាមាវចរកុសលចិត្តទាំងអស់នោះ បណ្ឌិតគប្បីសម្ដែងដោយបុញ្ញកិរិយា-វត្ថុ ១០ ប្រការ ។ សួរថា សម្ដែងដូចម្ដេច ។ ឆ្លើយថា បុញ្ញកិរិយាវត្ថុ ១០ គឺទានមយៈ បុញ្ញកិរិយាវត្ថុសម្រេចដោយទាន ១ សីលមយៈ បុញ្ញ-កិរិយាវត្ថុសម្រេចដោយសីល ១ ភាវនាមយៈ បុញ្ញកិរិយាវត្ថុសម្រេចដោយភាវនា ១ អបចិតិសហគតៈ បុញ្ញកិរិយាវត្ថុដែលសហគតៈដោយការឱនលំទោន ១ វេយ្យាវច្ចសហគតៈ បុញ្ញកិរិយាវត្ថុដែលសហគតៈដោយការខ្វល់ខ្វាយ ១ បត្តានុប្បទានៈ បុញ្ញកិរិយាវត្ថុ គឺការផ្សាយចំណែកបុណ្យ ១ អព្ភានុមោទនៈ បុញ្ញកិរិយាវត្ថុ គឺការអនុមោទនា ១ ទេសនាមយៈ បុញ្ញកិរិយាវត្ថុសម្រេចដោយការសម្ដែងធម៌ ១ សវនមយៈ បុញ្ញកិរិយាវត្ថុសម្រេចដោយការស្ដាប់ធម៌ ១ ទិដ្ឋុជុកម្ម បុញ្ញកិរិយាវត្ថុ គឺការធ្វើទិដ្ឋិឲ្យត្រង់ ១ ។

បណ្ដាបុញ្ញកិរិយាវត្ថុទាំងនោះ ទានទុំះឯង ឈ្មោះថា **ទានមយ** ការធ្វើបុណ្យនោះផង ជាវត្ថុ ( គឺទីតាំង ) នៃអានិសង្សទាំងឡាយនោះៗ ផង ព្រោះហេតុនោះ ទើបឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ។ ក្នុងបុញ្ញកិរិយាវត្ថុ សូម្បីដ៏សេសក៏ន័យនេះឯង ។

បណ្ដាបុញ្ញកិរិយាវត្ថុទាំងនោះ កាលបុគ្គលឲ្យវត្ថុនោះៗ បណ្ដាបច្ច័យ ៤ មានចីវរជាដើម ឬបណ្ដាអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ឬក្នុងទានវត្ថុ ១០ មានបាយជាដើម ចេតនាដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ គឺក្នុងកាលខាងដើមបន្ទាប់អំពីការកើតឡើងនៃវត្ថុនោះៗ ១ ក្នុងកាលបរិច្ចាគ ១ ក្នុង

ការតាមរឭកដល់ដោយចិត្តសោមនស្ស ក្នុងកាលខាងក្រោយ ១ ឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយទាន ។

ចេតនាដែលប្រព្រឹត្តទៅរបស់បុគ្គលអ្នកសមាទានសីល ៥ ឬសីល ៨ ឬសីល ១០ ឬរបស់អ្នកទៅកាន់វិហារដោយគិតថា អញនឹងបួសក្តី កំពុងបួសក្តី ញ៉ាំងមនោរថឲ្យដល់ទីបំផុតហើយ រំពឹងថា អញបួសហើយ ជាការល្អក្រៃលែងហ្ន៎ដូច្នេះក្តី សង្រួមក្នុងបាតិមោក្ខក្តី ពិចារណាបច្ច័យទាំងឡាយមានចីវរជាដើមក្តី សង្រួមទ្វារមានចក្ខុទ្វារជាដើម ក្នុងរូបជាដើម ដែលមកកាន់គន្លងក្តី ជម្រះអាជីវៈឲ្យបរិសុទ្ធក្តី ឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយសីល ។

ចេតនាដែលប្រព្រឹត្តទៅ របស់បុគ្គលអ្នកពិចារណាចក្ខុ ដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ពិចារណាសោតៈដោយ ។បេ។ ពិចារណា មនៈ ដោយភាពជារបស់មិនទៀង ។បេ។ ពិចារណារូបទាំងឡាយដោយ ។បេ។ ពិចារណាធម៌ទាំងឡាយដោយ ។បេ។ ពិចារណាចក្ខុវិញ្ញាណដោយ ។បេ។ ពិចារណាមនោវិញ្ញាណដោយ ។បេ។ ពិចារណាចក្ខុសម្ផស្សដោយ ។បេ។ ពិចារណាមនោសម្ផស្សដោយ ។បេ។ ពិចារណាវេទនា ដែលកើតអំពីចក្ខុសម្ផស្សដោយ ។បេ។ ពិចារណាវេទនាដែលកើតអំពីមនោសម្ផស្សដោយ ។បេ។ ពិចារណារូបសញ្ញាដោយ ។បេ។ ពិចារណា ជរាមរណៈដោយ ។បេ។ ដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ដោយឧបាយនៃវិបស្សនា ដែលព្រះសារីបុត្តត្ថេរពោលទុកក្នុងបដិ-

សម្ពិទាមគ្គ ឬចេតនាទាំងអស់ដែលមិនដល់អប្បនាក្នុងអារម្មណ៍ ៣៨ យ៉ាង ឈ្មោះថា **បុញ្ញកិរិយាវត្ថុ**សម្រេចដោយការនៃា ។

គប្បីជ្រាបបុញ្ញកិរិយាវត្ថុដែលសហគតៈដោយការឱនលំទោន ដោយការឃើញបុគ្គលដែលជាធំ ហើយធ្វើបដិសណ្ឋារៈ មានការទទួលបាត្រ ចីវរ ថ្វាយបង្គំ និងការចៀសផ្លូវជាដើម ។

គប្បីជ្រាបបុញ្ញកិរិយាវត្ថុដែលសហគតៈដោយការខ្វល់ខ្វាយ ក្នុងវេលាខ្វល់ខ្វាយតាមផ្លូវកាយ ដោយការធ្វើវត្ត និងធ្វើបដិវត្ត ដល់ភិក្ខុដែលចម្រើនជាឥក្តី ដោយការឃើញភិក្ខុដែលចូលទៅបិណ្ឌបាតក្នុងស្រុក ទទួលបាត្រហើយ បបួលអ្នកស្រុកឲ្យប្រគេនភិក្ខាក្តី ដោយការបានឮពាក្យថា ចូរអ្នកទៅ ចូរទទួលបាត្ររបស់ភិក្ខុទាំងឡាយមក ហើយប្រញាប់ទៅនាំបាត្រមកឲ្យជាដើមក្តី ។

កាលបុគ្គលឲ្យទាន ធ្វើការបូជាដោយរបស់ក្រអូបជាដើមហើយឲ្យចំណែកបុណ្យថា សូមចំណែកបុណ្យមានដល់បុគ្គលឈ្មោះនោះ ឬថា សូមចំណែកបុណ្យមានដល់សព្វសត្វទាំងឡាយ ដូច្នេះ គប្បីជ្រាបថា ជាបុញ្ញកិរិយាវត្ថុគឺការផ្សាយចំណែកបុណ្យ ។ សួរថា កាលបុគ្គលឲ្យនូវចំណែកបុណ្យនេះបុណ្យនឹងអស់ដែរឬទេ ឆ្លើយថា មិនអស់ ដូចបុគ្គលអុជប្រទីបឲ្យភ្លឺតែមួយដើម ហើយក៏ញ៉ាំងប្រទីបមួយពាន់ដើមឲ្យភ្លឺព្រោងព្រាតបាន ព្រោះប្រទីបមួយដើមនោះ នរណាៗ មិនគប្បីពោលបានថា ប្រទីបដួងដំបូងអស់ទៅហើយ តែពន្លឺនៃប្រទីបក្រោយៗ ជាមួយនឹងប្រទីបដំបូងរួមគ្នាហើយ ក៏ជាពន្លឺ

ភ្លឺក្រៃលែងឡើង យ៉ាងណា កាលបុគ្គលឲ្យនូវចំណែកនៃបុណ្យ ក៏យ៉ាងនោះ ដូចគ្នា ឈ្មោះថា បុណ្យទាំងឡាយ នឹងថយចុះទៅ រមែងមិនមាន គប្បីជ្រាបថា រមែងមានតែចម្រើនឡើងប៉ុណ្ណោះ ។

គប្បីជ្រាបបុញ្ញកិរិយាវត្ថុ គឺការអនុមោទនាដោយអំណាចនៃការអនុមោទនានូវចំណែកបុណ្យដែលបុគ្គលដទៃឲ្យហើយ ឬនូវបុញ្ញកិរិយាវត្ថុដទៃៗ ថា សាធុ សាធុ ដូច្នេះ ។

ភិក្ខុមួយរូប តាំងនៅក្នុងសេចក្ដីចង់បានដោយគិតថា ជនទាំងឡាយនឹងដឹងអញថា ជាធម្មកថិក ដូច្នេះហើយ ជាអ្នកឃើញដល់លាភ សម្ដែងធម៌ ការសម្ដែងធម៌នោះ មិនមានផលច្រើន ។ ចំណែកភិក្ខុមួយរូបមិនប្រាថ្នាផលតបស្នង សម្ដែងធម៌ដែលខ្លួនជំនាញដល់ជនពួកដទៃ ដោយឧបាយដែលនឹងឲ្យសម្រេចវិមុត្តិ ការសម្ដែងនេះ ឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយការសម្ដែងធម៌ ។

ភិក្ខុមួយរូប កាលស្ដាប់ធម៌ ក៏ស្ដាប់ដោយគិតថា ជនទាំងឡាយនឹងដឹងថា អញជាអ្នកមានសទ្ធា ការស្ដាប់នោះ មិនមានផលច្រើនទេ ។ ចំណែកភិក្ខុមួយរូប គិតហើយថា ផលច្រើននឹងមានដល់អញ ដោយអាការយ៉ាងនេះ ដូច្នេះហើយ រមែងស្ដាប់ធម៌ដោយចិត្តទន់ភ្លន់ ដោយការផ្សាយទៅនូវប្រយោជន៍ ការស្ដាប់ធម៌នេះ ឈ្មោះថា បុញ្ញកិរិយាវត្ថុ សម្រេចដោយការស្ដាប់ធម៌ ។

កាលបុគ្គលធ្វើសេចក្ដីយល់ឃើញឲ្យត្រង់ ឈ្មោះថា បុញ្ញកិរិយាវត្ថុ គឺ

ការធ្វើទិដ្ឋិឲ្យត្រង់ ។ តែអាចារ្យអ្នកពោលទីឃនិកាយ ពោលថា ទិដ្ឋុជុកម្ម ជាលក្ខណនិយមរបស់បុញ្ញកិរិយាទាំងអស់ ព្រោះថា កាលបុគ្គលធ្វើបុណ្យ យ៉ាងណាមួយ បុណ្យរមែងមានផលច្រើន ព្រោះទិដ្ឋិដ៏ត្រង់នុ៎ះឯង ដូច្នេះ ។

បណ្ដាបុញ្ញកិរិយាវត្ថុទាំងនោះ បុញ្ញកិរិយាវត្ថុដែលជាទានមយៈ រមែងកើតឡើងដល់បុគ្គលដែលគិតថា អញនឹងឲ្យទាន រមែងកើតឡើងដល់បុគ្គលកំពុងឲ្យទាន រមែងកើតឡើងដល់បុគ្គលដែលពិចារណាថា ទានខ្ញុំឲ្យហើយ ។ ដោយអាការយ៉ាងនេះ ឈ្មោះថា បុញ្ញកិរិយាវត្ថុ ដែលជាទានមយៈ រមែងមាន ព្រោះធ្វើចេតនាទាំង ៣ គឺបុព្វចេតនា ១ មុញ្ចនចេតនា ១ បរចេតនា ១ ឲ្យជារបស់តែមួយ ។ សូម្បីសីលមយៈ ក៏រមែងកើតដល់បុគ្គលដែលគិតថា អញនឹងបំពេញសីល រមែងកើតឡើងក្នុងវេលាដែលកំពុងបំពេញសីល រមែងកើតឡើងដល់បុគ្គល ដែលពិចារណាថា អញបានបំពេញសីលហើយ ឈ្មោះថា បុញ្ញកិរិយាវត្ថុដែលជាសីលមយៈ រមែងមាន ព្រោះធ្វើចេតនាទាំងពួងនោះ ឲ្យជារបស់តែមួយ ។បេ។ បុញ្ញកិរិយាវត្ថុ ដែលជាទិដ្ឋុជុកម្ម រមែងកើតដល់បុគ្គលដែលគិតថា អញនឹងធ្វើសេចក្ដីយល់ឃើញ ឲ្យត្រង់ រមែងកើតឡើង ដល់បុគ្គលដែលកំពុងធ្វើការយល់ឃើញឲ្យត្រង់ រមែងកើតឡើងដល់បុគ្គលដែលពិចារណាថា ទិដ្ឋិអញធ្វើឲ្យត្រង់ហើយ ។ ឈ្មោះថា បុញ្ញកិរិយាវត្ថុដែលជាទិដ្ឋុជុកម្ម រមែងមាន ព្រោះធ្វើចេតនាទាំងអស់នោះឲ្យជារបស់តែមួយ ។

ចំណែកក្នុងព្រះសូត្រ បុញ្ញកិរិយាវត្ថុមានត្រឹមតែ ៣ ប៉ុណ្ណោះ ។ គប្បី

ជ្រាបការសង្គ្រោះបុញ្ញកិរិយាវត្ថុក្រៅនេះ ចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ នោះ ។ មែនពិត ការប្រព្រឹត្តឱនលំទោន និងការខ្វល់ខ្វាយ សង្គ្រោះចូលក្នុងសីលមយៈនោះឯង ។ ការឲ្យចំណែកបុណ្យ និងការអនុមោទនាចំណែកបុណ្យ សង្គ្រោះចូលក្នុងទានមយៈ ។ ការសម្តែងធម៌ ការស្តាប់ធម៌ និងទិដ្ឋុជុកម្ម សង្គ្រោះចូលក្នុងភាវនាមយៈ ចំណែកជនទាំងឡាយណាពោលថា ទិដ្ឋុជុកម្ម ជាលក្ខណនិយម ( គ្រឿងជំនួយ ) របស់បុញ្ញកិរិយាវត្ថុទាំងពួង ទិដ្ឋុជុកម្មរបស់ជនទាំងនោះ រមែងដល់ការសង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ ។ បុញ្ញកិរិយាវត្ថុទាំងនេះ ដោយសង្ខេបមាន ៣ ដោយពិស្តារមាន ១០ ដោយប្រការដូច្នេះ ។

បណ្តាបុញ្ញកិរិយាវត្ថុទាំងនោះ កាលបុគ្គលគិតថា អញនឹងឲ្យទានដូច្នេះ រមែងគិតដោយកាមាវចរកុសលចិត្ត ៨ ដួង ដួងណាទីមួយដោយពិត ។ កាលឲ្យ ( ទាន ) ក៏រមែងឲ្យដោយចិត្តទាំងនោះ ដួងណាទីមួយទុំះឯង កាលពិចារណាថា ទានខ្ញុំឲ្យហើយ ក៏រមែងពិចារណា ដោយចិត្តទាំងនោះ ដួងណាទីមួយដូចគ្នា កាលគិតថា អញនឹងបំពេញសីលឲ្យបរិបូណ៌ ក៏គិតដោយចិត្តទាំងនោះ ដួងណាទីមួយទុំះឯង សូម្បីកំពុងបំពេញសីលក៏បំពេញដោយចិត្តទាំងនោះ ដួងណាទីមួយទុំះឯង សូម្បីពិចារណាថា សីលខ្ញុំបំពេញហើយ ក៏រមែងពិចារណាដោយចិត្តទាំងនោះ ដួងណាមួយដូចគ្នា កាលគិតថា អញនឹងចម្រើនភាវនា ក៏រមែងគិតដោយចិត្តទាំងនោះ ដួងណាមួយទុំះឯង កាលចម្រើនភាវនា ក៏រមែងចម្រើនដោយចិត្តទាំងនោះ ដួងណាមួយទុំះឯង

កាលពិចារណាថា ការនោះខ្ញុំចម្រើនហើយ ក៏រមែងពិចារណាដោយចិត្តទាំងនោះ ដួងណាមួយដូចគ្នា ។

កាលគិតថា អញនឹងធ្វើសេចក្ដីឱនលំទោនចំពោះបុគ្គលជាច្បង ក៏រមែងគិតដោយចិត្តទាំងនោះ ដួងណាមួយនុ៎ះឯង កាលធ្វើ ក៏រមែងធ្វើដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលពិចារណាថា សេចក្ដីឱនលំទោន ខ្ញុំធ្វើហើយ ក៏រមែងពិចារណាដោយចិត្តទាំងនោះ ដួងណាមួយដូចគ្នា កាលគិតថា អញនឹងធ្វើកម្ម គឺការខ្វល់ខ្វាយតាមផ្លូវកាយ កាលកំពុងធ្វើ កាលពិចារណាថា ខ្ញុំធ្វើការខ្នះខ្នែងហើយ ក៏រមែងពិចារណាដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលគិតថា អញនឹងឲ្យចំណែកបុណ្យ កាលកំពុងឲ្យ កាលពិចារណាថា ចំណែកបុណ្យខ្ញុំឲ្យហើយ កាលគិតថា អញនឹងអនុមោទនាចំណែកបុណ្យ ឬកុសលក្រៅអំពីនេះ ក៏គិតដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលកំពុងអនុមោទនា ក៏រមែងអនុមោទនាដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលពិចារណាថា ចំណែកបុណ្យ ខ្ញុំអនុមោទនាហើយ ក៏រមែងពិចារណា ដោយចិត្តទាំងនោះ ដួងណាមួយដូចគ្នា កាលគិតថា អញនឹងសម្ដែងធម៌ ក៏គិតដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលកំពុងសម្ដែង ក៏រមែងសម្ដែងដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលពិចារណាថា ខ្ញុំសម្ដែងធម៌ហើយ ក៏រមែងពិចារណាដោយចិត្តទាំងនោះ ដួងណាមួយដូចគ្នា កាលគិតថា អញនឹងស្ដាប់ធម៌ ក៏រមែងគិតដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលកំពុងស្ដាប់ ក៏រមែងស្ដាប់

ដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលពិចារណាថា ខ្ញុំស្ដាប់ធម៌ហើយ ក៏រមែងពិចារណាដោយចិត្តទាំងនោះ ដួងណានីមួយដូចគ្នា កាលគិតថា អញនឹងធ្វើទិដ្ឋិឲ្យត្រង់ ក៏រមែងគិតដោយចិត្តទាំងនោះ ដួងណាមួយនោះឯង កាលកំពុងធ្វើទិដ្ឋិឲ្យត្រង់ ក៏រមែងធ្វើដោយចិត្ត ដែលសម្បយុត្តដោយញាណ ៤ ដួង ដួងណាមួយ កាលពិចារណាថា ទិដ្ឋិខ្ញុំធ្វើឲ្យត្រង់ហើយ ក៏រមែងពិចារណាដោយកាមាវចរកុសលចិត្ត ដួងណាមួយ ។

ក្នុងឋានៈ ( នៃកាមាវចរកុសលចិត្ត ៨ ) នេះ លោកកាន់យកអនន្តៈ ៤ យ៉ាង ពិតហើយ អនន្តៈមាន ៤ យ៉ាង គឺ **អាកាសោ អនន្តោ** អាកាសមិនមានទីបំផុត ១ **ចក្កវាឡានិ អនន្តានិ** ចក្កវាឡទាំងឡាយ មិនមានទីបំផុត ១ **សត្តនិកាយោ អនន្តោ** ពួកសត្វមិនមានទីបំផុត ១ **ពុទ្ធញាណំ អនន្តំ** ពុទ្ធញាណមិនមានទីបំផុត ១ ។

ពិតហើយ ការកំណត់អាកាសថា ក្នុងទិសបូព៌ ទិសបច្ចិម ទិសឧត្តរ និងទិសទក្សិណ មានប៉ុណ្ណេះរយយោជន៍ ឬប៉ុណ្ណេះពាន់យោជន៍ ដូច្នេះ រមែងកំណត់មិនបាន ។ បុគ្គលធ្វើផែនដីឲ្យញែកជាពីរ ហើយបោះញញួរដែកប៉ុនស្ដេចភ្នំសិនេរុទៅខាងក្រោម ញញួរដែកគប្បីធ្លាក់ទៅដោយពិត មិនមានទីទ្រទ្របានឡើយ ។ អាកាស ឈ្មោះថា ជាអនន្តៈយ៉ាងនេះ ។

ការកំណត់ចក្កវាឡទាំងឡាយថា មានច្រើនរយ ច្រើនពាន់ ឬច្រើនសែនចក្កវាឡ កំណត់មិនបានឡើយ ។ ពិតហើយ សូម្បីមហាព្រហ្មទាំង ៤ ដែលកើតក្នុងអកនិដ្ឋភពដែលប្រកបដោយសម្ទុះ ដែលអាចឆ្លងកាត់សែននៃ

ចក្កវាឡ ទៅដោយវេលាត្រឹមកូនសរដ៏រហ័សបំផុតរបស់ខ្មាន់ធ្នូដ៏មានកម្លាំង ខ្លាំងក្លា បាញ់ធ្នូឯកាត់ស្រមោលដើមត្នោតខាងទទឹង គប្បីស្ទុះទៅដោយរហ័ស នោះ ដោយគិតថា អញនឹងមើលទីបំផុតចក្កវាឡ មហាព្រហ្មទាំងនោះ មិន ឃើញទីបំផុតនៃចក្កវាឡ នឹងគប្បីបរិនិព្វានដោយពិត ចក្កវាឡទាំងឡាយ ឈ្មោះថា ជាអនន្តៈយ៉ាងនេះ ។

ពួកសត្វដែលនៅក្នុងទឹក និងនៅលើគោក ក្នុងចក្កវាឡទាំងឡាយ មាន ប្រមាណប៉ុណ្ណោះ រមែងមិនមានប្រមាណ ពួកសត្វទាំងឡាយ ឈ្មោះថា ជា អនន្តៈ យ៉ាងនេះ ។ ពុទ្ធញាណ ឈ្មោះថា ជាអនន្តៈជាងអនន្តៈទាំង ៣ នោះដោយពិត ។

បណ្តាសត្វទាំងឡាយដែលមិនមានប្រមាណ ក្នុងចក្កវាឡដែលមិនមាន ប្រមាណយ៉ាងនេះ កុសលចិត្តដែលជាកាមាវចរ សហគតៈដោយសោមនស្ស ជាញាណសម្បយុត្ត ជាអសង្ខារិក រមែងកើតឡើងសន្ទឹកសន្ធាប់ ដល់សត្វ មួយ រមែងកើតឡើងសន្ទឹកសន្ធាប់ដល់សត្វច្រើន ។ កុសលចិត្តទាំងអស់ នោះ រមែងដល់នូវភាពតែមួយ ដោយអត្ថថា ជាកាមាវចរ ដោយអត្ថថា សហគតៈដោយសោមនស្ស ដោយអត្ថថា ជាញាណសម្បយុត្ត ដោយអត្ថ ថា ជាអសង្ខារិក ។ មហាកុសលចិត្តដែលសហគតៈដោយសោមនស្ស ជា តិហេតុកៈ ជាអសង្ខារិក មានមួយដួងប៉ុណ្ណោះ មហាកុសលចិត្តជាសសង្ខារិក ក៏ដូចគ្នា ។បេ។ ចិត្តដែលសហគតៈដោយឧបេក្ខា ជាញាណវិប្បយុត្ត ជា ទុហេតុកៈ ជាសសង្ខារិកក៏ដូចគ្នានុ៎ះឯង ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់កំណត់កាមាវចរកុសលចិត្តទាំងអស់ ដែលកើតឡើងដល់សត្វទាំងឡាយ មិនមានប្រមាណក្នុងចក្កវាឡ ដែលមិនមានប្រមាណយ៉ាងនេះ ដោយព្រះសព្វញ្ញុតញ្ញាណ ដូចទ្រង់ថ្លឹងដោយជញ្ជីងធំ ដូចដាក់ក្នុងនាឡិវាល់ដូច្នោះ ទ្រង់ធ្វើឲ្យជា ៨ ចំណែកប៉ុណ្ណោះ ដោយអត្ថថាដូចគ្នាហើយ ទ្រង់សម្ដែងថា ចិត្តទាំងនោះ មាន ៨ ប៉ុណ្ណោះ ។

ក្នុងទីនេះ ឈ្មោះថា ការបំពេញបុណ្យ លោកកាន់យកដោយអាការ ៦ យ៉ាងទៀត ។ ពិតហើយ បុណ្យដែលធ្វើខ្លួនឯងក៏មាន បុណ្យដែលធ្វើតាមអ្នកដទៃក៏មាន បុណ្យដែលធ្វើដោយដៃរបស់ខ្លួនក៏មាន បុណ្យដែលប្រើឲ្យអ្នកដទៃធ្វើក៏មាន បុណ្យដែលធ្វើដោយបញ្ញាក៏មាន បុណ្យដែលធ្វើដោយមិនមានបញ្ញាក៏មាន បណ្ដាបុណ្យទាំង ៦ នោះ បុណ្យដែលធ្វើតាមធម្មតារបស់ខ្លួន ឈ្មោះថា **សយំការំ** គឺធ្វើឯង បុណ្យដែលឃើញអ្នកដទៃធ្វើក៏ធ្វើតាម ឈ្មោះថា **បរំការំ** គឺធ្វើតាមអ្នកដទៃ បុណ្យដែលធ្វើដោយដៃរបស់ខ្លួនឯង ឈ្មោះថា **សាហត្ថិកំ** បុណ្យដែលប្រើឲ្យបុគ្គលដទៃធ្វើ ឈ្មោះថា **អាណត្តិកំ** បុណ្យដែលជឿកម្ម និងផលហើយធ្វើ ឈ្មោះថា **សម្បជានកតំ** បុណ្យដែលមិនដឹងកម្មក្ដី ផលក្ដីធ្វើហើយ ឈ្មោះថា **អសម្បជានកតំ** ។

បណ្ដាការធ្វើបុណ្យទាំង ៦ នោះ បុគ្គលកាលធ្វើខ្លួនឯង ក៏រមែងធ្វើដោយកុសលចិត្តទាំង ៨ ដួងនេះ ដួងណាទីមួយទុំះឯង កាលធ្វើតាមអ្នកដទៃក្ដី កាលធ្វើដោយដៃរបស់ខ្លួនក្ដី កាលប្រើឲ្យអ្នកដទៃធ្វើក្ដី ក៏រមែងធ្វើដោយកុសលចិត្តទាំង ៨ ដួងនេះ ដួងណាមួយដូចគ្នា ។ តែការធ្វើដោយបញ្ញា

រមែងមានដោយចិត្តដែលសម្បយុត្តដោយញាណ ៤ ដួង ។ ការធ្វើដោយមិនមានបញ្ញា រមែងមានដោយចិត្តដែលជាញាណវិប្បយុត្ត ៤ ដួង ។

ក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់កាន់យកទក្ខិណាវិសុទ្ធិ ៤ យ៉ាងដទៃទៀត គឺ **ធម្មិក** បច្ច័យទាំងឡាយកើតឡើងដោយធម៌ ១ **ចេតនាមហត្ត** ចេតនាមានកម្លាំងច្រើន ១ **វត្ថុសម្បត្តិ** ដល់ព្រមដោយវត្ថុ ១ **គុណាតិរេកតា** ភាពជាអ្នកច្រើនក្រៃលែងដោយគុណ ១ ។

បណ្តាទក្ខិណាវិសុទ្ធិទាំង ៤ យ៉ាងនោះ បច្ច័យទាំងឡាយដែលកើតឡើងដោយធម៌ ឈ្មោះថា **ធម្មិក** ។ កាលបុគ្គលជឿស៊ប់ប្រាកដ ហើយឲ្យទាន ឈ្មោះថា **ចេតនាមហត្ត** ។ ភាពជាព្រះខីណាស្រព ឈ្មោះថា **វត្ថុសម្បត្តិ** ។ ភាពដែលព្រះខីណាស្រពនុ៎ះឯង ចេញចាកនិរោធសមាបត្តិ ឈ្មោះថា **គុណាតិរេកតា** ។ កាលបុគ្គលអាចប្រមូលទក្ខិណាវិសុទ្ធិទាំង ៤ នេះមកហើយឲ្យទាន កាមាវចរកុសល រមែងឲ្យវិបាកក្នុងអត្តភាពនេះដោយពិត ដូចកាមាវចរកុសលដែលឲ្យវិបាកដល់បុណ្ណកសេដ្ឋី កាកវលិយមាណព[១] និងសុមនមាលាការជាដើម ។

កាលពោលដោយសង្ខេប កាមាវចរកុសលចិត្តទាំងអស់នោះ ឈ្មោះថា មានតែមួយប៉ុណ្ណោះ ដោយអត្ថថា ចិត្តជាសភាវៈដ៏វិចិត្រ ព្រោះធ្វើឲ្យវិចិត្រ ។ ពោលដោយអំណាចនៃវេទនាមាន ២ យ៉ាង គឺសហគតៈដោយសោមនស្ស និងសហគតៈដោយឧបេក្ខា ។ ពោលដោយអំណាចការសម្តែង

១- ច្បាប់របស់ស្យាមជា កាលវលិយ ច្បាប់របស់ភូមាជា កាឡវល្លិយ ។

ចែកដោយញាណ មាន ៤ យ៉ាង គឺអសង្ខារិកមហាកុសលចិត្តដែលសហគតៈដោយសោមនស្ស ជាញាណសម្បយុត្ត និងអសង្ខារិកមហាកុសលចិត្តដែលសហគតៈដោយឧបេក្ខា ជាញាណសម្បយុត្ត រួមជាម្យ៉ាងប៉ុណ្ណោះ ព្រោះអត្ថថា ជាញាណសម្បយុត្ត និងព្រោះអត្ថថា ជាអសង្ខារិក ។ សសង្ខារិកដែលជាញាណសម្បយុត្ត អសង្ខារិកដែលជាញាណវិប្បយុត្ត និងសសង្ខារិកដែលជាញាណវិប្បយុត្តក៏ដូចគ្នា ។ ព្រោះហេតុនោះ ក្នុងកាមាវចរកុសលចិត្ត ៤ យ៉ាងនេះ ដោយអំណាចនៃការសម្ដែងចែកដោយញាណ កាលចែកជាអសង្ខារ និងសសង្ខារ រមែងបានកុសលចិត្ត ៨ ដួងនោះឯង គឺអសង្ខារិក ៤ ដួង សសង្ខារិក ៤ ដួង ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ជាព្រះសព្វញ្ញូ ទ្រង់ប្រសើរជាងមេគណៈទាំងឡាយ ទ្រង់ជាអ្នកប្រាជ្ញប្រសើរបំផុត ទ្រង់ជ្រាបកាមាវចរកុសលចិត្តទាំងនោះ តាមសេចក្ដីពិតហើយ ទើបទ្រង់ប្រាប់ ទ្រង់សម្ដែង ទ្រង់បញ្ញត្តិ ទ្រង់តែងតាំង ទ្រង់បើកបង្ហាញ ទ្រង់ចែក ទ្រង់ធ្វើឲ្យងាយ ដូច្នេះ ។

## កាមាវចរកុសលនិទ្ទេស ចប់

# អភិធម្មបិដក

## រូបាវចរកុសល

## ចតុក្កន័យ

[ ១៣៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ឈ្មោះបឋវីកសិណ ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ក្នុងសម័យណា ផស្សៈ កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយកើតមាន ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៤០ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានដល់ ទុតិយជ្ឈាន ឈ្មោះបឋវីកសិណ ជាធម្មជាតកើតមានក្នុងសន្តានខ្លួន មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្ក គ្មានវិចារ មានតែបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត បីតិ សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយក៏កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៤១ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២

អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ៣ មគ្គប្រកបដោយអង្គ ៤ ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៤២ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា បីតិ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្ដីផ្គងឡើង សេចក្ដីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណា ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

[ ១៤៣ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បាននឿយណាយចាកបីតិរួចហើយ ជាបុគ្គលប្រកបដោយឧបេក្ខា មានសតិសម្បជញ្ញៈផង សោយសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលអ្នកចូលតតិយជ្ឈានោះថា បុគ្គលអ្នកចូលតតិយជ្ឈាន ប្រកបដោយឧបេក្ខា មានសតិ មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ដោយតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ ឈ្មោះបឋវីកសិណ កើតមានក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ

សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្ដីផ្គងឡើង សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៨៤ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ២ មគ្គប្រកបដោយអង្គ ៤ ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៨៥ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្ដីផ្គងឡើង សេចក្ដីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណា ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៨៦ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានលះសុខផង លះទុក្ខផង ធ្វើសោមនស្ស និងទោមនស្សឲ្យវិនាសអស់ក្នុងកាលមុន បានដល់នូវចតុត្ថជ្ឈាន ឈ្មោះបឋវីកសិណ មានអារម្មណ៍មិនជាទុក្ខ មិនជាសុខ មានសតិដ៏បរិសុទ្ធដោយ

ឧបេក្ខា ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត ឧបេក្ខា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផូងឡើង សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៤៧ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ២ មគ្គប្រកបដោយអង្គ ៤ ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៤៨ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផូងឡើង សេចក្តីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណាក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

**ចតុក្កន័យ ចប់**

# អដ្ឋកថា

## រូបាវចរកុសល

## ចតុក្កន័យ

[ ១៣៩ ] ឥឡូវនេះ ដើម្បីសម្តែងរូបាវចរកុសល ទើបព្រះមានព្រះភាគទ្រង់ផ្តើមពាក្យជាដើមថា **កតមេ ធម្មា កុសលា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **រូបូបបត្តិយា មគ្គំ ភាវេតិ** សេចក្តីថា រូបភព លោកហៅថា **រូប** ។ បទថា **ឧបបត្តិ** បានដល់ ការកើតឡើង គឺការកើត ការកើតព្រម ។ បទថា **មគ្គោ** បានដល់ ឧបាយ ។ សេចក្តីនៃពាក្យក្នុងបទថា **មគ្គ** នេះ ដូច្នេះថា សភាវធម៌ដែលឈ្មោះថា **មគ្គ** ព្រោះអត្ថថា ស្វែងរក គឺស្វែងរក ឲ្យកើត ឲ្យសម្រេចនូវការចូលដល់នោះ មានអធិប្បាយថា ការចូលដល់ ការកើតឡើង ការកើត ការកើតព្រម រមែងមានក្នុងរូបភពដោយមគ្គណា ព្រះយោគាវចរ រមែងចម្រើនមគ្គនោះ ។ សួរថា ដោយមគ្គនោះមានការចូលដល់រូបភពដោយពិតប្រាកដឬ ឆ្លើយថា មិនពិតប្រាកដ ។ ព្រោះថា ការឈានកន្លងរូបភព រមែងមានដោយចំណែកនៃការចាក់ធ្លុះដែលព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ ចម្រើននូវសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតម្កល់មាំហើយ រមែងដឹងច្បាស់តាមសេចក្តីពិត ដូច្នេះ ។ តែឈ្មោះថាមគ្គដទៃក្រៅអំពីមគ្គនេះ ដើម្បីការចូលដល់រូបភព រមែងមិនមាន ដោយហេតុនោះ ទើបត្រាស់ថា បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូប-

ភព ដូច្នេះ ។ មួយទៀត កាលពោលដោយអត្ថ ធម្មតាមគ្គនេះ ជាចេតនា ក៏មាន ជាធម៌ដែលសម្បយុត្តដោយចេតនា ក៏មាន ទាំងជាចេតនាផង ធម៌ដែលសម្បយុត្តដោយចេតនាផង ទាំង ២ ក៏មាន ។ ពិតហើយ **ចេតនា** ឈ្មោះថា **មគ្គ** ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) នេះថា ម្នាលសារីបុត្ត តថាគតស្គាល់នរកផង ស្គាល់ផ្លូវ ( ចេតនា ) ជាទីទៅកាន់នរកផង ដូច្នេះ ។ ធម៌ដែលសម្បយុត្តដោយចេតនា ឈ្មោះថា **មគ្គ** ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ) នេះថា

សទ្ធាទាន ហិរិទាន កុសលទាន ធម៌ទាំងនេះ ជាធម៌តាំងនៅក្នុងពួកសប្បុរស សប្បុរសទាំងឡាយ តែងពោលនូវធម៌ ( ធម៌ដែលសម្បយុត្តជាមួយដោយចេតនា ) នេះថា ជាផ្លូវទៅកាន់ទេវលោក ព្រោះថា បុគ្គលតែងទៅកាន់ទេវលោក បាន ដោយធម៌នេះ ដូច្នេះ ។

ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី ឈ្មោះថា **មគ្គ** ក្នុងព្រះសូត្រ មានសង្ខារូបបត្តិសូត្រជាដើមថា ម្នាលភិក្ខុទាំងឡាយ នេះផ្លូវ នេះបដិបទា ដូច្នេះ ។ តែក្នុងទីនេះ ទ្រង់បំណាងយកធម៌ដែលសម្បយុត្តដោយចេតនា ព្រោះព្រះបាលីថា **ឈានំ ។** តែព្រោះឈាន ចេតនា រមែងជាហេតុឲ្យបដិសន្ធិ ហេតុនោះ ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី រមែងសមគួរដូចគ្នា ។

បទថា **ភាវេតិ** បានដល់ រមែងឲ្យកើត គឺរមែងឲ្យកើតឡើង រមែង

ឲ្យបម្រើន ។ អត្ថនៃសេចក្ដីចម្រើនក្នុងទីនេះ មានត្រឹមតែប៉ុណ្ណេះសិន តែក្នុងទីដទៃ ពោលដោយអត្ថនៃឧបសគ្គ មានសេចក្ដីដោយន័យម្យ៉ាងទៀត យ៉ាងនេះថា **សម្ភាវនា** ( ការលើកសរសើរ ) **បរិភាវនា** ( ការអប់រំ ) **វិភាវនា** ( ការធ្វើឲ្យជាក់ច្បាស់ ) ។

បណ្ដាបទទាំង ៣ នោះ ព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) នេះថា ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត ក្នុងសាសនានេះ សរសើរចំពោះអធិសីលថា ព្រះសមណគោតម ព្រះអង្គមានសីល ព្រះអង្គប្រកបព្រមហើយ ដោយសីលក្ខន្ធដ៏ប្រសើរបំផុត ដូច្នេះ ។ ឈ្មោះថា **សម្ភាវនា** អធិប្បាយថា ការជឿមាំ និងព្រះតម្រាស់ទៀត ( ក្នុងទីឃនិកាយ មហាវគ្គ ) ថា សមាធិដែលអប់រំដោយសីល រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញា រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃពិត ដូច្នេះ ឈ្មោះថា **បរិភាវនា** អធិប្បាយថា ការសន្សំ ។ សេចក្ដីនេះថា សូមអ្នកចង្អុលបង្ហាញនូវរូប វេទនា សញ្ញា សង្ខារ វិញ្ញាណចុះ ដូច្នេះ ឈ្មោះថា **វិភាវនា** អធិប្បាយ ការចង្អុលបង្ហាញធ្វើឲ្យជាមាតិកា ។

ចំណែកបដិបទានេះ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា ម្នាលឧទាយិ មួយវិញទៀត តថាគតបានសម្ដែងបដិបទាដល់ពួកសាវ័ក ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយចម្រើននូវសតិប្បដ្ឋាន

ទាំង ៤ ប្រការ ដូច្នេះ ។ ឈ្មោះថា សម្រេចដោយភាវនា ព្រោះអត្ថថា ឲ្យកើត គឺឲ្យចម្រើន ។ ក្នុងទីនេះ បដិបទានេះប៉ុណ្ណោះ ទ្រង់បំណាងយកហើយ ព្រោះហេតុនោះ ទើបខ្ញុំពោលថា **ភាវេតិ** បានដល់ រមែងឲ្យកើត គឺ រមែងឲ្យកើតឡើង រមែងឲ្យចម្រើន ។

សួរថា ព្រោះហេតុអ្វី ក្នុងកាមាវចរកុសលនិទ្ទេស ទ្រង់ធ្វើទេសនាមានធម៌ជាប្រធាន តែក្នុងរូបាវចរនិទ្ទេសនេះ មិនធ្វើដូចយ៉ាងនោះ ទ្រង់ធ្វើទេសនាមានបុគ្គលជាប្រធាន ។ ឆ្លើយថា ព្រោះរូបាវចរ គប្បីសម្រេចឲ្យបានដោយបដិបទា ។ ពិតហើយ រូបាវចរកុសលនេះ ព្រះយោគាវចរ គប្បីជម្រះឲ្យបរិសុទ្ធបាន ដោយបដិបទា ៤ យ៉ាងណាមួយ វៀរចាកបដិបទាចេញ នឹងកើតដូចកាមាវចរក៏ទេ ។ មួយទៀត ធម្មតាបដិបទានេះ កាលនៅមានបុគ្គលអ្នកបដិបត្តិទើបមាន ព្រោះហេតុនោះ ដើម្បីនឹងសម្តែងសេចក្តីនោះ កាលទ្រង់ធ្វើទេសនាមានបុគ្គលជាប្រធាន ទើបត្រាស់ថា បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព ដូច្នេះ ។

បទថា **វិវិច្ចេវ កាមេហិ** សេចក្តីថា ស្ងាត់ហើយ គឺវៀរហើយ ឃ្លានកន្លងហើយ ចាកកាមទាំងឡាយ ។ **ឯវ** អក្ខរៈ ក្នុងពាក្យថា **វិវិច្ចេវ កាមេហិ** នេះ គប្បីជ្រាបថា ចុះក្នុងអត្ថថា និយម ( ពិតប្រាកដ ) ព្រោះ **ឯវ** អក្ខរៈ មានអត្ថថា ពិតប្រាកដ ហេតុនោះ ទើបធ្លុះបញ្ចាំងសេចក្តីថា កាមទាំងឡាយ មិនមានក្នុងសម័យជាទីចូលបឋមជ្ឈាននោះ ក៏នៅជាបដិបក្ខចំពោះបឋមជ្ឈាននោះ នឹងធ្លុះបញ្ចាំងសេចក្តីដល់ការសម្រេចបឋមជ្ឈាននោះ ដោយការ

លះបង់កាម បានដាច់ស្រឡះ ។ សួរថា សេចក្តីនេះដូចម្តេច ។ ឆ្លើយថា កាលធ្វើការកំណត់យ៉ាងនេះថា ស្ងាត់ចាកកាមទាំងឡាយ ដូច្នេះ ឈាននេះរមែងប្រាកដ កាមទាំងឡាយជាបដិបក្ខចំពោះឈាននេះពិត កាលកាមទាំងឡាយនៅមាន ឈាននេះ ក៏ប្រព្រឹត្តទៅមិនបាន ប្រៀបដូចងងឹតនៅមាន ពន្លឺនៃប្រទីបក៏មិនមាន ការសម្រេចឈាននោះ មានដោយការលះកាមទាំងនោះឯង ប្រៀបដូចការទៅដល់ត្រើយនាយ មានដោយការលះត្រើយអាយនេះ ព្រោះហេតុនោះ ទើប **ឯវ** អក្ខរៈនោះ ដល់នូវភាពពិតប្រាកដ ។

ក្នុងសេចក្តីនោះ បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើប **ឯវ** អក្ខរៈនេះលោកពោលក្នុងបទខាងដើមប៉ុណ្ណោះ មិនពោលក្នុងបទខាងក្រោយ ព្រះយោគាវចរ សូម្បីមិនស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ គប្បីចូលឈានបានឬ ឆ្លើយថា សេចក្តីនេះ មិនគប្បីយល់ឃើញយ៉ាងនោះ ដ្បិតថា **ឯវ** អក្ខរៈនេះ លោកពោលក្នុងបទដើម ព្រោះការរលាស់ចេញនូវកាមនោះ ។ ពិតហើយ ឈាននេះ ជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយនុ៎ះឯង ព្រោះជាហេតុឈានកន្លងកាមធាតុ និងព្រោះជាបដិបក្ខចំពោះកាមរាគៈ ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ ) ថា ការរលាស់ចេញចាកកាមទាំងឡាយនេះ បានដល់ នេក្ខម្មៈ ដូច្នេះ ។ មួយទៀត **ឯវ** អក្ខរៈក៏គួរនាំមកពោលក្នុងបទក្រោយ ដូច **ឯវ** អក្ខរៈ ដែលនាំមកត្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) នេះថា **ឥធេវ ភិក្ខវេ សមណោ ឥធ ទុតិយោ សមណោ** ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី ១ ) ( គឺ

សោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈទី ២ ( គឺសកទាគាមី ) ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។ ព្រោះបុគ្គលណាមួយដែលមិនទាន់ស្ងាត់ចាកអកុសលធម៌ ពោល គឺនីវរណៈ សូម្បីពួកដទៃអំពីកាមនេះហើយ ក៏មិនអាចចូលឈានបាន ហេតុនោះ គប្បីប្រើ **ឯវ** អក្ខរៈនេះ សូម្បីក្នុងបទទាំងពីរយ៉ាងនេះថា **វិវិច្ចេវ កាមេហិ វិវិច្ចេវ អកុសលេហិ ធម្មេហិ** ដូច្នេះ ។ បទនេះថា **វិវិច្ច** ក្នុងបទទាំង ២ ក្នុងទីទូទៅ រមែងរួមយកវិវេកទាំងអស់ ទាំងតទង្គវិវេកជាដើម ទាំងកាយវិវេកជាដើមក៏ពិត តែក្នុងទីនេះ គប្បីឃើញវិវេក ៣ ប៉ុណ្ណោះ គឺកាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក ។

វត្ថុកាមទាំងឡាយណា ដែលពោលក្នុងនិទ្ទេស ( មហានិទ្ទេស ) ដោយន័យជាដើមថា ពួកវត្ថុកាមដូចម្តេច ។ រូបជាទីគាប់ចិត្ត ដូច្នេះ ។ និងកិលេសកាមទាំងឡាយណា ដែលពោលក្នុងនិទ្ទេសនោះឯង និងដែលត្រាស់ក្នុងវិភង្គ យ៉ាងនេះថា ឆន្ទៈ ឈ្មោះថា កាម រាគៈ ឈ្មោះថា កាម ឆន្ទរាគៈ ឈ្មោះថា កាម ការត្រិះរិះ ឈ្មោះថា កាម រាគៈ ឈ្មោះថា កាម ការត្រិះរិះ និងរាគៈ ឈ្មោះថា កាម កិលេសទាំងនេះ ឈ្មោះថា កាម ដូច្នេះ វត្ថុកាម និងកិលេសកាមទាំងអស់នោះ គប្បីឃើញថា សង្គ្រោះចូលដោយបទនេះថា **កាមេហិ** នោះឯង ។ កាលបើដូច្នេះ សេចក្តីថា **វិវិច្ចេវ កាមេហិ** មានសេចក្តីថា ស្ងាត់ហើយចាកវត្ថុកាមទាំងឡាយ ក៏សមគួរ ។ ដោយបទថា **វិវិច្ចេវ កាមេហិ** នោះ ជាការត្រាស់ដល់កាយវិវេក ។

បទថា **វិវិច្ច អកុសលេហិ ធម្មេហិ** អធិប្បាយថា ស្ងាត់ហើយចាក

កិលេសកាមទាំងឡាយ ឬអកុសលធម៌ទាំងអស់ ដូច្នេះក៏សមគួរ ។ ដោយបទថា **វិវិច្ច អកុសលេហិ ធម្មេហិ** នោះ ជាការត្រាស់ដល់ចិត្តវិវេក ។ បណ្តាបទទាំង ២ នោះ បទដំបូង រមែងជាការដែលត្រាស់ការលះបង់សេចក្តីសុខក្នុងកាម ព្រោះត្រាស់ដល់សេចក្តីស្ងាត់ចាកវត្ថុកាមទាំងឡាយនុ៎ះឯង បទទីពីរ ត្រាស់អធិប្បាយដល់ការកំណាត់សេចក្តីសុខក្នុងនេក្ខម្មៈ ព្រោះត្រាស់ដល់ការស្ងាត់ចាកកិលេសកាមទាំងឡាយ ។ ព្រោះត្រាស់ដល់ការស្ងាត់ចាកវត្ថុកាម និងកិលេសកាម ដោយប្រការដូច្នេះឯង គប្បីជ្រាបសេចក្តីថា បណ្តាបទទាំងនោះ ដោយបទដំបូង ត្រាស់ការលះបង់សង្កិលេសវត្ថុ បទទីពីរត្រាស់ការលះបង់កិលេស ។ បទដំបូង ត្រាស់ការលះបង់ហេតុនៃសេចក្តីល្មើសល្មោះ បទទីពីរ ត្រាស់ការលះបង់ហេតុនៃភាពជាពាល ។ ដោយបទដំបូង ត្រាស់បយោគសុទ្ធិ បទទីពីរ ត្រាស់អប់រំអធ្យាស្រ័យរបស់ចិត្តដូច្នេះក៏មាន ។ ក្នុងកាមតាមដែលត្រាស់ថា **កាមេហិ** នេះ ក្នុងចំណែកវត្ថុកាម មានន័យត្រឹមប៉ុណ្ណោះឯង ។ ចំណែកក្នុងកិលេសកាម កាមច្ឆន្ទៈនុ៎ះឯង មានប្រភេទមិនមែនតិចដោយពាក្យជាដើមយ៉ាងនេះ គឺឆន្ទៈ ឈ្មោះថា កាម រាគៈ ឈ្មោះថា កាម ដូច្នេះ បំណងយកថា កាម ។ កាមច្ឆន្ទៈនោះ ជាប់ទាក់ទងដោយអកុសលធម៌ តែព្រោះជាបដិបក្ខចំពោះអង្គឈាន ទើបត្រាស់មួយចំណែកក្នុងវិភង្គដោយន័យជាដើមថា បណ្តាកាមទាំងនោះ កាមច្ឆន្ទៈ តើដូចម្តេច ។ ម្យ៉ាងទៀត កាម ត្រាស់ក្នុងបទដំបូង ព្រោះជាកិលេសកាម ត្រាស់ក្នុងបទទីពីរ ព្រោះទាក់ទងក្នុងអកុសល ។ ព្រោះកាមនោះ បែកចេញមិន

មែនតិច ទើបមិនត្រាស់ថា **កាមតោ** តែត្រាស់ថា **កាមេហិ** ដូច្នេះ ។ មួយទៀត ធម៌ពួកដទៃដែលជាអកុសលធម៌ តែត្រាស់ចំពោះនីវរណធម៌ប៉ុណ្ណោះក្នុងវិភង្គ ដោយទ្រង់សម្តែងនីវរណៈ ជាសត្រូវ និងរការំងអង្គឈានថ្នាក់ខ្ពស់ដោយន័យជាដើមថា ក្នុងមាតិកាទាំងនោះ ធម៌ជាអកុសល តើដូចម្តេច គឺកាមច្ឆន្ទៈ ដូច្នេះ ។ ពិតហើយ នីវរណធម៌ទាំងឡាយ ជាសត្រូវចំពោះអង្គឈាន អធិប្បាយថា អង្គឈានទាំងឡាយជាបដិបក្ខ ជាគូកម្ចាត់ជាគូពិឃាតនីវរណៈទាំងនោះ ។ ពិតហើយ ក្នុងគម្ពីរបេដកៈ ពោលថា សមាធិជាបដិបក្ខចំពោះកាមច្ឆន្ទៈ បីតិជាបដិបក្ខចំពោះព្យាបាទ វិតក្កជាបដិ-បក្ខចំពោះថីនមិទ្ធៈ សុខជាបដិបក្ខចំពោះឧទ្ធច្ចកុក្កុច្ចៈ វិចារជាបដិបក្ខចំពោះវិចិកិច្ឆា ។

ដោយអាការយ៉ាងនេះ ក្នុងបទទាំង ២ នោះ រមែងជាការត្រាស់វិវេកជាគ្រឿងគ្របសង្កត់កាមច្ឆន្ទៈ ដោយបទថា **វិវិច្ចេវ កាមេហិ** នេះ ត្រាស់វិវេកជាគ្រឿងគ្របសង្កត់នីវរណៈទាំង ៥ ដោយបទថា **វិវិច្ច អកុសលេហិ** នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ដោយន័យដែលមិនបានអធិប្បាយ រមែងជាការដែលត្រាស់វិវេកជាគ្រឿងគ្របសង្កត់កាមច្ឆន្ទៈដោយបទទីមួយ រមែងជាការដែលត្រាស់វិវេកជាគ្រឿងលះនីវរណៈដ៏សេស ដោយបទទីពីរ ។ មួយទៀត បណ្តាអកុសលមូល ៣ យ៉ាង រមែងជាការត្រាស់វិវេកជាគ្រឿងគ្របសង្កត់លោភៈដែលជាអារម្មណ៍នៃកាមគុណ ៥ ប្រភេទ ដោយបទទីមួយ

រមែងជាការត្រាស់វិវេកជាគ្រឿងសង្កត់ទោសៈ និងមោហៈ ដែលជាអារម្មណ៍ មានអាឃាតវត្ថុជាដើមដោយបទទីពីរ ។ ម្យ៉ាងទៀត បណ្តាធម៌ទាំងឡាយ មានឱឃៈជាដើម រមែងជាការត្រាស់វិវេកដែលជាគ្រឿងគ្របសង្កត់កាមោឃៈ កាមយោគៈ កាមាសវៈ កាមុបាទាន អភិជ្ឈាកាយគន្ថៈ និងកាមរាគ-សញ្ញោជនៈដោយបទទីមួយ រមែងជាការត្រាស់វិវេក ជាគ្រឿងគ្របសង្កត់ ឱឃៈ យោគៈ អាសវៈ ឧបាទាន គន្ថៈ និងសញ្ញោជនៈដ៏សេស ដោយបទទីពីរ ។ មួយទៀត រមែងជាការត្រាស់វិវេក ជាគ្រឿងគ្របសង្កត់តណ្ហា និងធម៌ដែលសម្បយុត្តដោយតណ្ហានោះ ដោយបទទីមួយ រមែងជាការត្រាស់វិវេកជាគ្រឿងគ្របសង្កត់អវិជ្ជា និងធម៌ដែលសម្បយុត្តដោយអវិជ្ជានោះ ដោយបទទីពីរ ។ ម្យ៉ាងទៀត គប្បីជ្រាបថា រមែងជាការត្រាស់វិវេកជាគ្រឿងគ្របសង្កត់ចិត្តុប្បាទ ៨ ដួង ដែលសម្បយុត្តដោយលោភៈ ដោយបទទីមួយ រមែងជាការត្រាស់វិវេក ជាគ្រឿងគ្របសង្កត់ចិត្តុប្បាទដែលជាអកុសល ៤ ដួងដ៏សេស ដោយបទទីពីរ ។ ការប្រកាសសេចក្តីក្នុងពាក្យនេះថា **វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ** ដូច្នេះ ប៉ុណ្ណេះសិន ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងអង្គដែលបឋមជ្ឈានលះបានហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឥឡូវនេះ ដើម្បីសម្តែងសម្បយោគធម៌ ទើបត្រាស់ពាក្យជាដើមថា **សវិតក្កំ សវិចារំ** ដូច្នេះ ។ បណ្តាបទទាំងនោះ ឈាននេះ ត្រាស់ហៅថា **សវិតក្កា សវិចារ** ព្រោះប្រព្រឹត្តទៅរួមជាមួយនឹង វិតក្ក និងវិចារដែលដល់នូវភាពជារូបាវចរ ព្រោះប្រកបដោយអប្បនាដោយ

ការចែកលក្ខណៈជាដើមតាមដែលពោលហើយខាងដើម ដូចដើមឈើដែលមានផ្កា និងផ្លែ ដូច្នោះ ។ តែក្នុងវិភង្គ ទ្រង់ធ្វើទេសនាជាបុគ្គលាធិដ្ឋានដោយន័យជាដើមថា ព្រះយោគាវចរជាអ្នកចូលដល់ហើយ ចូលដល់ព្រមហើយដោយវិតក្កនេះ ដោយវិចារនេះ ។ ចំណែកសេចក្តីក្នុងវិភង្គនោះ គប្បីឃើញតាមដែលពោលហើយនុ៎ះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វិវេកជំ** ដូចតទៅនេះ សេចក្តីស្ងាត់ លោកហៅថា វិវេក អធិប្បាយថា ប្រាសចាកនីវរណៈ ។ ន័យម្យ៉ាងទៀត ឈ្មោះថា **វិវេក** ព្រោះស្ងាត់ហើយ អធិប្បាយថា កងធម៌ដែលសម្បយុត្តដោយឈាន ស្ងាត់ចាកនីវរណៈ ។ ឈ្មោះថា **វិវេកជ** ព្រោះអត្ថថា កើតហើយអំពីវិវេកនោះ ឬកើតក្នុងវិវេកនោះ ។ បីតិ និងសុខក្នុងបទនេះថា **បីតិសុខំ** ខ្ញុំអធិប្បាយខាងដើមហើយនុ៎ះឯង ។ បណ្តាបីតិ និងសុខទាំងនោះ បីតិ ៥ យ៉ាង មានប្រការដូចដែលពោលមកហើយ ផរណាបីតិ ជាឫសគល់នៃអប្បនាសមាធិ ចម្រើនឡើង ដល់នូវភាពជាអង្គប្រកបរបស់សមាធិ ផរណាបីតិនេះ ជាបីតិដែលទ្រង់បំណងយកក្នុងសេចក្តីនេះ ។ បីតិនេះ និងសុខនេះ មានដល់ឈាននេះ ឬក្នុងឈាននេះ ព្រោះហេតុនោះ ទើបឈាននេះ ហៅថា មានបីតិ និងសុខ ដូច្នេះ ។

ម្យ៉ាងទៀត បីតិផង សុខផង ឈ្មោះថា បីតិ និងសុខ ដូចសព្ទថា ធម៌ផង វិន័យផង ឈ្មោះថា ធម្មវិន័យជាដើម ។ បីតិ និងសុខកើតអំពីវិវេកមានដល់អង្គឈាននេះ ឬក្នុងឈាននេះ ព្រោះហេតុនោះ ទើបឈាននេះ

ឈ្មោះថា មានបីតិ និងសុខដែលកើតអំពីការស្ងាត់នោះ ដូចពណ៌នាមកនេះ ។ ដូចឈានកើតអំពីវិវេកយ៉ាងណា បីតិ និងសុខក្នុងឈាននេះ ក៏កើតអំពីវិវេកយ៉ាងនោះដូចគ្នា ។ មួយទៀត បីតិ និងសុខដែលកើតអំពីវិវេកនោះ មានដល់ឈាននេះ ព្រោះហេតុនោះ ទោះពោលដោយពាក្យមួយប៉ុណ្ណោះថា **វិវេកជំ បីតិសុខំ** ( មានបីតិ និងសុខដែលកើតអំពីវិវេក ) ក៏សមគួរ ។ តែក្នុងវិភង្គត្រាស់ដោយន័យជាដើមថា សុខនេះ សហគតៈដោយបីតិនេះ ដូច្នេះ ចំណែកសេចក្ដីក្នុងវិភង្គនោះ គប្បីឃើញតាមន័យយ៉ាងនេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **បឋមំ ឈានំ** ដូចតទៅ

ដែលឈ្មោះថា បឋម ដោយលំដាប់នៃការរាប់ ឈ្មោះថា បឋមជ្ឈាន ព្រោះកើតឡើងទីមួយ ដូច្នេះក៏មាន ។ ឈ្មោះថា បឋមជ្ឈាន ព្រោះព្រះយោគាវចរគប្បីចូលជាទីមួយ ដូច្នេះក៏មាន ។ តែបទថា គប្បីចូលមុននេះ មិនមែនកំណត់ពិតប្រាកដ ព្រោះព្រះយោគាវចរ អ្នកបានសមាបត្តិ ៨ មានវសីប្រព្រឹត្តមកហើយ រមែងអាចចូលឈានតាំងអំពីដើម រហូតដល់ចុងក៏បាន អាចចូលឈានធ្វើតាំងអំពីចុងមកខាងដើមក៏បាន អាចចូលឈានខាងក្នុងចន្លោះក៏បាន ។ ឈាននោះ ឈ្មោះថា បឋម ព្រោះអត្ថថា កើតឡើងមុន ដោយប្រការដូច្នេះ ។

បទថា **ឈានំ** បានដល់ ឈាន ២ យ៉ាង គឺអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ បណ្ដាឈានទាំង ២ នោះ សមាបត្តិ ៨ រមែងដល់នូវការរាប់ថាជាអារម្មណូបនិជ្ឈាន ព្រោះរមែងចូលទៅសម្លឹងអារម្មណ៍ មាន

បឋវីកសិណជាដើម ។ ចំណែកវិបស្សនា មគ្គ និងផល ឈ្មោះថា លក្ខ-ណូបនិជ្ឈាន ។ បណ្តាវិបស្សនា មគ្គ ផលទាំងនោះ វិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះការចូលទៅសម្ងឹងលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ មគ្គ ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះកិច្ចដែលវិបស្សនាធ្វើហើយសម្រេចដោយមគ្គ ។ ចំណែកផល ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះចូលទៅសម្ងឹងនិរោធសច្ច ដែលមានលក្ខណៈពិត ។ ក្នុងអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈានទាំង ២ នោះ ក្នុងសេចក្តីនេះបំណងយកអារម្មណូបនិជ្ឈាន ព្រោះហេតុនោះ ឈាននោះ គប្បីជ្រាបថា ឈ្មោះថា **ឈាន** ព្រោះចូលទៅសម្ងឹងអារម្មណ៍ ឬព្រោះជាគ្រឿងដុតធម៌ដែលជាសត្រូវ ដូច្នេះ ។

បទថា **ឧបសម្បជ្ជ** ( ចូល ) បានដល់ ចូលដល់ហើយ គឺសម្រេចហើយ ។ម្យ៉ាងទៀត អធិប្បាយថា ឲ្យចូលដល់ហើយ ឬឲ្យសម្រេចហើយ ។ តែក្នុងវិភង្គទ្រង់ត្រាស់ថា ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវបឋមជ្ឈាន ដូច្នេះ ។ សេចក្តីនៃបទថា **វិហរតិ** ( សម្រេចឥរិយាបថ ) នោះ គប្បីឃើញដូចក្នុងវិភង្គនោះឯង ។ បទថា **វិហរតិ** បានដល់ ជាអ្នកដល់ព្រមនៃឈាន មានប្រការតាមដែលពោលហើយថា ដោយការនៅនៃឥរិយាបថដែលសមគួរដល់ឈាននោះហើយ រមែងឲ្យសម្រេចការកម្រើក ការប្រព្រឹត្តិទៅ ការរក្សា ដំណើរទៅ ការឲ្យដំណើរទៅ ការត្រាច់ទៅ ការនៅនៃអត្តភាព សមដូចព្រះតម្រាស់ក្នុងវិភង្គថា សេចក្តីត្រង់

ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាង អត្តភាពឲ្យរស់នៅ ត្រាច់ទៅ នៅ សម្រាក ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បឋវីកសិណំ** នេះ ដូចតទៅនេះថា

សូម្បីបឋវីមណ្ឌល លោកក៏ហៅថា បឋវីកសិណ ព្រោះអត្ថថា ជាវត្ថុ សម្រាប់សម្លឹង ។ សូម្បីនិមិត្តដែលបានព្រោះអាស្រ័យបឋវីកសិណនោះ ក៏ឈ្មោះថា បឋវីកសិណ ។ សូម្បីឈានដែលបានចំពោះហើយក្នុងនិមិត្ត ក៏ឈ្មោះថា បឋវីកសិណ បណ្ដាសេចក្ដីទាំងនោះ ឈានក្នុងសេចក្ដីនេះ គប្បីជ្រាបថា ជាបឋវីកសិណ ។ ក្នុងសេចក្ដីនេះថា សម្រេចឈាន ពោល គឺ បឋវីកសិណ ដូច្នេះ ជាសេចក្ដីសង្ខេបក្នុងបទនេះថា ដែលមានបឋវីកសិណ ជាអារម្មណ៍ ។ កុលបុត្តអ្នកប្រាថ្នាធ្វើបរិកម្មក្នុងបឋវីកសិណនេះ ញុំាងឈាន ពួក ៤ ឈានពួក ៥ ឲ្យកើតឡើងហើយ ចម្រើនវិបស្សនា មានឈាន ជាបទដ្ឋានហើយសម្រេចអរហត្ត គប្បីធ្វើដូចម្ដេចខ្លះ ។ ខាងដើម គប្បីជម្រះ សីល ៤ គឺបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល បច្ចយសន្និស្សិតសីលឲ្យបរិសុទ្ធជាមុន កាលតាំងនៅក្នុងសីលដែលបរិសុទ្ធ ល្អហើយ ក៏កាត់បលិពោធក្នុងបលិពោធ ១០ ប្រការ មានអាវាសបលិពោធ ជាដើម ដែលមាននៅនោះ ហើយចូលទៅរកកល្យាណមិត្ត អ្នកឲ្យកម្មដ្ឋាន ពិចារណាកម្មដ្ឋានក្នុងកម្មដ្ឋាន ៣៨ ប្រការ ដែលមានមកក្នុងព្រះបាលីតាម សមគួរដល់ចរិតរបស់ខ្លួន បើបឋវីកសិណនេះ សមគួរដល់ចរិតរបស់ខ្លួន

ក៏គប្បីកាន់យកកម្មដ្ឋាននេះប៉ុណ្ណោះ លះបង់វិហារ ដែលមិនសមគួរដល់ការចម្រើនឈាន នៅក្នុងវិហារដែលសមគួរ កាត់បលិពោធតូចតាច ធ្វើការរក្សាបរិកម្ម និងនិមិត្តនៃកសិណ វៀរអសប្បាយ ៧ យ៉ាង សេពសប្បាយ ៧ យ៉ាង ធ្វើការនាវិធីទាំងអស់ដែលមានអប្បនាកោសល ១០ យ៉ាង មិនឲ្យបាត់ គប្បីបដិបត្តិដើម្បីសម្រេចឈាន សេចក្តីសង្ខេបមានប្រមាណប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ គប្បីជ្រាបតាមន័យដែលពោលក្នុងវិសុទ្ធិមគ្គ ។ មួយទៀត ក្នុងកសិណដទៃអំពីនេះ គប្បីជ្រាបដូចក្នុងបឋវីកសិណនេះ ។ ពិតហើយ ការនាវិធីទាំងអស់នៃកម្មដ្ឋានទាំងពួង ខ្ញុំកាន់យកដោយន័យរបស់អដ្ឋកថា ពង្រីកឲ្យពិស្តារក្នុងវិសុទ្ធិមគ្គហើយ នឹងមានប្រយោជន៍អ្វីដោយវិធីចម្រើនកម្មដ្ឋាននោះ ដែលខ្ញុំពោលហើយក្នុងទីនោះៗ ( វិសុទ្ធិមគ្គ ) ព្រោះហេតុនោះ ខ្ញុំនឹងមិនអធិប្បាយវិធីចម្រើនកម្មដ្ឋាននោះទៀត តែខ្ញុំនឹងមិនធ្វើអត្ថដែលមិនទាន់បានពោលដល់ក្នុងព្រះបាលី ក្នុងខាងដើមឲ្យបាត់ នឹងពណ៌នាតាមលំដាប់បទជាប់តគ្នាទៅ

បទថា **តស្មឹ សមយេ** សេចក្តីថា ក្នុងសម័យដែលចូលបឋមជ្ឈាននោះ ធម៌ ៥៦ តាមលំដាប់ មានប្រការដូចដែលពោលហើយក្នុងកាមាវចរ-កុសលចិត្តដួងទីមួយទាំងនេះ គឺ **ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ** ផស្សៈកើតមាន សេចក្តីមិនរាយមាយកើតមាន ដូច្នេះ ។ សេចក្តីប្លែកគ្នាក្នុងបឋមជ្ឈាននេះមានតែម្យ៉ាង គឺធម៌ទាំង ៥៦ នោះ ជាកាមាវចរធម៌ ៥៦ ដែលពោលនេះជាមហគ្គតៈ ជារូបាវចរដោយអំណាចនៃភូមិ ។ ធម៌ដ៏សេស

ដូចគ្នាទាំងអស់នោះឯង ចំណែកយេវាបនកធម៌ និងធម៌ ៤ យ៉ាង មានឆន្ទៈ ជាដើម រមែងមានក្នុងឈាននេះ ។ កោដ្ឋាសវារ និងសុញ្ញតវារ ប្រព្រឹត្ត ទៅតាមប្រក្រតីនុ៎ះឯង ដូច្នេះ ។

## បឋមជ្ឈាន ចប់

# ទុតិយជ្ឈាន

[ ១៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃទុតិយជ្ឈានដូចតទៅ

បទថា **វិតក្កវិចារានំ វូបសមា** សេចក្តីថា ព្រោះការស្ងប់ បានដល់ ព្រោះការឈានកន្លងធម៌ទាំង ២ នេះ គឺវិតក្ក និងវិចារ មានអធិប្បាយថា ព្រោះការដែលវិតក្ក និងវិចារ មិនប្រាកដក្នុងខណៈនៃឈានទី ២ ។ ក្នុងឈានទាំង ២ នោះ ធម៌ដែលជាបឋមជ្ឈានទាំងអស់ រមែងមិនមានក្នុងទុតិយជ្ឈានដោយពិត ព្រោះថា ធម៌ទាំងឡាយ មានផស្សៈជាដើម ក្នុងបឋមជ្ឈានម្យ៉ាង ក្នុងទុតិយជ្ឈាននេះម្យ៉ាង ក៏ពិតមែន ទោះបីជាដូច្នោះ ក៏គប្បីជ្រាបថា ពាក្យដែលត្រាស់យ៉ាងនេះថា ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារ ដើម្បីសម្តែងថា ការសម្រេចទុតិយជ្ឈានជាដើម ដទៃអំពីបឋមជ្ឈាន រមែងមានព្រោះឈានកន្លងអង្គគ្រោតគ្រាត ។

ក្នុងបទថា **អជ្ឈត្តំ** នេះ លោកបំណងយកខាងក្នុងរបស់ខ្លួនឯង តែក្នុងវិភង្គត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះថា ចំពោះខ្លួន ឈ្មោះថា **អជ្ឈត្ត** ។ ព្រោះបទថា **អជ្ឈត្ត** នេះ បំណងយកខាងក្នុងរបស់ខ្លួន ព្រោះហេតុនោះ ទើបក្នុងបទថា **អជ្ឈត្តំ** នេះ មានអធិប្បាយថា កើតក្នុងខ្លួន គឺកើតឡើងក្នុងខ្លួន ។

សទ្ធា ហៅថា សេចក្តីផូរផង់ ក្នុងបទថា **សម្បសាទនំ** នេះ ។ សូម្បីឈានក៏ហៅថា សេចក្តីផូរផង់ ព្រោះប្រកបដោយសេចក្តីបរិសុទ្ធ ដូចសំពត់ឈ្មោះថា សំពត់ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ។ ម្យ៉ាងទៀត ព្រោះឈាននោះ ញ៉ាំងចិត្តឲ្យផូរផង់ ព្រោះប្រកបដោយសេចក្តីបរិសុទ្ធ និងព្រោះ

សេចក្ដីស្ងប់ការកម្រើកនៃវិតក្ក និងវិចារ ហេតុនោះ ទើបត្រាស់ថា **សម្ប-សាទនំ** ។ ក្នុងការកំណត់សេចក្ដីនេះ គប្បីជ្រាបសេចក្ដីសម្ពន្ធនៃបទយ៉ាងនេះថា **សម្បសាទនំ ចេតសោ** ។ តែក្នុងការកំណត់សេចក្ដីក្នុងគ្រាដំបូងបទថា **ចេតសោ** នេះ គប្បីប្រកបជាមួយនឹងបទ **ឯកោទិភាវំ** ។

ក្នុងបទនោះ មានការប្រកបសេចក្ដីដូចតទៅនេះ សមាធិណា រមែងផុសឡើងជាឯក ព្រោះហេតុនោះ ទើបសមាធិនោះ ឈ្មោះថា **ឯកោទិ** អធិប្បាយថា សមាធិនោះជាភាវៈដ៏លើស ប្រសើរខ្ពស់ ព្រោះវិតក្ក និងវិចារមិនគ្របសង្កត់ ។ ពិតហើយ សូម្បីបុគ្គលដែលប្រសើរបំផុត គេក៏ហៅថាជាឯកក្នុងលោក ។ ម្យ៉ាងទៀត ធម៌ដែលវៀរវិតក្ក និងវិចារ ក៏គួរពោលថា ជាធម៌ឯកមិនមានពីរ ។ ន័យម្យ៉ាងទៀត សមាធិណា រមែងញ៉ាំងសម្បយុត្តធម៌ឲ្យផុសឡើង ព្រោះហេតុនោះ ទើបសមាធិនោះ ឈ្មោះថា **ឧទិ** គឺរមែងឲ្យសម្បយុត្តធម៌ តាំងឡើង ។ សមាធិនោះជាឯក ព្រោះអត្ថថាប្រសើរផង និងញ៉ាំងសម្បយុត្តធម៌ឲ្យផុសឡើងផង ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកោទិ** ។ បទថា **ឯកោទិ** នេះ ជាឈ្មោះរបស់សមាធិ ។ ទុតិយជ្ឈានណា រមែងញ៉ាំងសមាធិ ឈ្មោះថា **ឯកោទិ** នេះឲ្យកើត ឲ្យចម្រើន ព្រោះហេតុនោះ ទើបទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាវ** ។ ព្រោះសមាធិនេះជាឯក ជាសភាវៈដែលញ៉ាំងសម្បយុត្តធម៌ ឲ្យផុសឡើងរមែងមានដល់ចិត្ត មិនមែនមានដល់សត្វ មិនមែនមានដល់ជីវៈ ហេតុនោះទើបព្រះមានព្រះភាគត្រាស់បទនេះថា **ចេតសោ ឯកោទិភាវំ** ដូច្នេះ ។

សួរថា សទ្ធានេះ និងសមាធិដែលមានឈ្មោះថា **ឯកោទិ** នេះ មាននៅក្នុងបឋមជ្ឈាន មិនមែនឬ កាលបើដូច្នោះ ព្រោះហេតុអ្វី ទុតិយជ្ឈាននេះប៉ុណ្ណោះ ទើបព្រះមានព្រះភាគត្រាស់ថា ផូរផង់ និងចិត្តដល់នូវភាពជាធម្មជាតផុសឡើងតែមួយ ខ្ញុំសូមឆ្លើយថា ព្រោះថា បឋមជ្ឈាននោះ នៅមិនទាន់ផូរផង់ពិត ព្រោះកម្រើកដោយវិតក្ក និងវិចារ ដូចទឹកដែលល្អក់ព្រោះរលក ព្រោះហេតុនោះ កាលសទ្ធាមាន ក៏មិនត្រាស់ថា ផូរផង់ ។ ម្យ៉ាងទៀត សូម្បីសមាធិក្នុងបឋមជ្ឈាននេះ ក៏មិនទាន់ប្រាកដច្បាស់ ព្រោះនៅមិនទាន់ផូរផង់ពិតនុ៎ះឯង ព្រោះហេតុនោះ ទើបបឋមជ្ឈាននោះ មិនត្រាស់ថា **ឯកោទិភាវ** តែក្នុងទុតិយជ្ឈាននេះ សទ្ធាមានកម្លាំងបានឱកាស ព្រោះមិនមានវិតក្ក និងវិចារជាបលិពោធ សូម្បីសមាធិក៏ប្រាកដ ព្រោះការបាននូវសទ្ធាដែលមានកម្លាំងជាសម្លាញ់ ព្រោះហេតុនោះ ទុតិយជ្ឈាននេះឯង គប្បីជ្រាបថា ត្រាស់យ៉ាងនោះ ។ ចំណែកក្នុងវិភង្គ ត្រាស់ត្រឹមប៉ុណ្ណោះថា ពាក្យថា ជ្រះថ្លាស៊ប់ គឺសទ្ធា អាការជឿ អាការចុះចិត្តស៊ប់ សេចក្ដីជ្រះថ្លា ក្រៃលែង ដូច្នេះ ។

ត្រង់ពាក្យថា មានសភាពជាចិត្តខ្ពស់ឯក បានដល់ ការស្ថិតនៅនៃចិត្ត ។បេ។ សម្មាសមាធិ ដូច្នេះ ។ គប្បីជ្រាបការពណ៌នាសេចក្ដីនេះជាមួយនឹងព្រះតម្រាស់ ដែលត្រាស់យ៉ាងនោះ ដោយប្រការដែលមិនខុសប្រៀបធៀបគ្នាបាន ចូលគ្នាបានដោយពិត ។

បទថា **អវិតក្កំ អវិចារំ** មានវិគ្គហៈថា ឈ្មោះថា **អវិតក្ក** ព្រោះ

អត្ថថា វិតក្កក្នុងទុតិយជ្ឈាននេះ ឬរបស់ទុតិយជ្ឈាននេះ មិនមាន ព្រោះវិតក្កនោះ លះបានហើយដោយភាវនា ។ ឈ្មោះថា **អវិចារ** ក៏ដោយន័យនេះដូចគ្នា ។ ក្នុងវិភង្គក៏ត្រាស់ថា វិតក្កនេះផង វិចារនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីងស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា មិនមានវិតក្ក មិនមានវិចារ ដោយប្រការដូច្នេះ ។

ក្នុងសេចក្តីនេះ បើមានអ្នកចោទសួរដោយពាក្យនេះថា ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារ ដូច្នេះ អត្ថសម្រួលហើយមិនមែនឬ កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ថា គ្មានវិតក្ក គ្មានវិចារទៀត ។ ឆ្លើយថា សេចក្តីនេះយ៉ាងនេះ អត្ថសម្រួលហើយនោះឯង តែពាក្យថា ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារនេះ មិនបានសម្តែងសេចក្តីថា គ្មានវិតក្ក គ្មានវិចារនោះ ខ្ញុំបានពោលហើយ មិនមែនឬថា ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារ ដើម្បីសម្តែងថា ការសម្រេចទុតិយជ្ឈានជាដើមដទៃអំពីបឋមជ្ឈាន រមែងមិនបាន ព្រោះឈានកន្លងអង្គគ្រោតគ្រាត ។

ម្យ៉ាងទៀត ពាក្យនេះជាពាក្យសម្តែងហេតុនៃសេចក្តីថ្លៃថ្លា ចិត្តដល់នូវភាពជាធម្មជាតផុសឡើង ផុសឡើងឯកយ៉ាងនេះថា ទុតិយជ្ឈាននេះ ឈ្មោះថា ថ្លៃថ្លា ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារ មិនមែនព្រោះកិលេសដែលធ្វើឲ្យប្រឡាក់អស់ទៅ ( នោះឡើយ ) កាលស្ងប់ ឈ្មោះថា មានសភាព

ជាចិត្តខ្ពស់ឯក ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារ មិនមែនព្រោះលះនីវរណៈបាន ដូចឧបចារជ្ឈាន មិនមែនព្រោះអង្គឈានប្រាកដ ដូចបឋមជ្ឈាន ពាក្យនេះ ជាពាក្យសម្ដែងហេតុនៃភាពដែលឈាន មិនមានវិតក្ក មិនមានវិចារ យ៉ាងនេះថា ទុតិយជ្ឈាននេះ ឈ្មោះថា គ្មានវិតក្ក គ្មានវិចារ ព្រោះវិតក្កវិចារស្ងប់រម្ងាប់ដូចគ្នា មិនមែនព្រោះមិនមានដូចតតិយជ្ឈាន និងចតុត្ថជ្ឈាន និងដូចចក្ខុវិញ្ញាណជាដើម មិនមែនជាពាក្យសម្ដែងដល់ភាពមិនមានវិតក្កមិនមានវិចារ ។ ចំណែកពាក្យថា គ្មានវិតក្ក គ្មានវិតក្កនេះ ជាពាក្យសម្ដែងដល់ការមិនមានវិតក្ក និងវិចារសោះ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា ស្ងប់រម្ងាប់នៃវិតក្ក និងវិចារខាងដើមហើយ ក៏គប្បីត្រាស់ថា គ្មានវិតក្ក គ្មានវិតក្កទៀតដោយពិត ។

បទថា **សមាធិជំ** សេចក្ដីថា កើតអំពីសមាធិក្នុងបឋមជ្ឈាន ឬអំពីសមាធិដែលសម្បយុត្តគ្នា ។ បណ្ដាសមាធិទាំង ២ នោះ សូម្បីឈានទីមួយកើតអំពីសមាធិដែលសម្បយុត្តគ្នាក៏ពិត តែតាមពិតសមាធិនេះប៉ុណ្ណោះរមែងគួរពោលថា សមាធិ ព្រោះជាសមាធិដែលមិនកម្រើកញាប់ញ័រដោយវៀរចាកការកម្រើករបស់វិតក្ក និងវិចារ និងព្រោះជាហេតុឲ្យសមាធិដូរផង់ល្អ ព្រោះហេតុនោះ ដើម្បីពោលសរសើរទុតិយជ្ឈាននេះ ទើបព្រះមានព្រះភាគត្រាស់ទុតិយជ្ឈានប៉ុណ្ណោះថា **សមាធិជំ** ដែលកើតអំពីសមាធិ ។ បទថា **បីតិសុខំ** នេះ មានន័យតាមដែលពោលមកហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ទុតិយំ** ដូចតទៅនេះថា ឈ្មោះថា **ទុតិយ**

ដោយលំដាប់នៃការរាប់ ។ ឈានេនះ ឈ្មោះថា ទុតិយជ្ឈាន ព្រោះអត្ថថា សម្រេចជាទីពីរ ដូច្នេះក៏បាន ។

ក្នុងបទថា **តស្មឹ សមយេ ជស្សោ ហោតិ** ជាដើម ពាក្យថា វិតក្ក និងវិចារក្នុងពួក ៥ នៃឈានបាត់ទៅ និងពាក្យថា សម្មាសង្កប្បៈ ក្នុងពួក ៥ នៃមគ្គ ក៏បាត់ទៅ ។ គប្បីជ្រាបវិនិច្ឆ័យបទដែលមានការចែក និងមិនមាន ការចែកដោយអំណាចនៃពាក្យថា វិតក្ក វិចារ និងសម្មាសង្កប្បៈទាំងនោះ ។ ក្នុងកោដ្ឋាសវារៈ ក៏មានព្រះតម្រាស់មកថា **តិវង្គិកំ ឈានំ ហោតិ ចតុ-រង្គិកោ មគ្គោ ហោតិ** ឈានប្រកបដោយអង្គ ៣ មគ្គប្រកបដោយអង្គ ៤ ដូច្នេះ ។ ពាក្យដ៏សេសដូចគ្នានឹងបឋមជ្ឈាននោះឯង ។

ទុតិយជ្ឈាន ចប់

# តតិយជ្ឈាន

[ ១៤៣ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងតតិយជ្ឈាននិទ្ទេសដូចតទៅនេះ

បទថា **បីតិយា ច វិរាគា** សេចក្តីថា សេចក្តីរង្កៀស ឬការកន្ទង់បង់បីតិ មានប្រការដូចដែលពោលមកហើយ ឈ្មោះថា **វិរាគ** ។ ច សព្ទក្នុងរវាងសព្ទទាំងពីរ មានអត្ថថា ប្រមូលមក ។ ច សព្ទនោះ រមែងប្រមូលមកនូវការស្ងប់ ឬនូវការស្ងប់វិតក្ក និងវិចារ ។ ក្នុងការប្រមូលមកទាំង ២ នោះ ក្នុងកាលណា ច សព្ទ ប្រមូលនូវសេចក្តីស្ងប់ប៉ុណ្ណោះ ក្នុងកាលនោះ គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះថា ព្រោះប្រាសចាកបីតិ និងព្រោះស្ងប់បន្ថែមឡើងទៀតតិចតួច ។ វិរាគៈក្នុងការប្រកបសេចក្តីនេះ រមែងមានអត្ថថា រង្កៀស ។ ព្រោះហេតុនោះ គប្បីឃើញអត្ថនេះថា ព្រោះរង្កៀសបីតិ និងព្រោះស្ងប់ ។ ក្នុងកាលណា ច សព្ទ ប្រមូលមកនូវការស្ងប់វិតក្ក និងវិចារ ក្នុងកាលនោះ គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះថា ព្រោះប្រាសចាកបីតិ និងព្រោះស្ងប់វិតក្ក និងវិចារ បន្ថែមឡើងទៀតតិចតួច ។ វិរាគៈ ក្នុងការប្រកបសេចក្តីនេះ រមែងមានអត្ថថា ឈានកន្ទង ព្រោះហេតុនោះ គប្បីឃើញសេចក្តីនេះថា ព្រោះឈានកន្ទងបីតិ និងព្រោះស្ងប់វិតក្ក និងវិចារ ដូច្នេះ ។ វិតក្ក និងវិចារទាំងនេះស្ងប់ហើយ ក្នុងទុតិយជ្ឈានក៏ពិត តែទ្រង់ត្រាស់ពាក្យថា ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារនេះ ដើម្បីអធិប្បាយគុណរបស់ឈាននេះ និងដើម្បីពោលសរសើរឈាននេះ ។ ពិតហើយ កាលត្រាស់ថា ព្រោះស្ងប់រម្ងាប់នៃវិតក្ក និងវិចារ ដូច្នេះ តតិយជ្ឈាននេះ រមែងប្រាកដច្បាស់ថា ការចូលទៅស្ងប់វិតក្ក និងវិចារ ជាឧបាយគ្រឿងសម្រេច

ឈានទេះពិតប្រាកដ ដូចការលះសក្កាយទិដ្ឋិជាដើម សូម្បីមិនបានលះក្នុង អរិយមគ្គទី ៣ ដែលត្រាស់យ៉ាងនេះថា ព្រោះលះសញ្ញោជនៈខាងក្រោម ៥ ដូច្នេះ ក៏ឈ្មោះថា ត្រាស់សរសើរសូម្បីឲ្យកើតសេចក្ដីឧស្សាហៈដល់បុគ្គល ដែលខ្វល់ខ្វាយដើម្បីសម្រេចអរិយមគ្គទី ៣ យ៉ាងណា ការស្ងប់វិតក្ក និង វិចារ សូម្បីមិនបានស្ងប់ក្នុងតតិយជ្ឈាននេះ ដែលនាំមកពោល ក៏ឈ្មោះថា ពោលសរសើរយ៉ាងនោះដូចគ្នា ។ ដោយហេតុនោះ ទើបខ្ញុំពោលសេចក្ដី នេះថា ព្រោះឈានកន្លងបីតិ និងព្រោះស្ងប់វិតក្ក និងវិចារ ដូច្នេះ ។

ក្នុងបទថា **ឧបេក្ខកោ ច វិហរតិ** នេះ មានវិគ្គហៈថា ធម៌ដែលឈ្មោះ ថា **ឧបេក្ខា** ព្រោះអត្ថថា ឃើញដោយការចូលដល់ អធិប្បាយថា ឃើញ ស្មើ គឺឃើញដោយមិនធ្លាក់ទៅក្នុងចំណែកណាមួយ ។ ព្រះយោគាវចរដែល ដល់ព្រមដោយតតិយជ្ឈាន ត្រាស់ហៅថា **ឧបេក្ខកោ** ព្រោះប្រកបដោយ ឧបេក្ខាដ៏បរិសុទ្ធ បរិបូណ៌ មានកម្លាំងនោះ ។

# ឧបេក្ខា ១០ យ៉ាង

ឧបេក្ខាមាន ១០ យ៉ាង គឺ **ឆឡង្គុបេក្ខា** ឧបេក្ខារបស់ព្រះខីណាស្រព ១ **ព្រហ្មវិហារុបេក្ខា** ឧបេក្ខាក្នុងព្រហ្មវិហារ ១ **ពោជ្ឈង្គុបេក្ខា** ឧបេក្ខាក្នុងសម្ពោជ្ឈង្គ ១ **វីរិយុបេក្ខា** ឧបេក្ខា គឺសេចក្តីព្យាយាម ១ **សង្ខារុបេក្ខា** ឧបេក្ខាក្នុងឈាន និងវិបស្សនា ១ **វេទនុបេក្ខា** ឧបេក្ខាវេទនា ១ **វិបស្សនុបេក្ខា** ឧបេក្ខាក្នុងវិបស្សនា ១ **តត្រមជ្ឈត្តុបេក្ខា** តត្រមជ្ឈត្តតាចេតសិក ១ **ឈានុបេក្ខា** ឧបេក្ខាក្នុងឈាន ១ **បារិសុទ្ធុបេក្ខា** ឧបេក្ខាធ្វើសតិឲ្យបរិសុទ្ធ ១ ។

បណ្តាឧបេក្ខាទាំង ១០ នោះ ឧបេក្ខាណាជាធម៌បរិសុទ្ធ ជាប្រក្រតីក្នុងគន្លងនៃអារម្មណ៍ ៦ ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាក្នុងទ្វារ ៦ របស់ព្រះខីណាស្រពជាអាការមាន ដែលមកក្នុងព្រះបាលី ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) យ៉ាងនេះថា ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនសោមនស្ស មិនទោមនស្ស មានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ឆឡង្គុបេក្ខា** ។

ឧបេក្ខាណាមានអាការជាកណ្តាលក្នុងសត្វទាំងឡាយ ដែលមកក្នុងព្រះបាលី ( ទីឃនិកាយ សីលក្ខន្ធវគ្គ ) យ៉ាងនេះថា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ព្រហ្មវិហារុបេក្ខា** ។

ឧបេក្ខាណា មានអាការជាកណ្តាលក្នុងសហជាតធម៌ទាំងឡាយ ដែលមកក្នុងព្រះបាលី ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ចម្រើននូវ

ឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ពោជ្ឈង្គុបេក្ខា** ។

ឧបេក្ខាណា ពោល គឺសេចក្តីព្យាយាមដែលមិនធូរពេក មិនតឹងពេក ដែលមកក្នុងព្រះបាលី ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) យ៉ាងនេះថា ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **វិរិយុបេក្ខា** ។

ឧបេក្ខាណា មានអាការជាកណ្តាល ក្នុងការពិចារណានីវរណៈជាដើម ហើយសម្រេចកាន់យក ដែលមកក្នុងព្រះបាលី ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) យ៉ាងនេះថា សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចសមថៈ សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចវិបស្សនា ។ សង្ខារុបេក្ខា ៨ កើតដោយអំណាចសមថៈ សង្ខារុបេក្ខា ១០ កើតដោយអំណាចវិបស្សនា ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **សង្ខារុបេក្ខា** ។

ឧបេក្ខាណា ដែលកំណត់ដឹងក្នុងសេចក្តីមិនមែនទុក្ខ មិនមែនសុខ ដែលមកក្នុងព្រះបាលី ( ក្នុងអភិធម្ម ធម្មសង្គណិ ) យ៉ាងនេះថា ចិត្តជាកាមាវចរកុសលប្រកបដោយឧបេក្ខា កើតឡើងក្នុងសម័យណា ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **វេទនុបេក្ខា** ។

ឧបេក្ខាណា មានភាពជាកណ្តាល ក្នុងការស្រាវជ្រាវពិចារណា ដែលមកក្នុងព្រះបាលី ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) យ៉ាងនេះថា ខន្ធបញ្ចកៈណាដែលមាន ដែលកើត ក្នុងកាលឥឡូវនេះ អាត្មាអញលះបង់នូវ

ខន្ធបញ្ចកៈនោះ ភិក្ខុនោះ បានទូវឧបេក្ខាយ៉ាងនេះ ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **វិបស្សនុបេក្ខា** ។

ឧបេក្ខាណា ញុំាំងសហជាតធម៌ឲ្យប្រព្រឹត្តទៅស្មើ ដែលមកក្នុងយេវាបនកធម៌ទាំងឡាយ មានឆន្ទៈជាដើម ឧបេក្ខានេះ ឈ្មោះថា **តត្រមជ្ឈត្តុបេក្ខា** ។

ឧបេក្ខាណា មិនញុំាំងការធ្លាក់ចុះជាចំណែកឲ្យកើតក្នុងតតិយជ្ឈាន សូម្បីមានសុខដ៏ប្រសើរនោះ ដែលមកក្នុងព្រះបាលី ( អភិធម្ម ធម្មសង្គណិ ) យ៉ាងនេះថា ប្រកបដោយឧបេក្ខា ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ឈានុបេក្ខា** ។

ឧបេក្ខាណា បរិសុទ្ធចាកបច្ចនិកធម៌ទាំងពួង មិនបាច់ខ្វល់ខ្វាយ សូម្បីក្នុងការស្ងប់បច្ចនិកធម៌ ដែលមានមកក្នុងព្រះបាលីយ៉ាងនេះថា បានដល់នូវចតុត្ថជ្ឈាន ឈានមានអារម្មណ៍មិនជាទុក្ខ មិនជាសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ចារិសុទ្ធុបេក្ខា** ។

បណ្តាឧបេក្ខាទាំង ១០ នោះ ឆឡង្គុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា តត្រមជ្ឈត្តុបេក្ខា ឈានុបេក្ខា បារិសុទ្ធុបេក្ខា ដោយអត្ថក៏តែមួយ គឺជាតត្រមជ្ឈត្តុបេក្ខានោះឯង ។ តែសេចក្តីផ្សេងគ្នានៃឧបេក្ខានោះ ព្រោះការផ្សេងគ្នានៃឋានៈនោះៗ ដូចការផ្សេងគ្នានៃមនុស្សម្នាក់ដោយឋានៈជាកុមារ ជាកំលោះ ជាមនុស្សធំ ជាសេនាបតី និងជាព្រះរាជាជាដើម ព្រោះហេតុនោះ បណ្តាឆឡង្គុបេក្ខាជាដើមទាំងនោះគប្បីជ្រាបថា ក្នុងទីណាមានឆឡង្គុបេក្ខា ក្នុងទីនោះមិនមានពោជ្ឈង្គុបេក្ខាជាដើម ឬថាក្នុងទីណាមានពោជ្ឈង្គុ-

បេក្ខា ក្នុងទីនោះ មិនមានធម្មឯទៀតជាដើម ។

មួយទៀត ឧបេក្ខាទាំង ៦ នោះ ពោលដោយអត្ថ មានភាវៈតែមួយយ៉ាងណា សង្ខារុបេក្ខា និងវិបស្សនុបេក្ខា ក៏មានភាវៈតែមួយយ៉ាងនោះ ។ ក៏សង្ខារុបេក្ខា និងវិបស្សនុបេក្ខានោះ គឺបញ្ញាទុំះឯង តែចែកចេញជា ២ ដោយអំណាចនៃកិច្ច ។ ដូចកាលបុរសកាន់ឈើមានសណ្ឋានដូចជើងពពែ ស្វែងរកពស់ដែលចូលទៅក្នុងផ្ទះក្នុងវេលាល្ងាច ឃើញពស់នោះដេកក្នុងទីដែលបិទបាំង ក្នុងគំនរចំបើង ក៏សម្លឹងមើលដោយសង្ស័យថា ជាពស់ ឬក៏មិនមែនទេហ្ន៎ ឃើញគ្រឿងសម្គាល់ផ្កាចន្ទន៍ ក៏អស់សេចក្ដីសង្ស័យ ទើបជាអ្នកព្រងើយក្នុងការវិនិច្ឆ័យថាជាពស់ ឬមិនមែនជាពស់ យ៉ាងណា កាលព្រះយោគាវចរ ប្រារព្ធវិបស្សនាឃើញត្រៃលក្ខណ៍ ដោយវិបស្សនាញាណហើយ ភាពជាអ្នកព្រងើយក្នុងការដែលពិចារណាសង្ខារទាំងឡាយ ជារបស់មិនទៀងជាដើម រមែងកើតឡើងក៏យ៉ាងនោះ ភាពជាអ្នកព្រងើយ ( មជ្ឈត្តតា ) នេះ ឈ្មោះថា **វិបស្សនុបេក្ខា** ។

ដូចកាលបុរសនោះ យកឈើមានសណ្ឋានដូចជើងពពែ សង្កត់កពស់យ៉ាងមាំ ហើយស្វែងរកអាការដែលលែងទៅថា អញនឹងចាប់ពស់នេះមិនឲ្យវាលំបាកដោយវិធីណា អញនឹងមិនឲ្យពស់ចឹកបាន ហើយលែងទៅដោយឧបាយដូចម្ដេច ដូច្នេះ ការព្រងើយ ( មជ្ឈត្តតា ) ក្នុងការចាប់ក៏មានយ៉ាងណា កាលព្រះយោគាវចរឃើញភពទាំង ៣ ដូចភ្លើងឆេះទូទៅហើយ ព្រោះឃើញត្រៃលក្ខណ៍ក៏មានសេចក្ដីព្រងើយ ( មជ្ឈត្តតា ) ក្នុង

ការប្រកាន់សង្ខារយ៉ាងនោះដូចគ្នា មជ្ឈត្តតានេះ ឈ្មោះថា **សង្ខារុបេក្ខា** ។ ដោយប្រការដូចដែលពោលមកហើយនេះ សូម្បីសង្ខារុបេក្ខានឹងសម្រេចបាន ក៏ព្រោះវិបស្សនុបេក្ខាសម្រេចហើយដោយពិត ។ ឧបេក្ខា ( គឺបញ្ញា ) នេះ បែកចេញជា ២ យ៉ាងដោយកិច្ចនេះ ពោល គឺការព្រងើយក្នុងការពិចារណា និងក្នុងការប្រកាន់ ។ ចំណែកវីរិយុបេក្ខា និងវេទនុបេក្ខា ដោយអត្ថ ផ្សេងអំពីគ្នាផង ផ្សេងអំពីឧបេក្ខាដ៏សេសផង ។

បណ្តាឧបេក្ខាតាមដែលពោលមកទាំងនេះ ក្នុងទីនេះ បំណងយកឈានុបេក្ខា ។ ឈានុបេក្ខានោះ **មជ្ឈត្តលក្ខណា** មានការដាក់ខ្លួនជាកណ្តាលជាលក្ខណៈ **អនាភោគរសា** មានការមិនចងចិត្តជាកិច្ច **អព្យាបារបច្ចុប្បដ្ឋានា** មានការមិនខ្វល់ខ្វាយជាអាការប្រាកដ **បីតិវិរាគបទដ្ឋានា** មានការនឿយណាយចាកបីតិជាហេតុជិត ។

ក្នុងអធិការនៃឈានទី ៣ នេះ បើមានអ្នកចោទសួរថា ឈានុបេក្ខានេះ ដោយអត្ថ ក៏ជាតត្រមជ្ឈត្តុបេក្ខា ឯតត្រមជ្ឈត្តុបេក្ខានោះ ក៏មាននៅក្នុងបឋមជ្ឈាន និងទុតិយជ្ឈានមិនមែនឬ ព្រោះហេតុនោះ សូម្បីក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ ឈានុបេក្ខានេះ ក៏គួរពោលយ៉ាងនេះថា **ឧបេក្ខកោ ច វិហរតិ** ព្រោះហេតុអ្វី ទើបមិនត្រាស់ឈានុបេក្ខា ឆ្លើយថា ព្រោះឈានុបេក្ខានោះ មានកិច្ចមិនទាន់ជាក់ច្បាស់ ។ ពិតហើយ កិច្ចនៃឈានុបេក្ខាក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ ជារបស់មិនជាក់ច្បាស់ ព្រោះត្រូវធម៌ដែលជាសត្រូវទាំងឡាយ មានវិតក្កជាដើមគ្របសង្កត់ហើយ ។ តែឈានុបេក្ខា

ក្នុងតតិយជ្ឈាននេះ មិនមានសត្រូវ គឺវិតក្ក វិចារ និងបីតិគ្របសង្កត់ឡើយ ដូចងើបក្បាលឡើងបានហើយ មានកិច្ចដែលជាក់ច្បាស់ហើយ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ឈានុបេក្ខាក្នុងតតិយជ្ឈាននេះ ។

ចប់ការពណ៌នាសេចក្តីទាំងពួង នៃពាក្យថា **ឧបេក្ខកោ ច វិហរតិ** ត្រឹមប៉ុណ្ណេះ ។

ឥឡូវនេះ គប្បីជ្រាបវិគ្គហៈក្នុងបទថា **សតោ ច សម្បជានោ** ដូចតទៅ

បុគ្គលណារឭកបាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា មានសតិ ។ បុគ្គលណា រមែងដឹងទូទៅដោយប្រពៃ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា មានសម្បជញ្ញៈ ។ ព្រះមានព្រះភាគត្រាស់សតិ និងសម្បជញ្ញៈដោយបុគ្គលាធិដ្ឋាន ។ បណ្តាសតិ និងសម្បជញ្ញៈនោះ សតិ **សរណលក្ខណា** មានការរឭកជាលក្ខណៈ **អសម្មុស្សនរសា** មានការមិនវង្វេងជាកិច្ច **អារក្ខបច្ចុបដ្ឋានា** មានការរក្សាជាអាការប្រាកដ ។ សម្បជញ្ញៈ **អសម្មោហលក្ខណំ** មានការមិនវង្វេងអារម្មណ៍ជាលក្ខណៈ **តីរណរសំ** មានការស្ទាបស្ទង់ជាកិច្ច **បវិចយបច្ចុបដ្ឋានំ** មានការពិចារណាជាអាការប្រាកដ ។

បណ្តាឈានទាំងនោះ សតិ និងសម្បជញ្ញៈនេះ មានទៅក្នុងឈានខាងដើមក៏ពិត ព្រោះថា កាលព្រះយោគាវចរមិនមានសតិ មិនមានសម្បជញ្ញៈ ត្រឹមតែឧបចារជ្ឈាន ក៏រមែងមិនសម្រេច នឹងពោលទៅថ្វីដល់អប្បនានោះ

ទោះបីជាដូច្នោះ ព្រោះឈានទាំងឡាយ ( បឋមជ្ឈាន ទុតិយជ្ឈាន ) ទាំងនោះនៅមានអង្គគ្រោតគ្រាត ទើបផ្លូវទៅ ( គតិ ) របស់ចិត្តប្រព្រឹត្តទៅបានដោយងាយ ដូចការដើរទៅរបស់បុគ្គលលើផែនដី កិច្ចនៃសតិ និងសម្បជញ្ញៈក្នុងឈានខាងដើមនោះ ទើបមិនមានកម្លាំងខ្លាំងក្លា តែព្រោះឈានទី ៣ នេះ ជាឈានមានអារម្មណ៍សុខុម ព្រោះលះបង់អង្គឈានគ្រោតគ្រាតបាន ការប្រព្រឹត្តិទៅនៃចិត្តដែលកិច្ចរបស់សតិ និងសម្បជញ្ញៈ ផ្គងទុកហើយនុ៎ះឯង ដែលព្រះយោគីគប្បីប្រាថ្នា ដូចការដើរទៅរបស់បុរស ក្នុងទីពុំរាបស្មើ ព្រោះហេតុនោះ ទើបសតិ និងសម្បជញ្ញៈ ត្រាស់ក្នុងតតិយជ្ឈាននេះប៉ុណ្ណោះ ។

គប្បីជ្រាបអត្ថនេះឲ្យក្រៃលែងឡើងបន្តិចទៀតថា ប្រៀបដូចកូនគោដែលនៅមិនទាន់ផឹកទឹកដោះមេគោ ម្ចាស់បំបែកចេញអំពីមេគោ មិនបានប្រយ័ត្នរមែងត្រឡប់មករកមេគោទៀតនុ៎ះឯង យ៉ាងណា សុខក្នុងតតិយជ្ឈាននេះ ក៏យ៉ាងនោះ សុខនោះ ដែលព្រះយោគាវចរប្រាសចាកបីតិបានហើយ មិនរក្សាដោយសតិ និងសម្បជញ្ញៈ ក៏គប្បីត្រឡប់មករកបីតិទៀតនុ៎ះឯង សុខនោះគប្បីសម្បយុត្តដោយបីតិដោយពិត ។ មួយទៀត សត្វទាំងឡាយ រមែងត្រេកអរក្នុងសុខ សុខនេះ ( តតិយជ្ឈាន ) ក៏ជាសុខគួរជាទីគាប់ចិត្ត ព្រោះមិនមានសុខដទៃក្រៃលែងជាងនេះ តែក្នុងតតិយជ្ឈាននេះ មិនមានការត្រេកអរក្នុងសុខ ដោយអានុភាពនៃសតិ និងសម្បជញ្ញៈ មិនមែនដោយអានុភាពដទៃទេ ព្រោះហេតុនោះ ដើម្បីសម្តែងការផ្សេងគ្នានៃសេចក្តីនេះ ទើបត្រាស់

ពាក្យថា មានសតិសម្បជញ្ញៈ ក្នុងតតិយជ្ឈានទេះនោះឯង ។

ឥឡូវនេះ គប្បីជ្រាបអធិប្បាយក្នុងពាក្យថា **សុខញ្ច កាយេន បដិសំវេទេតិ** នេះ ដូចតទៅ

ការបងចិត្តក្នុងការសោយសេចក្ដីសុខ របស់បុគ្គលដែលដល់ព្រមដោយតតិយជ្ឈាន រមែងមិនមានក៏ពិត ទោះបីយ៉ាងនោះ ព្រោះលោកមានសុខដែលសម្បយុត្តដោយនាមកាយ ឬព្រោះរូបរបស់លោកត្រូវរូបដែលប្រណីតក្រៃលែងដែលតាំងឡើងអំពីសុខ ដែលសម្បយុត្តដោយនាមកាយនោះជ្រួតជ្រាបហើយ ព្រោះកាយត្រូវជ្រួតជ្រាបហើយ សូម្បីលោកចេញហើយអំពីឈាន ក៏គប្បីសោយសុខបាន ហេតុនោះ កាលសម្ដែងសេចក្ដីនោះ ទើបត្រាស់ពាក្យថា **សុខញ្ច កាយេន បដិសំវេទេតិ** ដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបអធិប្បាយក្នុងបទថា **យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារី** ដូចតទៅ

ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម រមែងប្រាប់ រមែងសម្ដែង រមែងបញ្ញត្ត រមែងតែងតាំង រមែងបើកបង្ហាញ រមែងចែក រមែងធ្វើឲ្យងាយអធិប្បាយថា រមែងប្រកាស រមែងសរសើរនូវបុគ្គលដែលដល់ព្រមដោយតតិយជ្ឈាននោះ ព្រោះឈានណាជាហេតុ ព្រោះឈានណាជាការណៈ ។

សួរថា រមែងសរសើរដូចម្ដេច ។ ឆ្លើយថា រមែងសរសើរថា ជាអ្នកប្រកបដោយឧបេក្ខា មានសតិនៅជាសុខ ។ បណ្ឌិតគប្បីជ្រាបការប្រកបសេចក្ដីក្នុងពាក្យនោះយ៉ាងនេះថា ព្រះយោគាវចរចូលដល់ឈានទី ៣ នោះ ។

ព្រោះហេតុអ្វី ទើបព្រះអរិយៈទាំងឡាយ សរសើរព្រះយោគីនោះយ៉ាងនេះ ព្រោះលោកជាអ្នកគួរដល់ការសរសើរ ។ ពិតហើយ ព្រោះព្រះយោគាវចរនេះ ជាអ្នកព្រងើយក្នុងតតិយជ្ឈានដែលមានសេចក្តីសុខ ជាទីគាប់ចិត្តក្រៃលែងដែលដល់នូវការពេញដោយសេចក្តីសុខ ក៏មិនត្រូវសេចក្តីជាប់ចិត្តក្នុងសុខក្នុងតតិយជ្ឈាននោះទាញមក និងឈ្មោះថាជាអ្នកមានសតិ ព្រោះមានសតិតាំងមាំ ដោយប្រការដែលបីតិនឹងមិនកើតឡើង និងព្រោះសោយសុខដែលមិនសៅហ្មង ដែលព្រះអរិយៈប្រាថ្នា ដែលអរិយជនសេពហើយនុ៎ះឯង ដោយនាមកាយ ព្រោះហេតុនោះ ទើបព្រះយោគីនោះ ជាបុគ្គលគួរដើម្បីសរសើរ ។ បណ្ឌិតគប្បីជ្រាបថា ព្រះអរិយៈទាំងឡាយ កាលប្រកាសគុណ ដែលជាហេតុគួរដល់ការសរសើរទាំងនោះយ៉ាងនេះ ព្រោះជាអ្នកគួរដល់ការសរសើរ ទើបសរសើរព្រះយោគាវចរនោះយ៉ាងនេះថា ប្រកបដោយឧបេក្ខា មានសតិ មានធម៌ជាគ្រឿងនៅជាសុខ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **តតិយំ** ដូចតទៅនេះ ឈ្មោះថា **តតិយ** ដោយលំដាប់នៃការរាប់ ។ ឈាននេះ ឈ្មោះថា **តតិយជ្ឈាន** ព្រោះអត្ថថា សម្រេចលើកទី ៣ ។ ក្នុងបទជាដើមថា **តស្មិំ សមយេ ផស្សោ ហោតិ** សូម្បីពាក្យថា បីតិក្នុងពួក ៥ នៃឈានបាត់ទៅ គប្បីជ្រាបវិនិច្ឆ័យនៃពាក្យដែលមានការចែក និងមិនមានការចែក ដោយអំណាចនៃបីតិនោះ ។ ក្នុងកោដ្ឋាសវារៈ ក៏មានព្រះតម្រាស់ថា ឈានប្រកបដោយអង្គ ២ ។ ពាក្យដ៏សេស ដូចគ្នានឹងទុតិយជ្ឈាននុ៎ះឯង ។

**តតិយជ្ឈាន ចប់**

# ចតុត្ថជ្ឈាន

[ ២៤៦ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃចតុត្ថជ្ឈានដូចតទៅ

បទថា **សុខស្ស ច បហានា ទុក្ខស្ស ច បហានា** បានដល់ ព្រោះលះសុខតាមផ្លូវកាយ និងទុក្ខតាមផ្លូវកាយ ។ បទថា **បុព្វេវ** គឺការលះនោះមានក្នុងកាលមុននោះឯង មិនមែនមានក្នុងខណៈនៃចតុត្ថជ្ឈានទេ ។ បទថា **សោមនស្សទោមនស្សានំ អត្ថង្គមា** សេចក្តីថា ព្រោះដល់នូវការតាំងនៅមិនបាន ក្នុងកាលមុននៃធម៌ទាំង ២ នេះ គឺសុខតាមផ្លូវចិត្ត និងទុក្ខតាមផ្លូវចិត្ត មានអធិប្បាយយ៉ាងនេះថា ព្រោះលះបង់ហើយ ។ សួរថា ការលះសុខ និងទុក្ខ តាមផ្លូវចិត្តទាំងនោះ មានក្នុងកាលណា ឆ្លើយថា ក្នុងខណៈឧបចារនៃឈានទាំង ៤ ។ ពិតហើយ ព្រះយោគាវចរ លះសោមនស្សបានក្នុងខណៈនៃឧបចារៈរបស់ឈានទី ៤ ប៉ុណ្ណោះ ចំណែកទុក្ខ ទោមនស្ស និងសុខ រមែងលះបានក្នុងខណៈនៃឧបចារៈរបស់ឈានទីមួយ ទីពីរ និងទីបី ។ ដោយប្រការដូច្នេះ បណ្ឌិតគប្បីជ្រាបការលះសុខ ទុក្ខ សោមនស្ស និងទោមនស្សទាំងនោះ ដែលមិនត្រាស់តាមលំដាប់នៃការលះ ដោយប្រការដូច្នេះ តែគប្បីជ្រាបការលះសុខ ទុក្ខ សោមនស្ស និងទោមនស្ស ដែលត្រាស់ក្នុងទីនេះ តាមលំដាប់នៃឧទ្ទេសនៃឥន្ទ្រិយទាំងឡាយ ក្នុងឥន្ទ្រិយវិភង្គនុ៎ះឯង ។

សួរថា បើអង្គឈានទាំងនោះ ព្រះយោគាវចរលះបានក្នុងខណៈឧបចារៈនៃឈាននោះៗ សោត កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបត្រាស់ការរលត់ក្នុងឈានទាំងឡាយ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ចុះទុក្ខិន្ទ្រិយកើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ រមែងចូលកាន់បឋមជ្ឈាន ។ ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់ ។ ចុះទោមនស្សិន្ទ្រិយ ... សុខិន្ទ្រិយ ... សោមនស្សិន្ទ្រិយ កើតឡើងក្នុងទីដូចម្ដេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រេចសម្រាន្តនៅ ។ សោមនស្សិន្ទ្រិយកើតឡើងហើយ ក្នុងចតុត្ថជ្ឈាននុ៎ះ ទើបរលត់ទៅឥតមានសេសសល់ ដូច្នេះ ឆ្លើយថា ព្រោះការរលត់ល្អក្រៃលែង ។

តាមពិតការរលត់សុខជាដើមទាំងនោះ ក្នុងបឋមជ្ឈានជាដើម ជាការរលត់ល្អក្រៃលែងដូចគ្នា តែការរលត់ក្នុងខណៈនៃឧបចារជ្ឈាន មិនឈ្មោះថាជាការរលត់ដែលល្អក្រៃលែង ពិតយ៉ាងនោះ ទុក្ខិន្ទ្រិយសូម្បីរលត់ហើយក្នុងឧបចារៈនៃបឋមជ្ឈាន ក្នុងអាវជ្ជនចិត្តផ្សេងៗ គប្បីកើតឡើងបាន ព្រោះសម្ផស្សដែលកើតអំពីរបោមមូសជាដើម ឬថា ព្រោះសេចក្ដីលំបាក ដែលកើតអំពីការអង្គុយក្នុងទីដែលមិនស្មើ ចំណែកខាងក្នុងអប្បនា ទុក្ខិន្ទ្រិយនោះមិនកើតឡើងទេ ។ ម្យ៉ាងទៀត ទុក្ខិន្ទ្រិយដែលរលត់ទៅហើយ ក្នុងឧបចារជ្ឈាននេះ នៅមិនទាន់រលត់យ៉ាងស្និទ្ធ ព្រោះមិនទាន់ត្រូវបដិបក្ខធម៌ ( គឺឈាន ) សង្កត់សង្កិន តែថា ខាងក្នុងអប្បនា កាយទាំងពួង បានឈមចុះកាន់សេចក្ដីសុខហើយ ដោយការផ្សាយទៅនៃបីតិ ។ ទុក្ខិន្ទ្រិយរបស់ព្រះយោគាវចរដែលមានកាយឈមចុះហើយក្នុងសេចក្ដីសុខ រមែងជាធម៌ដែល

រលត់ស្និទ្ធ ព្រោះត្រូវបដិបក្ខធម៌កម្ចាត់ហើយ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ធ្វើសព្ទថា **អបរិសេស** ( មិនមានចំណែកសេសសល់ ) ក្នុងទីនោះៗ ថា ទុក្ខិន្ទ្រិយដែលកើតឡើងហើយ រមែងរលត់ទៅ មិនមានចំណែកសេសសល់ក្នុងទីនេះ ដូច្នេះជាដើម ព្រោះកាលព្រះយោគាវចរលះទោមនស្សិន្ទ្រិយបានហើយ ក្នុងឧបចារៈនៃទុតិយជ្ឈាន ក្នុងអាវជ្ជនចិត្តផ្សេងៗ ទុំះឯង ទោមនស្សិន្ទ្រិយនេះ រមែងកើតឡើងបាន ក្នុងកាលសេចក្តីលំបាកកាយ និងសេចក្តីចង្អៀតចង្អល់ចិត្តដែលមានវិតក្ក និងវិចារជាបច្ច័យនៅមាន តែកាលមិនមានវិតក្ក និងវិចារ ទោមនស្សិន្ទ្រិយ រមែងកើតឡើងមិនបាន ទោមនស្សិន្ទ្រិយ រមែងកើតឡើងក្នុងទីណា ក្នុងទីនោះ រមែងកើត ព្រោះមានវិតក្ក និងវិចារ វិតក្ក និងវិចារក្នុងឧបចារៈនៃទុតិយជ្ឈាន ព្រះយោគាវចរ មិនទាន់លះបាន ព្រោះហេតុនោះ ទោមនស្សិន្ទ្រិយ ក៏គប្បីកើតឡើងក្នុងឧបចារៈនៃទុតិយជ្ឈាននោះ ព្រោះមិនទាន់លះវិតក្ក និងវិចារ ដែលជាបច្ច័យបាន ចំណែកក្នុងទុតិយជ្ឈាន ទោមនស្សិន្ទ្រិយ កើតមិនបានឡើយ ព្រោះលះវិតក្ក និងវិចារដែលជាបច្ច័យបានហើយ ។ ពិតយ៉ាងនោះ ក្នុងឧបចារៈនៃតតិយជ្ឈាន សុខិន្ទ្រិយ សូម្បីព្រះយោគាវចរលះបានហើយ គប្បីកើតឡើងបានដល់កាយដែលរូបដ៏ប្រណីត មានបីតិជាសមុដ្ឋានពាល់ត្រូវហើយ ចំណែកក្នុងតតិយជ្ឈាន សុខិន្ទ្រិយកើតមិនបានឡើយ ព្រោះថា បីតិដែលជាបច្ច័យដល់សុខក្នុងតតិយជ្ឈាន រមែងរលត់ទៅដោយប្រការទាំងពួង ។ ពិតយ៉ាងនោះ ក្នុងឧបចារៈនៃចតុត្ថជ្ឈាន សោមនស្សិន្ទ្រិយសូម្បីព្រះយោគីលះបានហើយ ក៏

គប្បីកើតឡើងបាន ព្រោះភាពជាសភាវៈជិតចំពោះសុខ និងព្រោះនៅមិនទាន់ឈានកន្លងដោយប្រពៃ ព្រោះមិនមានឧបេក្ខាដែលដល់អប្បនា ចំណែកក្នុងចតុត្ថជ្ឈាន សោមនស្សិន្ទ្រិយ កើតមិនបានឡើយ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ធ្វើឲ្យកាន់យកដោយមិនមានចំណែកសេសសល់ ក្នុងទីនោះៗ យ៉ាងនេះថា ទុក្ខិន្ទ្រិយកើតឡើងហើយ រមែងរលត់ទៅ មិនមានចំណែកសេសសល់ ក្នុងទីនេះ ដូច្នេះ ។

ក្នុងអធិការនៃចតុត្ថជ្ឈាននេះ បើមានអ្នកសួរថា បើយ៉ាងនេះ វេទនាទាំងនេះ ដែលព្រះយោគាវចរលះហើយ ក្នុងឧបចារៈនៃឈាននោះៗ ព្រោះហេតុអ្វីទើបក្នុងទីនោះ ទ្រង់នាំមកត្រាស់ទៀត ។ ឆ្លើយថា ដើម្បីឲ្យយល់ងាយ ។ មែនពិត វេទនាដែលមិនមែនទុក្ខ មិនមែនសុខនេះ ដែលត្រាស់ទុកក្នុងអដ្ឋនៃឈាននេះថា មិនមែនទុក្ខ មិនមែនសុខ ដូច្នេះ វេទនានោះ ល្អិត ដឹងបានដោយលំបាក បុគ្គលណាមួយមិនអាចយល់បានដោយងាយ ព្រោះហេតុនោះទើបព្រះមានព្រះភាគ ទ្រង់នាំវេទនាទាំងអស់នេះមកទៀត ដើម្បីឲ្យកំណត់បានដោយងាយ ប្រៀបដូចនាយគោបាល ត្រូវការចាប់គោកាចមួយ ដែលបុគ្គលណាមួយមិនអាចចូលទៅចាប់ដោយវិធីណានីមួយ ទើបកៀងគោទាំងអស់ចូលទៅក្នុងក្រោលតែមួយ ពេលនោះ ទើបដេញចេញម្តងមួយ ហើយឲ្យចាប់គោកាចនោះ ដែលចេញមកដោយលំដាប់ថា គោនេះ គឺគោកាចនោះ ចូរពួកអ្នកចាប់វា ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងវេទនាទាំងនេះដែលទ្រង់ប្រមូលមកដោយអាការយ៉ាងនេះហើយ ក៏អាចឲ្យបុគ្គលកំណត់វេទនា

នោះបានថា សភាវៈណាមិនមែនសុខ មិនមែនទុក្ខ មិនមែនសោមនស្ស មិនមែនទោមនស្ស សភាវៈនេះ ជាអទុក្ខមសុខវេទនា ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់វេទនាទាំងនោះ ដើម្បីទ្រង់ចង្អុលបង្ហាញដល់បច្ច័យនៃចេតោវិមុត្តិ ដែលមិនមានទុក្ខ និងសុខ ព្រោះថា ការលះសុខ និងទុក្ខជាដើម ជាបច្ច័យនៃចេតោវិមុត្តិនោះ ដូចព្រះសារីបុត្តពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យប៉ុន្មាន ។ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្ដីសុខ ១ ព្រោះលះបង់នូវសេចក្ដីទុក្ខ ១ ព្រោះរម្ងត់នូវសោមនស្ស និងទោមនស្សក្នុងកាលមុន ១ ចូលកាន់ចតុត្ថជ្ឈានដែលឥតទុក្ខ ឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំងបួន ១ ម្នាលអាវុសោ អទុក្ខមសុខចេតោ-វិមុត្តិសមាបត្តិ មានបច្ច័យ ៤ នេះឯង ដូច្នេះ ។ ម្យ៉ាងទៀត សំយោជនៈមានសក្កាយទិដ្ឋិជាដើម ដែលព្រះអរិយៈលះបានហើយ ក្នុងមគ្គដទៃ ( បឋម-មគ្គជាដើម ) ព្រះមានព្រះភាគត្រាស់ថា លះហើយក្នុងមគ្គទី ៣ នោះ ដើម្បីទ្រង់សរសើរមគ្គទី ៣ យ៉ាងណា វេទនាទាំងនោះ គប្បីជ្រាបថា ត្រាស់ក្នុងឈានទី ៤ នេះ ដើម្បីសរសើរឈាននោះ ក៏យ៉ាងនោះ ។ ម្យ៉ាងទៀត វេទនាទាំងនោះ គប្បីជ្រាបថា ត្រាស់ដើម្បីសម្ដែងដល់ភាពដែលរាគៈ និងទោសៈជាសភាវៈឆ្ងាយក្រៃលែង ក្នុងឈានទី ៤ នេះ ដោយកម្ចាត់បច្ច័យ

បានហើយ ។ ពិតណាស់ បណ្ដាវេទនាទាំងនេះ សុខជាបច្ច័យដល់សោមនស្ស សោមនស្សជាបច្ច័យដល់រាគៈ ទុក្ខជាបច្ច័យដល់ទោមនស្ស ទោមនស្សជាបច្ច័យដល់ទោសៈ រាគៈនិងទោសៈព្រមទាំងបច្ច័យ ត្រូវចតុត្ថជ្ឈានកម្ចាត់ហើយ ព្រោះកម្ចាត់សេចក្ដីសុខជាដើមបានហើយ ព្រោះហេតុនោះទើបរាគៈនិងទោសៈ ឈ្មោះថា មាននៅក្នុងទីឆ្ងាយក្រៃលែង ដូច្នេះ ។

បទថា **អទុក្ខមសុខំ** សេចក្ដីថា ឈ្មោះថា **អទុក្ខ** ព្រោះការមិនមានទុក្ខ ឈ្មោះថា **អសុខ** ព្រោះការមិនមានសុខ ។ ក្នុងចតុត្ថជ្ឈាននេះដោយពាក្យថា មិនជាទុក្ខមិនជាសុខនេះ ទ្រង់រមែងសម្ដែងវេទនាទី ៣ ដែលជាបដិបក្ខចំពោះទុក្ខ និងសុខ មិនមែនព្រោះសម្ដែងដើម្បីការមិនមានទុក្ខ និងសុខ ។ ការមិនទុក្ខមិនសុខ ឈ្មោះថា វេទនាទី ៣ ហៅថា ឧបេក្ខាក៏មាន ។

ឧបេក្ខាវេទនានោះ គប្បីជ្រាបថា **ឥដ្ឋានិដ្ឋវិបរីតានុភវនលក្ខណា** មានការសោយអារម្មណ៍ ជាបដិបក្ខនឹងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាលក្ខណៈ **មជ្ឈត្តរសា** មានភាពជាកណ្ដាលជាកិច្ច **អវិភូតបច្ចុប្បដ្ឋានា** មានការមិនប្រាកដជាក់ច្បាស់ជាអាការប្រាកដ **សុខនិរោធបទដ្ឋានា** មានការរលត់សេចក្ដីសុខជាហេតុជិត ។

បទថា **ឧបេក្ខាសតិបារិសុទ្ធិំ** បានដល់ មានសតិបរិសុទ្ធដែលឧបេក្ខាឲ្យកើតឡើងហើយ ។ ព្រោះក្នុងឈាននេះ សតិជាធម្មជាតបរិសុទ្ធល្អហើយ ក៏សេចក្ដីបរិសុទ្ធរបស់សតិនេះ ដែលឧបេក្ខាធ្វើហើយ មិនមែនធម៌ដទៃធ្វើឲ្យ ព្រោះហេតុនោះ ទើបចតុត្ថជ្ឈាននេះ ឈ្មោះថា មានសតិដ៏បរិសុទ្ធដោយ

ឧបេក្ខា ដូច្នេះ ។ ក្នុងវិភង្គ ព្រះមានព្រះភាគក៏ត្រាស់ថា សតិនេះជាធម្មជាត របើក បរិសុទ្ធ ផូរផង់ដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ដូច្នេះ ។ មួយទៀត សេចក្តីបរិសុទ្ធនៃសតិក្នុងឈាននេះ រមែងមានដោយឧបេក្ខាណា ឧបេក្ខានោះ ពោលដោយអត្ថ គប្បីជ្រាបថា ជាតត្រមជ្ឈត្តតា ដូច្នេះ ក៏ក្នុងចតុត្ថជ្ឈាននេះ សតិប៉ុណ្ណោះ បរិសុទ្ធហើយដោយឧបេក្ខានោះ ត្រឹមតែម្យ៉ាងប៉ុណ្ណោះក៏ទេ តាមពិត សម្បយុត្តធម៌ទាំងអស់ ក៏បរិសុទ្ធព្រោះឧបេក្ខាដូចគ្នា តែត្រាស់ទេសនាដោយលើកសតិជាប្រធាន ។

បណ្តាឈានទាំងនោះ ឧបេក្ខានេះ សូម្បីមានក្នុងឈានខាងក្រោម ៣ ក៏ពិត តែប្រៀបដូចព្រះចន្ទសូម្បីមានក្នុងពេលថ្ងៃ ក៏មិនបរិសុទ្ធផូរផង់ ព្រោះក្នុងពេលថ្ងៃ ត្រូវរស្មីនៃព្រះអាទិត្យគ្របសង្កត់ និងព្រោះមិនបានរាត្រីដែលសមគួរ ដែលជារាត្រីផូរផង់ ឬជារាត្រីដែលជាឧបការៈដល់ខ្លួន យ៉ាងណា សូម្បីព្រះចន្ទ គឺតត្រមជ្ឈត្តុបេក្ខានេះក៏យ៉ាងនោះដូចគ្នា សូម្បីមានក្នុងឈានមានបឋមជ្ឈានជាដើម ក៏មិនបរិសុទ្ធ ព្រោះត្រូវតេជៈនៃធម៌ ដែលជាសត្រូវមានវិតក្កជាដើមគ្របសង្កត់ និងព្រោះមិនបានរាត្រីដែលសមគួរ គឺឧបេក្ខា-វេទនា ។ ម្យ៉ាងទៀត កាលតត្រមជ្ឈត្តុបេក្ខានេះ មិនបរិសុទ្ធសូម្បីសហ-ជាតធម៌ មានសតិជាដើមក៏មិនបរិសុទ្ធដូចគ្នា ប្រៀបដូចព្រះចន្ទ មិនបរិសុទ្ធក្នុងវេលាថ្ងៃ រស្មីនៃព្រះចន្ទក៏មិនបរិសុទ្ធ ។ ព្រោះហេតុនោះ ក្នុងឈានទាំងនោះ សូម្បីឈានមួយក៏មិនត្រាស់ថា មានសតិបរិសុទ្ធព្រោះឧបេក្ខា តែក្នុង

ចតុត្ថជ្ឈាននេះ ព្រះចន្ទ គឺតត្រមជ្ឈត្តុបេក្ខានេះ បរិសុទ្ធក្រៃលែង ព្រោះមិនមានតេជះនៃធម៌ដែលជាសត្រូវ មានវិតក្កជាដើមគ្របសង្កត់ និងព្រោះបានរាត្រី គឺឧបេក្ខាវេទនាដែលសមគួរ ។ ព្រោះឧបេក្ខានោះ ជាធម៌បរិសុទ្ធសូម្បីសហជាតធម៌ មានសតិជាដើមក៏បរិសុទ្ធផូរផង់ ដូចរស្មីនៃព្រះចន្ទដែលបរិសុទ្ធហើយ ។ ព្រោះហេតុនោះ គប្បីជ្រាបថា ចតុត្ថជ្ឈាននេះប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ថា មានសតិបរិសុទ្ធដោយឧបេក្ខា ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចតុត្ថំ** ដូចតទៅនេះ ឈ្មោះថា **ចតុត្ថ** ដោយលំដាប់នៃការរាប់ ។ ឈាននេះ ឈ្មោះថា ចតុត្ថជ្ឈាន ព្រោះអត្ថថា សម្រេចលើកទី ៤ ។ ក្នុងបទថា **ឧបេក្ខា ហោតិ** ជាដើម ឧបេក្ខាវេទនានេះប៉ុណ្ណោះ ក្នុងពួក ៥ នៃធម៌ មានផស្សៈជាដើមគប្បីជ្រាបថា ជាវេទនា ។ ម្យ៉ាងទៀត ក្នុងពួក ៥ នៃឈាន និងពួក ៨ នៃឥន្ទ្រិយ ក៏ត្រាស់ថា ជាឧបេក្ខា ជាឧបេក្ខិន្ទ្រិយនុ៎ះឯង ។ បទដ៏សេសដែលបាត់ទៅហើយ ក្នុងតតិយជ្ឈាន ក្នុងចតុត្ថជ្ឈាននេះ ក៏បាត់ទៅដូចគ្នា ។ សូម្បីក្នុងកោដ្ឋាសវារៈ ពាក្យថា ឈានប្រកបដោយអង្គ ២ គប្បីជ្រាបដោយអំណាចនៃឧបេក្ខា និងចិត្តេកគ្គតានុ៎ះឯង ។ ពាក្យដ៏សេសទាំងពួង ដូចគ្នានឹងតតិយជ្ឈាននុ៎ះឯង ។

**ចតុក្កន័យ ចប់**

# អភិធម្មបិដក

## បញ្ចកន័យ

[ ១៤៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៥០ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានដល់ទុតិយជ្ឈាន ឈ្មោះបឋវីកសិណ គ្មានវិតក្កមានត្រឹមតែវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈានក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិចារ បីតិ សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៥១ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ៤ មគ្គប្រកបដោយអង្គ ៤ ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៥២ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា វិចារ បីតិ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្ដីផ្គងឡើង សេចក្ដីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណា ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៥៣ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់នូវវិតក្ក និងវិចាររួចហើយ ។បេ។ បានដល់តតិយជ្ឈាន ឈ្មោះបឋវីកសិណ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត បីតិ សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្ដីផ្គងឡើង សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ឬថា ពួកអរូប-ធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៥៤ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ៣ មគ្គប្រកបដោយអង្គ ៤ ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើត

មានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៥៥ ] សង្ខារក្ខន្ធកើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា បីតិ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណាក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៥៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានជិនណាយចាកបីតិ ។បេ។ បានដល់ ចតុត្ថជ្ឈាន ឈ្មោះបឋវីកសិណា ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៥៧ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ២ មគ្គប្រកបដោយអង្គ ៤

ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៥៨ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណាក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៥៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានលះសុខផង ។បេ។ បានដល់ បញ្ចមជ្ឈាន ឈ្មោះបឋវីកសិណ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត ឧបេក្ខា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៦០ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៨ ឈានប្រកបដោយអង្គ ២ មគ្គប្រកបដោយអង្គ ៤

ពល ៧ ហេតុ ៣ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ១៦១ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាវាយាមៈ ។បេ។ សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ឬថា ពួកអរូបធម៌ដទៃណាក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

**បញ្ចកន័យ ចប់**

# អដ្ឋកថា

## បញ្ចកន័យ

[ ១៤៩ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់ផ្តើមបញ្ចកន័យថា **កតមេ ធម្មា កុសលា** ដូច្នេះ ។

បើសួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់សម្តែងឈានបញ្ចក-ន័យ ឆ្លើយថា ព្រោះសម្តែងតាមអធ្យាស្រ័យរបស់បុគ្គល និងព្រោះលម្អនៃទេសនា ។ បានឮថា ក្នុងទេវបរិស័ទដែលប្រជុំគ្នា វិតក្ករបស់ទេវតាពួកខ្លះប៉ុណ្ណោះ ប្រាកដជារបស់គ្រោតគ្រាត ចំណែកវិចារ បីតិ សុខ ឯកគ្គតានៃចិត្តប្រាកដជារបស់ល្អិត ។ ព្រះសាស្តាទ្រង់ចែកឈាន ឈ្មោះទុតិ-យជ្ឈាន មានអង្គ ៤ ដែលមិនមានវិតក្ក មានតែវិចារ ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ ។ ពួកខ្លះ មានវិចារ ប្រាកដជារបស់គ្រោតគ្រាត បីតិ សុខ ឯកគ្គតានៃចិត្តប្រាកដជារបស់ល្អិត ។ ព្រះសាស្តា ក៏ទ្រង់ចែកឈាន ឈ្មោះតតិយជ្ឈាន មានអង្គ ៣ ដោយអំណាចសប្បាយដល់ទេវតាទាំងនោះ ។ ពួកខ្លះ មានបីតិប្រាកដជារបស់គ្រោតគ្រាត សុខ ឯកគ្គតានៃចិត្ត ប្រាកដជារបស់ល្អិត ។ ព្រះសាស្តា ក៏ទ្រង់ចែកឈាន ឈ្មោះចតុត្ថជ្ឈាន មានអង្គ ២ ដោយអំណាចសប្បាយ ដល់ទេវតាទាំងនោះ ។ ពួកខ្លះ មានសុខប្រាកដជារបស់គ្រោតគ្រាត ឧបេក្ខា និងឯកគ្គតានៃចិត្តប្រាកដជារបស់ល្អិត ព្រះសាស្តា ក៏ទ្រង់ចែកឈាន ឈ្មោះបញ្ចមជ្ឈាន មានអង្គ ២ ដោយអំណាចសប្បាយដល់ទេវតាទាំងនោះ ។ នេះឈ្មោះថា អធ្យាស្រ័យរបស់បុគ្គល ។

ចំណែកការៈដែលវេនេយ្យសត្វ ចាក់ធ្លុះធម្មធាតុណាបានងាយ រមែងឈ្មោះថា ដល់ ព្រោះលម្អនៃទេសនា ធម្មធាតុនោះ ព្រះតថាគតទ្រង់ចាក់ធ្លុះមកល្អហើយ ព្រោះហេតុនោះ ព្រះសាស្តា ទ្រង់សម្រេចដល់លម្អនៃទេសនា ទ្រង់ឈ្លាសក្នុងវិធីទេសនា ព្រោះទ្រង់មានញាណធំ ទ្រង់កំណត់ទេសនាបានតាមបំណង ដោយអំណាចនៃអង្គនោះៗ ដែលទ្រង់បានហើយ ។ ក្នុងទីនេះ ទើបព្រះសាស្តាទ្រង់ចែកបឋមជ្ឈានមានអង្គ ៥ ទុតិយជ្ឈានមានអង្គ ៤ គឺមិនមានវិតក្ក មានតែវិចារ តតិយជ្ឈានមានអង្គ ៣ ចតុត្ថជ្ឈានមានអង្គ ២ បញ្ចមជ្ឈានក៏មានអង្គ ២ ទុំះឯង នេះឈ្មោះថា លម្អនៃទេសនា ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងសមាធិទាំង ៣ ពួកណា ក្នុងព្រះសូត្រ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ សមាធិ ៣ យ៉ាង គឺសមាធិប្រកបដោយវិតក្កវិចារ ១ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារ ១ សមាធិមិនមានវិតក្ក និងវិចារ ១ ដូច្នេះ ។ បណ្តាសមាធិទាំងនោះ សវិតក្កសវិចារសមាធិ និងអវិតក្កអវិចារសមាធិ ព្រះមានព្រះភាគទ្រង់ចែកសម្តែងខាងដើមហើយ ។ ចំណែកអវិតក្កវិចារមត្តសមាធិ ទ្រង់នៅមិនទាន់បានសម្តែង ព្រោះហេតុនោះ គប្បីជ្រាបថា ដើម្បីសម្តែងអវិតក្កវិចារមត្តសមាធិនោះ ទើបទ្រង់ផ្តើមបញ្ចកន័យនេះ ។ ក្នុងនិទ្ទេសនៃទុតិយជ្ឈានក្នុងបញ្ចកន័យនោះ បណ្តាធម៌ មានផស្សៈជាដើម មានត្រឹមវិតក្កដែលបាត់ទៅ ។ ចំណែកក្នុងកោដ្ឋាសវារៈ ពាក្យថា ឈានប្រកបដោយអង្គ ៤ មគ្គប្រកបដោយអង្គ ៤ ដូច្នេះប៉ុណ្ណោះដែលប្លែកគ្នា ពាក្យដ៏សេស

ទាំងអស់ដូចបឋមជ្ឈានទុំះឯង ។ ឯឈានទី ២ ទី ៣ ទី ៤ ក្នុងចតុក្កន័យ ជាឈានទី ៣ ទី ៤ ទី ៥ ក្នុងបញ្ចកន័យនេះ ។ ដើម្បីសម្ដែងការសម្រេចលំដាប់នៃឈានទាំងនោះ គប្បីជ្រាបន័យដូចតទៅ

បានឮថា កូនរបស់អមាត្យម្នាក់ មកកាន់នគរអំពីជនបទ ដើម្បីចូលគាល់ព្រះរាជា ចូលគាល់ព្រះរាជាត្រឹមតែមួយថ្ងៃប៉ុណ្ណោះហើយ បំផ្លាញទ្រព្យទាំងអស់ដោយការផឹកសុរា ។ ថ្ងៃមួយ ពួកអ្នកលេងស្រោតសំពត់គាត់ដែលកំពុងស្រវឹងស្រា ហើយយកកន្ទេលផែងចាស់មកបិទបាំង ហើយយកចេញអំពីរោងសុរា អ្នកចេះវិជ្ជាមើលលក្ខណៈម្នាក់ ឃើញបុត្តអមាត្យដេកលក់ត្រង់គំនរសំរាម ទើបសន្និដ្ឋានថា បុរសម្នាក់នេះ នឹងជាទីពឹងដល់មហាជនបាន អញគួរជួយបុរសនេះ ទើបឲ្យងូតទឹកជម្រះរាងកាយដោយដីឥដ្ឋ ឲ្យស្លៀកដណ្ដប់សំពត់សាច់គ្រោតគ្រាតមួយគូ ហើយឲ្យងូតដោយទឹកក្រអូបទៀត ឲ្យស្លៀកដណ្ដប់សំពត់ទុកូលសាច់ម៉ដ្ឋ ឲ្យឡើងកាន់ប្រាសាទ ឲ្យបរិ-ភោគភោជនដ៏ប្រណីត ហើយឲ្យមនុស្សប្រណិប័តន៍ដោយពាក្យថា ពួកអ្នកចូរបម្រើបុរសនេះយ៉ាងនេះ ហើយចៀសចេញទៅ ។

បន្ទាប់ពីនោះមក អ្នកបម្រើទាំងនោះក៏លើកបុរសនោះ ឲ្យឡើងកាន់ទីដេក បុរសអ្នកបដិបត្តិ ៤ នាក់ បានឈរសង្កត់ដៃ និងជើងបុរសនោះ ដើម្បីកុំឲ្យចូលទៅកាន់រោងសុរា ក្នុងទីនោះ បុរសម្នាក់ច្របាច់ជើង បុរសម្នាក់ យកផ្ចិតស្លឹកត្នោតមកបក់ បុរសម្នាក់អង្គុយដេញពិណាច្រៀងបំពេ ។

បុរសនោះបាត់នឿយហត់ហើយ ព្រោះចូលកាន់ដំណេកដេកលក់បន្តិច

ហើយភ្ញាក់ឡើង មិនអាចអត់ទ្រាំនឹងការសង្កត់ដៃ និងជើងបាន ទើបគំរាម ដោយពាក្យថា នរណាមកសង្កត់ដៃ សង្កត់ជើងយើង ចូរចេញទៅ ។ មនុស្សទាំងនោះ ក៏ចេញទៅដោយពាក្យត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ បុរសនោះ ក៏ដេកលក់បន្តិចទៀត ហើយភ្ញាក់ឡើង អត់ធន់ចំពោះការប្រចាប់ជើងមិនបាន ទើបនិយាយថា អ្នកណាមកប្រចាប់ជើងយើង ចូរចេញទៅ សូម្បីអ្នកគក់ ប្រចាប់ជើងនោះក៏ចៀសចេញទៅដោយពាក្យត្រឹមតែមួយម៉ាត់នោះឯង បុរស នោះដេកលក់បន្តិចទៀត ហើយភ្ញាក់ឡើង អត់ធន់នឹងខ្យល់ដែលកើតអំពីផ្លិត ស្លឹកត្នោត ដូចខ្យល់លាយដោយភ្លៀងមិនបាន ទើបនិយាយថា ទុំះនរណា ចូរ ចេញទៅ ។ សូម្បីបុរសនោះក៏ចៀសចេញទៅ ដោយពាក្យត្រឹមតែមួយម៉ាត់ ប៉ុណ្ណោះ បុរសនោះដេកលក់បន្តិចទៀត ភ្ញាក់ឡើងអន់ធន់នឹងសំឡេងច្រៀង និងសំឡេងប្រគំ ដូចស្នូចាក់ត្រចៀកមិនបាន ទើបគំរាមបុរសដេញពិណ សូម្បីអ្នកដេញពិណក៏ចេញទៅ ដោយពាក្យត្រឹមតែមួយម៉ាត់ដូចគ្នា ពេល នោះ បុរសនោះលះបង់ឧបទ្រវៈ គឺការនឿយហត់ ការត្រូវគេសង្កត់ ការគក់ ប្រចាប់ ការត្រូវគេបក់ផ្លិត និងសំឡេងភ្លេងប្រគំ ទើបដេកជាសុខ ភ្ញាក់ឡើង ហើយ បានចូលទៅគាល់ព្រះរាជា សូម្បីព្រះរាជាក៏បានព្រះរាជទានភាពជាធំ ឲ្យដល់បុរសនោះ បុរសនោះ បានជាទីពឹងដល់មហាជនហើយ ។

ក្នុងរឿងនោះ គប្បីឃើញកុលបុត្តដែលគ្រប់គ្រងផ្ទះដល់នូវសេចក្តីវិនាស ព្រោះសេចក្តីវិនាសទៅជាច្រើន ប្រៀបដូចកូននៃអមាត្យដែលដល់នូវសេចក្តី វិនាសទៅដោយការផឹកទឹកស្រវឹងនោះ ។ ព្រះតថាគត ប្រៀបដូចបុគ្គលអ្នក

ចេះវិជ្ជាមើលលក្ខណៈ ការដែលព្រះតថាគតទ្រង់សន្និដ្ឋានថា កុលបុត្តនេះនឹងជាទីពឹងដល់មហាជនបាន សមគួរនឹងបព្វជ្ជា ដូច្នេះ ប្រៀបដូចបុរសអ្នកចេះវិជ្ជាមើលលក្ខណៈ សន្និដ្ឋានថា បុគ្គលនេះនឹងបានជាទីពឹងដល់មហាជនសមគួរនឹងជួយសង្គ្រោះ ។

តមក កុលបុត្តបានបព្វជ្ជា ប្រៀបដូចបុត្តអមាត្យនោះបានងូតទឹក ធ្វើការជម្រះរាងកាយដោយជីឥដ្ឋ ។ តមក កុលបុត្តនេះបានស្លៀកដណ្ដប់សំពត់ គឺសីល ១០ ដូចកូនអមាត្យនោះស្លៀកសំពត់សាច់គ្រោតគ្រាត ។ ការដែលកុលបុត្តនេះបានងូតទឹកក្រអូប គឺបាតិមោក្ខសំវរសីលជាដើម ប្រៀបដូចកូនរបស់អមាត្យនោះ បានងូតទឹកក្រអូបទៀត ។ ការដែលកុលបុត្តនេះបានស្លៀកដណ្ដប់សំពត់ទុកូល គឺដល់ព្រមដោយសីលវិសុទ្ធិ តាមដែលពោលហើយ ប្រៀបដូចកូនរបស់អមាត្យនោះ បានស្លៀកដណ្ដប់សំពត់ទុកូលសាច់ម៉ដ្ឋទៀត ។

ការដែលកុលបុត្តនេះ ស្លៀកដណ្ដប់សំពត់ទុកូល គឺសីលវិសុទ្ធិ ឡើងកាន់ប្រាសាទ គឺសមាធិភាវនា ប្រៀបដូចកូនរបស់អមាត្យនោះ ស្លៀកដណ្ដប់សំពត់ទុកូលសាច់ម៉ដ្ឋ ឡើងកាន់ប្រាសាទ ។ តអំពីនោះមក កុលបុត្តនេះ បានការបរិភោគអមតធម៌ មានសតិ និងសម្បជញ្ញៈជាដើម ដែលមានឧបការៈចំពោះសមាធិ ប្រៀបដូចកូនអមាត្យនោះបរិភោគអាហារដ៏ប្រណីត ។ ការដែលកុលបុត្តនេះ ត្រូវធម៌ មានវិតក្កជាដើម លើកឡើងកាន់ឧបចារៈនៃឈាន ប្រៀបដូចកូនអមាត្យនោះ បរិភោគអាហារហើយ ត្រូវអ្នកបម្រើទាំង

ឡាយ លើកឡើងកាន់ទីដេក ។ នេក្ខម្មវិតក្ករបស់កុលបុត្តនេះសង្កត់ចិត្តក្នុងអារម្មណ៍ដើម្បីការពារចំពោះមុខ ចំពោះកាមសញ្ញា ប្រៀបដូចបុរស ៤ នាក់សង្កត់ដៃ សង្កត់ជើងរបស់កូនអមាត្យនោះ ដើម្បីមិនឲ្យទៅកាន់រោងសុរាទៀត ។ វិចារដែលពិចារណាចិត្តក្នុងអារម្មណ៍ របស់កុលបុត្តនេះ ប្រៀបដូចបុរស គក់ប្របាច់ជើងកូនរបស់អមាត្យនោះ ។ បីតិដែលឲ្យនូវសេចក្តីត្រជាក់ចិត្តដល់កុលបុត្តនេះ ប្រៀបដូចបុរសយកផ្ទិតស្លឹកត្នោត បក់ឲ្យកូនរបស់អមាត្យនោះ ។

សោមនស្ស អនុគ្រោះចិត្តរបស់កុលបុត្តនេះ ប្រៀបដូចតន្ត្រីករធ្វើការអនុគ្រោះសោតៈរបស់កូនអមាត្យនោះ ។ ការដែលកុលបុត្តបន្ទោបង់សេចក្តីនឿយហត់ គឺប្រាសចាកនីវរណៈ ដោយអាស្រ័យឧបចារជ្ឈាន ចូលដល់បឋមជ្ឈាននេះ ប្រៀបដូចកូនអមាត្យនោះ បន្ទោបង់សេចក្តីនឿយហត់បានបន្តិច ដោយការចូលទៅកាន់ទីដេកហើយលង់លក់ទៅ ។ ការដែលកុលបុត្តនេះចេញពីបឋមជ្ឈាន ឃើញទោសនៃវិតក្ក ព្រោះទ្រាំនឹងវិតក្កកៀបសង្កត់ចិត្តមិនបាន ព្រោះលះបង់វិតក្ក ទើបចូលឈានដែលជាអវិតក្កវិចារមត្តសមាធិ ( មិនមានវិតក្កមានត្រឹមវិចារ ) ប្រៀបដូចការដែលកូនរបស់អមាត្យលង់លក់ហើយភ្ញាក់ឡើង គំរាមអ្នកដែលសង្កត់ដៃ សង្កត់ជើង ព្រោះទ្រាំចំពោះការសង្កត់ដៃ សង្កត់ជើងមិនបាន លុះមនុស្សទាំងនោះចៀសចេញទៅទើបដេកលក់បន្តិច ។

តអំពីនោះមក ការដែលកុលបុត្តនេះ ចេញពីទុតិយជ្ឈានជាដើមរឿយៗ

ឃើញទោសវិចារជាដើម ដោយលំដាប់ ព្រោះមិនអាចទ្រាំចំពោះវិចារជាដើមដែលមានទោស តាមដែលពោលហើយ និងចូលឈានដែលមិនមានវិតក្ក មិនមានវិចារ មិនមានបីតិ លះសោមនស្សបានហើយរឿយៗ ព្រោះលះវិចារជាដើមទាំងនោះ ប្រៀបដូចកូនអមាត្យនោះ ដេកលក់ហើយ ភ្ញាក់ឡើងរឿយៗ គំរាមអ្នកដែលគក់ប្រចាប់ជើងជាដើម តាមលំដាប់ ព្រោះមិនអាចទ្រាំចំពោះការគក់ប្រចាប់ជើងជាដើម ដោយលំដាប់ តាមដែលពោលហើយ និងចូលដល់ការដេកលក់បន្តិចរឿយៗ ព្រោះអ្នកប្រចាប់ជើងជាដើមទាំងនោះ ចេញទៅហើយ ។

កាលកុលបុត្តនេះ ចេញចាកបញ្ចមជ្ឈានចូលដល់វិបស្សនាមគ្គ សម្រេចអរហត្ត ប្រៀបដូចកូនអមាត្យនោះ ក្រោកអំពីដំណេក ទៅគាល់ព្រះរាជាហើយដល់ព្រមដោយឥស្សរិយយស ។

ភាពដែលកុលបុត្តនេះ សម្រេចអរហត្តហើយ ជាទីពឹងដល់ជនច្រើនគប្បីជ្រាបដូចការដែលកូនអមាត្យនោះ បានឥស្សរិយយសហើយ ជាទីពឹងដល់ជនជាច្រើន ដូច្នោះ ។ ពិតហើយ កុលបុត្តនេះ ក៏ឈ្មោះថា ជាបុញ្ញក្ខេត្តដ៏ឧត្តម ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

**បញ្ចកន័យ ចប់**

ដោយពាក្យមានប្រមាណប៉ុណ្ណោះ ឈ្មោះថា រមែងជាការប្រកាសសុទ្ធិកនវកៈ ( ពួក ៩ បរិសុទ្ធៗ ) ដែលមានឈានចតុក្កន័យ និងឈានបញ្ចកន័យ ២ ពួក ។ តែកាលពោលដោយអត្ថ សុទ្ធិកនវកៈនោះ គប្បីជ្រាបថា ជាឈានបញ្ចកន័យទាំងឯង ព្រោះឈានចតុក្កន័យ សង្គ្រោះចូលក្នុងឈានបញ្ចកន័យបាន ។

# អភិធម្មបិដក

## បដិបទា ៤

[ ១៦២ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៦៣ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងរហ័សក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៦៤ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៦៥ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន

ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៦៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្ក និងវិចារ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិងាយ តែមានសេចក្តីត្រាស់ដឹងយឺតយូរ ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

បដិបទា ៤ ចប់

## អារម្មណ៍ ៤

[ ១៦៧ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា

ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៦៨ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានឈ្មោះបឋវីកសិណ មានប្រមាណតូច តែមានអារម្មណ៍ ប្រមាណមិនបានក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៦៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានឈ្មោះបឋវីកសិណ ប្រមាណមិនបាន តែមានអារម្មណ៍តូច ក្នុងសម័យណាផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៧០ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានឈ្មោះបឋវីកសិណ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៧១ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្ក និងវិចារ ។បេ។ ទុតិយជ្ឈាន ។បេ។

តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ច-មជ្ឈាន ឈ្មោះបឋវីកសិណ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបឋវីកសិណ មានប្រមាណតូច តែមានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបឋវីកសិណ ប្រមាណមិនបាន តែមានអារម្មណ៍តូច ។បេ។ ឈ្មោះបឋវីកសិណ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## ពួកអារម្មណ៍ ៤ ចប់

## វារៈ ១៦

[ ១៧២ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិ-បត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍

ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៧៣ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងដ៏ឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។

បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងដ៏ឆាប់ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងដ៏ឆាប់ ប្រមាណមិនបាន មានអារម្មណ៍តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៧៤ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងយឺត

យូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្ដីប្រតិបត្តិឯាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្ដីប្រតិបត្តិឯាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន តែមានអារម្មណ៍តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្ដីប្រតិបត្តិឯាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជា

កុសល ។

[ ១៧៥ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូចក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូចក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះបឋវី-

កសិណ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៧៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបឋវីកសិណ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់

ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ។បេ។ ឈ្មោះបបវិកសិណា មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

ភាវៈ ១៦ ចប់

## កសិណ ៨ មានវារៈ ១៦

[ ១៧៧ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ឈ្មោះអាបោកសិណ ។បេ។ ឈ្មោះតេជោកសិណ ។បេ។ ឈ្មោះវាយោ-កសិណ ។បេ។ ឈ្មោះនីលកសិណ ។បេ។ ឈ្មោះបីតកសិណ ។បេ។ ឈ្មោះលោហិតកសិណ ។បេ។ ឈ្មោះឱទាតកសិណក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

*កសិណ ៨ មានវារៈ ១៦ ចប់*

# អដ្ឋកថា

## បដិបទា ៤ ជាដើម

[ ១៦២-១៦៦ ] ឥឡូវនេះ ព្រោះឈាននេះ សម្រេចដោយលំដាប់បដិ-បទា ហេតុនោះ ដើម្បីសម្តែងប្រភេទលំដាប់បដិបទានៃឈាននោះ ទើបទ្រង់ប្រារព្ធបទជាដើមថា **កតមេ ធម្មា កុសលា** មួងទៀត ។ ក្នុងបដិបទាទាំងនោះ ឈានដែលឈ្មោះថា **ទុក្ខប្បដិបទំ** ព្រោះអត្ថថា ឈាននោះ បដិបត្តិលំបាក ។ ដែលឈ្មោះថា **ទន្ធាភិញ្ញំ** ព្រោះអត្ថថា ឈាននោះ ដឹងបានយឺតយូរ ។ ព្រោះហេតុនោះ ពាក្យទាំង ៣ គឺទុក្ខាបដិបទាក្តី ទន្ធាភិញ្ញាក្តី បបវីកសិណក្តី ជាឈ្មោះរបស់ឈានទាំងនោះ ។ ក្នុងពាក្យជាដើមថា **ទុក្ខាបដិបទា ខិប្បាភិញ្ញា** ក៏ន័យនេះដូចគ្នា ។

បណ្តាបដិបទាទាំងនោះជាដើម ការចម្រើនឈានដែលប្រព្រឹត្តទៅ តាំងអំពីផ្តើមតាំងចិត្តដំបូង រហូតដល់ឧបចារៈនៃឈាននោះៗ កើតឡើង ហៅថា **បដិបទា** ។ ចំណែកបញ្ញាដែលប្រព្រឹត្តទៅ តាំងអំពីឧបចារៈ រហូតដល់អប្បនា ហៅថា **អភិញ្ញា** ។ បដិបទានេះ រមែងលំបាកដល់បុគ្គលខ្លះ អធិប្បាយថា ឈ្មោះថា **បដិបត្តិលំបាក** គឺមិនងាយសេពបាន ព្រោះធម៌ជាសត្រូវ មាននីវរណៈជាដើម ធ្វើឲ្យរាយមាយ ។ បដិបទារបស់បុគ្គលខ្លះ បដិបត្តិបានងាយ ព្រោះមិនមានធម៌ដែលជាសត្រូវបែបនោះ ។ សូម្បីអភិញ្ញារបស់បុគ្គលខ្លះ ក៏យឺតយូរ គឺជាធម្មជាតទន់ខ្សោយ មិនប្រព្រឹត្តទៅដោយរហ័ស អភិញ្ញារបស់បុគ្គលខ្លះរហ័ស គឺមិនយឺតយូរ ប្រព្រឹត្តទៅដោយរហ័ស ព្រោះហេតុនោះ បុគ្គលណា កាលគ្របសង្កត់កិលេសទាំងឡាយ

ដោយវិបស្សនាញាណ តាំងអំពីដើមលំបាក ដោយសេចក្តីព្យាយាមប្រកប ដោយការតាក់តែង រមែងគ្រប់សង្កត់បានដោយលំបាក បដិបទារបស់បុគ្គល នោះ ឈ្មោះថា **ទុក្ខាបដិបទា** ។

ចំណែកបុគ្គលណា គ្រប់សង្កត់កិលេសបានហើយ កាលអប់រំអប្បនា រមែងសម្រេចភាពជាអង្គឈានបាន ដោយកាលយឺតយូរ ការដឹងរបស់ បុគ្គលនោះ ឈ្មោះថា **ទន្ធាភិញ្ញា** ។ បុគ្គលណា រមែងសម្រេចភាពជាអង្គ ឈានបានដោយរហ័ស ការដឹងរបស់បុគ្គលនោះ ឈ្មោះថា **ខិប្បាភិញ្ញា** ។ បុគ្គលណា កាលគ្រប់សង្កត់កិលេសទាំងឡាយមិនលំបាក គ្រប់សង្កត់បាន ដោយងាយ បដិបទារបស់បុគ្គលនោះ ឈ្មោះថា **សុខាបដិបទា** ។

ក្នុងអធិការនៃឈានទាំងនោះ សប្បាយក្តី អសប្បាយក្តី បុព្វកិច្ច មាន ការកាត់បលិពោធជាដើមក្តី អប្បនាកោសលក្តី ខ្ញុំអធិប្បាយក្នុងចិត្តការនា- និទ្ទេស ក្នុងវិសុទ្ធិមគ្គហើយ ក្នុងបដិបទាមានសប្បាយជាដើមទាំងនោះ បុគ្គលណាសេពអសប្បាយ បដិបទារបស់បុគ្គលនោះ ក៏ជាទុក្ខាបដិបទា និងទន្ធាភិញ្ញា ។ សម្រាប់បុគ្គលដែលសេពសប្បាយ បដិបទាក៏ជាសុខា- បដិបទា និងខិប្បាភិញ្ញា ។ ចំណែកបុគ្គលណាសេពអសប្បាយក្នុងចំណែក ខាងដើម សេពសប្បាយក្នុងចំណែកខាងក្រោយ ឬថា សេពសប្បាយ ក្នុងចំណែកខាងដើម សេពសប្បាយក្នុងចំណែកខាងក្រោយ បណ្ឌិតគប្បី ជ្រាបថា បដិបទា និងអភិញ្ញារបស់បុគ្គលនោះ លាយគ្នា ។

ម្យ៉ាងទៀត ព្រះយោគាវចរមិនធ្វើបុព្វកិច្ច មានការកាត់បលិពោធជាដើម

យ៉ាងនោះ ឲ្យសម្រេចសិន ហើយចម្រើនភាវនា បដិបទាជាទុក្ខាបដិបទា ដោយបរិយាយផ្ទុយគ្នាជាសុខាបដិបទា ។ មួយទៀត កាលព្រះយោគាវចរ មិនធ្វើអប្បនាកោសលឲ្យសម្រេច អភិញ្ញារបស់លោកជាទន្ធាភិញ្ញា កាលធ្វើអប្បនាកោសលឲ្យសម្រេច អភិញ្ញាជាខិប្បាភិញ្ញា ។

ម្យ៉ាងវិញទៀត គប្បីជ្រាបប្រភេទនៃបដិបទា និងអភិញ្ញាទាំងនោះ ដោយអំណាចតណ្ហា និងអវិជ្ជា និងដោយអំណាចនៃការបំពេញសមថៈ និងវិបស្សនា ។ ពិតហើយ បដិបទារបស់បុគ្គលដែលត្រូវតណ្ហាគ្របសង្កត់ហើយ ជាទុក្ខា-បដិបទា បដិបទារបស់បុគ្គលមិនត្រូវតណ្ហាគ្របសង្កត់ហើយ ជាសុខាបដិ-បទា និងបដិបទារបស់បុគ្គលដែលត្រូវអវិជ្ជាគ្របសង្កត់ហើយ ជាទន្ធាភិញ្ញា បដិបទារបស់បុគ្គល ដែលមិនត្រូវអវិជ្ជាគ្របសង្កត់ហើយ ជាខិប្បាភិញ្ញា ។ មួយទៀត បុគ្គលណា មិនសន្សំសមថៈ បដិបទារបស់បុគ្គលនោះ ជាទុក្ខាបដិបទា បដិបទារបស់បុគ្គលដែលសន្សំសមថៈ ជាសុខាបដិបទា ។ បុគ្គលណា មិនសន្សំវិបស្សនា បដិបទារបស់បុគ្គលនោះ ជាទន្ធាភិញ្ញា បដិបទារបស់អ្នកសន្សំវិបស្សនា ជាខិប្បាភិញ្ញា ។

គប្បីជ្រាបប្រភេទនៃបដិបទា និងអភិញ្ញាទាំងនោះ ដោយអំណាចនៃកិលេស និងឥន្ទ្រិយ ។ មែនពិត បដិបទា និងអភិញ្ញា របស់បុគ្គលដែលមានកិលេសខ្លាំងក្លា មានឥន្ទ្រិយទន់ខ្សោយ ក៏ជាទុក្ខាបដិបទាទន្ធាភិញ្ញា ចំណែករបស់បុគ្គលដែលមានឥន្ទ្រិយចាស់ក្លា ជាខិប្បាភិញ្ញា ។ បដិបទា និងអភិញ្ញារបស់បុគ្គល ដែលមានកិលេសទន់ខ្សោយ ឥន្ទ្រិយទន់ខ្សោយ ក៏ជាសុខាបដិបទាទន្ធាភិញ្ញា

ចំណែករបស់បុគ្គលដែលមានឥន្ទ្រិយចាស់ក្លា ក៏ជាខិប្បាភិញ្ញា ។

បណ្ដាបដិបទានិងអភិញ្ញាទាំងនេះ ដោយប្រការដែលពោលមកនេះ បុគ្គលណា សម្រេចឈានដោយបដិបត្តិលំបាក និងត្រាស់ដឹងយឺតយូរ ឈាននោះរបស់បុគ្គលនោះ ហៅថា ទុក្ខាបដិបទាទន្ធាភិញ្ញា ។ សូម្បីពាក្យដ៏សេស ក៏ន័យនេះដូចគ្នា ។ ក្នុងអធិការនៃឈាននោះ គប្បីជ្រាបបដិបទាក្នុងការសង្កត់កិលេស ដោយសតិតាមដែលត្រាស់ ( ក្នុងអភិធម្ម វិភង្គ ) យ៉ាងនេះថា សតិ មានសភាពដ៏សមគួរដល់បញ្ញានោះ តាំងនៅស្មើ ឈ្មោះថា បញ្ញា មានចំណែកនៃការតាំងនៅ ដូច្នេះ ឬក្នុងការសង្កត់សង្កិន ដោយសតិ ដោយសេចក្ដីត្រូវការឈាននោះៗ គប្បីជ្រាបអភិញ្ញាក្នុងការអប់រំអប្បនា របស់អ្នកសម្រេចឧបចារជ្ឈាននោះៗ ។ មួយ៉ាងទៀត បដិបទា និងអភិញ្ញា រមែងមានដោយអំណាចនៃការសម្រេចនោះឯង ព្រោះថា ទុតិយជ្ឈានដែលបុគ្គលសម្រេចបឋមជ្ឈាន ដែលជាទុក្ខាបដិបទាទន្ធាភិញ្ញាហើយសម្រេច ក៏ដូចគ្នានុ៎ះឯង សូម្បីក្នុងឈានទី ៣ ឈានទី ៤ ក៏ន័យនេះឯង ។ គប្បីជ្រាបសេចក្ដីផ្សេងគ្នា ៤ យ៉ាង ដោយអំណាចនៃបដិបទា សូម្បីក្នុងឈានបញ្ចកន័យ ដូចក្នុងឈានចតុក្កន័យ ។ ព្រះមានព្រះភាគ ត្រាស់ឈានពួក ៩ ( រួមទាំង ២ ន័យ ) ជា ៤ យ៉ាង ដោយអំណាចនៃបដិបទា ដោយ

ប្រការដូច្នេះ ។ ក្នុងឈានពួក ៩ បដិបទាទាំង ៤ នោះ ពោលដោយព្រះបាលី បានចិត្ត ៣៦ ដួង តែពោលដោយអត្ថ ( សេចក្តី ) បានចិត្ត ២០ ដួងប៉ុណ្ណោះ ព្រោះឈានចតុក្កន័យ ក៏សង្គ្រោះនៅក្នុងឈានបញ្ចកន័យនោះឯង ។

## បដិបទា ៤ ចប់

# អារម្មណ៍របស់ឈាន ៤

[ ១៦៧-១៧១ ] ឈ្មោះថា ឈាននេះ មាន ៤ យ៉ាង ដោយប្រភេទនៃអារម្មណ៍ដូចប្រភេទនៃបដិបទា ព្រោះហេតុនោះ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងប្រភេទនៃអារម្មណ៍នោះ ទើបទ្រង់ផ្ដើមពាក្យជាដើមថា **កតមេ ធម្មា កុសលា** ទៀត ។ ក្នុងរូបាវចរកុសលជ្ឈាននោះ គប្បីជ្រាបវិគ្គហៈ ក្នុងបទជាដើមថា **បរិត្តំ បរិត្តារម្មណំ** ដូចតទៅនេះថា ឈានណា មិនស្ទាត់ជំនាញ មិនអាចជាបច្ច័យដល់ឈានខាងលើ ឈាននេះ ឈ្មោះថា **បរិត្ត** ( មានកម្លាំងតិច ) ចំណែកឈានណា ប្រព្រឹត្តទៅក្នុងអារម្មណ៍ មាននិមិត្តប៉ុនចង្អេរឬប៉ុនផ្ដិលទឹក ដែលពង្រីកឲ្យធំមិនបាន ឈាននេះ ឈ្មោះថា **បរិត្ត** ។ អារម្មណ៍មានកម្លាំងតិចរបស់ឈាននេះមាន ព្រោះហេតុនោះ ទើបឈាននេះ ឈ្មោះថា **បរិត្តារម្មណំ** ( មានអារម្មណ៍ដ៏តូច ) ។ ឈានណា ស្ទាត់ជំនាញ អប់រំល្អហើយ អាចជាបច្ច័យដល់ឈានខាងលើ ឈាននេះ ឈ្មោះថា **អប្បមាណំ** ( មានកម្លាំងច្រើន ) ។ ឈានណា ប្រព្រឹត្តទៅក្នុងអារម្មណ៍ដ៏ទូលំទូលាយ ឈាននោះ ក៏ឈ្មោះថា **អប្បមាណំ** ព្រោះកំណត់និមិត្តដែលចម្រើនបាន ។ អារម្មណ៍មានកម្លាំងច្រើន មានដល់ឈាននោះ ព្រោះហេតុនោះ ទើបឈាននោះ ឈ្មោះថា **អប្បមាណារម្មណំ** ( មានអារម្មណ៍ប្រមាណមិនបាន ) ។ មួយទៀត គប្បីជ្រាបន័យដែលលាយឡំគ្នា ព្រោះ

លក្ខណៈតាមដែលពោលហើយ លាយឡំគ្នា ។ ព្រះមានព្រះភាគ ត្រាស់ឈានពួក ៩ ជា ៤ យ៉ាង ដោយអំណាចនៃអារម្មណ៍ដូចពណ៌នាមកនេះ ។ មួយទៀត ការរាប់ចិត្តក្នុងប្រភេទនៃអារម្មណ៍នេះ ដូចគ្នានឹងប្រភេទនៃបដិបទាទាំងឡាយនុ៎ះឯង ។

## អារម្មណ៍របស់ឈាន ៤ ចប់

# អារម្មណ៍ និងបដិបទាលាយគ្នា

[ ១៧២-១៧៦ ] ឥឡូវនេះ ដើម្បីសម្ដែងន័យ ១៦ យ៉ាង លាយដោយអារម្មណ៍ និងបដិបទា ទើបទ្រង់ផ្ដើមពាក្យថា **កតមេ ធម្មា កុសលា** ជាដើមដូច្នេះទៀត ។ បណ្ដាន័យទាំងនោះ ឈានដែលព្រះមានព្រះភាគត្រាស់ក្នុងន័យដំបូង ឈ្មោះថា **ហីន** ព្រោះហេតុ ៤ យ៉ាង គឺព្រោះជាទុក្ខាបដិបទា ព្រោះជាទន្ធាភិញ្ញា ព្រោះជាបរិត្ត ព្រោះជាបរិត្តារម្មណៈ ។ ឈានដែលត្រាស់ក្នុងន័យទី ១៦ ឈ្មោះថា **បណីត** ព្រោះហេតុ ៤ យ៉ាង គឺព្រោះជាសុខាបដិបទា ព្រោះជាខិប្បាភិញ្ញា ព្រោះជាអប្បមាណ ព្រោះជាអប្បមាណារម្មណៈ ។ ក្នុងន័យដ៏សេស ១៤ ន័យ គប្បីជ្រាបភាពជាហីនៈ និងបណីតៈដោយហេតុមួយ ហេតុពីរ និងហេតុបី ។

សួរថា ន័យនេះ លោកសម្ដែងព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះការកើតឡើងនៃឈានជាហេតុ ។ មែនពិត ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងសុទ្ធិកជ្ឈាន ក្នុងបឋវីកសិណ ដោយអំណាចនៃឈានចតុក្កន័យ និងឈានបញ្ចកន័យ ទ្រង់សម្ដែងសុទ្ធិកបដិបទា និងសុទ្ធិការម្មណៈយ៉ាងនោះដូចគ្នា ។ បណ្ដាចតុក្កន័យ និងបញ្ចកន័យទាំងពីរនោះ ទេវតាពួកណា អាចត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងបឋវីកសិណ ដែលព្រះអង្គសម្ដែងដោយអំណាចនៃឈានចតុក្កន័យ ក៏ទ្រង់សម្ដែងចតុក្កន័យ ក្នុងសុទ្ធិកជ្ឈាន ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ ។

ទេវតាពួកណា អាចត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងបឋវីកសិណ ដែលទ្រង់សម្ដែងដោយអំណាចនៃឈានបញ្ចកន័យ ក៏ទ្រង់សម្ដែងបញ្ចកន័យ ដោយ

អំណាចនៃសប្បាយដល់ទេវតាទាំងនោះ ។

ទេវតាពួកណា អាចត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងសុទ្ធិកប្បដិបទា និងក្នុងសុទ្ធិការម្មណៈ ដែលទ្រង់សម្តែងដោយអំណាចចតុក្កន័យ ក៏ទ្រង់សម្តែងចតុក្កន័យ ក្នុងសុទ្ធិកប្បដិបទា និងក្នុងសុទ្ធិការម្មណៈ ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ ។

ទេវតាពួកណា អាចត្រាស់ដឹងសុទ្ធិកជ្ឈាន ក្នុងសុទ្ធិកប្បដិបទា និងក្នុងសុទ្ធិការម្មណៈ ដែលទ្រង់សម្តែងដោយអំណាចនៃបញ្ចកន័យ ក៏ទ្រង់សម្តែងបញ្ចកន័យ ដោយអំណាចនៃសប្បាយដល់ទេវតាទាំងនោះ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើទេសនា ដោយអំណាចនៃអជ្ឈាស្រ័យរបស់បុគ្គល តាមដែលពោលហើយ ដោយប្រការដូច្នេះ ។

មួយទៀត ព្រះមានព្រះភាគ ទ្រង់ដល់នូវលម្អនៃទេសនា ទ្រង់បែកធ្លាយក្នុងបដិសម្ភិទា ទ្រង់មានទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណបរិសុទ្ធ អាចកំណត់ទេសនាដោយអំណាចន័យណាមួយក៏បាន ព្រោះព្រះអង្គឈ្លាសក្នុងការបញ្ញត្តិធម៌ ព្រោះធម៌ទាំងឡាយ ទ្រង់ចាក់ធ្លុះល្អហើយ តាមសេចក្តីពិតព្រមទាំងរស និងលក្ខណៈ ព្រោះហេតុនោះ ទើបទ្រង់ធ្វើទេសនានោះ ដោយអំណាចនៃឈានសុទ្ធិកចតុក្កន័យជាដើម ក្នុងបឋវីកសិណ ព្រោះដល់នូវលម្អនៃទេសនានេះ ។

ជនពួកណាមួយ ញ៉ាំងឈានឲ្យកើតឡើង ជនទាំងនោះវៀរអារម្មណ៍ និងបដិបទាក៏មិនអាចធ្វើឈានឲ្យកើតឡើងបាន ព្រោះហេតុនោះ ទើបត្រាស់ន័យ

នេះ ១៦ ដង ព្រោះជាហេតុនៃការកើតឡើងនៃឈានដោយពិតប្រាកដ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ជាការដែលត្រាស់ទុក ៩ ទុក ២៥ ន័យ គឺសុទ្ធិកនវកៈ ១ ន័យ បដិបទានវកៈ ៤ ន័យ អារម្មណនវកៈ ៤ ន័យ និងនវកៈ ១៦ ន័យនេះឯង ។ បណ្ដានវកធម៌ទាំង ២៥ ន័យនោះ ក្នុងនវកៈនីមួយៗ មាននវកៈ ២ ន័យ ដោយអំណាចចតុក្កន័យ និងបញ្ចកន័យ ព្រោះហេតុនោះ ទើបមាន ៥០ ន័យ ។ បណ្ដាន័យទាំង ៥០ នោះ ពោលដោយព្រះបាលី បានឈានចិត្ត ២២៥ ដួង គឺ ២៥ ន័យ ក្នុងចតុក្កន័យ បាន ១០០ ន័យ ( ២៥ × ឈាន ៤ ) ក្នុងបញ្ចកន័យ បាន ១២៥ ន័យ តែកាលពោលដោយអត្ថ បានចិត្ត ១២៥ ដួងប៉ុណ្ណោះ ព្រោះឈានចតុក្កន័យក៏សង្គ្រោះចូលក្នុងឈានបញ្ចកន័យ ។ ក្នុងនិទ្ទេសនៃចិត្តមួយដួង បណ្ដាចិត្តទាំង ២២៥ ដួងនោះ ក្នុងព្រះបាលីមានមហាវារៈនីមួយៗ ៣ មានធម្មវវត្ថានៈជាដើម ។ មហាវារៈទាំងនោះ ក្នុងទីនោះៗ ទ្រង់សង្ខេប សម្ដែងល្មមជាន័យប៉ុណ្ណោះ ដូច្នេះ ។

**បឋវីកសិណា ចប់**

# អាលោកសិណជាដើម

[ ១៧៧ ] ឈានទាំងនេះ រមែងកើតឡើង សូម្បីក្នុងអាលោកសិណជាដើម ព្រោះហេតុនោះ ឥឡូវនេះ ដើម្បីសម្តែងឈានទាំងនោះ ទើបទ្រង់ផ្តើមពាក្យជាដើមថា **កតមេ ធម្មា កុសលា** ដូច្នេះទៀត ។ ក្នុងឈានទាំងនោះ ន័យរបស់ព្រះបាលីទាំងអស់ ការអធិប្បាយសេចក្តី ការរាប់ចំនួនចិត្ត ការសន្និបវារៈ គប្បីជ្រាបដោយន័យដែលពោលក្នុងបឋវីកសិណនុ៎ះឯង ។ តែន័យរបស់ការវនាសូម្បីទាំងអស់ តាំងពីធ្វើបរិកម្មកសិណ ខ្ញុំប្រកាសហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ តែក្នុងមហាសកុលុទាយិសូត្រ ទ្រង់ត្រាស់កសិណ ១០ យ៉ាង ក្នុងកសិណទាំង ១០ នោះ វិញ្ញាណកសិណ ដែលជាមហគ្គតវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាសក្តី ដែលជាវិញ្ញាណញ្ចាយតនសមាបត្តិដែលកើតឡើង ព្រោះធ្វើបរិកម្មក្នុងអាកាសនោះក្តី រួមសម្តែងក្នុងអរូបនោះឯង ដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបវិញ្ញាណកសិណ ព្រះមានព្រះភាគមិនត្រាស់ក្នុងទីនេះ ។

កសិណុគ្ឃាដិមាកាស ( អាកាសដែលបើកកសិណទាំង ៩ វៀរអាកាសកសិណ ) ក្តី ខន្ធទាំងឡាយ ដែលប្រព្រឹត្តទៅព្រោះធ្វើអាកាសដែលបើកនោះឲ្យជាអារម្មណ៍ក្តី បរិច្ឆេទាកាស ( អាកាសដែលកំណត់ ) មាននិមិត្តដែលគប្បីកាន់យក ក្នុងប្រហោងជញ្ជាំងជាដើមណានីមួយក្តី ឈានចតុក្កន័យ និងឈានបញ្ចកន័យ ដែលកើតឡើងព្រោះធ្វើអាកាសនោះឲ្យជាអារម្មណ៍ក្តី ហៅថា អាកាសកសិណ ។ បណ្តាអាកាសកសិណទាំង ៤ នោះ ន័យខាងដើម ( ២ ន័យដំបូង ) រួមនៅក្នុងអារុប្បទេសនា ន័យក្រោយ

( ២ ន័យក្រោយ ) រួមនៅក្នុងរូបាវចរទេសនា ។ ដោយប្រការដូច្នេះ ទើបអាកាសកសិណមិនពោលក្នុងរូបាវចរទេសនានេះ ព្រោះជារបស់លាយឡំគ្នា តែឈានដែលកើតឡើងក្នុងបរិច្ឆេទាកាស រមែងជាផ្លូវដើម្បីចូលដល់រូបភព ព្រោះហេតុនោះ ទើបគួរកាន់យកឈាននោះ ឈានដែលជាចតុក្កន័យនិងបញ្ចកន័យប៉ុណ្ណោះ រមែងកើតឡើងក្នុងបរិច្ឆេទាកាសនោះ អរូបជ្ឈានរមែងមិនកើតឡើង ។

សួរថា ព្រោះហេតុអ្វី ទើបមិនកើត ។ ឆ្លើយថា ព្រោះមិនបានបើកកសិណចេញ ។ ពិតហើយ អាកាសកសិណនោះ សូម្បីបើករឿយៗ ក៏ជាអាកាសទុំះឯង ហេតុនោះ ទើបមិនបានបើកកសិណក្នុងអរូបជ្ឈាននោះ ព្រោះហេតុនោះ ទើបបរិច្ឆេទាកាសជ្ឈានដែលកើតឡើងក្នុងទីនោះ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ជាផ្លូវកើតអភិញ្ញា ជាផ្លូវកើតវិបស្សនា មិនជាផ្លូវកើតនិរោធ ។ តែការរលត់ដោយលំដាប់ ក្នុងរូបាវចរជ្ឈាននេះ រមែងមានរហូតដល់បញ្ចមជ្ឈាន រមែងជាហេតុនៃវដ្តៈប៉ុណ្ណោះ ។ ឈាននេះ ( បរិ-ច្ឆេទាកាស ) យ៉ាងណា សូម្បីឈានទាំងឡាយ ដែលកើតឡើងក្នុងកសិណមុនៗ ក៏យ៉ាងនោះ តែការដែលកសិណមុនជាបាទនៃនិរោធ ទើបជាការប្លែកគ្នាក្នុងបរិច្ឆេទាកាសនោះ ។ ពាក្យដ៏សេសក្នុងទីនេះ ពាក្យណាដែលគួរពោលក្នុងអាកាសកសិណ ពាក្យទាំងអស់នោះ បានពោលហើយ ក្នុងវិសុទ្ធិមគ្គទុំះឯង ។

ចំណែកព្រះយោគាវចរ អ្នកប្រាថ្នាសម្តែងឫទ្ធិផ្សេងៗ មានន័យជាដើម

ថា សូម្បីមនុស្សម្នាក់ក៏ធ្វើឲ្យជាច្រើននាក់បាន ដូច្នេះ គប្បីធ្វើសមាបត្តិ ៨ ឲ្យកើតក្នុងកសិណ ៨ ដែលជាខាងដើម ហើយគប្បីហ្វឹកហាត់ចិត្តដោយអាការ ១៤ យ៉ាងនេះ គឺ **កសិណានុលោមតោ** ចូលឈានតាមលំដាប់កសិណ ១ **កសិណបដិលោមតោ** ចូលឈានបញ្ច្រាសលំដាប់កសិណ ១ **កសិណានុលោមបដិលោមតោ** ចូលឈានតាមលំដាប់ និងបញ្ច្រាសលំដាប់កសិណ ១ **ឈានានុលោមតោ** ចូលតាមលំដាប់ឈាន ១ **ឈានបដិលោមតោ** ចូលបញ្ច្រាសលំដាប់ឈាន ១ **ឈានានុលោមបដិលោមតោ** ចូលតាមលំដាប់ឈាន និងបញ្ច្រាសលំដាប់ឈាន ១ **ឈានុក្កន្តិកតោ** ចូលឈានដោយរំលងលំដាប់ ១ **កសិណុក្កន្តិកតោ** ចូលឈានដោយរំលងកសិណ ១ **ឈានកសិណុក្កន្តិកតោ** ចូលរំលងទាំងឈាន និងកសិណ ១ **អង្គសង្កន្តិកតោ** ចូលឈាន ៥ ដោយឈានកន្លងអង្គ ១ **អារម្មណសង្កន្តិកតោ** ចូលឈានដោយផ្លាស់ប្តូរអារម្មណ៍ ១ **អង្គារម្មណសង្កន្តិកតោ** ចូលទាំងដោយកន្លងអង្គ និងដោយផ្លាស់ប្តូរអារម្មណ៍ ១ **អង្គវវត្ថានតោ** ចូលដោយកំណត់ដឹងអង្គឈាន ១ **អារម្មណវវត្ថានតោ** ចូលដោយកំណត់ដឹងអារម្មណ៍ ១ ។

ការអធិប្បាយដោយពិស្តារនៃការបង្ហឹកចិត្ត ដោយអាការទាំងនោះ ខ្ញុំពោលក្នុងវិសុទ្ធិមគ្គទាំងនោះឯង ព្រះយោគាវចរដែលមិនបង្ហឹកចិត្តដោយអាការ ១៤ យ៉ាងនេះ មិនធ្លាប់អប់រំការនាមកអំពីមុន ជាអាទិកម្មិក នឹងញុំាងការសម្តែងឫទ្ធិផ្សេងៗ ឲ្យសម្រេចនោះ មិនមែនជាឋានៈ ។ ពិតហើយ

សូម្បីការបរិកម្មកសិណរបស់ព្រះយោគាវចរ ដែលជាអាទិកម្មិកជារបស់ក្រ បណ្ដាអ្នកផ្ដើមបរិកម្មកសិណ រាប់រយ រាប់ពាន់អង្គ មួយអង្គ រមែងអាច ។ ការដែលព្រះយោគាវចរ អ្នកធ្វើកសិណបរិកម្មហើយ ការដែលនឹងធ្វើនិមិត្ត ឲ្យកើតឡើង ក៏ជារបស់ក្រ ក្នុងចំណោមទាំងមួយរយអង្គ មួយពាន់អង្គ មួយអង្គប៉ុណ្ណោះ រមែងអាច ។ កាលនិមិត្តកើតឡើងហើយ ការពង្រីក និមិត្តឲ្យចម្រើនឡើង ហើយដល់នូវអប្បនា ក៏ជារបស់ក្រ ក្នុងមួយរយអង្គ មួយពាន់អង្គ មួយអង្គប៉ុណ្ណោះ រមែងអាច ។ សូម្បីអ្នកសម្រេចអប្បនា ហើយ ការបង្ហឹកចិត្តដោយអាការ ១៤ ក៏ជារបស់ក្រ ក្នុងមួយរយអង្គ មួយពាន់អង្គ មួយអង្គប៉ុណ្ណោះ រមែងអាច ។ សូម្បីអ្នកដែលបង្ហឹកចិត្តដោយ អាការ ១៤ យ៉ាងហើយ ឈ្មោះថា ការសម្ដែងឫទ្ធិផ្សេងៗ ក៏ជារបស់ក្រ ក្នុងមួយរយអង្គ មួយពាន់អង្គ មួយអង្គប៉ុណ្ណោះ រមែងអាច ។ សូម្បីអ្នក សម្ដែងឫទ្ធិបានហើយ ឈ្មោះថា ការចូលឈានបានរហ័ស ក៏ជារបស់ក្រ បណ្ដាមួយរយអង្គ មួយពាន់អង្គ មួយអង្គប៉ុណ្ណោះ ចូលឈានបានរហ័ស ដូចបណ្ដាលោកអ្នកមានឫទ្ធិ ប្រមាណ ៣ ម៉ឺនអង្គ ដែលមកព្យាបាលព្រះ មហារោហណគុត្តត្ថេរ ដែលអាពាធក្នុងថេរម្ពត្ថលវិហារ ព្រះរក្ខិតត្ថេរដែល មានវស្សា ៨ ដោយការឧបសម្បទា ជាអ្នកចូលឈានបានរហ័ស រឿង ទាំងអស់ មានពិស្ដារហើយ ក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។

**កសិណកថា ចប់**

# អភិធម្មបិដក

## អភិភាយតនៈ

[ ១៧៨ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់រូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៧៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មាន

សេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះ ហើយគិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ហើយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹងឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើនមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាម

ទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹងឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងឆាប់ មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## បដិបទា ៤ ចប់

[ ១៨០ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់

បឋមជ្ឈាន មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញ នឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្កៈ និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

**ពួកអារម្មណ៍ ២ ចប់**

[ ១៨១ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច បានស្ងាត់ចាកកាមទាំងឡាយ គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តី

ប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច

គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ ជា

កុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ដ៏តូច ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ដ៏តូច ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

វារៈ ៨ ចប់

[ ១៨២ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច មានពណ៌ល្អ មានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច មានពណ៌ល្អ មានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចារ រួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

### នេះក៏ជាឈានមានវារៈ ៨ ដែរ

[ ១៨៣ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់

បឋមជ្ឈានក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចារ រួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ១៨៤ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បាន

ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា

អាត្មាអញទឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## បដិបទា ៤ ចប់

[ ១៨៥ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញទឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញទឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាម

ទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## ពួកអារម្មណ៍ ២ ចប់

[ ១៨៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើត

មានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើនមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹង

ដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្ដិលំបាក មានសេចក្ដីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្ដិងាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្ដិងាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជា

កុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញនឹងដឹង ឃើញ ដូច្នេះ បានរម្ងាប់វិតក្កៈ និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន

មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ ប្រមាណមិនបាន ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មាន សេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិន បាន ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ មាន ប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ មានសេចក្តីប្រតិបត្តិ លំបាក មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ប្រមាណ មិនបាន ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ មានសេចក្តីប្រតិ-បត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ប្រមាណមិនបាន មានអារម្មណ៍ ប្រមាណមិនបាន ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹង ឆាប់ មានប្រមាណតូច មានអារម្មណ៍ប្រមាណមិនបាន ។បេ។ មានសេចក្តី ប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ប្រមាណមិនបាន មានអារម្មណ៍ ប្រមាណមិនបាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជា កុសល ។

## ភារៈ ៨ ដទៃទៀត ចប់

[ ១៨៧ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បី ទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជា រូបប្រមាណមិនបាន មានពណ៌ល្អ មានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំង

នោះហើយ គិតថា អាត្មាអញទីងជីង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបប្រមាណមិនបាន មានពណ៌ល្អ មានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញទីងជីង ឃើញ ដូច្នេះ បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

### នេះក៏ជាវារៈ ៨ ដែរ

[ ១៨៨ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា ខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញទីងជីង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។

បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា លឿង មានពន្លឺលឿង ។បេ។ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុល ប្រាប់ថាក្រហម មានពន្លឺក្រហម ។បេ។ ជារូប**ស** មានពណ៌ស ជាទីចង្អុល ប្រាប់ថា**ស** មានពន្លឺ**ស** គ្របសង្កត់នូវរូបទាំងនោះហើយ គិតថា អាត្មាអញ ដឹងដឹង ឃើញ ដូច្នេះ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់ បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្ដី មិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

**នេះជាអភិភាយតនៈ មានវារៈ ១៦**

# អដ្ឋកថា

## អភិភាយតនៈ

[ ១៧៨-១៨៨ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងរូបាវចរកុសល ក្នុងកសិណ ៨ ដោយអាការយ៉ាងនេះហើយ ព្រោះរូបាវចរកុសល ពោល គឺអភិភាយតនៈ សូម្បីដទៃទៀត រមែងប្រព្រឹត្តទៅក្នុងកសិណទាំង ៨ នេះ ហេតុដែលភាវនាជាភាវៈដែលមិនដូចគ្នាក្នុងអារម្មណ៍ដែលដូចគ្នា ហេតុនោះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងរូបាវចរកុសលនោះ ទើបទ្រង់ផ្តើមពាក្យថា **កតមេ ធម្មា កុសលា** ដូច្នេះទៀត ។ បណ្តាបទទាំងនោះ បទថា **អជ្ឈត្តំ អរូបសញ្ញី** សេចក្តីថា វៀរបរិកម្មសញ្ញាក្នុងអជ្ឈត្តិករូប ព្រោះការមិនបានអជ្ឈត្តិករូប ឬថា ព្រោះមិនមានសេចក្តីត្រូវការអជ្ឈត្តិករូប ។ បទថា **ពហិទ្ធា រូបានិ បស្សតិ** សេចក្តីថា រមែងឃើញរូបក្នុងកសិណ ៨ ខាងក្រៅទាំងនោះដោយអំណាចបរិកម្ម និងអំណាចនៃអប្បនា ព្រោះធ្វើបរិកម្មក្នុងកសិណ ៨ ខាងក្រៅ ។ បទថា **បរិត្តានិ** បានដល់ មានអារម្មណ៍ពង្រីកមិនបាន ។ បទថា **តានិ អភិភុយ្យ** សេចក្តីថា បុគ្គលដែលមានញាណដ៏ក្រៃលែងដែលមានញាណបរិសុទ្ធ គិតថា ការចូលសមាបត្តិក្នុងអារម្មណ៍តូចនេះ មិនជាការថ្មី ការចូលសមាបត្តិនេះ មិនមែនលំបាកសម្រាប់អញ ដូច្នេះ ទើបគ្របសង្កត់រូបទាំងនោះ ហើយចូលសមាបត្តិ ព្រោះហេតុនោះ ទើបរូបធម៌នេះមិនមែនភារៈរបស់យើង ដូច្នេះ គឺញុំាងអប្បនាឲ្យកើតឡើង ក្នុងឈាននេះព្រមជាមួយនឹងការធ្វើនិមិត្តកើតឡើងនោះឯង ប្រៀបដូចបុគ្គលដែលល្មោភបរិភោគអាហារដែលបរិបូណ៌ បានបាយត្រឹមតែមួយស្លាបព្រា ក៏គិតថា ការ

បរិភោគបាយត្រឹមតែមួយស្លាបព្រានេះ តើលំបាកអ្វី ទើបប្រមូលមកបរិភោគត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ។ ឯបុព្វភាគរបស់ឈាននោះ លោកពោលដោយបទនេះថា **ជាឆាមិ បសហ្ហាមិ** តែលោកពោលក្នុងអដ្ឋកថា ដែលជាទីមកទាំងឡាយថា លោកពោលដល់ការបង់ចិត្តចំពោះឈាននោះ ដោយបទថា **ជាឆាមិ បសហ្ហាមិ** នេះ ។ ការបង់ចិត្តនោះ រមែងមានដល់ព្រះយោគាវចរ ដែលចេញអំពីសមាបត្តិហើយ មិនមែនមានក្នុងខាងក្នុងសមាបត្តិ ។ បទថា **អប្បមាណភាឆិ** បានដល់ មានអារម្មណ៍ធំដែលពង្រីកបាន ។

ក្នុងបទថា **អភិភុយ្យ** នេះ មានអធិប្បាយថា បុគ្គលដែលមានញាណដ៏ក្រៃលែង ជាអ្នកមានញាណបរិសុទ្ធ គិតថា ការចូលសមាបត្តិក្នុងអារម្មណ៍នេះ នឹងមានប្រយោជន៍អ្វី អារម្មណ៍នេះមិនជាអារម្មណ៍ធំ ការធ្វើចិត្តឲ្យតាំងមាំ មិនមែនជារបស់លំបាកសម្រាប់អញទេ ដូច្នេះ ទើបគ្របសង្កត់អារម្មណ៍នោះ ហើយចូលសមាបត្តិ គឺញុំាំងអប្បនាឲ្យកើតឡើង ក្នុងឈាននេះ មួយអន្ទើដោយការធ្វើនិមិត្តកើតឡើងនោះឯង ដូចបុរសដែលឃ្លានកស៊ី បានបាយដែលគេជូសឲ្យមួង ក៏គិតថា ចំណែកដទៃៗ នៅមានទៀត មួយចំណែកនឹងធ្វើអ្វីដល់អញបាន ដូច្នេះ ទើបមិនឃើញកត្តចំណែកនោះថាច្រើន ។

ក្នុងពាក្យថា **មានប្រមាណតូច មានអារម្មណ៍ដ៏តូច មានប្រមាណមិនបាន មានអារម្មណ៍ដ៏តូច** នេះ ទ្រង់មិនបានកាន់យកភាពជាអារម្មណ៍បរិបូណ៌ ព្រោះបានត្រាស់មកហើយថា មានប្រមាណតូច ។ ចំណែកក្នុងន័យទីពីរ ទ្រង់មិនបានកាន់យកភាពជាអារម្មណ៍តូច ព្រោះបានត្រាស់មកខាង

ដើមហើយថា **មានប្រមាណមិនបាន** ។ ពាក្យនេះ បានពោលហើយ ក្នុងអដ្ឋកថា តែក្នុងទីនេះ ទ្រង់មិនបានកាន់យកអារម្មណ៍នីមួយៗ ៤ យ៉ាង តែទ្រង់កាន់យកនីមួយៗ ២ យ៉ាងប៉ុណ្ណោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកាលកាន់យកអារម្មណ៍ ៤ យ៉ាង ទេសនា ក៏ជា ១៦ យ៉ាង ទេសនា ១៦ យ៉ាង ក៏នឹងជាទេសនាដែលព្រះសាស្តាត្រាស់ដោយទូលំទូលាយ ដូចព្រោះគ្រាប់ល្ងលើកនេ្តលផែង ក្នុងទីនេះ ព្រះអង្គមានអធ្យាស្រ័យ ដើម្បីទ្រង់ធ្វើទេសនាត្រឹមតែ ៨ យ៉ាង ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះអង្គទ្រង់កាន់យកអារម្មណ៍នីមួយៗ ២ យ៉ាងប៉ុណ្ណោះ ។

បទថា **សុវណ្ណទុព្វណ្ណានិ** សេចក្តីថា មានពណ៌បរិសុទ្ធ ឬមិនបរិសុទ្ធមែនពិត ក្នុងពាក្យនេះ រូបារម្មណ៍មានពណ៌ខៀវជាដើម ដែលបរិសុទ្ធ ទ្រង់បំណងយកថាពណ៌ល្អ និងរូបារម្មណ៍ដែលមានពណ៌មិនបរិសុទ្ធ ទ្រង់បំណងយកថាពណ៌មិនស្អាត ។ ចំណែកក្នុងអដ្ឋកថា ដែលជាទីមកទាំងឡាយ ពោលថា ព្រះមានព្រះភាគ ទ្រង់សម្តែងអភិភាយតនៈទាំងនេះដែលពណ៌ល្អ ឬមានពណ៌មិនល្អ ដោយអំណាចរូបដែលតូច ឬដែលមិនមានប្រមាណប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងអភិភាយតនៈទាំង ៤ នេះ អភិភាយតនៈដែលជារូបតូចសមគួរដល់បុគ្គលដែលមានវិតក្កចរិត អភិភាយតនៈដែលជារូបមិនមានប្រមាណ សមគួរដល់បុគ្គលដែលមានមោហចរិត អភិភាយតនៈ ដែលមានពណ៌ល្អ សមគួរដល់បុគ្គលដែលមានទោសចរិត អភិភាយតនៈ ដែលមានពណ៌មិនល្អ សមគួរដល់បុគ្គលដែលមានរាគចរិត ព្រោះអារម្មណ៍ទាំងនេះ

ជាសប្បាយ ដល់បុគ្គលទាំងនោះ ។ និងការដែលអារម្មណ៍ទាំងនោះ ជាសប្បាយដល់បុគ្គលទាំងនោះ ខ្ញុំបានពោលក្នុងចរិតនិទ្ទេស ក្នុងវិសុទ្ធិមគ្គដោយពិស្តារហើយ ។

សួរថា ព្រោះហេតុអ្វី ទើបក្នុងព្រះអភិធម្មនេះមិនត្រាស់ដូចដែលត្រាស់ក្នុងព្រះសូត្រដែលមានពាក្យជាដើមថា បុគ្គលពួក ១ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណតិច ដូច្នេះ តែត្រាស់ភាពដែលបុគ្គលមិនមានបរិកម្មសញ្ញាក្នុងរូបខាងក្នុង ក្នុងអភិភាយតនៈទាំង ៤ ទៅវិញ ឆ្លើយថា ព្រោះរូបខាងក្នុង មិនជាទីតាំងនៃការគ្របសង្កត់ ។ ពិតហើយ ក្នុងព្រះសូត្រនោះ ឬក្នុងព្រះអភិធម្មនេះ ត្រាស់ពាក្យជាដើមថា ឃើញរូបខាងក្រៅ ដែលមានប្រមាណតូច រូបខាងក្រៅនុ៎ះឯង ព្រះយោគាវចរគ្របសង្កត់បាន ព្រោះហេតុនោះ រូបខាងក្រៅទាំងនោះ គប្បីពោលដល់ដោយពិតប្រាកដ ហេតុនោះ ទើបត្រាស់ក្នុងព្រះសូត្រខ្លះ ក្នុងព្រះអភិធម្មខ្លះ ។

បទថា **អជ្ឈត្តំ អរូបសញ្ញី** នេះ ត្រឹមតែជាលម្អនៃទេសនារបស់ព្រះសាស្តាប៉ុណ្ណោះ ។ នេះជាការពណ៌នាតាមលំដាប់បទ ក្នុងអភិភាយតនៈទាំង ៤ ។ ចំណែកក្នុងអភិភាយតនៈនេះ គប្បីជ្រាបការផ្សេងគ្នានៃបដិបទា ក្នុងសុទ្ធិកន័យ ក្នុងអភិភាយតនៈនីមួយៗ ដោយន័យដែលពោលក្នុងបឋវីកសិណនុ៎ះឯង ។ ត្រឹមតែក្នុងបឋវីកសិណនោះ មានអារម្មណ៍ ៤ យ៉ាង ក្នុងអភិភាយតនៈនេះ មានអារម្មណ៍ ២ យ៉ាង និងក្នុងបឋវីកសិណនោះ សម្តែងឈាន ១៦ យ៉ាង ក្នុងអភិភាយតនៈនេះ សម្តែង ៨ យ៉ាង

សេចក្តីដ៏សេសដូចគ្នានុ៎ះឯង ។ ដោយប្រការដូច្នេះ បណ្តាអភិភាយតនៈទាំង ៤ នេះ អភិភាយតនៈនីមួយៗ មាននវកៈ ១៥ គឺសុទ្ធិកនវកៈ ១ បដិ-បទានវកៈ ៤ អារម្មណនវកៈ ២ នវកៈដែលមានអារម្មណ៍ជាមួយនឹងបដិបទាលាយគ្នា ៨ គប្បីជ្រាបថា ក្នុងអភិភាយតនៈ សូម្បីទាំង ៤ រួមជានវកៈ ៦០ ល្មម ។

បទថា **នីលានិ** ក្នុងអភិភាយតនៈទី ៥ ជាដើម ត្រាស់ដោយរួមនវកៈទាំងអស់ ។ បទថា **នីលវណ្ណានិ** នេះ ត្រាស់ដោយអំណាចពណ៌ ។ បទថា **នីលនិទស្សនានិ** ត្រាស់ដោយអំណាចការប្រៀបធៀប មានអធិប្បាយថា ខៀវមិនមានមន្ទិលប្រាកដ ខៀវមិនលាយឡំ ជាពណ៌ខៀវសុទ្ធនោះឯង ។ បទថា **នីលនិភាសានិ** នេះ ត្រាស់ដោយអំណាចនៃពន្លឺ អធិប្បាយថា ពន្លឺពណ៌ខៀវ ជាការប្រកបដោយរស្មីខៀវ ។ ដោយពាក្យថា រស្មីខៀវនេះ ព្រះមានព្រះភាគ សម្តែងដល់ភាពដែលរូបទាំងនោះ ជារូបបរិសុទ្ធល្អហើយ ព្រោះហេតុនោះ ទើបត្រាស់អភិភាយតនៈទាំង ៤ នេះ ដោយអំណាចពណ៌ដែលបរិសុទ្ធល្អហើយនុ៎ះឯង ។ សូម្បីក្នុងពាក្យជាដើមថា **បីតានិ** ក៏គប្បីជ្រាបសេចក្តីដោយន័យនេះ ។ ការធ្វើកសិណក្តី ការបរិ-កម្មក្តី ការកំណត់អប្បនាក្តី ក្នុងនីលកសិណនេះ ដែលមានពាក្យជាដើមថា

ព្រះយោគាវចរឡើងកាន់នីលកសិណ រមែងកាន់យកនិមិត្តក្នុងផ្កាឈើ ឬក្នុងសំពត់ ឬក្នុងវណ្ណធាតុដែលមានពណ៌ខៀវ សេចក្ដីទាំងអស់នេះ ខ្ញុំពោលដោយពិស្ដារ ក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។ ក្នុងអភិភាយតនៈនីមួយៗ ក្នុងនីលកសិណនេះ គប្បីជ្រាបនវកៈ ២៥ ដូចក្នុងបឋវីកសិណ ។

**អភិភាយតនកថា ចប់**

# អភិធម្មបិដក

## វិមោក្ខ ៣

[ ១៨៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បាននូវរូបជ្ឈាន ឃើញនូវពួករូប បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ បានស្ងាត់ចាកកាមទាំងឡាយហើយ ។បេ។ បានដល់បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព មានចិត្តត្រាច់ចុះកាន់អារម្មណ៍ល្អ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ ជាកុសល ។បេ។

**នេះវិមោក្ខ ៣ មានវារៈ ១៦**

# អដ្ឋកថា

## វិមោក្ខ ៣

[ ១៨៩ ] ធម្មតា រូបាវចរកុសលនេះ រមែងកើតឡើងដោយអំណាចអភិភាយតនៈ ព្រោះគ្របសង្កត់អាយតនៈ គឺអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះក៏ទេ ដោយពិត រូបាវចរកុសលនេះ រមែងកើតឡើងដោយអំណាចនៃវិមោក្ខផង ព្រោះហេតុនោះ ឥឡូវនេះ ដើម្បីសម្ដែងន័យនោះ ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា **កតមេ ធម្មា កុសលា** ដូច្នេះទៀត ។

សួរថា ធម៌ គឺវិមោក្ខនេះ បណ្ឌិតគប្បីជ្រាបបានដោយអត្ថដូចម្ដេច ។ ឆ្លើយថា គប្បីជ្រាបបានដោយអត្ថថា រួចផុត ។ អ្វី ឈ្មោះថា ដោយអត្ថថា **រួចផុត**នេះ ។ អត្ថថា **រួចផុត** នេះ ជាការរួចផុតយ៉ាងល្អអំពីបច្ចនិកធម៌ទាំងឡាយ និងជាការរួចផុតយ៉ាងល្អ ដោយអំណាចនៃសេចក្ដីត្រេកអរក្រៃលែងក្នុងអារម្មណ៍ មានអធិប្បាយថា ធម៌ គឺវិមោក្ខនេះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយការមិនប្រកាន់ព្រោះមិនសង្ស័យ ដូចទារកសណ្ដូកអវយវៈតូចធំលើភ្លៅរបស់បិតា ។

ដើម្បីទ្រង់សម្ដែងរូបាវចរកុសល ដែលដល់នូវភាពជាវិមោក្ខ មានលក្ខណៈយ៉ាងនេះ ទើបទ្រង់ផ្ដើមន័យនេះតទៅ

បណ្ដាបទទាំងនោះ បទថា **រូបី** មានវិគ្គហៈថា ដែលឈ្មោះថា **រូបី** ព្រោះអត្ថថា រូបរបស់បុគ្គលនោះមាន គឺរូបជ្ឈានដែលឲ្យកើតឡើងក្នុងកោដ្ឋាសៈ មានសក់ជាដើមក្នុងខាងក្នុង ។ ពិតហើយ ព្រះយោគាវចរ កាលធ្វើបរិកម្មនីលកសិណក្នុងខាងក្នុង រមែងធ្វើត្រង់សក់ ត្រង់ទឹកប្រមាត់ ឬ

ត្រង់កែវភ្នែក កាលនឹងធ្វើបរិកម្មបីតកសិណ រមែងធ្វើត្រង់ខ្ទាញ់ខាប់ ត្រង់សម្បុរស្បែក ត្រង់បាតដៃបាតជើង ឬត្រង់ភ្នែកដែលមានពណ៌លឿង កាលនឹងធ្វើបរិកម្មលោហិតកសិណ ក៏រមែងធ្វើត្រង់សាច់ ត្រង់ឈាម ត្រង់អណ្តាត ត្រង់បាតដៃបាតជើង ឬត្រង់ពណ៌ក្រហមនៃកែវភ្នែក កាលនឹងធ្វើបរិកម្មឱទាតកសិណ ក៏រមែងធ្វើត្រង់ឆ្អឹង ត្រង់ធ្មេញ ត្រង់ក្រចក ឬត្រង់ពណ៌ស របស់ភ្នែក ។ បទថា **រូបី** នេះ ព្រះមានព្រះភាគ ត្រាស់សំដៅយកបុគ្គលដែលដល់ព្រមដោយឈានដែលកើតឡើង ព្រោះធ្វើបរិកម្មដោយអាការយ៉ាងនេះ ។

បទថា **រូបានិ បស្សតិ** បានដល់ រមែងឃើញរូប មាននីលកសិណជាដើម សូម្បីខាងក្រៅដោយឈានចក្ខុ ។ ដោយពាក្យថា **រូបានិ បស្សតិ** នេះ ទ្រង់សម្តែងការបានឈាន ក្នុងកសិណវត្ថុទាំងក្នុងខាងក្នុង ទាំងខាងក្រៅ ។

បទថា **អជ្ឈត្តំ អរូបសញ្ញី** សេចក្តីថា មិនមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុង អធិប្បាយថា បុគ្គលនោះមិនមានរូបាវចរជ្ឈានដែលឲ្យកើតឡើងក្នុងកោដ្ឋាសៈទាំងឡាយ មានសក់ជាដើមរបស់ខ្លួន ។ ដោយពាក្យថា **អជ្ឈត្តំ អរូបសញ្ញី** នេះ ទ្រង់សម្តែងដល់ភាពដែលព្រះយោគាវចរ បានឈានក្នុងអារម្មណ៍ខាងក្រៅ ព្រោះធ្វើបរិកម្មក្នុងវត្ថុខាងក្រៅ ។ ដោយបទថា **សុភំ** នេះ ទ្រង់សម្តែងឈានទាំងឡាយ ក្នុងវណ្ណកសិណ មានពណ៌ខៀវជាដើមដែលបរិសុទ្ធល្អហើយ ។ បណ្តាឈានដែលប្រព្រឹត្តទៅ ក្នុងវណ្ណកសិណ

ទាំងនោះ ការចងចិត្តថា **សុភ** មិនមានក្នុងខាងក្នុងអប្បនាក៏ពិត តែព្រះយោគាវចរណា ធ្វើសុភកសិណដែលបរិសុទ្ធល្អហើយឲ្យជាអារម្មណ៍ ព្រះយោគាវចរនោះ ព្រោះចងចិត្តនៅក្នុងវណ្ណកសិណថា សុភ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ សម្រេចបឋមជ្ឈាន ។បេ។ ទុតិយជ្ឈានជាដើមក៏ដូចគ្នា ព្រោះហេតុនោះ ទើបទ្រង់ធ្វើទេសនាយ៉ាងនេះ ។ តែក្នុងបដិសម្ភិទាមគ្គ ពោលថា សភាវធម៌ដែលឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា បង្អោនទៅក្នុងអារម្មណ៍ថា សុភ ដូចម្ដេច ភិក្ខុក្នុងធម្មវិន័យនេះ មានចិត្តសហគតៈដោយមេត្តា ផ្សាយទៅកាន់ទិសមួយ ។បេ។ សត្វទាំងឡាយ រមែងជាអ្នកមិនគួររង្កៀស ព្រោះភិក្ខុនោះចម្រើនមេត្តា ភិក្ខុមានចិត្តសហគតៈដោយករុណា ... មុទិតា ... ឧបេក្ខា ផ្សាយទៅកាន់ទិសមួយ ។បេ។ សត្វទាំងឡាយ រមែងជាអ្នកមិនគួររង្កៀស ព្រោះភិក្ខុនោះចម្រើនឧបេក្ខា សភាវធម៌ដែលឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា បង្អោនទៅក្នុងអារម្មណ៍ថា សុភ ដោយប្រការដូច្នេះ តែក្នុងព្រះអភិធម្មនេះ ទ្រង់បដិសេធន័យនោះ ព្រោះព្រហ្មវិហារមកហើយក្នុងព្រះបាលីខាងមុខទុំះឯង ហើយទ្រង់អនុញ្ញាតសុភវិមោក្ខ ដោយអំណាចនីលកសិណដែលល្អ បីតកសិណដែលល្អ លោហិតកសិណដែលល្អ ឱទាតកសិណដែលល្អ នីលកសិណដែលបរិសុទ្ធ បីតកសិណដែលបរិសុទ្ធ លោហិតកសិណដែលបរិសុទ្ធ ឱទាតកសិណដែលបរិសុទ្ធប៉ុណ្ណោះ ។ ពាក្យថា **កសិណ** ឬពាក្យថា **អភិភាយតនៈ** ឬពាក្យថា **វិមោក្ខ** ក៏គឺរូបាវចរជ្ឈានទុំះឯង ។ ពិតហើយ រូបាវចរជ្ឈាននោះ ត្រាស់

ថា ឈ្មោះថា **កសិណ** ព្រោះអត្ថថា ទូទៅដល់អារម្មណ៍ ឈ្មោះថា **អភិ-ភាយតនៈ** ព្រោះអត្ថថា គ្របសង្កត់អារម្មណ៍ ឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា បង្អោនចិត្តទៅក្នុងអារម្មណ៍ និងព្រោះអត្ថថា រួចផុតចាកធម៌ដែលជាសត្រូវទាំងឡាយ បណ្ដាកសិណ អភិភាយតនៈ និងវិមោក្ខទាំងនោះ ការសម្ដែងកសិណ គប្បីជ្រាបថា ត្រាស់ដោយអំណាចព្រះអភិធម្ម ចំណែកការសម្ដែង ២ យ៉ាងក្រៅអំពីនេះ ត្រាស់ដោយអំណាចការសម្ដែងក្នុងព្រះសូត្រ ។ នេះជាការពណ៌នាបទ តាមលំដាប់ក្នុងវិមោក្ខនេះ តែវិមោក្ខនីមួយៗ គប្បីជ្រាបនវកន័យ ៧៥ ពួក ដោយធ្វើជាមួយមាតិកា ២៥ ដូចបឋវីកសិណ ។

**វិមោក្ខ ចប់**

# អភិធម្មបិដក

## ព្រហ្មវិហារជ្ឈាន ៤

[ ១៩០ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានប្រកបដោយមេត្តា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ បានដល់ទុតិយជ្ឈានប្រកបដោយមេត្តា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព ប្រាសចាកបីតិ ។បេ។ បានដល់តតិយជ្ឈាន ប្រកបដោយមេត្តាក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានដល់ទុតិយជ្ឈាន គ្មានវិតក្ក មានត្រឹមតែវិចារ មានបីតិ

និងសុខកើតពីសមាធិ ជាឈានប្រកបដោយមេត្តា ក្នុងសម័យណា ផស្សៈ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ បានដល់តតិយជ្ឈាន ប្រកបដោយមេត្តាក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព ប្រាសចាកបីតិផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយមេត្តាក្នុងសម័យណា ផស្សៈ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ប្រកបដោយករុណា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្កនិងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយករុណា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន

ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានលះសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខាក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## ព្រហ្មវិហារជ្ឈានទាំង ៤ មានវារៈ ១៦ ចប់

# អដ្ឋកថា

## ព្រហ្មវិហារជ្ឈាន

[ ១៩០ ] ឥឡូវនេះ ដើម្បីសម្តែងរូបាវចរកុសល ដែលប្រព្រឹត្តទៅដោយអំណាចព្រហ្មវិហារ មានមេត្តាជាដើម ទើបព្រះមានព្រះភាគ ផ្តើមពាក្យជាដើមថា **កតមេ ធម្មា កុសលា** ដូច្នេះទៀត ។ បណ្តាបទទាំងនោះ បទថា **មេត្តាសហគតំ** បានដល់ ប្រកបដោយមេត្តា ។ សូម្បីក្នុងបទថា **ករុណា-សហគតំ** ជាដើមខាងមុខ ក៏ន័យនេះដូចគ្នា ។ ព្រះយោគាវចរនោះ បដិបត្តិហើយដោយវិធីណា ទើបចូលដល់ឈានដែលសហគតៈដោយមេត្តាជាដើម វិធីចម្រើនមេត្តាជាដើមនោះ ខ្ញុំឲ្យពិស្តារក្នុងវិសុទ្ធិមគ្គហើយ ចំណែកសេចក្តីក្នុងព្រះបាលីដ៏សេស គប្បីជ្រាបដោយន័យដែលពោលក្នុងបឋវីកសិណនុ៎ះឯង ។ តែក្នុងបឋវីកសិណ បានធម៌ពួក ៩ រួម ២៥ ន័យ ។ ក្នុងព្រហ្មវិហារនេះ ក្នុងព្រហ្មវិហារ ៣ ខាងដើម បានធម៌ពួក ៧ រួម ២៥ ន័យ ដោយអំណាចតិកជ្ឈាន និងចតុក្កជ្ឈានជាដើម ក្នុងឧបេក្ខា បានធម៌ពួកមួយ រួម ២៥ ន័យ ដោយអំណាចនៃឈានទី ៤ ម្យ៉ាងទៀត ក្នុងករុណា និងមុទិតា រមែងបានយេវាបនកធម៌ទាំងនេះ គឺករុណា និងមុទិតា និងធម៌ ៤ មានឆន្ទៈជាដើម[១] ។

មួយទៀត ភាពជាទុក្ខាបដិបទាជាដើម ក្នុងព្រហ្មវិហារនេះ គប្បីជ្រាបដោយអំណាចការសង្កត់ព្យាបាទដោយមេត្តា ការសង្កត់វិហឹសាដោយករុណា

---

១- ធម៌ ៤ គឺឆន្ទៈ អធិមោក្ខ មនសិការ តត្រមជ្ឈត្តតា ដែលមានសម្តែងខាងដើមហើយ ។

ការសង្កត់អរតិដោយមុទិតា ការសង្កត់រាគៈ និងបដិឃៈដោយឧបេក្ខា មុន នោះឯង ។ ចំណែកសេចក្ដីដែលប្លែកគ្នា មានដូច្នេះថា ភាពជាបរិត្តារម្មណ៍ រមែងមិនមានដោយអំណាចនៃសត្វជាច្រើនជាអារម្មណ៍ ចំណែកភាពជាអប្បមាណារម្មណ៍ រមែងមានដោយអំណាចមានសត្វច្រើនជាអារម្មណ៍ ដូច្នេះ ។ ពាក្យដ៏សេសដូចគ្នានោះឯង ។

បណ្ឌិតជ្រាបព្រហ្មវិហារទាំងនេះ ដែលព្រះមានព្រះភាគ ទ្រង់ជាព្រហ្មដ៏ប្រសើរបំផុត ត្រាស់ហើយ ដោយអំណាចនៃព្រះបាលីយ៉ាងនេះជាមុនហើយ គប្បីជ្រាបបកិណ្ណកកថានេះ ក្នុងព្រហ្មវិហារជ្ឈានទាំងនេះ ឲ្យក្រៃលែងឡើង ដូច្នេះ ។

ពិតហើយ បណ្ដាព្រហ្មវិហារ គឺមេត្តាករុណា មុទិតា និងឧបេក្ខាទាំងនោះ ពោលដោយអត្ថ ធម៌ដែលឈ្មោះថា **មេត្តា** ព្រោះអត្ថថា អាណិត គឺស្នេហា ។ម្យ៉ាងទៀត ដែលឈ្មោះថា **មេត្តា** ព្រោះអត្ថថា ធម៌នេះ មានក្នុងមិត្ត ឬប្រព្រឹត្តទៅដើម្បីមិត្ត ។ ធម៌ដែលឈ្មោះថា **ករុណា** ព្រោះអត្ថថា រមែងធ្វើហឫទ័យរបស់សាធុជនទាំងឡាយឲ្យញាប់ញ័រ ក្នុងកាលអ្នកដទៃមានទុក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា **ករុណា** ព្រោះអត្ថថា រមែងកម្ចាត់ ឬបៀតបៀន គឺញ៉ាំងទុក្ខរបស់អ្នកដទៃឲ្យវិនាស ។ ម្យ៉ាងទៀត ឈ្មោះថា **ករុណា** ព្រោះអត្ថថា ជាហេតុឲ្យខ្ចាត់ខ្ចាយទៅ ឲ្យចេញទៅ ដោយការផ្សាយទៅក្នុងសត្វដែលមានទុក្ខ ។ ធម៌ដែលឈ្មោះថា **មុទិតា** ព្រោះអត្ថថា ជាគ្រឿងត្រេកអររបស់អ្នកព្រមព្រៀងដោយមុទិតានោះ ឬរមែងត្រេកអរ

ឯង ឬថា ត្រឹមតែជាសេចក្តីត្រេកអរប៉ុណ្ណោះ ។ ធម៌ដែលឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា ក្រឡេកមើលការលះសេចក្តីព្យាបាទជាដើមថា សូមសត្វទាំងឡាយ កុំបីមានពៀរ ដូច្នេះ និងដោយការចូលដល់ភាពជាកណ្តាល ។

មួយទៀត ក្នុងព្រហ្មវិហារទាំងនេះ ពោលដោយលក្ខណៈជាដើម គប្បីជ្រាបថា មេត្តា **ហិតាការប្បវត្តិលក្ខណា** មានការប្រព្រឹត្តិទៅនៃអាការដែលជាប្រយោជន៍ជាលក្ខណៈ **ហិតូបសំហាររសា** មានការបង្អោនចូលទៅនូវប្រយោជន៍ជាកិច្ច **អាឃាតវិនយបច្ចុប្បដ្ឋានា** មានការកម្ចាត់អាឃាតជាអាការប្រាកដ **សត្តានំ មនាបភាវទស្សនបទដ្ឋានា** មានការសម្លឹងមើលតែវត្ថុដែលគួរពេញចិត្តរបស់សត្វជាហេតុជិត មេត្តានេះ មានការស្ងប់ព្យាបាទជាសម្បត្តិ មានការកើតឡើងនៃស្នេហាជាវិបត្តិ ។

ករុណា **ទុក្ខាបនយនាការប្បវត្តិលក្ខណា** មានការប្រព្រឹត្តិទៅនៃអាការជួយបំបាត់ទុក្ខជាលក្ខណៈ **បរទុក្ខាសហនរសា** មានការអត់ធន់មិនបានចំពោះសេចក្តីទុក្ខរបស់អ្នកដទៃជាកិច្ច **អវិហឹសាបច្ចុប្បដ្ឋានា** មានការមិនបៀតបៀន ជាអាការប្រាកដ **ទុក្ខាភិភូតានំ អនាថភាវទស្សនបទដ្ឋានា** មានការឃើញសត្វដែលត្រូវទុក្ខគ្របសង្កត់ហើយ ជាអ្នកមិនមានទីពឹងជាហេតុជិត ករុណានេះ មានសេចក្តីស្ងប់ចាកការបៀតបៀនជាសម្បត្តិ មានការកើតឡើងនៃសេចក្តីសោកជាវិបត្តិ ។

មុទិតា **សត្តេសុ បមោទនលក្ខណា** មានការត្រេកអរក្នុងសត្វទាំងឡាយជាលក្ខណៈ **អនិស្សាយនរសា** មានការមិនច្រណែនជាកិច្ច **អរតិ-**

**វិឃាតបច្ចុប្បដ្ឋានា** មានការកម្ចាត់ការមិនត្រេកអរជាអាការប្រាកដ **សត្តានំ សម្បត្តិទស្សនបទដ្ឋានា** មានការឃើញសម្បត្តិរបស់សត្វទាំងឡាយ ជាហេតុជិត មុទិតានេះ មានការស្ងប់ការមិនត្រេកអរជាសម្បត្តិ មានការកើតឡើងនៃសេចក្តីត្រេកអរជាវិបត្តិ ។

ឧបេក្ខា **សត្តេសុ មជ្ឈត្តាការប្បវត្តិលក្ខណា** មានការប្រព្រឹត្តិទៅដោយអាការជាកណ្តាលក្នុងសត្វទាំងឡាយជាលក្ខណៈ **សត្តេសុ សមភាវទស្សនរសា** មានការឃើញសត្វទាំងឡាយដោយភាពស្មើគ្នាជាកិច្ច **បដិឃានុនយវូបសមបច្ចុប្បដ្ឋានា** មានការចូលទៅស្ងប់សេចក្តីក្រោធ និងសេចក្តីស្រឡាញ់ជាអាការប្រាកដ **បវត្តកម្មស្សកតាទស្សនបទដ្ឋានា** មានការឃើញសត្វមានកម្មជារបស់ខ្លួនយ៉ាងនេះថា សត្វទាំងឡាយ មានកម្មជារបស់ខ្លួន សត្វទាំងនោះ នឹងមានសេចក្តីសុខ ឬនឹងផុតចាកទុក្ខ ឬនឹងមិនវិនាសចាកសម្បត្តិ តាមសេចក្តីពេញចិត្តរបស់នរណា ដូច្នេះ ជាបទដ្ឋាន ឧបេក្ខានោះ មានការស្ងប់សេចក្តីក្រោធ និងសេចក្តីស្រឡាញ់ជាសម្បត្តិ មានការកើតឡើងនៃអញ្ញាណុបេក្ខា ដែលអាស្រ័យផ្ទះជាវិបត្តិ ។

សេចក្តីសុខក្នុងវិបស្សនា និងភវសម្បត្តិ ជាសាធារណៈប្រយោជន៍របស់ព្រហ្មវិហារទាំង ៤ នោះ តែការកម្ចាត់ព្យាបាទជាដើម ជាប្រយោជន៍ចំពោះអង្គ ។ មែនពិត ក្នុងអភិធម្មនេះ មេត្តាមានការកម្ចាត់ព្យាបាទជាប្រយោជន៍ ព្រហ្មវិហារ ៣ ក្រៅនេះ មានការកម្ចាត់ការបៀតបៀន ការមិនត្រេកអរ និងរាគៈជាប្រយោជន៍ ។ សេចក្តីនេះ សមដូចពាក្យដែលលោកពោលទុក

( ក្នុងអង្គុត្តរនិកាយ ឆក្កនិបាត ) ថា ម្នាលអាវុសោ តាមដែលពិតនុ៎ះ គឺចេតោវិមុត្តិដែលប្រកបដោយមេត្តាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវព្យាបាទ ... ម្នាលអាវុសោ តាមតែពិតនុ៎ះ គឺចេតោវិមុត្តិដែលប្រកបដោយករុណាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវវិហេសា ... ម្នាលអាវុសោ តាមតែពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយមុទិតាហ្នឹងឯងជាធម៌រលាស់ចោលនូវអរតិ ... ម្នាលអាវុសោ តាមតែពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយឧបេក្ខាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវរាគៈ ដូច្នេះ ។

ក្នុងព្រហ្មវិហារទាំងនេះ ព្រហ្មវិហារនីមួយៗ មានធម៌ដែលជាសត្រូវ ២ ដោយអំណាចនៃភាពជាសត្រូវជិត និងឆ្ងាយ ។ ពិតហើយ មេត្តាព្រហ្មវិហារ មានរាគៈជាសត្រូវជិត ព្រោះឃើញថាជាគុណស្មើគ្នា ដូចសត្រូវដែលត្រាច់ទៅជិតគ្នារបស់បុរស ។ រាគៈនោះ រមែងបានឱកាសរហ័ស ព្រោះហេតុនោះ គប្បីរក្សាមេត្តាឲ្យល្អចាករាគៈនោះ ។ ព្យាបាទជាសត្រូវឆ្ងាយ ព្រោះជាវិសភាគៈចំពោះសភាគៈ ដូចសត្រូវរបស់បុរស ដែលអាស្រ័យនៅក្នុងទីញៀតស្បាត មានភ្នំជាដើម ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីផ្សាយមេត្តាចេញទៅដោយប្រាសចាកសេចក្ដីខ្លាច ចំពោះព្យាបាទនោះ ការដែលបុគ្គលផ្សាយមេត្តាផង សេចក្ដីក្រោធផងព្រមគ្នានុ៎ះ មិនមែនហេតុដែលប្រព្រឹត្តទៅបាន ។

ទោមនស្សអាស្រ័យផ្ទះដែល ត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ដោយន័យជាដើមថា បុគ្គលកាលឃើញច្បាស់នូវការមិនបាននូវរូប

ដែលគប្បីដឹងដោយភ្នែកជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្តប្រកបដោយលោកាមិសៈថា ជាការមិនបានក្តី កាលរឭកឃើញនូវរូបដែលខ្លួនធ្លាប់បាន[១] ក្នុងកាលមុនក្តី ដែលកន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតទោមនស្សឡើង ទោមនស្សណាមានសភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា គេហសិតទោមនស្ស ដូច្នេះ ។ ជាសត្រូវជិត របស់ករុណាព្រហ្មវិហារ ព្រោះឃើញវិបត្តិដូចគ្នា ការបៀតបៀនជាសត្រូវឆ្ងាយ ព្រោះជាវិសភាគៈចំពោះសភាគៈ ។ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីផ្សាយករុណាដោយប្រាសចាកការខ្លាចចំពោះការបៀតបៀននោះ ឈ្មោះថា បុគ្គលធ្វើករុណា និងការបៀតបៀនសត្វដោយការប្រហារដោយបាតដៃជាដើមព្រមគ្នា ទុំមិនមែនជាហេតុដែលប្រព្រឹត្តទៅបាន ។

សោមនស្សអាស្រ័យផ្ទះ ដែលត្រាស់ដោយន័យថា បុគ្គលកាលឃើញច្បាស់នូវការបានរូបដែលគប្បីដឹងដោយភ្នែកជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសៈ គឺតណ្ហា ថាជាការបានក្តី កាលរឭកឃើញ ( នូវរូប ) ដែលខ្លួនធ្លាប់បានហើយ ក្នុងកាលមុនដែលកន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតសេចក្តីសោមនស្សឡើង សោមនស្សណាមានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា គេហសិតសោមនស្ស ដូច្នេះជាដើម ។ ជាសត្រូវជិតរបស់

១- ព្រះត្រៃបិដកបាលីថា អប្បដិលទ្ធ ប្រែថា ដែលខ្លួនមិនធ្លាប់បាន តែបាលីក្នុងអដ្ឋកថាជា បដិលទ្ធ ដែលប្រែថា ដែលខ្លួនធ្លាប់បាន ក្នុងទីនេះ យើងកាន់យកតាមអដ្ឋកថា ។

មុទិតាព្រហ្មវិហារ ព្រោះឃើញថា ជាសម្បត្តិស្មើគ្នា អរតិជាសត្រូវឆ្ងាយ ព្រោះជាវិសភាគៈចំពោះសភាគៈ ព្រោះហេតុនោះ ព្រះយោគាវចរគប្បីចម្រើនមុទិតាទៅដោយប្រាសចាកសេចក្ដីខ្លាច ចំពោះអរតិនោះ ។ បុគ្គលឈ្មោះថា ជាអ្នកត្រេកអរ និងនឿយណាយក្នុងសេនាសនៈដ៏ស្ងាត់ និងក្នុងកុសលធម៌ដ៏ក្រៃលែងព្រមគ្នា នុ៎ះមិនមែនឋានៈដែលប្រព្រឹត្តទៅបាន ។

អញ្ញាណុបេក្ខា ដែលអាស្រ័យផ្ទះ ដែលត្រាស់ដោយន័យជាដើមថា បុថុជ្ជនជាបុគ្គលល្ងង់វង្វេង ឬបុថុជ្ជនដែលមិនទាន់ផ្ចាញ់កិលេសបានមិនទាន់ផ្ចាញ់វិបាកបាន ជាអ្នកឃើញថា មិនមានទោស ជាអ្នកមិនចេះដឹងពុទ្ធវចនៈឃើញរូបដោយភ្នែកហើយ ក៏កើតឧបេក្ខាឡើង ឧបេក្ខាណាមានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវរូបឡើយ ព្រោះហេតុនោះ ឧបេក្ខានោះតថាគតហៅថា គេហសិតឧបេក្ខា ដូច្នេះ ជាសត្រូវជិតរបស់ឧបេក្ខាព្រហ្មវិហារ ព្រោះជាធម៌ស្មើគ្នា ដោយអំណាចនៃការមិនពិចារណាដល់ទោស និងគុណ រាគៈ និងបដិឃៈ ជាសត្រូវឆ្ងាយ ព្រោះជាវិសភាគៈចំពោះសភាគៈ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីផ្សាយឧបេក្ខាទៅ ដោយប្រាសចាកសេចក្ដីខ្លាចចំពោះរាគៈ និងបដិឃៈនោះ ។ ដែលឈ្មោះថា បុគ្គលផ្សាយឧបេក្ខាទៅផងត្រេកអរផង ក្រោធផង ព្រមៗគ្នានោះ មិនមែនជាហេតុដែលប្រព្រឹត្តទៅបាន ។

មួយទៀត ឆន្ទៈដើម្បីនឹងធ្វើ ( កត្តុកម្យតាឆន្ទៈ ) ជាខាងដើម ការគ្របសង្កត់នីវរណៈជាដើម ជាកណ្ដាល អប្បនាជាខាងចុងរបស់ព្រហ្មវិហារ

ទាំងអស់នោះ សត្វមួយ ឬច្រើន ជាអារម្មណ៍របស់ព្រហ្មវិហារនោះ ដោយបញ្ញត្តិធម៌ អារម្មណ៍បញ្ញត្តិធម៌នោះ កាលដល់ឧបចារៈ ឬអប្បនាហើយ ទើបពង្រីកអារម្មណ៍បាន ។

ក្នុងអធិការពោលដោយព្រហ្មវិហារនោះ មានលំដាប់នៃការពង្រីកអារម្មណ៍ដូចតទៅនេះ ព្រះយោគាវចរគប្បីកំណត់អាវាសមួយមុនសិនហើយ គប្បីចម្រើនមេត្តាទៅក្នុងសត្វទាំងឡាយ ក្នុងអាវាសនោះដោយន័យថា សូមសត្វទាំងឡាយ ក្នុងអាវាសនេះ កុំបីមានពៀរចុះ ដូចអ្នកស្រែដែលឈ្លាសកំណត់ស្ថានទីដែលខ្លួនគប្បីភ្ជួរ ហើយទើបភ្ជួរ ដូច្នោះ ។ ព្រះយោគាវចរគប្បីធ្វើចិត្តឲ្យទន់ និងគួរដល់ការងារ ក្នុងអាវាសនោះហើយ គប្បីកំណត់អាវាស ២ កន្លែង បន្ទាប់ពីនោះ ក៏កំណត់អាវាស ៣ កន្លែង ៤ កន្លែង ៥ កន្លែង ៦ កន្លែង ៧ កន្លែង ៨ កន្លែង ៩ កន្លែង ១០ កន្លែង ច្រកមួយ ពាក់កណ្តាលស្រុក ស្រុកមួយ ជនបទមួយ រដ្ឋមួយ ទិសមួយ រហូតចក្កវាឡមួយ ឬក្រៃលែងជាងនោះ ហើយចម្រើនមេត្តាទៅក្នុងសត្វនោះៗ ករុណាព្រហ្មវិហារជាដើមក៏ដូចគ្នា នេះជាលំដាប់នៃការពង្រីកអារម្មណ៍ ក្នុងព្រហ្មវិហារ ៤ ដូច្នេះ ។

ក្នុងព្រហ្មវិហារទាំង ៤ នេះ ឧបេក្ខាព្រហ្មវិហារ ជាផលហូរចេញរបស់ព្រហ្មវិហារ ៣ ខាងដើម ដូចរូបសមាបត្តិ ជាផលហូរចេញរបស់កសិណទាំងឡាយ នេវសញ្ញានាសញ្ញាយតនៈ ជាផលហូរចេញរបស់អរូបសមាធិ ផលសមាបត្តិ ជាផលហូរចេញរបស់វិបស្សនា និរោធសមាបត្តិ ជាផលហូរ

ចេញនៃសមថៈ និងវិបស្សនា ។ ដូចបុគ្គលសាងផ្ទះ មិនទាន់លើកសសរទាំងឡាយឡើង មិនទាន់បានលើកធ្នឹម និងធ្មៀនក៏មិនអាចលើកមេដំបូល និងបន្តន់ក្នុងអាកាសបាន យ៉ាងណា ព្រះយោគាវចរ វៀរតតិយជ្ឈានដែលកើតឡើងក្នុងព្រហ្មវិហារ ៣ ខាងដើម ក៏មិនអាចចម្រើនចតុត្ថជ្ឈានបានយ៉ាងនោះ តែឧបេក្ខាព្រហ្មវិហារនេះ រមែងមិនកើតឡើង ដល់បុគ្គលដែលមានតតិយជ្ឈានកើតឡើងហើយក្នុងកសិណទាំងឡាយ ព្រោះជាអារម្មណ៍មានចំណែកមិនស្មើគ្នា ។

ក្នុងព្រហ្មវិហារទាំងនោះ បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបមេត្តាករុណា មុទិតា និងឧបេក្ខា ហៅថា ព្រហ្មវិហារ ។ ព្រោះហេតុអ្វី ទើបព្រហ្មវិហារមាន ៤ លំដាប់របស់ព្រហ្មវិហារទាំងនោះ មានដូចម្ដេច ព្រោះហេតុអ្វី ទើបក្នុងវិភង្គត្រាស់ហៅថា ជាអប្បមញ្ញា ។ ឆ្លើយថា ភាពជាព្រហ្មវិហារក្នុងធម៌ មានមេត្តាជាដើមទាំងនេះ គប្បីជ្រាបដោយអត្ថថា ប្រសើរ និងភាពជាធម៌មិនមានទោសមុន ។

មែនពិត ធម៌ទាំងនេះ ឈ្មោះថា ជាធម៌គ្រឿងនៅដ៏ប្រសើរ ព្រោះជាការបដិបត្តិដោយប្រពៃក្នុងសត្វទាំងឡាយ ព្រហ្មទាំងឡាយ មានចិត្តប្រាសចាកទោសយ៉ាងណា ព្រះយោគីទាំងឡាយដែលប្រកបដោយព្រហ្មវិហារទាំងនេះ រមែងជាអ្នកនៅស្មើជាមួយព្រហ្មយ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបត្រាស់ហៅធម៌ទាំងនោះថា ព្រហ្មវិហារ ព្រោះអត្ថថា ប្រសើរ និងភាពជាធម៌ប្រាសចាកទោស ។

ចំណែកបញ្ហាថា ព្រោះហេតុអ្វី ទើបព្រហ្មវិហារមាន ៤ ជាដើម មានវិស្សជ្ជនាដូចតទៅ

ព្រហ្មវិហារ ឈ្មោះថា មាន ៤ ព្រោះអំណាចនៃផ្លូវបរិសុទ្ធជាដើម មួយទៀត លំដាប់នៃព្រហ្មវិហារទាំងនោះ រមែងមានព្រោះអំណាចនៃអាការមានប្រយោជន៍ជាដើម និងព្រហ្មវិហារទាំងនោះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ មិនមានប្រមាណព្រោះហេតុនោះ ទើបហៅថា អប្បមញ្ញា ដូច្នេះ ។

ពិតហើយ បណ្ដាព្រហ្មវិហារទាំងនោះ មេត្តា ជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលច្រើនដោយព្យាបាទ ករុណាជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលច្រើនដោយវិហឹសា មុទិតាជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលច្រើនដោយអរតិ ឧបេក្ខាជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលច្រើនដោយរាគៈ ។

មួយទៀត មនសិការក្នុងសត្វទាំងឡាយរបស់ព្រហ្មវិហារ ក៏មាន ៤ យ៉ាងដុំះឯង គឺការបង្អោនទៅនូវប្រយោជន៍ ១ ការនាំចេញនូវវត្ថុដែលមិនជាប្រយោជន៍ ១ ការត្រេកអរតាមដោយសម្បត្តិរបស់អ្នកដទៃ ១ និងការមិនចងចិត្ត ១ ។

ដូចកូន ៤ នាក់ បណ្ដាកូន ៤ នាក់ ជាក្មេងម្នាក់ ជាអ្នកជំងឺម្នាក់ ជាកំលោះក្រមុំម្នាក់ និងកំពុងប្រកបកិច្ចទាំងពួងបានម្នាក់ មាតារមែងប្រាថ្នាឲ្យកូនតូចចម្រើនធំធាត់ឡើង មានសេចក្ដីប្រាថ្នាកម្ចាត់ជំងឺ របស់កូនដែលឈឺ មានសេចក្ដីប្រាថ្នាឲ្យកូនជាកំលោះក្រមុំ តាំងនៅក្នុងសម្បត្តិនៃភាពជាកំលោះ

ក្រមុំអស់កាលយូរ និងមិនបានខ្វល់ខ្វាយ ក្នុងការចាត់ចែងការងារណាមួយ ដល់កូនដែលប្រកបកិច្ចទាំងពួងបានហើយ យ៉ាងណា សូម្បីព្រះយោគាវចរ ដែលមានអប្បមញ្ញាជាគ្រឿងនៅក៏យ៉ាងនោះ គប្បីចម្រើនទៅដោយអំណាច នៃអប្បមញ្ញា មានមេត្តាជាដើម ក្នុងសត្វទាំងពួង ព្រោះហេតុនោះ ដោយ ហេតុនេះ ទើបអប្បមញ្ញាមាន ៤ យ៉ាង ព្រោះអំណាចនៃផ្លូវបរិសុទ្ធជាដើម ។

ព្រោះហេតុណា ព្រះយោគាវចរ ដែលប្រាថ្នាចម្រើនអប្បមញ្ញាទាំង ៤ នោះ គប្បីបដិបត្តិក្នុងសត្វទាំងឡាយ ដោយអំណាចនៃការប្រព្រឹត្តិទៅ ដោយ អាការដែលជាប្រយោជន៍មុន ដ្បិតថា មេត្តា មានការប្រព្រឹត្តិទៅនៃអាការ ជាប្រយោជន៍ដល់សត្វជាលក្ខណៈ បន្ទាប់ពីនោះ ក៏គប្បីបដិបត្តិក្នុងសត្វទាំង ឡាយ ដោយអំណាចការប្រព្រឹត្តិទៅនៃអាការដែលឃើញ ឬបានស្តាប់ ឬ កំណត់សត្វទាំងឡាយ ដែលខ្លួនប្រាថ្នានឹងធ្វើឧបការៈយ៉ាងនោះ បុគ្គលដែល មានសេចក្តីទុក្ខគ្របសង្កត់ ហើយជួយនាំទុក្ខចេញទៅ ដ្បិតថា ករុណាមាន ការប្រព្រឹត្តិទៅនៃអាការនាំទុក្ខចេញទៅជាលក្ខណៈ លំដាប់នោះ ក៏គប្បី បដិបត្តិក្នុងសត្វទាំងឡាយ ដោយអំណាចសេចក្តីត្រេកអរក្នុងសម្បត្តិ ព្រោះ ឃើញសម្បត្តិនៃសត្វទាំងនោះ ដែលខ្លួនប្រាថ្នាឧបការៈ ប្រាថ្នាឲ្យមានទុក្ខ ទៅប្រាសហើយយ៉ាងនោះ ដ្បិតថា មុទិតា មានការត្រេកអរជាលក្ខណៈ ។ ខាងមុខអំពីនោះ គប្បីបដិបត្តិក្នុងសត្វទាំងឡាយ ដោយអាការនៃភាពជា កណ្តាល ពោល គឺភាពជាអ្នកព្រងើយកន្តើយ ព្រោះការមិនមានកិច្ចដែល គប្បីធ្វើទៀត ដ្បិតថា ឧបេក្ខាមានការប្រព្រឹត្តិទៅនៃអាការនៃភាពជាកណ្តាល

ជាលក្ខណៈ ព្រោះហេតុនោះ គប្បីជ្រាបលំដាប់នេះ នៃអប្បមញ្ញាទាំងនោះថា ត្រាស់មេត្តាមុនគេ បន្ទាប់អំពីនោះ ត្រាស់ករុណា មុទិតា និងឧបេក្ខា ដូច្នេះ ព្រោះអំណាចនៃអាការមានប្រយោជន៍ជាដើម ។

អប្បមញ្ញាទាំងអស់នេះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍មិនមានប្រមាណ ដោយហេតុនោះ ទើបលោកពោលថា ពិតហើយ សត្វមិនមានប្រមាណជាអារម្មណ៍របស់អប្បមញ្ញាទាំងនេះ និងសូម្បីសម្រាប់សត្វមួយ អប្បមញ្ញាមិនកាន់យកប្រមាណយ៉ាងនេះថា ភាវនា មានមេត្តាជាដើម និងត្រូវចម្រើនក្នុងប៉ុណ្ណេះ តែប្រព្រឹត្តទៅដោយអំណាចការផ្សាយទូទៅទាំងឯង ព្រោះហេតុនោះ ទើបហៅថា **អប្បមញ្ញា** ។ ដោយហេតុនោះ ទើបខ្ញុំពោលថា

ព្រហ្មវិហារ ឈ្មោះថា មាន ៤ ព្រោះអំណាចនៃផ្លូវបរិសុទ្ធ
ជាដើម មួយទៀត លំដាប់នៃព្រហ្មវិហារទាំងនោះ រមែង
មាន ព្រោះអំណាចនៃអាការ មានប្រយោជន៍ជាដើម និង
ព្រហ្មវិហារទាំងនោះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ មិនមាន
ប្រមាណ ព្រោះហេតុនោះ ទើបហៅថា **អប្បមញ្ញា** ដូច្នេះ ។

អប្បមញ្ញាទាំងនោះ សូម្បីមានអារម្មណ៍ជាលក្ខណៈតែមួយដូចគ្នាដោយភាពជាអារម្មណ៍មិនមានប្រមាណយ៉ាងនេះ តែអប្បមញ្ញា ៣ ខាងដើម រមែងប្រព្រឹត្តទៅក្នុងឈាន ៣ ( ចតុក្កន័យ ) និងឈាន ៤ ( បញ្ចកន័យ ) ។ ព្រោះហេតុអ្វី ព្រោះឈានទាំងនោះ មិនទាន់ប្រាសចាកសោមនស្ស ។ ព្រោះហេតុអ្វី ទើបអប្បមញ្ញា ៣ ខាងដើម មិនទាន់ប្រាសចាកសោមនស្ស

ព្រោះអប្បមញ្ញា ៣ ខាងដើម ជាធម៌ស្ងាត់ចាកព្យាបាទជាដើម ដែលមានទោមនស្សជាសមុដ្ឋានចេញទៅ ចំណែកអប្បមញ្ញាចុងក្រោយ មានចំពោះឈានមួយដ៏សេស ព្រោះហេតុអ្វី ព្រោះប្រកបដោយឧបេក្ខាវេទនា ។ ពិតហើយ ឧបេក្ខាក្នុងព្រហ្មវិហារ ដែលប្រព្រឹត្តទៅដោយអាការជាកណ្តាលក្នុងសត្វទាំងឡាយ វៀរឧបេក្ខាវេទនា រមែងប្រព្រឹត្តទៅមិនបានឡើយ ។

ព្រហ្មវិហារជ្ឈាន ចប់

# អភិធម្មបិដក

## អសុភជ្ឈាន

[ ១៩១ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានប្រកបដោយសេចក្តីសម្គាល់នូវអសុភហើមប៉ោង ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ប្រកបដោយសេចក្តីសម្គាល់នូវអសុភមានពណ៌ខៀវ ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភ មានខ្ទុះហូរចេញ ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភដាច់ពាក់កណ្តាលខ្លួន ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភដែលសត្វកកេរស៊ី ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភ ដែលរាត់រាយ ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភ ដែលគេកាប់ចិញ្ច្រាំ ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភដែលប្រឡាក់ឈាម ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភដែលមានដង្កូវចោះ ។បេ។ ប្រកបដោយសេចក្តីសម្គាល់នូវអសុភដែលសល់តែរាងឆ្អឹង ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ ជាកុសល ។បេ។

អសុភជ្ឈាន មានវារៈ ១៦ ចប់

រូបាវចរកុសល ចប់

# អដ្ឋកថា

## អសុភជ្ឈាន

[ ១៩១ ] ឥឡូវនេះ ដើម្បីសម្តែងរូបាវចរកុសល ដែលជាប្រយោជន៍ដោយចំណែកមួយ ដល់សត្វដែលមានរាគចរិតជាដើម ដែលប្រព្រឹត្តទៅដោយអំណាចឈានមួយប៉ុណ្ណោះ ក្នុងអារម្មណ៍ផ្សេងៗ ទើបទ្រង់ផ្តើមពាក្យថា **កតមេ ធម្មា កុសលា** ដូច្នេះជាដើមទៀត ។

បណ្តាបទទាំងនោះ គប្បីជ្រាបវិគ្គហៈក្នុងបទថា **ឧទ្ធុមាតកសញ្ញាសហគតំ** ជាដើមដូចតទៅ

សាកសព ឈ្មោះថា **ឧទ្ធុមាតក** ព្រោះហើមប៉ោង ដោយការហើមក្រលែងឡើងតាមលំដាប់ ក្រោយអំពីអស់ជីវិត ដូចសម្លៀកស្បែកប៉ោងឡើងដោយខ្យល់ **ឧទ្ធុមាត** នុ៎ះឯង ឈ្មោះថា **ឧទ្ធុមាតក** ។ម្យ៉ាងទៀត ឈ្មោះថា **ឧទ្ធុមាតក** ព្រោះអត្ថថា ជាសាកសពដែលហើមប៉ោងគួរខ្ពើម ព្រោះជារបស់បដិកូល ។ បទថា **ឧទ្ធុមាតក** នេះ ជាឈ្មោះនៃសាកសពយ៉ាងនោះ ។

សាកសពដែលមានពណ៌ផ្សេងៗ គ្នា ហៅថា **វិនីល** សាកសពដែលឈ្មោះថា **វិនីល** នុ៎ះឯង ឈ្មោះថា **វិនីលក** ម្យ៉ាងទៀត ឈ្មោះថា **វិនីលក** ព្រោះអត្ថថា ជាសាកសពដែលមានពណ៌ខៀវចាស់ គួរខ្ពើម ព្រោះរបស់បដិកូល ។ បទថា **វិនីលក** នេះ ជាឈ្មោះរបស់សាកសពដែលមានពណ៌ក្រហមក្នុងទីដែលមានសាច់ច្រើន មានពណ៌សក្នុងទីដែលកុំដោយ

ខ្ទុះ និងមានពណ៌ខៀវដោយច្រើនក្នុងទីដែលមានពណ៌ខៀវ ដូចដណ្តប់ដោយសំពត់ពណ៌ខៀវ ។

សាកសពដែលមានខ្ទុះហូរចេញក្នុងទីដែលបែកហើយ ឈ្មោះថា **វិបុព្វ** សាកសពដែលជាវិបុព្វៈនុ៎ះឯង ឈ្មោះថា **វិបុព្វក**ម្យ៉ាងទៀត ដែលឈ្មោះថា **វិបុព្វក** ព្រោះអត្ថថា សាកសពមានខ្ទុះហូរចេញគួរខ្ពើម ព្រោះជារបស់បដិកូល ។ បទថា **វិបុព្វក** នេះ ជាឈ្មោះរបស់សាកសពដែលមានសភាពយ៉ាងនោះ ។

សាកសពដែលដាច់ជា ២ កំណាត់ ហៅថា **វិច្ឆិទ្ទ** សាកសពដែលជា **វិច្ឆិទ្ទ** នុ៎ះឯង ឈ្មោះថា **វិច្ឆិទ្ទក** ម្យ៉ាងទៀត ឈ្មោះថា **វិច្ឆិទ្ទក** ព្រោះអត្ថថា សាកសពជាកំណាត់ផ្សេងៗ ឈ្មោះថា គួរខ្ពើម ព្រោះជារបស់បដិ-កូល ។ បទថា **វិច្ឆិទ្ទក** នេះ ជាឈ្មោះរបស់សាកសព ដែលដាច់ពាក់កណ្តាល ។

សាកសពទាំងឡាយ ដែលមានឆ្កែស្រុក និងចចកជាដើមកកេរស៊ីដោយអាការផ្សេងៗ ដោយខ្ចាត់ខ្ចាយទៅ ឈ្មោះថា **វិក្ខាយិត** សាកសពដែលជា **វិក្ខាយិត** នុ៎ះឯង ឈ្មោះថា **វិក្ខាយិតក** ម្យ៉ាងទៀត ដែលឈ្មោះថា **វិក្ខាយិតក** ព្រោះអត្ថថា ជាសាកសពដែលត្រូវសត្វកកេរស៊ីគួរខ្ពើម ព្រោះជារបស់បដិកូល ។ បទថា **វិក្ខាយិតក** នេះ ជាឈ្មោះរបស់សាកសពមានសភាពបែបនោះ ។

សាកសពដែលខ្ចាត់ខ្ចាយទៅ ឈ្មោះថា **វិក្ខិត្ត** សាកសពដែលជា

**វិក្ខិត្ត** នុ៎ះឯង ឈ្មោះថា **វិក្ខិត្តក** មា៉្យងទៀត ដែលឈ្មោះថា **វិក្ខិត្តក** ព្រោះអត្ថថា ជាសាកសពខ្ចាត់ខ្ចាយទៅ គួរខ្ពើម ព្រោះជារបស់បដិកូល ។ បទថា **វិក្ខិត្តក** នេះ ជាឈ្មោះរបស់សាកសព ដែលខ្ចាត់ខ្ចាយទៅអំពីទីនោះៗ យ៉ាងនេះ គឺដៃទៅដោយឡែក ជើងទៅដោយឡែក ក្បាលទៅដោយឡែក ។

សាកសពដែលត្រូវគេកាប់ចិញ្ច្រាំ ខ្ចាត់ខ្ចាយទៅ ដោយន័យមុននុ៎ះឯង ឈ្មោះថា **ហតវិក្ខិត្តក** បទថា **ហតវិក្ខិត្តក** នេះ ជាឈ្មោះរបស់សាកសពដែលត្រូវកាប់ចិញ្ច្រាំដោយសស្ត្រាត្រង់អវយវៈតូចធំ ដោយអាការដូចកាកបាទខ្ចាត់ខ្ចាយ ដោយន័យដែលពោលហើយនុ៎ះឯង ។

សាកសពឈ្មោះថា **លោហិតក** ព្រោះអត្ថថា ឈាមហូរស្រោចក្នុងទីផ្សេងៗ ។ បទថា **លោហិតក** នេះ ជាឈ្មោះរបស់សាកសពដែលប្រឡាក់ឈាមហូរទៅ ។

ហ្វូងដង្កូវទាំងឡាយ ហៅថា **បុឡុវា** សាកសពដែលឈ្មោះថា **បុឡុវក** ព្រោះដេរដាសទៅដោយពួកដង្កូវរួងជញ្ជក់ ។ បទថា **បុឡុវក** នេះ ជាឈ្មោះរបស់សាកសពដែលដេរដាសដោយហ្វូងដង្កូវ ។

សាកសពដែលមានតែរាងឆ្អឹងប៉ុណ្ណោះ ហៅថា **អដ្ឋិក** មា៉្យងទៀត ឈ្មោះថា **អដ្ឋិក** ព្រោះអត្ថថា សាកសពដែលជាឆ្អឹងគួរខ្ពើម ព្រោះជារបស់បដិកូល ។ បទថា **អដ្ឋិក** នេះ ជាឈ្មោះរបស់សាកសពដែលមានរាងឆ្អឹងខ្លះ មានឆ្អឹងមួយកំណាត់ខ្លះ សាកសពទាំងនេះឯង ជាឈ្មោះរបស់និមិត្ត

ដែលកើតឡើង ព្រោះអាស្រ័យសាកសពដែលហើមប៉ោងជាដើមទាំងនេះខ្លះ ជាឈ្មោះរបស់ឈានដែលបានក្នុងនិមិត្តទាំងឡាយខ្លះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ឧទ្ធុមាតកសញ្ញាជាដើមទាំងនោះដូចតទៅនេះ សញ្ញាដែលកើតឡើង ដោយអំណាចអប្បនាក្នុងនិមិត្តនៃសាកសពដែលហើមប៉ោង ឈ្មោះថា **ឧទ្ធុមាតកសញ្ញា** ។ ឈានដែលសហគតៈដោយឧទ្ធុមាតកសញ្ញានោះ ដោយអត្ថថា ជាសម្បយោគ ឈ្មោះថា **ឧទ្ធុមាតកសញ្ញាសហគតំ** ។ សូម្បីក្នុងឈានដែលសហគតៈដោយវិនីលកសញ្ញាជាដើម ក៏ន័យនេះដូចគ្នា ។ តែក្នុងអធិការនៃអសុភនេះ វិធីចម្រើនឯណាដែលគប្បីពោល វិធីចម្រើននោះ ខ្ញុំបានពោលហើយ ក្នុងវិសុទ្ធិមគ្គដោយប្រការទាំងពួង ការពណ៌នាព្រះបាលីដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនុ៎ះឯង ក្នុងអសុភនេះ មួយពួកៗ មានឯកន័យ ២៥ ដោយអំណាចនៃបឋមជ្ឈានតែម្យ៉ាង ដូចក្នុងឧបេក្ខាព្រហ្មវិហារ មានដោយអំណាចចតុត្ថជ្ឈាន ។ គប្បីជ្រាបថា អារម្មណ៍នៃនិមិត្តដែលកើតឡើងក្នុងតំណែងដែលសាកសពហើមប៉ោងបន្តិចបន្តួច ជាបរិត្តាអារម្មណ៍ ដែលកើតឡើង ក្នុងតំណែងដែលសាកសពហើមប៉ោងឡើងច្រើន ជាអប្បមាណារម្មណ៍ ព្រោះអារម្មណ៍ដែលជាអសុភមិនជាទីតាំងនៃការពង្រីក ក្នុងអសុភដ៏សេសក៏ន័យនេះដូចគ្នា ។

ព្រោះហេតុនេះ ព្រះទសពលទ្រទ្រង់នូវគុណដ៏ល្អ ទ្រង់មាន
ព្រះកិត្តិគុណ ដែលសក្កទេវរាជសរសើរហើយ បានត្រាស់

អសុភទាំងឡាយ ពួកណា ដែលជាហេតុនៃឈានទីមួយៗ បណ្ឌិតកាលជ្រាបអសុភទាំងអស់នោះ ដោយន័យរបស់ព្រះបាលីយ៉ាងនេះមុនហើយ គប្បីជ្រាបបកិណ្ណកកថានេះ ក្នុងអសុភទាំងនោះនុ៎ះឯង ឲ្យក្រៃលែងឡើង ។

មែនពិត បុគ្គលរមែងប្រាសចាកការប្រព្រឹត្តិឡេះឡោះបាន ព្រោះអសុភណាមួយក្នុងអសុភទាំងនោះ ដូចអ្នកមានរាគៈទៅប្រាសហើយ ព្រោះរាគៈដែលខ្ទនសង្កត់បានហើយក្នុងឈានដែលសម្រេចហើយ កាលបើយ៉ាងនោះ ប្រភេទនៃអសុភនេះ ដែលទ្រង់ត្រាស់ហើយ ប្រភេទនៃអសុភនោះ គប្បីជ្រាបថា ត្រាស់ដោយអំណាចការដល់សភាវៈនៃសាកសព និងដោយអំណាចនៃប្រភេទរបស់បុគ្គលមានរាគចរិត ។

ព្រោះសាកសព កាលដល់ភាពជារបស់បដិកូល គប្បីដល់សភាពហើមប៉ោង ឬដល់សភាពជាសាកសពយ៉ាងណាទីមួយ មានពណ៌ខៀវជាដើម ។ ដោយហេតុនេះ ព្រះយោគាវចរ អាចរកអសុភប្រភេទណាមួយបាន គប្បីកំណត់និមិត្តក្នុងអសុភនោះៗ យ៉ាងនេះ គឺសាកសពហើមប៉ោងជារបស់បដិ-កូល សាកសពដែលមានពណ៌ខៀវជារបស់បដិកូលជាដើម ព្រោះហេតុនោះ គប្បីជ្រាបថា ត្រាស់ប្រភេទអសុភ ១០ ដោយអំណាចការដល់សភាពនៃសាកសព ។

មួយទៀត ពោលដោយការបែកគ្នាក្នុងអសុភទាំង ១០ នោះ សាកសពដែលហើមប៉ោង ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងសរីរសណ្ឋាន ព្រោះ

ប្រកាសសេចក្ដីវិបត្តិរបស់សរីរសណ្ឋាន ។ សាកសពដែលមានពណ៌ខៀវ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងសរីរវណ្ណៈ ព្រោះប្រកាសសេចក្ដីវិបត្តិក្នុងសេចក្ដីត្រេកអរក្នុងពណ៌សម្បុរ ។ សាកសពដែលមានខ្ទុះហូរចេញ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរ ក្នុងក្លិននៃសរីរៈ ដែលតាក់តែងឡើងដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ព្រោះប្រកាសភាពជាក្លិនស្អុយដែលជាប់ទាក់ទងដោយពណ៌សម្បុររបស់សាកសព ។ សាកសពដែលត្រូវកាត់ជាកំណាត់ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងសរីរៈថាជាដុំ ( ឃនៈ ) ព្រោះប្រកាសដល់ការប្រហោងនៃរាងកាយក្នុងខាងក្នុង ។ សាកសពដែលត្រូវសត្វកកេរស៊ី ជាសប្បាយដល់បុគ្គលអ្នកត្រេកអរ ក្នុងទីមានសាច់ប៉ោងក្នុងចំណែកនៃរាងកាយ មានសុដនជាដើម ព្រោះប្រកាសសេចក្ដីវិនាសនៃការបរិបូរណ៍ដោយសាច់ប៉ោង ។ សាកសពដែលមានអវយវៈខ្ចាត់ខ្ចាយទៅ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងការកែក្រាយនៃអវយវៈតូចធំ ព្រោះប្រកាសការខ្ចាត់ខ្ចាយនៃអវយវៈតូចធំ ។ សាកសពដែលត្រូវកាត់ជាកំណាត់ៗ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងការដល់ព្រមនៃរាងកាយ ព្រោះប្រកាសភាពពិការដោយការបែកធ្លាយទៅរបស់រាងកាយ ។ សាកសពដែលប្រឡាក់ឈាម ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងភាពស្រស់ស្អាត ដែលកើតអំពីការប្រដាប់តាក់តែង ព្រោះប្រកាសដល់ភាពបដិកូល ដោយការប្រឡាក់ដោយឈាម ។ សាកសពដែលមានពួកដង្កូវរូងជញ្ជក់ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរ ក្នុងរាងកាយថា ជារបស់អញ ព្រោះប្រកាសដល់ភាព

ដែលរាងកាយជារបស់សាធារណៈដល់ត្រកូលហ្វូងដង្កូវមិនមែនតិច ។ សាកសពដែលសល់តែរាងឆ្អឹង ជាសប្បាយដល់បុគ្គលអ្នកត្រេកអរ ក្នុងការបរិបូរណ៍នៃធ្មេញ ព្រោះប្រកាសដល់ភាពជារបស់បដិកូលនៃរាងឆ្អឹង ក្នុងសរីរៈ គប្បីជ្រាបថា ប្រភេទនៃអសុភ ១០ យ៉ាង ព្រះមានព្រះភាគ ត្រាស់ដោយអំណាចប្រភេទនៃបុគ្គលមានរាគចរិត ដោយប្រការដូច្នេះ ។

ក្នុងអសុភ ១០ យ៉ាងនេះ ចិត្តជាឯកគ្គតាតាំងនៅបាន ដោយកម្លាំងរបស់វិតក្កប៉ុណ្ណោះ វៀរវិតក្កហើយ ក៏មិនអាចតាំងនៅបាន ព្រោះអារម្មណ៍មានកម្លាំងទន់ខ្សោយ ដោយភាពជារបស់បដិកូល ដូចទូកចតនៅត្រង់ស្ទឹងមានក្រសែទឹកហូរខ្លាំងខ្លាញ់មិនឈប់ រមែងឈប់បានដោយកម្លាំងនៃថ្នោលប៉ុណ្ណោះ វៀរចាកថ្នោល ក៏មិនអាចចតបាន ។ ក្នុងអសុភកម្មដ្ឋាននេះ រមែងមាន ( បាន ) ត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ទុតិយជ្ឈានជាដើមមិនមានទេ ។

មួយទៀត ក្នុងអារម្មណ៍ជារបស់បដិកូលនេះ បីតិ និងសោមនស្ស ក៏រមែងកើត ព្រោះព្រះយោគាវចរឃើញអានិសង្សយ៉ាងនេះថា អញនឹងរួចផុតចាកជរា និងមរណៈ ព្រោះបដិបទានេះដោយពិត និងព្រោះលះបង់សេចក្តីក្តៅក្រហាយនៃនីវរណៈបាន ដូចជនអ្នកចោលផ្កា ( អ្នកចាក់សំរាម ) ឃើញអានិសង្សថា ថ្ងៃនេះ អញនឹងបានតម្លៃឈ្នួលច្រើន ទើបកើតបីតិសោមនស្សក្នុងគំនរលាមក និងដូចមនុស្សមានរោគជាទុក្ខ ព្រោះព្យាធិដែលកើតឡើង កើតបីតិសោមនស្សក្នុងការប្រព្រឹត្តទៅនៃថ្នាំដែលធ្វើឲ្យក្អួត និងរាគ ដូច្នោះ ។

អសុភទាំង ១០ នេះ ដោយលក្ខណៈ ក៏មានតែមួយប៉ុណ្ណោះ ដ្បិតថា

អសុភទាំង ១០ នេះ មានភាពជារបស់បដិកូល ដោយភាពជារបស់មិនស្អាត មានក្លិនស្អុយ គួរខ្ពើមរអើមប៉ុណ្ណោះជាលក្ខណៈ អសុភនេះដោយលក្ខណៈនេះ រមែងប្រាកដក្នុងសរីរៈ ដែលស្លាប់ហើយតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន តែរមែងប្រាកដក្នុងសរីរៈដែលនៅមានជីវិត ដូចដែលប្រាកដដល់ព្រះមហាតិស្សត្ថេរ អ្នកនៅក្នុងវិហារចេតិយបពិត ឃើញធ្មេញ និងដូចដែលប្រាកដដល់សាមណេរជាឧបដ្ឋាកព្រះសង្ឃរក្ខិតត្ថេរ ដែលសម្លឹងមើលព្រះរាជាប្រថាប់លើកដំរី ។ រាងកាយដែលស្លាប់ហើយ ជាអសុភយ៉ាងណា សូម្បីសរីរៈដែលកំពុងនៅមានជីវិត ក៏ជាអសុភយ៉ាងនោះឯង តែក្នុងរាងកាយដែលនៅរស់នេះ លក្ខណៈនៃអសុភ រមែងមិនប្រាកដ ព្រោះគ្រឿងប្រដាប់ចរមកបិទបាំង ដូច្នេះឯង ។

## អសុភជ្ឈាន ចប់

សួរថា រូបាវចរអប្បនានេះ មានបឋវីកសិណជាដើម មានអដ្ឋិកសញ្ញាជាទីបំផុត ជាអារម្មណ៍ប៉ុណ្ណោះឬ ឬសូម្បីយ៉ាងដទៃ ក៏មាន ។ ឆ្លើយថា សូម្បីយ៉ាងដទៃ ក៏មាន ។ តែក្នុងអភិធម្មនេះ មិនបានត្រាស់អានាបានជ្ឈាន និងកាយគតាសតិភាវនា សូម្បីមិនត្រាស់ក៏ពិត តែកាលទ្រង់ប្រារព្ធវាយោកសិណ ទើបជាការប្រារព្ធដល់អានាបានជ្ឈានដោយពិត ។ មួយទៀត កាលប្រារព្ធដល់វណ្ណកសិណទាំងឡាយក៏ឈ្មោះថា ប្រារព្ធដល់កាយ-គតាសតិ ដែលកើតឡើងដោយចតុក្កជ្ឈាន និងបញ្ចកជ្ឈានក្នុងកោដ្ឋាស មាន

សក់ជាដើម ។ ម្យ៉ាងទៀត កាលទ្រង់ប្រារព្ធអសុភ ១០ ក៏ឈ្មោះថា ប្រារព្ធដល់កាយគតាសតិ ដែលប្រព្រឹត្តទៅដោយអំណាចនៃឈាន ដែលមនសិការបដិកូលក្នុងអាការ ៣២ និងដោយអំណាចនៃឈាន ដែលកើតឡើងអំពីវណ្ណៈក្នុងនវសីវថិកា ( ព្រៃខ្មោច ៩ ) ដូចគ្នា ។ អប្បនាដែលជារូបាវចរទាំងអស់ ឈ្មោះថា ត្រាស់ហើយក្នុងទីនេះ ដោយប្រការដូច្នេះ ។

រូបាវចរកុសល ចប់

# អភិធម្មបិដក

## អរូបាវចរកុសល

[ ១៩២ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងបង់នូវពួករូបសញ្ញា ព្រោះវិនាសបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ព្រោះលះបង់សុខផង ដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកាសានញ្ចាយតនសញ្ញាដ៏ប្រកបដោយឧបេក្ខាក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងបង់នូវអាកាសានញ្ចាយតនៈ ព្រោះលះបង់សុខផង ដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយវិញ្ញាណញ្ចាយតនសញ្ញា ដ៏ប្រកបដោយឧបេក្ខា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនៈ ព្រោះលះបង់សុខផង ដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកិញ្ចញ្ញាយតនសញ្ញា ដ៏ប្រកបដោយឧបេក្ខា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌

ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនៈ ព្រោះលះបង់សុខផង ដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានាសញ្ញាយតន-សញ្ញា ដ៏ប្រកបដោយឧបេក្ខា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

អរូបជ្ឈាន ៤ មានវារៈ ១៦ ចប់

អរូបាវចរកុសល ចប់

# អដ្ឋកថា

## អរូបាវចរកុសល

[ ១៩២ ] ឥឡូវនេះ ដើម្បីទ្រង់សម្តែងអរូបាវចរកុសល ទើបទ្រង់ផ្តើមពាក្យថា **កតមេ ធម្មា កុសលា** ដូច្នេះជាដើមទៀត ។

បណ្តាបទទាំងនោះ បទថា **អរូបូបបត្តិយា** សេចក្តីថា អរូបភព ក៏គឺអរូប ការចូលដល់ក្នុងអរូបបែបនេះ ឈ្មោះថា អរូបូបបត្តិ ។ ដើម្បីចូលដល់អរូបភពនោះ ។ បទថា **មគ្គំ ភាវេតិ** សេចក្តីថា រមែងញុំាងឧបាយគឺហេតុ គឺការណៈ ឲ្យកើតឡើង គឺឲ្យចម្រើនឡើង ។ បទថា **សព្វសោ** បានដល់ ដោយអាការទាំងពួង ម្យ៉ាងទៀត អធិប្បាយថា ដែលមិនមានចំណែកសេសសល់ ។ បទថា **រូបសញ្ញានំ** បានដល់ នូវរូបាវចរជ្ឈានដែលត្រាស់ដោយមានសញ្ញាជាប្រធាន និងជាអារម្មណ៍របស់ឈាននោះ ។ ពិតហើយ សូម្បីរូបាវចរជ្ឈាន ក៏ត្រាស់ហៅថា **រូប** ដូចក្នុងប្រយោគជាដើមថា **រូបី រូបានិ បស្សតិ** បាននូវរូបជ្ឈាន ឃើញនូវពួករូប ដូច្នេះ សូម្បីអារម្មណ៍នៃរូបាវចរជ្ឈាននោះ ក៏ត្រាស់ហៅថា **រូប** ដូចក្នុងប្រយោគជាដើមថា **ពហិទ្ធា រូបានិ បស្សតិ សុវណ្ណទុព្វណ្ណានិ** ឃើញនូវពួករូបខាងក្រៅ មានពណ៌ល្អ មានពណ៌អាក្រក់ ដូច្នេះ ព្រោះហេតុនោះ ក្នុងទីនេះគប្បីជ្រាបថា បទថា **រូបសញ្ញានំ** នេះ ទើបជាឈ្មោះរបស់រូបាវចរជ្ឈាន តាមដែលពោលដោយមានសញ្ញាជាប្រធាន យ៉ាងនេះថា សញ្ញាក្នុងរូបាវចរជ្ឈាន ឈ្មោះថា **រូបសញ្ញា** ។ ដែលឈ្មោះថា **រូបសញ្ញា** ព្រោះអត្ថថា មានរូបជាគ្រឿងចំណាំ អធិប្បាយថា រូបារម្មណ៍ជាឈ្មោះរបស់ឈាននោះ ។ ដោយប្រការ

យ៉ាងនេះ ពាក្យថា **រូបសញ្ញា** នេះ ទើបជាឈ្មោះរបស់អារម្មណ៍នៃឈាននោះ ដែលតំណាងដោយអារម្មណ៍ មានបឋវីកសិណជាដើម ។

បទថា **សមតិក្កមា** បានដល់ ព្រោះបន្ទោបង់ និងរម្ងត់ឥតសេសសល់ ។ ពាក្យនេះមានអធិប្បាយដូចម្ដេច មានអធិប្បាយថា ព្រះយោគាវចរចូលអាកាសានញ្ចាយតនៈ ដែលជាហេតុបន្ទោបង់ និងជាហេតុរម្ងត់ ព្រោះបន្ទោបង់ និងរម្ងត់នូវរូបសញ្ញាទាំងនោះ គឺឈាន ១៥ ដោយអំណាចកុសលវិបាក និងកិរិយា និងនូវរូបសញ្ញាទាំងនោះ គឺអារម្មណ៍ ៨ យ៉ាងដោយអំណាចបឋវីកសិណជាដើម ដោយអាការទាំងពួង ឬដែលមិនមានចំណែកសេសសល់ ។ ពិតហើយ ព្រះយោគាវចរដែលមិនទាន់បានឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង មិនអាចចូលអាកាសានញ្ចាយតនៈនោះបាន ។

ក្នុងរូបសញ្ញាទាំងនោះ ព្រោះបុគ្គលមិនទាន់ប្រាសចាកការត្រេកអរ ក្នុងអារម្មណ៍ រមែងឈានកន្លងសញ្ញាទៅមិនបាន កាលឈានកន្លងសញ្ញាទាំងឡាយបានហើយ អារម្មណ៍ក៏ឈ្មោះថា ឈានកន្លងទៅបានដូចគ្នា ព្រោះហេតុនោះ ទើបមិនត្រាស់ដល់ការឈានកន្លងអារម្មណ៍ ត្រាស់តែការឈានកន្លងសញ្ញាទាំងឡាយប៉ុណ្ណោះ ក្នុងវិភង្គយ៉ាងនេះថា ពាក្យថា ព្រោះឈានកន្លងរូបសញ្ញា ដោយប្រការទាំងពួង មានអធិប្បាយថា

> រូបសញ្ញា តើដូចម្ដេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃការសម្គាល់ណា របស់បុគ្គលអ្នកចូលកាន់រូបសមាបត្តិក្ដី

របស់បុគ្គលអ្នកប្រកប ( ដោយរូបសមាបត្តិ ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយរូបាវចរសមាបត្តិ ) ក្តី នេះហៅថា រូបសញ្ញា បុគ្គលកន្លង ប្រព្រឹត្តកន្លង ឈានកន្លងនូវរូបសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងរូបសញ្ញាដោយសព្វគ្រប់ ដូច្នេះ ។

ក៏ព្រោះសមាបត្តិទាំងនេះ គប្បីពោលដោយការឈានកន្លងអារម្មណ៍ មិនដូចបឋមជ្ឈានជាដើមដែលគប្បីពោលក្នុងអារម្មណ៍មួយប៉ុណ្ណោះ ហេតុនោះ គប្បីជ្រាបថា ការពណ៌នាសេចក្តីនេះ ទ្រង់ធ្វើដោយអំណាចការឈានកន្លងអារម្មណ៍ ។

បទថា **បដិឃសញ្ញានំ អត្ថង្គមា** សេចក្តីថា សញ្ញាដែលកើតឡើងព្រោះវត្ថុ មានចក្ខុជាដើម និងអារម្មណ៍ មានរូបារម្មណ៍ជាដើម ប៉ះខ្ទប់គ្នា ឈ្មោះថា **បដិឃសញ្ញា** ។ បទថា **បដិឃសញ្ញា** នេះ ជាឈ្មោះរបស់រូបសញ្ញាជាដើម ។ ដូចព្រះតម្រាស់ក្នុងវិភង្គថា ពាក្យថា ព្រោះការរលត់ទៅនៃបដិឃសញ្ញា មានអធិប្បាយថា បដិឃសញ្ញា តើដូចម្តេច ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា នេះហៅថា បដិឃសញ្ញា ដូច្នេះ ។ មានអធិប្បាយថា ព្រោះរលត់ គឺព្រោះលះ គឺព្រោះការមិនកើតឡើង បានដល់ ធ្វើមិនឲ្យប្រព្រឹត្តទៅនៃបដិឃសញ្ញាទាំង ១០ នោះ គឺកុសលវិបាក ៥ អកុសលវិបាក ៥ ដោយប្រការទាំងពួង ។ បដិឃសញ្ញាទាំងនោះ រមែងមិនមានសូម្បីដល់បុគ្គលដែលចូលឈាន មាន

បឋមជ្ឈានជាដើមដោយពិត ព្រោះក្នុងសម័យនោះ ចិត្តរមែងមិនប្រព្រឹត្តទៅតាមបញ្ចទ្វារ ។ កាលបើយ៉ាងនោះ គប្បីជ្រាបពាក្យដែលត្រាស់ដល់បដិឃសញ្ញាទាំងនោះ ក្នុងអរូបាវចរជ្ឈាននេះ ដោយអំណាចនៃការសរសើរឈាននេះ ដើម្បីឲ្យកើតឧស្សាហៈក្នុងឈាននេះ ដូចការពោលដល់សុខ និងទុក្ខដែលលះបានហើយ ក្នុងឈានដទៃក្នុងឈានទី ៤ និងដូចការពោលដល់សក្កាយទិដ្ឋិជាដើម ដែលលះបានហើយ ក្នុងមគ្គដទៃ ក្នុងមគ្គទី ៣ ដូច្នោះ ។ ម្យ៉ាងទៀត បដិឃសញ្ញាទាំងនេះ មិនមានដល់អ្នកដែលចូលរូបាវចរជ្ឈានក៏ពិត តែរមែងមិនមាន ព្រោះលះបានហើយក៏មិនមែន ព្រោះថា ការចម្រើនរូបាវចរមិនមែនប្រព្រឹត្តទៅព្រម ដើម្បីការប្រាសចាកសេចក្តីត្រេកអរក្នុងរូប ។ មួយទៀត បដិឃសញ្ញាទាំងនេះ រមែងប្រព្រឹត្តទៅព្រមព្រោះអាស្រ័យរូប តែភាវនានេះ រមែងប្រព្រឹត្តទៅព្រមដើម្បីបន្ទោបង់សេចក្តីត្រេកអរក្នុងរូប ព្រោះហេតុនោះ សមគួរនឹងពោលបានថា បដិឃសញ្ញាទាំងនោះ ព្រះយោគាវចរលះបានហើយ ក្នុងឈាននេះ ។ មួយទៀត មិនមែនត្រឹមតែការពោលប៉ុណ្ណោះ សូម្បីការទ្រទ្រង់ចាំយ៉ាងនេះ ដោយចំណែកមួយទុំឯង ក៏សមគួរ ពិតហើយ ព្រះមានព្រះភាគត្រាស់ថា សំឡេងជាបន្លា ដូច្នេះ របស់អ្នកចូលបឋមជ្ឈាន ព្រោះមិនទាន់លះបដិឃសញ្ញាទាំងនោះ ក្នុងកាលមុនអំពីកាលនេះ ។ តែក្នុងទីនេះ ព្រះអង្គត្រាស់ភាពដែលអរូបសមាបត្តិទាំងឡាយ ជាអនេញ្ជា និងភាពដែលអរូបសមាបត្តិទាំងឡាយជាសន្តវិមោក្ខ ព្រោះលះ ( បដិឃសញ្ញា ) បានហើយដោយពិត ៦

អាឡារតាបសកាលាមគោត្ត ចូលអរូបជ្ឈាន មិនបានឃើញ និងមិនបានឮសំឡេងរទេះ ប្រមាណប្រាំរយដែលធ្វងកាត់ជិតលំនៅជាទីនៅអាស្រ័យ ។

បទថា **នានត្តសញ្ញានំ អមនសិការា** សេចក្តីថា នូវសញ្ញាទាំងឡាយដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងគ្នា ឬនូវសញ្ញាទាំងឡាយ ដែលមានសេចក្តីផ្សេងគ្នា ព្រោះក្នុងទីនេះ បំណងយកសញ្ញាទាំងនេះ ព្រោះត្រាស់ចែកក្នុងវិភង្គយ៉ាងនេះថា ពាក្យថា ព្រោះមិនមនសិការនូវនានត្តសញ្ញា មានអធិប្បាយថា នានត្តសញ្ញា តើដូចម្តេច ។ ការសម្គាល់ អាការសម្គាល់ភាពនៃការសម្គាល់ណារបស់បុគ្គលអ្នកមិនចូលកាន់ ( រូបសមាបត្តិ ) ជាអ្នកព្រមព្រៀងដោយមនោធាតុក្តី ព្រមព្រៀងដោយមនោវិញ្ញាណធាតុក្តី នេះហៅថា នានត្តសញ្ញា ដូច្នេះ សញ្ញាដែលព្រមព្រៀងដោយមនោធាតុ និងមនោវិញ្ញាណធាតុរបស់អ្នកមិនចូលសមាបត្តិ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមានសេចក្តីផ្សេងគ្នា និងមានសភាវៈដែលផ្សេងគ្នា មានផ្សេងគ្នាដោយរូប និងសំឡេងជាដើម ។ ព្រោះសញ្ញាទាំង ៤៤ គឺកាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសល-វិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១ មានសេចក្តីផ្សេងគ្នា មានសភាវៈផ្សេងគ្នា មិនដូចគ្នានិងគ្នា ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា នានត្តសញ្ញា ។ ព្រោះមិនមនសិការ ព្រោះមិនពិចារណា ព្រោះមិនរំពឹង ព្រោះមិននាំមក ព្រោះមិនពិចារណានូវនានត្តសញ្ញាទាំងនោះ ដោយប្រការទាំងពួង មានអធិប្បាយថា ព្រោះមិនពិចារណា មិនមនសិការ មិន

ពិចារណាសញ្ញាទាំងនោះ ហេតុនោះ ( ទើបសម្រេចចតុត្ថជ្ឈានដែលសហគតៈដោយអាកាសានញ្ចាយតនសញ្ញា ) ។ ព្រោះក្នុងសញ្ញា ៣ នោះ រូបសញ្ញា បដិឃសញ្ញាខាងដើម រមែងមិនមានក្នុងភពដែលកើតឡើងដោយឈាននេះ នឹងពោលទៅថ្វី ក្នុងកាលដែលចូលឈាននេះក្នុងភពនោះ ព្រោះហេតុនោះ ទើបត្រាស់ការមិនមានសញ្ញាទាំង ២ នោះឯង ដោយពាក្យថា ព្រោះកន្លងបង់ ព្រោះវិនាស ។ ក្នុងនានត្តសញ្ញាទាំងឡាយ គប្បីជ្រាបថា ព្រោះសញ្ញា ២៧ គឺកាមាវចរកុសលសញ្ញា ៨ កិរិយាសញ្ញា ៩ ( មហាកិរិយា ៨ មនោទ្វារាវជ្ជនៈ ១ ) អកុសលសញ្ញា ១០ ( វៀរទោសៈ ២ ) មានក្នុងភពដែលកើតហើយដោយឈាននេះ ហេតុនោះ ទើបត្រាស់ថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញាទាំងនោះ ព្រោះថាសូម្បីក្នុងពាក្យនោះថា ព្រោះមិនធ្វើទុកក្នុងចិត្ត ព្រះយោគាវចរ កាលចូលឈាននេះ ក៏ចូលឈានព្រោះមិនមនសិការសញ្ញាទាំងនោះឡើយ តែកាលមនសិការសញ្ញាទាំងនោះ ក៏រមែងចូលមិនបាន ។ កាលពោលដោយសង្ខេបក្នុងទីនេះ គប្បីជ្រាបថា ត្រាស់ការលះរូបាវចរធម៌ទាំងពួងដោយពាក្យនេះថា **រូបសញ្ញានំ សមតិក្កមា** ព្រោះកន្លងបង់នូវពួករូបសញ្ញា ត្រាស់ការលះនិងការមិនមនសិការចិត្ត និងចេតសិកដែលជាកាមាវចរទាំងពួង ដោយពាក្យនេះថា **បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា** ព្រោះវិនាសបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្ត នូវពួកនានត្តសញ្ញា ដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់គុណរបស់អាកាសានញ្ចា-

យតនសមាបត្តិ ដោយបទទាំង ៣ គឺដោយការកន្លងបង់រូបសញ្ញា ១៥ ដោយការវិនាសទៅនៃបដិឃសញ្ញា ១០ ដោយការមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ៤៤ ។

បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនោះ ឆ្លើយថា ដើម្បីឲ្យកើតឧស្សាហៈ និងដើម្បីលួងលោមដល់អ្នកស្តាប់ទាំងឡាយ ។ ព្រោះបើអាចារ្យពួកខ្លះ ដែលមិនមែនបណ្ឌិតគប្បីពោលថា ព្រះសាស្តាមែនត្រាស់ថា ចូរពួកលោកធ្វើអាកាសានញ្ចាយតនសមាបត្តិឲ្យកើត ដូច្នេះ អ្វីហ្ន៎ ជាប្រយោជន៍ អ្វីហ្ន៎ ជាអានិសង្សរបស់អាកាសានញ្ចាយតនសមាបត្តិដែលឲ្យកើតឡើងនោះ ។ ព្រះសាស្តាត្រាស់គុណរបស់សមាបត្តិដោយហេតុទាំងនេះ ដោយបំណងថា អាចារ្យទាំងនោះកុំបីពោលយ៉ាងនេះ ។ ពិតហើយ ជនទាំងនោះ បានស្តាប់ព្រះតម្រាស់នោះហើយក៏នឹងគិតថា បានឮថា សមាបត្តិនេះ ល្អិតយ៉ាងនេះ ប្រណីតយ៉ាងនេះ ពួកយើងនឹងញ៉ាំងសមាបត្តិនោះឲ្យកើត ពេលនោះ ពួកជនទាំងនោះ នាំគ្នាធ្វើឧស្សាហៈដើម្បីឲ្យសមាបត្តិនោះកើតឡើង ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ត្រាស់គុណរបស់អាកាសានញ្ចាយតនសមាបត្តិនេះ ដល់ព្រះយោគាវចរទាំងនោះ ដើម្បីលួងលោមដូចវិសកណ្តកពាណិជ ។ វិសកណ្តកពាណិជគេតែងហៅថា គុឡពាណិជ ( ឈ្មួញស្ករ ) ។ បានឮថា ឈ្មួញស្ករនោះ យករទេះផ្ទុកស្ករអំពៅ និងស្ករក្រាមជាដើម ទៅកាន់បច្ចន្តគ្រាម ហើយឃោសនាថា ចូរពួកអ្នកមកទទួលវិសកណ្តក ពួក

ចូរអ្នកមកទទួលវិសកណ្ដក ( ថ្នាំពិស និងបន្លា ) ។ ពួកអ្នកស្រុកស្ដាប់ពាក្យឃោសនានោះហើយ ក៏គិតថា វត្ថុនេះអាក្រក់ណាស់ ឈ្មោះថា ថ្នាំពិស បុគ្គលណាទំពាស៊ីវា បុគ្គលនោះ ត្រូវស្លាប់ សូម្បីបន្លាមុតហើយ ក៏ឲ្យស្លាប់បាន វត្ថុទាំង ២ នេះ កាចសាហាវណាស់ វានឹងមានប្រយោជន៍អ្វី ដូច្នេះ ទើបនាំគ្នាបិទទ្វារផ្ទះ និងឲ្យពួកក្មេងគេចចេញទៅ ។ ពួកឈ្មួញឃើញការធ្វើយ៉ាងនោះហើយ ទើបគិតថា អ្នកស្រុកទាំងនេះ មិនឈ្លាសក្នុងវោហារណ្ហើយចុះ អញនឹងឲ្យគេទិញដោយឧបាយ ទើបឃោសនាថា ចូរពួកអ្នកមកទទួលទឹកឃ្មុំ ចូរពួកអ្នកមកទទួលរបស់ធ្លាញ់ ពួកអ្នកនឹងបានស្ករអំពៅ និងស្ករក្រាម មានតម្លៃដ៏សមគួរ ទោះយកមាសកហុនអន់ និងកហាបណៈធុនអន់ជាដើម មកទិញក៏បាន ។ ពួកអ្នកស្រុកស្ដាប់ពាក្យនោះហើយ ម្នាក់ៗក៏នាំគ្នាត្រេកអរ ទៅហើយ ឲ្យតម្លៃច្រើន ទិញយកហើយ ។

ក្នុងពាក្យទាំងនោះ មានសេចក្ដីឧបមាដូច្នេះ ព្រះតម្រាស់របស់ព្រះមានព្រះភាគថា ចូរពួកអ្នកញ៉ាំងអាកាសានញ្ចាយតនសមាបត្តិ ឲ្យកើត ដូច្នេះ ប្រៀបដូចការឃោសនារបស់ឈ្មួញថា ចូរពួកអ្នកទទួលថ្នាំពិស និងបន្លា ។ ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកគប្បីធ្វើអាកាសានញ្ចាយតនៈឲ្យកើត ដូច្នេះ ពួកអ្នកស្ដាប់ក៏គិតថា អ្វីហ្ន៎ ជាអានិសង្ស ក្នុងអាកាសានញ្ចាយតនៈនេះ ពួកយើងមិនដឹងនូវគុណរបស់អាកាសានញ្ចាយតនៈនេះ ប្រៀបដូចពួកអ្នកស្រុកនាំគ្នាគិតថា របស់ទាំង ២ នេះ អាក្រក់ពន់ពេក អ្វីជាប្រយោជន៍ក្នុងរបស់នេះ ។ ពេលនោះ ព្រះមានព្រះភាគទ្រង់ប្រកាសអានិសង្ស មានការឈាន

កន្ទុងរូបសញ្ញាជាដើម ដូចកាលឈ្មួញនោះ ឃោសនាពាក្យជាដើមថា ចូរពួកអ្នកមកទទួលយកទឹកឃ្មុំ ។ ព្រះមានព្រះភាគត្រាស់សរសើរគុណអាកាសានញ្ចាយតនសមាបត្តិ ក៏ដើម្បីឲ្យកើតឧស្សាហៈ និងដើម្បីលួងលោមដោយទ្រង់ព្រះតម្រិះថា ជនទាំងនេះ ដែលព្រះអង្គឲ្យត្រេកអរហើយ ដោយអានិសង្សនេះ នឹងធ្វើឧស្សាហៈធំ ហើយញុំាងសមាបត្តិនេះឲ្យកើត ប្រៀបដូចអ្នកស្រុកទាំងឡាយនោះ ស្តាប់ពាក្យឃោសនាឈ្មួញ ហើយឲ្យតម្លៃច្រើន ទិញយកស្ករអំពៅ ដូច្នោះ ។

គប្បីជ្រាបវិគ្គហៈ ក្នុងបទថា **អាកាសានញ្ចាយតនសញ្ញាសហគតំ** ដូចតទៅនេះថា អាកាស ដែលឈ្មោះថា **អនន្ត** ព្រោះអត្ថថា មិនមានទីបំផុត ។ អាកាសនុ៎ះឯងមិនមានទីបំផុត ឈ្មោះថា **អាកាសានន្ត** អាកាសានន្តៈនុ៎ះឯង ឈ្មោះថា **អាកាសានញ្ច** អាកាសានញ្ចៈនោះ ឈ្មោះថា **អាយតន** នៃឈាន ព្រមទាំងសម្បយុត្តធម៌នេះ ព្រោះអត្ថថា ជាទីតាំងមាំ ដូចទីតាំងនៅរបស់ទេវតាទាំងឡាយ ឈ្មោះថា **ទេវាយតន** ព្រោះហេតុនោះ ទើបឈាននេះ ឈ្មោះថា **អាកាសានញ្ចាយតន** ។ អាកាសានញ្ចៈនោះផង ជាអាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា **អាកាសានញ្ចាយតន** ដោយប្រការដូច្នេះ ។ បទថា **អាកាសានញ្ចាយតន** នេះ ជាឈ្មោះរបស់កសិណុគ្ឃាដិមាកាស ( អាកាសដែលបើកកសិណ ) ។ ឈានដែលសហគតៈជាមួយនឹងសញ្ញា ដែលដល់អប្បនាក្នុងអាកាសានញ្ចាយតនៈនោះ ឈ្មោះថា **អាកាសានញ្ចាយតនសញ្ញាសហគត** ។

ក្នុងទីដទៃត្រាស់ថា អាកាសជាអនន្តៈ ( មិនមានទីបំផុត ) យ៉ាងណា ក្នុងទីនេះ ទ្រង់មិនបានកាន់យកថា អាកាសមិនមានទីបំផុត ឬថា តិចតួច ដូច្នោះ ។ ព្រោះហេតុអ្វី ព្រោះកាលទ្រង់កាន់យកអាកាសមិនមានទីបំផុត ក៏មិនកាន់យកអាកាសតិចតួច កាលកាន់យកអាកាសតិចតួច ក៏មិនកាន់យកអាកាសមិនមានទីបំផុត កាលបើដូច្នោះ អារម្មណ៍ ៤ ពួក ក៏មិនបរិបូណ៌ ទេសនាក៏មិនបាន ១៦ ដង ។ តែព្រោះអជ្ឈាស្រ័យរបស់ព្រះសម្មាសម្ពុទ្ធ ដើម្បីធ្វើទេសនា ក្នុងទី ១៦ ដង ព្រោះហេតុនោះ ទើបមិនត្រាស់ពាក្យថា មិនមានទីបំផុត ឬថា តិចតួច តែត្រាស់ថា ប្រកបដោយអាកាសានញ្ចា-យតនសញ្ញា ។ កាលបើយ៉ាងនោះ ពាក្យទាំង ២ ក៏រមែងជាពាក្យដែលទ្រង់កាន់យកហើយនោះឯង អារម្មណ៍ ៤ ពួក ក៏បរិបូណ៌ ទេសនាក៏ដល់ ១៦ ដង ។ សេចក្តីនៃព្រះបាលីដ៏សេស គប្បីជ្រាបដោយន័យដែលពោលក្នុងខាងដើមនុ៎ះឯង ។

មួយទៀត ក្នុងអាកាសានញ្ចាយតនៈនេះ រមែងជា **ទុក្ខាបដិបទា** ព្រោះសេចក្តីលំបាក ក្នុងការអស់ទៅនៃសេចក្តីត្រេកអរ ក្នុងរូបាវចរចតុត្ថជ្ឈាន រមែងជាទន្ធាភិញ្ញា ព្រោះសេចក្តីយឺតយូរក្នុងការអប់រំអប្បនា របស់បុគ្គលដែលមានសេចក្តីត្រេកអរ អស់ទៅហើយ ។ គប្បីជ្រាបសុខាបដិបទា និងខិប្បាភិញ្ញា ដោយពាក្យអធិប្បាយផ្ទុយគ្នា ។ ឈានដែលប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណតូច គប្បីជ្រាបថា ជាបរិត្តារម្មណ៍ ឈានដែលប្រព្រឹត្តទៅក្នុងអាកាស ដែលបើកកសិណធំទូលាយ គប្បីជ្រាបថា ជា

អប្បមាណារម្មណ៍ ។ សូម្បីក្នុងឈាននេះ មានធម៌មួយពួកៗ ២៥ ដោយអំណាចចតុក្កជ្ឈានដូចក្នុងឧបេក្ខាព្រហ្មវិហារ ក៏ក្នុងអាកាសានញ្ចាយតនៈនេះ យ៉ាងណា សូម្បីក្នុងវិញ្ញាណញ្ចាយតនៈជាដើមក្រៅអំពីនេះ ក៏យ៉ាងនោះ ។ តែខ្ញុំនឹងពណ៌នា ត្រឹមតែការផ្សេងគ្នា ក្នុងវិញ្ញាណញ្ចាយតនៈជាដើមទាំងនោះ ប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **អាកាសានញ្ចាយតនំ សមតិក្កម្មា** ដូចតទៅនេះ **អាកាសានញ្ចុំ** ឈ្មោះថា អាយតនៈនៃឈាននេះ ព្រោះអត្ថថា ជាទីតាំងមាំ ដោយន័យដែលពោលខាងដើមនុ៎ះឯង ព្រោះហេតុនោះ សូម្បីឈាននេះ ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ។ សូម្បីអារម្មណ៍ ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ដោយន័យដែលពោលហើយ ។ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ព្រោះព្រះយោគាវចរឈានកន្លងធម៌ទាំង ២ នេះ គឺ ឈាន និងអារម្មណ៍ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនមនសិការ គប្បីចូលដល់វិញ្ញាណញ្ចាយតនៈនេះ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅយកធម៌ទាំង ២ នេះហើយ ទើបត្រាស់ពាក្យនេះថា ព្រោះកន្លងបង់នូវអាកាសានញ្ចាយតនៈ ដូច្នេះ ។

គប្បីជ្រាបវិគ្គហៈក្នុងបទថា **វិញ្ញាណញ្ចាយតនសញ្ញាសហគតំ** នេះ ដូចតទៅនេះថា ទីបំផុតនៃវិញ្ញាណនោះ មិនមានដោយអំណាច ដែលធ្វើទុកក្នុងចិត្តថា **អនន្តំ** ព្រោះហេតុនោះ ទើបវិញ្ញាណនោះ ឈ្មោះថា **អនន្ត** អនន្តៈនុ៎ះឯងឈ្មោះថា **អានញ្ចុំ** ។ ព្រះមានព្រះភាគមិនត្រាស់ថា វិញ្ញាណ

ដែលមិនមានទីបំផុត ឈ្មោះថា **វិញ្ញាណានញ្ចំ** តែត្រាស់ថា **វិញ្ញាណញ្ចំ** ដូច្នេះ ព្រោះថា ក្នុងពាក្យថា វិញ្ញាណញ្ចាយតនសញ្ញាសហគតៈនេះ ជារុឡ្ហីសព្ទ ( ពាក្យផ្សេងតែន័យផ្សេង ) ។ វិញ្ញាណញ្ចៈនុ៎ះឯង ឈ្មោះថា **អាយតន** នៃសញ្ញានេះ ព្រោះអត្ថថា ជាទីតាំងមាំ ព្រោះហេតុនោះ ទើបឈ្មោះថា **វិញ្ញាណញ្ចាយតន** ឈានដែលសហគតៈដោយសញ្ញាដែលប្រព្រឹត្តទៅក្នុងវិញ្ញាណញ្ចាយតនៈនោះ ព្រោះហេតុនោះ ទើបឈាននោះ ឈ្មោះថា **វិញ្ញាណញ្ចាយតនសញ្ញាសហគត** ពាក្យថា វិញ្ញាណញ្ចាយតនសញ្ញា-សហគតៈនេះ ជាឈ្មោះរបស់ឈានដែលមានវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាសជាអារម្មណ៍ ។ ក្នុងវិញ្ញាណញ្ចាយតនៈនេះ ជាទុក្ខាបដិបទា ព្រោះលំបាកក្នុងការអស់ទៅនៃការត្រេកអរ ក្នុងអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថា ជាទន្ធាភិញ្ញា ព្រោះការយឺតយូរក្នុងការអប់រំអប្បនារបស់អ្នកមានសេចក្តីត្រេកអរដែលទៅហើយជាសុខាបដិបទា និងខិប្បាភិញ្ញាដោយបរិយាយផ្ទុយគ្នា ។ គប្បីជ្រាបឈាននេះថា ជាបរិត្តារម្មណ៍ ព្រោះប្រារព្ធសមាបត្តិដែលមានការបើកកសិណាតិចតួចជាអារម្មណ៍ប្រព្រឹត្តទៅ គប្បីជ្រាបថា ជាអប្បមាណារម្មណ៍ដោយបរិយាយដែលផ្ទុយគ្នា ពាក្យដ៏សេសដូចគ្នានឹងន័យមុននុ៎ះឯង ។

គប្បីជ្រាបវិគ្គហៈក្នុងបទថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** នេះ ដូចតទៅនេះ

វិញ្ញាណញ្ចៈ ឈ្មោះថា អាយតនរបស់ឈាននោះ ព្រោះអត្ថថា ជាទី

តាំងមាំ ដោយន័យដែលបានពោលខាងដើមនុ៎ះឯង ព្រោះហេតុនោះ ឈានក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ សូម្បីអារម្មណ៍ក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ដោយន័យដែលពោលហើយនោះឯង ។ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ព្រោះព្រះយោគាវចរកន្លងបង់ធម៌ទាំង ២ នេះ គឺឈាន និងអារម្មណ៍ ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនមនសិការ ហើយគប្បីចូលដល់អាកិញ្ចញ្ញាយតនៈនេះ ព្រោះហេតុនោះ ព្រះមានព្រះភាគសង្គ្រោះធម៌ទាំង ២ នេះ ហើយត្រាស់ពាក្យនេះថា ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនៈ ដូច្នេះ ។

គប្បីជ្រាបវិគ្គហៈ ក្នុងបទថា **អាកិញ្ចញ្ញាយតនសញ្ញាសហគតំ** នេះ ដូចតទៅ

ឈាននេះ ឈ្មោះថា **អាកិញ្ចន** ព្រោះអត្ថថា មិនមានអ្វីសូម្បីតែបន្តិច មានអធិប្បាយថា វត្ថុដែលសេសសល់នៃវិញ្ញាណនោះ ដោយហោចសូម្បីត្រឹមតែភង្គក្ខណៈក៏មិនមាន ។ ភាវៈនៃការមិនមានអ្វីបន្តិចបន្តួច ឈ្មោះថា **អាកិញ្ចញ្ញ** ។ ពាក្យថា អាកិញ្ចញ្ញៈនេះ ជាឈ្មោះរបស់អារម្មណ៍ដែលមិនមានវិញ្ញាណដែលមានអាកាសជាទីតាំងមាំ ។ អាកិញ្ចញ្ញៈនោះ ឈ្មោះថា ជាអាយតនៈនៃសញ្ញានេះ ព្រោះអត្ថថា ជាទីតាំងមាំ ព្រោះហេតុនោះ ទើបឈាននេះ ឈ្មោះថា **អាកិញ្ចញ្ញាយតន** ។ ឈានដែលសហគតៈដោយសញ្ញាដែលប្រព្រឹត្តទៅក្នុងអាកិញ្ចញ្ញាយតនៈនោះ ឈ្មោះថា **អាកិញ្ចញ្ញាយតនសហគត** ពាក្យថា អាកិញ្ចញ្ញាយតនសហគតៈនេះ ជាឈ្មោះរបស់ឈានដែលមានអារម្មណ៍ដែលមិនមានវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាស ។

ក្នុងអាកិញ្ចញ្ញាយតនៈនេះ ជាទុក្ខាបដិបទា ព្រោះលំបាកក្នុងការអស់ទៅនៃការត្រេកអរក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ជាទន្ធាភិញ្ញា ព្រោះការយឺតយូរក្នុងការចម្រើនអប្បនា របស់អ្នកមានសេចក្ដីត្រេកអរដែលអស់ទៅ ជាសុខាបដិបទា និងខិប្បាភិញ្ញាដោយបរិយាយដែលផ្ទុយគ្នា ។ គប្បីជ្រាបឈាននេះថា ជាបរិត្តារម្មណ៍ ព្រោះមានអារម្មណ៍ដែលមិនមានវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណបន្តិចបន្តួច គប្បីជ្រាបថា ជាអប្បមាណារម្មណ៍ដោយបរិយាយផ្ទុយគ្នានឹងបរិត្តារម្មណ៍ ។ ពាក្យដ៏សេសដូចគ្នានឹងន័យមុនន៉ុះឯង ។

គប្បីជ្រាបវិគ្គហៈ ក្នុងបទថា **អាកិញ្ចញ្ញាយតនំ សមតិក្កម្ម** នេះ ដូចតទៅនេះ **អាកិញ្ចញ្ញ** ឈ្មោះថា អាយតនៈនៃឈាននោះ ព្រោះអត្ថថាជាទីតាំងមាំដោយន័យដែលពោលហើយក្នុងកាលមុនន៉ុះឯង ព្រោះហេតុនោះ សូម្បីឈាន ក៏ឈ្មោះថា **អាកិញ្ចញ្ញាយតន** សូម្បីអារម្មណ៍ ក៏ឈ្មោះថា **អាកិញ្ចញ្ញាយតន** ដោយន័យដែលពោលហើយន៉ុះឯង ។ ពាក្យដ៏សេសដូចគ្នានឹងន័យមុននោះឯង បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ព្រោះព្រះយោគាវចរ កន្លងបង់ធម៌ទាំង ២ នេះ គឺឈាន និងអារម្មណ៍ ដោយការធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនមនសិការហើយ គប្បីចូលដល់នេវសញ្ញានាសញ្ញាយតនៈនេះ ហេតុនោះ ព្រះមានព្រះភាគទ្រង់សង្គ្រោះធម៌ទាំង ២ នេះហើយ ត្រាស់ពាក្យថា ព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនៈ ដូច្នេះ ។

គប្បីជ្រាបវិគ្គហៈក្នុងបទថា **នេវសញ្ញានាសញ្ញាយតនសហគតំ** នេះ

ដូចតទៅ

ឈានទោះ ត្រាស់ហៅថា នេវសញ្ញានាសញ្ញាយតនៈ ព្រោះសភាវៈនៃសញ្ញាណា សញ្ញានោះ រមែងមានដល់អ្នកបដិបត្តិដូចម្ដេច ដើម្បីសម្ដែងសញ្ញានោះមុន ទើបទ្រង់លើកបទក្នុងវិភង្គថា **នេវសញ្ញីនាសញ្ញី** ឡើងជាមេបទ ហើយត្រាស់ថា **ភិក្ខុធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនជ្ឈានទោះឯងដោយល្អិត** ចម្រើននូវ**សមាបត្តិមានសង្ខារសល់នៅ** ព្រោះហេតុនោះ ទើបពោលថា នេវសញ្ញីនាសញ្ញី ដូច្នេះ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **ភិក្ខុធ្វើទុកក្នុងចិត្ត ... ដោយល្អិត** បានដល់ រមែងមនសិការសមាបត្តិនោះថា ល្អិត ព្រោះមានអារម្មណ៍ល្អិតយ៉ាងនេះថា សមាបត្តិនោះធ្វើនូវភាពមិនមានឲ្យជាអារម្មណ៍តាំងនៅល្អិតហ្ន៎ ។ សួរថា បើមនសិការដោយភាពជារបស់ល្អិតហើយ ការកន្លងបង់ តើមានដូចម្ដេច ឆ្លើយថា ព្រោះភាពជាអ្នកត្រូវការនឹងមិននឹកដល់ ។ ពិតហើយ ព្រះយោគាវចរនោះ រមែងមនសិការឈានទោះ ដោយជារបស់ល្អិតក៏ពិត តែការជញ្ជឹងគិត ការប្រមូលមក ការដាក់ចិត្តនោះ រមែងមិនមានដល់ព្រះយោគា-វចរនោះថា អញនឹងនឹកដល់ អញនឹងចូល អញនឹងតាំងនៅ អញនឹងចេញ អញនឹងពិចារណាឈានទោះ ព្រោះហេតុអ្វី ព្រោះនេវសញ្ញានាសញ្ញាយតនៈជាធម៌ល្អិតជាង ប្រណីតជាងអាកិញ្ចញ្ញាយតនៈ ។

ដូចព្រះរាជាទ្រង់ប្រថាប់លើកដំរីដ៏ប្រសើរ ស្ដេចត្រាច់ទៅតាមផ្លូវ ក្នុងនគរដោយអានុភាពនៃព្រះរាជាដែលជាធំ ទ្រង់ទតឃើញជនដែលមានសិប្បៈ

មានជាងធ្លាក់ក្លុកជាដើមស្លៀកសំពត់មួយផ្ទាំង ជួតសំពត់មួយផ្ទាំងត្រង់ក្បាល ឱ្យឃ្លាតធ្វើការ មានខ្លួនប្រឡាក់ដោយលម្អិតក្លុកជាដើម កំពុងធ្វើសិប្បៈធ្លាក់ក្លុកជាដើម មិនមែនតិច ទ្រង់សព្វព្រះហឫទ័យក្នុងការឈ្លាស របស់ជាងទាំងនោះយ៉ាងនេះថា គួរអស្ចារ្យណាស់ហ្ន៎ អាចារ្យដ៏ឈ្លាស អាចធ្វើសិប្បៈទាំងឡាយឈ្មោះនេះបាន តែទ្រង់មិនបានត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ខ្លួនអញនឹងលះបង់រាជសម្បត្តិហើយធ្វើជាអ្នកសិប្បៈបែបនេះ សេចក្តីនោះព្រោះហេតុអ្វី ព្រោះសិរីរាជសម្បត្តិមានតម្លៃច្រើន ។ ព្រះអង្គទ្រង់យាងធ្លងកាត់អ្នកសិប្បៈទាំងឡាយទៅយ៉ាងណា ព្រះយោគាវចរក៏យ៉ាងនោះដូចគ្នា រមែងមនសិការសមាបត្តិនោះដោយជារបស់ល្អិត ក៏ពិត តែលោកក៏មិនជញ្ជឹងគិតមិនប្រមូលមក មិនដាក់ចិត្តថា អញនឹងនឹកដល់ នឹងចូលសមាបត្តិ នឹងតាំងនៅ នឹងចេញ នឹងពិចារណាសមាបត្តិនេះ ។ ព្រះយោគាវចរនោះ កាលមនសិការសមាបត្តិនោះដោយភាពជារបស់ល្អិត រមែងសម្រេចសញ្ញាដែលដល់អប្បនាដែលល្អិតយ៉ាងក្រៃលែង នុ៎ះជាហេតុឲ្យបានឈ្មោះថា **នេវ-សញ្ញីនាសញ្ញីបុគ្គល** ដោយន័យដែលពោលក្នុងកាលមុននោះឯង ទ្រង់ត្រាស់ហៅព្រះយោគាវចរនោះថា រមែងចម្រើនសមាបត្តិ មានសង្ខារសេសសល់ ។

ពាក្យថា **សមាបត្តិមានសង្ខារសេសសល់នៅ** គឺអរូបសមាបត្តិទី ៤ ដែលមានសង្ខារដល់នូវភាពល្អិតបំផុត ។

ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់ណាថា នេវសញ្ញានាសញ្ញាយតនៈ

ដោយអំណាចនៃសញ្ញាដែលព្រះយោគាវចរសម្រេចហើយយ៉ាងនេះ ឥឡូវនេះ ដើម្បីសម្តែងព្រះតម្រាស់នោះដោយអត្ថ ទើបត្រាស់ ( ក្នុងអភិធម្មវិភង្គ ) ថា ត្រង់ពាក្យថា នេវសញ្ញានាសញ្ញាយតនៈ បានដល់ ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប ( ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន ) ក្តី ដូច្នេះ ។

បណ្តាបុគ្គលទាំង ៣ ប្រភេទនេះ ក្នុងទីនេះ ទ្រង់បំណងយកធម៌ គឺចិត្ត និងចេតសិករបស់បុគ្គលដែលចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ។

ក្នុងឈាននេះ មានវចនត្ថៈដូចតទៅនេះ ឈានដែលឈ្មោះថា **នេវសញ្ញានាសញ្ញា** ព្រោះអត្ថថា សញ្ញារបស់ឈាន ព្រមទាំងសម្បយុត្តធម៌នោះមិនមាន ព្រោះមិនមានសញ្ញាគ្រោតគ្រាត មិនមានសញ្ញា ក៏មិនមែន ព្រោះមានសញ្ញាល្អិត ។ ឈាននោះ ជាសភាវៈដែលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនផង ជាអាយតនៈ ព្រោះទាក់ទងក្នុងមនាយតនៈ និងធម្មាយតនៈផង ព្រោះហេតុនោះ ទើបឈាននោះ ឈ្មោះថា **នេវសញ្ញានាសញ្ញាយតន** ។

ម្យ៉ាងទៀត សញ្ញាក្នុងឈាននេះ ឈ្មោះថា **នេវសញ្ញា** ព្រោះមិនអាចធ្វើកិច្ចរបស់សញ្ញាបានដោយជាក់ច្បាស់ និងឈ្មោះថា **នាសញ្ញា** ព្រោះជាធម៌មាននៅដោយភាពជាធម៌ល្អិតនៃសង្ខារដ៏សេស ព្រោះហេតុនោះ ទើប

ឈាននោះ ឈ្មោះថា **នេវសញ្ញានាសញ្ញា** ។ នេវសញ្ញានាសញ្ញានោះផង ឈ្មោះថា ជាអាយតនៈ ព្រោះអត្ថថា ជាទីតាំងមាំនៃធម៌ដ៏សេសផង ព្រោះហេតុនោះ ទើបឈ្មោះថា **នេវសញ្ញានាសញ្ញាយតន** ។

មួយទៀត ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននេះ សញ្ញាបែបនេះតែម្យ៉ាងក៏មិនមែន ដោយពិត សូម្បីវេទនាក៏ឈ្មោះថា **នេវវេទនានាវេទនា** សូម្បីចិត្តក៏ឈ្មោះថា **នេវចិត្តនាចិត្ត** សូម្បីផស្សៈក៏ឈ្មោះថា **នេវផស្ស-នាផស្ស** ។ ក្នុងសម្បយុត្តធម៌ដ៏សេសក៏ន័យនេះ ។ តែទេសនានេះ គប្បីជ្រាបថា ទ្រង់ធ្វើសញ្ញាឲ្យជាប្រធាន ។ បណ្ឌិតគប្បីជ្រាបសេចក្ដីនេះ ដោយឧបមាទាំងឡាយ មានរឿងប្រេងលាបបាត្រជាដើម ។

បានឮថា សាមណេរយកប្រេងលាបបាត្រហើយ ព្រះថេរៈពោលនឹងសាមណេរក្នុងវេលាឆាន់បបរថា សាមណេរ ចូរនាំបាត្រមក សាមណេរពិតលោកថា ក្នុងបាត្រមានប្រេងលោកម្ចាស់ ពេលនោះ ព្រះថេរៈពោលថា ចូរសាមណេរនាំមក ខ្ញុំនឹងចាក់ដាក់នាឡិដែលវាល់ប្រេង សាមណេរក៏ប្រាប់ថា លោកម្ចាស់ ប្រេងមិនមានទេ ។

ក្នុងការឧបមានោះ ប្រេង ឈ្មោះថា **មាន** ព្រោះអត្ថថា ជារបស់មិនគួរជាមួយនឹងបបរ ព្រោះភាពមាននៅក្នុងខាងក្នុង ប្រេងនោះ ឈ្មោះថា **មិនមាន** ព្រោះការមិនមានល្មមដាក់ក្នុងនាឡិ ឲ្យពេញជាដើម យ៉ាងណា សូម្បីសញ្ញាក៏យ៉ាងនោះ ឈ្មោះថា មានសញ្ញាក៏មិនមែន ព្រោះមិនអាចដើម្បីធ្វើកិច្ចរបស់សញ្ញាដោយជាក់ច្បាស់ ឈ្មោះថា មិនមានសញ្ញាក៏មិន

មែន ព្រោះភាពមាននៅដោយភាពជារបស់ល្អិតនៃសង្ខារដ៏សេស ។

សួរថា ក្នុងឈាននេះ កិច្ចរបស់សញ្ញា តើដូចម្តេច ។ ឆ្លើយថា កិច្ចរបស់សញ្ញា គឺការចាំបាន ចំណាំអារម្មណ៍ និងការចូលដល់ភាពជាអារម្មណ៍នៃវិបស្សនាហើយឲ្យកើតសេចក្តីនឿយណាយ ។ ពិតហើយ សញ្ញានោះមិនអាចធ្វើកិច្ច គឺការចាំបាន ចំណាំដោយជាក់ច្បាស់ ដូចតេជោធាតុក្នុងទឹកប្រក្រតី មិនអាចធ្វើកិច្ច គឺការដុតឲ្យឆេះ ។ សញ្ញាមិនអាចធ្វើសូម្បីការចូលដល់ភាពជាអារម្មណ៍នៃវិបស្សនាហើយឲ្យកើតសេចក្តីនឿយណាយ ដូចសញ្ញាក្នុងសមាបត្តិដ៏សេស ព្រោះថា ភិក្ខុមិនបានធ្វើការប្រកាន់ក្នុងខន្ធទាំងនោះ ឈ្មោះថា អាចពិចារណានេវសញ្ញានាសញ្ញាយតនៈ ហើយដល់នូវនិព្វិទា រមែងមិនមាន តែព្រះសារីបុត្ត លោកឃើញច្បាស់ដោយប្រក្រតី តែព្រះសារីបុត្តអាចឃើញ ព្រោះមានបញ្ញាច្រើន ក៏គប្បីឃើញបាន ដោយអំណាចការពិចារណាជាកលាបៈប៉ុណ្ណោះយ៉ាងនេះថា ធម៌ទាំងនេះ មិនដែលមានត្រឡប់ជាមាន មានហើយត្រឡប់ជាគ្មានវិញយ៉ាងនេះ ដូច្នេះ មិនមែនឃើញដោយអំណាចនៃវិបស្សនាធម៌តាមបទ ។ សមាបត្តិនេះ ដល់នូវភាពល្អិតយ៉ាងនេះ ។ បណ្ឌិតគប្បីជ្រាបសេចក្តីនេះ ដោយការឧបមាដូចទឹកក្នុងដងផ្លូវ ដូចឧបមាដោយប្រេងលាបបាត្រតទៅ

បានឮថា សាមណេរដើរទៅខាងមុខព្រះថេរៈ ដែលកំពុងធ្វើដំណើរតាមផ្លូវ ឃើញទឹកបន្តិចហើយ ពិតព្រះថេរៈថា លោកម្ចាស់មានទឹក សូមលោកម្ចាស់ដោះស្បែកជើងទាន លំដាប់នោះ កាលព្រះថេរៈពោលថា បើមានទឹក

ចូរអ្នកនាំសំពត់ងូតទឹកមក ខ្ញុំនឹងងូតទឹក សាមណេរពិតថា ទឹកមិនមានទេ លោកម្ចាស់ ដូច្នេះ ។

ក្នុងពាក្យឧបមានោះ ទឹកឈ្មោះថា **មាន** ដោយអំណាចត្រឹមតែសើមស្បែកជើង ឈ្មោះថា **មិនមាន** ដោយអត្ថថា មិនល្មមនឹងងូត យ៉ាងណា សមាបត្តិនោះ ក៏យ៉ាងនោះដែរ ឈ្មោះថា **នេវសញ្ញា** ព្រោះមិនអាចធ្វើកិច្ចរបស់សញ្ញាដោយជាក់ច្បាស់បាន ឈ្មោះថា **នាសញ្ញា** ព្រោះសញ្ញាមានដោយភាពជារបស់ល្អិត នៃសង្ខារដ៏សេស និងមិនមែនប្រៀបដោយឧបមាទាំងនេះប៉ុណ្ណោះទេ គប្បីធ្វើសេចក្តីនេះឲ្យជាក់ច្បាស់ដោយឧបមាដែលសមគួរដទៃទៀត ។ ដោយន័យដែលពោលមក ឈានឈ្មោះថា **នេវសញ្ញា-នាសញ្ញាយតនសញ្ញាសហគត** ព្រោះអត្ថថា សហគតៈដោយសញ្ញាដែលប្រព្រឹត្តទៅក្នុងនេវសញ្ញានាសញ្ញាយតនៈនេះ ឬសហគតៈដោយសញ្ញាដែលជានេវសញ្ញានាសញ្ញាយតនៈ ។ ពាក្យនេះ ជាឈ្មោះរបស់ឈាន ដែលមានអាកិញ្ចញ្ញាយតនសមាបត្តិជាអារម្មណ៍ ។

ក្នុងឈាននេះ **ជាទុក្ខាបដិបទា** ព្រោះលំបាកក្នុងការអស់ទៅនៃការត្រេកអរ ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ជា **ទន្ធាភិញ្ញា** ព្រោះការយឺតយូរក្នុងការចម្រើនអប្បនារបស់អ្នកដែលមានសេចក្តីត្រេកអរអស់ទៅហើយ ជាសុខាបដិបទា និងខិប្បាភិញ្ញា ដោយបរិយាយដែលផ្ទុយគ្នា គប្បីជ្រាបឈាននេះថា ជាបរិត្តារម្មណ៍ ព្រោះប្រារព្ធសមាបត្តិដែលមានអារម្មណ៍ ដែលមិនមានវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាស ដែលបើកកសិណតូចប្រព្រឹត្ត

ទៅ គប្បីជ្រាបថា ជាអប្បមាណារម្មណ៍ដោយបរិយាយដែលផ្ទុយគ្នា ពាក្យដ៏សេសដូចនឹងន័យមុនទាំងឯង ។

ព្រះពុទ្ធ ទ្រង់ជាទីពឹង មានព្រះរូប មិនមាននរណាស្មើដូច ត្រាស់អរូបជ្ឈាន ៤ យ៉ាង ឯណា ព្រះយោគី កាលជ្រាបអរូបជ្ឈាន ៤ នោះហើយ គប្បីដឹងបកិណ្ណកកថា ក្នុងអរូបជ្ឈាននោះតទៅ ។

ព្រោះអរូបសមាបត្តិទាំង ៤ នេះ រមែងមាន ព្រោះការឈានកន្លងអារម្មណ៍ ទើបអ្នកប្រាជ្ញ ដែលមានបញ្ញា មិនប្រាថ្នាការឈានកន្លងអង្គនៃសមាបត្តិទាំងនោះ ។

ពិតហើយ បណ្ដាសមាបត្តិទាំងនោះ គប្បីជ្រាបអរូបសមាបត្តិ ៤ ដែលកើតឡើងដោយការឈានកន្លងអារម្មណ៍ដោយប្រការទាំងពួង គឺអរូបសមាបត្តិទីមួយ ឈានកន្លងឈានដែលមានរូបនិមិត្ត អរូបសមាបត្តិទី ២ ឈានកន្លងអាកាស អរូបសមាបត្តិទី ៣ ឈានកន្លងវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស អរូបសមាបត្តិទី ៤ ឈានកន្លងការទៅប្រាសនៃវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាស ។

តែបណ្ឌិតទាំងឡាយ មិនប្រាថ្នាការឈានកន្លងអង្គនៃសមាបត្តិទាំងនោះ ព្រោះការឈានកន្លងអង្គ មិនមានក្នុងសមាបត្តិទាំងនេះ ដូចក្នុងរូបាវចរសមាបត្តិទេ ដ្បិតថា ក្នុងអរូបសមាបត្តិទាំងអស់នោះ រមែងមានអង្គឈាន ២ ប៉ុណ្ណោះ គឺឧបេក្ខា និងឯកគ្គតានៃចិត្ត ។

កាលបើដូច្នោះ

សមាបត្តិដែលកើតក្រោយៗ ក្នុងទីនេះ ក៏ជាសភាពប្រណីត

ជាងសមាបត្តិមុនៗ គប្បីជ្រាបឧបមាក្នុងសមាបត្តិទាំងនោះ

ដូចផ្ទៃប្រាសាទ និងសំពត់សាដក ។

ឧបមាដូចប្រាសាទ ៤ ជាន់ ប្រាសាទជាន់ខាងក្រោមបំផុត មានកាម-គុណ ៥ ដែលប្រណីតដោយអំណាចនៃការរាំ ច្រៀង ប្រគំ ក្លិនក្រអូប ផ្កាកម្រង គួរជាទីពេញចិត្ត ភេសជ្ជៈ ភោជនដែលមានរសដ៏ល្អ មានទីអង្គុយ ទីដេក និងសំពត់ដែលជាទិព្វជាដើមប្រាកដហើយ ប្រាសាទជាន់ទី ២ មានកាមគុណទាំងនោះ ប្រណីតជាងជាន់ទីមួយ ប្រាសាទជាន់ទី ៣ មានកាមគុណទាំងនោះប្រណីតជាងជាន់ទី ២ ប្រាសាទជាន់ទី ៤ មានកាមគុណទាំងនោះប្រណីតជាងគ្រប់ជាន់ ។ ក្នុងប្រាសាទទាំងនោះ មានផ្ទៃប្រាសាទ ៤ ជាន់ ការផ្សេងគ្នារបស់ផ្ទៃប្រាសាទទាំងនោះ មិនមានក៏ពិត តែប្រាសាទជាន់ខាងលើក៏ប្រណីតជាងប្រាសាទជាន់ខាងក្រោម ព្រោះវិសេសជាងដោយភាពបរិបូណ៌នៃកាមគុណ ៥ ប្រៀបដូចសំពត់សាដក ទម្ងន់ ៤ បលៈ ៣ បលៈ ២ បលៈ និង ១ បលៈនៃអំបោះយ៉ាងគ្រោតគ្រាត យ៉ាងល្អិត យ៉ាងល្អិតជាង យ៉ាងល្អិតបំផុតដែលស្ត្រីម្នាក់ត្បាញដោយចំណែកទទឹង និងប៉ុនគ្នា បណ្តាសំពត់សាដកទាំងនោះ សូម្បីទាំង ៤ មានទំហំស្មើគ្នា មិនប្លែកពីគ្នា តែថា សំពត់ដែលត្បាញលើកក្រោយៗ ប្រណីតជាងដែលត្បាញលើកមុនៗ ដោយមានសម្ផស្សសប្បាយ មានសាច់ម៉ដ្ឋ និងមានតម្លៃច្រើន

យ៉ាងណា ក្នុងអរូបជ្ឈានសមាបត្តិទាំង ៤ នេះ ក៏យ៉ាងនោះដូចគ្នា អង្គឈាន ទាំងនេះ មានត្រឹម ២ យ៉ាង គឺឧបេក្ខា និងឯកគ្គតានៃចិត្តប៉ុណ្ណោះក៏ពិត តែក្នុងទីនេះ គប្បីជ្រាបថា អរូបសមាបត្តិក្រោយៗ ប្រណីតជាងដោយភាពប្រណីត និងប្រណីតជាងនៃអង្គឈានទាំងនោះ ព្រោះការផ្សេងគ្នានៃភាវនា ។ អរូបជ្ឈានសមាបត្តិទាំងនេះប្រណីត និងប្រណីតដោយលំដាប់ ដោយប្រការដូច្នេះ ។ ( គប្បីជ្រាបឧបមាដូចតទៅនេះ )

បុរសម្នាក់ឈរតោងមណ្ឌប ក្នុងទីដែលមិនស្អាត ម្នាក់ទៀតឈរអាស្រ័យបុរសម្នាក់នោះ ម្នាក់ទៀត មិនអាស្រ័យ ឈរនៅខាងក្រៅ ម្នាក់ទៀត អាស្រ័យមនុស្សដែលនៅខាងក្រៅឈរនៅ បណ្ឌិតអ្នកមានប្រាជ្ញា គប្បីជ្រាបអរូបសមាបត្តិទាំង ៤ ដោយភាពជាសភាវៈស្មើគ្នា ដូចបុរសទាំង ៤ នាក់នេះ តាមលំដាប់ ។

ក្នុងគាថានោះ គប្បីជ្រាបការប្រកបសេចក្ដីដូចតទៅ

បានឮថា មណ្ឌបមួយខ្នងតាំងនៅក្នុងទីដែលមិនស្អាត ពេលនោះ បុរសម្នាក់មកហើយតាមលំដាប់អំពីបុរស ៤ នាក់នោះ រង្កៀសនូវទីដែលមិនស្អាតនោះ ទើបយកដៃតោងមណ្ឌប សំយុងខ្លួនត្រង់មណ្ឌបនោះ ឈរដូចតោងជាប់ត្រង់មណ្ឌបនោះ ខាងក្រោយមក បុរសម្នាក់ទៀត មកអាស្រ័យបុរសដែលសំយុងត្រង់មណ្ឌបនោះ តមក បុរសដទៃទៀតមកហើយ គិតថា បុរសដែលឈរតោងមណ្ឌប និងបុរសដែលអាស្រ័យគេ ជនទាំង ២ នេះ

ឈរមិនល្អ នឹងធ្លាក់ទៅក្នុងរណ្តៅរបស់មណ្ឌបពិតប្រាកដ ណ្ហើយចុះ អញនឹងឈរខាងក្រៅមណ្ឌប ទើបមិនអាស្រ័យនឹងជនដែលអាស្រ័យគេនោះ ហើយទៅឈរខាងក្រៅមណ្ឌបនោះឯង តមក មានបុរសម្នាក់ទៀតមកហើយ គិតថា បុរសដែលឈរតោងមណ្ឌប និងបុរសដែលអាស្រ័យនឹងបុរសនោះ មិនមានសេចក្តីក្សេម ដឹងថា ជនដែលឈរនៅខាងក្រៅមណ្ឌបឈរល្អហើយ ទើបបានឈរអាស្រ័យបុរសនោះ ។

ក្នុងពាក្យទាំងនោះ បណ្ឌិតគប្បីឃើញអាកាសដែលបើកកសិណឡើង ដូចមណ្ឌបក្នុងប្រទេសដែលមិនស្អាត ។ អាកាសានញ្ចាយតនជ្ឈាន ដែលមានអាកាសជាអារម្មណ៍ ព្រោះរង្កៀសរូបនិមិត្ត គប្បីឃើញដូចបុរសឈរតោងមណ្ឌប ព្រោះរង្កៀសរបស់ដែលមិនស្អាត ។ វិញ្ញាណញ្ចាយតនជ្ឈានដែលប្រារព្ធអាកាសានញ្ចាយតនជ្ឈានដែលមានអាកាសជាអារម្មណ៍ ប្រព្រឹត្តទៅហើយ គប្បីឃើញដូចបុរសដែលឈរអាស្រ័យបុរសដែលតោងមណ្ឌប ។ អាកិញ្ចញ្ញាយតនជ្ឈាន មិនធ្វើអាកាសានញ្ចាយតនជ្ឈានឲ្យជាអារម្មណ៍ ធ្វើការមិនមាននៃអាកាសានញ្ចាយតនៈនោះឲ្យជាអារម្មណ៍ ប្រៀបដូចបុរសគិតដល់សេចក្តីមិនក្សេមរបស់បុរសទាំងពីរនោះ ទើបមិនអាស្រ័យបុរសនោះ ហើយទៅឈរខាងក្រៅ ។ នេវសញ្ញានាសញ្ញាយតនជ្ឈាន ដែលប្រារព្ធអាកិញ្ចញ្ញាយតនៈ ដែលតាំងនៅក្នុងប្រទេសខាងក្រៅ ពោល គឺការមិនមានវិញ្ញាណប្រព្រឹត្តទៅ គប្បីឃើញដូចបុរសគិតថា បុរសដែលឈរតោងមណ្ឌប និងបុរសដែលឈរអាស្រ័យទាំងពីរនោះ មិនមានសេចក្តីក្សេម ដឹងថាបុរស

ដែលឈរនៅខាងក្រៅ ជាអ្នកឈរល្អហើយ ទើបឈរអាស្រ័យបុរសនោះ ដូច្នោះ ។ នេវសញ្ញានាសញ្ញាយតនៈនេះ កាលនឹងប្រព្រឹត្តទៅបានយ៉ាងនេះ

រមែងធ្វើអាកិញ្ចញ្ញាយតនៈនោះ ឲ្យជាអារម្មណ៍ ព្រោះការមិន
មានអារម្មណ៍ដទៃ ដូចប្រជាជនលើកព្រះរាជាដែលខ្លួនឃើញ
ថាមិនល្អឲ្យឡើងគ្រងរាជ្យ ព្រោះហេតុនៃការរស់នៅ ។

ពិតហើយ នេវសញ្ញានាសញ្ញាយតនៈនេះ រមែងធ្វើអាកិញ្ចញ្ញាយតនៈនោះ ដែលឃើញហើយថា មិនល្អ យ៉ាងនេះថា អាកិញ្ចញ្ញាយតនសមាបត្តិនេះមានវិញ្ញាណញ្ចាយតនៈជាសត្រូវជិត ដូច្នេះ ឲ្យជាអារម្មណ៍ ព្រោះមិនមានអារម្មណ៍ដទៃ ។ សួរថា ដូចអ្វី ។ ឆ្លើយថា ដូចមហាជនលើកព្រះរាជាដែលខ្លួនឃើញថា មិនល្អឲ្យឡើងគ្រងរាជ្យ ព្រោះហេតុនៃការរស់នៅ ។ ដូចព្រះរាជាដែលជាធំក្នុងទ្វីបទាំងអស់ មិនសង្រួម មានសេចក្តីប្រព្រឹត្តតាមផ្លូវកាយ វាចា និងផ្លូវចិត្តគ្រោតគ្រាត មហាជន ឃើញទោសយ៉ាងនេះថា ព្រះរាជាអង្គនេះមានការប្រព្រឹត្តិគ្រោតគ្រាត តែកាលមិនបានការរស់នៅក្នុងទីដទៃ ទើបត្រូវអាស្រ័យនឹងព្រះរាជាអង្គនោះប្រព្រឹត្តទៅ ព្រោះហេតុនៃការរស់នៅ យ៉ាងណា នេវសញ្ញានាសញ្ញាយតនៈនេះ កាលមិនបានអារម្មណ៍ដទៃក៏ធ្វើអាកិញ្ចញ្ញាយតនៈ សូម្បីដែលខ្លួនឃើញហើយថា មិនល្អនោះ ឲ្យជាអារម្មណ៍យ៉ាងនោះឯង ។ មួយទៀត ឈាន គឺនេវសញ្ញានាសញ្ញាយតនៈនេះ កាលធ្វើដោយអាការយ៉ាងនេះ

រមែងអាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាននោះ ទើបប្រព្រឹត្តទៅ

បាន ដូចបុគ្គលឡើងជណ្តើរវែង គប្បីតោងបង្កាន់ដៃ និង ដូចបុគ្គលឡើងកំពូលភ្នំ គប្បីតោងកំពូលភ្នំ ឬដូចបុគ្គលឡើងភ្នំ ក៏ត្រូវលុតជង្គង់របស់ខ្លួនប៉ុណ្ណោះ ។

## អរូបាវចរកុសល ចប់

# អភិធម្មបិដក

## កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣

## កាមាវចរកុសល

[ ១៩៣ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ ចិត្តជាកាមាវចរកុសលកើតឡើង ជាចិត្តប្រទ្បំដោយសោមនស្សប្រកបដោយញាណដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានឆន្ទៈជាអធិបតី ។បេ។ មានវិរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានវីមំសាជាអធិបតី ។បេ។ មានឆន្ទៈជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានវិរិយៈជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានចិត្តជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានវីមំសា ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ ចិត្តជាកាមាវចរកុសលកើតឡើង ជាចិត្តប្រទ្បំដោយសោមនស្សប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រទ្បំ

ដោយឧបេក្ខា ប្រាសចាកញាណប្រកបដោយសង្ខារដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានឆន្ទៈជាអធិបតី ។បេ។ មានវិរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានឆន្ទៈជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវិរិយៈជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានចិត្តជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## កាមាវចរកុសល ចប់

[ ១៩៤ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានឈ្មោះបឋវីកសិណដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានឆន្ទៈជាអធិបតី ។បេ។ មានវិរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានវីមំសាជាអធិបតី ។បេ។ មានឆន្ទៈជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវិរិយៈជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានចិត្តជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវីមំសាជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន

ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កនិងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈានឈ្មោះបឋវីកសិណដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានឆន្ទៈជាអធិបតី ។បេ។ មានវីរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានវីមំសាជាអធិបតី ។បេ។ មានឆន្ទៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវីរិយៈជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ មានចិត្តជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវីមំសាជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## រូបាវចរកុសល ចប់

[ ១៩៥ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងបង់នូវពួករូបសញ្ញា ព្រោះវិនាសបដិឃ-សញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ព្រោះលះបង់សុខផងដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកាសា-នញ្ចាយតនសញ្ញាដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានឆន្ទៈជាអធិបតី ។បេ។ មានវីរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិ-

បតី ។បេ។ មានវីមំសា ជាអធិបតី ។បេ។ មានឆន្ទៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានវីរិយៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានចិត្ត ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានវីមំសា ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព កន្លងបង់នូវអាកាសានញ្ចាយតនៈ ព្រោះលះបង់នូវសុខផង ដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយវិញ្ញាណញ្ចាយតនសញ្ញាដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានឆន្ទៈ ជាអធិបតី ។បេ។ មានវីរិយៈ ជាអធិបតី ។បេ។ មានចិត្ត ជាអធិបតី ។បេ។ មានវីមំសា ជាអធិបតី ។បេ។ មានឆន្ទៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានវីរិយៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានចិត្ត ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ។បេ។ មានវីមំសា ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្ដាល ។បេ។ ដ៏ឧត្ដម ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះ

កន្លងបង់នូវវិញ្ញាណញ្ចាយតនៈ ព្រោះលះបង់សុខផង ដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកិញ្ចញ្ញាយតនសញ្ញាដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានឆន្ទៈ ជាអធិបតី ។បេ។ មានវិរិយៈ ជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានវីមំសា ជាអធិបតី ។បេ។ មានឆន្ទៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវិរិយៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានចិត្ត ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវីមំសា ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តមក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនៈ ព្រោះលះបង់នូវសុខផង ដោយអាការទាំងពួង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញា-នាសញ្ញាយតនសញ្ញាដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានឆន្ទៈ ជាអធិបតី ។បេ។ មានវិរិយៈ ជាអធិបតី ។បេ។ មានចិត្ត ជាអធិបតី ។បេ។ មានវីមំសា ជាអធិបតី ។បេ។ មានឆន្ទៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវិរិយៈ ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានចិត្ត ជាអធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ។បេ។ មានវីមំសា ជា

អធិបតីដ៏ថោកទាប ។បេ។ ជាកណ្តាល ។បេ។ ដ៏ឧត្តម ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## អរូបាវចរកុសល ចប់

# អដ្ឋកថា

## កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣

[ ១៩៣-១៩៥ ] ព្រោះកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់នេះ រមែងប្រព្រឹត្តទៅដោយប្រភេទ មានថោកទាបជាដើម ហេតុនោះ ឥឡូវនេះ ដើម្បីសម្តែងប្រភេទនោះនៃធម៌ទាំងនោះ ទើបទ្រង់ផ្តើមពាក្យជាដើមថា **កតមេ ធម្មា កុសលា** ដូច្នេះទៀត ។

បណ្តាបទទាំងនោះ បទថា **ហីនំ** បានដល់ លាមក គឺថោកទាប គប្បីជ្រាបកុសលថោកទាប ដោយអំណាចនៃការប្រមូលមក ។ កុសលដែលមានក្នុងកណ្តាលនៃហីនៈ និងឧត្តម ឈ្មោះថា **មជ្ឈិម** ។ កុសលដែលនាំទៅកាន់សេចក្តីព្យាយាម ឈ្មោះថា **ប្រណីត** បានដល់ កុសលដែលឧត្តម ។ បណ្ឌិតគប្បីជ្រាបកុសលទាំងនោះ ដោយអំណាចការប្រមូលមកនុ៎ះឯង ។

ពិតហើយ ក្នុងខណៈដែលប្រមូលមកនូវកុសលណា នឹងជាឆន្ទៈ វិរិយៈ ចិត្តៈ ឬវីមំសា ជាហីនៈមាន កុសលនោះ ឈ្មោះថា **ថោកទាប** ។ ធម៌ទាំងនោះ ជាមជ្ឈិម ប្រណីតនៃកុសលណា កុសលនោះ ឈ្មោះថា មជ្ឈិម និងឧត្តម ។ កុសលណាប្រមូលមកនូវឆន្ទៈ គឺភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ ធ្វើឆន្ទៈឲ្យជាធុរៈ ឲ្យជាធំ ឲ្យជាប្រធាន កុសលនោះ ឈ្មោះថា មានឆន្ទៈជាអធិបតី ព្រោះកុសលមកហើយ ដោយមានឆន្ទៈជាធំ ឯក្នុងវិរិយាធិបតេយ្យជាដើម ក៏ន័យនេះឯង ។

តែក្នុងទីនេះ គប្បីកាន់យកន័យទាំងឡាយ ដែលតាំងទុកហើយ គឺន័យដែលចែកទុកមុន ជាងន័យទាំងអស់ ជាន័យ ១ ពាក្យថា **ហីន** ជាន័យ ១

ពាក្យថា **មជ្ឈិម** ជាន័យ ១ ពាក្យថា **បណីត** ជាន័យ ១ ពាក្យថា **ឆន្ទាធិបតេយ្យ** ជាន័យ ១ ន័យទាំង ៥ នេះ ក្នុងឆន្ទាធិបតេយ្យប៉ុណ្ណេះ មុន ៗ សូម្បីក្នុងវិរិយាធិបតេយ្យជាដើមក៏យ៉ាងនេះ ព្រោះហេតុនោះ បញ្ចក-ន័យទាំង ៤ ទើបជា ២០ ន័យ ។ ម្យ៉ាងទៀត ជា ២០ ន័យយ៉ាងនេះ គឺន័យដំបូងជាសុទ្ធិកន័យ ១ ន័យ ៣ មានហីនៈជាដើម ន័យ ៤ មានឆន្ទាធិបតេយ្យជាដើម និងន័យ ១២ មានឆន្ទាធិបតីថោកទាបជាដើម ។

ន័យទាំងនេះ ជាមហាន័យ ២០ មុន ៗ សួរថា ទ្រង់ចែកន័យទាំងនេះក្នុងទីណា ឆ្លើយថា ទ្រង់ចែកក្នុងហីនត្តិកៈ ក្នុងមហាបករណ៍ ។ តែក្នុងទីនេះ គប្បីកាន់យកកងធម៌មជ្ឈិមចាកហីនត្តិកៈ ហើយចែកជា ៣ ចំណែកដោយអំណាចហីនៈ មជ្ឈិម បណីត គប្បីវៀរកងធម៌មជ្ឈិមចាកហីនត្តិកៈនោះហើយ កាន់យកហីនៈ និងបណីត ហើយចែកចេញជានីមួយៗ ៩ ចំណែក ព្រោះថា ក្នុងហីនៈនុ៎ះឯង កុសលធម៌ដែលជាហីនៈក៏មាន កុសលធម៌ដែលជាមជ្ឈិមក៏មាន កុសលធម៌ដែលជាបណីតក៏មាន សូម្បីក្នុងបណីតសោត កុសលធម៌ដែលជាហីនៈក៏មាន កុសលធម៌ដែលជាមជ្ឈិមក៏មាន កុសលធម៌ដែលជាបណីតក៏មាន ៗ មួយទៀត ក្នុងធម៌ដែលជាហីនៈក្នុងហីនៈ កុសល-ធម៌ដែលជាហីនៈក៏មាន ក្នុងធម៌ដែលជាហីនៈក្នុងហីនៈ កុសលធម៌ដែលជាមជ្ឈិមក៏មាន ក្នុងធម៌ដែលជាហីនៈក្នុងហីនៈ កុសលធម៌ដែលជាបណីតក៏មាន ក្នុងធម៌ដែលជាមជ្ឈិមក្នុងហីនៈ កុសលធម៌ដែលជាហីនៈក៏មាន ក្នុងធម៌ដែលជាមជ្ឈិមក្នុងហីនៈ កុសលធម៌ដែលជាមជ្ឈិមក៏មាន ក្នុងធម៌ដែលជាមជ្ឈិម

ក្នុងហីនៈ កុសលធម៌ដែលជាបណីតក៏មាន ក្នុងធម៌ដែលជាបណីតក្នុងហីនៈ កុសលធម៌ដែលជាហីនៈក៏មាន ក្នុងធម៌ដែលជាបណីតក្នុងហីនៈ កុសលធម៌ដែលជាមជ្ឈិមក៏មាន ក្នុងធម៌ដែលជាបណីតក្នុងហីនៈ កុសលធម៌ដែលជាបណីតក៏មាន នេះហៅថា នវកៈ ១ ។

សូម្បីក្នុងធម៌ដែលជាហីនៈក្នុងបណីត ឈ្មោះថា កុសលធម៌ដែលជាហីនៈក៏មាន ក្នុងធម៌ដែលជាហីនៈក្នុងបណីត កុសលធម៌ដែលជាមជ្ឈិមក៏មាន ក្នុងធម៌ដែលជាហីនៈក្នុងបណីត កុសលធម៌ដែលជាបណីតក៏មាន ។ មួយទៀត ក្នុងធម៌ដែលជាមជ្ឈិមក្នុងបណីត កុសលធម៌ដែលជាហីនៈក៏មាន ក្នុងធម៌ដែលជាមជ្ឈិមក្នុងបណីត កុសលធម៌ដែលជាមជ្ឈិមក៏មាន ក្នុងធម៌ដែលជាមជ្ឈិមក្នុងបណីត កុសលធម៌ដែលជាបណីតក៏មាន ក្នុងធម៌ដែលជាបណីតក្នុងបណីត កុសលធម៌ដែលជាហីនៈក៏មាន ក្នុងធម៌ដែលជាបណីតក្នុងបណីត កុសលធម៌ដែលជាមជ្ឈិមក៏មាន ក្នុងធម៌ដែលជាបណីតក្នុងបណីត កុសល-ធម៌ដែលជាបណីតក៏មាន នេះជានវកៈទី ២ ។ ព្រោះហេតុនោះ រួមនវកៈទាំងពីរជាធម៌ ១៨ ។ ធម៌ទាំង ១៨ នេះ ឈ្មោះថា **កម្មទ្វារ** ។ គប្បីជ្រាបក្សត្រ ១៨ ព្រាហ្មណ៍ ១៨ វេស្សៈ ១៨ សូទ្រៈ ១៨ គោត្តចរណៈ ៤៨ ដោយអំណាចនៃកម្មទ្វារទាំងនេះ ព្រោះភាពជាអ្នកអប់រំហើយដោយកម្មទ្វារទាំង ១៨ នេះ ។

បណ្ដាកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នេះ កាមាវចរកុសលជា**តិ**ហេតុកៈខ្លះ ទុហេតុកៈខ្លះ ដោយការសម្បយុត្តដោយញាណ និងវិប្ប-

យុត្តបាកញ្ញាណ តែរូបាវចរ និងអរូបាវចរ ជា**តិ**ហេតុកតែម្យ៉ាង គឺជាញាណ-សម្បយុត្តប៉ុណ្ណោះ ក្នុងកុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នេះ កាមាវចរកុសល រមែងកើតរួមគ្នាជាមួយនឹងអធិបតីខ្លះ វៀរចាកអធិបតីខ្លះ ។ តែរូបាវចរកុសល និងអរូបាវចរកុសល រមែងសម្បយុត្តដោយអធិបតី-ប៉ុណ្ណោះ ។ ក្នុងកុសលប្រកបដោយភូមិ ៣ នេះ ក្នុងកាមាវចរកុសល បាន អធិបតីត្រឹមតែ ២ ប៉ុណ្ណោះ គឺ អារម្មណាធិបតី សហជាតាធិបតី ។ ក្នុង រូបាវចរកុសល និងអរូបាវចរកុសល រមែងមិនបានអារម្មណាធិបតី រមែង បានចំពោះសហជាតាធិបតីប៉ុណ្ណោះ ។ ក្នុងសហជាតាធិបតីទាំងនោះ ត្រាស់ ភាពដែលចិត្តជាចិត្តាធិបតេយ្យ ដោយអំណាចសម្បយុត្តធម៌ទាំងឡាយ ។ តែព្រោះចិត្ត ២ ដួង មិនមានព្រមគ្នា ឈ្មោះថា **ចិត្តាធិបតិ** របស់សម្ប-យុត្តចិត្តក៏មិនមាន ។ មួយទៀត ឆន្ទាធិបតីជាដើមនៃធម៌មានឆន្ទៈជាដើមក៏ ដូចគ្នា ។ តែអាចារ្យពួកខ្លះ រមែងប្រាថ្នាឈ្មោះអធិបតីដោយអំណាចនៃការ មកយ៉ាងនេះថា កុសលចិត្តដួងដទៃទៀត ធ្វើចិត្តណា ឲ្យជាធុរៈ ឲ្យជាធំ ប្រមូលមកហើយយ៉ាងនេះថា បើកុសលធម៌មានដល់បុគ្គលអ្នកមានចិត្តសោត កុសលធម៌ក៏នឹងមានដល់អញ ចិត្តដើមនោះរបស់បុគ្គលនោះ ឈ្មោះថា ជា ចិត្តាធិបតី ចិត្តនេះ ឈ្មោះថា ចិត្តាធិបតេយ្យ ព្រោះមកពីចិត្តដួងនោះ ។ ន័យនេះ មិនប្រាកដក្នុងព្រះបាលី និងអដ្ឋកថា ព្រោះហេតុនោះ គប្បីជ្រាប ភាពដែលចិត្តជាអធិបតី ដោយន័យដែលពោលហើយនុ៎ះឯង ។

ក្នុងមហាន័យទាំង ១៩ នេះ ចិត្តទាំងឡាយ នវកៈទាំងឡាយ និងវារៈ

នៃព្រះបាលីទាំងឡាយ មានប្រមាណតាមដែលពោលហើយ ក្នុងសុទ្ធិកន័យ ដែលមានក្នុងកាលមុននោះឯង ។ ព្រោះហេតុនោះ គប្បីជ្រាបប្រភេទនៃចិត្ត នវកៈ និងវារៈដែលគុណដោយ ២០ ដោយប្រមាណដែលពោលក្នុងញាណសម្បយុត្ត និងគុណដោយ ១៦ ក្នុងញាណវិប្បយុត្ត ៤ នេះ ឈ្មោះថា **បកិណ្ណកកថា** ក្នុងកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយប្រការដូច្នេះ ឯង ។

## កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចប់

# អភិធម្មបិដក

## លោកុត្តរកុសល

[ ១៩៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ជាឈានដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាដំបូង បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានតែបីតិ និងសុខដ៏កើតអំពីទីស្ងាត់នោះ មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្ក វិចារ បីតិ សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សម្បជញ្ញៈ សមថៈ វិបស្សនា សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយកើតឡើង ក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែល

កើតឡើងដោយអាស្រ័យហេតុ រមែងកើតមាន ក្នុងសម័យនោះ ។ នេះពួកធម៌ជាកុសល ។

[ ១៩៧ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈ កើតមាន ក្នុងសម័យនោះ ។

[ ១៩៨ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់សេចក្ដីឆ្ងាញ់ពិសា និងសេចក្ដីសុខនោះ ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ កើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនា កើតមាន ក្នុងសម័យនោះ ។

[ ១៩៩ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សញ្ញា សេចក្ដីសម្គាល់ សេចក្ដីចាំបានណា កើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់កុសលសញ្ញានោះ នេះសញ្ញា កើតមានក្នុងសម័យនោះ ។

[ ២០០ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ចេតនា សេចក្ដីរិះគិត ការតាក់តែងណា កើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់កុសលចេតនានោះ នេះចេតនា កើតមានក្នុងសម័យនោះ ។

[ ២០១ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា

មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដ៏សមគួរដល់ធម៌មានផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះចិត្តកើតមានក្នុងសម័យនោះ ។

[ ២០២ ] វិតក្ក កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកចិត្តឡើង គឺសម្មាសង្កប្បៈជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះវិតក្កកើតមានក្នុងសម័យនោះ ។

[ ២០៣ ] វិចារ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រួតត្រា ការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការផ្គងនូវចិត្ត ការសម្លឹងមើលណា ក្នុងសម័យនោះ នេះវិចារ កើតមានក្នុងសម័យនោះ ។

[ ២០៤ ] បីតិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល សេចក្តីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណរ ការអណ្តែតអណ្តូង សេចក្តីត្រេកអររបស់ចិត្ត គឺបីតិសម្ពោជ្ឈង្គណា កើតមានក្នុងសម័យនោះ នេះបីតិកើតមានក្នុងសម័យនោះ ។

[ ២០៥ ] សុខ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសុខ

កើតមានក្នុងសម័យនោះ ។

[ ២០៦ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់ស្ងាប់ គឺសមាធិន្ទ្រិយ សមាធិ-ពល សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា របស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ២០៧ ] សទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ជំនឿ សេចក្ដីជឿ សេចក្ដីជឿស៊ប់ សេចក្ដីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលណា ក្នុងសម័យនោះ នេះសទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២០៨ ] វីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីឧហាត សង្ខាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្ដីសង្វាត ការមិនធូរថយ ការមិនដាក់ចុះនូវសេចក្ដីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងនូវធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះវីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២០៩ ] សតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីរឭក សេចក្ដីរឭករឿយៗ សេចក្ដីរឭកចំពោះ ស្មារតី សេចក្ដីនឹកបាន

ការចាំបាន ការមិនកាន់ប្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិ-ពល សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសតិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២១០ ] សមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ សភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណារបស់ចិត្ត ក្នុងសម័យនោះ នេះសមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២១១ ] បញ្ញិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតដូចជាផែនដី ធម្មជាតកម្ចាត់បង់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះបញ្ញិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ២១២ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោ-វិញ្ញាណធាតុ ដ៏សមគួរដល់ធម៌ មានផស្សៈជាដើមនោះណា ក្នុងសម័យនោះ នេះមនិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ២១៣ ] សោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២១៤ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការស្ថិតនៅ ការឃើននៅ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តិទៅ ការរក្សា គឺជីវិត ជីវិតិន្ទ្រិយណា នៃអរូបធម៌ទាំងនោះ ក្នុងសម័យនោះ នេះជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២១៥ ] អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ កើតមាន ក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចា-រណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្តីជ្រះស្អាត ភាពនៃអ្នកមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតដូចជាផែនដី ធម្មជាតកម្ចាត់

កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ ការដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្វុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ ដែលសត្វមិនទាន់ស្គាល់ មិនទាន់ឃើញ មិនទាន់ដល់ មិនទាន់ដឹងច្បាស់ មិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២១៦ ] សម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្តីជ្រះស្អាត ភាពនៃអ្នកមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតដូចផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្វុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ ។

[ ២១៧ ] សម្មាសង្កប្បៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្ត

គឺសម្មាសង្កប្បៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះសម្មាសង្កប្បៈ កើតមានក្នុងសម័យនោះ ។

[ ២១៨ ] សម្មាវាចា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការវៀរ ការចៀសវាង ការគេចចេញ ការងាកចេញចាកវចីទុច្ចរិតទាំង ៤ គឺមិនសាង មិនធ្វើ មិនប្រព្រឹត្តល្មើស ការមិនប្រព្រឹត្តកន្លងដែន ការសម្លាប់ហេតុ គឺសម្មាវាចា ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្មាវាចា កើតមានក្នុងសម័យនោះ ។

[ ២១៩ ] សម្មាកម្មន្តៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការវៀរ ការចៀសវាង ការគេចចេញ ការងាកចេញចាកកាយទុច្ចរិតទាំង ៣ គឺមិនសាង មិនធ្វើ មិនប្រព្រឹត្តល្មើស មិនប្រព្រឹត្តកន្លងដែន ការសម្លាប់ហេតុ គឺសម្មាកម្មន្តៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្មាកម្មន្តៈ កើតមានក្នុងសម័យនោះ ។

[ ២២០ ] សម្មាអាជីវៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការវៀរ ការចៀសវាង ការគេចចេញ ការងាកចេញចាកការចិញ្ចឹមជីវិតខុស គឺមិនសាង មិនធ្វើ មិនប្រព្រឹត្តល្មើស មិនប្រព្រឹត្តកន្លងដែន ការសម្លាប់ហេតុ គឺសម្មាអាជីវៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្មាអាជីវៈ កើតមានក្នុងសម័យនោះ ។

[ ២២១ ] សម្មាវាយាមៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សង្វាត ខិតខំ

ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្ដីសង្វាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្ដីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវិរិយៈ វិរិ-យិន្ទ្រិយ វិរិយពល សម្មាវាយាមៈ វិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្មាវាយាមៈ កើតមានក្នុងសម័យនោះ ។

[ ២២២ ] សម្មាសតិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីរឭក សេចក្ដីរឭករឿយៗ ការរឭកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនកាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្មាសតិ កើតមានក្នុងសម័យនោះ ។

[ ២២៣ ] សម្មាសមាធិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមា-ធិពល សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា របស់ចិត្ត ក្នុងសម័យនោះ នេះសម្មាសមាធិ កើតមានក្នុងសម័យនោះ ។

[ ២២៤ ] សទ្ធាពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ជំនឿ សេចក្ដីជឿ សេចក្ដីជឿស៊ប់ ការជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពល ណា ក្នុងសម័យនោះ នេះសទ្ធាពល កើតមានក្នុងសម័យនោះ ។

[ ២២៥ ] វីរិយពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឧហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្វាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈគឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គៈជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះវីរិយពលៈកើតមានក្នុងសម័យនោះ ។

[ ២២៦ ] សតិពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសតិពល កើតមានក្នុងសម័យនោះ ។

[ ២២៧ ] សមាធិពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា របស់ចិត្ត ក្នុងសម័យនោះ នេះសមាធិពល កើតមានក្នុងសម័យនោះ ។

[ ២២៨ ] បញ្ញាពល កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណា

ធម៌ ការកំណត់ ការកត់សម្គាល់ សេចក្ដីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្ដីជ្រះស្អាត ភាពនៃអ្នកមានសេចក្ដីភ្លឺច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតដូចផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងឆ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះបញ្ញាពលកើតមាន ក្នុងសម័យនោះ ។

[ ២២៩ ] ហិរិពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលខ្មាសដោយវត្ថុដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនឹងអកុ-សលធម៌ដ៏លាមកក្នុងសម័យនោះ នេះហិរិពល កើតមានក្នុងសម័យនោះ ។

[ ២៣០ ] ឱត្តប្បពល កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលតក់ស្លុតដោយវត្ថុដែលគួរតក់ស្លុត តក់ស្លុតដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះឱត្តប្បពល កើតមានក្នុងសម័យនោះ ។

[ ២៣១ ] អលោភៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការមិនចង់បាន ការមិនជាប់ជំពាក់ សេចក្ដីមិនជាប់ជំពាក់ ការមិនត្រេកអរខ្លាំង ការមិនត្រេកត្រអាល សេចក្ដីមិនត្រេកត្រអាល ការមិនសម្លឹងចំពោះ គឺអលោភៈជាកុសលមូលណាក្នុងសម័យនោះ នេះអលោភៈកើតមានក្នុងសម័យ

នោះ ។

[ ២៣២ ] អទោសៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីមិនទឹង ការមិនប្រទូស្ត សេចក្ដីមិនប្រទូស្ត ការមិនព្យាបាទ សេចក្ដីមិនព្យាបាទ គឺអទោសៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអទោសៈ កើតមានក្នុងសម័យនោះ ។

[ ២៣៣ ] អមោហៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ បញ្ញា សេចក្ដីដឹងសព្វ សេចក្ដីពិចារណា សេចក្ដីជ្រើសរើស សេចក្ដីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្ដីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្ដីជ្រះស្អាត ភាពនៃអ្នកមានសេចក្ដីភ្លឺច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតដូចផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្ទុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះអមោហៈ កើតមានក្នុងសម័យនោះ ។

[ ២៣៤ ] អនភិជ្ឈា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការមិនចង់បាន ការមិនជាប់ជំពាក់ សេចក្ដីមិនជាប់ជំពាក់ ការមិនត្រេកអរខ្វាំង ការមិនត្រេកត្រអាល សេចក្ដីមិនត្រេកត្រអាល ការមិនសម្លឹងចំពោះ គឺអលោភៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអនភិជ្ឈា កើតមានក្នុង

សម័យនោះ ។

[ ២៣៥ ] អព្យាបាទ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីមិនខឹង ការមិនប្រទូស្ត សេចក្ដីមិនប្រទូស្ត ការមិនព្យាបាទ គឺអទោសៈ ជាកុសលមូលណា ក្នុងសម័យនោះ នេះអព្យាបាទ កើតមានក្នុងសម័យនោះ ។

[ ២៣៦ ] សម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ បញ្ញា សេចក្ដីដឹងសព្វ សេចក្ដីពិចារណា សេចក្ដីជ្រើសរើស សេចក្ដីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្ដីជ្រះស្អាត ភាពនៃអ្នកមានសេចក្ដីភ្លឺច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតដូចផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជន្ទញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ ។

[ ២៣៧ ] ហិរិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលខ្មាស ដោយវត្ថុដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះហិរិ កើតមានក្នុងសម័យនោះ ។

[ ២៣៨ ] ឱត្តប្បៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ត្រង់ដែល

បុគ្គលតក់ស្លុតដោយវត្ថុដែលគួរតក់ស្លុត តក់ស្លុតដោយការជួបប្រទះនឹងអកុ-សលធម៌ដ៏លាមក ក្នុងសម័យនោះ នេះឱត្តប្បៈ កើតមានក្នុងសម័យនោះ ។

[ ២៣៩ ] សេចក្តីស្ងប់កាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្ងប់ សេចក្តីរម្ងាប់ ការស្ងប់ ការរម្ងាប់ សេចក្តីស្ងៀមស្ងាត់ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ គឺបស្សទ្ធិសម្ពោជ្ឈង្គ ក្នុងសម័យនោះ នេះសេចក្តីស្ងប់កាយ កើតមានក្នុងសម័យនោះ ។

[ ២៤០ ] សេចក្តីស្ងប់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្ងប់ សេចក្តីរម្ងាប់ ការស្ងប់ ការរម្ងាប់ សេចក្តីស្ងៀមស្ងាត់ណា នៃវិញ្ញាណក្ខន្ធ គឺបស្សទ្ធិសម្ពោជ្ឈង្គក្នុងសម័យនោះ នេះសេចក្តីស្ងប់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ២៤១ ] សេចក្តីស្រាលកាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្រាល ការបង្អោនទៅដោយរហ័ស សេចក្តីមិនយឺតយូរ សេចក្តីមិនទម្រន់ណានៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីស្រាលកាយ កើតមានក្នុងសម័យនោះ ។

[ ២៤២ ] សេចក្តីស្រាលចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីស្រាល ការបង្អោនទៅដោយរហ័ស ការមិនយឺតយូរ ការមិនទម្រន់ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្តីស្រាលចិត្ត កើតមានក្នុងសម័យនោះ ។

[ ២៤៣ ] សេចក្តីទន់កាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។

សេចក្ដីទន់ សេចក្ដីទោរ សេចក្ដីមិនរឹង មិនរបឹងណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្ដីទន់កាយ កើតមានក្នុងសម័យនោះ ។

[ ២៤៤ ] សេចក្ដីទន់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីទន់ សេចក្ដីទោរ សេចក្ដីមិនរឹង មិនរបឹងណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្ដីទន់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ២៤៥ ] កាយគួរដល់ការងារ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការគួរដល់ការងារ សេចក្ដីគួរដល់ការងារ សភាពគួរដល់ការងារណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះកាយគួរដល់ការងារ កើតមានក្នុងសម័យនោះ ។

[ ២៤៦ ] ចិត្តគួរដល់ការងារ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការគួរដល់ការងារ សេចក្ដីគួរដល់ការងារ សភាពគួរដល់ការងារណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះចិត្តគួរដល់ការងារ កើតមានក្នុងសម័យនោះ ។

[ ២៤៧ ] សេចក្ដីស្ទាត់កាយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ទាត់ សេចក្ដីស្ទាត់ សភាពស្ទាត់ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធក្នុងសម័យនោះ នេះសេចក្ដីស្ទាត់កាយ កើតមានក្នុងសម័យនោះ ។

[ ២៤៨ ] សេចក្ដីស្ទាត់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការស្ទាត់ សេចក្ដីស្ទាត់ សភាពស្ទាត់ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ

នេះសេចក្ដីស្ងាត់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ២៤៩ ] សេចក្ដីត្រង់កាយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការត្រង់ សេចក្ដីត្រង់ ការមិនវៀច មិនកោង មិនរំពត់ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្ដីត្រង់កាយ កើតមានក្នុងសម័យនោះ ។

[ ២៥០ ] សេចក្ដីត្រង់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការត្រង់ សេចក្ដីត្រង់ ការមិនវៀច មិនកោង មិនរំពត់ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្ដីត្រង់ចិត្ត កើតមានក្នុងសម័យនោះ ។

[ ២៥១ ] សតិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីរឭក សេចក្ដីរឭករឿយៗ សេចក្ដីតាំងស្មារតីចំពោះ ការទឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសតិ កើតមានក្នុងសម័យនោះ ។

[ ២៥២ ] សម្បជញ្ញៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្ដីជ្រះស្អាត ភាពនៃអ្នកមានសេចក្ដីភ្លឺច្បាស់ សេចក្ដីគិត សេចក្ដីយល់ ធម្មជាតដូចជាផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជាជន្ទួញ គឺបញ្ញា បញ្ញិន្ទ្រិយ

បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្ម-វិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសម្បជញ្ញៈ កើតមានក្នុងសម័យនោះ ។

[ ២៥៣ ] សមថៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ សភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណារបស់ចិត្តក្នុងសម័យនោះ នេះសមថៈកើតមានក្នុងសម័យនោះ ។

[ ២៥៤ ] វិបស្សនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្តីជ្រះស្អាត ភាពនៃអ្នកមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតដូចផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងផ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្ម-វិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះវិបស្សនា កើតមានក្នុងសម័យនោះ ។

[ ២៥៥ ] សេចក្តីផ្គងឡើង កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សន្ធាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសន្ធាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ក្នុងសម័យនោះ នេះសេចក្តីផ្គងឡើង កើតមានក្នុងសម័យនោះ ។

[ ២៥៦ ] សេចក្តីមិនរាយមាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការស្ថិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ សភាពនៃចិត្ត មិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពល សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា របស់ចិត្ត ក្នុងសម័យនោះ នេះសេចក្តីមិនរាយមាយ កើតមានក្នុងសម័យនោះ ។

[ ២៥៧ ] មួយទៀត ពួកអរូបធម៌ដទៃណា ដែលកើតឡើងដោយអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

[ ២៥៨ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៩ ឈានប្រកបដោយអង្គ ៥ មគ្គប្រកបដោយអង្គ ៨ ពល ៧ ហេតុ ៣ ផស្សៈ ១ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ មនាយតនៈ ១

មនិន្ទ្រិយ ១ មនោវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតដោយអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។បេ។

[ ២៥៩ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្ក វិចារ បីតិ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជីវិតិន្ទ្រិយ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មា-វាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពល វីរិយពល សតិពល សមាធិពល បញ្ញាពល ហិរិពល ឱត្តប្បពល អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សម្បជញ្ញៈ សមថៈ វិបស្សនា សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ ឬក៏ពួកអរូបធម៌ដទៃណា ក្រៅអំពីវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ដែលកើតដោយអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ២៦០ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុ-ត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះ

បង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ២៦១ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ២៦២ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ២៦៣ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។

បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

[ ២៦៤ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងឆាប់ ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងយឺតយូរ ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងឆាប់ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## សុទ្ធិកប្បដិបទា ចប់

[ ២៦៥ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន សុញ្ញ ( ចាករាគៈជាដើម ) ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយក៏កើតមាន ក្នុង

សម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កនិងវិចាររួចហើយ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈានដ៏សូន្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## សុញ្ញតៈ ចប់

[ ២៦៦ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ដ៏សូន្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងឆាប់ ដ៏សូន្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយ

មាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ តែមានសេចក្តីត្រាស់ដឹងយឺតយូរ ដ៏សុន្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ដ៏សុន្យ ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ដ៏សុន្យ ។បេ។ មានសេចក្តីប្រតិបត្តិលំបាក តែមានសេចក្តីត្រាស់ដឹងឆាប់ ដ៏

សូន្យ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងយឺតយូរ ដ៏សូន្យ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានសេចក្តីត្រាស់ដឹងឆាប់ ដ៏សូន្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## សុញ្ញតមូលកប្បដិបទា ចប់

[ ២៦៧ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ( និព្វានគ្មានកិលេសជាគ្រឿងតម្កល់ខ្ជាប់ ) ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ជាអប្បណិហិតៈក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

## ឈានជាអប្បណិហិតៈ ចប់

[ ២៦៨ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ តែមានសេចក្តីត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន

ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈ និងវិចាររួចហើយ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក តែមានសេចក្ដីត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ។បេ។ មានសេចក្ដីប្រតិបត្តិងាយ តែមានសេចក្ដីត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានសេចក្ដីត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្ដីមិនរាយមាយ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។

អប្បណិហិតមូលកប្បដិបទា ចប់

[ ២៦៩ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរមគ្គ ។បេ។ ចម្រើននូវសតិប្បដ្ឋាន ជាលោកុត្តរ ។បេ។ ចម្រើននូវសម្មប្បធាន ជាលោកុត្តរ ។បេ។ ចម្រើននូវឥទ្ធិបាទ ជាលោកុត្តរ ។បេ។ ចម្រើននូវឥន្ទ្រិយ ជាលោកុត្តរ ។បេ។ ចម្រើននូវពល ជាលោកុត្តរ ។បេ។ ចម្រើននូវពោជ្ឈង្គ ជាលោកុត្តរ ។បេ។ ចម្រើននូវសច្ចៈ ជាលោកុត្តរ ។បេ។ ចម្រើននូវសមថៈ ជាលោកុត្តរ ។បេ។ ចម្រើននូវធម៌ ជាលោកុត្តរ ។បេ។ ចម្រើននូវខន្ធ ជាលោកុត្តរ ។បេ។ ចម្រើននូវអាយតនៈ ជាលោកុត្តរ ។បេ។ ចម្រើននូវធាតុ ជាលោកុត្តរ ។បេ។ ចម្រើននូវអាហារ ជាលោកុត្តរ ។បេ។ ចម្រើននូវផស្សៈ ជាលោកុត្តរ ។បេ។ ចម្រើននូវវេទនា ជាលោកុត្តរ ។បេ។ ចម្រើននូវសញ្ញា ជាលោកុត្តរ ។បេ។ ចម្រើននូវចេតនា ជាលោកុត្តរ ។បេ។ ចម្រើននូវចិត្ត ជាលោកុត្តរ ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

មហាន័យ ២០ ចប់

[ ២៧០ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានឆន្ទៈជាអធិបតី ។បេ។ មានវីរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានវីមំសាជាអធិបតី ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្ក និងវិចាររួចហើយ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ មានឆន្ទៈជាអធិបតី ។បេ។ មានវីរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានវីមំសាជាអធិបតីក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។ ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរមគ្គ ។បេ។ ចម្រើននូវសតិប្បដ្ឋាន ជាលោកុត្តរ ។បេ។ ចម្រើននូវសម្មប្បធាន ជាលោកុត្តរ ។បេ។ ចម្រើននូវឥទ្ធិបាទជាលោកុត្តរ ។បេ។ ចម្រើននូវឥន្ទ្រិយជា

លោកុត្តរ ។បេ។ ចម្រើននូវពល ជាលោកុត្តរ ។បេ។ ចម្រើននូវពោជ្ឈង្គ ជាលោកុត្តរ ។បេ។ ចម្រើននូវសច្ចៈ ជាលោកុត្តរ ។បេ។ ចម្រើននូវសមថៈ ជាលោកុត្តរ ។បេ។ ចម្រើននូវធម៌ ជាលោកុត្តរ ។បេ។ ចម្រើននូវខន្ធជា លោកុត្តរ ។បេ។ ចម្រើននូវអាយតនៈ ជាលោកុត្តរ ។បេ។ ចម្រើននូវធាតុ ជាលោកុត្តរ ។បេ។ ចម្រើននូវអាហារ ជាលោកុត្តរ ។បេ។ ចម្រើននូវ ផស្សៈ ជាលោកុត្តរ ។បេ។ ចម្រើននូវវេទនា ជាលោកុត្តរ ។បេ។ ចម្រើន នូវសញ្ញា ជាលោកុត្តរ ។បេ។ ចម្រើននូវចេតនា ជាលោកុត្តរ ។បេ។ ចម្រើន នូវចិត្ត ជាលោកុត្តរ ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំង ឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តី ត្រាស់ដឹងយឺតយូរ មានឆន្ទៈជាអធិបតី ។បេ។ មានវីរិយៈជាអធិបតី ។បេ។ មានចិត្តជាអធិបតី ។បេ។ មានវីមំសាជាអធិបតី ក្នុងសម័យណា ផស្សៈក៏ កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យ នោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

**អធិបតី ចប់**

**មគ្គទី ១ ចប់**

# អដ្ឋកថា

## លោកុត្តរកុសល

[ ១៩៦-២៧០ ] ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងកុសល ដែលញ៉ាំងសម្បត្តិក្នុងភព ៣ ឲ្យកើតឡើងយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងលោកុត្តរកុសល ដើម្បីឈានកន្លងភពទាំងអស់ ទើបទ្រង់ផ្តើមពាក្យថា **កតមេ ធម្មា កុសលា** ជាដើមទៀត ។ បណ្តាបទទាំងនោះ បទថា **លោកុត្តរំ** ធម៌ដែលឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ដូចម្តេច ។ ធម៌ដែលឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ឆ្លងលោក ឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ឆ្លងផុតចាកលោកទៅ ឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ឈានកន្លង គ្របសង្កត់លោកទាំង ៣ តាំងនៅ ។

បទថា **ឈានំ ភាវេតិ** បានដល់ ព្រះយោគាវចរញ៉ាំងអប្បនាឈានដែលប្រកបក្នុងខណៈចិត្តមួយដួងឲ្យកើត គឺឲ្យចម្រើន ។

លោកុត្តរជ្ឈាន ឈ្មោះថា **និយ្យានិកំ** ព្រោះអត្ថថា ចេញទៅចាកលោក ចេញទៅចាកវដ្តៈ ន័យម្យ៉ាងទៀត ដែលឈ្មោះថា **និយ្យានិកំ** ព្រោះអត្ថថា ជាគ្រឿងចេញទៅចាកលោក និងចាកវដ្តៈនោះ ។ មែនពិត បុគ្គលដែលដល់ព្រមដោយលោកុត្តរជ្ឈាននោះ កាលកំណត់ដឹងទុក្ខ ឈ្មោះថា រមែងចេញទៅ កាលលះសមុទ័យ ឈ្មោះថា រមែងចេញទៅ កាលធ្វើឲ្យជាក់ច្បាស់នូវនិរោធ ឈ្មោះថា រមែងចេញទៅ កាលចម្រើនមគ្គ ក៏ឈ្មោះថា រមែងចេញទៅ ព្រោះហេតុនោះ ទើបលោកុត្តរជ្ឈាននោះ ឈ្មោះថា **និយ្យានិកំ** ។

កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ រមែងនាំឲ្យមានចុតិ និងបដិសន្ធិ ធ្វើឲ្យចម្រើនក្នុងវដ្តៈ ព្រោះហេតុនោះ ទើបកុសលនោះ ឈ្មោះថា **អាចយគាមី** យ៉ាងណា លោកុត្តរកុសលនេះយ៉ាងនោះក៏ទេ លោកុត្តរកុសលនេះ កើចកន្ត្រាក់ទម្លាយនូវចុតិ និងបដិសន្ធិ ដែលកុសលក្នុងភូមិ ៣ សាង ដោយធ្វើឲ្យដាច់ចុះនូវបច្ច័យទៅ ប្រៀបដូចកាលបុរសម្នាក់សាងកំពែងកម្ពស់ ១៨ ហត្ថ តែម្នាក់ទៀត យកញញួរធំរុះរើ ធ្វើឲ្យខ្ចាត់ខ្ចាយនូវទីដែលបុរសនោះកឡើងហើយគប្បីទៅ ព្រោះហេតុនោះ ទើបលោកុត្តរជ្ឈានទោះ ឈ្មោះថា **អបចយគាមី** ។

ក្នុងបទនេះថា **ទិដ្ឋិគតានំ បហានាយ** ទិដ្ឋិទាំងឡាយទុំះឯង ឈ្មោះថា **ទិដ្ឋិគត** ដូចពាក្យជាដើមថា **គូថគតំ** ជាក់លាមក **មុត្តគតំ** ជាក់មូត្រ ដូច្នេះ ។ ម្យ៉ាងទៀត ដែលឈ្មោះថា **ទិដ្ឋិគតំ** ព្រោះអត្ថថា ទៅហើយក្នុងទិដ្ឋិទាំងឡាយ ព្រោះឈមចុះក្នុងខាងក្នុងនៃទិដ្ឋិ ៦២ ។ ម្យ៉ាងទៀតធម្មជាតដែលឈ្មោះថា **ទិដ្ឋិគតំ** ព្រោះអត្ថថា មានទិដ្ឋិប្រព្រឹត្តទៅ អធិប្បាយថា សភាវៈដែលមានការទៅដូចគ្នានឹងទិដ្ឋិ គឺសភាវៈដែលប្រព្រឹត្តទៅ ដូចគ្នានឹងទិដ្ឋិ ។ សួរថា សភាវៈដែលប្រព្រឹត្តទៅទូទៅ ដូចគ្នានឹងទិដ្ឋិនោះ តើដូចម្តេច ឆ្លើយថា បានដល់ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស និងអកុសល មានរាគៈ ទោសៈ មោហៈ ដែលញ៉ាំងសត្វឲ្យទៅកាន់អបាយ ដែលសម្បយុត្តជាមួយទិដ្ឋិនោះ ។ ពិតហើយ សភាវធម៌ទាំងនោះ លោកហៅថា សភាវៈដែលមានការទៅដូចគ្នានឹងទិដ្ឋិ ព្រោះមានសភាពប្រព្រឹត្តទៅ

វេហុតដល់មគ្គទីមួយកើត ព្រោះហេតុនោះ ទិដ្ឋិទាំងឡាយផង សភាវៈដែលមានការទៅរបស់ទិដ្ឋិទាំងឡាយផង ទើបឈ្មោះថា **ទិដ្ឋិគតំ** គឺ ( ដើម្បីលះ ) ទិដ្ឋិទាំងនោះ ។ បទថា **បហានាយ** បានដល់ ដើម្បីលះដោយអំណាចសមុច្ឆេទប្បហាន ។

បទថា **បឋមាយ** បានដល់ ឈ្មោះថា **បឋម** ដោយអំណាចនៃការរាប់ខ្ទះ ដោយអំណាចនៃការកើតឡើងលើកដំបូងខ្ទះ ។ បទថា **ភូមិយា** សេចក្តីថា ក្នុងខាងដើមមហាប្រឹថពីនេះ លោកហៅថា **ភូមិ** ដូចក្នុងប្រយោគជាដើមថា **អនន្តរហិតាយ ភូមិយា** នៅលើផ្ទៃដី ប្រាសចាកគ្រឿងកម្រាលដូច្នេះ ។ **ចិត្តុប្បាទ** ក៏ហៅថា **ភូមិ** ដូចក្នុងប្រយោគជាដើមថា **សុខភូមិយំ កាមាវចរេ** ក្នុងសុខភូមិជាកាមាវចរ ដូច្នេះ ។ តែក្នុងទីនេះទ្រង់បំណងយកសាមញ្ញផល ព្រោះថា សាមញ្ញផលនោះ ឈ្មោះថា **ភូមិ** ព្រោះជាលំនៅនៃធម៌ទាំងនោះ ដ្បិតជាទីអាស្រ័យនៃសម្បយុត្តធម៌ទាំងឡាយ ម្យ៉ាងទៀតព្រោះកាលភាពជាលោកុត្តរមាន សាមញ្ញផល រមែងកើតឡើងប្រាកដបានឯងមិនមែនមិនប្រាកដដូចព្រះនិព្វាន ហេតុនោះ ទើបហៅថា **ភូមិ** គឺភូមិខាងដើមនោះ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបអត្ថយ៉ាងនេះថា បទថា **បត្តិយា** បានដល់ដើម្បីប្រយោជន៍ដល់ការសម្រេច គឺដើម្បីប្រយោជន៍ដល់ការបានចំពោះសាមញ្ញផលទីមួយ ពោល គឺសោតាបត្តិផល ។ បទថា **វិវិច្ច** គឺស្ងាត់ហើយ វៀរហើយដោយអំណាចសមុច្ឆេទវិវេក ។

លោកិយជ្ឈាន វៀរបដិបទារមែងមិនសម្រេច ក៏ពិត កាលបើដូច្នោះ

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **ទុក្ខាបដិបទំ ទន្ធាភិញ្ញំ** ទុកក្នុងលោកុត្តរជ្ឈានេះ ព្រោះទ្រង់បំណងលះសុទ្ធិកន័យ ហើយសម្តែងលោកុត្តរជ្ឈាន មួយអន្លើដោយបដិបទានោះឯង ។

ក្នុងបទជាដើមថា **ទុក្ខាបដិបទា** នោះ មានអធិប្បាយដូចតទៅនេះ យោគាវចរបុគ្គលណា កាលគ្របសង្កត់កិលេសទាំងឡាយ តាំងអំពីចាប់ផ្តើមត្រូវលំបាក មានការក្រាក់រពូក ប្រារព្ធព្យាយាម ទើបសង្កត់សង្កិនបាន បដិបទារបស់បុគ្គលនោះ ជាទុក្ខាបដិបទា ចំណែកយោគាវចរបុគ្គលណា សង្កត់កិលេសបានហើយ កាលអប់រំវិបស្សនា ត្រូវប្រើពេលវេលាយូរ ទើបមគ្គប្រាកដ ការត្រាស់ដឹងរបស់បុគ្គលនោះ ជាទន្ធាភិញ្ញា ។ ដោយប្រការតាមដែលពោលហើយ វារៈយ៉ាងណានីមួយ ឈ្មោះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** ជាការអធិប្បាយហើយ ។

សួរថា ក៏វារៈណាព្រះអដ្ឋកថាចារ្យគាប់ចិត្ត ។ ឆ្លើយថា ក្នុងវារៈណា កិលេសទាំងឡាយ ដែលព្រះយោគាវចរគ្របសង្កត់ជាលើកដំបូងហើយ ផ្សាយឡើង ត្រូវសង្កត់ហើយលើកទីពីរក៏ផ្សាយឡើងទៀត ព្រះយោគាវចរធ្វើកិលេសដែលសង្កត់ហើយលើកទី ៣ ឲ្យជាកិលេសដែលត្រូវសង្កត់ហើយយ៉ាងនោះឯង ហើយទើបឲ្យដល់នូវការដកឡើងដោយមគ្គ វារៈនេះព្រះអដ្ឋ-កថាចារ្យគាប់ចិត្ត លោកតាំងឈ្មោះវារៈនេះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ន័យមិនទាន់ប្រាកដច្បាស់ ព្រោះហេតុនោះ ក្នុងអធិការនេះ គប្បីជ្រាបការអធិប្បាយតាំងអំពីដើមយ៉ាងនេះថា ព្រះ

យោគាវចរបុគ្គលណា កំណត់មហាភូតរូប ៤ បានហើយ កំណត់ឧបាទាយរូបបាន កំណត់អរូបបាន តែកាលកំណត់រូប និងអរូប ត្រូវលំបាក ទើបកំណត់បាន បដិបទារបស់លោក ឈ្មោះថា ជាទុក្ខាបដិបទា ។ ការត្រាស់ដឹងរបស់ព្រះយោគាវចរបុគ្គលដែលកំណត់រូប និងអរូបបានហើយ ឈ្មោះថា **ឧន្ធាភិញ្ញា** ព្រោះក្នុងការអប់រំវិបស្សនា មគ្គប្រាកដយឺតយូរ ។

យោគាវចរបុគ្គលណា កំណត់រូប និងអរូបបានហើយ កាលកំណត់ចែកនាមរូបត្រូវលំបាក ទើបកំណត់ចែកបាន កាលកំណត់ចែកនាមរូបបានហើយ កាលអប់រំវិបស្សនា ប្រើពេលវេលាយូរ ទើបអាចឲ្យមគ្គកើតឡើងបាន បដិបទារបស់បុគ្គលនោះ ឈ្មោះថាជា **ទុក្ខាបដិបទា ឧន្ធាភិញ្ញា** ។

ព្រះយោគាវចរអង្គដទៃទៀត កំណត់ចែកនាមរូបបានហើយ កាលកំណត់បច្ច័យទាំងឡាយត្រូវលំបាក ទើបកំណត់បាន កាលកំណត់បច្ច័យបានហើយ កាលអប់រំវិបស្សនាប្រើពេលយូរ ទើបញុំាងមគ្គឲ្យកើតឡើងដោយអាការយ៉ាងនេះ បដិបទារបស់លោកក៏ឈ្មោះថាជា **ទុក្ខាបដិបទា ឧន្ធាភិញ្ញា** ។

ព្រះយោគាវចររូបដទៃទៀត កំណត់បច្ច័យទាំងឡាយបានហើយ កាលចាក់ធ្លុះលក្ខណៈទាំងឡាយ ត្រូវលំបាក ទើបចាក់ធ្លុះបាន លោកចាក់ធ្លុះលក្ខណៈបានហើយ កាលអប់រំវិបស្សនាប្រើពេលយូរ ទើបញុំាងមគ្គឲ្យកើតឡើងបាន ដោយអាការយ៉ាងនេះ បដិបទារបស់លោកក៏ឈ្មោះថាជា **ទុក្ខាបដិបទា ឧន្ធាភិញ្ញា** ។

ព្រះយោគាវចររូបដទៃទៀត ចាក់ធ្លុះលក្ខណៈទាំងឡាយបានហើយ ខណៈកាលវិបស្សនាញាណដ៏មុតថ្លា និងផូរផង់ប្រព្រឹត្តទៅ កាលគ្របសង្កត់ការជាប់ចិត្តក្នុងវិបស្សនាដែលកើតឡើង ត្រូវលំបាក ទើបគ្របសង្កត់បាន កាលគ្របសង្កត់ការជាប់ចិត្តបានហើយ កាលអប់រំវិបស្សនា ប្រើពេលយូរ ទើបញ៉ាំងមគ្គឲ្យកើតឡើងបាន ដោយអាការយ៉ាងនេះ បដិបទារបស់លោក ក៏ឈ្មោះថាជា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** ។ វារៈនេះ ព្រះអដ្ឋកថាចារ្យគាប់ចិត្ត និងតាំងឈ្មោះវារៈនេះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** គប្បីជ្រាបបដិបទា ៣ ខាងមុខដោយឧបាយនេះ ។

បណ្ដាបទទាំងឡាយ មានបទជាដើមថា **ផស្សោ ហោតិ** មានបទផ្ដើម ៤ គឺអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ និងក្នុងនិទ្ទេសវារៈក្នុងនិទ្ទេសនៃបទ មានវិតក្កជាដើម មានបទបន្ថែមជាដើមថា **មគ្គង្គំ** ។ ពាក្យដ៏សេសទាំងអស់ ដូចគ្នានឹងពាក្យដែលពោលហើយខាងដើមនុ៎ះឯង តែក្នុងអធិការនេះ មានសេចក្ដីប្លែកគ្នាដោយអំណាចនៃភូមិ និងព្រោះជាលោកុត្តរ ។

បណ្ដាបទបន្ថែមទាំង ៤ នោះ បទថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** បានដល់ ឥន្ទ្រិយដែលកើតឡើងដោយចំណែកខាងដើមនេះ របស់យោគាវចរអ្នកបដិបត្តិដោយមនសិការថា អញនឹងដឹងនូវទៅនូវអមតបទ គឺសច្ចធម៌ ៤ នុ៎ះឯង ដែលមិនធ្លាប់ដឹងហើយក្នុងសំសារវដ្ដ ដែលមានខាងដើម និងទីបំផុតដែលបុគ្គលដឹងមិនបានហើយ ។ ចំណែកលក្ខណៈជាដើមរបស់អនញ្ញាតញ្ញ-

សម្មាមីតិន្ទ្រិយនោះ គប្បីជ្រាបដោយន័យដែលពោលក្នុងបញ្ញិន្ទ្រិយ ក្នុងខាងដើមនុ៎ះឯង ។

វាចាល្អ ឬវាចាដែលបណ្ឌិតសរសើរ ឈ្មោះថា **សម្មាវាចា** ពាក្យថា សម្មាវាចានេះ ជាឈ្មោះនៃការវៀរចាកមិច្ឆាវាចា ដែលជាគ្រឿងដកឡើងនូវវចីទុច្ចរិត ។ សម្មាវាចានោះ **បរិគ្គហលក្ខណា** មានការកំណត់ជាលក្ខណៈ **វិរមណរសា** មានការវៀរជាកិច្ច **មិច្ឆាវាចប្បហានបច្ចុប្បដ្ឋានា** មានការលះបង់មិច្ឆាវាចាជាអាការប្រាកដ ។

ការងារដែលល្អ ឬដែលបណ្ឌិតសរសើរ ឈ្មោះថា **សម្មាកម្មន្ត** ពាក្យថា សម្មាកម្មន្តៈនេះ ជាឈ្មោះនៃការវៀរចាកបាណាតិបាតជាដើម ដែលជាគ្រឿងដកឡើងនូវមិច្ឆាកម្មន្តៈ សម្មាកម្មន្តៈនោះ **សមុដ្ឋានលក្ខណោ** មានការតាំងឡើងល្អជាលក្ខណៈ **វិរមណរសោ** មានការវៀរចាកជាកិច្ច **មិច្ឆាកម្មន្តប្បហានបច្ចុប្បដ្ឋានោ** មានការលះបង់មិច្ឆាកម្មន្តៈជាអាការប្រាកដ ។

អាជីវៈល្អ ឬដែលបណ្ឌិតសរសើរ ឈ្មោះថា **សម្មាអាជីវ** ពាក្យថា សម្មាអាជីវៈនេះ ជាឈ្មោះរបស់ការវៀរចាកមិច្ឆាអាជីវៈ សម្មាអាជីវៈនោះ **វោទានលក្ខណោ** មានការផូរផង់ជាលក្ខណៈ **ញាយាជីវប្បវត្តិរសោ** មានការប្រព្រឹត្តិទៅនៃអាជីវៈប្រពៃតាមធម៌ជាកិច្ច **មិច្ឆាជីវប្បហានបច្ចុប្បដ្ឋានោ** មានការលះបង់មិច្ឆាអាជីវៈជាអាការប្រាកដ ។

ម្យ៉ាងទៀត គប្បីជ្រាបលក្ខណៈជាដើម ក្នុងសម្មាវាចាជាដើមទាំងនេះ ដោយអំណាចនៃពាក្យដែលពោលហើយ ក្នុងវិរតិ ៣ ខាងដើម ។ ដោយ

ប្រការយ៉ាងនេះ គប្បីជ្រាបមគ្គ ៥ ដែលបានពោលហើយខាងដើម គប្បីជ្រាបមគ្គ ៨ ក្នុងទីនេះដោយអំណាចនៃធម៌ទាំង ៣ នេះ និងក្នុងយេវាបនកធម៌ទាំងឡាយ មិនមានសម្មាវាចាជាដើមទាំងនេះ ករុណា និងមុទិតាក៏មិនមានដូចគ្នា ដ្បិតថា ក្នុងលោកុត្តរកុសលនេះ មិនបានកាន់យកធម៌ទាំង ៣ ( មានសម្មាវាចាជាដើម ) ទាំងនេះទុកក្នុងយេវាបនកធម៌ទាំងឡាយ ព្រោះមានមកក្នុងព្រះបាលីនោះឯង ។ ចំណែកករុណា និងមុទិតា មានសត្វជាអារម្មណ៍ តែធម៌ទាំងនេះ មាននិព្វានជាអារម្មណ៍ ព្រោះហេតុនោះ ទើបករុណា និងមុទិតាទាំងនេះ មិនបានកាន់យកក្នុងយេវាបនកធម៌នេះ ។ ន័យដែលផ្សេងគ្នាក្នុងឧទ្ទេសវារ មានត្រឹមតែប៉ុណ្ណេះ ។

ក្នុងនិទ្ទេសវារ គប្បីជ្រាបវិគ្គហៈក្នុងបទនេះថា **មគ្គង្គំ មគ្គបរិយាបន្នំ** ជាលំដាប់ដំបូង ។ ធម៌ដែលឈ្មោះថា **មគ្គង្គំ** ព្រោះអត្ថថា ជាអង្គនៃមគ្គ អធិប្បាយថា ជាចំណែកនៃមគ្គដូចវត្ថុដែលទាក់ទងក្នុងព្រៃ ឈ្មោះថា **អរញ្ញបរិយាបន្ន** យ៉ាងណា ធម៌ដែលរាប់បញ្ចូលក្នុងមគ្គ ឈ្មោះថា **មគ្គបរិយាបន្ន** យ៉ាងនោះ អធិប្បាយថា អាស្រ័យមគ្គ ។

ក្នុងសេចក្តីនេះថា **បីតិសម្ពោជ្ឈង្គោ** សម្ពោជ្ឈង្គ គឺបីតិ ឈ្មោះថា **បីតិសម្ពោជ្ឈង្គ** ។ ក្នុងសម្ពោជ្ឈង្គទាំងនោះ ធម៌ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ឬជាអង្គនៃបុគ្គលអ្នកត្រាស់ដឹង ពាក្យនេះមានអធិប្បាយថា ធម្មសាមគ្គីនេះត្រាស់ហៅថា **ពោធិ** ព្រោះធ្វើអធិប្បាយថា ព្រះអរិយសាវករមែងត្រាស់ដឹងដោយធម្មសាមគ្គី ពោល

គឺសតិ ធម្មវិចយ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខាដែលកើតឡើង ក្នុងខណៈនៃលោកុត្តរមគ្គ ដែលជាបដិបក្ខចំពោះឧបទ្ទវ មិនមែនតិច មាន ការរួញរា ការធ្ងន់ធ្ងុយ ការរាយមាយ កិលេសជាគ្រឿងទាញទុក កិលេស ជាគ្រឿងប្រកបទុក កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ និងការ ប្រកាន់មាំក្នុងឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិជាដើម ។ ពាក្យថា **រមែងត្រាស់ដឹង** សេចក្តីថា រមែងក្រោកឡើងអំពីការដេកលក់ គឺការបន្តនៃកិលេស ឬរមែង ត្រាស់ដឹងអរិយសច្ច ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានទុ៎ះឯង ។ អង្គនៃ ធម៌ជាគ្រឿងត្រាស់ដឹង ពោល គឺធម្មសាមគ្គីនោះមាន ហេតុនោះ ទើបធម៌ នោះឈ្មោះថា **ពោជ្ឈង្គ** ដូចអង្គនៃឈាន និងអង្គនៃមគ្គជាដើម ។ ព្រះអរិយ-សាវកនេះ ក៏ហៅថា **ពោធិ** ព្រោះធ្វើអធិប្បាយថា រមែងត្រាស់ដឹងដោយ ធម្មសាមគ្គី មានប្រការតាមដែលពោលហើយនោះ ។ សូម្បីអង្គនៃអរិយ-សាវកអ្នកត្រាស់ដឹងនោះ លោកក៏ហៅថា **ពោជ្ឈង្គ** ដូចអង្គនៃសេនា និងអង្គ នៃរថជាដើម ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃបុគ្គលអ្នកត្រាស់ដឹង ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃពោជ្ឈង្គ សូម្បីដោយន័យបដិសម្ភិទាមគ្គ នេះថា សំណួរត្រង់ពាក្យថា ពោជ្ឈង្គ តើពោជ្ឈង្គដោយអត្ថថាដូចម្តេច ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុប្រព្រឹត្តទៅព្រមក្នុងការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង តាម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ

ព្រោះហេតុត្រាស់ដឹងព្រម ដូច្នេះ ។ ពោជ្ឈង្គដែលបណ្ឌិតសរសើរហើយផង ជាពោជ្ឈង្គដ៏ល្អផង ឈ្មោះថា **សម្ពោជ្ឈង្គ** ។ ដោយប្រការដូច្នេះ សម្ពោជ្ឈង្គ គឺបីតិ ឈ្មោះថា **បីតិសម្ពោជ្ឈង្គ** ។ សូម្បីក្នុងនិទ្ទេសនៃឯកគ្គតារបស់ចិត្តជាដើម បណ្ឌិតគប្បីជ្រាបដោយន័យនេះឯង ។

បទថា **តេសំ ធម្មានំ** បានដល់ ធម៌ គឺសច្ចៈ ៤ ដែលដល់នូវការចាក់ធ្លុះក្នុងសម័យនោះ ។ បទថា **អញ្ញាតានំ** សេចក្តីថា ធម៌ទាំងនោះដែលព្រះយោគាវចរ ឈ្មោះថា ដឹងហើយ ដោយបឋមមគ្គក៏ពិត តែលោកពោលឧបមាថា ដូចបុគ្គលមកកាន់វិហារ ដែលមិនធ្លាប់មកតាមប្រក្រតី សូម្បីឈរនៅក្នុងកណ្តាលវិហារក៏ពោលថា ខ្ញុំមកកាន់ទីដែលមិនធ្លាប់មក ព្រោះអាស្រ័យភាពជាអ្នកមិនមកតាមប្រក្រតី យ៉ាងណា និងដូចបុគ្គលប្រដាប់ផ្កាដែលមិនធ្លាប់ប្រដាប់តាមប្រក្រតី ស្លៀកសំពត់ដែលមិនធ្លាប់ស្លៀក ( សំពត់ថ្មី ) បរិភោគអាហារដែលមិនធ្លាប់បរិភោគ ព្រោះអាស្រ័យភាពជាអ្នកមិនធ្លាប់បរិភោគតាមប្រក្រតី ទើបនិយាយថា ខ្ញុំបរិភោគអាហារដែលនៅមិនធ្លាប់បរិភោគ យ៉ាងណា សូម្បីក្នុងសេចក្តីនេះក៏យ៉ាងនោះ ព្រោះធម៌ទាំងនេះដែលបុគ្គលនេះមិនធ្លាប់ដឹងតាមប្រក្រតី ហេតុនោះ ទើបពោលថា **អនញ្ញាតានំ** មិនទាន់ស្គាល់ ដូច្នេះ ។ ក្នុងបទថា **អទិដ្ឋានំ** ជាដើម ក៏ន័យនេះឯង ។ បណ្តាបទទាំងនោះ បទថា **អទិដ្ឋានំ** បានដល់ មិនធ្លាប់ឃើញដោយបញ្ញា-ចក្ខុ ក្នុងកាលមុនអំពីកាលនេះ ។ បទថា **អប្បត្តានំ** បានដល់ ដែលនៅមិនធ្លាប់សម្រេចដោយអំណាចនៃការចូលដល់ ។ បទថា **អវិទិតានំ** បាន

ដល់ ដែលនៅមិនទាន់ប្រាកដដោយញាណ ។ បទថា **អសច្ឆិកតានំ** បាន ដល់ ដែលនៅមិនធ្លាប់ធ្វើឲ្យប្រចក្ស ។ បទថា **សច្ឆិកិរិយាយ** បានដល់ ដើម្បីធ្វើឲ្យប្រចក្ស ។ គប្បីប្រកបសេចក្ដីសូម្បីជាមួយនឹងបទដ៏សេសដូចគ្នា នឹងបទនេះថា ដើម្បីដឹងធម៌ដែលនៅមិនទាន់ស្គាល់ ដើម្បីឃើញធម៌ដែល នៅមិនទាន់ឃើញ ដើម្បីដល់ធម៌ដែលនៅមិនទាន់ដល់ ដើម្បីដឹងច្បាស់នូវ ធម៌ដែលមិនទាន់ដឹងច្បាស់ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនធ្លាប់ធ្វើឲ្យ ជាក់ច្បាស់ ដូច្នេះ ។

ក្នុងបទទាំងឡាយ មានបទថា **ចតូហិ វចីទុច្ចរិតេហិ** ជាដើម មាន អធិប្បាយដូចតទៅ បទថា **វចី** គប្បីជ្រាបថា ជាគ្រឿងចំណាំឲ្យដឹង តាមផ្លូវវាចា ( វចីវិញ្ញត្តិ ) ។ ធម៌ដែលឈ្មោះថា **ទុច្ចរិត** ព្រោះអត្ថថា ការប្រព្រឹត្តិដែលទោស ៣ យ៉ាងណាមួយប្រទូស្តហើយ ។ ទុច្ចរិតដែល ប្រព្រឹត្តទៅតាមផ្លូវវាចា ឈ្មោះថា **វចីទុច្ចរិត** មា្យ៉ាងទៀត ទុច្ចរិតដែល សម្រេចដោយវាចា ហៅថា វចីទុច្ចរិត ។ ចេតនាដែលឈ្មោះថា **អារតិ** ព្រោះវៀរឆ្ងាយចាកវចីទុច្ចរិតទាំងនោះ ។ ឈ្មោះថា **វិរតិ** ព្រោះវៀរចាក វចីទុច្ចរិតទាំងនោះ ។ ឈ្មោះថា **បដិវិរតិ** ព្រោះជាអ្នកថយចេញចាកវចី-ទុច្ចរិតនោះៗ និងវៀរចាកវចីទុច្ចរិតទាំងនោះ ។ មា្យ៉ាងទៀត បទទាំងបីនេះ លោកបន្ថែមឧបសគ្គ ។ បទទាំង ៣ នេះ ជាឈ្មោះនៃការវៀរចាក ( **វិរ-មណ** ) ទាំងអស់ ។ ដែលឈ្មោះថា **វេរមណី** ព្រោះអត្ថថា ញាំញី គឺធ្វើពៀរឲ្យវិនាស ។ សូម្បីពាក្យថា **វេរមណី** នេះ ក៏ជាវេវចនៈរបស់

ពាក្យថា **ឱរមណា** នុ៎ះឯង ។ បុគ្គលកាលពោលមុសាវាទជាដើម ឈ្មោះថា រមែងធ្វើដោយចេតនាណា វិរតិក្នុងលោកុត្តរមគ្គនេះកើតឡើងហើយ រមែងមិនឲ្យធ្វើកិរិយានោះ រមែងកាត់ផ្តាច់ផ្លូវនៃការធ្វើ ព្រោះហេតុនោះ ទើបចេតនានោះ ឈ្មោះថា **អកិរិយា** ( មិនសាង ) ។ មួយទៀត ធម្មជាតណា មិនឲ្យធ្វើការប្រកបនោះ កាត់ផ្តាច់ផ្លូវជាគ្រឿងប្រកប ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **អករណំ** ( មិនធ្វើ ) ។ មួយទៀត បុគ្គលកាលពោលវចីទុច្ចរិត ៤ យ៉ាង ដោយចេតនាណា ឈ្មោះថា រមែងកន្លងល្មើសវិរតិក្នុងលោកុត្តរមគ្គនេះកើតឡើងហើយ រមែងមិនឲ្យកន្លងល្មើសយ៉ាងនោះ ព្រោះហេតុនោះ ទើបចេតនានោះ ឈ្មោះថា **អនជ្ឈាបត្តិ** ( មិនប្រព្រឹត្តល្មើស ) ។

ក្នុងបទនេះថា **វេលាអនតិក្កមោ** អធិប្បាយថា កាល ហៅថា **វេលា** ដូចក្នុងប្រយោគជាដើមថា **តាយ វេលាយ** ក្នុងកាលនោះ ដូច្នេះ ។ **រាសិ** ( គំនរ ) ហៅថា **វេលា** ដូចក្នុងប្រយោគជាដើមថា **ឧរុវេលាយំ វិហរតិ** គង់នៅក្នុងឧរុវេលាប្រទេស ( គំនរខ្សាច់ ) សីមា ( ព្រំដែន ) ហៅថា វេលា ដូចក្នុងប្រយោគជាដើមថា **ឋិតធម្មោ វេលំ នាតិវត្តតិ** តាំងនៅនឹងជាធម្មតាមិនដែលឡើង ឬជារហួសប្រាំងទៅ ដូច្នេះ ។ ក្នុងអធិការនេះទ្រង់បំណាងយកវេលា គឺព្រំដែនប៉ុណ្ណោះ ពិតហើយ វចីសុចរិត ៤ ទ្រង់បំណាងយកថា វេលា ( គឺព្រំដែន ) ព្រោះអត្ថថា មិនគួរប្រព្រឹត្តកន្លង ។ ដោយប្រការដូច្នេះ បុគ្គលកាលពោលវចីទុច្ចរិត ៤ ដោយចេតនាណា

ឈ្មោះថា រមែងប្រព្រឹត្តកន្លងព្រំដែន វិរតិក្នុងលោកុត្តរមគ្គនេះកើតឡើងហើយ រមែងមិនឲ្យប្រព្រឹត្តកន្លងព្រំដែននោះ ព្រោះហេតុនោះ ទើបចេតនានោះ ទ្រង់ត្រាស់ថា **វេលាអនតិក្កមោ** ។ ម្យ៉ាងទៀត ឈ្មោះថា **វេលា** ព្រោះអត្ថថា រមែងឲ្យថមថយទៅ អធិប្បាយថា ធ្វើឲ្យវិនាស ឲ្យខ្ចាត់ខ្ចាយទៅ ។ សួរថា ធ្វើអ្វីឲ្យថមថយទៅ ។ ឆ្លើយថា ធ្វើវចីទុច្ចរិត ៤ ឲ្យថមថយទៅ ដោយប្រការដូច្នេះ ទើបឈ្មោះថា **វេលា** ព្រោះធ្វើឲ្យថមថយទៅ ។ ដែលឈ្មោះថា **អនតិក្កម** ព្រោះអត្ថថា មិនឈានកន្លងប្រយោជន៍ និងសេចក្តីសុខរបស់បុគ្គលប្រព្រឹត្តទៅ ។ គប្បីជ្រាបអត្ថដោយអំណាចបទទាំង ២ ក្នុងពាក្យថា **វេលាអនតិក្កមោ** នេះ ដោយប្រការដូច្នេះ ។

ធម៌ដែលឈ្មោះថា **សេតុឃាតោ** ព្រោះអត្ថថា រមែងសម្លាប់នូវហេតុ ( សេតុ ) គឺសម្លាប់ផ្លូវនៃវចីទុច្ចរិត ៤ អធិប្បាយថា សម្លាប់បច្ច័យ ។ បច្ច័យ ទ្រង់បំណងយកថា **សេតុ** ក្នុងទីនេះ ។ ក្នុងពាក្យនោះ មានអត្ថ-វចនៈដូចតទៅនេះ បច្ច័យនៃវចីទុច្ចរិត ៤ មានរាគៈជាដើម រមែងភ្ជាប់ គឺរមែងចងបុគ្គលទុកក្នុងវដ្ដៈ ព្រោះហេតុនោះ ទើបបច្ច័យនោះ ឈ្មោះថា **សេតុ** ។ ការសម្លាប់បច្ច័យដែលឈ្មោះថា **សេតុ** ឈ្មោះថា **សេតុឃាត** ។ ពាក្យនោះជាឈ្មោះរបស់វិរតិ ដែលជាគ្រឿងដកឡើងនូវបច្ច័យនៃវចីទុច្ចរិត ។ តែវិរតិ គឺសម្មាវាចានេះ រមែងបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម ព្រោះវៀរចាកមុសាវាទដោយចិត្តមួយដួង វៀរចាកបេសុញ្ញវាទជាដើម ដោយចិត្តដួងដទៃ ។ តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានក្នុងចិត្តមួយដួងប៉ុណ្ណោះ ។

ដ្បិតថា វិរតិតែម្យ៉ាងប៉ុណ្ណោះកើតឡើង ធ្វើការកាត់ផ្លូវរបស់ចេតនាក្នុងវចីទុច្ចរិត ៤ ញុំាងអង្គមគ្គឲ្យបរិបូណ៌ ។

បទថា **កាយទុច្ចរិតេហិ** បានដល់ ទុច្ចរិត មានបាណាតិបាតជាដើម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ឬដែលឲ្យសម្រេចដោយកាយ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុនន៉ុះឯង ។ វិរតិ ពោល គឺសម្មាកម្មន្ទៈនេះ រមែងបានក្នុងចិត្តផ្សេងៗ ក្នុងកាលខាងដើម ព្រោះវៀរចាកបាណាតិបាតដោយចិត្តមួយដួង វៀរចាកអទិន្នាទាន និងមិច្ឆាចារបានដោយចិត្តដួងដទៃ ។ តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានក្នុងចិត្តមួយដួងប៉ុណ្ណោះ ដ្បិតថា វិរតិតែម្យ៉ាងប៉ុណ្ណោះ កើតឡើងធ្វើការកាត់ផ្លូវនៃចេតនាក្នុងកាយទុច្ចរិត ៣ ធ្វើអង្គមគ្គឲ្យបរិបូណ៌ ។

គប្បីជ្រាបអត្ថវចនៈក្នុងពាក្យជាដើមថា **អកិរិយា** ក្នុងនិទ្ទេសនៃសម្មា-អាជីវៈ ដោយន័យនេះថា បុគ្គលចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ឈ្មោះថា ធ្វើកិរិយាដោយចេតនាណា លោកុត្តរចេតនានេះកើតឡើងហើយ រមែងមិនឲ្យធ្វើកិរិយានោះ ព្រោះហេតុនោះ ទើបចេតនានោះ ឈ្មោះថា **អកិរិយា** ។ មួយទៀត ឈ្មោះថា **អាជីវ** នេះ ជាចំពោះចំណែកមួយមិនមាន កាលប្រារព្ធដល់វាចា និងការងារហើយ អាជីវៈក៏ឈ្មោះថា ប្រារព្ធដល់ហើយដូចគ្នា ព្រោះអាជីវៈនោះ ប្រព្រឹត្តទៅក្នុងចំណែកនៃវាចា និងការងារនោះ តែអាជីវៈនេះ ព្រះអង្គទ្រង់នាំចេញចាកវាចា និងការងារនោះ សម្តែងដោយអំណាចនៃការសេពអាស្រ័យនៅជានិច្ច កាលបើដូច្នេះ បើសម្មាអាជីវៈមិនមានកិច្ចរបស់

ខ្លួន អង្គនៃមគ្គ ៨ ក៏រមែងមិនបរិបូណ៌ ព្រោះហេតុនោះ គប្បីធ្វើសម្មាអាជីវៈឲ្យមានកិច្ចរបស់ខ្លួន អង្គនៃមគ្គ ៨ ក៏គប្បីបរិបូណ៌ ។ ក្នុងអធិការនេះ គប្បីជ្រាបន័យដូចតទៅ

ដែលឈ្មោះថា អាជីវៈ សូម្បីកាលបែក ក៏រមែងបែកក្នុងកាយទ្វារ និងវចីទ្វារនុ៎ះឯង ឈ្មោះថា ការបែកនៃអាជីវៈក្នុងមនោទ្វារមិនមានទេ កាលបរិបូណ៌ ក៏រមែងបរិបូណ៌ក្នុងទ្វារពីរនោះឯង ឈ្មោះថា សេចក្តីបរិបូណ៌នៃអាជីវៈមិនមានតាមមនោទ្វារ ព្រោះហេតុនោះ គប្បីធ្វើសម្មាអាជីវៈ ឲ្យមានកិច្ចរបស់ខ្លួន អង្គនៃមគ្គ ៨ ក៏គប្បីបរិបូណ៌ ។ នេះជាន័យក្នុងអាជីវៈនោះឯការឈានកន្លងក្នុងកាយទ្វារ មានអាជីវៈជាហេតុខ្លះ មិនមានអាជីវៈជាហេតុខ្លះ ក្នុងវចីទ្វារក៏ដូចគ្នា ។

ក្នុងសេចក្តីនោះ មានអធិប្បាយដូចតទៅនេះ ព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ជាអ្នកខ្វល់ខ្វាយក្នុងការលេង កាលសម្តែងភាពជាអ្នកក្លាហាន រមែងធ្វើការបរបាញ់ម្រឹគខ្លះ ប្លន់មនុស្សដើរតាមផ្លូវខ្លះ ប្រព្រឹត្តល្មើសក្នុងភរិយារបស់អ្នកដទៃខ្លះ នេះឈ្មោះថា **កាយកម្មជាអកុសល** ។ ចេតនាវៀរចាកអកុសលកាយកម្មនោះ ក៏ឈ្មោះថា **សម្មាកម្មន្ត** មួយទៀត ព្រះរាជា និងមហាមាត្យរបស់ព្រះរាជា រមែងពោលវចីទុច្ចរិត ៤ មិនមែនមានអាជីវៈជាហេតុ នេះឈ្មោះថា **វចីកម្មដែលជាអកុសល** ចេតនាវៀរចាកវចីកម្មដែលជាអកុសលនោះ ក៏ឈ្មោះថា **សម្មាវាចា** ។

តែនាយព្រាន និងអ្នកប្រមង់ជាដើម ព្រោះអាជីពជាហេតុ ទើបសម្លាប់

សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តមិច្ឆាចារ នេះឈ្មោះថា **មិច្ឆាអាជីវៈ** ។ ចេតនាវៀរចាកមិច្ឆាអាជីវៈនោះ ឈ្មោះថា **សម្មាអាជីវ** ។ ពួកជនទទួលថ្លៃឈ្នួលហើយពោលមុសា រមែងញុំាងបេសុញ្ញវាទ ផរុសវាទ សម្ផប្បលាបឲ្យប្រព្រឹត្តទៅ នេះក៏ឈ្មោះថា **មិច្ឆាអាជីវ** សូម្បីចេតនាវៀរចាកមិច្ឆាអាជីវៈនោះ ក៏ឈ្មោះថា **សម្មាអាជីវ** ។

ព្រះមហាសិវត្ថេរពោលថា ការប្រព្រឹត្តិកន្លងតាមកាយទ្វារ និងវចីទ្វារ មានអាជីវៈជាហេតុក្តី មិនមានអាជីវៈជាហេតុក្តី រមែងរាប់ថា ជាកាយកម្ម និងវចីកម្មខាងអកុសលដោយពិត សូម្បីការវៀរចាកកាយកម្ម និងវចីកម្មខាងអកុសល ក៏ហៅថា សម្មាកម្មន្តៈ សម្មាវាចាបាន ។ ព្រះថេរៈត្រូវសួរថា អាជីវៈបាត់ទៅណា ក៏ពោលថា ការដែលបុគ្គលអាស្រ័យកុហនវត្ថុ ( រឿងកុហក ) ៣ យ៉ាង ញុំាងបច្ច័យ ៤ ឲ្យកើតឡើង ហើយបរិភោគបច្ច័យទាំងនោះ ក៏គឺអាជីវៈ ។ នេះជាមិច្ឆាអាជីវៈដល់ទីបំផុត ការវៀរចាកមិច្ឆាអាជីវៈនោះ ឈ្មោះថា **សម្មាអាជីវ** ។

សម្មាអាជីវៈនេះ រមែងរកបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម ព្រោះការវៀរចាកការឈានកន្លងតាមកាយទ្វារ ក៏បានចិត្តមួយ៉ាង ចាកការឈានកន្លងតាមវចីទ្វារ ក៏បានចិត្តមួយ៉ាង ។ តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានចិត្តមួយដួងប៉ុណ្ណោះ ដ្បិតថា វិរតិតែមួយ៉ាងកើតឡើង ធ្វើការកាត់ផ្លូវនៃចេតនា ជាគ្រឿងទ្រុស្តសីល គឺមិច្ឆាអាជីវៈដែលកើតឡើងដោយអំណាចនៃកម្មបថ ៧ គឺកាយកម្ម និងវចីកម្មក្នុងកាយទ្វារ និងវចីទ្វារ ធ្វើអង្គមគ្គឲ្យ

បរិបូណ៌ ព្រោះហេតុនោះ សេចក្ដីនេះ ទើបប្លែកគ្នាក្នុងនិទ្ទេសវារ ។

តែក្នុងឥន្ទ្រិយទាំងឡាយ ទ្រង់បន្ថែមអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ និងក្នុងអង្គនៃមគ្គ ទ្រង់បន្ថែមសម្មាវាចាជាដើមណា ដោយអំណាចនៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ និងសម្មាវាចាជាដើមនោះក្នុងសង្គហវារៈ ទើបត្រាស់ថា ឥន្ទ្រិយ ៩ និងមគ្គមានអង្គ ៨ ។ សុញ្ញតវារៈប្រព្រឹត្តទៅតាមប្រក្រតីនុ៎ះឯង ។ នេះជាការផ្សេងគ្នាក្នុងសុទ្ធិកប្បដិបទា ។

ខាងមុខអំពីនេះទៅ ជាប្រភេទនៃទេសនា គឺសុទ្ធិកសុញ្ញតា ១ សុញ្ញតបដិបទា ១ សុទ្ធិកអប្បណិហិត ១ អប្បណិហិតបដិបទា ១ ។

បណ្ដាប្រភេទនៃទេសនាទាំង ៤ នោះ ពាក្យថា **សុញ្ញតា** នេះ ជាឈ្មោះរបស់លោកុត្តរមគ្គ ពិតហើយ លោកុត្តរមគ្គនោះ រមែងបានឈ្មោះដោយហេតុ ៣ យ៉ាង គឺដោយការមកដល់ ១ ដោយគុណរបស់ខ្លួន ១ ដោយអារម្មណ៍ ១ ។

ក្នុងសេចក្ដីនេះ ដូចម្ដេច ភិក្ខុក្នុងធម្មវិន័យនេះ ប្រកាន់ ( សង្ខារទាំងឡាយ ) ដោយភាពជាអនត្តា រមែងឃើញសង្ខារដោយភាពជាអនត្តា តែធម្មតាការចេញចាកសង្ខតធម៌ដោយមគ្គ រមែងមិនមានដោយត្រឹមតែឃើញដោយភាពជាអនត្តាប៉ុណ្ណោះ ការឃើញដោយភាពជារបស់មិនទៀងខ្លះ ដោយភាពជាទុក្ខខ្លះ ទើបសមគួរ ព្រោះហេតុនោះ ទើបលោកលើកឡើងកាន់អនុបស្សនា ៣ យ៉ាង គឺអនិច្ចំ ទុក្ខំ និងអនត្តា ហើយពិចារណា ។ ក៏វិបស្សនាដែលជាវុដ្ឋានគាមិនី របស់ភិក្ខុនោះ រមែងឃើញសង្ខារទាំងឡាយ

សុម្បីដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយភាពជារបស់សូន្យនោះឯង ។ វិបស្សនានេះ ឈ្មោះថា **សុញ្ញតា** ។ វិបស្សនានោះតាំងនៅក្នុងឋានៈ ជាទីតាំងនៃការមកដល់ ( បដិបទា ) ទើបឲ្យឈ្មោះមគ្គរបស់ខ្លួនថា **សុញ្ញត** ។ មគ្គរមែងបានឈ្មោះថា សុញ្ញតដោយការមកដល់ ដោយប្រការដូច្នេះ ។ តែព្រោះមគ្គនោះ សូន្យចាករាគៈជាដើម ហេតុនោះ ទើបបានឈ្មោះថា សុញ្ញត ដោយគុណរបស់ខ្លួននោះឯង ។ សុម្បីព្រះនិព្វាន ក៏ហៅថា **សុញ្ញត** ព្រោះជាសភាវៈសូន្យចាករាគៈជាដើម ។ មគ្គរមែងបានឈ្មោះថា សុញ្ញតដោយអារម្មណ៍ ព្រោះមគ្គនោះ ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍កើតឡើង ។

បណ្ដាហេតុទាំង ៣ នោះ ដោយបរិយាយដែលមានក្នុងព្រះសូត្រ លោកុត្តរមគ្គ រមែងបានឈ្មោះដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ ។ ការសម្ដែងនេះ ជាការសម្ដែងដោយល្អ ។ ចំណែកក្នុងអភិធម្មកថា ជាការសម្ដែងដោយត្រង់ ព្រោះហេតុនោះ ក្នុងអភិធម្មកថានេះ លោកុត្តរមគ្គរមែងមិនបានឈ្មោះដោយគុណរបស់ខ្លួន ឬដោយអារម្មណ៍ រមែងបានដោយការមកដល់ប៉ុណ្ណោះ ព្រោះការមកដល់នោះឯង ជាធុរៈ ។ ការមកដល់នោះមាន ២ យ៉ាង គឺការមកដល់ដោយវិបស្សនា និងការមកដល់ដោយមគ្គ ។ ក្នុងការមកដល់ទាំង ២ នោះ ក្នុងទីដែលមគ្គមកដល់ ការមកដល់ដោយវិបស្សនាជាធុរៈ ក្នុងទីដែលផលមកដល់ ការមកដល់ដោយមគ្គជាធុរៈ ក្នុងលោកុត្តរចិត្តនេះ ព្រោះមគ្គមកហើយ ការមកដល់ដោយវិបស្សនាប៉ុណ្ណោះទើបជាធុរៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា **អប្បណិហិតំ** ដូចតទៅ

បទថា **អប្បណិហិតំ** នេះ ជាឈ្មោះរបស់មគ្គ ។ មគ្គរមែងបានឈ្មោះនេះដោយហេតុ ៣ ដូចគ្នា បានដូចម្ដេច ភិក្ខុក្នុងធម្មវិន័យនេះ ប្រកាន់មាំដោយភាពជាទុក្ខអំពីដើមនោះឯង រមែងឃើញសង្ខារទាំងឡាយដោយភាពជាទុក្ខប៉ុណ្ណោះ ។ តែធម្មតាមគ្គវុដ្ឋាន រមែងមិនមានដោយត្រឹមតែឃើញដោយភាពជាទុក្ខប៉ុណ្ណោះ ការឃើញដោយភាពមិនទៀងខ្លះ ដោយអនត្តាខ្លះ ទើបសមគួរ ព្រោះហេតុនោះ ទើបលោកលើកឡើងកាន់អនុបស្សនា ៣ យ៉ាង គឺមិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណា ។ វិបស្សនាដែលជាវុដ្ឋានគាមិនីរបស់ភិក្ខុនោះ ញុំាំងបណិធិ ( តណ្ហា ) ក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឲ្យហួតហែង ឲ្យអស់ទៅ ទើបដាក់ចុះ វិបស្សនានេះឈ្មោះថា **អប្បណិហិត** ។ វិបស្សនានោះ តាំងនៅក្នុងឋានៈជាទីតាំងនៃការមកដល់ ( បដិបទា ) ទើបឲ្យឈ្មោះមគ្គរបស់ខ្លួនថា **អប្បណិហិត** ។ មគ្គ រមែងបានឈ្មោះថា **អប្បណិហិត** ដោយការមកដល់ ដោយប្រការដូច្នេះ ។ ព្រោះបណិធិ គឺរាគៈ ទោសៈ និងមោហៈក្នុងមគ្គនោះមិនមាន ហេតុនោះ ទើបមគ្គនោះ បានឈ្មោះថា អប្បណិហិតដោយគុណរបស់ខ្លួនទុំះឯង ។ ព្រះនិព្វានក៏ហៅថា **អប្បណិហិត** ព្រោះមិនមានបណិធិទាំងនោះ ។ មគ្គរមែងបានឈ្មោះថា **អប្បណិហិត** ( ដោយអារម្មណ៍ ) ព្រោះធ្វើព្រះនិព្វាននោះឲ្យជាអារម្មណ៍កើតឡើង ។ បណ្ដាហេតុទាំង ៣ នោះ ដោយបរិយាយក្នុងព្រះសូត្រ មគ្គរមែងបានឈ្មោះដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍

ខ្លះ ។ ការសម្តែងនេះ ជាការសម្តែងដោយអម ។ តែអភិធម្មកថា ជាការសម្តែងដោយត្រង់ ។ ព្រោះហេតុនោះ ទើបក្នុងអភិធម្មកថានេះ លោកុត្តរមគ្គ មិនបានឈ្មោះដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ រមែងបានឈ្មោះ ដោយការមកដល់ប៉ុណ្ណោះ ព្រោះការមកដល់នោះឯងជាធុរៈ ។ ការមកដល់ នោះមាន ២ យ៉ាង គឺការមកដល់ដោយវិបស្សនា និងការមកដល់ដោយ មគ្គ ។ ក្នុងការមកដល់ ២ យ៉ាងនោះ ក្នុងទីដែលមគ្គមកដល់ ការមក ដល់ដោយវិបស្សនាជាធុរៈ ក្នុងទីដែលផលមកដល់ ការមកដល់ដោយមគ្គ ជាធុរៈ ក្នុងលោកុត្តរចិត្តនេះ ព្រោះមគ្គមកហើយ ( មគ្គចិត្តដួងទីមួយ ) ការមកដល់ដោយវិបស្សនាប៉ុណ្ណោះ ទើបជាធុរៈ ។

សួរថា មគ្គ មានឈ្មោះ ៣ យ៉ាង គឺសុញ្ញត អនិមិត្ត អប្បណិហិត មិនមែនឬ ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា ម្នាល ភិក្ខុទាំងឡាយ វិមោក្ខនេះមាន ៣ យ៉ាង គឺសុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ក្នុងមគ្គដែលមានឈ្មោះទាំង ៣ នោះ ក្នុង លោកុត្តរចិត្តនេះ ទ្រង់កាន់យកមគ្គ ២ យ៉ាង ទើបទ្រង់មិនកាន់យកអនិមិត្តមគ្គ ព្រោះហេតុអ្វី ព្រោះមិនមានការមកដល់ ។ ពិតហើយ អនិមិត្តវិបស្សនា តាំងនៅក្នុងឋានៈ ជាទីតាំងនៃការមកដល់ឯងហើយ ទើបមិនអាចឲ្យឈ្មោះ ដល់មគ្គរបស់ខ្លួន ។ ព្រះសម្មាសម្ពុទ្ធបានត្រាស់អនិមិត្តវិបស្សនា ដល់ព្រះ រាហុលត្ថេរ ជាព្រះឱរសរបស់ព្រះអង្គថា

មួយទៀត ចូរចម្រើននូវអនិមិត្តវិបស្សនា ចូរលះនូវអនុស័យ

គឺមានះ លំដាប់តអំពីនោះ អ្នកប្រព្រឹត្តស្ងប់រម្ងាប់ ព្រោះលះបង់មានះ ដូច្នេះ ។

ពិតហើយ វិបស្សនា រមែងដកឡើងនូវនិមិត្តថា ទៀង នូវនិមិត្តថាស្ថិតស្ថេរ នូវនិមិត្តថា អត្តា នូវនិមិត្តថា ជាសុខ ហេតុនោះ ទើបទ្រង់ត្រាស់ថា អនិមិត្ត ។ វិបស្សនានោះ រមែងដកឡើងនូវនិមិត្តនោះក៏ពិត តែក៏ឈ្មោះថា មាននិមិត្តនោះឯង ព្រោះខ្លួនឯងប្រព្រឹត្តទៅក្នុងនិមិត្តធម៌ទាំងឡាយ ព្រោះហេតុនោះ អនិមិត្តវិបស្សនា តាំងនៅក្នុងឋានៈជាទីតាំងនៃការមកដល់ឯងហើយ ទើបមិនអាចឲ្យឈ្មោះដល់មគ្គរបស់ខ្លួន ។

ម្យ៉ាងទៀត ធម្មតាព្រះអភិធម្ម ជាបរមត្ថទេសនា ។ បើពោលដោយបរមត្ថ ការខ្វះខាតនៃហេតុនោះឯង រមែងមានដល់អនិមិត្តមគ្គ ។ មានការខ្វះខាតដូចម្តេច គឺអនិមិត្តវិមោក្ខ ត្រាស់ដោយអំណាចនៃអនិច្ចានុបស្សនា ។ សទ្ធិន្ទ្រិយ មានប្រមាណក្រៃលែង ដោយវិមោក្ខនោះ សទ្ធិន្ទ្រិយនោះ មិនជាអង្គមួយក្នុងអរិយមគ្គ ព្រោះមិនមែនអង្គមគ្គ ទើបមិនអាចឲ្យឈ្មោះមគ្គរបស់ខ្លួន ដោយបរមត្ថបាន ។ ចំណែកវិមោក្ខ ២ ក្រៅនេះ ទ្រង់ត្រាស់សុញ្ញតវិមោក្ខ ដោយអំណាចនៃអនត្តានុបស្សនា ត្រាស់អប្បណិហិត-វិមោក្ខ ដោយអំណាចនៃទុក្ខានុបស្សនា ។ បណ្តាវិមោក្ខទាំងនោះ បញ្ញិន្ទ្រិយមានកម្លាំងក្រៃលែងដោយសុញ្ញតវិមោក្ខ សមាធិន្ទ្រិយ មានកម្លាំងក្រៃលែងដោយអប្បណិហិតវិមោក្ខ បញ្ញិន្ទ្រិយ និងសមាធិន្ទ្រិយទាំងនោះ អាចឲ្យឈ្មោះដល់មគ្គរបស់ខ្លួនដោយបរមត្ថបាន ព្រោះភាពជាអង្គនៃអរិយមគ្គ ។

ពិតមែន ក្នុងការចែកធម៌ដែលជាមគ្គាធិបតី ក្នុងមគ្គារម្មណត្តិកៈ ក្នុងវេលាដែលឆន្ទៈ និងចិត្តជាអធិបតី ទ្រង់មិនត្រាស់ភាពជាមគ្គាធិបតិ ព្រោះធម៌ គឺឆន្ទៈ និងចិត្តទាំងនោះ មិនមែនជាអង្គនៃមគ្គ ។ គប្បីជ្រាបពាក្យដែលដល់ព្រមហើយយ៉ាងនោះចុះ ។ ពាក្យអធិប្បាយនេះ ក្នុងសេចក្តីនេះជាពាក្យអធិប្បាយក្រៅអដ្ឋកថា ជាវិនិច្ឆ័យរបស់អាចារ្យមួយរូប ។ ដោយប្រការដូច្នេះ អនិមិត្តវិបស្សនា តាំងនៅក្នុងឋានៈជាទីតាំងនៃការមកដល់ឯងហើយ ទើបមិនអាចឲ្យឈ្មោះដល់មគ្គរបស់ខ្លួនបានដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបទ្រង់មិនបានកាន់យកអនិមិត្តមគ្គ ។

តែអាចារ្យពួកខ្លះពោលថា អនិមិត្តមគ្គ សូម្បីមិនបានឈ្មោះដោយការមកដល់ តែដោយបរិយាយនៃព្រះសូត្រ ក៏បានឈ្មោះដោយគុណរបស់ខ្លួន និងដោយអារម្មណ៍ ។ កាលអាចារ្យពួកនោះពោលពាក្យនេះហើយ ក៏ត្រូវសកវាទីអាចារ្យជំទាស់ថា កាលអនិមិត្តមគ្គបានឈ្មោះដោយគុណរបស់ខ្លួន និងដោយអារម្មណ៍ សូម្បីសុញ្ញតមគ្គ និងអប្បណិហិតមគ្គ ក៏គប្បីបានឈ្មោះនេះដោយគុណរបស់ខ្លួន និងដោយអារម្មណ៍ តែក៏មិនបាន ព្រោះហេតុអ្វី ព្រោះថា ធម្មតាមគ្គនេះ រមែងបានឈ្មោះដោយហេតុ ២ យ៉ាង គឺដោយកិច្ចរបស់ខ្លួន និងដោយជាបច្ចនិកៈ គឺថា ដោយហេតុ ២ យ៉ាង គឺដោយកិច្ចរបស់ខ្លួន និងដោយភាពជាបច្ចនិកៈ ( សត្រូវ ) អធិប្បាយថា ដោយសភាវៈ និងដោយជាបដិបក្ខ ។ ក្នុងហេតុទាំង ២ នោះ សុញ្ញតមគ្គ និងអប្បណិ-ហិតមគ្គ រមែងបានឈ្មោះដោយកិច្ចរបស់ខ្លួនខ្លះ ដោយជាបច្ចនិកៈខ្លះ ។ ពិត

ហើយ សុញ្ញតមគ្គ និងអប្បណិហិតមគ្គ រមែងបានឈ្មោះដោយកិច្ចរបស់ខ្លួន យ៉ាងនេះ គឺទទេចាករាគៈជាដើម និងមិនមានទីតាំង ព្រោះមិនមានទីតាំង ដោយទីតាំង គឺរាគៈជាដើម និងរមែងបានឈ្មោះដោយជាបច្ចនិកៈយ៉ាងនេះ គឺសុញ្ញតមគ្គ ជាបដិបក្ខចំពោះការប្រកាន់អត្តា អប្បណិហិតមគ្គ ជាបដិបក្ខចំពោះជាទីតាំង ( គឺរាគៈជាដើម ) ។ ចំណែកអនិមិត្តមគ្គ រមែងបានឈ្មោះដោយកិច្ចរបស់ខ្លួនប៉ុណ្ណោះ ព្រោះមិនមាននិមិត្តនៃរាគៈជាដើម និងនិមិត្តជាទៀងជាដើម មិនមែនបានឈ្មោះដោយជាបច្ចនិកៈ ដ្បិតថា អនិមិត្តមគ្គនោះ មិនជាបដិបក្ខចំពោះអនិច្ចានុបស្សនា ដែលមានសង្ខារនិមិត្តជាអារម្មណ៍ ។ អនិច្ចានុបស្សនា តាំងនៅក្នុងភាពជាអនុលោមដល់អនិមិត្តមគ្គនោះ ព្រោះហេតុនោះ ទើបអនិមិត្តមគ្គមិនមានដោយបរិយាយនៃព្រះអភិធម្ម ដោយប្រការទាំងពួង ។

តែដោយបរិយាយនៃព្រះសូត្រ លោកនាំអនិមិត្តមគ្គនោះ មកសម្តែងយ៉ាងនេះ គឺក្នុងវារៈណា មានការចេញចាកកិលេសដោយមគ្គ លក្ខណៈទាំង ៣ រមែងមកកាន់គន្លងដូចអាវជ្ជនៈតែមួយ ដែលឈ្មោះថា ការមកកាន់គន្លងនៃលក្ខណៈទាំង ៣ ព្រមគ្នាមិនមាន តែដើម្បីសម្តែងសេចក្តីជាក់ច្បាស់នៃកម្មដ្ឋាន ទើបព្រះអង្គត្រាស់យ៉ាងនេះ សេចក្តីប្រកាន់ក្នុងទីណាមួយតាំងអំពីដើម ចូរលើកទុក តែវិបស្សនាដែលជាវុដ្ឋានគាមិនី ពិចារណាធម៌ណាៗ ហើយ រមែងចេញចាកកិលេស តាំងនៅក្នុងឋានៈជាទីតាំងនៃការមកដល់ដោយអំណាចនៃធម៌នោះៗ ឯង រមែងបានឈ្មោះដល់មគ្គរបស់ខ្លួន សេចក្តី

នេះ តើដូចម្តេច ព្រះយោគាវចរ ប្រកាន់ធម៌ណាមួយ បណ្តាលក្ខណៈមានការមិនទៀងជាដើម ក៏សមគួរឃើញលក្ខណៈទាំង ២ ក្រៅអំពីនេះទៀតនោះឯង ។ ធម្មតាការចេញចាកកិលេសដោយមគ្គ ដោយត្រឹមតែការឃើញលក្ខណៈតែមួយប៉ុណ្ណោះ រមែងមិនមាន ព្រោះហេតុនោះ ភិក្ខុប្រកាន់ហើយដោយការមិនទៀង ព្រោះចេញទៅអំពី ( កិលេស ) ដោយភាពជារបស់មិនទៀងតែម្យ៉ាងក៏មិនមែន រមែងចេញទៅចាក ( កិលេស ) ដោយភាពជាទុក្ខ ដោយភាពជាអនត្តាផងនុ៎ះឯង ។ ក្នុងភិក្ខុដែលប្រកាន់ដោយភាពជាទុក្ខ ក៏ន័យនេះឯង ។ ដោយប្រការដូច្នេះ ការប្រកាន់ក្នុងវត្ថុណានីមួយជាអារម្មណ៍តាំងពីដើម ចូរលើកទុក តែវិបស្សនាដែលជាវុដ្ឋានគាមិនី ពិចារណាធម៌ណាៗ រមែងចេញទៅ តាំងនៅក្នុងឋានៈជាទីតាំងនៃការមកដល់ ដោយអំណាចនៃធម៌នោះៗ ឯងហើយ រមែងឲ្យឈ្មោះមគ្គរបស់ខ្លួន ។ ក្នុងលក្ខណៈទាំងនោះ កាលព្រះយោគាវចរ ចេញដោយអនិច្ចលក្ខណៈ មគ្គក៏ជាអនិមិត្ត កាលចេញដោយទុក្ខលក្ខណៈ មគ្គក៏ជាអប្បណិហិត កាលចេញដោយអនត្តលក្ខណៈ មគ្គក៏ជាសុញ្ញត ព្រោះហេតុនោះ ទើបទ្រង់នាំអនិមិត្តមគ្គមកសម្តែងដោយបរិយាយនៃព្រះសូត្រ ដោយប្រការដូច្នេះ ។

សួរថា វិបស្សនាដែលជាវុដ្ឋានគាមិនី មានអ្វីជាអារម្មណ៍ ។ ឆ្លើយថា មានលក្ខណៈជាអារម្មណ៍ ។ ធម្មតាលក្ខណៈមានគតិជាបញ្ញត្តិ ជានវត្តព្វធម៌ ( ធម៌ដែលគប្បីពោលមិនបាន ) តែភិក្ខុណា កំណត់លក្ខណៈ ៣ គឺ អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ៥ របស់ភិក្ខុនោះ រមែងដូចជាសាកសពដែលចង

ត្រង់ក ។ ញាណមានសង្ខារជាអារម្មណ៍នុ៎ះឯង រមែងចេញទៅចាកសង្ខារ ។ ដូចភិក្ខុមួយរូបត្រូវការទិញបាត្រ ឃើញបាត្រដែលឈ្មួញបាត្រនាំមកហើយ ក៏មានសេចក្តីត្រេកអរ គិតថា អញនឹងបានបាត្រ ដូច្នេះ កាលពិនិត្យមើល ឃើញប្រហោងធ្លុះ ៣ កន្លែង ភិក្ខុនោះ អស់សេចក្តីអាល័យក្នុងប្រហោងធ្លុះ ទាំងឡាយក៏មិនមែន តាមពិត អស់សេចក្តីអាល័យក្នុងបាត្រយ៉ាងណា ភិក្ខុ កំណត់លក្ខណៈទាំង ៣ ហើយ ទើបជាអ្នកអស់សេចក្តីអាល័យ ក្នុងសង្ខារ ទាំងឡាយក៏យ៉ាងនោះដូចគ្នា ។ គប្បីជ្រាបថា ភិក្ខុនោះ រមែងចេញទៅចាក សង្ខារដោយញាណ មានសង្ខារជាអារម្មណ៍នុ៎ះឯង ដូច្នេះ ។ សូម្បីឧបមា ដោយសំពត់ ក៏ន័យនេះដូចគ្នា ។

ព្រះមានព្រះភាគ កាលទ្រង់ចែកលោកុត្តរជ្ឈាន ទើបទ្រង់នាំន័យទាំង ២ គឺចតុក្កន័យ និងបញ្ចកន័យ ក្នុងសុទ្ធិកប្បដិបទាមក ដោយប្រការដូច្នេះ ។ ក្នុងសុទ្ធិកសុញ្ញតា ក្នុងសុញ្ញតប្បដិបទា ក្នុងសុទ្ធិកអប្បណិហិត ក្នុងអប្ប-ណិហិតប្បដិបទា ក៏ទ្រង់នាំន័យទាំង ២ គឺចតុក្កន័យ និងបញ្ចកន័យ មក សម្តែងដូចគ្នា ។

សួរថា ព្រោះហេតុអ្វី ទើបទ្រង់នាំមកយ៉ាងនេះ ឆ្លើយថា ព្រោះ អធ្យាស្រ័យរបស់បុគ្គល និងព្រោះលម្អនៃទេសនា គប្បីជ្រាបសូម្បីទាំង ២ ន័យនោះ ដោយន័យដែលពោលហើយក្នុងខាងដើមនុ៎ះឯង ។

ដោយប្រការយ៉ាងនេះ ក្នុងពាក្យថា **លោកុត្តរំ ឈានំ ភាវេតិ** នេះ ទ្រង់ចែក ១០ ន័យ ក្នុងកោដ្ឋាសទាំងអស់ ៥ គឺក្នុងសុទ្ធិកប្បដិបទា

ទ្រង់ចែក ២ ន័យ ដោយអំណាចចតុក្កន័យ និងបញ្ចកន័យ ក្នុងកោដ្ឋាស ដ៏សេសក៏ដូចគ្នា ។

# លោកុត្តរកុសល បកិណ្ណកកថា

ក្នុងលោកុត្តរជ្ឈានទោះ គប្បីជ្រាបបកិណ្ណកធម៌ ដូចតទៅនេះ

ធម៌ខាងក្នុង ធម៌ខាងក្រៅ ក្នុងរូប និងអរូប ក្នុងខន្ធ ៥ ការ

ប្តូរអង្គ ៧ និង ៨ និមិត្ត បដិបទា និងអធិបតី ។

ពិតហើយ ក្នុងលោកុត្តរមគ្គ ភិក្ខុអាស្រ័យធម៌ខាងក្នុង រមែងចេញចាកធម៌ខាងក្នុង អាស្រ័យធម៌ខាងក្នុងហើយ រមែងចេញចាកធម៌ខាងក្រៅ អាស្រ័យធម៌ខាងក្រៅហើយ រមែងចេញចាកធម៌ខាងក្រៅ អាស្រ័យធម៌ខាងក្រៅហើយ រមែងចេញចាកធម៌ខាងក្នុង ។ ភិក្ខុអាស្រ័យរូបហើយ រមែងចេញចាករូប អាស្រ័យរូបហើយ រមែងចេញចាកអរូប អាស្រ័យអរូបហើយ ចេញចាកអរូប អាស្រ័យអរូបហើយ រមែងចេញចាករូប រមែងចេញចាកខន្ធ ៥ ព្រមគ្នា ។

ពាក្យថា **ការប្តូរអង្គ ៧ និង ៨** អធិប្បាយថា គប្បីជ្រាបការប្តូរអង្គមានអង្គ ៧ និងអង្គ ៨ ជាដើមយ៉ាងនេះ គឺមគ្គនេះ មានអង្គ ៨ ខ្លះ មានអង្គ ៧ ខ្លះ សុទ្ធវិបស្សនាជា ៧ ក៏មាន ជា ៦ ក៏មាន សុទ្ធឈានមានអង្គ ៥ ក៏មាន មានអង្គ ៤ ក៏មាន មានអង្គ ៣ ក៏មាន មានអង្គ ២

ក៏មាន ។

ពាក្យថា **និមិត្ត បដិបទា និងអធិបតី** អធិប្បាយថា ពាក្យថា **និមិត្ត** បានដល់ ដែនជាទីចេញ ។ ពាក្យថា **បដិបទា និងអធិបតី** គប្បីជ្រាបការញ៉ាប់ញ៉័រ និងមិនញ៉ាប់ញ៉័រនៃបដិបទា និងអធិបតីនោះឯង ។

ក្នុងពាក្យទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា **អាស្រ័យធម៌ខាងក្នុងហើយ រមែងចេញចាកធម៌ខាងក្នុងមុន** ។ ភិក្ខុបុគ្គលខ្លះ ក្នុងសាសនានេះ រមែងអាស្រ័យខន្ធ ៥ ដែលជាខាងក្នុងតាំងអំពីដើម ដោយមនសិការថា ភិក្ខុក្នុងធម្មវិន័យនេះខាងដើម រមែងចេញចាកធម៌ខាងក្នុង ដូច្នេះ កាលអាស្រ័យហើយ រមែងឃើញខន្ធទាំង ៥ នោះ ដោយភាពជារបស់មិនទៀងជាដើម តែព្រោះការចេញដោយមគ្គ រមែងមានត្រឹមតែការឃើញធម៌ខាងក្នុងសុទ្ធៗ ប៉ុណ្ណោះក៏ទេ គប្បីឃើញធម៌ខាងក្រៅផងដែរ ហេតុនោះ គប្បីឃើញខន្ធរបស់អ្នកដទៃខ្លះ សង្ខារក្ខន្ធដែលមិនមានចិត្តគ្រប់គ្រងខ្លះ ថាជាអនិច្ចំ ទុក្ខំ អនត្តា ។ ភិក្ខុនោះ រមែងពិចារណាធម៌ខាងក្នុងដោយកាលដ៏គួរ រមែងពិចារណាធម៌ខាងក្រៅ ដោយកាលដ៏គួរ ដូច្នេះ ។ កាលលោកពិចារណាយ៉ាងនេះ ក្នុងកាលដែលពិចារណាធម៌ខាងក្នុង វិបស្សនារមែងជាប់តជាមួយមគ្គ ។ ដោយអាការយ៉ាងនេះ ឈ្មោះថា **អាស្រ័យធម៌ខាងក្នុងហើយរមែងចេញចាកធម៌ខាងក្នុង** ។ បើក្នុងវេលាដែលលោកពិចារណាធម៌ខាងក្រៅ វិបស្សនារមែងជាប់តជាមួយមគ្គ ។ ដោយអាការយ៉ាងនេះ ឈ្មោះថា **អាស្រ័យធម៌ខាងក្នុងហើយ រមែងចេញចាកធម៌ខាងក្រៅ** ។ សូម្បីក្នុងការ

អាស្រ័យធម៌ខាងក្រៅហើយ ចេញចាកធម៌ខាងក្រៅ និងចេញចាកធម៌ខាងក្នុង ក៏ន័យនេះដូចគ្នា ។

ភិក្ខុមួយរូបទៀត រមែងអាស្រ័យរូបតាំងអំពីដើម កាលអាស្រ័យហើយ ក៏កំណត់ភូតរូបនិងឧបាទាយរូប រមែងឃើញដោយភាពជារបស់មិនទៀងជាដើម តែព្រោះការចេញដោយមគ្គ រមែងមានដោយត្រឹមការឃើញរូបសុទ្ធៗក៏មិនមែន គប្បីឃើញអរូបផងដែរ ហេតុនោះ ភិក្ខុនោះ ធ្វើរូបនោះឲ្យជាអារម្មណ៍ ហើយកំណត់វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលកើតឡើងហើយថា នេះជាអរូប ដូច្នេះហើយ រមែងឃើញដោយភាពមិនទៀងជាដើម ។ ភិក្ខុនោះ រមែងពិចារណាឃើញរូបដោយកាលដែលគួរ រមែងពិចារណាឃើញអរូបដោយកាលដែលគួរ កាលលោកពិចារណាយ៉ាងនេះ ក្នុងកាលពិចារណារូប វិបស្សនា រមែងជាប់តជាមួយមគ្គ ។ ដោយអាការយ៉ាងនេះ ឈ្មោះថា **អាស្រ័យរូបហើយរមែងចេញចាករូប** ។ បើក្នុងកាលដែលលោកពិចារណាអរូប វិបស្សនារមែងជាប់តជាមួយមគ្គ ។ ដោយអាការយ៉ាងនេះ ឈ្មោះថា **អាស្រ័យរូបហើយ រមែងចេញចាកអរូប** ។ ក្នុងការអាស្រ័យអរូប ហើយចេញចាកអរូប និងចេញចាករូប ក៏ន័យនេះដូចគ្នា ។

ក្នុងកាលដែលភិក្ខុអាស្រ័យធម៌យ៉ាងនេះថា ធម៌ណានីមួយ មានការកើតឡើងជាធម្មតា ធម៌ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ដូច្នេះហើយចេញចាក ( សង្ខតធម៌ ) យ៉ាងនេះទុំឯង ឈ្មោះថា **រមែងចេញចាកខន្ធ ៥ ព្រមគ្នាតែម្យ៉ាង** ។ នេះជាវិបស្សនា របស់ភិក្ខុដែលឃើញច្បាស់ដោយ

បញ្ញាដ៏មុតថា ដែលមានបញ្ញាច្រើន ។

ដូចបុគ្គលដាក់ដុំលាមកក្នុងកណ្តាលភោជន ហើយបង្អោនថាស ដែលពេញដោយភោជន មានរសដ៏ប្រសើរផ្សេងៗ ទៅដើម្បីបុរសអ្នកមានសេចក្តីស្រេកឃ្លាន បុរសអ្នកស្រេកឃ្លាននោះ យកដៃច្របាច់បេះមួយចេញហើយ ឃើញដុំលាមក ហើយពោលថា នេះជាអ្វី កាលគេពោលថា ដុំលាមក ដូច្នេះ ទើបពោលថា ថ្វីយៗ ចូរយកចេញ ជាអ្នកអស់សេចក្តីអាល័យទាំងក្នុងអាហារទាំងក្នុងថាសយ៉ាងណា ពាក្យឧបមាដែលនាំមកប្រៀបនេះ គប្បីជ្រាបយ៉ាងនោះ ។

ពិតហើយ កាលដែលភិក្ខុនេះកាន់យកខន្ធ ៥ ថាជាអញ ជារបស់អញ ក្នុងកាលដែលនៅជាបុថុជ្ជនល្ងង់ខ្លៅ គប្បីជ្រាបដូចកាលដែលបុរសស្រេកឃ្លាននោះ មានចិត្តត្រេកអរក្នុងការឃើញថាសភោជន កាលដែលកំណត់លក្ខណៈ ៣ គប្បីជ្រាបដូចបុរសនោះឃើញដុំលាមក ។ កាលដែលភិក្ខុអ្នកមានការឃើញច្បាស់ដោយបញ្ញាដ៏មុតថា ដែលមានបញ្ញាច្រើនឃើញថាធម៌ណាមួយ មានការកើតឡើងជាធម្មតា ធម៌ទាំងអស់នោះមានការរលត់ទៅជាធម្មតា ហើយចេញចាកខន្ធ ៥ ព្រមគ្នានុ៎ះឯង គប្បីជ្រាបដូចកាលដែលបុរសស្រេកឃ្លាននោះ អស់សេចក្តីអាល័យក្នុងភោជន និងក្នុងថាសដូច្នោះ ។

ក្នុងពាក្យថា **ការប្តូរអង្គ ៧ និង ៨** នេះ គប្បីជ្រាបការប្តូរអង្គធម៌មានប្រភេទតាមដែលពោលនេះដោយប្រការដែលមាន ។ ពិតណាស់ សង្ខា-

រុបេក្ខាញាណប៉ុណ្ណោះ រមែងកំណត់សេចក្តីផ្សេងគ្នានៃពោជ្ឈង្គ អង្គមគ្គ និង អង្គឈាននៃអរិយមគ្គ តែព្រះថេរៈពួកខ្លះពោលថា ឈានដែលជាបាទរមែង កំណត់សេចក្តីផ្សេងគ្នានៃពោជ្ឈង្គ អង្គមគ្គ និងអង្គឈាន ដូច្នេះ ។ ព្រះថេរៈ ពួកខ្លះពោលថា ខន្ធទាំងឡាយដែលជាអារម្មណ៍នៃវិបស្សនា រមែងកំណត់ ។ ព្រះថេរៈពួកខ្លះពោលថា អធ្យាស្រ័យរបស់បុគ្គល រមែងកំណត់ ។ ក្នុងវាទៈ ទាំងឡាយរបស់ព្រះថេរៈទាំងនោះ គប្បីជ្រាបថា វិបស្សនាដែលជាវុដ្ឋាន- គាមិនីដែលជាបុព្វភាគ ពោល គឺសង្ខារុបេក្ខាញាណនេះ រមែងកំណត់ក្នុង សេចក្តីនេះ មានអនុបុព្វីកថាដូចតទៅ

ពិតហើយ ពោលដោយការកំណត់នៃវិបស្សនា មគ្គដែលកើតឡើង ដល់ព្រះសុក្ខវិបស្សកៈក្តី មគ្គដែលកើតឡើងដល់បុគ្គល ដែលបានសមាបត្តិ ដែលមិនធ្វើឈានឲ្យជាបាទក្តី មគ្គដែលកើតឡើងព្រោះធ្វើបឋមជ្ឈាន ឲ្យជា បាទ ហើយពិចារណាបកិណ្ណកសង្ខារក្តី រមែងជាមគ្គប្រកបដោយបឋមជ្ឈាន ទាំងអស់ ។ ក្នុងមគ្គចិត្តទាំងអស់ រមែងមានពោជ្ឈង្គ ៧ មគ្គមានអង្គ ៨ និងអង្គឈាន ៥ ។ វិបស្សនាដែលជាបុព្វភាគនៃមគ្គទាំងនោះ ជាសភាព សហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ ក្នុងកាលដែលចេញ ទៅ ដែលដល់នូវភាពជាសង្ខារុបេក្ខាញាណ រមែងជាសភាវៈដែលសហគតៈ ដោយសោមនស្សប៉ុណ្ណោះ ។

ក្នុងបញ្ចកន័យ ក្នុងមគ្គដែលព្រះយោគាវចរឲ្យកើតឡើង ព្រោះធ្វើទុតិ- យជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈានឲ្យជាបាទ ឈានមានអង្គ ៤ អង្គ ៣ និង

អង្គ ២ ដោយលំដាប់ទុះឯង ។ ក្នុងមគ្គទាំងអស់ អង្គមគ្គមាន ៧[១] ក្នុងឈានទី ៤ ពោជ្ឈង្គមាន ៦ ។ ការផ្សេងគ្នានេះ រមែងមានដោយការកំណត់នៃឈានដែលជាបាទ និងដោយការកំណត់នៃវិបស្សនា ។ វិបស្សនាដែលជាបុព្វភាគនៃមគ្គទាំងនោះ ជាសភាពសហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ តែវិបស្សនាដែលជាវុដ្ឋានគាមិនី ជាសភាពសហគតៈដោយសោមនស្សប៉ុណ្ណោះ ។

ចំណែកក្នុងមគ្គដែលព្រះយោគាវចរឲ្យកើតឡើង ព្រោះធ្វើបញ្ចមជ្ឈានឲ្យជាបាទ អង្គឈានមាន ២ ដោយអំណាចនៃឧបេក្ខា និងឯកគ្គតានៃចិត្ត បានពោជ្ឈង្គ ៦ អង្គមគ្គ ៧ ប៉ុណ្ណោះ សេចក្តីប្លែកគ្នានេះ រមែងមានដោយអំណាចនៃការកំណត់ទាំង ២ យ៉ាង ( ឈាន និងវិបស្សនា ) ក្នុងន័យនេះ វិបស្សនាដែលជាបុព្វភាគ រមែងជាសភាពសហគតៈដោយសោមនស្ស ឬសហគតៈដោយឧបេក្ខា ។ តែវិបស្សនាដែលជាវុដ្ឋានគាមិនីជាសភាពសហគតៈដោយឧបេក្ខាប៉ុណ្ណោះ ។ សូម្បីក្នុងមគ្គដែលព្រះយោគាវចរឲ្យកើតឡើង ព្រោះធ្វើអរូបជ្ឈានទាំងឡាយឲ្យជាបាទក៏ន័យនេះឯង ដោយអាការយ៉ាងនេះ សមាបត្តិដែលចេញហើយ ក្នុងទីជិតនៃមគ្គដែលព្រះយោគាវចរ ចេញចាកឈានដែលជាបាទហើយពិចារណាសង្ខារឯណានីមួយ ហើយឲ្យកើត រមែងធ្វើភាវៈដូចគ្នានឹងខ្លួន ដូចពណ៌ដីធ្វើសត្វទន្សង ឲ្យមានពណ៌ដូចគ្នា ។

តែក្នុងវាទៈរបស់ព្រះថេរៈពួកទី ២ មានអធិប្បាយថា មគ្គដែលព្រះ

---

១- វៀរសម្មាសង្កប្បៈ ។

យោគាវចរ ចេញចាកសមាបត្តិណាមួយ ហើយពិចារណាធម៌ក្នុងសមាបត្តិណាៗ កើតឡើង មគ្គក៏ដូចជាសមាបត្តិនោះៗ ឯង គឺដូចនឹងសមាបត្តិដែលលោកពិចារណាហើយ ។ បើលោកពិចារណាធម៌ ដែលជាកាមាវចរទាំងឡាយ មគ្គក៏ជាការដែលប្រកបដោយបឋមជ្ឈានប៉ុណ្ណោះ ។ ក្នុងវាទៈនេះ គប្បីជ្រាបការកំណត់វិបស្សនា ដោយន័យដែលពោលហើយនោះឯង ។

ក្នុងវាទៈរបស់ព្រះថេរៈពួកទី ៣ មានអធិប្បាយថា មគ្គដែលព្រះយោគាវចរធ្វើឈានណាមួយឲ្យជាបាទ ឬពិចារណាធម៌ក្នុងឈានណាមួយដោយសមគួរដល់អធ្យាស្រ័យរបស់ខ្លួនថា ឱហ្ន៎ អញគប្បីសម្រេចមគ្គប្រកបដោយអង្គ ៧ ឬអង្គ ៨ ដូច្នេះហើយ ឲ្យកើតឡើង មគ្គក៏ដូចនឹងឈាននោះឯង តែមគ្គនោះ វៀរឈានដែលជាបាទ ឬឈានដែលពិចារណាហើយ រមែងមិនសម្រេចដោយត្រឹមតែអធ្យាស្រ័យតែម្យ៉ាង ។ សេចក្ដីនេះ បណ្ឌិតគប្បីសម្ដែងដោយនន្ទកោវាទសូត្រ ។ ពិតហើយ ព្រះតម្រាស់នេះ ព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថទី ១៥ ជនជាច្រើនតែងមិនមានសេចក្ដីសង្ស័យ ឬងឿងឆ្ងល់ថា ព្រះចន្ទខ្វះ ឬព្រះចន្ទពេញ ដូច្នេះឡើយ គឺចូលចិត្តថា ព្រះចន្ទពេញដោយពិត សេចក្ដីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីនោះ មានសេចក្ដីត្រេកអរក្នុងធម្មទេសនារបស់នន្ទកភិក្ខុផង មានបំណងពេញលេញផង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុនីទាំងឡាយប្រាំរយនោះ ភិក្ខុនីដែលក្រោយគេបំផុត ភិក្ខុនីនោះជា

សោតាបន្នា មានសភាពមិនធ្លាក់ទៅក្នុងអបាយភូមិ ជាអ្នកទៀងតទៅកពខាង មុខ នឹងបានត្រាស់ដឹង ( នូវសច្ចធម៌ ) ដូច្នេះ ។

បណ្តាភិក្ខុនីទាំងនោះ ភិក្ខុនីរូបណា មានឧបនិស្ស័យនៃសោតាបត្តិផល ភិក្ខុនីរូបនោះ ក៏មានសេចក្តីត្រិះរិះបរិបូណ៌ហើយ ដោយសោតាបត្តិផលនោះឯង ។បេ។ ភិក្ខុនីរូបណា មានឧបនិស្ស័យនៃព្រះអរហត្ត ភិក្ខុនីរូបនោះ ក៏មានសេចក្តីត្រិះរិះបរិបូណ៌ហើយ ដោយព្រះអរហត្តនោះឯង ។

មគ្គដែលព្រះយោគាវចរធ្វើឈានណាមួយ ឲ្យជាបាទ ឬពិចារណាធម៌ក្នុងឈានណាមួយ ដោយសមគួរដល់អធ្យាស្រ័យរបស់ខ្លួន ឲ្យកើតឡើងហើយ រមែងជាការដែលដូចគ្នានឹងឈាននោះៗ ឯង ។ មគ្គដែលដូចគ្នានឹងឈាននោះៗ វៀរឈានដែលជាបាទ ឬវៀរឈានដែលពិចារណាហើយ រមែងមិនសម្រេចដោយត្រឹមតែអធ្យាស្រ័យប៉ុណ្ណោះ ព្រោះហេតុនោះ ក្នុងវារៈនេះ គប្បីជ្រាបការកំណត់វិបស្សនា ដោយន័យដែលពោលហើយនោះឯង ។

បណ្តាវាទៈរបស់ព្រះថេរៈទាំងនោះ ព្រះចូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក មានវាទៈយ៉ាងនេះថា ឈានដែលជាបាទប៉ុណ្ណោះ រមែងកំណត់ដូច្នេះ ត្រូវអន្តេវាសិកសួរថា បពិត្រលោកដ៏ចម្រើន ក្នុងទីណាមានឈានដែលជាបាទ ក្នុងទីនោះឈានដែលជាបាទនោះ ក៏កំណត់ចុះ តែក្នុងទីណា ( អរូបភព ) ឈានដែលជាបាទមិនមានក្នុងអរូបភពនោះ អ្វីកំណត់ ។ ព្រះថេរៈតបថា អាវុសោ សូម្បីក្នុងទីនោះ ឈានដែលជាបាទនោះឯងរមែង

កំណត់ ដ្បិតថា ភិក្ខុណាបានសមាបត្តិ ៨ ធ្វើបឋមជ្ឈានឲ្យជាបាទហើយ ញ៉ាំងសោតាបត្តិមគ្គ និងសោតាបត្តិផលឲ្យកើតឡើងហើយ ជាអ្នកមានឈាន មិនសាបសូន្យ ធ្វើកាលកិរិយាហើយ កើតក្នុងអរូបភព ចេញចាកសមាបត្តិ នៃសោតាបត្តិផលដែលប្រកបដោយបឋមជ្ឈាន ផ្ដើមចម្រើនវិបស្សនា ញ៉ាំង មគ្គ និងផល ៣ ខាងលើឲ្យកើតឡើង មគ្គ និងផលទាំងនោះរបស់លោក ក៏ រមែងប្រកបជាមួយនឹងបឋមជ្ឈាននោះឯង សូម្បីក្នុងមគ្គផល ដែលប្រកប ជាមួយនឹងទុតិយជ្ឈានជាដើម ក៏ន័យនេះដូចគ្នា ។ ឈានដែលជាពួក ៣ ពួក ៤ រមែងកើតឡើងក្នុងអរូបបាន ក៏ឈានពួក ៣ ពួក ៤ នោះឯង ជាលោកុត្តរ មិនមែនលោកិយ អាវុសោ សូម្បីដោយអាការយ៉ាងនេះក៏ដូច គ្នា ឈានដែលជាបាទប៉ុណ្ណោះរមែងកំណត់ ។ ពួកអន្តេវាសិកពិតលោកថា លោកម្ចាស់ បញ្ហារបស់លោក ពោលល្អហើយ ដូច្នេះ ។

សូម្បីព្រះមហាទត្តត្ថេរគង់នៅមោរវាបិវិហារ មានវាទៈយ៉ាងនេះថា ខន្ធ ទាំងឡាយដែលជាអារម្មណ៍របស់វិបស្សនារមែងកំណត់ ដ្បិតថា ព្រះយោ- គាវចរពិចារណាធម៌ណាៗ ហើយចេញ មគ្គរមែងដូចគ្នានឹងធម៌នោះៗ ឯង ត្រូវ ពួកអន្តេវាសិកសួរថា បពិត្រលោកម្ចាស់ ក្នុងវាទៈរបស់លោក ការខុស ភ្លាំងភ្លាត់រមែងប្រាកដ ដ្បិតថា ភិក្ខុអ្នកពិចារណារូប ហើយចេញ ( ចាក សន្និតអារម្មណ៍ ) បានហើយ មគ្គក៏គប្បីជាអព្យាកតដូចរូប កាលព្រះ យោគាវចរ កំណត់នេវសញ្ញានាសញ្ញាយតនៈដោយន័យហើយចេញ មគ្គក៏ គប្បីដល់នូវភាពជានេវសញ្ញានាសញ្ញាយតនៈ ដូចគ្នានឹងនេវសញ្ញានាសញ្ញា-

យតនៈនោះ ព្រះថេរៈឆ្លើយថា អាវុសោ ដូច្នោះក៏ទេ ព្រោះលោកុត្តរមគ្គដែលមិនដល់នូវអប្បនាមិនមាន ព្រោះហេតុនោះ កាលភិក្ខុពិចារណារូបហើយចេញទៅបាន មគ្គរមែងប្រកបដោយអង្គ ៨ រមែងសហគតៈដោយសោមនស្ស កាលពិចារណានេវសញ្ញានាសញ្ញាយតនៈ ហើយចេញទៅបាន មគ្គរមែងយ៉ាងនោះ ដោយអាការទាំងពួងក៏ទេ តែមគ្គដែលសហគតៈដោយឧបេក្ខា រមែងប្រកបដោយអង្គ ៧ ។

ភិក្ខុទាំងឡាយ នាំវាទៈរបស់ព្រះចូឡាភយត្ថេរដែលមានវាទៈថា អជ្ឈាស្រ័យនៃបុគ្គលរមែងកំណត់ មកសាកសួរដល់ព្រះចូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ។ ព្រះចូឡនាគត្ថេរក៏ពោលថា សម្រាប់បុគ្គលដែលមានឈានជាបាទ អជ្ឈាស្រ័យនៃបុគ្គល ចូរកំណត់ចុះ សម្រាប់បុគ្គលដែលមិនមានឈាននោះ អជ្ឈាស្រ័យអ្វីកំណត់ វេលានោះ ដូចវេលានៃការស្វែងរកភាពរុងរឿងនៃបុគ្គលដែលឥតទ្រព្យ ។

ភិក្ខុទាំងឡាយបាននាំពាក្យនោះមកសាកសួរដល់ព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ។ ព្រះថេរៈនោះពោលថា អាវុសោទាំងឡាយ ពាក្យនេះ លោកពោលសម្រាប់បុគ្គលអ្នកមានឈានជាបាទ ដូចអជ្ឈាស្រ័យរបស់បុគ្គលអ្នកមានឈានជាបាទ យ៉ាងណា សូម្បីរបស់បុគ្គលអ្នកមានឈានពិចារណាហើយ ក៏គប្បីជ្រាបយ៉ាងនោះដូចគ្នា ព្រោះមគ្គដែលកើតឡើងហើយដល់ព្រះយោគាវចរដែលចេញចាកបញ្ចមជ្ឈាន ហើយពិចារណាបឋមជ្ឈានជាដើម ជាមគ្គប្រកបដោយបញ្ចមជ្ឈាន តាមវាទៈរបស់ព្រះថេរៈពួកទីមួយ

និងជាមគ្គដែលប្រកបដោយបឋមជ្ឈានជាដើម តាមវាទៈរបស់ព្រះថេរៈពួកទីពីរ ព្រោះហេតុនោះ វាទៈទាំង ២ រមែងជំទាស់គ្នា តែក្នុងវាទៈទី ៣ ព្រះយោគាវចរ រមែងប្រាថ្នាឈានណា ក្នុងឈានទាំងនេះ មគ្គក៏ប្រកបដោយឈាននោះ ព្រោះហេតុនោះ ទើបវាទៈទាំងនោះមិនខុស អជ្ឈាស្រ័យក៏មានប្រយោជន៍ដោយអាការយ៉ាងនេះ ព្រះថេរៈទាំង ៣ រូប ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកសម្បូរដោយគុណធម៌ដ៏ចម្រើន ។ ដោយហេតុនោះ អន្តេវាសិកទាំងនោះ ទើបធ្វើវាទៈរបស់ព្រះថេរៈទាំង ៣ នោះ ឲ្យជាបែបផែន ។ ទើបក្នុងអភិធម្មនេះ ខ្ញុំលើកអត្ថនោះឯង ឡើងសម្ដែងថា វិបស្សនា រមែងកំណត់វាទៈទាំង ៣ នេះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **និមិត្ត បដិបទា និងអធិបតី** ដូចតទៅ សួរថា ក្នុងកាលកើតឡើងនៃមគ្គដែលបួរអង្គយ៉ាងនេះ គោត្រភូរមែងចេញទៅអំពីទីណា មគ្គរមែងចេញទៅអំពីទីណា ។ ឆ្លើយថា គោត្រភូមែងចេញចាកនិមិត្តមុន តែមិនអាចកាត់ការប្រព្រឹត្តិទៅ ( នៃនិមិត្ត ) ព្រោះគោត្រភូនោះ មានការចេញទៅតែម្យ៉ាង ។ មគ្គរមែងចេញចាកនិមិត្តរមែងកាត់ការប្រព្រឹត្តិទៅ ព្រោះមគ្គនេះមានការចេញទៅទាំង ២ យ៉ាង ។ បណ្ដាការចេញទៅនៃគោត្រភូ និងមគ្គនោះ គប្បីជ្រាបន័យ គឺការកើតឡើងដូចតទៅ

ក្នុងវារៈ ( គឺក្នុងមគ្គវីថិ ) ណា មានការចេញទៅដោយមគ្គ ក្នុងវារៈនោះ មិនមែនមានអនុលោមញាណមួយដួង មិនមានអនុលោមញាណដួងទី

៥ ។ ព្រោះអនុលោមញ្ញាណមានម្តង រមែងមិនបានអាសេវនប្បច្ច័យ អនុ-លោមញ្ញាណជួនទី ៥ រមែងញាប់ញ័រ ព្រោះជិតធ្លាក់ចុះកាន់ភវង្គ ព្រោះថាក្នុងកាលនោះ ជវនចិត្ត ឈ្មោះថា ធ្លាក់ទៅហើយ ព្រោះហេតុនោះ ទើបអនុលោមញ្ញាណ មិនមែនមានមួយជួន មិនមានជួនទី ៥ ។ បុគ្គលមានបញ្ញាច្រើន មានអនុលោមញ្ញាណ ២ ជួន ជួនទី ៣ ជាគោត្រភូ ជួនទី ៤ ជាមគ្គចិត្ត មានផលចិត្ត ៣ ជួន បន្ទាប់អំពីនោះ ចិត្តក៏ចុះកាន់ភវង្គ ។

ចំណែកបុគ្គលអ្នកមានបញ្ញាកណ្តាល អនុលោមញ្ញាណមាន ៣ ជួន ជួនទី ៤ ជាគោត្រភូ ជួនទី ៥ ជាមគ្គចិត្ត មានផលចិត្ត ២ ជួន បន្ទាប់អំពីនោះ ចិត្តក៏ធ្លាក់ចុះកាន់ភវង្គ ។

សម្រាប់បុគ្គលអ្នកមានបញ្ញាតិច អនុលោមញ្ញាណមាន ៤ ជួន ជួនទី ៥ ជាគោត្រភូ ជួនទី ៦ ជាមគ្គចិត្ត ជួនទី ៧ ជាផលចិត្ត បន្ទាប់អំពីនោះ ចិត្តក៏ធ្លាក់ចុះកាន់ភវង្គ ។

បណ្តាព្រះយោគាវចរ ៣ ប្រភេទនោះ ខ្ញុំមិនពោលដោយអំណាចនៃលោកអ្នកមានបញ្ញាច្រើន និងមានបញ្ញាតិច តែគប្បីពោលដោយអំណាចនៃលោកអ្នកមានបញ្ញាកណ្តាល ។ ក្នុងវារៈណា មានការចេញទៅដោយមគ្គ មនោវិញ្ញាណធាតុដែលជាអហេតុកកិរិយា សហគតៈដោយឧបេក្ខា ជាមនោ-ទ្វារាវជ្ជនចិត្ត ធ្វើខន្ធទាំងឡាយដែលជាអារម្មណ៍នៃវិបស្សនា ឲ្យជាអារម្មណ៍ ហើយធ្វើភវង្គឲ្យប្តូរទៅ បន្ទាប់អំពីនោះទៅ ជវនជួនដំបូង ឈ្មោះ**អនុលោ-មញ្ញាណ** ក៏កើតឡើងកាន់យកខន្ធដែលមនោទ្វារាវជ្ជនចិត្តនោះ កាន់យកជា

អារម្មណ៍ អនុលោមញ្ញាណនោះ ក៏ប្រព្រឹត្តទៅក្នុងខន្ធទាំងនោះថា មិនទៀង ខ្លះ ជាទុក្ខខ្លះ ជាអនត្តាខ្លះ បន្ទាប់ងងឹតដ៏គ្រោតគ្រាតដែលបិទបាំងសច្ចៈ ធ្វើលក្ខណៈទាំង ៣ ឲ្យជាក់ច្បាស់ក្រៃលែងឡើងៗ ហើយក៏រលត់ទៅ បន្ទាប់ អំពីនោះ អនុលោមញ្ញាណជួនទី ២ ក៏កើតឡើង បណ្ដាអនុលោមញ្ញាណ ២ ជួននោះ ជួនដំបូងមិនមានអាសេវនប្បច្ច័យ ជួនទី ២ មានជួនដំបូងជា អាសេវនប្បច្ច័យ ជួនទី ២ នោះ ព្រោះបានអាសេវនប្បច្ច័យហើយ ទើប ជាញាណមុតថ្លា ផូរផង់ ប្រព្រឹត្តទៅក្នុងអារម្មណ៍នោះៗ ឯង ដោយអាការ នោះដូចគ្នា បន្ទាប់ងងឹតជាកណ្ដាលដែលបិទបាំងនូវសច្ចៈ ធ្វើលក្ខណៈ ៣ ឲ្យជាក់ច្បាស់ក្រៃលែងឡើងៗ ហើយរលត់ទៅ ក្នុងលំដាប់នោះ អនុលោ-មញ្ញាណជួនទី ៣ ក៏កើតឡើង អនុលោមញ្ញាណជួនទី ៣ នោះ មាន អនុលោមញ្ញាណជួនទី ២ ជាអាសេវនប្បច្ច័យ ។ អនុលោមញ្ញាណជួនទី ៣ នោះ ព្រោះបានអាសេវនប្បច្ច័យហើយ ទើបមុតថ្លា ផូរផង់ ប្រព្រឹត្តទៅក្នុង អារម្មណ៍នោះៗ ឯងដោយអាការនោះដូចគ្នា បន្ទាប់ងងឹតដែលល្អិតដែលនៅ សេសសល់ ដែលបិទបាំងសច្ចៈនោះ ធ្វើឲ្យអស់ទៅ ធ្វើលក្ខណៈ ៣ ឲ្យ ជាក់ច្បាស់ក្រៃលែងឡើងៗ ហើយរលត់ទៅ ។ កាលអនុលោមញ្ញាណទាំង ៣ បន្ទាប់ងងឹត ដែលបិទបាំងសច្ចៈយ៉ាងនេះហើយ លំដាប់នោះ គោត្រភូញាណក៏កើតឡើង ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ។

ក្នុងសេចក្ដីនោះមានឧបមាដូច្នេះ បានឮថា បុរសមានភ្នែកល្អម្នាក់ គិត ថា អញនឹងដឹងការប្រកបផ្កាយឫក្ស ទើបចេញទៅក្នុងវេលារាត្រី សម្លឹង

មើលព្រះចន្ទ ដួងចន្ទមិនប្រាកដដល់គេ ព្រោះពពកទាំងឡាយបិទបាំង ខណៈនោះ ខ្យល់មួយតាំងឡើងហើយ បក់ពពកក្រាស់ៗ ទាំងឡាយឲ្យខ្ចាត់ខ្ចាយទៅ ខ្យល់ដទៃទៀតតាំងឡើងបក់ពពកយ៉ាងកណ្ដាល ខ្យល់មួយទៀត ក៏តាំងឡើងបក់ពពកដែលល្អិតឲ្យខ្ចាត់ខ្ចាយទៅ ។ លំដាប់នោះ ទើបបុរសនោះ ឃើញដួងចន្ទនោះ លើផ្ទៃមេឃដែលប្រាសចាកពពកទាំងឡាយ បានដឹងហើយ នូវការប្រកបផ្កាយឫក្ស ។

ក្នុងពាក្យឧបមាទាំងនោះ ងងឹត គឺកិលេសយ៉ាងគ្រោតគ្រាត យ៉ាងកណ្ដាល យ៉ាងល្អិត ដែលបិទបាំងនូវសច្ចៈ ប្រៀបដូចពពក ៣ ក្រុម ។ អនុលោមញ្ញាណ ៣ ដួង ប្រៀបដូចខ្យល់ ៣ ប្រភេទ ។ គោត្រភូញាណ ប្រៀបដូចបុរសអ្នកមានភ្នែកល្អ ។ ព្រះនិព្វាន ប្រៀបដូចព្រះចន្ទ ។ ការបន្ទោបង់ងងឹតដែលបិទបាំងនូវសច្ចៈរបស់អនុលោមចិត្តមួយដួងៗ ប្រៀបដូចខ្យល់មួយប្រភេទៗ ទម្លាយពពក ៣ ក្រុមដោយលំដាប់ ។ កាលងងឹតដែលបិទបាំងនូវសច្ចៈ នឹងប្រាសចាកទៅហើយ គោត្រភូញាណ ក៏ធ្វើព្រះនិព្វានដែលបរិសុទ្ធឲ្យជាអារម្មណ៍ ប្រៀបដូចការដែលបុរសនោះ ឃើញព្រះចន្ទបរិសុទ្ធ លើផ្ទៃមេឃដែលប្រាសចាកពពក ដូច្នោះ ។

ដូចខ្យល់ ៣ ប្រភេទ រមែងកម្ចាត់ពពក ដែលបិទបាំងដួងចន្ទប៉ុណ្ណោះឯង រមែងមិនអាចឃើញដួងចន្ទយ៉ាងណា អនុលោមញ្ញាណទាំងឡាយ ក៏អាចកម្ចាត់ងងឹតដែលបិទបាំងសច្ចៈ តែមិនអាចធ្វើព្រះនិព្វានឲ្យជាអារម្មណ៍យ៉ាងនោះដូចគ្នា ។ បុរសរមែងឃើញដួងចន្ទនោះឯង តែមិនអាចកម្ចាត់ពពកទាំង

ឡាយបានយ៉ាងណា គោត្រភូញាណក៏រមែងអាចធ្វើព្រះនិព្វាននោះឯង ឲ្យជាអារម្មណ៍បាន តែមិនអាចកម្ចាត់ងងឹត គឺកិលេសបានយ៉ាងនោះ ។ អនុលោមញ្ញាណ មានសង្ខារជាអារម្មណ៍ គោត្រភូញាណ មានព្រះនិព្វានជាអារម្មណ៍ ដោយប្រការដូច្នេះ ។

បើគោត្រភូញាណ គប្បីទទួលអារម្មណ៍ដែលអនុលោមញ្ញាណទទួលហើយ អនុលោមញ្ញាណក៏គប្បីចង ( មានអារម្មណ៍តែមួយ ) គោត្រភូញាណនោះទៀត ព្រោះហេតុនោះ ការចេញដោយមគ្គនុ៎ះឯង ក៏មិនគប្បីមាន ។ តែគោត្រភូញាណ មិនទទួលអារម្មណ៍របស់អនុលោមញ្ញាណ ធ្វើអារម្មណ៍នោះឲ្យប្រព្រឹត្តទៅខាងក្រោយគោត្រភូញាណឯង មិនមែនអាវជ្ជនៈ តែក៏តាំងនៅក្នុងឋានៈនៃអាវជ្ជនៈ ដូចឲ្យសញ្ញាដល់មគ្គនោះដោយពាក្យថា ចូរអ្នកកើតឡើងយ៉ាងនេះ ដូច្នេះហើយ ក៏រលត់ទៅ ។ សូម្បីមគ្គក៏មិនបានលះបង់សញ្ញាដែលគោត្រភូញាណនោះឲ្យហើយ ចងនូវញាណនោះដោយអំណាចនៃការបន្ត ដូចក្រសែរលក ( ជាប់តគ្នាមិនដាច់ ) រមែងកើតឡើងចោះទម្លុះ ចាក់ទម្លាយនូវគំនរលោភៈ គំនរទោសៈ គំនរមោហៈ ដែលមិនធ្លាប់ចោះទម្លុះ មិនធ្លាប់ទម្លាយ ។ ក្នុងសេចក្តីនោះ មានឧបមាដូចតទៅនេះ បានឮថា នាយខ្មាន់ធ្នូម្នាក់ ឲ្យតាំងនូវខែល មួយរយខែល ក្នុងទីចម្ងាយមួយរយធ្នូ យកសំពត់ចងមុខ ហើយផ្ទាប់ព្រួញឈរលើក្តារយន្ត បុរសដទៃបង្វិលយន្ត កាលណាផ្ទាំងខែលនៅត្រង់មុខនាយខ្មាន់ធ្នូ ក្នុងកាលនោះ ក៏ឲ្យសញ្ញាដោយដំបងតូចៗ ក្នុងពេលនោះនាយខ្មាន់ធ្នូ មិនលះសញ្ញាដំបងតូចៗ បាញ់ព្រួញ

ចេញទៅទម្លុះខែលរបស់រយបាន ។

ក្នុងសេចក្ដីឧបមានោះ គោត្រភូញាណប្រៀបដូចសញ្ញានៃដំបងតូចៗ ។ មគ្គញ្ញាណប្រៀបដូចនាយខ្មាន់ធ្នូ ។ ការដែលមគ្គញ្ញាណមិនលះសញ្ញាដែលគោត្រភូញាណឲ្យហើយនុ៎ះឯង ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍តែម្យ៉ាង និងបោះទម្លាយគំនរលោភៈជាដើម ដែលមិនធ្លាប់បោះហើយ មិនធ្លាប់ទម្លាយហើយ ប្រៀបដូចការដែលនាយខ្មាន់ធ្នូ មិនលះសញ្ញាដំបងតូចៗ ហើយឈរបាញ់ទម្លុះខែលរបស់រយបាន ។ ការបោះទម្លាយគំនរលោភៈជាដើមនេះ លោកក៏ពោលថា ការដកឡើងនូវកិលេសដែលបានភូមិហើយ និងកិលេសដែលទាក់ទងក្នុងវដ្ដៈ ព្រោះកិច្ចនៃមគ្គមានតែម្យ៉ាងប៉ុណ្ណោះ គឺការលះអនុស័យ ។ មគ្គនោះ កាលលះអនុស័យទាំងឡាយ ឈ្មោះថា រមែងចេញចាកនិមិត្ត ឈ្មោះថា រមែងកាត់ការប្រព្រឹត្តិទៅ ។ ពាក្យថា **និមិត្ត** គឺនិមិត្តនៃរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ ពាក្យថា **ការប្រព្រឹត្តិទៅ** គឺការប្រព្រឹត្តិទៅនៃរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណនុ៎ះឯង ។ ការប្រព្រឹត្តទៅនោះមាន ២ យ៉ាង បានដល់ ឧបាទិន្នក និងអនុបាទិន្នក ។ ក្នុងពីរយ៉ាងនោះ អាចារ្យពួកខ្លះពោលថា ស្រមោលនៃការចេញទៅចាកអនុបាទិន្នក រមែងប្រាកដដល់មគ្គ ហើយពោលថា មគ្គ រមែងចេញចាកអនុបាទិន្នក ។

ពិតហើយ សោតាបត្តិមគ្គ រមែងលះអកុសលចិត្ត ៥ ដួង គឺចិត្ត ៤ ដួងដែលសម្បយុត្តដោយទិដ្ឋិ និងចិត្ត ១ ដួងដែលសហគតៈដោយវិចិកិច្ឆា ។ អកុសលចិត្តទាំង ៥ ដួងនោះ រមែងញុំាងរូបឲ្យតាំងឡើង ។ រូបនោះជា

រូបក្ខន្ធដែលជាអនុបាទិន្នក ចិត្តទាំង ៥ ដួងនោះ ជាវិញ្ញាណក្ខន្ធ វេទនា សញ្ញា និងសង្ខារដែលសម្បយុត្តដោយវិញ្ញាណក្ខន្ធនោះ ជាអរូបក្ខន្ធ ៣ ។ ក្នុងអនុបាទិន្នកនោះ បើព្រះសោតាបន្នទឹងមិនបានចម្រើនឲ្យសោតាបត្តិមគ្គកើតឡើងសោត អកុសលចិត្តទាំង ៥ នេះ ក៏គប្បីដល់នូវការរួបរឹតក្នុងអារម្មណ៍ទាំង ៦ ។ ក៏សោតាបត្តិមគ្គ កាលទឹងហាមការកើត ការបោមរោមរបស់អកុសលទាំងនោះ ទើបធ្វើការដកឡើងនូវកិលេសដែលរួបរឹតឲ្យមានភាវៈដែលមិនគួរកើតឡើងបាន ទើបឈ្មោះថា **រមែងចេញចាកអនុបាទិន្នក** ។

សកទាគាមិមគ្គ រមែងលះអកុសលចិត្ត ៦ ដួង ដែលជាកាមរាគៈ និងព្យាបាទយ៉ាងគ្រោតគ្រាត គឺចិត្ត ៤ ដួងដែលជាទិដ្ឋិវិប្បយុត្ត និងចិត្ត ២ ដួងដែលជាទោមនស្សសហគតៈ ។ អនាគាមិមគ្គ រមែងលះអកុសលចិត្តទាំង ៦ ដួងនោះឯង ដែលជាកាមរាគៈ និងព្យាបាទយ៉ាងល្អិត ។ **អរហត្តមគ្គ** រមែងលះអកុសលចិត្ត ៥ ដួង គឺចិត្ត ៤ ដួងដែលជាទិដ្ឋិវិប្បយុត្ត និងចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ។ ក្នុងអនុបាទិន្នកនោះ បើព្រះអរិយៈទាំងនោះមិនគប្បីចម្រើនមគ្គឲ្យកើតឡើងសោត អកុសលចិត្តទាំងនោះ ក៏គប្បីដល់នូវការបោមរោមក្នុងអារម្មណ៍ ៦ អំពីមគ្គទាំងនោះ កាលហាមការកើតឡើងបោមរោមនៃអកុសលចិត្តទាំងនោះ ទើបធ្វើការដកឡើងនូវកិលេសដែលរួបរឹត ឲ្យមានភាវៈដែលគួរកើតឡើងបាន ទើបឈ្មោះថា **រមែងចេញចាកអនុបាទិន្នក** ។

អាចារ្យពួកខ្លះពោលថា ស្រមោលនៃការចេញទៅចាកឧបាទិន្នក រមែង

ប្រាកដ ដូច្នេះហើយ ពោលថា មគ្គរមែងចេញចាកឧបាទិន្នក ដូច្នេះ ។ បើព្រះសោតាបន្ន មិនបានចម្រើនឲ្យសោតាបត្តិមគ្គកើតហើយសោត ការប្រព្រឹត្តិទៅនៃឧបាទិន្នកក្ខន្ធ ក៏គប្បីប្រព្រឹត្តទៅក្នុងសំសារវដ្ដ ដែលមានខាងដើម និងខាងចុងដែលបុគ្គលដឹងមិនបានហើយដែលលើស ៧ ភព ។ ព្រោះហេតុអ្វី ព្រោះហេតុទាំងឡាយ នៃការប្រព្រឹត្តិទៅរបស់ឧបាទិន្នកក្ខន្ធនោះ នៅមាន ។ ក៏សោតាបត្តិមគ្គ កាលកើតឡើងនុ៎ះឯង រមែងដកឡើងនូវកិលេសទាំង ៥ នេះ គឺសញ្ញោជនៈ ៣ យ៉ាង ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ។ ឥឡូវនេះ ការប្រព្រឹត្តិទៅនៃឧបាទិន្នករបស់ព្រះសោតាបន្ន នឹងប្រព្រឹត្តទៅក្នុងសំសារវដ្ដដែលមានខាងដើម និងខាងចុងដែលបុគ្គលដឹងមិនបានហើយ ដែលលើសជាង ៧ អំពីទីណា ។ សោតាបត្តិមគ្គ កាលធ្វើការប្រព្រឹត្តិទៅនៃឧបាទិន្នក មិនឲ្យប្រព្រឹត្តទៅ ឈ្មោះថា **រមែងចេញចាកឧបាទិន្នក** ដោយប្រការដូច្នេះ ។

បើព្រះសកទាគាមីមិនបានចម្រើនសកទាគាមិមគ្គឲ្យកើតឡើងសោត ការប្រព្រឹត្តទៅរបស់ឧបាទិន្នក ក៏គប្បីប្រព្រឹត្តទៅក្នុងភព ៥ លើស ២ ( ប្រាំពីរ ) ។ ព្រោះហេតុអ្វី ព្រោះហេតុទាំងឡាយ នៃការប្រព្រឹត្តិទៅរបស់ឧបាទិន្នកនោះនៅមាន ។ សកទាគាមិមគ្គនោះ កាលកើតឡើងនុ៎ះឯង រមែងដកឡើងនូវកិលេសទាំង ៤ គឺកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ យ៉ាងគ្រោតគ្រាត កាមរាគានុស័យយ៉ាងគ្រោតគ្រាត បដិឃានុស័យយ៉ាងគ្រោតគ្រាត ។ ឥឡូវនេះ ការប្រព្រឹត្តិទៅនៃឧបាទិន្នក របស់ព្រះសកទាគាមីនឹង

ប្រព្រឹត្តទៅក្នុងភពទាំង ៥ លើស ២ អំពីណា ។ សកទាគាមិមគ្គ កាល ធ្វើការប្រព្រឹត្តិទៅនៃឧបាទិន្នកមិនឲ្យប្រព្រឹត្តទៅ ឈ្មោះថា **រមែងចេញចាក ឧបាទិន្នក** ដោយប្រការដូច្នេះ ។

បើព្រះអនាគាមី មិនបានចម្រើនអនាគាមិមគ្គឲ្យកើតសោត ការប្រព្រឹត្តិ ទៅនៃឧបាទិន្នក ក៏គប្បីប្រព្រឹត្តទៅក្នុងភព ២ លើស ១ ។ ព្រោះហេតុអ្វី ព្រោះហេតុទាំងឡាយនៃការប្រព្រឹត្តទៅនៃឧបាទិន្នកនោះនៅមាន អនាគាមិមគ្គ នោះ កាលកើតឡើងនុ៎ះឯង រមែងដកឡើងនូវកិលេសទាំង ៤ នេះ គឺកាម-រាគសំយោជនៈដ៏ល្អិត ១ បដិឃសំយោជនៈដ៏ល្អិត ១ កាមរាគានុស័យដ៏ ល្អិត ១ បដិឃានុស័យដ៏ល្អិត ១ ។ ឥឡូវនេះ ការប្រព្រឹត្តិទៅនៃឧបាទិន្នក របស់ព្រះអនាគាមី នឹងប្រព្រឹត្តទៅក្នុងភព ២ លើស ១ អំពីណា ។ អនាគាមិមគ្គ កាលធ្វើការប្រព្រឹត្តិទៅនៃឧបាទិន្នក មិនឲ្យប្រព្រឹត្តទៅ ឈ្មោះ ថា **រមែងចេញចាកឧបាទិន្នក** ដោយប្រការដូច្នេះ ។

បើព្រះអរហន្ត មិនបានចម្រើនអរហត្តមគ្គឲ្យកើតសោត ការប្រព្រឹត្តិទៅ នៃឧបាទិន្នក ក៏គប្បីប្រព្រឹត្តទៅក្នុងរូបភព និងអរូបភព ព្រោះហេតុអ្វី ព្រោះ ហេតុទាំងឡាយ នៃការប្រព្រឹត្តិទៅរបស់ឧបាទិន្នកនៅមាន ។ អរហត្តមគ្គនោះ កាលកើតឡើងនុ៎ះឯង រមែងដកឡើងនូវកិលេសទាំង ៨ នេះ គឺរូបរាគៈ ១ អរូបរាគៈ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ មានានុស័យ ១ ភវរាគា-នុស័យ ១ អវិជ្ជានុស័យ ១ ។ ឥឡូវនេះ ការប្រព្រឹត្តិទៅនៃឧបាទិន្នករបស់ ព្រះខីណាស្រព នឹងប្រព្រឹត្តទៅក្នុងភពថ្មីបានអំពីណា ។ អរហត្តមគ្គ កាល

ធ្វើការប្រព្រឹត្តិទៅនៃឧបាទិន្នកមិនឲ្យប្រព្រឹត្តទៅនុ៎ះឯង ឈ្មោះថា **រមែងចេញចាកឧបាទិន្នក** ដោយប្រការដូច្នេះ ។

បណ្តាមគ្គទាំង ៤ នេះ សោតាបត្តិមគ្គ រមែងចេញចាកអបាយភព សកទាគាមិមគ្គ រមែងចេញចាកចំណែកខ្លះនៃសុគតិកាមភព អនាគាមិមគ្គ រមែងចេញចាកកាមភព អរហត្តមគ្គ រមែងចេញចាករូបភពនិងអរូបភព អាចារ្យពួកខ្លះពោលថា អរហត្តមគ្គ រមែងចេញចាកភពទាំងពួងដូច្នេះតែម្យ៉ាង ។

ដើម្បីការជាក់ច្បាស់នូវសេចក្តីនេះ គប្បីជ្រាបបាលី ( ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ) ដូចតទៅនេះ ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើត ក្នុងសង្សារ មានទីបំផុតខាងដើម ដែលគេមិនអាចដឹងបាន វៀរលែងតែ កំណើត ៧ ចេញ ធម៌ទាំងនុ៎ះរលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងសោតាបត្តិមគ្គនោះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណដោយសោតា-បត្តិមគ្គញាណ ។ ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើតក្នុងកំណើត ៥ វៀរលែងតែកំណើត ២ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់ រម្ងាប់ក្នុងសកទាគាមិមគ្គនោះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយ សកទាគាមិមគ្គញាណ ។ ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើតក្នុង កាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី វៀរលែងតែកំណើត ១ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ក្នុងអនាគាមិមគ្គនុ៎ះ ព្រោះកិរិយារលត់ អភិសង្ខារវិញ្ញាណដោយអនាគាមិមគ្គញាណ ។ ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើត ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់

ក្នុងអរហត្តមគ្គនុ៎ះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយអរហត្ត-មគ្គញ្ញាណ ។ ព្រះអរហន្ត កាលបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ បញ្ញាផង សតិផង នាម និងរូបផង ធម៌ទាំងនុ៎ះតែងរលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់ រម្ងាប់ក្នុងអរហត្តមគ្គនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណមុនដូច្នេះ ។ វិនិច្ឆ័យក្នុងនិមិត្តមានប្រមាណប៉ុណ្ណេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បដិបទា** និង **អធិបតី** នេះដូចតទៅ

សួរថា បដិបទា ញាប់ញ័រ ឬមិនញាប់ញ័រ ឆ្លើយថា រមែងញាប់ញ័រ ។ មគ្គសូម្បីទាំង ៤ របស់ព្រះតថាគត និងព្រះសារីបុត្តត្ថេរ ជាសុខាបដិបទា-ខិប្បាភិញ្ញា មគ្គដំបូងរបស់ព្រះមហាមោគ្គល្លានត្ថេរ ជាសុខាបដិបទាខិប្បា-ភិញ្ញា តែមគ្គ ៣ ខាងលើរបស់លោក ជាទុក្ខាបដិបទាខិប្បាភិញ្ញា ព្រោះហេតុអ្វី ព្រោះលោកត្រូវសេចក្តីងោកងក់គ្របសង្កត់ ។

បានឮថា ព្រះសម្មាសម្ពុទ្ធ រង់ចាំមើលព្រះថេរៈ ដូចក្មេងតូច អស់ ៧ ថ្ងៃ ។ សូម្បីព្រះថេរៈក្នុងថ្ងៃមួយក៏អង្គុយងោកងក់ គ្រានោះ ទើបព្រះសាស្តាត្រាស់ ( ក្នុងអង្គុត្តរនិកាយ សត្តកនិបាត ) ថា នែមោគ្គល្លាន អ្នកងោកងក់ឬ នែមោគ្គល្លាន អ្នកងោកងក់ឬ ជាដើម ។ បដិបទារបស់សាវកអ្នកសម្រេចនូវមហាអភិញ្ញា សូម្បីមានសភាពបែបនេះ នៅញាប់ញ័រ បដិបទារបស់សាវកដ៏សេសនឹងមិនញាប់ញ័រដូចម្តេច ។ ពិតហើយ **មគ្គ** ៤ របស់ភិក្ខុរូបខ្លះជាទុក្ខាបដិបទាទន្ធាភិញ្ញា រូបខ្លះជាទុក្ខាបដិបទាខិប្បាភិញ្ញា រូបខ្លះ

ជាសុខាបដិបទាទន្ធាភិញ្ញា រូបខ្វះជាសុខាបដិបទាខិប្បាភិញ្ញា ។ សម្រាប់ភិក្ខុរូបខ្វះ មគ្គទី ១ ជាទុក្ខាបដិបទាទន្ធាភិញ្ញា មគ្គទី ២ ជាទុក្ខាបដិបទាខិប្បាភិញ្ញា មគ្គទី ៣ ជាសុខាបដិបទាទន្ធាភិញ្ញា មគ្គទី ៤ ជាសុខាបដិបទាខិប្បាភិញ្ញា ។

មួយទៀត អធិបតីក៏រមែងញាប់ញ័រដូចបដិបទានុ៎ះឯង ពិតហើយ មគ្គទាំង ៤ របស់ភិក្ខុរូបខ្វះ រមែងជាឆន្ទាធិបតេយ្យ របស់រូបខ្វះជាវិរិយាធិបតេយ្យ របស់រូបខ្វះជាចិត្តាធិបតេយ្យ របស់រូបខ្វះជាវីមំសាធិបតេយ្យ ។ ម្យ៉ាងទៀត សម្រាប់ភិក្ខុខ្វះ មគ្គទី ១ ជាឆន្ទាធិបតេយ្យ មគ្គទី ២ ជាវិរិយាធិបតេយ្យ មគ្គទី ៣ ជាចិត្តាធិបតេយ្យ មគ្គទី ៤ ជាវីមំសាធិបតេយ្យ ដូច្នេះឯង ។

## លោកុត្តរកុសលបកិណ្ណកកថា ចប់

# មហាន័យ ២០ ក្នុងបឋមមគ្គ

ឥឡូវនេះ ព្រះយោគាវចរ កាលចម្រើនលោកុត្តរកុសល រមែងចម្រើនឈាន ដោយអត្ថថា ចូលទៅសម្ងឹងតែម្យ៉ាងប៉ុណ្ណោះក៏ទេ តាមពិត រមែងចម្រើនមគ្គ ដោយអត្ថថា នាំចេញ រមែងចម្រើនសតិប្បដ្ឋាន ដោយអត្ថថា ការតាំងមាំ រមែងចម្រើនសម្មប្បធាន ដោយអត្ថថា ការធ្វើសេចក្តីព្យាយាម រមែងចម្រើនឥទ្ធិបាទ ដោយអត្ថថា ការសម្រេច រមែងចម្រើនឥន្ទ្រិយ ដោយអត្ថថា ភាពជាធំ រមែងចម្រើនពល ដោយអត្ថថា មិនញាប់ញ័រ រមែងចម្រើនពោជ្ឈង្គ ដោយអត្ថថា ការត្រាស់ដឹង រមែងចម្រើនសច្ចៈ ដោយអត្ថថា ជាធម៌ពិត រមែងចម្រើនសមថៈ ដោយអត្ថថា ការមិនរាយមាយ រមែងចម្រើនធម៌ ដោយអត្ថថា ភាពជាសុញ្ញតៈ រមែងចម្រើនខន្ធ ដោយអត្ថថា ជាគំនរ រមែងចម្រើនអាយតនៈ ដោយអត្ថថា ជាប្រភពកើត រមែងចម្រើនធាតុ ដោយអត្ថថា ជាសភាវៈសូន្យ និងជានិស្សត្តធម៌ រមែងចម្រើនអាហារ ដោយអត្ថថា ជាបច្ច័យ រមែងចម្រើនផស្សៈ ដោយអត្ថថា ប៉ះខ្ទប់ រមែងចម្រើនវេទនា ដោយអត្ថថា សោយអារម្មណ៍ រមែងចម្រើនសញ្ញា ដោយអត្ថថា សេចក្តីចាំបាន រមែងចម្រើនចេតនា ដោយអត្ថថា ការតាំងចិត្ត រមែងចម្រើនចិត្ត ដោយអត្ថថា ការដឹងច្បាស់ ព្រោះហេតុនោះ ដើម្បីទ្រង់សម្តែងន័យ ១៩ នៃធម៌ទាំងនោះ ទើបត្រាស់ពាក្យជាដើមថា **កតមេ ធម្មា កុសលា** ដូច្នេះទៀត ។

ព្រះអង្គទ្រង់សម្តែងន័យ ២០ ដោយអជ្ឈាស្រ័យរបស់បុគ្គល និងដោយទេសនាវិលាសដោយព្រះតម្រិះថា បុគ្គលរមែងចម្រើនធម៌នេះ រមែងចម្រើន

ធម៌នេះ ដោយប្រការដូច្នេះ ។

ពិតហើយ ក្នុងទេវបរិស័ទដែលអង្គុយស្តាប់ធម៌ ទេវតាទាំងឡាយណា កាលព្រះអង្គត្រាស់ថា **លោកុត្តរជ្ឈាន** ដោយអត្ថថា ចូលទៅសម្ងំដូច្នេះ រមែងត្រាស់ដឹងបាន ព្រះអង្គក៏ត្រាស់ពាក្យថា **ឈាន** ដូច្នេះ ដោយអំណាចនៃសប្បាយ ដល់ទេវតាទាំងឡាយនោះ ។បេ។ ទេវតាទាំងឡាយណា កាលព្រះអង្គត្រាស់ថា ចិត្ត ដោយអត្ថថា ដឹងច្បាស់ ដូច្នេះ រមែងត្រាស់ដឹងបាន ព្រះអង្គក៏ត្រាស់ពាក្យថា **ចិត្ត** ដោយអំណាចសប្បាយដល់ទេវតាទាំងនោះ ។ នេះជាអធ្យាស្រ័យរបស់បុគ្គលក្នុងអធិការនេះ ។

ព្រះសម្មាសម្ពុទ្ធ ព្រោះការដែលព្រះអង្គត្រាស់ដឹងហើយ និងមានពោធិញ្ញាណដ៏ល្អ និងព្រោះទ្រង់ប្រកបដោយទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ បដិសម្ភិទា ៤ និងអសាធារណញ្ញាណ ៦ ទើបទ្រង់កំណត់ទេសនាសម្តែងធម៌តាមគាប់ព្រះហឫទ័យបាន ។ កាលព្រះអង្គទ្រង់ប្រាថ្នា ក៏រមែងសម្តែងថា លោកុត្តរជ្ឈាន ដោយអត្ថថា ចូលទៅសម្ងំ កាលទ្រង់ប្រាថ្នាក៏ទ្រង់សម្តែងថា **លោកុត្តរមគ្គ** ដោយអត្ថថា នាំចេញ ។បេ។ កាលទ្រង់ប្រាថ្នា ក៏ទ្រង់សម្តែងថា **លោកុត្តរចិត្ត** ដោយអត្ថថា ការដឹងច្បាស់ នេះឈ្មោះថា **ទេសនាវិលាស** ។ ក្នុងទេសនាវិលាសនោះ ក្នុងទីដែលត្រាស់ថា **លោកុត្តរជ្ឈាន** ទ្រង់ចែកជា ១០ ន័យ យ៉ាងណា គប្បីជ្រាបន័យទាំងនោះ ក្នុងមគ្គជាដើមក៏យ៉ាងនោះឯង ដោយប្រការដូច្នេះ រមែងជាការដែលទ្រង់ចែកន័យ ២០០ ន័យ ដោយធ្វើឋានៈនីមួយៗ ១០ ន័យក្នុង ២០

ឋាន: ។

ឥឡូវនេះ ដើម្បីទ្រង់សម្ដែងប្រភេទនៃអធិបតី ទើបផ្ដើមពាក្យថា **កតមេ ធម្មា កុសលា** ដូច្នេះជាដើមទៀត ។ បណ្ដាពាក្យ មានពាក្យថា ឈាន ជាដើមនោះ លោកុត្តរជ្ឈានដែលព្រះយោគាវចរធ្វើឆន្ទ: ឲ្យជាធុរ: ឲ្យជាធំ ឲ្យជាប្រធានកើតឡើងហើយ ឈ្មោះថា មាន**ឆន្ទជាអធិបតី** ។ ក្នុងពាក្យដ៏សេស ក៏ន័យនេះដូចគ្នា ។ ព្រះធម្មរាជាទ្រង់សម្ដែងបឋមមគ្គ ចែកដោយពាន់ន័យ គឺក្នុង ( លោកុត្តរជ្ឈាន ) ខាងដើមសុទ្ធៗ ២០០ ន័យ និងក្នុងធម៌ មានឆន្ទាធិបតេយ្យជាដើម នីមួយៗ ២០០ ន័យ ( ២០០ × ៤ = ៨០០ ) ដោយប្រការដូច្នេះ ។

**បឋមមគ្គ ចប់**

# អភិធម្មបិដក

## មគ្គចិត្តដួងទី ២ ជាដើម

[ ២៧១ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីធ្វើកាមរាគ និងព្យាបាទឲ្យស្រាលស្តើង ដើម្បីដល់នូវទុតិយភូមិ ( សកទាគាមិមគ្គ ) បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អញ្ញិន្ទ្រិយ ។បេ។ សេចក្ដីមិនរាយមាយក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

មគ្គទី ២ ចប់

[ ២៧២ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវកាមរាគ និងព្យាបាទឲ្យអស់រលីង ដើម្បីដល់នូវតតិយភូមិ ( អនាគាមិមគ្គ ) បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានសេចក្ដីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អញ្ញិន្ទ្រិយ ។បេ។ សេចក្ដីមិនរាយមាយក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

មគ្គទី ៣ ចប់

[ ២៧៣ ] ពួកធម៌ជាកុសល តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវកាមរាគ អរូបរាគ មានះ ឧទ្ធច្ចៈ និងអវិជ្ជាឲ្យអស់រលីង ដើម្បីដល់នូវភូមិទី ៤ ( អរហត្តមគ្គ ) បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានសេចក្តីត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អញ្ញិន្ទ្រិយ ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាកុសល ។បេ។

[ ២៧៤ ] អញ្ញិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតដូចជាផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល គ្រឿងសស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្លុះ គឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ ដែលបុគ្គលដឹង ឃើញ ដល់ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ហើយណា នេះអញ្ញិន្ទ្រិយ កើតមានក្នុង

សម័យនោះ ។បេ។ សេចក្តីមិនរាយមាយ កើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងដោយអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

## មគ្គទី ៤ ចប់

## លោកុត្តរចិត្ត ចប់

# អដ្ឋកថា

## មគ្គចិត្តដួងទី ២ ជាដើម

[ ២៧១-២៧៤ ] ឥឡូវនេះ ដើម្បីទ្រង់សម្ដែងមគ្គទីពីរជាដើម ទើបផ្ដើមបទថា **កតមេ ធម្មា កុសលា** ដូច្នេះទៀត ។

បណ្ដាបទទាំងនោះ បទថា **កាមរាគព្យាបាទានំ តនុភាវាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើកិលេសទាំងនោះឲ្យស្រាលស្ដើង ។ ពាក្យនោះ គប្បីជ្រាបការធ្វើឲ្យស្រាលស្ដើងដោយហេតុ ២ យ៉ាង គឺការកើតឡើងក្នុងកាលខ្លះ និងការរួបរឹតដ៏ទន់ខ្សោយ ។

ពិតហើយ កិលេសទាំងឡាយ រមែងមិនកើតឡើងរឿយៗ ដល់ព្រះសកទាគាមី ដូចកើតឡើងដល់មហាជនដែលត្រាច់រង្គាត់ទៅក្នុងវដ្ដៈ រមែងកើតឡើងក្នុងកាលខ្លះ កាលកើតឡើង ក៏ជាការដែលកើតឡើងស្រាលៗ ដូចពន្លកពូជក្នុងស្រែដែលគេព្រោះស្ដើងៗ កាលកើតឡើងក៏ផ្សាយទៅ បិទបាំងស្រាលៗ មិនកើតឡើងធ្វើការងងឹត ដូចកើតឡើងដោយមហាជនដែលត្រាច់ទៅក្នុងវដ្ដៈ ។ ព្រោះត្រូវមគ្គទាំងពីរប្រហារហើយ ទើបកើតឡើងស្រាលៗ រមែងកើតឡើងជាសភាវៈស្រាលៗ ដូចពពកស្ដើងៗ និងដូចស្លាបរុយ ។

ក្នុងសេចក្ដីនេះ ព្រះថេរៈពួកខ្លះពោលថា កិលេសកើតឡើង ដល់ព្រះសកទាគាមីយូរៗម្ដងក៏ពិត ទោះបីជាដូច្នោះ ក៏ជាកិលេសក្រាស់នោះឯងកើតឡើង ព្រោះថា ព្រះសកទាគាមីនោះនៅមានបុត្ត និងធីតាប្រាកដនៅឡើយ ។ តែសេចក្ដីនេះ មិនជាប្រមាណ ព្រោះថា បុត្ត និងធីតារមែងមានដោយហេតុត្រឹមតែការស្ទាបអង្អែលអវយវៈតូចធំក៏មាន តែភាពដែលកិលេសទាំងឡាយ

នៅក្រាស់មិនមាន ព្រោះកិលេសទាំងឡាយ លោកលះដោយមគ្គទាំងពីរហើយ ព្រោះហេតុនោះ គប្បីជ្រាបភាពស្រាលស្តើងនៃកិលេសទាំងឡាយរបស់ព្រះសកទាគាមីនោះ ដោយហេតុ ២ គឺដោយការកើតឡើងក្នុងគ្រាខ្លះ និងដោយការរួបរឹតដ៏ទន់ខ្សោយ ។

បទថា **ទុតិយាយ** បានដល់ ទី ២ ដោយអំណាចនៃការរាប់ខ្លះ ដោយអំណាចនៃការកើតឡើងគ្រាទី ២ ខ្លះ ។ បទថា **ភូមិយា បត្តិយា** បានដល់ ដើម្បីប្រយោជន៍ដល់ការបានសាមញ្ញផល ។ សូម្បីក្នុងពាក្យថា ដើម្បីដល់នូវភូមិទី ៣ ទី ៤ ក៏ន័យនេះឯង ។ ខ្ញុំនឹងពោលតែចំពោះសេចក្តីដែលផ្សេងគ្នាប៉ុណ្ណោះ ។

បទថា **អញ្ញិន្ទ្រិយំ** បានដល់ ឥន្ទ្រិយដែលដឹងទូទៅ មានអធិប្បាយថា ឥន្ទ្រិយដែលដឹងសច្ចធម៌ទាំង ៤ នោះឯង ដែលសកទាគាមិមគ្គនោះដឹងហើយ មិនលើសព្រំដែន ដែលបឋមមគ្គដឹង ។ សូម្បីក្នុងនិទ្ទេសវារៈនៃអញ្ញិន្ទ្រិយនោះ ក៏គប្បីជ្រាបសេចក្តីដោយន័យនេះ ។ ក្នុងកោដ្ឋាសវារៈ រួមជាមួយនឹងឥន្ទ្រិយនេះ ក៏ជាឥន្ទ្រិយ ៩ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននុ៎ះឯង ។

ក្នុងមគ្គចិត្តជួនទី ៣ បទថា **អនវសេសប្បហានាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការលះបង់សំយោជនៈទាំងនោះឯង ដែលស្រាលស្តើងហើយ ដោយអំណាចសកទាគាមិមគ្គ មិនឲ្យសេសសល់ ។

ក្នុងមគ្គចិត្តជួនទី ៤ បទថា **រូបរាគអរូបរាគមានឧទ្ធច្ចអវិជ្ជាយ**

**ឆវសេសប្បហានាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការលះបង់ឧទ្ធម្ភាគិយសំយោជនៈទាំង ៥ នោះ មិនឲ្យសេសសល់ ។ បណ្តាឧទ្ធម្ភាគិយសំយោជនៈទាំងនោះ បទថា **រូបរាគោ** បានដល់ សេចក្តីតម្រេកដោយអំណាចសេចក្តីពេញចិត្ត ក្នុងរូបភព ។ បទថា **អរូបរាគោ** បានដល់ សេចក្តីត្រេកអរ ដោយអំណាចនៃសេចក្តីពេញចិត្តក្នុងអរូបភព ។ បទថា **មានោ** បានដល់ មានះដែលអរហត្តមគ្គគប្បីសម្លាប់នុ៎ះឯង ។ ឧទ្ធច្ចៈ និង អវិជ្ជា ដែលអរហត្តមគ្គគប្បីសម្លាប់ក៏ដូចគ្នា ។ ក៏ក្នុងមគ្គចិត្តទាំង ២ ( ទី ៣ ទី ៤ ) នេះ ជាឥន្ទ្រិយទី ៩ ក៏គឺអញ្ញិន្ទ្រិយនោះឯង ។

# ន័យមួយពាន់ក្នុងមគ្គចិត្ត ៤ ដួង

ក្នុងមគ្គទាំងអស់ មានបទ ៦០[១] ដោយលំដាប់ រួមជាមួយនឹងអង្គអបណ្ណក ( ពិតប្រាកដ ) ៤ ជា ៦៤ បទ ។ តែពោលដោយបទដែលមិនលាយឡំគ្នា មាន ៣៣ បទ កោដ្ឋាសវារៈ និងសុញ្ញតវារៈជារបស់មានតាមប្រក្រតីនុ៎ះឯង ។ ព្រះធម្មរាជាទ្រង់ចែកមគ្គទាំង ៤ សម្តែង ៤០០០ ន័យ គឺក្នុងមគ្គចិត្តដួងទី ២ ជាដើម ក៏ជាមួយពាន់ន័យដូចបឋមមគ្គនុ៎ះឯង ។

ក្នុងសច្ចវិភង្គ ព្រះអង្គទ្រង់តាំងលោកុត្តរ ៦ ម៉ឺនន័យ ដោយអំណាចនៃមគ្គទាំងនុ៎ះឯង ក្នុងសតិប្បដ្ឋានវិភង្គ ទ្រង់តាំងលោកុត្តរ ២ ម៉ឺនន័យ ក្នុងសម្មប្បធានវិភង្គ ២ ម៉ឺនន័យ ក្នុងឥទ្ធិបាទវិភង្គ ៣ ម៉ឺន ២ ពាន់ន័យ ក្នុងពោជ្ឈង្គវិភង្គ ៣ ម៉ឺន ២ ពាន់ន័យ ក្នុងមគ្គវិភង្គ ២ ម៉ឺន ៨ ពាន់ន័យ ដោយអំណាចនៃមគ្គចិត្តទាំងនោះឯង ។

តែក្នុងទីនេះ ក្នុងមគ្គចិត្តទាំង ៤ ដួង ទ្រង់តាំងលោកុត្តរ ៤ ពាន់ន័យ ។ បណ្តាមគ្គចិត្តទាំងនោះ ក្នុងមគ្គចិត្តដួងទីមួយ ដែលប្រកបដោយបឋមជ្ឈាន ទ្រង់ចែកអង្គ ៨ ក្នុងទុតិយមគ្គជាដើមក៏ដូចគ្នា ។ បណ្តាអង្គមគ្គទាំងនោះ សម្មាទិដ្ឋិក្នុងមគ្គទីមួយ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថាលះមិច្ឆាទិដ្ឋិ ។ មគ្គទាំងឡាយ មានសម្មាសង្កប្បៈជាដើម ក៏គប្បីជ្រាបដោយអត្ថថា លះមិច្ឆាសង្កប្បៈជាដើមនុ៎ះឯង ។

សួរថា កាលបើដូច្នេះ ឈ្មោះថា **ទិដ្ឋិ** ដែលមគ្គខាងលើ ៣ គប្បីលះក៏មិនមាន ព្រោះទិដ្ឋិ ៦២ ដែលមគ្គទីមួយនោះឯងលះបានហើយ ឈ្មោះថា

១- រាប់តាំងអំពីផស្សៈ រហូតដល់អវិក្ខេប ( អ្នកប្រែ ) ។

**សម្មាទិដ្ឋិ** ក្នុងមគ្គខាងលើ ៣ នោះ នឹងមានបានដូចម្ដេច ។ ឆ្លើយថា ពិសពស់មានក្ដី មិនមានក្ដី ពស់ លោកក៏ហៅថា ពស់ពិសទុំះឯង យ៉ាងណា មិច្ឆាទិដ្ឋិមានក្ដី មិនមានក្ដី **សម្មាទិដ្ឋិ** នេះក៏ឈ្មោះថា **សម្មាទិដ្ឋិ** យ៉ាងនោះដូចគ្នា ។

មានពាក្យពោលថា កាលបើយ៉ាងនេះ សម្មាទិដ្ឋិនោះ ក៏ត្រឹមតែជាឈ្មោះប៉ុណ្ណោះ តែសម្មាទិដ្ឋិក្នុងមគ្គ ៣ ខាងលើ មិនមានកិច្ច អង្គមគ្គមិនបរិបូណ៌ ព្រោះហេតុនោះ ទើបសម្មាទិដ្ឋិគួរមានកិច្ចដែលត្រូវធ្វើ ទើបអង្គមគ្គបរិបូណ៌ ។ មានពាក្យអធិប្បាយថា សម្មាទិដ្ឋិមានកិច្ចក្នុងមគ្គ ៣ ខាងលើនេះ គប្បីសម្ដែងដោយកំណត់តាមដែលបាន ។ ការពិត នៅមានមានះមួយទៀតដែលមគ្គ ៣ ខាងលើ គប្បីសម្លាប់ មានះ នោះរមែងតាំងនៅក្នុងឋានៈនៃទិដ្ឋិ សម្មាទិដ្ឋិនោះ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា លះមានះនោះ ។ សម្មា-ទិដ្ឋិក្នុងសោតាបត្តិមគ្គ រមែងលះមិច្ឆាទិដ្ឋិ ។ តែមានះដែលសកទាគាមិមគ្គគប្បីសម្លាប់ មានដល់ព្រះសោតាបន្ន សម្មាទិដ្ឋិរបស់ព្រះសកទាគាមីនោះឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា រមែងលះមានះនោះ ។ សង្កប្បៈដែលកើតឡើងព្រមជាមួយនឹងអកុសលចិត្ត ៧ ដួង ក៏នៅមានដល់ព្រះសោតា-បន្ននោះឯង ការកម្រើកអង្គនៃវាចា ក៏មានដោយអកុសលចិត្តទាំងនោះឯង ការកម្រើកអង្គនៃកាយ ក៏មានដោយអកុសលចិត្តទាំងនោះឯង ការបរិភោគបច្ច័យក៏មាន សេចក្ដីព្យាយាមដែលកើតព្រមគ្នាក៏មាន ការមិនមានសតិក៏មាន ឯកគ្គតានៃចិត្តដែលកើតព្រមគ្នាក៏មាន ទាំងអស់នេះ ឈ្មោះថា មិច្ឆា-

សង្កប្បៈជាដើម ។ សង្កប្បៈជាដើម ក្នុងសកទាគាមិមគ្គ គប្បីជ្រាបថា សម្មាសង្កប្បៈជាដើម ព្រោះលះមិច្ឆាសង្កប្បៈទាំងនោះជាដើម ។ អដ្ឋមគ្គ ៨ ក្នុងសកទាគាមិមគ្គមកធ្វើកិច្ចរបស់ខ្លួន ដោយប្រការដូច្នេះ ។

មានះរបស់ព្រះសកទាគាមី ដែលគប្បីសម្លាប់ដោយអនាគាមិមគ្គនៅមាន មានះនោះ រមែងតាំងនៅក្នុងឋានៈនៃទិដ្ឋិ សង្កប្បៈជាដើម ដែលកើតព្រមជាមួយនឹងអកុសលចិត្ត ៧ ដួង ក៏នៅមានដល់ព្រះសកទាគាមីនោះឯង គប្បីជ្រាបភាពនៃអដ្ឋមគ្គ ៨ ក្នុងអនាគាមិមគ្គធ្វើកិច្ចរបស់ខ្លួនដោយការលះមិច្ឆា-សង្កប្បៈជាដើមទាំងនោះ ។ មានះរបស់ព្រះអនាគាមីដែលគប្បីសម្លាប់ដោយអរហត្តមគ្គមាន មានះ នោះរមែងតាំងនៅក្នុងឋានៈនៃទិដ្ឋិ ។ មួយទៀត អកុ-សលចិត្តទាំងឡាយណា ៥ ដួង មានដល់ព្រះអនាគាមីនោះ មិច្ឆាសង្កប្បៈជាដើម ដែលកើតរួមគ្នាជាមួយនឹងអកុសលចិត្តទាំងនោះនៅមាន គប្បីជ្រាបភាពដែលអដ្ឋមគ្គ ៨ ក្នុងអរហត្តមគ្គ ធ្វើកិច្ចរបស់ខ្លួន ដោយការលះមិច្ឆាសង្កប្បៈជាដើមទាំងនោះ ។

សួរថា បណ្តាមគ្គទាំង ៤ នេះ បឋមមគ្គឃើញសច្ចៈទាំង ៤ មគ្គ ៣ ខាងលើ រមែងឃើញសច្ចៈដែលបឋមមគ្គឃើញហើយនុ៎ះឯង ឬរមែងឃើញសច្ចៈដែលបឋមមគ្គមិនឃើញហើយ ឆ្លើយថា ពាក្យនេះថា មគ្គ ៣ ខាងលើ រមែងឃើញសច្ចៈដែលបឋមមគ្គឃើញហើយនុ៎ះឯង ដូច្នេះ ជាពាក្យដែលពួកអាចារ្យឃើញស្មើគ្នា ។ តែអាចារ្យវិតណ្ឌវាទី ពោលថា មគ្គ ៣ ខាងលើ រមែងឃើញសច្ចៈដែលបឋមមគ្គមិនបានឃើញ ។ គប្បីពោលនឹង

អាចារ្យវិតណ្ឌវាទីនោះថា ព្រះមានព្រះភាគ ទ្រង់ចែកឥន្ទ្រិយណា ក្នុងបឋមមគ្គ កាលអាចារ្យវិតណ្ឌវាទីដឹង ក៏នឹងពោលថា អនញ្ញាតញ្ញស្សាមី-តិន្ទ្រិយ ដូច្នេះ សូម្បីត្រូវសួរថា ព្រះមានព្រះភាគ ទ្រង់ចែកឥន្ទ្រិយណា ក្នុងមគ្គខាងលើ ដូច្នេះ ក៏នឹងពោលថា អញ្ញិន្ទ្រិយ ។ គប្បីពោលនឹងអាចារ្យវិតណ្ឌវាទីទៀតថា កាលការឃើញសច្ចៈ ដែលបឋមមគ្គមិនឃើញមាន ក៏ចូរចែកអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ សូម្បីក្នុងមគ្គខាងលើ កាលបើយ៉ាងនេះ បញ្ហារបស់លោក ក៏នឹងសមគ្នា ។ អាចារ្យវិតណ្ឌវាទីសួរថា មគ្គដទៃ រមែងលះកិលេសដទៃៗ ឬរមែងលះកិលេសដែលលះបានហើយនោះឯង គប្បីឆ្លើយនឹងលោកថា មគ្គមួយរមែងលះកិលេសដទៃៗ ។ អាចារ្យវិតណ្ឌវាទីពោលថា បើមគ្គដទៃ រមែងលះកិលេសដទៃៗ គឺដែលមិនទាន់លះបានសោតមគ្គ ៣ ខាងលើ រមែងឃើញសច្ចៈទាំងឡាយ ដែលបឋមមគ្គមិនទាន់បានឃើញនុ៎ះឯង ។ បុគ្គលដែលពោលយ៉ាងនេះ សកវាទីគួរសួរពាក្យនេះថា ឈ្មោះថា សច្ចៈទាំងឡាយ មានប៉ុន្មាន អាចារ្យវិតណ្ឌវាទីកាលដឹង ក៏នឹងឆ្លើយថា មាន ៤ គប្បីសួរលោកថា ក្នុងវាទៈរបស់លោក សច្ចៈប្រាកដដល់ទៅ ១៦ យ៉ាង លោករមែងឃើញសច្ចៈសូម្បីព្រះពុទ្ធមិនទ្រង់ឃើញហើយ លោកឈ្មោះថា ជាអ្នកមានសច្ចៈច្រើន លោកកុំកាន់យកយ៉ាងនេះឡើយ ការឃើញសច្ចៈដែលមិនធ្លាប់ឃើញ រមែងមិនមាន តែមគ្គ រមែងលះកិលេសទាំងឡាយ ដែលនៅមិនទាន់បានលះ ដូច្នេះ ។

ក្នុងសេចក្តីថា ការឃើញសច្ចៈដែលមិនធ្លាប់ឃើញមកអំពីមុន មិនមាន

ក្នុងអធិការនៃមគ្គនោះ លោកកាន់យកការប្រៀបធៀប ដោយហិបរតនៈ ដូចតទៅ

បានឮថា បុរសម្នាក់ដាក់ហិបរតនៈ ៤ ក្នុងបន្ទប់ដែលជាទីរក្សារតនៈ ដ៏ខ្ពង់ខ្ពស់ បុរសនោះ មានធុរៈកើតឡើងក្នុងហិប ក្នុងវេលាយប់ ទើបបើកទ្វារ អុចប្រទីបឲ្យភ្លឺ កាលងងឹតត្រូវប្រទីបកម្ចាត់ហើយ ហិបទាំងឡាយក៏ប្រាកដ បុរសនោះ ធ្វើធុរៈក្នុងហិបនោះហើយបិទទ្វារចេញទៅ ងងឹតក៏នៅបិទបាំងដូចដើម សូម្បីក្នុងគ្រាទី ២ ក្នុងគ្រាទី ៣ ក៏បានធ្វើយ៉ាងនោះ ក្នុងគ្រាទី ៤ កាលបុរសនោះពិសោធមើលថា កាលបើកទ្វារហើយហិបរតនៈនឹងប្រាកដក្នុងទីងងឹត ឬមិនប្រាកដនុ៎ះឯង ព្រះអាទិត្យក៏រះឡើង កាលងងឹតត្រូវពន្លឺព្រះអាទិត្យកម្ចាត់ហើយ បុរសនោះ ក៏ធ្វើធុរៈក្នុងហិបទាំងឡាយ ស្រេចហើយចេញទៅ ។

បណ្តាពាក្យទាំងនោះ សច្ចៈ ៤ ប្រៀបដូចហិបរតនៈ ៤ ។ វេលាដែលវិបស្សនា ឆ្ពោះមុខទៅកាន់សោតាបត្តិមគ្គ ប្រៀបដូចវេលាដែលបុរសនោះមានធុរៈកើតឡើងក្នុងហិបរតនៈហើយបើកទ្វារ ងងឹតដែលបិទបាំងសច្ចៈប្រៀបដូចងងឹតរបស់រាត្រី ពន្លឺនៃសោតាបត្តិមគ្គប្រៀបដូចពន្លឺនៃប្រទីប ការដែលសច្ចៈទាំងឡាយប្រាកដដល់មគ្គញាណ ប្រៀបដូចការដែលហិបរតនៈទាំងឡាយប្រាកដដល់បុរសនោះ ព្រោះងងឹតត្រូវកម្ចាត់ទៅ ។ សច្ចៈទាំងឡាយដែលប្រាកដដល់មគ្គញាណ រមែងប្រាកដដល់បុគ្គល អ្នកដល់ព្រមដោយមគ្គនុ៎ះឯង ។ វេលាដែលសោតាបត្តិមគ្គ លះបង់កិលេសដែលខ្ទង់គួរ

លះបង់ហើយរលត់ទៅ ប្រៀបដូចវេលាដែលបុរសនោះធ្វើធុរៈក្នុងហិបរតនៈទាំងឡាយហើយទៅ ផងឹតដែលបិទបាំងសច្ចៈ ដែលគប្បីសម្លាប់ដោយមគ្គ ៣ ខាងលើ ប្រៀបដូចផងឹតដែលគ្របសង្កត់តទៅ ។

វេលាដែលវិបស្សនា ឆ្ពោះមុខទៅកាន់សកទាគាមិមគ្គ ប្រៀបដូចវេលាដែលបុរសនោះបើកទ្វារក្នុងគ្រាទីពីរ ពន្លឺនៃសកទាគាមិមគ្គ ប្រៀបដូចពន្លឺនៃប្រទីប វេលាដែលសកទាគាមិមគ្គ លះបង់កិលេសដែលខ្លួនគប្បីលះបង់ហើយរលត់ទៅ ប្រៀបដូចវេលាដែលបុរសនោះ ធ្វើធុរៈក្នុងហិបរតនៈទាំងឡាយស្រេចហើយទៅ ផងឹតដែលបិទបាំងសច្ចៈដែលមគ្គពីរខាងលើ គប្បីសម្លាប់ ប្រៀបដូចផងឹតដែលគ្របសង្កត់តទៅ ។

វេលាដែលវិបស្សនាឆ្ពោះមុខទៅកាន់អនាគាមិមគ្គ ប្រៀបដូចវេលាដែលបុរសនោះ បើកទ្វារក្នុងគ្រាទីបី ។ ពន្លឺនៃអនាគាមិមគ្គ ប្រៀបដូចពន្លឺនៃប្រទីប ។ វេលាដែលអនាគាមិមគ្គលះកិលេសដែលខ្លួនគប្បីលះ ហើយរលត់ទៅ ប្រៀបដូចបុរសធ្វើធុរៈក្នុងហិបទាំងឡាយស្រេចហើយទៅ ។ ផងឹតដែលបិទបាំងសច្ចៈ ដែលអរហត្តមគ្គខាងលើគប្បីសម្លាប់ ប្រៀបដូចផងឹតគ្របសង្កត់ទៀត ។

វេលាដែលវិបស្សនាឆ្ពោះមុខទៅកាន់អរហត្តមគ្គ ប្រៀបដូចវេលាដែលបុរសបើកទ្វារក្នុងគ្រាទី ៤ ។ ការកើតឡើងនៃអរហត្តមគ្គ ប្រៀបដូចការរះឡើងនៃព្រះអាទិត្យ ។ ការកម្ចាត់ផងឹត ដែលបិទបាំងសច្ចៈនៃអរហត្តមគ្គ ប្រៀបដូចការកម្ចាត់ផងឹត ។ ការដែលសច្ចៈទាំង ៤ ប្រាកដដល់អរហត្ត-

មគ្គញ្ញាណ ប្រៀបដូចការដែលហិបរតនៈទាំងឡាយ ប្រាកដដល់បុរសនោះ ព្រោះងងឹតត្រូវកម្ចាត់ទៅ សច្ចៈទាំងឡាយ ដែលប្រាកដដល់ញាណ ប្រៀបដូចហិបរតនៈដែលប្រាកដដល់បុគ្គល ការដែលអរហត្តមគ្គ ញុំាងកិលេសទាំងអស់ឲ្យអស់ទៅ ប្រៀបដូចវេលាដែលបុរស ផ្ញើធុរៈក្នុងហិបរតនៈទាំងឡាយស្រេចហើយទៅ ។ ការមិនមានងងឹតបិទបាំងសច្ចៈទៀត ចាប់ផ្តើមអំពីវេលាដែលកើតឡើងនៃអរហត្តមគ្គ ប្រៀបដូចវេលាដែលពន្លឺនុ៎ះឯងប្រព្រឹត្តទៅចាប់ផ្តើមអំពីការរះឡើងនៃព្រះអាទិត្យ ដូច្នោះ ។ នេះជាពាក្យឧបមាក្នុងការមិនមានការឃើញសច្ចៈដែលមិនទាន់ធ្លាប់ឃើញ ត្រឹមតែប៉ុណ្ណោះ ។

ក្នុងសេចក្តីនេះថា មគ្គ ៣ ខាងលើ រមែងឃើញសច្ចៈដែលបឋមមគ្គឃើញហើយនុ៎ះឯង ប៉ុន្តែ មគ្គយ៉ាងដទៃ រមែងលះកិលេសដទៃៗ ដូច្នេះ លោកកាន់យកឧបមាដោយទឹកក្បុងដូចតទៅនេះ

បុរសម្នាក់បានប្រគល់សំពត់ដ៏ស្មោកគ្រោក ដល់ជាងជ្រលក់ ជាងជ្រលក់ក៏ត្រាំក្នុងទឹកក្បុង ៣ ប្រភេទ គឺទឹកក្បុងអំបិល ទឹកក្បុងផេះ ទឹកក្បុងអាចម៍គោ ជាងជ្រលក់ដឹងថា ទឹកក្បុងកាត់វត្ថុដែលស្មោកគ្រោក ហើយក៏ចាក់ទឹកចោល បោកជម្រះមន្ទិលគ្រោតគ្រាត បន្ទាប់មក ជាងជ្រលក់ក៏ដឹងថា សំពត់នៅមិនទាន់ស្អាត លើកទីពីរ ទើបត្រាំក្នុងទឹកក្បុងយ៉ាងនោះឯង ហើយចាក់ទឹកចោល បោកគក់លាងមន្ទិលដែលល្អិតជាងនោះ បន្ទាប់មក ជាងជ្រលក់ក៏ដឹងថា នៅមិនទាន់ស្អាត លើកទីបី ទើបត្រាំនៅក្នុងទឹកក្បុងយ៉ាងនោះឯង ចាក់ទឹកចោលហើយ បោកគក់លាងមន្ទិលដែលល្អិតជាងនោះ បន្ទាប់

មក ក៏ដឹងថា សំពត់នៅមិនទាន់ស្អាត លើកទីបួន ទើបត្រាំក្នុងទឹកក្បុងទាំងនោះ ចាក់ទឹកចោលហើយ បោកគក់ លាងមន្ទិលមិនឲ្យមានសេសសល់ សូម្បីប្រព្រឹត្តទៅក្នុងសរសៃអំបោះហើយ ទើបប្រគល់ឲ្យដល់ម្ចាស់របស់ ម្ចាស់របស់ក៏បត់ដាក់ក្នុងហិប អប់ក្លិន រមែងស្លៀកដណ្តប់ក្នុងវេលាដែលខ្លួនប្រាថ្នាហើយ ។

បណ្តាពាក្យទាំងនោះ ចិត្តដែលប្រព្រឹត្តទៅតាមកិលេសប្រៀបដូចសំពត់ដែលស្មោកគ្រោក វេលាដែលញ៉ាំងការងារ ឲ្យប្រព្រឹត្តទៅក្នុងអនុបស្សនា ៣ ប្រៀបដូចការត្រាំដោយទឹកក្បុង ៣ ប្រភេទ ការញ៉ាំងកិលេស ៥ យ៉ាងឲ្យអស់ទៅដោយសោតាបត្តិមគ្គ ប្រៀបដូចការចាក់ទឹកចោលហើយ បោកគក់លាងមន្ទិលគ្រោតគ្រាត ការដឹងថា ចិត្តនោះនៅមិនទាន់បរិសុទ្ធល្អ ហើយញ៉ាំងការងារឲ្យប្រព្រឹត្តទៅក្នុងអនុបស្សនាទាំង ៣ នោះឯង ប្រៀបដូចការត្រាំទឹកក្បុងទាំងនោះ សូម្បីលើកទី ២ បន្ទាប់អំពីនោះ ការញ៉ាំងសំយោជនៈយ៉ាងគ្រោតគ្រាត ២ យ៉ាង ឲ្យអស់ទៅដោយសកទាគាមិមគ្គ ប្រៀបដូចការបោកគក់លាងមន្ទិលដែលល្អិតជាងនោះ ។ ការដឹងថា ចិត្តនេះបរិសុទ្ធមិនគ្រប់គ្រាន់ ហើយញ៉ាំងការងារឲ្យប្រព្រឹត្តទៅក្នុងអនុបស្សនាទាំង ៣ នោះឯង ប្រៀបដូចជាងជ្រលក់គិតថា សំពត់នេះស្អាតមិនគ្រប់គ្រាន់ ហើយទើបដាក់ទឹកក្បុង ៣ យ៉ាង ឲ្យកាត់ទៀត បន្ទាប់អំពីនោះ ការញ៉ាំងសំយោជនៈដ៏ល្អិត ២ យ៉ាង ឲ្យអស់ទៅដោយអនាគាមិមគ្គ ប្រៀបដូចការបោកគក់លាងមន្ទិលសំពត់ដែលល្អិតជាងនោះ ការដឹងថា ចិត្តនេះស្អាតនៅមិនទាន់

គ្រប់គ្រាន់ ហើយញ៉ាំងការងារឲ្យប្រព្រឹត្តទៅក្នុងអនុបស្សនាទាំង ៣ នោះឯង ប្រៀបដូចជាងជ្រលក់ដឹងថា សំពត់នេះនៅស្អាតមិនគ្រប់គ្រាន់ ទើបដាក់ត្រាំក្នុងទឹកក្បុង ៣ យ៉ាងទៀត បន្ទាប់អំពីនោះ ការដែលចិត្តរបស់ព្រះខីណាស្រពបរិសុទ្ធ ព្រោះកិលេស ៨ យ៉ាង ដែលអរហត្តមគ្គឲ្យអស់ទៅហើយ សម្រាំនៅដោយវិហារធម៌ គឺផលសមាបត្តិក្នុងខណៈដែលប្រាថ្នាហើយ ប្រៀបដូចការស្លៀកដណ្តប់សំពត់ដែលបរិសុទ្ធ ព្រោះបោកគក់ ជម្រះមន្ទិលដែលនៅក្នុងសរសៃអំបោះចេញទៅ ដោយការបោកគក់ដែលដូចគ្នានឹងផែនប្រាក់ដែលរក្សាទុកក្នុងប្រអប់អប់ក្លិន ក្នុងខណៈដែលខ្លួនប្រាថ្នាហើយ នេះជាការឧបមាក្នុងសេចក្តីថា មគ្គយ៉ាងដទៃ រមែងលះបង់កិលេសយ៉ាងដទៃ ដូច្នេះ ។

សេចក្តីនេះ សមដូចពាក្យដែលព្រះខេមកៈពោល ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា អាវុសោ ដូចសំពត់ដ៏សៅហ្មង ប្រឡាក់ក្អែល ពួកជនជាម្ចាស់យកសំពត់នោះទៅប្រគល់ឲ្យជាងជ្រលក់ ជាងជ្រលក់ ក៏ប្របាច់ប្របល់សំពត់នោះក្នុងទឹកប្រែក្តី ក្នុងទឹកក្បុងក្តី ក្នុងគោម័យក្តី ហើយយកទៅគក់ក្នុងទឹកដ៏ថ្លា សំពត់នោះត្រឡប់ជាសំពត់ស្អាត ផូរផង់ ក៏មែនពិតហើយ តែថា សំពត់នោះ គង់មានក្លិនទឹកប្រែ ក្លិនទឹកក្បុង ក្លិនទឹកគោម័យដែលជ្រួតជ្រាប មិនទាន់បាត់នៅឡើយ លុះតែជាងជ្រលក់ ឲ្យសំពត់នោះដល់ពួកជនជាម្ចាស់ ពួកជនជាម្ចាស់ក៏ដាក់សំពត់នោះក្នុងទូ ដែលអប់ដោយក្លិន ឯក្លិនទឹកប្រែក្តី ក្លិនទឹកក្បុងក្តី ក្លិនទឹកគោម័យក្តីដែលជ្រួតជ្រាបនៅ ក៏ហើរបាត់អស់ទៅ យ៉ាងណាមិញ ។ អាវុសោ ពួកឱរម្ភាគិយ-

សំយោជនៈ ៥ ប្រការដែលអរិយសាវកលះបង់បាន ក៏មែនពិតហើយ តែថា មានះថាជាអញ ឆន្ទៈថាជាអញ អនុស័យថាជាអញ ជាកិលេសយ៉ាងល្អិត នៅក្នុងឧបាទានក្ខន្ធទាំង ៥ ក៏លោកគាស់រម្លើងមិនទាន់បាននៅឡើយ លុះសម័យខាងក្រោយមក លោកពិចារណាឃើញនូវសេចក្ដីកើត និងសេចក្ដីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា ដូច្នេះជារូប ដូច្នេះជាហេតុឲ្យកើតរូប ដូច្នេះជាសេចក្ដីរលត់រូប ។ ដូច្នេះជាវេទនា ។ ដូច្នេះជាសញ្ញា ។ ដូច្នេះជាសង្ខារទាំងឡាយ ។ ដូច្នេះជាវិញ្ញាណ ដូច្នេះជាហេតុឲ្យកើតវិញ្ញាណ ដូច្នេះជាសេចក្ដីរលត់វិញ្ញាណ ។ កាលបើលោកពិចារណាឃើញនូវសេចក្ដីកើត និងសេចក្ដីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ហើយ មានះថាជាអញ ឆន្ទៈថាជាអញ អនុស័យថាជាអញ ជាកិលេសយ៉ាងល្អិត ក្នុងឧបាទានក្ខន្ធទាំង ៥ ដែលលោកគាស់រម្លើងមិនទាន់បាននៅឡើយ ក៏ដល់នូវកិរិយាគាស់រម្លើងឡើងបានយ៉ាងនោះឯង ដូច្នេះ ។

បណ្ដាមគ្គទាំងនោះ សោតាបត្តិមគ្គ រមែងលះអកុសលចិត្ត ៥ ដួង ព្រមជាមួយនឹងបាបធម៌ដែលកើតឡើងដោយអំណាចអង្គនៃចិត្ត សកទាគាមិមគ្គ រមែងធ្វើចិត្តដែលសហគតៈដោយទោមនស្ស ២ ដួង ឲ្យជាសភាវៈស្រាលស្តើង មួយអន្លើដោយបាបធម៌ដែលកើតឡើងដោយអំណាចអង្គនៃចិត្ត អនាគាមិមគ្គ រមែងលះចិត្ត ២ ដួងនោះឯង មួយអន្លើដោយសម្បយុត្តធម៌ អរហត្តមគ្គ រមែងលះអកុសលចិត្ត ៥ ដួង មួយអន្លើដោយបាបធម៌ ដែលកើតឡើងដោយអំណាចអង្គនៃចិត្ត ។ ចាប់ផ្ដើមអំពីកាលដែលអកុសលចិត្តទាំង

១២ ដូងនេះ ដែលមគ្គលះបានហើយ ឈ្មោះថា កិលេសដែលជាប់តាមទៅខាងក្រោយទៀត ដោយអំណាចអន្តនៃចិត្ត រមែងមិនមានដល់ព្រះខីណាស្រព ។

ក្នុងសេចក្ដីនោះ មានឧបមាដូចតទៅ បានឮថា ព្រះរាជាជាធំមួយព្រះអង្គ ព្រះរាជទានអារក្ខាបច្ចន្តជនបទ ហើយសោយភាពជាឥស្សរិយយសក្នុងមហានគរ ខាងក្រោយ បច្ចន្តជនបទរបស់ព្រះអង្គកើតចលាចល សម័យនោះ មានពួកមេចោរ ១២ នាក់ ព្រមទាំងបុរសច្រើនពាន់ នាំគ្នាទៅប្លន់ដែនមហាអមាត្យអ្នកនៅក្នុងបច្ចន្តជនបទ បញ្ជូនសារទៅក្រាបទូលដល់ព្រះរាជាថា បច្ចន្តជនបទកើតចលាចល ដូច្នេះ ព្រះរាជាទ្រង់បញ្ជូនរាជសាសន៍ទៅថា ចូរបង្រ្កាបឲ្យអស់ យើងនឹងតបស្នងពួកលោក អមាត្យទាំងនោះសម្លាប់មេចោរ ៥ នាក់ ជាមួយនឹងបុរសជាចោរច្រើនពាន់ ដោយការបង្រ្កាបជាលើកទីមួយទុំះឯង មេចោរ ៧ នាក់ដែលនៅសល់ នាំបរិវាររៀងៗ ខ្លួន ចូលទៅកាន់ភ្នំ ។ ពួកអមាត្យ ក៏បញ្ជូនដំណឹងក្រាបទូលការប្រព្រឹត្តិទៅនោះដល់ព្រះរាជា ។

ព្រះរាជាបញ្ជូនទ្រព្យទៅដោយព្រះរាជសាសន៍ថា យើងនឹងដឹងវត្ថុដែលគួរធ្វើដល់ពួកលោក ចូរពួកលោកបង្រ្កាបចោរ ដែលនៅសេសសល់ទាំងនោះ ពួកអមាត្យទាំងនោះក៏ប្រហារមេចោរ ២ នាក់ ដោយការបង្រ្កាបជាលើកទី ២ បានធ្វើបរិវាររបស់ពួកចោរទាំងនោះឲ្យខ្សោយកម្លាំង ពួកចោរទាំងអស់នោះក៏នាំគ្នាគេចទៅកាន់ភ្នំ ពួកមហាអមាត្យបញ្ជូនរាជសារ ក្រាប

ទូលការប្រព្រឹត្តិទៅនោះដល់ព្រះរាជា ។

ព្រះរាជា ទ្រង់បញ្ជូនព្រះរាជទ្រព្យទៅដោយព្រះរាជសាសន៍ថា ចូរពួកលោកបង្ក្រាបពួកចោរឲ្យអស់ ពួកអាមាត្យទាំងនោះ សម្លាប់មេចោរ ២ នាក់មួយអន្ទើដោយចោរជាសម្លាញ់ដោយការបង្ក្រាបជាលើកទី ៣ ហើយបញ្ជូនសារក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់បញ្ជូនព្រះរាជទ្រព្យ ព្រមទាំងព្រះរាជសាសន៍ថា ចូរពួកលោកបង្ក្រាបចោរដែលនៅសេសសល់ឲ្យអស់ ពួកអមាត្យទាំងនោះ ក៏សម្លាប់មេចោរ ៥ នាក់ ព្រមទាំងបរិវារចោរដោយការបង្ក្រាបជាលើកទី ៤ ។ ចាប់ផ្តើមអំពីពួកមេចោរ ១២ នាក់ត្រូវសម្លាប់ស្លាប់ហើយ ឈ្មោះថា ចោរណាមួយក៏មិនមាន ។ ជនបទដល់នូវសេចក្តីក្សេមក្សាន្ត នៅដូចឲ្យកូនប្រៀងរាំលើទ្រូង ដូច្នោះ ។ ព្រះរាជាទ្រង់ចោមរោមដោយយោធា អ្នកឈ្នះសង្គ្រាម ទ្រង់យាងឡើងកាន់ប្រាសាទដ៏ប្រសើរ សោយមហាសម្បត្តិ ។

ក្នុងពាក្យទាំងនោះ ព្រះធម្មរាជា ប្រៀបដូចព្រះរាជាជាធំ កុលបុត្ត ជាព្រះយោគាវចរ ប្រៀបដូចមហាអមាត្យ អ្នកនៅក្នុងបច្ចន្តជនបទ អកុសល-ចិត្ត ១២ ដួង ប្រៀបដូចមេចោរ ១២ នាក់ ។ បាបធម៌ដែលកើតឡើងដោយអំណាចអង្គនៃចិត្ត ប្រៀបដូចបុរសជាបក្ខពួកច្រើនពាន់នាក់ របស់មេចោរទាំងនោះ ។ វេលាដែលព្រះយោគាវចរកុលបុត្ត ក្រាបទូលព្រះសាស្តាក្នុងកាលកិលេសទាំងឡាយ កើតឡើងក្នុងអារម្មណ៍ថា បពិត្រព្រះអង្គដ៏-ចម្រើន កិលេសទាំងឡាយកើតឡើងដល់ខ្ញុំព្រះអង្គ ដូច្នេះ ប្រៀបដូចវេលា

ដែលអមាត្យ បញ្ជូនរាជសារក្រាបទូលព្រះរាជាថា បច្ចន្តជនបទកើតចលាចល ការដែលព្រះធម្មរាជាត្រាស់ប្រាប់កម្មដ្ឋានថា ម្នាលភិក្ខុ ចូរអ្នកគ្រប សង្កត់កិលេស ដូច្នេះ ប្រៀបដូចការព្រះរាជទានទ្រព្យ ព្រមទាំងព្រះរាជសាសន៍ថា ចូរពួកអ្នកបង្ក្រាបឲ្យអស់ ដូច្នេះ ។ ការលះអកុសលចិត្ត ៥ ដួង ព្រមទាំងសម្បយុត្តធម៌ ដោយសោតាបត្តិមគ្គ ប្រៀបដូចវេលាដែលអមាត្យ សម្លាប់មេចោរទាំង ៥ នាក់ ព្រមទាំងបរិវារ ។

ការក្រាបទូលគុណដែលខ្លួនបានហើយ ដល់ព្រះសម្មាសម្ពុទ្ធ ប្រៀបដូច ការបញ្ជូនសារថ្វាយព្រះរាជា ការដែលព្រះមានព្រះភាគ ត្រាស់ប្រាប់វិបស្សនា នៃសកទាគាមិមគ្គ ប្រៀបដូចការព្រះរាជទានទ្រព្យទៀត ព្រមទាំងព្រះ តម្រាស់ថា ចូរបង្ក្រាបពួកចោរដែលនៅសល់ ។ ការធ្វើចិត្តដែលសហគតៈ ដោយទោមនស្ស ២ ដួង ព្រមទាំងសម្បយុត្តធម៌ឲ្យស្តើងដោយសកទាគាមិមគ្គ ប្រៀបដូចការធ្វើមេចោរ ២ នាក់ ព្រមទាំងបរិវារឲ្យទុព្វលភាពដោយ ការបង្ក្រាបជាលើកទី ២ ។

ការក្រាបទូលគុណដែលខ្លួនបាន ដល់ព្រះសាស្តា ប្រៀបដូចការបញ្ជូន សារថ្វាយព្រះរាជាឲ្យទ្រង់ជ្រាបការប្រព្រឹត្តទៅទៀត ការដែលព្រះមានព្រះ ភាគ ត្រាស់ប្រាប់វិបស្សនានៃអនាគាមិមគ្គ ប្រៀបដូចការព្រះរាជទានទ្រព្យ ទៀត ព្រមទាំងរាជសាសន៍ថា ចូរពួកលោកបង្ក្រាបចោរឲ្យអស់ ។ ការលះ ចិត្តដែលសហគតៈដោយទោមនស្ស ២ ដួង ព្រមទាំងសម្បយុត្តធម៌ ដោយ អនាគាមិមគ្គ ប្រៀបដូចការសម្លាប់មេចោរ ២ នាក់ ព្រមទាំងបរិវារដោយ

ការបង្ក្រាបជាលើកទី ៣ ។

ការក្រាបទូលគុណដែលខ្ជួនបានហើយ ដល់ព្រះតថាគត ប្រៀបដូចការបញ្ជូនសារថ្វាយព្រះរាជា ឲ្យទ្រង់ជ្រាបទៀត ។ ការដែលព្រះមានព្រះភាគត្រាស់ប្រាប់វិបស្សនានៃអរហត្តមគ្គ ប្រៀបដូចការព្រះរាជទានទ្រព្យទៀត ព្រមទាំងព្រះតម្រាស់ថា ចូរពួកលោកបង្ក្រាបចោរឲ្យអស់ កាលអរហត្តមគ្គលះអកុសលចិត្ត ៥ មួយអន្លើដោយសម្បយុត្តចិត្តបានហើយ ការមិនមានអកុសលធម៌ដែលកើតឡើង ដោយអំណាចអង្គនៃចិត្តទៀត ចាប់ផ្តើមអំពីអកុសលចិត្ត ១២ ដួង ត្រូវលះហើយ ប្រៀបដូចវេលាដែលជនបទជាដែនក្សេម ចាប់តាំងអំពីកាលដែលអមាត្យសម្លាប់មេចោរ ៥ នាក់ ព្រមទាំងបរិវារដោយការបង្ក្រាបជាលើកទី ៤ គប្បីជ្រាបការសោយសុខដោយផលសមាបត្តិតាមដែលព្រះធម្មរាជា ដែលមានព្រះខីណាស្រពចោមរោម ទ្រង់ប្រាថ្នាហើយ ក្នុងសុខដែលកើតអំពីសមាបត្តិទាំងឡាយ មានសុញ្ញត អនិមិត្ត អប្បណិហិត ( ជាដើម ) ប្រៀបដូចការសោយមហាសម្បត្តិលើប្រាសាទដ៏ប្រសើររបស់ព្រះរាជាអ្នកឈ្នះសង្គ្រាម ចោមរោមដោយអមាត្យនោះឯង ។

ពណ៌នាបទថា ធម៌ជាកុសល ចប់

# ក្បាលទី ៦៤

# អភិធម្មបិដក បាលីប្រែ -៧៨

## សន្លឹកចង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| អភិធម្មបិដក មាតិកា | ២ |
| ពាក្យប្រារព្ធ | ៥ |
| និទានកថា | ៨ |
| អត្ថរបស់ អភិ សព្ទ | ៨ |
| **អធិគមនិទាន** | |
| សុមេធកថាទី ១ | ៧២ |
| កោណ្ឌញ្ញកថាទី ២ | ១៥ |
| មង្គលកថាទី ៣ | ១១៧ |
| សុមនកថាទី ៤ | ១២៧ |
| រេវតកថាទី ៥ | ១២៨ |
| សោភិតកថាទី ៦ | ១២៩ |
| អនោមទស្សីកថាទី ៧ | ១៣០ |
| បទុមកថាទី ៨ | ១៣១ |
| នារទកថាទី ៩ | ១៣៣ |
| បទុមុត្តរកថាទី ១០ | ១៣៤ |
| សុមេធកថាទី ១១ | ១៣៥ |
| សុជាតកថាទី ១២ | ១៣៦ |
| បិយទស្សីកថាទី ១៣ | ១៣៨ |
| អត្ថទស្សីកថាទី ១៤ | ១៤០ |

ធម្មទស្សីកថាទី ១៥ .......... .......... .......... .......... ............ ១៤១
សិទ្ធត្ថកថាទី ១៦ .......... .......... .......... .......... ............ ១៤២
តិស្សកថាទី ១៧ .......... .......... .......... .......... ............ ១៤៣
ផុស្សកថាទី ១៨ .......... .......... .......... .......... ............ ១៤៥
វិបស្សីកថាទី ១៩ .......... .......... .......... .......... ............ ១៤៦
សិខីកថាទី ២០ .......... .......... .......... .......... ............ ១៤៧
វេស្សភូកថាទី ២១ .......... .......... .......... .......... ............ ១៤៨
កកុសន្ធកថាទី ២២ .......... .......... .......... .......... ............ ១៥០
កោនាគមនកថាទី ២៣ .......... .......... .......... .......... ............ ១៥១
កស្សបកថាទី ២៤ .......... .......... .......... .......... ............ ១៥២
ទេសនានិទាន .......... .......... .......... .......... ............ ១៦៥

# អដ្ឋកថា

## ចិត្តុប្បាទកណ្ឌ

អធិប្បាយបទតិកមាតិកា .......... .......... .......... .......... .......... ១៦៧
កុសលត្តិកៈទី ១ .......... .......... .......... .......... .......... ១៧១
អត្ថរបស់ កុសល សព្ទ .......... .......... .......... .......... ............ ១៧១
អត្ថរបស់ ធម្ម សព្ទ .......... .......... .......... .......... ........... ........ ១៧២
វេទនាត្តិកៈទី ២ .......... .......... .......... .......... ........... ........ ១៧៤
អត្ថរបស់ សុខ សព្ទ .......... .......... .......... .......... ........... ........ ១៧៨
អត្ថរបស់ ទុក្ខ សព្ទ ........ .......... .......... .......... ................ ១៧៩
វិបាកត្តិកៈទី ៣ .......... .......... .......... .......... ............ ........ ១៨២
ឧបាទិន្នុបាទានិយត្តិកៈទី ៤ .......... .......... .......... .......... .......... ១៨៣
សង្កិលិដ្ឋសង្កិលេសិកត្តិកៈទី ៥ ........ ......... .......... ......... ........ ១៨៤

វិតក្កត្តិកៈទី ៦ .......... .......... .......... .......... ......... ១៨៥

បីតិត្តិកៈទី ៧ .......... .......... .......... .......... .......... ១៨៦

ទស្សនត្តិកៈទី ៨ .......... .......... .......... .......... .......... ១៨៧

ទស្សនហេតុកត្តិកៈទី ៩ .......... .......... .......... .......... .......... ១៨៨

អាចយគាមិត្តិកៈទី ១០ .......... .......... .......... .......... ........ ១៨៩

សេក្ខត្តិកៈទី ១១ .......... .......... .......... .......... ........ ១៩០

បរិត្តត្តិកៈទី ១២ .......... .......... .......... .......... ......... ១៩១

បរិត្តារម្មណត្តិកៈទី ១៣ .......... .......... .......... .......... .......... ១៩២

ហីនត្តិកៈទី ១៤ .......... .......... .......... .......... ......... ១៩៣

មិច្ឆត្តិកៈទី ១៥ .......... .......... .......... .......... ......... ១៩៤

មគ្គារម្មណត្តិកៈទី ១៦ .......... .......... .......... .......... ......... ១៩៥

ឧប្បន្នត្តិកៈទី ១៧ .......... .......... .......... .......... ......... ១៩៦

អតីតត្តិកៈទី ១៨ .......... .......... .......... .......... .......... ១៩៧

អតីតារម្មណត្តិកៈទី ១៩ .......... .......... .......... .......... ........... ១៩៨

អជ្ឈត្តត្តិកៈទី ២០ .......... .......... .......... .......... ........ ១៩៩

សនិទស្សនត្តិកៈទី ២២ .......... .......... .......... .......... ........ ២០១

អភិធម្មបិដក អភិធម្មមាតិកា .......... .......... .......... .......... ....... ២០២

អភិធម្មបិដក សុត្តន្តមាតិកា .......... .......... .......... .......... ....... ២១០

ហេតុគោច្ឆកៈ .......... .......... .......... .......... ...... ២១២

## អដ្ឋកថា បទអភិធម្មធុកមាតិកា

ចូឡន្តរទុកៈ .......... .......... .......... ......... ..... ២១៤

អាសវគោច្ឆកៈ .......... .......... ......... .......... ..... ២១៥

សញ្ញោជនគោច្ឆកៈ .......... .......... .......... .... ២១៦

គន្ថគោច្ឆកៈ .......... .......... .......... ..... ២១៧

ឱឃគោច្ឆកៈ .......... .......... ......... .... ២១៨

យោគគោច្ឆកៈ .......... .......... ......... .... ២១៨

នីវរណគោច្ឆកៈ .......... ......... ......... .... ២១៨

បរាមាសគោច្ឆកៈ .......... ....... ....... ......... ២១៩

មហន្តរទុកៈ ......... ......... ...... ...... ២១៩

ឧបាទានគោច្ឆកៈ .......... ....... ....... ...... ២២១

កិលេសគោច្ឆកៈ ....... ........ ......... ....... ២២១

បិដ្ឋិទុកៈ ........ .......... ...... ....... ២២១

បទសុត្តន្តិកទុកមាតិកា .......... .......... ........ ....... ២២៣

អភិធម្មបិដក បទភាជនីយ ........ ........ ......... ....... ២៣១

អដ្ឋកថា បទភាជនីយកាមាវចរកុសល .......... ....... .......... ........ ២៣២

អត្ថរបស់ សមយ សព្ទ .......... .......... .......... .......... ២៣៧

អត្ថរបស់ ឧប្បន្ន សព្ទ ........ ........ .......... ........ ២៦០

អត្ថរបស់ សហគត សព្ទ .......... ........ ....... ....... ២៦៥

ទ្វារនៃកាយកម្ម ....... .......... ........ ....... ២៩៤

ទ្វារនៃវចីកម្ម ........ ....... .......... ....... ៣០៣

ទ្វារនៃមនោកម្ម .......... ........ ....... ....... ៣០៦

កម្មកថា .......... ........ ....... ....... ៣០៨

អកុសលកម្មបថ .......... ........ ....... ....... ៣២៧

កុសលកម្មបថ .......... ......... ....... ....... ៣៤១

## ធម្មុទ្ទេសវារ

ពោលដោយការប្រៀបធៀបកម្មបថ .......... ......... ....... .... ៣៤៥

អធិប្បាយពួក ៥ មានផស្សៈជាដើម ........ ....... ..... ៣៥១

អធិប្បាយពួកអង្គឈានមានវិតក្កជាដើម ........ ....... ..... ៣៦៧
អធិប្បាយពួកឥន្ទ្រិយមានសទ្ធាជាដើម ........ ....... ..... ៣៧៧
អធិប្បាយពួកអង្គមគ្គមានសម្មាទិដ្ឋិជាដើម ........ ....... ..... ៣៨៨
អធិប្បាយពួកពលមានសទ្ធាជាដើម ........ ....... ..... ៣៨៩
អធិប្បាយពួកធម៌ដែលជាមូលមានអលោភៈជាដើម ........ ........ ..... ៣៩៥
អធិប្បាយពួកកម្មបថមានអនភិជ្ឈាជាដើម ........ ....... ..... ៤០២
អធិប្បាយពួក ២ នៃធម៌ជាលោកបាល ........ ....... ..... ៤០៣
អធិប្បាយយុគលធម៌មានបស្សទ្ធិជាដើម ........ ....... ..... ៤០៤
អធិប្បាយពាក្យថាយេវាបនកន័យ ........ ....... ..... ៤០៨
អភិធម្មបិដក និទ្ទេសវារ ......... ....... ..... ៤១៩
អដ្ឋកថា និទ្ទេសវារ កាមាវចរកុសល ......... ....... ..... ៤៣៤
អធិប្បាយវេទនានិទ្ទេសជាដើម ........ ....... ..... ៤៤១
អត្ថរបស់ អារម្ភ សព្ទ ......... ....... ..... ៤៥៥
អភិធម្មបិដក កោដ្ឋាសវារ ......... ....... ..... ៤៧១
អដ្ឋកថា កោដ្ឋាសវារ ......... ....... ..... ៤៨៦
អភិធម្មបិដក សុញ្ញតវារ ......... ....... ..... ៤៩២
អដ្ឋកថា សុញ្ញតវារ បឋមចិត្ត ......... ....... ..... ៤៩៦
អភិធម្មបិដក ទុតិយចិត្តជាដើម ......... ....... ..... ៤៩៨
អដ្ឋកថា ទុតិយចិត្តជាដើម ......... ....... ..... ៥០៦
ឆដ្ឋចិត្តជាដើម ......... ...... ..... ៥១១
បុញ្ញកិរិយាវត្ថុជាដើម ......... ....... ..... ៥១២
អភិធម្មបិដក រូបាវចរកុសល ចតុក្កន័យ .......... .......... ... ៥២៤
អដ្ឋកថា រូបាវចរកុសល ចតុក្កន័យ ......... ....... ........ ៥២៨

ឧបេក្ខា ១០ យ៉ាង ......... ....... ........ ៥៥១

អភិធម្មបិដក បញ្ចកន័យ ........ ....... ........ ៥៦៨

អដ្ឋកថា បញ្ចកន័យ ......... ....... ........ ៥៧៣

អភិធម្មបិដក បដិបទា ៤ ជាដើម ......... ....... ........ ៥៨១

អដ្ឋកថា បដិបទា ៤ ជាដើម ........ ....... ........ ៥៩២

អភិធម្មបិដក អភិភាយតនៈ .......... ........ ..... ៦០៦

អដ្ឋកថា អភិភាយតនៈ ........ ....... ........ ៦២៥

អភិធម្មបិដក វិមោក្ខ ៣ ......... ....... ........ ៦៣១

អដ្ឋកថា វិមោក្ខ ៣ ......... ....... ........ ៦៣២

អភិធម្មបិដក ព្រហ្មវិហារជ្ឈាន ៤ ......... ....... ........ ៦៣៦

អដ្ឋកថា ព្រហ្មវិហារជ្ឈាន ៤ ........ ....... ........ ៦៣៩

អភិធម្មបិដក អសុភជ្ឈាន ......... ....... ........ ៦៥២

អដ្ឋកថា អសុភជ្ឈាន ........ ....... ........ ៦៥៣

អភិធម្មបិដក អរូបាវចរកុសល ........ ....... ........ ៦៦២

អដ្ឋកថា អរូបាវចរកុសល ........ ....... ........ ៦៦៤

អភិធម្មបិដក កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ........ ....... ........ ៦៩០

អដ្ឋកថា កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ........ ....... ........ ៦៩៦

អភិធម្មបិដក លោកុត្តរកុសល ......... ....... ........ ៧០១

អដ្ឋកថា លោកុត្តរកុសល ......... ....... ........ ៧៣០

អត្ថរបស់ វេលា សព្ទ ......... ....... ........ ៧៤១

លោកុត្តរកុសលបកិណ្ណកកថា ......... ....... ........ ៧៥៥

មហាន័យ ២០ ក្នុងបឋមមគ្គ ........ ........ ........ ៧៧៧

អភិធម្មបិដក មគ្គចិត្តជួនទី ២ ជាដើម ......... .......... ....... .......... ៧៨០

អដ្ឋកថា មគ្គចិត្តដួងទី ២ ជាដើម .......... ........ ....... .......... ៧៨៣
ន័យមួយពាន់ក្នុងមគ្គចិត្ត ៤ ដួង .......... ........ ....... .......... ៧៨៦